ប្រចាំ
COMMISSION

ភាគ្គិយសុត្តិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ៣៤ លេខ ៣ ខែ កក្កដា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -

ប-ឯ-២២៤





ភ្នំពេញសៃទិយ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញាពល់ខែពិតុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
–	អនុត្តិកម្ម អធិប្បាយ អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង (ត១ចប់)	៣២៣
–	ព្រះអភិធម្មបិដក (គម្ពីរព្រះយមក:) លោកប៊ូ-ប៊ុំ ប្រែរៀបរៀង (ត)	៣៣៣
–	មធុរសៅហ៊ីណី សម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សា ប្រែរៀបរៀង (ត)	៣៤១
–	មហោសថជាតក លោក អឹម-ភន ចម្លងពីសាស្ត្រាស្វ័កវិតព្រះពុទ្ធវង្ស កំម-គួរ ព័ន្ធគ្យ (ត)	៣៥១
–	ប្រវត្តិព្រះពុទ្ធទំនួងសង្គ្រោមអសុរ (ភាក្យភាក្យ)លោកដល-ទ័ត្យ ឱតន្ទ (ត១ចប់)	៣៦៣
ផ្នែកអក្សរសាស្ត្រ		
–	ភាសាទំងអក្សរសាស្ត្រខ្មែរ លោក ឱក-គាម រៀបរៀង (ត)	៣៧៦
–	ភាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ "ក" (ត)	៣៨១
–	វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត)	៣៩២
–	រឿងសាមកុក អ្នកឧកញ៉ា ទូ-ភន ប្រែរៀបរៀង (ត)	៣៩៣
–	រឿងព្រេងទាក់ទងដោយប្រវត្តិសាស្ត្រប្រទេសកម្ពុជា	៤១២
–	អង្គរទំនិងសម័យអង្គរ លោក ដេង-ត្រីវ ប្រែពីទស្សនាវដ្តី "ញ៉ូ-អ៊ូយ៉ិង" (ក្រុងប្រាក) លេខ ៣ ឆ្នាំ ៦១	៤២០
–	អ្នករៀនដើម្បីជាតិ លោកអាំង-ហួន អតីតអប់រំសុខាភិបាលខេត្តសៀមរាបរៀបរៀង	៤២៧
ចុងក្រោយ		
–	ព្រះរាជពិធីបួងសួងសព្រះបំណង់នៅខេត្តសៀមរាប និងព្រះវិហារសួរ (កណ្តាល)	៤៣១

មួយឆ្នាំមាន ១២ លេខ តម្លៃជាវ ៤៣០រ០០

34è Année — N° 7 — Juillet 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse

—Athangikamgga expliqué par l'Oknha TEA-SAN (suite et fin) . . 723
—Préah Abhidhamma pitaka «Kampir Préah Yamaka»
par M. BOU-PO (suite) 733
—Madhurasavahini par Samdech Préah Dhammalikhita
LOUIS-EM (suite) 741
—Mahosotha Jataka relevé du manuscrit sur feuilles de la tanier
par M. IM-PHON, revu et corrigé par le Vén. KEM-TO (suite) . . 751
—L'Histoire d'Indra et de la guerre des Asora (en vers)
par M. PHAL-TIT (suite et fin) 763

Partie littéraire

—Le Langage et la littérature Khmèrs par M. DIK-KEAM (suite) . . . 776
—Activité de la Commission Culturelle chapitre «Ka» (suite) . . . 791
—Dictionnaire Sanscrit-Khmer par Vén. PANG-KHAT (suite) . . . 792
—Histoire de Sam-Kok traduite par Oknha NOU-KAN (suite) . . . 793
—Un conte relatif à l'histoire du Kampuchéa 812
—Angkor et son époque traduit de New-Orient (Prague) n° 3/1961
par M. PHÈNG-CHRIV 820
—S'instuire pour l'intérêt de la Nation par M. AING-HUON 829

Actualités Nationales

—Céremonies Royales de BUONGSUONG à la Province de SIEMRÉAP
et de KANDAL 831

Prix d'Abonnement annuel (comprenant 12 numéros) : 230 ; 00

អដ្ឋង្គិកមគ្គអដ្ឋង្គិកប្បាយ

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ ។
ឲ្យចិត្តស្អាតចិត្ត កុំឲ្យហួងហែង
នេះឯងលោកហៅ ពុទ្ធសាសនា ។

ច.ព.

អ្នកទុកញ៉ា ជា-សាធ អតីតវេជ្ជមន្ត្រីរៀបរៀង

(តមក)

ឯ១ខ្ទង ៥ នេះជាអនិច្ច មិនខៀង មិនគាំងនៅថិតថេរយូរអង្វែងឡើយ ព្រោះ១ខ្ទង ៥ នោះដែលហៅតុបច្ច័យតាក់តែងឲ្យកើតមានឡើងហើយ ត្រូវតែខ្ទុះក្រមចាស់គ្រាំគ្រាវិនាសសាបសូន្យទៅវិញជាធម្មតា ។

១ខ្ទង ៥ ជាទុក្ខំ នាំមកនូវទុក្ខ ព្រោះកើយោចាស់គ្រាំគ្រាខ្ទុះក្រមវិនាសទៅវិញ ដោយជរា ព្យាធិ មរណៈ តែងនាំមកនូវទុក្ខសោកសង្រេងខ្លោចផ្សាគ្រប់យ៉ាង ។

១ខ្ទង ៥ ជាអនត្តា មិនមែនជារបស់យើង មិនមែនជាខ្លួនប្រាណរបស់យើងទេ ព្រោះ១ខ្ទង ៥ នេះ មិនស្តាប់បង្គាប់យើងឡើយ បើទុកជាយើងបង្គាប់ថា ១ខ្ទង ៥ កុំចាស់ កុំឈឺ កុំស្លាប់ក៏ដោយ ១ខ្ទង ៥ នៅតែចាស់ឈឺ ស្លាប់ជាធម្មតាឥតមានស្តាប់បង្គាប់អ្នកឯណាឡើយ ។

មិនតែប៉ុណ្ណោះខន្ធ ៥ នេះលោកថាគ្មានទុក ៖

១- ដូចជារបស់ខ្លីគេប្រើ ៖- ធម្មតារបស់ខ្លីគេ កាលប្រើប្រាស់តាមត្រូវការរួចហើយ ត្រូវតែប្រគល់ឲ្យទៅម្ចាស់គេវិញ ។

ដោយហេតុនេះ យើងពុំគប្បីប្រកាន់ម៉ាំក្នុងចិត្តថា ខន្ធ ៥ នោះជារបស់យើង ជាយើង ជាខ្លួនប្រាណរបស់យើងឡើយ ពីព្រោះការគាំងចិត្តប្រកាន់ម៉ាំដូច្នេះ នាំឲ្យយើងជំពាក់ជាប់ចិត្តនឹងខន្ធ ៥ នោះ ដែលជាហេតុនាំឲ្យយើងតក់ស្លុតរន្ធត់ចិត្ត ព្រួយចិត្ត ខ្វោចឆ្អាចិត្ត នៅវេលាដែលខន្ធនោះមានវិបត្តិប្រែប្រួលម្តងៗ ដោយជរា ព្យាធិ ឬមរណៈមកបៀតបៀនពុំខានឡើយ ។

២- ដូចជាផ្ទះក្តៅងនេះ ៖- ធម្មតាផ្ទះដែលក្តៅងនេះ រមែងតែនេះខ្លួចខ្លីវិនាសសាបសូន្យអស់ដូចម្តេចមិញ រីឯខន្ធ ៥ ដែលនេះដោយក្តៅងកាលសន្ធឹងក្តៅងពុក កាំតែងតែនេះទ្រុឌទ្រោមបែកធ្លាយវិនាសខ្លួចខ្លីសាបសូន្យអស់កំដូច្នោះដែរ ពីព្រោះខន្ធ ៥ ដែលហេតុបច្ច័យតាក់តែងឲ្យកើតឡើងហើយរមែងតែចាស់គ្រាំគ្រាទ្រុឌទ្រោមវិនាសសាបសូន្យអស់ទៅវិញជាធម្មតា ។

៣- ជាទីប្រជុំនៃសាកអសុកគឺ អាការៈ ៣២ មានសក់ រោម សែ្បក ឆ្អឹងជាដើមដែលសុទ្ធតែជារបស់ចង្អិលគួរឲ្យខ្ពើម ។

៤- មិនតែប៉ុណ្ណោះខន្ធ ៥ នេះជាការៈ គឺជាបន្ទុកមួយដ៏ធ្ងន់ពន់ពេក

គួរតែខម្មាក់ចោល ព័ត្រោះការទេបន្តម្តងំខ្ទុកបំរុងខ្ទ ៥ នេះឱ្យមានដំណើរ
ប្រព្រឹត្តទៅបានសុខស្រួលជាប្រក្រតីនោះ បង្ខំសត្វស្ងៀងប្រើនប្រែនខ្លះខ្ទែង
ឥតគិតដល់ការលំបាកខ្លួយហត់អ្វីសោះ គឺគិតតែចំប្រកបការងារគ្រប់
បែបយ៉ាង ជួបប្រទះនឹងគ្រោះថ្នាក់ធ្ងន់ឬស្រាល ឬជួបប្រទះនឹងសេចក្តី
ទុក្ខព្រួយលំបាកគ្រប់បែបយ៉ាងកសេចក្តីសប្បាយសុខស្រួលគ្មានឡើយ ។

រីឯអាម្មណ៍ ៥ នោះគឺ៖

១ - រូប គឺសំដៅរូបសត្វនឹងរូបសង្ខារ.- ឯរូបសត្វ បានដល់រូប
មនុស្សនឹងសត្វ, រីឯរូបសង្ខារ បានដល់រូបដែលគេតាក់តែងឱ្យកើតឡើង
ជារូបដូចផ្លែជាដើម ។

២- សម្លេង គឺសំដៅសម្លេងសត្វ នឹងសម្លេងសង្ខារ ។ សម្លេង
សត្វបានដល់សម្លេងមនុស្សសត្វជាដើម, សម្លេងសង្ខារបានដល់សម្លេង
ដែលគេតាក់តែងឱ្យកើតឡើងជាសម្លេងមានសម្លេងច្រៀ ជាប៉ី ខ្លុយជាដើម ។

៣- ក្លិន គឺសំដៅក្លិនផ្កា ក្លិនគ្រឿងក្រអូប នឹងក្លិនរបូប ។

៤- រស គឺសំដៅសម្ផស្សដែលបំរះពាល់ត្រូវដោយអណ្តាត មាន
ការបំរះពាល់ត្រូវគោជនាហារដោយអណ្តាតជាដើម ។

៥- ផោដ្ឋព្វៈ គឺសំដៅសម្ផស្សដែលបំរះពាល់ត្រូវដោយកាយ
មានការស្ទាប ទុបជាដើមដែលអាចនឹងញ៉ាំងកាត. គឺសេចក្តីត្រេកត្រអាល
ឱ្យកើតឡើង ។

ឯអារម្មណ៍ទាំង ៥ ដូចខាងលើ សុទ្ធតែមានសុភនិមិត្តជាគ្រឿងសម្គាល់ថាល្អ, ដូចជារូប មានសោភគណាភាពជាដើម ជាសុភនិមិត្ត, សំឡេងមានពីរោះជាសុភនិមិត្ត ។ល។

ឯសុភនិមិត្តនេះហើយដែលជាគ្រឿងសំរើបចិត្ត, លួងលោមចិត្តឲ្យប្រាថ្នាទូវអារម្មណ៍ ៥ នោះ ដែលជាហេតុនឹងញ៉ាំងភគៈ គឺសេចក្តីត្រេកត្រអាល ឬសេចក្តីសប្បាយរីករាយឲ្យកើតមានឡើងជាលំដាប់ ។

ដោយហេតុនោះ ទើបបណ្ឌិតលោកចាត់ទុកអារម្មណ៍៥ នោះជាវត្ថុកាម គឺវត្ថុជាទីគួរឲ្យពេញចិត្ត, គួរឲ្យស្រឡាញ់នឹងគួរឲ្យប្រាថ្នា ។

ចំណែកឯភគៈដែលកើតឡើងដោយអារម្មណ៍ ៥ នោះ បណ្ឌិតលោកចាត់ទុកជាកិលេសកាម គឺកិលេសជាគ្រឿងញុះញង់ចិត្តឲ្យស្រឡាញ់ នឹងឲ្យប្រាថ្នាទូវអារម្មណ៍ ៥ នោះវិញថែមទៀត ។

គឺអារម្មណ៍ ៥ នេះហើយ ដែលធ្វើសត្វឲ្យស្រេកឃ្លាន ឲ្យរង្វិនរង្គេចភ្ញាំងស្មារតីបណ្តោយចិត្តឲ្យជាប់ជំពាក់នឹងកាមគុណ ៥ នោះឯង ។

គឺអារម្មណ៍ ៥ នេះហើយ ដែលធ្វើសត្វឲ្យភ្លក់រសទៅជាខ្ញែនតណ្ហា, រំលេចរំលាស្ងាប់កន្ទរវដ្តសង្សារនៅក្នុងវេនាអនាគតបន្តបន្ទាន់ឡើយ ។

៧- តើបណ្ឌិតលោកប្រើឧបាយដូចម្តេច ដើម្បីនឹងរារាំងកុំឲ្យចិត្តលុះទៅក្នុងការលួងលោមនៃអារម្មណ៍ ៥ នោះបាន?

ដើម្បីនឹងរារាំងចិត្តកុំឲ្យលុះទៅកន្លងការលួងលោមរបស់អារម្មណ៍ ៥

នោះបាន បណ្ឌិតពាំងឲ្យយ មានអរិយបុគ្គលជាដើម លោកវែងតែ
ព្យាយាមចំរើនវិបស្សនា ៤ មានបឋមជ្ឈានជាដើម ដើម្បីទំលះអង្គឈាន ៤
គឺវិតក្កៈ, វិចារៈ, ប៊ីតិ ទំនងសុខ ឲ្យជាប់ស្រឡះកុំឲ្យមានដំណើរប្រព្រឹត្ត
ទៅបានទៀត ដែលជាហេតុទំនងធ្វើឲ្យវិបស្សនា គឺវិតក្កៈ, វិចារៈ ហើយ
ទំនងចិត្តសង្ខារ គឺសញ្ញា ៥ ទំនងវេទនា ៤ គឺសោមនស្ស, ទោមនស្ស,
សុខ ទំនងទុក្ខលេត់ត្រមទៅជាមួយគ្នាជាលំដាប់ ។

កាលបើវេទនា ៤ នេះលេត់អស់លែងប្រព្រឹត្តទៅបានទៀតហើយ
ទើបទៅឯណោះនោះវេទនាទី ៥ គឺឧបេក្ខាក៏កើតឡើងហើយតាំងទៅជាស្ថា-
ពរ ជាតួអង្គទី ២ នៃចតុត្ថជ្ឈាននោះឯង ។

គឺឧបេក្ខានេះហើយ ដែលបណ្ឌិតលោកចាត់ទុកថាជាធម្មឡង្ហិបេក្ខា
គឺឧបេក្ខាដែលអាចកាំងចិត្ត, ឧបត្ថម្ភចិត្តមិនឲ្យលុះទៅកន្លងការលួងលោម
នៃអារម្មណ៍ ៥ នោះបាន ព្រមតាំងអាចការពារទ្រទ្រង់ចិត្តមិនឲ្យលុះទៅ
ក្នុងការញុះញង់នៃកតៈទោសៈបានថែមទៀត ។ ព័ត្រោះធម្មឡង្ហិបេក្ខា
នោះ កាលកើតមានក្នុងខន្ធសន្តានហើយ រមែងតែតាំងទៅជាកណ្តាល
មិនអើពើ គឺមិនសោមនស្សមិនទោមនស្សជាទិច្ចំពោះវត្ថុនិងអារម្មណ៍
ដែលជាហេតុធ្វើឲ្យកតៈនឹងទោសៈគ្មានឱកាសនឹងចូលមកកើតក្នុងខន្ធស-
ន្តានបានសោះ ។

អាស្រ័យហេតុនេះ បានជាអរិយបុគ្គលដែលបានសម្រេចចតុត្ថជ្ឈាន

ប្រកបដោយអង្គឯកគ្គតានឹងចេក្ខា រមែងតែលះកាត: ភោស: ជាច់ស្រឡះ ដោយសមុច្ឆេទប្បហាន ហើយបានត្រាស់ដឹងនូវអនាគាមិមគ្គនឹងអនាគាមិផលជាលំដាប់ដូច្នេះឯង ។

លំដាប់តទៅនេះ ខ្ញុំនឹងធ្វើអត្ថាធិប្បាយអំពីសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ដែលជាកម្មដ្ឋានអាចញ៉ាំងការត្រាស់ដឹងមគ្គ ៤ ផល ៤ នឹងនិព្វានឲ្យសម្រេចឡើងបានដូចតទៅនេះ ៖

៨- តើកម្មដ្ឋានទាំង ២ ប្រការនេះ ជាកម្មដ្ឋានពិបាកហួសវិស័យនៃយោគាវចរក្នុងបច្ចុប្បន្នធំងំចំរើនឲ្យសម្រេចប្រយោជន៍ ឬដូចម្តេច ?

តាមយោបល់ខ្ញុំនោះ កម្មដ្ឋានទាំង ២ ប្រការនេះ ពិតជាមជ្ឈិមបដិបទាគឺបដិបទាយ៉ាំងកណ្តាលមិនតឹងតេកមិនធូរតេក ដែលយោគីអាចនឹងញ៉ាំងយាមបំពេញឲ្យសម្រេចទៅបានដោយស្រួលទេ ពីព្រោះខ្ញុំយល់ឃើញថា ការដែលពិបាកបំផុតនោះ គឺការចំរើនកសិណ ពីព្រោះការចំរើនកសិណ ដែលជាបុព្វកិច្ច រមែងតែនាំឲ្យជួបប្រទះនឹងទុបសគ្គគ្រប់យ៉ាងតុំពានឡើយ ។

ម្យ៉ាងទៀត ការតត់តម្រង់ចិត្តឲ្យនៅស្ងប់ក្នុងអារម្មណ៍តែមួយ ក៏ជាការពិបាកបំផុតដែរ មិនដែលនឹងធ្វើឲ្យបានសម្រេចក្នុងរយៈពេលដ៏ខ្លីទៅ

ចានឡើយ ពីព្រោះចិត្តជាធម្មជាតមិនចេះនៅស្ងៀម មិនត្រមនៅនឹងមួយ
កន្លែង ដោយចិត្តនោះចេះតែអន្ទះអន្ទែងធ្វេទ្វាចដ៏រកផ្លូវនឹងស្ទុះចេញទៅ
កាន់អារម្មណ៍នៅគ្រប់ទិសទីជានិច្ច ទោះនៅដឹតប្តូនៅឡាយក៏ដោយ ។

អាស្រ័យហេតុនេះ ទើបយោគាវចរអង្គណាចានតាំងចិត្តយ៉ាងមាំ
កងការចំរើនកម្មដ្ឋាន ហើយព្យាយាមតស៊ូចំពោះទុបសគ្គតាំងឡាយ លុះ
ក្រៅតែចានសម្រេចនូវអប្បនាសមាធិ គឺចិត្តតាំងចុះស៊ប់នៅក្នុងអារម្មណ៍
តែមួយការណាហើយ យោគាវចរអង្គនោះតង់នឹងមានសង្ឃឹមខុកជាមុន
ថា មុខតែនឹងមានឥរិយាបថដើរទៅដល់ទីដៅពោលគឺការត្រាស់ដឹង
មគ្គ៤ផល ៤ នឹងនិព្វានពុំខានឡើយ ពីព្រោះអប្បនាសមាធិនោះពុកដូចជា
កូនសោមួយតាំសេសសម្រាប់ឲ្យយោគាវចរចាក់បើកទ្វារកម្មដ្ឋានផ្សេង ។
ដើរចូលទៅកាន់មគ្គ ផល និព្វាន សមតាមសេចក្តីប្រាថ្នាទៅចាន ។

ឯហេតុដែលនាំទុំឲ្យហ៊ានានិច្ចយ៉ាងដូច្នេះ ពីព្រោះទុំយល់ឃើញថា
គុណធម៌តាំងឡាយដែលនឹងសម្រេចឡើងចាន ក៏ត្រូវអាស្រ័យអប្បនា-
សមាធិជាមូលដ្ឋាន ។

មែនតាត កាចំរើនវិបស្សនាការនោះដោយចិត្តស្ងប់ជាអប្បនាសមាធិ
រមែងតែញ៉ាំងវិបស្សនាញាណ គឺញាណដែលដឹងនូវដំណើរសង្ខារធម៌
ទៅតាមការណ៍ពិតឲ្យសម្រេចឡើងចាន ។

ឯការចំរើនឈាន ក៏ត្រូវការអប្បនាសមាធិជាមូលដ្ឋានដែរ ពីព្រោះ

ឈានចិត្តពាំង ៨ សុទ្ធតែសម្បយុត្តដោយអង្គឯកគ្គតា តើអប្បនាសមាធិនោះឯង ។

អាស្រ័យហេតុនេះ បើតុទ្ធបរិស័ទណាមានចិត្តច្រឡំច្រឡាចនឹត្រាស់ដឹងនូវលោកុត្តរធម៌នោះ តម្រូវតាមបដិបត្តិធម៌ទៅតាមកម្មវិធីដែលខ្ញុំបានរៀបរាប់ខ្លះកន្លងមកនេះ ហើយកុំត្តភកិសម័យ ជាកិច្ចតំណោធន៍ល្អដ៏ប្រសើរទៅកុំឲ្យខាន ក្រែងខុបនិស្ស័យដែលបានកសាងសន្សំពុកពីអតីតជាតិជួយខុបត្តម្ភនាំឲ្យបានសម្រេចគោលបំណងនៅថ្ងៃណាមួយទៅក៏មិនដឹង?

ម្យ៉ាងវិញទៀត ឯការត្រាស់ដឹងមគ្គ ៤ ផល ៤ នោះមានមជ្ឈដ្ឋានអ្នកដំណាក់ខាងតុទ្ធសាសនាខ្លះ អះអាងថាមិនចាំបាច់ចំរើនសមថកម្មដ្ឋានមានការចំរើនកសិណនឹងឈានទេ គឺចំរើនតែវិបស្សនាតាមនាំអាចនឹងញុំាងការត្រាស់ដឹងមគ្គផលនោះដែរ ដោយសំអាងទៅព្រះអហារន្តសុត្តវិបស្សកៈ ដែលចំរើនតែវិបស្សនាសុទ្ធជាតួយ៉ាងស្រាប់ ។

ចំពោះរឿងនេះ ខ្ញុំមិនយល់ស្របទៅតាមមតិខាងលើនេះទេ ពីព្រោះខ្ញុំយល់ឃើញថា មានតែច្រើនកម្មដ្ឋាន ២ គឺសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋានតែប៉ុណ្ណោះទេ ដែលអាចញុំាងខន្ធសន្តានឲ្យរួចពីកសំរោជន: ១០ ដើម្បីការត្រាស់ដឹងមគ្គ ៤ និងផល ៤ ឬនជាជាច់ខាត ដោយសំអាងថាការចំរើនកសិណ និងឈានតែងផ្តល់ទ្បាយោគាវចរនូវសមាធិ និងឈានចិត្ត ដែលជាគ្រឿងអាចញុំាងចេតោវិមុត្តិ តើការរួចពីកិលេស

ដោយផ្លូវចិត្តឱ្យសម្រេចទៅបាន ហើយមគ្គ័ង្គខៀត ការចំរើនវិបស្សនាកម្ម-
ដ្ឋាន កំរែងហុចឱ្យដោតវិបស្សនាញាណ ដែលជាគ្រឿងអាច
នាំឱ្យបញ្ចាមុត្តិ គឺការរួចចាកកិលេសដោយបញ្ចាកើតឡើងបាន ។

មែនពិត កុងបណ្តាសំយោជនៈ១០ មានសំយោជនៈ ៤ គឺសក្កាយ-
ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស នីវរណៈឆ្នាំង ត្រូវលះដោយបញ្ចា, ហើយ
សំយោជនៈ ៦ ទៀតគឺ កាមរាគ បដិឃៈ រូបរាគ អរូបរាគៈ មានៈ ឧទ-
ច្ចៈ ត្រូវលះដោយចិត្ត ពោលគឺដោយឈានចិត្តនោះឯង ។

តាមយោបល់ខ្ញុំ ការចំរើនវិបស្សនាការដោយចិត្តមិនសម្បយុត្តដោយ
អប្បនាសមាធិ តាំងនៅកុងអារម្មណ៍តែមួយទេ ពុំអាចនឹងញ៉ាំងវិបស្សនា-
ញាណ គឺញាណដែលដឹងច្បាស់នូវដំណើរសង្ខារធម៌ មានបញ្ចក្ខន្ធជា
ដើមទៅតាមហេតុពិត ឱ្យសម្រេចកើតមានឡើងបានឡើយ ។

អាស្រ័យហេតុនេះ បានជាខ្ញុំយល់ឃើញថាមានតែប្រដុំការនា ៦ គឺ
សមថការនា វិបស្សនាការនានោះទេ ដែលអាចញ៉ាំងការគ្រាស់ដឹងមគ្គ
ផល និព្វាន ឱ្យសំរេចឡើងបានដោយប្រការដូច្នេះឯង ។

រីឯមជ្ឈដ្ឋានខ្លះ ដែលអះអាងថាការចំរើនវិបស្សនាការនាអាចនាំឱ្យ
គ្រាស់អរហត្តមគ្គ អរហត្តផលបាន ដោយលើកយកព្រះអរហន្តសុក្ខវិបស្ស-
កោ ជាឧទាហរណ៍នោះ គឺសំដៅការគ្រាស់ដឹងកុងសម័យពុទ្ធកាល ពី

ព្រោះក្នុងពុទ្ធសម័យ ទើបមានព្រះអរហន្ត ៤ ពួក មានព្រះអរហន្តសុក្ខវិ-
បស្សកោជាដើម ។

បើតោលក្នុងពុទ្ធកាលវិញ ឃើញថាមិនចាំបាច់ពាំងចំរើនវិបស្សនា
ភាវនា ឬសមថភាវនាផង ក៏មានពុទ្ធបរិស័ទជាច្រើនអាចត្រាស់ដឹងលោកុ-
ត្តរធម៌បានដែរ ពីព្រោះក្នុងដំនាន់ពុទ្ធកាលនោះ ព្រះសម្មុទ្ធជាបរមគ្រូព្រះ
អង្គតែងតែសំដែងធម្មទេសនាប្រោសសត្វ ដែលមានបុញ្ញាភិនីហារត្រាស់
មានបញ្ញាវត្ថិយ៍ជាដើម ឲ្យត្រាស់ដឹងលោកុត្តរធម៌ ចាប់ពីសោតាវធ្វូត
ដល់ព្រះអរហន្ត ពុំអាចនឹងកប់ឈ្មោះឲ្យអស់បានផង ។

សរុបសេចក្តីទៅ ខ្ញុំសូមអំពាវនាវដល់ពុទ្ធបរិស័ទដែលបានអានសៀវ
ភៅនេះ មេត្តាជួយពិនិត្យអំពីរឿងនេះឲ្យបានជាក់ច្បាស់ឡើង ដើម្បីចំ-
ណាត់កុំឲ្យនៅមានមតិខុសគ្នាចំពោះវត្ថុប្រតិបត្តិ ដើម្បីមគ្គ ផល និព្វាននោះ
តទៅទៀត ពីព្រោះពុទ្ធកាលកន្លងផុតទៅបាន ២៥ សតវត្សទៅហើយ
គេពុំមានចំបានឮដំណឹងថាមានយោគាវចរ ពុទ្ធសាសនិកអង្គណាមួយបាន
សម្រេចនូវលោកុត្តរកិលេសមីយនៅឡើយសោះ ។

ព្រះអភិធម្មបិដក

គម្ពីរព្រះយមក:

លោក ប៊ុ - ប៊ុ ប្រែរៀបរៀង

(តមក)

ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច

ភគវាអដ្ឋសម្ដេចព្រះមានព្រះភាគត្រាស់ទេសនាទុក្ខនិរោធគាមិនី-បដិបទាអរិយសច្ចជាគំរប់បួនតទៅ ទ្រង់ត្រាស់បុច្ឆាថា បេស់ពិតនៃព្រះអរិ-យៈជាគំរប់បួននោះតើមានប្រការដូចម្ដេច គឺបេស់អ្វី ?

ទើបទ្រង់ត្រាស់វិសជ្ជនាថា បេស់ពិតនៃព្រះអរិយៈជាគំរប់បួននោះ គឺបដិបទាដ៏ញុំាងសត្វឲ្យដល់នូវព្រះនិព្វានជាទីលេតុំទុក្ខ ។

ទ្រង់ត្រាស់បុច្ឆាថា បដិបទាដ៏ញុំាងសត្វឲ្យដល់នូវព្រះនិព្វាននោះតើគឺអ្វី ?

ទ្រង់ត្រាស់វិសជ្ជនាថា គឺព្រះអដ្ឋង្គិមគ្គ ផ្លូវមានអង្គប្រាំបីប្រការ ។

ទ្រង់ត្រាស់បុច្ឆាថា ចុះអដ្ឋង្គិកមគ្គ ផ្លូវមានអង្គប្រាំបីនោះតើដូចម្ដេច?

ទ្រង់ត្រាស់វិសជ្ជនាថា ព្រះអដ្ឋង្គិកមគ្គ ផ្លូវមានអង្គប្រាំបីប្រការនោះគឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្ត ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១

សម្មាសតិ ១ សម្មាសមាធិ ១ រួមជាច្រើនប្រការ ។

ក្នុងសម្មាទិដ្ឋិនោះ មានព្រះពុទ្ធដីកាត្រាស់ប្តូចថា កតមា សម្មាទិដ្ឋិ សម្មាទិដ្ឋិនោះតើដូចម្តេច ? វេទស្តីហៅថា សម្មាទិដ្ឋិ ?

ទើបត្រាស់វិសជ្ជនាថា សម្មាទិដ្ឋិនោះ ចានទ្ធិបញ្ញាយើញត្រូវ យើញមិនវិបរិតខុសពីព្រះពុទ្ធាទ្ធ យើញទៅក្នុងកន្ធកុ ទីកើតនៃទុក្ខជាដើម ដូច្នេះឯងឈ្មោះថា សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិ យើញត្រូវក្នុងការប្រតិបត្តិដែលនឹងញុំងសត្វឲ្យដល់នូវព្រះនិព្វាន ចាត់ជាមគ្គិកណ្ណាល មិនតឹងតែកមិនធូរពេក ។ ព្រះអរិយៈទាំងឡាយនឹងចានដល់នូវព្រះនិព្វាន ព្រោះហេតុធ្វើដំណើរទៅតាមមគ្គិតីសម្មាទិដ្ឋិនេះ បើប្រាសចាកសម្មាទិដ្ឋិហើយ ក៏មិនអាចទៅកាន់ព្រះនិព្វានចានឡើយ ។

មានពាក្យអធិប្បាយថា សម្មាបកាវេន ឧស្សន្នំ សម្មាទិដ្ឋិនោះ ចានទ្ធិបញ្ញាពិចារណាយើញដោយប្រពៃ ដោយកំណត់មានកន្ធទីបំផុត បញ្ញាដែលពិចារណាយើញថាសត្វកើតមកក្នុងសង្សារវដ្តទាំងអស់សុទ្ធតែមានកម្មជាបេះខ្លួន តើថាចានកសាងការកុសលកំតាមទុបត្តម្ភឲ្យប្រកបដោយទ្រព្យស្រិទ្ធិវារ បរិបូណ៌ដោយកត្តិយសសរសើរដោយសបរិវារយសចេញមុខចេញមាត់ប្រាកដដល់លោកទាំងឡាយ លោកទាំងពួងតែងស្រឡាញ់រាប់អានស្មើមុខ ។ អ្នកដែលចានកសាងអកុសលទុក អកុសលក៏ជាប់តាមឲ្យផលតាមកម្មវិស័យឲ្យសោយទុក្ខវេទនា ជាមនុស្សកំព្រា

អនាថាគាល់ក្រគ្មានលាភ គ្មានញាតិគ្មានមិត្រជាទីស្រឡាញ់គោរពចិត្តនឹងប្រាថ្នាអ្វីមិនបានសម្រេចដូចប្រាថ្នា បញ្ញាតិចាណាយើញដូច្នេះរាប់ចូលក្នុងសម្មាទិដ្ឋិបាន ព្រោះថាបុគ្គលនឹងធ្វើការកុសលនោះ ក៏អាស្រ័យនូវកម្មសទ្ធាតាញ្ញាណ ដូចសាធុជនលះបង់ការងារក្នុងផ្ទះជាស់តឿនបបួលគ្នាមកស្តាប់ព្រះធម្មទេសនាអស់កាលជាន់ច្រ ព្រោះហេតុមានបញ្ញាជា សម្មាទិដ្ឋិ ។ បើបុគ្គលមានបញ្ញាជា មិច្ឆាទិដ្ឋិ យើញទុសតីព្រះពុទ្ធាក់ទេហើយ ក៏គ្មានចិត្តជ្រះថ្លានឹងការកុសល ឲ្យយល់យើញថានឹងមានការងារ ឲ្យមានយើញថានឹងអស់ទ្រព្យ រក្សាសីលនឹងខឿយហាត់ ត្រូវដុសខាត់កាយនឹងចិត្ត ឯចិត្តនោះមិនដាំយកនឹងដុសខាត់ឲ្យស្អាតបានទេ ស្តាប់ធម្មទេសនាក៏ត្រូវអង្គុយស្តាប់ដូចគេ នឹងនាំឲ្យកេយ្យនឹងឆ្អែដើនដៃគ្មានការសប្បាយសោះ កាលបើយល់យើញដូច្នេះហើយក៏រាប់ចូលក្នុងមិច្ឆាទិដ្ឋិ ដែលនឹងឲ្យឃ្លាតឆ្ងាយពីព្រះនិព្វាន ។ ឯសម្មាទិដ្ឋិនោះ បេះតែនាំឲ្យបានដិតព្រះនិព្វានពាល់ត្រា សូម្បីនៅជាលោកិយ ក៏អាចឲ្យបានសម្រេចលោកុត្តរកេងអបរាបរកេតទាងមុខ ។ ហេតុនោះ សម្តេចព្រះបរមអនុត្តញ្ញាណទ្រង់ប្រោសប្រទាន ព្រះធម្មទេសនានូវសម្មាទិដ្ឋិនេះឈ្មោះថាជាបដិបទាញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វាន ។

ក្នុងសម្មាសង្កប្បៈនោះ សម្តេចព្រះតថាគតទ្រង់ត្រាស់បុច្ឆាថា កតមោ សម្មាសង្កប្បោ សម្មាសង្កប្បៈនោះតើតីអ្វី ? ទើបត្រាស់វិសេ-

ដ្ឋនាថា សម្មាសង្កប្បៈនោះជានឹងការត្រិះរិះត្រូវ ។ ឯការត្រិះរិះត្រូវនោះ គឺជានឹងការត្រិះរិះកន្លងដំណើរចេញចាកផ្លូវ ហៅថា នេក្ខម្មសង្កប្បៈ១ ត្រិះរិះកន្លងការមិនព្យាបាទមនុស្សសត្វដទៃ ហៅថា អព្យាបាទសង្កប្បៈ ១ ត្រិះរិះកន្លងការមិនបៀតបៀនមនុស្សសត្វដទៃឲ្យវង្វេងពុំគួរពេញ ហៅថា អវិហឹសាសង្កប្បៈ ១ រួមគ្នាត្រូវជាសម្មាសង្កប្បៈ ៣ ប្រការ ។

កន្លងសម្មាវាចានោះ ជានឹងសំដីត្រូវ ។ ឯសំដីត្រូវនោះ ជានឹងការពោលតាក្យរៀបរាងវចីទុច្ចរិតបួនប្រការ ដែលផ្ទុយពីសម្មាវាចា ។ ឯវចីទុច្ចរិតបួនប្រការនោះ គឺពោលមុសាវាទ ១ ពោលជាបេសុញ្ញវាទ ១ ពោលជាផរុសវាទ ១ ពោលជាសម្ផប្បលាបវាទ ១ ។

មុសាវាទ គឺការនិយាយកុហកបញ្ឆោត, និយាយមិនពិត ដូចជារបស់មាននិយាយថាគ្មាន, របស់ដែលបានឮបានស្តាប់ច្បាប់គេថាមិនបានឮ មិនបានស្តាប់ នឹងមិនបានឃើញជាដើម ។

បេសុញ្ញវាទ គឺការនិយាយពាក្យញុះញង់កាច់ពន់បំបែកបំបាក់អ្នកដទៃឲ្យគេបែកខ្ញែកចិត្តពីគ្នា ឲ្យគេស្អប់គ្នា ដើម្បីឲ្យគេមកស្រឡាញ់ខ្លួនឯងវិញ ។

ផរុសវាទ គឺការនិយាយពាក្យអាក្រក់គ្រោះថ្នាក់ ដោះច្រេះខេចឆ្អាសា នឹងពោលប្រកបដោយអាក្កោសវត្ថុដប់ប្រការ មានជាថាអាឯងជាសត្វតិរច្ឆាន, ជាប្រេត, ជាខ្មួច, ជាគោ, ជាលា, ជាសត្វនរកជាដើម ។

សម្ផប្បលាបៈ គឺការនិយាយពាក្យឥតប្រយោជន៍ ចាននឹងការនិយាយពាក្យដាក់ក្នុងកំផ្លែងលេនសើច ជាហេតុនឹងឲ្យអ្នកស្តាប់សើចលេងសប្បាយជាដើម ។ ការដែលវៀរចាកវចីទុច្ចរិតបួនប្រការនេះឈ្មោះថាសម្មាវាចា ។

ក្នុងសម្មាកម្មន្តៈនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ប្តូថា កតមោ សម្មាកម្មន្តោ សម្មាកម្មន្តៈនោះតើដូចម្តេច ? ទើបទ្រង់ត្រាស់វិសជ្ជនាថា សម្មាកម្មន្តៈនោះ ចាននឹងការធ្វើល្អ គឺចាននឹងការលះបង់នូវកាយទុច្ចរិតប្រការ គឺ ចាណាតិចាត មិនសម្លាប់មនុស្សប្រសត្វ ១ អទិន្នាទាន មិនលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ ១ កាមេសុមិច្ឆាចារ មិនប្រព្រឹត្តទុស្សកន្តកាមដ៏ជាអកម្មញ្ញ ក្នុងស្ត្រី ២០ ចំពួក ១ ។ ការដែលវៀរចាកកាយទុច្ចរិតប៉ប្រការនេះឯងហៅថា សម្មាកម្មន្តៈ ។

ក្នុងសម្មាអាជីវៈនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ប្តូថា កតមោ សម្មាអាជីវោ សម្មាអាជីវៈនោះតើដូចម្តេច ? ទើបទ្រង់ត្រាស់វិសជ្ជនាថា សម្មាអាជីវៈនោះ ចាននឹងការចិញ្ចឹមជីវិតត្រូវ ។ ឯការចិញ្ចឹមជីវិតត្រូវនោះ ចាននឹងកសិកម្ម, គោរក្ខកម្ម ទើងពាណិជ្ជកម្ម ។

កសិកម្មនោះ ចាននឹងការធ្វើស្រែចម្ការច្បារដំណាំផងតាំងពីងតួង។

គោរក្ខកម្ម នោះ ចាននឹងការទិញលុយលើយលក់ដូរគោ ប្តូរគ្រប៉ដីរសែះជាដើម យកថ្លៃឈ្នួលមកចិញ្ចឹមជីវិត ។

ពាណិជ្ជកម្ម នោះ ជានន័យការធ្វើដំណើរទៅផ្សេង ។ រឿងពាក
មិញ្ចពាណិជ្ជប្រាំប្រការដូចពោលហើយនេះ ហៅថា សម្មាអាជីវៈ ។

ក្នុងសម្មាវាយាមៈនោះ ជានន័យសម្មប្បធានទាំងបួន ។

ក្នុងសម្មាសតិនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់បុច្ឆាថា កតមា
សម្មាសតិ សម្មាសតិនោះតើដូចម្តេច ? ទើបទ្រង់ត្រាស់វិសជ្ជនាថា
សម្មាសតិនោះ ជានន័យការនឹកពិចារណាត្រូវ គឺនឹកពិចារណាក្នុងព្រះសតិបដ្ឋានទាំង
បួន ឬនឹងនឹកពិចារណាក្នុងព្រះអនុស្សតិកម្មដ្ឋានទាំងដប់ប្រការ មានព្រះពុទ្ធ-
នុស្សតិជាដើម ។ បុគ្គលដែលជាបច្ចុប្បន្នជនតាសត្វ គឺសត្វកើតក្នុងដំណាន់
ក្រោយ សូម្បីនឹងពោលដោយអត្តនោមត្បាធិប្បាយ បុគ្គលទាំងឡាយ
ដែលច្រើនពៅដោយសទ្ធាជឿ កាលឃើញវត្ថុទានហើយនឹកពិចារថា របស់
នោះវត្ថុនេះនឹងយកពុកជាក់ឆ្លើយជាបិណ្ឌបាតទានក៏ជាន ព្រោះហេតុថាទាន
នោះនឹងជាឧបនិស្ស័យទៅក្នុងបារមីទាំងមូល ឯទាននោះសោតក៏
កប់បញ្ចូលក្នុងបារមី ៣០ ប្រការ សូម្បីព្រះពុទ្ធជាអម្ចាស់ទាំងឡាយដែល
ជានត្រាស់ដឹងនូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ក៏អាស្រ័យតែជានបំ-
ពេញទានបារមីផង ទើបជានសម្រេចត្រាស់ព្រះអង្គ ។ ព្រោះហេតុនោះ
បណ្ឌិតជាតិតប្បីកំណត់ពុកក្នុងចិត្តថា ការដែលនឹកពិចារថា វត្ថុនោះ ។
អាត្មានឹងដាក់បម្រុងធ្វើបិណ្ឌបាតទាន យ៉ាងនេះក៏ចាត់ដោយពោលថាជា
សម្មាសតិជាន ព្រោះការនឹកពិចារនោះដែរ ។ ប៉ុន្តែក្នុងព្រះពុទ្ធដីកា

ប្រាថ្នាការនឹកឃើញត្រូវដែលនឹងឲ្យសម្រេចសម្បត្តិជាលោកុត្តរ ។ ឯ-លោកុត្តរសម្បត្តិនោះ គឺសម្រេចដោយសម្បត្តិកើតពីលោកិយ ។ ការនឹកឃើញអ្វី ។ ប្រាសចាកទោសឥតទោស អាចជាត់ជាសម្មាសតិបាន ព្រោះនឹងជាបច្ច័យឲ្យបានខ្ជួរលោកុត្តរសម្បត្តិកន្លងពពាងមុខ ។

កន្លងសម្មាសមាធិនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាសំដៅយកចិត្តតាំងមាំកន្លងឈាន ។ ឯសត្វកើតមកកន្លងកាលខាងក្រោយនេះ មិនបានតាំងចិត្តឲ្យមាំកន្លងឈានគឺឥតមែនហើយ ប៉ុន្តែអ្នកប្រាជ្ញតម្រិះសន្និដ្ឋានថា ចិត្តដែលតាំងមាំស៊ប់សួនកន្លងខាងសីលនឹងកន្លងការកុសលតាំងពួន គឺហៅថា សម្មាសមាធិបាន ព្រោះសម្មាសមាធិនោះប្រែថា តាំងចិត្តមាំដោយល្អប្រពៃ ព្រះនិព្វាន ដើម្បីមិនបានសម្រេច កន្លងជាតិនេះទេ គឺតែងជាបច្ច័យឲ្យសម្រេចខ្ជួរព្រះនិព្វានកន្លងជាតិខាងមុខដែរ ។

អដ្ឋង្គមគ្គតាំងប្រាំប៉ប្រការ មានសម្មាទិដ្ឋិជាដើម មានសម្មាសមាធិជាបរិយោសានខេះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាថា ជាមគ្គ, ជាផ្លូវប្រតិបត្តិញ៉ាំងសត្វឲ្យដល់ខ្ជួរព្រះនិព្វានជាទីលែងខ្វល់ក្នុងបានឥតប្រាកដ ដើម្បីឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដែលព្រះពុទ្ធត្រាស់ទេសនាកន្លងសច្ចយមក: កន្លងតម្ពីព្រះយមកៈដោយប្រការដូច្នេះ ។

សង្ខារយមក

តត្ថយោ សង្ខារេ កាយសង្ខារេ វចីសង្ខារេ ចិត្ត-

សង្ខារភេតំ យស្ស កាយសង្ខារោ ឧប្បដ្ឋិតំ តស្ស វចី សង្ខារោ ឯ ចិត្តសង្ខារោ ឧប្បដ្ឋិតីតិ ។

លំដាប់នេះ ខ្ញុំនឹងវិស្សជ្ជនាក្នុងសង្ខារយមកៈតទៅ សេចក្តីថា កាលបើ សម្តេចព្រះមានព្រះភាគ កាលព្រះអង្គនឹងត្រាស់ទេសនាទូវសង្ខារយមកៈ នោះ ទើបមានព្រះពុទ្ធដីកាបុច្ឆាជាគូ ។ ហើយវិស្សជ្ជនាជាគូ ។ ដូចគ្នា ។ ព្រះអង្គទ្រង់ត្រាស់បុច្ឆាថា តត្រយោ សង្ខារា សង្ខារទាំងឡាយនោះមាន ប៉ុន្មានប្រការ គឺ កាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់បុច្ឆាថា កតមោ កាយសង្ខារោ ដូចម្តេច កាយនោះឬ ឈ្មោះថា កាយសង្ខារ, កាយសង្ខារនោះឬ ឈ្មោះថា កាយ ។ វចីនោះឬ ឈ្មោះថា វចីសង្ខារ វចីសង្ខារនោះឬឈ្មោះថា វចី ។ ចិត្តនោះឬឈ្មោះថា ចិត្តសង្ខារ, ចិត្តសង្ខារនោះឬឈ្មោះថា ចិត្ត ?

ត្រាស់បុច្ឆាដូច្នេះហើយ ទើបត្រាស់វិស្សជ្ជនាថា អាមន្តា អើ! កាយនោះឯងហើយឈ្មោះថា កាយសង្ខារ, កាយសង្ខារនោះឯងហើយ ឈ្មោះថា កាយ ។ វចីនោះឯងហើយឈ្មោះថា វចីសង្ខារ ។ នោះឯង ហើយឈ្មោះថា វចី ។ ចិត្តនោះឯងហើយឈ្មោះថា ចិត្តសង្ខារ ។ នោះ ឯងហើយឈ្មោះថា ចិត្ត ។

(នៅមានត)

សម្តែចធម្មលិខិត លេខ - ៧៩ ប្រៃរៀបរៀង

(តមក)

លុះព្រះអង្គមានព្រះភុទ្ធដីកាដូចនេះហើយ កំនាំយកអតីតនិទានមក សម្តែងប្រាប់ទុត្តរសាមណេរថា: តិរ បានឮរឿងៗមក នាកាលអតីត-កាលកន្លងរំលងទៅយូរណាស់ហើយ អ្នកបានកើតជាពាសេតុបនៅអាស្រ័យក្នុងស្រុកមួយ បានលេងល្បែងជាមួយនឹងកូនក្មេងអ្នកស្រុកចាំងខ្លាយ ហើយបានគាន់យកបន្ទាដ៏ស្អិតស្រួចទៅដោតសត្វរុយ ដែលមានជីវិតរស់នៅទ្បែងកង្វាលើបន្ទាដ៏ស្រួច ដោតក្បាច់ឆ្អឹងសំបកស្តៅក្នុងមណ្ឌលសម្រាប់លេងនាកាលនោះឯង ។ ម្យ៉ាងទៀត អ្នកឯងត្រូវស្តាប់ជាបកម្មរបស់អ្នកមួយសណ្តានទៀត, មានសេចក្តីដំណាលថា មានរបស់អ្នកបានឃើញអ្នកលេងល្បែងមិនគួរដូចនោះហើយ កំតោលខ្លួនបានប្រដៅអ្នកមិនឲ្យលេងល្បែងដែលប្រកបដោយតៀរដូចនោះទៀតឡើយ, ហើយអ្នកបានក្រោធខឹងដេរប្រទេចផ្តាសាទៅលើមាតាវិញថា បើម៉ែមិនឲ្យខ្ញុំលេងយាំងនេះទេ មានតែម៉ែឲ្យខ្ញុំចាប់ម៉ែយកទៅដោតឲ្យអង្គុយលើឈើស្រួចចាំងរស់វិញ ហេតុតែបាបកម្មចាំងតិរយ៉ាំងនេះហើយ បានជាអ្នកអន្ទោលទៅមកកន្លងសាគតីសង្សារវដ្ត តែតែងចាប់ចងអ្នកយកទៅឲ្យអង្គុយលើឈើអណ្តោត

ពាន់ឆ្នាំរស់កំណត់ ៥០០ ជាតិនឹងជាតិនេះឯង អ្នកសោយទុក្ខវេទនាតែក្នុងជាតិនេះខ្លៀតក៏នឹងបានរួចស្រឡះអំពីជាបកម្មានោះហើយ ។ លុះព្រះអង្គបានប្រកាសច្រាច់នូវជាបកម្មយ៉ាងនេះ ហើយក៏សំដែងព្រះធម៌ទេសនាតទៅទៀត ដ៏សំគួរដល់អធ្យាស្រ័យនៃទុគ្គរសាមណេរដោយយន័យផ្សេង ។ ដូចបានពណ៌នាមកហើយប៉ុណ្ណោះជាដើម ។

ឯទុគ្គរសាមណេរក៏មានសេចក្តីសោមនស្សជ្រះថ្លាស្អាតបរិសុទ្ធ តើតឡើងព្រមអាស្រ័យដោយឱហត្តសម្ផស្សនៃព្រះសាស្តាចារ្យជាម្ចាស់ ដែលទ្រង់ស្តាបលើសិរសោរបស់ខ្លួនច្រកដៃស្មើដោយទឹកអម្រិតដ៏ត្រជាក់ដែលបុគ្គលយកមកស្រោចពីលើដោយពិត ហើយបានញ៉ាំងចិត្តនឹងឆ្ងាមោដ្ឋដំលើសលប់ឲ្យតើតឡើងក្នុងសន្តាន ពាន់ឆ្នាំបានញ៉ាំងចិត្តឲ្យឡើងកាន់វិបស្សនាមគ្គ ដោយប្រាជ្ញាចាស់ក្លាហើយញ៉ាំងកិលេសពាន់ឆ្ងាយឲ្យអស់សូន្យទៅតាមលំដាប់នៃវិបស្សនាមគ្គនោះ ព្រមពាន់បានសំរេចនូវអគ្គញ្ញាប្រាំមួយ នឹងបដិសម្ភិទាបួន ជាអគ្គព្រះអរហន្តដ៏វិសេសក្នុងលោក ។

ចំណែកឯសត្វពាន់ឆ្ងាយប្រមាណប្រាំបីម៉ឺនបួនពាន់ ដែលបានមកប្រជុំស្តាប់ព្រះធម៌ទេសនាកុងពីនោះ សឹងបានសំរេចនូវមគ្គផលសំគួរតាមឧបនិស្ស័យរៀងខ្លួនដោយពិត ។

រីឯទុគ្គរសាមណេរលុះបានអគ្គញ្ញាពាន់ឆ្នាំហើយ សឹងប្រកបដោយមហិទ្ធិឫទ្ធិច្រើន កំហោះឡើងអំពីឈើអណ្តែតទៅស្ថិតនៅលើអាកាស

សម្តែងថាជាដំហរបស់អស្ចារ្យផ្សេង ។ ក្នុងកាលនោះហាន ។

មហាជនតាំងឡាយសោត កំសឹងមានចិត្តស្ងើចសប្បាយសែងជាអស្ចារ្យពន់ពេកក្នុងកាលនោះដែរ ។ ចំណែកតិក្ខាតាំងឡាយកាលបើបានឃើញទត្តរសាមណេរសម្តែងខ្លួនថាជាដំហរបស់អស្ចារ្យដូចនោះហើយ ក៏សួរថា ម្នាលអ្នកមានអាយុ អ្នកមានបុនិស្ស័យធម៌ដ៏ក្លៀវក្លាដល់ម្លេះ ចុះកាលដែលអ្នកសោយទុក្ខវេទនាក្រាកជាដល់ខ្លួនដូចមានហើយ ហេតុអ្វីក៏អ្នកមិនប្រកបបែបស្បាទាមគ្គនោះ ឲ្យសំរេចព្រះអរហត្តភាវតែម្តងទៅ ។

ឯទត្តរសាមណេរបានស្តាប់ហើយនោលតបថា: បពិត្រលោកអ្នកដ៏មានអាយុតាំងឡាយ ទោសក្នុងសង្សារវដ្តនឹងសភាវៈរបស់សង្ខារតាំងឡាយត្រូវតែខ្ញុំបានឃើញជាមុនដូច្នេះឯង ។

ព្រោះហេតុនោះ កាលខ្ញុំសោយទុក្ខវេទនាក្រាកជាដូច្នោះ ក៏ពុំអាចនឹងចំរើនបែបស្បាទាមគ្គហើយត្រាស់ដឹងខ្លួនតុណ្ហីសែសបានឡើយ ។ លុះដល់ចំណេរមកជាខាងក្រោយ ទត្តរសាមណេរនោះបានប្រកាសសម្តែងខ្លួនថាជាអាងបុត្តចរិតរបស់ខ្លួន ដែលភ្ជាប់សន្សំតាំមុខមកក្នុងកណ្តាលទីប្រជុំព្រះកំណុសង្ឃ ហើយនោលខ្លួនបទព្រះគាថាតាំងឡាយថា:

សុមេធោ នាម សម្ពុទ្ធោ ទ្វត្តិំសវរលក្ខណោ
វិវេកថាមោ អកថ្កិ ហិមវន្តមុបាគមិ ។

អធិប្បាយថា: ព្រះសម្មាសម្ពុទ្ធព្រះនាមសុមេធ ទ្រង់មានជោគ

ដ៏ឃ្លាតព្រះអង្គប្រកបដោយព្រះមហាបុរិសលក្ខណៈចំនួន៣២ ដ៏ប្រសើរ ព្រះអង្គមានឧត្តមព្រះទ័យក្រៃថ្នាខ្ពស់ពីវិវេកដ៏ស្ងាត់ចាកពួក ព្រះអង្គចូលគង់ប្រទេសហិមពាន្តជាទីរហាស្ថានដ៏សប្បាយដោយពិត ។

អដ្ឋាកមោត្វា ហិមវន្តំ អន្តា ភារុណាភោ មុនិ
បស្សន្តំ អាកុដ្ឋិត្វាន ឯសីនិ បុរិសុត្តមោ ។

ព្រះសុមេធសម្ពុទ្ធជាអគ្គបុគ្គល ប្រកបដោយសេចក្តីភ័យណាដ៏ប្រសើរខ្លាំងណាស់, ជាមហាបុរសដ៏ឧត្តមជាងបុរស លុះព្រះអង្គបានយាងចុះគង់ព្រៃហិមពាន្តហើយ ក៏ពាត់ព្រះកែវពែនព្រះបាទគង់នៅក្នុងទីនោះឯង ។

វិជ្ជាធរោ តទា អាសិំ អន្តលិក្ខេ ចរោ អហំ
តំសុលក្ខណំ ភារំ ភយ្ហ កច្ឆាមិ អម្ពរេ តទា ។

កាលនោះ ខ្ញុំម្ចាស់បានអន្ទោលទៅកើតជាវិជ្ជាធរមួយប្រាណបានហោះទៅតាមអាកាស បានកាន់ផ្កាកណ្ណិការមួយចង្កោមដែលប្រដាប់ដោយឧត្តមមួយមានផ្កាបី មានអាការហាក់ដូចជាដោតចង្កត្រនំនឹងឈើស្រួចចំនួនបី ស្រេចហើយហោះទៅតាមអាកាសក្នុងកាលនោះឯង ។

បព្វតគ្គេ យថា អគ្គិ បុណ្ណាមាសេវ ចន្ទិមា
វនំ ឱភាសតេ តុង្គោ សាលរាជាវ ផុល្លិតោ ។

ព្រះសុមេធសម្ពុទ្ធជាម្ចាស់ ទ្រង់ញ៉ាំងវៃព្រចំនួនអស់ឲ្យភ្លឺរុងរឿងដូចជាអណ្តាតភ្លើង នេះឲ្យរឿងលើកំពូលភ្នំ ពុំនោះសោត ដូចជាព្រះចន្ទរះ

ឡើងទៅថ្ងៃពេញបុរេម៉ែ តុំនោះសោត ប៉ដូចជាដើមត្រែងប្រចាំទ្វីប ដែលជាស្តេចនៃឈើភាំងឡាយ មានឆ្កាំដ៏កែសុះស្គាយហើយមានតន្ទីរុងរឿងក្រៃលែង ។

ការជា ជិតមិត្តាន តុន្ទរំសីវ ជាវរេ
ជឡក្តីវ ជសំការសា ជិស្សា ចិត្តំ បសីជយី ។

តន្ទីស្នើបេស់ព្រះសម្ពុទ្ធជាម្ចាស់ បានផ្សាយតាំត្រៃហ៊ាមភាន្តស្ទុះចេញសន្ធោសន្ធៅ ប៉ដូចក្តៅនេះគំនរសម្រាមឮដ៏ត្រៃបំបុស, លុះខ្ញុំម្ចាស់បានឃើញស្នើនោះហើយ កំមានចិត្តជ្រះថ្លាភន់ភេក ។

រិចិនំ អច្ចុសំ បុប្ផំ កណ្ណិការកណ្ណិកំ ច
តីណិ បុប្ផានិ អាជាយ តុន្ទុសេដ្ឋំ អបូជយី ។

ខ្ញុំម្ចាស់បានជ្រើសរើសទូវត្តុម្មផ្កាកណ្ណិការ កំបានយើញផ្កាកែសុះហើយបានកាច់ផ្កាតាំងឡាយបី កាន់យកទៅបូជាព្រះសម្ពាសម្ពុទ្ធដ៏ប្រសើរវិសេស កន្លងលោក ដោយសេចក្តីគោរព ។

តុន្ទុស្ស អានុភាវេន តីណិ បុប្ផានិ មេ តជា
ឧទ្ធំ វណ្ដា អនោ បត្តា ជាយិំ តុវ្ហន្តិ សត្តជោ ។

ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់ ផ្កាតាំងបីបេស់ខ្ញុំ កន្លងកាលនោះ កំមានខ្នងត្រឡប់ទៅខាងលើ មានត្រចកស្រទាប់ផ្កាសំយុងចុះមកខាង

ក្រោម ធ្វើជាមូលប៉ាន់ថ្វាយព្រះសាស្តា មានអាការដូចជាឆត្តរបើកប៉ាន់
តាលើដូច្នោះ ។

តេន ភាម្មេន សតេន ចេតនាបណិធិហិ ច
ចជ្ជិត្វា មានុសំ ទេហំ តាវត្តិំសូបគញ្ឆិហំ ។ ដោយអំពើ
ជាកុសលរបស់ខ្ញុំនោះផង ដោយចេតនាដែលដំកល់ទុកល្អជាកំណប់
បុណ្យនោះផង ខ្ញុំម្ចាស់ច្យាលះបង់កាយជារបស់មនុស្សហើយ ច្យាន
អន្លាស់ទៅកាន់ស្ថានតាវតឹសសួគ៌ាយដោយពិត ។ តត្ថ មេ សុកតំ
អំពើដែលខ្ញុំច្យានធ្វើល្អហើយនោះ សឹងមានវិមានទិព្វដ៏ច្រោកដដោយឆ្លាក
កណ្តាការតាំងឡាយមានកំពស់ហុកសិបយោជន៍, ទទឹងសាមសិប-
យោជន៍, មានល្វែងមួយរយគត់, មានទំហំល្វែងតាំងអស់ប្រមាណមួយ
ភាន់កូនសរសឹងប្រដាប់ទៅដោយទន់ដាយ ទន់ជ្រួងដ៏ច្រើនដេរដាស សំ-
រេចដោយមាសសុទ្ធ ។ ឯគ្រឿងកម្រាលដ៏វិសេសប្រមាណមួយសែន
សំរេចដោយមាសខ្លះ ដោយកែវមណីខ្លះ ដោយកែវមានពណ៌ដូចឈាម
សត្វខ្លះ សំរេចដោយកែវផលឹកខ្លះ ឯបល្ល័ង្កកើតឡើងតាមតែច្រាថ្នា បើ
ច្រាថ្នាចង់ច្យានយ៉ាងណា ក៏សំរេចយ៉ាងនោះ, តាំងទីដំណេកដ៏មានដំឡៃ
ច្រើនសោត សឹងប្រដាប់ដោយភួកចំឡែកវិចិត្រដោយកែវផ្សេង ។ ក្រម
តាំងខ្ពស់ខ្ពើយក៏សំរេចដោយកែវផ្សេង ។ ដូចគ្នាតាំងអស់, បើវេលាណា
ខ្ញុំធ្វើដំណើរចេញអំពីទេវវិមាន ទៅកាន់ទេវវិមានឯទៀត សឹងមានពួកទេវតាតាម

ហៃហម, រីឯអាកាសខាងក្រោម មានផ្កាកណ្តៀរប្រតិស្ថាន (ដូចជាកម្រាល) ឯខាងលើមានផ្កាត្របាំង (ដូចជាឆត្រ) មានទំហំប្រមាណមួយរយយោជន៍ដុំវិញខ្លួន ។ ចំណែកឯក្លិនតូរ្យតន្ត្រីយ៍ប្រមាណជុំមួយមីនត្រឹង សឹងប្រជាប់ដោយផ្កាកណ្តៀរ តែងតាមចោមរោមបំរើខ្ញុំខាងពេលព្រឹកល្ងាច ខាងយប់ខាងថ្ងៃ ដោយលេស្សឯក្រៀងពាំប្រគំអស់កាលជាខន្ធតុំដែលដាច់ឡើយ ហេតុតែផលានិសង្សដែលខ្ញុំបានធ្វើភុំ-បូជានោះ ខ្ញុំបានសោយសម្បត្តិដូចបានតណិនាមកយ៉ាងនេះ គឺបានជាស្តេចនៃទេវតាជ្រុំរយៈកាត, បានជាស្តេចចក្កពត្តិធាតុជម័យជាតិ បានជាស្តេចបរទេសកជ, ឯកកជ, សាមន្តកជ ជាអស់រយៈយូរ ជាតិរាប់ពុំបានឡើយ ។

កកកវេ សំសរន្តោ មហាកោតំ លភាមហំ
កោតេ មេ ជិនភាគត្តំ ពុទ្ធបូជាយិទំ ផលំ ។

កាលខ្ញុំម្ចាស់អន្ទោលទៅកន្លងភពតូចភពធំ តែងបានសោយនូវសម្បត្តិដ៏ប្រសើរ, ខ្ញុំនឹងបានខ្លះនូវភាគសម្បត្តិប្រើប្រាស់ដល់ម្តងឥតអង្គើមានឡើយ, នេះជាផលដែលខ្ញុំបានធ្វើភុំ-បូជាដោយតិត ។

ឧបវេ កវេ សំសរាមិ នេវរ៉ះ អជ មានុសេ
អញ្ញំ កតិ ន ជាជាមិ ពុទ្ធបូជាយិទំ ផលំ ។

ម្យ៉ាងវិញទៀត ខ្ញុំតែងបានអន្ទោលទៅកន្លងភពតាំងពីរ គឺទេវភពនឹង

មនុស្សភព ខ្ញុំតំណែលបានស្គាល់ខ្លួនតតិដំខែលម្តងទៀយ នេះជាផលដែល ខ្ញុំបានធ្វើពុទ្ធបូជា ។

ទុវេ កុលោបបជ្ជាមិ ទេវត្តយេចាបិព្រាហ្មណោ
ឯកេ កុលេ ន ជាតាមិ ពុទ្ធបូជាយិទំ ផលំ ។

ចំណែកខាងមនុស្សភព ខ្ញុំតែងបានទៅកើតតែក្នុងត្រកូលពីរគឺត្រកូលក្សត្រិយ៍ ១ ត្រកូលព្រាហ្មណ៍មហាសាល ១ ខ្ញុំតំណែលស្គាល់ត្រកូលថោកទាបទៀយ, នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

ហត្ថិយានំ អស្សយានំ សិវិកាសន្ទមានិកំ
លភាមិ សព្វមេវេតំ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំតែងបានខ្លួរយានដ៏រ យានរេះ រវមាស ខ្ចីរថមានសណ្ឋានដូចរូបត្រួយតាំងអស់នេះកាល់ ។ ជាតិតំណែលខ្លះទៀយ, តាំងអស់នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

ឆាសិកណាំ ឆាសកណាំ ឆាវិយោច អលង្កតា លភាមិ
សព្វមេវេតំ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំតែងបានខ្លួរខ្ញុំស្រីជាច្រើនផង ខ្ញុំប្រុសជាច្រើនផង ខ្លួនារីតាំងឡាយសឹងមានដងខ្លួនប្រដាប់ដោយគ្រឿងអម្ពរផង តាំងអស់នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

គោសេយ្យកម្ពលិយានំ ខោមកប្បាសិកានំ ច

លភាមិ សព្វមេវតំ ពុទ្ធបូជាយិទំ ៥លំ ។

ខ្ញុំតែងបានទូរសំពត់កោសេយ្យពស្ត្រ សំពត់កម្ពលពាំងឡាយផង សំពត់ដែលត្បាញដោយសម្បកឈើ ឧដ្ឋសំពត់កប្បាសពាំងឡាយផង ពាំងអស់នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

ឧវត្តំ ឧ៥លំ ជាឧក្តាសកោ៥ំ

លភាមិ សព្វមេវតំ ពុទ្ធបូជាយិទំ ៥លំ ។

ខ្ញុំតែងបានទូរសំពត់ថ្មី ផ្ទៃឈើដំបូង កោ៥ឧដ៏មានឧជាសដ៏ប្រសើរផ្សេង។ ពាំងអស់នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

ឥមំ ខាឧ ឥមំ ភុញ្ជ ឥមស្មឹ អាសនេ សយ

លភាមិ សព្វមេវតំ ពុទ្ធបូជាយិទំ ៥លំ ។

ខ្ញុំតែងបានទូរពាក្យសំដីដ៏ពីរោះថា អ្នកម្ចាស់សូមពីសាក្រយានេះ សូមបរិភោគភោ៥ឧនេះ សូមសំពះលើអាសនេះ ពាំងអស់នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

សព្វត្តបូ៥ិតោ ហោមិ យសោ អភុក្តតោ មម

មហោសក្កោ សឧា ហោមិ អភេជ្ជបរិសោ សឧា

ញាតីនំ ឧុត្តមោ ហោមិ ពុទ្ធបូជាយិទំ ៥លំ ។

តួខ្ញុំនេះឯង តែងតែបូជាត្រប់ប្រទេសពាំងពួង ខ្ញុំមានបរិវារយសខ្ពង់ខ្ពស់ក្រៃលែង មានយសសក្តិដ៏សព្វ។ កាល មានយសបរិវារតុំដែល

បែកខ្វែកតាំងតែវេលាតំណាងពួន ខ្ញុំជាបុគ្គលប្រាសើរវិសេសជាងញាតិតំណ
ឡាយ នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជាដោយពិត ។

សីតំ ឧណ្ហំ ន ជានាមិ បវិទ្ធោ ន វិជ្ជតិ
អថោ ចេតសិកំ ទុក្ខំ ហានយេ មេ ន វិជ្ជតិ
សុវិណ្ណាវណ្ណា ហុត្វាន សំសរាមិ ភវេ ភវេ
វេវណ្ណិយំ ន ជានាមិ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំពុំដែលស្គាល់ត្រជាក់ក្តៅ ស្គៅពេកដល់ម្តងឡើយ តាំងសេចក្តី
ក្តៅក្រហាយកំពុំដែលកើតមានដល់ខ្ញុំដែរ ម្យ៉ាងវិញទៀតសេចក្តីលំបាក
កាយលំបាកចិត្តពុំដែលកើតមានក្នុងហឫទ័យរបស់ខ្ញុំដែរ ខ្ញុំតែងអន្ទោល
ទៅកើតក្នុងតតាំងពួនសឹងមានពណ៌សំបូរល្អដូចជាពណ៌មាស ខ្ញុំពុំដែល
ស្គាល់ពណ៌សម្បុរផ្សេងពីមាសឡើយ នេះជាផលដែលខ្ញុំបានធ្វើពុទ្ធបូជា
ដោយពិត ។

នេវលោកា ចវិត្វាន សុក្កមូលេន ចោទិតោ
កជកហបុរេ ជាតោ មហាសាលេសុ អទ្ទសេ
បញ្ចកាមគុណោ ហិត្វា បព្វជ្ជឹ អនគារិយំ
ជាតិយា សត្តវស្សោហំ អរហត្តមថាបុណិំ ។

(នៅមានត)

លោក អ៊ឹម-កន បម្រុងព័ស្រាស្ត្រសិក្សិតត

ព្រះភិក្ខុវង្ស កឹម-ស្ងួរ តិន្តិស្ស

(តមក)

កាលនោះមានបុរសម្នាក់ធ្វើមុសាវាទស្រដីនូវពាក្យតូចតួចថា ឆេះបតិត្រអើយ ! មានកាលមួយថៃ្ង អញទ្រុងដឹកស្រាហើយស្រែកឮក ចូលទៅកន្លែងនៃតលុះដោយនូវគ្នាបន្ទិច អញទ្រុងទៅយល់ស្រះបោក្ខរណីដ៏មួយ គេធ្វើប្រយោជន៍ដើម្បីតែងនឹងលេងទឹកនៃអ្នកនៃតវេងតាំងពាយ សប្បាយជិះលើទូក តែងនៃនមកបេះផ្កាលេងជាសប្បាយនឹងគេហោង; បុរសនោះពួលថា បតិត្រអើយ ! រីស្រះនោះសោត អញទ្រុងដឹងស្គាល់ឆ្នេរស្រះនេះដូច្នេះ, មួយទៀតសោត អញទ្រុងដឹងស្គាល់ដៅស្រះនោះ មាននៅកុម្ភនោះស្រាប់ ប្រវែង ១០០ ហត្ថមែនតិតហោង ។ កាលនោះព្រះបាទបុលនីស្តេចស្តាប់ពាក្យបុរសនោះហើយ មានព្រះបន្ទូលនឹងអាចារ្យកៅដ្ឋព្រាហ្មណ៍ថាដូច្នេះ អាចរិយ ! ហៃអាចារ្យអើយ ! រីយើងពុំអាចនឹងចាប់គេបាននឹងបង្អត់ទឹកនេះឡើយ, ស្តេចបន្ទូលថា ចូរបាន់នូវគំនិតថ្មីទៀតហោង ។ ទើបអាចារ្យកៅដ្ឋព្រាហ្មណ៍ពួលថា បតិត្រមហាកដអើយ ! ពោះយោបល់មានដូច្នោះ យើងតំចាប់យកឲ្យបាននឹងបង្អត់ចាយនេះម្តង ឥតន្លងនតនោះមានប៉ុន្តែស្រះនៅឯក្រៅនោះឯងអេះ ។ ស្តេចមានបន្ទូលថា អាចរិយ

វិហរាចារ្យអើយ ! តោះយោមមានដូច្នេះ យើងនឹងទៅដូច្នោះហោង ។ ចៅ-
មហាសេដ្ឋអ្នកដឹងពីតិមានោះជាក់ដូចនូវដំណើរនិយាយមុននោះហោង ;
ន មេ តោវិដ្ឋ ភាហ្មណោ បណ្ឌិតតោវំ ជានាតីតិ អនុ-
ថាតោរមត្តតោ តោលសំ ធត្វា វិហ តត្ត តោថាបេសិ ។
តោធិសត្តានំ អធិប្បាយោ ជាម ឥដ្ឋតិ ។ ព្រះមហា-
សត្វថា នាអាចារ្យតោវិដ្ឋព្រាហ្មណ៍នេះ ក៏ពុំដឹងសតាពនៃអញជាអ្នកមាន
ប្រាជ្ញាឈ្លាសប្រតិភាល ឃើញអស់អាថិសេចក្តីកំប៉ាំងនូវតំណែងសង្គ្រាម
ដ៏ឃៃនៃអញសតាពជាអ្នកប្រាជ្ញានោះឡើយ ហើយតោធិសត្វអ្នកឲ្យជាន់
តក់លើតាតបន្ទាយនោះល្អហើយ ឲ្យដាំនូវពូជស្រូវលើតាតបន្ទាយនោះ ។
ហេតុតែព្រះបារមីនៃតោធិសត្វនឹងបានត្រាស់ប្រាជ្ញាសតើឋតញ្ញាណនោះ
មិញ នាមីហៅតលអធិប្បាយសំរឹទ្ធិតោធិសត្វហោង ។ រីពូជស្រូវនោះ
កំលាស់ឡើងតែមួយពាត្រីនោះ ឃើញប្រាកដលើតាតបន្ទាយនោះហោង ។
រីព្រះបាទបុលទីព្រហ្មទត្តពាជ ស្តេចយាលស្រូវព្រះមហាសេដ្ឋីនោះហើយ
មានព្រះបន្ទូលថា អម្ពោ ម្នាលគ្នាយើងពាំងឆ្ងាយអើយ ! នោះអ្វីឃើញ
មកប្រាកដខៀវលើតាតបន្ទាយនោះហ្នឹង ? ។ បុរសដែលជាខបខ្ញុំក្តីត
ចៅមហាសេដ្ឋ ឮពាក្យស្តេចបុលទីនោះហើយ ខងអណ្តាតមាត់ដូចតេ
តក់ តំក្រាបទូលថា ទេវ បតិត្រអម្ចាស់ ! ដូចយើងឮមកថា ចៅមហា-
សេដ្ឋបុត្រតហបតិសិរីវឌ្ឍកសេដ្ឋី តាត់យាលអនាតតតាលនឹងមកដល់ក្តីត

ស្អែកនឹងក្រមុំនេះឡើយ អ្នកឲ្យជញ្ជូនខ្លួស្រូវអំពីស្រុកក្រៅ យកទៅចាក់បំពេញក្នុងឃ្លាំងតាំង ១៨ នោះ រីស្រូវសំណល់លែងនោះ ឲ្យចាក់ទុកនាខាងបន្ទាយនោះហាន, ដូចយើងឮមកថា ស្រូវនោះដោយត្រូវកំដៅថ្ងៃស្ងួត ស្រូវនៅជាតួដ នៅត្រូវភ្លៀងខ្យុះខ្ចីកត្រជាក់ ស្រូវនោះដុះឡើងលើក្បាលបន្ទាយនោះ; មានការមួយថ្ងៃ, សូមីអញខ្ញុំចូលទៅដោយទ្វារបន្ទិច អញខ្ញុំឃើញដួកស្រូវខាងក្បាលបន្ទាយនោះ ហើយអញខ្ញុំយកស្រូវនោះនឹងដៃឯងមកមើល ដែលគេចាក់ចោលបង់នៅកណ្តាលផ្លូវគ្នា; លំដាប់នោះ, រីអ្នកផងតាំងពាយកស្រដីនឹងអញខ្ញុំថា ម៎ៃហប្បុរសអាយ! ព្រះស្តេងកេអំពើអ្វីខ្លួលប្រគាវដូច្នោះ ក៏ថាដូចយើងគិតហើយ រីព្រះស្តេងឃ្វាងបាយដឹង? ចូរព្រះស្តេងយកសំពត់មកនឹងវេចស្រូវនោះនាំទៅនាផ្ទះអាត្មា, ព្រះស្តេងនឹងចើស នឹងបុកដណ្តាំបាយ ព្រះស្តេងយកបរិភោគហាន ។ ស្តេចស្តាប់ពាក្យបុរសនោះហើយ ឥន្ទ្រលនឹងអាចារ្យកេវដ្តព្រាហ្មណ៍ថា អាចរិយ ម៎ៃអាចារ្យអើយ! រីយើងពុំអាចចាប់បានស្តេចវិទេហរាជដោយខ្លួបន្លំត់បាយឡើយ ។ អាចារ្យកេវដ្តព្រាហ្មណ៍ខ្លួលថា ឧវ៎ ម.តិត្រអើយ! អញខ្ញុំមានឧបាយមួយវិញទៀត, ខ្លួលថា បតិត្រអើយ! ពោះយោបល់មានដូច្នោះ យើងនឹងធ្វើឲ្យមាននឹងឥតអុសដុតហាន; នាម៉ោងតរនោះ មានអុសបុំខ្លែងស្រាំនោះឯង ។ ស្តេចឥន្ទ្រលថា ម៎ៃអាចារ្យអើយ! ពោះយោបល់មានដូច្នោះ យើងនឹងធ្វើដូច្នោះហាន ណា

បពិត្រអម្ចាស់ ។ ចៅមហាសេដ្ឋអ្នកជ្រាជ្ញ អ្នកដឹងពត៌មានជាក់ថា គេចាម
ចង្កឹតអ៊ុសដូច្នោះហើយ , ពោធិសត្វអ្នកឱ្យរណ្តាប់តអ៊ុសខុកលើក្បាល
បន្ទាយនោះ យល់ប្រមាណប៉ុនតុំ ។ រីមនុស្សដងតាំងឡាយ មួយអន្ទឹ
នដងបុរសអាមាត្យស្តេចចុលនីធ្វើនូវការស្វែងរកអ៊ុសនូវបន្ទែរាត់តុំបានឡើយ,
រីបុរសពោធិសត្វថា ម្នៃម្ចាស់ព្រះស្តែងតាំងឡាយ ព្រះស្តែងអត់អ៊ុស
ដណ្តាំចាយហួបនោះ ពោះយោបល់ឃ្វានណាស់ដឹង ? ចូរព្រះស្តែងមកយក
អ៊ុសនេះទៅមួយថ្ងាច់ម្នាក់ គ្រាន់ចំអិនបបរយោគូដណ្តាំចាយ ព្រះស្តែង
បរិភោគរហាង, ពួកមហាជនតាំងឡាយ ចោះនូវអ៊ុសដំធំ ។ ទៅឲ្យ ។
ឯចំណែកស្តេចចុលនីក៏យល់ក្រែកដនាអ៊ុសលើភាគបន្ទាយនោះ ហើយ
ដណ្តឹងអាមាត្យថា នោះអ្វីអ្នកតាំងឡាយ ? ។ អាមាត្យទូលថា នេះ
បពិត្រអើយ ! ដូចយើងគិតហើយ, រីចៅមហាសេដ្ឋបុត្រគហបត៌អ្នកយល់
អនាគតទៅឯក្នែកស្តេចនឹងក្រ អ្នកឱ្យដញ្ជូនអ៊ុសឮដីនាក្រកូលចំណែក
ភាគបន្ទាយខាងឯលើមកគរខុកលើភាគបន្ទាយនោះច្រើនក្រៃ ។ ព្រះចុ
ចុលនី ស្តាប់ពាក្យបុរសជាទូតនិតចៅមហាសេដ្ឋនោះ ហើយបន្ទូលនឹង
អាចារ្យតែវដ្តព្រាហ្មណ៍ថា អាចារ្យ ម្នៃអាចារ្យអើយ ! យើងពុំគាច
នឹងចាប់ចាន សូមឱ្យនឹងផ្តាច់នូវអ៊ុសនេះឡើយ, ស្តេចបន្ទូលថា កែលទុចាយ
អំពើនោះ ចូរអ្នកតាំមកវិតរហាង ។ អាចារ្យតែវដ្តព្រាហ្មណ៍ទូលថា
ដូច្នេះ មរណភាព បពិត្រមហាភដអើយ ! កុំបីអម្ចាស់ចារម្ភឡើយ,

មានទុក្ខយកសម្លាប់ភ្លាមទៀត ។ ស្តេចបន្ទូលថា ម្នែអាចារ្យអើយ ! នាបីហៅទុក្ខយកសម្លាប់នោះដូចម្តេច ? អញគិតមិនយល់ក្នុងទុក្ខយកសម្លាប់ព្រះស្តេចឡើយ, អាចារ្យក៏ក្រាបទូលថា ទេវ បពិត្រមហាក្សត្រអើយ ! រីយើងខ្ញុំឆ្លាយអម្បាលនេះ ពុំអាចនឹងចាប់ចោទយកសម្លាប់ស្តេចរិះគេហក្សត្រនេះបានឡើយ, អាចារ្យក៏ក្រាបទូលថា បើដូច្នេះ យើងនៅកាន់ទុតរយើងរិះភ្លាមហ្នឹង ។ អាចារ្យក៏ក្រាបទូលថា ទេវ បពិត្រអើយ ! អស់អ្នកឯងខ្ញុំឆ្លាយគេដឹងថា ស្តេចចុលនីព្រហ្មទត្ត គាត់នៅមួយអន្ទេះមួយស្តេចមួយរយនឹងមួយ ពុំអាចនឹងចាប់ស្តេចរិះគេហក្សត្រជាន សមយើងនឹងខ្មាសគេអស់រោងគេហ្នឹង; អាចារ្យថា ដូចអញគិតហើយ រីឯមហាសត្វសោតជាអ្នកប្រាជ្ញ, អញឯងសោត ក៏សឹងជាអ្នកប្រាជ្ញដែរ អញនឹងអាងយកនូវប្រាជ្ញាអញមួយ ធ្វើកលឱ្យលើនូវប្រាជ្ញាមហាសត្វទៀតហ្នឹង ។ ស្តេចបន្ទូលថា ម្នែអាចារ្យអើយ ! នាបីហៅឱ្យលើសកលមួយនោះ តើដូចម្តេច ? ។

ទេវ ធម្មយុទ្ធំ ជាម កាវំសុ ភាតិ ។ កឹ ជាមេតំ ធម្មយុទ្ធំ ជាមាតិ ។ មហាភគ ធ ទ្វេ សេធា យុជ្ឈិ-សុន្តិ . . . . អាចារ្យក៏ក្រាបទូលថា ទេវ បពិត្រមហាក្សត្រអើយ ! អញខ្ញុំនឹងធ្វើហៅតធម្មយុទ្ធ ។ ស្តេចបន្ទូលថា ម្នែអាចារ្យអើយ ! រីអ៎ាតើហៅតធម្មយុទ្ធនេះ តើដូចម្តេច ? ។ អាចារ្យក៏ក្រាបទូលថា

ទូលថា មហាភន្តេអើយ ! រីឯព្រាំដែនទឹងសេតាយោធាជាតំរប់ពីរនោះគ្មាន
ខ្លឹយ, បពិត្រអម្ចាស់អើយ ! មួយទៀតសោត មានតែអម្ចាស់ស្តេចតែងឲ្យ
ស្បៀមនៅកូវ អញខ្ញុំមានប៉ុន្តែអ្នកច្រាំដ្ឋនឹងអ្នកច្រាំដ្ឋ អាចមកនៅហាន
មួយផងគ្នា ថាលើសនឹលែងអ្នក ២ នោះ នូវអ្នកឯណា ថាចើសំពះមុន
ហើយ ក៏អ្នកនោះហៅថាញ៉ាមែនពិតហោង ; ឯមហាសថ៌សោត សភាព
មិនដឹងគំនិតអាត្មាអញនេះ, រឹតអញជាអ្នកច្រាំដ្ឋ ហើយថាស់ផង រឹមហោ.
សថ៌ជាអ្នកច្រាំដ្ឋក្មេងក្តាត់ ថាចើតាត់យល់អញថាស់ហើយ តាត់សំពះ
អញហោង, មួយទៀតសោត ថាចើតាត់សំពះអញហើយ នោះហៅស្តេច
វិទេហរាជថាញ៉ាយើងហោង; ឮដំណាលនោះ, យើងផ្តាំមហាសថ៌បុត្រ
គហបតី ទឹងស្តេចវិទេហរាជនោះ, យើងទៅកាន់នគរយើង, នោះយើង
ក៏មិនភ្លេចនោះខ្លឹយ, អាចារ្យកេវដ្តព្រាហ្មណ៍ទូលថា អំពើដូច្នេះនេះ
ហៅតធម្មយុទ្ធ ។ សូមឬទៅមហាសថ៌តុំដឹងនូវអំពើកំចាំងនេះ ដូចយើង
ស្រដីនោះហោង, ពោធិសត្វអ្នកដឹងមុន ហើយអ្នករំពឹងគិតថា នោះ
យោចើ អាចារ្យកេវដ្តព្រាហ្មណ៍ផ្តាំញ៉ាអញថាខលហើយ កុំចើឲ្យអស់អ្នកផង
ហៅអញជាអ្នកច្រាំដ្ឋខ្លឹយ ។ ព្រះចាខបុលនីព្រហ្មខត្តកជចទូលថា ម្នៃ
អាចារ្យអើយ ! រឹតបាយនេះល្អហើយ, យើងធ្វើធម្មយុទ្ធនាស្អែកឯងហោង
ឮដំនាអ្នកច្រាំដ្ឋទាំងពីរ នោះយោចើចាញ់ នោះយោចើឈ្នះក្តី សឹងស្ងិត
ដោយនូវធម៌មែនពិតហោង, នូវអ្នកឯណាតុំធ្វើនូវធម្មយុទ្ធ, រឹអ្នកនោះ

ហៅចាញ់ហោង, តែតដូច្នោះហើយ ឲ្យសរសេរសំបុត្រប្រើឲ្យដូនៅ
ស្តេចវិទេហរាជ ដោយខ្លួវគ្មានបន្ទូច ។ ស្តេចវិទេហរាជ ស្តាប់ឥតមាន
នោះហើយ, ស្តេចឲ្យហៅចៅមហាសថមកសំដែងប្រាប់ខ្លួវអាថ៌នោះ
សព្វគ្រប់ ។ រីមហាសថអ្នកដឹងខ្លួវអាថ៌នោះហើយទូលថា ឧេវ បពិត្រ
មហារាជអើយ! សាធុ តីរេះតេត, នាត្រីកស្អែក អម្ចាស់ឲ្យរណ្តាប់
មណ្ឌលធម្មយុទ្ធ ដោយគ្មានទោងលិចស្រេចហើយ អម្ចាស់ប្រើឥតមាន
ទៅឲ្យលោកមកនាមណ្ឌលធម្មយុទ្ធនោះហោង ។ ព្រះមហាសត្វ ស្តាប់
ខ្លួវភាសុរោធិសត្វហើយ ស្តេចឲ្យសំបុត្រទៅកាន់ខ្លួតដែលនាំមកនោះត្រ.
ឡប់ទៅវិញហោង ។ លុះត្រឹកឡើងចៅមហាសថថា នាអញនឹងផ្ញាញ់
អាចារ្យកែវដ្តព្រាហ្មណ៍នេះ នឹងចំណេះប្រជ្ញាវៃនៃអញហោង, ស្តេចឲ្យ
រណ្តាប់ខ្លួវមណ្ឌលធម្មយុទ្ធ ដោយគ្មានឯលិចស្រេច ។ ស្តេចវិទេហរាជ
បន្ទូលថា អ្នកឯងពាំងឡាយ ជាបុរសទុបនិក្ខិត្តនៃស្តេចមួយរយេនឹងមួយ
គេនឹងធ្វើម្តេច ? ក្តី នរណានឹងដឹងឡើយ ប្រយោជន៍អញឲ្យរក្សាព្យា-
បាលចុងមហាសថនោះហោង ។ លំដាប់នោះអាចារ្យកែវដ្តព្រាហ្មណ៍
មកនាមណ្ឌលធម្មយុទ្ធ ខ្លួវបរិវារឯងពាំងឡាយ ខ្លួវស្តេចមួយរយេនឹងមួយ
ហើយអាចារ្យកែវដ្តព្រាហ្មណ៍ឯង គេរមិលរមើលទៅដ៏សាងឯកើតបិត
នៅហោង ។

ឮដំណាលនោះ, តោធិសត្វសោត អ្នកស្រង់ខ្លួវតែតប់ ត្រឡប់នឹងទៅ

ខ្លួនតន្ទៅដោរអំពីព្រឹក ហើយបរិភោគខ្លួរភោជនាហារមានរុជារសនោះពី-
សារស្រេចហើយ អ្នកស្មៀនខ្លួរសំពត់កាសិកពស្ត្រ, ដ៏មានដំឡៃមួយ-
សែនដំឡឹង, ប្រដាប់ដោយគ្រឿងអលង្ការតាំងពួង ទៅដល់ខ្លួរភរាជកំង
ស្តេច ត្រមតាំងបរិពារច្រើន ឈរបិតនៅហើយ; ព្រះមហាសត្វស្តេច
បន្ទូលថា ម្នាលកូនសំឡាញ់នៃអាតុក ចូរចូមកឯអាយហោង, រីតោធិ-
សត្វអ្នកក៏ចូលទៅហើយ អ្នកថ្វាយបង្គំស្តេចបិតនៅឰដ៏ហានមួយ, ព្រះ-
មហាសត្វត្រូវបន្ទូលដណ្តឹងថា តាត មហោសធ ម្នាលចូមហោសធ
អើយ! តាតជម្ងឺខ្លួនោះ មានប្រការម្តេចខ្លះ? ? មួយទៀតសោត តើលា
ចូនហើយហ៎ះ? ចៅមហោសធក្រាបទូលថា ឱ! បពិត្រអើយ! តើលាតា
អញខ្ញុំនឹងទៅតាជម្ងឺខ្លួមណ្ឌលនោះចូនហើយហោង; ស្តេចបន្ទូលថា
ដូច្នេះគួរហោង, អញនឹងធ្វើម្តេច? តោធិសត្វក្រាបទូលថា បពិត្រអម្ចាស់
អើយ មានតែព្រះអង្គស្តេចគង់ក្នុងព្រះដំណាក់ឲ្យស្រួមហោង; ទើប
តោធិសត្វក្រាបទូលថា ឱ! បពិត្រអើយ! អញខ្ញុំនេះ គួរឲ្យចូនមណីរតន
ពិចិត្រមានថ្នាក់ច្រើនថ្ងៃ អញខ្ញុំមានចំណង់នឹងចង់លួងអាចារ្យកែវដ្ត-
ព្រាហ្មណ៍នឹងមណីរតន៍នេះ។ ព្រះមហាសត្វស្តាប់ហើយបន្ទូលថា តាត
ចៅចូមហោសធអើយ! ចូរទៅហើយ ចូរចូរវៀសរវៃមកហោង ទើប
ស្តេចឲ្យអាមាត្យយកកែវមណីរតន៍ថ្នាក់ច្រើនមកឲ្យ។ តោធិសត្វនោះ
អ្នកកាន់យកមណីរតន៍នោះហើយ អ្នកសំពះស្តេចលាចុះរួចទៅដល់លើ

រវេះប្រសើរ ខ្ញុំមនុស្សសេះសបរិសុទ្ធ ប្រដាប់ខ្នុរគ្រឿងមាសមានដំណៃនោះ
មួយសែនដង្ហើមហើយនឹងយោធាដែលកើតថ្ងៃមួយព្រមនឹងពោធិសត្វទាំង
មួយភាន់នោះមកជាបរិពារ ទាតេលាត្រឹកហួបថ្វាយនោះ ទៅដល់ទៀប
ទ្វារបន្ទាយនោះហោង ។ សូម្បីអាចារ្យកៅដ្ឋព្រាហ្មណ៍តែងតាថា ឥឡូវ
នេះ ចៅមហោសថ សមនឹងមកហើយហោង, អាចារ្យកៅដ្ឋព្រាហ្មណ៍
តែងតយតន់មើលមើលចៅមហោសថ នាទីឯងមកឯតទៅ ។ រីឯកនៃអាចារ្យ
កៅដ្ឋព្រាហ្មណ៍ ដូចគេដកឡើង លូតតួចហើយវែង ។ ហេតុនោះឯង
ដោយត្រូវកំដៅព្រះអាទិត្យដិត ជំហូរចេញទ្វារភ្នែកសស្រោកសំណក់
ឯតទៅហោង ។ សូម្បីពោធិសត្វសោត អ្នកលីលាទៅនឹងបរិពារច្រើន
ដ៏ឮស័ព្ទសូរគគុកគគឹក ដូចស័ព្ទសេកមហាសមុទ្ទ, ព្រះមហាសត្វក៏ក្រាក់
តតឿចំណាចនោះនៃកេសរកេសរាជសីហ៍ ច្រាសលែងម្រឹគ នឹងភ្នំកព្រឹ
សម្បុរឡើង ដល់ហើយឲ្យបើកទ្វារគ្រអាលចូលទៅកន្លែងព្រះនគរ ជំមាន
ដំណើរនោះទន្ទោលល្អ ដូចដំណើរកេសរីសីហ៍ចេញអំពីគុហាមាស ច្រាស
លែងម្រឹគាគណនាកា ។ ឯអស់ស្តេចមួយរយនឹងមួយ សឹងតែយល់លំអ
ស្រីសួស្តីរូបនៃពោធិសត្វហើយ រីអស់ស្តេចតាំងអម្ចាស់នោះ សឹងស្រ-
ដីថា ដូចយើងភ្ញាក់រឿងមកនេះឯង ចៅមហោសថជាកូនសិរីឱ្យកសេដ្ឋី
ឈ្មោះចៅមហោសថបណ្ឌិតអ្នកប្រាជ្ញ មានប្រាជ្ញាស្រួចស្រេចផ្តាច់អស់
ស្តេចតាំងសកលជម្ពូទីប ឥតអ្នកណាមួយស្មើបាន, អច្ឆរិយោ អត

អ្នកជាតំរបស់ពីរឡើយ, រីឯសំស្តេចតំណាងឡាយ សឹងបង្កើតនូវពាក្យសំដែងសរសើរនោះមួយសែនជាន ។ សោបិ ខោ គឺដោយនូវពិត សូម្បីថៅមហោសថនោះ ប្រាកដដូចជាព្រះឥន្ទ្រាធិរាជ អាចមានពួកទេវតាជាន់តាំងឡាយសម្រាប់ជាបរិវារក្រគាលមានប្រាជ្ញាឥតអ្នកស្មើ ល្អរុងរឿងពណ្ណរាយនូវឥស្សរសម្បត្តិបីតនៅ មានដៃកាន់មណីរតនៈទៅឆ្ពោះត្រង់អាចារ្យកេវដ្តព្រាហ្មណ៍, អនោសិ ស្រេចមានហោង ។ អាចារ្យកេវដ្តព្រាហ្មណ៍យល់នូវពោធិសត្វហើយ តុំអាចដើម្បីនឹងទប់អាត្មាភាពបានឡើយ ហើយធ្វើ បទក្កមនិ ថៅខ្លួលកំស្រដីនូវពាក្យថាដូច្នេះ បណ្ឌិត មហោសធ ម៉ែហថៅមហោសថអើយ ! រីឯងសឹងជាអ្នកប្រាជ្ញតាំង ២, យើងមកទៅនាហាននេះ ឥឡូវថៅលុះកំនាលកាលអម្បាលនោះហើយ សូម្បីមាត្រាត្រឿងបណ្ណាការ ថៅតុំគប្បីឲ្យដូនយើង, ហេតុអ្វីមកប្រការដូច្នេះហ៎: ? ។ ត្រានោះពោធិសត្វធ្វើយនឹងអាចារ្យកេវដ្តព្រាហ្មណ៍ថា ចូរព្រះស្តេងរមិលមើលនូវត្រឿងបណ្ណាការដ៏គួរនឹងថៅនាព្រាហ្មណ៍ជាអ្នកប្រាជ្ញ, ពោធិសត្វថា ដូច្នេះ ឥឡូវនេះ អញយកមណីរតនៈនេះគួរហោង, ព្រះស្តេងចូរយកមណីរតនៈនេះ, មណីរតនៈនេះ ជាលាភ នាមីហៅសភាពបង្ហូរដូច្នេះនោះគ្មានឡើយ ។ លំដាប់នោះ អាចារ្យកេវដ្តព្រាហ្មណ៍ យល់មណីរតនៈរុងរឿងពណ្ណរាយនូវស្មើនាដៃពោធិសត្វហើយ អាចារ្យកេវដ្តព្រាហ្មណ៍គិតថា រីមណីរតនៈនេះលាមក ឥឡូវនឹងឲ្យអញ

មែន ។ អាចារ្យកៅដ្ឋព្រាហ្មណ៍ថា ខោះយោមដូច្នេះ អញនឹងសណ្តែក
ដៃទៅ ប្រើឲ្យមកអញហោង ។

ពោធិសត្វថា ម្នាលអាចារ្យអើយ! ចូរអ្នកយកហោង, អញនឹងបោះ
ឲ្យអ្នក ថាដូច្នោះហើយ អ្នកទំលាក់ចុះលើពុងអង្កាលដៃអាចារ្យកៅដ្ឋ-
ព្រាហ្មណ៍ដែលសណ្តែកមកនោះ ។ លំដាប់នោះ មណីវត្តនោះ ហេតុតែ
ជួនពុំអាចនឹងឋិតនៅលើម្រាមដៃអាចារ្យកៅដ្ឋព្រាហ្មណ៍ ។ មណីវត្តនោះ
ក៏រមៀលធ្លាក់ចុះទៅខៀបព្រះបាទពោធិសត្វវិញ ។ អាចារ្យកៅដ្ឋព្រាហ្មណ៍
ហេតុតែលោភ ហើយគិតថា អញនឹងយកមណីវត្តនេះ គិតដូច្នេះហើយ
ក៏ទុនក្បាលចុះរើសខៀបដើរតោពោធិសត្វហោង ។ លំដាប់នោះ, ព្រះពោធិ-
សត្វ ក៏ចាប់ច្រកបាច់កអាចារ្យកៅដ្ឋព្រាហ្មណ៍ទំលាងដៃជាប់ មិនឲ្យដោះខ្លួន
បាន, ដៃមួយកាន់ក្រចឹ ហើយពោធិសត្វថា ម្នាលអាចារ្យអើយ ! ចូរអ្នក
ដោះខ្លួន អញនេះជាក្មេងក្តាត់ហោង, អញនេះគ្រាន់តែជាចៅនៃអ្នក
ប៉ុណ្ណោះ, ពោធិសត្វអ្នកថា ព្រះស្តេចកុំទុនចុះសំពះអញឡើយ, ពោធិ-
សត្វអ្នកថាអម្បាលនោះហើយ អ្នកឈ្លីមុខអាចារ្យកៅដ្ឋព្រាហ្មណ៍ផ្លាស់
ដល់ដី ឈ្លីទៅវិញទៅមក, អ្នកធ្វើឲ្យចេញឈាមតេញតាំងថ្ងាស, ពោ-
ធិសត្វថា ព្រះស្តេចជាអ្នកខ្លាំងអង្គាល ឲ្យបានត្រឹមចំអិនត្រឹមស៊ុកជាប់នៃ
អញ, អ្នកកាន់កអាចារ្យកៅដ្ឋព្រាហ្មណ៍នោះខ្ជាប់ ហើយជាក់ធ្លាក់ទៅមាន
ចម្ងាយមួយយោជន៍ ឧបដ្ឋាយបលាយិ ដោះខ្លួនហើយរត់ទៅ ។

រីឯមនុស្សពាល ឲ្យយកជាបរិភោគនៃពោធិសត្វ ក៏រើសយកមណ្ឌរតន៍នោះមក
វិញហោង ។ ពោធិសត្តសប្ប បន ឧដ្ឋេ ឧដ្ឋេ មា មំ
វិទ្ធថាតិ វាចំ ឃោសោ សកលបរិសំ ជានេត្វា អដ្ឋាសិ ។
ពោធិសត្វអ្នកថា ម្នៃអាចារ្យអើយ ! ចូរដោះឡើង ចូរដោះឡើង កុំសំពះ
អញនេះជាអ្នកប្រាជ្ញក្មេង, ម្តេចឡើយអាចារ្យឯងជាចាស់ស្តាំគ្រោង ក៏
មកសំពះឯអញវិញ សព្វពោធិសត្វនោះ ក៏ឮពួកជាដស់អស់បុរសជាបរិ-
ភោគដែលឋិតនៅឯក្រោយ ។ គេថាដូច្នេះ ឥឡូវនេះ អ្នកអាចារ្យគេវដ្ត-
ព្រាហ្មណ៍យើងមិញ គាត់ចាញ់ចុះដល់សំពះបាទដើងព្រះមហាសត្វ
ហើយ តើយើងនឹងធ្វើម្តេចទៅអេះ ? រីឯអស់បុរិភោគស្តេចមួយរយនឹងមួយ
សឹងធ្វើបញ្ចេញខ្លួនស្តាយពោធិសត្វនោះព្រមជាមួយផងឡើងហោង ។ សូម្បីរីឯអស់
ស្តេចពាំងអម្ចាស់នោះ ពុកស្តេចបុលទីព្រហ្មទត្តរាជជាចាញ់ ដូចគ្នាយល់
អាចារ្យគេវដ្តព្រាហ្មណ៍ ទនចុះសំពះបាទដើងព្រះមហាសត្វហើយ ។ គេ
ថា ឥឡូវនេះ អាចារ្យគេវដ្តព្រាហ្មណ៍ជាអ្នកប្រាជ្ញនៃយើងនេះ គាត់សំ-
ពះចាមមហាសត្វអ្នកប្រាជ្ញហើយ, អស់ស្តេចពាំងឮយថា ឥឡូវនេះ
យើងចាញ់គេហើយហោង, ព្រះមហាសត្វសមគាត់ទីដ៏មិនពុកដ៏រឹតយើង
ឡើយ, អស់ស្តេចពាំងឮយ ខ្លះឡើងដំរេះអាត្មាខ្លះ ។ ឆ្ពោះមុខ
ទៅគាន់ទត្តរបញ្ហាលទតរនោះហោង ។

(នៅមានត)

ប្រវត្តិព្រះតិន្ន ទីន សង្គ្រាមអសុរ

លោក ជ ល-ជិត នៅភូមិសាសនបណ្ឌិត្យ

ខំពន្យល់ជាភាសាឲ្យតាមសេចក្តីក្នុងគម្ពីរសោតត្ថទីបនី

វិនយដីកា សមន្តបាសាទិកាវណ្ណនា

(តមក)

ប្រវត្តិព្រះតិន្ន ទៀតដ
ដែលវាគអំណាច ទៅសូតិ
ទីងអសុរយ៉ុទ្ធ ដោយយោធា
ជួរមិត្រាល់គ្នា កំណត់ដំងឹង

ឲ្យគេសេពសោយដោយអាណិត គេមិនពេញចិត្តត្រេកត្រអាល
បែរជាកន្ធើអំតើពាល បណ្តាលកម្រោលចោលយើងអស់ ។
មកវ៉ុយ ! តួកយើងកុំរួញនៅ បបួលគ្នាទៅកេតុមតី
សម្លាប់កាប់គ្នាក៏ឲ្យអស់ កុំឲ្យវាស់ខ្ពស់សាគល ។
ពេលនោះព្រះបាទវេបចិត្តិ បង្គិតមិត្រក្រុមបង្គំពល
គោះគងខ្ទរស្គរខ្ទេមល្ហល ឮសំរៀមទ័ពជាប់សង្កាត់ ។
ខឹកឃើញរឿងដើមដង្រើមធំ ស្តេរយ៉ំអួលឯកបែកប្រមាត់
ប្រជុំយោធាជាសង្កាត់ សម្បើមពេកក្តាត់ញ៉ាប្រើថ្ម ។

ខ្លះលើកដំបងគងលើស្មា ខ្លះកងសង្ហារហោះវាគរី
ខ្លះកងសង្គិះដុះសេះញី ខ្លះលឺប៉ូវចៅមើលទៅទាយ ។
ខ្លះលើកក្រងារកាន់ដាវផ្លាក់ ខ្លះមាញកន្ត្រាក់ធមកស្ពាយ
ខ្លះខូចលួចមើលព្រៃលនាយអាយ បែរកាយនេបនិត្យដិតស្រីស្រី ។
ខ្លះដកព្រួញចេញពីបំពង់ ផ្គងផ្គងតម្រង់ផ្គងស្មារតី
សាតមើលបន្ទោះដាក់សរបី ក្រែងពេលក្រក្រីឲ្យដៃចាំ ។
ខ្លះលើកព្រះខ័នកាន់សំឡឹង សំឡក់ឈរធ្មឹងប្រឹងខន្ទ្រាំ
នេត្រាលក្រហមមុខក្រមជាំ ក្រឹតធ្មេញភ្លេញភាំមាំពេកក្រៃ ។
ខ្លះលើកដំបងផ្គងដាក់លី គ្រវាត់គ្រវីខ្លាយព្រឺក្បាលព្រៃ
ខ្លះឈរកាន់ព្រែងលំពែងដ៏យ ខ្លះឈរក្តាប់ដៃស្តីក្អេងក្អាង ។
ពួកខ្លះគាញសេះដុះតម្រៀប ឈរត្រៀបខៀបផ្លូវនៅសងខាង
ខ្លះដុះដំរីចង់រយាង រូបកងក្រអឺតស្មើតក្រអាញ ។
កកកើនច្រើនណាស់ដាសពិភព សុទ្ធសឹងតែខ្លាំងស្ទាត់ស្ទាញ
ចំណាប់ស្មាដៃក្រៃដំទាញ ប៉ង់ផ្ទាញសួគ៌ាទាំក្រែងធ្ល ។
ដៃកាន់អាវុធយុទ្ធភណ្ឌ ភប់ម៉ឺនកោនពាន់លាន់ទ្រហឹង
កាន់ខែលមាសពេជ្រស្រេចឈរធ្មឹង សំឡឹងខម្ពុះខ្ពោះសត្រូវ ។
លុះរៀបពលផងកងពន្ធឹក ក្បួនសឹកចាត់ចែកគ្រប់ផ្នែកផ្លូវ
ក៏លើកត្បូហ៍យោគ្រោះ តម្រង់ផ្លូវជេរគ្រប់យុទ្ធ ។

តកកុញរុញឡើងដើរដេញប្រជាក់ ប្រទើសគ្នាចាក់ចោតអាវុធ
ប្រហៀតជ្រៀតគ្នាក្លាតស្ទុត ហែកទឹកសមុទ្រផុតធើបច្រាំណា ។
ប្រិចប្រិចលេចចេញដូចមេរក្មៀង ដៃលកៀងហើរឡើងដំបូកហាន
តកកើនច្រើនជ្រុសហួសប្រមាណ ក្លាហានគ្មានឈប់គ្រប់ពួកក្រុម ។
រីឯពួកទាគកតំរិះខ្វៃ ដឹងពិតនិត្យទៅហៅគ្នាដុំ
ប្រុងខ្លួនពួនកាយកាយជាក្រុម ចង្កឹមធំធំជាអាវុធ ។
លុះឃើញអសុរត្បូលមកជល់ កំសុំរចល់ចាប់ប្រយុទ្ធ
ពួកខ្លះទើបធើបតាសមុទ្រ នាគដុតដោយពិសឫសសាហាវ ។
អសុរបន្ទើតសង្កើបវើ នាគចាំងឈ្លោលញ៉ាក់រួសរាំវ៉ៃ
ព្រួសទាំចឹករួតជាច់ទោអាវ អសុរកំពាកាប់សាច់សង ។
រីកសន្ធឹកទឹកមែកមែង មែកចេញជាផ្សែងលាន់គឹកកង
ក្មៀងផ្គរខ្លេះតាសរំពង ពាលផងមុះមុតប្រយុទ្ធចាក់ ។
ចាញ់កាប់ចាប់ក្រយូរញាយញ៉ឹក គគ្រឹកគគ្រែងជ្រែងគគ់ធាក់
ប៉ុន្តែគ្រប់គ្នាសូម្បីម្នាក់ មិនមានគ្រោះថ្នាក់ចាក់មែកសោះ ។
គឺគ្មានអ្នកណាត្រូវស្បែកជាច់ ឬមុតឆ្អុះសាច់ជាច់ស្បែកពោះ
ឬចេញលោហិតទ្បាហ្នឹងមោះ គ្មានបន្តិចសោះគ្រប់ៗច្រាំណា ។
គ្រាន់តែតក់ស្ទុតរន្ធត់ចិត្ត ចង់ជាយចង់មិតបកគេហាន
ដូចជាកូនក្មេងលេងកំសាន្ត ឥតមានហ្នឹងមោះគ្រោះថ្នាក់ឡើយ ។

នាគរាប់កោដិលានគ្មានគក់ស្មុគ ប្រយុទ្ធខប់ខល់មណ្ឌលត្រើយ
រាយច្រានសត្រូវឲ្យរើយ ឲ្យសើរើយគត់បកវកកន្លែង ។
ឯពួកអសុរកំរុលខ្លាំង ធ្វើយុទ្ធប្រធាំងច្បាំងឥតត្រែង
គ្មានដៃតាំងពីរទំប្រឹងប្រែង សំដែងចុះខ្លីរៀង។ ខ្លួន ។
តែពួកអសុរពេលជោគជ័យ ច្បាំងបានថ្លីដៃយ៉ាងម៉ាមួន
សំពងពួកនាគឲ្យងាកខ្លួន ច្រាសច្រាត់រត់ពួនអស់ព័ទ្ធវ ។
ហើយទាំងគ្នាត្រង់តម្រង់ចំ ស្ទុះស្រឡើងក្តុំពុំអាស្រូវ
ច្រើនពេកមេឃដិតងងឹតផ្លូវ តម្រូវតម្រង់ត្រង់សូតិ៍ ។
លុះឆ្ងងពីនាគងាកទៅផុត ស្រាប់តែព្រើបយុទ្ធនឹងគ្រុឌា
ប្រុងចាត់ស្លាត់ផ្លូវទៅត្រៀបត្រា ច្រើនឥតគណនាគ្នាណែនណាន់ ។
ក្រញ្ជៅក្រញ៉ាំដើងក្របួច ចំពុះមុតស្រួចដូចព្រះខ័ន
ដើងគាបស្លាបកាងកន្ទុយសកន់ ភប់ពាន់កប់ម៉ឺនកើនកោដិលាន ។
ហោះហើរប្រុងប្រៀបរៀបក្បួនសឹក គគ្រឹកគគ្រែងរែងក្អាហាន
លុះឃើញអសុរត្បូលដល់ហាន ត្រប់ប្រាណចាប់ចើកឆាកប្រយុទ្ធ ។
ស្ទុះហោះផ្លោះចឹកថ្នឹកស្លាត់ណាស់ ហើរច្រាសអមិត្រឥតមានស្មុគ
អសុរកំសប់ឃតបត្រុគ ប្រយុទ្ធដណ្តើមសម្បើមក្រៃ ។
ហោះផ្លោងគោងដើងឡើងដិះជាប់ ជុំវិញតាក់កាប់ចំងឡុះឡុយ
ខ្លះចាញ់ខ្លួសរខ្លួរគេញត្រៃ វិស័យដូចផុសត្បុះសង្ឃរ ។

មហាមេឃធំធឹតបិទជុំជិតភ្លឺ ដោយការចំបាប់កាប់ចាក់គ្នា
រលំព្រឹក្សាត្រែត្រដែងក្រឡា តស៊ូជាខ្លាំងខ្លីរៀងខេចក់ ។
អស៊ុរវុលបុកវុកខម្ចាយ ខម្ចុះធ្លុះធ្លាយរាយខម្ចាក់
ពួកគ្រុឌាប់ម៉ឺនកើនកោដាច់ ចាញ់ចាក់បបូរាចអំណាចឫទ្ធិ ។
លុះឃើញពួកគ្រុឌត់ដោះដៃ ចូលត្រៃលៃខ្លួនពួនភ័យតក់ក
ស្រេចខើចព្រះបាទវេបចិត្តិ បង្ខិតមិត្រខ្លួនផ្ទួនទៅខៀត ។
ឲ្យតែទៅមុខសម្រុកចូល តលជង្កឹមូលចូលជ្រែកជ្រៀត
តាមផ្លូវទៅតុំចំចង្អៀត ដល់ទៀតតំបន់កុម្ភណ្ឌសឹក ។
ស្រាប់តែតើបក់កំអុកកុម្ភណ្ឌ ច្រើនម៉ឺនច្រើនពាន់ឈរដួចស្លឹក
កាន់ដាវលំពែងសំដែងឫទ្ធ ស្ទាត់ថ្នឹកសឹកសាមសង្គ្រាមជ័យ ។
អស៊ុរយើញបោះកំពុះពារ ឥតឲ្យយូរយោរការតែដៃ
សំពង់កុម្ភណ្ឌជាន់បែកត្រៃ រិស័យដួចខ្លាហាក់ក្តាន់ ។
កុម្ភណ្ឌក៏គ្រាន់គ្មានខ្នែត់ គ្មានថយគ្មានត់ស៊ុះស្មុកខ្ពង់
ចាក់សបតបសាប់កាប់ជន្លាន់ សន្ធឹកខ្លរណន់ដួចខ្នុះ ។
អាខ្លះដៃដែកគ្រាប់ក្នែកប្រាក់ ក្បាលដួចកង្កែបក្រៃលាត្រដុះ
ខេញាក្តែងឡើងក្តីស្មើខ្នុះ ចោលជន្លេះទៅចំក្រុមសត្រូវ ។
អាខ្លះបុងសក់ដួចលំពែង គ្រវែងកេសាការតោរផ្លូវ
អាខ្លះក្នែកលៀនមុខក្រញូវ ងាកត្រូវដៃបស្រាស្រាក់ផឹក ។

មានកងសែ្មកស្តាន់ច្រើនពាន់នាក់ ញ៉ែញាក់លាក់ខ្លួនតាមក្បួនសឹក
កំសុះមកកាប់សំពួសទ្លឹក តគ្រឹកតគ្រែងវង្វែងគ្នា ។
ឯពួកព្រះបាទវេបចំត្តិ គ្មានកិតគិតក្រោយថយរួញា
សំពងកុម្ភណ្ឌខន់ចស្តា កុម្ភណ្ឌរុញគ្នាវត់ការត្រៃ ។
វត់ការប្រតន្ទជាន់កួនតួច វត់ផ្លូចចូលផ្លូវនៅតែភ័យ
អសុរដេញពន់ផ្តួលជាន់ថ្ម កុម្ភណ្ឌខន់ដៃផ្ទាស្រាប់ ។
អាខ្លះភ័យហួសជ្រួសជ្រាក់ជ្រោះ អាខ្លះតេចហោះផ្ទោះតាបតាប
ភ័យត្រែងអសុរវុលធ្វើបាប កម្ចាំងថយដាបបន្ទាក់មកដី ។
ថែកខ្មែកច្រាស់ព្រាត់វត់ព្រៃងព្រាត ចូលព្រៃញាតស្ងាត់លែងតបស្តី
វន្ទត់ស្ងួតស្ងាំងកាំងស្មារតី ខ្លាចបុណ្យចារមើបច្ចាមិត្រ ។
លុះបានទុកាសឈ្នះកុម្ភណ្ឌ អសុរច្រើនពាន់ភ័ចង្កិត
ចង្ខំពីខ្លួនផ្លូនទៅដិត គ្មានកិតគិតភ័យលែងតែស្មៀត ។
ខ្សែងស្រលើកខ្នុំទំសម្រុក ចូលបុកបោកផ្លូវតទៅខ្មៀត
មាតាវកាន់ណាន់ចង្កៀត ចូលជ្រៀតបៀតដល់យល់សួតា ។
ខ្លះហោះខ្លះហើរខ្លះដើរដី ខ្លះដិះដាំដិះសេះលា
ខ្លះវេចសំពាយស្តាយដបស្រា ខ្លះស្រែកឡូឡាខ្លាចមេឈ្លស ។
កំពុងតែលើកបើកសមយុទ្ធ ចេញផុតកុម្ភណ្ឌខន់ឥន្ទ្រិលស
ស្រាប់តែថែរខេត្រភ្លែតទៅយល់ ពួកពលយក្សយងំពង្សាហាន ។

ឈរកាន់លំពែងផឹកស្រែងដើងចាំ មានអាសមសួនចំនួនលាន
កោដិសែនម៉ឺនគាន់ជាន់ខប់ក្រាណា ឥតមានញាញើតដើតតយៃសោះ ។
នៅរបៀបរងើបដ្ឋដ៏ស្អាត ការតាសេដ្ឋាត់ទ័ពបួនទោះ
ខ្លះយាមក្នងដ៏ខ្លះលៃហោះ ហើរផ្លោះជ្រោះជ្រៅកំផង់ផ្ទៃភ្លាន ។
ឈរជ្រៀតបៀតប្រកកកស្រាចាប់ សន្ធឹកសន្ធាប់កប់មិនបាន
ខ្លះមានធំខ្ពស់ហួសប្រមាណ ក្បាហានច្រើនលោតរបូតក្បាន ។
ខ្លះកន្ធរធំជាត់មាត់សំញើញ កញ្ជើញាកែសែ្ប៉ះស្ពាយខ្នងិន
ភ្លាត់ជួលត្រឡប់ផ្តាច់ត្រឡិន សន្ធិនស្រមោចហិនហោចអស់ ។
ខ្លះចេញចង្កឹមពេមស្រម៉ូវ មុខខ្លួកក្រញូវមិនសូវស្រស់
ដេញចាប់ខ្លាញីស៊ីពាំងរស់ ខ្លះចាប់បានតស់មកព័ទ្ធខ្លួន ។
ក្បាលដែតក្តែកប្រាក់សក់ខង់ដែន ពេមដុះវែងវែងល្មមចូលតួន
ខ្លះមានសាច់ដុំធំមាំមួន ក្រអួនសម្រែកស្រែកក្រអៅ ។
ខ្លះកាន់ធ្នូសរល្អចំណាប់ ខ្លះចាប់ពាញក្រញាក្រញូខ្លួនទៅ
ខ្លះកាន់ដំបងផ្គងប្លំវៃថៅ ខ្លះបញ្ចេញក្តៅសុទ្ធតែយ័ន្ត ។
ឯតួកអសុរតេលអសោច ច្រើនដូចស្រមោចគ្មានបង្ខំទ់
យើញយក្សចោលចូលដូចត្រីមន្ត ប្រឹងតន់តែកាប់សត្វប្រញាយ ។
បរសេះដំរីដើញាក់ញ័រ ខ្លាខ្លែគេគ្រឹតសន្ធឹកភ្នាយ
ចូលបុកកុកចាក់ឥតលាក់កាយ ខ្លះប្រាយមិតបកកេគ្គីគ្នា ។

យក្សកំប្រើងកាច់សាច់សំពាង ខ្លះរងខ្លះរុលស្បុលឥតភា
ខ្លះជាញ់ផ្ទួងដាំងខ្ទាំងមហិមា តសុធាតក្រើករំពើកវៃក្រ ។
ស្មើរនឹងក្រឡាប់ផ្កាប់រលំ រលើងអស់កំពុក្រមក្រឹក្សវៃព្រ
ខ័ពខាំងសង្ខាងតឹតអស់ដៃ ដណ្តើមយកដំយកក្បាទី ។
ពួកយក្សកំណាចគាចដូចក្តើង សុទ្ធតែជាដើងពួកអាទ្រើ
ប្រើងតឹតចំចាប់កាប់វាស៊ី ប្រើឥតរំដួលច្រួលច្របល់ ។
ប៉ុន្តែដោយគុណបុណ្យឥទ្ធិរិទ្ធិ នៃវេបចិត្តិអង្គិចមតល
យក្សខ្លាំងពូកែបែរស្រេងល់ មិនអាចខល់ខល់តប្រតាំង ។
អស់ឫទ្ធិឥតបុណ្យគុណវិបត្តិ តាលយក្សខ្លាយខ្លាត់ខន់កម្លាំង
អស់រាបានចិត្តរឹតតែខ្លាំង យក្សតាំងកំងកាយក៏យមិនបែក ។
ដោះខ្លួនរបុំយដូចរុយហើរ ខ្លះទើរណើរព្រៃគ័យហួសគេក
ខ្លះត្រូវអស់រុលចំក្អែក ខ្លះដេកស្រាងខាងដើងគ្នំ ។
បក្សាពួកអស់រាជ្រុលដើងដេញ ដួលធ្លើមាត់ស្រេញឈឺចង់ប៉ំ
យក្សខ្លះក័យពេកដេកសម្ងំ ទឹកព្រួយថាម្តេក្រែងគេតាម ។
លុះពួកអស់រាចូលតដៃ ដណ្តើមយកដំយកតីយក្សយាម
បានហើយនាំគ្នាចេញទៅភ្លាម លើកទ័ពរុកតាមហានបពិត ។
ហោះហើរដើរឡើងទៅដើងគ្នំ ច្រើនក្រុមច្រើនកងធ្វងដនបព
ដោយបុណ្យកុសលដល់កំណត់ គ្មានហត់គ្មានអន់ខន់កម្លាំង ។

លុះខ្លើងដល់កំដុំតាតត(១) មកបំរះសឹកខប់ខល់ប្រចាំង
មួយខ្មៅតូចហានមានកម្លាំង តតាំងដណ្តើមសម្លាប់ក្រៃ ។
ខ្មែរនោះគឺកងព្រះមហាក្សត ចាំងបួនអំណាចរួមត្រួតដៃ
មានតួលយោធាគ្នាច្រើនក្រៃ ពីតដៃប្រយុទ្ធបើកឈុតច្បាំង ។
មហាក្សចាំងបួនជួនតែយឺត ធ្វើបាញ់ដោយប្រុងស្រាំង ។
កងតួលក៏បុកចូលរុកច្បាំង ប្រចាំងរៀងខ្លួនយ៉ាងមួនមាំ ។
ប៉ុន្តែមហាក្សមិនអាចចាត់ ការពារសង្កាត់ខ្លួនឱប្រុំ
ពួកតួលក្រាសក្រែលដែលប្រចាំ សង្កាត់ឱប្រុំក៏ឆ្ងាយខ្មែត ។
អស្សុរបានចិត្តពីតែតែដេញ ខឹកថាចំណេញគេញាមានស្មៀត
លើកតួលបដេលហានសួគ៌ខ្មែត ជ្រែកជ្រៀតតែងាន់ខ្លួនខ្លួនខ្លាយ
ខ្មែរតាចុងកាត់បិតមាត់ញាក រត់ជ្រែករកតួនខ្លួនឥតឆ្ងាយ
អស្សុរដេញចាប់តាមពីក្រោយ ខ្លួនតាខ្លាត់ខ្លាយតែយញ៉ាញ្ជាក់ ។
តើតក្តៅក្រហាយខ្លាយមេកេត ភ្លេញចាំងខ្លែលោកស្ទើរខ្ទើងភ្លាក់
នៅស្រុកខ្មែរតែកើតតែយក្សាក់ គ្រោះថ្នាក់អស្សុរលុះរុកពន ។
ឯព្រះលោកចាលចាំងបួនអង្គ ត្រូវបង់ជោគជ័យក្តីក្សាហាន
ខប់ខល់កម្លាំងច្បាំងតុំចាន កំប្រាយប្រាសប្រាណឥតបង្គន់ ។

• ភ្នំនៃលៅដុំថ្មៃភ្នំព្រះសុមេរុ មានភ្នំឈ្មោះយុគន្ធរជាដើម នៃលជាហានរបស់ចតុលោក-បាលមហារាជ ។

ទៅខ្លួលព្រះឥន្ទ្រតិនតិកត ដាមួយបាវម៉ៃថ្លួចញ្ចូនំ
បញ្ជាក់ប្រាប់ហេតុនាំណាតាមត្រង់ ខ្លួលគឿនព្រះអង្គឲ្យប្រញាប់ ។
ព្រះឥន្ទ្រថានស្តាប់សារឮភ្លាវ នៃទៅភ្លាក់ឆាវដែលថានប្រាប់
ស្តេចឡើងវែងយន្ត.. ប្រញាប់ បង្គាប់យោធាបញ្ជាទៅ ។
ឃើញពួកអសុរវុលឥតខ្លាច ដេញពួកទេវហោជរចាលលំទៅ
ទ្រង់គឿនយោធាឲ្យចូលទៅ សំដៅតតាំងប្រចាំឆ្នេរល់ ។
អសុរពេលខោះគ្រោះថ្នាក់ធំ ត្រូវមាំក្រុំខ្លួនផ្ទួនអំពល់
ព្រះឥន្ទ្រចាប់ចោកឥតរយោគយល់ ក្រហល់បកក្រោយថយប្រយុទ្ធ ។
ជ្រុលល្បីចរគេចខ្លួនតួនមិនទាន់ ព្រះឥន្ទ្រប្រសព្វគាន់ការុង
ចាប់ដើងត្រវត់ក្នុងសមុទ្រ ភ្នាក់ស្រុតផុតពីទីសួគ៌ហាន ។
ជ្រុះចុះរបុំយដូចរុយភ្នាក់ គ្មានទៅសល់ម្នាក់ចាំងម៉ឺនលាន
ពួកពលអសុរអន្តរធាន អស់ពីវិមានសួគ៌គ្មានសល់ ។
រួចស្រេចទើបស្តេចត្រាច់យោងយាត្រ វិលចូលច្រកសាខស្អាតខ្ពស់ល
សោយសុខសម្បត្តិសម្បើមផល លែងព្រួយអំពល់ខ្លួលហូរខ្លី ។
ឯពួកអសុរជ្រុលខ្លួនភ្នាក់ រងាញ់ញ្ជាក់ភ្ញាក់តក់ឆ្ងល
ដើមជ្រាណាបានពីជលាស័យ រត់ផាសដើងរៃចូលតិកត ។
បិទទ្វារខេត្តយ៉ាងមាំមួន ប្រុងការពារខ្លួនចាំងរៃថ្ងៃយប់
ទើបអស់ហូរខ្លីយកខ្លីយចំប្រប់ សោយសុខក្នុងភពដូចឆម្ងាត ។

តាំងតែតិរោះលុះឥឡូវ　　តែដល់ផ្លូវប្រទៀងផ្លាំ

ចិត្តពួកអសុរកើហានក្លា　　ឡើងកាប់ខៅតាតែកាលជង ។

ប៉ុន្តែដួងកាលមិនហ៊ានរុក　　ចូលលុកដល់ហានសួតនេះផង

ព្រោះខ្លាចព្រះឥន្ទ្រចេញសំតាង　　ឲ្យហ្នឹងដួចមុនស៊ុនខ្លួនឡើយ ។

ឯព្រះឥន្ទ្រវិញគេញាប់ប្រាជ្ញ　　ដឹងថាគេខ្លាចដូច្នេះហើយ

គេលចាំងមិនទៅខ្លួនឯងឡើយ　　នៅស្រណុះដើយតែក្នុងកំង ។

ប្រើតែបុត្រម្នាក់សក្តិសមសួន　　ជាតំណាងខ្លួនទៅតតាំង

ឯពួកអសុរតុំហ៊ានចាំង　　សំកាំងមិតចតរកហានខ្លួន ។

មួយទៀតព្រះឥន្ទ្រមិម្ចិតប្រាណ　　ឲ្យទៅទីហានខ្លាំងជាងបួន

បើពួកអសុរជ្រុលរុកកួន　　ចៃខ្លួនឯងកយល់ចេលំតែ ។

ព្រោះខ្លាចព្រះឥន្ទ្រសង្កិនជាក់　　ចាប់ចោកទម្លាក់ធ្លាក់ទឹកហ្នត់

ខ្លាចនេះខ្លាចងាប់ជាប់ជាល្បត់　　ខ្លាចហួសកំណត់ព្រោះបារមី ។

តោះបីយ៉ាងនេះកិតសុរ　　រុករុលចង់ពៀរដោយប្រក្រតី

តែងតែនាំពលខ្លើងផែនដី　　ពាសេចិទ្ធសេរីរៅខៅតា ។

ប្រសិនពួកគេមានកម្លាំង　　កំអាចតតាំងចាំងសេនា

នៃមាតគ្រុឌយក្សក្រុមណា　　ឥតមហាកជាតាំងបួនបាន ។

សម្រុកលុកដេញខេតនិករ　　រកែវប្រចលំពេញសួគ៌ហាន

ទាល់តែព្រះឥន្ទសំពងច្រាណ ទើបវាត់វិលភ្លាមគ្នានសេសសល់ ។
ប្រសិនជាខ្សោយថយកម្លាំង កងទ័ពចម្បាំងបុះខុតិល
ចូលដល់ត្រឹមនាគកំរចល់ ច្របល់គេចថយក្រោយគ្រប់គ្នា ។
ដួនបានឈ្នះនាគជាកចាញ់ត្រូវ ឬចាញ់ប្រយុទ្ធក្តីមួយណា
ឬកំឡាយដល់តលយក្ស ឬចាញ់ឯជាតំងបួនអង្គ ។
ក៏វិលមឹតបកវាកវែងឆ្ងាយ វង្វេងត្រាត់ច្រាសវិនាសបង់
វាត់ចូលនគរគ្មានបង្អង់ តម្រង់ច្រមុលគ្នាចូលទី ។
បើតាមសំនួនក្សត្តគម្រោ ដីកាសារគ្តីបនី
គោលដល់ប្រទេសខ្វែរគាតី ដែលជាធានីតំងពីរពាត ។
គឺតំងអសុរតំងទេវតា មានដែនសីមាជាតិសង្ឃ
មានកជធានីកំពែងដំគ ព្រះបិទឥតស្បើកលើកតុំបាន ។
បើពួកអសុរវុលសម្រុក ចូលលុកបុកគ្នាយដល់សួគ៌ឋាន
អស់ពលទេវតាតំងប៉ុន្មាន ច្រាយច្រាណច្រាសចូលកងនគរ។
តែបិទដំគព្រះនាកំពែង ស្រេចហើយកំលែងក្រែងក្តីមរណ៍
តុកជាអសុរប្រឹងត្រជរ ក៏ចូលនគរតុំបានឡើយ ។
ឯអសុរវិភ្លាកំដូចបោះ ប្រសិនមានគ្រោះមកដល់ហើយ
គឺបើចម្បាំងកម្លាំងស្បើយ កំមឹតរកគ្រើយពីតំងខ្លួន ។

ប្រាសប្រាណតែបោលចូលខាងក្នុង កំពែងខ័ណ្ឌក្រុងដ៏ម៉ាំមួន
ទ្វារបិទជិតជាប់គ្រប់ទាំងបួន ស្រែចហើយរួចខ្លួនជាក្សេមក្សាន ។
ទោះបីខេត្តតាពប់កោដិថ្ងាយ ក៏ទីធំខម្លាយៅតុំបាន
ដូច្នេះនគរទាំងពីរហ៊ាន ឈ្មោះថាសុខសាន្តគ្មានចម្បាំង ។
តីក្សេមទាំងប្រាណក្សត្តទាំងកត គ្មានព្រួយពីខប់ខល់ប្រទាំង
ម៉ោចង់រុះរើធ្វើចម្បាំង លុះណាតែតាំងខ័ណ្ឌចេញក្រៅ ។
បើនៅខ័ណ្ឌក្នុងកំពែង អស់ពីតតិតក្រែងលែងក្តួលក្តៅ
សប្បាយកាយចិត្តឥតហ្មង់សៅ សប្បាយនិត្យនៅដៅសុខសាន្ត ។
រឿងនេះស្ទះចប់បញ្ចប់ស្តី សូមលោកប្រុសស្រីមិត្រអ្នកអាន
យកជាអារម្មណ៍ផ្សំកំសាន្ត ខ្ញុំបន្ទន់ប្រាណលាសិនអីយ ! ។

-ចប់-

ភាសាសាស្ត្រ និង អក្សរសាស្ត្រខ្មែរ

រៀបរៀងដោយ ឧ. តាម

(តមក)

អក្សរសាស្ត្រខ្មែរ ខ្មែរធ្លាប់ចែចួន
ឲ្យជាទន្លាប់ខ្លួន តង់រង់តម់តម់ ។
ព្រោះអក្សរជាតិ ដោលជាតិប្រាកដ
អក្សរលត់ ជាតិក៏រលាយ ។

ប.ព.

ជំពូកទី ១

តារាងភាសាជំពូកនេះខ្លះ

ភាសាអារក្ស	ភាសាសាមញ្ញ
កាជាំង	ប្រាក់មួយរៀល
តន្ទេំជាក់ក	ចេក
អការសោហារ	ស្រា
ក្នុងបាយ	មនុស្សឈឺ
កន្ទើញ	សាច់ជ្រូក

ការសិក្សាខ្ទង់ភាសាអារក្ស មានច្រើនទៀតទៀត តែពេលនេះ ខ្ញុំលើកយកតែប៉ុណ្ណេះមកជាឧទាហរណ៍ ។

១)– ចំណែកមន្តអាគមភាសា ក៏នៅមានប្លែកពីភាសាអារក្សដែរ ។

មុនគេសេកជាស់មន្តអាគមអ្វីមួយគេថា ឱម សិន ដែលជាតំណាងឈ្មោះ ព្រះវិស្ណុ.សិវ នឹងព្រះនាកយណ៍ ។

ភាសាចំពូកនេះ មិនមែនមានត្រឹមតែសម័យព្រហ្មញ្ញាសាសនាចូលមកប្រទេសយើងទេ ឬក៏តាមតែការនឹកឃើញរបស់មនុស្សទេ សូម្បីតែនៅកន្លងភ្នុសម័យ ក៏នៅតែមានដែរ តែមន្តអាគមរបស់ព្រះភុទ្ធ មិនមានប៉ះពាល់ដល់ដីតែសត្វណាមួយឡើយ ។

ខ. កឹ ការណំ ឃដេសិ ឃដេសិ អហមម្បិ តំ ជានាមិ។

ចុះភាសាមន្តអាគមមានតែខ្មែរ ឬសាសន៍ដទៃទៀតមានដែរ ? មានស្ទើរតែគ្រប់ភាសា ។ អាមេរិកាំង សៀម, ឃួន, ចិន, ឥណ្ឌៀ មានដូចគ្នាតែខ្ញុំមិនយកពាក្យពាំងនោះមកជូន ព្រោះមិនសូវមានការសំខាន់ ។

៨- សិល្បភាសា (Art of Language)

សិល្បភាសា សំដៅយកសិល្បដែលចំនួសភាសា ។ សិល្បមែបនេះ គេមិនចាប់សរសេរតួអក្សរច្រាប់ដល់ខ្សែជនទេ ព្រោះថាសិល្បនោះ អាចសំដែងច្រាប់សិល្បនេះ មានន័យយ៉ាងនេះ សិល្បនោះមានន័យយ៉ាងនោះ ។

ប្រទេសកម្ពុជា ជាប្រទេសកាន់ព្រះភុទ្ធសាសនា សិល្បករកសាងព្រះភុទ្ធរូប មិនចាប់ចាំកែអក្សរច្រាប់គេថា នេះជាព្រះភុទ្ធទ្រង់ចំណាំថ្កាត្រនេះសំដែងធម្មចក្រ គេគ្រាន់តែកសាងឲ្យទៅតាមភុទ្ធចរិត គេអាចយល់

ថាខាងព្រះពុទ្ធរូបនេះ គេធ្វើតំណាងព្រះអង្គតាមពុទ្ធចរិតខ្លះ ឬក៏តាមពុទ្ធប្រវត្តិខ្លះ ។

ដូចគួយ៉ាងព្រះពុទ្ធរូបគង់ពត់ព្រះកែន មានព្រះហស្តស្តាំនៅលើព្រះហស្តឆ្វេងដាក់នៅលើព្រះកែន ។ ព្រះពុទ្ធរូបបែបនេះ អាចសន្មតថាខាង ថា ព្រះពុទ្ធរូបទ្រង់សមាធិ ឬ វិតិកមុទ្រា ។

ការកសាងព្រះពុទ្ធរូបមាន ៩ បែប តែខ្ញុំលើកយកតែការកសាងព្រះពុទ្ធរូបមួយនេះជាឧទាហរណ៍ ។ ការរចនាព្រះពុទ្ធរូបបែបនេះគេអាចសំគាល់បានថា ព្រះពុទ្ធទ្រង់សមាធិ ចុះមើលបានតែគេស្គាល់ថា "ទ្រង់សមាធិ" ? មកពីសិល្បៈប្រាប់ព្រះនាមព្រះពុទ្ធ ។

មួយទៀតសិល្បៈខាងស្លាន គួយ៉ាងដូចមុខយក្ស មុខឥសី តើគេមានសរសេរអក្សរប្រាប់ថា នេះមុខយក្ស នេះមុខឥសីឬទេ ? អត់មានទេ ! ។ ចុះមើលបានតែគេស្គាល់ជាមុខយក្ស មុខឥសី ? មកពីសិល្បៈប្រាប់ឲ្យស្គាល់ថា មុខដែលគួរឲ្យខ្លាចក្រអើមក្រអាម គេថា "មុខយក្ស" ។ បើឃើញមុខញញឹមរួចបែកខ្ចែងដូចកន្ទុយត្រីប្រា គេស្គាល់ឮៗថា "មុខឥសី" ។ បើឃើញមុខ ៤ គេអាចថាមុខ "ព្រហ្ម" ។

សិល្បៈកម្ម (Ballet) ដូចរបាំព្រះរាជទ្រព្យ បង្ហាញការយ៉ាងណា គេអាចដឹងថា ល្ខោនពាក្យនេះឬស្តែងរឿងនោះ ។ គេមិនសូវប្រកាសឈ្មោះរឿងដែលត្រូវពាក្យនោះទេ តែសម័យក្រោយមក មនុស្សយើងមិនសូវយល់

សិល្បការសា មេរ៉ាំរហើយគេចោះតុម្ពកម្មវិធីចែក ។

សិល្បសាកាខាងព្រហ្មញ្ញសាសនាវិញ ដូចជាស្នាធម៌ដូង សាជម ជាដើម គេត្រាន់តែយើញវត្តុទាំងនោះ គេអាចឲ្យឈ្មោះថា « ស្នាធម៌ សាជម » ។

ការលើកយកទាហរណ៍មកជាឧស្សាន: ក៏គួរយល់បានថា សិល្ប វចនាទាំងនេះ គេអាចយល់បានដោយមិនបាច់មានពាក្យសំដីច្រើនប្លែយ ដោយហោចទៅទៀត គេអាចសំគាល់បានមនុស្សសាសន៍ប្លែក ។ គ្នា ដោយគេមើលសំលៀកបំពាក់គ្រឿងអលង្ការ ។

ជំពូកទី ២

ភាសាខ្មែរតាមឯរុត្តិសាស្ត្រ

ដូចខ្ញុំបានបរិយាយមកក្នុងចំពូកទី ១ រួចខ្លះមកហើយ អំពីកំណើត ភាសាខ្មែរ តែខ្ញុំមិនបានបរិយាយឲ្យច្បាស់លាស់ ។ ឥឡូវខ្ញុំសូមបែរ ទៅខាងភាសាសាស្ត្រខ្មែរវិញ ។ ដើម្បីឲ្យស្រួលនិងចំយល់នូវបញ្ហាភាសា សាស្ត្រខ្មែរ ខ្ញុំសូមលើកប្រស្នាមួយ ព្រោះខ្មែរយើងមានចំនួនច្រើនថា ភាសាខ្មែរមានដើមកំណើតមកពីភាសាជាលី ឧដ្ឋ សំស្ក្រឹត បើលោកអ្នក យល់យើញថា ដើមកំណើតភាសាខ្មែរយកមកពីជាលី-សំស្ក្រឹត ចុះតើ ជនជាតិឥណ្ឌៀដែលនាំសាវ្យធម៌ចូលមកប្រទេសខ្មែរ សម័យគោកធ្លក

នៅសតវត្សរ៍ទីប៉ុន្មាន ? ចុះជនជាតិគោកធ្នក មានមុនឥណ្ឌៀចូលមក ឬខាងក្រោយ ?

បញ្ហានេះអាចបញ្ជាក់ឲ្យយល់ច្បាស់ថា ឥណ្ឌៀនាំអារ្យធម៌ចូលមក ប្រទេសកម្ពុជាសម័យសតវត្សរ៍ ២ ក្រោយសម័យគ្រិស្តាំឲ្យ តាំងអាណាខែត្រនៅខនតុំ ។ ជនគោកធ្នក គេមានភាសានិយាយរួចទៅហើយ តែនៅមិនទាន់មានអក្សរសរសេរនៅឡើយទេ ។ ចុះគេនិយាយភាសាអ្វី ? ពិតជាភាសាខ្មែរ ។ បើសិនជាជនគោកធ្នក មានក្រោយជនជាតិឥណ្ឌៀនាំអារ្យធម៌មកនោះ ខ្ញុំហ៊ានពាយថា បៃបត្នានជាតិកម្ពុជាទេ ឬប្រហែលជាសត្វវិញ្ញេះ ខ្មែរយើងនិយាយភាសាដូចឥណ្ឌៀ ។ តែថាសម័យឥណ្ឌៀនាំអារ្យធម៌មកប្រទេសខ្មែរជនជាតិខ្មែរគឺខ្លួលយកអារ្យធម៌នេះ មកឆ្លងជាអារ្យធម៌ខ្មែរឡើង ហើយខើបភាសាបាលី សំស្ក្រឹត ផ្សាយឥទ្ធិពលលាយឡំចូលជាមួយភាសាខ្មែរឡើង ។

ដល់ប្រទេសកម្ពុជាមានភាសាហើយ តែមិនទាន់មានអក្សរជារូបភាពឲ្យងាយស្រួលកត់ត្រាចំណាំទេ ។ ចុះសម័យនោះខ្មែរយើងយកអ្វីជាអក្សរសាស្ត្រសំរាប់កត់ចំណាំ ? នេះតាមអ្នកនិរុត្តិសាស្ត្រ (étymologists) ថា គេច្រើនតែយកវត្ថុ ឬការក្រិត ឆ្លាក់ចំណាំចំពោះរឿងហេតុអ្វីៗ ។ យើងតំនិត្យមើលខាងព្រះពុទ្ធសាសនា ដែលយើងមិនទាន់មានមាំងប្រើ តើគេអាចចំណាំមាំងដូចម្តេច ? ត្រង់នេះគេយក

ស្រមោលដាយ លក្ខណ៍ ដូច្នេះហើយ ចានជាព្រះសង្ឃមាន «កាត្រ» ជាគ្រឿងសំអាង ដែលសត្វលៃគេ ហៅថា «ឆាយា» ។

មួយទៀត យើងឮគេនិយាយឬទេ ? ដូចគេសួរគ្នាគេថា :

មីងយ៉ុះ : យី ! យាំន់ ! យាំន់ ! កូនឮសុខទៅគេបង្អស់កើតខែណាទេ, យាំន់ឯងចាំឬទេ ?

មីងយ៉ាំន់ : ឃ្យូ ! ឯងគិតមើល៍ គ្នាដូចជាភ្លេចដែរ តែមើល៍ឆ្នាំទៅ គេធ្វើបុណ្យបញ្ចុះសីមាវត្តចំបក់ឆ្នាំជូត វាមិនហ៊ានទៅមើលតិចបុណ្យនោះទេ វាខ្លាចក្រែងធុន ។

មីងយ៉ុះ : មែនហើយ វាកើតឆ្នាំជូតមែន ខែដែលយើងទៅបេះត្រកួនទៅត្រាំងត្រើងនោះណា ។


យើញថា ស្រីចាំងតាំរនេះ ឃកតិធីបុណ្យបញ្ចុះសីមា ឃកការបេះត្រកួន កំណត់តេលវេលា (ខែឆ្នាំ) ។

មួយទៀត តាមភាសាបាមបាថា (សូមកុំយកជាការប្រមាណ គ្រាន់តែជាគ្រឿងតិចារណា) គេថាឮឮ ឃកការក្រិតឈើ ឬ ឫស្សីជាគ្រឿងចំណាំជំនួសអក្សរ ដូចជាគេផ្ញើសំបុត្រទៅការលុយគេ គេត្រូវធ្វើ "ឫស្សីមួយកំណាត់" ចានន័យថា "ការលុយ" រួចអ្នកដំណាក់ចំណុលមិនចាន់មានលុយសង គេត្រូវដុតចុងឫស្សីម្ខាងផ្ញើទៅម្ចាស់លុយវិញ ដោយសំដៅឃកន័យថា "គ្មានលុយទេ" បើម្ចាស់លុយបង្ខំការឲ្យចានតែ

ជាន ត្រូវជុតចុងខ្ចាងខៀត ហើយផ្ទៀងកូនបំណុលដែលជានន័យថា "ត្រូវតែសង" ។ ការស្មានរបស់ខ្ញុំ ដូចជាត្រូវដែរ តែការលើកយក ឧទាហរណ៍មកដូនេះ សូមលោកទុកថាជាល្បាយផ្សំក្នុងការស្រាវជ្រាវអក្សរសាស្ត្រខ្មែរទៅចុះ ចាំថ្ងៃណាយើងដឹងពិតថា តួកត្តងគួយ គេច្រើរបៀបនេះជាអក្សរសាស្ត្រ ដូចខ្ញុំជានអធិប្បាយមកខាងលើនេះ សូមយកជាការទៅចុះ ព្រោះសម័យឥឡូវ យើងមិនទាន់មានអ្នកបច្ចេកទេសខាងការស្រាវជ្រាវអក្សរសាស្ត្ររបស់ជនជាតិក្នុងគួយ តាមរបៀបរូបអក្សរសាស្ត្រ (Pictography) ដូចជាតិអេហ្ស៊ីបជាដើម ។

ខ្ញុំសូមលើកយកអក្សរបៀបអេហ្ស៊ីបមកធ្វើជាឧទាហរណ៍រូបនេះ 

អេហ្ស៊ីបថា "ខា" (Kha) ប្រែថាផ្កាឈូក ហើយគេធ្វើដូចរូបផ្កាឈូកឬមានន័យថាលេខ ១.០០០ ។ ពាក្យថាដ្យេបា (dje ba) មានន័យថា ម្រាមដៃ ឬលេខ ១០.០០០ រួចគេធ្វើម្រាមដៃ ។ ពេលដែលគេត្រូវសរសេរផ្សំជាពាក្យជាសេចក្តីអ្វីមួយ ដូចជាឧទាហរណ៍នេះ(១)




ជានន័យតាមទស្សនន័យមថា "គោ

១- រូបអក្សរនេះ ចម្លងចេញមកពីសៀវភៅ (The Gift of Language by Margaret Schlauch P. 38)

គ្រាមដៃ ៣ ភ្លាំឈូក ៤ ។ តែដូចខ្ញុំបានពោលរួចមកហើយថា គ្រាមដៃ ១០.០០០ ភ្លាំឈូក ១.០០០ដូច្នេះត្រូវអានថា «គោ ៣៤.០០០ក្បាល»

ឯរូបអក្សរសាស្ត្រចម្លាក់ជនជាតិអាមេរិកាំងវែស្យកក្រហម នៅដ្ឋមិស្សួរខាងលើ (Tribes of the Upper Missouri) សរសេរដូច្នេះថា(១)



Reading: We are in a camp of thirteen lodges (1); encamped on a creek above the forks (2); started hunting with eight horsemen (3); (each symbol ɔ represents one horseman); on the way slept out two nights (4); traveled in the direction indicated by . . . ɔ (5); found buffalo (6); behind the second creek from the camp; killed some and made travois, or sledges (7); and slept but one night (8) on our return home.

អានថា: លេខ១ យើងនៅក្នុងជំរំដែលមានបង្ហួច១៣ ។ លេខ ២ យើងបោះជំរំនៅកែ្សរប្រឡាយខឹកមួយ ។ រួបលេខ ៣ ចាប់ផ្តើមបរបាញ់ជាមួយអ្នកជិះសេះ ៨ នាក់(សញ្ញា ɔ នេះមួយៗ ចំនួនអ្នកជិះសេះម្នាក់) ។ រួបលេខ ៤ ទៅតាមផ្លូវ ដេកផ្លូវ ២ យប់ ។ រួបដល់ ៥ ធ្វើដំណើរឆ្ពោះទៅកាន់ទិសដោយប្រើសញ្ញា . . . . ɔ ។ លេខ ៦ ប្រទះសត្វក្របីនៅខាងក្រោយ

១– រូបនេះ បម្លងចេញមកពីសៀវភៅ Man Culture and Society P. 217 ។

ប្រឡាយមីតខ្ទី ២ ពីដំរៀ ។ លេខ ៧ សម្គាល់ក្រមខ្លះ ហើយខ្លះទៀត
យកធ្វើជាតារ ។ លេខ ៨ ហើយដេកផ្ដូរមួយយប់ដល់ ពេលដែលយើង
ត្រឡប់មកផ្ទះវិញ ។

សូមតិចិត្តមើលសញ្ញានេះមួយទៀត ។



ស្នាមគំនូសនេះ ចិនយកប្រើថា « ភ្នំង » ប៉ែចិនចង់
សរសេរថាភ្នំង ត្រូវសរសេរដូច្នេះ ។ ពាក្យនេះ ចិន
ថាភ្នំង សមណាស់ ដោយយើងមើលឃើញអណ្ដាត
ភ្នំងត្រលាច្បើនលើ ។

ឥឡូវយើងបែរមកគន្សរសាស្ត្រខ្មែរវិញ ។ តាមប្រភពខ្លះថាអក្សរ
ខ្មែរយកបែបមកពីឥណ្ឌា ខ្លះថាយកអក្សរបែបឥណ្ឌាមកឆ្លងក្រវៀ ហេតុ
ចាំងពីរនេះមិនខុសគ្នាប៉ុន្មានទេ តែអក្សរបែបឥណ្ឌាមានច្រើនយ៉ាង ។
នៅប្រទេសឥណ្ឌាបែកខាងដើង គេប្រើអក្សរមួយបែបឯងដ្រុងៗ ដែល
ជាកេរ្តិ៍តំណនៃអក្សរខ្មែរខាងតី ឯអក្សរដែលថាខ្មែរយកលំនាំតាមនោះមាន
រូបទ្រង់ទ្រាយមូល ជាអក្សរដែលគេប្រើនៅឥណ្ឌាបែកខាងត្បូង(ខក្ខិណ-
បថ) Deckan ឬជាអក្សរ «ក្រាន្ថា» នៅក្នុងសតវត្សទី ៦ ។

គេនឹកឆ្លៀថា ភាសាដ៏ស្រួតជាភាសាដំបូងជនជាតិឥណ្ឌា ដែល
ជាអំបូរ ឥណ្ឌា-អឺរ៉ុប (Indo Europrean) ដែលជាមូលហេតុ ។ ចុះ
ភាសាខ្មែរមើចមិនចូលទៅក្នុងអំបូរ ឥណ្ឌា-អឺរ៉ុប ផង? លោក អៀ-

គេហ៊ីសសរសេរថា "ភាសាខ្មែរមានភាគ្យសំស្ក្រឹតនឹងបាលីលាយបញ្ចូលផងជាច្រើនក្រៃលែង ប៉ុន្តែភាសាយើងមិនមែនទៅក្នុងអំបូរ ឥណ្ឌូ-អឺរ៉ុបទេ ព្រោះបើសិនជាយើងមានដូចខ្លះនឹងភាសាក្នុងត្រកូលនេះ គ្រាន់តែជាន៊ីយ៉ាណាសាស្ត្រ (Sémantique) គឺខាងសេចក្តីរបស់ពាក្យ (Vocabulaire) តែខុសគ្នាខាងសូរសាស្ត្រ (phonétique) គឺខាងការបញ្ចូលសំឡេង រីឯអានហ៊ីយ៉ាខុសគ្នាខាងរូបសាស្ត្រ (morphologie) គឺរឿងប្រើពាក្យ សំរេចរូបពាក្យ គឺខាងវេយ្យាករណ៍ (Grammaire) ។

ភាសាខ្មែរយើងនៅក្នុងអំបូរភាសាមួយហៅថា អំបូរ-មន-ខ្មែរ (Le Cambodgien appartient à la famille des parlers indochinois appelés Mon-Khmer) (France Asie numéro spécial 114-115-P 428.

យើងអាចសន្និដ្ឋានបានថា ភាសាខ្មែរពិតជាភាសាខ្មែរ មិនទទួលពីគេ តែជាអក្សរខ្មែរមានលំនាំតាមឥណ្ឌៀ ។

ដើម្បីវិភាគយល់ច្បាស់នូវភាសាសាស្ត្រខ្មែរ យើងត្រូវតែសិក្សាអក្សរសាស្ត្រឲ្យជ្រៅជ្រះដែរ ។ ចុះការសិក្សាភាសានេះមានប្រយោជន៍ដូចម្តេច ? ពាក្យថាភាសា ខ្ញុំបានពន្យល់ពីមុនរួចមកហើយ តែពេលនេះខ្ញុំនិយាយពីភាសាទៀតដោយយល់យើញថា ភាសានឹងអក្សរជាប់ទង្គិច ។ ខ្ញុំសូមលើកយកភាគ្យថា "សេះ" ខ្មែរយើងមានសំឡេងថា "សេះ" បារាំងថា (Cheval) ឯអង់គ្លេសថា «Horse» ភាសាទាំង ៣ នេះ មាន

លំនាំសំឡេងផ្សេងៗគ្នា មានលំនាំអក្សរផ្សេងៗគ្នា តែសំដៅយកសត្វតែមួយ ដែលខ្មែរឲ្យឈ្មោះថា «សេះ» តែសំឡេងនិងលំនាំពាក្យបែបនេះ មនុស្សពាំងពាក្រមនេះផ្សេងៗគ្នា ។ ការសិក្សាខ្លួវភាសាត្រូវតំណាន់ដូច្នេះ ៖

១- ភាសាសាស្ត្រ (Philologie) គេរៀនភាសាស្ត្រ ដើម្បីឲ្យយល់ច្បាស់ខ្លួវប្បធម៌របស់ជាតិ គឺអក្សសាស្ត្រ·ភាសាប្បកិសាសនា ។ ដូចគេរៀនភាសាចាក់ឯ អង់គ្លេស គេមុខតែចេះយល់ខ្លួវការប្បធម៌របស់សាសន៍នោះ ។ បើយើងរៀនភាសាយល់ច្បាស់ខ្លួវឫសគល់ភាសាហើយ យើងមុខជាចាន់ដំនាញខាងភាសា (Linguistic) ។ ការដំនាញខាងភាសានេះ គេសន្មតថាជាអ្នកដំនាញខាងវិទ្យាសាស្ត្រនិងភាសាសាស្ត្រ ។

២- វិបីភាសាសាស្ត្រ (Linguistic) ការសិក្សាឲ្យស្ទាត់ដំនាញខាងសំដីនិយាយរបស់មនុស្ស ហើយនិងរសាកណាភាសា ។ ការសិក្សាខាងវិចីភាសាសាស្ត្រនេះ គឺសំដៅយកការសិក្សារដើមកំណើតភាសា ធម្មជាតិភាសា វេយ្យាករណ៍ភាសា របៀបនិងការប្រែប្រួលនៃភាសា ការសំខាន់ចំផុតក្នុងវិចីភាសាសាស្ត្រ គឺត្រូវសិក្សាឲ្យយល់ច្បាស់ខ្លួវ សព្ទវិទ្យា, សត្វសាស្ត្រ សណ្ឋានវិទ្យា មូលវិទ្យា និងវេយ្យាករណ៍ ។

ក)- សព្ទវិទ្យា ឬ សូរសាស្ត្រ (Phonétique) សូមកុំច្រឡំនិងពាក្យថា សត្វសាស្ត្រ ។ សព្ទវិទ្យា ការសិក្សាខ្លួវការបញ្ចេញសំឡេងភាសា និងវិញ្ញាណណាខ្លះ ដែលពាក់ព័ន្ធក្នុងការបង្កើតឲ្យចេញសំឡេង

ត្យញ្ជន: ស្រែលយល់ប្លាស់ដល់សោតប្សសោតអ្នកស្តាប់ ។ ឧបមា ថា ត្យញ្ជន: កើតក្នុងហាន:នេះ ហាន:នោះ ដូចជាកណ្ដាដ: តាលុដ: ជាដើម ។

១)- សំព្ធសាស្ត្រ (Phonologie) ការសិក្សាខាងសំឡេងរបស់ភាសាដែរ តែថាមានការសិក្សាពិសេសដូចជាសារតាភាសានឹងទ្រឹស្តីភាសា ដែលសំឡេងភាសាត្រូវប្រែ ឬសម័យណាគេប្រើភាស្ស ។ ការសិក្សាទូវសំឡេងភាសានេះ ជានិច្ចខាងអក្ខរាវិរុទ្ធដូចគ្នា តែដល់អានផ្សេងគ្នាទៅវិញ ឧបមាដូចជាប្រយោគខ្ញុំនេះ ។

" ទិញកន្ទែលប្រគែនលោកនែង "

អ្នកខ្មែរ (នៅខ្សាច់កណ្ដាល) អានប្រយោគនេះថា

" ទិញកន្ទើលប្រគើនលោកនើង "

អ្នកខ្មែរ នៅឃុំត្រែកប្រសប់ ស្រុកឆ្នូង ខែត្រក្រចេះ អានប្រយោគនេះ

" ស៊ីនំបញ្ចុកឬ ចុកថ្ងាំមួយឆ្នក ទៅអង្គុយក្បែរត្រែក " ថា ។

" ស៊ីនំប៉ាជក់ឬ ជក់ថ្ងាំមួយឈ្នក់ ទៅអង្គុយក្បែរគ្រោក "

នេះហើយដែលថាស័ត្តសាស្ត្រ ប្លែកតិស័ត្តវិទ្យា ។ បើអធិប្បាយឲ្យវែងឆ្ងាយទៅទៀតទៅ មុខតែចូលក្នុងវេយ្យាករណ៍ ដូច្នេះខ្ញុំនឹងដាក់ទៅក្នុងវេយ្យាករណ៍ ។

ការសិក្សាខ្លួនសំឡេងអក្ខរវិធីដែលមានដូចគ្នា គេអាចនិយាយថា អក្ខរវិប្បលាស គឺការប្រែប្រួលនៃអក្សរ ។

ការប្រែប្រួលមានដូចតទៅនេះ:

ស្រៈដើម	ប្រែជា	ទាហរណ៍	អានថា	សង្គមភាសា
ិ	ែ	សិរ	សែរ	
ុ	ោ	បិតា	បីដា	
ឹ	ែ	សឹរ	សែរ	
ូ	ៅ	ខូរ	ខ្ពៅរ	តាមសំដីអ្នកសៀមភាគខ្លះ អានចេញសំឡេង- ូ ដដែល
ព្យញ្ជនៈ	ប្រែជា	ទាហរណ៍	អានថា	
ត	ដ	បិតា	បីដា	
រ	ឆ	មេរ៉ុ	មេឆ	តាមសំដីសៀម

តែចំពោះភាសាឯខ្មែរ ។ ទំនឹបញ្ហាអក្ខរវិប្បលិងខ្មែរ ។ ស្រួចតែសម្រួលទៅតាមវេយ្យាករណ៍ ដូចជាយោស: អរយោស:ជាដើម ។ បើគួរតំនិត្យខ្លះដូចពាក្យថា "អញ" ហាក់ដូចជាសរសេរថា "អញ់" មួយខ្មែរ ដូចពាក្យថា "ឲ្យ" តាមក្បួនវេយ្យាករណ៍ មិនឲ្យតម្រួតតាមវិធីដូច្នេះទេ តែគ្រប់ភាសា ទៅក្នុងវេយ្យាករណ៍ គេមានពាក្យមួយថា "អញ្ញត្រស័ព្ទ" (Exception) ។

គ)- សណ្ឋានវិទ្យា ឬ រូបសាស្ត្រ (Morphologie) ការសិក្សាទូទ្រង់ទ្រាយភាសា គឺការរៀនឱ្យចេះភាសា តាមក្បួនវេយ្យាករណ៍ ដែលនឹងសរសេរឱ្យបានត្រឹមត្រូវ ដូច្នេះនឹងមានភាឡាំងៗនៅក្នុងវេយ្យាករណ៍ ។

ឃ)- អត្ថវិទ្យា (Sémantique) តាមគណៈកម្មការវិបស្សនាធម៌ នឹងនៅក្នុងសៀវភៅ « ភាសាខ្មែរ » របស់លោក អឿ៉ង-តោ៉ស ប្រែ (Sémantique) ជាន័យណ្ណាសាស្ត្រ ។

ការសិក្សាទូវាក្យដែលប្រែប្រួលទៅតាមទ្រឹស្តី នឹងសាវតារអក្សរសាស្ត្រដូចជាមានភាក្យមួយថា « លោះ » ។ លោះជាឈើស៊ីផ្លែតែជាលំសម័យសព្វថ្ងៃនេះ គេប្រើថា « ជើមបំពេញរាជ្យ » ទៅវិញ នេះតាមទ្រឹស្តីអក្សរសាស្ត្រ ឯតាមសាវតារអក្សរសាស្ត្រថា « ព្រះបាទសម្តេចទ្រង់យកជា ទ្រង់សព្វព្រះកដហថ្វាយទឹងនឹងផ្លែឈើនេះ ព្រះអង្គក៏ប្រោសព្រះកដានឱ្យហៅថា « ជើមបំពេញរាជ្យ » ។ ទ្រឹស្តីអក្សរសាស្ត្រមួយទៀត ដូចជាភាក្យថា « បង្គន់ » តើដើមគេថា « ចាំងគន់ » គឺបិទចាំងកុំឱ្យគេគយគន់ » ។

ង)- វេយ្យាករណ៍ ខ្ញុំត្រង់នេះខ្ញុំស្ទើរតែមិនចាប់ភាឡាំងទេ ព្រោះសៀវភៅជាច្រើនបានសរសេរអំពីវេយ្យាករណ៍ខ្មែរ តែខ្ញុំបានដំកបទៅក្នុង

សណ្ឋានវិទ្យាថា ខ្ញុំនឹងអធិប្បាយទៅក្នុងវេយ្យាករណ៍ ។ វេយ្យាករណ៍ខ្មែរដែលមើលទៅឃើញច្បាស់ជាងគេបំផុតនៅត្រង់ "សេចក្តី" និង "ការ" ដូចតាក្យថា :

ជើរ - ស្ទឹ

ដល់ការកនាមឬក្រៃនាម យើងប្រើថា "ការជើរ, ការស្ទឹ" តែម៉ើយើងថា "សេចក្តីជើរ, សេចក្តីស្ទឹ" ដូចជាគ្នាឯណាស់ ។

រាល់ប្រើ ការ, សេចក្តីនៅមុខនាមក្រៃ ឬការកនាមកុំឲ្យច្បាស់នោះត្រូវយល់ថា បើអំពើឬនាមជារូបី (nom concret) ត្រូវប្រើ "សេចក្តី" នៅមុខ បើនៅមុខនាមក្រៃ ឬការកនាមជាអរូបី (nom abstrait) ត្រូវប្រើ "ការ" ។

ការសិក្សាខ្លួវេយ្យាករណ៍នេះ គេត្រូវរៀនឲ្យចេះទៅតាមដំនាន់វេយ្យាករណ៍ ដែលវិវត្តប្រែប្រួលទៅតាមដំនាន់សាវតារ (Grammaire historique) ។

វេយ្យាករណ៍ខ្មែរ ដែលឃើញមានប្លែកគ្នាបន្តិចបន្តួចដូចជានៅតាមសង្គមជនជាតិសាខ្លះ ដែលនិយាយផ្ទុយគ្នា ដូចជាអ្នកនៅជាត់ដំបងតោងសាត់ជាដើម :

ខ. "ប្រែកុំ" ថា "កុំប្រែក"

ម៉ែតិនិត្យទៅ ដូចជាភាសាអង់គ្លេស ឬដូចជាលីដែរ ។

(នៅមានត)

ពាក្យខ្មែរប្រែតាមរាជសព្ទ

ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ « ក »

(តមក)

Section	(n.f.)	ផ្នែក (ព-ញ-) : ចំណែកនៃចំណួក ។
Séance préliminaire		សម័យប្រជុំប្រាថ្ម ។
Tome	(n.m.)	កណ្ឌ (កាន់)
Titre	(n.m.)	មាត៌ក : មេសេចក្តីដែលដាក់នៅខាងដើមនៃចំណួក ។ ចំណែកនៃគន្ថ ។
Volume	(n.f.)	ក្បាល (សៀវភៅ) ។

x x x

Abandonner le domicile conjugal	ចោះបង់លំនៅសង្វាស ។ ពញ ។
Abandon du domicile conjugal	ការចោះបង់លំនៅសង្វាស ។ពញ។
Abroger (v.t.)	ធ្វើនិរាករណ៍ : ធ្វើនិរាករណ៍ដល់អត្ថបទ ជំពង់សេចអត្ថបទនេះទៅអនាគត ជាទសេចក្តីជាសៃងឲ្យមានជំលាចាប់ពីពេលនិរាករណ៍ ។ពញ ។
Absence du consentement	ការគ្មានសេចក្តីព្រមព្រៀង ។ពញ។
Acquérir la nationalité cambodgienne	ជាទសញ្ជាតិជាខ្មែរ ។
Acquisition la nationalité cambodgienne	ការជាទសញ្ជាតិជាខ្មែរ ។
Acquérir à titre onéreaux	ជាទដោយចេញថ្លៃ ។ ពញ ។
Acquisition à titre onéreaux	ការជាទដោយចេញថ្លៃ ។ពញ ។

(នៅមានត)

វិបុលានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង . ខាត់ រៀបរៀង

(តមក)

អតិវ្យៃ ប៉ុ. ការិយាអន់ទៅក្រៃលែង, អន្តរធាន ។

អតិវ្យសនិន គុ. នែលវិនាសក្រៃលែង ។

អតិវ្យាធិន គុ. នែលចាក់ក្រៃលែង, នែលមុត . . . ។

អតិវ្រជ នាគុ. ងើរទៅក្រៃលែង, ឆ្ងៃកាត់ ។

អតិវ្រត គុ. នែលមានព្រតក្រៃលែង, នែលទ្រុះថ្នាក្រៃលែង ។

អតិឝក្ត គុ. នែលអង់អាចក្រៃលែង, នែលមានអំណាច ។

អតិឝក្រ គុ. នែលជាតន្ត្រៃក្រៃលែង, នែលជាព្រះតន្ត្រប្រសើរ ។

អតិឝក្រឝេកិន គុ. នែលល្អជាងព្រះតន្ត្រដោយក្រៃលែង ។

អតិឝង្ក នាគុ. សង្ស័យក្រៃលែង ។ *អតិឝង្កិត* គុ. នែលរង្កៀកក្រៃលែង ។

អតិឝង្កា ស្ត្រី. សេចក្តីខ្លាចក្រៃលែង ។

អតិឝង្កិតវ្យ គុ. នែលគប្បីរង្កៀកក្រៃលែង ។

អតិឝប គុ. នែលម្រះភ្លឺក្រៃលែង ។

(នៅមានត)

កំណែទី ៤៨

ទុតញ្ជាំរបុលកដសេនា ឆ្ន-កាឆ ប្រែរៀបរៀង

(ត្រមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកកាឯរៃធ្វាសបើបានអាន
> ទឹងចេះទាយកាលចំណាន
> ចាំងមានសន្តានស្នេហាជាតិ
>
> ——យូរ - អ៊ុន

ម៉ាថេងទឹងណាស់ ស្រែកដេរអ៊ុយកុយថា អាមនុស្សកំឡៅធ្វើឲ្យ ខ្ញុចការអញអស់ទៅ ខោះបើខ្ញុនអញនឹងស្លាប់ អញក៏មិនស្តាយដីវិត តែ មកគិតគូចចិត្តថា ទឹងរំលងអាសត្រូវកែដសម្បត្តិចេញ ដើម្បីនឹងជួយទំ- នុកបំរុងផែនដីឲ្យបានសុខ ក៏មិនសមប្រកបតាមគំនិតគិត ចូធ្លូកំឲ្យឃក ខ្ញុនម៉ាថេង ម៉ាហ៊ីវ ទឹងអ៊ុយកុយទៅប្រហារដីវិតកូនខណៈខោះ ម៉ាថេងក៏ ស្រែកដេរចូធ្លូមិនដាច់ពីមាត់ពាល់តែគេជួយឃតចុះជាប្រហារដីវិតកូយ ។ ចូធ្លូក៏និយាយទឹងហៀវគេកថា ខ្ញុនអ្នកមានសេចក្តីគាប់ប្រសើរដល់យើង ជាច្រើនណាស់ អ្នកចូរប្រុញ្ចាំចុះ បើចង់ចាំបានប្រយោជន៍អ្វី យើង ទឹងឲ្យបានតាមចិត្ត ។ ហៀវគេកធ្វើយថា ខ្ញុំចាំទឹងចាំបានស្រឡាញ់យស

ចណ្តាសក្តិតិះខ្មៅ តើវេលាខេះ ខ្ញុំបាទសុំឲ្យបានតែខ្លួនទាន់លើសុំនអៀង ដែលជាប្រពន្ធបុន្តែអ៊ុយកុយយកមកធ្វើជាកវីយោខ្ញុំបាទ ។

ចូរឆ្ងល់ថា ទាន់លើសុំនអៀងនោះ ជាមនុស្សអាក្រក់មិនដឹង មិនស្គាល់គុណស្រីយ៉ាខៃស្អាម៉ ដែលជាបងនៃថ្លៃអ្នកឯង ។ ទើនស្អាប់តិតព្រោះមានតែជាដែលអ្នកនឹងយកវាមកចិញ្ចឹមធ្វើជាកវីយានោះមិនគួរទេ ។ ចៀវតែកបានស្តាប់ដូច្នោះហើយ តិនតែកបានម្តងខ្លាចក្រែងចូរឆ្ងល់ទើសម្លាប់ទាន់លើសុំនអៀងអសារបង់ ទើបថ្លែងពាក្យសេចក្តីដែលខ្លួនទើនទាន់នោះ បានលបលាក់លួចសហាយទើនគ្នាតាំងថ្ងៃដំបូងមក ហើយរិះគិតប្រើតិនិតប្រាជ្ញាទើនប្រហារជីវិតអ៊ុយកុយជាបងនៃថ្លៃចេញ ព្រោះចិត្តស្នេហ្គស្រឡាញ់ស្រីម្នាក់នេះ ឲ្យចូរឆ្ងល់ស្តាប់គ្រប់ប្រការ ។

ចូរឆ្ងល់បានឮដូច្នោះ តិនទើនក្រែវក្រោធស្រែកថា ខ្លួនឯងជាប្អូនកវីយោគេ ហ៊ានលបលួចសហាយស្មន់ទើនប្រពន្ធបុន្តែរបស់បងនៃថ្លៃ ហើយឲ្យដៃគិតរំលាន់បំផ្លាញជីវិតប្តីគេទៀត ឯងនេះគេញាជាមនុស្សពេលមឿតចិត្តអាក្រក់ពន់ប្រមាណ គ្មានសេចក្តីសត្យកតញ្ញូសោះ វេលានេះ បើយើងមិនយកគេសងឯង មនុស្សតំនិតួងយកតម្រាប់តាម ខូចប្បាប់ខ្មាប់ស្រុកអស់ ។ ចូរឆ្ងល់តែប៉ុណ្ណោះ តិនប្រើតាហានឲ្យចាប់ចៀវតែក ទើនស្តីត្រូបក្សាព្តកបងប្អូនចៀវតែកទៅសម្លាប់ត្រមគ្នា ជាមួយទើនបុត្រកវីយោបក្សាព្តកអ៊ុយកុយ ហើយចូរឆ្ងល់ឲ្យប្រកាសបញ្ជាបញ្ឈប់ ភ្លាតាហានមាំបងថា

ម៉ាថេងនឹងម៉ាហ៊ីវប្រព្រឹត្តអំពើទុស គឺមានគំនិតប្រឌិសក់យនឹងមហាទុ-
ពជ ។ ឲ្យសម្លាប់ចេញហើយ អ្នកពល់គ្នាជាសេនាពហាន មិនបានដឹង
យើញចូលរួមគំនិតជាមួយគ្នា មិនត្រូវមានទោសអ្វីទេ បើនឹងស្មគ្រចូល
ចិត្តទៅធ្វើពជការជាមួយនឹងមហាទុពជក៏ឲ្យចូលទៅចុះ មហាទុពជ
នឹងជម្រៀងតាមសមគួរ ហើយមានសំបុត្រទៅកាន់ទីតាំងតួងថាម៉ាថេង
ប្រែចិត្តស្មត់ផែនដី ពជការឲ្យចាប់ខ្លួនសម្លាប់តាំងតួងអស់ហើយ
នៅសល់តែម៉ាតាយជាកូយ ឲ្យដនតាំងតួងស៊ើបចាប់ខ្លួនម៉ាតាយបញ្ជូន
ទៅស្រុកក្រុងឲ្យបាន នឹងឲ្យចំណាប់ផ្ទាន់ ។

ខណៈនោះ ម៉ាតាយបានទាំពាហាន ១ ពាន់ លើកជាទ័ពមកជួយ
ម៉ាថេង លុះលើកមកដល់ក្រុងហ៊ូតេ ប្រទះនឹងពួកពាហានម៉ាថេងដែល
រត់បែកខ្ចែកទៅជួបកណ្តាលផ្លូវ ។ ពាហានតាំងនោះក៏ពណិនារឿងក៏វ
ឲ្យស្តាប់ ។ ម៉ាតាយឮដូច្នោះ ក៏ភ័យតក់ស្លុតក្នុងចិត្ត ទើបគិតក្លែងខ្លួន
ជាកូនឈ្លួលអ្នកលក់ខ្ទិញរត់គេចចេញត្រឡប់ទៅស្រុក ។

សាមកុកខ្សៀ ៤៩

តាំងពីចូចូសម្លាប់ម៉ាថេង ហើយគិតលើកទ័ពទៅវាយស្រុកកាំងតាំង រហូតដល់ចូចូ
ប្លាំងនឹងម៉ាឈៀវមានជ័យជំនះ ចាប់បានពាហានម៉ាឈៀវមកជាឈ្លើយ ។

ឯចូចូលុះសម្លាប់ម៉ាថេងបានហើយ ក៏រៃគិតនឹងលើកកងទ័ពទៅ
ប្លាំងនឹងស៊ុនគួនហើយនឹងឡៅភី ខណៈបំរើពាហានដែលទៅស៊ើបស្តាប់

ការកងការខោះ ត្រឡប់មកប្រាប់ចូនួថា ខ្លៅតីរៀបចាត់ចែងទ័ពនឹង
លើតទៅច្បាំងយកស្រុកសៃឈ្នួន ។

ចូនួឮដូច្នោះ ក៏ទំនកទំនុកក្តីរអែលណាស់ ទើបនិយាយថា បើប្រសិន
ខ្លៅតីទៅវាយបានស្រុកសៃឈ្នួនមែនហើយ ក៏គង់នឹងប្រមូលតសាវ.
ហានទ័ពស្បៀងអាហារបានយ៉ាងច្រើន បើយើងលើកទ័ពទៅតនឹងខ្លៅ.
តីវេលាណា យើញថាជាការលំបាក ។ ត៍នគុយទើប្រឹក្សាធ្វើយតបនឹងចូនួ
ថា សេចក្តីនេះ សូមកុំឲ្យមហាឧបរាជព្រួយឡើយ ខ្ញុំបាទនឹងរិះគិតជា
កលឧបាយមួយយ៉ាង ឲ្យស៊ុនគួនទ័ពខ្លៅតីត្រឡប់ខុសចិត្តគ្នាទៅវិញ
មិនឲ្យរួមគំនិតជាមួយគ្នាបាន ដើម្បីនឹងឲ្យស្រុកចាំងពីរនេះ ជាសិទ្ធិទៅ
ក្នុងកណ្តាប់ដៃលោកតទៅ ។

ចូនួបានឮដូច្នោះ ក៏មានអំណរណាស់ ត្រឡប់សួរថាតម្រិះអ្នក
នឹងគិតកលឧបាយនោះប្រការម្តេច ? ។ ត៍នគុយឆ្លើយថាសព្វថ្ងៃនេះ
ខ្លៅតីនឹងស៊ុនគួនជាបងប្អូនថ្លៃនឹងគ្នា ចិត្តនឹងគំនិតគិតរួមជាមួយគ្នា លោក
នឹងរំលាងចេញដោយកម្រណាស់ ត្រានេះខ្លៅតីគិតនឹងលើកទ័ពទៅ
វាយស្រុកសៃឈ្នួនហើយ សូមឲ្យលោកកេណ្តាកងទ័ពទៅភ្ជាប់គ្នានឹង
ខៀវលៀវទៅស្រុកហ័បថាំ លើតទៅវាយស្រុកចាំងតាំង ខាងស៊ុនគួនតង់
នឹងឲ្យទៅសុំកងទ័ពខ្លៅតីមកជួយ ឯខ្លៅតីកំពុងរៀបចំដំណើរទ័ពទៅ
វាយយកស្រុកសៃឈ្នួន នោះនឹងមិនព្រមឲ្យកងទ័ពទៅជួយទេ យើងតង់

ចាន់ស្រុកកាំង តាំងដោយងាយ បើស្រុកកាំងតាំងចាន់មកយើងហើយ យើងត្រូវលើកកងទ័ពត្រឡប់ទៅវាយយកស្រុកកេងដីវ ទឹងស្រុកសែឈួនទៀត ផែនដីយើងកំទឹងចាន់ពាយជាសុខតទៅ ។

ចូនធួយលំយើញត្រូវ ទើបនិយាយថា កលទុបាយយ៉ាងនេះល្អណាស់ ត្រូវនឹងគំនិតដែលយើងគិតទុកត្រប់ប្រការ ។ ខណៈនោះ ចូនធួ ក៏ឲ្យកេណ្ឌកងពលបាន ១ សែនទាក់ ហើយឲ្យលើកទៅស្រុកហ័បថ្មាំ រួចបង្គាប់ថា ឲ្យខ្មៅលៀវដែលនៅរក្សាស្រុកនោះ ចាត់ចែងស្បៀងអាហារលើកមកបញ្ចូលគ្នា ទៅវាយយកស្រុកកាំងតាំង យើងនឹងលើកទាហានបញ្ជូនទៅជួយខ្មៅទៀត នាយទ័ពនាយកងកំលាចូនធួលើកទ័ពទៅដល់ស្រុកហ័បថ្មាំ ក៏ចូលទៅជ្រាបខ្មៅលៀវតាមបណ្តាំដែលចូនធួបង្គាប់មកនោះគ្រប់ប្រការ ។ ខ្មៅលៀវក៏ចាត់ចែងកេណ្ឌទាហានទឹងស្បៀងអាហារគ្រឿមខុកជាស្រេច ដើម្បីទឹងលើកទៅវាយស្រុកកាំងតាំង ។

ខណៈនោះ ប៉ាវើសេះក៏នាំយកសេចក្តីទៅជ្រាប់ស៊ុនគួន ។ ក៏ឲ្យហៅប្រជុំទីប្រឹក្សាមកតាំគ្រោះការពាជការថា ឥឡូវ ចូនធួ ប្រើ ខ្មៅ-លៀវ ឲ្យធ្វើជាមេកងទ័ពទឹងលើកមកវាយយកស្រុកយើង អ្នកពាល់គ្នាទឹងរិះគិតការនោះប្រការម្តេច ? ។ ខ្មៅលៀវធ្វើយថា សូមឲ្យលោកប្រើខ្លោសុកធ្វើសំបុត្រទៅឯកេងដីវ សុំកងទ័ពខ្លៅតាមកជួយ ខ្លៅតាជាប្អូនថ្លៃលោកស្រាប់ហើយ ខ្លោសុក ក៏មានគុណទឹងខ្លៅតាដែរ ទុំៗជាខ្លៅតា

មិនបង្អង់ខាន តង់ទឹងលើកទ័ពមកដួយធ្វើការសឹក ។ ស៊ុនគួន ឮដូច្នោះ
កំយល់ឃើញត្រូវ ទើបប្រើប៉ារ៉ែឲ្យទៅប្រាប់ខ្មោសុក ឯស្រុកធសង់គុន
ឲ្យខ្មោសុកធ្វើសំបុត្រទៅដល់ ខ្លៅតី តាមដំណើរ លុះខ្លៅតីបានទទួល
សំបុត្រដឹងសេចក្តី ក៏ឲ្យទៅអញ្ជើញខុងបេងតីស្រុកឡាំគុនមក ហើយ
យកសំបុត្រខ្មោសុកបង្ហាញឲ្យខុងបេងមើល ។

ខណៈនោះ ខុងបេងក៏ទំនាយដេនឹងខ្លៅតីថា លោកកុំព្រួយចិត្តឡើយ
ខ្ញុំនឹងគិតកលទប្រយុទ្ធ កុំឲ្យតាហានស្រុកយើងលើកទៅដួយស៊ុនគួន
ឯតាហាន ស៊ុនគួនក៏កុំឲ្យលើកទៅប្លន់ដែនចូឆូ ស្រុកកាំងក៏ឲ្យបាននៅជា
សុខ មិនឲ្យចូឆូមើលងាយយើងបាន ហើយខុងបេងក៏បង្គាប់អ្នកកាន់
សំបុត្រនោះថា អ្នកឯងចូរវិលត្រឡប់ទៅប្រាប់ ស៊ុនគួន ចៅហ្វាយអ្នក
ឯងចុះថា កុំឲ្យព្រួយចិត្តឡើយ ឲ្យស៊ុនគួនទឹងអ្នកស្រុកកាំងតាំងដែនឆ្នេច
កែកឲ្យលុកជាសុខសំកនទៅចុះ បើប្រសិនជាកងទ័ពចូឆូលើកមកដល់វេ-
លាណា ក្នាត់ជារខ្លួនយើងនឹងចេញជាធ្លុះឯង ។ ប៉ារ៉ែស្តាប់ឮដូច្នោះ ក៏
លាខ្លៅតី ខុងបេងត្រឡប់ទៅស្រុកស៊ុនគួនឯស្រុកកាំងតាំងវិញ ។

ក្រោយនោះ ខ្លៅតីក៏ទំនាយប្រាប់ខុងបេងថា ឥឡូវឮថាចូឆូកេណ្ឌ
កងទ័ពមកបញ្ចូលគ្នាជាពីរមណ្ឌល ចំនួនពលដល់ ៥០ ម៉ឺន ទឹងលើកមក
វាយស្រុកកាំងតាំង ដែលលោកប្រុងទឹងជួយស៊ុនគួននោះ កលទប្រយុ
ទ្ធបង់លោកនឹងធ្វើដូចម្តេច ។ ខុងបេងធ្វើយថា កាលពីដើមស្រុកដែល

នៅក្រោមបង្គាប់ចូលទូលនោះ ក៏ទឹកញាក្បើតតែថ្លាដែរ ហានស្រុកសែលៀវ ឥឡូវចូលទូលសម្ងាប់មាំថេនៅហើយ នៅតែមាំឈ្មៀវជាកូនភ្នំ ហានៅក្បែស្រុកសែលៀង គង់ចិត្តគិតសងសឹកចូលវិញជាដរាប សូមឲ្យលោកមានសំបុត្រទៅដល់មាំឈ្មៀវ ឲ្យស្រួតរួតលើកហានទៅកាយស្រុកហ៊ូគោះបុះ មុខជាចូលទូលទឹងលើកទ័ពត្រឡប់ទៅវិញ ។ ខ្លៅតាស្តាប់ឃើញត្រូវចិត្តក៏គិតធ្វើសំបុត្រតាមសំដីខុងបេងនិយាយ ហើយឲ្យបំរើដែលខុកចិត្តកាន់សំបុត្រនោះស្រួតរួតទៅឲ្យមាំឈ្មៀវ ឯស្រុកសែលៀង ។

ឯមាំឈ្មៀវនោះ លុះដល់ពេលយប់កន្លងថ្ងៃនោះក៏ដេកលក់ស្និទ្ធដល់ពេលអង្គ្រាត្រសុបិនមិត្តឃើញថា «មានខ្វាមួយហ្វូងចូលមកព័ទ្ធជាំខ្លួន» លុះភ្ញាក់ឡើងក៏ភ័យខ្លាចណាស់ ទើបហៅរីប្រឹក្សាពាំងតួងមកជួយទំនាយសុបិ្ត ។ ប៉ាំងតេកធ្វើយដរាបថា លក្ខណៈដែលយល់សុបិ្តនេះកាចណាស់ បិតាលោកដែលលើកទ័ពចូលទៅស្រុកហ៊ូគោះនោះ មុខជាមានសេចក្តីភ័យអន្តរាយច្រាកដណាស់ លុះនិយាយមិនទាន់ផុតមាត់ ខ្លួលឃើញមាំ-តាយមកដល់ ថ្ងៃនិតិមានឲ្យស្តាប់គ្រប់ប្រការហើយថា សូមម្បីតែខ្លួនខ្ញុំនេះ ចូលក៏ប្រឆំនឹងសម្ងាប់ចោលដែរ តែដោយសារខ្ញុំភ្លែងខ្លួនបន្ទុំធ្វើជាកូនឈ្លួលអ្នកជំនួញវ៉ៃរត់មកពាំងយប់.ថ្ងៃបានជារួចខ្លួន ។

មាំឈ្មៀវឮដូច្នោះ ក៏ខ្លួញយំដួលសន្ធប់មួយរំពេច ។ ពាហានពាំងតួងឃើញដូច្នោះ ក៏នាំគ្នាគ្រាហ៍លើកមាំឈ្មៀវឡើង ។ លុះដឹងខ្លួនហើយ

ម៉ាំឈៀវនឹកខឹងក្តៅលើសកម្ចាំង តាំងតែងាំមាត់ហើយថា អញនឹងសងសឹកអាចូឆ្នូឲ្យបានវិញ ។ ខណៈនោះ ខ្លួលចំរើឡើងពីកាន់សំបុត្រចូលមកដល់ ហុចឲ្យទៅម៉ាំឈៀវ ម៉ាំឈៀវខ្លួលយកហើយ មើលឃើញសេចក្តីថា សំបុត្រឡើងពីឲ្យពារមកដល់ម៉ាំឈៀវ ព្រោះចូឆ្នូមហាឧបរាជនៅស្រុកហ៊ូគោ គិតធ្វើការគេក្រក់ផ្សេងៗ ទាល់តែព្រះចៅហៀនតេបានសេចក្តីក្តៅក្រហាយខ្លាំងអំពើតាំងនេះអ្នកគឺនឹកខ្លាចស់ណាស់ហើយមួយទៀត គឺការព្រះចៅហៀនតេ ទ្រង់ព្រះអស្សរដោយព្រះលោភិតឲ្យតិងសុខនោះ បិតាអ្នកនឹងយើងក៏បានបុះឈ្មោះព្រមគំនិតគ្នាថា នឹងធ្វើការកំចាត់ចូឆ្នូចេញឲ្យបាន តាមួយវិញយើងដឹងច្បាស់ថា បិតាអ្នកធ្វើការឲ្យថ្លៃស់ថាញ់ទុយកលចូឆ្នូ លុះដល់ដំរីតអន្លក់យ យើងក៏នឹកស្លាយតួចចិត្តណាស់ ខ្លួនអ្នកក៏ជាជាតិឥហាន តង់នឹងមានចិត្តខ្មោះឈឺក្តៅ ត្រូវសងសឹកឥតុភវិញ ដើម្បីអ្នកនឹងលើកកងទ័ពទៅវាយយកស្រុកហ៊ូគោវិលណា យើងនឹងលើកទ័ពតាមជួយស្រុកកេងដ៏វាងនេះទៅជួយត្រួតគ្នាកំចាត់ចូឆ្នូឲ្យបានវិញ ដើម្បីនឹងជួយបំពេញព្រះកដហឫទ័យ នៃព្រះចៅហៀនតេឲ្យបានសេចក្តីសុខ ។

ម៉ាំឈៀវមើលចប់សេចក្តីសំបុត្រខ្មោះ ក៏ឲ្យនឹកខ្មោចពុះកកនឹងចិត្តតិតក្តៅនឹងភាវនា លុះរំសាយសេចក្តីសោកវិលណា ក៏សរសេរផ្ញើសារតបទៅឲ្យឡើងវិញ ហើយម៉ាំឈៀវក៏តាំងចាត់ចែងកេណ្ឌពលទាំងនេ

ដើម្បីនឹងលើកទៅវាយស្រុកហ៊ូតោ ខ្លួនមានបំរើមកដំណាលថា ហ៊ានស៊ុយ ឲ្យអញ្ជើញមាំឈៀវទៅជួប ។ មាំឈៀវក៏ចូលទៅជួបនឹងហ៊ានហ៊ុយ ។ ហ៊ានស៊ុយនិយាយប្រាប់មាំឈៀវថា ចូរឲ្យសំបុត្រមកដល់យើងថា ឲ្យចាប់ទៅតាំងពីនោកបញ្ជូនចូលទៅក្រុងហ៊ូតោ ចូរ នឹងតាំងយើងឲ្យធ្វើជាទៅហ្វាយស្រុកសៃលៀង ។

មាំឈៀវឮដូច្នោះ ក៏ក្រាបចុះគំនាប់ហើយនិយាយដំណាលថា លោកនឹងបិតាខ្ញុំបាទ គឺជាមិត្រសំឡាញ់នឹងគ្នាស្និទ្ធស្នាលណាស់ ឥឡូវចូរសម្លាប់បិតាខ្ញុំបាទទៅហើយ រឿងតាំងនេះសូមឲ្យលោកឈ្លងយល់ទៅដល់បិតាខ្ញុំបាទផងចុះ ។ ហ៊ានស៊ុយឆ្លើយថា បិតាទៅនឹងយើងបានស្រឡាញ់រាប់អានគ្នាជាប្រាកដណាស់ ដែលចូរសម្លាប់បិតាទៅទៅហើយនោះ យើងក៏មានចិត្តទោមនស្សរន់ប្រមាណ បើទៅនឹងលើកទ័ពទៅវាយស្រុកហ៊ូតោសងសឹកចូរឲ្យគ្រាណា យើងក៏ត្រូវទៅជាមួយផង ។

មាំឈៀវឮដូច្នោះ ក៏គោរពដោយសេចក្តីត្រេកអរក្លាំងណាស់, ហ៊ានស៊ុយក៏ឲ្យយកខ្លួនមាំហានចូរ ដែលកាន់សំបុត្រទៅនោះទៅប្រហារជីវិតនៅមុខមាំឈៀវ ហើយមាំឈៀវនឹងហ៊ានស៊ុយក៏រៀបចាត់ចែងមាំហានចាត់ឲ្យ ហៅឈ្មួន ធៀនិង លីវ៉ា ខៀវហង សៀងហ៊ុង សេងធី បែកអនអៀវឈើ ទាំង ៨ នាយនេះ នាំមាហានទៅជាមួយនឹងហ៊ានស៊ុយមួយកង, លុះបានឫកតាតេលស្ត មាំឈៀវនឹងហ៊ានស៊ុយក៏លើកទ័ពចេញទៅ

ក្រុងហ្គូតា ។

ខណៈគាលលើកទ័ពទៅដល់តំបន់ស្រុកខៀងអ័ន ចុងហ៊ុវ ចៅហ្វាយស្រុក ក៏ឲ្យបំរើរេសះកាន់សំបុត្រប្តឹងចូលទៅដល់ចូនហ៊ីយលើកទាហានចេញមកកំឆាំងទ័ព លុះមាំតាយលើកទាហាន ៥ ពាន់ជាកងមុខទៅដល់ប្រទល់គ្នា ចុងហ៊ុវក៏បំផាយរេសះចូលតយុទ្ធនឹងមាំតាយបាន ១ ភ្លែង ចុងហ៊ុវទ្រទ្រឹងមាំតាយពុំបាន ក៏ញាក់បំផាយរេសះនាំទាហានត់ចូលទៅក្នុងស្រុកវិញ ឯគ្នាប់ទាហានឲ្យត្រួតគ្រាយាមល្បាតតាមរេសៀនចន្លោយដុំវិញមាំមួន ។ មាំឈៀវហ៊ុនស៊ុយលើកតទៅដល់ក៏ដេញឲ្យចូលព័ទ្ធដុំវិញស្រុកខៀងអ័នគំរប់ ១០ ថ្ងៃ គ្មានឃើញរេសៀនណាចេញមកតយុទ្ធគ្នាសោះ លុះលើកទាហានសង្កត់ចូលទៅកាយតំណាយ ក៏ឃើញចុងហ៊ុវចាត់ការយាមល្បាតជាមាំមួនណាស់ ។

ចាំងតេត ក៏និយាយនឹងមាំឈៀវថា ស្រុកខៀងអ័ននេះជាមណ្ឌលធំ កំពែងមន្លោយដុំវិញក៏មាំមួន គ្រោះជាក្រុងដែលត្រេះចៅហៀនតេ ជាន់រៀបចំគុកមក, យើងនឹងមកតាំទ្រគុកស្ទៀតដូច្នេះ ក៏មិនជាការមានប្រយោជន៍ នាំឲ្យតែត្រួយនឿយទាហាន បើប្រសិនជាចូនហ៊ីលើកកងទ័ពមកជួយពាន់ ជាន់ខ្លាចតែក្រៅមួយជាន់ទៀត យើងក៏តង់នឹងលំបាកខ្លាំងការ ខ្ញុំគិតឃើញថាយមួយឲ្យជាន់ស្រុកខៀងអ័នដោយងាយគ្រោះគេសនេះ ប្រជាពលរដ្ឋនៅស្រុកខៀងអ័នតំណាងជាប់ស្បៀងអាហារ

ណាស់ សូមឱ្យលោកបង្ហុយសោយទឹតទៅបង្គាប់ឱ្យឆ្ងាយតាស្រុកដើម្បី
ទិនឱ្យអ្នកស្រុកទេះចេញមករកស្បៀងអាហារ ខ្ញុំបាទនឹងបង្ខំចូលទៅក្នុង
ស្រុកឱ្យបាន ហើយនឹងជុតក្លៀងជាសញ្ញាថាបើកទ្វារទុលលោកឱ្យ
ចូលទៅ ។ មាំឈៀវឮដូច្នោះក៏តេញចិត្តណាស់ លុះដល់តេលាយប់ ក៏
ឱ្យយកទង់លើកឡើងច្រាប់តាហានឱ្យសំគាល់ថា ត្រូវថយទ័តចេញទៅ
ចោះនៅពីចម្ងាយវិញ តាមគំនិតចាំងតេក ។

វេលានោះ បណ្តាមនុស្សម្នាក្នុងស្រុកខៀងអ័នក៏សឹងតែដាច់ផុត
ស្បៀងអាហារ ដាច់តាំងពីកនឹងទុសក្លើងភ្លាំងណាស់ ព្រោះក្នុងនាទី
ស្រុកខៀងអ័ននោះជាទីសួតក្រៀម តោះបើដីកអណ្តូងឱ្យជ្រៅយ៉ាំងណា
ក៏គ្មានទឹកចេញសោះ ប៉ុន្តែនៅពុកចិត្តថា ចូរឆ្ងួតនឹងលើកទ័តមកជួយ
បានជាត្រធើយកន្តើយគ្រាន់តែការតោតើក្នុង លុះព្រឹកព្រហាមឃើញកង
ទ័តមាំឈៀវលើកថយចេញទៅវិញក៏មានសេចក្តីត្រេកអរគ្រប់គ្នា នៅតែ
ចុងហ៊ីវម្នាក់ មានសេចក្តីសង្ស័យក្រែងជាកលសឹក ទើបប្រើបំរើឱ្យចេញ
ទៅលបមើល ក៏មិនឃើញមានកងទ័តតាំងជាក្បួន ចុងហ៊ីវក៏ឱ្យបើកទ្វារ
ស្រុកបញ្ចេញមនុស្សម្នាក្នុងស្រុកនោះឱ្យទៅរកស្បៀងអាហារប្រហែលថ
ថ្ងៃ ។ ខណៈនោះ ចាំងតេក ទីងតាហានដែលស្និទ្ធពុកចិត្ត ក៏បន្ធំជាមនុស្ស
តែកទុសចូលទៅក្នុងស្រុកខៀងអ័ន តាលបើមាំឈៀវបានដឹងហើយ ក៏
ប្រមូលពលលើកត្រឡប់ទៅតំបន់ស្រុកនោះដុំវិញដូចថ្ងៃមុន, ចុងហ៊ីវឃើញ

ដូច្នោះ កំបង្គាប់ឲ្យខ្ចប់ចំណីគ្រាស្រុកជាប់មាំមួន ហើយចាត់ការយោម-
ល្បាតជាំនថ្ងៃ.យប់ ។

ឯជាំនតេក ដែលបានចូលទៅនៅតាក្នុងកំផែង លុះដល់ភេលយោម
៣ យប់ កំយកភ្លើងអុជឲ្យឆេះឡើងក្នុងស្រុកខាងទិសឯលិច ។ ឈ្មោះ
ចុងជិនជាប្អូនចុងហ៊ីវ ជាអ្នកនៅក្រុតពាហានខាងទិសនោះ លុះឃើញ
ភ្លើងឆេះសន្ធោឡើង កំភ័យខ្លាំងណាស់ ឡើងសេះបំផាយចូលទៅទីឈរ
តត់ភ្លើង ។ ជាំនតេកក្រឡេកឃើញ កំបរសេះចេញទៅស្លាក់ពីមុខ
ចុងជិនហើយស្រែកថា ឃើងឈ្មោះជាំនតេក ចូលមកនៅក្នុងស្រុកនេះ
ហើយ អ្នកឯងដឹងឬទេ ? ។ ចុងជិនទើបតែបានស្គាល់មិនទាន់ខ្លួល
អាវុធ ជាំនតេកកំដកដាវកាប់ចុងជិនភ្លាត់ពីលើសេះស្លាប់ ។ ឯពួក
ពាហានដែលយោមល្បាតជាំនប៉ុន្មាន កំសឹងតែបាក់បែកខ្ចាត់ខ្ចាយទៅជាំន
អស់ ។ ជាំនតេក កំតាច់សោបើកគ្រាស្រុកចេញទៅខ្លួលមាំឈ្មៀវឲ្យ
ចូលទៅក្នុងស្រុក ។

ឯចុងហ៊ីវ ដែលនាំពាហានទៅនៅរក្សាគ្រាខាងទិសឯកើតនោះ លុះ
ឃើញភ្លើងឆេះសន្ធោឡើង ឃើញពាហានបែកខ្ចែកគ្នាតតាក់ពពួនដូច្នោះ
កំដឹងថា នាំឈ្មៀវនឹងហ៊ានស៊ុយចូលស្រុកបាន មានសេចក្តីភ័យខ្លាំង
ណាស់ នាំពាហានគ្រង់ចេញទៅតាំងនៅទីតុងគួន ហើយប្រើប៉ារើស្រួច
រូតទៅថ្ពក់ចូនឆ្នុ ។ ឯមាំឈ្មៀវនឹងហ៊ានស៊ុយ កាលបើយកបានស្រុក

ខឿនអ័ន ហើយកំណែកបំណាច់ ជាហានចាំនួនតាមសមគួរ ហើយកំស្រួតលើកទ័ពតាមបុនហ៊ីវៅឯបន្ទាយតុងគួន ។

ឯណៈ កាល បូធូតិនធីលើកទ័ពទៅវាយយកស្រុកកាំនតាំនៗ លុះឮដំណឹងថា មាំឈៀវលើកកងទ័ពមកវាយយកបានស្រុកខឿនអ័នដូច្នោះ កំចាត់ចែនធីនលើកទ័ពទៅជួយ ខ្លួនមានចំរើបួលទៅប្តីថា មាំឈៀវធីនហ៊ានសុំយកវាយយកបានស្រុកខឿនអ័នហើយ ធីនលើកកងទ័ពមកវាយយកស្រុកហ៊ូគោខឿត ឯបុនហ៊ីវទៅហ្វាយស្រុកខឿនអ័នកំណែកទ័ពត្រឡប់ទៅនៅតយតុងគួន ។

បូធូកំនិយាយថា តាដើមយើងតិតនធីនលើកទ័ពលួងទៅវាយយកស្រុកកាំនតាំន ឥឡូវមាំឈៀវធ្វើបង្អាប់លើកទ័ពត្រឡប់ប្រូនធីនមកវាយយកស្រុកយើងដូច្នេះ ត្រូវតែយើងធីនត្រិះរិះកំចាត់មាំឈៀវចេញជាមុន លុះថាហើយកំឲ្យគេហៅខ្លួនចាហាងជាប្អូន ធីនស៊ីឡុងមកបង្គាប់ថា ទៅឯងបួលនាំតលចាហានមួយម៉ឺនទៅជួយបុនហ៊ីវ ដើម្បីធីនការពារគេយតុងគួនឲ្យមាំមួន បើយើញកងទ័ពមាំឈៀវលើតមកដល់ ត្រូវឲ្យព្រួតគ្នារក្សាបន្ទាយឲ្យមាំមួន កុំឲ្យអន្តរាយក្នុងរវាង ១០ ថ្ងៃ បើបន្ទាយតុងគួនខោះខ្លួនធីនមាំឈៀវកងរវាងនេះ យើងធីនយកខោសដល់ខ្លួន បើហួស ១០ ថ្ងៃ ហើយខ្លួចកំហ៊ុះ ចាហាងធីនស៊ីឡុងក៏ខ្លួលបង្គាប់ រួចលើកទ័ពចេញទៅបន្ទាយតុងគួន ។

ក្រោយនោះ ចោយមិនយោយដម្រាបចូលថា ចោហង៍នេះនៅក្នុងសេចក្តីណាស់ ចំពោះកំណាមនុស្សនែ៎រួសមិនសូវមានតាំគ្រោះហេតុការណ៍ធ្ងន់ឬស្រាល ដែលលោកនឹងប្រើឲ្យទៅកាប់ឆ្កាយក្នុងគួននោះ ខ្ញុំបាទយើញថានឹងមានសេចក្តីអន្តរាយជាក្រោកជ ចូលួយលាំយើញត្រូវផង ទើបចាត់ប្រើចោយិនឲ្យលើកតាហានតាមចោហង៍ទៅហើយចូលួកំលើកទ័ពធំតាមទៅជាខាង៍ក្រោយ ។

ឯមាំឈៀវនោះ លុះលើកកងទ័ពទៅដល់ខ្លាំនឹងបន្ទាយក្នុងគួន ក៏ឲ្យរេហ៍តលាយគ្នាព័ទ្ធជុំវិញបន្ទាយ នោះចោហង៍នឹងស៊ុឡុងចុងហ៊ុវកំចាត់តាហានឲ្យយាមល្បាតតាមសើន នឹងក្តារបន្ទាយយាយព័ទ្ធជុំវិញ មិនបានចេញតតាំង៍ច្បាំង់គ្នា ឯមាំឈៀវក៏ឲ្យតាហានចូលទៅស្រែកដេរប្រមាថចូលួជាតាក្យអាស្រូវតាសផ្សង។ ហើយរំលើកដៀលដល់តួដត្រកូល ចោហង៍ឮដូច្នោះកំនឹង្ហាំង់ណាស់ តិតនឹងចេញទៅតយុទ្ធគ្នាឧ៍ងមាំឈៀវ ស៊ុឡុងក៏ហាមឃាត់ថាដែលមាំឈៀវប្រើតាហានឲ្យមកដេរប្រមាថយ៉ាំង៍នេះ ប្រាថ្នាឲ្យយើង៍ខឹង៍ចំពោះឈើក្តៅ ត្រូវតែអ្នកខំអត់សង្កត់ចំពោះទៅសិនចុះ ពោះបើយ៉ាំង៍ណាក៏កុំត្រូវចេញទៅតយុទ្ធគ្នាឡើយ ត្រូវតែការាំបង្ហ័ចាំទំព័ទ័ពធំលើកមកដល់ មហាឧបាយនឹងគិតដោយកលល្បិចប្រការម្តងសឹមយើង៍ធ្វើតាម ចោហង៍ក៏យើញត្រូវផង ។

ឯមាំឈៀវ កំចាត់តាហានឲ្យផ្លាស់ប្តូរគ្នាចូលទៅស្រែកដេរចូលួចាំង

យប់ថ្ងៃមិនដាច់ ចោហាន៦ធ្វាំងណាស់ ក៏បរគេលចេញមកតក្បាំង ស៊ីឡុង
ហាមឃាត់ថា មហាទុបាដបង្គាប់ផ្តាំជាដាច់ខាតថា ឲ្យយើងគិតរក្សា
តែបន្តិចកុំឲ្យអន្តរាយក្នុងរវាង ១០ ថ្ងៃ ឥឡូវបាន ៨ ថ្ងៃហើយ ត្រូវតែ
អ្នកខំអត់ធន់ឲ្យបានគ្រប់ ១០ ថ្ងៃចុះ ចោហានស្តាប់ហើយនឹកបារម្ភចិត្តស៊ី
ឡុងក៏នៅស្ងៀម ស៊ីឡុងបំរុងចាត់ចែងស្ងៀងអាហារនឹងចែកឲ្យហាន
ការស៊ីឡុងទៅហើយ ចោហានក៏ទៀងលើសើនបន្តិច យើញគហាន
ម៉ាឈៀរនៅកងគ្នា ខ្លះដេកខ្លះអង្គុយមិនមែនជាក្បួនច្បាប់ ចោហានក៏នាំ
គហាន ៣ ពាន់ ប៉ើតក្តារចេញទៅខាងក្រៅ គហានម៉ាឈៀរដែល
នៅកងគ្នានោះក៏តត់ក្រាតត់ក្រាយ ចោហានក៏បំផាយសេះដេញតាមទៅ ស៊ី
ឡុងដឹងដូច្នោះក៏ឆក់យកធ្វាំងណាស់ នាំចុងហ៊ុំលើកគហានតាមចោហាន
ចេញទៅ លុះទៅពាន់ហើយក៏ស្រែកហៅឲ្យចោហានឈប់ត្រឡប់វិញ
ខ្លួលម៉ាឈៀរលើកគហានចេញមកស្ងាត់ពីមុខ ចោហានក៏បំផាយសេះ
វេះតេចនឹងចូលបន្តិច ខ្លួលប្រុះនឹងម៉ាតាយលើកគហានស្ងាត់ពី
ក្រោយ ហើយឆ័ត្តដុំវិញខ្លួនចោហាននឹងស៊ីឡុង។ យើញលើសកម្លាំង
ណាស់នឹងច្រំតភ្លាំឈ្នះ ក៏ខំលាយចោលបន្តិចតួន នាំគហានតេ
យកតែខ្លួនចេញទៅ ជាំងតេកក៏បង្ហាយសេះស្ទុះតាមទៅគាល់តែផុតភាគ
បន្តិចតួន ប្រុះនឹងចោយនលើកទ័តមកជួយចោហានស៊ីឡុង
ម៉ាឈៀរយើញដូច្នោះ ក៏បរគេលចូលទៅជួយជាំងតេកហើយត្រឡប់នាំ

យកខ្លួនជាំដ៏តេតចូលទៅនៅក្នុងបន្ទាយតុងគួន ។

ខណៈនោះចាហង សុីឡុងទំដ៏ចាយ៉ិន ចុងហ៊ុវ កំទាំងហាន លើកត្រឡប់ទៅក្រោយអស់រោង ១ ថ្ងៃ ខ្លួលប្រុះទំដ៏តងតែចូលឆ្ងាកសួរ សាកយកសេចក្តីដល់ចាហងថា តាលយើងចាត់ប្រើខ្លួនឲ្យលើកទ័ពមកនោះ យើងតំបានផ្តាំកំជាប់ពុកថា ឲ្យទំតាំដ៏រក្សាបន្ទាយតុងគួនពុកឲ្យមាំមួនកុំឲ្យថ្លស់ការណ៍ក្នុងរវាង ១០ ថ្ងៃ ហេតុអ្វីក៏ខ្លួនរត់ចោលបន្ទាយបណ្តាយឲ្យសត្រូវយកបាន ចាហងឆ្លើយថា តាលខ្ញុំបានទៅនៅរក្សាបន្ទាយនោះ តំបានចាត់ការប្រុងប្រៀបប្រយ័ត្នឲ្យយាមល្បាតលាតប្រវែងមិនដែលប្រមាទឲ្យឃ្លៀងឃ្លាតតិប្រតាសមហាឧបាជសោះ តែក្រោះមាំ-ឈ្លៀវឲ្យចាហងមកវ៉ៃស្រុកដេរំលើតដល់ត្រកូលមហាឧបាជជាពលំរោលតាំងយប់ថ្ងៃ ខ្ញុំបានកំទំតំទំដ៏ណាស់ ទំមានរអត់សន្តិត់ជិត្ត តែត្រាំអត់ភ្លុំបាន ទើបលើកចាហានចេញទៅតច្បាំងគ្នាទំដ៏មាំឈ្លៀវ ដែលខ្ញុំបានមើលឆាយប្រមាទឲ្យតើតថ្លស់ការណ៍យ៉ាងដូច្នេះ ទោសខ្ញុំបានកំត្រូវខុសណាស់ហើយ តាមតែមហាឧបាជទំដ៏ដ៏ប្រោសចុះ ។

ចូចឮដូច្នោះ កំថា ចាហងនៅក្មេងសេចក្តីខ្ចីតំខ្ចិត យើងកំមិនបានពុកចិត្តជាច្រើនដណាស់ ទើបប្រើខ្លួនជាមនុស្សចាស់ឲ្យមកជួយ ដើម្បីទំដ៏ចាំជួយតឿនរំលឹកស្មារតីឲ្យធ្វើការអ្វី ។ តប្បីឲ្យដ៏ងខុសទំដ៏ត្រូវ ឥឡូវគួរហើយឬ? ដែលខ្លួនធ្វើឲ្យខូចការរបស់យើងយ៉ាងនេះ សុីឡុងធ្វើឆ្លើយថា

កាលមាំឈៀវប្រើគាហានមកដេរដៀមជាមនោះ ចោហង៉ចេះតែប្រឡោតទឹងប្រុងតែនឹងចេញច្បាំង ខ្ញុំបាទក៏ចេះតែយាត់ទាំងក៏ងកជាច្រើនវេលាមកហើយ កាលចោហង៉ចេញទៅតយុទ្ធនឹងមាំឈៀនោះ ខ្លួលខ្ញុំបាទមិននៅដឹត ចេញទៅតាំងតវ៉ាចែកស្បៀងអាហារឲ្យចណ្តាតួកគាហាន លុះដឹងថា ចោហង៉ចេញទៅក៏មានចិត្តកិតក៏យណាស់ ក្រែង៉ចោហង៉នឹងថ្វស់ការណ៍ដល់មាំឈៀ ខ្ញុំបាទក៏លើកគាហានខ្លួនតាមទៅជួយកុំឲ្យថ្វស់ការណ៍ក្តីខ្លាំងនោះ ។

ចូធូរឮដូច្នោះទឹងណាស់ បង្គាប់ឲ្យចាប់ខ្លួនចោហង៉ទៅសម្លាប់ តួកនាម៉ឺនក្តីកង៉តំប្រញាប់ទៅជម្រាបចូធូថា វេលានេះយើងកំពុងធ្វើការសង្គ្រាមនឹងមាំឈៀជាសឹកធំ គួរតែកេឫក្សាជោគជាមង្គលទុត្តម ដែលមហាឧបាជនឹងបង្គ្រឲ្យសម្លាប់ប្អូនចេញនោះមិនគួរសោះ សូមឲ្យអនុគ្រោះលើកទោសម្តងចុះ ចូធូយល់ឃើញគួរដូច្នោះ ក៏ឲ្យឃុំខ្លួនចោហង៉ទុកហើយក៏ស្រួតលើកទ័ពតម្រង់ទៅបន្ទាយតុងគួន លុះទៅដឹតត្រាំបន្ទាយចម្ងាយផ្លូវ ២០ សិន (៨០០ម.) ចោយ៉ានក៏ជម្រាបចូធូថា បើយើងនឹងលើកគាហានតុះតាវំលាយបន្ទាយចូលទៅកង៉ត្រាវឲ្យវែនេះ តង់មាំឈៀនឹងច្រើកលទុបាយបញ្ឆោតដោយប្រការម្តេចក៏យើងតុំអាចដឹង គួរតែបង្ខំកង៉ទ័ពឈប់នៅទីនេះស្តាប់ការសិន សឹមលើកចូលទៅវាយកបន្ទាយតុងគួនវិញនឹងបានដោយងាយ ចូធូក៏យល់តាម ទើបឲ្យបញ្ឈប់

ខ្ញុំតាំងបន្ទាយខ្ចាប់នៅមីនោះឯង អាទ្មើ ឲ្យចាយដេនៅក្បាលបន្ទាយខាងស្តាំ ឲ្យហែហួនអៀនៅក្បាលបន្ទាយខាងឆ្វេង ឯខ្លួនចូលនៅបន្ទាយកណ្តាល ហើយសម្រាំងរើសយកតែគាហានដែលមានថ្លៃដេ ដើម្បីទំនុកដំណាយ រាយយកបន្ទាយគុំងគួនឲ្យបាន ។

ម៉ាំឈៀរឃើញចូលលើកមកតាំងបន្ទាយនោងដូច្នោះ កំនាំគាហានចេញពីក្នុងបន្ទាយទៅតទល់នឹងគាហានចូលមក ម៉ាំឈៀរចរសេះស្ទុះទៅឈរមុខខ្លួន ចូលក៏ឰដើងសេះមកបញ្ឈប់នៅមុខបន្ទាយ ក្រឡេកឃើញគាហានម៉ាំឈៀរនេះរោងមានរូបសម្បត្តិម៉ាំមួនប្រហែលគ្នា ហើយឃើញម៉ាំឈៀរតែក់ក្រោះច្រាក់តាក់មួកស ដឹះសេះកាន់លំពែងឈរមុខគាហានមានរួចយ៉ាងសម្លឹម ស្មាតាងកងចង្កេះមួល មុខសត្រូតមាត់ក្រហមសមគួរជាគាហានឯក ហើយឃើញចុងដឹះសេះខៅខាងស្តាំ ម៉ាតាយខៅខាងឆ្វេង ចូលក៏ទំតុកដងចិត្តថា ម៉ាំឈៀរនេះមិនបងជាតិ ដែលតើតមកធ្វើជាគាហាន ទំងចូលតយុទ្ធសង្គ្រាមក៏មានស្ទាហាប់ចំណាប់ណាស់ ចូលក៏បរសេះចូលទៅរហ័ស លុះដល់ជិតហើយក៏ស្រែកទៅឲ្យម៉ាំឈៀរថា ខ្លួនអ្នកជាមនុស្សមានតួជាត្រកូលខ្ពស់ ឈ្មោះថាមន្ត្រីខ្ពើកដការ ហេតុម្តេចក៏លើកតសយោធាមកជាស្នួនស្មត់ផែនដីដូច្នេះ ។

ម៉ាំឈៀរឮដូច្នោះខឹងណាស់ ទាំមាត់ត្រឹតឆ្នេញហើយស្រែកដេរទៅចូលថាអាចេរសត្រូវកាជសម្បត្តិ អាឯងជាតួរក្សត់ផែនដីមានសេចក្តី

ប្រព្រឹត្តអាក្រក់ណាស់ ធ្វើឲ្យព្រះពៅហៀនគេជាម្ចាស់មានព្រះទ័យមិនសប្បាយសោះ ទោសអាឯងនុសជាខមួន គួរតែនឹងកាប់ដង្ហើសាច់ឲ្យល្អិតល្អន់ដូចប្រអូល ទើបគួរនឹងទោសកំហុស ហេតុអ្វីអាឯងនិតនុសមកសម្លាប់អាតុកអញ ។ អញមានសេចក្តីខឹងខ្លាំងណាស់ អញមកនេះប្រាថ្នានឹងចាប់អាឯងវះតន្ទុះសាច់ហុតឈាមចាំងសៀងឲ្យបាន ជាហើយកំបរសេះចូលតម្រង់ទៅនឹងចាប់ខ្លួនបួនដួ អ៊ុកមយើញដូច្នោះក៏ញាក់សេះស្ទុះមកតទល់នឹងមាំឈៀវបាន ៦០ ភ្លេង អ៊ុកមអស់កម្លាំងប្រឹងតពុំបានក៏គាញសេះវះត្រឡប់តត់ទៅក្រោយ លីកងក៏ស្ទុះបណ្តោយមកតនឹងមាំ-មាំឈៀវបាន ៩ ភ្លេង មាំឈៀវលើកលំពែងចាក់ត្រូវលើកងក្តាក់ពីលើសេះស្លាប់ មាំឈៀវក៏បរតេលចូលខ្ចាប់ តាំងតែប្រកាប់ជាប់ដៃគ្នានឹងខ្លួន គាហានបួនដួសុំពុំបានក៏បែកភ្លាយចាក់ចាំងខ្លួនសន្ធាប់សន្ធឹកណាស់ មាំឈៀវក៏ដេញគាហានឲ្យចូលរហ័សសង្ខឹញទៅទៀត មាំឈៀវស្រែកឲ្យចាប់ខ្លួនបួនដួឲ្យបាន គាហានក៏ស្ទុះចូលប្រូលប្រូបលស្រែកថា អ្នាក់ក្រោះក្រហមនោះជាមេចោរក្បត់ឲ្យចាប់ខ្លួនវាឲ្យបាន បួនដួក្តួដូច្នោះក៏យខ្លាំងណាស់ដោះក្រោះចេញពីខ្លួន ហើយចំជាយសេះស្ទុះចេញទៅជាមួយនឹងកូនគាហាន ពួកគាហានមាំឈៀវស្រែកថា អាចោរពុកចង្កាវែងនោះហើយឈ្មោះបួនដួ ឲ្យចាប់វាឲ្យបាន ។

(នៅមានត)

រឿងព្រេងទាក់ទងដោយប្រវត្តិសាស្ត្រខ្មែរ
តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមទម្លាប់	នៃទេសជាតិ	
ខ្មែរគួរឲ្យឃ្លាត	សិក្សាពេញទី	។
ព្រោះទេសជាតិ	ជាជាតិសោភ័	
ក្នុងទ្វីបអាស៊ី	ពាំងតែព្រេងនាយ	។

ប.ព

រឿងប្រាសាទជាន់ខ្ទៅ

នៅខេត្តកោះកែវ

បើយើងធ្វើដំណើរតាមក្រុងភ្នំពេញ ទៅកាន់ខេត្តកោះកែវ ដល់ទៅឃុំរវៀង ស្រុកសំរោង យើងនឹងឃើញវត្តបុរាណមួយឈ្មោះវត្តប្រាសាទជាន់ខ្ទៅ តាំងនៅជាប់នឹងភ្នំថ្មតាមក្រុងភ្នំពេញទៅ ។

បានជាហៅថា វត្តប្រាសាទជាន់ខ្ទៅ ព្រោះវត្តនោះមានប្រាសាទបុរាណ ២ ឈ្មោះប្រាសាទជាន់ខ្ទៅនៅជាន់លើបង្អែរអំពារ ចំខ្ទង់ភ្នំវត្តពីទិសឋាងត្បូង ។ ប្រាសាទទាំងពីរនោះ ធ្វើពីថ្មដុនឥដ្ឋដុន ទំហំ ៤ ម៉ែត្រ ៥ដ្រួង, កំពស់ ១០ ម៉ែត្រ កំពូលស្រួចដូចចេតិយ ខ្ពស់ត្រដែត ។

ប្រវត្តិនៃប្រាសាទនោះ មានសេចក្តីដំណាលថា៖

កន្លងអតីតកាលដ៏កន្លងយូរមកហើយ មានស្តេចមួយព្រះអង្គទ្រង់ព្រះ

តាមព្រះសុរិយោដែរឬទ្បា ជាស្តេចប្រកបដោយមហិទ្ធិឫទ្ធិនឹងបុណ្យជាច្រើន ។ ព្រះអង្គមានព្រះរាជបុត្រីមួយព្រះអង្គព្រះនាមនាងភ្ញៅ ហើយព្រះអង្គតម៌នៅលើភ្នំដីសូរ ។ ព្រះអង្គបានកសាងប្រាសាទ ៩ នៅលើភ្នំនោះ ព្រះអង្គដឹកស្រះ ៤ លើភ្នំ នៅត្រង់ជ្រុងប្រាសាទ ។ អំពីកំពូលភ្នំចុះមកខាងក្រោមចម្ងាយប្រហែល ៧០០ ម៉ែត្រ មានខន្ធ ៤ ត្រង់ជ្រុងតាំង ៤ គឺ ខន្ធអ៊ុំ១, ខន្ធស្ងួត ១, ខន្ធស្តុក ១, ខន្ធប្រជ្រុង ១ ។ ខន្ធតាំង ៤ នេះជាកន្លែងសម្រាប់ការក្រសាលរបស់ស្តេចអង្គនោះ ។ លុះព្រះរាជបុត្រីមានវ័យវឹង្គាការចំរើនឡើងបានព្រះជន្ម ១៦ ព្រះវស្សា ព្រះនាងមានព្រះរូបឆោមល្អជាងស្រីឯទៀតក្នុងព្រះនគរ ។ សម័យថ្ងៃមួយ ព្រះនាងនឹកក្អួកចង់ទៅក្រសាលខន្ធប្រជ្រុង បានចូលទៅថ្វាយចង្គំលាព្រះរាជាសុំទៅក្រសាលខន្ធនោះ ។ ព្រះរាជាក៏ទ្រង់ព្រះរាជានុញ្ញាត ហើយទ្រង់បានតំឡើងបំរើឲ្យរៀបចំរៀបចាមដំណើរព្រះនាង ទៅក្រសាលក្នុងវេលាថ្ងៃរសៀល។

គ្រានោះ មានបុរសម្នាក់ឈ្មោះបណ្ឌិតស្រី ដើមតែនឹងសឹកពីសាមណេរ មានរូបឆោមល្អល្អះស្អាតជាងបុរសឯទៀត ព្រមទាំងចេះអាគមវិជ្ជាការផង ។ បណ្ឌិតនេះ មានទីលំនៅ ។ ភូមិមួយខាងលិចភ្នំដីសូរ ជិតផ្លូវដែលចុះទៅខន្ធប្រជ្រុង ។ ថ្ងៃនោះ បណ្ឌិតស្រីមានសេចក្តីអផ្សុក រួចចេញទៅលេងជិតផ្លូវ ក៏បានឃើញព្រះរាជធីតាយាងចុះពីលើភ្នំជាមួយនឹងស្រីជាបរិវារ ។ លុះបានយល់កាលណា បណ្ឌិត

ស្រីស្រាប់តែមានសេចក្តីស្នេហាប្រតិពទ្ធជាប់ចិត្តនឹងព្រះនាងនោះក្រៃពេក ។ បណ្ឌិតនោះគិតារណាថា: ថ្ងៃនេះជាថ្ងៃមានលាភធំដោយបានជួបប្រទះនឹងស្រីត្រប់លក្ខណ៍ តែអាត្មាអញជាកូនពាស្ត្រអ្នកកំសត់ ធ្វើម្តេចនឹងបានព្រះនាងនេះហ្ន៎ ! , ព្រះនាងនេះមិនមែនជាស្ត្រីធម្មតាទេ គឺជាព្រះរាជបុត្រីរបស់ស្តេច អាត្មាអញនឹងព្រះនាងពុំសមសក្តិគ្នាសោះ ដើរដូច្នេះអញនឹងគិតយ៉ាងណាទៅអេះ ! ។ បណ្ឌិតស្រីគិតសព្វគ្រប់ទៅ ចេះតែស្រឡាញ់ខ្លាំងឡើង ។ ទើបនឹកថា នឹងចូលទៅដណ្តឹងតាមច្បាប់ក៏ពុំសមមុខជាស្តេចនឹងយកគោសដល់ស្លាប់ ។ លុះសេចក្តីស្រឡាញ់ចេះតែកើតខ្លាំងឡើង ។ ក៏ស៊ូប្តូរស្លាប់ ជាពុំគប្បីជាស្តេចយកគោសយ៉ាងណា ។ ក៏សុខចិត្តតែស្លាប់ ទើបបាននឹកដល់មន្តវិជ្ជាការដែលខ្លួនចេះតាំងប៉ុន្មាន រួចបេះស្លឹករឃើយកមកសូត្រផ្តុំមន្តវិជ្ជាការ ហើយឡើងលើដើមឃើផ្តុំស្លឹកបង្វិលឡើង ។ ឯសូរសម្លេងស្លឹកដែលបណ្ឌិតនោះផ្តុំ ហាក់ដូចជាទៅជុំចំបេះដូងព្រះនាង ។ ក៏ភ័ន្តភាំងស្មារតី ។ លុះក្សេរដើងព្រះអង្គឡើង ព្រះនាងទ្រង់គិតថា អាត្មាអញជាកូនស្តេច ឆ្លាប់ស្តាប់ក្នុងដូរៀបត្រូវថ្ងៃតែពុំដែលមានក្នុងអ្វីធ្វើឲ្យអញស្ទុតចិត្តដូចសម្លេងនេះសោះ ។ ព្រះនាងទ្រង់សម្រើងគិតយូរទៅ ។ សម្លេងនោះរំតែតែពីពេះឡើង ។ , ព្រះនាងអត់ទ្រាំពុំបានក៏លាន់ព្រះឧស្ន្ហថា " ឃើអើហ្ន៎ ! សម្លេងនេះជាសម្លេងថ្លែកណាស់ គួរតែអញទៅតាមស្តាប់មើលឲ្យឃើញច្បាស់ តើអ្នកនោះដូច

ម្តេចបានជាចេះដូចគ្នាដល់ម្ល៉ឺន ! " ។ ព្រះនាងទ្រង់យាងទៅកាន់មើលឃើញដោយព្រះអង្គឯង ។ លុះទៅដល់ ព្រះនាងទតឃើញរូបឆោមឋណ្ឌិតនោះស្អាតល្អ កំមានសេចក្តីប្រតិព័ទ្ធជាប់ចិត្តនឹងឋណ្ឌិតនោះ បានសាកសួរសេនូនាគ្នាទៅវិញទៅមកតាមដំណើរបស់បុរសនឹងស្ត្រី ដែលស្រឡាញ់គ្នាតាមបវេណី ។ ជនទាំងពីរកើបានឱយាយមត់គ្នាថា ថ្ងៃក្រោយយើងនឹងមកជួបគ្នាទៀត ហើយលាគ្នាបែកមុខរៀងខ្លួន ។ ចំណែកព្រះនាង បាប់ដើមតាំងពីបែកមុខអំពីឋណ្ឌិតនោះមក តែងមានទឹកព្រះកន្ត្រៃហូរប្រក្រតី ព្រះកន្ត្រៃក្រៀមក្រំលែងកេះកយនឹងពួកបរិវារ ។ ពួកបរិវារមានចិត្តសន្ទិះសង្ស័យ ។ ថ្ងៃក្រោយ នាងចូលលាព្រះពុទ្ធទៅមន្ទីរទៀត។ ព្រះពុទ្ធទ្រង់អនុញ្ញាតឱ្យព្រះនាងទៅ ទ្រង់ចាត់អ្នកចំរើឱ្យហែហមដំណើរព្រះនាងដូចថ្ងៃមុន ។ លុះទៅដល់កន្លែងនោះ ព្រះនាងទ្រង់មានព្រះសព្វនីយ៍ប្រាប់ពួកបរិវារថា "អ្នកពួកគ្នាត្រូវឈប់ចាំខ្ញុំ ។ មានកិច្ចទៅកន្លែងឯនោះបន្តិច" ។ មានព្រះសព្វនីយ៍ប្រាប់ហើយ ព្រះនាងទ្រង់ស្តេចសំដៅទៅកន្លែងដែលសន្ទុតឱ្យឋណ្ឌិតស្រីមកជួបនោះ ។ លុះបានជួបគ្នាហើយ គួរស្នេហាក៏សម្រេចសេចក្តីប្រាថ្នារបស់ខ្លួនទៅ ។ ពួកបរិវារសង្ស័យទៅលបមើលឃើញកិរិយាមិនល្អ មានស្តេចក្តីកតក័យភ្លាចត្រែងព្រះពុទ្ធយកទៅសដល់ជីវិត ក៏ជំនុំគិះគ្រោះគ្នាថា: " យើងគួរតែក្រាបទូលស្តេចកុំខាន" ។ លុះត្រឡប់ទៅវិញ ពួកបរិវារ ក៏ចូលទៅតាល់ទូលស្តេចសព្វគ្រប់

តាមដំណើរ ។ ស្តេចទ្រង់ទ្រាល់ជាយ៉ាងខ្លាំង ទ្រង់រំលេចពួកពេជ្ឈឃាតមក ប្រាប់ថា ''ត្រូវយកកូនអញទៅសម្លាប់ឲ្យឆាប់'' ។ ចំណែកព្រះមាតាជាអគ្គមហេសី ក្រាបទូលសូមទោសព្រះស្វាមីថា ''សូមព្រះករុណាទ្រង់ព្រះមេត្តាប្រោស កូនរបស់យើងនៃតមួយ បើខុសជាមានទោសខុសយ៉ាងណា។ សូមព្រះអង្គកុំសម្លាប់ គ្រាន់តែបំបរបង់ចេញអំពីទីនេះចុះ សូមទ្រង់អនុញ្ញាតឲ្យទាន'' ។ ស្តេចក៏ទ្រង់អនុញ្ញាតតាមសេចក្តីសុំរបស់ព្រះនាងជាមាតា ។ ទ្រង់ព្រះបញ្ជាទៅពួកសេនាបតីឲ្យធ្វើប្រាសាទ ២ ខ្នង បម្រុងតំកល់ដីសូរ ៣ យោជន៍ ។ ពួកសេនាបតីក៏ធ្វើតាមព្រះរាជបញ្ជារួចហើយ ស្តេចទ្រង់បង្គាប់ឲ្យនាំព្រះនាងទៅគង់នៅទីនោះ ។ ប្រាសាទនេះនៅខាងលិចភ្នំដីសូរ ។ តាំងពីថ្ងៃនោះទៅ ព្រះនាងកើតទុក្ខជាខ្លួនឯងមួយព្រះជាតិ ជាប់ជាប់ខ្លួនចោលឲ្យទៅនៅតែម្នាក់ឯង ឈឺមួយបែកពីសង្ឃរាលែងជាខ្លួនមកដូចលោះ ដោយមិនជ្រាបថាទៅទីណា ។

សម័យនោះ មានតិក្ខមួយអង្គឈ្មោះវែកវ លោកនិមន្តចេញពីស្រុកខ្នែរ ទៅរៀនមន្តវិជ្ជាការនៅស្រុកក្រៅ លោករៀនបានចេះគ្រប់គ្រាន់ លោកត្រឡប់មកស្រុកវិញ គង់នៅទីមួយកន្លែងក្រៅវែកវ ទីនោះអត់ទឹកអ្នកស្រុកនាំគ្នាជីកស្រះមួយប្រវែងលោក ។ ដោយសារស្រះនោះជារបស់លោកត្រៃវែកវ ទើបស្រះនោះមានឈ្មោះថាស្រះវែកវ។ រហូតដល់សព្វថ្ងៃ ។

លោកត្រៃតង្គនោះគង់នៅយូរបន្តិចទៅ មានតិក្ខសត្វមួយទៅត្រប់ស្រុក

ភូមិកំពង់កែខាងមន្ទីរដ្ឋាការ ។ ព្រះនាងឮដូច្នេះទ្រង់ជ្រាបដំណឹងថា លោកគ្រូនោះទើបតែនិមន្តមកពីស្រុកក្រៅ ចេះមន្តវិជ្ជាការល្បីល្បាញដូច្នោះ មានបំណងចង់ជួបលោក ដើម្បីចង់ដឹងសេចក្តីទុក្ខរបស់នាងថា តើថ្ងៃណានឹងបានស្រោកស្រាន្តស្បើយស្លេីយ ។ ព្រះនាងមានព្រះសង្វេគយ៉ាងក្រៃលែង ក្រាបទូលអង្វរព្រះបាទជាឪពុកឲ្យរៀបព្រះទីនាំងដំរី ដើម្បីទៅថ្វាយបង្គំលោកគ្រូអង្គនោះ ។ លុះធ្វើព្រះដំណើរទៅដល់ទីកន្លែងលោកគ្រូនោះហើយ ព្រះនាងស្តេចចូលទៅថ្វាយបង្គំលោកតាមធម្មតា ឃាត់ឃើញលក្ខណៈលោកគ្រូគង្គនោះសព្វគ្រប់ ក៏ទ្រង់រៃមកព្រះទ័យថាអំពីសង្ឃរាចស់ មកជាប់នឹងលោកគ្រូតែវិញ ពីព្រោះលោកអង្គនោះមានប្រុសម្បត្តិល្អជាង តេញលក្ខណៈជាប្រុសគួរឲ្យស្រឡាញ់ ។ ព្រះនាងក៏ដំណាលពីសេចក្តីសុខទុក្ខរបស់ទ្រង់ទូលលោកសព្វគ្រប់ ហើយសំដែងអាការស្និទ្ធស្នាល់ហាក់ដូចជាទុកចិត្តយូរមកហើយ ។ ការដែលព្រះនាងតណិនារឿងពីរបៃរបស់ព្រះនាងនោះគួរឲ្យលោកយល់ឃាតថា ព្រះនាងមានហេតុយ៉ាងជាប់ជំពាក់ទឹងលោក ។ លោកគ្រូកែវ អត់ត្រាំតុំបានក៏មានចិត្តតោះទន់ទៅរកព្រះនាងដែរ ហើយមានតុដ្ឋដីកាទន់ភ្លន់ទៅរកព្រះនាង ។ កាលបើព្រះនាងទ្រង់បានឮតុដ្ឋដីកាលោកផ្ញែមល្ហែមទន់ភ្លន់មកកាន់ទ្រង់ ក៏នឹកសង្ឃឹមថា " តទៅមុខ អញនឹងមានអាងលែងកើតទុក្ខតាំងពីថ្ងៃនេះទៅហើយ " ។ ចាប់តាំងពីថ្ងៃនោះមក ព្រះនាងមានឥណិសម្បុរស្រស់បំព្រង ដូចស្រីទេពអប្សរទ្បើងវិញ ។

ចំណែកលោកគ្រូតែវ លោកខំប្រឹងតិចារណាធម៌ ដើម្បីដកចិត្តអំពីព្រះនាងនោះខ្លាំងណាស់ដែរ តែដកចិត្តពុំរួចសោះ ។ ពេលក្រោយមក ព្រះនាងស្តេចត្រឡប់ទៅថ្វាយបង្គំសុំឲ្យលោកស្រោចទឹក ដើម្បីឲ្យមានសិរីសួស្តី ពេលស្តេចទៅស្រោចទឹកនោះ ព្រះនាងរឹតតែសំដែងសេចក្តីភក់ពាក់ទៅរកលោកគ្រូតែវខ្លាំងឡើងទៀត ព្រះនាងទូលលោកថា:"សូមឲ្យលោកម្ចាស់គង់នៅជាសុខសប្បាយចុះ" ។ កាលបើឮព្រះសូរសៀងព្រះនាងដូច្នោះ លោកគ្រូតែវក៏ក្រឿមក្រំ ស្រពោនកើតទុក្ខដោយសំដីព្រះនាង ។ អាការដែលលោកធ្វើនោះ ហាក់ដូចជាច្រាបព្រះនាងឲ្យដឹងច្បាស់ថាលោកកើតទុក្ខតែព្រោះតែព្រះនាង. ។ ព្រះនាងរឹតតែមានសេចក្តីស្រឡាញ់ខ្លាំងឡើង រួចទ្រង់ស្តេចត្រឡប់ទៅព្រះដំណាក់វិញ កើតទុក្ខផ្ទំពុំលក់ សោយក្រយាពុំបាន អត់ទ្រាំពុំបានក៏ចាក់បំរើឲ្យរៀបព្រះទីនាំងដំរី ឲ្យទៅនិមន្តលោកមកដំណាក់ព្រះនាង ។ ចំណែកលោកគ្រូតែវ កាលបើបានឃើញអ្នកបំរើទៅនិមន្ត ក៏សប្បាយព្រះទ័យបានរៀបចំដំណើរនិមន្តមកដាប្រញាប់ ។ ព្រះនាងរៀបចំបណ្តាអាហារសុទ្ធតែរបស់ប្លែក ។ ពុកបំរុងប្រគេន ។ លុះលោកនិមន្តទៅដល់ ព្រះនាងក៏លើកប្រគេនលោកភ្លាមៗដែរ ។ លោកគ្រូតែវឆាន់ពុំបាន អាការដែលលោកឆាន់មិនបាននោះ ហាក់ដូចជាច្រាបនាងឲ្យរឹតតែច្បាស់ឡើង ។ ព្រះនាងក៏រឹតតែកើតទុក្ខខ្លាំងឡើង ។ អត់ទ្រាំក្តៅខ្លាសពុំបាន ទ្រង់ចូល

ទៅខ្លួលលោកថា « សូមលោកម្ចាស់ចាកសិក្ខាបទមកចុះ » ហើយព្រះនាងប្រគេនសំលៀកបំពាក់ ព្រមទាំងប្រដាប់ប្រដាសព្វគ្រប់ ។ លោកគ្រែកគ្រែកខ្លួលយល់ព្រមតាមសំដីព្រះនាងនិមន្ត ហើយក៏សឹកចាកសិក្ខាបទជាឃរាវាស នៅរួមសុខទុក្ខជាមួយព្រះនាងទៀតក្នុងប្រាសាទនោះ ជាន់ជាកន្លែងនោះគេហៅថា « ប្រាសាទនាងទៀ » តាំងពីនោះរហូតមក ។

ចំណែកកាលមកខាងក្រោយ មានតុន្ទបរិស័ទជ្រះថ្លាបានស្ថាបនាវត្តនៅទីនោះឡើង បានជាវត្តនោះហៅថា « វត្តប្រាសាទនាងទៀ » រហូតមកដល់សព្វថ្ងៃ ។

លោកថាធ្នូតប៉ ធ្នូតមួយនឹងស្រី ធ្នូតមួយនឹងស្រា ធ្នូតមួយនឹងលែ្បង អំតើពាលា ធ្នូតនេះហៅមហា ធ្នូតក្រែកទ្វង ។ ធ្នូតស្រីធ្នូតស្រា ធ្នូតលែ្បងពាលា អំតើសឹងធ្លង លោកពុំឲ្យសេព ឲ្យរៀងជាមួងកាតែងឲ្យហ្មង ក្មេងក្លាំងស្មារតើ ។ ឲ្យក្មេងក្តីតាប់ ក្មេងចាំងខ្លួនស្ងាប់ ក្មេងសាស្ត្រសួស្តី ក្មេងសីលក្មេងទាន ក្មេងញាណវិរ្យ៉ី ក្មេងឈ្លាប់ប្រក្រតី ធ្នូតប៉ប្រការ ។

ឈ្លាប់ក្នុងបៅ

អង្គរនឹងសម័យអង្គរ តាមទស្សនាវដ្តី "ព្រះអង្គរយ៉ង"

(ក្រុងប្រាក) លេខ ៣/១៩៦១

ជនណាដែលជាប់ចិត្តនឹងប្រវត្តិសាស្ត្រ ហើយនឹងវប្បធម៌ប្រទេសឥណ្ឌា មិនគប្បីបែកនៅត្រង់ឱកន្តើយ ចំពោះសម័យដែលហាន:ដ៏ខ្ពង់ខ្ពស់នឹងអារ្យធម៌ថាស់ពុំនៃប្រទេសឥណ្ឌាជាន់ថាស់ បានចាប់ផ្តើមបង្ហាញឲ្យយើញច្បាស់ ប្រហែលចំនួនពីរពាន់ឆ្នាំហើយ ដោយសារការតម្រឹកផ្សាយខាងពាណិជ្ជកម្មនឹងវប្បធម៌ នៃតំបន់មាត់សមុទ្រប្រទេសអាស៊ីភាគអគ្នេយ៍ទេ ។ ឬតាំភាគខាងមូលនៃសាគរឥណ្ឌា ឈូងសមុទ្របេងហ្គាល ច្រកសមុទ្រម៉ាឡាកា សមុទ្រជ្វានឹងសមុទ្រចិនខាងត្បូង ខាងអស់នេះ ពៅជាវិស័យនៃការដឹកនាំខាងសមុទ្រ នឹងពាណិជ្ជកម្មរបស់ប្រទេសឥណ្ឌា ។ មាគ៌ាតាំងឡាយដែលនាំពៅកន្លែងដែលមានតម្លៃថោកនឹងពៅកន្លែងដ៏ថ្លៃថ្លា ដែលពៃមតាំងមានលេចឡើងពៅផ្សារជាតិរ៉ូម៉ាំងតាមរយៈនៃប្រទេសឥណ្ឌានោះ រមែងតែប្រត្រិត្តពៅតាមផ្លូវសមុទ្រតាំងនេះឯង ។ ដូច្នេះហើយទើបគេយើញលេចកើតមានរដ្ឋថ្មី ។ ជាច្រើនពៅកោះសុង (Sonde)[1] នឹងនៅប្រទេសឥណ្ឌាឬភាគ តែការកើតរដ្ឋថ្មីតាំងនេះ ក៏រមែងបិតនៅតែក្រោមអនុភាពនៃប្រទេសឥណ្ឌាជាធម្មតា ។ ការដឹកនាំឲ្យចាប់មុខនៃជនជាតិឥណ្ឌាពោះពៅខ្លួបអាស៊ីភាគអគ្នេយ៍

១- កោះប្រទេសម៉ាឡាយ៉ូបច្ចុប្បន្នពីគ្រោះកោះម៉ាឡាការហូតពៅទល់នឹងកោះម៉ូលុក ។

ខ្ញុំដែលបានកើតក្នុងប្រទេសដ៏ប្រសើរ ព្រមទាំងអាទុកភាពនៃការតាំងអាណាខេត្តមទាំងវប្បធម៌ផងណៀ តែងទៅមានទៅខ្លាយ ទៅពេលដែលការគ្រឹកផ្សាយខាងសាសនាផ្សេងក្នុងដំបន់ទាំងនោះ កំពុងជួសខ្លាំង ។ សព្វថ្ងៃនេះក៏ដោយ គេទៅតែជួបប្រទះនូវអាទុកាភសាសនាផ្សេងណៀ ខ្ញុំដែលវប្បធម៌ផ្សេងណៀ ក្នុងតំបន់ទាំងនោះ ។ ដែនដីប្រទេសកម្ពុជាបច្ចុប្បន្នក៏បានទៅក្នុងវង្វេងនៃអាទុកាភនោះដែរ ។

ប៉ុន្តែកាលបើដឿថា តែដែលទៅតដាំវាំងខាងមុខសិល្បៈនៃសម័យនោះ គឺជាឧទ្រដ្ឋានតែមួយក្នុងវង្វេងនៃសិល្បៈផ្សេងណៀ ការដឿយាំងនេះពុកជាការគាន់ប្រឡាំ ។ តាមពិត សិល្បៈខ្មែរនៃដែនសិលាគឺអង្គរ ជាកន្លែងដ៏ជាក់ស្តែងនៃការរីកត្តន់ខាងសិល្បៈរបស់ខ្មែរ ដែលជាប្រកពដ៏រស់រើកដែលបង្ហើតឲ្យប្រពៃណីខាងចេនាសិល្បៈរបស់ខ្មែរនោះ ។

កាលដែលខ្ញុំបានឧកាសទៅទស្សនាលើកដំបូង ខ្ញុំប្រាសាទអង្គរជិលល្បាញ ទៅពេលនោះ ខ្ញុំចង់ដឹងថា សិល្បៈអង្គរស្រេដៀងគ្នានឹងនិម្មបនកម្មផ្សេងណៀខាងប្រាសាទ ខាងចម្លាក់នឹងខាងគាតក់តែងលំអ ដោយវិធានការណ៍បែបណា ? ហើយម្យ៉ាងទៀត ការណ៍ទាំងនេះផ្សាយចេញនូវគាម្មណ៍ខ្លះទៅដូចម្តេច ? ខ្ញុំដឿទៀតថា ចម្លើយចំនោះបញ្ហានេះជាគាម្មណ៍មួយដ៏ខ្ពាំងជាងគាម្មណ៍ដែលខ្ញុំបានទាំយកមកពីអង្គរទៅទៀត ។

សព្វថ្ងៃ គេឲ្យឈ្មោះអង្គរ (ជាភាសាស័ស្ត្រតថា ខនរ: ជាភាសា

ខ្មែរថានគរ (ប្រែថាទីក្រុងឋ្លាង) ជាក្រុមប្រាសាទដ៏សំខាន់ តាំងនៅខាងជើងបឹងទន្លេសាប ក្នុងខេត្តសៀមរាប ដែលបានចាប់កសាងឡើង ជាច្រើនលើកច្រើនគ្រា ពីសតវត្សទី ៩ រហូតមកដល់សតវត្សទី ១៥ គឺជាព្រះរាជធានីនៃព្រះអង្គរាជាណាចក្រខ្មែរ ។ សម័យនោះ ព្រះរាជធានីមិនបានកសាងថ្មី នៅតែកន្លែងដដែលជាធម្មតា ដូនកាលយកទីក្រុងចាស់មួយភាគធំទីក្រុងថ្មីមួយភាគរួមបញ្ចូលគ្នាស្ថាបនាជាព្រះរាជធានីថ្មីៗ មុនសម័យនោះធំអត្តិកាលក៏ដោយ ព្រះរាជធានីខ្មែរ ត្រូវបានស្ថាបនាឡើងជាបណ្តោះអាសន្នក្នុងតាគដទៃផ្សេងនៃព្រះរាជអាណាចក្រ ។ មិនដែលមានប្រាសាទណាមានសភាពដូចគ្នាបានគង់វង់នៅទេ ឃើញមានគង់វង់នៅតែសំណល់នៃប្រាសាទតាំងពីខ្លាយដែលកសាងពីឥដ្ឋ ឬ ពីថ្មប៉ុណ្ណោះ ។ ប្រាសាទព្រះមហាឥសូត្រធំធាកំពង់ អាតារសាធារណៈធំធាគេហស្ថានអ្នកស្រុក សុទ្ធសឹងសង់ពីឥដ្ឋឈើ ។ មិនដែលឈើណាមានបើជាប់ដូចម្តេចក៏ដោយ អាចខ្ទប់ទល់នឹងភ្លើងនឹងធាតុក្តៅសើមនៃប្រទេសក្តៅធំធាការពុកពាលនៃព្រៃញាតសព្វតរបស់ខ្មែរបានឡើយ ។ ទីក្រុងគេចោះបង់ចោលហើយគ្មានជីវភាព បានត្រឡប់ក្លាយទៅជារំពាគ្មានត្រឹងការពារនៃធម្មជាតដ៏សាហាវ ដែលដុះរួបរោមរឹត ដូចកម្រាលមួយរចនាដោយរុក្ខជាតិពណ៌បៃតង ក្នុងរយៈកាលច្រើនសតវត្ស ។ សព្វថ្ងៃនេះទៀត អ្នកទស្សនាអាចយល់ច្បាស់បាន នូវការធឿនធ្ងន់នឹងការគោត

សរសើរបេះសំអុកប្រាជ្ញចាក់ដំម្នាក់ឈ្មោះ (ហង់រី មូហ៊ិត) នៅឆ្នាំ ១៨៦២ កាលដែលលោកកំពុងចរត្រាច់ក្នុងព្រៃស្បាត ហើយស្រាប់តែទៅដល់នៅចំតោះមុខប្រាសាទអង្គរក្នុងនោះ ។ អ្នកភូមិដ៏តខាង់ នៅក្រោមកិច្ចចាត់ការនៃអ្នកប្រាជ្ញខាងបុកណាវត្ត ដែលកំពុងធ្វើការដើម្បីរក្សាយុំគ្រង ទីងរើរៀបឡើងវិញនូវប្រាសាទដ៏ថ្លៃថ្លាចំផុតនៃសិល្បៈខ្មែរ បានខំប្រឹងខប់ទីងរុញប្រាទឱ្យថយឡាយបន្តិច នូវក្បែរជាតិដុះស្មាប់យាំងច្រើនដែលតែងតែស្ងែរក (ឧកាស) ទីងកនទន្ទ្រានមកលើសិល្បៈខ្មែរជាទិច្នេះ ។ ប្រាសាទខ្លះលិចកប់តាក់កណ្តាលជាន់ទៅក្នុងស្មាប់ព្រៃភ្លាតស្បាត ប្រាសាទខ្លះត្រូវគេបណ្តាយឱ្យបិតនៅក្នុងសភាពដើមតាមចិត្ត ដូចនៅគេលដែលគេទើបទីងបានរកឃើញ បានជាទុកបណ្តាយដូច្នេះ គឺដើម្បីបញ្ជាក់នូវកំស្តុតាងខាងកម្ចាំងចង្អិនបង្ហាញរបស់ជម្ងាតិរស់នៅលើសិលាឥតវិញ្ញាណ ។

ក្នុងទីងដែលគេបានឃើញគ្រុំងាំងល្បាយនៃប្រាសាទធ្វើអំពីឥដ្ឋដ៏នាន់ចាស់ចំផុត កំណត់ឱ្យឃើញទៀតនូវចំណុចនៃការចេញដំណើរឆ្ពោះទៅកាន់ការស្ងែរស្ងែរកជានៃខ្មែរបុកណា ។ ដូច្នេះហើយទើបគេបានរកឃើញនូវប្រាសាទទីងធ្ងាំងសិលាជាច្រើន មានចារឹកអក្សរសំស្ក្រឹត ឬ អក្សរខ្មែរជាន់ចាស់ សិលាចារឹកទាំងនោះរោលរំពីប្រវត្តិសាស្ត្រខ្មែរខ្លះ ។ ក្នុងសម័យនេះឬ សម័យនោះ ។ ឬក៏កន់ទីងឬថ្មាយក្រឿងដែលមានជាប់

ទំនួកាតដ៏ប៉ុនប្រសប់នៃជាងចម្លាក់ខ្មែរអាចឲ្យគេឃើញថាខ្លួនមានបំណងបុគ្គលនឹងព្រឹត្តិការណ៍ទាំងឡាយ ។ ព្រះអធិរាជអាណាចក្រដែលតាំងនៅលើដែនដីដ៏ធំលើសលុបក្រៃលែងនៃទ្វីបអាស៊ីកាតអន្លើយ ជាន់ត្រូវគេទើបនឹងធ្វើឲ្យលេចឃើញច្បាស់ ។ គេបានរកឃើញខ្លួនថ្មីទាំងស្តាប់តម្បាក់ម្នាក់ទាំងឡាយ ដែលរាប់បញ្ចូលក្នុងចំណោមស្នាដៃឯកនៃសិល្បៈសាកលរហូតមកដល់សម័យយើងនេះ ។

សេចក្តីចំណងចង់ស្គាល់យ៉ាងតិចក្រាតដូរឿងអតីតខ្មែរ ហើយនឹងចង់ដោះស្រាយនូវបញ្ហាទាំងឡាយដែលបានចាប់ឡើងចំពោះការរកឃើញថ្មីមួយៗ កាន់តែកើតឡើង ។ ប្រតិភូនៃសម្ភារៈមានតុជាវិសេសមិនអាចរើសូតនេះ ដែលសម្រាប់តុសាងប្រាសាទដ៏ល្អអស្ចារ្យ នឹងយ៉ាងណាខ្លួលខ្លួលាយទាំងនោះ ផ្សាយមកតែពីការណ៍ខាងលើឬ ? ដោយហេតុដូចម្តេចបានជាមានប្រាសាទថ្មីៗ ទាំងឡាយដ៏យ៉ាងល្អ នឹងប្រកបដោយកត្តិនាមជាឱច្ច ដែលមានតាសពេញដែនដី បានកកើតឡើងដោយពាជ័ប្បណ្ឋ មានការខាក់ខនឹងនឹងស្តាបតម្បាក់ដ៏តិចក្រាតជានេះ ? ខេបនភាព (ការរុញ) ដូចម្តេច ដែលរុញច្រានសិល្បៈខ្មែរឲ្យមានវិសិដ្ឋភាពដ៏សមគួរពុកជាតំរូនេះ ? ហើយម្យ៉ាងទៀត ប្រហែលចំនួនច្រាំសតវត្សពីនោះមក តើមានការប្រព្រឹត្តទៅយ៉ាងណា ដែលញ៉ាំងប្រាសាទទាំងឡាយនៃអង្គរ ព្រមទាំងព្រះអធិរាជាណាចក្រខ្មែរឲ្យស្ទើរតែកប់បាត់ទៅក្នុងការមិនដឹងខ្លួន ?

ខ្មែរ (ដើម) ជាបុត្តបុរសខ្មែរសព្វថ្ងៃ នឹងជាអ្នកទទួលកេរ្តិ៍តំព្រះអធិ
ពជាណាចក្រដ៏យាំងធំចាស់បំផុត ដែលប្រទេសឥណ្ឌៀបស្ថិមទិសស្គាល់
ច្បាស់ ហើយដែលប្រកតចិនហៅថា (ហ្វូណន) បានចាប់តើតនូវទម្រង់រដ្ឋ
ខ្លួនមួយ ក្នុងរវាងឆ្នាំ ៥៥០ ។ ដរៃតំកិច្ចវិវត្តន៍ខាងប្រវត្តិសាស្ត្រប្រកប
ដោយការរំកើប ហើយក្នុងសម័យនោះ ប្រទេសត្រូវបែកខ្ញែកគ្នា ព្រម
ទាំងបានចាត់ឯកភាពជ្រុះផងនោះ គេប្រទះឃើញការកសាងឯកភាព នឹង
អំណាចជាថ្មីឡើងវិញ នៃព្រះពជាណាចក្រ ក្នុងរជ្ជកាលនៃព្រះបាទ
ជ័យវរ្ម័នទី ២ (៨០២-៨៤៩) ដែលតាំងនៅក្នុងសតវត្សទី ៩ ។ សម័យ
ខ្មែរចាប់ផ្តើមមានឡើងតាំពេលនោះឯង ។ តមក សម័យនោះមានការ
ចំរើនឡើងដល់កំពូលទៅសតវត្សទី១២ នឹងទី១៣ រួចធ្លាក់ចុះទៅសតវត្ស
ទី១៥ ។ សេដ្ឋកិច្ចនឹងវប្បធម៌ដែលមានការរីកចំរើនដ៏ល្អ កសិកម្មដែល
មានការវិវត្តន៍ ខុសជាមួលដ្ឋានខាងសេដ្ឋកិច្ចនៃព្រះអធិពជាណាចក្រ ។
ខ្មែរជាគ្រួកងការកសាងរមៀងទឹក ព្រែកជីក ប្រឡាយបញ្ចូលទឹក នឹងប្រឡាយ
បង្ហូរទឹក ។ ព្រះមហាក្សត្រទ្រង់ព្រះអំណាចផ្តាច់ការ ។ សាសនា
ព្រាហ្មណ៍ជាសាសនារដ្ឋ តមកព្រះពុទ្ធសាសនាក៏ផ្សាយចូលមកដែរ តែ
មានសភាពមិនបរិតថែរ ។ តាមការពិត ប្រជាជាតិ (ខ្មែរ) មិនបាន
កាន់សាសនាទាំងឡាយនៃប្រទេសឥណ្ឌៀ ដូចជានៅក្នុងប្រទេសឥណ្ឌៀ
សោះទេ ។ មជ្ឈដ្ឋានខ្មែរក៏មិនបានប្រកាន់លំនៀងដ៏យាំងណាស់ណា

ដូចជានៅប្រទេសឥណ្ឌាដែរទេ ។ ប្រជារាស្ត្រកាន់ទុកនូវការគោរព
បូជាខាងសាសនាតាមដើមកំណើតនៃខ្លួន ម្យ៉ាងទៀតការគោរពបូជានេះ
ច្រើនតែមានអានុភាពមកពីប្រពៃណីខាងសាសនានៃព្រះរាជបល្ល័ង្ក ។
គេអាចខ្លួលស្គាល់ជាន នូវការគោរពបូជាបុគ្គលបុរសក្នុងការបង្ហាញឲ្យ
ឃើញនូវបែបខ្មែរសុទ្ធ គឺការគោរពព្រះមហាក្សត្រទុកជាទេពតានេះឯង
ព្រោះព្រះមហាក្សត្រគឺជាទេពតាដែរ ។ ការទុកព្រះមហាក្សត្រតាំងឡើង
ជាទេពតា ក្នុងវេលាដែលទ្រង់គង់ព្រះជន្មនៅ បង្កើតនូវប្រកបនៃអំណាច
ដ៏តេជានុភាពនៃព្រះអង្គ ព្រះអំណាចនេះជាជាតុកម្មនៃសម្ពន្ធភាពរវាង
រដ្ឋនិងសាសនា ។ សារវន្តពីរសៃនៃស្ថាបត្យកម្មខ្មែរនិងមិនដាច់ស្រឡះ
ក្នុងកិច្ចស្ថាបនានៃព្រះមហាក្សត្រតាំងឡើង បណ្តាលមកតែពីដំណើរខាង
លើនេះដែរ ។

ព្រះមហាក្សត្រតាំងឡើង កាលដែលទ្រង់គង់ព្រះជន្មនៅ រមែង
មានខម្ចាប់សត្វព្រះរាជហប្ញទ្ធិយបញ្ជាឲ្យស្ថាបនាសម្រាប់ព្រះអង្គ នូវបច្ច-
មរណប្រាសាទ ។ ឯប្រាសាទតាំងនេះមិនមែនសម្រាប់មនុស្សនៅទេ
គឺសម្រាប់ទេពតា ហើយមានតែព្រះសង្ឃទើបអាចនិមន្តចូលក្នុងប្រា-
សាទនេះបាន ។ ប្រាសាទតាំងឡើងសង់នូវតែណាលពីក្រុង ហើយ
ជាតំណាងផ្តិតពីតតាលោក គឺភ្នំព្រះសុមេរុនេះឯង ដែលយើងធ្លាប់ស្គាល់
អំពីរឿងបូរាណសាស្ត្រនៃប្រទេសឥណ្ឌាជាន់ចាស់ទោះ ។ ការបញ្ជាក់

ជំត្រឹមត្រូវដែលសម្រេចឡើងតាមចំណុចវិសេសចាំងឡាយ ក៏ជាហេតុនៃតំណើរសង់របៀបនេះដែរ ប្រាសាទចាំងឡាយកសាងលើកូនភ្នំធម្មជាតិហើយតមកលើភ្នំអធម្មជាតិក៏មកពីហេតុនេះដែរ ប្រាសាទចាំងឡាយតែងមានរោងទឹកដូចជាកូនសាគរពន្ធដុំវិញ ក៏មកពីហេតុនេះដែរ សេចក្តីសណ្ឋាននៃស្ថាបត្យកម្មក៏មកតែពីហេតុនេះដែរ ។

ដូច្នេះ ពីសម័យមួយទៅសម័យមួយ គេអាចយកប្រាសាទអង្គរជាបែប ហើយតាមតំណែកខ្លះកាលវិវត្តន៍ទំនើកការកែចំរើននៃសិល្បៈខ្មែរបានមិនឃ្លាតប៉ុន្មាន ឥដ្ឋសម្រាប់កសាងមានចំនួនមិនគ្រប់គ្រាន់ ហើយគេទៅយកថ្មាំងសិលាដ៏ធំ ពីរខ្នងយកថ្មដែលនៅឆ្ងាយ ។ ។ សិល្បៈកន្ទើនសិល្បៈខ្មែរតាំងឡាយជាមេចម្លាក់ឈើតាំងពីដើមមក ក៏បានរៀនតុបតែងលំអថ្មាវេដ្ឋ ហើយជាអាសនចេះលំអតាំងជញ្ជាំងសិលាតាំងឡាយថែមទៀត ។ ពួកនេះវេទានាថ្នាក់ដូចជាធ្នាក់ឈើមានសាច់ខ្លះដែរ ។ ជាបឋម ខ្មែរធ្វើស្តម្ភសិលា ដូចស្តម្ភនេះជាផ្លោងផ្ងារធ្វើពីឈើ ។ ភ្នំបាក់ខែងមានកាលបរិច្ឆេទនៅដំណាច់សតវត្សទី ៩ ជាសំណង់ព្រះលានលើកជំបូង គឺសំណង់នេះហើយជាដានតន្ទុកនៃអនាគតស្ថាបត្យកម្មដ៏រុងរឿង ។ គឺនៅបន្ទាយស្រី ដែលកសាងពីថ្នាក់តាំងប៉ុន្តែក្បាច់ក្នុងសតវត្សទី ១០ នេះហើយ ដែលគេដួបប្រទះនូវក្បាច់ចម្លាក់លើថ្មាំងសិលាដ៏ល្អបំផុត នូវ

ក្បាច់ចម្លាក់ក្បាលសរសរល្អយ៉ាងធ្វើតអស្ចារ្យក្រៃលែង ទំនង់ជាំងចម្លាក់គួរជាខ័ខេតនា ហើយដែលគេខួលទុកជាសោភណភាពខាងផែនដី ។ ប្រាសាទចាក្ខ (សតវត្សរ៍ទី ១១) បណ្តាលឲ្យយល់ច្បាស់នូវគោលគំរូបូរាណនៃស្ថាបត្យកម្មខ្មែរ ។ ស្ថាបត្យកម្មខ្មែរដែលអាចបង្កើតនូវតួតាំងពួងក្នុងសម័យខ្ពស់បំផុតបាន (ក្នុងសតវត្សរ៍ទី ១៣) ក៏ដោយសារតែមានប្រាសាទតាំងអស់ខាងលើនេះ ទំនង់ប្រាសាទដទៃទៀតច្រើន ជាការផ្តើម ។ វត្តដ៏ថ្លៃថ្លាក្នុងសម័យនោះ គឺប្រាសាទអង្គរវត្ត ព្រោះអង្គរវត្តជាខ័ប្រជុំចុះនៃប្រាសាទតាំងល្បាយ ដែលចាត់ទុកជាសំណង់ធំបំផុតប្រកេទនេះក្នុងលោក វត្តដ៏ថ្លៃថ្លាមួយទៀត គឺអង្គរធំដែលជាដំណែលនៃព្រះពុទ្ធជាន័ ។

គ្មរមនុស្សទាំងឡាយ ទិតខំខ្វល់ខ្វាយ
គិតដល់ការស្លាប់ មុនធឹងផ្លាស់ភព
ត្រូវមានគុណគាប់ ណាខ្លះសម្រាប់
ទុកជាក្បែរហោង

អ្នកភៀងដើម្បីជាតិ

ហៃកុមារ ចូរខំទាំគ្នា រៀនអក្សរសោស្ត្រ ចូរកុំតេរលេង ត្រូវខឹកអៀនខ្មាស ហាត់អានឲ្យច្បាស់ សរសេរឲ្យត្រូវ ។ រៀនសូត្រឲ្យចេះអស់អាថិចំណេះ កុំឲ្យសត្រូវ ញាំញីលើក្បាល ចំរកាលតទៅ នាំឲ្យអាស្រូវ ថោកដល់ជាតិខ្មែត ។ រដ្ឋខ្មែរតូចណាស់ ចូរប្រែក្រឡាស់ រិះរកស្មៀត កុំទៅរៀបឡ ខាតគេលចធំមៀត នាងអើយខំធ្វើត ខាន់នាងទៅក្មេង ។ ចូរនាងជឿថា រដ្ឋខ្មែរថ្លៃថ្លា ដោយសារនោងឯង ដែលខំស្វាធ្យាយ ដើម្បីចាត់ចែង តាំងផ្ទះសម្បែង ឲ្យល្អដូចគេ ។ ខ.មោ.ក.ខ ហាត់អានឲ្យល្អ កុំទៅខំខេរ ដ៏សម្ដៅដៃ ត្បាយមសរសេរ កុំចាំគ្រូជេរ រៀនសោះគេថា ។ កុំដូចមនុស្សខ្វាក់ តាមតែគេញាក់ ទ្រេងស្តាំតាមការ តួកជនបែបខេះ មានកូនតម្រា ថានាំអាត្មា ទៅរកក្តីខុក្ខ ។ ខ-ម-ក-ម បូកសងតាមក្បួន គុណចែកតាមមុខ កុំច្រេសប្រហែស ខំរៀនត្រង់ស្រួក ទើបដេញបានសុខ រស់ពនក្សេមក្សាន្ត ។ អនាគតតីអ្នក ដូច្នេះត្រូវស្ងើគ្រកុំខំខេរច្រណែ ខ្មៀយហាត់កុំគួញ យកចេះឲ្យបាន ខ្លួនខាងថ្ងៃនថ្ងាន តីព្រោះខ្មៀយមុន ។ ខំគួសខំគួរ អស់ពីងគំនួរ ជួនស្រាលខំពន់ ចំណេះខេះហើយ ដែលនាំខ្លួនគុណ បុណ្យសក្តិត្រូវជន ដល់ជាតិដល់អ្នក ។ ជំនួញជួញប្រែ ជាតិគេថ្លើតែ បន្ទំលួចលាក់ ចិតក្អែកខ្មែរស៊ី ព្រោះជាតិខ្មែរខ្វាក់ នាងអើយគួរភ្ញាក់ ខំរុលទៅមុខ ។ រៀនដើម្បីអ្វី ដើម្បីទឹកដីចូរចងចាំខ្ពុក រដ្ឋកម្ពុជា កេរ្តិ៍ម៉ែឪតាំពុក សាងបានជាស្រុក ដោយសារសោចំឈាម ។ បើជាតិត្រូវការ នាងកុំសាកំ ថយក្រោយខ្មីមតាម ស៊ុះស្ងើគ្រ

ចំរើ ឲ្យចាន់តេលក្តាម នោះរើបដល់តាម តើសុខសប្បាយ ។ តោះរស់តោះស្លាប់ ស្រីប្រុសប្រញាប់ ត្រូវបួងាយ ដល់មាតុភូមិ កុំបីខឿយ-ណាយ ដីវិតកុំស្តាយ ស្តាយត្រង់តែជាតិ ។ បើសត្រូវដំរះជាន់ ត្រូតតកុំ-ត្រាន់ ភយាក់ឲ្យឃ្លាត កុំដេកផ្សងត្រេង ត្រូវក់យឲ្យត្រាត់ ភយឲ្យខ្លាយ ខ្លាត់ ចាកតិតិតដី ។ ត្រូវបួងដីវិត ស្លាប់រស់កុំគិត ណាខាងប្រុសស្រី រស់នៅខ្ញុំគេ មិនប្រសើរអើ ស្លាប់ព្រោះបួរី ជយោស្លាប់ចុះ ។ បើខាង បណ្តាយ ដល់ពេលថ្ងៃក្រោយ គ្មានបញ្ហាឆ្ងុះ ព្រោះខ្លីលកុំរៀន តំនិត-តុញតុះ ដល់ដឹងថាខុស ចាស់ជ្រុលពេលហើយ ។ តេលកន្ទុងពៅ អ្នក-ខាងស្រែកហៅ ពុំលៃរៀបឡើយ ទៅក្នុងត្រូវប្រឹង កុំធ្វើព្រងើយ នៃអ្នក ខាងអើយ មកពៅ! មកពៅ! ។ មកពៅសាលា ខាងកណ្តៀតក្តារ ក្រាបណាមែន បបួលមិត្តភ័ក្តិ កុំគិតកាត់ខ្លៅ ខំរៀនណាពៅ អ្នកខាង ភូនខ្មែរ ។ មែនសប្បាយ ចិត្តលោកខ្វល់ខ្លាយ ខិតខំធ្វើស្រែ ខាងសង្ឃឹត រៀន ឲ្យបានពូកែ កុំយំឲ្យខ្សែខ្សួ ខ្មាសជាតិដែតខាង ។ គុណគ្រូត្រូវស្គាល់ យប់ថ្ងៃខាងតាល់ ឆ្លឹតឆ្លងសំអាង តើត្រូវខេះហើយ ដែលដួយកសាង ភស-នាសំណាង ឲ្យខាងពលគ្នា ។ ចូរខាងចងចាំ អស់តំងបណ្តាំ ខាងលើ ខេះណា ព្រឹកស្អែកត្រៀមខ្លួន ចេញចរយាត្រា ឆ្ពោះពៅសាលា ខំសិក្សាអើយ ។

(១).

ខេះតើបណ្តាំរបស់ខ្ញុំ ជាពាក្យសុខុមបរមរម្យ សូមអស់លោកអ្នក តិនិត្យថែម បើមិនសូវផ្អែមសូមជួយតម្រង់ ។

(១) ពាក្យខេះអ្នកនិពន្ធដាក់បន្ថែមខាងចុងអត្ថបទ:បង់ខ្លួន ។

ព្រះរាជពិធីបួងសួងលាព្រះបំណង់នៅខេត្តសៀមរាប និងខេត្តកណ្តាល

ពិធីបុណ្យបួងសួងលាព្រះបំណង់នៅលើភ្នំគូលេន

នៅថ្ងៃទី ៤ កក្កដា មានធ្វើព្រះរាជពិធីបួងសួងលាព្រះបំណង់នៅលើភ្នំគូលេន ។

នៅថ្ងៃនោះ ឥស្សរជនតំណាងព្រះពុទ្ធសាសនិកមកពីគ្រប់ទីកន្លែងនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានតំណាងប្រតិភូតំណាងខេត្តនានា ក្នុងព្រះរាជអាណាចក្រ រួមជាមួយអ្នកស្រុកបានធ្វើដំណើរឡើងកាន់ភ្នំគូលេន ដែលមានចម្ងាយ ៤០ គ.ម. ពីអង្គរវត្ត ។

នៅម៉ោង ១១ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំសម្តេចម៉ែ ឡើងទៅលើភ្នំគូលេន ។

នៅពេលដែលស្តេចយាងចុះពីព្រះមហាក្សត្រ ព្រះអង្គបានទទួលការក្រាបថ្វាយបង្គំ អំពីអ្នកអង្គម្ចាស់ ឧកញ៉ាឧត្តម-ភក្តី ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ, ឯ.ឧ. សាន-យុន ផ្ទះ-ព្រៀង ពីឯកឧត្តម-នេរ៉ូ ភូ-ពុន សមាជិកវដ្ឋកិច្ចសភា សមាជិកសភាពីរ មន្ត្រីអ្នកជំនាញ ពាណិជ្ជករ ស៊ីវិលទីជ្រាលវដ្ឋជាច្រើន រួចស្តេចយាងបន្តព្រះដំណើរឡើងលើកំពូលភ្នំ ដើម្បីបួងសួងក្នុងពិធីបុណ្យព្រះបរិត្ត-ប្រគេនខ្សែគ្រឿងបរិក្ខារផ្សេងៗ ជូនព្រះសង្ឃ ។

បន្ទាប់មកព្រះអង្គបានស្តេចយាងទៅកាន់ព្រះតន្លា ដើម្បីទ្រង់ជាព្រះអធិបតីក្នុងព្រះពិធីបួងសួងលាព្រះបំណន់ ។

នៅលើព្រះតន្លា មានរៀបចំដង្វាយផ្សេង ។ ដំកល់នៅលើតុបែរមុខឆ្ពោះទៅព្រះស្តូបនៃព្រះបដិមាករុក្ខរូបចូលព្រះបរិនិព្វាន ដែលបិតនៅខ្ពស់លើថ្នាំងសិលា ។

ក្រោយដែលលោក ហ៊ឹន តេជ្រសុវិយោ ញែម.ចន ថ្លែងប្រកាសប្រគេនថ្វាយព្រះបដិមាករ ព្រះអតីតព្រះមហាក្សត្រតាមព្រះពរជប្រពៃណីនិងបួងសួងសុំទឹកភ្លៀង និងក្រោយដែលស្តេចព្រះពរជទ្រង់បានកាំថ្វាយព្រះពុទ្ធបដិមាករ និងព្រះអតីតព្រះមហាក្សត្រហើយ សម្តេចជាអគ្គស្តីព្រះអង្គបានទ្រង់ប្រកាសថ្លែងចំពោះព្រះបដិមាករ ចំពោះព្រះអតីតព្រះមហាក្សត្រ ចំពោះទេវតាថាំងឡាយ និងចំពោះវត្ថុស័ក្តិសិទ្ធិថាំងអស់អំពីអំពើយោរយៅយង់ឃ្នងនៃសៀមនិងយួន ដែលចេះតែរុកពន្លឺចាបក្រស្តែខ្មែរនឹងបន្ថែកដីខ្មែរ ។

ព្រះអង្គបានក្រាបចង្គំទូលសុំឲ្យជាក់ខណ្ឌកម្ម ចំពោះសត្រូវរបស់ខ្មែរឲ្យវិនាសឲ្យឆ្លុតឆាប់ដោយព្រឹត្តិការណ៍ណាមួយ ។

ក្រោយពិធីបួងសួង ព្រះអង្គបានស្តេចយាងឡើងទៅលើព្រះស្តូបជាក់ព្រះកេសថ្វាយចំពោះព្រះបដិមាករ ជាព្រះពរជកិច្ចលាព្រះបំណន់ ។

នៅឧកាសនោះ ឥស្សរជន ព្រះពរជវង្សានុវង្ស និងពលហ្វូងខែក្រ

ខ្ញុះ ចាន់ដាក់ព្រះកេស ចានកោរសក់ ថ្វាយព្រះបដិមាកដៃឆ្លែសម្តេច ព្រះប្រមុខរដ្ឋដែរ ។

សូមជ្រាបថា ពិធីបុណ្យនៅលើកំភូលេននេះ មានធ្វើជាបន្តនៅថ្ងៃ ទី ៩ ទឹងថ្ងៃទី ៦ កក្កដា តាមទំនៀមទម្លាប់អ្នកស្រុកខ្មែរ ។

ពិធីដាក់បាត្រព្រះសង្ឃមួយរយអង្គនៅអង្គរវត្ត

នៅវេលាព្រឹកនៃថ្ងៃទី ៩ កក្កដា នៅអង្គរវត្ត ត្រង់ព្រះពាន់ មានធ្វើពិធីដាក់បាត្រព្រះសង្ឃមួយរយអង្គ ក្រោមព្រះពាក្យធិបតីភាពនៃសម្តេចព្រះពុជមនិដ្ឋាស្នើសោភ័ណ ជាព្រះពុជដំណាងនៃសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ដីតែលើតួង ដោយមានសហជីវិន ចាន ឧ . ឈឺន ឥន្ទ មន្ត្រីក្រសួងធម្មការអមជង ។

ពិធីនេះ ចានកើតឡើងដោយហេតុការណ៍ថ្ងៃមេសា ១៩៦១ សហជីវិន អាំង-គីម-ឃង ចានអញ្ជើញភ្ញៀវកិត្តិយសជាង ក្រុងចាំងអស់ទៅទស្សនាអង្គរវត្ត ។ ក្នុងពេលនោះ ប្រទេសថៃកំពុងតែកាន់អាកប្បកិរិយាដ៏តឹងរឹង មិនត្រមទទួលស្គាល់សមត្ថកិច្ចតុលាការអន្តរជាតិចំពោះទុក្ខកង្វល់ក្តីព្រះវិហារ ហើយប្រើអាកប្បកិរិយាយ៉ាងការគាបសង្កត់លើកម្ពុជា ក្នុងរឿងព្រះវិហារនេះទៀតផង ។ អ្នកតំណាងក្រុងចាំងអស់ក៏ចានាំគ្នាចន់ស្រន់ដល់ព្រះពាន់ ដែលមានព្រះភក្ត្រតែនលិចដាំប្រជានសូមឲ្យព្រះតេជៈជាម៉ែ ជួយឲ្យខ្មែរចានឈ្នះក្តីព្រះវិហារនេះ ។

លុះដល់មកថ្ងៃទី ១៩ មិថុនា ១៩៦២ ខ្មែរកំពុងឈ្នះក្តីព្រះវិហារ ខេះដូចជាបំណងមែន ។

ហេតុដូច្នេះ ពួកជាអ្នកតំណាងរាស្ត្រទាំងអស់ ពួកនាំគ្នាមកធ្វើបុណ្យជាក់ជាក្រលាបំណងនឹងថ្វាយក្នុងតិណាគារ ៧ ចប់ ។

ព្រះរាជពិធីបុណ្យរំលឹកជ័យជំនះក្តីព្រះវិហារ នៅខែត្រសៀមរាប ក្នុងថ្ងៃទី ៩ កក្កដា

ថ្ងៃទី ៩ កក្កដា ជាថ្ងៃទី ៧ នៃព្រះរាជពិធីបុណ្យបួងសួងលាព្រះមហាទន រំលឹកដល់ជ័យជំនះរឿងក្តីព្រះវិហារ នៅខែត្រសៀមរាប ។ ព្រះរាជពិធីនាថ្ងៃនេះ កំគ្មានអ្វីប្លែកដែរ ដោយបានប្រារព្ធឡើងជាពិធីបុណ្យតាមទំនៀមទម្លាប់នៃព្រះពុទ្ធសាសនាតែនៅព្រះរាជតំណាក់ខែត្រសៀមរាប វេលាម៉ោង ៧ ព្រឹក សម្តេចព្រះមាតាជាតិជាទីគោរពនឹងសម្តេចព្រះប្រមុខរដ្ឋ បាននិមន្តព្រះសង្ឃមួយចោមអង្គ ដែលមានព្រះតេជព្រះគុណព្រះគោជាវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សាក្នុងព្រះរាជអាណាចក្រនឹងព្រះតេជព្រះគុណមេគណខែត្រសៀមរាប ជាប្រធានសង្ឃ និមន្តមកជាអធិបតីដើម្បីជាក់ជាត្រជាកចិត្តថ្វាយព្រះរាជកុសល ដល់ព្រះអតីតព្រះមហាក្សត្រខ្មែរទាំង ៤ ។

គេលឺដែលព្រះសង្ឃបាននិមន្តមកដល់ហើយ សម្តេចព្រះមាតាជាតិជាទីគោរពដោយមានសម្តេចព្រះប្រមុខរដ្ឋ សម្តេចក្រុមព្រះ ស៊ីសុវត្ថិ-

ម្ចាស់ដីវត្ត ប្រជានុត្តមក្រុមប្រឹក្សាព្រះកដឋលស្ងួត សម្តេចព្រះកដឋតនិដ្ឋ វេស្ស៊ីសោភ័ណ ព្រមទាំងព្រះកដឋបរិតាវជាន់ខ្ពស់ជាច្រើនអមព្រះកដឋំណើរផង ចានស្តេចយាងចេញពីព្រះកដឋំណាក់មកតង់ប្រថាប់នៅព្រះតន្ទាដ៏យ ។

តមក ព្រះសង្ឃកិច្ចានស្វាធ្យាយធម៌ដយន្តោប្រសិទ្ធិពរដ៏យនឹងធ្វើភត្តានុមោទនា ជាកិច្ចថ្វាយព្រះកដឋកុសលក្នុងពិធីដាក់ឫត្រនេះ ។

បន្ទាប់ពីនេះមក ព្រះសង្ឃទាំងឡាយ កំចានទទួលចង្ហាន់បិណ្ឌបាត្រ ហើយសម្តេចព្រះមាតាជាតិ នឹងសម្តេចព្រះប្រមុខរដ្ឋ ព្រះកដវង្សានុវង្ស សមាជិកគណៈរដ្ឋមន្ត្រី សមាជិកសភាទាំងពីរខ្នះ ចៅហ្វាយខែត្រនានា មន្ត្រីខែត្រ ព្រមទាំងពុទ្ធបរិស័ទប្រុសស្រីជាច្រើន ចានស្តេចយាង នឹងអញ្ជើញជាក់ឫត្រព្រះសង្ឃទាំង ១០០ អង្គ ក្រោមបរិយាកាសដ៏សែនរីករយ ។

ព្រះរាជពិធីប្លងសួងប្លាយវត្តសក្តិសិទ្ធិ

នៅប្រាសាទអង្គរ ក្នុងថ្ងៃទី ១០ កក្កដា ១៩៦២

នៅថ្ងៃទី ១០ កក្កដា ១៩៦២ ជាថ្ងៃបុងក្រោយបំផុតនៃព្រះកដឋពិធីប្លងសួងលាព្រះបំណន់ នឹងពិធីបុណ្យរំលឹកដល់ដយដំនះក្នុងរឿងក្តីប្រាសាទព្រះវិហារនៅខ្ទមខែត្រសៀមរាប ។ ព្រះកដឋពិធីនាថ្ងៃនេះ កំចានប្រព្រឹត្តទៅដូចជាថ្ងៃមុនៗដែរ គឺនៅវេលាព្រឹកមានមហាជនប្រុសស្រីចាស់

ក្នុងគ្រប់សាសន៍ ចាននាំគ្នាទៅទស្សនាប្រាសាទបុរាណនានាជាដម្ងែ ។
លុះល្ងាច នៅប្រាសាទអង្គរវត្ត មានធ្វើពិធីបួងសួងថ្វាយវត្ថុសក្តិសិទ្ធិ
ដ៏មហោរឹក ដែលនៅទីនោះ មានការរៀបចំតាក់តែង រំលេចរចនាទៅ
ដោយខន់ជាតិ ភ្លឺផ្លាយាំងប្រសើរគួរជាទីទស្សនា ព្រមទាំងមានរៀបចំ
ភោជ្យភក្ត្រក្រយាប្រណីត វិចិត្រដោយគ្រឿងទេសវិសេសវិសាលគ្រ-
កាលរុងរឿងជាគ្រឿងជង្ហាយចំពោះវត្ថុសក្តិសិទ្ធិទាំងអស់ ព្រមទាំងមាន
ការដួបជុំព្រះពជវង្សានុវង្ស នាហ្មឺនសព្វមុខមន្ត្រី ពហាន ស៊ីវិល ឃុំនែ
ឃុំតែ ខ្មែរប្រជាតាលរដ្ឋជារច្រើនតាន់នាក់ ដែលបាននិយាយ ខ្មែរ
អញ្ជើញទៅ ដើម្បីរង់ចាំក្រាបថ្វាយបង្គំតាល់សម្តេចព្រះមាតាជាតិជាទី
គោរពនៅទីនោះ ។

នៅវេលាម៉ោង ៥ ល្ងាច សម្តេចព្រះមាតាជាតិជាទីគោរព ដោយ
មានសម្តេចព្រះប្រមុខរដ្ឋ សម្តេចក្រុមព្រះប្រធានខុតុមក្រុមប្រឹក្សាព្រះពជ
បល្ល័ង្ក ព្រះពជវង្សានុវង្សខ្លះ ខ្មែរព្រះពជបរិពារជាន់ខ្ពស់ថ្នាល់ព្រះអង្គអម
ព្រះពជដំណើរផង បាននិយាយទៅដល់ប្រាសាទអង្គរវត្ត ជាកន្លែង
ប្រារព្ធព្រះពជពិធីបួងសួងសាព្រះបំណន់ ។

តមក ហ្មឺនតេជ្រសុវិយោ ភ្ញៀម-ចន កំបានសូត្រប្រកាសបួងសួង
សាព្រះបំណន់ ។ លុះចប់សេចក្តីប្រកាសបួងសួងនេះហើយ ក្រុម
ស្មោនព្រះរាជទ្រព្យ កំបានចញ្ចឹមករៀបថ្វាយវត្ថុដ៏សក្តិសិទ្ធិទាំងឡាយ

ដោយថានគាប់ក្បាច់យ៉ាងស្រស់ឆើតឆាយ ហាក់បីដូចជាកិន្នរី នឹងទេព អប្សរបៅតញ្ចាំនៃចម្ងាក់ប្រាសាទអង្គរ ដោយមានក្រុមភ្ញៀវតំណាងឲ្យព្រះ ពជទ្រឲ្យ ថានបន្ទីនូវបទនានាជាចង្ហាក់នៃការកំនេះផង ។

ព្រះពជតិធីនេះ ថានប្រព្រឹត្តទៅក្នុងបរិយាកាសដ៏ជាទីរីករាយក្រៃលែង។

ព្រះរាជពិធីបួងសួងលាព្រះបំណង់នៅព្រះវិហារស្ទរ ស្រុកខ្សាច់កណ្តាល (កណ្តាល)

នៅថ្ងៃទី ១៨ ខែកក្កដា ១៩៦២, ពេលរសៀល សម្តេចព្រះបិតាជាតិ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុតនៃប្រជាពលរដ្ឋខ្មែរពាំងមួល ព្រះអង្គថានស្តេចយាងច្រាត្ន ព្រះពជតិធីបួងសួងលាព្រះបំណង់នៅវត្តព្រះវិហារស្ទរ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

នៅពេលម៉ោង ៤ ទឹង ៣០ នាទីរសៀល ព្រះទីនាំងទ្វម្ចាតចក្រតិសេស របស់ព្រះអង្គមួយគ្រឿង ដោយមានអាកាសយានពាំងឡាយហោះអមផង ថានដឹកនាំព្រះពជដំណើរបស់ព្រះអង្គ មកចុះចតនៅលើមណ្ឌលចុងភូមិ ព្រះវិហារស្ទរដែលគេថានរៀបចំចុក ។ នៅពេលយាងចុះពីព្រះទីនាំងក្នុង ព្រះអង្គថានទទួលកូនផ្កាអំពីកញ្ញាដ៏ស្រស់ឆើតឆាយបីរូបនៃភូមិព្រះវិហារ - ស្ទរ ជានិមិត្តរូបនៃការថ្វាយព្រះពរសេពួសាធុការយ៉ាងទត្តមចំពោះព្រះអង្គ ទឹងដើម្បីជានិមិត្តរូបនៃសេចក្តីស្នេហានឹងស្មារតីក្តីដឹងស្មោះស្ម័គ្រផង ។

ចន្លោះមក ព្រះអង្គបានទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជនច្រើនរូបជាអាទិ៍ ឯកឧត្តមព្រឿង-ភាង ឯកឧត្តមតូ-វុន សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក លោកឧត្តមសេនីយ៍ឯកលន់-ណុល ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីភ្នាក់ងារការពារប្រទេស ឯកឧត្តមជុំច-ឈឺន រដ្ឋមន្ត្រីក្រសួងធម្មការ ហើយបន្ទាប់មកទៀត ព្រះអង្គបានទទួលតាវៃកិច្ចយ៉ាងខ្ពង់ខ្ពស់ជំនុត អំពីកងរាយោធពលខេមរភូមិន្ទ កងរាជតម្រួត កងអាសាស្ត្រ ឃុវជនរាជសង្គមនិយមខ្មែរជាច្រើនក្រុមដែលបានលើកអាវុធធ្វើវន្ទនកិច្ចនឹងបន្ទូលបទភ្លេងចរលីលា ទីឯកន្លែងជាតិថ្វាយជាព្រះរាជកិត្តិយសចំពោះព្រះអង្គ រួចហើយស្តេចយាងឡើងព្រះទីនាំងរថយន្តយាងព្រះរាជដំណើរ ចូលមកកាន់វត្តព្រះវិហារសួរ ដែលមានចម្ងាយជាង ៩០០ម. ពីកន្លែងចុះព្រះទីនាំងទទួលភ្ញៀវកិត្តិយស ។ ក្រោយពេលដែលបានយាងចូលមកដល់ទីវត្តហើយ ព្រះអង្គបានយាងឡើងលើខ្នើតព្រះវិហារដែលតាក់តែងរៀបចំយ៉ាងស្រស់ដោយភ្លឺថ្លា ទីឯរំយោលនានាគួរជាទីរីករាយ ។ បន្ទាប់មកព្រះអង្គបានក្រាបថ្វាយបង្គំព្រះសង្ឃជារាច្រើនអង្គ ដែលគង់ក្នុងទីនោះមានព្រះតេជព្រះគុណអនុគណជាប្រធាន ហើយព្រះអង្គបានទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជនជារាច្រើនរូបទៀត ។

ក្រោយពេលដែលទ្រង់គង់ប្រថាប់ សម្រួលព្រះឥរិយាបថបន្តិចមកក្រុមឃុវ័ន ឃុវ័តនៃដំបន់ព្រះវិហារសួរមួយក្រុមបានច្រៀងនូវបទម្រៀង

ថ្វាយពរដ៏ឃ្លាំងចំពោះព្រះអង្គ ។

លុះចប់ចម្រៀងថ្វាយព្រះពរដ៏ឃ្លាំងហើយ សម្តេចឧជ្ជាទីឥសោរ ជាន
ទ្រង់ថ្វែងព្រះពុទ្ធសង្គីតិ មួយរៀបចប់អតីនយោ ជាយក្នុងប្រទេសខ្លះ នឹង
ក្រៅប្រទេសខ្លះ ដែលសោរតេញដោយទុត្តគតិយុត្តិធម៌ ។

លុះចប់ សម្តេចព្រះបិតាជាតិ ជានស្តេចយាងចូលកាន់កោងក្រសាល
សម្រាប់ប្រារព្ធពិធីបួងសួងលាព្រះបំណន់ ដែលតាំងនៅអមតួព្រះវិហារ
ធំដែលតំកល់ព្រះភុទ្ធបដិមាករមានព្រះជាមើយាំងភូកែស័ក្តិសិទ្ធ ហើយ
នៅពេលជាបន្ទាប់គ្នានោះ មានចាប់ផ្តើមតិធីនមស្សការថ្វាយបង្គំ ចំពោះ
គុណព្រះរតនត្រៃយ៉ាងកងរំពង ។

បន្ទាប់ពីពិធីនមស្សការព្រះរតនត្រៃនេះមក សម្តេចព្រះបិតាជាតិ
ជាទីសោរេដោយមានព្រះរាជបរិវារអមព្រះរាជដំណើរផង ជានស្តេច
យាងចូលក្រាបថ្វាយបង្គំព្រះដីវ៉ែអង្គធំ ក្នុងតួព្រះវិហារធំដែលមានព្រះជាមើ
យាំងភូកែស័ក្តិសិទ្ធអស្ចារ្យនោះ ដោយព្រះឥរិយាបថយ៉ាងរៀបរយ ប្រ.
កបដោយព្រះកាយយ៉ាងខ្ពង់ខ្ពស់ជាទីបំផុត រួចហើយស្តេចយាងនិវត្តន៍
ចូលមក ក្នុងព្រះរាជកោងក្រសាលវិញ ។

ចំណែកក្រុមសេវកាមាត្យទាំងឡាយ ក៏ជានចាប់ផ្តើមធ្វើពិធីបួងសួង
លាព្រះបំណន់ ដែលនៅទីនោះមានរៀបចំភាជនីយភោជនីយាហារក្រយា
ស្វាយ ជាយសី ស្វាធមិ យ៉ាងសោរសាស ដែលជាដំបូង

ម៉ឺនពេជ្រសុវិយោ ព្រៃម.ចន កំចានសូត្រតាក្យលាព្រះចំណន់ដែលព្រះអង្គចានចន់កងរឿងក្តីប្រុសាទព្រះវិហារមានដីយដំនះនេះ ។

បន្ទាប់ពីសេចក្តីប្រកាសលាព្រះចំណន់នេះរួចហើយ ក្រុមភ្ងេងពិណតាខ្យព្រះពរជ្រត្យកំចានចន្ទីឡើង ហើយក្រុមកុមារីនៃចាំព្រះពរជ្រត្យចានរចាវេកំថ្វាយព្រះអង្គជាកិច្ចបង្ហើយលាព្រះចំណន់ ។ ការកំនេះចានប្រព្រឹត្តទៅយ៉ាងស្រស់ឆើតឆាយ ខន់ភ្ងន់គួរជាទីចាប់អារម្មណ៍យ៉ាងក្រៃលែង ។

ពិធីនេះចានប្រព្រឹត្តទៅដំសែនរីកកយគន់ពេក ។

សម្តេចទ្រង់រិទ្ធិ	សីហនុបពិត្រ
ជៃនកម្ពុជា	ទ្រង់ផ្តាល់សត្រូវ
ដោយព្រះធម្មា	បានព្រះវិហារ
វិលប្ងូលសីមា ។	ឮកអង្គរជាតិ
ជាប់ចិត្តសុទ្ធសាធ	ធឹងព្រះបញ្ញា
ខ្ពង់ខ្ពតិ	ដោះស្រាយបញ្ហា
តាមបញ្ញសីលា	ទៀងទាត់កន្លង

ភក្តីសទ្ធិយា


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៤ លេខ ៨ ខែ សីហា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -



ភ្នំពេញសន្ទេយ្យ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បែបរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
–	ធម៌សមណសុខកថា ព្រះមុនីកោសល សូរ-ហាយ តែងនិងរៀបរៀង	៨៤៥
–	ជោលច្បាប់ព្រះពុទ្ធសាសនា លោក ហេង-សមអាន តែងនិងរៀបរៀង	៨៦១
–	ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) លោកប៊ុំ-ប៉ុំ ប្រែរៀបរៀង (ត)	៨៣៣
–	មធុរសវាហិណី សម្តេចព្រះធម្មលិខិត ស្ង៊ី-ឯម នគរមប្រើក្សា ប្រែរៀបរៀង (ត)	៨៨៩
–	មហោសថជាតក លោក អឹម-ភន ចម្លងពីសាស្ត្រាស្ងឹកវិតព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ (ត)	៨៩៩
ផ្នែកអក្សរសាស្ត្រ		
–	ការសាងនិងអក្សរសាស្ត្រខ្មែរ លោក ឆឹក-ផាម តែងនិងរៀបរៀង (តចប់)	៩០១
–	សិលាចារឹកនៅប្រាសាទវិមានអាកាស ព្រះមហា ជាំង-ខាត់ ប្រែរៀបរៀង	៩១៥
–	អង្គារនិងសម័យអង្គារ លោក នេង-ច្រើរ ប្រែពីទស្សនាវដ្តី "ញូវ-អូរីយ៉ង់" (ក្រុងប្រាក) លេខ ៣១៩៦១ (តចប់)	៩២៤
–	ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ "ក" (ត)	៩៣៨
–	វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត)	៩៣៩
–	រឿងសាមកុក អ្នកនាងកញ្ញា នូ-ភន ប្រែរៀបរៀង (ត)	៩៤០
–	សកម្មភាពក្រុមជំនុំទំនៀមទម្លាប់ខ្មែរ	៩៤៥
ប្រជុំប្រវត្តិសាស្ត្រជាតិ		
–	ពិធីសម្ពោធព្រះវិហារអោ្គធិការនុគ្រោះ និងពិធីបញ្ចុះសីមាវត្តអង្គសិម្ពលី	៩៥២

មួយចាំមាន ១២ លេខ តម្លៃជាវ ២៣០រ០០

34è Année — N° 8 — Aout 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse

—Gihisamanasokhakatha par Préah Monikosal SO-HAY 845
—Principes bouddhiques par M. HENG-SAM-AN 861
—Préah Abhidhammapitaka «Kampir Préah Yamaka» par M. BOU-PO (suite) 877
—Madhurasavahini par Samdech Préah Dhammalikhita LOUIS-EM Haut conseiller (suite) 889
—Mahosotha Jataka (suite) 899

Partie littéraire

—Le Langage et la littérature Khmèrs par M.DIK-KEAM (suite et fin) 904
—Inseription Khmèrs au monument de Viméan-Akas traduite par le Vén. PANG-KHAT. 915
—Angkor et son époque traduit de New-Orient (Prague) n° 3/1961 par M. PHÉNG-CHRIV (suite et fin) 924
—Activité de la Commission Culturelle chapitre «Ka» (suite) . . . 938
—Dictionnaire Sanscrit-Khmer par Vén. PANG-KHAT (suite) . . . 939
—Histoire de Sam-Kok traduite par Oknha NOU-KAN (suite) . . . 940
Activités de la Commission des mœus et coutumes 945

Actualités Nationales

—Cérénomie D'inaguration du temple APÉATHIKARNUKROH et Cérénomie de pose de pierres Sima de la Pagode ANGSIMBALI 952

Prix d'Abonnement annuel (comprenant 12 numéros) : 230 ; 00

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ ។
ឲ្យជុំសាត់ចិត្ត កុំឲ្យហួងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។
ប.ព.

តិហិតសមណសុខកថា

ព្រះមុនីកោសល ស្វូរ – មាយ អធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដក

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ចត្តារិមានិ ភគវតោ តិហិសុខានិ អត្ថិសុខំ ភោគសុខំ អនណសុខំ អនវជ្ជសុខំ ។

នេះជាពុទ្ធភាសិត ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងអំពីសេចក្តីសុខរបស់គ្រហស្ថចំពោះពួកគហបតី ដូចសេចក្តីវែកញែក អធិប្បាយពន្រឹកពុកជាសណ្តាប់នៃសិក្ខាកាមកុលបុត្រ តទៅនេះ

សេចក្តីប្រៃនៃពុទ្ធភាសិត

ម្នាលគហបតីទាំងឡាយ សុខរបស់គ្រហស្ថនេះមាន ៤ យ៉ាងគឺ ៖

១– អត្ថិសុខ សុខព្រោះមានទ្រព្យ

២- ខេមកសុខ ១ សុខព្រោះប្រើប្រាស់ទ្រព្យ

៣- អនណសុខ ១ សុខព្រោះមិនចំពាក់បំណុល

៤- អនវជ្ជសុខ ១ សុខព្រោះមិនមានទោស ។

ពាក្យថា សុខនេះជាឥដ្ឋារម្មណ៍គឺអារម្មណ៍ជាទីប្រាថ្នា ជាទីពាប់ចិត្ត របស់មនុស្សសត្វ ។ សេចក្តីស្រួលកាយសប្បាយចិត្ត របស់មនុស្សសត្វ ត្រូវជាតិកុសលវិបាក ហៅថា សុខ គឺលទ្ធផលណាមួយ ដែលទាំចិត្តមនុស្សសត្វឲ្យត្រេកអរកើតឡើយ ឲ្យត្រូវការចង់បាន ចង់ផ្ទួចប្រទះ ។ ពាក្យថា សុខ នេះ ពុតជាបញ្ហាមួយ ដែលមនុស្សសត្វតែងដោះស្រាយដោយមធ្យោបាយផ្សេង ៗ គ្នា ដើម្បីស្វែងរកឲ្យជួបប្រទះ ។ សេចក្តីសុខជាធម្មជាតមួយ ដែលជាទីស្រឡាញ់ពេញចិត្តរបស់មនុស្សសត្វទាំងអស់ តមានខណៈណាមួយ បដិសេធចោលឡើយ គឺមនុស្សត្រូវប្រកេប សុខ្នែតែបែរមុខឈមទៅរកសេចក្តីសុខត្រូវ ៗ គ្នា ។ ការណីយកិច្ចដើម្បីរស់នៅរបស់មនុស្សត្រូវជាន់ថ្នាក់ មានរបរកសិកម្មពាណិជ្ជកម្មជាដើម សុខ្នែតែជាកិច្ចការឈមទៅរកសេចក្តីសុខ ទាំងអស់ព្រោះមុខព្រួញគឺសេចក្តីប៉ុនប៉ងតម្រង់ទៅរកសេចក្តីសុខតែម្យ៉ាង ។ អ្នកដែលមានទុក្ខយប្រាជ្ញា មានព្យាយាម មានតំនិតល្អ ក៏អាចស្វែងរកសេចក្តីសុខបានដោយងាយ អ្នកដែលគ្មានទុក្ខយប្រាជ្ញា គ្មានព្យាយាម គ្មានតំនិតល្អ ក៏ស្វែងរកសេចក្តីសុខបានដោយលំបាកណាស់ ។

ពាក្យថា សុខ មួយម៉ាត់នេះ នាំឲ្យបែកសាខាមានកម្មវិធី ប្លែកគ្នាជាច្រើនបែប ដូចយើងបានយើញជាស្រេចស្រាប់ហើយ ព្រោះតែសេចក្តីសុខមួយប៉ុណ្ណោះ ។ គ្រាន់តែការស្វែងរកសេចក្តីសុខ ដើម្បីជីវិតនេះនាំបណ្តាលហេតុមិនមែនតិចតួចទេ គឺនាំឲ្យមានជម្លោះឈ្លោះប្រកែកចោទប្រកាន់ រហូតដល់ការប្រកាសសង្គ្រាមទំនឹងគ្នាទៅវិញទៅមក ព្រោះតែការស្វះស្វែងដណ្តើមដេញដោលគ្នា រកសេចក្តីសុខប៉ុណ្ណោះឯង នេះជាសេចក្តីបញ្ជាក់ឲ្យយើញថា សុខមួយម៉ាត់សោះ ក៏អាចក្លាយទៅជាបញ្ហាសាំញ៉ាំដែលលំបាករកផ្លូវដោះស្រាយជាទីបំផុត ។

ក្នុងករណី ដូចសេចក្តីអធិប្បាយដោយសង្ខេបមកនេះ ទើបព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែង បញ្ញត្តធម៌នៃយុគមក ដែលយើងហៅថា ពុទ្ធសាសនា ប្រែថាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ ពុទ្ធសាសនានេះ ហើយជាមធ្យោបាយមួយ ដ៏ប្រសើរបំផុត សម្រាប់ដោះស្រាយបញ្ហាក្នុងការស្វែងរកសេចក្តីសុខ ដើម្បីមិនឲ្យប៉ះពាល់សិទ្ធិសេរីភាព ចំពោះជីវិត ទ្រព្យសម្បត្តិនឹងកិត្តិឯង ដែលជាកម្មសិទ្ធិ របស់អ្នកណាមួយ ។ នេះជាបុព្វកថាបរិយាយចំពោះពាក្យថា សុខ ។

អធិប្បាយពន្យល់សេចក្តី តិវិធសុខ ៤ យ៉ាង

សេចក្តីសុខនេះ បើចែកតាមប្រភេទនៃបុគ្គលមាន៤យ៉ាងគឺ តិវិធ-សុខ សុខរបស់គ្រហស្ថ១ សមណសុខ សុខរបស់សមណៈ១ ។

ក្នុងអត្ថបទខាងដើមនេះ សូមសំដែងចំពោះ គីហិសុ១ ជាមុន, លុះដល់សេចក្តីអធិប្បាយអំពីគិហិសុ១ ទើបសំដែងចំពោះ សមណសុ១ មាន ៩ យ៉ាង តទៅជាខាងក្រោយ ។

១- អត្តិសុ១ សុះព្រោះមានទ្រព្យ ។ ទ្រព្យសម្បត្តិគ្រប់យ៉ាង ទោះជាទ្រព្យសង្ហរិមក្តី ទ្រព្យអសង្ហរិមក្តី រមែងប្រគល់សេចក្តីសុខដល់ជនជាម្ចាស់ ដោយពិតប្រាកដ ប៉ុន្តែទ្រព្យទាំងនោះសំដៅយកទ្រព្យដែលស្វែងរកបានមកដោយផ្លូវធម៌ រាប់ជាទ្រព្យបរិសុទ្ធផុតអំពីសេចក្តីរង្កៀសចោទប្រកាន់របស់បុគ្គលណាមួយ ជាទ្រព្យប្រកបដោយកម្មសិទ្ធិបរិបូណ៌ ទាំងការថែទាំ រក្សាទុកដោយការប្រយ័ត្ន មិនឲ្យមានអន្តរាយមានអន្តរាយជាដើម ។ ទ្រព្យគ្រប់យ៉ាង ដែលជនជាម្ចាស់ទុកដាក់ក្នុងផ្ទះក្តី នៅក្រៅផ្ទះក្តី កាលបើជនជាម្ចាស់ត្រូវការប្រើប្រាស់ចាយវាយក្នុងវេលាណាមួយ ក៏អាចចាយវាយបានដោយស្រួល មិនចាំបាច់ព្រួយបារម្ភចំពោះការខ្វះខាតឡើយ ។ ទ្រព្យសម្បត្តិដែលមានបាននេះ ជាគ្រឿងញាំងចិត្តនៃជនជាម្ចាស់ ឲ្យកើតសេចក្តីសប្បាយ រីករាយជានិច្ច ដោយហេតុថា ទ្រព្យគ្រប់យ៉ាងដែលមានបាននេះ កាលបើជនជាម្ចាស់ប្រាថ្នាត្រូវការទិញដូរបានណាមួយក៏អាចទិញដូរបានភ្លាម ។ តាមសេចក្តីពេញចិត្ត ដែលខ្លួនចង់បាន ដោយសេចក្តីសប្បាយ ឥតមានព្រួយលំបាកចិត្តក្នុងការស្វែងរកខ្ជិលច្អូលច្អែងការអ្នកណាឡើយ ។ ទ្រព្យសម្បត្តិដែលមាន

ខៅក្នុងអំណាចរបស់ជនជាម្ចាស់.ទេ ប្រាកដជាសុខចិត្តនៃគ្រហស្ថ ពិត
ជាប្រកាន់មួយរបស់សេចក្តីសុខ សមដូចតាសិតថា "គ្រឿងទ្រនាប់ទ្វេ"
ដែលតើតមានដល់ជនជាម្ចាស់ ។

អត្ថិសុខ ដែលអាចកើតឡើងបាន ដោយអាស្រ័យ ចិដ្ឋឆម្ចិ-
កាត្ត (ប្រយោជន៍បច្ចុប្បន្ន) ៤ យ៉ាង មានទង្គានសម្បាជាដើម សូម
លោកអ្នកគាន់ចាំងឡាយ សិក្សាក្នុងប្រយោជន៍បច្ចុប្បន្ន ៤ យ៉ាងនោះចុះ។
ប្រយោជន៍ ៤ យ៉ាងនោះហើយ ទុកថាជាកម្មវិធីធំបំផុត សម្រាប់ស្វែង
រកទ្រព្យសម្បត្តិឲ្យមានបាន ដើម្បីដឹតជាសុខចម្រើន ឃើញជាក់ច្បាស់
ក្នុងបច្ចុប្បន្នដោយពិត ។

២- គោកសុខ សុខព្រោះប្រើប្រាស់ទ្រព្យ ។ ការចាយក់យ
ទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់ខ្លួន ក្នុងការទិញដូរវត្ថុណាមួយក្តី
ក្នុងការបរិច្ចាគទានចំពោះសមណបព្វជិតក្តី ក្នុងការសង្គ្រោះដោះទុក្ខខ្លួន
ឯឬអ្នកណាមួយក្តី ក្នុងការទំនុកបម្រុងជាតិសាសនាក្តី ក៏អាចមានសិទ្ធិ
បរិបូណ៌ ក្នុងការប្រើប្រាស់ចាយក់យជាដរាប ។ ការបញ្ចេញទ្រព្យ
សម្បត្តិ ដើម្បីប្រើប្រាស់ចាយក់យដោយសេចក្តីពេញចិត្តនេះ ទុកថា
ជាការសប្បាយតែកយមួយ របស់ជនជាម្ចាស់ ដូចយ៉ាងការចាយក់យ
ទ្រព្យសម្បត្តិ ដើម្បីសង់សេនាសនៈ សម្រាប់បម្រើព្រះពុទ្ធសាសនាក្តី
សង់សាលាសិក្សាសម្រាប់ជាតិ ប្តូរលើកទួល សង់ស្ពាន ជីកស្រះអណ្តូងក្តី

ឆ្នើបុណ្យចំពោះពួកកិច្ចកតញ្ញូកតវេទិតាធម៌ ចំពោះលោកអ្នកមានគុណ មាន
មាតាបិតាជាដើមក្តី ។ ការប្រើប្រាស់ចាយវាយទ្រព្យសម្បត្តិ ត្រូវតាម
គោលចំណងរបស់ខ្លួនខេះ ជាការនាំមកនូវសេចក្តីសុខសប្បាយ រីករាយ
ត្រេកអរដ៏ក្រៃលែងរបស់ជនជាម្ចាស់ដោយពិត ពោះបើប្រើប្រាស់ចាយ
វាយទ្រព្យសម្បត្តិខាំងខ្លះ ចេះតែរលស់ទៅ អស់ទៅពិតមែន ប៉ុន្តែជា
ហេតុឲ្យមានបីតិបាមោជ្ជៈ គឺមានអំណរសុខចិត្ត សប្បាយចិត្តជារឿយ។
កើតឡើងព្រោះការចាយវាយដោយចិត្តជ្រះថ្លា ឬ ចិត្តជាព្រហ្មវិហារ ពុំ
មែនក្តៅក្រហាយចិត្ត ដូចការអស់ទ្រព្យ ព្រោះអន្តរាយ មានចោរន្តរាយ
ជាដើមនោះឡើយ ។

ការប្រើប្រាស់ចាយវាយទ្រព្យ ប្រកបដោយធម៌ខេះ ជាផ្លូវនាំមក
នូវសេចក្តីសុខចិត្តរបស់គ្រហស្ថ ខាំងបច្ចុប្បន្នខាំងបរលោក ។ ការមិន
ចាន់ប្រើប្រាស់ចាយវាយទ្រព្យ ដោយភាពនៃបុគ្គលជាមនុស្សមានមច្ឆេ-
រិយៈ កំពប់ថាជាទុក្ខទោសមួយ របស់ជនជាម្ចាស់ទ្រព្យសម្បត្តិ ។

៣- អនវជ្ជសុខ សុខព្រោះមិនចំពាក់បំណុល ។ ការចំពាក់
បំណុលគេ ឈ្មោះថាជាទុក្ខព្រួយមួយដែលឲ្យផលផ្ទុំគានតិចគានចំណុល
ដោយគិតឃើញថា អាត្មាអញ ជាប់ចំពាក់ខាក់ខិនទ្រព្យសម្បត្តិគេ មិន
ដឹងជាគេនឹងមកតម្រាមកំហែងតឹងគាំរបីអូសក្នុងថ្ងៃណាមួយទេ ធម្មតាអ្នក
ចំពាក់បំណុលគេ តែងមានសេចក្តីតក្រួយ គានតិចចំលែងកន្ត្រុងជាខ្លួ

ចាំងការប្រមាថមើលងាយ អំពើដនជាម្ចាស់ចំណុលក៏តែងមានជាទំនៀមៗ
ភាពនៃជនអ្នកចំពាក់គេ តែងមានសេចក្តីខ្វក់ក្រៀមក្រមជានិច្ច ឥតមាន
មុខស្រស់ស្រាយសប្បាយចិត្តទេ ។ ភាពនៃការមិនចំពាក់បំណុលគេ
ទើបជាហេតុនាំមកនូវសេចក្តីសុខសួស្តី ក្នុងចិត្តរបស់ខ្លួន ដែលនាំចិត្តឲ្យ
អរសប្បាយ រីករាយរៀងរាល់ថ្ងៃ ។

៤- អនវជ្ជសុខ សុខព្រោះមិនមានទោស ។ ការមានទោស
ក្នុងផ្លូវអាណាចក្រក្តី ក្នុងផ្លូវពុទ្ធចក្រក្តី សុទ្ធតែជាហេតុនាំមកនូវវិប្បដិ-
សារៈ គឺសេចក្តីក្តៅក្រហាយ ស្តាយក្រោយជាប្រាកដ ដូចយ៉ាងភាពនៃ
ខ្លួន ប្រព្រឹត្តចោរកម្មក្តី លក់ដូរបរបស់ខុសបញ្ញត្តិរបស់ពជការក្តី ឬប្រព្រឹត្ត
ខុសខុស ចំពោះអំពើណាមួយក្តី សុទ្ធតែនាំមកនូវសេចក្តីខ្វក់ក្រៃលែង ចាំង
អស់ ចំណែកខាងទោសក្នុងផ្លូវពុទ្ធចក្រ ដូចយ៉ាងប្រព្រឹត្តខុសវិន័យ ដោយ
កាយវាចាចិត្ត ក្នុងផ្លូវអកុសលកម្មបថ ១០ មានការសម្លាប់សត្វ លួចប្លន់
ប្រាសចាកព្រហ្មចរិយធម៌ ឧទ្ធច្ចកុក្កុច្ចៈ ការប្រព្រឹត្តខុសចំពោះកូនប្រពន្ធគេជាដើម ឬក៏
ធ្វើខ្លួនឲ្យថ្លង់ភ្លោយភ្លាក់ភ្លើកក្នុងអបាយមុខ៦ប្រការ មានល្បែងស៊ីសងជា
ដើម ចាំងនេះសុទ្ធតែជាទោសនាំមកនូវទុក្ខភ័យ ចាំងក្នុងបច្ចុប្បន្នទិដ្ឋធម្ម-
លោក ដែលផ្ទុយគ្នានឹងការគ្មានទោស ។ ការមិនមានទោស ទើបជា
ហេតុនាំមកនូវសេចក្តីសុខសប្បាយដោយពិត, ភាពនៃបុគ្គលអ្នកមិនមាន
ទោស ក្នុងផ្លូវពុទ្ធិតែណាមួយនេះជាការប្រសើរបំផុត ដោយហេតុថាជា

អ្នកចេះប្រកបការរស់នៅដោយសុខស្រួល ប្រាសចាកសេចក្តីរង្គៀសអំ-
តីខ្លួនឯងផង អំពីអ្នកដទៃផង ឈ្មោះថាជាអ្នករស់នៅរួចខ្លួន អំពីទុក្ខភ័យ
គោសទណ្ឌតាំងបច្ចុប្បន្នទីនឹងបរលោក ។ ភាពនៃការមិនមានគោសនេះ
រមែងសុខចិត្តរបស់គ្រហស្ថដែលមូលមិត្រជាមួយនឹងគ្រួសាររៀងរាល់ថ្ងៃ។

គិហិសុខទាំង ៤ ប្រការ ចានវែកញែកអធិប្បាយតទៅលៅដោយ
សេចក្តីសង្ខេបតែប៉ុណ្ណោះ ។ សេចក្តីសុខរបស់មនុស្ស ពោះបីមានច្រើន
ស្ថានក៏ពិតមែន ប៉ុន្តែសេចក្តីសុខតាំង ៤ យ៉ាង ដូចអធិប្បាយមកហើយ
នោះ ឈ្មោះថាជាសុខចាំបាច់របស់គ្រហស្ថដោយពិត ព្រោះថាគ្រហស្ថ
ជាអ្នកខ្វល់ការៈគ្រប់គ្រងផ្ទះគឺគ្រួសារ តែងមានកិច្ចការច្រើន មានកង្វល់
បលិពោធច្រើន មានមុខការត្រូវចាយវាយច្រើន ម្ល៉ោះហើយចានជាគ្រ-
ហស្ថភាគច្រើន តែងប្រាថ្នាចំពោះភាពនៃខ្លួនជាអ្នកមានទ្រព្យ, ការប្រើ
ប្រាស់ចាយវាយទ្រព្យ, ភាពនៃខ្លួនមិនចំពាក់ចំណុលគេ នឹងភាពនៃខ្លួន
មិនមានគោស ។ សេចក្តីប្រាថ្នារបស់គ្រហស្ថដែលសុខចិត្តចំពោះភាព
នៃខ្លួនជាអ្នកមានទ្រព្យដូចអាថ៌នេះ កាលបើសេចក្តីសុខចិត្តចានសម្រេច
ហើយ ឈ្មោះថាជាសុខក្នុងផ្លូវចិត្ត សមដូចសេចក្តីប្រាថ្នានោះឯង ។
មនុស្សគ្រប់រូប កាលបើមានចំណង់ប្រាថ្នាចំពោះហេតុការណ៍ណាមួយ
ហើយមិនចានសម្រេចដូចប្រាថ្នា រមែងនាំមកនូវទុក្ខ ដែលធ្ងន់ធ្ងរនឹង
សេចក្តីសុខតុំចាន ដូចយ៉ាងលិខិតភាត (ភាពនៃសេចក្តីទាល់ក្រ) នេះដែ

ទុក្ខមួយរបស់គ្រហស្ថ, ភាពនៃការមិនមានគ្រឿងប្រើប្រាស់, ភាពនៃខ្លួន
ជាអ្នកបំពាក់បំណុលគេ នឹងភាពនៃខ្លួនជាអ្នកមានទោស ទាំងនេះសុទ្ធ
តែជាទុក្ខរបស់គ្រហស្ថជាប្រាកដ ព្រោះមិនសុខចិត្ត ចំពោះភាពទាល់ក្រ
នោះទេ ដោយហេតុថា ទាល់ក្រភាពជាដើម ជាអនិដ្ឋារម្មណ៍របស់គ្រហស្ថ
តុំមែនជាឥដ្ឋារម្មណ៍ឡើយ ។ ចំពោះតិហិសុខ ៤ យ៉ាង ដូចអធិប្បាយ
មកហើយ ឈ្មោះថាជា ឥហិសុខ ផង ជា ឥដ្ឋារម្មណ៍ នៃគ្រហស្ថផង
ជាវត្ថុបំណងត្រូវតាមគោលដៅនៃគ្រហស្ថផង ។

ឥនជាគ្រហស្ថ កាលបើប្រកបដោយតិហិសុខ ៤ យ៉ាងហើយ ត្រូវ
តម្កល់ខ្លួនក្នុងស្ថាន ៤ យ៉ាងទៀត ទើបត្រឹមត្រូវនឹងហេតុនៃខ្លួនជាគ្រហស្ថឲ្យ
តាំងនៅផ្លូវស្ថាពរតទៅបាន ។

ស្ថាន ៤ យ៉ាងនោះគឺ

១- ស្វែងរកគ្រឿងដែលវិនាស ឲ្យមានបានឡើងវិញ

២- ជួសជុលរបស់ដែលចាស់គ្រាំគ្រា

៣- ដឹងប្រមាណក្នុងការប្រើប្រាស់គ្រឿង

៤- តាំងស្ត្រី ឬ បុរសមានសីល ឲ្យជាអ្នកការពារផ្ទះ ។

សំដែងអំពីតិហិសុខ ៤ យ៉ាង ចប់តែប៉ុណ្ណោះ

សមណសុខ ៨ យ៉ាង

បន្ទាប់តទៅនេះ សូមសំដែងចំពោះសមណសុខ ដែលមានមកក្នុង

អដ្ឋកថាជាគត ឯកនិបាត ដូចសេចក្តីដែលវែកគ្នាគតអធិប្បាយ ដោយ
សង្ខេបគត។

សមណសុត្តទី ៨ ឃ្លាំង

១- ឧទ្ធច្ចញ្ចវិក្ខេបាភាវេ ការមិនមានសេចក្តីហួងហែង
ចំពោះព្រឿងសម្បត្តិនឹងស្រូវអង្ករ;

២- អនវដ្ឋិតិដ្ឋានវិរាយសនភាវេ ភាពនៃការស្វែង
រកចំពោះបិណ្ឌបាត ដែលឥតគោស គឺបិណ្ឌបាតប្រកបដោយធម៌;

៣- និព្ភុតបិណ្ឌាបាតភុញ្ជនភាវេ ភាពនៃការបរិភោគ
អាហារបិណ្ឌបាតដ៏ត្រជាក់;

៤- វដ្ដបីឡាភាវេ ការមិនមានការបៀតបៀនអំពីអ្នកដែន;

៥- ឧបការណោសុ និច្ចន្ធកតភាវេ ភាពនៃសមណៈ
មិនមានឆន្ទរាគ ក្នុងឧបការណ៍;

៦- ចោរវិលោបេ និព្ភយភាវេ ភាពនៃសមណៈមិន
មានភ័យ ក្នុងការលួចប្លន់នៃចោរ;

៧- កដកដមហាមគ្គេហិ អសំសដ្ឋភាវេ ភាពនៃ
សមណៈមិនជាប់ចំពាក់ ដោយស្មៅចន្ទនឹងមហាមគ្រនៃស្មៅ;

៨- ចតូសុ ទិសាសុ អប្បដិហតភាវេ ភាពនៃ
សមណៈមិនខ្វែងចាក់ចំពោះទិសទាំងបួន ។

អធិប្បាយពាក្យសេចក្តី

១- ពាក្យថា "មិនមានសេចក្តីហួងហែងចំពោះទ្រព្យសម្បត្តិទេ ស្រួលអង្គុយ" ដោយហេតុថា សមណៈជាបព្វជិតក្នុងព្រះពុទ្ធសាសនា ជាអ្នកមានការណែនាំយកចិត្តដោយឡែកផ្សេងពីគ្រហស្ថហើយ មិនត្រូវមានការខ្វល់ខ្វាយស្វែងរកទ្រព្យសម្បត្តិ ទើបធ្វើជាតិផ្សេង។ មានស្រួលអង្គុយជាដើមទេ បើទុកជាបានទ្រព្យសម្បត្តិជាសមណបរិក្ខារដោយសទ្ធាជ្រះថ្លារបស់គ្រហស្ថក៏មិនត្រូវហួងហែង ទុកជាកំលាក់កំសៀ ដែលប្រកបដោយមច្ឆរិយៈទេ។ ការហួងហែង ការលាក់លៀម ការបំបិទបំបាំង ដោយការទុកជាក់នេះ លោកពោលថាជាហេតុមួយនាំមកនូវទុក្ខរឿយៗ។ ព្រោះជាហេតុនាំឲ្យមានសេចក្តីទុក្ខព្រួយ ភ័យចាប់ម្តងជាច្រើន ចំពោះទ្រព្យសម្បត្តិដោយខ្វាចក្រែងអន្តរាយផ្សេងៗ មានចោរន្តរាយជាដើម។ ត្រង់ការដែលគ្មានសេចក្តីហួងហែងនេះ ឈ្មោះថាជាសុខចិត្តរបស់សមណៈដោយពុំមានទុក្ខព្រួយក្នុងការថែទាំ។ ពាក្យថា សម៌ណៈនេះពុំបានអធិប្បាយទេ គឺសំដៅយកបុគ្គលជាបព្វជិត ក្នុងព្រះពុទ្ធសាសនា។

២- ពាក្យថា "ការស្វែងរកបិណ្ឌបាត ដែលឥតទោស" បានដល់ការស្វែងរកអាហារប្រកបដោយធម៌និយ័ ដែលជាការស្វែងរកប្រាសចាកអនេសនធម៌។ ការរស់នៅរបស់សមណៈតែងជាប់ទាក់ទងដោយគ្រហស្ថដែលមានសទ្ធាជ្រះថ្លាដោយពិត ប៉ុន្តែមិនមែនរស់ដោយកិច្ចទាក់

ខ្លួនទើបគ្រហស្ថ ក្នុងផ្លូវចាំងឲ្យឃើញមានតាណិជ្ជកម្ម កសិកម្ម ឬ វេជ្ជកម្ម ជាដើមឡើយ ។ ការស្វែងរកវេបស់សមណៈ ដើម្បីជីវភាពរបស់ខ្លួន ត្រូវប្រកបដោយផ្លូវបរិសុទ្ធិវិសេសជាងគ្រហស្ថ ទើបសមគួរដល់ឋានៈនៃខ្លួនជាសមណៈជាបុត្តាកូនតកូនព្រះពុទ្ធសាសនា, មិនត្រូវបណ្តោយឲ្យការរស់នៅរបស់ខ្លួនជាសមណៈប្រឡូកប្រឡំដោយផ្លូវខុសឡើយ ។ ការស្វែងរកបិណ្ឌបាត ដែលប្រាសចាកទោសនោះ សំដៅយកការរៀនស្រឡះចាកបាបធម៌ ទើបអានេសនធម៌ ឈ្មោះថាជាការស្វែងរកដ៏បរិសុទ្ធរបស់សមណៈ លោកចាត់ថាជាសុខវេបស់សមណៈ ដោយអាជីវៈបរិសុទ្ធ ដែលគេមិនអាចបង្ខាំក់បាន ។

៣- ពាក្យថា "ការបរិភោគអាហារបិណ្ឌបាតដ៏ត្រជាក់" ដោយហេតុថា សមណៈដែលស្ម័គ្រចិត្តខ្លួនផ្នួសក្នុងព្រះពុទ្ធសាសនា ត្រូវជាអ្នកសុខចិត្ត ព្រមខ្លួនអាហារបិណ្ឌបាតតាមតែប្រទះ គឺបួនកាលបានអាហារត្រជាក់ បួនកាលបានអាហារក្តៅ ប៉ុន្តែធម្មតាអាហារបិណ្ឌបាតដែលតាយកតាយកា ដោះដូរសម្រន់ខុសជាក់ជាត្រនោះ បើទើបនឹងដោះថ្មី ។ ហើយកិក្ខុសាមណេរបាននៅខ្លួលបិណ្ឌបាតជាដំបូងក្នុងកាលដែលនៅក្តៅ, ក៏ជាភ័ព្វរបស់កិក្ខុសាមណេរ ដែលខ្លួលបិណ្ឌបាតមុននោះម្តង ។ តាមដោយពិត អាហារបិណ្ឌបាតសម្រាប់ជាក់ឆ្អែតចំពោះព្រះសង្ឃរមែងតែត្រជាក់ ព្រោះគេដោះដូរសុខុសយូរ ដើម្បីព្រះសង្ឃដែល

ទំមន្តមកបិណ្ឌបាត ដែលឃ្លានតេលតែគ្នា តែបួនការព្រះសង្ឃភ្លាមប្តូរ
បូមកនឹងបិណ្ឌបាតជាមួយគ្នា បួនការព្រះសង្ឃ ១ រូប ។ មកនឹងរួល
រយាល ។ អំពីគ្នា ទៅនិងហើយអាហារបិណ្ឌបាតនោះ ក៏នៅជាអាហារ
ត្រជាក់ ។ សមណៈដែលរស់នៅដោយអាហារបិណ្ឌបាតនេះ តុំសូវបាន
អាហារឆ្ងាយទេ ច្រើនតែប្រទះអាហារត្រជាក់ ។ ត្រង់ការដែលសមណៈ
ព្រមសុខចិត្តបរិភោគអាហារត្រជាក់នេះ ពន់ពាជាតបជាមិមួយ របស់
សមណៈ សម្រាប់ញុំាងចិត្តឲ្យស្ងួតស្ងប់ ឈ្មោះថាជាសុខស្រួលរបស់
សមណៈក្នុងការចូរឱនចិត្ត មិនបណ្តោយចិត្តឲ្យរហើរហាប់រលោរលាំ
សព្វបើគ្រាន់តែរសអាហារនោះឡើយ ។

៤- ពាក្យថា "មិនមានការបៀតបៀនអំពីអ្នកដែន" ដោយ
ហេតុថាសមណៈមានភាពជាអ្នកស្ងួតសុភាព មានកាយវាចាចិត្តស្ងប់ តាម
ព្រៃសិក្ខាសម្រាប់សមណៈមិនមានអ្នកពាការបៀតបៀន ឬប្រើអំណាច
យសស័ក្តិដ៏ជាន់ស្តិត់សង្កិន របអូសយកទ្រព្យសម្បត្តិដូចជនអ្នកនៅកន្លែ
ដែនណាមួយទេ, តុំមែនដូចជាមនុស្សក្នុងដែនដែលត្រូវបង់ពន្ធជារ ឬត្រូវ
គេមានអំណាចបៀតបៀន ដោយទាយណាមួយ ដើម្បីឲ្យបានទ្រព្យ
សម្បត្តិ មានមាសប្រាក់ជាដើម អំពីសមណៈនោះឡើយ ។ ការមិនប្រ-
ព្រឹត្តបៀតបៀនអំពីអ្នកពាការក្នុងដែននេះ ឈ្មោះថាសុខរបស់សមណៈ

ដោយពុំមានគេចោទប្រកាន់តឹងតែងការចៀតចៀន ដែលនាំឲ្យមានឈ្មោះ
សៅហ្មងនោះឡើយ ។

៥- ពាក្យថា "មិនមានឆន្ទរាគ ក្នុងឧបករណ៍" នោះសំដៅ
យកភាពនៃសមណៈ: មិនមានសេចក្តីប្រាថ្នាប៉ុនប៉ងត្រេកអរវង្វេងវង្វាមចំពោះ
គ្រឿងប្រើប្រាស់ មានចីវរជាដើមនោះទេ ។ គ្រឿងឧបករណ៍ផ្សេងៗ
មានចីវរនឹងសេនាសនៈជាដើម ដែលសមណៈ បានទទួលមកហើយ
ប្រកបដោយធម៌ជាវបស់ខ្ពង់ខ្ពស់ក្តី ថោកទាបក្តី មិនត្រូវជាប់ចំពាក់ប្តូរ
គន់រើសអើង ចំពោះគ្រឿងឧបករណ៍នោះឡើយ ។ ត្រូវតាំងចិត្តជា
ទុបេក្ខាក្នុងគ្រឿងឧបករណ៍ជាដរាប ។ គ្រឿងឧបករណ៍ដែលមិនទាន់
បានមក ក៏មិនត្រូវប្រាថ្នា វង្វេងវង្វាមហួសហេតុ ដើម្បីរក្សាភាពនៃខ្លួនជា
សមណៈឲ្យបរិសុទ្ធ ។ ត្រង់ដែលមិនមានឆន្ទរាគគឺសេចក្តីប្រាថ្នារហើរ
រហាប់ក្នុងឧបករណ៍ ឈ្មោះថាជាសុខរបស់សមណៈ ដោយសេចក្តី
សន្តោសពុំមានគេរិះគន់តេបង្រាយបាន ។

៦- ពាក្យថា "មិនមានភ័យក្នុងការលួចបន្លំនៃចោរ" បានដល់
ភាពនៃសមណៈ: មិនមានកិតភ័យព្រួយបារម្ភអំពីចោរដែលលួចបន្លំ ព្រោះ
សមណៈ ជាអ្នកមិនសន្សំទ្រព្យសម្បត្តិ ដែលគួរឲ្យចោរមានបំណងមក
លួចបន្លំបានទេ ។ ការលួចបន្លំនៃចោរនេះ ជាទុក្ខភ័យមួយ របស់
មនុស្សអ្នកមានទ្រព្យក្នុងលោក, ការមិនមានភ័យអំពីចោរលួចបន្លំ ឈ្មោះ

ថាជាសុខមួយដែរ ។ ភាពនៃសមណៈឈ្មោះថា ផុតចាកសេចក្តី
ទុក្ខព្រួយអំពីចោរហើយ ទើបលោកចាត់ថាជាសុខរបស់សមណៈ ។

៧- ពាក្យថា «មិនជាប់ចំពាក់ដោយស្តេចនឹងមហាមាត្រនៃស្តេច»
សំដៅយកភាពនៃសមណៈ មិនត្រូវប្រឡូកប្រឡាំពាក់ពន្ធនាគារដោយ
ការចុះឡើងប្របូកប្របល់រឿយៗ ជាមួយនឹងស្តេចឬមហាមាត្រ (លោក
អ្នកពាក់ការ) របស់ស្តេចទេ ព្រោះថាស្តេចនឹងមហាមាត្រតែងមានកិច្ចការ
ក្នុងប្រទេសច្រើនយ៉ាង សមណៈជាអ្នកមានកេរផ្សេង មានការណ៍យកចិត្ត
ទុកផ្សេង មិនត្រូវបណ្តោយខ្លួន ឲ្យមានការប្រព្រឹត្តជាប់ពាក់ពន្ធនាគារប្រ-
ឡំជាមួយដោយញឹកញាយទេ ព្រោះថា ការជាប់ចំពាក់ដោយឥស្សរជន
មានស្តេចជាដើមនោះ ជាហេតុនាំឲ្យឥស្សរជន ដែលមានកិច្ចការច្រើន
រវល់ធំធីឯចែរមកធ្វើចដិសណ្ឋារៈ ចំពោះសមណៈផង នាំឲ្យមានហេតុ
ការណ៍ណាមួយ ពុំសមគួរដល់សមណភាពផង ។ ការមិនជាប់ចំពាក់
នេះ ឈ្មោះថាជាសុខរបស់សមណៈ ដ្បិតសមណៈត្រូវមានឧកាសខំ-
នេរ អំពីកិច្ចការរបស់គ្រហស្ថហើយ ។

៨- ពាក្យថា «មិនខើសចាក់ចំពោះទិសទាំង ៤» បានដល់ភាព
នៃសមណៈដែលគ្រាច់ទៅក្នុងទិសណាមួយ បណ្តាទិសទាំង ៤ ឬទិស
ទាំង ៨ ចេះតែអាចទៅបានទាំងអស់ មិនស្ទាមានចិត្តជាប់ចំពាក់ចំពោះទិ

ភវន្តែងមួយៗទេ ដោយសមណៈជាអ្នកមិនមានទ្រព្យសម្បត្តិ ពុកជាកម្ម-
សិទ្ធិរបស់ខ្លួនទេ ពោះបីនឹងចង់គ្រាប់ទៅកាន់ទិសណាមួយ ក៏អាចទៅ
បានដោយងាយ មិនលំបាកក្នុងការដោះខ្លួនចេញដូចគ្រហស្ថនោះទេ ។
ថាវ៉ាវត្ត ជាកម្មសិទ្ធិរបស់សមណៈក្តី ការឃាត់ខាំនៃពពកការពារពោះ
សមណៈក្តី ក៏ពុំសូវមាន ព្រោះហេតុនោះ សមណៈអាចចេញដើរទៅកាន់
ទីណាមួយក៏ចេះតែទៅបានដោយស្រួល ឥតមានទើសទាក់ជាប់ជំពាក់
ដូចគ្រហស្ថនោះឡើយ ។ ការមិនមានទើសទាក់ក្នុងទិសរបស់សមណៈ
ឈ្មោះថាជាសុខរបស់សមណៈដោយហេតុមានផ្លូវលួចកន្លងការសិក្សាក្តី
កន្លងការទៅកាន់ទីណាមួយក្តី មិនជាប់ទៅកន្លែងមួយៗ ដូចគ្រហស្ថឡើយ ។

ធម្មិសមណសុខកថា ចប់

ចាតុធម្មបទ - ខុទ្ទកនិកាយ

លោក ខោន-សមអាន រៀបរៀង

ពលនិកខ្មែរ មានច្រើនជាតិ ច្រើនសាសន៍ ច្រើនប្រទេស ដែលអាស្រ័យនៅលើពិភពលោក សុទ្ធតែមានជំនឿក្នុងអ្វីមួយ បើមិនតិចក៏ច្រើន ដែលខ្លួនយល់ឃើញថាជាវត្ថុដ៏សក្តិសិទ្ធិគួរពឹងពាក់អាស្រ័យ គួរគោរពកប់អាន ពុំសូវនៅតែឯកឯងឥតទីពឹងឡើយ ។ វត្ថុដ៏សក្តិសិទ្ធិពាំងនោះ គេច្រើនទិយមយកសាសនា ឬ លទ្ធិដែលជាបវេណី របស់បុព្វបុរសសម្រាប់ជាតិនីមួយៗតែងប្រព្រឹត្តកាន់ជាប់តៗ គ្នាមក ទើបឈ្មោះថា សាសនា ។ សាសនានេះមានផ្សេងៗគ្នា តាមមតិរបស់សាស្តាចារ្យនីមួយ ។ បង្កើតឲ្យមានឡើង ដើម្បីញុំាងចរិស័ទឲ្យចូលដឿស្តាប់គោរពកប់អាន ដូចយើងបានឃើញ បានឮមកហើយដែលមានក្នុងលោកនេះ ។ បណ្តាសាសនាពាំងអស់ក្នុងលោក មានតែព្រះពុទ្ធសាសនមួយទេ ដែលជាសាសនាមានសារៈសំខាន់បណ្តាប់ជាងសាសនាឯទៀតៗពាំងអស់ ព្រោះជាសាសនាដែលអាចធ្វើមនុស្សគ្រប់ហាន: ជាអ្នកប្រតិបត្តិតាម ឲ្យមានសទ្ធិភាព សេរីភាព មេត្រីភាព សាមគ្គីភាព

ឯកពាជ្យ ទំនឹងឥស្សរភាពខ្លួនក្នុងត្រៃលោកធាតុ ។ ព្រះមហាបុរសមួយរូប អ្នកមានវិចារណញ្ញាណដ៏ជ្រាលជ្រៅ បានពាយាមរកឃើញសេចក្តីប្រតិបត្តិដែលមានទ្វីមសារវិសេស អាចធ្វើមនុស្សត្រង់ហាន: ឲ្យបានរួចចាកភ្លើងតិលេស ហើយបានប្រកាសផ្សាយពុកដកចមកដល់សត្វថ្ងៃនេះ ឯមហាបុរសនោះ គឺព្រះសម្មាសម្ពុទ្ធបរមគ្រូយើងហ្នឹងឯង ។ កាលដែលព្រះសម្ពុទ្ធទ្រង់ស្វែងរកសេចក្តីប្រតិបត្តិ ដែលមានទ្វីមសារវិសេសនោះ ពុំមែនទើបទំនឹងស្វែងរកកន្លងមួយជាតិជាទីបំផុតនេះទេ គឺស្វែងរកអស់កាលជាច្រើនជាតិណាស់ ដូចមានប្រវត្តិដែលអ្នកប្រាជ្ញចាំងឡាយ បានពាយាមរកកន្លងគម្ពីរជាច្រើន មានគម្ពីរបឋមសម្ពោធជាដើម ដែលមានសេចក្តីដំណាលថា កាលព្រះបរមគ្រូនៃយើងនៅក្នុងជាតិ: ជាគោធំសត្វ មានព្រះនាមថា សុមេធបណ្ឌិត បានបំពេញបារមីធម៌ចាំងឡាយ មានទានបារមីជាដើម អំណើះអំពីនោះមក សូម្បីសោយព្រះជាតិជាអ្វី ទោះបីជាតិជាមនុស្សក្តី ជាអមនុស្សក្តី ជាតិរច្ឆានក្តី សុទ្ធតែបានបំពេញបារមីធម៌គ្រប់ ។ ជាតិដើម្បីស្វែងរកនូវមោក្ខធម៌តែម្យ៉ាង រហូតដល់ជាតិជាតិ ដែលមានឈ្មោះថា សិទ្ធត្ថ គំរប់កាលអស់ ៤ អសំខេយ្យ មួយសែនកប្ប ទៅតែមិនដួចប្រទះនឹងទ្វីមរបស់សេចក្តីប្រតិបត្តិ គឺមោក្ខធម៌ឡើយ ។

ព្រះសិទ្ធត្ថ-គោតម ទ្រង់ប្រសូតនៅថ្ងៃសុក្រ ១៥ កើត ខែ

វិសាខ ឆ្នាំច ព្រះវរកជបិតាព្រះនាម ព្រះសុភោទនៈ គោតម ព្រះវរកជមាតា ព្រះនាម ព្រះសិរីមហាមាយា ជាព្រះចៅក្រុងកបិលព័ស្តុ នៃដែនសក្កៈ ។

លុះព្រះជន្មាយុបាន ១៦ ព្រះវស្សា ព្រះសិទ្ធត្ថទ្រង់ទទួលភជាតិ-សេកជាព្រះចៅក្រុងកបិលវត្ថុ ដោយមានព្រះនាង យសោធរាពិឡា-ឌេវី ជាអគ្គមហេសី ហើយទ្រង់មានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមព្រះរាហុលកុមារ ។ ដល់ព្រះជន្មាយុបាន ២៩ ព្រះវស្សា ក្រោយពេលដែលទ្រង់យល់ឮវៃវៃពួតពាំង ៤ គឺៈ ជរា-ត្បាធិ-មរណៈ ទីង អ្នកបួសព្រះសិទ្ធត្ថទ្រង់ខ្សឹយណាយ ក្នុងកេរជាយភាវៈ តំទ្រង់យាងចេញពាំងកណ្តាលអធ្រាត្រទៅចំពេញបព្វជ្ជា ស្វែងរកនូវសព្វញ្ញុតញាណជាមោក្ខ-ធម៌ មិនយូរប៉ុន្មាន ជាន់យល់ឃើញច្បាស់នូវសព្វញ្ញុតញាណនោះនៅលើរតនបល្ល័ង្ក ក្រោមដើមពោធិព្រឹក្ស ពេលព្រះអាទិត្យរះចំព្រាងៗនៃថ្ងៃ ១៥ កើត ខែវិសាខ ឆ្នាំរកា ក្រោយធ្វើទុក្ករកិរិយា ៦ វស្សា ។ ព្រះសិទ្ធត្ថទ្រង់ជាន់ព្រះនាមហៅថា «ព្រះពុទ្ធ» ចាប់តាំងពីថ្ងៃនោះរហូតមក ។

ចាប់ពីពេលដែលជាន់ត្រាស់ដឹងនូវសព្វញ្ញុតញាណមក ព្រះពុទ្ធជាម្ចាស់ ទ្រង់ប្រកាសសាសនធម៌ដល់សត្តនិករទូទៅក្នុងលោក ។ លុះដល់ថ្ងៃ ១៥ កើត ខែមាឃ ឆ្នាំរកា ជាគំរប់ ៩ ខែគត់ គិតពីថ្ងៃដែល

ព្រះអង្គជាន់ត្រាស់ដឹង ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រជុំព្រះអរហន្តចាំង៦ឡាយ ធ្វើមហាសន្និបាត ក្នុងវត្តវេឡុវ័ន ប្រគល់ដំណែងអគ្គសាវកដល់ព្រះថេរៈ ពីរអង្គគឺ :

អគ្គសាវកទី១ បានដល់ព្រះសារីបុត្រជាឯតទគ្គ (Record) ខាងបញ្ញា

សាវកទី ២ បានដល់ព្រះមោគ្គល្លានជាឯតទគ្គ (Record) ខាងឫទ្ធិ

ហើយទ្រង់ប្រកាសគោលច្បាប់ព្រះពុទ្ធសាសនាគឺ :

សព្វបាបស្ស អករណំ កុសលស្សូបសម្បទា

សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ

ការមិនធ្វើបាបចាំងពួង ១ ការបំពេញកុសល ១

ការជូសខាត់សំអាតចិត្តរបស់ខ្លួន ១ ចាំង ៣ នេះ

ជាគោលច្បាប់ព្រះពុទ្ធសាសនានៃព្រះពុទ្ធចាំង៦ឡាយ ។

ព្រះពុទ្ធចាំង៦ឡាយគ្រប់ព្រះអង្គ ដែលបរិនិព្វានទៅហើយក្តី ដែលនឹងត្រាស់ដឹងក្នុងអនាគតក្តី សុទ្ធតែទ្រទ្រង់នូវមហាករុណាគុណ ប្រកបដោយអត្តសម្បត្តិ (គុណជាចំណែករបស់ព្រះអង្គ) ឧត្តមបរហិតសម្បត្តិ (គុណជាចំណែកដល់សត្វដទៃ) ព្រះអង្គជាតន្ទុជាន្ធិយៈនៃទេព្តា ឧត្តមមនុស្សចាំង៦ឡាយ ទ្រង់សំដែងធម៌ខ្លាន់ប្រឿនប្រដៅសត្វលោកដោយព្រះន័យដ៏បរិសុទ្ធ សំដែងប្រាប់ហេតុផលនៃសេចក្តីសុខ-ទុក្ខ ដើម្បីអ្នកស្តាប់

អ្នកវៀនតាំចារណាឲ្យឃើញច្បាស់ដឿងយ៉ាងខ្លួនឯង តាមលំអានៃពុទ្ធ
ឱវាទដូចគ្នាគ្រប់ៗព្រះអង្គ ឥតជាក់អាជ្ញាបង្គាប់បញ្ជាឲ្យដឿងឡើយ ។

ព្រះពុទ្ធ ដែលទ្រង់សំដែងធម្មវិន័យប្រោសពេនេយ្យសត្វអស់រយៈកាល
៤៥ ព្រះវស្សា កំចូលបរិនិព្វានទៅ ទើបព្រះសង្គីតិកាចារ្យ ប្រមូលរៀប
រៀងទូវាក្យពុទ្ធវចនៈនោះ ដោយពួក ។ ឲ្យដឹងថា នេះជាធម៌ នេះជាវិន័យ
នេះជាពុទ្ធប្បញ្ញត្តិ នេះជាពុទ្ធានុញ្ញាតិ ទើបចាត់ទៅជាបិដកមាន ៣ គឺ
វិន័យបិដក សុត្តន្តបិដក អភិធម្មបិដក ចាត់ទៅជាធម្មក្ខន្ធ មាន ៨៤០០០
ព្រះធម្មក្ខន្ធ ។ ពុទ្ធសាសនធម៌ មានចំនួនច្រើនយ៉ាងនេះក៏ដោយ គង់
សង្គ្រោះចូលក្នុងគោលច្បាប់ ៣ យ៉ាង ដែលមានការមិនធ្វើបាបជាំងពួង
ជាដើមនេះដែរ ដូចសេចក្តីអធិប្បាយចំពោះគោលមួយៗតទៅ ៖

១- សព្វបាបស្ស អករណំ ការមិនធ្វើបាបទាំងពួង
(គោលទី ១ នេះសង្គ្រោះចូលក្នុងវិន័យបិដក)

គោលទី ១ នេះជាច្បាប់ប្រដៅសត្វលោកមិនឲ្យធ្វើបាប, ។

ពាក្យថា បាប នេះ បានដល់អំពើអាក្រក់គ្រប់យ៉ាង នាំឲ្យក្តៅ
ក្រហាយ ជាហេតុញ៉ាំងសត្វលោកឲ្យធ្លាក់ទៅអបាយ ។

ពាក្យថា បាប នេះ ប្រែថា អំពើអាក្រក់ ការដល់នូវសេចក្តីវិ-
នាស ការរក្សាទុកនូវសេចក្តីវិនាស ។

ចាប សត្វនេះ មានជាលិសម្រាប់និយាយ ផ្សាស់ប្តូរគ្នាជាច្រើន យ៉ាងគឺ :

ចាប អំពើលាមក

ទុច្ចរិត ការប្រព្រឹត្តិអាក្រក់

អកុសល អំពើមិនល្អ

អកតរណីយៈ អំពើដែលមិនត្រូវធ្វើ

វិសមចរិយា ការប្រព្រឹត្តិរំលោភ

អព្រហ្មចរិយៈ ការប្រព្រឹត្តិមិនប្រសើរ ។

ពាក្យថា មិនធ្វើចាបចាំងតួង ចានដល់ការព្យាយាមកំចាត់ចាបចាំងអស់ ដោយកាយ វាចាចិត្ត គឺវៀរចាកអកុសលកម្មបថ ១០ ប្រការ(១)។

ឯអកុសលកម្មបថ ១០ ប្រការនេះ លោកចែកចេញជា ៣ ពួក គឺ កាយកម្មជាពួក ១ វចីកម្មជាពួក ១ មនោកម្មជាពួក ១ ។

កាយកម្ម

កាយកម្ម : គឺអំពើដែលធ្វើអាក្រក់ដោយកាយ មាន ៣ យ៉ាង គឺ: ចាណាតិចាត ១, អទិន្នាទាន:១, កាមេសុមិច្ឆាចារ១ ។

១- ចាណាតិចាត: កិរិយាសម្លាប់សត្វដោយកាយខ្លួនឯង ឬប្រើអ្នកដទៃឲ្យសម្លាប់ ។

---

(១) ព្រះសីរីមង្គលាចារ្យ ជាអ្នកប្រមូលអត្ថបទពីក្នុងអដ្ឋកថា ព្រះវិន័យ ព្រះសូត្រជាច្រើនអង្វែមកតម្រៀបរៀងក្នុងគម្ពីរមង្គលត្ថទីបនី

បណ្តាជីវិតរបស់មនុស្សនិងសត្វនិមួយ ។ ជាទីស្រឡាញ់គេញាចិត្ត ជាងវត្តដទៃ ។ ព្រោះការស្លាប់នេះមិនជាទីគេញាចិត្តនរណាម្នាក់ឡើយ ។ ព្រោះហេតុដូច្នោះ ជាន់ជាមនុស្សសត្វទាំងអស់ក្នុងពិភពលោក ទំរឹងប្រែងស្វែងរកសុីទាំងយប់ទាំងថ្ងៃ មិនគិតដល់ការនឿយហត់ ដើម្បីញ៉ាំងជីវិតឲ្យរស់ស្ថិតស្ថេរតទៅ ។

ជីវិតជាទីស្រឡាញ់គេញាចិត្តរបស់មនុស្សសត្វ សេចក្តីស្លាប់ជាទីសំអប់របស់មនុស្សសត្វ ចើបុគ្គលណាហ៊ានខ្មាយសេចក្តីស្រឡាញ់របស់គេ គឺសម្លាប់ផ្តាច់ជីវិតគេ បុគ្គលនោះ រមែងខ្លួចខ្លួចខ្លាចក្រែងទោសដួចគេវិញមិនខាន ។ អំពើសម្លាប់នេះអាចឲ្យទោសជាក់ស្តែងនឹងភ្នែកក្នុងជាតិនេះក៏មាន ដួចជាសម្លាប់មនុស្ស ទឹងត្រូវខ្លួចចាប់ត្រោះជាខមួន់ តឹត្រូវកាជការផ្តន្ទាទោស មានជាក់គុកច្រក់ជាដើម សូម្បីតែសម្លាប់សត្វតិរច្ឆានពាល់ ។ ថ្ងៃយូរវែង ឆ្នាំ ក៏ទឹងមានទោសក្នុងជាតិនេះដែរ ដួចជាគោយាតក: គោយាតកនេះគាត់សម្លាប់គោចិញ្ចឹមដីវិតពាល់ ។ ថ្ងៃថ្ងៃណាគ្មានសាច់គោបរិភោគ ថ្ងៃនោះគាត់មិនបរិភោគអាហារទេ មានថ្ងៃមួយគ្មានសាច់គោ គាត់ទៅកាត់អណ្តាតគោទាំងរស់យកមកអាំងបរិភោគ រំពេចនោះស្រាប់តែអណ្តាតរបស់គាត់ធ្លាក់ចុះក្នុងចានចុយស្រែកពេញដួចគោ មិនយូរប៉ុន្មាន ក៏ស្លាប់ទៅកើតក្នុងអបាយនរក រងទុក្ខវេទនាក្រៃអនេក ។

ជាណាតិជាតកម្មរមែងនាំខ្លួនវេទនាមកឲ្យគ្រប់គ្នាដែលបានប្រព្រឹត្ត
សមតាមអំពើដែលបានធ្វើពីព្រេងមក ។ តាហារណ៍ដូចជា ៖

រឿងព្រាហ្មណ៍ទិសាបាមោក្ខាចារ្យ (១)

កន្លងអតីតកាល មានព្រាហ្មណ៍ម្នាក់ជាទិសាចារ្យមោក្ខាចារ្យ បង្រៀន
វិជ្ជាការដល់ទិស្សតៃតាំងឡាយ ដែលមកពីគ្រប់ទិស នៅក្នុងក្រុងតាក-
ណសី នៃដែនកាសី ។ លោកសាស្ត្រាចារ្យនោះបានសម្លាប់ចៀម ១
ហើយឲ្យនូវមែតកកត្តុ(២) ។ ដោយកម្មដែលគាត់សម្លាប់ចៀមនោះ លុះ
អន្លងទៅចាប់កំណើតកើតនៅទីណា តែងស្លាប់ដោយជាប់ក្បាលនៅទី
នោះ ប្រមាណជា ៤៩៩ ជាតិ ក្នុងគំរប់ ៥០០ ជាតិ គាត់បានមកកើត
ជាចៀមរបស់ព្រាហ្មណ៍ជាទិសាចារ្យមោក្ខាចារ្យ ដូចគ្នានឹងព្រាហ្មណ៍មុន
នោះ ។ ឯព្រាហ្មណ៍ជាទិសាចារ្យចង់ធ្វើមែតកកត្តុ គាត់ចាប់
ចៀមប្រុងនឹងសម្លាប់ ។ ចៀមជាសត្វដឹងជាតិ ទឹកឃើញបុព្វកម្មរបស់
ខ្លួនហើយសើច ។ ហើយយំ ។ ព្រាហ្មណ៍ឃើញដូច្នោះក៏សួរថា "នែ!
សត្វចៀម ម្តេចបានជាសើចហើយយំ?" ចៀមក៏ឆ្លើយតាមសួរថា "ខ្ញុំ
មានសេចក្តីត្រេកអរ ដោយគិតថាមុខជារួចពីសេចក្តីទុក្ខមានសភាព
ដូច្នេះក្នុងថ្ងៃនេះ បានជាខ្ញុំសើចដែលខ្ញុំយំនោះ ដោយខ្ញុំអាណិតលោក
ព្រោះឃើញថា បើលោកសម្លាប់ខ្ញុំ មុខជាលោកត្រូវជាប់ក្បាល ៥០០

១— មកពីភាសាបាលី ទុតិយវគ្គ ឯកនិបាត ។ ២- ភក្តដែលទុំសងិល់មនុស្សស្លាប់ ។

ជាតិដូចខ្ញុំដែរ។ ។ ព្រាហ្មណ៍ថា "នែ! ចៀម ឯងកុំតក់ស្លុតឡើយ អញមិនសម្លាប់ឯងទេ" ។ ចៀមថា "បើខុតជាលោកមិនសម្លាប់ខ្ញុំ ខ្ញុំក៏ត្រូវស្លាប់ថ្ងៃនេះដែរ" ។ ព្រាហ្មណ៍លែងចៀមទៅ ហាមកូនចៅទាំងសិស្សានុសិស្សកាំងឡាយមិនឲ្យសម្លាប់ចៀមនោះឡើយ ។

ឯសត្វចៀម កាលបើរួចខ្លួនហើយ ក៏ទៅអើតកស៊ីស្មៅឈើដែលដុះអស្រ័យនឹងថ្ម ១ ដុំ រំពេចនោះស្រាប់តែមានន្ទុះចាញ់ត្រូវខ្នងថ្ម បែកឆ្អឹងតាត់មកត្រូវចៀមដាច់ក ស្លាប់កន្ទិចនោះទៅ ។

ព្រោះហេតុនោះ ព្រះបរមសាស្តាចារ្យទ្រង់ត្រាស់ថា "ម្នាលភិក្ខុកាំងឡាយ! ចុរាណាតិចុតត ដែលបុគ្គលធ្វើហើយ ជាអំពើប្រព្រឹត្តទៅដើម្បីអចាយ ក្នុងកំណើតទៅកើតកន្លងរក រួចពីនរកមកកើតជាប្រេត រួចពីប្រេតមកកើតជាអសុរកាយ រួចពីអសុរកាយមកកើតជាតិរច្ឆាន ចាន ខុក្ខវេទនាជាអង្វែងឆ្ងាយ លុះចុតកម្មនោះស្រាល មកកើតជាមនុស្ស ក៏ជាមនុស្សឈឺច្រើន អាយុខ្លី[1] ។

ចុរាណាតិចុតកម្ម លោកឲ្យឈ្មោះថា ទាប ជាអំពើមិនត្រូវធ្វើឡើយ ។

២- អនិដ្ឋាទាន: កិរិយាលួចលាក់នូវដណ្តើមទ្រព្យគេដោយខ្លួនឯង ឬប្រើគេឲ្យលួច ។

បណ្តាទ្រព្យសម្បត្តិទាំងអស់ ដែលគេកេចាននមក ទោះមាន

១- អង្គុត្តរនិកាយតតិយ អដ្ឋកថាទីឆាត សព្វលហុសូត្រ ។

វិញ្ញាណក្តី ឥតវិញ្ញាណក្តី ល្អក្តី អាក្រក់ក្តី សុទ្ធតែជាទីពេញចិត្ត គេ
មិនចង់ឲ្យនរណាមកលួច ឬធ្វើជណ្តើមឡើយ ។ ព្រោះហេតុនោះអំ
ពើលួច លោកឲ្យឈ្មោះថាបៀតបៀនគេ ធ្វើឲ្យគេសៅហ្មងចិត្ត បើនរ-
ណាធ្វើឲ្យគេសៅហ្មងចិត្តហើយ ខនោះនឹងខ្ជួលទោសទុក្ខដូចគេវិញ ។

អធិដ្ឋានបាន ដែលបុគ្គលធ្វើហើយ ជាអំពើប្រព្រឹត្តទៅ ដើម្បី
អបាយ គឺនាំជនល្មួចទាំងឡាយឲ្យដល់នូវសេចក្តីវិនាស ក្នុងបច្ចុប្បន្ន
ជាតិនេះប្រាកដ ។ ដ្បិតថា អំពើលួចនេះ កុំថាឡើយដល់ទៅបន្ទន់ជណ្តើម
យកទ្រព្យមានតម្លៃច្រើន ដោយរហាចទៅ សូម្បីតែលួចទ្រព្យតិចតួច
ប៉ុណ្ណោះ ក៏ត្រូវតែរងទុក្ខបត្រោះយ៉ាងពន្លឹកពុំខាន គឺត្រូវគេចាប់ចងជាក់
ព្យួងដំ ដាក់គុកប្រកាក់ឆ្នាក់ខ្នួនជាមនុស្សគ្មេសពេញទី ។ កាលបើ
ឆ្នាប់ជាប់គ្មេសដូច្នោះហើយ តមកនឹងចេញមុខធ្វើការធំដុំពុំបាន ដោយ
ជាប់ខាត ព្រោះគេសំគាល់ថា ជាមនុស្សអាក្រក់ ។ ជួនកាលទ្រព្យ
គេបាត់ ដោយហេតុអ្វីដទៃទៀតសោះ ប៉ុន្តែខ្លួនដែលឆ្នាប់មានកេរ្តិ៍អាក្រក់
ត្រាន់តែនៅផ្ទះតែឯង គ្មានប៉ុណ្ណោះ ក៏គេប្រថាប់ថាខ្លួនលួចកិសឹងមាន ។ ជន
លួចជាទីមើលងាយនៃជនទាំងឡាយ ដូចជារូបក្តែលួច ។

បើបុគ្គលណាហ៊ានប្រព្រឹត្តអទិន្នាទាន បន្តិចបន្តួចហើយ បុគ្គល
នោះនឹងហ៊ានប្រព្រឹត្តអទិន្នាទានដ៏ក្លាហាន គឺហ៊ានបន្ទន់ដណ្តើមមិនសែង

តែហ៊ានប្ដូនគេញាបខ្លុកហើយ ទឹងត្រូវឆ្កាបគ្រោះជាមិនខាន តើត្រូវពង
ការចាប់មកផ្ដន្ទាទោស បើពងការចាប់មិនបាន ក៏ត្រូវឃ្លាតចាកផ្ទះញាតិ
មិត្រ ឪពុក.ម្ដាយ នៅដេកក្នុងព្រៃ មិនហ៊ានចូលស្រុកមួយអាយុះ ។
ទោសនៃអទិន្នាទាននេះ។ តាហារណ៍ដូចជា ៖

រឿងកុហកតាបស:

ក្នុងកាលកន្លងយូរយារណាស់ហើយ មានតាបសម្នាក់ឈ្មោះកុ-
ហក: អាស្រ័យនៅបណ្ណសាលាក្បែរក្រុងពារាណសីនៃដែនកាសី មាន
កុដុម្ពីក៍ម្នាក់និមន្តនាំកាល់ ។ ថ្ងៃ ។ ដល់មានចោរកើយ កុដុម្ពីក៍យកមាស
ប្រាក់ទៅកប់ក្រោមសាលាផ្ទើនឆ៍តាបស ។ ឃើញមាសប្រាក់ច្រើនដូច្នេះ
ក៏គិតថា « មាសប្រាក់របស់កុដុម្ពីក៍នេះ បើអញយក នឹងអាចចិញ្ចឹមជីវិត
រស់ដោយស្រួលអស់ ១ អាយុះ » គិតដូច្នោះហើយក៏លួចមាសប្រាក់នោះ
យកទៅកប់កន្លែងផ្សេងទៀត ហើយទៅបញ្ឆោតកុដុម្ពីក៍ថា « អាត្មាភាព
នៅទីនេះ ច្របូកច្របល់ជាមួយនឹងមនុស្សច្រើនមានសេចក្ដីធុញទ្រាន់ពេក
នឹងសូមលាញោមទៅព្រៃហិមពាន្តថ្ងៃនេះហើយ » កុដុម្ពីក៍និយាយអង្វរថា
« បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់គង់នៅទីនេះចុះ ខ្ញុំព្រះ
ករុណានឹងសាងសាលាហើយ ធ្វើបង់ពន្ធជុំវិញជាថ្មីទៀត ដើម្បីចៀសវាង
ការច្របូកច្របល់នឹងមនុស្ស » តាបសនៅតែមិនយល់ព្រមទទួលនិមន្តន៍
របស់កុដុម្ពីក៍ឡើយ ការចេញចាកបណ្ណសាលាជាការចាំបាច់របស់កុហក

តាបស ។ លុះនិមន្តចេញបន្តិចក៏ត្រឡប់មកវិញ ដោយមានយកស្បូវ
ពីរបីសរសៃមកសៀតនឹងផងសក់ហើយប្រាប់កុដុម្ពីក៍ថា ‘‘ញោមស្បូវ
នេះជាក់ពីដំបូលផ្ទះញោមមកជាប់ផងសក់អាត្មា ។ ខ្ញុំបង្រៃនឹងខ្ញុំជាន
ជានយកមកជូនញោមវិញ ’’ ។

គ្រានោះ ព្រះបរមពោធិសត្វបានឮសំដីតាបស ក៏ជ្រាបថា ជាសំដី
បង្វែងជាន ហើយសួរកុដុម្ពីក៍ថា «លោកមានយកអ្វីទៅផ្ញើនឹងតាបសនោះ
ដែរ? » កុដុម្ពីក៍ឆ្លើយថា «មានមាសប្រាក់ខ្លះដែរ» ព្រះពោធិសត្វប្រាប់
ថា « បើដូច្នោះតាបសនេះលួចទៅហើយ ជានតាន់និយាយយ៉ាំង
ម្ដាំង» ។ ថាហើយក៏នាំគ្នាទៅមើលឯសាលា ឃើញថាមាសប្រាក់នោះ
ជាប់មែន ក៏នាំគ្នារត់ទៅតាម លុះទាន់ក៏ឃាដំច្រំជាក់ហៀបនឹងស្លាប់
ហើយយកទ្រព្យត្រឡប់មកផ្ទះវិញ ។

ជនល្មួចស្លាប់ទៅ ខឿនតែទៅកើតកូនឥតទុ រួចពីនរកមកកើតជា
ប្រេត រួចពីប្រេតមកកើតជាអសុរកាយ រួចពីអសុរកាយមកកើតជាតិ-
រច្ឆាន រង់ទុក្ខវេទនាជាអង្វែង ។ លុះផលកម្មនោះស្រាល មកកើតជា
មនុស្ស វិនាសទ្រព្យសម្បត្តិ សូម្បីតែប្រាក់ ១០០ ក៏ទុកមិនគង់ដែរ ។

អនិដ្ឋាផានកម្ម លោកឲ្យឈ្មោះថា ទាប ដាំអំពៅមិនត្រូវ
ផ្លែឡើយ ។

៣ - ការមេសុមិច្ឆាចារកំរើយាប្រព្រឹត្តខុសកូនកាមចាំដឹងឮយ
គឺធ្វើខ្លួរសៅនៃកិច្ច ជាមួយកូនប្រពន្ធ ប្តី អ្នកដទៃ ។

មនុស្សក្នុងពិភពលោកមែងហួងហែងរក្សាផ្លូវកាមជាធម្មតា បើ
បានស្រីណាមួយជាប្រពន្ធហើយគេស្រឡាញ់ប្តូរដើរតែ ហួងហែងរក្សា
មិនឲ្យបុរសណាដទៃមកប្រព្រឹត្តល្មើសនឹងស្រីខ្លួនឡើយ ។ បើគេ
ចិញ្ចឹមស្រីណាជាកូនរបស់គេ ។ ស្រឡាញ់ថែរក្សាខុកបំរុងរៀបចំខុកដាក់
ឲ្យបុរសណាដែលស្រឡាញ់ពេញចិត្តមកដណ្តឹងតាមច្បាប់ប្រពៃណីគេមិន
ចង់ឲ្យបុរសដទៃមកប្រព្រឹត្តល្មើសកន្ទុងច្បាប់ប្រពៃណីឡើយ ។ បើបុរស
ណាទៅលួចរួមរកែនឹងកូនក្រមុំ ឬ កំរើយាគេ បុរសនោះឈ្មោះថាធ្វើឲ្យគេ
ពិបាកចិត្ត ជាហេតុធ្វើឲ្យខូចសាមគ្គីធម៌ជាបឋមល់ឈ្មោះប្រកាប់គ្នាកំមាន ។
ទោសដែលមើលឃើញក្នុងជាតិនេះក៏មានច្រើន ។ ការប្រព្រឹត្តខុសកូន
កាមនេះ បើចេះលាក់បិទជ្រុងមិនឲ្យឃើញក្នុងជាតិនេះ ក៏គង់ខ្លួលទោស
ក្នុងបរលោកមិនខាន ។ ឧទាហរណ៍ដូចជា ៖

រឿងនាងឥសីទាសីបើរី (១)

នៅក្នុងនគរកុសុមបាដលិបុត្ត មានទាងកំកូនីពីរបូ គឺព្រះទាងឥស
ទាសីបើរី ១ ព្រះទាងរោធិបើរី ១ ជាធីតាក្នុងសាក្យត្រកូល ជាបើរបើបូណ
ដោយសីល ជាតហូស្តុត មានកំលេសកំចាត់បង់ហើយ ក្នុងពេលក្រោយ

---

១ ជាតបើរីធាវិ ខណ្ឌឡើសនិបាត ខុទ្ទកនិកាយ ។

ធ្វើភត្តកិច្ច ព្រះនាងតិក្ខិណ៍ពាំងព័រ នៅតង់ក្នុងទីស្ងាត់ ។ ព្រះនាងពោធិ
ថេរីផ្តើមសួរថា « ម្នាលនាងឥសីទាសី ! នាងប្រកបដោយរូបឆោមស្រស់
ប្រិមប្រិយទំនងកស្រីណាប្រដូចគ្នាន ពាំងវ័យក៏នៅក្មេង តើនាងមានយោ
បល់ដែលដូចម្តេច ចានជាមកបួស ? » ។ ព្រះនាងឥសីទាសីក៏ឆ្លើយថា
« ម្នាលនាងពោធិ ! បួរនាងប្រុងចាំស្តាប់តាមដំណើរនេះចុះ ៖

ចិតាខ្ញុំជាមហាសេដ្ឋី ប្រកបដោយសីល នៅក្រុងទន្លេន ដែនប្រ-
ទេសអវន្តិ ។ ខ្ញុំជាធិតាម្ចាស់ជាទីពេញចិត្តចិតា ។ លុះពេលក្រោយមក
ចិតាបានលើកខ្ញុំឲ្យមានស្វាមី ខ្ញុំក៏ទៅចំរើស្វាមីម្ចាយ-ឪពុកក្មេក ។ កាល
បើឃើញសាច់ញាតិស្វាមីខ្ញុំ ឬបរិវារស្វាមីខ្ញុំមក ខ្ញុំទទួលរាក់ទាក់ជូនភោ-
ជនាហារតាមសមគួរដល់វត្ថុដែលគេត្រូវការ ។ ខ្ញុំតែងក្រោកមុនស្វាមី
ហើយចូលទៅគោរពប្រតិបត្តិប្តី ខ្ញុំជូតលាងដៃប្តី ពាំងជូតលាងសំអាត
ភ្នែរណីជាដើម ។ ខ្ញុំដាំបាយខ្លួនឯង លាងចានខ្លួនឯង ខ្ញុំថ្នមស្វាមី
ដូចមាតាបិតាថ្នមកូនខ្ចី តែប្តីខ្ញុំខឹងនឹងខ្ញុំ ។ ប្តីខ្ញុំនិយាយនឹងមាតាបិតា
របស់គេថា « ខ្ញុំសូមលាលោកឪពុក-ម្ចាយហើយ ខ្ញុំមិនអាចនៅជាមួយ
នាងឥសីទាសីបានឡើយ » ។ មាតាបិតាក្មេកខ្ញុំសួរខ្ញុំថា « នែកូន
ស្រីសំឡាញ់ តើនាងធ្វើអ្វីខុសនឹងប្តីនាង បួរនាងប្រាប់កំហុសនោះ តាម
ពិតឲ្យមែនដឹងផង ? ខ្ញុំប្រាប់ថា « លោកម្ចាយឪពុក ! ខ្ញុំគ្មានធ្វើអ្វីខុសទេ
បើប្តីខ្ញុំស្អប់ប្រខ្ញុំ តើឲ្យខ្ញុំធ្វើអ្វីត្រូវចិត្តគាត់ ។ ម្ចាយ-ឪពុកក្មេកខ្ញុំ កំនាំខ្ញុំ

ទៅប្រគល់ឲ្យម្តាយ-ឪពុកខ្ញុំវិញ ។ ក្រោយមកម្តាយ-ឪពុកខ្ញុំឲ្យខ្ញុំមានប្តី ម្តងទៀត ប្តីទីពីរ ខ្ញុំនៅផ្ទះស្វាមីបានតែ១ខែគត់ ប្តីខ្ញុំលែងខ្ញុំចោល ដែលខ្ញុំជាស្រីបំរើប្តីដូចទាស៊ី មានមារយាទល្អ ។

ថ្ងៃមួយ បិតាខ្ញុំនិយាយនឹងបុរសម្នាក់ឲ្យមកធ្វើជាស្វាមីខ្ញុំ បានរួមគ្នា តែពីរខែ ក៏គេចោលខ្ញុំទៅទៀត ។ ខ្ញុំអត្តឃាតសញ្ជឹងតែម្នាក់ឯងថា អាត្ម-អញត្រូវលាមាតាបិតាចេញទៅបួស ។ គ្រានោះ មានព្រះនាង ជិន-ឧត្តរាថេរី កំពុងគ្រាច់ដើម្បីកិក្ខាហារ បានមកដល់ផ្ទះបិតាខ្ញុំ ខ្ញុំក្រោកឡើងទទួលទ្បើងលើផ្ទះ ហើយអង្គាសចង្ហាន់ ព្រះថេរីនោនឆ្អែតស្កប់ស្កល់ ហើយ ខ្ញុំក៏លាមាតាបិតាចេញបួស ។ លុះបានអនុញ្ញាតពីមាតាបិតា ហើយ ខ្ញុំក៏ទៅកាន់សំណាក់ព្រះសង្ឃសម្ពុទ្ធ ដើម្បីសូមបព្វជ្ជា បួស បាន ៧ ថ្ងៃបានសម្រេចវិជ្ជាជ័ ។ ម្នាលនាងពោធិ! ចូរនាងចាំស្តាប់នូវ ចរិតកម្មរបស់ខ្ញុំដូចតទៅនេះ ៖

ម្នាលនាងពោធិ! កន្លងអតីតជាតិ ខ្ញុំជាបុរសកេរ ធ្វើជាឯមាស ខ្ញុំ ជាមនុស្សស្រីវ័យបានប្រព្រឹត្តខុសកន្លងកាមចំនួនឯក ។ លុះស្លាប់ទៅ បានកើតកន្លង សង្ឃាតនរក អស់កាលជាយូរ លុះរួចពីនរកនោះ ហើយ មកកើតជាស្វា ស្វាឈ្មោលជាមេហ្វូង បានទាំស្តាប់អត្តជាតិ របស់ខ្ញុំ ក្រោយពីថ្ងៃកើត ៧ ថ្ងៃ ។ រួចពីស្វា បានមកចាប់កំណើតជា តិរច្ឆានកន្លង ខ្លួនជង ខ្ញុំត្រូវគេព្រានក់កូនក្មេងអស់ ១២ ឆ្នាំ ហើយត្រូវ

គេត្រៀវ មានដង្ហើរចៀតចៀន ។ រួចពីពពែខ្វាក់-ខ្វក ចានមកចាប់
កំណើតជាគោខ្វាក់-ខ្វក កើតចាន ១៤ ខែ មានកេមក្រហាមដូចជ្រលក់
ល័ខ កំត្រូវគេត្រៀវ ហើយចាញ្ជូនឆ្ពិលទោស់អូសរខេះដែលផ្តុតខំនិញ
ធ្ងន់ ទៅចំនឹងខ្វាក់-ខ្វក ។ រួចពីគោខ្វាក់-ខ្វក ចានមកចាប់កំណើតជា
មនុស្ស មានភេទមិនច្បាកដ មិនច្បាកដប្រុស-ស្រី (ខ្ទើយ) ។ រួចពី
មនុស្សខ្ទើយ ចានមកចាប់កំណើតជាតាវិកា ក្នុងត្រកូលនៃអ្នករខេះ ត្រូវ
ឈ្មួញជាម្ចាស់វិបជាន់ អូសចាញ្ជូចេញពីផ្ទះ ។ ពេលនោះ បុត្រវិបស់
ឈ្មួញរខេះឈ្មោះ កិរិនាសៈ យកខ្ញុំទៅចុកក្នុងផ្ទះវិបស់គេ ។ ប្រពន្ធ
ធំវិបស់ កិរិនាសៈ ជាស្ត្រីមានសីលធម៌ មានគុណធម៌ ជាស្ត្រីប្រព្រឹត្ត
តាមភស្តា ខ្ញុំញុះញង់ឲ្យ កិរិនាសៈដេញប្រពន្ធដើមចេញពីផ្ទះ ។ លុះ
ដល់ក្នុងជាតិជាខ័ប់ផុតនេះ ខ្ញុំចានមកកើតក្នុងសាក្យត្រកូល ប្តីចាំងឡាយ
លះលែងចោលខ្ញុំ ជាស្ត្រីខ្វះខ្ជែងចំរើប្តីដូចភាស ។ នេះព្រោះតែកម្មអា-
ក្រក់ដែលខ្ញុំចានធ្វើ ។

(នៅមានត)

ព្រះអភិធម្មបិដក

គម្ពីរព្រះយមក:

លោក ប៊ុ - ប៊ុ ប្រែរៀបរៀង

(តមក)

អនុសយយមក

សន្តានុសយោ កាមរាគានុសយោ បដិឃានុ-
សយោ មានានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុ-
សយោ ភវរាគានុសយោ អវិជ្ជានុសយោតិ ។

*លំដាប់នេះ សូមវិសជ្ជនាក្នុងអនុសយយមកតទៅ ដំណើរសេចក្តី
ថា កតមា សម្តេចព្រះទ្រង់ព្រះភាគ កាលព្រះអង្គត្រាស់ទេសនាទូរ
សង្ឃរយមកចប់ចុះហើយ ក្នុងលំដាប់នោះទើបត្រាស់ទេសនាទូរអនុសយ
យមកតទៅទៀត ។ ក្នុងអនុសយយមកនោះ ទ្រង់ត្រាស់ទេសនា
ដោយអនុស័យប្រាំពីរប្រការ ។*

សន្តានុសយោ អនុស័យប្រាំពីរប្រការនោះគឺ:

១- កាមរាគានុស័យ

២- បដិឃានុស័យ

៣- មានានុស័យ

៤- ទិដ្ឋានុស័យ

៥- វិចិកិច្ឆានុស័យ

៦- ភវភគានុស័យ

៧- អវិជ្ជានុស័យ ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់បុច្ឆាថា យស្ស អនុសេតិ(១) បើកាមភគានុស័យ ដេកនៅក្នុងសន្ដានៃបុគ្គលណា បដិឃានុស័យដេកនៅក្នុងសន្ដានៃបុគ្គលនោះឬ? ម្យ៉ាងទៀត បើបដិឃានុស័យដេកនៅក្នុងសន្ដានៃបុគ្គលណា កាមភគានុស័យដេកនៅក្នុងសន្ដានៃបុគ្គលនោះឬ? បើកាមភគានុស័យដេកនៅក្នុងសន្ដានៃបុគ្គលណា មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវភគានុស័យ ទឹង អវិជ្ជានុស័យដេកនៅក្នុងសន្ដានៃបុគ្គលនោះឬ? បើមានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវភគានុស័យ ទឹងអវិជ្ជានុស័យដេកនៅក្នុងសន្ដានៃបុគ្គលណា កាមភគានុស័យដេកនៅក្នុងសន្ដានៃបុគ្គលនោះឬ ឬមិនបានដេកនៅផងទេ?

ទ្រង់ត្រាស់វិសជ្ជនាថា បើកាមភគានុស័យដេកនៅក្នុងសន្ដានៃបុគ្គលណា បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវភគានុស័យ ទឹងអវិជ្ជានុស័យ ក៏ដេកនៅក្នុងសន្ដានៃបុគ្គលនោះ បើកាមភគានុស័យមានក្នុងសន្ដានៃបុគ្គលណា អនុស័យប្រាំមួយប្រការ

១- ប្រែតាមវាក្យនេះថា ដេកតាមឬដេកនៅ ។ ប្រែតាមសេចក្ដីថា មាន, ស្ថិត ឬកើត។

ទៀតក៏មានក្នុងសន្តានៃបុគ្គលនោះដែរ ។

កាមកតានុសយមូលកានិ អនុស័យទាំង៦ប្រការ នោះ រមែងមានកាមកតានុស័យជាឫសគល់ជាមូលហេតុ បើគ្មានកាមកតានុស័យជាទីតាំងទេ អនុស័យទាំង៦ប្រការ មានបដិឃានុស័យជាដើម ក៏កើតឡើងមិនបាន ។

មានពាក្យបុច្ឆាថា កាមកតានុស័យនោះតើដូចម្តេច ? អ្វីហៅថា កាមកត ? អ្វីហៅថា អនុស័យ ? កាមកតានុស័យនោះតើអាស្រ័យហេតុដូចម្តេច ?

មានពាក្យវិសជ្ជនាថា កាមកតៈនោះបានន័យសេចក្តីតម្រេកក្នុងកាមអនុស័យនោះ គឺការដេកតាមឫត្រាំនៅក្នុងខន្ធសន្តានៃសត្វរឿយៗ ។ កាមកត គឺសេចក្តីត្រេកអរក្នុងកាម ២ ប្រការ គឺកិលេសកាម ១ វត្ថុកាម ១ ។

កិលេសឈ្មោះថាកាមនោះ ព្រោះហេតុថាកិលេសដែលសត្វគប្បីប្រាថ្នា ។ វត្ថុឈ្មោះថាកាមនោះ ព្រោះហេតុថាជារបស់ដែលសត្វគប្បីប្រាថ្នាដូចគ្នា ។

សេចក្តីត្រេកអរក្នុងកាម ២ ប្រការនោះឈ្មោះថា អនុស័យ ព្រោះហេតុថាដេកត្រាំនៅឫលិចនៅក្នុងខន្ធសន្តាន នៃសត្វសត្វដេកនៅរឿយៗ ដេកត្រាំនៅជានិច្ច ក្នុងខន្ធសន្តាននៃសត្វទាំងឡាយ រៀរលែងតែព្រះ

អរិយបុគ្គលដែលប្រកបដោយសេចក្តីក្តៅចិត្ត ទើបមិនអាចដកត្រាំនៅបាន ។

បដិឃៈ បាននឹងចិត្តប្រកបដោយសេចក្តីក្រោធ ។

មានៈ បាននឹងសេចក្តីប្រកាន់ខ្លួន ។

ទិដ្ឋិ: បាននឹងការដែលបុគ្គលយល់ឃើញខុស នឹងប្រកាន់ខុស ហើយប្រឿនប្រដៅឲ្យអ្នកដទៃយល់ឃើញខុសប្រកាន់ខុសតាមខ្លួន ។

វិចិកិច្ឆា: បាននឹងបុគ្គលមានចិត្តគិតសង្ស័យ មិនបានសំណាត់ឲ្យជាប់ស្រេច ។

ភវរាគៈ បាននឹងសេចក្តីត្រេកអរក្នុងភពបី គឺកាមភព រូបភព នឹងអរូបភព ។

អវិជ្ជា បាននឹងការមិនដឹង ។

ធម៌ទាំង៥ប្រការនេះឈ្មោះថា អនុសយ ព្រោះហេតុថាដកត្រាំនៅជាប់ជានិច្ចក្នុងខន្ធសន្តានៃសត្វទាំងឡាយ លុះតែបានសម្រេចអរិយមគ្គ អរិយផល ទើបធម៌ទាំង៥ប្រការនេះលែងត្រាំក្នុងសន្តាន ។

ធម៌ទាំង៥ប្រការនេះ គ្រាន់តែកាមភតមួយប្រការណោះ បើកើតមានក្នុងចិត្តអ្នកណាហើយ តែងធ្វើអ្នកនោះឲ្យក្តៅក្រហាយអន្ទះអន្ទែង បើមិនខំបំបាត់ចេញទេ ចេះតែបណ្តាយឲ្យកើតខ្លាំងក្លាឡើងៗ ពាល់តែអត់ត្រាំមិនបានដល់វេលាឃើញស្ត្រីមានសេចក្តីស្នេហាស្រឡាញ់ខ្លាំងពេក ទៅជាក្តៅ

ខ្ញុំគ្មានគំនិតអៀនខ្មាស ហ៊ានឱយយកចំអកចំអន់លេងសើចប្តូហ៊ានបួលទៅចាប់ដៃគាល់ខ្ជួនប្រាណស្រីនោះ ដែលគេមិនដឹងខ្លួនសោះ ដួនកាលត្រូវកដខ្លាំងណាគឺកដការចាប់យកទៅធ្វើខណ្ឌកម្ម្តបានន័យថាប្រាក់កាស ដួនកាលកើតឈ្លោះប្រកែកវាយដំគ្នា ព្រោះទៅស្រឡាញ់ប្រពន្ធគេប្តូប្តីគេ ។

ម្យ៉ាងទៀត អនុស័យប្រាំពីរប្រការមានកាមពគានុស័យជាដើមនេះ បើកើតមានក្នុងចិត្តនៃបុគ្គលណាហើយ តែងញ៉ាំងបុគ្គលនោះឲ្យប្រព្រឹត្តខុសច្បាប់ផ្សេងៗ ដែលខ្ជួនមិនធ្លាប់ប្រព្រឹត្តពីមុនមកសោះ ទៅជានាំឲ្យហ៊ានប្រព្រឹត្ត ជាហេតុនឹងឲ្យបានខ្លួនសេចក្តីវិនាសក្នុងជាតិនេះនឹងជាតិមុខ ។ ហេតុដូច្នោះ អ្នកមានប្រាជ្ញាគួរតែខំតាត់បង់ខ្លួនអនុស័យទាំងប្រាំពីរប្រការមានកាមពគានុស័យជាដើមនេះឲ្យអស់ចេញពីសន្តាន ដូចជាការលះបង់ខ្លួនសេចក្តីត្រេកអរក្នុងកាមពីរប្រការ លោកសំដៅយកកេរបព្វជ្ជាខ្ពើបលះបង់កាមពីរនោះបាន នេះកំណត់ជាន់ខ្ពស់ចំផុត បើកំណត់ជាន់ខាងវិញ បុគ្គលជាឃរាវាសក៏អាចលះបង់កាមពីរនោះបានដែរ គឺមិនឲ្យត្រេកអរក្នុងកាមគុណរបស់អ្នកដទៃ ទឹងតែរបស់អ្នកដទៃ បើគ្រាន់តែនឹកត្រេកអរក្នុងចិត្តរបស់ខ្លួនប៉ុណ្ណោះមិនបញ្ចេញអាការខាងក្រៅឲ្យឃើញច្បាស់ក៏ឥតទោស ជាការដែលអ្នកប្រាជ្ញសរសើរថាជាបុគ្គលសន្តោស។

បដិឃានុស័យ បានន័យសេចក្តីក្រោធ កើតមានក្នុងចិត្តអ្នកណាតែងធ្វើអ្នកនោះឲ្យបានទុក្ខទោសឲ្យវិនាសច្រើនប្លែកៗ តាមកម្លាំងក្រោធ

ខ្ញាំងប្លុកចិត ។ អ្នកក្រោធខឹងមិនចាន់សេចក្តីសុខឬការចំរើនផលប្រយោជន៍អ្វី ។ ឡើយ ។

មានជាឧស័យ ចាន់ខឹងការប្រកាន់ខ្លួនច្រើណា ម៉េកើតមានក្នុងចិត្តអ្នកណាហើយ តែងធ្វើអ្នកនោះឲ្យចាន់នូវសេចក្តីវិនាសជាច្រើនប្រការ ។

ព្រះអដ្ឋកថាចារ្យ សំដែងដោយអនុលោមតាមព្រះពុទ្ធភាសិតនៃសម្តេចព្រះបរមទសពលមានច្រើនប្រការ ព្រោះថាមានៈនោះម៉េកើតមានឡើង ហើយបណ្តាយឲ្យចេះតែចំរើនច្រើន ។ ឡើង កំនាំបណ្តាលឲ្យស្រវឹងផៅផ្សេង ។ គឺស្រវឹងព្រោះជាតិ ១ ស្រវឹងព្រោះគោត្រ ១ ស្រវឹងព្រោះឥតរោគ ១ ស្រវឹងក្នុងជីវិត ១ ស្រវឹងក្នុងលាភ ១ ស្រវឹងសក្ការៈ ១ ស្រវឹងក្នុងការគោរព ១ ស្រវឹងក្នុងបរិវារ ១ ស្រវឹងក្នុងសម្បត្តិ ១ ស្រវឹងក្នុងការសរសើរគុណ ១ ស្រវឹងក្នុងភាពជាតពហុសូត្រ ១ ស្រវឹងក្នុងឋដិភាណ ១ ស្រវឹងក្នុងយស ១ ។ បុគ្គលមានមានៈច្រើនតែងនាំឲ្យកើតមានសេចក្តីស្រវឹងផ្សេង ។ ដូចរៀបរាប់មកប៉ុណ្ណេះជាដើម ។

អ្នកស្រវឹងព្រោះជាតិនោះ តែងកើតអំពីភេទទាំងបួនជាមូលហេតុ គឺភេទក្សត្រ ១ ភេទព្រាហ្មណ៍ ១ ភេទឈ្មួញ ១ ភេទអ្នកត្រួ ១ ។

ភេទក្សត្រតែងកើតមានៈប្រកាន់ខ្លួនថា ជាតិសម្បន្នោ ហំ ខត្តិយោ ឈ្មោះថាក្សត្រជាអ្នកបរិបូណ៌ដោយជាតិ អាត្មាជាក្សត្រប្រកប

ដោយជាតិខ្ពង់ខ្ពស់ គ្មានអ្នកណាស្មើឡើយ អាត្មានជាក្សត្រកើតមកអំពីក្សត្រសន្តតិវង្ស ។

ឯការស្រែងដោយជាតិនោះ ជាហេតុនឹងឲ្យដល់នូវសេចក្តីវិបត្តិ ដូចសាក្សកដ៏ងឡាយដែលប្រកបដោយមាន:នោះ ព្រះពុទ្ធកុមារព្រះនាមវិឌូឌភៈ សម្ងាប់ព្រះញាតិវង្សានុវង្សឲ្យអស់ព្រះជន្មជាច្រើន ។

ការស្រែងព្រោះគោត្រនោះ គឺកើតមាន:ថា អាត្មាកើតក្នុងអាទិត្យវង្ស ក្សត្រផ្សេង។ មានវង្សថោកទាបជាងអាត្មា ។

ចំណែកព្រាហ្មណ៍ដ៏ងឡាយដែលស្រែងក្នុងជាតិនោះ គឺមានមាន:ប្រកាន់ខ្លួនថា យើងជាព្រាហ្មណ៍កើតអំពីជាតិនៃព្រាហ្មណ៍មហាសាល។

ព្រាហ្មណ៍ដែលប្រកាន់គោត្រនោះ គឺប្រកាន់ខ្លួនថា អាត្មាជាព្រាហ្មណ៍កើតអំពីកស្សបគោត្រជាដើម ។

ឈ្មួញនឹងអ្នកត្រួតដ៏ងឡាយនោះ មានមាន:ព្រោះអាស្រ័យនូវជាតិនឹងគោត្រនៃខ្លួន។ ដូចគ្នា ។

មាន:អាស្រ័យនូវជាតិទើបកើតមានឡើង ឈ្មោះថា ជាតិមទោ ស្រែងព្រោះជាតិ ។ មាន:អាស្រ័យនូវគោត្រទើបកើតមានឡើង ឈ្មោះថា គោត្តមទោ ស្រែងព្រោះគោត្រ ។

សេចក្តីស្រែងក្នុងភាពគ្មានរោគនោះ គឺកើតមាន:ប្រកាន់ខ្លួនថា អហំ អរោគោ អាត្មានេះជាអ្នកឥតរោគ កល្យាណធម្មត្តំបិ

សូម្បីមាត្រាថាព្យាធិ គឺបួសកើតឡើងដល់អាត្មាកំគ្មាន ជនចាំងឡាយដទៃ
ក្រៅអាត្មា សុទ្ធតែជាអ្នកមានរោគច្រើន ។

សេចក្តីស្រេវឹងកង្វល់នោះ គឺមានមានៈថា អាត្មានៅក្មេង ជន
ឯទៀតច្រើនតែជាអ្នកចាស់ជរា ឯអាត្មាអញសូម្បីចាស់ជរាក៏មែនហើយ
ប៉ុន្តែសក់នៅខ្មៅមិនទាន់ស្កូវមួយសរសៃទេ ធ្មេញមិនទាន់ចាក់មួយ សាច់
នឹងស្បែកមិនទាន់ស្វិតជ្រួញជ្រីវ ភ្នែកមិនទាន់ងងឹត ត្រចៀកមិនទាន់
ថ្លង់ជាដើម ។

ការស្រេវឹងថាខ្លួនគ្មានរោគ នឹងស្រេវឹងកង្វល់នោះ ចាំងពីប្រការនេះកើត
មានឡើង ព្រោះតែបុគ្គលមិនបានពិចារណាឲ្យឃើញច្បាស់ដោយបញ្ញា
របស់ខ្លួន ។ អ្នកមានច្រើនជាគប្បីចូលចិត្តថាជម្មតាមនុស្សឬសត្វមិនដែល
គ្មានរោគទេ សុទ្ធតែមានរោគនៅប្រចាំខ្លួនគ្រប់គ្នាជានិច្ច ប្លែកគ្នាតែអ្នក
ខ្លះមានរោគតិច អ្នកខ្លះមានរោគច្រើនប៉ុណ្ណោះ ហើយរោគនោះខុសគ្នា
ទៀត មិនសូវដូចគ្នាទេ ។ ប៉ុន្តែមានរោគមួយដ៏ធំដូចគ្នា គ្រប់រូបមនុស្ស
សត្វ គឺរោគស្រេកឃ្លានឆន់រោគឃ្លានបាយ ដែលជារោគធំបំផុតប្រចាំជីវិត
ព្រោះថាមនុស្សគ្រប់រូបយកចិត្តទុកដាក់ខំថែរក្សា មើលរោគស្រេកនឹងរោគ
ឃ្លាននេះជានិច្ច សូម្បីបានផឹកទឹកនឹងបរិភោគបាយមួយពេលឆ្អែតហើយ
ក៏នៅតែមិនសះជារោគនេះ ព្រោះថាកន្លងពេលពីនោះបន្តិចទៅ ក៏កើត
រោគស្រេកឃ្លានទៀត ពាល់ថ្ងៃខែហួតទៅដល់ស្លាប់ ។

ចំណែកការស្រែរឹងកន្លះយែនោះ ក៏តម្រូវឲ្យដាំតាមរដូវណាឲ្យបានល្អហើយ តំបាត់ស្រែរឹងចេញបានណាស់ ។ អ្នកមានច្រើនតែគប្បីចូលចិត្តចុះថា បើខ្ញុំជាខ្ញុំនឹងនៅក្មេង ក៏ឈ្មោះថាច្រើនជាងយ ព្រោះជាកូនចូលមកគ្រប់សង្កត់ជាងចិត្ត តើថាមានជាកាលំបាកដែរ ឯជីវិតចេះតែចិតចូលទៅដិតសេចក្តីស្លាប់កាលំបាកថ្ងៃខ្លាំង ។ ហើយកាលំបាកថ្ងៃខែដែលខ្ញុំនៅរួចមកហើយ ឃើញថាចេះតែចំរើនច្រើន ។ ឡើង ឯថ្ងៃខ្លាំងមុខចេះតែថយតិចៗទៅ ហេតុនោះ បានជាលោកច្រើនប់ថា បុគ្គលកើតមកកន្លះលោកនេះមិនបានស្ថិតនៅឲ្យខ្លាំងតាត់កន្លះយែណាមួយទេ តើដំបូងជាជម្រមយែ ហើយលឿនទៅដល់មជ្ឈិមយែជាថ្នាក់កណ្តាលរហូតដល់ថ្នាក់បំផុតជាចច្ចិមយែ ។

បុគ្គលអ្នកស្រែរឹងកន្លះយែនោះ សូម្បីដឹងថាខ្ញុំនឹងមានសក់ស្កូវ ធ្វេញបាក់ ក្អែកឆ្កឹតឆឹត សាច់ស្បែកជ្រួញជ្រីវហើយ ក៏នៅតែគិតថាខ្ញុំនៅក្មេង មិនយល់ព្រមថាខ្ញុំចាស់ជាកទេ បើគេហៅតាយាយក៏អាក់អន់ចិត្ត បើគេហៅប្អូនប្តូចឆឹកសប្បាយរីករាយចិត្ត ដូច្នេះចាត់ថាអ្នកស្រែរឹងកន្លះយែ ។

ឧបន្ទោ មាណោ មានន័យប្រកាន់ខ្ញុំនកើតឡើងដោយអំណាចនៃចិត្តគិតថា អហំ ចិរំ ជីវិ ជិកាមិ អញមានជីវិតរស់នៅឥឡូវនេះហើយនឹងមានជីវិតរស់នៅតទៅមុខទៀតបានយូរក្តី អញតែងបានសុខឥតទុក្ខព្រួយ អញមានជីវិតដ៏មាំមួនចិតវេរ អ្នកឯទៀតមានជីវិតមិនមាំមួនទេ មានជីវិតមិនបានសុខដូចអញឡើយ មានន័យដ៏នេះឈ្មោះថា ស្រែរឹងកន្លះជីវិត ។

ការស្រវឹងក្នុងលាភនោះ គឺប្រកាន់ថាខ្លួនជាអ្នកមានលាភច្រើន ជាអ្នករកលាភបានងាយ ។ ឯអ្នកដទៃសូម្បីមានលាភក៏មែនហើយ ប៉ុន្តែមិនស្មើនឹងអញទេ ។ ចំណែកបណ្តិតជនវិញ មិនស្រវឹងក្នុងលាភយ៉ាងនេះទេ លោកសំគាល់ថាអាត្មាអញបានលាភច្រើនដូច្នេះ មកពីហេតុដែលអញបានធ្វើកុងការកុសលពុក ទើបលោកទុស្សាហ៍បរិចាគទាន ។

ការស្រវឹងក្នុងបរិវារនោះ គឺប្រកាន់ថាអាត្មាអញនេះមានបរិវារច្រើនពាន់រយពាន់តាន់នាក់ តែអ្នកណាមានបរិវារច្រើនស្មើនឹងអញទេ លុះស្រវឹងយ៉ាងនេះហើយ ក៏តាំងអហង្ការមមង្ការ គឺប្រកាន់ថាមានតែអញជាអ្នកប្រសើរវិសេសជាងគេ ចំណែកអ្នកប្រជុំវិញ ប៉ើពុកជាមានបរិវារច្រើនដល់ប៉ុន្មាន ក៏លោកមិនស្រវឹងដូច្នេះដែរ ។

ការស្រវឹងក្នុងសម្បត្តិនោះ គឺស្រវឹងដោយអំណាចនៃតំនិតគិតឃើញថា អាត្មាអញមានគ្រឿងឧបភោគបរិភោគជាច្រើន ទំនឹងមានកាមគុណតាំងប្រាំ ជាទីប្រសោមលួងលោមចិត្តក៏ច្រើន ស្រស់ស្រីឆ្អែតឆ្អន់ដែរ តែអ្វីៗក៏មានគ្រប់ម្បុខតន្ត្រី ឃើញដូច្នេះហើយមិនបានធ្វើការកុសលណាមួយទេ ថែរដាតាំងខ្លួនក្នុងអហង្ការមមង្ការសំគាល់ថា អាត្មាអញជាអ្នកមានសម្បត្តិច្រើនជាងគេ តែអ្នកណាមានស្មើគេវិញ ។ ចំណែកបណ្តិតវិញ ប៉ើពុកជាមានសម្បត្តិច្រើនដល់ប៉ុន្មាន ក៏លោកមិនស្រវឹងយ៉ាងនេះដែរ លោកតែងចែងចែកគ្រប់គ្រងជាប្រយោជន៍ចំណែក តែមួយចំណែកពុក

ចំណាយក្នុងគ្រាមានគ្រោះថ្នាក់អាសន្នអន្តរាយ ពីរចំណែកសម្រាប់ប្រកបកិច្ចការចិញ្ចឹមដំណែមានពាណិជ្ជកម្មជាដើម ទំនិចិញ្ចឹមគ្រួសារខ្លួន មួយចំណែកទៀតសម្រាប់ធ្វើបុណ្យ បណ្តុំតលោកបែងចែកទ្រព្យជាបួនចំណែកយ៉ាងនេះ ។

ការស្រែរឹងក្នុងសរីរៈពាណិសណ្ឋាននោះ គឺសំគាល់ថា អកិរ្យចោចាសាធិតោ អាត្មាអញមានរូបពងក្រាយពាណិសម្បុរខ្មៅត្រាយល្អឆើតឆាយសមរម្យទាំងអស់មានចិត្តជ្រះថ្លាស្រឡាញ់ អ្នកដទៃសូម្បីមានរូបពងល្អ កំមិនស្មើនឹងអញ គ្មានគេសរសើរដូចអញដែរ ។

ការស្រែរឹងក្នុងភាពជាពហុសូត្រនោះ គឺស្រែរឹងដោយគំនិតគិតឃើញថា អាត្មាអញជាអ្នកបានរៀនច្រើន ចាំទន់ស្តាប់ច្រើន គ្មានអ្នកណាចេះដឹងស្មើនឹងអញទេ ។ ការស្រែរឹងនេះមានពីប្រការ គឺស្រែរឹងថាខ្លួនជាអ្នកចេះដឹងច្រើនជាងគេ ១ ស្រែរឹងថាមិត្រសម្លាញ់ឬ បក្សពួករបស់ខ្លួនជាអ្នកចេះដឹងច្រើនជាងគេ ១ ។

ការស្រែរឹងក្នុងបដិភាណនោះ គឺសំគាល់ថា អាត្មាអញជាអ្នកមានបញ្ញាឈ្លាសវៃ ចុំនប្រសប់ក្នុងការបុច្ឆានឹងវិសជ្ជនាយ៉ាងស្ទាត់ គ្មានអ្នកណាឈ្លាសវៃចុំនប្រសប់ចោទធ្វើយស្មើនឹងអញទេ ។

ការស្រែរឹងក្នុងសិល្បសាស្ត្រវិជ្ជាការនោះ គឺសំគាល់ថា អាត្មាអញមានវិជ្ជាការប្រសើរជាងអ្នកដទៃ គ្មានអ្នកណាស្មើនឹងអញឡើយ ។

មានដែលកើតមានឡើងដោយអំណាចនៃសេចក្តីស្រែរឹងនោះ បើ

រោលដោយប្រកែមានច្រើនយ៉ាងណាស់ ប៉ុន្តែនាំមកសំដែងក្នុងទីនេះ ដោយសង្ខេបប៉ុណ្ណោះ ។ អ្នកមានបញ្ញាគប្បីជ្រាបចុះថា មានន័យនោះជាន ន័យការប្រកាន់ផ្សេង ។ ដែលន័យឲ្យមានពាសក្នុងជាតិនេះឬជាតិមុន។ ភួ-យ៉ាងដូចសុបុប្ផាពុទ្ធសាក្យវង្ស ជាព្រះបរមញាតិរបស់សម្តេចព្រះពុទ្ធអង្គ ជាព្រះបិតានៃព្រះនាងពិម្ពាទេវីនៃព្រះពោធិសត្ត ជាព្រះបរមរាជវង្សរបស់សម្តេច ព្រះទាន់សិរីមហាមាយា រាប់បួលក្នុងវង្សនៃសាក្យវង្សប្រកបដោយព្រះ ជ័យរីឯរូបមានមានះ ទើបបានចង់អាឃាតព្យាបាទក្នុងសម្តេចព្រះបរម. សាស្តាដោយហេតុពីរប្រការ គឺលះបង់ចោលនូវព្រះនាងពិម្ពាទៅបព្វជ្ជា១ ន័ងតាំងនៅក្នុងទីជាពៀរនៃព្រះពោធិសត្ត ១ លុះបង់ពៀរដូច្នេះហើយ ទើប ភ័ន្តវ៉ែនាគបរិណ្ណាបាតនៃសម្តេចព្រះបរមគ្រែលោកនាថ ពាល់តែបាន សោយផលនៃកម្មជាទិដ្ឋធម្មវេទនីយ៍ គឺមហាប្រឹបព័ស្រួបចុះទៅកើតក្នុង មហានរកឯនេះ អាស្រ័យហេតុដែលប្រកបដោយមានានុស័យ ។

បុគ្គលដែលប្រកបដោយទិដ្ឋានុស័យ វិចិកិច្ឆានុស័យ សីលព្តានុ-ស័យ ន័ងអវិជ្ជានុស័យ កំជាហេតុន័ងឲ្យដល់នូវសេចក្តីវិនាសក្នុងជាតិ នេះន័ងជាតិមុនដូចគ្នា ។ ហេតុនោះ បានជាសម្តេចព្រះបរមសាស្តាទ្រង់ ត្រាស់ទេសនា អនុស័យប្រាំពីរប្រការបញ្ចូលក្នុងយមកបករណ៍ដោយ ប្រការដូច្នេះ ។

អនុសយយមកៈ ចប់ប៉ុណ្ណោះ

(នៅមានត)

សម្តែងព្រះធម្មលិខិត ល្ងី-ឯម ប្រែរៀបរៀង

(តមក)

ខ្ញុំបួតចាកស្ថានខេរ៉ៃលោកនាយដោយកុសលមួលជាស់ខ្លឿន ក៏ចានមកកើតក្នុងត្រកូលព្រាហ្មណ៍ដ៏ស្តុកស្តម្ភម៉ាមួនឮដ៏ក្រុងកជគ្រែះ ហើយចានលះបង់នូវកាមគុណ ចាំង៥ ជាស្រឡះចូលមកបួសក្នុងព្រះពុទ្ធសាសនា ខ្ញុំមានអាយុ ៧ ឆ្នាំកប់ពីឆ្នាំកំណើត ចានសំរេចអរហត្តកំចាត់បង់នូវកិ-លេសចាំងអស់ ជាអគ្គព្រះខីណាស្រពមួយដែរ ។

ឧបសម្បាទយិ ពុទ្ធោ កុណាមញ្ញាយ ចក្ខុមា
តរុណោ បូជនិយោហំ ពុទ្ធបូជាយិទំ ផលំ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានចក្ខុញាណ ចានតំចារណាប្រាប ប្បាស់នូវគុណវិសេសរបស់ខ្ញុំហើយ ទ្រង់ចានអនុញ្ញាតឲ្យចបសម្រ័ទជា តិកូតាវះក្នុងព្រះពុទ្ធសាសនា ឯខ្លួនខ្ញុំជាកុលបុត្តមានវ័យទៅក្មេងក៏ពិត មែន តែថាជាបុគ្គលគួរគេបូជា ចានជាព្រះអគ្គទ្រង់កប់អាន នេះជាផល ដែលខ្ញុំចានធ្វើពុទ្ធបូជាដោយពិត ។

ឯកូចក្ខុវិសុទ្ធិ មេ សមាធិ កុសលោ អហំ
អកិញ្ចាចារមិប្បត្តោ ពុទ្ធបូជាយិទំ ផលំ ។

ឯកូចក្ខុរបស់ខ្ញុំ ស្អាតប្រពៃហើយ ខ្ញុំជាបុគ្គលឆ្លាសក្នុងសមាធិចាំង

ចានដល់នូវត្រើយនៃអភិញ្ញាចាំង ៦ផង នេះជាផលដែលខ្ញុំចានធ្វើពុទ្ធបូជា
ដោយពិត ។

បដិសម្ភិទាឧប្បត្តោ ឥទ្ធិចាឧេសុ តោវិទោ
សទ្ធម្មេចាវមិប្បត្តោ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំចានដល់នូវបដិសម្ភិទាចាំងបួន មានធម្មប្បដិសម្ភិទាជាដើម ហើយ
ជាបុគ្គលឆ្លាសាច់ងវៃកន្ត ឥទ្ធិចាំងឡាយបួនផង ចាំងចានដល់នូវតាចេះ
ចប់ព្រះសទ្ធម្មថែមទៀត នេះជាផលដែលខ្ញុំចានធ្វើពុទ្ធបូជាដោយពិត ។

តីសុកប្បសហស្សម្ហិ សម្ពុទ្ធមកិបូជយឺ
ទុគតឺ ជាកិជាជាមិ ពុទ្ធបូជាយិទំ ផលំ ។

ខ្ញុំចានបូជាហើយចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ នូវផ្កាកណ្ដិការ
ខ្ញុំពុំដែលស្គាល់នូវទុគតិភពដល់ម្ដងឡើយ កន្លះវាងបីម៉ឺនកប្ប នេះជាផល
ដែលខ្ញុំចានធ្វើពុទ្ធបូជាដោយពិត ។

កកិលេសា ឈាបិតា មយ្ហំ កាសត្ថេសម្ភវាតា
ជាគោវ ឥទ្ធិំ ឆេត្វា វិហាភមិ អជាសវោ
ស្វាភតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិសេ្សា វិជ្ជា អនុប្បត្តោ កតំ ពុទ្ធស្ស សាសនំ ។

ខ្ញុំចានដុតកំទេចនូវកិលេសចាំងឡាយអស់ហើយ កតតូចធំចាំងអស់
ខ្ញុំក៏ចានដឹកតាស់រម៉ើងចេញស្រេចហើយ ចានកាត់ចំណងដែលជាគ្រឿង

ចង់កន់តតអស់ហើយ ជាអ្នកមិនមានអាសវៈមិនឡើយ គួរនាដូចជាដំរីដ៏ប្រសើរ ដែលបានកាត់ខ្នើចង់ដើងហើយចូលទៅទៅកន់ព្រៃតតក័យដូច្នោះឯង ខ្ញុំមានដំណើរទៅកាន់ព្រះវិញ្ញានល្អហើយ វិជ្ជាចាំង់ឡាយបីក៏ខ្ញុំបានសំរេចហើយ កន់សំណាក់នៃព្រះសម្ពុទ្ធ ជាឫស្ថកន់លោកសាសនារបស់ព្រះភុទ្ធជាម្ចាស់សោត ក៏ខ្ញុំបានធ្វើឲ្យសម្រេចហើយដែរ ។

បដិសម្ភិទា ចតុស្សេ្ត វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំពុទ្ធុស្ស សាសនំ ។

ម៉្យាង់ទៀត បព្វជិតគុណចាំង់ឡាយគឺបដិសម្ភិទាបួន វិមោក្ខប្រាំបីនឹងអភិញ្ញាចាំង់ឡាយប្រាំមួយ ក៏ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ សាសនាដែលប្រកបដោយអង្គចាំង់ប្រាំបួន ក៏ខ្ញុំបានធ្វើសម្រេចហើយដែរ ។

លុះទត្តរសោមណោរ បានសម្តែង់ព្រះគាថាចាំង់អស់នេះចប់ហើយ ពួកជនជាច្រើនដែលបានស្តាប់នូវព្រះគាថាចាំង់នោះហើយ កំមានសេចក្តីសោមនស្សជ្រះថ្លា តែង់ចំណាយទ្រព្យសម្បត្តិចាត់ធ្វើពុទ្ធបូជាបំពេញកុសលកម្ម ឲ្យប្រព្រឹត្តទៅខាង់មុខតុំជាច់ឡើយ ។

ព្រោះហេតុដូច្នោះបានជាព្រះអរហន្តចាំង់ឡាយលោកគោលជាបទព្រះគាថាដូចនេះថា

សហេតុកា បច្ឆិមកា បិ សត្តា ចាបិ ន សន្តាន្តិ ឥហាតុមេវំ អនិច្ចមានេហិ ជនេហិ ទុក្ករំ អាភវ ចាបិ

បរិវជ្ជនិយំ ។

អធិប្បាយថា៖ សត្វតាំងឡាយដែលកើតក្នុងបច្ចុប្បន្នកាលមកកាន់ប្រទេសនេះ ដោយប្រការដូចម្តេច ដោយហេតុដូច្នេះ ព្រះអរហន្តក្តី កំពង់តុំអាចនឹងលះបង់នូវបាបកម្មបាន ដូចយ៉ាងនេះឯង ជនតាំងឡាយអ្នកមិនប្រាថ្នានូវសេចក្តីសុខក្នុងលំបាក ត្រូវតែរៀវលែងបាបកម្មចេញឲ្យឆ្ងាយចាកសន្តាន មិនត្រូវធ្វើឲ្យកើតមានក្នុងសន្តានឡើយ ។

សម្តែងរឿងនិទានទុតិយសាមណេរជាគំរប់ប្លុងក្នុងវគ្គទី៧ កំចប់សេចក្តីជាសង្ខេបតែប៉ុណ្ណេះឯង ។

៥- កាបិរបដ្ឋិនវត្ថុកថា

សំដែងរឿងនិទានជនអ្នកនៅក្នុងកំពង់ឈ្មោះកាបិរៈតទៅទៀតដោយវាវចាល័ថា ឥមិនាបិ បេ បេច្ចយេរដ្ឋេ កាបិរបដ្ឋនំ នាម អហោសិ ដូច្នេះជាដើម អធិប្បាយជាសេចក្តីថា មានកំពង់មួយឈ្មោះកាបិរៈក្នុងវដនឈ្មោះបេច្ចយៈក្នុងជម្ពូទ្វីបនេះឯង ។

មនុស្សតាំងឡាយ អ្នកនៅអាស្រ័យនាកំពង់នោះសុទ្ធតែជាមិច្ឆាទិដ្ឋិ អ្នកពាប់អានបូជាព្រះសង្ឃ ដែលយើងថ្លាប់ហៅនាបច្ចុប្បន្នថាអ្នកតាសម្រាប់តែរាវប្រតិបត្តិជាក្រម្រតី ។

ភ្លាមមនុស្សដែលជាមិច្ឆាទិដ្ឋិតាំងអស្លាសនោះ កំពាត់ចែងគ្នូរប្រគំនូរជាអ្នកតាលើឆែនភ្នាមួយស្ងាត់ ដំកល់ក្នុងកន្លែងអ្នកតានោះ ហើយចាប់

គួរបូជាដោយព្រះមានព្រះភាគ ដោយអាការហាក់ដូចជាខ្ញុំបុះក្រាបថ្វាយបង្គំរូបអ្នកតានោះឯង ។

ឯជនទាំងឡាយជាឧបាសក ឧបាសិកាទៅនាក់ពីរនាក់ចាប់ផ្តើមនោះ បានចូលទៅកាន់ពេងអ្នកតា បានតយុគន់មើលរូបគំនូរផ្សេង ។ ក្នុងទីនោះ ។ ក៏បានឃើញរូបបដិមាដំណាងអង្គព្រះសម្មាសម្ពុទ្ធ ដែលពួកជនជាមិច្ឆាទិដ្ឋិតាត់ជាងឲ្យគួរបន្ទុះបង្អាប់ដូច្នោះ ។

ទើបពួកជនជាឧបាសកឧបាសិកាទាំងនោះ កើតចេមសទ្ធាចិត្តដោយការនឹកដល់ព្រះគុណច្រើនអនេកប្បការ កើតខឹងផ្ទុះផ្ទីះឡើកឡួលថា ‘‘នែយើងទាំងឡាយបានឃើញនូវរូបដែលមិនគួរគប្បីឃើញ ដែលពួកគេធ្វើបង្អាប់យ៉ាងនេះសោះ ’’ ដោយយើងយល់ឃ្លាស់ថា ក្នុងលោកត្រមាំងខ្លះលោកមារលោក ព្រហ្មលោកត្រមាំងសមណខាងព្រាហ្មណ៍ ក្នុងពួកសត្វត្រមាំងមនុស្សជាសម្មតិទេពខាងមនុស្សជាប្រក្រតី ក្នុងផែនក្រាស់ដែលពប់ប្រមាណមិនបាន បើរៀវលែងតែព្រះមានព្រះភាគជាម្ចាស់ទេញ៉ាហើយ ពុំមានបុគ្គលណាមួយពីសេសលើសលប់ឬត្រឹមស្មើដោយព្រះមានព្រះភាគឡើយ ។

ឯព្រះមានព្រះភាគព្រះអង្គជាបុគ្គលគួរពួកសត្វទាំងអស់ បូជាមនស្សការថ្វាយបង្គំដោយពិត ឯរូបគំនូរដែលពួកមិច្ឆាទិដ្ឋិឲ្យគួរនេះ មិនសំគួរដល់កិត្តិយសរបស់ព្រះសម្មាសម្ពុទ្ធឡើយ ។ លុះពួកមនុស្សជាសម្មាទិដ្ឋិ

ចាន់រតីដ៏គិតយ៉ាងនេះហើយ កំអត់ត្រាំពុំចាន់គ្នាស្រែកទ្រហោខ្លួញយំ
បំរះនទៀលតែកល់ ។ គ្នា ទើបលីលាត្រេចទៅកាន់ទ្វារព្រះបរមកដកំង
ហើយស្រែកឲ្យលាន់ឮសំឡេងគឹកកងខ្ទើងកងកាលនោះឯង ។

ព្រោះនោះហេតុ ចាន់ជាព្រះគន្ធបនាចារ្យ លោកពោលនូវបទ
ព្រះគាថាក្នុងអបទានដូច្នេះថា:

ទ្វត្តិំសលក្ខណធរោ សុក្កបក្ខេវ ចន្ទិមា
អនុព្យញ្ជនសម្បន្នោ សាលរាជាវ ផល្លិតោ ។

អធិប្បាយថា: ព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គទ្រទ្រង់នូវមហាបុ-
រិសលក្ខណៈ ៣២ ដ៏ប្រសើរបរិបូណ៌ ដោយអនុព្យញ្ជនចាំងរំលេចសិរ
តត់ដ៏ភ្លឺស្វាងរុងរឿងដូចជាព្រះចន្ទ្រះខ្នើងក្នុងសុក្កបក្ខ ចំណែកខាងខ្នើត
នាថ្ងៃ១៤ ពុំនោះសោត ប៉ាដូចជាដើមសាលព្រឹក្សជាឈើប្រចាំទ្វីប ដែល
មានផ្ការីកស្គុសស្គាយ មានពន្លឺភ្លឺស្វាងរុងរឿងផ្សាយទៅកាន់ទិសានុទិស។

វិសីជាលបរិក្ខិត្តោ ឯត្ថោ កាឧកាកសោ
ព្យាមប្បភាបរិក្ខិត្តោ សកវិសីឯកកោ

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់មានបណ្តាញរស្មីព័ទ្ធព័ន្ធជុំវិញ ដ៏
ភ្លឺច្រាលខ្ចាលប៉ាដូចជាភ្នើងឆេះព្រៃ ទ្រង់មានឆព្ណារង្សីប្រមាណមួយ
ព្យាយាមព័ទ្ធព័ន្ធជុំវិញដ៏ភ្លឺស្វាងរុងរឿងប៉ាដូចជាព្រះអាទិត្យមានរស្មីដ៏ច្រើន
រះឡើងនាកណ្តាលអាកាស ។

សោណ្ណាជាសោ ជិនវរោ សមណោ សិលុច្ចយោ
ករុណាបុណ្ណាហទយោ វីរវន្ទោ វិយ សាគរោ
លោកាវសុតកិត្តី ច សិនេរុវនគុត្តមោ
យសសាវត្តោ ជិនោ អាកាសសទិសោមុនិ

ព្រះជិនស្រីដ៏ប្រសើរ ទ្រង់មានព្រះឧស្ណីសច្រឹមប្រិយដូចផ្ទៃភ្នក់មាស ទ្រង់មានព្រះកត្រុំចំរើនស្មើដូចកែវមណី ទ្រង់មានដួងហឫទ័យត្រជាក់ពោរពេញដោយសេចក្តីករុណា ប៉ាដូចជាសមុទ្រសាគរដ៏ត្រជាក់ ជាគ្រឿងបណ្តុះបណ្តាលឲ្យកើតកែវពាំងពួង ព្រះអង្គជាវីរបុរសដ៏ឆ្នើមខ្ពង់ខ្ពស់បំផុត ប៉ាដូចភ្នំសិនេរុ ជំនួសជាងភ្នំទាំងឡាយក្នុងលោក ព្រះអង្គទ្រទ្រង់នូវទំហំយសបារាំរដ៏ធំ ទ្រង់ជាវរមុនី មានព្រះបញ្ញាញាណដ៏ទូលំទូលាយ ដូចផ្ទៃអាកាស ។

អសង្ខ្យេចត្តោ សព្ពត្ថ អនិល្លោ ឧជាយកោ
បតិដ្ឋោ សព្ពភូតានំ មហាវ បុរិសុត្តមោ
អនុបលិត្តោ លោកេន តោយេន បទុមំយថា ។

ព្រះមានព្រះភាគ លោកនាយកទ្រង់ឥតមានមន្ទិលកំលែស ព្រះអង្គមានព្រះទ័យពុំបានជាប់ជំពាក់នៅក្នុងគារម្មណ៍ពាំងពួង ប៉ាដូចជាឈើបក់ជាត់ទៅឥតមានចូលី ព្រះអង្គជាបុរសដ៏ឧត្តមជាទីពឹងនៃសត្វពាំងឡាយពាំងពួង ប៉ាដូចជាផែនដីធំជាទីប្រតិស្ឋាននៃពួកសត្វទឹងសម្ភារៈពាំងឡាយ

ព្រះអង្គមានព្រះមនោគតិ ពុំបានដឹងជាប់ក្នុងលោកធម៌ ដូចជាស្ងួតឈួត ដែលពុំបានដឹងជាប់ ដោយទឹកក្រឿងដូច្នោះ ។

កុកនកដ្ឋនហាសោ អក្ខិនាសោ សោកតិ
អក្ខនាវិយ សព្វត្ថ កិលេសវិនាសនោ ។

ព្រះមានព្រះភាគ ទ្រង់ជុតបំផ្លាញនូវពាក្យពោលតិះដៀលដ៏អាក្រក់ របស់ជនដទៃ ដូចជាជុតទុស ទ្រង់មានព្រះសរីរាវយវៈដ៏ល្អ ដូចគំនរភ្នើង ទ្រង់ញាំញីកិលេសឲ្យវិនាសសព្វ។ កាលដូចជាថ្នាំទុសថសម្រាប់រម្ងាប់ភេតទាំងពួងដូច្នោះ ។

កន្ទមានន្តសេលោវ កុណាកន្ទវិកូសិតោ
កុណាធំ អាតាកោធំកេ វតនាធំ វ សាកកេ ។

ព្រះមានព្រះភាគទ្រង់ប្រដាប់ស្អិតស្អាង ដោយគ្រឿងក្រអូបគឺគុណ ដូចជាភ្នំគន្ធមាទន៍ ព្រះអង្គជាអ្នកប្រាជ្ញទ្រទ្រង់នូវធម៌ ជាអណ្តូងទឹកសំរាប់បន្លឺរចេញនូវគុណទាំងឡាយ ដូចជាសមុទ្រសាគរជាទីកើតនៃកែវទាំងឡាយ ។

លុះភិក្ខុមនុស្សជាសម្ងាំដឹងច្បាស់នូវគុណយ៉ាងនេះជាដើមហើយ ក្រាបបង្គំទូលព្រះបរមគ្រូត្រង់ដូច្នេះថា នេវ: បពិត្រព្រះសម្មាសម្ពុទ្ធ ព្រះភ្នែនរូបដែលជនមិច្ឆាទិដ្ឋិធ្លើយយ៉ាងនេះកុំគួរសោះឡើយ សូមព្រះអង្គទ្រង់ជ្រាប ។

ឯព្រះបរមគ្រូត្រៃយ៍ ស្តេចទ្រង់ព្រះសណ្តាប់ពាក្យនោះហើយក៏ត្រាស់ថា ម្នាលអ្នកដ៏ចំរើន មនុស្សទាំងអស់នេះគេតែងពោលសរសើរខ្លួនអាទុកាតនៃអ្នកតាបសខ្លួនដែរ ថាជាធំប្រសើរពិសេសផ្សេង ។ ចំណែកខាងអ្នកទាំងឡាយ តើអាចញ៉ាំងយើងឲ្យដឹងនូវអាទុកាតនៃព្រះសាស្តាចារ្យរបស់អ្នកទាំងឡាយថា ជាធំប្រសើរពិសេសផ្សេង ។ ឬទេ ? ។

លើបទ ឮសេចក្តីទាំងឡាយក្រាបបង្គំទូលថា បពិត្រមហាភ័ក្ត្រ ការណ៍នេះមិនក្រអូសោះឡើយ សូមព្រះអង្គចាត់សេវកាមាត្យទាំងឡាយឲ្យលើកឡើងនូវរូបអ្នកតានីមួយបដិមានៃព្រះមានព្រះភាគរបស់យើងឡើងកាន់បល្ល័ង្ក ហើយរុំបិទបាំងដោយសំពត់សសុទ្ធស្រេច ប្រថាប់ត្រាមុទ្រាព្រះហស្តលើសំពត់នោះផ្តាំលព្រះអង្គ ហើយបញ្ជាមនុស្សឲ្យកាន់ទុកដោយប្រពៃក្នុងកន្លែងអ្នកតាជាមួយគ្នា លុះដល់កន្លងទៅបាន ៧ ថ្ងៃហើយ សូមព្រះអង្គចាត់មនុស្សអ្នកគ្រប់គ្រងឲ្យនាំមកថ្វាយ សូមព្រះអង្គឧត្តរមិលមើលនូវរូបភាពទាំងនោះ ព្រះអង្គនឹងអាចជ្រាបបាននូវអាទុកាតនៃព្រះសាស្តាចារ្យជាម្ចាស់នៃខ្ញុំព្រះអង្គទាំងឡាយថា ជាធំប្រសើរពិសេសផ្សេង ។ កន្លងកាលនោះឯង ។

កាលនោះ ព្រះបរមគ្រូត្រៃយ៍ ទ្រង់ចាត់សេវកាមាត្យឲ្យតាក់តែងធ្វើតាមពាក្យពោលរបស់ពួកសកទាំងឡាយនោះឯង ហើយទ្រង់ត្រាស់បង្គាប់ឲ្យដាក់នូវទុកក្នុងកន្លែងនៃអ្នកតានោះដូចនេះថា អ្នកទាំង

ឡាយត្រូវបំពេញព្រះពាំងអស់ ហើយបោះត្រាចាត់សោរក្សាទុកឲ្យមាំមួនកំ-
ណត់ ៧ ថ្ងៃកុំប្រហែសធ្វេសឡើយ ។

ឯសេវកាមាត្យ កំបានធ្វើតាមព្រះរាជបញ្ជាព្រះមហាក្សត្រនោះ
ហោង ។ លំដាប់តពីនោះមក ពួកទេវាសកពាំងអស់នោះ បានប្រជុំគ្នា
ចាត់ចែងឲ្យមាន រក្សាសីលប្រុំ រក្សាឧបោសថសីល ចំរើនខ្លួរមេត្តាចិត្ត
ផ្សាយទូលៅកន្លងសត្វពាំងឡាយពាំងពួនគ្រប់ ៧ ថ្ងៃ ហើយទុំដុសចំណែក
ឫណ្យជូនទៅ ព្រមពាំងបានធ្វើកិរិយាបូជាចំពោះព្រះរតនត្រ័យគ្រប់ទិវា
ពត្រី ហើយបញ្ចេញសំឡេងសច្ចវាចាបួនសួនឲ្យលាន់ឮគឹកកងឡើងថា:
« ដោយតេជៈអានិសង្ស ជាគ្រឿងហូរមកពុំដាច់នៃកុសលពាសីដែល
យើងពាំងឡាយបានធ្វើមកហើយ សូមទេវតាពាំងឡាយពាំងពួន ដែល
មានរិទ្ធិអានុភាពធំក្នុងលោកនេះក្តី ស្តេចចតុលោកបាលបួនព្រះអង្គ
ដែលរក្សាមនុស្សលោកក្តី សូមអញ្ជើញមកសម្តែងខ្លួរសេវាតសក្តិសំខ្ចី
ជាក់ស្តែងគួរជាទីអស្ចារ្យដល់យើងពាំងឡាយ ក្នុងកាលឥឡូវនេះឯង» ។
ដោយបុញ្ញានុភាពរបស់ទេវាសកពាំងនោះ បណ្តាកម្ពលសិលាសនៈរបស់
សម្តេចព្រះអម្រិន្ទ្រាធិរាជជាស្តេចនៃទេវតា ក៏សម្តែងខ្លួរអាការក្តៅក្រ-
ហាយដូចជាគំនរភ្លើងជាទីអស្ចារ្យក្នុងខណៈនោះឯង ។

(នៅមានត)

លោក អ៊ឹម-កង បម្លែងពីសាស្ត្រាសុីកវីត

ព្រះពុទ្ធវង្ស កឹម-ភ្ងារ ពិនិត្យ

(តមក)

ប៉ុន្តែ-អាមាត្យនៃពោធិសត្វ ក៏យល់ស្តេចចាំងឡាយតែងៗដូច្នោះ ហើយ ក៏ធ្វើបញ្ជូនខ្លួនស័ព្ទនោះច្រើនថា ឥឡូវនេះ ស្តេចបុលនី ធនស្តេចមួយយោធនីមួយតែងៗវិញហើយ ។ ម្ល៉ោះហើយស្តេចចាំងឡាយ ឮស័ព្ទមហាជនផងចាំងឡាយកិតភ្ញាចភ័យ នាធនីស្ងាប់នោះច្រើនមួយ សា កំតែងៗចំលាយសេនាយោធាចាំងឡាយ តែងៗដោយទិសនាយ ទិសនាយ ប្រញាយទីនៃខ្លួន ឥតបីមានឈប់ឈរឡើយ ។ សូម្បីតែបុ-រសអាមាត្យនៃពោធិសត្វឯង ក៏កំស្រែកហៅធ្វើខ្លួនស័ព្ទបន្ទឹងរោលកោល-ហាលរំលៀងច្រើនហោង ។ ពោធិសត្វអ្នកលបក្រឡាប់ចូលទៅក្នុងព្រះនគរ ធនីងអស់សេនាយោធាចាំងឡាយជាបរិពារច្រើន ។ រីសេនាយោធាស្តេច បុលនីត្រហ្មុខត្តក៏ដ កិតភ័យខ្លាចធនីងស្ងាប់ កំតែងៗចម្ងាយមាត្រាបី យោជន៍ ។ ឯអាចារ្យតែងៗដ្តព្រាហ្មណ៍ឯង កំឡើងជិះសេះបរ ហើយ ជួតឈាមថ្ងាសអំក្នាងទៅដល់សេនាយោធាចាំងឡាយនោះហើយ ជិះ នៅលើខ្នងសេះនោះចូលទៅក្នុងនគរ ហើយថា គោរព្តា ម្នាលគ្នាយើង អើយ ! កុំបីតែចូលទៅក្នុងនគរឡើយ ចូរអ្នកចាំងឡាយឈប់។ អញ

ខេះពុំសំពះចៅមហោសថបុត្រគហបតីឡើយ ។ រីសេនាយោធាចាំងនោះ
គេមិនដឿ មិនឈប់ឡើយ គេសឹងតែរត់ទៅហោង អស់ពលសកល
យោធាចាំងឡាយ ឯស្រែកដេរមើគអាចារ្យកៅវដ្តព្រាហ្មណ៍ថា ម្នាល
ព្រាហ្មណ៍កំណាចថ្មបអប្រិយអើយ ! ព្រះស្តែងមកធ្វើខ្លួវអំពើហៅធម្មយុទ្ធ
នេះ សុភាពអស្រួវអ្វីមាល្បាយម៉ែះ គេថា ព្រះស្តែងឯងពុំទាន់ចុះស្រេ-
ដីដល់ ១ ម៉ាត់នឹងគេ ស្រាប់តែខ្លួនចុះសំពះគេមុន អំពីចំណែកចំណេះ
នាអ្នកគប្បីធ្វើឲ្យគាប់ខ្លួវស្តេចនោះគ្មានឡើយ លំដាប់នោះ អាចារ្យកៅវដ្ត-
ព្រាហ្មណ៍ ធ្វើដូចជាមិនឮខ្លួវពាក្យសេនាយោធាចាំងឡាយនោះ គេដើរ
រមូងចៅហោង ។ អាចារ្យកៅវដ្តព្រាហ្មណ៍ ចៅដោយខ្លួវផ្លូវនោះ ដល់
ចៅសេនាយោធាចាំងឡាយហើយថា គោរន្តោ ម្នាលអ្នកចាំងឡាយ
អើយ ! អ្នកចូរដឿអញ អញនេះ មិនសំពះថ្មមហោសថឡើយ
មហោសថនេះ វាបំពោតអញនឹងតែវាមណ៌តែន់ខេ សព្វបិ តេ
ភដ្ឋាលោ ជានាគារេហិ ពោធេត្វា អត្តនោ គាឌិ គា-
ហាបេត្វា . . . រីអាចារ្យកៅវដ្តព្រាហ្មណ៍ស្រដីបន្ទូអស់ស្តេចចាំងឡាយ
នោះ ដោយខ្លួវប្រការផ្សេង ។ ប្រយោជន៍ទឹងឲ្យយកពាក្យគាត្ត តែ
សូម្បីសេនាយោធាដែលក្តាយចៅនោះ ស្តេចឲ្យត្រឡប់វិលមកវិញ ។

(នៅមានត)

ភាសាសាស្ត្រ និង អក្សរសាស្ត្រខ្មែរ

រៀបរៀងដោយ ឧ. តាម

(តទៅ)

អក្សរសាស្ត្រខ្មែរ ខ្មែរធ្លាវែងឆ្ងាយ
ឲ្យបានខ្ជាប់ខ្ជួន ជង់វង់ជង់មត់ ។
ព្រោះអក្សរជាតិ ដោលជាតិព្រាយនិ
អក្សរលេង ជាតិកំរោយ ។

ប.ព.

បំព្លឹកទី ៣

ប្រវត្តិអក្សរ

១– ឫញ្ជូន: សម័យមុនព្រះពោធ (កៅណ្ឌិន្យ) មកកាន់ប្រទេសយើង នៅក្នុងរវាងសតវត្សទី ១ ក្រោយព្រះពុទ្ធកាលប្រមាណ ៦០០ ឆ្នាំ ប្រជាជាតិគោកធ្លកនៅមិនទាន់មានអក្សរប្រើនៅឡើយទេ តែដល់សម័យឥណ្ឌៀនាំអារ្យធម៌មកកាន់ប្រទេសយើង ខ្មែរយើងក៏បានចម្លងយកបែបទម្រង់អក្សរបស់ឥណ្ឌៀមកដែលជាអក្សរខ្មែរឡើង ។ តែបែបអក្សរឥណ្ឌៀមានច្រើនបែប ដូចនៅបំភ្លឺកប្រទេសឥណ្ឌៀទាងដើង ឥណ្ឌៀប្រើអក្សរមួយបែបហាងជ្រុង ។ ដែលជាអក្សរមានរូបហាងដែលគេថាអក្សរក្វាយមកពី

ទេវនាគរី ឯអក្សរដែលឥណ្ឌៀនាំមកឲ្យខ្មែរសម័យនោះ មានភាគមួលៗ ដែលគេប្រើនៅក្នុងប្រទេសឥណ្ឌៀ ចែកខាងត្បូងសម័យនោះ។ តែអក្សរថៃបឥណ្ឌៀក៏ក្លាយបន្តិចម្តងៗ រហូតមកដល់អក្សរខ្មែរយើងសព្វថ្ងៃនេះ។

សម័យមុន យើងប្រើព្យញ្ជនៈមានដល់ទៅ ៣៩ តួ ឃើញថាលើសសព្វថ្ងៃ ២ តួគឺ ឫ ឭ តែព្យញ្ជនៈ ២ តួនេះ គេយក ស នេះប្រើជំនួសវិញនៅពេលចុងសតវត្សទី ១៧ (គ.ស. ១៧៤៧)។

ក) មានវណ្ណយុត្តិ (ៗ) ផ្ទាស់ជា ង (សិលាចារឹកលេខ ៩.១២,១៥ សៀវភៅសិលាចារឹកនគរវត្តទំព័រ ២៧,៣១,៣៧) សំដៅសិក្ខាវិញ្ញាណ= សឹងជាសទិវិញ្ញាណ

N° 17 (B) . . . ជុំនំមច្ចោរពោរតាំមាង = ជុំនំចៅពៅនាងមាង ។

N° 21 (B) . . . តុបតយោកប្រាកតាំកវិយ . . . = ត្បិតយកប្រាក់ដង្ហាយ . . . ។

ខ) វិសជនីយ ផ្ទាស់ទៅជាព្យញ្ជនៈ ឃ សិលាចារឹកលេខ ១៧ N° 22 (B) សៀវភៅសិលាចារឹកនគរវត្ត ទំព័រ ៤៩ សរសេរជា កាលមុះហ្មឹ បីរៃង្គឹង= កាលម្ងួយធឺ បីរៃង្គឹង

២- ស្រៈ ស្រៈខ្មែរយើងដែលប្រើនៅក្នុងសិលាចារឹកអង់គរដ៏ជម្ងឺត

(ឃុំកោះ ស្រុកចុង្កុំ ខែត្រព្រៃវែង នៅក្នុងសតវត្សទី៧ នៅមានខ្វះស្រៈច្រើនដែលយើងប្រើសព្វថ្ងៃ ។ តែលោះស្រៈមានតែ ១៤ តួ ដូចជាស្រៈសំស្ក្រឹតគឺ:

អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ហើយនឹងនិគ្គហិត-នឹងវិសដនីយ ។

រហូតមកដល់សម័យដែលខ្មែរបានឡើងជាចក្រពត្តិហើយ គំរើងនៅតែប្រើស្រៈ តាំង ១៤ តួនេះ ។ ស្រៈប៉ុណ្ណោះនៅមិនទាន់គ្រប់គ្រាន់ទេ ព្រោះភាសាខ្មែរយើងច្រើនជាឯកតព្យាង្គនឹងទ្វេព្យាង្គ ។

ស្រៈខ្មែរដែលមិនឃើញមានប្រើនៅក្នុងសម័យសិលាចារឹកអង់ដម្ពីកជាដើមគឺ: អឹ អឺ អួ អើ អឿ អៀ អែ ។

សូមកុំច្រឡំថាសម័យនោះ យើងមិនមានពាក្យដែលមានសំឡេងផ្សំជាមួយស្រៈនេះ ។ ចុះហេតុដូចម្តេចបានជាមិនមានស្រៈតាំងនោះ ព្រោះថាបុព្វបុរសយើងមិនទាន់រកឃើញស្រៈតាំងនោះឃើញ ម្យ៉ាងហើយគាត់ប្រើឃើញស្រៈតាំងនោះដូចតទៅនេះ ។

ក)- ស្រៈ អឹ = ស្រៈនេះកើតក្រោយគេបង្អស់ តែគេមិនដឹងជាកើតនៅក្នុងវដ្តកាលណាទេ ។ នៅសម័យអង្គរ ស្រៈ អឹ មានឃើញប្រើហើយ តែច្រើនតែប្រើនៅជាមួយពាក្យដែលមកពីសំស្ក្រឹត ដូចពាក្យ

ថា ប្ដឹ= ធ្វើមអំពារ នៅក្នុងសិលាចារឹកប្រាសាទតំណ ស. ៨៧២ ។

២)- ស្រៈ អឹ, អ្ឫ, អើ, អឿ, អៀ ស្រៈទាំងនេះមានខាងដើមសតវត្សទី ១៧ (១៧០១) តែស្រៈទាំងនេះ ជួនកាលគេប្រើតាមរបៀបដើម ។

១) - ស្រៈ អ្ឫ គេផ្សំជាមួយប្រើដើងអក្សរ រ ហើយមានបន្ទាត់ខ្វែមួយពីលើ ដូចពាក្យថា ម្ឫយ=មួយ តែក្រោយមកគេសរសេរថា ម្ហ៊ុយ=មួយ វិញ តែដល់មកសតវត្សទី ១១ គេប្រែទៅជាសរសេរ ម្ហ៊ុយ ដូចដើមវិញ។ តែដល់មកសតវត្សទី ១៨ ដែលខ្មែរមានស្រៈ អ្ឫ ហើយកំទៅតែសរសេរជួរច្នេះខ្លះ ម្ហ៊ុ = មួយ ។

២) - ស្រៈ អ្ឹ ពីដើមឃើញមានសរសេរជាស្រៈ អ្ឺ តែអានថា អ្ឹ ដូចពាក្យនៅក្នុងសៀវភៅសិលាចារឹកនគរវត្ត (សិលាចារឹកលេខ ១) ខ័ណ្ឌ

ជាព្រះពុទ្ធគិបិសំតេបព្រះមហាបើរ = ជាព្រះពុទ្ធគីបីសម្ដេបព្រះមហាបើរ

៣) - ស្រៈ អ្ើ នៅដើមសតវត្សទី ១៧ កាលយើងមិនទាន់មានស្រៈ អ្ើ យើងកត់សំឡេងតាមសៀមខ្លះ ។

នៅក្នុងសិលាចារឹកលេខ ១០ ស. ១៦២៨ (នៅក្នុងសៀវភៅសិលាចារឹកនគរវត្តខ័ណ្ឌ ៣០) មានស្រៈ អ្ើ ដូច្នោះគឺ

កំម្បីតេបលេយ ទុំម្លេហជាគ្រាហាស = កុំបីតិចឡើយ ទុំបើជាគ្រហស្ថ

នៅក្នុងសិលាចារឹកនគរវត្តខ្ទំព័រ ៣៨ ឧយរន្ទះបញ្ឈេហ អព្ទ ទិស្សត្តិ កុំម្បីឱ្យត្រូហ ឈេហដោងទាំងហ្លាយនោះលេយ = ឱ្យ រន្ទះបាញ់ឈើ អាប់ទិសក្តី កុំបីឱ្យត្រូវឈើផងទាំងឆ្ការយនោះ ឡើយ

៦)- ស្រៈ អឿ នៅក្នុងសិលាចារឹកលេខ ៨ គ.ស. ១២២៨ គេ ឃើញមានប្រើពាក្យ មឿង *នៅក្នុងសៀវភៅសិលាចារឹកខ្ទំព័រ ២២ សរ-សេរថា*

អ្នកស្នេំ (១៩) ចយសងឯង អំពិឆ្នាំមខាល ហ្លោម្ដែង ជាប្រាំពិល= អ្នកស្នេចយសងឯង អំពីឆ្នាំខាល ចៅមឿងជាប្រាំពីរ

៧)- ស្រៈ អឿ នៅក្នុងសៀវភៅសិលាចារឹក លេខ ២ ក្នុងសៀវ-ភៅសិលាចារឹកនគរវត្តខ្ទំព័រ ២ សរសេរថា តំណាចត្រប្រឭទ្ធិសាងសព្វ កុសលរឿងមោក = តម្លាចិត្តប្រព្រឹត្តកសាងសព្វកុសលរឿងមក *នៅក្នុងសៀវភៅដដែល ខ្ទំព័រ ៤ សរសេរថា. . . .* មានព្រះកេសកោរ ឱ្យនត្យឹងប្រាកតព្វនកផ្កាលដំនុំ នៃបតុត៌ាធបរសត្វ = មាន

ព្រះកេសកោរក្បូណាដៀងប្រាកដឯកណ្ឌាលដំនុំ នៃបតុពិធបរិ-
សទ្ធ ពាក្យថា = ដៀងប្រាកដ គឺ ជិងប្រាកដ ឬ ទៀងប្រាកដ
យើញថាសរសេរមិនដូចគ្នា មួយសរសេរជា ៤ឯង មួយទៀតជា ឯង ជួន
កាលសរសេរថា ៤ឹង តែមានសំឡេងជា ៤ឯង ។

សិលាចារឹកលេខ ១៧ សៀវភៅសិលាចារឹកនគរវត្តខំព័រ ៤៣ សរ-
សេរជា ព្រះពុទ្ធប្រែរើងមោក = ព្រះពុទ្ធរូបរៀងមក

គ)- ចំណែកស្រៈ: អ្នវិញ យើញថាសម័យដើមគេសរសេរឲ្យ
យើញមានរូបស្រៈ អ ដូចនៅក្នុងសិលាចារឹកលេខ ៣៦ ក្នុងសៀវភៅ
សិលាចារឹកនគរវត្តខំព័រ ៨៧ សរសេរជា . . . នែះសំម្តែបជោតិទេវិ
មហាសឃីរាជបុពិត្រមាន = នែះសម្តែបជោតិទេវិមហាសង្ឃរាជ
បពិត្រមាន

នៅក្នុងសាស្ត្រាស្ងឹកតឹត យើញសរសេរស្រៈ អ្ន ដូច្នេះ ,, នៅខាង
ក្រោមតួព្យញ្ជនៈ ដើម្បីកុំឲ្យច្រឡំថាតួនេះ ជាតួប្រកប ដូច្នេះហើយបាន
ជាមានអ្នកខ្លះអានថា ប្បូពិត្រ ។ នៅក្នុងសៀវភៅដដែលនេះ មាន
កន្លែងខ្លះ ។ សរសេរដូច្នេះ គឺ

១- សិលាចារឹកលេខ ៣៧ សរសេរជា . . . ប្រាប្តាព្រម្ហនឹង

គ្នាលាប្រពន្ធបើញ្ជួសៈយកផលអន្លឹងណា... = ប្រាប្ញាត្រមឹងគ្នាលាប្រពន្ធបើញ្ជួសយកផលអានិសង្ស

២- សិលាចារឹកលេខដដែលសរសេរដូច្នេះ ... ផ្ទៃដីយោកសំបូតមានតំម្លៃប្រាំពៃកាតជាពីតាន ២ ហើយបាប្រាកឲ្យជាទានឥស្សរកំម្រៃតែងសង្ស្យាដោង = ផ្ទៃដីយកសំពត់មានតម្លៃប្រាំពៃ កាត់ជាពីតាន ២ ហើយបាយប្រាក់ឲ្យជាទានអស់តម្លៃដែងសង្ស្យាដែង ។

ឃ)- ចំណែកនិគ្គហិតវិញច្រើនប្រើជំនួស ម *មានប្រើច្រើនជាងសព្វថ្ងៃ* ។ *សូមអានតាមតារាងខាងក្រោមនេះ*

សម័យបុរាណ		សម័យបច្ចុប្បន្ន	
ស្រៈ	ឧទាហរណ៍	ស្រៈ	ឧទាហរណ៍
អំ	អំបស្ស(១)	អម	អម្ចាស់
◌ំ	◌ុំ (២)	◌ុម	ធ្នើម
◌ុំ	សុំ	◌ុម	សុម
◌ើំ	◌ើំ	◌ើម	ដើម
◌ាំ	កាំ (៣)	◌ាម	ក្រាម

១- សិលាចារឹកលេខ ២ ក្នុងសៀវភៅសិលាចារឹកខេត្តទំព័រ ២ ។ ២ សិលាចារឹកប្រាសាទកំដែល គ.ស. ៩៣២ ។ ៣- សិលាចារឹកលេខ ៣ ក្នុងសៀវភៅសិលាចារឹកទំព័រ ៦ (*សុំ សំយ៉ាក្ស = សូមសំណាក់*) ។

បំពូកទី ៤

មរតកភាសា

ដែលហៅថាមរតកភាសា គឺភាសាដែលមិនមានកំណើតកើតមកតែឯកឯង គឺមានពាក្យជាច្រើនដែលរួមផ្សំគ្នា ទើបគេហៅថា សមាសភាសា ក៏ចាន់ដែរ ។

១- សមាសភាសា គឺគេយកពាក្យមកផ្សំគ្នា ដើម្បីឲ្យចាន់តែតជាពាក្យមួយមានន័យដោយឡែក ។

ក)- ពាក្យខ្មែរសុទ្ធ តែមានពាក្យច្រើន ហើយផ្សំគ្នាមកចាន់ជាពាក្យមានន័យផ្សេង ដូច សត្វជាល់អំបុក

សត្វជាល់អំបុក < សត្វ + ជាល់ + អំបុក ។ ពាក្យនេះមានន័យ ៣ យ៉ាង តែជាល់គេរួមគ្នាមកចាន់ជាសត្វមួយ ។

ខ)- ពាក្យចាលី ឬ សំស្ក្រឹតវិញក៏ដូចតែពាក្យខ្មែរខាងលើដែរ

អង្គការសហប្រជាជាតិ < អង្គ + ការ + សហ + ប្រជា + ជាតិ

២- បរសមាសភាសា គឺពាក្យណាដែលផ្សំពាក្យខ្មែរ និងពាក្យបរទេស ដូចយ៉ាងពាក្យថា ទូកដ ឬដា ជាងទូង ជាដើម ។

ពាក្យខ្មែរ	បរទេសភាសា
ទូក	ដ (ចម្លង)

ពាក្យខ្មែរ	បរទេសភាសា
ថ្ម	ជា (ថ្ម)
ជាង	ខង (មាស)

๓- អាទិភាសា គឺពាក្យដែលគេចំប្រញាពាក្យវែង ។ ឲ្យមកនៅខ្លីវិញ តែមានន័យនៅដដែល ។ ដូចពាក្យថា ពិស្វាសុ ដែលគេច្រើនយកទៅសូត្រធ្វើជាមន្តអាគម

ពិ គឺ ឥតិ បិ សោ (ពុទ្ធគុណ)

ស្វា គឺ ស្វាក្ខាតោ (ធម្មគុណ)

សុ គឺ សុបដិបន្នោ (សង្ឃគុណ)

ពាក្យមួយទៀត ដែលគេតែងពោលនៅមុនពេលស្ពោះព្រួសថា ឱម ។ ពាក្យពីរព្យាង្គនេះ មានន័យខ្ពស់ណាស់ គេយកឈ្មោះព្រះ ๓ អង្គ នៅក្នុងព្រហ្មញ្ញាសាសនាមកសង្ខេបនៅតែពីរព្យាង្គ ។ ចើចង់ឲ្យត្រឹមត្រូវគេថា អ.ម ឱ. តែគេផ្សាស អ + ឧ > ឱ + ម > ឱម បានន័យថា :

អ គឺ ព្រះ វិស្ណុ

ឧ គឺ ព្រះ សិវ

ម គឺ ព្រះ ព្រហ្ម

ពាក្យថា ព្រះតេជៈព្រះគុណ គឺជាពាក្យដែលគេនិយាយសំដៅយកៈ

ព្រះតេជៈ គឺ ព្រះឥស្សរៈ

ព្រះគុណ គឺ ព្រះនភយណ៍

๔- ប្រជានិរុត្តិសាស្ត្រភាសា (Populary Etymology)

ដែលគេហៅថា ប្រជានិរុត្តិសាស្ត្រភាសា គឺជាពាក្យដែលសង្គមមនុស្សនីមួយៗ ហៅសំពាច់សង្គម ឬបង្កើតពាក្យថ្មីខ្មៅ ដើម្បីឲ្យស្រួលដល់ការត្រូវការប្រើរបស់សង្គមនោះ ។

ដូចជាពាក្យ សម្ពន្ធឡាប

សម្ពន្ធឡាបនេះ ដូចជាមិនឃើញមាននៅគ្រប់ឃុំ ខែត្រទេ ខ្ញុំឃើញមាននៅតែ ឃុំបំបក់-ឫស្សីកែវស្រែកឆ្លងខែត្រព្រៃបេះ ។ ខ្ញុំតែងសួរគេខ្មៅដែរ តែមានភាគច្រើន ដែលមិនស្គាល់ឈ្មោះសម្ពន្ធនេះ ។ សម្ពន្ធនេះពិតជាពាក្យខ្មែរ ។ សម្ពន្ធនេះមិនខុសគ្នាពីសម្ពកកូរប៉ុន្មានទេ ។

មានពាក្យដទៃខ្មៅ ដែលអាចចាត់ចូលថា ជាប្រជានិរុត្តិសាស្ត្រភាសាបាន ដូចពាក្យថា ផ្សឹតខ្សាប់, ផ្សឹតពងលលក . . . ។

ចានជាគេហៅថា ផ្សឹតខ្សាប់ ព្រោះផ្សឹតនេះ ជុះនៅលើដីខ្សាច់ ឯផ្សឹតពងលលកវិញ ព្រោះមានសណ្ឋានដូចជាពងលលក ។

មួយទៀត ភាសាស្នេហា ច្រើនតែប្លែកៗ ពីគ្នាព្រោះមានពាក្យ

ខ្លះគេបង្កើតឡើងសំកប់តែគួស្វាមីកវិយោ ឬសង្ឃរបស់គេ ។ ពាក្យដែលគេប្រើជាញឹកញាប់ ហើយឮសូរតែគ្រប់សង្គមដូចពាក្យថា ព្រលឹង បេះដួង សរកាមទេព កែវភ្នែក ស្មើជីវិត . . . ។

តែបើយើងពិនិត្យទៅតាមឯកឫសស្ត្រទៅវិញ មិនថាឯកឫសស្ត្រខ្មែរ ឬបរទេសទេ គេច្រើនប្រដូចស្រីនៅក្នុងប្រលោមលោកថា កូឡាប, ណាគ្រី, បំប៉ោ, បំប៉ី ... ឯបុរសវិញគេថា កន្ធង់, មេអំបៅ, ឃ្មុំ ... ។

បើយើងមែមកស្តាប់ពួកមាំកខ្លះនិយាយជាកំផែង ឬនិយាយបំខុមុខវិញ គេថា :

– ម៉ែចមេគោទៅណាហើយ ! ឬថា

– ម៉ែចមិនសណ្តាន់រុំម៉ក មកផង ! ឬក៏ថា

– ម៉ែចមិនយកម្ហូបមកផង !

ពាក្យ មេគោ, រុំម៉ក, ម្ហូប សុទ្ធតែជាពាក្យគេប្រើជាមួយនឹងប្រពន្ធ។

៥– ឥទ្ធិពលភាសា (Influence of Language)

ឥទ្ធិពលភាសានេះមានកំឡាំងណាស់ ដូច្នេះបានជាគេចំផ្សាយភាសាមុំះ ។ ដូចគួយាងសហរដ្ឋអាមេរិក ដែលធ្លាប់នៅក្រោមការត្រួតត្រារបស់ចក្រពត្តិអង់គ្លេស សហរដ្ឋអាមេរិក ក៏យកភាសាអង់គ្លេសជាភាសាជាតិ ។ ជនជាតិអាមេរិកាំងពាំងខាងត្បូង (Amérique du Sud ឬ Amérique latine) ដែលភាសាអេស្ប៉ាញ៉ូលផ្សាយចូលមក ប្រទេស

តាំងឡាយនោះ ក៏និយាយភាសាអេស្ប៉ាញ៉ុល លើកលែងតែជាតិប្រេស៊ីល (Brazil) ដែលយកភាសាពកុយក្រែជាភាសាសំរាប់ជាតិ ព្រោះជាតិពកុយក្រែត្រួតប្រេស៊ីលមុន ។

ចំពោះភាសាខ្មែរយើងវិញ ដែលមិនមែនជាភាសាផ្ទាល់ប្លុកស្រួតនោះ យើងក៏យកពាក្យច្រើនដែលខ្ចីយកមកពីផ្ទាល់ប្លុកស្រួត ។ មិនថាសាសន៍ណា ឬ ជាតិណាទេ គេតែងតែខ្ចីយកពាក្យចរទេសប្រើច្រើនខ្លះ បើសាសន៍នោះជាតិនោះត្រូវការចាំបាច់ទៅហើយ ។

ឥទ្ធិពលភាសា ដែលចូលមកជ្រៀតជ្រែកភាសាខ្មែរច្រើនតែផ្ទាល់សំស្រួត.ចិន-ឃួន.សៀម ជាដំបូង

១- ភាសាខ្មែរខ្ចីពាក្យពីបាលីនិងសំស្រួតជាច្រើន ដូចជា ព្រឹក្សា, មនុស្ស, គេហស្ថាន . . ។

២- ភាសាខ្មែរខ្ចីពីចិន គឺច្រើនតែមុខម្ហូបស៊ី គេច្រើនតែដូចប្រទះនឹងពាក្យចិន ដូចយ៉ាង តុយភាវ, សាមចូក . . . ។

៣- ភាសាខ្មែរខ្ចីពីឃួន ភាសាឃួនផ្សាយឥទ្ធិពលមកស្រុកខ្មែរច្រើនណាស់ដែរ ហើយច្រើនតែខាងម្ហូបដែរ ។ ពាក្យឃួនខ្លះ ដូចជើងហែម.ជើងបង . . . ។

៤- ភាសាខ្មែរខ្ចីពីសៀម ភាសាខ្មែរយើងបានជាខ្ចី ឬមានលំនាំ

ដូចសៀមដោយហេតុ ៣ យ៉ាងគឺ

ក)- ព្រោះសៀមខ្ចីពាក្យខ្មែរទៅប្រើច្រើនជាងគ្រប់គ្រាន់

ខ)- ព្រោះសៀមក៏ខ្ចីពាក្យសំស្ក្រឹតធំជាលើ

គ)- ព្រោះនៅបុរាណសតវត្សទី ១៦ សៀមរាយលុកបន្ទាយលង្វែក សៀមយកពាក្យសៀមមកសរខ្មែរ ។

ភាសាខ្មែរសៀមដូចគ្នាតែខាងនិយាយស្តាប់ធំរឹងរបៀបសាស្ត្រហើយថែមគ្នាខាងសូរសាស្ត្រ ។

ខ្មែរយើងនៅមានពាក្យសង្គមមនុស្សខ្លះទៀត ដែលច្រើនតែចូលសៀម នៅក្នុងមន្តអាគម ឬ នៅក្នុងចំរៀងខ្លះ ត្រង់នេះខ្ញុំសូមលើកយកឧទាហរណ៍ ចំរៀងមួយដែលខ្មែរនៅ ឃុំលួស ខេត្តសៀមរាប គេច្រើនតែច្រៀងនៅក្នុងពេលល្បែងអ្នកតា "ចាប្ញាំង" ដើម្បីសុំទឹកភ្លៀង

គេច្រៀងថា: ជាងម៉ែរៗអើយ ទំបុតទំកៃ ទំម៉ែដាយ រំងៃហៅទំម៉ា សៃ ៗ ទ្បុងម៉ា លោកតាភ្លៀងមក់ ។


នេះមកពីឥទ្ធិពលភាសាសៀម ភ្ជាប់នៅត្រួតខេត្តសៀមរាបនេះស្រាប់ តែទុកជាខេត្តខ្លះដែលសៀមមិនត្រួត ក៏ខ្មែរយើងនិយមប្រើពាក្យសៀមខ្លះដែរ ដូចពាក្យថា ជាងទង . . .

៦- ភាសាខ្មែរខ្ចីមកពីអឺរុប

ក)- ភាសាខ្មែរយកមកពីបាលី ដោយខ្មែរយើងខ្លះភាសាខាងបច្ចេកទេសនឹងវិទ្យាសាស្ត្រ ដូចជា "គីមី"

ខ)- ខ្មែរយើងក៏បានខ្ចីភាសាអង់គ្លេសខ្លះដែរ ដូចពាក្យថា "រ៉ុក អាន់រ៉ុល, ធ្វិស, (Rock n'Roll, Twist) ជាដើម ។

ខ្មែរនៅមានខ្ចីបរភាសាមកប្រើច្រើនទៀត ។



សិលាចារឹកនៅប្រាសាទវិមានអាកាស (សុធាតិលក)



Nouvelle inscription du Bimēānākas

សិលាចារឹកនៅប្រាសាទវិមានអាកាស (សុជាតិលក[1])

សិលាចារឹកនៅប្រទេសខ្មែរយើងមានច្រើនណាស់ ជាភាសាសំស្ក្រឹតក៏មាន ជាភាសាខ្មែរក៏មាន ។ យើងបានដឹងថា ភាសាខ្មែរជាអម្បូរភាសាមួយដោយឡែកហៅថា មន-ខ្មែរ ជាភាសាមួយក្នុងក្រុមភាសានៅអាស៊ីភាគអាគ្នេយ៍ ដែលគេហៅថា « អូស្ត្រូអាស៊ីយាទិក » (Austro - asiatique) ។ អ្នកផងយល់ថា ភាសាខ្មែរ ជាភាសាអម្បូរ ភាសាហិណ្ឌូ - អារ្យ័ន តាមការណ៍ពិត ពុំមែនទេ តែមានបុព្វហេតុខ្លះដែលនាំឲ្យគេកន្ត្រឹងឡើ តឹមតែពីបុព្វបុរសយើង បានខ្ចីយកពាក្យសព្ទសំស្ក្រឹតឬបាលីភាគច្រើនមកប្រើក្នុងភាសាយើង ដូចពាក្យសព្ទខ្មែរថា ភ្នែក ច្រមុះ មាត់ ក្បាល សក់ ត្រចៀក លោកខ្ចីយកពាក្យសព្ទសំស្ក្រឹតឬបាលីមកប្រើជំនួសសម្រាប់ពាក្យសព្ទនឹងឮថ្នូជាងសព្ទដូចជា នេត្រ នាសា ព្រះនេត្ត ព្រះកេស ព្រះកាណ៌ជាដើម មកបន្ថែមទៀត ។ ត្រង់នេះហើយដែលអ្នកខ្លះយល់ថា ភាសាខ្មែរជាអម្បូរភាសាហិណ្ឌូ.អារ្យ័ន ។ ក្នុងភាសាខ្មែរយើងមានពាក្យដែលអាចយកមកប្រើបានតាមត្រូវការ ស្ទើរតែមិនចាប់ខ្លឹពាក្យគេមកបន្ថែមក៏សឹងតែបាន តែការខ្ចីគ្នានេះ ជាការធម្មតាភាសាឬអ្វីនៅក្នុងលោកនេះទេ ព្រោះការចាក់ឌែងទៅវិញទៅមកតែងតែមាន ឧទាហរណ៍ពេលតែម្នាក់ឯងពុំបានប្រសើរឡើយ ។ ក្នុងសិលាចារឹកជាភាសាខ្មែរ យើងសង្កេតឃើញថា បុព្វបុរសយើងបានប្រើ

(1)- BFEO. T. XVIII 1918 P. 9 N. suivantes

ភាសាយើងជាផ្លូវការបានការគ្រប់សព្វ ទោះជាការនិយាយក្តី ទោះជាការសរសេរក្តី ឬទោះជាការចារឹកក្តី ប្រើបានគ្រប់គ្រាន់តាំងពីបុរាណកាល ។ ភាសាយើងមានប្រវត្តិសាស្ត្រមកយូរអង្វែងស្ទើរតែដល់ ២០០០ ឆ្នាំហើយ មិនអន់ថយជាងភាសាបរទេសទេ ។

ក្នុងពេលមួយដែលខ្ញុំអានសៀវភៅ ខ្ញុំបានប្រទះឃើញសិលាចារឹកនៅមានអាកាសនេះ ជាសំស្ក្រឹតផង ជាភាសាខ្មែរផង ។ សិលាចារឹកនេះ និយាយពីការដាំដើមពោធិមួយដើម មិនមានកាលបរិច្ឆេទទេ ទំនងមិនមែនជាបុរាណពេកផង ហើយអក្សរសិលាចារឹកនេះប្រាប់ថា ជារបស់សម័យកណ្តាល គឺសម័យមហានគរ ក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ៧ គឺក្នុងគ្រិស្តសតវត្សទី ១៣ ។ ខ្ញុំអានហើយជាប់ចិត្ត ដោយឃើញមានប្រយោជន៍ច្រើនប្រការដូចតទៅនេះគឺ:

១- សេចក្តីប្រែជាខ្មែរ ជាសេចក្តីប្រែត្រង់តាមសំស្ក្រឹត ដូចជាយើងនិយាយថា „ប្រែផ្ទាត„ មិនមែនដូចសិលាចារឹកដទៃ ។ ទៀតទេ សិលាចារឹកបុរាណយើងដោយច្រើន តែងតែមានផ្នែកភាសា ជាសំស្ក្រឹតផង ជាខ្មែរផង តែសេចក្តីជាខ្មែរ មិនមែនជារបៀបប្រែផ្ទាត់ដូចសិលាចារឹកមានអាកាសនេះទេ គ្រាន់តែនិយាយជាសេចក្តីច្បាប់ដូចសេចក្តីភាសាសំស្ក្រឹត ។

២- យើងមានលទ្ធិសាសនារលាយចូលគ្នា គឺពុទ្ធសាសនា និងសាសនាព្រាហ្មណ៍ ។ រឿងលទ្ធិរលាយចូលគ្នានេះ បើយើងបានមើល

សិលាចារឹកច្រើន ។ យើងនឹងយើញត្រឹត្តិការណ៍នេះពិតមែន បុព្វបុរសយើងហាក់ដូចជាមិនសូវរវល់ ឬមិនមានការបារម្ភក្នុងរឿងរាយចូលគ្នានេះទេ អ្នកកាន់សាសនាព្រាហ្មណ៍ នៅរួមជាមួយអ្នកកាន់ពុទ្ធសាសនាដោយសុខក្សេមក្សាន្ត មិនសូវរនឹងគ្នា ។

៣- សិលាចារឹកនេះ និយាយពីការដាំដើមពោធិព្រឹក្ស ។ យើងបានដឹងថា ការគោរពពោធិព្រឹក្សនេះជាប្រពៃពីពុទ្ធសាសនា ក្នុងកាលនោះ តែគេទុកពោធិព្រឹក្សនេះទៅជា "ត្រៃមូរ្តិ" គឺព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ ដែលជាសាសនាព្រាហ្មណ៍ទៅវិញ ។

៤- ភាសាខ្មែរ មានការវិវឌ្ឍន៍ខ្លាំងណាស់ ហើយចូលទៅក្នុងអក្សរសាស្ត្រពេញលក្ខណៈពិតប្រាកដ គួរឲ្យកោតស្ងើចក្រៃលែង ។ ក្នុងភាសាខ្មែរ បុព្វបុរសយើងប្រើពាក្យសព្ទខ្មែរ ឧទាហរណ៍សព្ទសំស្ក្រឹតលាយចំរុះគ្នា ហើយខ្ញុំសូមយកមកលាតត្រដាងជាប្លង់ដែលដូចខាងក្រោមនេះ ៖

សិលាចារឹកសំស្ក្រឹត	សិលាចារឹកខ្មែរ	ប្រែផ្ទាល់	ប្រែយកសេចក្តី
តិវ:	ព្រះឦសូរ	ព្រះឥសូរ	ព្រះឥសូរ
សនាតន:	ទិត្យ	ទិត្យ	នៃបទិត្យ ជានិច្ច
ប្ឫក្ស:	ប្រ្ក័ស	ព្រឹក្ស	ព្រឹក្ស ដើមឈើ
ភាគ្យ:	ភាគ្យ	ភាគ្យ	ភាគ្យ មានបុណ្យ មានជោគ

សិលាចារឹកសំស្ក្រឹត	សិលាចារឹកខ្មែរ	ប្រែផ្ទិត	ប្រែយកសេចក្តី
អាគ្រេយ:	អាគ្រេយ	អាស្រ័យ	អាស្រ័យ
ផល:	ផល	ផល	ផល-ផ្លែ
អនិល:	ព្រះពាយុ	ព្រះពាយុ	ព្រះពាយោ ព្រះពាយ
ក្រុន្ធ:	ក្រោធ	ក្រោធ	ក្រោធ ខឹង
ទុស្សប្ត:	សប្ដអសុរ	សប្ដអាស្រវ	ចេល់សប្ដអាក្រក់
ទុរ្ជ្ជាចិន្តិត:	ចិន្តាអសុរ	ចិន្តាអាស្រវ	ចិត្តអាក្រក់
ទិវ្យ:	សួគ៌	ស្ថានសួគ៌	ស្ថានសួគ៌

យើញមានប្រយោជន៍ដូច្នេះហើយ ខ្ញុំបាននិយាយច្រាប់មិត្តទាំង ឡាយ ។ មិត្តទាំងនោះក៏មានមតិស្រេចគ្នា ទើបខ្ញុំដកស្រង់យកមកសឹ អស់លោកអក្សរសាស្ត្រទាំងឡាយទុកជាការសិក្សា តទៅដូចខាងក្រោម

អត្ថបទជាសំស្ក្រឹត

ប្រហ្មមូលតំស្ពន	ឋិប្តគ្គទសនាតន:
ឬក្សព្រេជមហាភាគ្យ	សភ្ជិត្រយ ផលប្រទ
មា ភ្លា គ្គន ម្ចិ បវត្ -	ម្ចានិនោ មា ហុតាគ្គន:
មា ភជា មា គជ: ក្រុត្តេ	វិនាគ្គមុបនេត្តិ
អក្ស្ញិស្សន្ធុ ក្រុវេស្ស្យ -	ន្ទុស្សប្ដន្ធុវិចិន្តិតម
អស្ងត្ត គ្គមយេត្ស្យ្ញ	យទ្ធិវ្យ យត្ត មានុថ-មិ

សេចក្តីប្រែជាខ្មែរ

បពិត្រព្រះមហាវោធិ៍ ! ព្រះអង្គមានឫសគឺព្រះព្រហ្ម មានដើមគឺព្រះឥសូរ មានមែកគឺព្រះវិស្ណុ បិតថែរជាន់ចុង ជាស្តេចនៃព្រឹក្ស មានបុណ្យច្រើនក្រៃ ជាទីអាស្រ័យនៃសព្វសត្វ ទ្រង់ប្រទានផល ។

សូមរន្ធះកុំបុកញ៉ា សូមពួថៅកុំកាប់ សូមខ្សាច់កុំបំបាក់ សូមភ្លើងកុំឆេះ សូមព្រះរាជាកុំបំផ្លាញ សូមដំរីកុំក្រេច (ព្រះមហាវោធិអង្គនេះ) ឡើយ។

ឧព្រះមហាវោធិ ! សូមទ្រង់រម្ងាប់កុំឲ្យមានការព្រួចក្អែកអាក្រក់ ការញាក់ចិញ្ចើមអាក្រក់ ការយល់សប្តិអាក្រក់ ការគិតអាក្រក់ ពាំនអស់នេះដែលជារបស់ទេវតាក្តី ដែលជារបស់មនុស្សក្តី កុំបីឲ្យមានឡើយហោង ។

ឯសិលាចារឹកខ្មែរ ខ្ញុំចាត់ជាបីបែបគឺ ១) ពាក្យសិលាចារឹកខ្មែរសុទ្ធ ២) ប្រែជាពាក្យសម័យ ៣) ប្រែយកសេចក្តីតាមសម័យនិយមដូចខាងក្រោម ៖

ពាក្យសិលាចារឹកខ្មែរ	ប្រែផ្ទិតជាពាក្យសម័យ	ប្រែយកសេចក្តី
១. ថៃព្រះមហាកេធិ	១. ថៃព្រះមហាវោធិ	១. បពិត្រព្រះមហាវោធិ
២. ថៃតមាន្ធំគតិព្រះ	២. ថៃដ៏មានដើមដ៏គឺ	២. បពិត្រព្រះអង្គដែលមានដើមជាព្រះ
ប្រហ្ម	ព្រះព្រហ្ម	ព្រហ្ម

ពាក្យស៊ីលាចារឹកខ្មែរ	ប្រែផ្ទឹតជាពាក្យសម័យ	ប្រែយកសេចក្តី
៣- ព្រៃមានទ្វូន តគិព្រះឥសូរ	៣- ព្រៃដ៏មានទ្វូនដ៏តី ព្រះឥសូរ	៣- បពិត្រព្រះអង្គ ដែលមានព្រះកាយជា ព្រះឥសូរ
៤- ព្រៃមានមែក តគិព្រះវិស្ណុ	៤- ព្រៃដ៏មានមែក ដ៏តីព្រះវិស្ណុ	៤- បពិត្រព្រះអង្គ ដែលមានមែកជាព្រះ វិស្ណុ
៥- ព្រៃតនិត្យ	៥- ព្រៃដ៏និត្យ	៥- បពិត្រព្រះអង្គ ដែលស្ថិតនៅជានិច្ច
៦- ព្រៃតជាកុរុង តវ្រឹក្សជោង	៦- ព្រៃដ៏ជាក្រុងដ៏ ព្រឹក្សជោង	៦- បពិត្រព្រះអង្គ ដែលជាស្តេចព្រឹក្សជង
៧- ព្រៃ តភាគ្យ វេត	៧- ព្រៃដ៏ភាគ្យពេក	៧- បពិត្រព្រះអង្គ ដែលមានបុណ្យ មាន ជោគជ័យពន់ពេក
៨- ព្រៃតជាអាស្រ័យ ឃតជតត	៨- ព្រៃដ៏ជាអាស្រ័យ ដ៏ផ្ទៃក្រោមជង	៨- បពិត្រព្រះអង្គ ដែលជាទីសំណាក់អា- ស្រ័យនាផ្ទៃក្រោមជង

ពាក្យសំណាចរឹតខ្នែរ	ប្រែផ្តិតជាពាក្យសម័យ	ប្រែយកសេចក្តី
៩- ហៃតឲ្យផលច្បាស់	៩- ហៃដឹងឲ្យផលឆ្ងាស់	៩-បពិត្រព្រះអង្គដែលប្រទានផលសម្រាប់ចិញ្ចឹមជីវិតនៃអាត្មា
១០- កំបិទន្ទុះបញ្ជាក់ត្រេងអញ	១០- កុំបីទន្ទុះបាញ់តម្ពែងអញ	១០- កុំបីឲ្យទន្ទុះបាញ់ខ្ញុំ (ប្រហែលពោធិ)
១១- កំបិត្រូតិង	១១- កុំបីត្រូវដឹង	១១- កុំបីត្រូវគេកាប់ឆ្កឹងដឹងឡើយ
១២- កំបិប្រែរាំយុកច	១២- កុំបីព្រះពាយកាច់	១២- កុំបីឲ្យព្រះរាំយោបក់កាច់ចំបាក់
១៣- កំបិប្រែវ្រេងតុត	១៣- កុំបីព្រះក្តើងដុត	១៣- កុំបីឲ្យព្រះក្តើងឆាបឆេះឡើយ
១៤- កំបិតម្រេតេងផ្លែកពេចំបត	១៤- កុំបីតម្ពែងផ្លែក្រមំបាក់	១៤- កុំបីឲ្យស្តេចផ្លែក្រមំផ្ងាញ់ឡើយ
១៥- កំបិតម្រ្យាក្រោធកំបិប្រែ	១៥- កុំបីដំរីក្រោធកុំបីព្រេច	១៥- កុំបីដំរីចុះប្រែងព្រេចបំបាក់ឡើយ
១៦នៅកម្រែកវែកយេងតអស្ចរ	១៦- នៅកំរើកកែកយើងដ៏អាស្រូវ	១៦-ខ្លួកំរើកកែកយើងដ៏អាក្រក់

ពាក្យសិលាចារឹកខ្មែរ	ប្រែផ្ទិតជាពាក្យសម័យ	ប្រែយកសេចក្តី
១៧- នៅកម្រែកចំ	១៧- នៅកវើក	១៧. នូវកម្រើកចិត្តមិ
ចេតំអស្រ	ចិត្តមិនអាស្រ	ជឺអាក្រក់
១៨- នៅសូបតអស្រ	១៨- នៅសប្តជឺ	១៨- នូវឃើលសប្តជឺអា
	អាស្រ	ក្រក់
១៩- នៅចិត្តាតអស្រ	១៩-នៅចិត្តជឺអាស្រ	១៩- នូវចិត្តជឺអាក្រក់
២០- នៅមះតអស្រ	២០- នៅមោះជឺ	២០- នូវមោះមៃអាក្រក់
ផៅង៑ តមាន តសូគ្គិ	អាស្រវែង ជឺមាន	ផង ដែលមានៅស្ថាន
តមនុម្ស លោះបុរ បំ-	ជឺសួគ៌ ជឺមនុស្ស	សួគ៌ក្តី ស្ថានមនុស្សក្តី
បននោះ	លោះបំបាត់នោះ	ទាំងអស់ ចូរបំបាត់កុំឲ្យ
		មាននឡើយ

អង្គរធំឯសម័យអង្គរ តាមទស្សនាវដ្តី «ញូវអ្ហរិយ៉ង់»

(ក្រុងប្រាក) លេខ ៣/១៩៦១

(តចប់)

សព្វថ្ងៃ ប្រាសាទតាំងពីរនេះ ជាវត្ថុបំណងដ៏ធំរបស់អ្នកទស្សនាតាំងឡាយនៅអង្គរ ។ អង្គរវត្ត (ប្រាសាទនៃទីក្រុង) មានគូទឹកមួយមានទទឹងប្រហែល ២០០ ម៉ែត្រព័ទ្ធជុំវិញ ។ កន្ទែងត្រង់សង់ប្រាសាទមានបណ្តោយ ១៥០០ ម៉ែត្រ ទំនឹងទទឹង ១៣០០ម៉ែត្រ ។ ស្ថាបត្យកម្មនៃប្រាសាទមានលក្ខណៈថៃបំផុតជាទីលាន មានសិទ្ធិសណ្ឋានឥតខ្ចោះ សូម្បីមើលពីអាកាសយានមកក៏ដោយ . . . ។ មានកំពូលប្រាសាទសិលាសង់នៅត្រង់ជ្រុង ចំណែកកណ្តូប្រាសាទធំមានកំពស់ ៦៥ ម៉ែត្រ ។ បើគេក្រឡេកមើលបញ្ជៀង តាមតែទីតាំងណាក៏ដោយ គេតែងតែឃើញស្រមោលកំពូលបីដ៏ល្អអស្ចារ្យនៃអង្គរវត្ត ។ វត្ថុរូបទាំងនេះផ្សាយចេញនូវមហាសក្តានុពលសមស្ទួន តោរពេញដោយវិញ្ញាណភាព ហើយអាម្មៃថបនេះកាន់តែមានខ្លាំងឡើង បើកាលណាគេចូលទៅខាងក្នុង ។ មិនមានកន្ទែងត្រង់ណាមួយ ដែលទៅលាតស្ថាតទំនេរសោះនោះទេ ជញ្ជាំងក្តី សរសេរក្តី បង្ហិចក្តី ពិតានក្តី ខ្ទោងទ្វារក្តី សុទ្ធសឹងមានគំនូរក្បាច់រចនាប្រកបដោយការប៉ិនប្រសប់យ៉ាងសម្បឹម គ្រឿងតុបតែងលំអក៏សុទ្ធសឹងយ៉ាងសំខាន់តាំងអស់ ។

ឈុតសិល្បៈផ្នែកបុរាណស្ត្រី ទីឆ័ឈុតផ្នែកនាដការីដែលប្រកបដោយចលនាដ៏សមសួន បានញ៉ាំងឆ្អាំងសិលាឲ្យមានសភាពកាន់តែស្រស់ប្រពៃឡើង ។ ប្រាសាទមិនមែនកសាងសម្រាប់មនុស្សទេ ។ ហេតុដូច្នេះហើយ បានជាជាងចម្លាក់ខ្មែរ មិនទុកឲ្យសល់នៅមានកន្លែងលាតត្រដាងទេ សូម្បីតែកន្លែងដែលគេមិនអាចមើលដល់ ទីឆ័កន្លែងឆ័ងឆឹតក៏គង់មានក្បាច់ចម្លាក់ដែរ ។ នៅកន្លែងចាំងនេះ គេឃើញមានឆ្អាំងចម្លាក់ពពាំងគឺរូបមនុស្សនឹងរូបទេពតា រូបស្រីទេពអប្សរលេងស្រស់រេរាំ ញញឹមប្រឹមប្រិយ៍ ខ្លួនទេហាក់ដូចមានវិញ្ញាណជាន់ខ្ពស់ ។ ឯវិធីតម្រូវប្រកបដោយសោភណភាពនៃស្រីទេពអប្សរខាងលើ គឺដូចជាវិធីមុខនៃយុវនារីខ្មែរដើលឆ្នើតសព្វថ្ងៃនេះដែរ ។ អង្គរវត្តគេទុកសំរាប់ព្រះវិស្ណុដែលជាទេពតាមួយព្រះអង្គនៅព្រះវិហារហិណ្ឌូ (ក្នុងប្រទេសឥណ្ឌា) ។ ឆ្អាំងចម្លាក់ច្រើនតែថ្លែងនូវនាគរឿងបុរាណស្ត្រី នៃប្រទេសឥណ្ឌាជាន់ចាស់ ។ ឯនាគរឿងកំម៉ាយណៈទីឆ័មហាភារតៈក៏គេឃើញមាននៅខោះផងដែរ ។ ស្រីទេពអប្សរគឺជានាដការីនៅស្ថានព្រះឥន្ទ្រ ក្នុងប្រាសាទខ្លះនៃអង្គរ គេក៏ឃើញមានព្រះពុទ្ធបដិមាករ ប្រកបដោយសភាពពិសេសទីឆ័រូបព្រះពោធិសត្វ ព្រមចាំងឆ្អាំងចម្លាក់ផង ។ ការណ៍នេះមិនមែនសម្រាប់បំភាន់ជនណាទេ គឺគ្រាន់តែជាទម្រង់ក្រៅបន្ថែមបន្ថយ ទីឆ័ជាកិច្ចការខាងឆ័សាសនាប៉ុណ្ណោះ ។ ចំពោះរឿងនេះ មួយផ្នែកមកពីសិល្បការ

និយមធ្វើដោយយកលំនាំពីគេ មួយផ្នែកទៀត មកពីព្រះមហាក្សត្រខ្លាំង ព្រះបញ្ញា ។ ប៉ុន្តែមិនមានការបាត់អ្វីដែលអាចឲ្យបង់សេធចោលបានខ្លួសភាពពីសេសខាងសិល្បៈនៃសិល្បខ្មែរ ហើយនឹងដាក់ឲ្យខាងសោភណភាពជំនួសរបស់សិល្បខ្មែរទេ ។ អានុភាពនៃវប្បធម៌ឥណ្ឌា ពិតជាមានមុខងារដ៏ធំក្នុងសិល្បខ្មែរ នេះគឺជាការធម្មតា ។ អានុភាពវប្បធម៌ឥណ្ឌា បានបង្កើតឲ្យមានប្រភពខាងសិល្បៈនៃប្រទេសច្រើន តែនៅសម័យដើមបំផុត ហើយក្នុងករណីយ៉ាងច្រើន អានុភាពនេះបានចាក់ឫសញាំងសភាពខាងបង្កើតដោយខ្លួនឯងឲ្យកើតមានទៅវិញទេ ។ មិនយូរប៉ុន្មាន ទេពកោសល្យនៃសិល្បករខ្មែរ ក៏ដោះខ្លួនស្រឡះចេញពីអានុភាពសិល្បឥណ្ឌានោះ ដើម្បីងាកមកចូលក្នុងមាគ៌ានៃការកសាងជាបែបរបស់ខ្លួនវិញ ។

រជ្ជកាលនៃព្រះចាន់សុរ្យវរ្ម័ន ២ បានតាំងនៅអស់រយៈពេល ៣៦ ឆ្នាំ (១១១៣-១១៤៩) ប្រាសាទអង្គរវត្តជាស្នាព្រះហស្តនៃព្រះអង្គ ។ គឺព្រះអង្គនេះហើយដែលបានឡើងត្រង់កដសម្បត្តិ ដោយសារតែទ្រង់ធ្វើការប្រយុទ្ធ ព្រះអង្គទ្រង់ការពារប្រឆាំងនឹងការលុកលុយមិនឈប់ឈរនៃពួកចាម អ្នកជិតខាង ក៏ដោយតាំងពីប្រយុទ្ធដែរ ព្រោះតាំងពីយូរណាស់មកហើយ ដែលចាមមានគោលបំណងនឹងដណ្តើមយកព្រះអង្គពីជាណាចក្រដ៏មានអំណាចនេះ ។ ព្រះមហាក្សត្រខាំងឡាយជាតំណពីព្រះចាន់សុរ្យ-

វ៉ែន ទ្រង់ចាត់ឲ្យស្តេចធ្វើសង្គ្រាមជាមួយ ប្រទាំងនឹងពួកចាម។ ។ មាន
ព្រះរាជបាយាទមួយព្រះអង្គនៃព្រះរាជបល្ល័ង្កខ្មែរ ទ្រង់ចាត់ការប្រយុទ្ធ
ក្នុងចំណោមទ័ពស្រុចនៅតាសនៃការរុករានរបស់ពួកចាម។ ព្រះអង្គនេះ
ឥតចានសោយរាជ្យ មិនមានព្រះហានុភាពសក្តិជាអ្វីក្នុងព្រះរាជអាណាចក្រ
ទេ ហើយមិនយូរប៉ុន្មាន ទ្រង់ក៏កៀសព្រះអង្គចេញពីឆាកនយោយ ព្រម
ទាំងពីព្រះបរមរាជវង្សផងដែរ។ ។ ក្នុងរយៈកាលប្រមាណជាង ១០
ឆ្នាំ ទ្រង់ចានជ្រាបអស់នូវសេចក្តីទុក្ខព្រួយកើតអំពីការលុកលុយរាតត្បាត
ផ្សេង។ ។ ទ្រង់ចានស្តេចចេញធ្វើព្រះរាជដំណើរទស្សនាក្នុងប្រទេស
ដោយប្តូរព្រះអង្គជាមនុស្សធម្មតា ហើយទ្រង់ចានឃើញច្បាស់នូវ
ជីវភាពនៃជនសាមញ្ញទាំងឡាយ។ ព្រះអង្គមានព្រះជន្ម ៥០ ឆ្នាំហើយ
ទ្រង់មានការពិសោធន៍ មានព្រះហឫទ័យស្ងួតបួត សុភាពរាបសា តាម
ការណ៍ដែលទ្រង់ចានបួលស៊ីបក្នុងព្រះពុទ្ធសាសនា។ ក្នុងរយៈកាល
ប៉ុន្មានឆ្នាំក្រោយមក ទ្រង់ស្រាប់តែចានឡើងជាឥស្សរជនដ៏ធំបំផុតក្នុង
ប្រវត្តិសាស្ត្រខ្មែរ។ តមក ឥស្សរជននេះមិនគឺអ្នកណាក្រៅពីព្រះចាន
ជយវ៉ែនទី ៧ ឡើយ ទ្រង់សោយរាជ្យពីឆ្នាំ ១១៨១ ទៅឆ្នាំ ១២០១។

នៅសម័យនោះ ខ្មែរនឹងចាមប្រយុទ្ធគ្នាយកស្លាប់រស់។ តាមដើម
គោក ចាមទទួលបរាជ័យ ហើយចានប្រែក្លាយជាបុរីក្រោយអង្គរ
គឺវាចានដឹកនាំទ័ពតាមទូកដោយសម្ងាត់ ចេតប្រាសទន្លេមេគង្គ ឆ្ពោះមក

ខេត្តសាច ។ នៅឆ្នាំ ១១៧៧ កងទ័ពដើនទឹកបានមកចោះយុទ្ធ
ដោយលួចលាក់ នៅពីខាងក្រោយទីក្រុងដែលគ្មានការប្រុងប្រៀបសោះ។
ខាងក្រោយពីការប្រយុទ្ធស៊ីសាច់មក អង្គរក៏ត្រូវខូលបរាជ័យ រួចត្រូវ
បង្ខាំមិត្រូវន់ដណ្តើមយកសម្បត្តិទ្រព្យ ទឹងចំផ្លេចចំផ្លាញចោល ។ នៅ
ឆ្នាំ ១១៨០ ពួកចាមក៏ដកខ្លួនថយទៅវិញ ហើយនាំយកទៅជាមួយផង
ខ្លួរបស់របរជាច្រើន ព្រមទាំងអ្នកទោសទាំងឡាយ ព្រោះវាយលុកឡាស់
ថាខ្មែរអស់ហានករម្រើករហើយ ។

តែមិនមែនដូច្នោះឯណា ដំណើរការណ៍ស្រាប់តែប្រែត្រឡប់ផ្សេង
ទៅវិញ គួរជាទីអស្ចារ្យពន់ពេកក្រៃ គឺថាព្រះកងណាចក្រខ្មែរត្រូវមាន
ជ័យជំនះឡើងវិញ ។ រឿងនេះជាហេតុមួយដែលបញ្ជាក់ឲ្យឃើញច្បាស់នូវ
កស្តូតាងនៃថាមពលដ៏រឹងមាំរបស់អារ្យធម៌ខ្មែរទើងជាកស្តូតាងដែលបញ្ជាក់
ឲ្យឃើញម្យ៉ាងទៀតថាការត្រឡប់មានកំណើតឡើងវិញនេះ គឺជាភួងនូរ
នៃមហាប្រជាពលរដ្ឋតែម្តង ។ ពេលនោះ ព្រះបាទជយវរ្ម័នទី ៧ ទ្រង់
កាន់បង្គំតនៃព្រះកងរដ្ឋាភិបាល ។ មិនឆ្ងាយពីប្រាសាទអង្គរវត្តប៉ុន្មាន
មានព្រះពុទ្ធរូបមួយបានផុះឡើង គឺអង្គរធំ ។ ទ្រង់បានកសាងព្រះពុទ្ធ-
រូបនេះ ដោយមានកំផែងសិលាកម្រាស់ ៧ មែត្រព័ទ្ធជុំវិញ ដើម្បីការពារ
នឹងការលុកលុយដ៏យ៉ាងរហ័ស ។ ឯការធ្វើរបៀបនេះ ជាគ្រាលើកដំបូង
បង្អស់ក្នុងប្រវត្តិសាស្ត្រអង្គរ ។ ដីវាគាតកំត្រឡប់មានដំណើរប្រព្រឹត្តទៅ

ជាធម្មតាឡើងវិញ ។ រដ្ឋកាលនៃព្រះបាទជយវរ្ម័នទី ៧ មានសភាពដ៏ខ្លី
យូរ (ប្រហែល[1]៤០ ឆ្នាំ) ។ សេដ្ឋកិច្ចនៃប្រទេសបានត្រូវរីកចំរើនឡើង
ជាថ្មី ។ ក្នុងតំបន់អង្គរ មានប្រជាកសិករចំនួនមួយលាននាក់ ។ ចំណែក
របៀបបង្ហូរទឹកជាក់ស្តែង ក៏បានត្រឡប់មានជាថ្មីឡើងវិញដែរ ។ គេ
កសាងប្រាសាទសុទ្ធសឹងតែក្រាលថ្ម ។ ព្រះវិហារ សាលាសំណាក់ពេលកត្រី
ជម្រកសម្រាប់បូជនីយសក្ខីនឹងឈ្មួញ ដុះដូចផ្សិតនៅហូរហែតាមថ្នល់
ចាំងឡាយ ។ តាមប្រវត្តិសាស្ត្រជាន់ចាស់ថាមានការកសាងមន្ទីរពេទ្យ
ដល់ទៅ ១២០ ខ្នងផង ។ ព្រះបរមរាជក៏ដ៏ ឆ្លាតវៃ ភ្លឺ
ចិញ្ចាចចិញ្ចែង តោះតេញដោយព្រះមហាកិត្តិយសរកអ្វីប្រៀបគ្មាន ។
ព្រះពុទ្ធសាសនាមិនបានធ្វើអ្វីឲ្យមានការប្រែប្រួល ចំពោះរឿងស្តីពីការ
ទុកព្រះមហាក្សត្រជាទេពតាឡើយ ហើយព្រះមហាក្សត្រទ្រង់តែង
អនុញ្ញាតឲ្យប្រជាកសិករក្រីក្រចូល[2]ក្រាបបង្គំគាល់ជាធម្មតា ដើម្បីថ្វាយ
សេចក្តីសុខទុក្ខថ្វាយព្រះអង្គទ្រង់ជ្រាប ។ សិលាចារឹកពោលអំពីព្រះបាទ
ជយវរ្ម័នទី ៧ ថា : ។

---

១. សេចក្តីព្រាងនេះ ហាក់ដូចជាមិនស្របនឹងសេចក្តីខាងលើដែលថាទ្រង់សោយរាជ្យពី
១១៨១ ដល់១២០១ ។ ២ ដំណើរការស្តីពីការអនុញ្ញាតឲ្យប្រជាកសិករបស់ព្រះអង្គ ចូល
ក្រាបបង្គំគាល់ដើម្បីថ្វាយសេចក្តីសុខទុក្ខថ្វាយ ជាព្រះរាជប្រពៃណីខ្មែរមានមកតាំងពីដំនាន់
អង្គរនេះ គឺជាព្រះរាយការដ៏សែនសប្បុរស ខ្ញុំសូមព្រះមហាក្សត្រប្រទេសនៃទៀមកប្រៀប
ធ្ងឹមតុំបាន ។

" ទ្រង់ឈឺចាប់អំពីជម្ងឺនៃប្រជាកស្ត្រព្រះអង្គ ជាងទ្រង់ឈឺចាប់អំពីជម្ងឺជាស់ព្រះអង្គ " " ដ្បិតថា សេចក្តីទុក្ខនៃប្រជាកស្ត្រ គឺជាសេចក្តីទុក្ខនៃព្រះមហាក្សត្រ "

រឿងនេះ ជាសក្ខីភាពស្តីពីព្រះគុណសម្បត្តិ ដែលមិនសូវមានចំពោះព្រះមហាក្សត្រសម័យស្តេចក្រាញ់ (moyen âge: យុគកណ្តាល) ។

ត្រូវតែសង់ឲ្យមានប្រាសាទមួយទៅអគ្គីរាជ នេះជាទម្លាប់កន្លងក្រុងធំខ្មែរនីមួយ ។ កន្លងសម័យនោះ ។ មានសំណង់ពិសេសមួយអំពីថ្ម ទៅកណ្តាលកំផែងជាទីការពារ ជាមហាសំណង់ចុងក្រោយបង្អស់នៃសម័យខ្មែរអង្គរ ។ ឯមហាសំណង់នេះ គឺប្រាសាទបាយ័ន ។ ប្រាសាទនេះជាចំណុចបង្ហើយនូវការវិវត្តន៍នៃស្ថាបត្យកម្មខ្មែរ ។ សព្វថ្ងៃប្រាសាទបាយ័នបាក់បែកអស់ ។ ទោះបីយ៉ាងដូច្នេះក៏ដោយ គេនៅតែមានគំនិតអាចយល់បាន នូវហេតុដែលថាប្រាសាទបាយ័ន កាលពីដើមនោះយ៉ាងណា . . . ។ មានអ្នកដំនាញការខ្លះពោលថា: ទិដ្ឋភាពប្រាសាទបាយ័នមិនជាបែប ជាគំរូបូជាទិដ្ឋភាពនៃប្រាសាទអង្គរវត្តទេ ។ ប៉ុន្តែបាយ័នក៏ជាស្នាដៃខាងស្ថាបត្យកម្មមួយដ៏តប្រាកដដែរ ដែលមិនគប្បីបំភ្លេចឡើយ ។ បាយ័នជាភ្នំអចម្ងាតិមួយដ៏តធ្វើអំពីថ្ម ដែលមានកំពូលជារាប់សិបលេចប្រដាប់ឡើង ហើយក្នុងកំពូលនីមួយៗ មានមុខព្រហ្មបួនដ៏សម្បើម បែរទៅគ្រប់ទិសទាំងបួន ។ បាយ័នជាប្រាសាទមួយដ៏

ចម្លែកផ្សេង ហើយទៅអង្គុះ គឺប្រាសាទចាយ័ននេះហើយជាលើកដំបូង ដែលគេដឹងថាទៅមានជាតិឬទាំងស្រុង ។ គេនិយាយទៀតថា ការញាញីមនៃមុខព្រហ្មដ៏សម្បើមនៅប្រាសាទចាយ័ន នាំឱ្យនឹកដល់ព្រះភក្ត្រនៃព្រះបាទជយវរ្ម័នទី៧ ។ ចំពោះរឿងនេះ អ្នកទស្សនាមិនអាចបំភ្លេចបានឡើយ ។

ដំបូង ដួងព្រលឹងរមែងពោរពេញដោយចិត្តសោមនុស្សនឹងដោយការកោតសរសើរ កាលណាគេត្រាន់តែដើរកាត់ប្រាសាទទាំងឡាយទៅអង្គុះ ។ រួចមានបញ្ហាមួយចោទឡើងដល់គំនិតថា : មនុស្សទាំងនោះដែលបានធ្វើឱ្យកើតមានការដ៏ធំច្រើនដូច្នេះ ដែលបានធ្វើឱ្យកើតមានជាមតលទាំងការបង្កើតច្រើនដូច្នេះ តើមានជីវភាពដូចម្តេច ? កាលគេកសាងប្រាសាទទាំងនោះ ដើម្បីជាបច្ចាមរណកិត្តិយសដល់ព្រះមហាក្សត្រនៃអាត្មា តើគេគិតឃើញដូចម្តេច ហើយគេមានអារម្មណ៍ដូចម្តេច? មួយទៀត ចុះហេតុអ្វី ក៏គេមិនកសាងប្រាសាទទាំងនោះទុះ ដើម្បីជាកិត្តិយសដល់ខ្លួនកោសល្យដ៏ឆ្នើមអស្ចារ្យរបស់ខ្លួនផង ទឹងដល់កម្លាំងយកចិត្តទុកដាក់ធ្វើមិនចេះខ្សោយហត់រសាយខ្លួនផង ? តើបែបសង្គមសម័យនោះដូចម្តេច តើសង្គមសម័យនោះ បានធ្វើការតែបញ្ជាប់ញ៉ាំដូចម្តេច ហើយបានធ្វើការប្រយុទ្ធយ៉ាងណា ? ការណ៍ទាំងនេះ ពិតជាអាចបញ្ជាក់ឱ្យយើញពីបានក្នុងការស្តាយបានប្រាសាទទាំងនោះដែរ ព្រោះប្រាសាទ

ចាំងឡាយជាតំណាងវត្ថុធាតុនៃសង្គមសម័យនោះ គេរមែងដឹងថាសិល្ប-
ការត្រប់សម័យ តែងធ្វើដោយយកលំនាំជាន់ក្នុងពីមនុស្ស ទើងពីវត្ថុចាំង
ឡាយដែលនៅដុំវិញខ្លួន ។ ត្រូវយើងនិយាយដូច្នេះទៀតថា: បែបនិង
និមិត្តរូប គឺជារូបភាពមួយដោយចំពោះ ឬមិនចំពោះដែលតាក់ជាប់ទៅ
នឹងការណ៍ដែលមានពិតប្រាកដ ។ ដំរីភាពសម័យនោះ សឹងប្រកបតែ
ដោយប្រយោគ ដោយពិធីបុណ្យផ្សេង ។ ទើងដោយសេចក្តីស្នេហា ។
គេពោលជាញឹកញាយតែអំពីការញាំមចម្អែក ដែលផ្សាយចេញពីស្នាដៃ
ខាងវេទនានៃអង្គរ គឺជាការញាំមដែលគេមិនអាចរកអ្វីមកប្រៀបផ្ទឹម
បាន ។ ការញាំមនេះមានសភាពដ៏មុតស្រួលស្រៀវក្រៃលែង តែមិន
មែនជាការញាំមនៃអមនុស្សនៅឡើយទេ ។ ចំពោះរឿង
នេះ មិនត្រឹមតែការញាំមប៉ុណ្ណោះទេ គឺមានរបាំងនៃអង្គរផងថែម
ទៀត ! ប្រសិនបើគេអាចយករបាំងនេះចេញបាន នោះរឿងអាថ៌កំបាំង
នៃអតីតកាលដ៏ពិតប្រាកដរបស់អង្គរ ប្រហែលជាទើងអាចលេចមានពន្លឺ
ឡើងបាន ។

ឯក្នុងចេះធ្វើឲ្យមានការរំភើបដែរ គ្រោះនៅត្រង់ទ្វារមួយនៃប្រា-
សាទអង្គរវត្ត មានការចងភ្ជាប់តែងជារូបភាពស្តីពីស្នានសួគ៌ ទើងស្នាន
នរក ។ ចំណែកស្នានសួគ៌ គេចងាមានចំនួនដ៏ច្រើនសោះតក្រោះបន្ទប
តែឯការធ្វើទុក្ខទោសខាងស្នានរកវិញ គឺជារូបសំណាកដ៏ពិតរបស់លោ

ធម្មជាតិនិយមតែម្តង ។ តើឡាំងចម្លាក់ទាំងនេះ គេធ្វើសម្រាប់អ្នកណា? តើសិលាចារឹកទាំងនេះ គេទុកសំរាប់អ្នកណា ? ព្រោះសិលាចារឹកទេះមិនមានន័យថាការសាសន៍ស្រ្តីតទេ គឺនិយាយថាការខ្វែរជាន់ចាស់ដូច្នេះថា :

" ស្តាយនរក : ការធ្វើទោសបំបែកឆ្អឹង ចំពោះជនណាដែលបំផ្លេច
" បំផ្លាញសួនច្បារ ដែលធ្វើអន្តរាយដល់ទីលំនៅ រហូតទឹក
" អណ្តូងទឹក ព្រះវិហារ . . . ។

" ស្តាយនរក: ការធ្វើទោសដោយយកទៅស្មូរក្នុងឡាំងខ្លះ ចំពោះ
" ជនណាដែលបានគៃបំបាត់យកព្រះពរជ្រៃ ដែលលួចជ្រៃ
" គ្រូ ទីឆ្ងាយពួកព្រាហ្មណ៍ទាំងឡាយ . . . . ។

" ការធ្វើទោសដោយយកទៅឆ្អែរលើឆេីកក្តៅ ចំពោះជនណា
" ដែលមិនសងបំណុលគេ . . . ។

" ការចងព្យួរនឹងដើមឈើមានបន្លា (រកា?) ដល់អ្នកធ្វើសាក្សី
" កោង . . . ។

" ការធ្វើទោសគួរឲ្យស្រួបស្បែងជាងគេនៅស្តាយនរក គឺនរកដង្កូវ
" ចំពោះជនណា ដែលប្រមាថមើលងាយព្រះអាទិទេព ពួក
" ព្រាហ្មណ៍អ្នកចេះដឹង តាមាបិតានឹងមិត្តសំឡាញ់ . . . "

លុះតែកន្លងពេលនេះ ទើបអនុសញ្ញារំយោនៃដីវតាកួន អ្នកការខ្លួនចិន

អមព្រះមហាក្សត្រខ្មែរ (១៦៤៦) ហើយដែលបានអាស្រ័យនៅប្រ-
ហែលមួយឆ្នាំទាអង្គរធំ មានន័យពេញលក្ខណៈ ។ កសុតាង៉ជាលាយ
លក្ខអក្សរនេះ ជាប្រភពតែមួយដែលសម្រាប់ឲ្យគេអាចក្រេបយកបាន
ខ្លះដំណើរការណ៍ចាំង៉ឡាយស្តីពីជីវភាពក្នុងសម័យនោះ ។ ជីវតាកួន
មិនសង្កេតតែត្រឹមជីវភាពនៅព្រះពជ្រាំងប៉ុណ្ណោះទេ តីបានសង្កេតពិនិត្យ
ចាំង៉ជីវភាពនៅតាក្រុងផង ។ មុនពេលដែលគេរកឃើញអង្គរ នៅប្រ-
ទេសអឺរ៉ុប គ្មានឧណាយកចិត្តទុកដាក់ជាខ្លាំង ចំពោះអនុស្សាវរីយ៍ជា
លាយលក្ខអក្សរបស់ជីវតាកួនឡើយ ។ សព្វថ្ងៃនេះ ទើបគេដឹង៉ថាជីវ-
តាកួន មិនបានតាក់តែង៉ មិនបានបំផ្លើសអ្វីបន្តិចបន្តួចសោះ ។

ជីវតាកួនន៉ិយាយថា :

ខ្មែរអ្នកស្រែប្រតស្រូវបី ឬបួនដង៉ក្នុង៉មួយឆ្នាំ ។ តើត្រូវឲ្យប្រជា
ភស្តុចិញ្ចឹមជីវិតដោយប្រការម្តេចទៅវិញ ក្រៅពីរបៀបនេះ ?

ជញ្ជាំង៉ប្រាសាទសឹង៉តុបតែង៉លំអដោយរូបគំនូរផ៉ាត់ពណ៌ ដំបូល
ក្រឡឹមនៃកំពូលប្រាសាទបិទសុទ្ធតែមាសសន្ធឹក ។

គេបានឃើញស្នាមក្រហមផ្ទៅ នៅត្រង់កន្លែង៉កំពាំង៉ខ្លះនៃប្រា-
សាទអង្គរ ។

ព្រះមហាក្សត្រ លុះតែព្រះអង្គទ្រង់គ្រឿងក្រោះដែលមុខកាប់គក់ក្តី
ព្រួញក្តី មិនអាចធ្វើឲ្យព្រះអង្គរបួសបាន ដើមទ្រង់ស្តេចយាង៉ចេញពីព្រះ

បរមេកជក់ធំ ។ ព្រះអង្គទ្រង់ព្រះមួជមាស ផ្ចង់ព្រះកេសាលំអដោយកួងមាលាដំឃាំងក្រអូបដូចផ្កាម្ទិះ ។ ព្រះសុវណ៌ទ្រង់កងគជទម្ងន់ប្រហែលបីនាឡិ ។ កព្រះហស្ត ទំង់តួព្រះហស្ត លំអដោយគ្រឿងអលង្ការមាសជាតួងដ៏មានដំឡៃ ។ ព្រះអង្គទ្រង់ព្រះខ័នមាសផង នៅវេលាដែលទ្រង់ស្តេចចេញពីព្រះបរមេកជក់ធំ ។ ក្បួនហែព្រះអង្គ មានសកាតដូចគ្នាបេះបិទ ទំង់រូបភាពនៅផ្ទាំងចម្អាត់ជាងឡាយ ។ ព្រះខ័នមាសជានិមិត្តរូបនៃព្រះពជ្ឈាធិបតេយ្យ គេដំកល់ទុកនៅព្រះពជ្ឈានីភ្នំពេញសព្វថ្ងៃ ។

រឿងប្រើខ្ញុំកំជរ មានគ្រប់ទីកន្លែង មានតែអ្នកក្រខ្សត់ទេដែលគ្មានខ្ញុំកំជរប្រើ ។ ការជំរះក្តីនៃតុលាការ ច្រើនមានទម្រង់ជាតុលាការដោយយកទេពតាជាប្រធាន ។ ការពិន័យទោសមានសកាតដ៏តឹងរឹងណាស់: សម្លាប់ក្មាម ។ កាត់ដៃកាត់ជើង ឬកប់ពាក់ស៊ង ។

នេះហើយជារឿងដែលដីតាកូនបានឱពាទ ។ គឺពិតជាមួយរយឆ្នាំតត់ មុនពេលដែលគាត់មកដល់អង្គរ ដែលសិល្បករខ្មែរបានឆ្លាក់រូបភាពដែលមានក្តីសៀវភៅរបស់គាត់ នៅទីដ៏ជញ្ជាំងចាយ័នជាប្រាសាទដែលអ្នកមិនគោរពសាសនា មិនអាចចូលដល់បាន ។ រូបភាពនេះជាផ្នែកដ៏មានដំឡៃបំផុតនៃប្រាសាទចាយ័ន ដែលជាឃ្លាំងមានដំឡៃខាងប្រវត្តិសាស្ត្រដ៏ពិតប្រាកដ ។ ជាងបានយករឿងធាតដ៏តែនៅតាមថ្នល់ទីឆ

ទីលំនៅដ៏គ្រោតគ្រាត មកផ្ទាក់ខ្ពុកនៅប្រាសាទបាយ័ន ហាក់ដូចជាខ្លួន
ខើបនឹងមានសេរីភាពភ្លាម អំពីការអនុស្សាវរីយ៍អស់ទាំងសាសនា ។ ជា
លើកដំបូង នៅប្រាសាទនោះ គេឃើញរូបភាពនៃស្ត្រីសាមញ្ញ រូបកូន-
ក្មេង ផ្សារកំពង់លក់ដូរ ភាពពិតប្រាកដនៃទីលំនៅ ហើយមិនតែប៉ុណ្ណោះ
មានទាំងការប្រជល់មាន់ មានសិល្បករគោចរកំពុងសំដែងរឿងផង ...។
រឿងចាញ់សង្គ្រាមប្រដាំងនឹងចាមក៏នៅរស់រវើកកន្លងតំនិតដែរ ។ នៅផ្នាំង
ចម្ងាក់នៃប្រាសាទបាយ័ន គេឃើញរូបភាពផ្សេងច្រើនទៀត តែរូបភាពមិន
ត្រឹមតែស្តីអំពីសេចក្តីអង់អាចក្លាហាន ទឹងជោគជ័យនៃមេទ័ពប៉ុណ្ណោះទេ
មានទាំងការប្រយុទ្ធគ្នារវាងទាហានម្ខាក់ទល់នឹងម្ខាក់ សេចក្តីទុក្ខព្រួយនៃ
ប្រជាពស្ត្រផងថែមទៀត . . . ។ នេះជាលើកដំបូងហើយ ដែលរូបភាព
នៃការពិតការមែន ចាន់ច្រៀតចូលកន្លងស្រមោលព្រឹល ។ នៃប្រាសាទ
នៅអង្គរ ។

កាលដែលអ្នកការទូតចិន ទាន់ត្រាយការសំណាក់អស្រ័យនៅ
មួយឆ្នាំ ចាន់ចាយចេញពីប្រទេសនៅ អានុភាពនៃព្រះអធិរាជ ណាចក្រ
ខ្មែរ ចាន់ឡើងដល់កំពូលហើយ ។ ឯការរស់នៅនៃប្រជាពលរដ្ឋ ចាន់
ប្រព្រឹត្តទៅស្រួល តែដោយសារលទ្ធផលដ៏ណាចជោគជ័យពីអតីតកាល
របស់ខ្លួនប៉ុណ្ណោះ ។ គេមិនដឹងខ្លួរហេតុដ៏ជាក់ច្បាស់ដែលបណ្តាលឲ្យ
ដីរាជាខោមង្គលវិនាសសាបសូន្យ នៅសតវត្សទី ១៥ ឡើយ ។ ប្រហែល

ទីតាំងនៃព្រះពុទ្ធជាទី ស្ថិតនៅជ្រុលទៅទិសពាយព្យពេកក៏មិនដឹង ដែលជាហេតុទាំឲ្យគ្មានចិហ្នរទៅកេការលុកលុយរាតត្បាតនៃពួកថៃ មានចំនួនច្រើនជានិច្ចនោះ ។ ប្រហែលមកពីមានទឹកដីនៅ មានពុះកញ្ជ្រែងមានជម្ងឺរាតត្បាត ធ្វើឲ្យអន្តរាយដល់ប្រជាពលរដ្ឋខ្មែរដឹង? ព្រោះគ្រានៅតែមានការប្រហែសបន្តិចក្នុងកិច្ចថែរក្សាទូវរបៀបដ៏សំខាន់ខាងពិធីបញ្ចូលទឹកជាក់ស្តែង អាចកំហែងគំរាមដល់ផលដំណាំចាំងឡាយបាន ។ រឿងសាបសូន្យនេះបណ្តាលមកពីដំលោះគ្នាឯង ទំនឹងមកពីការប្រយុទ្ធនៃវណ្ណៈក៏សឹងថាបាន ។ ប៉ុន្តែរឿងមួយដ៏ពិតនោះ គឺនៅត្រង់ដែលទីក្រុងចាន់ត្រូវរំលើទៅទិសបូព៌ ហើយជាអវសាន មកដល់ទីកន្លែងបច្ចុប្បន្នគឺក្តេញនេះឯង ដែលជាព្រះពុទ្ធជាទីប្រទេសកម្ពុជាសព្វថ្ងៃ ។

អង្គរតំណាងតែឆាតុសកម្មមួយនៃប្រពៃណីជាតិសព្វថ្ងៃ ។ គេយកបូបអង្គរវត្តមកធ្វើជាទង់ជាតិប្រទេសកម្ពុជា ។ ហើយសិល្បៈខ្មែរសោតរមែងស្ថិតនៅអាចិន្ត្រៃ ជាសម្បត្តិដ៏ប្រសើរថ្លៃថ្លាមួយកាត សម្រាប់ចូលរួមកង់អំណោយជាកេរ្តិ៍ខាងវប្បធម៌នៃមនុស្សលោក ។

ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ « ក »

(តមក)

Acquérir à titre gratuit	ជានដោយទេ	(ព.ប្ប.) ។
Acquisition à titre gratuit	ការជានដោយទេ	(ព.ប្ប.) ។
Action en nullité	បណ្តឹងសុំឲ្យទុកជាមោឃៈ	(ព.ប្ប.) ។
Aliéner à titre onéreux	ផ្ទេរដោយចេញថ្លៃ	(ព.ប្ប.) ។
Aliéner à titre gratuit	ផ្ទេរដោយទេ	(ព.ប្ប.) ។
Annuler (v.t.)	ធ្វើមោឃកម្ម	(ព.ប្ប.) ។
Annulation (n.f.)	មោឃៈកម្ម	(ព.ប្ប.) ។
Aveugle (abj.)	ខ្វាក់ ។	
Assistance judiaire	គុណការសង្គ្រោះ	(ព.ប្ប.) ។
Astreintes (n.f. pl.)	ជ្រាក់បង្ខំ	(ព.ប្ប.) ។

— B —

Biens communs	ទ្រព្យរួម	(ព.ប្ប.) ។
Biens propres	ទ្រព្យដើម	(ព.ប្ប.) ។

— C —

Casser ou annuler un jugement ou un arrêt	បដិសេធសាលក្រម ឬសាលដីកា	(ព.ប្ប.)។
Cause de divorce	បុព្វហេតុនៃការលះលែងគ្នា	(ព.ប្ប.) ។
Cécité (n.f.)	ភាពខ្វាក់	(ព.ប្ប.) ។

(នៅមានត)

វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង . ខាត់ រៀបរៀង

(តមក)

អតិគ្គយ, ពុំ. ភាពច្រើន, ។ *អតិគ្គយម៑ អតិគ្គយេន អតិគ្គយតន៑* ដោយច្រើន ។ *អតិគ្គយវន្ត* គុ. ដែលមានភាពច្រើន ។

អតិគ្គយន អតិគ្គយនី គុ. ដែលប្រសើរកន្ទុង, ឧត្តម ។

អតិគ្គយិត គុ. ដែលថ្លៃថ្នាកន្ទុង ។

អតិគ្គយិន៑ គុ. ដែលខ្ពង់ខ្ពស់ ដែលថ្លៃថ្នាកន្ទុង ។

អតិគ្គស្ត្រ គុ. ដែលមានអាវុធក្រៃលែង ។

អតិគ្គាត គុ. ដែលរឹកាយក្រៃលែង ។

អតិគ្គាយន ឧបុំ. ការយោខ្ពង់ខ្ពស់ក្រៃលែង ។ គុ. ដែលខ្ពង់ខ្ពស់កន្ទុង ។ *អតិគ្គាយិន៑* គុ. ដែលប្រសើរកន្ទុង ។

អតិគិគិរ គុ. ដែលត្រដាក់ក្រៃលែង ។

អតិគិម្ប៑ ឆាគុ. សល់នៅ ។ *អតិគិម្ប* គុ. ដែលសល់នៅ ។

អតិគី ឆាគុ. ហោចក្រៃលែង ចោះបង់ចោល លះបង់ចោល ។

(នៅមានត)

ភាគ ទី ៤៨

ទេសនាវិបុលភជសេនា ន្ធ-កាន ប្រៃរៀបរៀង

(ត្រមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃធ្លាសបើបានអាន
> ទំនិរបេះទយាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិ
>
> ——ឃ្លោ - អ៊ុន

ចូឆូកំយកក្រយ៉ាកាត់ពុកមាត់ពុកចង្កាអស់ ក្នុងហានម៉ាឈៀវស្រែក ថា ចូឆូកាត់ពុកមាត់ពុកចង្កាអស់ហើយ ឲ្យចាប់ខ្លួនអាពុកមាត់ខ្វិឲ្យបាន ចូឆូកំយកវែកកន្ទុយខន់ទុំចង្កាហើយចំផាយសេះចេញទៅ ម៉ាឈៀវបំ. ផាយសេះតាម ចូឆូក្រឡេកមកឃើញម៉ាឈៀវតាមពីក្រោយក៏យណាស់ ភ្លាត់ធ្លាក់ពីលើសេះតំបូលទៅអែបផ្ទាប់តស៊ល់ឈើមួយ ម៉ាឈៀវតំបង្គំសេះ ស្ទុះបូលទៅជិតលើកលំពែងពួយទៅ មិនត្រូវចូឆូក៏ត្រូវដើមឈើផាប់លំ. ពែង ចូឆូក៏គេចស្ទុះតំរួចពីទីនោះបូលទៅកន្លែងព្រៃ ម៉ាឈៀវស្ទុះទៅដក យកលំពែងបាន ហើយដេញតាមចូឆូទៅទៀតជិតនឹងខាន់ ខ្លួលចោ ហង់ឋរសេះមកតាំង កំតំងតែប្រយុទ្ធគ្នានឹងម៉ាឈៀវបាន ៥០០ ភ្លេង

ហៅហ៊ូអៀនឃើញចោរហាន់ខ្លាំងណាស់ ក្រែងថ្លស់ការនឹងម៉ាឈៀវ
ក៏បរសេះចូលទៅជួយ ម៉ាឈៀវគិដេញហួសផុតពួកខាហានទៅតែម្នាក់
ឯង មិនខុកចិត្តក៏ញាក់សេះវិលថយមកក្រោយវិញចូលបន្ទាយគុនគួន
ចូឆូក៏ត្រឡប់ចូលបន្ទាយ តាំងកំជាប់ពលខាហានឲ្យយាមល្បាតប្រយ័ត្ន
ការជាមាំមួន មិនឃានចេញតនឹងម៉ាឈៀវ ហើយកំលើកសេចក្តីគាប់
ប្រសើរដេលចោហាន់ឲ្យបានបំណាច់ភ្លាំនាំជាច្រើន ។

ឯម៉ាឈៀវក៏ចាត់ការប្រុងប្រៀបខាហាន ដើម្បីនឹងចេញទៅវាយ
យកបន្ទាយចូឆូទៀត តែឃើញថាចូឆូប្រយ័ត្នការមាំមួនមិនបានចេញត
ម៉ាឈៀវក៏ឲ្យផ្ទាស់ប្តូរខាហានទៅស្រែកដេរបញ្ជីចិត្តចូឆូ នៅមុខបន្ទាយ
តាំងយប់ថ្ងៃមិនដាច់ ខាហានចូឆូឮដូច្នេះខឹងណាស់ គិតគ្នានឹងលើក
ចេញមកតយុទ្ធនឹងម៉ាឈៀវ ។

ចូឆូនិយាយយកចិត្តខាហានតាំងពួងថា ដែលម៉ាឈៀវឲ្យមកដេរ
បញ្ជីចិត្តដូច្នេះ ប្រាថ្នាថ្នមឲ្យយើងក្តៅក្រាំនៅស្រុកមិនបាន បើយើងនឹង
លើកខាហានចេញទៅតវាយនេះ គឺដូចជាចាញ់ប្រាថ្នាម៉ាឈៀវ អ្នក
តាំងពួងចូរជួយគ្នាគិតតែរក្សាបន្ទាយកុំឲ្យអន្តរាយសិនចុះ ការដែលនឹង
គិតយកជ័យជំនះនោះ ជាភ្នាក់ងារលើយើង បើអ្នកឯណាមិនស្តាប់
យើង ខំតែលើកគ្នាចេញទៅតនឹងម៉ាឈៀវ យើងនឹងកាត់ក្បាលចេញ ។

ខាហានតាំងពួងឮដូច្នោះ ក៏នាំគ្នាថយចេញទៅ ហើយនិយាយគ្នាថា

ពីដើមមហាឧបាគនឹងចេញធ្វើការណែនាំសង្គ្រាម កំអង់អាចមិនចេះខ្លាច
សោះ មានតែចេញទៅមុខបង្អស់ ដូចគ្មានញញើតអ្នកឯណា រំលេះនេះ
ទើបឃើញថាមហាឧបាគខ្លាចថ្លើដែរ៉ាំឈៀវ សូម្បីតែរ៉ាំឈៀវឲ្យមនុស្ស
មកស្រែកដេរប្រមាថដល់មុខបន្ទាយក៏នៅស្ងៀមបាន កន្លងមក ៣ ថ្ងៃ
ទាហានចេញទៅស៊ើបការវិលមកជំរាបបច្ចួថា ឥឡូវមានទាហាន
ម៉ាំឈៀវលើកមកថែមទៀតពីមុន បច្ចួពួកដូច្នោះក៏គិតថា ពីស្រុកសៃ-
លៀនទើបមកដល់បន្ទាយតុងគួននេះ គឺជាផ្លូវឆ្ងាយជាច់ស្រយាលណាស់
ម៉ាំឈៀវមានកម្លាំងខ្លាំងពូកែមែន តែនៅក្មេងសេចក្តីខ្វិតខ្វិនគ្រាជ្រាជ្រមិន
ធ្លាប់កាន់ការដំរោះ ចាំងមិនទាន់ចំណានចេះផ្ទាស់ប្តូរយកចិត្តទាហាន
ចាំងពួង ឃូរទៅស្ងៀងអាហារកើតដំណើរជាច់ពុះ មុខជាទាហានកងចំ-
ណុះទើរប្រែចិត្តចេញពុំខាន យើងក៏ទើរបានធ្វើការតេញដៃ បច្ចួនិយាយ
ទើរទាហានចាំងពួងថា ដែលទាហានម៉ាំឈៀវបញ្ជូនមកទៀត ២ ម៉ឺននោះ
យើងមានអំណរណាស់ ទើរតែយកជ័យជំនះឲ្យបាន ។

មានមួយថ្ងៃនោះ ពេលព្រឹក មានចំរើមកជ្រាបច្ចួថា ទាហានម៉ាំ-
ឈៀវបញ្ជូនមកទៀតច្រើនណាស់ បច្ចួពួកដូច្នោះក៏អស់សំណើចហើយថា
ការសង្គ្រាមគ្រានេះ យើងមុខជាយកជ័យជំនះឲ្យបាន ហើយក៏តែងតុ-
លៀងអាហារបណ្តាសេនាទាហានឡើកជាការចាំងពួង ពេលកំពុងសេព
សុកនោះ ពួកទាហានក៏ទាំងគ្នាតំរែះដល់ការសង្គ្រាមដែលបច្ចួពួកញញើត

ខ្លាចមាំឈៀវហើយក៏នាំគ្នាញញឹម ចូធូក្លែងសួរសង្កិនច្រាថ្នាំធំឯចង់ឲ្យស់ចិត្តធំឯតំនិតសេនាគាហានចាំឯពួងថា អ្នកចាំឯពួងញញឹមឲ្យយើងឬអ្វី? ប្រហែលអស់អ្នកលក់គ្នាសំគាល់ថា យើងនឹងចាញ់ថ្នាំដៃមាំឈៀវអស់តំនិតគិតហើយឬ? តើសេចក្តីគិតនៃអ្នកចាំឯពួងនឹងរិះគិតដូចម្តេច? ដែលនឹងយកជ័យជំនះបាន ក៏ចូរប្រាប់មកឲ្យយើងដឹងចុះ ។

ស៊ីឡុងធ្វើយថា ដែលមហាឧបាដៅក្បាលនាយនេះឲ្យខ្លាប់មាំមួនខ្លោះក៏ជាការប្រពៃណាស់ តឲ្យមាំឈៀវកំតាំងនៅក្នុងបន្ទាយតុងគួនមានចិត្តកំរើបគ្មានសេចក្តីភ័យការតោរផ្លូវក្រោយទេ សូមឲ្យមហាឧបាដចាត់ឲ្យហានឲ្យលើកទ័ពទៅចាំស្ទាក់ស្ទះផង ហើយខ្លួចាប់ពីក្រោយមកវិញដើម្បីឲ្យមាំឈៀវវៃផ្ទៃឯងសូន់ខាងក្រោយ ហើយសឹមយើងលើកទ័ពខ្លួចាប់ហើយយកបន្ទាយតុងគួនវិញ តង់ទំធំបានដោយងាយ ចូធូឮដូច្នោះក៏ក្លែងធ្វើយតបទៅស៊ីឡុងវិញ ដើម្បីមិនឲ្យមនុស្សចាំឯពួងមើលងាយច្រាថាយល់តាមតំនិតគេ ថាតំនិតអ្នកឯងដែលនិយាយនេះ ត្រូវតំនិតខ្ញុំដែរតែថាមិនទាន់ច្បាស់ប៉ុន្មាន តំនិតយើងយល់ច្បាស់ឯងនេះ យើងត្រូវប្រើឲ្យអ្នកឯងនឹងដូឡែងលើកតលៗ ៣ ថ្ងៃលបចេញទៅ បើឃើញព្រៃនឹងភ្នំឯណាជាផ្លូវមានចំនងស្រួល ក៏ត្រូវឲ្យពួនបង្កប់ទៅចាំនោះ យើងនឹងលើកពលទៅតាមចាំស្ទាក់មុខវិតពីក ហើយនឹងកមកកាយយកបន្ទាយតុងគួនវិញ ខាងអ្នកឯងត្រូវកៀយខ្លួចូលមកតាមខ្លាង ស៊ីឡុងនឹងដូឡែង ខ្លួល

ប្រសាសន៍ហើយលាចូនូវលើកទាហានចេញទៅ ចូនកំប្រើចាយដើនឃុំ
ទាហាននៅក្បែបន្ទាយ ហើយកំនាំចេញដើលើកទាហានតំទៅតាំនត
ខ្លួនចម្បាំនទៅមាត់កំពង់ស្ទឹនហ៊ុយហោនាំនទៅសឹងកើតបន្ទាយតុំនគួន ។

ឯមាំឈៀវ កាលបើដឹំនការណ៍ដូច្នោះកំនិយាយនឹំនហ៊ានស៊ុយនៅ
ទាហានតាំនគួនថា តម្បូវចូនូវលើកទំពៅតាំននៅមាត់កំពង់ ប្រាប្តាំនឹំ
ចាំរាយទំពតំការបស់យើនំ យើយើនំលើកទំពនូនៅត្រើយម្ខាំនចាំស្ទាក់
ផ្លូវស្បៀនឲ្យបាន គនំវិតចូនូនឹំនចាញ់ប្រៀបយើនំប្រាកដ ហ៊ានស៊ុយឆ្លើយ
ថា ដៃលនឹំនលើកទំពៅស្ថាត់ផ្លូវស្បៀននោះយើញមិនស្រួល ព្រោះ
ជាទំកណ្តាលកនំទំពចូនូ ត្រូវយើនំរនំាំឲ្យចូនូនូនឹំមកត្រើយខាំនណោះ
កាលណា សឹមចៅលើកទំពៅទូបំតាំក្រោយ យើនំនឹំឃុំពលទល់តំមុខ
មុខដាចូនូនឹំនបែកខ្ញែកមិនខាន មាំឈៀវឮដូច្នោះកំគិតឃើញត្រូវផង ទើប
ឲ្យទាហានទៅស៊ើបយកការខាំនកនំទំពចូនូថា នឹំនចូលវាយយកបន្ទាយ
តុំនគួនវិលាណា ។

(នៅមានត)

សេចក្តីភាព

នៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បានតាំងឡើងតាមព្រះរាជប្រកាសលេខ ១៦ ចុះថ្ងៃ ២៥ មករាឆ្នាំ ១៩៣៤ ។ ក្រុមជំនុំនេះ ជាផ្នែកមួយសំខាន់ណាស់កន្លងចំណោមផ្នែកនានា ដែលមានតម្លៃនៅក្នុងរង្វង់នៃក្រុមពុទ្ធសាសនបណ្ឌិត្យ កំពេញ ។

គោលធំរបស់ក្រុមជំនុំនេះ នៅត្រង់ការតែងជាសៀវភៅមួយបែបស្តីអំពីទំនៀមទម្លាប់ខ្មែរ ទីធ្លប្រមែប្រមូលរក្សាទុក ព្រមទាំងផ្សាយជាបន្ត។ នូវឯកសារទាំងឡាយ ដែលស្តីអំពីការប្រពៃទម្លៃខ្មែរបុរាណ ដើម្បីជាប្រយោជន៍ខាងជាតិពន្ធវិជ្ជា ។

សមាសភាពនៃក្រុមជំនុំនេះ មានអធិបតីម្នាក់ អធិបតីរងម្នាក់ មានអ្នកដំណាងខាងអក្សរសាស្ត្រខ្មែរទីលេខាធិការ ដែលបានទទួលការអប់រំសម្រាប់ជួយធ្វើការ ព្រមទាំងមានសមាជិកធ្វើយ៉ាងច្រើនរូបដែលកយតាមក្រុងទីតាមខេត្តនានាក្នុងកម្ពុជាណាចក្រទាំងមូល សម្រាប់ធ្វើការទាក់ទងជាមួយផង ហើយសមាជិកទាំងនោះបានជួយធ្វើការដោយសប្បុរស ។

ក្រុមជំនុំបានទទួលឯកសារជាច្រើនភាន់ ដោយសមាជិកធ្វើយ៉ាងធ្ងន

ពាំងនោះបានឲ្យការមកខ្លះ ដោយការអង្វែតយកការរបស់ក្រុមដំខុំផ្ទាល់ខ្លះ ដោយដាក់ឲ្យប្រឡងប្រជែងក្នុងមួយធមាសម្ពងខ្លះ ទិងដោយវិញ្ញាជនក្រៅពីសមាជិកធ្វើអំណោយមកខ្លះ ។ ឯកសារពាំងនេះច្រើនតែជារឿងពំនៀមទម្លាប់ខ្មែរ ដែលមានប្ញសគល់ពាក់ទងដោយព្រហ្មញ្ញាសាសនា ឬដោយព្រះពុទ្ធសាសនា ។ ក្រុមដំខុំបានចុះលេខរៀងឯកសារពាំងនោះរក្សាទុកដោយជំពូក ។ ជា ៩៩ ជំពូក ហើយបានប្រែចេញជាភាសាបារាំងផង តំកល់ទុកក្នុងទូមាន ៩៩ ថត ។ ឯកសារពាំងនោះ មានប្រយោជន៍ដល់អ្នកស្រាវជ្រាវបរទេសផង ដល់ខ្មែរជំនាន់ក្រោយផង ដែលក្រុមដំខុំតែងបានខ្ចួលជនរួមជាតិទិងជនបរទេស ចូលមកសួរកិច្ចការអំពីពំនៀមទម្លាប់ខ្មែរសឹងតែរាល់ថ្ងៃ ។

ក្នុងប៉ុន្មានឆ្នាំនេះ ក្រុមដំខុំបានចាត់ការតាមគោលដៅដូចរៀបរាប់ខាងមុខនេះ ៖

១- ប្រមូលឯកសារស្តីអំពីជាតិពន្ធុសាស្ត្រខ្មែរ តំប្រវត្តិការណ៍ផ្សេង ។ - បច្ចេកទេស - ពំនៀម - ដំនឿ ។ ល ។ ដែលមានសេចក្តីអធិប្បាយសព្វគ្រប់យ៉ាងហ្មត់ចត់ ។

២- ផ្សាយជាភាសាខ្មែរ នូវពំនៀមដោយពួក ។ ដែលបានចេញសៀវភៅព្រះរាជពិធីក្នុងសមាស ៣ ភាគរួចមកហើយ ព្រមទាំងសៀវភៅប្រជុំរឿងព្រេង ៣ ភាគផង ដែលបានចុះពុម្ពរួចហើយ ។

៣- ផ្សាយជាភាសាចាក់ដន្ទឹងភាសាអង់គ្លេស ខ្លះសៀវភៅស្តីអំពីខ្មែរជនជាតិខ្មែរ ដែលបានចេញសៀវភៅចំនួន ២ ក្បាច ហើយ គឺពិធីភ្ជុំទេសមាស ១ ភាគ ពិធីកន្ត្រឹសារខ្មែរ ១ ភាគ ជាភាសាចាក់ដន្ទឹង។ ឯសៀវភៅចំនួន ៣ មួយក្បាលទៀត ស្តីអំពីដីវភាពខ្មែរជាភាសាចាក់ដន្ទឹងដែរ កំពុងរៀបរៀងសព្វថ្ងៃនេះ ។

៤- ធ្វើជាសារមន្ទីរមួយខុនៅការិយាល័យចំនេះមនុស្ស សម្រាប់ដាក់លក់នូវសំណាកវត្ថុដែលជាគ្រឿងដំណែលរបស់ខ្មែរ ព្រមទាំងមានផ្សាំនូវរូបភាពដំណាងចំនេះមផ្សេង ។ ជាដំនួយសេចក្តីអធិប្បាយទៀតផង។

ក្រៅពីការងម្មតា ជាអាទិ៍គឺការអង្កេត ការពិនិត្យស្រាវជ្រាវ ការប្រែឯកសារជាភាសាបរទេស នឹងការតែងជាសៀវភៅស្តីអំពីចំនេះមខ្មែរ ដើម្បីបោះពុម្ពផ្សាយ មានការប្រឡងប្រជែងជ្រើសយកឯកសារចំនេះមខ្មែរប្រចាំឆមាសរៀងរាល់ឆ្នាំ ។ សម្រាប់ឆមាសទី ១ ឆ្នាំ ១៩៦២ នេះ បានបើកការប្រឡងប្រជែង ២ មុខ ទី ១ អំពីរឿងកម្មកើត ដែលទាក់ទងដោយចំនេះមខ្មែរ ទី ២ អំពីពិធីឲ្យឈ្មោះមនុស្ស ឈ្មោះសត្វ ឈ្មោះទីលំនៅ នឹងឈ្មោះបរស់ប្រើប្រាស ។

កន្លងមក ៦ ខែនេះ ក្រុមជំនុំបានទទួលឯកសារ ១៨ រឿង អំពីបេក្ខជន នឹងអំពីសមាជិកគឺ:

- លោក ឡង - អ៊ិច អតីតមេឃុំ ឃុំអង្គញ្ញា ស្រុកព្រៃកប្បាស ខេត្តតាកែវ ឯកសារឿងភមក្នើ ទំនិងពិធីឲ្យឈ្មោះ ។

- លោកភិក្ខុ ណាប - កាង វត្តអង្គព្រះចតិយ ឃុំអង្គតាសោម ស្រុកត្រាំកក់ (តាកែវ) ពិធីឲ្យឈ្មោះ ។

- លោក ធឹក - តាម ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញភាសា-សាស្ត្រខ្មែរ ។

- លោក គ្រូ ចាម - ចន្ទ វត្តក្តីក្រៅ ឃុំខ្ចាស ស្រុកស្រីសុន្ទរ (កំពង់ចាម) រឿងភមក្នើនិងពិធីឲ្យឈ្មោះ ។

- លោក ប៊ូ - ប៊ូ ផ្ទះលេខ ៤៣៩ មហាវិថីព្រះបាទមុនីវង្ស សង្កាត់លេខ ៥ ភ្នំពេញ រឿងបុណ្យផ្កា ។

- លោក កៀត - កី ឃុំកំពង់ហួន ស្រុកពញាពុក កណ្តាល រឿងភមក្នើនិងពិធីឲ្យឈ្មោះ ។

- លោក ពេជ្រ - ឯក ពុទ្ធសាសបណ្ឌិត្យ ភ្នំពេញ រឿងខ្លែកអុំ និងខ្លែកចៃប្រណាំង ។

- លោក ម៉ាក់ - ម៉ែង ឃុំអង្គតាសោម ស្រុកត្រាំកក់ (តាកែវ) រឿងភមក្នើ ។

លោកគ្រូ កែវ - ឆៃ វត្តក្តីក្រៅ ឃុំខ្ចាស ស្រុកស្រីសុន្ទរ (កំពង់ចាម) រឿងភមក្នើ ។

- លោក តោ៧ . យ៉ ឃុំបឹងត្រាញ់ ស្រុកសំពៅង (តាកែវ) ពិ
ធីឡ្យឈ្មោះទីដ៏កំណៅតក្តីដ ។

- លោក ជឹម . ឈុំ ឃុំឫស្សីព្រៃ ស្រុកសណ្តាន់ (កំពង់ធំ)
រឿងភមក្តើ ទីដពិធីឡ្យឈ្មោះ ។

- លោក សេក . សែ៣ ឃុំតាំងក្រសាំង ស្រុកសន្ទុក (កំ-
ពង់ធំ) រឿងភមក្តើ ទីដពិធីឡ្យឈ្មោះ ។

- លោក ម្រាក់ . ខាត់ ឃុំពង្រ ស្រុកទ្ងួង (ក្រចេះ) ពិធី
ឡ្យឈ្មោះ ។

ក្រុមដំទុំបានជួបដុំពិទិត្យវិញ្ញាសាប្រឡងដោយយកត្រង់ចត់ ឃើញបាន
លទ្ធផល ដូចរៀបរាប់ខាងមុខ :

ផ្នែករឿងភមក្តើ

- លេខ ១ បានដល់លោក កែវ . កុល ឃុំអង្គតាសោម
ស្រុកត្រាំកក់ (តាកែវ) រង្វាន់ ៧០០រ០០ ។

- លេខ ២ បានដល់លោក ជឹម . ឈុំ ឃុំឫស្សីព្រៃ ស្រុក
សណ្តាន់ (កំពង់ធំ) រង្វាន់ ៥០០រ០០ ។

- លេខ ៣ បានដល់លោក សេក . សែ៣ ឃុំតាំងក្រសាំង
ស្រុកសន្ទុក (កំពង់ធំ) ៤០០រ០០ ។

- លេខ ៤ ជានដល់លោក ច្រាក់ - ខាត់ ឃុំពង្រ ស្រុកឆ្លូង (ក្រចេះ) រង្វាន់ ២០០រ០០ ។

ផ្នែកពិធីឲ្យឈ្មោះ

- លេខ ១ ជានដល់លោក ឆួង - អ៊ិច អតីតមេឃុំ ឃុំអង្គាញ់ ស្រុកព្រៃកប្បាស (តាកែវ) រង្វាន់ ៧០០រ០០ ។

- លេខ ២ ជានដល់លោក គៀត - គី ឃុំកំពង់ហ្លួង ស្រុកពញាឮ (កណ្តាល) រង្វាន់ ៥០០រ០០ ។

- លេខ ៣ ជានដល់លោក គោ - យឺ ឃុំចឹងត្រាញ់ ស្រុកសំរោង (តាកែវ) រង្វាន់ ៤០០រ០០ ។

លេខ ៤ ជានដល់លោកគ្រូ ណុប - ភាង វត្តអង្គព្រះចតុយ ឃុំអង្គតាសោម ស្រុកត្រាំកក់ (តាកែវ) រង្វាន់ ២០០រ០០ ។

រង្វាន់ដែលត្រូវជានដល់អ្នកប្រឡងជាប់ ក្រុមដំទុំជានជូនគ្រប់រូបរួចហើយ ។

ចំណែករង្វាន់ដែលត្រូវជានដល់សមាជិកឆ្នើយឆ្វង ក្រុមដំទុំនឹងជូននៅថ្ងៃខាងមុខ ។

ក្រុមដំទុំទំនៀមទម្លាប់ខ្មែរ មានអំណរណាស់ ចំពោះការដែលលោកអ្នកជាបេក្ខជន ឬ ជាសមាជិកជានយកចិត្តទុកដាក់រៀបរៀងឯកសារ

មកដាក់ប្រឡង ឬធ្វើអំណោយកន្លងមកសិន ១ ឆ្នាំ ១៨៦២ រួចមកហើយ
ទៅមាសទី ៤ ឆ្នាំជូលនេះ មានបើកការប្រឡង ២ មុខទៀត គឺ-
អំពីពត្តិល ១ មុខ អំពីទឹក ១ មុខ ដូចជាខែកប្រកាសប្រឡងផ្សាយខ្លះទៅ
តាមខែត្រ ស្រុក នឹងជនបទនានារួចហើយ សូមព្រះគុណនឹងអស់
លោកអ្នកយកព្រះទ័យនឹងយកចិត្តទុកដាក់ជួយទំនុកបម្រុងក្រុមជំទុំទៀម
ទម្លាប់ ដោយការតែងឯកសារទៅដាក់ប្រឡង ឬទៅធ្វើអំណោយគ
ទៅទៀត សូមទទួលអំណរគុណទុកជាមុន !

ក្រុមជំទុំទៀមទម្លាប់ខ្មែរ

ពិធីសម្ពោធព្រះវិហារអោពាធិការនុគ្រោះ

នៅក្នុងមន្ទីរពេទ្យព្រះកុសុមៈ មានការស្ថាបនាព្រះវិហារតូច ១ មាន បរិណ្ណាយ ១៦ ម. x ១៦ ម. x ៦ ម. ធ្វើអំពីបេតុងគារមេ ដំបូលឈើប្រក់ក្បឿង ជាហ្វាជង់ការសុទ្ធតែធ្វើអំពីស៊ីម៉ង់ត៍ទាំងអស់ ។ នៅតាមបរិវេណនៃឃ្យែនខាងក្រៅ មានបរិណ្ណាយ ៦២ ម. x ១៦ ម. ក្រាលឥដ្ឋពណ៌យ៉ាងរលើបរលោងល្អឆើតឆាយ គួរជាទីសម្រាន់ដ៏ជាទីមនោរម្យ ។

ព្រះវិហារអោពាធិការនុគ្រោះនេះ ស្ថាបនានៅខាងកើតជាប់នឹងមន្ទីរពេទ្យ ។ ការចាប់ផ្តើមគំនិតស្ថាបនានេះ តាំងពីថ្ងៃសម្ពោធមន្ទីរពេទ្យព្រះកុសុមៈម្ល៉ះ គឺតាំងពីថ្ងៃទី ២១ កុម្ភៈ ១៩៥៦ មក អ្នកដែលផ្តើមគំនិតដ៏ប្រសើរនេះ គឺសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយដោយមានការជួយឧបត្ថម្ភយ៉ាងពេញទំហឹង អំពីឥហបតី តាន់ហុងអាង និងភរិយាវេជ្ជបណ្ឌិតសោភ ។ ជាប់មកព្រះតេជព្រះគុណ ភឹង និងតុន្តុបរិស័ទជាច្រើនទៀត ដែលមានសទ្ធាយ៉ាងមុតមាំ បានជួយខ្នែងដោយកម្លាំងធនធាន កម្លាំងកាយ និងកម្លាំងចិត្ត លុះត្រាតែសំណង់ថ្មីនេះ បានសម្រេចរួបរាងជាតួព្រះវិហារយ៉ាងមនោរម្យ គួរដល់ការធ្វើសង្ឃកម្មតាមវិន័យព្រះពុទ្ធសាសនា ។

លុះព្រះវិហារអាទាធិគាន្ទុគ្រោះ ទៅមទ្ទីរពេទ្យព្រះកុសុម:នេះ សម្រេចហើយ កាលពីកត្រីនៃថ្ងៃទី ១៩ កក្កដា ១៩៦២ មានការរៀបចំធ្វើបុណ្យឆ្នូន ទីធ្លបញ្ចុះខ្លួសីមាយ៉ាងមហោឡារិក ក្រោមការទទួលត្តម្ព នៃក្រុមអតិថិជនសមាគមគីលានសង្គ្រោះ ដែលមានសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណ:មហានិកាយជាប្រធាន ។

លុះព្រឹកឡើងថ្ងៃទី ១៦ កក្កដា ១៩៦២ វេលាម៉ោង ៨ ព្រឹក សម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាឯករាជ្យជាតិ បានស្តេចយាងដល់មទ្ទីរពេទ្យព្រះមហាក្សត្រិយានីកុសុម:តាមព្រះទីនាំងវេលាយន្ត ដោយមានសមាជិកត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ទីធ្លឥស្សរ:ជនជាន់ខ្ពស់ជាច្រើនតាមហែអមព្រះរាជដំណើរផង សម្តេចព្រះបិតាជាតិ ស្តេចបានយាងចូលទៅកន្លែងបង្ហាញសាលា នៅបរិវេណនៃគីលានដ្ឋានព្រះមហាក្សត្រិយានី ដើម្បីថ្វាយបង្គំព្រះសង្ឃ ដែលមានជាអាទិ៍គឺព្រះសង្ឃនាយកទាំងពីរគណ:ជាប្រធានកន្លែងនោះ នៅត្រង់មាត់ទ្វារចូល សម្តេចព្រះប្រមុខរដ្ឋទ្រង់ស្តេចបានទទួលបាច់ផ្កាពីកញ្ញាបីរូប ដែលបានថ្វាយចំពោះព្រះអង្គ ជានិមិត្តរូបនៃការថ្វាយព្រះពរស្វាគមន៍ចំពោះសម្តេច ។

បន្ទាប់មក សម្តេចព្រះបិតាជាតិ បានស្តេចយាងចូលទៅកន្លែងព្រះវិហារថ្មី ដើម្បីទ្រង់គាត់ឫសសីមា ហើយព្រះសង្ឃបានស្វាធ្យាយព្រះពុទ្ធមន្តជយន្តោប្រសិទ្ធពរជ័យថ្វាយព្រះអង្គជាកិច្ចបង្ហើយពិធីនេះ ។

លុះព្រះសង្ឃស្វាធ្យាយព្រះពុទ្ធមន្តជយន្តោចប់ សម្តេចព្រះមហាសុមេធាធិបតី ថ្វាយព្រះពរជ័យសួស្តីចំពោះសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ ទីឯសម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាជាតិ ។

សម្តេចព្រះប្រមុខរដ្ឋ ស្តេចចូលយាងនិវត្តន៍ កាន់ព្រះពន្ធដំណាក់វិញ នៅវេលាម៉ោង ១០ នឹង ៣០ នាទី ដោយសុវត្ថិភាព ។

វិត្រូចាធ្យាយ អាចឱ្យពណ្ណពេយ្យ មានរូបស្មើ ហើយឱ្យរុងរឿង អស់បញ្ចាវន្ទ្រីយ ស្មើព្រះជនន៍ ជនកសោតហោង ។ ព្រះជនកសោតណា បង្កើតអាត្មា ឱ្យមានសិរីលង ក្សត្រីតូច មិនឱ្យមានហ្មង អស់សុខពុទ្ធផង តុំដែលនឹងធ្លន់ ។ ព្រះជនកព្រះជនន៍ បើនឹងស្រដីប្រសើរពេកពន់ ថាកុំព្រះសុមេរ៉ុ នោះហោងមហាធន់ ថាបើនឹងគណន៍ តុំអាចកន្ទង ។ វិត្រូចាធ្យាយ ប្រដូចខ្លួរម្ពាយ អាត្មកឯងហោង អាចឱ្យក្តីប្បាប់ ប្រដៅធមិងង ដោយខ្លួរគន្ធង ព្រះពុទ្ធចាំងឡាយ ។ ខ្លួរអ្នកណា នោះមានប្រាជ្ញា ឱ្យគិតវែងឆ្ងាយ គុណលោកចាំងបី ហៅមហាខ្លួលាយ កុំឱ្យអន្តរាយ ក្តីពីឡាយាម ។

សម្តេចឪជាព្រះអគ្គមហាសាសនូបត្ថម្ភក៍
បានស្តេចយាងជាព្រះអធិបតីក្នុងពិធីបញ្ចុះសីមាវត្តអង្គសិម្ពលី
ស្រុកភ្នំពេញ (កណ្តាល) ។

ក្នុងព្រះហានៈព្រះអង្គជាព្រះអគ្គមហាសាសនូបត្ថម្ភក៍ សម្តេចព្រះប្រមុខវង្សព្រះបិតាជាតិ ជាទីគោរព ស្តេចបានយាងទៅជាព្រះអធិបតី ក្នុងពិធីបញ្ចុះសីមាវត្តអង្គសិម្ពលី ឃុំពោធិ៍ តំបន់អង្គស្នួល ស្រុកភ្នំពេញ ខេត្តកណ្តាល នៅពេលព្រឹកថ្ងៃទី ១ សីហា ១៩៦២ ។

នៅវេលាម៉ោង ៨ ទឹង ៣០ នាទី នៅទីវត្តអង្គសិម្ពលី មានសភាពអ៊ូអរយ៉ាំងក្រៃលែង ពេញពោរពៅដោយមនុស្សម្នាមហាជនយ៉ាំងកកកុញជាពិសេសគឺព្រះសង្ឃពួកគណៈទឹងឥស្សរជនជាក្បៀកក្បិតត្តិយសតំងឡាយ បានទទឹមទទឹងអញ្ជើញទៅដល់ជាបន្តបន្ទាប់គ្នា ដែលយើងបានសង្កេតឃើញជាអាទិ៍នៅពេលនោះគឺ : ផ្នែកព្រះសង្ឃមានសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្ត ព្រះគ្រូមង្គលមេធា អ៊ូ-អ៊ួង ចៅអធិការវត្តអង្គសិម្ពលីនាកាម ព្រះគ្រូសាសនសោភ័ណ ចន្ទ.សាលី វត្តបទុមវតីពជវាកាម ។

ចំណែកខាងគ្រហស្ថ យើងបានសង្កេតឃើញជាអាទិ៍នៅពេលនោះគឺ : សហជីវិន ទៅសែនក្សត្រ ប្រធានវង្សត ឯកឧត្តម ភ្ជុ-រ៉ុន

សមាជិកទត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក សហជីវិន ឃួន-កឹមម៉ន ចេង-ហោង លោកវរសេនីយឯកមាស-ហ៊ុល ។

ចំណែកខាង ឥស្សរជនស៊ីវិលក្នុងខែត្រ យើងបានសង្កេតឃើញជាអាទិ៍ សហជីវិន ឧត-សុង្ខ៊ី ចៅហ្វាយខែត្រកណ្តាល សហជីវិន ហួត-ថន ចាងហ្វាងសាលាដំបូងកណ្តាល សហជីវិន សៅ-ភ័ ព្រះរាជអាជ្ញា ។

នៅវេលាម៉ោង ៩ ព្រះទីនាំងទ្វេម្តាគចក្រ ដែលបើកបរដោយអនុ-សេនីយ៍ឯក លុន-កៀង បានដឹកនាំព្រះរាជដំណើរនៃសម្តេចឪទៅចុះចតនៅកន្លែងប្រាសាទពិធី ដែលនៅទីនោះ ក្រោយដែលព្រះអង្គទ្រង់យាងចុះពីព្រះទីនាំងទ្វេម្តាគចក្រ សម្តេចឪព្រះបិតាជាតិ បានទទួលបាច់ផ្កាពីកញ្ញាពីរូប ដែលបានថ្វាយចំពោះព្រះអង្គ ជានិមិត្តរូបនៃសេចក្តីស្នេហាស្មោះត្រង់ ទឹងថ្វាយព្រះពរស្វាគមន៍ដំណាងឥស្សរជន មន្ត្រីរាជការពាណិជ្ជ ស៊ីវិល ទឹងប្រជាពលរដ្ឋទាំងអស់ ។ បន្ទាប់មកទ្រង់បានទទួលការគ្រាបថ្វាយបង្គំអំពីឥស្សរជន ពាណិជ្ជ ស៊ីវិល ដែលមានលោកប្រមុខខែត្រ បានរង់ចាំគ្រាបថ្វាយបង្គំព្រះអង្គនៅទីនោះ ។

ក្រោយដែលបានទទួលការគ្រាបថ្វាយបង្គំអំពីឥស្សរជន ពាណិជ្ជ ស៊ីវិលចាំងអស់រួចហើយ ព្រះអគ្គមគ្គុទ្ទេសជាតិ ស្តេចយាងទៅទទួលការគ្រាបថ្វាយបង្គំ ពីមន្ត្រីក្នុងរាជការ យុវន យុវតី ទឹងប្រជា

ពលរដ្ឋតាំងអស់ ដែលឈរអមសងខាងផ្លូវឡើងទៅកាន់វេទិកាតិរោសេម ដែលតាំងនៅក្នុងបរិវេណនៃព្រះវិហារថ្មី ។ ពេលនោះកងទ័ពមកគ្រប់ចំនួនបានលើកអាវុធវាគ្នា ទាំងបន្ទឺបទៈក្នុងចរលើលាថ្វាយជាព្រះពរជ័យ ។

បន្ទាប់ពីនេះ សម្តេចព្រះប្រមុខរដ្ឋ បានស្តេចយាងឡើងលើវេទិកាតិរោសថ្វាយបង្គំព្រះសង្ឃ ដែលមានសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តជាប្រធាន ។

ក្រោយដែលបានថ្វាយបង្គំព្រះសង្ឃ ទាំងក្រោយដែលព្រះអង្គទ្រង់សម្រួលព្រះឥរិយាបថបន្តិចមក ក៏មានឧច្ចរិតជាគោរពទាំងផាតិ ហើយព្រះសង្ឃបានសូត្រព្រះពុទ្ធមន្តជយន្តោប្រសិទ្ធិពរជ័យ ហើយតមកយុវតីមួយក្រុមស្ទើរតែពាក់យ៉ាងស្អាត បានច្រៀងថ្វាយព្រះពរជ័យគួរជាទីចាប់អារម្មណ៍ក្រៃលែង ។

បន្ទាប់មក ព្រះគ្រូសាសនៈសោភ័ណ ចន្ទ-សាលី វត្តបទុមវតីតំណាងព្រះសង្ឃ ទាំងពុទ្ធបរិស័ទគាំងអស់កងវត្តអង្គសិម្ពលីបានថ្វែងសុន្ទរកថាមួយ រៀបរាប់ជាអាទិ៍អំពីប្រវត្តិនៃការកសាងព្រះវិហារនោះ ។

លុះចប់សុន្ទរកថានៃព្រះគ្រូសាសនៈសោភ័ណនេះមក សម្តេចព្រះប្រមុខរដ្ឋ បានស្តេចប្រគេនទឹងប្រោសព្រះពរជ័យព្រះសង្ឃតបវិញមួយដែរ ដែលមានអត្ថន័យដ៏សែនពិរោះទឹងជាទីចាប់ចិត្តយ៉ាងពន់ពេក ។

លុះចប់ព្រះសង្ឃថា ប្រកបដោយគតិន័យដ៏ជ្រាលជ្រៅនេះមក ព្រះបីតាជាតិជាខ្ញុំគោរព ស្តេចយាងឡើងកាន់ព្រះវិហារថ្មី ដែលជាទីប្រារព្ធបញ្ចុះសីមាយ៉ាងមហោឡារកនាព្រឹកថ្ងៃនោះ ដើម្បីជាព្រះអធិបតីកង់ពិធីកាត់ឫសសន្ធតវ័ណ្ណសីមា ។

ក្រោយដែលព្រះអង្គនិងពុទ្ធបរិស័ទចាំងឡាយ ចានទមស្ការព្រះរតនត្រៃនិងសមាទានសីលតាមប្រពៃណីនៃព្រះពុទ្ធសាសនារួចហើយ ពិធីកាត់ឫសសីមា ដែលមានព្រះសង្ឃចានស្វាធ្យាយជយន្តោប្រសិទ្ធិពរជ័យជង កំចានប្រារព្ធធ្វើឡើងគ្រប់ចាំង ៨ ទិស ដែលមានសម្តេចព្រះអគ្គមហាសន្ធបឌិតមុក ទ្រង់ជាព្រះអធិបតី ក្រោយដែលស្នាគន់ទី ៣ ចានចាប់ផ្តើមឡើង ។

ពិធីកាត់ឫសសន្ធតវ័ណ្ណសីមានេះ ចានចប់សព្វគ្រប់នៅវេលាម៉ោង ១២ ថ្ងៃត្រង់ ។

សម្តេចព្រះអគ្គមគ្គុទ្ទេសក៍ជាតិ ស្តេចចានថ្វាយបង្គំព្រះសង្ឃ ខ្ញុំលាឥស្សរជន ព្រមទាំងប្រជាពលរដ្ឋ ជាកូនចៅព្រះអង្គយាងនិវត្តចូលព្រះរាជធានីវិញ ដោយព្រះសុវត្ថិភាព ។

យើងសូមបញ្ជាក់ថា ក្នុងឱកាសដែលសម្តេចឪជាទីគោរពស្តេចយាងទៅជាព្រះអធិបតី ក្នុងពិធីបញ្ចុះសីមានៅក្នុងអង្គសីមាវិនាត្រឹមថ្ងៃនោះ ព្រះអង្គចានទ្រង់ប្រោសព្រះរាជទានសំពត់ជាប្តីរយមែត្រ ដល់កូនចៅព្រះអង្គនៅដងខ្ញុំនោះផង ។

ភក្តីជសទិយា


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៤ លេខ ៩ ខែ កញ្ញា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -



ភ្នំពេញសន្ទេយ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញាវាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
–	ធម្មវិចារណាកថា ព្រះសាសនមុនី កឹម-គួរ រៀបរៀង	៩៦៣
–	គោលប្បាប់ព្រះពុទ្ធសាសនា លោក ហោង-សមអាន តែងនិងរៀបរៀង (ត)	៩៧៩
–	ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) លោកប៊ុំ-ប៉ុំ ប្រែរៀបរៀង (ត)	៩៨៨
–	មធុរសរាហិណី សម្តេចព្រះធម្មលិខិត ស្វ៊ី-ឯម ឧត្តមប្រឹក្សា ប្រែរៀបរៀង (ត)	៩៩៦
–	មហោសថជាតក (ត)	១០០៦
ផ្នែកអក្សរសាស្ត្រ		
–	បែបអក្សរខ្មែរ សម័យសិលាចារឹកហាន់ដ័យ	១០១៩
–	ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ "ក" (ត)	១០២៨
–	វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត)	១០៣០
–	រឿងសាមកុក អ្នកនាកញ្ញា នូ-ហន ប្រែរៀបរៀង (ត)	១០៣១
–	រឿងព្រេងចិន លោក ភ័យ-ប៊ុក ភូឈួយខែត្រតាកែវ ប្រែរៀបរៀង (ត)	១០៤១
–	រឿងខាក់ដំរី នៃក្រមទំនៀមទម្លាប់ខ្មែរ	១០៤៧
កំណាត់ឧដ្ឋានប្រវត្តិការណ៍		
–	សុន្ទរកថានៃលោកវន្ទិលេខាធិការ ក្រសួងធម្មការ	១០៦១
–	សន្និសីទស្តីពីពុទ្ធសាសនានៃលោកបណ្ឌិតជាតិជាតិឥណ្ឌៀ	១០៦៦

មួយឆ្នាំមាន ១២ លេខ តម្លៃជាវ ២៣០រ០០

34è Année — N° 9 — Septembre 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse

—Dhammavicharanakatha par le Vénérable KEM-TO 963
—Principes bouddhiques par M. HENG-SAM-AN (suite) 979
—Préah Abhidhammapitaka «Kampir Préah Yamaka» par M. BOU-PO (suite) 988
—Madhurasavahini par S.Em. Préah Dhammalikhita LOUIS-EM Haut Conseiller (suite) 996
—Mahosotha Jataka (suite) 1006

Partie littéraire

—Les caractères Khmèrs à l'époque de Hanchey par M. DIK-KEAM 1019
—Activité de la Commission Culturelle chapitre «Ka» (suite) . . . 1028
—Dictionnaire Sanscrit-Khmer par Vén. PANG-KHAT (suite) . . . 1030
—Histoire de Sam-Kok traduite par Oknha NOU-KAN (suite) . . . 1031
—Légende Chinoise traduite par M. RAY-BOUC Phouchhouykhèt de TAKEO. (suite) 1041
—Histoire de Prise des éléphants par la Commission des mœurs et coutumes Khmer 1047

Notes et chroniques

—Discous prononcépar M. le Seerétaire d'Etat anx cultes le 3-9-62 à l'occasion de la Conférence conscrnant la religion Bouddhique 1061
—Texte de Conférence relative à l'évolution de la réligion Bouddhique par M. le Docteur Dut 1066

Prix d'Abonnement annuel (comprenant 12 numéros) : 230 ; 00

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការសាមញ្ញ, ឲ្យធ្វើល្អទៅ ។
ឲ្យដុំសាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

ធម្មវិចារណាកថា

ឧបត្ថ រតនត្តយស្ស

សូមនមស្ការ ចំពោះព្រះរតនត្រ័យ គឺព្រះពុទ្ធ

ព្រះធម៌ ព្រះសង្ឃ ដោយសេចក្តីគោរព ។

បន្ទាប់ពីនេះ សូមលើកយកបញ្ហាធម៌ខ្លះ ដែលគេតែងពោលថា បណ្តាមនុស្សក្នុងលោក មនុស្សខ្លះ ប្រព្រឹត្តធ្វើតែអំពើអាក្រក់ ដោយកាយ វាចា ចិត្ត អ្នកផងឃើញថា មនុស្សនោះ បានខូចសេចក្តីក្តៅលំបាក រហូតអស់ជីវិតសមកៀតាមអំពើរបស់គេនោះកើមាន មនុស្សខ្លះ ប្រព្រឹត្តធ្វើតែអំពើល្អដោយកាយ វាចា ចិត្ត អ្នកផងឃើញថា មនុស្សនោះ បានខូចសេចក្តីសុខ ចំរើន រហូតអស់ជីវិតសមកៀតាមអំពើរបស់គេនោះ កើមាន ប៉ុន្តែផ្ទុយពីនេះទៅវិញ គឺមានមនុស្សខ្លះ ប្រព្រឹត្តធ្វើតែអំពើ

អាក្រក់ដោយកាយ វាចា ចិត្ត តែមកំាងសោះទេ តែមនុស្សនោះ ត្រឡប់ទៅជាបានទទួលសេចក្តីសុខ ចំរើនរុងរឿង រហូតអស់ជីវិតទៅក៏មានមនុស្សខ្លះ ប្រព្រឹត្តធ្លៅតែអំពើល្អដោយកាយ វាចា ចិត្ត តែមកំាងសោះទេ តែមនុស្សនោះ ត្រឡប់ទៅជាបានជួបប្រទះនឹងសេចក្តីទុក្ខលំបាកវិញ រហូតអស់ជីវិតទៅក៏មាន ព្រោះហេតុអ្វី?

កន្លងផ្លែអត្ថបទធម៌នេះ សូមអធិប្បាយវែកញែកចំពោះតែមនុស្ស ២ ពួកខាងចុងគឺ មនុស្សដែលប្រព្រឹត្តធ្លៅតែអំពើអាក្រក់ ហើយត្រឡប់ទៅជាបានទទួលសេចក្តី សុខ-ចំរើនមួយពួក នឹងមនុស្សដែលប្រព្រឹត្តធ្លៅតែអំពើល្អ ហើយត្រឡប់ជាបានទទួលសេចក្តីទុក្ខលំបាកមួយពួក ។ មនុស្សទាំង ២ ពួកនេះ ខ្ញុំសូមលើកយកភ្លាមតាសិតតាវគ្គ កន្លងមកខ្លះ ទុកនិកាយធម្មបទ មកធ្វើជាគោលនៃបញ្ហា ដើម្បីអធិប្បាយវែកញែកដោះស្រាយបំភ្លឺសេចក្តីឲ្យឃើញហេតុផល ភ្លាមតាសិតនោះដូចខ្លះ ៖

ចាទោបិ បស្សតិ កទ្រិ យាវ ភាបំ ន បច្ចតិ
យទា ច បច្ចតិ ចាបំ អថ ចាទោ ចាចាឯ បស្សតិ
កទ្រោបិ បស្សតិ ចាបំ យាវ កទ្រំ ន បច្ចតិ
យទា ច បច្ចតិ កទ្រិ អថ កទ្រោ កទ្រោឯ បស្សតិ។

ប្រែថា មនុស្សថ្លង ដរាបណាបើថ្លងមិនទាន់ឲ្យផលទេ ដរាបនោះរមែងជួបប្រទះតែនឹងអំពើល្អ លុះតែកាលណាថ្លងឲ្យផល កាល

នោះមនុស្សបាប ទើបជួបប្រទះទុំធំបាប ។ មនុស្សល្អ ដរាបណាបើអំពើល្អមិនទាន់ឲ្យផលទេ ដរាបនោះរមែងជួបប្រទះតែទុំធំអំពើអាក្រក់ លុះតែកាលណាអំពើល្អឲ្យផល កាលនោះមនុស្សល្អ ទើបជួបប្រទះទុំធំអំពើល្អ ។

មនុស្សបាបជួបទុំធំអំពើល្អ

អធិប្បាយពន្យល់សេចក្តីតាមអត្ថន័យក្នុងព្រះសូត្រនេះថា អ្នកណាដែលប្រព្រឹត្តធ្វើអំពើអាក្រក់ ដោយកាយទ្វារមានបាណាតិបាតជាដើម ប្រព្រឹត្តធ្វើអំពើអាក្រក់ ដោយវចីទ្វារ មានមុសាវាទជាដើម ប្រព្រឹត្តធ្វើអំពើអាក្រក់ ដោយមនោទ្វារ មានអភិជ្ឈាជាដើម អ្នកនោះហៅថា មនុស្សបាប ឬ មនុស្សលាមកអាក្រក់ ។ មនុស្សដែលប្រព្រឹត្តធ្វើអំពើអាក្រក់នោះ សូម្បីអ្នកដទៃក៏គេដឹងឮឃើញថាជាមនុស្សប្រព្រឹត្តធ្វើតែអំពើអាក្រក់មែន។ ប៉ុន្តែមនុស្សនោះ បែរត្រឡប់ជាបានទទួលនូវសេចក្តីសុខ-ចំរើនរុងរឿង ដោយសម្បត្តិមានលាភសក្ការៈ ទុំធំយសបរិវារជាដើម ក្នុងបច្ចុប្បន្ននេះទៅវិញ ព្រោះហេតុអ្វី? ព្រោះហេតុថាបាបគឺអំពើអាក្រក់ដែលមនុស្សនោះកំពុងតែធ្វើមិនទាន់ឲ្យផល លុះតែបាបនោះឲ្យផលកាលណា ទើបមនុស្សនោះឯងទទួលរងនូវទុក្ខគឺអំពើអាក្រក់ផ្សេងៗក្នុងបច្ចុប្បន្ន ឬ ក្នុងបរលោកកាលនោះ ។

មនុស្សល្អជួបទុំធំអំពើអាក្រក់

ចំណែកខាងអ្នកណា ដែលប្រព្រឹត្តធ្វើអំពើល្អគឺអំពើជាកុសលដោយ

កាយ វាចា ចិត្ត អ្នកនេះហៅថា មនុស្សល្អ ឬមនុស្សបុណ្យ ។ មនុស្ស
ដែលប្រព្រឹត្តធ្វើអំពើល្អនោះ សូមឱ្យអ្នកជាខែកំបានដឹងឮយើញថាជាមនុស្ស
ប្រព្រឹត្តធ្វើតែអំពើល្អសុចរិតមែន ។ ប៉ុន្តែមនុស្សនោះផ្ទុយទៅវិញ បែរ
ត្រឡប់ជាបានទទួលនូវសេចក្តីទុក្ខលំបាកវេទមរហាម ក្នុងបច្ចុប្បន្នឬក្នុង
បរលោកព្រោះហេតុអ្វី ? ព្រោះហេតុថាអំពើល្អដែលមនុស្សនោះ កំពុង
ប្រព្រឹត្តធ្វើមិនទាន់ឱ្យផល លុះតែអំពើល្អនោះឱ្យផលកាលណា ទើប
មនុស្សល្អនោះឯង បានជួបប្រទះទទួលនូវអំពើល្អ គឺសេចក្តីសុខ-ចំរើនរុង-
រឿងដោយសម្បត្តិយសសក្តិផ្សេង ។ ក្នុងបច្ចុប្បន្នជាតិនេះ ឬក្នុងបរលោក
កាលនោះ ។

អធិប្បាយសេចក្តីដោយរបៀបរួម

បើមានគេសួរថា មនុស្សខ្លះ ប្រព្រឹត្តធ្វើតែអំពើអាក្រក់សោះទេ ចុះ
ហេតុអ្វីបានជាមនុស្សនោះ ត្រឡប់ជាបានសេចក្តីសុខ-ចំរើនរុងរឿងទៅ
វិញ ? មនុស្សខ្លះប្រព្រឹត្តធ្វើតែអំពើល្អដោយកាយ វាចា ចិត្ត តែម្យ៉ាង
សោះទេ ចុះហេតុអ្វីបានជាមនុស្សនោះ ត្រឡប់ជាបានសេចក្តីទុក្ខលំបាក
ដោយហេតុផ្សេង ។ ទៅវិញ ? បញ្ហានេះ គេអាចធ្វើយបានតែត្រឹមប៉ុណ្ណោះ
ថា មនុស្សដែលប្រព្រឹត្តធ្វើតែអំពើអាក្រក់ ហើយត្រឡប់បានទទួលនូវ
សេចក្តីសុខ-ចំរើន ។ នោះកើតឡើងដោយសារសេចក្តីប្រព្រឹត្តិល្អចាស់
របស់មនុស្សនោះដែលមានមកពីកន្លងកាលមុនមកផ្តល់ឱ្យ ឯសេចក្តីអាក្រក់

របស់មនុស្សនោះដែលប្រព្រឹត្តធ្វើថ្មីក្នុងបច្ចុប្បន្ននេះ មិនទាន់ឲ្យផល ថា
ដូច្នេះក៏បាន ឬថាបើផលដែលកើតអំពីសេចក្តីប្រព្រឹត្តល្អ របស់មនុស្ស
នោះពីនាយមកគ្មានទេ បើពិតជាគ្មានមែន ហើយមនុស្សនោះនៅតែបាន
ទទួលសេចក្តីសុខ-ចំរើន ត្រង់នេះត្រូវជ្រាបថា មនុសនោះមានសម្បត្តិ
ណាមួយក្នុងសម្បត្តិទាំង ៤ យ៉ាងគឺ គតិសម្បត្តិ,(១) ឧបធិសម្បត្តិ(២),
កាលសម្បត្តិ(៣) នឹងបយោគសម្បត្តិ(៤) អាចជួយការពារឃុំគ្រងមនុស្ស
អាក្រក់នោះ មិនឲ្យទទួលនូវទោសកំហុសរបស់ខ្លួននោះទៅបានដែរ ។
ចំណែកខាងមនុស្សដែលប្រព្រឹត្តធ្វើតែអំពើល្អ គឺឲ្យមានក្សត្រិយ៍ជាដើម
ហើយត្រឡប់ជាបានទទួលនូវសេចក្តីទុក្ខលំបាកគ្រោះថ្នាក់ ដោយហេតុ
ផ្សេង ។ ក្នុងបច្ចុប្បន្នទៅវិញ ក៏ព្រោះតែបាបកម្មចាស់របស់មនុស្សនោះ
ដែលបានធ្វើទុកតាំងពីកាលមុនមកផ្តល់ឲ្យ ឯសេចក្តីល្អដែលមនុស្សនោះ
ប្រព្រឹត្តធ្វើថ្មីក្នុងបច្ចុប្បន្ននេះមិនទាន់ឲ្យផល តុំនោះសោត បើបាបកម្មរបស់
មនុស្សនោះពីនាយមកគ្មានសោះទេ ត្រង់នេះគួរជ្រាបថា មនុស្សនោះប្រ-
កបដោយវិបត្តិណាមួយក្នុងវិបត្តិទាំង ៤ យ៉ាងគឺ គតិវិបត្តិ ឧបធិវិបត្តិ កាល
វិបត្តិនឹងបយោគវិបត្តិ មកពាក់ព័ន្ធមិនឲ្យមនុស្សប្រព្រឹត្តល្អនោះ បានទទួល
នូវសេចក្តីសុខ ចំរើនទៅបាន ។

១- ការដល់ព្រមដោយគតិ ធំកើតក្នុងសុគតិភព ។ ២- ការដល់ព្រមដោយឧបធិ
គឺមានពេញកាយសមរម្យ ។ ៣ ការដល់ព្រមដោយកាល ធំកើតក្នុងសម័យដែលសម្បុរដោយ
អាហារដើម ។ ៤- ការដល់ព្រមដោយបយោគ ធំចេះលៃលកទុកដាក់ខ្លួនឲ្យប្រព្រឹត្តទៅ
តាមកាលៈទេសៈ ។

សេចក្តីធ្វើយមកនេះ ល្មមស្តាប់ចុះ ឃើញថាសមហេតុសមផល ហើយ ប៉ុន្តែតែងឮពាក្យអ្នកខ្លះ គេសួរថាអើ ខាងជនជាតិខ្មែរយើង គេសង្កេតឃើញថា ច្រើនតែជាអ្នកកាន់ពុទ្ធសាសនា មានការធ្វើបុណ្យឲ្យទានរក្សាសីលជាដើម អស់កាលជាយូរអង្វែងណាស់មកហើយ ចុះហេតុអ្វីបានជាជនជាតិខ្មែរយើងឃើញច្រើនតែជាអ្នកអន់ខ្សោយខាងជីវភាពសេចក្តីសុខនឹងសម្បត្តិផ្សេង ។ មានគោលសម្បត្តិជាដើមជាងជនជាតិដទៃដែលមិនកាន់ពុទ្ធសាសនាទៅវិញ បើអ្នកសួរសើរថា ការកាន់ពុទ្ធសាសនាគឺធ្វើបុណ្យឲ្យទាន រក្សាសីលជាដើម តែងទទួលអំណោយផលបុណ្យដែលខ្លួនធ្វើនោះនឹងឲ្យទៅជាយ៉ាងនេះ ជាយ៉ាងនោះ តាមចំណងដែលខ្លួនត្រូវការ នេះមិនដូច្នោះ ត្រឡប់ជាធ្លុះធ្លាយទៅវិញ ត្រង់ជនជាតិខ្មែរអ្នកប្រព្រឹត្តធ្វើបុណ្យទៅជាខ្សត់ខ្សោយ ឯជនជាតិដទៃគេមិនសូវអើពើនឹងពុទ្ធសាសនាធ្វើបុណ្យឲ្យទានប៉ុន្មានផង ម្តេចក៏គេចេះតែកបកល់សម្បូរដោយសេចក្តីសុខ-ចំរើន ទីងកោតព្រួយគ្រប់យ៉ាងទៅវិញ ?

ការធ្វើយតបទីងសំនួរខាងលើនេះ ឃើញថាមានមតិផ្សេងពីគ្នាជាច្រើនយ៉ាងគឺ អ្នកខ្លះថា បុណ្យដែលគេធ្វើនោះ ឥឡូវនេះមិនទាន់ផ្តល់ឲ្យផលទេ លុះតែដល់សាសនានៃព្រះពុទ្ធទៅខាងមុខទៀត ទើបបានឲ្យផល អ្នកខ្លះថា ទោះបីមនុស្សជាតិខ្មែរ ឬ មនុស្សជាតិដទៃណាក៏ដោយ ដែលបានប្រកបដោយសេចក្តីសុខ-ចំរើនរុងរឿងគ្រប់យ៉ាងគ្រាន់ប៉ុន្មានទោះ

តើមនុស្សអ្នកកាន់ពុទ្ធសាសនាធ្វើបុណ្យឲ្យទាន រក្សាសីលហ្នឹងឯង ដែលទៅកើតជាមនុស្សជាតិអស់ពាន់ឯនោះ អ្នកខ្លះថា ធម្មតាអ្នកកាន់ពុទ្ធសាសនាធ្វើបុណ្យឲ្យទាន រក្សាសីលពាន់ប៉ុន្មាន លុះអស់អាយុដំរែតហើយ រមែងបានទៅកើតជាខេវបុត្រខេវធីតា សោយសម្បត្តិទិព្វកន្លះហានសួគ៌ខេវរលោកអស់ទៅហើយ ព្រោះកំណើតរបស់ខេវបុត្រ ខេវធីតាកន្លះហានសួគ៌នោះមានអាយុវែងៗណាស់ មិនដាច់នឹងធាប់ត្រឡប់មកកើតជាមនុស្សវិញទេ ព្រោះហេតុនោះបានជាមិនសូវមានមនុស្សជាតិខ្មែរគ្រាន់បើជាងគេ អ្នកខ្លះថា ជនជាតិខ្មែរជាអ្នកទស្សាហ៍ធ្វើបុណ្យនេះ ធ្វើបុណ្យនោះជារឿយ ។ ប្រហែលជាជាតិខ្មែរទៅកាន់និព្វានអស់ទៅហើយទេដឹង? ពីព្រោះជាតិខ្មែរ កាលណាធ្វើបុណ្យម្តងៗ ច្រើនតែប្រាថ្នាទៅកាន់និព្វាន បើមិនដូច្នោះទេ គឺជាតិខ្មែរអ្នកធ្វើបុណ្យក្នុងពុទ្ធសាសនាហ្នឹងឯង ដែលទៅកើតជាជាតិជនអ្នកគ្រាន់បើអស់ពាន់ឯនោះ ។

តាមមតិរបស់អ្នកធ្វើយដូចខាងលើពាន់អស់នោះ ប្រហែលជាមានជំនឿយល់ថា មានតែជនជាតិខ្មែរទេដែលចេះធ្វើបុណ្យ ឯជនជាតិដទៃគ្មានចេះធ្វើបុណ្យទានអ្វីទេដឹង? ឬយល់ថា ការធ្វើបុណ្យទានមានតែក្នុងពុទ្ធសាសនាទេដឹង? បើយល់ដូច្នោះមែន ឲ្យឈ្មោះថាសេចក្តីយល់នោះនៅក្នុងផ្នត់ផ្នែងសេចក្តីឆ្កឹតឆ្គងល់ចង្អៀតចង្អល់ណាស់ មិនគាន់ឈ្មោះថាមានសេចក្តីយល់ដ៏ទូលំទូលាយ ឬ ត្រឹមត្រូវនៅឡើយ ម្ល៉ោះហើយបានជា

មានមនុស្សខ្លះមានគំនិតយល់ថែបនេះកំមាន តាល់គំនិតគិតមិនឃើញកំមាន អ្នកខ្លះបើធ្វើបុណ្យអ៊ីចឹងឲ្យបុណ្យនោះជួយឆាប់ៗ តាមគោលបំណងដែលខ្លួនត្រូវការ តាលថើមិនបានសម្រេចដូចបំណងទេ កំភ្លាយទៅជាមនុស្សមិច្ឆាទិដ្ឋិ លះបង់នូវការកុសលដែលខ្លួនធ្លាប់ធ្វើមកហើយនោះចោលចេញ ដោយគិតឃើញថា ឯងទំប្រឹងធ្វើសេចក្តីល្អគឺឲ្យតែនរក្សាសីលណាស់ដែរ ប៉ុន្តែនៅតែមានការដួបប្រទះ នឹងទុក្ខទោសគ្រោះថ្នាក់អន្តរាយមិនសូវស្រាកយ៉ាងនេះកំមាន ។

ក្នុងបញ្ហាខាងលើនេះ សូមជ្រាបថា ការធ្វើបុណ្យកុសលមិនមែនមានចំពោះតែក្នុងពុទ្ធសាសនាប៉ុណ្ណោះទេ សូម្បីក្រៅពីពុទ្ធសាសនាដូចជាសាសនាដទៃខ្លះ ក៏គង់មានការធ្វើកុសលសេចក្តីល្អ ជាបុណ្យខ្លះដែរ ព្រោះថាកុសលចែកជា ៣ ផ្នែកគឺហៅថា ~~កាយ~~ វចីកុសល ១ រូបាវចរកុសល ១ អរូបាវចរកុសល ១ ។ កុសលទាំង ៣ យ៉ាងនេះ មានតែធ្វើកើត ធ្វើបាន តាំងពីមុនពុទ្ធកាល គឺមុនដែលព្រះពុទ្ធមិនទាន់បានត្រាស់ដឹងឡើងក្នុងលោកម្ល៉ះ ។

បណ្តាកុសលទាំង ៣ យ៉ាងនោះ ត្រង់កាមាវចរកុសលមួយនេះជាកុសលដ៏ខ្ពស់ខ្ពុលយ៉ាងណាស់ ខុតជាជាតិណា សាសនាណា ក៏គង់មានគេកាន់ គេប្រព្រឹត្តធ្វើបានខ្លះដែរ ពោះបីតិចច្រើន ដោយហោចទៅសូម្បីសត្វតិរច្ឆានខ្លះ ក៏អាចធ្វើកាមាវចរកុសលនេះបានដែរ មិនចាំបាច់ពាក្យ

ទាហរណ៍លើកមកជាបុគ្គលាធិដ្ឋានថាដូចជាសត្វនេះ ឬសត្វនោះទេ បើ
ជាទឹកពេញដោយខ្លួនឯងទៅក៏គង់ឃើញថាខ្វះពុំមាន ព្រោះហេតុ
នោះ យើងដែលជាពុទ្ធសាសនិកអ្នកមានជំនឿកាន់ខាងពុទ្ធសាសនា កុំ
អាលស្មានថាជនជាតិដទៃ មិនឃើញមានធ្វើបុណ្យទានកុសលអ្វីសោះ
នោះ ប្រហែលជាពុំសូវសមទេ ឬយើងយល់ថា កុសលតាំង ៣ យ៉ាង
មានកាមាវចរកុសលជាដើម តើតមានតែក្នុងពុទ្ធសាសនាទេដឹង ? បើ
យល់ដូច្នេះមែន ពុកថាសេចក្តីយល់នោះ ជាការខុសស្រឡះ ភ្លេចយ៉ាង
ដូចព្រាហ្មញ្ញសាសនា គឺសាសនាព្រាហ្មណ៍ ជាសាសនាចាស់មានមក
ជាយូរអង្វែងហើយ តាំងតាំងពីមុនពុទ្ធកាលម៉្លេះ សាសនានេះក៏មានន័យនិ-
យាយតន្យល់ពីដំណើរបុណ្យនឹងគេបាប ឬពីកុសលផ្សេងៗ មានកាមាវចរ
កុសលជាដើម ស្រេចគ្នានឹងពុទ្ធសាសនាខ្លះដែរ មានបរិស័ទអ្នកកាន់
សាសនានេះ គេធ្វើបុណ្យឲ្យទាន សង្គ្រោះសូមយាចកអ្នកកំសត់ទុគ្គត
ក្បាស់លាសង្រ្គមកាយវាចា ពោះបីដឹងដល់ក្តី មិនដឹងដល់ក្តី តាំងនេះក៏ពាប់
ថាជាកុសលមួយរហៀថាកាមាវចរកុសលដែរ ដោយអំណាចកាមាវចរកុ-
សលនេះ គង់តែគេបានទៅកើតក្នុងសុគតិភពណាមួយពុំខាន មិនតែប៉ុណ្ណោះ
មានយោគីឬតាបសខ្លះ ជាអ្នកបួសពួកមួយខាងក្រៅពុទ្ធសាសនាទេ ប៉ុន្តែ
ជាកម្មកិច្ចបុគ្គល គេអាចតាំងព្យាយាមប្រព្រឹត្តតបធម៌ស្ងប់ស្ងាត់យ៉ាងតឹង
រឹង រហូតដល់ញុំាងរូបសមាបត្តិ ឬអរូបសមាបត្តិនឹងអភិញ្ញាជាន់ខ្ពស់ឲ្យ

កើត ដូចអាឡារគាមសន្ធឹងទុកគាមសជាគួយាន ។ កុសលចិត្តដែល
កើតឡើងដោយអំណាចសមាបត្តិទាំងនេះ ហៅថារូបាវចរកុសល ឬអ
រូបាវចរកុសល ជាកុសលអាចញ៉ាំងយោគី ឬតាបសពួកនោះឲ្យទៅកើត
ក្នុងជាន់រូបព្រហ្មទាំងអរូបព្រហ្មបាន ។

មានជនជាតិដទៃខ្លះទៀត មិនប្រាកដថាជាអ្នកកាន់សាសនាអ្វីទេ
ប៉ុន្តែគេមានចិត្តប្រកបដោយសប្បុរិសធម៌ ចំណាយទ្រព្យធន កសាង
របស់ជាប្រយោជន៍សាធារណៈដូចសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន
ស្រះទឹក អណ្តូងទឹកជាដើម អំពើទាំងអស់នេះ តើយើងយល់ថាមិនមែន
ជាបុណ្យកុសលទេឬ ? មួយទៀត ដូចជនជាតិចិនដែលយើងធ្លាប់ឃើញ
ស្រាប់ហើយ គេមានកតញ្ញូកតវេទិតាធម៌ចំពោះមាតាបិតារបស់គេ តាំង
ពីនៅរស់រហូតដល់អស់ជីវិតទៅហើយ កាលបើដល់រដូវ គេទៅជម្រះទី
ដាំផ្សេត លើកដីថ្មីពូនបន្ថែមឲ្យស្អាត ហើយគេរៀបចំគ្រឿងសក្ការៈ
ផ្សេង ។ ដាក់សែនទុំសែនឆ្ពោះទៅកន្លែងមាតាបិតា ឬដីដូនដីតារបស់គេ
ដោយគាបជាអ្នកមានកតញ្ញូកតវេទិតាធម៌ពិត ។ ត្រង់ការបានឬមិនបាន
ដល់ឬមិនដល់នោះយើងកុំបាច់និយាយចុះ គឺនិយាយចំពោះតែត្រង់អាការ
ដែលគេធ្វើដោយចិត្តស្មោះសរដៅទៅកន្លែងដ៏មានគុណានោះ ដូច្នេះតើ
យើងអាចបាត់ថាជាកុសលឬទេ ? យើងយល់ថាពិតជាកុសលរបស់គេ
ជាប្រាកដ ។ កុសលចិត្តនេះឯងហើយ ដែលអាចញ៉ាំងគេឲ្យបាន

ខ្លួនឲ្យអាងសង្ឃឬសម្បត្តិផ្សេង ។ មានសេចក្តីសុខចំរើន ក្នុងមនុស្ស
លោកនេះជាដើម កាលបើដូច្នេះ យើងនឹងថាខ្លួនថាគេគ្មានធ្វើបុណ្យទាន
អ្វីសោះ ក៏ដូចជាតុំសមសោះ ឯយើងដែលប្រកាសខ្លួនថាជាអ្នកពុទ្ធសា-
សនិកនោះ ប្រហែលជាយល់ថាបុណ្យកុសលមានតែក្នុងពុទ្ធសាសនាតែ
ម្យ៉ាងទេដឹង ឬយល់ថា លុះតែចូលវត្តក៏ធ្វើបុណ្យទានចំពោះព្រះសង្ឃ
ទើបហៅថាធ្វើបុណ្យទេដឹង ? បើយល់ដូច្នេះមែន ឈ្មោះថាយល់ឃើញ
ខ្វី ឬយល់ឃើញតែម្ខាង ។ ព្រោះកាមាវចរកុសលនេះ ដូចបានភណិ-
តាតាំងដើមរួចមកហើយថាជាកុសលដ៏ខ្ពស់ខ្ពល់ណាយជាយធ្វើ កុំបាច់និ-
យាយឡើយចំពោះទានដែរគេធ្វើដល់មនុស្ស សូម្បីគេធ្វើដល់សត្វតិរច្ឆាន
ក៏ឈ្មោះថាបានបុណ្យខ្លះដែរ ។

ខ្ញុំនិយាយរៀបរាប់មកនេះ មិនមែននិយាយប្រកបដោយអគតិ លំ-
អៀងទៅកាន់ជើងសាសនាណា ឬ ជាតិណានិមួយទេ គឺគ្រាន់តែនិយាយ
វែកញែកឲ្យឃើញជាសេចក្តីតាមការណ៍ពិតប៉ុណ្ណោះ ។ ត្រង់ការធ្វើបុណ្យ
ឲ្យទានជាសាធារណៈ ខ្លួនមិនចំពោះបដិគ្គាហកៈខាងក្នុងពុទ្ធសាសនាឬ
ខាងក្រៅពុទ្ធសាសនានោះ ពោះឲ្យដល់មនុស្សថ្នាក់ខ្ពស់ ឬ តាប ឬក៏ឲ្យ
ដល់សត្វតិរច្ឆាន មានគុណធម៌ក្តី គ្មានគុណធម៌ក្តី តែងមែនដែលថាបាន
បុណ្យ ប៉ុន្តែសូមឲ្យអ្នកមានវិចារណញ្ញាណដ៏ល្អ ក៏គួរតែពិចារណារៈ
លៃលកផងដែរ ថ្វីដ្បិតតែថាបានបុណ្យ ដូចគ្នានឹងអ្នកធ្វើស្រែ ។ បើចង់

ចានផលស្រូវច្រើនជាងគេញាំចិត្ត កំគួរពិនិត្យមើលពូជនឹងដីស្រែផង ទើប
អាចសម្រេចផលតាមគោលបំណងដែលខ្លួនត្រូវការនោះបាន ។

សូមអធិប្បាយបញ្ជាក់អំពីផលនៃទានម្តងទៀតថា បុគ្គលអ្នកធ្វើទាន
នឹងត្រូវបានខ្លួលអំណាចផលានិសង្សនៃទាននោះ ឲ្យទៅជាអ្នកមាន
ភោគសម្បត្តិក្នុងជាតិនេះ ឬក្នុងជាតិណាមួយ ក្នុងភពមុខនោះនឹងមានជា
ប្រាកដ ប៉ុន្តែឯផលទានដែលត្រូវបានក្នុងជាតិណាមួយក្នុងភពមុខនោះ ខ្ញុំ
មិនបានលើកយកមកពណ៌នាបញ្ជាក់ក្នុងទីនេះទេ គឺនិយាយចំពោះតែផល
ដែលថាត្រូវផ្តល់ឲ្យក្នុងជាតិនេះ ។ ចុះផលរបស់ទាន ដែលត្រូវផ្តល់ឲ្យ
ក្នុងជាតិនេះ តើនឹងផ្តល់ឲ្យដោយវិធីណា? បើផលរបស់ទាននោះ បំរុង
តែនឹងចេញមុខឲ្យផលដល់យើងជាម្ចាស់ទានពិតមែន ប៉ុន្តែបើយើងជា
មនុស្សខ្ជិលច្រអូសនៅតែស្ងៀម គ្មានការយកវិការប្រាថ្នាការងារអ្វីខំមួយ
សោះ តើអំណោយផលរបស់ទាននោះ នឹងអាចឲ្យផលកើតដែរឬទេ?.
ពិតជាមិនកើតទេ ព្រោះហេតុអ្វី?. ព្រោះគ្មានហេតុជាបច្ច័យនាំអោយឲ្យ
កើត ។ ដំណើរនេះគួរជ្រាបថា ខ្លួនយើងត្រូវផ្តើមពឹងខ្លួនយើងជាមុន គឺ
ត្រូវប្រាថ្នាការងារណាមួយឲ្យជាហេតុឲ្យបានសិន ប៉ុន្តែបើការងារដែល
ផ្តើមធ្វើនោះ ជាការងារបំបិចបំបិចបន្តិចបន្តួច ក៏មិនអាចឲ្យសម្រេចប្រយោជន៍
ដ៏ធំដុំបានដែរ ។ ឧទាហរណ៍ដូចអ្នកធ្វើបេកសិកម្ម គឺមានត្រឹមតែដាំស្រែអំពក
មួយឬពីរ ឬក៏មានដីចំការត្រឹមតែមួយក្បាលតូចបុំណ្ណោះ បើខាងបេរ

តាណាជ្ជកម្ម (ការជួញ) គឺមានតែដំនួញរបៀបប៉ុណ្ណោះ ចាំធ្វើមិន
សមចំនង់ទៅតាមកាលៈទេសៈផង តុំនោះសោតបើពុកជាមានដីស្រែចំ-
ការ ឬរបៀបដំនួញច្រើនលើសពីនោះក៏ដោយ ប៉ុន្តែខ្លួនជាមនុស្សលែងលះ
ខ្ជិលច្រអូស គ្មានការតស៊ូ មិនប៉ុនប្រសប់ក្នុងការងារ មានចរិយាថោក
ទាប ខ្វះសម្បទាចាំង ៤ យ៉ាងមានឧដ្ឋានសម្បទាជាដើម បើប្រកបដោយ
ហេតុដូចថាមកនេះ ចំណែកទាំងបុណ្យ ដែលបំរុងនឹងឧបត្ថម្ភផ្គត់ផ្គង់ឲ្យ
នោះ ក៏នឹងរកឧកាសឲ្យផលតុំតើតដែរ ប្រៀបដូចមនុស្សណាមួយ ជា
អ្នកខ្ជិលច្រអូសផង គ្មានសច្ចធម្មក្នុងខ្លួនផង លួចឆ្មើងផង មានចរិយាថោក
ទាបផង ហើយទៅពឹងពាក់ជ្រុលស្រែយឧទ្ទិងអ្នកមានទ្រព្យសម្បត្តិឲ្យគេជួយ
ឧបត្ថម្ភខ្លួនដោយជ្រុលក់ការ ដើម្បីប្រកបការងារគេស៊ី អ្នកមានទ្រព្យ
សម្បត្តិនោះ កាលបើគេដឹងឮឃើញថាមនុស្សនេះ ជាអ្នកខន់ខ្សោយ
ខ្វះសមត្ថភាពគ្រប់យ៉ាងហើយ គេគ្រាន់តែមានមេត្តាចិត្តទៅគេប៉ុណ្ណោះ
ប៉ុន្តែគេនឹងចេញទ្រព្យសម្បត្តិ ជួយឧបត្ថម្ភទៅតាមសំណូមរបស់ខ្លួនផងតុំ
បាន យ៉ាងណា តុំនោះសោត ប្រៀបដូចពពែជើ ជាស្តេចនៃម្រឹគទាំង
អស់ ជាសត្វមានឥទ្ធានុភាពខ្លាំងពូកែអស្ចារ្យ ឯសត្វទ្វេបាទ ចតុប្បាទដទៃ
គ្រាន់តែក្រឡេកឃើញពពែជើ ក៏តក់ស្លុតខ្លាចញ័រចំប្រប់ ស្ទើរ
តែក្សិណក្សយជីវិត ប៉ុន្តែបើពពែជើ ដោយអាងថាអញជាស្តេចនៃម្រឹគ
ហើយដេកសម្ងំស្ងៀម ហាមាត់ចង្រ្កឹង ដើម្បីឲ្យសត្វម្រឹគចូលមកចូល

កន្លងមកនៃជាអាហារបស់ខ្លួននោះ ប្រាកដជាគ្មានម្រឹតណាមួយព្រមសុខចិត្តរត់ទៅចូលកន្លងមកជស័ហ៍ឲ្យស្លាប់ខ្លួនខ្លះទេ ។ នោះឡើយ កជស័ហ៍នោះលុះមានការងារការ ប្រកបដោយព្យាយាមស្វែងរកផង ទើបបានម្រឹតនោះមកជាអាហារបស់ខ្លួន យ៉ាងណាមិញ ចំណែកខាងផលបុណ្យដែលចំរើនធ្វើឲ្យ ក៏ត្រូវប្រឹងធ្វើឲ្យបានផលឲ្យខ្ពស់ដែរ ។

ត្រង់ពាក្យមួយម៉ាត់ខាងដើម ដែលថាខ្ញុំយាយមកហើយថា សូមឲ្យកន្លងសាសនាដទៃខ្លះក្រៅពីពុទ្ធសាសនាដែលថាកម្មវាទី កំមានន័យយោបល់ការប៉ះពេញកុសលផ្សេង ។ ចំពោះតែការចំរើនកុសល រួចាំចំរើនកុសល អរួចាំចំរើនកុសល ដូចជាកន្លងពុទ្ធសាសនាដែរ ហើយមានន័យគេពេញចិត្តជ្រះថ្លាធ្វើបុណ្យឲ្យទានរក្សាសីលហើយបានទាំងទៅកើតក្នុងសុគតិភពជាមនុស្ស ឬជាទេវតាណាមួយដោយកម្លាំងនៃការចំរើនកុសលនោះក៏មានមានយោគៈ តាមសទ្ធរបួសខាងក្រៅពុទ្ធសាសនា ព្យាយាមប្រព្រឹត្តតបធម៌យ៉ាងតឹងរ៉ឹងថ្នាក់ទ្រឹង្គដែលហៅថាធ្វើសមាធិ អាចញុំាងឈានទី៨ អភិញ្ញាឲ្យកើតឡើង លុះដល់ទីបំផុតនៃជីវិត ក៏បានកើតកន្លងជាន់ព្រហ្ម ឬអរូបព្រហ្ម ដោយកម្លាំងរួចាំចំរើនកុសល ឬអរួចាំចំរើនកុសលនោះក៏មានបើតាមសេចក្តីអធិប្បាយនេះ សឲ្យយើញថា ខាងក្រៅពុទ្ធសាសនាក៏គង់មានផ្លូវធ្វើសេចក្តីប្រតិបត្តិអាចឈោងចាប់យកត្រឹមសម្បត្តិសួគ៌ សម្បត្តិព្រហ្ម ឬសម្បត្តិមនុស្សដូចពុទ្ធសាសនាបានដែរ គ្រាន់តែមិនមានអរិយ-

មគ្គ អរិយផលប៉ុណ្ណោះ ព័ត្រោះព្រហ្មញ្ញសាសនានេះ ជាសាសនាទៅប្រ-
ចាំលោកតែមានមកតាំងអំពីកាល ដែលទើបនឹងកកើតផែនដីឡើងជាដំបូង
ហើយបន្តាប់មកមានមនុស្សកើតឡើង ឯសាសនាក៏កើតឡើងក្នុងសម័យ
ដែលមានមនុស្សនោះដែរ ព្រោះមូលហេតុដែលនាំឲ្យកើតសាសនាមាន
៣ យ៉ាងគឺ

១- សេចក្តីខ្លាច

២- សេចក្តីត្រូវការ

៣- សេចក្តីខ្វះខាត ។

សេចក្តីខ្លាច ជាមូលហេតុនាំឲ្យកើតសាសនា ដូចម្តេច ? ធម្មតា
មនុស្សក្នុងលោក សុទ្ធតែមានសេចក្តីស្រឡាញ់ជីវិតគឺការចង់រស់នៅជា
ប្រក្រតី កាលបើមានហេតុអ្វីជាសត្រូវកើតឡើង បំរុងនឹងប៉ះពាល់ដល់
ជីវិតរបស់ខ្លួន រមែងមានសេចក្តីកិតក័យតក់ស្លុតដោយហេតុតែខ្លាចវិ-
នាស ម្ល៉ោះហើយក៏ស្រែះស្រាវរកវិធីសិក្តិសិទ្ធិ្ធ សម្រាប់ឃុំគ្រងការពារ
កំដរកុំឲ្យជីវិតវិនាសដោយហេតុណាមួយ ដូចមានពុទ្ធដីកាក្នុងគម្ពីរធម្មបទ
ជាព័ស្តុតាងស្រាប់ថា :

ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា

សេចក្តីថា មនុស្សមានចំនួនច្រើន កាលបើត្រូវភ័យគម្រាមសម្លុត

ហើយ រមែងរត់ទៅរកយកក្តីកំមាន យកព្រៃឈើកំមាន យកសួនច្បារ
កំមាន យកដើមឈើជាចេតិយកំមាន ជាទីតឹងប្តូជាបង្គួត (នៃជីវិត
របស់ខ្លួន) ។ សេចក្តីភ័យខ្លាចនេះឯង ជាមូលហេតុនាំឲ្យកើតសាសនា ។

សេចក្តីត្រូវការ ជាមូលហេតុនាំឲ្យកើតសាសនា ដូចម្តេច ? ធម្ម-
តាមនុស្សនីមួយ ។ នឹងបណ្តាយឲ្យនៅតាមចំនើនចិត្ត ពេលតែឯកឯង
គ្មានពិធីកម្មណាមួយជាច្បាប់សម្រាប់ឃុំគ្រង ដើម្បីឲ្យមានរបៀបរៀបរយ
តុំបាន កាលបើធ្វើជាមនុស្សនៅចំនេះ ឥតមានច្បាប់ឃុំគ្រងជួយការពារ
ទេ រមែងក្លាយទៅជាមនុស្សឥតសណ្តាប់ធ្នាប់ព្រៃហើនកោងកាច ហ៊ាន
ប្រព្រឹត្តអំពើអាក្រក់ផ្សេង ។ មានការសម្ងាប់ជីវិតគេ បៀតបៀនយកទ្រព្យ
សម្បត្តិគេជាដើម ដោយហេតុថាអំពើអាក្រក់មិនជាទីស្រឡាញ់ពេញចិត្ត
នៃមនុស្សសត្វខ្លួនទៅ ទើបគេត្រូវការតែងតាំងបទបញ្ញត្តិជាច្បាប់សម្រាប់
គ្រប់គ្រងការពារ ដើម្បីឲ្យមនុស្សមានចរិយាសណ្តាប់ធ្នាប់ល្អរវាងគ្នាខឹងគ្នា
ឡើង សេចក្តីត្រូវការនេះឯង ជាមូលហេតុនាំឲ្យកើតសាសនា ។

(នៅមានត)

ចាក់ធម្មបទ - ខុទ្ទកនិកាយ

លោក ខោង-សមអាន រៀបរៀង

(តមក)

ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា កិលេសជាមលធំណាស់ ការមេសុមិច្ឆាចារ ដែលបុគ្គលបានធ្វើហើយ ជាអំពើប្រព្រឹត្តទៅដើម្បីអបាយ នាំជនទាំងឡាយដល់នូវសេចក្តីវិនាសកន្លងបច្ចុប្បន្ន គឺ : វិនាសទ្រព្យសម្បត្តិដែលរកបានមកល្មមប្រើប្រាស់គ្រប់គ្រាន់ ក៏ត្រឡប់ជាមិនគ្រប់គ្រាន់វិញ ព្រោះអំពើនេះត្រូវតែជំនួសហេតុ ចាយកាយហួសខ្នាត ។ វិនាសញាតិ-មិត្រទាំងឡាយដែលធ្លាប់កាន់ចិត្តស្និទ្ធស្នាល ព្រោះមនុស្សដែលប្រព្រឹត្តការមេសុមិច្ឆាចារនេះ រមែងតែតែហ៊ានឡើង ជាបបដល់ក្រុមមិត្រ ឥតគិតចិត្តនរណាសោះ ប្រពន្ធកូននរណាក៏ដោយ ឲ្យតែបូស្ម ការបើដូច្នោះ ឱធ្លាក់ខ្លួនទៅជាគ្រោនានាគ្មាននរណាចូលចិត្ត ។ វិនាសខ្លួនច្រណែ ដែលធ្លាប់មានកម្លាំងធ្លាប់មានសាច់ឈាមល្អ ធ្លាប់ជាអ្នកមិនមានពេត ក៏ត្រឡប់ទៅជាមនុស្សមានការពេត ខ្លួចខ្លួនអសារឥតការ លុះស្លាប់ទៅទៀតតែទៅកើតកង់នរក រួចពីនរកមកកើតជាប្រេត រួចពីប្រេតមកកើតជាអសុរកាយ

រួចពីអសុរកាយ មកកើតជាតិរួចទន រួចពីតិរួចទន មកកើតជាមនុស្សខ្ទើយ រួចពីខ្ទើយមកកើតជាមនុស្សស្រី មានប្តីនៅជាមួយគ្នាមិនបាន (១) ។

ការមេសុមិច្ឆាចារកម្ម លោកឲ្យឈ្មោះថា " ចារ " ជាអំពើមិនត្រូវធ្វើឡើយ ។

វិបត្តិកម្ម

វចីកម្ម គឺអំពើដែលធ្វើអាក្រក់ដោយសំដី មាន ៤ យ៉ាងគឺ : មុសាវាទ ១ បិសុណាវាទ ១ ផរុសវាទ ១ សម្ផប្បលាបវាទ ១ :

៤- មុសាវាទ គឺរៀបរាលទូវពាក្យកុហក ។

ពាក្យកុហក ធ្វើឲ្យអ្នកដទៃវិនាសទ្រព្យសម្បត្តិក៏មាន វិនាសយសសក្តិក៏មាន វិនាសដំណែងក៏មាន ឲ្យកើតសេចក្តីលំបាកផ្សេងៗក៏មាន ។ មុសាវាទនេះ ខ្លួនជាអ្នកស្អប់មិនដឿ មិនធ្វើតាមក៏ឈ្មោះថា រៀបរាលពាក្យកុហក ជាហេតុធ្វើឲ្យអ្នកដទៃ មិនដឿពាក្យសំដីពាំងអស់ គឺគេដឹងថា អ្នកនោះឆ្លាប់កុហក ថ្ងៃក្រោយនិយាយត្រង់ក៏គេមិនដឿ ។ អំពើកុហកនេះ បើមានកម្លាំងច្រើនក៏អាចធ្វើឲ្យឃើញៗសកង់ចុចប្បន្ននេះ ។ ភាហារណ៍ដូចជា :

១- អង្គុត្តរនិកាយ អដ្ឋកថានិបាតសព្ទលហុសូត្រ ។

រឿងនាងចិញ្ចមាណវិកា

កាលព្រះបរមសាស្តាចារ្យនៃមនុស្សទាំងពួង ទ្រង់គង់ក្នុងវត្តជេតពន នាក្រុងសាវត្ថីនៃដែនកោសល ព្រះអង្គគង់លើតេនបល្ល័ង្ក សំដែងព្រះធម៌ ដោយមានពុទ្ធបរិស័ទចាំង ៤ ពួកគឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា អង្គុយតាល់ស្តាប់ព្រះធម៌ទេសនា ។ នាងចិញ្ចមាណវិកាបានឧទ្ទិសបញ្ឆោតពួកតិត្ថិយ ទៅនិយាយកុហកបង្កាច់ព្រះសាស្តាចារ្យ ដោយមេថុនធម្ម ចំពោះមុខពុទ្ធបរិស័ទ ។ តែដោយបារមីព្រះអង្គ មានព្រះឥន្ទ្រមកជួយក្នុងរឿងនោះ នាងចិញ្ចមាណវិកាក្លែងចោទបង្កាច់មិនបានត្រឡប់ជាមានទោស គឺពួកមហាជនក៏យកជាក់ហៀបនឹងស្លាប់ ។ លុះគេចផុតពីទីនោះទៅ ទើបតែផុតកន្លុះព្រះនេត្រព្រះសម្មុខ ផែនដីមិនអាចទ្រទ្រង់បាន ក៏ស្រូបទម្លាក់ចុះទៅក្នុងអវីចីមហានរក រងទុក្ខវេទនា រហូតសព្វថ្ងៃនេះ ។

ព្រោះហេតុនោះ ព្រះមានព្រះភាគបរមគ្រូទ្រង់ត្រាស់ថា « ម្នាលភិក្ខុទាំងឡាយ ! មុសាវាទ ដែលបុគ្គលបានពោលហើយ ជាអំពើប្រព្រឹត្តទៅដើម្បីអបាយ (គឺឲ្យទៅនាសអន្តរាយក្នុងទ្រព្យសម្បត្តិក៏មាន ឲ្យទៅកាយដល់ខ្ទួនក៏មាន ជួនកាលស្លាប់ខ្ទួនក៏មាន) លុះស្លាប់ទៅ ទៀងតែទៅកើតក្នុងនរក រួចពីនរកមកកើតជាប្រេត រួចពីប្រេតមកកើតជាអសុរកាយ រួចពីអសុរកាយមកកើតជាតិរច្ឆាន រួចពីតិរច្ឆានមកកើតជា

មនុស្ស តែជាមនុស្សត្រូវគេបង្អាប់បង្ខូចដរាប តើថាកំហុសបុគ្គលដទៃ
សោះ ស្រាប់តែកំហុសនោះធ្លាក់មកខ្លួនវិញ ហើយជាមនុស្សមានតំណែប
រឿច-ស្អុយ(១)» ។

មុសាភាឝ ជាពាក្យអាក្រក់ លោកឲ្យឈ្មោះថា ចាប ជាពាក្យ
មិនត្រូវគោលឡើយ ។

៥- បិសុណាភាឝ កិរិយាគោលនូវពាក្យញុះញង់ សឹកសៀត
បំបែកបំបាក់អ្នកដទៃ ។

ពាក្យញុះញង់សឹកសៀត គឺវើសយកពាក្យខាងម្ខាង ទៅប្រាប់ដល់
ម្ខាង ដោយចេតនាប្រាថ្នាឲ្យគេស្អប់ខ្ពើមមនុស្សដែលខ្លួនមិនត្រូវចិត្ត។
បើរឿងនិយាយញុះញង់ជាពាក្យពិត ក៏គ្រាន់តែជាបិសុណាភាឝតែម្យ៉ាង
ប៉ុណ្ណោះ បើរឿងនិយាយញុះញង់ជាពាក្យមិនពិតផង ក៏ជាមុសាភាឝ
ថែមទៀត ។

ពាក្យញុះញង់សឹកសៀត ជាពាក្យទាំងឲ្យអ្នកស្អាប់បែកចេញពីគ្នា
ឈ្លោះវិវាទចងពៀរនឹងគ្នា ។ មិនតែប៉ុណ្ណោះ ឆ្លើតទាំងអ្នកនិយាយនោះ
ឲ្យកើតសេចក្តីក្តៅក្រហាយដល់ខ្លួនវិញក្នុងជាតិនេះក៏មាន ទន្ទឹងជាតិខាង
មុខក៏មាន ឧទាហរណ៍ដូចជា ៖

១- អង្គុត្តរនិកាយ អដ្ឋកថាទំនៅត សព្វលហុសូត្រ ។

រឿងស្មូករប្រែត (១)

កន្លងសាសនកាលនៃព្រះពុទ្ធព្រះនាម កស្សប មានភិក្ខុពីរបួរួមអាវាសជាមួយគ្នា ព្រះមហាថេរបួសបាន ៦០ វស្សា អនុថេរ បួសបាន ៥៩ វស្សា ស្រឡាញ់គ្នាដូចជាបងប្អូនបង្កើត ។

គ្រានោះ មានភិក្ខុជាធម្មកថិក ១ រូប បានមកទៅអាវាសនោះ ឃើញវត្តនោះសម្បូណ៌បរិភោគ ក៏ចង់និយាយញុះញង់បំបែកព្រះថេរៈទាំងពីរឲ្យបែកគ្នា ទើបនិយាយថា « បពិត្រលោកម្ចាស់ដ៏ចំរើន តាំងពីខ្ញុំព្រះករុណាមកដល់ អនុថេរតែងនិយាយនឹងព្រះករុណាថា ម្នាលលោកសប្បុរស លោកជាកុលបុត្រ ឯមហាថេរជាតិភិក្ខុអលជ្ជី គ្មានសីលជាទីស្រឡាញ់ឡើយ បើលោកអួរមានជាមួយមហាថេរនោះ ត្រូវតិចារណាសិន » ។ ព្រះធម្មកថិក គោលញុះញង់ព្រះមហាថេរហើយ ក៏ទៅនិយាយញុះញង់អនុថេរដូច្នោះដែរ ។ ព្រះថេរៈទាំងពីរបែកចិត្តគ្នាក៏ដើរចេញពីវត្តនោះទៅទីនៃតាគ្នា ។

លុះកន្លងចំនួន ១០០ វស្សា ក៏បានជួបគ្នាហើយនិយាយប្រាប់គ្នានឹងគ្នា ជឿជាក់មិនមែនដូច្នោះ ក៏ស្រុះស្រួលគ្នាទៅបណ្តេញព្រះធម្មកថិកចេញពីវត្តនោះទៅ ។

---

១ ធម្មបទដ្ឋកថាមលវគ្គ

សមណធម៌ដែលព្រះធម្មកថិកបានធ្វើហើយ ២ ហ្នឹងឆ្ងាំ កំមិនអាច
ទ្រទ្រង់ព្រះធម្មកថិកបានឡើយ លុះព្រះធម្មកថិកនោះអស់ព្រះជន្មាយុ
បានទៅកើតកន្លែមហាអវិចីនរកអស់ ១ តុន្ទន្តរ ដល់មកសាសនាព្រះពុទ្ធ-
គោតមយើងនេះ សត្វនរកនោះមកកើតជាប្រេតឈ្មោះ ស្នូកករ ទៅនា
ភ្នំគិជ្ឈកូដ មានសរីរៈដូចជាមនុស្ស មានកំពស់ ៣ គាវុត(១) មានក្បាល
ដូចជាដ្រក មានកន្ទុយចេញពីមាត់ ហើយមានដង្កូវហូរចេញពីមាត់នោះ
ជាច្រើន ។

ព្រោះហេតុនោះ ព្រះសក្យមុនីជាម្ចាស់ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ
ទាំងឡាយ កិរិយាញុះញង់ដែលបុគ្គលបានគោលហើយ ជាអំពើប្រព្រឹត្ត
ទៅដើម្បីអធ្ម៌ឃ គឺនាំឲ្យវិនាសសេចក្តីសុខផ្ទាល់ខ្លួន ទំាងសេចក្តីសុខ
សម្រាប់ស្រុកទេស ព្រោះថាបុគ្គលណាគោលញុះញង់បំបែកបំបាក់គ
សេចក្តីបែកបាក់នោះទំាងឆ្ងាក់មកលើខ្លួនវិញ ហើយឥតមានសាមគ្គីជា
កម្លាំងប្រទេសឡើយ ។

ម្យ៉ាងទៀត ប្រទេសណាមានមនុស្សប្រព្រឹត្តញុះញង់គ្នា ប្រទេស
នោះមិនស្ងប់បានសន្តិសុខទេ ច្រើនតែមានរឿងហេតុនាំឲ្យខូចប្រយោជន៍
នាំឲ្យទៅកាបដល់ជាតិនឹងប្រទេស ។ មនុស្សប្រព្រឹត្តនូវពាក្យញុះញង់
នោះ លុះស្លាប់ទៅទៀងតែទៅកើតក្នុងនរក រួចពីនរកមកកើតជាប្រេត

---

១ អាត្រាវិស់មានចំនួនពីរពាន់ព្យាម ត្រូវជាមួយរយសិន ។

រួចពីប្រេតមកកើតជាអសុរកាយ រួចពីអសុរកាយមកកើតជាតិរច្ឆាន រួចពីតិរច្ឆានមកកើតជាមនុស្ស តែជាមនុស្សត្រូវបែកធ្លាក់ម៉ត្រសម្លាញ់ ឥតមានឧណាស្រឡាញ់ដូច្នេះស្មាលឡើយ ។

បិសុណាវាចា ជាពាក្យអាក្រក់ លោកឲ្យឈ្មោះថា ចាប ជាអំពើមិនត្រូវគោលឡើយ

ខ - ផរុសវាចា កិរិយាពោលនូវពាក្យគ្រោះថ្នាក់ដល់ប្រ-ពេចអ្នកដទៃ ។

បុគ្គលដែលមានបំណងទំនងឲ្យអ្នកដទៃអប្បិយស ហើយនិយាយបន្ទុះបន្ទាប់ថា "អាឯងជាជាតិតាល" ឬនិយាយចំអកថា "អើចាឯងជាជាតិបណ្ឌិតហើយ ដូច្នេះជាដើម ហៅថាសំដីគ្រោះ សំដីគ្រោះនេះឯងតែងធ្វើអ្នកដែលស្តាប់ឲ្យច្រណែនខឹង ហើយដេរប្រពេចផ្តាសាមកវិញ កាលបើតបតគ្នាទៅវិញទៅមកហើយ ក៏កាលជាលធំថ្នាសឡើង ដកបចង់តៀវដែលគ្នាទំនងគ្នាតទៅបាន ។ សូមតិនិត្យអ្នកដែលឈ្លោះវិវាទាស់ខែងខ្វែងគំនិតគ្នា ដែលធ្លាប់ឃើញមកហើយនោះចុះ ។ ចើដេរប្រពេចផ្តាសាចំនោះបុគ្គលមានគុណច្រើនជាងខ្លួន មានទោសធ្ងន់ ចើមានគុណវិសេសតិចជាងខ្លួន ទោសនោះក៏ស្រាល ដូចជាគោគាលិកភិក្ខុ ដែលធណើស្រូបធ្លាក់ទៅក្នុង បទុមនរក នោះក៏ព្រោះតែទោសដែលដេរប្រពេចព្រះអគ្គសាវក ។

ពាក្យទ្រគោះដេរប្រទេចផ្តាសានេះ សូម្បីតែសត្វតិរច្ឆានក៏មិនពេញចិត្តឡើយ ។ តាហរណ៍ដូចជា៖

រឿងគោធន្ធិវិសាល[1]

មនុញ្ញំ វៃ ភាសេយ្យ ជាមនុញ្ញំ តុជាចរំ
មនុញ្ញំ ភាសមានស្ស តរុភាវំ ឧទព្ភវ៎ា
ឆឆញ្ច ំ អលាភេសិ តេន ចត្តមនោ អហុ[2] ។

"ត្រប់ពេលទំពាំងត្រី បុគ្គលប្រុសស្រីចាំងក្នុងចាស់ ត្រូវពោលពាក្យផ្អែមតិរកេះច្បាស់ មិនត្រូវពោលផ្តាសច្រាសល្អខ្លើយ ។ ការព្រាញ្ញាណ៍ពោលពាក្យស្នេហ៍ស្និទ្ធស្នាល គោធន្ធិវិសាលមិនកន្តើយ ចំអូសរកេះធ្វន់ចាន់ហើយ គោញ៉ាងព្រាហ្មណ៍ឲ្យចាន់មាសច្រាក់" ។

ក្នុងអតីតកាល ព្រះពោធិសត្វយកកំណើតកើតជាគោឈ្មោះ គោធន្ធិវិសាល នៅក្នុងក្រុងតក្កសិលានៃប្រទេសគន្ធារៈ ។ ព្រាហ្មណ៍ជាម្ចាស់នៃគោធន្ធិវិសាល មានសេចក្តីពាប់អាធស្រឡាញ់ពេញចិត្តណាស់ ហាក់ដូចជាកូនបង្កើតរបស់ខ្លួន តែងឲ្យចំណីអាហារ ដល់គោថវិគោតជាពាល់ថ្ងៃ ។ គោធន្ធិវិសាលមានសេចក្តីអនុគ្រោះដល់ព្រាហ្មណ៍ក៏និយាយថា « បពិត្រព្រាហ្មណ៍ ! សូមអ្នកនិយាយថា គោខ្ញុំ ១ អាចអូស

១-ព្រះបរមសាស្តាទ្រង់តំរេងលេបញ្ជាវត្តុយភិក្ខុ ដែលពោលនូវដំណើរវិញ ទើបតាំងអតីតនិទានេះមកលំនែង

២-ជាតកធ្លិវិសាលជាតក ឯកនិបាត

រវេះ ១០០ ដែលចង់ជាប់គ្នា ហើយអ្នកចុះប្តេជ្ញាតាំងក្បាល់ទឹងគោវិទ្ធសេដ្ឋី ជាក់ច្បាក់ ១០០០ គហបណៈចុះ" ។ ឯព្រាហ្មណ៍ជាម្ចាស់ ក៏ទៅនិយាយ ជូនគ្នាះហើយផ្តុំកន្ទូរវេះ ១០០ ដោយការៈដ៏ធ្ងន់ មានដីឡូរច់ក្រួសទឹងថ្ម ជាដើម រៀបចំតាមលំដាប់ ចង់ក្បាច់ដោយខ្សែព្រួរដ៏មាំ ទើបនាំគោឈ្មោះ ខន្ធវិសាលមកចំម ហើយអង្គុយលើកូនរវេះ លើកដងដង្ហូញឡើងស្រែក គម្រាមខន្ធវិសាល ដែលមិនមែនជាគោគៀចថា : នែគោកៀច ! ចូលឯង ទំប្រឹងអូសរវេះនេះទៅ នែគោកៀច ! ចូរឯងប្រឹងអូសការៈធ្ងន់នេះទៅ" ។ គោខន្ធវិសាលបានស្តាប់សំដីមិនជាទីគាប់ចិត្ត ក៏ខំប្រឹងទឹងទៅកន្លែងដែលមាន គ្នានកំរើក ។ ព្រាហ្មណ៍ចាញ់អស់ច្បាក់ ១០០ គហបណៈ ហើយ ត្រឡប់ទៅផ្ទះវិញ មានសេចក្តីស្តាយតេកណាស់ ក៏ដេកសន្ធឹកសន្ធៃ តែម្នាក់ឯង ។

(នៅមានត)

ព្រះអភិធម្មបិដក

គម្ពីរព្រះយមក:

លោក ប៊ូ - ប៉ូ ប្រែរៀបរៀង

(តមក)

បិដ្ឋយមក

យស្ស ចិត្តំ ឧប្បជ្ជតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ ឯ
និរុជ្ឈិស្សតិ យស្ស និរុជ្ឈតិ តស្ស ឧប្បជ្ជិស្សតីតិ ឯ
ឧប្បជិស្សតីតិ ។ អាមន្តា យស្ស ឧប្បជ្ជតិ តស្ស និ-
រុជ្ឈិស្សតិ យស្ស និរុជ្ឈតិ តស្ស ឧប្បជ្ជិស្សតីតិ ។

*លំដាប់ខេះ សូមវិសជ្ជនាក្នុងចិត្តមយកតទៅ ដំណើរសេចក្តីថា
សត្តា សម្តេចព្រះបរមសាស្តាលោកុត្តមាចារ្យ ជម្ចាងម្នុសុគោ-
វិនោ ព្រះអង្គទ្រង់ព្រះប្រាជ្ញាញាណក្នុងធម៌ទំនងមិនមែនធម៌ កាលត្រាស់
ទេសនាអនុសយយមកចប់ហើយ ក្នុងលំដាប់នោះ ទើបត្រាស់ទេសនា
នូវចិត្តយមក.តទៅទៀត ដោយបុច្ឆានិវិសជ្ជនាជាគូៗ គ្នា ទ្រង់ត្រាស់
បុច្ឆាថា យស្ស ចិត្តំ ឧប្បជ្ជតិ ចិត្តនៃបុគ្គលណាកើតឡើង ចិត្តនៃ
បុគ្គលនោះរលត់ទៅ ឬថាមិនចុះរលត់ទេ ចិត្តនៃបុគ្គលណារលត់ទៅ*

ចិត្តនៃបុគ្គលនោះកើតឡើងឬ ឬថាមិនបានកើតឡើងទេ ចិត្តនៃបុគ្គលណាកើតឡើង ចិត្តនៃបុគ្គលនោះ រមែងរលត់ទៅក្នុងបច្ចុប្បន្នឬ ឬថាខឹងរលត់ទៅក្នុងអនាគតកាល ចិត្តនៃបុគ្គលណារលត់ទៅក្នុងបច្ចុប្បន្ន ចិត្តនៃបុគ្គលនោះរមែងកើតឡើងក្នុងបច្ចុប្បន្នឬ ឬថាខឹងកើតឡើងក្នុងអនាគតកាល ?

ទ្រង់ត្រាស់ឫទ្ធដូច្នេះហើយ ទើបត្រាស់វិសជ្ជនាថា អាមន្តា អើ ! ចិត្តនៃបុគ្គលណាកើតឡើង ចិត្តនៃបុគ្គលនោះឯងរលត់ទៅ ចិត្តដែលកើតឡើងហើយនឹងមិនរលត់ទៅវិញនោះគ្មានទេ ចិត្តនៃបុគ្គលណារលត់ទៅ ចិត្តនៃបុគ្គលនោះឯងដែលនឹងមិនកើតឡើងវិញគ្មានទេ ចិត្តនៃបុគ្គលណាកើតឡើងក្នុងបច្ចុប្បន្ន ចិត្តនៃបុគ្គលនោះឯងតែងរលត់ទៅក្នុងបច្ចុប្បន្ន ចិត្តនៃបុគ្គលណាកើតឡើងក្នុងអនាគត ចិត្តនៃបុគ្គលនោះតំរេលត់ទៅវិញក្នុងអនាគត ចិត្តដែលកើតឡើងក្នុងអតីតកាល តំមានតំណត់ថារលត់ទៅហើយក្នុងអតីតកាល ការកើតនឹងរលត់នោះដាច់ដូចគ្នា ចិត្តកើតឡើងក្នុងកាលណា តំរេលត់ទៅវិញក្នុងកាលនោះ ចិត្តដែលកើតឡើងហើយមិនបានរលត់ទៅវិញនោះគ្មានទេ ចិត្តដែលរលត់ទៅហើយនឹងមិនកើតឡើងវិញនោះតំគ្មានដែរ សមតាមបាលីថា អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ ជាអាទិ ។

សង្ឃាទៅនឹងឆ្លើយមិនទៀងខាត់ទេ ព្រោះហេតុអ្វី ព្រោះហេតុថា

កើតឡើងហើយតែងរលត់ទៅវិញ មានការកើតនឹងរលត់ជាធម្មតា ដែលថាកើតហើយរលត់ទៅវិញជាធម្មតានោះ ព្រោះហេតុថា កើតឡើងហើយរលត់ទៅវិញ ។

ប្រការមួយទៀត សម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ថា ចិត្តំ លហុបវត្តំ ចិត្តនោះកើតក៏រហ័សរលត់ក៏រហ័ស ។ ហេតុនោះបានជាពោលថា ចិត្តនៃបុគ្គលណាកើតឡើង ចិត្តនៃបុគ្គលនោះតែងរលត់ទៅវិញ ចិត្តនៃបុគ្គលណារលត់ទៅហើយ ចិត្តនៃបុគ្គលនោះតែងកើតឡើងវិញ ។

គន្ថគម្ពីរព្រះអភិធម្មត្ថសង្គហៈពោលថា ចិត្តមានបួនប្រការគឺកាមាវចរចិត្ត ១ រូបាវចរចិត្ត ១ អរូបាវចរចិត្ត ១ លោកុត្តរចិត្ត ១ ។

កាមាវចរចិត្តមាន ៥៤ គឺអកុសលចិត្តមាន ១២ អហេតុកចិត្តមាន ១៨ កាមាវចរកុសលចាត់ជាសោភណចិត្តមាន ២៤ រួមជាកាមាវចរចិត្ត ៥៤ ។ រូបាវចរកុសលមាន ៥ ។ អរូបាវចរកុសលមាន ៤ ។ លោកុត្តរកុសលចិត្តមាន ៤ ។

អកុសលចិត្ត ១២ នោះ គឺលោភចិត្ត ៨ ទោសចិត្ត ២ មោហចិត្ត ២ រួមបូលគ្នាជា ១២ ដួង ។

អហេតុកចិត្ត ១៨ នោះ គឺអកុសលវិបាកអហេតុក ៧ មហាវិបាកចិត្ត ៨ អហេតុកកិរិយាចិត្ត ៣ រួមបូលគ្នាជា ១៨ ដួង ។

កាមាវចរសោភណចិត្ត ២៤ នោះ គឺមហាកុសល ៨ មហាវិបាក៨ មហាកិរិយា ៨ រួមបូលគ្នាជា ២៤ ដួង ។

រូបាវចរកុសល ៥ នោះ គឺចិត្តកន្លះបឋមជ្ឈាន ១ ចិត្តកន្លះទុតិយជ្ឈាន១ ចិត្តកន្លះតតិយជ្ឈាន ១ ចិត្តកន្លះចតុត្ថជ្ឈាន ១ ចិត្តកន្លះបញ្ចមជ្ឈាន ១ រួមបូលគ្នាជា ៥ ដួង ។ បើគោលដោយតស្ថារូបាវចរកុសលមាន ១៥ ដួង បន្ថែម ១០ មកខ្មែត គឺរូបាវចរវិបាកចិត្ត ៥ រូបាវចរកិរិយាចិត្ត ៥ រួមនឹងចិត្តកន្លះឈាន ៥ ខាងដើមផង ត្រូវជា ១៥ ដួង ។

អរូបាវចរចិត្ត ៤ នោះ គឺអាកាសានញ្ចាយតនចិត្ត ១ អាកិញ្ចញ្ញាយតនចិត្ត ១ វិញ្ញាណញ្ចាយតនចិត្ត ១ នេវសញ្ញានាសញ្ញាយតនចិត្ត ១ ។ អរូបាវចរចិត្តនេះចែកចេញទៅខ្មែតមាន ១២ គឺបន្ថែមវិបាកចិត្ត ៤ និងកិរិយាចិត្ត ៤ ខ្មែត ផ្សំនឹងអរូបាវចរចិត្ត ៤ ខាងដើមផង ត្រូវជា ១២ ដួង។

លោកុត្តរចិត្ត ៤ នោះ បើគោលដោយប្រភេទមាន ៨ ប្រការ គឺចិត្តដើម ៤ ជាមគ្គចិត្ត បន្ថែមផលចិត្ត ៤ ខ្មែត ផ្សំគ្នាជា ៨ ដួង ។

ចិត្តដែលឈ្មោះថា កាមាវចរ នោះ មានពាក្យព្រះអដ្ឋកថាចារ្យ គោលទុកដោយបទវិគ្រោះថា កាមេ អាវចរតីតិ កាមាវចរំ ចិត្តចំពូកណាវមែនប្រព្រឹត្តទៅក្នុងកាមាវចរភព ចិត្តចំពូកនោះឈ្មោះ កាមាវចរចិត្ត ។ ចិត្តជាកាមាវចរមាន ១១ ប្រការ ព្រោះហេតុបង្កើតកន្លងកាមាវចរភូមិ ១១ ។ ឯកាមាវចរភូមិនោះ ខាងក្រោមពីបាតឆ្ងាយពីមហា

អរិចនកម្មឡើងមកជាកម្មជាប់ជាន់ចរនិម្មិតវសវត្តី ឈ្មោះថាកាមកត ព្រោះ
ហេតុជាទីបង្កើតនៃកិលេសកាមនឹងវត្ថុកាម ។

ចិត្តចំពួកណាប្រព្រឹត្តទៅក្នុងកាមាវចរភូមិទាំង ១១ ជាន់នោះ ចិត្ត
ចំពួកនោះឈ្មោះថាកាមាវចរចិត្ត ។

ចិត្តដែលប្រព្រឹត្តទៅក្នុងរូបកត ឈ្មោះ រូបាវចរចិត្ត ។

ចិត្តដែលប្រព្រឹត្តទៅក្នុងអរូបកត ឈ្មោះ អរូបាវចរចិត្ត ។

ចិត្តដែលប្រព្រឹត្តទៅក្នុងលោកុត្តរធម៌ ឈ្មោះ លោកុត្តរចិត្ត ។

អារម្មណំ ចិន្តេសិ ធម្មជាតដែលហៅថាចិត្តនោះ ព្រោះ
ហេតុគិតនូវអារម្មណ៍ ។ ន័យមួយទៀតថា ធ្វើនូវអារម្មណ៍ឲ្យវិចិត្រ ។
ន័យម្យ៉ាងទៀតថា សន្សំនូវសន្តានៃខ្លួន ដោយអំណាចវិថីនៃជវនៈ ។
ន័យម្យ៉ាងទៀតថា ហេតុវិចិត្រដោយសមគួរដល់ប្រកតីនៃខ្លួន ឈ្មោះធ្វើនូវ
អារម្មណ៍ឲ្យវិចិត្រផ្សេង ។ អធិប្បាយថា ប្រកបដោយយាគៈក៏មាន ប្រកប
ដោយទោសៈក៏មាន ជួនកាលប្រកបដោយមោហៈក៏មាន ។

ចិត្តនោះជាពួក ។ ដោយខ្សែកគ្នា គឺចិត្តជាកាមាវចរនោះពួកជាខ្សែ
ចិត្តជារូបាវចរនោះពួកជាខ្សែ ចិត្តជាអរូបាវចរនោះពួកជាខ្សែ ។ ចិត្តមានរូបា-
រម្មណ៍ជាដើមនោះភ្លុកជាខ្សែ ។ ចិត្តដែលមានរូបារម្មណ៍ជាដើមនោះ ជួន
កាលក៏ជាកុសល ជួនកាលក៏ជាអកុសល ។ ឯចិត្តនេះមានច្រើនប្រការ
ណាស់ កម្រនឹងតណិនាឲ្យអស់ឃាន ប៉ុន្តែ អ្នកមានប្រាជ្ញាគប្បីចូលចិត្ត

ថា ចិត្តនេះពោលដោយសង្ខេបមានត្រឹម ៤ ប្រការ គឺ កាមាវចរចិត្ត ១ រូបាវចរចិត្ត ១ អរូបាវចរចិត្ត ១ និងលោកុត្តរចិត្ត ១ ដូចវិសជ្ជនាមកហើយនេះ ។

ចិត្តយមក ចប់ប៉ុណ្ណេះ ។

ធម្មយមក:

ឧទ្ទេសវារៈ

ធម្មយមកតំ ធម្មេ សម្មេ ចព្រះខ្ញុំសូមថ្វាយបង្គំព្រះគាគ ក្រាបទូលសួរនូវធម្មយមក ដែលព្រះអង្គទ្រង់ត្រាស់ទេសនាទុកក្នុងបិដកទាំងបី ។ ក្នុងធម្មយមកនោះ ព្រះអង្គទ្រង់ត្រាស់បុច្ឆាទុកជាមាតិកាដូច្នេះ ទ្រង់ត្រាស់បុច្ឆាថា កតមេ ធម្មា កុសលា ធម្មទាំងឡាយដែលជាកុសលតើដូចម្តេច ? កុសលធម្មទាំងនោះ ដែលជាកុសលតើដូចម្តេច ? អកុសលធម្មទាំងនោះ ដែលជាអកុសលតើដូចម្តេច ? ធម្មទាំងនោះ ដែលជាអកុសលតើដូចម្តេច ? ធម្មទាំងនោះ ដែលជាអព្យាកតធម៌ត

ធម៌ជាកុសលនោះ ជានឹងចិត្តចេតសិកជាកុសល ។

ធម៌ជាអកុសលនោះ ជានឹងចិត្តចេតសិកជាអកុសល ។

ធម៌ជាអព្យាក្រឹតនោះ ជានឹងចិត្តចេតសិកជាអព្យាក្រឹត ។

ចិត្តជាកុសលនឹងជាអកុសលនោះ ដូចចិត្តជាកុសលនឹងជាអកុសលដែលជានសំដែងរួចហើយក្នុងចិត្តយមក ។

ក្នុងធម្មយមកនេះ សំដែងតែចេតសិកជាកុសលនឹងជាអកុសលសួមក្នុងសំដែងក្នុងអកុសលចេតសិកជាមុន ។ ក្នុងអកុសលចេតសិកនោះ គឺ មោហេហ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ លោភៈ ទិដ្ឋិ មានៈ ទោសោ ឥស្សា មច្ឆរិយៈ ថីនមិទ្ធៈ វិចិកិច្ឆា ។

ឯមោហោនោះ ជានឹងសេចក្តីវង្វេង ។ អហិរិកៈនោះជានឹងគ្មានសេចក្តីអៀនខ្មាសអំពីបាប ។ អនោត្តប្បៈនោះ ជានឹងគ្មានសេចក្តីខ្លាចអំពីបាប ។ ឧទ្ធច្ចៈនោះ ជានឹងចិត្តអណ្តែតអណ្តឹងកយមាយ ។ លោភៈនោះ ជានឹងចិត្តលោភ ។ ទិដ្ឋិនោះ ជានឹងមិច្ឆាទិដ្ឋិ គឺគំនិតយល់ឃើញខុស ៦២ ប្រការ ។ មានៈនោះ ជានឹងការប្រកាន់ខ្លួនមានប្រកាន់ដោយជាតិជាដើម ។ ទោសោនោះ ជានឹងសេចក្តីក្រោធនឹង ។ ឥស្សានោះ ជានឹងចិត្តឫស្យាគឺច្រណែនគេ ។ មច្ឆរិយៈនោះ ជានឹងសេចក្តីកំណាញ់ ។ ថីនមិទ្ធៈនោះ ជានឹងចិត្តធុញ្ជប់ប្រួញរដោកងុយដេក ។ វិចិកិច្ឆានោះ ជានឹងសេចក្តីសង្ស័យ ។

អកុសលចេតសិកធម៌ទាំងពួងនេះ បើកើតមានក្នុងសន្តានៃបុគ្គលណា ក៏ជាហេតុនឹងធ្វើបុគ្គលនោះ ឲ្យមានសេចក្តីប្រយោជន៍ក្នុងជាតិនេះនឹងជាតិមុខ ។ ហេតុនោះ សម្តេចព្រះបរមសាស្តាទើបត្រាស់ទេសនាកប់ទូវធម៌ទាំងឡាយមានមោហៈជាដើមនេះចូលក្នុងអកុសលចេតសិក ។

ឯចេតសិកខាងកុសលនោះ គឺ សទ្ធា សតិ ហិរិ ឱត្តប្ប តត្រមជ្ឈត្តតា ។

សទ្ធានោះ ជានធម៌អាការដែលជឿក្នុងព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណ នឹងជឿក្នុងផលទាន ផលសីល ។

សតិនោះ ជានធម៌ការនឹកឮកក្នុងព្រះពុទ្ធគុណជាដើម ។

ហិរិនោះ ជានធម៌សេចក្តីអៀនខ្មាសអំពីបាប ។

ឱត្តប្បៈនោះ ជានធម៌សេចក្តីខ្លាចអំពីបាប ។

តត្រមជ្ឈត្តតានោះ ជានធម៌ទបេក្ខាទាំង ១០ ប្រការ ។

កុសលចេតសិកទាំងនេះ បើកើតមានក្នុងសន្តានៃបុគ្គលណា តែងនឹងញ៉ាំងបុគ្គលនោះឲ្យដល់នូវសេចក្តីសួស្តីមង្គល ប្រកបដោយប្រយោជន៍ជាសុខក្នុងជាតិនេះនឹងជាតិមុខ ។ ហេតុនោះ សម្តេចព្រះបរមសាស្តាទ្រង់ត្រាស់ទេសនាលើកសទ្ធាឡើងជាអាទិ៍ កប់ចូលក្នុងចេតសិកខាងកុសលក្នុងធម្មយមកដោយប្រការដូច្នេះ ។

ធម្មយមក ចប់ប៉ុណ្ណេះ ។

(នៅមានត)

សម្តែបព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

លំដាប់នោះ ព្រះសក្កទេវរាជ ទ្រង់បើកទិព្វចក្ខុមើលមើលស្ថានមនុស្សលោក ឃើញខ្លួនអាកប្បកិរិយាដ៏អាក្រក់ ដែលពួកជនជាមិច្ឆាទិដ្ឋិធ្វើដូចនោះ ហើយទ្រង់ដល់ខ្លួនសេចក្តីសំវេគស្តុតព្រះហឫទ័យ ក៏ហោះផ្លែផ្លោះចុះមកកាន់ស្ថានមនុស្សលោកមួយរំពេច ហើយនិមិត្តធ្វើឲ្យព្រះពុទ្ធរូបមានអាការហាក់ដូចជាផ្ទះ និមិត្តធ្វើរូបអ្នកគាឲ្យនុងសំវាក្រាបថ្វាយបង្គំព្រះចេតិយគូនៃព្រះដ៏មានដំណាងព្រះមានព្រះភាគដោយគោរពស្រេចហើយ សម្តែងប្រាប់ខ្លួនតាមានោះដល់ឧបាសកឧបាសិកាទាំងឡាយឲ្យបានដឹងហេតុសព្វគ្រប់ ក៏ហោះទៅកាន់ស្ថានសួគ៌ជាទីលំនៅរបស់ព្រះអគ្គីវិញ្ញាហោង ។

លុះដល់ថ្ងៃជាន់រប់ថ្ងាំតីរ ពេលព្រឹក ពួកឧបាសកឧបាសិកាទាំងនោះ ក៏បបួលគ្នាចូលទៅកាន់ស៊ីណាក់ព្រះបរមសាស្ត្រ ហើយលើកកំពង់អញ្ជលីឡើងក្រាបបង្គំខ្លួនយ៉ាងនេះថា ខេរៈបតិត្រព្រះសម្មតិ-ទេព ឥឡូវនេះព្រះឥសូរដែលជារូបអ្នកគា របស់ជនជាមិច្ឆាទិដ្ឋិប្រែការយ នុងសំវាក្រាបថ្វាយបង្គំប្រះចេតិយគូនៃព្រះដ៏មានដំណាងព្រះមានព្រះភាគជាម្ចាស់នៃយើងទាំងឡាយទៀបព្រះចេតិយនេះឯង ។

កាលនោះ សម្តេចព្រះនរិន្ទ្រាធិបតីបរមក្សត្រិយ៍ ជាន់ព្រះសណ្តាប់ពាក្យនៃតាបសបរិស័ទចាំងឡាយហើយ ស្តេចក៏ទ្រង់បញ្ជាឲ្យអាមាត្យចាំងឡាយកាយស្តរកេរដើយផ្សាយទៅកន្លងនគរចាំងអស់ថា "ឲ្យមហាជនចាំងឡាយមកប្រជុំសន្ធិបាតក្នុងទីនោះស្រេចហើយ ស្តេចយាងទៅជាមួយនឹងមហាជនចាំងអស់នោះដែរ លុះស្តេចចូលទៅកាន់ពេងអ្នកតា ហើយស្តេចទ្រង់គ្រាស់បង្គាប់ឲ្យចំណាយគ្រាលើវត្ថុសម្រាប់បិទចាំងបើកទ្វារពេងអ្នកតាហើយ ទ្រង់បញ្ជាឲ្យនាំយកផែនក្តារនោះចេញមក ស្រាយសំពត់សាជកដែលរុំព័ទ្ធព័ន្ធនោះចេញក្នុងគ្រានោះឯង ។

លំដាប់នោះ ព្រះមហាក្សត្រិយ៍ក្តី មហាជនចាំងឡាយក្តី បានឃើញនូវបាដិហារ្យដ៏ប្រសើរជាទីអស្ចារ្យយ៉ាងនោះហើយ កំកើតសេចក្តីស្រឡាំងកាំងក្នុងចិត្តពន់ពេក ចាំងកើតជ្រះថ្លាក្នុងគុណព្រះសាស្តាក្រៃលែង ហើយជនចាំងអស់នោះក៏លះបង់មិច្ឆាទិដ្ឋិ តាំងនិតដែលតែងឃើញខុស គឺប្រកាន់យកបូជាអ្នកតាជាទីគោរពនោះចោលជាស្រេចហើយ បានដល់នូវព្រះគុណនៃព្រះបរមគ្រូសាស្តាចារ្យជាម្ចាស់ជាទីពឹងទីរលឹក ឥតមានសេចក្តីសង្ស័យឡើយ ។

គ្រានោះព្រះកូមិន្ទ្រាធិបតីបរមក្សត្រិយ៍ ស្តេចទ្រង់គ្រាស់បញ្ជាសេវកាមាត្យ ឲ្យកាយបំបែកចំលុះចំលាយពេងអ្នកតានោះចោលចេញហើយ ស្តេចចាំបាតទ្រព្យកសាងព្រះវិហារយ៉ាងធំតួរជាទីសប្បាយ ហើយព្រះអង្គ

តែងបំពេញនូវបុញ្ញកម្មផ្សេង ។ ដកជដល់អស់ព្រះជន្មក៏ចាន់ឡើងទៅកើត
ក្នុងស្ថានសួគ៌ទេវលោកនាយ សោយនូវទិព្វសម្បត្តិជាសុខក្សេមក្សាន្តដ៏
ក្រៃលែង ។

ព្រោះហេតុនោះ ព្រះអហន្តចាន់ឡាយ ដែលចាន់សម្តែងរឿងនិទាន
នេះចប់ហើយ លោកពោលជាបទព្រះគាថាថែមទៀតថា :

អនញ្ញតំ សត្ថុ ឧរិយមានេ
កកេន្ធំ និស្សា កុសលានំ ឥទ្ធិំ
យេ តេ មុនិន្ទេ បរិនិព្ពុតម្ហិ
កកេន្ធំ បុញ្ញានំ មហាភូតន្តំ ។

អធិប្បាយថា .. កាលដែលព្រះបរមសាស្តាទ្រង់ធរមានទៅ ជន
ចាន់ឡាយណា ចាន់ឃើញនូវឥទ្ធិចាន់ដ៏ហាវ្យ (នៃព្រះអង្គ) ហើយទ្រុលភ្ញាយ
ចាត់ចែងធ្វើនូវកុសលផ្សេង ។ អំពើនោះក៏មិនជាអស្ចារ្យឡើយ កាល
បើព្រះមុនីមានព្រះភាគជាធំជាងអ្នកប្រាជ្ញ ទ្រង់ចូលព្រះបរមនិព្វានទៅ
ហើយ ជនចាន់ឡាយណា ចាន់ឃើញនូវឥទ្ធិចាន់ដ៏ហាវ្យ (នៃព្រះអង្គ)
ហើយជ្រះថ្លាចាត់ចែងធ្វើបុណ្យចាន់ឡាយ អំពើនោះហៅពេញជាអស្ចារ្យ
ប្រសើរមែនពិត ។

សម្តែងរឿងនិទានជនអ្នកនៅនាកំពង់ឈ្នោះគាចរៈជាគំរប់ប្រាំ ក្នុង
វគ្គទីបី ក៏ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណេះឯង ។

៦- ចោរឃាដកវិត្តកថា

សម្តែងរឿងនិទានបុរសអ្នកសម្លាប់ចោរតៅខៀត ដោយពាក្យថា ឯកាស្មិ កាកេ សមយេ ជូរច្នេះជាដើម អធិប្បាយថា បានឮរឿង។ មកថា កាលសម័យមួយ ព្រះមានព្រះភាគជាម្ចាស់នៃយើងទ្រង់ប្រកាសធម្មទេសនាតឲ្យល់ទ្វារស្ថានសួគ៌និងព្រះនិព្វាន ដល់មហាជនហើយព្រះអង្គអាស្រ័យនៅក្នុងវិហារជេតពន ទៀបក្រុងសាវត្ថី ។

សម័យនោះឯង មានចោរប្លន់យកទ្រព្យគេមកអំពីដងព្រៃ បានធ្វើចោរកម្មក្នុងចំណោមភក្ត្រី តុំដែលជាប់គឺលួចប្លន់យកទ្រព្យគេ មកចិញ្ចឹមជីវិតខ្លួន ព្រមទាំងកូនប្រពន្ធ ដោយអំពើនោះឯង ។

លុះថ្ងៃមួយជាខាងក្រោយទៀត ចោរទាំងនោះក៏នាំគ្នាចូលទៅកាន់ទីក្រុងដើម្បីធ្វើចោរកម្ម ក៏បានឃើញមនុស្សអ្នកជនបទម្នាក់ជាអ្នកតំសត់អត់ឃ្លានឈរនៅទៀបទ្វារក្រុងហើយសួរថា ម្នាលបុរសដ៏ចំរើន អ្នកឯងអាស្រ័យនៅស្រុកណា ។

ឯបុរសតំសត់នោះ បានឆ្លើយប្រាប់ថា ខ្ញុំនេះជាអ្នកតំសត់នៅអាស្រ័យក្នុងជនបទឯណោះអ្នក? ។

ចោរទាំងឡាយនោះ និយាយតបទៅនឹងបុរសអ្នកជនបទវិញ ដើម្បីល្បងបញ្ចូលឲ្យចូលក្នុងពួកខ្លួនថា: អ្នកឯងរស់នៅដោយការចិញ្ចឹមជីវិតទាំងខ្លុកលំបាកយ៉ាងនេះធ្វើអ្វី ត្រូវតែអ្នកចូលមកប្រព្រឹត្តធ្វើចោរកម្មជាមួយ

ទំនងពួកយើងហើយចិញ្ចឹមកូនប្រពន្ធដោយអំពើនោះជាការងាយជាងអ្នកមិនត្រូវនៅដោយការចិញ្ចឹមដ៏វៃជំលំជាក មានទុក្ខព្រួយដូចនេះទៀតឡើយ ។

ឯបុរសនោះ កំពុងខឹងលួសព្រមតាមពាក្យចោរទាំងនោះដោយគំនិតឈ្លើងយល់ថា ចោរទាំងឡាយនិយាយនេះគួរស្តាប់បានមែន ដូចនេះត្រូវតែអាត្មាអញរួមគំនិតជាមួយនឹងចោរទាំងនោះចុះ ។

លុះពួកចោរនឹងអ្នកជនបទ យល់ស្របគ្នាហើយ ទើបពួកចោរទាំងនោះក៏និយាយផ្ទួនទៀតថា អ្នកត្រូវចូលមកជាមួយនឹងយើងក្នុងកាលឥឡូវនេះឯង ហើយក៏នាំយកបុរសនោះដើរចូលទៅខាងក្នុងទីក្រុងលួចប្លន់អ្នកក្រុងជាលំដាប់តាមផ្ទះមួយទៅផ្ទះមួយ ។ តែយ៉ាងនោះឯង ។

មិនយូរប៉ុន្មាន បុរសអ្នកជនបទតែងសង្កេតបានឮឮច្បាស់ច្រើនទើបគិតថា អំពើដែលអាត្មាអញប្រព្រឹត្តនេះ ជាអំពើដ៏ប្រសើរដោយពិត លុះគិតយ៉ាងនេះហើយក៏ប្រព្រឹត្តធ្វើអំពើចោរកម្មចិញ្ចឹមជីវិត ជាមួយនឹងពួកចោរទាំងនោះជាដរាប ។

ស្រាប់តែដល់ថ្ងៃជាខាងក្រោយទៀត ពេលបុរសទាំងឡាយគេដើរល្បាតចាប់ពួកចោរទាំងនោះបាន គេចងសេកយ៉ាងមាំ នាំយកទៅថ្វាយដល់ព្រះបាទបសេនទិកោសលរាជ សូមស្តេចទ្រង់វិនិច្ឆ័យទោសានុទោសតាមច្បាប់សម្រាប់ព្រះនគរ ។

ឯសម្តេចព្រះបរមបុរី ស្តេចទ្រង់ទតទៅឃើញពួកចោរចាំងឡាយ ហើយ ទ្រង់មានព្រះពាក្យត្រាស់យ៉ាងនេះថា នែនាយចាំងអស់គ្នាអើយ ! កូនចំណោមអ្នកចាំងឡាយនេះ តើអ្នកណាអាចសំឡាប់ចោរចាំងនេះឲ្យក្សិណក្សើយដែរតែបាន យើងនឹងឲ្យដីតែងតាំងដល់អ្នកនោះឯង ។

ឯចោរចាំងអស់នោះ លុះបានស្តាប់ព្រះពាក្យត្រាស់សួរដូចនោះហើយ ក៏ពុំបានប្រកាន់ដើម្បីនឹងសំឡាប់គ្នានឹងគ្នាឡើយ ព្រោះពួកចោរចាំងនោះ សុទ្ធតែជាញាតិមិត្តនឹងគ្នាទៅវិញទៅមកយូរយារណាស់ហើយ ទើបពុំអាចសំឡាប់គ្នាឯងបាន ។

ចំណែកឯបុរសអ្នកជនបទនោះ ក៏ក្រាបបង្គំទូលថា: បពិត្រព្រះសម្មតិទេព ខ្ញុំព្រះករុណាថ្ងៃវិសេស អាចនឹងសំឡាប់ពួកចោរចាំងអស់នេះបានសូមទ្រង់ជ្រាប ។ ស្តេចក៏ទ្រង់អនុញ្ញាតដល់បុរសនោះ ។ ក៏សំឡាប់ពួកចោរចាំងអស់នោះ ឥតមានសល់ឡើយ ។

ព្រះបរមក្សត្រិយ៍ ទ្រង់បានឃើញបុរសនោះអាចហ៊ានសំឡាប់ចោរចាំងឡាយបានដូចនោះហើយ ក៏មានព្រះហឫទ័យត្រេកអរពន់ពេក ទ្រង់ព្រះពាក្យតែងខ្លួចោរឃាដកម្ម ដំណែងជាសេម្រាប់សំឡាប់ចោរដល់បុរសនោះតាំងពីថ្ងៃនោះតទៅ ។

លុះបុរសនោះបានទទួលការៈជាអ្នកសម្លាប់ចោរហើយ ក៏តែងតែសម្លាប់ចោរកាល់។ ថ្ងៃអស់កាលជាអម្ចាស់យូរអង្វែង ២៥ ឆ្នាំ ក៏ដល់ខ្លួនគាត

ថាស់ដកមានកម្លាំងថយ តុំអាចនឹងប្រហារចោរ តែមួយដងបាន ខ្សោយ មានតែប្រហារពីរបីដងទើបបានស្លាប់ ព្រោះខ្លួនមានកម្លាំងថយ ពេកណាស់ ។

ទើបព្រះបាទបសេនទិកោសលក៏ ស្តេចទ្រង់ជ្រាបសេចក្តីនោះ ហើយ ទ្រង់បានបញ្ជាប់បុរសនោះចេញពីមុខដំណែង ហើយទ្រង់ប្រ-ទានដំណែងចោរឃាដកម្មនោះ ដល់បុរសដទៃវិញ ។

ឯចោរឃាដកបុរសនោះ កាលបើស្តេចបានបន្ទុយចេញអំពីទីដំ ណែងជាអ្នកសម្លាប់ចោរហើយ ក៏ដល់នូវសេចក្តីលំបាកខាល់ក្រ តែង ទៅអាស្រ័យក្នុងផ្ទះរបស់ខ្លួនតាមភាពជាអ្នកខ្សត់ខ្សោយនោះ ។

កាលនោះ មានបុរសកំឡោះដទៃម្នាក់ពុំស្គាល់ឈ្មោះជាអ្នកចេះមន្ត អាចសម្លាប់មនុស្សដោយគ្រាន់តែកាយមន្តហើយ បញ្ចេញខ្យល់តាមច្រមុះ ក៏អាចសម្លាប់បាន ។

ឯមន្តនោះសោត បើយើងមានច្រកថ្នាចដំកាត់បំបាក់ ទំលាយ បណ្តាអវយវៈទាំងឡាយ មានដៃ ជើង ត្រចៀក ច្រមុះ ទឹងក្បាលជាដើម អវយវៈណាមួយហើយ យើងសូត្រកាយមន្តបញ្ចេញផ្សាយមន្តទៅតាមច្រ-មុះ សំដៅទីត្រង់ណា ទីត្រង់នោះក៏ដាច់ចេញមួយរំពេច ដោយវិជ្ជាអា នុភាពនៃមន្តនេះឯង ។

មិនយូរប៉ុន្មាន ស្រាប់តែបុកណាចោរឃាដកាមាគ្បាស់នោះ បាន

ចូលទៅផ្ទាប់ផ្តុំណាប់រើអ្នកតំឡោះដែលចេះមន្តហើយសុំរៀនមន្តនោះ ឲ្យចេះចប់សំរេចដូចបំណងក៏ត្រឡប់មកផ្ទះវិញ ទើបបញ្ជូនចុតហ្នាយទៅថ្វាយបង្គំព្រះបរមក្សត្រិយ៍ដើម្បីទ្រង់ជ្រាបសេចក្តីសព្វគ្រប់ថា: ខ្ញុំព្រះករុណាថ្លៃវិសេសនេះ កាលតាមុនតែងធ្វើអំពើកាត់ផ្ទាប់ទូវអាយុមានដៃខ្លីដើរដាំដើមរបស់ពួកចោរឲ្យខ្លាំងលំបាក ឬការសម្ងាប់ចោរដែលគួរសម្ងាប់ក៏ឲ្យខ្លាំងលំបាកណាស់ ព្រោះខ្លួលព្រះបង្គំមានភ័យខ្លាចស់ តែឥឡូវនេះ ខ្ញុំព្រះអង្គសូមធ្វើទីដំណែងនោះទៀត ព្រោះខ្ញុំព្រះអង្គបានចេះមន្តមួយតូចតែវិសេសឆ្ងាប់ណាស់ ខ្ញុំព្រះអង្គអាចនឹងកាត់បំបែកទម្លាយឬសម្ងាប់ចោរចាំងឲ្យដោយអានុភាពមន្តរបស់ខ្ញុំព្រះអង្គ បានដោយងាយ ។

ឯព្រះបរមក្សត្រិយ៍ លុះទ្រង់ព្រះសណ្តាប់សេចក្តីចុតហ្នាយនោះហើយ ទ្រង់ក៏ខ្ជួលត្រមថា:សាធុប្រពៃហើយ ទ្រង់គ្រាស់បង្គាប់ឲ្យហៅបុរសនោះចូលមកគាល់ ទ្រង់ក៏ឲ្យប្រទានទីដំណែងឋានដៃដែលនោះដល់បុកណាចោរឃោដកាមាត្យនោះដូចប្រក្រតីវិញ ។

អាមាត្យនោះ តែងប្រព្រឹត្តអំពើសំឡាប់ ចាកខ្ទង់ទៅបាន ៤៩ ឆ្នាំទៀត ។

ក្នុងកាលជាខាងក្រោយនេះ អាមាត្យនោះក៏កាន់តែចាស់ជរាពន់ពេកមានអាយុច្រើន មានកំឡាំងថយចុះ មានតែសេចក្តីស្ងប់នៅខាងមុខ

មានជម្ងឺឈឺជាខមួនជាបដល់ស្រែកថ្ងូរដោយសម្រែកលាន់ឮខ្ទាំង មានភ័យយ៉ាងធំបំផុត ព្រោះមរណទុក្ខបៀតបៀនក្រពេក តែអាមាត្យនោះឆ្នេចក្អែកទៅ ក៏ឃាននឹយថាលទាំងឮយកាន់ញញួរដែក ដំបងដែកមានជ្រុងបួនសឹងនេះក្តុំរឹងរឿងដោយអណ្តាតភ្លើងនេះ មុខគួរខ្លាចស្ញប់ស្ញែងពន់ពេក គាត់ក៏ដេកចំរះនៅលក្នុងកាលនោះឯង ។

លំដាប់នោះ មនុស្សអ្នកស្ថិតស្ថាលនាផ្ទះដែតខាងនោះ លុះឃាននូវសំឡេងដែលគួរខ្លាចស្ញប់ស្ញែងជួចនោះ ក៏ភ័យញ័រខ្លួនរត់ចោលផ្ទះទំលាក់ទៅក្នុងកាលនោះឯង ។

មានសេចក្តីដំណាលថា សម័យមួយនោះ ព្រះសារីបុត្តត្ថេរដ៏មានអាយុ លោកឃាននមើលមើលដោយទិព្វចក្ខុឃាននឃើញនូវបុរសអ្នកសម្លាប់ចោរដែលដែតនឹងស្លាប់ លុះស្លាប់ហើយមុខជាទំងទៅកើតកន្លែងអវិចីនរកដោយពិត កាលបើព្រះថេរឃាននជ្រាបសព្វគ្រប់ហើយ ក៏មានព្រះហឫទ័យមេត្តាអាណិតបុរសនោះឃានរំតឹងពិចារណាថា ប្រសិនបើអាត្មាអញឃាននទៅកន្លែងនោះហើយ ចោរឃាដកាមាត្យនេះ ទំងមានចិត្តជ្រះថ្លាចំពោះអាត្មាហើយ ក៏ធ្វើកាលកិរិយាក្សិណក្សយ ទំងឃាននឡើងទៅកើតឯស្ថានសួគ៌ទេវលោកនាយ ដោយពិត ។ ព្រះថេរឃាននគិតតទៅទៀតថាថ្ងៃនេះគ្រាតែអាត្មាអញធ្វើសេចក្តីអនុគ្រោះចំពោះបុរសនោះទើបគួរ លុះគិត

យ៉ាងនេះហើយ កំទ្រេងស្បង់ប្រដាប់ចាត្រ ក្នុងបុព្វណ្ហសម័យនិមន្តចេញ
ទៅឈរទៀបទ្វារផ្ទះនៃចោរយោដកបុរសនោះឯង ។

ចំណែកឯបុរសនោះ ឃើញព្រះថេរហើយ កំរោធទឹងជា
ញឹកញាយដូចលេកខ្ចប់ច្រាំងមានចិត្តញាប់ញ័រលាន់មាត់ថា: តជ:តជ:
ដោយសេចក្តីក្រោធខ្លាំង គាត់ដេកគិតថា អញនឹងឃាមន្តសំឡាប់សម-
ណកំណាចនេះ ឥឡូវនេះឯង ហើយសូត្រឃាមន្តផ្សាយឲ្យលាំចេញ
ទៅតាមច្រមុះ ដើម្បីសំឡាប់ព្រះថេរនោះដូចបំណង ។

ក្នុងខណនោះ ព្រះថេរកើបានចូលកាន់សមាបត្តិ ហើយចេញអំពី
សមាបត្តិមួយរំពេច លោកមានស្មារតីរឿងបីដូចព្រះអាទិត្យទើបនឹងរះ
ឡើងបានឈានទើងនៅកន្លែងដែលនោះឯង ។

ចំណែកឯចោរយោដកាមាត្យ កំរើងតែតែងខ្លាំងហើយសូត្រឃាមន្ត
ផ្សាយឲ្យលាំចេញទៅតាមច្រមុះ យ៉ាងនោះតើរដងបីដង កំតងំពុំអាចនឹងធ្វើ
អាយុវ: ខ័ណ្ឌយោធស់ព្រះថេរឲ្យកម្រើកបានឡើយ ហើយត្រឡប់ជា
មានចិត្តតិសារឿស្បថ់ស្បែងក្រៃពេក ក្នុងគុណព្រះថេរកំញាំងចិត្តឲ្យជ្រះ
ថ្លាជាថ្មីទៀត ទើបចាត់ចែងបុត្តកឲ្យថ្វាយបង្គំសាដែលគេតាក់តែង
បម្រុងខ្លួនចំពោះព្រះមហាសាវបុត្តថេរកន្លែងនោះឯង ។

(នៅមានត)

(តមក)

មួយទៀតសោត ស្តេចចុលនីព្រហ្មទត្ត ទ្រង់សេនាយោធានោះច្រើន ទោះ
យោធីកាន់ទ្រង់ខ្លាចម្នាក់មួយដៃ ចំលាក់ចោះចុះក្នុងគួតីពេញឡើងហោង
ទោះយោធីកាន់ដំដុំមួយដុំម្នាក់ក្តី ចោះចុះជាផុតឡើងប្រមាណស្មើភាគ
បន្ទាយកំគប្បីបានហោង មួយទៀតសោតទាបីហៅកលអធិប្បាយ (សេចក្តី
ក្រោយ) នោះ សំរីខ្ញុំជាពោធិសត្វទាំងឡាយ តស្មា ព្រោះហេតុ
ដូច្នេះ ឯកោបិ ជនោ សូម្បីនឹងមានអ្នកណាមួយនាំហៅនឹង
ចោះចុះទ្រង់ខ្លាចមួយដៃក្តី ដុំដីមួយដុំក្តី ឆ្ពោះចូលទៅកន្លែងគរនោះគ្មាន
ឡើយ ។ អស់តលសកលយោធាទាំងឡាយ កំក្រឡាបវិលមកក្រោយ
ហើយទៅកាន់ស្ថានទំពាក់ទំពិរៃ ។ ហោង ។ កដា តោវដ្ឋំ ឬដ្ឋំ
តេ តេភេម អាចរិយាតិ ។ ស្តេចចុលនីព្រហ្មទត្ត បន្ទូលដល្អើង
អាចារ្យតើវដ្តព្រាហ្មណ៍ថា ម៎ៃអាចារ្យអើយ ! តើយើងធ្វើដូចម្តេច ? ។
ទើបអាចារ្យតើវដ្តព្រាហ្មណ៍ទូលថា ទេវ បតិត្រអើយ ! រឯងមនុស្សទាំង
ឡាយក្នុងគរនោះសោត យើងនឹងក្រវែលចាំសម្លាប់ កុំឲ្យចេញបាន
ដោយខ្លួនឯងបន្ទិចដល់តិចឡើយ រីមនុស្សមិនបាននឹងចេញទៅណា នឹង
ជាក្រសាលនោះ ដ្បិតគេនឹងបើកទ្វារចេញមកឯងហោង លំដាប់នោះ

អាចារ្យកៅដ្ឋព្រាហ្មណ៍ថា នាយើងនឹងចាប់ឲ្យបានរាជាសត្រូវនេះ ដោយ
ខ្លួវដំរេកលក្រាជ្ញាយើងហោង ។ ស្តេចចុលនីព្រហ្មទត្តទទួលយល់
ព្រមថា ហៃអាចារ្យអើយ ! ទុជ្ឈាយនេះ យល់ល្អក្រៃពេកហោង ។
សូមម្ល៉ាំរៀបៀមហោសថអ្នកក្រាជ្ញ អ្នកដឹងខ្លួវតាមានដូចយើងស្រដីអំពីមុន
នោះហោង តោធិសត្តំពើនគិតថា ទីលែងកាសត្រូវនេះកមកនៅនាហាន
នេះលន់ពេកហោង នាបីហៅនឹងជាសុខនាយើងនោះគ្មានឡើយ ថា
បើដូច្នោះហើយ គួរហោងអញនឹងបណ្តេញដោយទុជ្ឈាកលមួយ តោ-
ធិសត្តថា អញនឹងបណ្តេញស្តេចចុលនីព្រហ្មទត្តនឹងមន្តគាំងឡាយ ។
តោធិសត្តថា អញនឹងជ្រើសរើសឲ្យបានអាមាត្យមួយ ឲ្យបេះស្រដី
ឈ្លាសវៃខ្លួវតោក្សទុជ្ឈាយល្អក្លាត់ តោធិសត្តថា អញនឹងបណ្តេញស្តេច
ចុលនីព្រហ្មទត្ត តោធិសត្តអ្នកយល់អាចារ្យមួយឈ្មោះ អន្ទុកៅដ្ឋ-
ព្រាហ្មណ៍ តោធិសត្តអ្នកឲ្យហៅអាមាត្យនោះមកហើយផ្តាំថា ហៃអា-
ចារ្យអើយ ! គួរយើងមានអំពើកលអ្វីមួយ អញនឹងធ្វើជាឲ្យព្រះស្តេចឯង
ចុះគេហើយមកអញគិត ។ អន្ទុកៅដ្ឋព្រាហ្មណ៍ថា ហៃបៀអ្នកក្រាជ្ញ
អើយ ! យើងនឹងធ្វើដូចម្តេច ? ចូរអ្នកសំដែងខ្លួវអំពើនោះហោង ។
តោធិសត្តថា ចូរព្រះស្តេចឯងឡើងទៅបិតលើកាគចន្ទាយ ព្រះស្តេច
រមៀលមើលខ្លួវសេចក្តីប្រមាទនៃមនុស្សម្នាមហាជនផងគាំងឡាយ ឯយើង

ឯគេនោះឲ្យសព្វគ្រប់ ចូរព្រះស្តេចប្រោះឲ្យជាដើម គឺខំចំណីត្រីសាច់ផង
ចាំងឡាយ ឮដំមនុស្សនៃស្តេចចុលទ័ព្រហ្មទត្តរាជចាំងឡាយ ព្រះស្តេច
អាចឲ្យដោយផ្តាច់ចិត្តមនុស្សនោះ ហើយព្រះស្តេចថា អង្គ្រា ម្ចាលអ្នក
ចាំងឡាយអើយ! ចូរឆៃចំណីត្រីសាច់នេះ កុំបីមុងមិនស្រណុកចិត្តឡើយ
ព្រះស្តេចចូរពិគ្រាយាមដើម្បីនៅបានពីរ . បីថ្ងៃវិញទៀត រឯមនុស្សផង
ចាំងឡាយ នៅកងនគរនេះ នោះក៏មិនស្រណុកចិត្តវ ឧបមាដូចមាន់
គេគ្របខ្ទុកក្នុងអង្រុតក្រាកជ វានឹងនៅមិនយូរលន់ឡើយ ស្មែកហើយវ
នឹងបើកទ្វារចេញឲ្យអ្នកចាំងឡាយហោង ចូរព្រះស្តេចថាដូច្នេះ ហើយ
លំដាប់ពីនោះទៅ អ្នកចាំងឡាយចូរចាប់ស្តេចវិទេហរាជ នឹងមហាសេន
ជាកូនគហបតីកំណាច ព្រះស្តេចនឹងខ្លាចអ្វី ឯមនុស្សចាំងឡាយនៃយើង
នោះ វាឮពាក្យព្រះស្តេចបង្កើតដេរគំរាមឲ្យឈ្លស់ស្តេចចុលទ័ព្រហ្មទត្តរាជ
ព្រះស្តេចធ្វើដូចគេវាយឮដំដើងដៃនៃអាចារ្យជាគំពុះអំពីក្បាលបន្ទាយ ចង
សក់ជាច្រុំអន្ទឹងធ្វើឲ្យចុះដោយខ្លួលំអិតតដ្ឋ ព្រះស្តេចរំសាយមាលាសង្វា
រក ដែលពាក់ទាកនោះ រឹទ្ធិនព្រះស្តេចនោះ ឡកបន្ទាខ្សែត្រួត ឲ្យឈ្ល
ដូចគេវាយពីរ-បី ដង ឲ្យស្តេចថា ខ្សែព្រះស្តេចយកមកដោយនូវត្បូរដ៏
ខ្ទុកនឹងសង្រែក ឲ្យគេដាក់ព្រះស្តេចចុះអំពីលើភាគបន្ទាយនោះ ព្រះស្តេច
ទៅធ្វើស្រដីបំបែក នឹងចំណីមនុស្សនៃស្តេចចុលទ័ព្រហ្មទត្តរាជសំដែងឲ្យ

ឃល់ព្រះស្តែងឯង គេនឹងនាំព្រះស្តែងទៅសំណាក់ថ្វាយស្តេច រីស្តេចបុលនីសោត ឃល់ព្រះស្តែងហើយ គេនឹងដណ្តឹងព្រះស្តែងថា រីពេលខ្ញុំសុំកំហុសតើដូចម្តេច? លំដាប់នោះព្រះស្តែងនឹងទូលក្រាបស្តេចបុលនីនូវពាក្យថាដូច្នេះ មហារាជ បពិត្រមហាពាជអើយ! រីសក្តិយសអញខ្ញុំកាលមុនឡើយជាធំ មហាសថជាកូនគហបតី សិរីវឌ្ឍកសេដ្ឋីក្តី ដោយជាអ្នកកំណាញ់យសនោះមិញ គេចឹងនឹងអញខ្ញុំក្តាត់ គេកំចាត់អញខ្ញុំចេញអំពីយស ហើយគេទៅទូលក្រាបស្តេចវិទេហរាជ ឲ្យបំបរបង់អញខ្ញុំ ហើយគេរឹបយកអស់ទ្រព្យសម្បត្តិអញខ្ញុំអស់ហោង ព្រះស្តែងទូលក្រាបស្តេចបុលនីថា អំពីថ្ងៃនេះទៅ បួរអម្ចាស់នឹងឲ្យគេចាប់ក្បាលមហាសថចោរកំណាចជាកូនគហបតី សិរីវឌ្ឍកសេដ្ឋី ជាស្មង់សក្តិយសអញខ្ញុំវិញហោង ហេតុនោះហោង អញខ្ញុំយល់ឃើញមនុស្សពាល់ឆ្លាយនៃអម្ចាស់ គេតិតខ្ចាចអំណាចមហាសថ គេមិនក្រសាលសប្បាយឡើយ អញខ្ញុំឲ្យចំណីកោដនាហារមនុស្សពាល់អម្បាលនោះ ដំស្មើដោយអំពើតែអម្បាលនោះហោង រីមហាសថគេធ្វើចិត្តនឹងអញខ្ញុំ ដូចនឹងជាតៀតើបុពណា មហាសថធ្វើឲ្យចុះលុះកំចាត់អញខ្ញុំចេញអំពីយសសម្បត្តិ ឲ្យវិនាសបាត់ដូច្នេះឯង ព្រះស្តែងទូលថា មហារាជ បពិត្រមហាពាជអើយ! អស់មនុស្សជនពាល់ឆ្លាយឯអម្ចាស់នេះ គេនឹងបានដឹងជាង ព្រះស្តែងធ្វើឲ្យស្តេច ខ្លួមនុស្សពាល់ឆ្លាយគឿងដោយខ្លួប្រការនោះផង។

គេនឹងបង្កើតជាស្រឡាញ់ស្និទ្ធស្នាល ព្រះស្តែងទូលថា មហាភាជ
បតិត្រមហាភាជអើយ! អម្ចាស់ ចាប់ដើមពីបានអញ្ជើញខ្ញុំមកនៅហើយនោះ
តុំបីអម្ចាស់ម្នាក់ជាវម្កាឡើយ ព្រះស្តែងទូលថា បតិត្រអើយ! ឥឡូវនេះ
ជាតែស្តេចវិទេហរាជក្តី ខ្លាចៅមហោសថបុត្រគហបតីក្តី សមនឹងគ្នាន
ព្រះស្តែងទូលថា នាបន្ទាយនគរនេះ គោះស្ថានណាខ្លាចក្តី ស្ថានណា
ចាស់ចាក់បែកក្តី ចំនើបមានគួមានក្រតើសាហាវក្តី ស្ថានណាគ្មានក្តី ក៏អញ
ខ្ញុំសឹងដឹងអស់ហោង ចូរព្រះស្តែងចាំសំដែងថា បតិត្រអើយ! អញខ្ញុំ
យកនគរនោះនឹងទ្បែមហាភាជមិនលង់ឡើយ លំដាប់នោះ ស្តេចនឹងឮ
ព្រះស្តែង ហើយស្តេចនឹងណាត់សក្ការៈឲ្យព្រះស្តែងនោះច្រើនហោង
ឮដំណាលនោះ នាស្តេចនឹងណាត់សេនាតាហនៈឲ្យនៅជុំនេះ ព្រះស្តែង
នោះរណាត់ខ្លួនតួកសេនាយោធាជុំនេះ សេនាយោធាទាំងឡាយនៃ
ស្តេចចុលនីក្តី ព្រះស្តែងនាំមកឲ្យធ្លុងត្រនំហ៊ានណាមានក្រតើកាចសា-
ហាវ រីសេនាយោធានៃស្តេចចុលនីនោះ ដោយខ្លាចក្រតើ តុំអាចនឹង
ធ្លុងបានឡើយ ឮដំណាលនោះ ព្រះស្តែងទូលថា ឆេះ បតិត្រអើយ!
ក្រតើកាចសាហាវ សេនាយោធាស្តេចចុលនីអម្ចាស់នោះ គឺចៅមហោ-
សថជាកូនគហបតីគេឲ្យរង្គាន់ រីអម្ចាស់កុំខ្វល់ចិត្តអស់មនុស្សស្តេចទាំង
អម្បាលនេះ នឹងអាចរ្យកេវដ្តព្រាហ្មណ៍នេះឡើយ នាយករង្គាន់ចៅ
មហោសថនោះ មិនប្លែកម្នាក់ឡើយ នាអស់បរិតោរអម្ចាស់នេះ ទាំង

អស់ហោង រីអស់អ្នកទាំងអម្បាលនេះ គេសឹងភៅសំណាក់ចៅមហោ-
សថបុត្រគហបតីសិរីវឌ្ឍកសេដ្ឋីអស់ហើយ មានប៉ុន្តែអញខ្ញុំម្ចាស់ឯង ជា
បុរសអាមាត្យស្មូតនឹងអម្ចាស់មែនពិតហោង ព្រះស្តេងទូលថា បពិត្រ
អើយ ! ពោះយោបីអម្ចាស់មិនជឿនៃអញខ្ញុំ ចូរអម្ចាស់អ្នកប្រើហៅអស់
ស្តេចទាំងអម្បាលនោះមក អម្ចាស់មើលគ្រឿងប្រដាប់ដោយពាក្យអញ
ខ្ញុំហោង លំដាប់តាំងពោះភៅ ចៅមហោសថអ្នកឱ្យសរសេរនាមឈ្មោះ
អាត្មានៅនាគ្រឿងដង្វាយក្តី នៅនាសំគត់នូវគ្រឿងប្រដាប់មានទំនើប នូវ
គ្រឿងព្រះខាន់ក្តី ទំនើបអស្សទាំងអម្បាលនោះ យល់ប្រាកដឡើងនៃ
ស្តេចទាំងឡាយនោះ ពោធិសត្វអ្នកផ្តាំថា ព្រះស្តេងចូរភៅគាស់អស្ស
នេះឡើងហោង រីអាចារ្យអនុកវដ្ត កំធ្វើដូចបង្គាប់ពោធិសត្វនោះ ហើយ
ធ្វើគាស់អស្សនោះយល់អស្សនោះយល់ប្រាកដឡើងកូវ អស់ស្តេចទាំង-
ឡាយនោះតិតខ្ចាច ទឹងឱ្យស្តេចទាំងឡាយវិលភៅ ស្តេចទឹងដណ្តើងព្រះ
ស្តេងថា ម៉ៃអ្នកប្រាជ្ញអើយ ! យើងទឹងធ្វើម្តេច ឥឡូវនេះ ? ព្រះស្តេង
ឯងចូរទូលស្តេចនោះនូវពាក្យថាដូច្នេះ ម ហាភាគ បពិត្រមហាកដអើយ !
រីចៅមហោសថបុត្រគហបតី គេចេះស្រដីកុហកមាយានោះច្រើន ពោះ
យោបីអម្ចាស់អ្នកចំនោះបានតែតិ៤-បីថ្ងៃវិញទៀតហើយ រីចៅមហោសថ
គេនឹងចាប់អ្នកធ្វើទុក អស់សេនាយោធាអម្ចាស់ឱ្យលង្វែកយាម
អង្រួត ចូរអម្ចាស់អ្នកឡើងលើខ្នងសេះកាន់ខ្លាបក្តងកណ្តាប់ដៃនៃអាត្ម

គេហោង កុំបីអម្ចាស់ប្រហែសធ្វេសផ្សង់ចង្អង់ឲ្យយូរលង់ឡើយ ថ្ងៃ
នេះ ថ្ងៃស្អែក នាលង្អែកយោមអង្រាត្រ ចូរអម្ចាស់អ្នកឡើងលើខ្នងសេះ
យើងបរត់ទៅហោង ព្រះស្តេងទូលថា ធម្មតាហៅជាអ្នកជ្រាជ្ញ កុំបី
អាចឲ្យស្ងាច់ទឹងកណ្តាប់ដៃសត្រូវឡើយ ព្រះស្តេងថាដូច្នោះហើយ រី
ស្តេចនោះស្តាប់តាក្យព្រះស្តេងហើយ ស្តេចទឹងធ្វើដូចព្រះស្តេងថានោះ
ហោង រីស្តេចចុលនីព្រហ្មទត្តពាជ តេលាទឹងនាគ់ហើយ ព្រះស្តេង
ទឹងក្រឡាប់ដៃលមក រីមនុស្សនៃយើង ចូរព្រះស្តេងមកថាឲ្យគេដឹងផង
ហោង ។

តំ សុត្វា អន្ធកវិន្ទព្រាហ្មណោ សាធុ បណ្ឌិត
ករិសច្ឆាមិ តេ វចនន្តិ អាហ ។ រីអាចារ្យអន្ធកវិន្ទព្រាហ្មណ៍
ស្តាប់តាក្យពោធិសត្វហើយថា ម្នៃអ្នកជ្រាជ្ញអើយ! សាធុ ល្អពេក
ហោង អញទឹងធ្វើដោយនូវតាក្យអ្នកហោង ។ ពោធិសត្វអ្នកថា ត្រូវ
ហោង ពេះយោបល់ដូច្នោះ ចូរព្រះស្តេងអត់ឲ្យគេវាយចាន់ពីរ-បីដងហើយ
សន្សឹមព្រះស្តេងទៅហោង ។ អាចារ្យអន្ធកវិន្ទព្រាហ្មណ៍ថា ម្នៃចៅ
អ្នកជ្រាជ្ញអើយ! ឥរៀបប៉ុន្តែដំរីតអញកុំឲ្យស្ងាប់ ទឹងដើងដៃអញកុំឲ្យចាក់
ម្ចែក សំណល់អំពីនោះចូរអ្នកធ្វើដោយសម្ចាចំណង់ចិត្តអ្នកហោង ។
សោ តស្ស តេហេ មន្ធុស្សាធំ សុត្វាវំ ករិត្វា . . .

រីតោធិសត្វអ្នកឲ្យធ្វើណ្តាប់លេងវិទមនុឬត្រាំងឡាយ នាផ្ទះអាចារ្យអនុ-
កេវដ្តព្រាហ្មណ៍ រមនុស្សផងបញ្ចុះទូវត្តកើដាក់សំយុងទូវអាចារ្យអនុកេ-
វដ្តព្រាហ្មណ៍ ឲ្យដាវិប្បការដូចដំណើនៃយាយដែលតោធិសត្តឆ្លាំហោង
អ៩ តេ ព្រហ្មទត្តមនុសេ្ស តំ តហោត្វា នេត្វា ព្រហ្ម-
ទត្តស្ស ឧសេ្សសុំ ។ លំដាប់នោះ អាចារ្យអនុកេវដ្តព្រាហ្មណ៍
រមនុស្សនៃស្តេចចុលនីព្រហ្មទត្តពាជនោះ គេយល់អាចារ្យអនុកេវដ្ត-
ព្រាហ្មណ៍នោះគេនាំទៅថ្វាយស្តេចចុលនី រីស្តេចចុលនីព្រហ្មទត្តស្តេចឲ្យ
ស្រាយលែងអាចារ្យអនុកេវដ្តព្រាហ្មណ៍ស្រេចហើយ ស្តេចឲ្យដណ្តើងសួរ
ខួលដូចពាក្យយើងបានស្រដីតោលហើយនោះហោង ។ ស្តេចចុលនី-
ព្រហ្មទត្តស្តាប់ហើយឮ ស្តេចបង្គែរវង្វាន់ឲ្យ ហើយបង្គែរសេនាយោធា
ពាំងឡាយ ឲ្យអាចារ្យអនុកេវដ្តព្រាហ្មណ៍ នាំសេនាយោធាទៅឲ្យទូន្តត្រង់
ស្តេចមានក្រតើសាហាវ ។ រីក្រតើសាហាវនោះ ឥតាំមនុស្សផងដែល
ឋិតនៅលើល្អក តែងចាក់ខាងបណ្តោយនឹងសាវល់តែងទូវស្នូនោះ ឲ្យលុះ
វិនាសហោង ។ ម្ល៉ោះហើយ ចាប់ដើមអំពីនោះទៅ សឹងក្មួចនឹងមាន
ក្អកឯណាមួយ តុំអាចនឹងចូលទៅជាន់ឡើយ ។ លំដាប់នោះ អាចារ្យ
អនុកេវដ្តព្រាហ្មណ៍ ចូលទៅខួលស្តេចថា ឧេវ បតិត្រអើយ! រីអស់
ស្តេចពាំងអម្បាលនោះ នាបើហៅនឹងច្បាំងយកអាសាអម្ចាស់នោះគ្មាន
ឡើយ រីអស់ស្តេចពាំងអម្បាលនោះ សឹងយកវង្វាន់គេហើយ អាចារ្យ

អនុរុទ្ធព្រាហ្មណ៍ថា នែអ្នកដ៏ចម្រើន ចូរអ្នកមកទៅ ចូរអ្នកមកទៅ ចូរអ្នកមកទៅ ចូរអ្នកមកដល់ហើយ ចូរអ្នកមកដល់ហើយ ចូរអ្នកមកដល់ហើយ

លែងពាក្យអញទុំហើយ ទើងមានអ្នកដទៃឯណាមួយ នាំយកសូតទើងអ្នកនោះគ្មានឡើយ ស្តេចបន្ទូលថា អាចារ្យ ម្ចាស់អើយ ! បើដូច្នេះហើយ ចូរព្រះស្តេងធ្វើភ្លាត់ យានដំនិះនេះ ចងសេះនៃអញហោង ។

ព្រាហ្មណោ តស្ស ឯច្ចយេន បលាយនភាវំ ញត្វា មា ភាយិ មហារាជាតិ តំ អស្សាសេត្វា .... អាចារ្យអន្ទុកៅវដ្តព្រាហ្មណ៍ ដើងជាស្តេចបុលទីសុភាពទើងត់ហើយមិនលង់ឡើយក្តី អាចារ្យអន្ទុកៅវដ្តព្រាហ្មណ៍ធ្វើជាលោមស្តេចនោះ ហើយចេញទៅក្រៅថា ឲ្យដើងទើងមនុស្សទាំងឡាយជាទមទិក្ខិត ហើយឲ្យដំបូន្មានថាដូច្នេះ តុម្ហេ ទៃព្រះស្តេងអើយ ! ថ្ងៃនេះ ស្តេចទើងត់ទៅហើយ កុំបីព្រះស្តេងដេកឡើយ ស្តេចទើងត់ហើយ អញទើងឈ្វៀសសេះស្តេច អញទើងដកយកសេះប្រសើរស្តេចនោះចេញ អញទើងចងត្រឿងសេះមិនគួរបីទើងចងនោះ លុះដល់លង្វែកនាយាមអព្រាត្រ អាចារ្យអន្ទុកៅវដ្តព្រាហ្មណ៍ នាំមកនាសេះនោះហើយទូលថា បពិត្រអើយ ! អញទុំចងហើយសេះនោះ អម្ចាស់ចូរដើងហោង រំពេលនាទើងត់នោះ ចូរអម្ចាស់ឡើងតង់លើសេះត់ហោង ។ សូម្បីអាចារ្យអន្ទុកៅវដ្តព្រាហ្មណ៍ ឡើងដំរសេះ ធ្វើហាក់ដូចទើងៗមួយអន្លើទើងស្តេចនាំទៅបន្តិចក្រឡាប់រំលេមកវិញ ។ អាចារ្យអន្ទុកៅវដ្តព្រាហ្មណ៍ ចង

គ្រឿងមិនគួរបរិភោគនោះ នាំស្តេចវត់ទៅហោង ។ អាចារ្យអនុកវដ្ត-
ព្រាហ្មណ៍ ឃុកសេះនោះដឹកចូលទៅក្នុងលំនៅក្នុងសេនាយោធាចាំងឡាយ
ស្រែកបន្ទឹមស័ព្ទឡើងថា រីស្តេចចុលទ័ពិញវត់ហើយ ។ ស្រែកទៅ
មួយអន្ទឹងទៀមទុស្សចាំងឡាយ ទើងបុរសជាខេត្តតអាក្នាងនោះ ក៏
ស្រែកហ៊ោកងរំពងឡើងថាត្រមាមួយគ្នាហោង ។ រីស្តេចសំណាល់
លែងនោះ ឮស័ព្ទអាចារ្យអនុកវដ្តព្រាហ្មណ៍នោះថា ចៅមហាសថ
អ្នកច្រោជគាត់បើកទ្វារមកហើយ ខ្មាំងហើយអស់អ្នកចាំងឡាយថា
ឥឡូវនេះ ចៅមហាសថបន្ទឹមស័ព្ទគាត់មិនឲ្យយើងរស់ដីតែឡើយ អស់
ស្តេចចាំងឡាយ កំតភ្លាមមិនអាចនឹងរមិលមើលក្រោយឡើយ ហើយ
ទ្រព្យគាត់គប្បីបរិភោគ មិនគួរបរិភោគនោះ គាត់វត់ទៅចោលអំពី
ទ្រព្យនោះ ។ មនុស្សចាំងឡាយជាស្រែកឮស័ព្ទនោះច្រើនថា សូមប្រតែ
ស្តេចក៏វត់ហើយ ។ សេនាយោធាចាំងឡាយ ដែលបិតនៅនាទ្វារ
បន្ទាយល្ហាងនឹង ឮស័ព្ទមនុស្សចាំងឡាយនោះស្រែកឡើងហ៊ោ ខ្លះខ្លះដៃ
ជាដៃ ។ អឺងកងអឺងអាប់ ស័ព្ទនោះរលាស់ចេលទៅហោង ។ ឥតិ
តស្មឹ ខណេ បឋវី កម្បិត្ថ មាណា វិយ សមុទ្ទោ វិយ
សំខុព្ភិតោ សកលនគរំ អន្តោ ច ពហិ ច ឯក-
ន្ធោនទមហោសិ ។ ឮដំកូរណោះ រស័ព្ទនោះ ហាក់ដូច
ទឹងឆ្ងាយទ្រូងមហាប្រថពី ឮដូចរលកមហាសមុទ្រឮដំផ្គរក្រោម រីអស់អ្នក

នៅក្នុងនគរនោះក្តី អ្នកនៅឯក្រៅនគរនោះក្តី សឹងបញ្ចេញស័ព្ទនោះអឺង
កង៉ជាមួយគ្នៅហោង ។ សឹងថាដូច្នេះ កាល ដូចយើងភ្ញាក ឮថា
មហាសេដ្ឋអ្នកជ្រាជ្ញ គាត់អាចចាប់ស្តេចចុលនីព្រហ្មទត្តជ ន្ទួរស្តេច
មួយរយទឹងមួយ ទឹងមនុស្សពាំងឡាយជាតល ១៨ អក្ខោហិនី សឹងតែ
ភ័យខានទឹងស្ងាប់ តែហានខានទឹងពំនាក់អាត្មាតុំបានឡើយ ហើយលះបង់
ន្ទួរទ្រព្យផង នៅតែនឹងតែសំពត់មួយចង្កេះតែនៅ ។ នាហានទ័ពនោះ
ស្ងាត់ជ្រងុំខ្មេហោង ។ រីស្តេចចុលនីយកអស់ស្តេចមួយរយទឹងមួយទៅ
កាន់នគរអាត្មាឯងហោង ។ បុនដ្ឋាសេ ចាតោ ឧកវត្ថាភនំ
វិវរិត្វា ពលនិកាយា ឧកភ ជិតូមិត្វា មហាវិលោបំ
ជិស្វា តឹ តកភេម បណ្ឌិតាតិ មហាសត្តស្ស អាភេ-
ចយឹសុ ។ លុះព្រឹកឡើង នាកាលថ្ងៃនោះ អស់ពលសកល
យោធាពាំងឡាយ នៃព្រះមហាសេដ្ឋ បើកទ្វារពេលចេញទៅអំពីព្រះ
នគរ យល់សម្បត្តិស្តេចចុលនីគេតែតចោលច្រើនហើយ កំពុងជ្រាប់ព្រះ
មហាសត្វថា បណ្ឌិត ហៃអ្នកជ្រាជ្ញអើយ ! តើយើងធ្វើម្តេច? ។
រីឯពោធិសត្វថា នាស្តេចពាំងអម្បាលនោះ ចោះបង់ម្បៀតទ្រព្យនោះ
ហើយ ចានយើងហោង, សត្វេសំ ភជ្ជនំ សន្តកំ រញ្ញោ
ឧទ្ទ . . . សូម្បីអស់ទ្រព្យស្តេចពាំងឡាយនោះ ចូរអ្នកពាំងឡាយ

ថ្វាយស្តេចយើង ទ្រព្យរបស់សេដ្ឋីនាំងឡាយក្តី របស់អាចារ្យកែវដ្ត-
ព្រាហ្មណ៍ក្តី សំណឹកបានខ្លះយើងហោង ។ ពោធិសត្វថា ទ្រព្យសំ-
ណល់លែងនោះ ឲ្យអ្នកខ្លះនាំយកហោង ។ ពោធិសត្វអ្នកឲ្យដាច្ចូន
យកទ្រព្យផង ខ្លួរតែនសឹងមានដំឡៃច្រើននោះ កន្លះទៃទើបអស់ ។
រីទ្រព្យសំណល់លែងនោះ លោកឲ្យដាច្ចូនយកបួនទៃទើបអស់ ។ រីព្រះ
មហាសត្វ ឲ្យណាប់រង្វាន់ផងច្រើនដល់អាចារ្យអនុកែវដ្តព្រាហ្មណ៍នោះ
ហោង ។ តតោ បដ្ឋាយ កិរ មិថិលនគរវាសិនោ សហិ.
ញ្ញាសុវណ្ណា ជាតា ។ មហាសត្វរត្តាធិ ជាតាធិ ។ កិរ
ដួចយើងឮមក ចាប់ដើមអំពីនោះទៅ រីអ្នកនៅមិថិលានគរសោត កើត
មានមាសប្រាក់ ទឹងរតនាការផងសឹងមានដំឡៃនោះច្រើនហោង ។

សូម្បីស្តេចបុលទ័ព្រហ្មទត្តរាជ នៅនាទត្តរបញ្ចាលនគរនោះ មួយ
អន្លើ ទឹងស្តេចមួយរយទឹងមួយ នៅកន្លងមកមួយឆ្នាំ ។

(ឆម្មយុទ្ធមជ្ឈលកណ្ឌំ ឯដ្ឋិតំ ។ នេះយើងទំនឹងស្រដីដំ-
ណើរកណ្ឌ កាលព្រះមហាសត្វតធម្មយុទ្ធជាមជ្ឈល ក៏ស្រែចដោយខ្លួ
ប្រការទាំងអម្បាលនេះឯងហោង) ។

(នៅមានត)

ខ្មែរកសង្ស្រាសាស្ត្រ

ជើមកំណើតព្យញ្ជនៈខ្មែរ

បើចង់ចម្លងពាក្យខ្លះក្នុងអត្ថបទនេះ ត្រូវសុំសេចក្តីអនុញ្ញាតពីអ្នកនិពន្ធ

រៀបរៀងដោយ ឧ. តាម

អក្សរសាស្ត្រខ្មែរ ខ្មែរធ្លាប់ថែរួន
ឲ្យបានភ្លាប់ខ្លួន តង់រង់តម់តំ ។
ព្រោះអក្សរជាតិ ដោលជាតិជ្រោកជិ
អក្សរលេត់ ដាតិកំរោយ ។

ប.ព.

អក្សរសាស្ត្រខ្មែរ មានល្បីឈ្មោះហើយខ្មែរយើងយកអក្សរខ្មែរមកប្រើជាផ្លូវការជាង ២.០០០ ឆ្នាំមកហើយ , ដល់មកសម័យនេះទៀតក្រសួងអប់រំជាតិបានបញ្ចូលសៀវភៅខ្មែរជាច្រើនទៅក្នុងកម្មវិធីសិក្សា ។

អាស្រ័យហេតុនេះ សាស្ត្រាចារ្យនិងនិស្សិតត្រូវតែខំស្រាវជ្រាវរកប្រវត្តិ នឹងលំនាំអក្សរដោយខ្លួនឯង ព្រោះក្បួនច្បាប់ជាអក្សរខ្មែរ មិនសូវមានបរិបូណ៌ ។

ខ្ញុំជាអ្នកស្រឡាញ់អក្សរសាស្ត្រមួយប្រភេទ ហើយជាអ្នកចង់ដឹងថាតើអក្សរខ្មែរ ដែលយើងប្រើនៅសព្វថ្ងៃនេះ ចូលមកប្រទេសកម្ពុជា នៅសម័យណា ។ សេចក្តីព្យាយាមរបស់ខ្ញុំក៏បានសម្រេចដូចបំណង ខ្ញុំបានអានវចនានុក្រមសំស្ក្រឹតអង់គ្លេសរបស់លោក មូនីយោ មូនីយោ វិល្យាម្ស

(Sir Monier Monier Williamns) ។ លោកនេះបានប្រៀបធៀប
អក្សរក្រែកខ្មែរនាគរី ព្រមទាំងអក្សរមែបព្រាហ្មីខៀត ។ មែបអក្សរ
ព្រាហ្មីដែលខ្ញុំយកមកជូនមើលពេលនេះ សូមលោកយកទៅប្រៀបធៀប
ខ្មែរសិលាចារឹកនៅភ្នំហាន់ជ័យ ខែត្រកំពង់ចាម ។ តែមែនតែខ្ញុំមិន
បានចម្លងព្យញ្ជនៈគ្រប់ទាំងអស់ តែលោកអ្នកអានអាចតាមដឹងព្យ
ញ្ជនៈខ្លះ ។ ហើយយកមកប្រៀបអក្សរសម័យនោះបាន ដូច
តទៅនេះ =

តែមុនខ្មែរលោកអ្នកអាន យកអក្សរព្រាហ្មីទៅប្រៀបធៀបនឹងអក្សរ
សិលាចារឹកនៅហាន់ជ័យ សូមលោកអ្នកយល់ឲ្យច្បាស់នូវន័យថាព្រាហ្មី
សិន ។ អក្សរព្រាហ្មី គឺជាអក្សរបូរាណខ្ទង់ ២ របស់អារ្យ ។ អក្សរនេះ
បានជាគេឲ្យឈ្មោះថាព្រាហ្មី ពីព្រោះពួកព្រាហ្មណ៍ឲ្យឈ្មោះ ហើយពួក
ព្រាហ្មណ៍ជឿថាអក្សរនេះព្រះព្រហ្មបង្កើត (. . . The second kind
of ancient Indian script is called Brāhma or Brāhmī: . . . .
given to it by the Brāhmans because as they assert, it was
invented by their God Brahma . . . . . អក្សរបូរាណខ្ទង់ ២ របស់
អារ្យ ហៅថាព្រាហ្ម ឬ ព្រាហ្មី . . . . ដែលពួកព្រាហ្មណ៍ឲ្យឈ្មោះ
ពីព្រោះពួកព្រាហ្មណ៍ជឿថាព្រះព្រហ្មបង្កើតអក្សរនេះ)

បៃបព្យញ្ជនៈធៀបគ្នារវាងអក្សរក្រិកព្រាហ្មីនាគរី និង ខ្មែរ

ក្រិកបុរាណ	ព្រាហ្មី	ព្រាហ្មីវែកឆ្ងាយ				នាគរី	ខ្មែរ
٨	٨	٨	٨	٨	٨	٨	٨
٨	٨	٨	٨	٨	٨	٨	٨
٨	٨	٨	٨	٨	٨	٨	٨
٨	٨	٨	٨	٨	٨	٨	٨
٨	٨	٨	٨	٨	٨	٨	٨
٨	٨	٨	٨	٨	٨	٨	٨
٨	٨	٨	٨	٨	٨	٨	٨
٨	٨	٨	٨	٨	٨	٨	٨
٨	٨	٨	٨	٨	٨	٨	٨
٨	٨	٨	٨	٨	٨	٨	٨

មុខនឹងប្រៀបធៀបអក្សរព្រាហ្ម៏ ទៅនឹងអក្សរដែលមកច្រត់ស្លាន
នៅប្រទេសកម្ពុជាមុន ខ្ញុំសូមជូនបៃបញ្ជូនៈទៅសម័យសិលាចារឹក
ហាន់ជ័យកំពង់ចាម ទៅសតវត្សទី ៦ ។

តាមការស្រាវជ្រាវរបស់លោក ហ្សក ម៉ាសេរ៉ូ (George Maspéro) ថាព្យញ្ជនៈដែលចាស់ជាងគេអង្គស់ គឺនៅសិលាចារឹក ហាន់ជ័យ ។ តែបើតាមការសង្កេតស្រាវជ្រាវរបស់អ្នកប្រាជ្ញខ្មែរវិញ ថា អក្សរចារឹកចាស់ជាងគេ គឺអក្សរចារឹកនៅភ្នំគាញ់ ។

ការធៀបគ្នារវាងអក្សរខ្មែរបច្ចុប្បន្ន នឹងអក្សរនៅសិលាចារឹកហាន់ជ័យ



បែបព្យញ្ជនៈខាងលើនេះ នៅក្នុងវគ្គទី ២ សម័យសតវត្សទី ៦ របស់លោក ហាវ្រីកេ ម៉ាសេរ៉ូ មិនឃើញមានព្យញ្ជនៈ ឈ ទេ ។ វគ្គទី ៣ មិនឃើញមានព្យញ្ជនៈ ង ន៏ងវគ្គទី ៥ មិនមានព្យញ្ជនៈ ញ ទេ ។

សូមលោកតាំងចិត្តស្រមើលអក្សរបែបព្រាហ្មី នឹងបែបសិលាចារឹកហាន់ជ័យមានលំនាំដូចគ្នាម្តេចខ្លះ ដូច្នេះខ្ញុំសូមជូនសេចក្តីសង្កេតដូចតទៅ :

១- អក្សរ ក្ក សម័យសិលាចារឹកហាន់ជ័យ ឃើញមានលំនាំដូចព្រាហ្មីមែន ។ ហើយអក្សរ ក្ក ក្រែកក៏មានលំនាំដូចគ្នាដែរ ។

២- អក្សរ ឋ ព្រាហ្មីកន៏មូលហើយមានគូសវែកណ្តាល ឯសម័យសិលាចារឹកហាន់ជ័យ គួរនេះ កន៏មូលទ្រវែងហើយមានគូសវែកណ្តាលដូចគ្នា តែចំណែកក្រែកគូសខ្វែងដើងក្អែកកណ្តាល ។

៣- ព្យញ្ជនៈ ឃ នៃអក្សរព្រាហ្មីក្តាយ ន៏ងអក្សរខ្មែរមានលំនាំដូចគ្នាបេះបិទ សូម្បីតែព្រាហ្មីមិនទាន់ក្តាយ ក៏នៅមានលំនាំដូចគ្នាដែរ ។

៤- ព្យញ្ជនៈ ធ សម័យព្រាហ្មីន៏ងសិលាចារឹកហាន់ជ័យ ក៏ស្រដៀងគ្នាដែរ (ផ្នាំន៏ងទី ២) ។

៥- ព្យញ្ជនៈ ទ្ធ រវាងហាន់ជ័យ ន៏ងព្រាហ្មីក្តាយក៏មានលំនាំដូចគ្នាដែរ ។

ការប្រៀបដូច្នេះនៅ ឃើញថាសម័យអក្សរនៅសិលាចារឹកហាន់ជ័យដែលចូលមកប្រទេសកម្ពុជាមុន តិតជាអក្សរសម័យព្រាហ្មីនៅប្រទេសឥណ្ឌាមែន ។

ស្រៈខ្លះសម័យសិលាចារឹកហាន់ជ័យ

១)- ស្រៈ អ៊ុ នៅសិលាចារឹកហាន់ជ័យមានតាំរបៃបៈ

ក)- ᨾᩣᩈᨠ᩠ᩁᩮᩣᨵᩣᩈᩉ = មាសង្រែរិណាសហ

ខ)- ᨿᩣᨶᩴᩈᩩᩁᩥᨶᩣᩁᨷᩴ = យានំ សុរិណារបិតំ

តាមការពិនិត្យទៅឃើញថាស្រៈ អ៊ុ សម័យជាមួយគ្នានោះ មិនដូចគ្នាទេ ។ លេខ ១ ក ស្រៈ អ៊ុ មានសណ្ឋានដូចជាដើងព្យញ្ជនៈ ង្រ (គ្រ-ភត់) ។ លេខ ១ ខ ស្រៈ អ៊ុ មានសណ្ឋានដូចជានិគ្គហិត ។

នៅឧទាហរណ៍ ខ- ខាងលើនេះ (យានំ សុរិណារបិតំ) លោកអ្នកអាចសង្កេតឃើញវណ្ណយុត្តិ (រចុះ) នៅខាងលើព្យញ្ជនៈ ណ ដូចជាសំយោគសញ្ញា ។

២) ស្រៈ អ៊ី សូមពិនិត្យមើលនូវពាក្យទាំងនេះ

ក) ᨸᨶ᩠ᨶᩣᩁᩮᩦ = បណ្ណារី:បណ្ណ+អារី

ខ) ᨩᩣᨾᩥᨲ᩠ᨲᩣᨾᨸᩤ = ជាមិត្តាមពីរ=ជ+អា-មិត្ត+តា+ពីរ

ស្រៈ អ៊ុ : ស្រៈ អ៊ុ និស្ស័យមានរបៀបប្រើដូចស្រៈ អ៊ុ យើងបច្ចុប្បន្នេះដែរ ។

ខ- បុត្រ = បុត្រា


ង) ស្រះ អ្ន ន៎ស្ស័យមានរបៀបដូច្នេះ



ម្ហូទ្ធិកាញ្ចនវ៉ុទ្ធំ = ម + ឧ ទ្ធិកាញ្ចនវ៉ុទ្ធំ

ច) ស្រះ អ្ន ន៎ស្ស័យនៅសម័យសិលាចារឹកហាន់ដ័យយើញមាន

ដូចឃ្លឹងយ្ងាគបន្ទិច តែកងស្រះដៀងគ្នា (សូមសង្កេត)



ស្នាមំាងដិក្សរស្ត្ឋយ



មនាគសិនបេតសិ = ម + អនាគសិ + ន + បេតសិ

ដោយតាំនិត្យតាមភាក្យខាំងនេះ យើញថាស្រះ អ្ន ឃ្លឹងយ្ងាគគ្នានៅ

ត្រង់កន្លែងដែលស្រះសល្ងាំត

ក)- ស្រះ អ្ន ស្ថិតនៅលើភ្យាន:

១)- ស្រៈ អ្ន ស្ថិតនៅអែបញ្ជាន: (មានលំនាំដូចជាស្រៈ អ្ន បច្ចុប្បន្ន)

២) ស្រៈ អ្ន សុទ្ធ (សូមលោកតាំនិត្សាមើលស្រៈ អ្ន សុទ្ធនេះតាកង តាញ្ជាន:ព្រាហ្ម៏) មានសណ្ឋានដូចអក្សរព្រាហ្ម៏ តែបែកគ្នាត្រង់ស្រៈ អ្ន បែប សិលាចារឹកហាន់ជ័យកង់ត្រាត់ខ្លីដាងបែបអក្សរព្រាហ្ម៏

ខ. = អ្ន

៣) ស្រៈ អ្ន មានលំនាំដូចស្រៈ អ្ន (សូមអានលេខ ១ ក) តែថា ស្រៈ អ្ន មានត្រាត់មួយកន្ទុះ ។ សូមតាំនិត្សាពាហារណ៏

យស្ស ឈ្ន ម្ភ ហ បំ ស

យស្ស យោធៃម្ភវាចិត> យស្ស យោធៃ ការាចិត

៤)- ស្រៈ អ្ន មានសណ្ឋានលំនាំតាវបែប សូមលោកតាំនិត្សា មើលនូវពាហារណ៏លេខ ៥ ក, ទំនិលេខ ៧ ។ ពាហារណ៏លេខ ៥ក ស្រៈ អ្ន មានសណ្ឋានលំនាំដូច ស្រៈ អ្ន ដែលប្រើសព្វថ្ងៃ ឯពាហារណ៏លេខ ៧វិញ ស្រៈ អ្ន មានលំនាំដូចស្រៈ អ្ន សៀម ។

សូមជូនពរ ភាវណ៌ អក្សរសិលាចារឹកនៅហាន់ជ័យមួយយ៉ាងគួរជា
គោល :

មង្គលចក្ខុ ម្ចាស់ការដោះដង្កៀប
យាសុជាតិ ហាស្យរីបរិវារមាម

អត្ត បិត្រា មលធត្រ មុទ្ធិកាញ្ជនវុទ្ធិទ្ធមិ
យានំសុរិណ៌រចិតំ ហេស្ស ភ្ជួររើហ៊ែណាម

ប្រែថា ត្រែដែលពាសដោយសំពត់លាត ខាងក្នុងមានចាំក់ ខាងលើ
មានកំពូលមាស ពាជវៀរធ្វើដោយមាស ហើយទឹងហូរគោទឹងដំរីមាស ។

ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ « ក »

(តមក)

Contraindre	(v.t.)	បង្ខំ ។
Contrainte	(n.f.)	ការបង្ខំ ។
Conseil communal		ក្រុមប្រឹក្សាឃុំ ។
Conseil de famille		ក្រុមប្រឹក្សាញាតិ (ព.ប្ប.) ។

— D —

Corriger	(v.t.)	កែ ។
Devoir de fidélité de la femme mariée		ការណ៍យចិត្តស្មោះត្រង់នៃស្ត្រីមានប្តី (ព.ប្ប)។
Devoirs d'aide et de secours entre époux		ការណ៍យកិច្ចជួយទំនុកបម្រុងរវាងស្វាមី-ភរិយា (ព.ប្ប.) ។
Devoirs d'assistance entre époux		ការណ៍យកិច្ចសង្គ្រោះរវាងស្វាមី ភរិយា- (ព.ប្ប.) ។
Divorce	(n.m.)	ការលែងលះគ្នា (ព.ប្ប.) ។
Diviser l'étude du droit		ចែកការសិក្សានៃនីតិសាស្ត្រ (ព.ប្ប) ។
Division de l'étude du droit		ការចែកការសិក្សានៃនីតិសាស្ត្រ (ព.ប្ប.) ។
En droit commun		នីតិសាស្ត្រសាមញ្ញ (ព.ប្ប.) ។
Dissoudre le mariage		រំលាយអាពាហ៍ពិពាហ៍ (ព.ប្ប.) ។

Dissolution du mariage ការរំលាយអាពាហ៍ពិពាហ៍ (ពប្ប) ។

— E —

Erreur (n.f,) ការភាន់ច្រឡំ ។

Erroné (adj.) ដែលភាន់ច្រឡំ ។

— F —

Faible d'esprit អ្នកសតិទន់ខ្សោយ (ពប្ប) ។

Faiblesse d'esprit ភាពសតិទន់ខ្សោយ (ពប្ប) ។

Femme de ler rang ភរិយាទី ១ (ពឍ្ឍ) ។

Femme de 2è rang ភរិយាទី ២ ។ ពឍ្ឍ ។ ប៉ុះសម្គាំអាចមានភរិយាទី ២ ច្រើនឆាក់ជាន ។

Femme infidèle ស្ត្រីអស្ចារ្យភក្តី (ពឍ្ឍ) ។

Fille impubère នារីអវយបត្ត (ពឍ្ឍ) ។

Foyer conjugal ក្រាទសង្វាស (ពឍ្ឍ ។

— G —

Garçon impubère នរៈអវយបត្ត (ពឍ្ឍ) ។

Gaspiller (v.t.) ខ្ជះខ្ជាយ ។

Gaspilleur (n.m.) អ្នកខ្ជះខ្ជាយ ។

Gaspillage (n.m.) ការខ្ជះខ្ជាយ ។

Gens du peuple ប្រជារាស្ត្រ ។

(នៅមានត)

វិបុលានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ទ៉ាំង - ខាត់ រៀបរៀង

(តមក)

អតិអ្តិ ឆគុ. ដើក ។

អតិអ្តិត ន.ប៉ុ. រងាក្រៃលែង ។

អតិអ្តុទ្ធ គុ. ដែលសុទ្ធក្រៃលែង, ដែលសុទ្ធកន្ទង ។

អតិអ្តុភ ឆគុ. ល្អក្រៃលែង ។

អតិអ្តុរ គុ. ដែលក្លៀវក្លាកន្ទង ។

អតិអ្តេម ប៉ុ. សេសក្រៃលែង ។

អតិអ្តៅភាឝ គុ. សោភ័ទកន្ទង, ដែលល្អកន្ទង ។

អតិអ្តៅភាការ គុ. ដែលធ្វើឲ្យសោភាកន្ទង ។

អតិអ្តៅប ន.ប៉ុ. សេចក្តីបរិសុទ្ធកន្ទង ។

អតិអ្ត្រម ប៉ុ.កិរិយាអន់កម្ចាត់ក្រៃលែង ។

អតិអ្ត្រី ស្រ. សិរីក្រៃលែង, សិរីប្រសើរ ។

អតិអ្ត្រិប្ត គុ. ដែលស្កឹតងាប់ក្រៃលែង ។

(នៅមានត)

ភាគទី ៤៨

ទុកញ៉ាំបុលកដសេនា ឆ្ង-កង ប្រៃរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្វាសបើបានអាន
ទំងបេះទុយកលចំណាន
ពាំងមានសន្ដានស្នេហាជាតិ
យូ: - អ៊ុន

ឯបួនឆ្លុះតខ្លួកចម្បាំងរួចហើយ ក៏ចាត់ចែងទាហានចុះខ្លួកចម្បាំងជាបីកង លើកឆ្ពងចេញទៅ ចំរើដែលចេញទៅសើបល្បាត ក៏នាំយកសេចក្ដីមកប្រាប់ម៉ាឈៀវ ក៏ចាត់ចែងទាហានឲ្យចេញទៅតួនបង្កប់ស្កាត់តាមរយៈផ្លូវ លុះកងទ័ពបួនឆ្ពងដល់ត្រើយ បួនឆ្ពងទាហានមួយភាន់ក៏ឡើងគោក ហើយរៀបតាំងបន្ទាយនៅទីនោះ ម៉ាឈៀវក៏ចុះខ្លួកចម្បាំងតំខ្លួស្កាត់តីក្រោយបួលទៅ ទាហានបួនទំងអស់ដែលនៅមិនទាន់ឆ្ពងដល់ត្រើយក៏បែកខ្ចាត់ខ្ចាយអស់ ពួកដែលនៅលើគោកក៏រត់ចុះខ្លួកបួនមិនឃានដំងថាសត្រូវនឹងមកផ្លូវលើនឹងផ្លូវក្រោមប្រការម្ដេច ក៏កាន់ក្រប៉ីលើកឡើងយាត់ ប្រាប់ទាំងយកចិត្តទាហានទាំងពួងថា កុំឲ្យភ្ញាក់ផ្អើល

ជ្រួលច្របល់អ្វី យើងនៅនេះហើយនឹងខ្លាចអ្វី ។

មាំឈៀវឃើញចូនួអង្គុយបង្គាប់ ប្រើតាហានឲ្យធ្វើចន្ទាយនៅមាត់ច្រាំង កំអែបខ្លួនៅខាងឆ្ងើងគោក ហើយដុះសេះដេញកាប់ពួកកងទ័ពចូនួ តាហានតាំងនោះក៏រត់ប្រញូនប្រញាក់ស្រែកថាមាំឈៀវមកហើយ ខៅជួយើញមាំឈៀវដេញកាប់តាហានចូលមកដិត នៅប្រមាណ ៥០ ត្បាម (១០០ ម.) នឹងដល់ខ្លួន ចូនួ កំព័យស្មុតចិត្ត ស្ទុះចូលទៅតយកខ្លួនចូនួចុះខ្លួក ដៃស្តាំកាន់កន្ទុយខ្លា ដៃឆ្វេងក្រានខ្លួនចេញពីច្រាំង តាហានតាំងពួនក៏ព័យស្មុតតាំងអស់គ្នា រត់ចុះទៅចាប់តែមខ្លួកចូនួខ្លួក ហើយស្រែកថាមហាឧបាជដួយយកដីតែខ្ញុំឯង ។

ខៅនួយើញមាំឈៀវស្ទុះដិតចូលមក កន្ត្រាក់ក្រចីកាប់ពួកតាហានខោះ ខ្លះដាច់ដៃខ្លះដាច់ជើង ហើយចយខ្លួកចេញពីច្រាំងទៅកណ្តាលស្ទឹង ឆ្ងាយប្រហែល ៣ ត្បាម (៦ម.) ខ្លួលមាំឈៀវស្ទុះមកដល់ច្រាំង ចូនួយើញដូច្នោះព័យខ្លាំងណាស់ញ័រអស់តាំងខ្លួន ស្ទុះទៅឧបខៅនួ ។ កំស្រួតចេវខ្លួកទៅ មាំឈៀវក៏ឲ្យយកធ្នូបាញ់ចម្រុះតម្រង់ទៅជ័ដួចត្រាប់ភ្លៀង ខៅនួខ្លាចក្រែងព្រួញធ្នឹងត្រូវចូនួ ក៏យកកែបសេះត្រួបលើខ្លួនចូនួ ហើយយកក្រចីក្រវីការពារព្រួញធ្លាក់ខ្លួន បង្ខំឲ្យចេវខ្លួកតម្រង់ទៅស្រុកអ៊ុយឡាំ គណៈនោះចៅហ្វាយស្រុកអ៊ុយឡាំក៏ចេញមកខ្លួលចូនួឡើងទៅ ខ្លួលមាំឈៀវចុះខ្លួកចម្ងាំងតាមទៅដល់ស្រុកអ៊ុយឡាំ លើក

ខាហានឡើងគោកនឹងចូលទៅកាយដណ្តើមយកខ្លួនបួនឆ្នូ តែងហ៊ុយចេញ-ហ្វាយស្រុកអ៊ុយឡាំយើញដូច្នោះក៏គិតថា ខាហានមាំឈ្មៀវលើកមកពីស្រុកសៃលឿងក៏យូរណាស់ហើយ តង់នឹងអស់ស្បៀងអាហារជាច្រើនដងចាំអញតែងបាយកលំធ្វើឲ្យកងទ័ពមាំឈ្មៀវញ៉ាំដើម្បីឲ្យបួនឆ្នូរត់រួច ទើបបើកទ្វារចេញហួងគោក្របីឲ្យចេញពីស្រុកជាច្រើន នោះខាហាមាំ-ឈ្មៀវក៏នាំគ្នាចាប់គោក្របីសម្លាប់ស៊ីជាអាហារ មិនបានឱនឱនតែលើកតាមបួនឆ្នូទៅទៀត ។

ឯបួនឆ្នូលុះទៅដល់បន្ទាយអ៊ុយហោ យើញដែកបុងត្រួញជាប់ឱនក្រោះទៅជាច្រើន ក៏និយាយថា គ្រានេះបើយើងកុំបានទៅឆ្ងៃ កាលណាឡើយនឹងគង់ជីវិតរស់រួចមកដល់ទីនេះ ខាហានទាំងពួងពុំបួនឆ្នូថាដូច្នោះ ក៏នាំគ្នាក្រាបចុះទៀបជាខដើងបួនឆ្នូ ។ ក៏សើចថា យើងធ្វើសឹកគ្រានេះ មិនគួរនឹងចាញ់ប្រៀបអាចោរកូនក្មេងសោះ បើកុំតែបានទៅឆ្ងៃជួយកែវ ។ យើងក៏មិនរួចជីវិតរស់មកឡើយ ទៅឆ្ងៃពួងដូច្នោះក៏ថា កាលខ្ញុំបានឱនលោកឡើងគោកបាន ហើយមាំឈ្មៀវលើកខាហានតាមមកតែងហ៊ុយធ្វើកលកុងបាយបើកលែងហួងគោក្របី ឲ្យចេញទៅលំនឹងទ័ពមាំឈ្មៀវលើកតាមមិនខាន់ ។

ខ្លួលតែងហ៊ុយមកដល់ បួនឆ្នូក៏និយាយនឹងតែងហ៊ុយថា អ្នកបានជួយរំនែតែកែវ ដើម្បីឲ្យយើងរួចពីចំណាមទ័ពមាំឈ្មៀវគ្រានេះ អ្នកក៏

មានទុបការៈ ខ្ញុំដឹងយើងច្រើនណាស់ ហើយក៏តាំងតេងហ៊ុយជាខ្ញុំខ្មៀនគុយ
ហៅហ៊ុយ ប្រែថា នាម៉ឺនស្តេចសម្រាប់ប្រឹក្សាការពារជាតិ តេងហ៊ុយក៏
ជម្រាបបចូតូថា ឥឡូវម៉ាឈៀវមានចិត្តកំរើបលើកគ្រឡប់ទ័ពទៅវិញហើយ
ព្រឹកនេះមុខជាខ្ញុំលើកទ័ពមកធ្វើការខ្មែរ មហាទុបជត្រូវគិតធ្វើទ-
ប្បាយកលទុកសងសឹកទៅវិញកុះ ។

បូតូថា អ្នកកុំរិតក្តាឡើយ ឯការគ្រង់ណេះយើងក៏បានរិះគិតទុកជា
ស្រេចហើយ បូតូឲ្យប្រមូលពាហនដឹកដង្វើស្មាមភ្លោះដុំវិញបន្ទាយ ត្រៀ
បន្ទាយឲ្យដឹកដុំរៀ ២ ញាម ឲ្យដោតចំរ៉ែងក្នុងគូ លើមាត់គូឲ្យយកឈើ
មកពាយជារនូត ហើយឲ្យយកដីត្រៀបលុបមិនឲ្យឃើញស្មាម ប្រាប់ថ្នា
ខ្ញុំឯបញ្ជោតឲ្យពាហនម៉ាឈៀវឆ្លាក់ចុះកូនគូនោះ ហើយឲ្យពាហនកូន
បន្ទាយដោតខ្ញុំត្រៀមគ្រឿងសាស្ត្រាវុធទុកឲ្យត្រៀម ។

កាលម៉ាឈៀវត្រឡប់ទៅដល់បន្ទាយហើយ កំនិយាយប្រាប់ហ៊ុន
ស៊ុយថា ខ្ញុំបាទទៅធ្វើការគ្រានេះមានជ័យជំនះ ហៀបតែនឹងចាប់ខ្លួនបូតូ
បាន តែមានពាហនម្នាក់រូបកង៉ែងយ៉ាងស្វាហាប់ អាចពង្រីយកខ្លួនបូតូចុះ
ខ្លួករត់រួចទៅបាន ហ៊ុនស៊ុយថា ពាហនបូតូមានថ្ងៃដង្វាំងតូចៗ ២ ភាក់ តី
ខ្មៀនអ៊ុយនឹងទៅជួ ឥឡូវខ្មៀនអ៊ុយស្លាប់ទៅហើយ ដែលដោះចុះបូតូ
គ្រានេះក៏តីទៅជួនោះឯង ឯទៅជួនោះជាមនុស្សមានកម្លាំងនឹងថ្ងៃដតូចៗ
ជាងពាហនទាំងពួង ប្រៀបដូចខ្លាសាហាវ បើទៅបានទៅប្រទះនឹង

ឥតច្បាំងគ្នា កុំតប្បីធ្វេសប្រហែស ចូរពង់ឥក្សាខ្លួនឲ្យមាំមួន ម៉ាំឈ្មៀវ
ថា ទៅជួម្នាក់នោះខ្ញុំបានបានឮល្បីឈ្មោះមកយូរហើយ ទើបនឹងបាន
ឃើញរូបក្នុងគ្រានេះ ។

ហ៊ានស៊ុយថា ឥឡូវចូរធ្លាត់ធ្លងត្រើយទៅទៅក្នុងបន្ទាយអ៊ុយហោ
ហើយ ខ្ញុំគិតថានឹងលើកទ័ពទៅច្បាំងកុំឲ្យឥតាំងខ្លួនជាមុនបាន បើបង្ហិន
ឲ្យយូរឲ្យចូរធ្លាំងបន្ទាយជាមាំបានហើយ មុខជាយើងនឹងធ្វើការលំបាក
ទៅទៅឯក្រោយចូរពង់ឥក្សាបន្ទាយនឹងផ្លូវក្រោយឲ្យមាំមួន ខ្លាចចូរធ្លងនឹង
លើកទាហានតាមក្រោយមកកាត់ស្បៀងរបស់យើង ម៉ាំឈ្មៀវបានស្តាប់ដូច្នោះ
ក៏យល់ឃើញត្រូវ ទើបធ្វើយថា គំនិតដែលបំតាគិតនេះប្រពៃណាស់
នឹងលើកទៅក៏ទៅចុះ អំពីបន្ទាយនឹងផ្លូវខាងក្រោយនោះ ជាភ្នាក់ងារខ្ញុំ
បានឲ្យរក្សាការពារមិនឲ្យអន្តរាយ ប្រសិនបើចូរធ្លងនឹងលើកធ្លងមកត្រើយ
ខាងណោះ ខ្ញុំបានឲ្យលើកទាហានទៅស្កាត់ពង់មិនឲ្យឥធ្លងមកបាន
ហើយម៉ាំឈ្មៀវក៏បានតាំងឲ្យជាំងតេក ឃុំទាហាន៥ម៉ឺនជាទ័ពមុខទៅជាមួយ
នឹងហ៊ានស៊ុយ ។ ក៏លើកទ័ពធ្លងទៅបន្ទាយអ៊ុយហោ ។

ចូរធ្លងដឹងថា កងទ័ពម៉ាំឈ្មៀវលើកមកដូច្នោះ ក៏បានតាំងឲ្យមនុស្សបាស់ៗ
ចេញរក្សាស្មាមភ្លោះទៅក្រោយបន្ទាយ ហើយបង្គាប់ថា បើប្រសិនជា
ទាហានម៉ាំឈ្មៀវរុកពន្ធខ្ទ្រានចូលមក ក៏ឲ្យធ្វើជារត់បណ្តោតឲ្យដេញធ្លង
តូចូលមកឲ្យបាន ហើយបង្គាប់ទាហានឆ្នាំងត្រៀបខ្លួនទៅក្នុងបន្ទាយ ។

លុះហ៊ានស៊ុយលើកខ័ពទៅដល់ ចាំដឹងតែកយើញគាហានចូឆ្លូវក្បាបន្ទាយនោះស្ដើងស្ដួចណាស់ ក៏លើកខ័តចូលទៅវាយ គាហានដែលរក្សាស្នាមក្លោះនៅនោះ ក៏ឆ្លើជាថយរត់ទៀដេញ ចាំដឹងតែកនឹងគាហានយើញចាន់ការ ក៏ដេញសន្ធឹ លទៅធ្លាក់ពុះកងគ្នូ ចូឆ្លូទៀចោអេងលើកគាហានព័ទ្ធដេញតាប់សម្លាប់គាហានចាំដឹងតែកស្លាប់កងគ្នូ ប្រហែល ២០០ ចាយ ស្លាប់ចាំដឹងទៀវហ៊ូ ដេនដឹនជាគាយគាហាន ឯទ្ធួនចាំដឹងតែកតាក់ក្រែវដែកទើបមិនមានអន្តរាយ លោតឡើងលើមាត់គូបានយើញចោអេងជិះសេះកាន់លំពែង ចាំដឹងតែកកឹស្ទុះតម្រង់ទៅយកដាវតាប់ចោអេងធ្លាក់ពីលើសេះស្លាប់ ហើយក៏លោតឡើងខ្នងសេះនាំហ៊ានស៊ុយនឹងគាហានចាំដឹងតួងតាប់ចំណាយចេញពីកងចំណោមខ័ពត្រឡប់ទៅបន្ទាយតុងគ្នូនវិញ ចូឆ្លូក៏លើកខ័ពដេញតាមទៅ ។

ឯមាំឈៀវចាំមើលឆ្លូវហ៊ានស៊ុយយើញយូរហួសកំណត់ ខ្លាចក្រែងហ៊ានស៊ុយថ្ងស់ការក៏លើកគាហានឆ្លងទៅតាម លុះទៅដល់មាត់ស្ទឹងយើញចូឆ្លូដេញហ៊ានស៊ុយមក ក៏លើកគាហានចូលទៅជួយនាំយកខ្លួនហ៊ានស៊ុយនឹងចាំដឹងតែកចុះខ្លូកឆ្លងមកបន្ទាយតុងគ្នូន មាំឈៀវនិយាយនឹងហ៊ានស៊ុយថាចូឆ្លូមានច្រាជាច្រើខ្លាយណាស់ បើនឹងស្ទឹមខុកឲ្យយូរទៅយើញថានឹងធ្វើការលំបាក ត្រូវតែយើងលើកគាហានយាំងប្រញាប់ទៅបន្ទ

បន្ទាយចូនឲ្យបានក្នុងពេលយប់នេះទៅបត្រូវ ហ៊ានស៊ុយកំយល់ផង ទើប
រៀបចាត់ចែងគាហានឲ្យមាំឈៀវឃុំទាំគាហានជាមុខ ចាំឯងតេកនឹង
មាំតាយជាខាងក្រោយ ខ្លួនហ៊ានស៊ុយឃុំគាហាន ៥ កងជាសារីត្រមើល
ខុសត្រូវ ស្រួតលើកទ្នួងទៅត្រើយនាយទាំងកណ្តាលថ្ងៃ លុះដល់ច្រាំង
ហើយកំឲ្យគាហានឡើងបង្កប់តួនត្រមគ្នាទៅក្នុងព្រៃ ចាំដល់ពេលយប់
នឹងលើកចូលទៅបន្ទំបន្ទាយចូន ។

ឯចូនកាលបើមានដំណឹងលើហ៊ានស៊ុយហើយ កំលើកទ័ពត្រឡប់
ទៅបន្ទាយ ហើយហៅទៅចូមកបង្គាប់ថា មាំឈៀវអោយមកធ្វើអង់អាចហ៊ាន
ច្បាំងនឹងយើងវេលានេះ ព្រោះវាមិនឲ្យយើងតាំងខ្លួនជាប់ ក្នុងថ្ងៃនេះវា
ចាញ់ប្រៀបយើងហើយ គង់វានឹងមានចិត្តឈឺក្តៅ វិលមកបន្ទំបន្ទាយ
យើងវិញក្នុងពេលយប់នេះមិនខាន ខ្លួនអ្នកឯងត្រូវចាត់ចែងគាហានចេញ
ទៅតួនបង្កប់កយគ្នាខាងក្រៅបន្ទាយ បើដល់ពេលយប់ហើយ មាំឈៀវ
លើកមកបន្ទំបន្ទាយ យើងត្រូវអុចផាវជាសញ្ញាឡើង ហើយឲ្យគាហាន
ដែលបង្កប់នោះ ចេញមកព័ទ្ធរួបប្រសប់គ្នាពីមុខពីក្រោយចូលមក គង់តែ
យើងនឹងមានជ័យជំនះចាប់យកខ្លួនមាំឈៀវឲ្យបានជាប្រាកដ ទៅចូ-
ឲ្លួលបង្គាប់ហើយ កំចេញទៅចាត់ចែងការពុកត្រមតាមចូនបង្គាប់នោះ
គ្រប់ប្រការ ។

លុះដល់ពេលយប់ក្នុងថ្ងៃនោះ មាំឈៀវក៏ចាត់ប្រើសេនីនីនីនាំ-ហាន ៣ នាក់លបចូលទៅល្បាតស៊ើបការឯបន្ទាយចូនួ តើនឹងត្រួតត្រៀមបំរុងការពុកដូចម្តេចខ្លះ ឯមាំឈៀវនឹងចាំនាំគេកកំលើកតាហានទៅជាក្រោយនោះ សេនីនីនីនាំ ៣ នាក់ ចាន់ទៅដល់បន្ទាយចូនួហើយ ក៏ឃើញស្មាត់ព្រៀងមិនឃើញមានតាហានត្រៀមបំរុងការដូចធម្មតា ក៏មានអំណរណាស់ ដើរចាំតាហានសេះ ៣០ ក្នុងស្វាមក្មេះចូលទៅ ចូនួឃើញដូច្នោះ ក៏ឲ្យអុជផ្ទាំងសញ្ញាឡើង នោះពួកតាហានដែលចង្កាប់ក្រៅបន្ទាយក៏ស្ទុះស្រេចញ្ជាមកពីក្នុងព្រៃជុំវិញបន្ទាយ ហៃហួ-អៀនក៏ឡើងសេះកាន់លំពែងចាក់សេនីនីធ្លាក់ពីលើសេះស្លាប់ ហើយក៏-ដេញកាប់តាហានសេនីនីបែកខ្ចាត់ខ្ចាយជាច្រួលច្របល់ មាំឈៀវនឹងចាំនាំគេកដែលលើកតាមទៅពីក្រោយដឹងដូច្នោះ ក៏រំសាយភ្លែកគ្នាជា ៣ កងតាំងតែកាប់តុះតារំលាយតាហានចូនួចូលទៅជួយគ្នា នោះបណ្តាតាហានកងទ័ពតាំងសងខាងក៏ប្រឡូកកាប់ជាប់ដៃគ្នាទៅវិញទៅមក ទាំងសងខាងក៏ស្មើកំឡាំងគ្នាហើយថយចូលបន្ទាយវិញ ។

មាំឈៀវចាត់តាហានឲ្យចេញទៅបន្ទន់បន្ទាយចូនួតែកល់ថ្ងៃ ចូនួក៏ចាត់ការត្រួតត្រាបន្ទាយដែលតាំងនៅក្បែរស្ទឹងអ៊ុយហោនោះមាំមួនណាស់ ហើយឲ្យធ្វើស្ពានឆ្លងស្ទឹងនោះ ទឹងចាន់ទៅមកជួយគ្នា ដល់បន្ទាយថោយិន ឯមាំឈៀវដឹងការដូច្នោះ ក៏បង្គាប់តាហានឲ្យមានគប់ភ្លើង

គ្រប់គ្នា រហូតទៅដល់ទាហានហ៊ានស៊ីយ ហើយលើកចូលវាយ
បន្ទាយចូនួ យកភ្លើងដុតបន្ទាយនោះនេះគ្រប់ទិស កងទ័ពចូនួនលន់តុ
ឈ្នះ ក៏បែកបាក់ព្រាត់ព្រាយរត់ចេញអស់ពីកងបន្ទាយទៅទិសផ្សេង ។
ម៉ាឈៀ ហ៊ានស៊ីយក៏ចាត់ទាហានឲ្យកន្ត្រើជាបន្ទាយយ៉ាងម៉ា ត្រង់ទី
បន្ទាយចាស់ចូនួនោះ ចូនួបែកទ័ពថយទៅពីនោះចម្ងាយប្រហែល ៩០
សិន (៦ គី) ឃើញម៉ាឈៀឲ្យតាំងបន្ទាយត្រង់ទីចាស់បែរខ្នងដូច្នោះ
លុះទីតាំងបន្ទាយខួលរឹងក៏មិនខាន់ការ ទើបឲ្យទាហានដឹកដីយកមក
បូកជាប់គ្នាជាដុំៗ ហើយរៀបឡើងជាស្មាមភ្នោះនៅកងទ័ពនោះ ។

មានបំរើសេះចូលទៅដំណឹងម៉ាឈៀថា ចានយើញចូនួឲ្យរៀបធ្វើ
ស្មាមភ្នោះ ម៉ាឈៀបានឮដូច្នោះ ក៏ឃុំទាំងទាហានទៅដល់មុខស្មាមភ្នោះ
បន្ទាយចូនួឆ្ងាយដឹងដូច្នោះក៏ឡើងសេះចេញទៅឈរនៅមុខបន្ទាយជាមួយនឹង
ទៅគួ ហើយស្រែកប្រាប់ទៅទាហានម៉ាឈៀថា ឲ្យប្រាប់នាយឯងឯងថា
យើងចេញមកចាំនៅទីនេះតែម្នាក់ឯងទេ ឲ្យម៉ាឈៀចេញមក យើងនឹង
ចរចាផង ម៉ាឈៀបានឮចូនួស្រែកមកដូច្នោះ ក៏បរសេះចេញមកឈរ
នៅត្រង់មុខចូនួឆ្ងាក៏ស្រែកថា អ្នកឯងឃើញថ្ងៃដែរយើងឬទេ ? អ្នកឯងគិត
ថាដុតបន្ទាយយើងចេញ មុខជារកបន្ទាយនៅទៀតគ្មានឬ? យើងគ្រាន់តែ
ធ្វើមួយស្របក់ក៏កើតជាបន្ទាយបានដូចខេតតាមកនិម្មិតឲ្យ អ្នកឯងនឹងតស៊ូ

នោះ កាលណាខ្ញុំមានដំណើរដូចនេះយើងបាន ត្រូវតែនាំចុះចាញ់ឲ្យហើយ
ទៅវិញជាជាង ។

ម៉ាំឈៀវឈួលក្នុងចិត្តខ្លាំងណាស់ ក៏បរសេះសំរុកចូលទៅទីចាប់
យកខ្លួនចូរួ ខណួលក្រឡេកឃើញទៅធូកាន់លំពែងសំឡក់ក្អែកក្រឡោត
នៅពីក្រោយចូរួ ក៏នឹកខ្លាចពាញសេះឈប់គិតថា ពាហាននេះហើយ
ឬដែលឈ្មោះថាទៅធូនោះ ឮល្បីថ្លៃដៃខ្លាំងពូកែណាស់ឬក៏មិនមែនទេឬ?
ទើបស្រែកសួរថា ពាហានខ្លាបេះសំលោកឈ្មោះអ្វី នៅទីឯណាខ្លះ ទៅធូ
ឮដូច្នោះក៏បរសេះចេញមកខាងមុខហើយស្រែកថា ខ្លួនយើងនេះហើយ
ជាពាហានខ្លាឈ្មោះទៅធូ អ្នកឯងនឹងចង់ធ្វើយើងយ៉ាងម៉េច ម៉ាំឈៀ
ក្រឡេកឃើញរូបទៅធូបែបគ្រុនងងឹតអាច គួរឲ្យញាញើតខ្លាចមែន ក៏
មិនបានតបថាប្រការម្តង ពាញសេះត្រឡប់ចូលចន្លោះ ។

(នៅមានត)

លោក ភ័ក្ត្រ-ប៊ុត ប្រែរៀបរៀង

(តមក)

៣- រឿងជាក់ទិព្វ

គេបាននិទានថា: តាំងតែពីអតីតកាលមក មានកុមារតូចម្នាក់ប្រកបដោយប្រាជ្ញាដ៏មោះមុត នាមថា: "ម៉ាលៀង" ។ កុមារនេះពេញចិត្តខាងគូរគំនូរហើយមានបំណងចង់ធ្វើជាជាងវិចិត្រសិល្បៈខាងគំនូរពណ៌ ។ បិតាមាតាខ្លួនមរណភាពតាំងពីកុមារនេះនៅជាទារក ។ ការកាប់ទុនធ្វើការកាត់ស្មៅយកទៅលក់ធ្វើឲ្យកុមារនោះរស់ពនមានជីវិតបាន តែមានសភាពក្រីក្រលំបាកពន់ពេកហើយពុំអាចរកប្រាក់មកទិញជក់បានសោះ ។

មានឧ ថ្ងៃ ម៉ាលៀង បានដើរទៅមុខសាលារៀនមួយ ស្រាប់តែឃើញលោកគ្រូម្នាក់បានយកជក់គូរទិដ្ឋភាពដោយពណ៌ស្រស់ឆ្អៅ ។ ជក់នោះបានប្រព្រឹត្តពុះឡើងលើផ្ទាំងសំពត់ ធ្វើឲ្យម៉ាលៀងពេញចិត្តពន់ពេកពាល់តែត្រាំពុំបានក៏ចូលទៅជិតលោកគ្រូហើយពោលពាក្យថា:

"លោកគ្រូ ខ្ញុំចង់រៀនខាងវិជ្ជាវិចិត្រសិល្បៈគំនូរពណ៌! សូមលោកគ្រូមេត្តាឲ្យជក់មកខ្ញុំបន្តិច" ។

លោកគ្រូក្រឡេកសំឡក់ដោយខឹងយោរយៅឥតប្រមាណ ហើយក៏ស្ពោះទឹកមាត់ដាក់មុខមាំលៀងរួចគោលថា :

នែអាប្រម៉ក់! ឯងក្រលំបាកគោកយ៉ាកយ៉ាងនេះ ឯងចង់រៀនវិជ្ជាគ្រូសិល្ប៍:គំនូរពណ៌? ឯងប្រហែលជាយល់សប្តិទេដឹង? រួចលោកគ្រូក៏ដេញក្មេងនោះចេញពីទីនោះទៅ ។

មាំលៀងមានចំណង់ពេកក៏គោលថា: "ម្តេចកិរ្តិ៍ឮភ្នែ! ក្មេងគួចរៀនវិជ្ជាគ្រូសិល្ប៍:គំនូរពណ៌មិនបានទេឬ?យើងចាំមើលទៅថ្ងៃក្រោយ!" ។

តាំងពីថ្ងៃនោះមក មាំលៀង ក៏ព្យាយាមរៀនវិជ្ជាដោយមានចំណង់ចង់ធ្វើជាជាងវិជ្ជាគ្រូសិល្ប៍:គំនូរពណ៌ថ្ងៃណាមួយឲ្យបាន ។ នៅពេលដែលវាទៅរើសទុសនៅតុំ វាយកមែកឈើគូសវាសលើដី ខ្លះរូបបក្សាបក្សីហើរឡើងអាកាស ។ នៅពេលដែលទៅគាត់ស្មៅតាមមាត់ស្ទឹង វាយកចង្កឹលដែលវាជ្រលក់ទឹកយកមកគូសនឹងថ្មខ្លះមួយ ដែលវាឃើញហែលក្នុងទឹកជ្រៅ ។ នៅជញ្ជាំងក្នុងរូងភ្នំដែលជាលំនៅរបស់វា ។ ព្យាយាមគូរវាសខ្លួនរូប ខ្លួនត្រឿងប្រដាប់ដណ្តាំជាយូរថ្ងៃមកហើយ ។ ជញ្ជាំងជាំងបួនសុទ្ធតែមានគំនូរគ្រប់បែបយ៉ាង ។

លុះជាច្រើនឆ្នាំតមក មាំលៀងក៏បានព្យាយាមគូរវាសរាល់ថ្ងៃជានិច្ចរាល់មែនពិត មាំលៀង ក៏បានចម្រើនខាងវិជ្ជានេះជាអនេកប្រការ ។ ក៏គូរបក្សាបក្សី មច្ឆជាតិយ៉ាងល្អរស់រវើកដូចជាបក្សាពិតប្រាកដ មច្ឆាជេះ

ហៅលក្ខណៈគេទៅតាមធម្មជាតិពិតៗ ។ តែម៉ាលៀងមិនមានដក់សម្រាប់គូរទេ ហើយក៏ចង់ចាន់ដក់នោះមួយ តែមិនដឹងជានឹងធ្វើយ៉ាងណាឲ្យបាន។

គេលសាយល្ហាសម៉ាយមួយ ម៉ាលៀង ខ្ចីលុយគេដំណែក ក្រោយដែលបានព្យាយាមសិក្សាវិជ្ជាគំនូរជាយ៉ាងម៉ាមួនគេញមួយថ្ងៃ ។ ដល់វាលក់ស៊ុប ស្រាប់តែនិម្មិតឃើញតាចាស់ម្នាក់ មានភ្នែកចង្អាសឈរតែមុខ ហើយឲ្យដក់មួយមកវា ។ តាចាស់នោះពោលថា: « នេះជាដក់ទិព្វមួយ ឯងយកទៅប្រើតាមសេចក្តីប្រាថ្នាចុះ » ។

ម៉ាលៀងបានពិនិត្យមើលដក់ទិព្វនោះ គឺជាដក់មានដងលាបមាសភ្លឺចាំងហើយធ្ងន់ផង ។

ម៉ាលៀង មានចិត្តសោមនស្សឥតឧបមា ហើយស្រែកថា « ដក់ទិព្វនេះល្អណាស់ ខ្ញុំសូមអរគុណលោកតាហើយ . . . » ។

ម៉ាលៀង និយាយមិនទាន់ផុតពីមាត់ ស្រាប់តែតាចាស់នោះបាត់ពីទីនោះទៅ ។ ម៉ាលៀងនឹកងឿងឆ្ងល់ពន់ពេក . . . ក្បាក់ខ្លួនឡើងខ្លាចជាន់ថាខ្លួនយល់សប្តិ . . . តែម៉ាលៀងកាន់ដក់ទិព្វទីនឹងដៃ ហើយនឹកកាន់តែឆ្ងល់ ។ ឡើង ។

ម៉ាលៀង បានយកដក់ទិព្វនោះគូរជាបក្សាមួយ ។ បក្សានោះស្រាប់តែខះស្លាបហើរទៅលើនគរយ៉ាហើយយំយ៉ាងពិរោះអស្ចារ្យ ។ ដល់ក្រោយទៀត ម៉ាលៀងគូរត្រីមួយ ។ ស្រាប់តែត្រីនោះបក់កន្ទុយហែលទឹក

ទៅតាមស្តីនឹងធ្វើជាវេន់មួលច្រើនលើក-ច្រើន ។ ម៉ាលៀង ឃើញដូច្នោះ ត្រេកអរពន់ប្រមាណ ។

ម៉ាលៀង ចាន់យកដក់ពិព្វនោះ គួរជាប្រយោជន៍ដល់ពួកកសិករដែលក្រខ្សត់នៅក្នុងភូមិ ។ អ្នកណាគ្មានខន្លឹល ម៉ាលៀងគួរខន្លឹលឲ្យ ។ អ្នកណាគ្មានចបចូក វាគួរចបចូកឲ្យ ។ អ្នកណាគ្មានចង្អឹងវាគួរចង្អឹងឲ្យ ។ អ្នកណាគ្មានចាំងជង់ខ្ចីក វាគួរចាំងឲ្យ ។

រឿងដក់ពិព្វចាន់យកលេចឮខ្ចីដល់កុដុម្ពីក៍ម្ចាស់ទៅពីនោះ ។ កុដុម្ពីក៍ចាត់ឲ្យទាសាតាមនាក់ទៅចាប់ម៉ាលៀង ដល់ចាប់ម៉ាលៀងយកមកដល់គេហដ្ឋាន កុដុម្ពីក៍ឲ្យម៉ាលៀងគួរគំនូរផ្សេង ។ ។ ម៉ាលៀងពិតមែនតែខ្លួនទៅក្នុង តែមានគំនិតចាស់ ។ ម៉ាលៀងស្គាល់ជាក់ច្បាស់នូវចិត្តលោកនៃកុដុម្ពីក៍នេះហើយ បើខុតណាជាកុដុម្ពីក៍សន្យាថាឲ្យកោតទ្រព្យច្រើន ក៏មិនត្រមគួរសោះឡើយ សូម្បីតែកុដុម្ពីក៍កំហែងគំរាមយ៉ាំងណាក៏ដោយ ក៏នៅតែស្ងៀមត្រងើយមិនត្រមគួរអ្វីតាល់តែសោះ ។ ឃើញអាការដ៏ថ្នឹងដូច្នោះ កុដុម្ពីក៍ចាន់ចាប់ម៉ាលៀងទៅឃុំទាំងនៅក្នុងក្រោលសេះហើយហាមប្រាមមិនឲ្យអ្នកណាយកម្ហូបអាហារទៅឲ្យបរិភោគ ។

ដល់បីថ្ងៃក្រោយមក ក្នុងពេលរាត្រី មានព្រឹលធ្លាក់ត្រជាក់ខ្លាំង កុដុម្ពីក៍គិតក្នុងចិត្តថា: ប្រហែលជាម៉ាលៀង បើមិនស្លាប់ដោយអត់អាហារ គង់អនិច្ចកម្មដោយរងាខ្លាំងមិនខាន អញចង់ដឹងតើយ៉ាំងណាទៅ ។

លុះទៅដល់ជិតក្រោលសេះ កុដុម្ពីក៍ឃើញស្មៅក្រហមភ្លឺចាំង តាមប្រទេះភ្នែរ មានកូនឈ្មួយឆ្ងាញ់ចេញសាយតាក្រោលសេះ ។ លោកបានឈ្នឹងភ្នែកមើលតាមប្រទេះភ្នែរ បានឃើញមាំលៀងកំពុងបរិភោគនំក្តៅ ។ អង្គុយជិតដើងក្រានមានឆ្មើកក្តៅក្រហមផ្ទៅ ។ កុដុម្ពីក៍នឹកឆ្ងល់ថា តើដើងក្រាននេះអ្នកណាយកមកដាក់ក្នុងទីនេះ តើនំបង់ឆ្ងាញ់នេះបានមកពីណា លោកបានយល់ដាក់ឮស្តាប់ថានំនេះប្រហែលជាបានមកពីដក់ទិញខោះទេដឹង ! កុដុម្ពីក៍មានចិត្តខ្មេមខ្សប់ខ្លាំង ក៏បង្អាប់ឲ្យពួកទាសាជណ្តើមយកដក់ទិញពីមាំលៀងហើយប្រហារជីវិតក្មេងនេះចង់ ។

ពួកទាសាកុដុម្ពីក៍ជាង ១០ នាក់ បានចូលទៅកន្លែងក្រោលសេះ តែមាំលៀងគេចបាត់ពីទីខោះទៅ ដោយឆ្លៅលើដញ្ជាំងក្រោលសេះទៅត្រៃដែលមានដណ្តើរវែងដាក់ទៅលើកំផែងស្រាប់ ។ កុដុម្ពីក៍ស្ទុះឡើងទៅលើដណ្តើរវែង ទើបទន្ទឹងជាន់បានពីបើកាំស្រាប់តែភ្លាក់មកដីវិញ ហើយសំឡឹងមើលដណ្តើរស្រាប់តែចាត់មិនដឹងជាទៅឯណា ។

លុះតែចេញពីគេហដ្ឋានកុដុម្ពីក៍ការណា មាំលៀងសម្រេចចិត្តថាត្រូវតចាកចេញពីភូមិនេះ ទៅកាន់ភូមិដទៃ ។ មាំលៀងដឹងស្រាប់ថាបើពួនលាក់ខ្លួនទៅកន្លែងណាមួយក៏បាន តែកុដុម្ពីក៍នេះនឹងអាចកេខ្ចួនឃើញបានដោយងាយ ហើយរឿងនេះទឹងនាំឲ្យមានភ័យន្តរាយដល់អ្នកដែលឲ្យទីលំនៅជ្រកពួនខោះមិនខាន ។ មាំលៀងមានការចាំពាះអ្នកភូមិ

នោះថា « ខ្ញុំសូមលាចង់ប្អូនហើយ » ។ រួចម៉ាំលៀងបានយកដក់ខ្ចីតួរវែសជាសេះមួយមានលំអអស្ចារ្យ រួចកំឡើងជិះលើសេះនោះបំផាយទៅកន្លែងធំ ។

ម៉ាំលៀងមិនទាន់បានធ្វើដំណើរឆ្ងាយប៉ុន្មាន ស្រាប់តែមានមនុស្សអ្នកអោសេតញ៉ាងតាមពីក្រោយ ។ ដល់ក្រឡេកមើលក្រោយ ម៉ាំលៀងស្រាប់តែឃើញកុដុម្ពីក៍ជិះសេះកាន់ដាវ មានទាំងតួកទាសាជាង ២០ នាក់តាមពីក្រោយផង ។ នៅពេលយប់ មានក្លើងចន្ទ្រសាច់ងពន្លឺ ឃើញច្បាស់ទូវទេសភាពផ្សេង ។ ។

ដល់ឃើញថាកុដុម្ពីក៍តាមជិតទាន់ខ្លួន ម៉ាំលៀងគ្មានតក់ស្លុតអ្វីសោះឡើយ ហើយយកដក់ខ្ចីតួរជាព្រួញទឹងធ្នូ ។ ម៉ាំលៀងយកធ្នូងាកបាញ់មកក្រោយ ព្រួញនោះត្រូវចំដើមកនៃកុដុម្ពីក៍ជ្រាក់ពីលើខ្នងសេះដល់ដី ។ ម៉ាំលៀងយកខ្សែតីវាយសេះដាយយ៉ាងលឿន ឥតឈប់ឈរ រួចមកឈប់ត្រង់កូមួយគួច ដោយយល់ឃើញថាអ្នកដែលជិះសេះតាមនោះស្ថិតនៅឆ្ងាយជាច់ស្រយាល ។ ដោយយល់ឃើញថាខ្លួនគ្មានការអ្វីធ្វើ ម៉ាំលៀងគិតចង្អឹមជីវិតដោយវិជ្ជាគួរវែស ។ ដល់គួរបានជារូបភាពហើយ ម៉ាំលៀងយកគំនូរនោះទៅលក់តាមផ្លូវ តែដោយមិនចង់ឲ្យគេស្គាល់ខ្លួនបាន កំធ្វើរូបនោះកុំឲ្យគេម្រើកបាន ។ ដើម្បីទឹងសម្រេចទូវគោលបំណងនេះ ម៉ាំ-លៀងគួរបែសតូ ប្តូរបក្សាដោយគ្មានដំពុស ឬគ្មានជើង ។

(នៅមានត)

ទំនៀមទម្លាប់ នៃទេមរដាតិ
ខ្មែរគួរឱ្យឃ្លាត សិក្សាពេញទី ។
ព្រោះទេមរដាតិ ជាជាតិសោភី
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប.ព

រឿងទាក់ជីរី

ជាដំបូង សូមដាក់បថា ដំរីមាន ២ ប្រភេទ គឺដំរីកន្ធឹងដំរីខោម ឬដំរីត្រែង ។ ឯការចាក់ដំរីក៏មាន ២ ប្រភេទដែរ ។

ដំរីកន្ធឹមានកាយធំ កាលខ្ចស់ជាងខ្លួន ដែលគេតែងជួបប្រទះនៅកន្លែងព្រៃដែលមានភ្នំច្រើន ដូចជាកំពត កំពង់ស្ពឺ តោធិសាត់ ។ល។ ពួកដំរីម្យ៉ាងទៀត ដែលមានរូបកាយតូចល្មម ហើយកាលនឹងជង្គង់ខ្លួនមានកំពស់ស្មើគ្នា ហៅថាដំរីខោមឬដំរីត្រែង ។ គេច្រើនប្រទះឃើញនៅក្នុងព្រៃកំពង់ឆ្នាំង កំពង់ធំ សៀមរាប ខ្ទឹងតាមមាត់ទន្លេសាបជាដើម ។

តាមធម្មតា គេមិនសូវចាក់ដំរីធំទេ គេច្រើនចាក់ដំរីតូច ។ ល្មមជាយនឹងផ្ទាំងប្រើបាន ។ ឯដំរីដែលគេត្រូវចាក់ហៅថាជ្រុកស ។ ពួកហ្មង់ដែលត្រូវការចេញទៅចាក់ដំរី ត្រូវធ្វើពាក្យសុំអនុញ្ញាតចាក់ពីហ្លួងយកព្រៃ ដោយមានបង់ពន្ធផង ។ លុះបានអនុញ្ញាតដែលពេលការ

មានសមត្ថកិច្ចចេញឲ្យនោះ មានជាក់ឈ្មោះអ្នកសុំទាក់ ចំនួនដំរីសុំទាក់ នឹងកំណត់ពេល ៣ ខែ គិតពីថ្ងៃចេញប្បាប់អនុញ្ញាតនោះ ថែមទាំងមានបំពាមមិនឲ្យសម្លាប់ដំរីផង លើកលែងតែដំរីណារំលោភលើអ្នកទាក់ហួសកម្លាំងនឹងការពារពុំឈ្នះ ។ ហើយប្រសិនបើជាមានការសម្លាប់ដំរី ត្រូវនាំយកកូនចឹងប្រគល់ដើងទៅប្តឹងដល់ពេជការដែលនៅជិតជាងគេ ។

គេលក្រឡប់មកពីទាក់វិញ ហ្នឹត្រូវនាំយកដំរីដែលទាក់បានទៅដូនពេជការឲ្យកាត់តម្លៃលក់ ហើយពេជការត្រូវហូតភាគខ្លះ ជាប្រយោជន៍ចរិកជាតិ ទើបចេញសំបុត្រសំគាល់កិនភាគដំរីឲ្យម្ចាស់កាន់ ។

របៀបទាក់ជំរឹក

ចំពោះរបៀបនេះ ហ្នឹងមចេញទៅទាក់នៅរដូវក្រាំង គឺពីខែមាឃទៅខែពិសាខ ។ មុននឹងចេញទៅទាក់ ពួកហ្មបបួលគ្នាឲ្យបានច្រើន គឺពី ១០ នាក់ឡើងទៅ ។ លុះបានសំបុត្រអនុញ្ញាតស្រេច គេត្រូវរៀបចំសម្ភារៈអាហារ មានអង្ករ ត្រីងៀត ត្រីឆ្អើរប្រហុក អំបិល ក៉ាប៉ិត ចានឆ្នាំង (ឆ្នាំងដីមិនយកខ្វាចបែក) ហើយដាក់ត្រណមឲ្យប្រពន្ធកាន់រៀង ២ខ ។ ប្រពន្ធហ្នឹងឡាយដែលប្តីចេញទៅទាក់ដំរី ត្រូវតែមមិនឲ្យមានសហាយ មិនឲ្យលួតកកាយចាយនឹងដៃចេញពីឆ្នាំង មិនឲ្យគងវែកលើមាត់ឆ្នាំង សឹតសក់កាត់សក់យប់ គោះចាក់កំទេចហិបស្វាចោល លេង

ចាក់ចង្កេះគ្នា ប្តូគក់គ្នាក៏មិនបាន ។ ល ។ តែមិនកាន់ត្រណមចាំងនេះ
មុខជាប្តីនឹងមានគ្រោះថ្នាក់ដល់ស្លាប់ផងក៏មាន ។

រួចហើយ ទើបហ្មរៀបចំគ្រឿងភាក់-ចាប់ ដូចជាត្រីត្រ[1] ប្រកាំ
កង្វែរ ពូថៅ ក្រវិលសម្រាប់ក់យកដែង ស្មៃងដើងរង ដងកញ្ចាម[2]
។ ល ។ ផ្កុកលើខ្នងភ្ជាក់ជាមួយនឹងគ្រឿងចរកោត ប៉ុន្តែបេះចាំងនេះ
ផ្កុកលើខ្នងភ្ជាក់តែតាំកាលធ្វើដំណើរទៅទេ តែដល់ព្រៃ គេទំលាក់មក
ព្រយុងពីក្រោមគោះភ្ជាក់វិញ ព្រោះកុំឲ្យខ្ទើសខែងទៅពេលចូលព្រៃ
ទឹងទៅពេលដួបហ្វូងដំរីព្រៃ ។ ហ្មងឹងតង្វាលរើសរកថ្ងៃល្អឈ្នះសត្រូវ
ខ្មោចបីសាចទើបហ៊ានចេញទៅ ។ ទៅតំបន់ខ្លះ អ្នកភាក់ដំរីធ្វើពិធីសែន
ព្រេនដល់ម្រេញតង្វាល ទឹងអ្នកតាបង់បត់សុំបើកព្រៃ ទឹងសុំឲ្យចេញ
ទៅមានដំរីដងផងដែរ ។ របៀបសែនម្រេញតង្វាលមានប្រាសាទ ១ បំពង់
ទឹក ១គូ កន្ទោង ១ ស្មៃងផ្តុំ ១ កង្វែរ ១ ពន ៣ ថ្នាក់ ប្រមូ ៨ ពជវតៃ
ដុំវិញពន មួ ៥ ស្វា ៥ ចារី ៥ បង្អែមធ្វេង-ស្ពាំ ទឹងសំពត់សក្រហម ។
លុះរៀបចំសព្វគ្រប់ហើយ ទើបគេនាំគ្នាចេញដំណើរទៅ ។ ដំរីភ្ជាក់ខ្លះ
មានស្នាមហើម ២-៣ អន្ទៅ ដែលពួកហ្មងយកថ្មកទឹងកន ឲ្យហើមសាច់

១- ធ្នើអំពីស្បែកគោ ឬ ក្របីចាស់ ដើម្បីឲ្យងាយប្រើបានដល់ក្ងន ដល់ជើងកំមាន ។

២- ជាឧបករណ៍អមត្រាំត្រសម្រាប់ឈូកទាក់ធើងដំរីព្រៃ ។ ជាឧបករណ៍នេះ គេប្រើនប្រើតែ
នៅទំរាំល តែដំរីរត់ចូលព្រៃ គេមិនប្រើទេ ព្រោះនាំទ្រើសទ្រែងណាស់ ។

ខុសជាមុន សម្រាប់ដល់ពេលដេញប្រយុទ្ធនឹងដំរីព្រៃ ក៏ឃើញស្នាមហ៊ាមស្រាប់នេះ ទើបធ្លាក់ឈឺរត់លៀនខាន់ការ ។ នៅលើខ្នងធ្លាក់ខ្ទមួយៗ មានហ្នាមក់ពាមស្ទាល កាន់ប្រកាំចាំតែពាក់ កិច្ចការម្ល៉ូដនៃស្រែចលើគង្វាលដែលដំរនៅចន្លោះពាំងអស់ ។

កាលណាឈប់ពាក់ គង្វាលត្រូវមើលរៀបចំព្រ័ត្រប្រកាំទំងន្រឿនពាក់ចាប់ពាំងឲ្យឃ ធ្វើដូច្នេះ ឬគួបកំពស់ប្រមាណជា ៣ ឬ ៤ ម៉ែត្រ ពីដើម្បីដាក់ន្រឿនពាំងនោះ ខ្ពាចក្រែងឆ្កែត្របែង ។ គួបនោះត្រូវធ្វើទៅក្រៅភូមិចម្ងាយប្រហែលជា១០០ឬ១៥០ ម៉ែត្រ ។ គួបនេះ បើស្រុកមានផ្លែពោះដើរកាត់មុខ ទំងមានអន្តរាយដល់ការកក្ខដ្ឋផ្លែ ។

អំពីការពាក់ដំរីនេះ មិនមែនចូលព្រៃភ្លាមពាក់ឲ្យនភ្លាមទេ ដូនកាលដើរ ដប់-ប្រាំថ្ងៃ មិនខាន់ប្រុះហ្នងដំរីមួយផង ។

នៅពេលចូលព្រៃ ហ្មមានអណាចធំជាងគង្វាល ។ គង្វាលត្រូវរៀបចំដំណេកហ្ន ការងអង្គុតនៅពុំរើង ហើយខ្លួនឯងត្រូវដេកនៅចុងជើងហ្នង ។ គង្វាលត្រូវគោរពហ្មយ៉ាងព្រៃលែង សូម្បីតែចាប់ចានសត្វ ដូចជាអណ្តើក ខន្យង គង្វាលមិនហ៊ានអាស្រ័យឲ្យងទេ ត្រូវដួនទៅហ្មតាំងអស់ ខ្លួនអាស្រ័យឲ្យនតែសាច់ ។ នៅពេលដេកលក់ បើមានការណ៍អ្វី ហ្មមិនយកដៃគេះហៅគង្វាលទេ ត្រែងដំរីស្ទាវព្រៃតដៃនឹងធ្លាក់ ត្រូវយកដើងឈូសងាស់ ។ ឯដំរីធ្លាក់ គោះជាឈ្មោលមានភ្លុក ក្តី ស្តុក្តី ឬមេក្តី កំអាចយកធ្វើជាធ្លាក់តាំងអស់ឲ្យនឥតឲ្យសទេ ។ គេល

ដូចខ្ញុំកក្នុងដំរៃ ហ្នឹមមហ៊ានដុសក្អែលទឹងដំរៃ ប្តូរដុសក្អែលតួតទឹងក្រមា
ទេ ទាំងក្រែងដំរៃ ចោសគង្វាលខម្ងាក់តែលើខ្នងឆ្កាក់ ។

តួកហ្នាំគ្នារៃស្តាប់សម្រែកដំរីតែមដងអូរ ទឹងប្រកក្នុងដែលមាន
ទឹក ក្រែងមានហ្វូងដំរីចុះផឹកទឹក ។ តែកាលណាគេដឹងថា មានដំរីនៅ
ទីណាហើយ គេកំប្រញាប់ដណ្តើមបាយបរិភោគឲ្យហើយស្រេច ព្រោះ
គិតថាមុខជាជាប់ដៃប្រយុទ្ធជាមិនខាន ហើយសម្រួតអាវ៉ាន់មកជាក់ក្រោម
តោះឆ្កាក់តែញ រួចបរសំដៅទៅរកហ្វូងដំរីព្រៃ ។

ដល់ប្រទះទឹងហ្វូងដំរីព្រៃ ហ្នឹងាំងឡាយក៏បរឆ្កាក់ចូលសម្រុកទៅ
កណ្តឹហ្វូងដែលមានដំរីតែ ៤០ ទៅ ៦០ ហើយស្រែកសន្ធាប់បង្កើលកង
រំពង ។ គេលោះ ដំរីព្រៃភ័យស្លន់ស្លៅបែកខ្ញែកគ្នាប្រុសចប្រសាច ។
លុះឃើញតុងាសល្អហើយ ទើបពួកហ្នាំចុះព្រ័ត្រទៅទាក់កូនដំរីណាដែល
ខ្ជូនស្រឡាញ់តែរៀងខ្លួន (តួចគោកខ្លាចស្លាប់ ធំគោកក្រែងការគោរពុំឈ្នះ
គឺយកតែល្មម) ។ តែកាលណាព្រ័ត្រប្រកាំទាក់ជាប់ដើងកូនដំរីហើយ
គង្វាលលើកព្រ័ត្រទាំងចង្ហាយចោះទៅដី ហើយលោតខ្ជូនឯងចុះទៅតាម
ដើម្បីទៅចាប់យកកន្ទុយព្រ័ត្រព័ទ្ធចងនឹងគល់ឈើ ។ ពុងព្រ័ត្រនេះ អ្នក
ខ្លះមានចងស្នែងដើងរង ឬក្រងារធ្វើអំពីស្នែងក្របីគេលក្លើងតន់ឲ្យខុចក្តក់
គេមិនយកដែកឬឈើធ្វើខ្លាចបាក់ ។ តែកាលណាជាប់ចាកស ។
អូសព្រ័ត្រទៅ ឲ្យស្នែងនេះប្តក់ជាប់នឹងគល់ឈើ កុំឲ្យទៅបានឡាយ ។

ពេលនោះពួកស្តេចព្រៃ ក៏មិនមែនបណ្តោយឲ្យគេចាប់កូនចៅវាតាមអំពើចិត្តទេ រួចតាំងើលមួយភ្លែត ក៏ត្រឡប់មកតដៃនឹងឆ្នាក់ ដើម្បីដណ្តើមយកដំរីពីប្រកាំវិញ ។ ខណៈនោះ ហ្នាគ់ឡើងលើខ្នងឆ្នាក់ចាប់ជាវិនឹងតូចៅតដៃនឹងដំរីព្រៃ គង្វាលគិតតែពយចាក់ឆ្នាក់ឲ្យគ្រាន់ដេញដំរីព្រៃគាល់តែចាក់បបគ្រាន់ព្រាយទៅ ។ ពេលដែលចាកសជាប់ប្រកាំហើយគ្រាន់ ហ្នាគចសំគាល់បានថា ចាកសនោះ មានកម្លាំងប៉ុន្មាន ។ តែកាលណាជាប់ប្រកាំហើយ ចាកសនោះគ្រាន់តែគាល់តែដួលដេក ហ្នាគប្រញាប់លក់ចោល បើទុកទៅមុខជាស្វាប់ខាតប្រយោជន៍ ។ ម្យ៉ាងទៀត ដំរីដែលខើបនឹងឆាក់បាននោះ បើពួកហ្នាឈ្លោះប្រកែកគ្នាតើរឿងចៃដន្យមិនស្មើនោះ គេត្រូវលក់ចោលដែរ សុះចិត្តឲ្យខាតខ្លះ តែទុកទៅដំរីនោះអាយុខ្លី ។

តាមទម្លាប់ ហ្នុងឹងគង្វាលដែលធ្វើការរួមគ្នា ត្រូវខាក់ឲ្យបានចាកសពីគឺ ចាកសមួយចំណែកហ្ន ចាកសមួយចំណែកម្ចាស់ឆ្នាក់ ចាកសមួយទៀតចំណែកគង្វាល ។

ឯការថែរក្សាកូនចាកសស្រេចទៅលើគង្វាល ។ មួយថ្ងៃ គង្វាលដឹះឆ្នាក់ទៅផែបមើលទម្លឹងតិចិដង ផែបនាំចាកសទៅឲ្យផឹកទឹក ទៅលាងទឹក ។ ម្យ៉ាងទៀត ការនាំចាកសពីព្រៃទៅស្រុកជាការលំបាកព្រៃលែង ព្រោះថា ធម្មតាសត្វព្រៃមិនមែនចង់ចូលទៅទៅស្រុក ឲ្យមនុស្សធ្វើចាប់ត្រប់ពេលវេលាទេ ណាមួយពព្រាត់ហ្វូង ព្រាត់មេចង់ប្តូន

ដែលភ្ជាប់សប្បាយជាមួយគ្នាផង ។

កាលមកដល់ស្រុកភូមិហើយ ហ្នឹកដាក់ត្រណមពីប្រពន្ធចេញ រួចបង្គាប់ឲ្យគង្វាលរកឈើណាធ្វើជាអង្ក្រ ឬ សន្ទុះសម្រាប់ផ្សាំឆក្រស ។ រកបានហើយ គង្វាលយកឆ្កាសទៅចងត្រយុង ចង្អុតស្មៅ ៣ ៤ ថ្ងៃ ឲ្យហៅកុំឲ្យក្ងានគេក ជាហេតុទាំឲ្យងាយផ្សាំង ហើយគង្វាលបង្ហាក់ទៅអែបបង្ហាត់ចន្ទិចម្ខាង។ ពាល់តែមនុស្សព្រាល់បានឥតផ្តើល ។ ក្រោយពីនោះ មានការបង្ហាត់ឲ្យចេះស្តាប់ការសាទ្រមាក់ដូចជាថា ៖

ហាវ៎ = ឈប់

ជុន។ = ថយ

ជូន។ = លើកដើងមុខ

ត្រម = ក្រាប

ជាក់ = លុតជង្គង់ក្រោយ

ដៃ = ហាមមិនឲ្យចុចភេច

កាន់ = ចាប់ កាច់ ឬ ដក ។ ល ។

លុះឆ្កាសចេះស្តាប់ចង្គាប់លែងផ្តើលហើយ ទើបហ្នឹកបំរៀបចំធ្វើពិធី "ចាប់ដើង" ឲ្យឈ្មោះដំរីនោះ ។

តាមសេចក្តីឲ្យការរបស់លោក ឡង-អ៊ួច អតីតមេឃុំ។ អង្គាញ់ស្រុកត្រែកប្បាស (តាកែវ) ដែលភ្ជាប់ជានយើញគាត់ធ្វើពិធីនេះនៅដំបន់

រថស់លោកប្រមាណជា ៥០ ឆ្នាំមកហើយនោះ ថាមានធ្លុះប្រហែល ៤ ថ្ងាយ សង្ឃាដក់ជាប់ក្នុងកន្ទេង ៤ ស្វាធម៌ ៤ ស្វាក ៤ មានសរសេរឈ្មោះសត្វតាមម្ចាស់ស្រឡាញ់ ហើយដឹកសត្វនោះមកចញ្ចរនៅស្បែកខ្នែងពិធី ។ ហ្នាតាំងចាប់អុជខ្នែង-ធូបបួងសួងអធិដ្ឋានឡើងថា ៖

<< ឧតេជៈ! ថ្ងៃនេះជាថ្ងៃជាតេលាល្អ ព្រះភូមិភរ ព្រះធរណី អ្នកតាចាស់ស្រុកម្រេញគង្វាល ដែលរក្សាខ័ណ្ឌដី បឹង បួ ខួលខ័ន្ធនេះ ឥឡូវនេះ ខ្ញុំត្រូវការឲ្យឈ្មោះសត្វដំរីនេះ បើឈ្មោះណាដែលសុខចំរើនដល់ម្ចាស់ទ្រព្យ សូមឲ្យសត្វនេះ ដើរជាន់ស្មាកឈ្មោះនោះមុនគេទៅ>> ។

លុះបួងសួងគ្រប់ ៣ ដងហើយ ទើបដឹកដំរីដើរប្រទក្សិណកន្ទេងពិធី ៣ ជុំ ។ បើដំរីនោះ ជាន់ទៅលើស្មាកឈ្មោះណា ក៏ហៅដំរីតាមឈ្មោះនោះទៅ មានឈ្មោះ អារជ្រៃ អាស្ត អាកន្ធង់ មេក្រពុំជាដើម ហើយគេនាំគ្នាស៊ុធឹកសប្បាយទៅ ។ បើអ្នកណាទៅកន្ទេងនោះហើយមិនព្រមខួលចំរើកោតចំណីអាហារជាមួយនឹងគេ តែដល់ក្រោយមក ដំរីគេឈឺ គេថាមកពីអ្នកនោះមិនព្រមខួលអំណរគេ ។ នេះជាទំនៀមកន្ធង់ទុកាសពិធីជាក់ឈ្មោះឲ្យដំរី ។

ចំណែកទៅខាងខ្សែត្រពោធិសត្វវិញ ពិធីនេះធំជ្រហែលនឹងរៀបអាពាហ៍ពិពាហ៍មួយដែរ ប៉ុន្តែគេច្រើនហៅថា "សែនផ្តាំចំត្រៃ" ឲ្យឈ្មោះដំរីនោះវិញ ហើយការឲ្យឈ្មោះខ្លះ មិនមែនធ្វើផ្សងតាមកន្ទេង

ឬស្វាកទេ គឺស្រែចម្ការលើការស្រេឡាញ់របស់ប្រពន្ធហ្ន ។ ឯរបៀប
សំណែនក៏ងុសគ្នាដែរ ។ របៀបទាន់ខែត្រពោធិសាត់ មានថ្មយ៉ាស៊ុ
ប៉ាក់នាម តែរួត ស្វាធម៌ ១ គូ ខៀន ៩ ធួប ៥ ជម បង្ហែមចំអាបតួធ្វើង
ស្ពាំ សំពត់ថ្នត់ មាន់ស្វោ ឧដ្ឋស្រោ ១ ដប ព្រមទាំងមានធ្វើពិធីជ្រោះ
ត្រំទឹកមន្តអ្វីបប់ចង្រៃបាកសផង ។

របៀបទាក់ជំរីរនាម ឬ ជំរីត្រែង

តាមសេចក្តីឲ្យការរបស់លោក មាស-ម៉ាំ កាលដែលលោកនៅ
ធ្វើជាចាងត្បាត់ស្រុកកំពង់ស្វាយ ខែត្រកំពង់ធំនៅឡើយថា ការទាក់ជំរី
នោមឬជំរីត្រែង ច្រើនធ្វើនៅរដូវស្លា ពិសេសគឺនៅពេលដែលត្រៃ
នោមលិចទឹកអស់ ហើយហ្វូងជំរីត្រែវនាំគ្នាឆ្លងទៅកៃត្រៃដ៏ទួលដែល
មិនលិចទឹក ។ នៅរដូវសម្រក ជំរីនោមត្រូវត្រឡប់ចុះពីត្រៃដ៏ទួលទៅ
ស៊ីស្មៅខ្ចីនៅមាត់ទន្លេសាប ប៉ុន្តែ អ្នកស្រុកមិនហ៊ានទាក់កង់រដូវនេះទេ
ខ្លាចវាឆ្លើសជាន់បង្កេណាំផ្សេង ។ ។ គេត្រូវរង់ចាំរដូវស្លា កាលណា
ត្រៃនោមលិចទឹកអស់ ទើបគេចាប់ ។

ការទាក់ជំរីនោម ក៏មានការសុំឫទ្ធិដូចជាដំរីកុំដែរ ប្លែកតែការចាប់
ទាក់ប៉ុណ្ណោះ ។ ការទាក់ជំរីនោមគ្មានត្រណមតឹងរឹងដូចជាការទាក់ដំរីកុំ
ទេ មានត្រណមតែមួយមុខថា បើទាក់បានហើយ ។ មានការឈ្លោះ
ប្រកែកគ្នារវាងអ្នកទាក់ ជំរីនោះនឹងអាយុខ្ចីតែប៉ុណ្ណោះ ។

ក្នុងពេលចាក់ដំរី មនុស្សផ្តើលៅស្ងាត់ស្រុកភូមិ សូម្បីអ្នកដែលមិនចាក់ក៏ៅមើលលេងនឹងគេដែរ ព្រោះជាការកំសាន្តមួយ ប៉ុន្តែ បើមនុស្សមានធម៌សប្បុរស ត្រូវប្រាប់ជាមុនការសង្វែគណាស់ៅវិញ ។

ដំរីរាមច្រើនដើរដោយហ្វូង ។ មានចំនួនពី ១០០ ៅ ២០០ តាមហ្វូងធំ-តូច ។ អ្នកស្រុកចាត់គ្នាឲ្យយាមល្បាត តាមផ្លូវដែលវាធ្លាប់ដើរ។ បើកាលណាឃើញដំរីឡើង គេនាំគ្នាគោះត្រដោកដុតគប់ភ្លើងបង្កើលឲ្យវារត់ចុះៅក្រោមវិញ ។ លុះដល់ចំកណ្តើងបង្កុំប៉ោយ គេបបួលគ្នា ១០០ ឬ ១៥០ នាក់ លបយកខ្លួកជាច្រើនផ្លុំកស្បៃអាហារព្រ័ត្រប្រកាំ ហើយអុំៅចតចង់លាក់ស្ងាត់ផ្លូវដំរី បណ្តាក់គ្នាប្រហែលជា ២០ នាក់ពីកន្លែងមួយៅកន្លែងមួយ ចាប់ពីចំកពាក់ៅចំកក្រៅ ។ អ្នកដែលកៀងដេញពីចំកពាក់ៅដល់កន្លែងខ្លួកចត កំនាំគ្នាឡើងខ្លួកស្រែកសន្ធាប់កន្ទឹរពង ។ ឯហ្វូងដំរីកំយកខ្លាំង កំស្រែកពេញតែកន្លងចំក អ្នកអុំអ្នកចែវទំស្រួតប្រកិតអ្នកពាក់ចោរព្រ័ត្រប្រកាំពាក់យកដំរីណាដំនើ ។ ហើយមានក្តុយព្រ័ត្រកំតំពង់ស្ងាប់ៅដើមឈើណាជិតជាងគេ ហើយខុតឲ្យវាប្រមាញប្រពន់តាមចិត្តវាចុះ ។ អ្នកពាក់ឃ្លានកំឈប់រកបាយចំកៅ អ្នកមិនពាន់ឃ្លានកំដេញតៅទៀត ព្រោះគេដឹងថាដំរីកាន់តែដ្រលៅចំកក្រៅហើយ ។ នៅពេលប្រយុទ្ធពាក់គោះ កាលបើអ្នកពាក់ដេញសង្កត់ញាំងខ្លាំងគេក ដំរីធំ ។ មានវាកមកតវៃ ហើយបុកខ្លួកតទ្ទិច មនុស្សហែលព្រាតគ្រាងកំ

មានដែរ ។ អ្នកខាក់ក៏មិនក សុះតែចតែមួយភ្លែត រួចវិលចូលមកចាក់កាប់ជាញឹកញាប់ឲ្យខាងតែឈ្នះ ។

ដំរីដែលខាក់បាន តែងឲ្យនៅកន្លែងនោះរវាង ៣-៤ ថ្ងៃ ដោយចាត់គ្នាឲ្យយាមផង ។ ក្រោយពីនោះមក តែងយកដំរីស្រុកទៅអបនាំមកផ្សាផងដែរ ។ របៀបក្រៅពីនេះ ធ្វើដូចដំរីកុំពង់អស់ ។

ការខាក់ដំរីនោមមួយលើក ។ បានពី ១០ ទៅ ២០ ដំរីក៏មាន ថែមពាំងមានស្លាប់ខ្លះនៅពេលប្រយុទ្ធផង ។

អំពីហ្មូថាវ

ពួកហ្មូថាវប្រហែលទំនងពួកបាតូដែរ គឺបើមានហ្មូថាវធំស្លាប់ ត្រូវសែងយកកូនប្រុសរបស់ហ្មូនោះឲ្យធ្វើជាដំណតទៅខ្មៅ តោះជាកូននោះនៅក្មេងសេចក្តីពុំទាន់ដឹងការអ្វីក៏ដោយ តែត្រូវឲ្យកូននោះរៀនរបៀបហ្មូដើម្បីតំណាងត្រកូលខ្លួនតទៅ ពុំមែនសែងយកពូជហ្មូជាខ្មៅខ្មៅតេ ។ នៅក្រោមបង្គាប់ហ្មូថាវ មានហ្មូស្នងស្តាំ-ឆ្វេងពីរនាក់ ។ ហ្មូរងពីរនាក់នេះ មិនចាំបាច់សែតតាំងពីតូចនៅកូនប្រុសតេ ហ្មូណាចេះដឹងជ្រៅជ្រះអំពីកិច្ចការហ្មូថាវ តែអាចតាំងជាហ្មូស្តាំ ឬហ្មូឆ្វេងបាន ។

នៅក្នុងខ្មែត្រតោងតែលាត់ ហ្មូថាវជាត្រូវជាមេ លើហ្មូទ្រមាក់គ្នាល្ងាចាំងឡាយដែលនៅក្រោមអំណាចហ្មូថាវនេះ ។ ពួកនេះ តែងលៃខ្មែមាយតែងនាំគ្នាធ្វើពិធីឡើងព្រះគាំបិតស្តាំ ដែលជាវត្ថុសក្តិសិទ្ធិដែលហ្មូថាវថែ

រក្សា ដូចពួកសិស្សអារក្ស ឬមេមត់ធ្វើពិធីឡើងកេងលៀងគ្រូដូច្នោះដែរ ។

លុះដល់ដូវឡើងព្រះគ្រូកាំបិតស្តាំ ហ្មងស្តាំ - ធ្មេង ធ្វើសំបុត្រ កំណត់ថ្ងៃ-វែ ទីឯពេលវេលាប្រជុំប្រាប់ទៅគ្រប់ហ្មៃ ទ្រមាក់ តង្វាលដែលនៅក្រោមអំណាចខ្លួនតាំងប៉ុន្មាន ឲ្យចូលមករួមនៅពេលប្រជុំឡើងព្រះគ្រូកាំបិតស្តាំ ត្រមាំងឲ្យនាំគ្នាក់ទីធ្វើបាកស ព្រ័ត្រប្រកាំទៅផង ដើម្បីធ្វើពិការតាមចំនៀមដូចកាលឆ្នាំរៀងមក ហើយរៀបសង់កេងពិធីមួយនៅជិតអាស្រមដាក់ព្រះគ្រូកាំបិតស្តាំនោះ ។

នៅថ្ងៃចូលកេងបុណ្យ ពួកហ្មៃ ទ្រមាក់ តង្វាល បាកស ឆ្នាក់ទីងបរាហ្មមកជួបជុំតាំងអស់ ។ នៅពេលរសៀល គេនាំគ្នាដង្ហែព្រះគ្រូកាំបិតស្តាំចេញពីអាស្រមប្រទក្សិណ ៣ ជុំ ហើយទើបនាំទៅដាក់កន្លែងកេងលើអាសនៈមួយដ៏វិចិត្រ ដែលគេបានរៀបគ្រឿងសក្ការបូជាឲ្យគ្រប់ ។ តាមចំនៀមទម្លាប់ ដូចជាជមចារ ស្មាធមិ ចាយសិ ធ្មេង-ស្តាំ សំពត់ ហួលព្រៃ ខ្នុំ ចំណី ផ្លែឈើ ចេក អំពៅ មានតាំងតែរួត កន្ធោងចាយ កន្ធោងញាំក្អា រណ្តាប់ដូចគ្នាទីធ្វើការព្រះពិស្ណុការ ឬក្រុងពាសីដែរ ។ ឯហ្មងថាវត្រូវស្មៀកពាក់ស ។ យប់មានពួកជន្ត្រីប្រគំកំដរបុណ្យពាល់ត្រឹក។

ត្រឹកឡើង ហ្មងធ្មេង-ស្តាំ ក៏រៀបពីការបួងសួង សូត្រមន្តប្រោះព្រំព្រះគាំបិតស្តាំរម្ងាប់ចង្រៃ ចប់ហើយទើបហ្មងថាវធ្វើពិធីហូតព្រះគាំបិតចេញពីស្រោម ដើម្បីទីធ្វើចំនាយកេងស្រុក តាមចំណាំជាយូរអង្វែង

ណាស់មកហើយនោះ ។ ហ្នឹងថាវៀបចំស្រាយស្រោមសំពត់ រួចស្រោមព្រៃ រួចស្រោមជាតិ រួចស្រោមកម្ម ។ ដូនកាលគេឃើញមានគ្រាប់-ស្រូវ-អង្ករ-សណ្តែក-ល្អ ឬពងស្រមោចនៅក្នុងស្រោមនោះ ។ ទើបហួតព្រះកាំបិតចេញពីបំពង់ស្រោម ហ្នឹងថាត្រូវគាន់ព្រះកាំបិតសំយុងចុងចុះក្រោម មុខឈមមកមុខហ្នឹងថាវ ហួតចេញផុតមកហើយ ក៏ជាក់ទៅក្នុងទឹកផ្តិលមួយទៅកៃវែនោះ ហើយទាំគ្នាពិនិត្យមើលរូបពងព្រះកាំបិតនោះខៀត ។ គេសន្និដ្ឋានតាំងពីពេលហួតថា ដូនកាលធ្លា ដូនកាលតើងដូនកាលមុខព្រះកាំបិតមានព្រៃ មានស្ទេះរេចរែប ឬឃើញស្នាមដូចជាមានប្រឡាក់ឈាមយូរមកហើយ ដូនកាលឃើញក្តីហាក់ដូចជាគេខើបនឹងសំលៀងហើយថ្មី ។ រួចទើបហ្នឹងថាវំនាយគេទស្រុក តាមការដែលបានសន្និដ្ឋានឃើញនោះទៅ ។

ក្រោយពីនោះមក ពួកហ្នឹងថាវកំទាំគ្នាសំលៀងដុះខាត់ឲ្យជ្រុះអស់មន្ទិល ហើយលាបប្រេងស្អិតស្អាងឲ្យយ៉ាងស្អាតរៀបរុំខ្ចប់ប្រគុំកុកក្នុងស្រោមដូចដើមវិញ ។

ស្រេចហើយ គេដង្ហែព្រះកាំបិតស្តាំនោះ ចូលទៅដំកល់ក្នុងគាស្រមវិញ មានពាំងភ្លេងដូរៀងជន្ត្រីប្រគំកំដរផង ។

តពីនោះមក មានការលេងចាក់ដំរី ហ្នឹងស្តាំ-ឆ្វេង ចាត់ឲ្យរៀបជាំភ្នាក់ដោយឆ្នាក់ ឆាកសដោយឆាកស នៅចម្ងាយតាំគ្នាប្រហែល ៥០ ម៉ែត្រ ។ ហ្នឹងចាត់ឲ្យទ្រមាក់ដុះឆាកស ឲ្យហ្នឹងតង្វាលជុះឆ្នាក់ មាន

តាំងព្រ័ត្រប្រគាំដូចចេញទៅខាងដំរីមែន ។ ។ ហើយទ្រមាក់ បំបោលចាកសេចក្តីទៅ ឲ្យហ្មូងគង្វាលវាយបំបោលជ្រាក់ដេញតាមក្រោយ ។ គេធ្វើដូច្នេះ ចំនួនជា ៣ ឬ ៤ លើក ជាការកំសាន្ត ពួកអ្នកមើលហោកញ្ជ្រៀវសើចសប្បាយ រួចក៏នាំគ្នាស៊ីផឹកអធឹកអធម ។

តាមសេចក្តីឲ្យការរបស់លោក ឆួង-អ៊ុន អតីតយោគ្បាត់ ខេត្តឃុំលលកស ស្រុកចុកាន ខែត្រពោធិសាត់ កាលឆ្នាំ ១៩៥០ គឺកាលដែលគាត់រស់នៅឡើយ ហើយធ្វើជាសមាជិករបស់ក្រុមដំនុំខ្មែរខ្ញុំនោះ លោកបានសរសេរទុកថា : តាំងពីរវាងឆ្នាំ ១៩០៦ _ ១៩០៧ មក ពួកហ្មាំងឡាយ តុំមានការគោរពហ្មាថាវ ហ្មាស្នងឆ្នេង-ស្តាំខែតឡើយ ព្រោះពួកពូជហ្មានេះ កាន់តែរៀវរោយធុតរលត់អស់ទៅ ខែតែស្រី ។ ហើយតែជល់រដូវ កំគ្រាន់តែរៀបចំបន្ទិចបន្តួចបង្ក្រៀបកិច្ច ។

តមកទៀតថា កុងឆ្នាំ ១៩២៩ មានចោរបានចូលទៅលួចព្រះកាំបិតស្តាំយកចុតទៅ ដែលជាហេតុនាំឲ្យរឿងហ្មាថាវនេះ សាបសូន្យបរណ្តាយតែម្តង ។

សព្វថ្ងៃនេះ រូបហ្មាថាវគឺគ្មាន ហ្មាឆ្នេង-ស្តាំគឺគ្មាន កាលឆ្នាំ ១៩៥០ នៅមានគ្រឹះដំណែលខ្លះរបស់ហ្មាថាវ ដូចជាខ្ទ ស្នែងជ័រ-គួច សម្រាប់ផ្ទុំ នៅផ្ទះក្រុមញាតិហ្មាថាវ នៅឯភូមិចាក់ខ្នារ ឃុំលាជ ស្រុកកុំក្រវាញ ខែត្រពោធិសាត់ គេរក្សាទុក ។ ឥឡូវរបស់ទាំងអស់នេះ មិនដឹងជានៅមានឬចុតបង់អស់ទៅហើយទេ ។

ផ្នែកការងារសំណាក់ដើមប្រវត្តិសាស្ត្រ

សុន្ទរកថាលោករដ្ឋលេខាធិការក្រសួងធម្មការ

សូមទូលសម្តេចតំណាងព្រះអង្គ

ព្រះរាជាគ្មានក្តីព្រះ

ទ្រង់

សូមដំកល់ឯកឧត្តម

លោកដំណាង

ឯកឧត្តមឯកអគ្គរដ្ឋទូត

លោកស្រី

អស់លោក

ក្នុងនាមព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា ដែលមានអង្គសម្តេចព្រះ នរោត្តម-សីហនុ ជាព្រះប្រមុខរដ្ឋ ទើបក្នុងនាមប្រជាជាតិខ្មែរទាំងមូល ព្រមទាំងក្នុងនាមខ្ញុំព្រះករុណាខ្ញុំជារដ្ឋលេខាធិការក្រសួងធម្មការ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះរដ្ឋាភិបាលប្រទេសផ្សេងៗ ដែលមានឯកអគ្គរដ្ឋទូតផ្សេងៗ ប្រចាំប្រទេសកម្ពុជា ជាប្រជាជន ចាប់ផ្តើមពីលោកបណ្ឌិត ជាត់ ជាតិផ្សេងៗ ជាអ្នក

ក្រោដ្ឋភាគបរមត្ថវិជ្ជា ទឹងភាគព្រះពុទ្ធសាសនាឲ្យបានមកធ្វើសន្និសីទនៅ ប្រទេសកម្ពុជានេះ ស្តីពីអានុភាពព្រះពុទ្ធសាសនា ហើយជាពិសេស សូមថ្លែងអំណរគុណចំពោះលោកបណ្ឌិត ជាត់ ដែលបានអញ្ជើញមក ធ្វើសន្និសីទនេះដើម្បីញ៉ាំងចិត្តលោក-អ្នកស្តាប់ឲ្យបានជ្រួតជ្រាប នូវ ព្រះអនុត្តរធម៌របស់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូ រឹងរឹតតែខ្លាំងឡើង ។

អស់លោកអ្នកស្តាប់ទាំងឡាយ មានសេចក្តីអរគុណចំពោះលោក បណ្ឌិតជាអនេក ។

ក្នុងឱកាសដ៏ខ្លីនេះ សូមសម្តែង ព្រះធម្មនុត្តរៈ ទ្រង់ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក អនុញ្ញាតឲ្យខ្ញុំព្រះករុណា ខ្ញុំ ថ្លែង នូវប្រវត្តិរបស់លោកបណ្ឌិត ជាត់ ដោយសង្ខេបដូចតទៅនេះ៖

លោកបណ្ឌិត ជាត់ អាយុ ៧០ ឆ្នាំ មានសញ្ជាប័ត្រជុំគរវៈ ខាងបរ. មត្ថវិជ្ជា ជានរង្វាន់ឈ្មោះថា " អនុស្សាវរីយ៍ត្រហ្វហ្វីត (Griffith) ក្នុង ការស្រាវជ្រាវ " ហើយនឹង ១ ទៀតឈ្មោះ " រង្វាន់ការស្រាវជ្រាវនៃម. ហាវិទ្យាល័យហ្សូយប៊ីលី (Jubilee) ទឹងមេដាយមាស ។

លោកបានបម្រើនៅមហាវិទ្យាល័យ ទីវដែលី ពីឆ្នាំ ១៩២៤ ទៅ ១៩៤៩ ជាទាយកវិទ្យាល័យ រ៉ៃប៉ែស ទឹងធ្វើជាប្រធានសន្និសីទនៅមហា. វិទ្យាល័យអង់គ្លេស ។

លោកបានខិតខំលះបង់ទី ២ របស់ខ្លួនក្នុងការប្រឡងតែងសេចក្តីសាកលលោក ក្រោមការទទួលខុសត្រូវនៃផ្នែកជាលព្រះចៅអធិការជប៉ុន ដោយបានតែងសេចក្តី មានចំនួន ៨.០០០ ពាក្យអំពី "វប្បធម៌ជប៉ុនជាភាសាហ៊ីណ្ឌូ" ហើយបានប្រែជាភាសាជប៉ុន ចោះត្អូតផ្សាយក្នុងសារពត៌មានធំមួយនៅតូក្យូពីឆ្នាំ ១៩៤០ ។

លោកជាអ្នករដ្ឋការពាក់ព័ន្ធខាងកិច្ចការវប្បធម៌ក្នុងស្ថានទូតចិនជាតិនិយមនៅនីវដែលីវ៉ា ១៩៤៨ ដល់ ១៩៥០ លោកបានសិក្សាប្រវត្តិសាស្ត្រចិន ទំនៀព្រះពុទ្ធសាសនានៅប្រទេសចិន ក្នុងសម័យធ្វើការនោះបានសរសេរអំពីសាលាសិក្សា ១០ ខាងព្រះពុទ្ធសាសនានៅប្រទេសចិន បានសរសេរអំពីប្រវត្តិសាស្ត្រ ផ្នែកបរមេត្តាំដ្ឋាខាងជនជាតិបូតាំប្រទេសទីបរស្ថិមប្រទេស ដែលផ្នែកនេះលោកបានខិតខំចោះត្អូតសៀវភៅនោះផ្សាយរួចហើយ ។

លោកបានធ្វើការជាមួយសាស្ត្រាចារ្យ ខូកស៊ី (Tucci) នៅមហាវិទ្យាល័យកេម ទីអ៊ីស្មេ (ISMEO) ចំនួន ៣ ខែ ពីឆ្នាំ ១៩៥៣-១៩៥៤ ។

លោកជាព្រឹទ្ធបុរសនៃសមាជិកអមមហាវិទ្យាល័យខាងការស្រាវជ្រាវ នៅមហាវិទ្យាល័យនីវដែលី តាំងខែមករា ឆ្នាំ ១៩៥៨ ដល់ខែមិថុនា

ឆ្នាំ ១៩៦០ ជាអ្នកចាត់ចែងខាងការិយាល័យ ការសិក្សាព្រះពុទ្ធសាសនា ។

លោកជាអ្នកនិពន្ធសៀវភៅខាងព្រះពុទ្ធសាសនា មានឈ្មោះដូច តទៅនេះ ៖

ក- អំពីប្រវត្តិសាស្ត្រដែលទ្រទ្រង់ព្រះពុទ្ធសាសនា

ខ- អំពីព្រះសម្មាសម្ពុទ្ធ នឹងក្រោយពុទ្ធនិព្វាន ៩០០ ឆ្នាំ

គ- អំពីបព្វជិតពុទ្ធសាសនិក នឹងវត្តនៅប្រទេសឥណ្ឌា ។

ដំណើរដែលលោកបណ្ឌិត ជាត់ ចាន អញ្ជើញមកធ្វើសន្និសីទ ស្តីពីព្រះពុទ្ធសាសនានេះ ជាដំណើរដ៏ប្រកបដោយសុមង្គលក្រៃពេក នាំឲ្យព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា នឹង ប្រជាពលរដ្ឋខ្មែរដែលជាពុទ្ធសាសនិក រលឹកឃើញជាថ្មីនូវប្រវត្តិសាស្ត្រ នឹង ព្រះពុទ្ធសាសនាបន្ថែមទៀត ហើយសង្ឃឹមថា ប្រទេសឥណ្ឌា នឹង ប្រទេសកម្ពុជា ដែលធ្លាប់មានសម្ព័ន្ធភាពខាងសង្ឃសាសនា នឹងខាងវប្បធម៌ចាក់ឬសគល់គ្នាតាំងពីបុរាណរៀងមក ហើយថែមទាំងកងឋបច្ចុប្បន្នកាលនេះ មានន័យបាយអស្ចារ្យក្រៃបរិសុទ្ធដូចគ្នាផង មុខជាពង្រឹងសម្ព័ន្ធភាពនេះ ឲ្យរឹតតែរឹងប៉ឹងម៉ាំមួនចំរើនឡើង ហើយជាតិសាសនាចញ្ចាំងព្រះពុទ្ធសាសនា ជាសាសនាប្រកបដោយព្រះធម៌ជាសន្តិវរៈបំផុត ។ មានអហឹសាជាដើម ដែលនាំឲ្យពិភពលោកបានសន្តិភាព នឹងសេចក្តីសុខចំរើនថ្កើងរុងរឿងផង ។

ជាអាសាន ក្រសួងធម្មការតាងទាមព្រះពរជារ្ជាភិបាលខ្មែរ នឹងពុទ្ធ-
សាសនិកខ្មែរ ក្នុងព្រះពរអាណាចក្រកម្ពុជាទាំងមូល សូមប្រសិទ្ធីពរ
ជូនដល់រ្ជាភិបាលផងណ្តៅ ដល់ឯកឧត្តមឯកអគ្គរដ្ឋទូតផងណ្តៅប្រចាំប្រ-
ទេសកម្ពុជា ដល់ប្រជាជាតិផងណ្តៅទាំងមូល ដល់លោកបណ្ឌិត ជាត់ នឹង
លោកស្រី សូមឱ្យបានប្រកបដោយសេចក្តីសុខចំរើនិ នឹងប្រកបដោយ
សិរីសួស្តីជ័យមង្គលគ្រប់ប្រការ តរៀងទៅកុំបីឃ្លាត ។

សន្និសីទស្តីពីពុទ្ធសាសនានៃបណ្តាំដាត់

ពុទ្ធសាសនាក្នុងអាស៊ីខ្ទីប

សាស្ត្រាចារ្យពុទ្ធសាសនិកមៀន ជាតិជប៉ុនម្នាក់ឈ្មោះ ស៊ុមាត្សុកិ ជានលោយថា៖ រាល់ជួញប្រទេសនីនិយមប្រទេសចាំងឡាយ គេត្រូវតែស្រាវជ្រាវរាវរកនូវសភាពផ្សេងគ្នាក្នុងគំនិតទ្រឹស្តី ដែលបិតនៅក្នុងព្រះពុទ្ធសាសនា ។ ព្រះពុទ្ធសាសនាគឺជាមតិកសាធារណៈរបស់ប្រជាជាតិជាច្រើននៃអាស៊ីខ្ទីប គឺថាព្រះពុទ្ធសាសនាផ្តល់ឲ្យនូវលក្ខណៈនីនិកត្តិយសដ៏ខ្ពង់ខ្ពស់ ចំពោះវប្បធម៌នៃប្រជាជាតិចាំងនេះ ។ ពុទ្ធសាសនាគឺជាអនុភាពដែលធ្វើប្រវត្តិសាស្ត្រ នៃប្រជាជាតិចាំងនេះឲ្យមានសណ្ឋានទ្រង់ទ្រាយក្នុងសម័យដើមបំផុត ។ អាស្រ័យហេតុនេះ គេមិនអាចសិក្សាប្រវត្តិពុទ្ធសាសនា ដាច់ដោយឡែកអំពីការវិវត្តន៍នៃប្រវត្តិសាស្ត្រនៃប្រទេសចាំងនេះឡើយ ។

សព្វថ្ងៃ ប្រវត្តិសាស្ត្រនៃអាស៊ីខ្ទីបបុកណា នៅខ្វះសម្បូណ៌ភាពនីនិសហសម្ពន្ធភាពនៅឡើយ ។ ការសរសេរប្រវត្តិសាស្ត្រអាស៊ីខ្ទីបដែលធ្វើបាំងស្នាដៃនៃពួកអ្នកប្រាជ្ញបស្ចិមប្រទេស បានរួមនៅក្នុងមតិយោបល់របស់ជនជាតិអឺរ៉ុបស្ទើរតែចាំងអស់ ។ តាមធម្មតា អ្នកប្រាជ្ញចាំងនោះ តែងមានយោបល់យល់ឃើញថា ប្រទេសចាំងឡាយក្នុងអាស៊ីខ្ទីប បានលូតលាស់ចំរើនឡើងដោយអាស្រ័យការទាក់ទងនីនីនិងបស្ចិមប្រទេស ដោយ

ភាគច្រើន ឯសម័យប្រវត្តិសាស្ត្របរមបុកណានៃប្រទេសចាំងនេះ គឺជាបរិច្ឆេទ ប្តូរព័ត៌មានយ៉ាងនៃប្រវត្តិសាស្ត្រ គ្មានសេចក្តីសំខាន់ប៉ុន្មាន ហើយដែលលាយឡំទៅដោយទេវកថានឹងរឿងព្រេងប៉ុណ្ណោះ ។ ដោយបស្ចិមប្រទេសចាំងឡាយបានដកចេញនូវអំណាចគ្រប់គ្រងរបស់ខ្លួនអំពីប្រទេសជាច្រើនកន្លងបួនរយឆ្នាំ សព្វថ្ងៃនេះ កែវន្ទុះនៃប្រវត្តិសាស្ត្រក៏បានផ្ទាស់ប្តូរទ្រង់ទ្រាយដែរ ។ ឥឡូវនេះ គេបានឃើញថា សម័យប្រវត្តិសាស្ត្របុកណាដែលអ្នកប្រវត្តិសាស្ត្របស្ចិមទិសបានមើលរំលង ឬថាព្រងើយកន្តើយមិនយកចិត្តទុកដាក់ពិនិត្យមើលផងនោះ គឺជាផ្នែកសំខាន់នៃដំណាប្រវត្តិសាស្ត្រប៉ែសប្រទេសចាំងនេះ ។ ចំពោះប្រជាជាតិជាច្រើន ក្នុងអាស៊ីអគ្នេយ៍ ការនាំផ្សាយចូលមកនៃព្រះពុទ្ធសាសនា គឺជាគោលដើមធំនៃអារ្យធម៌ ។ ទេពកោសល្យជាតិ គឺប្រាជ្ញាដើមកំណើតនៃប្រទេសចាំងនេះ បានបង្ហាញឲ្យដឹងគឺស្នាដៃដ៏ទត្តមបំផុតក្រោមអាទិភាពលើកទឹកចិត្តនៃពុទ្ធសាសនា ។

បើយើងយល់ថាព្រះពុទ្ធសាសនាជា «លទ្ធិនិយម» ជាដំរៀមួយបែប ឬថាជារបបនៃទស្សនវិជ្ជាមួយបែបនោះ ប្រហែលយើងនឹងមានកំហុសជាមូលដ្ឋានមួយ ។ តាមសេចក្តីពិត ពុទ្ធសាសនាមានប្រតិបត្តិការទាំងលទ្ធផលច្រើនលើសលុបជាងនោះទៅទៀត ។ ព្រះសាស្តានៃសាសនានេះ បានទុកនូវនិកាយនៃដំបូន្មានចាំងឡាយ ដែលត្រូវបាន

រៀបរៀងឡើងមានរបៀបបែបផែនជាច្រើនក្នុងសម័យក្រោយមកទៀត ។
ប៉ុន្តែក្នុងពាក្យប្រៀនប្រដៅទាំងនេះ ព្រះអង្គមិនបានបណ្តុះឲ្យជាប់ខ្ជាប់ខ្ជួនតែបណាមួយជាស្ថាពរឡើយ ទ្រង់បានខុតបញ្ជា (គឺសមត្ថភាពពិចារណារកហេតុផល) ឲ្យបុគ្គលគ្រប់ ។ រួចប្រើប្រាស់ដោយសេរី ខ្ជិនដោយមិនមានការភ្ញាំងខ្ជប់ ។ ព្រះអង្គទ្រង់បានឲ្យដំបូន្មានដ៏ខ្ពង់ខ្ពស់ចំពោះសាវ័ករបស់ព្រះអង្គថា "ចូរអ្នកទាំងឡាយជាប្រទីប (ជាដាក់) របស់ខ្លួន ចូរអ្នកទាំងឡាយពឹងខ្លួនឯង ពឹងព្រះធម៌ ចូរកុំពឹងអ្នកដទៃឡើយ" ។ នេះគឺជាព្រះសីហនាទដ៏ខ្ជួរខ្ជាក ដែលហៅរកពិចារណាញាណនិយម ។ ក្នុងសម័យដើមបំផុត ពុទ្ធសាសនាគឺពុំមែនជាលំអានៃលទ្ធិ ឥន្ទ្រិយសន្ទនៈវិជ្ជាទេ ព្រះអភិធម្មបិដក គឺជាធម៌ល្អតណាស់ឡើងក្នុងសម័យក្រោយ ។ តាមសេចក្តីពិត ពុទ្ធសាសនាគឺជាទស្សនៈនៃជីវិត ជារបបមួយនៃវប្បធម៌ជាមាគ៌ាមួយ (សម្រាប់) ប្រតិបត្តិ ។ កាលដែលគេបានទាំពុទ្ធសាសនាអំពីប្រភពនានាចូលមកក្នុងប្រទេសផ្សេង ។ នៃអាស៊ីខ្ជឺបនេះ អានុភាពនៃពុទ្ធសាសនាដែលគ្រប់ដណ្តប់លើប្រជាជាតិទាំងនេះ មិនមែនគ្រាន់តែជាលទ្ធិ ឬសាសនាប៉ុណ្ណោះទេ ពុទ្ធសាសនាបានទាំមកផ្តល់ឲ្យប្រជាជាតិទាំងនេះជាដំបូងបំផុតនូវទស្សនៈថ្មីមួយចំពោះដំរៃលោក នូវរបបថ្មីមួយនៃការឲ្យតម្លៃមនុស្ស នូវចរិយាសាស្ត្រទំនើបរបៀបបែបផែននៃការពិចារណាឲ្យតម្លៃចំពោះចរិយាសាស្ត្រ សីលធម៌ថ្មីមួយទៀត ដែលផ្ទុយគ្នាទំនើបរបប

លទ្ធិអត្តនិយម ឬបរិសាចនិយម ដែលគេប្រកាន់ជឿក្នុងសម័យនោះ ។

ពុទ្ធសាសនាពុំបានប្រឆាំងជាដាច់ខាត ទឹងដំឡើងដើមតាំងនោះទេ ប៉ុន្តែដោយការខ្ជិចប្រើវិចារណញ្ញាណទឹងបញ្ញាញ្ញាណ ពុទ្ធសាសនាបានធ្វើលទ្ធិតាំងនោះឲ្យអស់មានសារៈសំខាន់អ្វីតទៅទៀត ។ ដោយទុបាយបែបនេះ ពុទ្ធសាសនា បានជំរុញទាំប្រជាជាតិតាំងនោះ ឲ្យដើរតាមមាគ៌ាមួយឆ្ពោះទៅកាន់ជ័រភាពទឹងគំនិត ដែលប្រកបដោយអារ្យធម៌ត្រប់គ្រាន់ដោយបានជាស់តឿនក្រើនរំលឹកប្រជាជាតិតាំងនោះ ឲ្យមានសមត្ថភាពវិចារណញ្ញាណ ទឹងទម្លាប់តាងការវិនិច្ឆ័យឲ្យតម្លៃខ្លួនឯង ។ ពុទ្ធសាសនា មានគម្ពីរអក្សរសាស្ត្របរិបូណ៌ ហើយសេចក្តីត្រៃការ (នៃប្រជាជាតិនានា) ដើម្បីរៀនគម្ពីរតាំងនេះ បានតម្រើកនូវអក្សរសិក្សាក្នុងចំណោមប្រជាជាតិសម័យមុនអក្សរសាស្ត្រថែមទៀត ។ មិនតែប៉ុណ្ណោះ ពុទ្ធសាសនា មានឥទ្ធិមាការណសាស្ត្រ មានពិធីគោរពបូជាព្រះពុទ្ធរូប ដែលជាហេតុនាំឲ្យមានការអភិវឌ្ឍន៍តាងបម្លាក់ទឹងសិល្បៈផ្សេងៗទៀតជាច្រើន ។ ទីបំផុត ពុទ្ធសាសនា មានទិដ្ឋភាពតាំងឡាយដែលជាទីគោរពបូជាថែមទៀត គឺវត្តអារាម វិហារ ចេតិយ ដែលជាតួត្រូវការសេចក្តីស្មគ្រ័ងជំនាញតាងផ្នែកស្ថាបនកម្មដើម្បីកសាងស្ថាបនា ។ តាំងនេះ សឲ្យឃើញថាមូលដ្ឋានៃអារ្យធម៌បស់ប្រជាជាតិតាំងនេះ បានកើតមានឡើងជាស្ថាពរដោយសាការនាំចូលមកនូវព្រះពុទ្ធសាសនា ។

ខ្ញុំមិនចាប់ពោលអំពីប្រវត្តិសាស្ត្រពុទ្ធសាសនានៅភូមិភាគផ្សេងៗទេ ដាច់ដែលមិនចាប់អធិប្បាយឲ្យវែងឆ្ងាយអំពីអតីតកាល ដែលពុទ្ធសាសនាបានមកចម្រើនសាសកម្មភាព ក្នុងប្រវត្តិសាស្ត្រនៃប្រជាជាតិនានាក្នុងអាស៊ីខ្ញុំបាទនេះឡើយ ។ ប៉ុន្តែ គឺជាការពិតណាស់ថា: កាលណាគេសរសេរសៀវភៅប្រវត្តិសាស្ត្រអាស៊ីខ្ញុំបាទសម័យបុរាណ កាលនោះ ភាគច្រើននៃវិជ្ជាទិន្នន័យក្នុងសៀវភៅនោះ ទំនងត្រូវពោលអំពីការទាំងចូល ទំនងការផ្សាយពុទ្ធសាសនាលើផ្ទៃអាស៊ីផ្នែកអគ្នេយ៍ ទំនងដំណើរការណ៍ទាក់ទងវប្បធម៌ដែលចំរើនឡើងតាមលំអានពុទ្ធសាសនា ។ ការពិនិត្យស្រាវជ្រាវខាងប្រវត្តិសាស្ត្រ ទំនងខាងស្ថាបនកម្មក្នុងប្រទេសនានា គឺជាការចាំបាច់ជាទីបំផុត ដើម្បីបំពេញហើយបញ្ចប់នូវវិជ្ជាទិន្នប្រវត្តិសាស្ត្រនោះ។ ។

ប៉ុន្តែ កិច្ចដែលមានសារៈសំខាន់ជាងវត្ថុផ្ទាក់ផែក ដែលគេតាស់កកាយឡើងក្នុង សំខាន់ជាងឯកសារដែលគេអាចរកឃើញនោះទៅទៀត គឺការៈកិច្ចដែលចង្អុលបង្ហាញឬបំភ្លឺឲ្យឃើញច្បាស់នូវពុទ្ធសាសនា ដែលបានរៀបចំតំបន់ក្នុងជីវភាពប្រជាជាតិ ទំនងវប្បធម៌នៃប្រទេសទាំងមួយៗ ។ ក្នុងប្រទេសទាំងឡាយនៃអាស៊ីភាគអគ្នេយ៍ គឺ ប្រទេសភូមា ថៃ ទំនងកម្ពុជា ដែលត្រូវរៀបបញ្ចូលទាំងប្រទេសសីរីលង្កាផងនោះ ព្រះពុទ្ធសាសនា ជាសាសនារស់រើក ដែលត្រូវទទួលស្គាល់ក្នុងដួងមនុស្សហើយដែលរដ្ឋការគ្រប់គ្រងផង ។ ប៉ុន្តែ ប្រទេសដទៃទៀត ដែល

លែងប្រតិបត្តិតាមពុទ្ធសាសនា ហើយលែងខ្លួលពុទ្ធសាសនាថាជា
សាសនាសម្រាប់ផ្នែកខ្លួន ហើយសូម្បីក្នុងអតីតកាលព្រះពុទ្ធសាសនាជា
សាសនាសម្រាប់ផ្នែបស់ប្រទេសជាតិនោះក៏ដោយ ។ ប្រទេសឥណ្ឌា
ដែលជាស្រុកកំណើតនៃពុទ្ធសាសនា គឺជាទេវហារណ៍មួយឲ្យាស់លាស់
ជាងគេក្នុងរឿងនេះ ។ ប៉ុន្តែ បើអស់លោកយល់ថា ពុទ្ធសាសនាបាន
រលត់អស់រលើងអំពីប្រទេសឥណ្ឌាដូច្នេះ នោះនឹងជាកំហុសមួយចំនោះ
ខ្លួនលោក ។ សិល្បៈនឹងអារ្យធម៌ ខេត្តនៃជ្ញានឹងអាកប្បកិរិយាចំនោះ
ជីវភាព ព្រមទាំងទំដួកាតដ៏ច្រើននៃវប្បធម៌នឹងច្បាប់ដើមសំកប់ជាតិរបស់
ប្រទេសនេះ បានបង្ហាញឲ្យឃើញឲ្យាស់ថា ពុទ្ធសាសនាជាហ៊ាមតល
មួយតុំពាន់លេត់លោយចេញពីប្រទេសឥណ្ឌានៅឡើយទេ ។ ពុទ្ធសា-
សនាបានរលត់ចេញពីផ្ទៃមុខញាមែន ប៉ុន្តែ នៅរស់រើកក្នុងវប្បធម៌
សង្គមធម៌នៃប្រទេសឥណ្ឌាជាបជល់សព្វថ្ងៃនេះ ។ សភាពកំពាំងនៃ
ពលភាពរបស់ពុទ្ធសាសនាក្នុងឥណ្ឌាសព្វថ្ងៃ បានត្រូវបង្ហាញជាក័ស្ដុ-
តាង់ឲ្យាស់លាស់ដោយសេចក្តីពិតថា ប្រជាជនឥណ្ឌាសព្វថ្ងៃនៅតែមាន
គំនិតទំស្ងែរកការណែនាំបណ្តុះប្រាជ្ញា អំពីនិមិត្តរូបសាសនាច្រើនបែប
យ៉ាង នឹងអតីតែជាក់បែកតិបុកណាកាល ដែលបិតនៅ..តំកយពាសតេញ
ប្រទេសជាង់មួល ហើយដែលបង្ហាញនូវរូបភាពនៃអតីតកាលដ៏រុងរឿង
អស្ចារ្យ នៃព្រះពុទ្ធសាសនាក្នុងប្រទេសនេះអស់រយៈកាល ១៧ សតវត្ស

គឺតាំងពីសតវត្សទី ៥ មុនគ្រិស្តសកពជ ដល់សតវត្សទី ១២ ក្រោយគ្រិស្តសកពជ ។ សាសនាហិណ្ឌូដែលបានឈរជំនួសពុទ្ធសាសនាក្នុងប្រទេសឥណ្ឌា អស់ជាង ៨ សតវត្សទៅហើយនោះ បានរួមបញ្ចូលលាយឡំគ្នានូវគោតន្រ្តច្រើននៃពុទ្ធសាសនា ទំនៀមទម្លាប់ហិណ្ឌូសាសនាបានតាំងលើកដំកល់ព្រះពុទ្ធជាម្ចាស់ក្នុងឋានៈជាទេវតាមួយ នៃទេវតាណៈរបស់ខ្លួន គឺកាប់ព្រះអង្គថាជា អវតារ(១) នៃព្រះវិស្ណុ ។ ហើយក្នុងតម្រាហិណ្ឌូបុរាណៈ យើងបានឃើញគេចាត់ទុកតំណែងមួយ ក្នុងប្រភេទតំណែងថាជាតំណែងសក្តិសិទ្ធិសំរាប់តែទេវបូជាព្រះពុទ្ធរូបផង ។ ព្រះពុទ្ធជាម្ចាស់ គឺជាទេវតាមួយក្នុងចំណោមទេវតាតាំងឡាយនៃហិណ្ឌូសាសនា បើទុកជាក្នុងប្រទេសឥណ្ឌាសព្វថ្ងៃ គេពុំប្រតិបត្តិឲ្យខ្ជាប់ខ្ជួនតាមព្រះពុទ្ធវចនៈនោះទាំងស្រុង ។

កាលណែលប្រទេសអង់គ្លេសដកអំណាចខ្លួនចេញពីឥណ្ឌា ហើយប្រទេសឥណ្ឌាបានឯករាជ្យឡើងនោះ សកម្មភាពដំបូងបំផុតនៃការប្រកាសខ្លួនឯងរបស់ប្រទេសឯណ្ឌា គឺការអនុម័តយកកងិ៏ចក្រដែលមហាពលាធិបតីពុទ្ធសាសនិកនៃអាស៊ីក្នុងសតវត្សទី ៣ មុនគ្រិស្តសកពជ (គឺ

១— នេះជាយោបល់នៃអ្នកប្រទេសឥណ្ឌា ដែលជឿតាមសាសនាព្រាហ្មណ៍ តាមការណ៍ពិត ព្រះពុទ្ធមិនមែនជាអវតារពីព្រះវិស្ណុទេ ព្រោះពួកណូវ៉ាតជាតិជាដើមនោះទេ ព្រះអង្គគឺជាមនុស្សពិត ។ នៃលបរិនិព្វានបានមានវ័យ ៨០ អស់ ៤ អសង្ខ្យៃ និង ១ សែនកប្ប ទើបបានត្រាស់ជាព្រះពុទ្ធសំរាប់ប្រោសសត្វលោក ។

ព្រះបាទអសោក) បានដាក់ជាឱមិត្តរូបនៃព្រះពជាណាចក្ររបស់ព្រះអង្គ នោះ មកធ្វើជាសញ្ញាខ្លាំជាតិរបស់ប្រទេសឥណ្ឌា ហើយយកបូបសីហៈដែលគេឆ្លាក់ជាក់លើបុងសសរស្ពឹមព្រះបាទអសោកមកធ្វើជាសញ្ញាពិសេសរបស់ជាតិ ។ នេះគឺជាការផ្តុះចេញជាផ្លែផ្កាកងវិញ្ញាណស្មើជាដំបូងបំផុតនៃឯកភាពក្នុងខណៈដែលប្រទេសឥណ្ឌាមានសមត្ថភាព ប្រកាសដោយខ្លួនឯងបានឡើងវិញ ទ្វាធម្មជាតិដែលបិតនៅលាក់កំបាំងអស់កាលយូរក្នុងជីវភាពនឹងវប្បធម៌របស់ខ្លួន ។ ដោយអាស្រ័យហេតុនេះ ប្រទេសឥណ្ឌាមានចិត្តគំនិតនឹងចំទៀមទន្ទាប់មិនឆ្ងាយអំពីអស់លោក-អ្នក ទឹងប្រជាជាតិដទៃឯទៀតក្នុងអាស៊ីភាគអគ្នេយ៍ ដែលបានរក្សាទុកនូវពន្ធីនៃពុទ្ធសាសនាឱ្យក្លាំងកចន៍ដកបមកដល់សព្វថ្ងៃនេះប៉ុន្មានទេ ។

(ខ្ញុំសង្ឃឹមថា) ការចាក់ចងគ្នាខាងផ្នែកវប្បធម៌ នឹងការយោគយល់គ្នាខាងចិត្តគំនិត រវាងប្រទេសឥណ្ឌា នឹងប្រទេសពុទ្ធសាសនិកដទៃនេះ ប្រហែលជានឹងជីកនាំយើងទៅកាន់អនាគតមួយ ប្រកបដោយលទ្ធផលល្អដែលយើងពុំអាចបង្ហាញរូបជាមុន ប្រយើញពុកជាមុនក្នុងសម័យសព្វថ្ងៃនេះ ។ ប៉ុន្តែ ទោះបីលទ្ធផលបែបណាក៏ដោយដែលនឹងមានមកនោះ លទ្ធផលនោះ ប្រាកដជានឹងតម្រូវឱ្យមានការខិតខាងចិត្តគំនិតនៃសកលលោកដោយឥតមានសង្ស័យឡើង ។

ក្នុងរវាងពីរសតវត្សកន្លងទៅហើយ ដែលប្រទេសឥណ្ឌាបានស្ថិត

នៅក្រោមអំណាចត្រួតត្រានៃប្រទេសអង់គ្លេសនោះ ការពាក់ព័ន្ធគ្នាខាងផ្នែកវប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីផ្សេងៗ រវាងប្រទេសឥណ្ឌា និងប្រទេសជាតិក្នុងអាស៊ីខ្លួប ជានិច្ចកាលមានតិចតួចណាស់ ។ យើងបានដឹងដំណឹងដែលនិយាយអំពីប្រទេសផ្សេង ។ ក្នុងអាស៊ីខ្លួប ដោយសារតែការសែត ដែលគេបញ្ជូនត្រឡប់មកវិញ (អំពីប្រទេសអង់គ្លេស) ហើយដំណឹងពាក់ព័ន្ធនឹងហេតុការណ៍នយោបាយប៉ុណ្ណោះ ។ យើង (ជាតិឥណ្ឌា) មិនត្រឹមតែល្ងង់ខ្លៅក្នុងរឿងសម្ពន្ធភាពច្រើនបែបច្រើនយ៉ាងខាងផ្នែកវប្បធម៌និងសាសនា ជាមួយប្រទេសជាច្រើនឡាយដែលបានៅក្រៅត្រើយច្រកល់ដែនយើងប៉ុណ្ណោះទេ ថែមទាំងត្រូវគេអប់រំហ្វឹកហាត់ការចាត់ចែងឲ្យយើង ក្រឡេកទៅតែខាងលិចមួយចំងប៉ុណ្ណោះ ដើម្បីស្វែងរកឧបាជនកម្ម នឹងមគ្គុទ្ទេសក៍ ។ ព្រោះហេតុនោះ ត្រើយដែនទៃនចិត្តគំនិតរបស់យើង ជានិច្ចត្រូវគេតំណែលមាឲ្យបានតែតាមតែក្នុងប្រទេសឥណ្ឌា និងក្នុងវប្បធម៌ និងការសិក្សាបែបអឺរ៉ុបតែប៉ុណ្ណោះ ។ អ្នកច្បាស់ជាតិអង់គ្លេសចាំងឡាយដែលបានផ្តល់ចំពោះយើង ខ្លួប្រវត្តិសាស្ត្រប្រទេសយើង តែងតែបានចាប់ផ្តើមសរសេរឡើងដោយសេចក្តីពណ៌នាយ៉ាងវែងអំពីការរៀបកប្រទេសឥណ្ឌា ឲ្យនៅតែឯកឯងផុតស្រឡះអំពីប្រទេសឯទៀត ។ ក្នុងអាស៊ីខ្លួប ដោយជាក់ច្បាស់ជាងដោយជួរភ្នំហិមាល័យពីខាងជើង ហើយសមុទ្រនិងមហាសាគរ ពីខាងទិសដៅទៃនៃប្រទេសនេះ ។

យើងបានដឹងថា អង្គបុគ្គលទាំងនេះហើយដែលខ្ជួលខ្ញុំសត្រូវកន្លងការធ្វើឲ្យឯកភាពនៃអារ្យធម៌របស់យើង ទំនៀមទំលាប់នៃការគ្រងីកវប្បធម៌របស់យើង ឲ្យឃ្លាតចេញឆ្ងាយអំពីប្រទេសជាច្រើន ទៀតនៃអាស៊ីទ្វីប ។ យើងត្រូវគេលួងលោមបំភ្លេចឲ្យភ្លឿថា ប្រទេសឥណ្ឌៀស្ថិតនៅដោយឯកឯងជាច់អំពីអាស៊ីទ្វីប ហើយជាប្រទេសអាស៊ីគ្រាន់តែកន្លងបូកធំ ទំនឹកមិសាស្ត្រប៉ុណ្ណោះ ។

ជាក់សមាល្អណាស់ ឥឡូវនេះ ជំនឿទំនៀមទំលាប់ថែបនេះ បានត្រូវអន្តរាគមន៍ចេញអស់លើងហើយ ។ ការស្រាវជ្រាវរបស់អ្នកប្រាជ្ញទំនើងអ្នកប្រវត្តិសាស្ត្រថ្មីៗ បានបញ្ជាក់ឲ្យយើងយល់ច្បាស់ថា: គឺមានតែកន្លងសម្ព័ន្ធភាពពីបុរាណកាលជាមួយប្រទេសជាច្រើន ។ កន្លងអាស៊ីទ្វីបទេ ដែលប្រទេសឥណ្ឌៀបានរកឃើញនូវទ្រព្យសម្បត្តិរបស់ខ្លួន ។ អ្នកប្រាជ្ញទំនើងអ្នកភូមិវិជ្ជាជាតិបានតាស់ដឹងរកឃើញនូវអ្វីដែលគេបានឲ្យឈ្មោះថា "ឥណ្ឌៀខាងក្រៅ" ក្នុងផែនទីអាស៊ីទ្វីប គឺភូមិភាគដែលអាទិភាពឥណ្ឌៀបានច្នៃខ្លួនឲ្យរីងប៉ុងអស់រយៈកាលប្រើនសតវត្ស ហើយបានរកឃើញនូវសម្បុរណ៍ភាពក្នុងការលូតលាស់ជាផ្លែផ្កាខ្លើង នៃស្នាដៃសិល្បៈទំនឹងវប្បធម៌ របស់ជាតិទាំងនោះ រំហាងធំ ។ ទំនឹងព្រះពុទ្ធរូបទាំងឡាយ ដូចខ្ញុំបានឃើញនៅពុទ្ធធានីចាស់របស់លោកអ្នកកន្លងទៅត្រូវសៀមកបនោះ គឺជាឯតទគ្គកម្មយ៉ាងធំសម្បើម (ដែលបញ្ជាក់ឲ្យឃើញច្បាស់)

ខ្លួនការរួមបួលគ្នាយ៉ាងរីកចម្រើនមិនឈប់ឈរ ដែលជាហេតុនាំឲ្យមានការ
ផ្លាស់ប្តូរវប្បធម៌ជាច្រើនក្នុងសង្គមខ្មែរ ដែលមានការប្រែប្រួលទាំងល្អទាំងអាក្រក់
ដែលជាការពិតណាស់ ការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យ
ភាសាផងដែរ ដែលភាសាខ្មែរយើងមានការប្រែប្រួលច្រើនណាស់ ដែលការប្រែ
ប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់ ដែលការ
ប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលមានការរួមបញ្ចូលគ្នានូវភាសាបរទេស
ដែលមានភាពសមស្របទៅនឹងភាសាខ្មែរ ដែលមិនធ្វើឲ្យភាសាខ្មែរយើងបាត់បង់
នូវអត្តសញ្ញាណរបស់ខ្លួនឯង ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅ
ក្នុងវិស័យអក្ខរាវិរុទ្ធ ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និង
ការប្រែប្រួលដែលអាក្រក់ ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែល
ធ្វើឲ្យភាសាខ្មែរយើងមានភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួល
ដែលអាក្រក់នោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញ
ក្នុងការប្រើប្រាស់ ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យ
ឃ្លាដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែល
អាក្រក់ ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរ
យើងមានភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់
នោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការ
ប្រើប្រាស់ ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យប្រយោគ
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យអត្ថន័យ ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យសំឡេង ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យសរសេរ ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យនិយាយ ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យអាន ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យស្តាប់ ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យមើល ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យសរសេរ ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យនិយាយ ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យអាន ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យស្តាប់ ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់
ដែលការប្រែប្រួលនេះមានទាំងការប្រែប្រួលនៅក្នុងវិស័យមើល ដែលការ
ប្រែប្រួលនេះមានទាំងការប្រែប្រួលដែលល្អ និងការប្រែប្រួលដែលអាក្រក់
ដែលការប្រែប្រួលដែលល្អនោះគឺជាការប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមាន
ភាពងាយស្រួលក្នុងការប្រើប្រាស់ ដែលការប្រែប្រួលដែលអាក្រក់នោះគឺជាការ
ប្រែប្រួលដែលធ្វើឲ្យភាសាខ្មែរយើងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់

គឺជាអាថិកំបាំងដែលតថាគតនឹងយល់ ។ ក្នុងអាស៊ីទ្វីបបូកណា ព្រះពុទ្ធ
សាសនាជាអាទុកាតសំរាប់ប្រជារួមមួយ ។ ក្នុងកាលដែលពុទ្ធសាសនា
ផ្សាយចេញទៅបន្តិច ។ ម្ល៉ងលើទ្វីបនេះ ប្រហែលជាមនុស្សជាតិផ្សេង
ដែលប្រើភាសាផ្សេង ។ គ្នា មានចិត្តគំនិតនឹងការចាប់អារម្មណ៍ផ្សេង ។ គ្នា
មានការពិសោធខាងប្រវត្តិសាស្ត្រផ្សេងគ្នាច្រើន ដែលចែកចេញជាច់ពីគ្នា
ដោយហេតុកេរគ្រប់យ៉ាង ដែលជាគ្រឿងបែងចែកប្រជាជាតិមួយ អំពី
ប្រជាជាតិមួយទៀត- (ប្រជាជាតិទាំងនេះ) បានចូលរួមជាតិជាមួយគ្នា
ក្រោមការទទួលតម្កើងនៃពុទ្ធសាសនា ពុទ្ធសាសនាបានផ្តល់ឱ្យប្រជាជាតិនី-
មួយ ។ នូវតំរូវតម្រាប់ដែលសមរម្យល្អទៅតាមទេពកោសល្យរបស់ខ្លួន ធ្វើ
ប្រជាជាតិនោះ ។ ឲ្យមានសណ្ឋានជាបែបផែន ដែលគ្រោងទុកដើម្បីបំ.
ពេញនូវសេចក្តីត្រូវការផ្នែកខាងចិត្តគំនិត ហើយតាមសេចក្តីពិត គឺបាន
ណែនាំប្រជាជាតិនោះ ឲ្យប្រកបដោយសម្បុរាប្លែក ។ គ្នាមួយបែប ដែល
សព្វថ្ងៃនេះយើងតែងនិយាយថា "ពុទ្ធសាសនាឥណ្ឌា" "ពុទ្ធសាស-
នាលង្កាទ្វីប" ពុទ្ធសាសនាចិន" "ពុទ្ធសាសនាជប៉ុន" "ពុទ្ធសាស-
នាខ្មែរ" ជាដើម ។ នៅពេលជាមួយគ្នានេះ យើងបានដឹងឮតាមប្រ
វត្តិសាស្ត្រពុទ្ធសាសនា អំពីចលនាសកម្មភាពនៃសមណៈខូតចាំងឡាយ
ពីប្រទេសមួយទៅប្រទេសមួយទៀត- ដូចពីឥណ្ឌាទៅប្រទេសទីបេត៍ ពី
ប្រទេសលង្កាទ្វីបទៅប្រទេសកូមា ថៃ (កម្ពុជា) ពីប្រទេសចិនទៅប្រទេស

ក្បូរដាដើម (សមណៈខ្មែរតាំងនោះ) ទំរ្រឹងទ្រែងព្យាយាមដើម្បីដឹកនាំប្រទេសតាំងអស់នោះឲ្យចូលរួមក្នុងសម្ព័ន្ធសាសនាដូចគ្នា បើទុកជាមានរនាំងរាំងកខាងផ្លូវកាយ សេចក្តីលំបាកខាងភាសាទំនងរវៀចគួរសមគ្នាតាមលទ្ធិផ្សេងៗ យ៉ាំងណាក៏ដោយ។ នៅលើភាគធំនៃអាស៊ីខ្លួប ព្រះពុទ្ធសាសនាបានប្រព្រឹត្តទៅជាមូលដ្ឋានសាធារណៈនៃផ្លូវចិត្ត នឹង បញ្ញាដែលជាទុកយ៉ាឲ្យមានសម្ព័ន្ធភាពខាងវិញ្ញាណមិនឆ្ងាយប្រជាជាតិតាំងពួយដែលមានការយោគយល់គ្នា នឹងសមានចិត្តស្រឡាំងគ្នាទៅវិញទៅមក។

សព្វថ្ងៃនេះ ពុទ្ធសាសនាតុំមានមុខងារកន្លងមកស៊ីខ្លួប ដូចដែលបានពោលមកខាងលើនេះទេ។ ការយល់ផលប្រយោជន៍ខាងខយោបាយនឹងសេដ្ឋកិច្ច តែងតែបំបែកយើងចេញពីគ្នា ផលប្រយោជន៍តាំងនេះតែងធ្វើជាតំនិះមឲ្យលាយចូលគ្នា ជាមួយនឹងលក្ខណៈឈ្មោនតាមមួយបែប ហើយជាក់ច្បាំងគ្រប់បែបគ្រប់យ៉ាង ដើម្បីរាំងផ្លូវនៃសមានចិត្តនឹងការយោគយល់គ្នា។ (ដូច្នេះ) សេចក្តីត្រូវការធំបំផុតរបស់យើងក្នុងសម័យនេះ គឺការលើកស្ទួយចិត្តយើងឲ្យខ្ពស់ផុតផលប្រយោជន៍តាំងនេះហើយនាំគ្នាស្វែងរកទំនាក់ទំនងគ្នា ដើម្បីសាមគ្គីរួបរួមគ្នានៅក្នុងមគ្គផលរួមគ្នាខាងផ្លូវចិត្ត ដោយសំគាល់ឲ្យដឹងជាតិតាំងពួយដែលចូលមគ្គផលរួមគ្នានេះ ថាជាបងប្អូនបង្កើតខាងផ្លូវចិត្តរបស់យើង។

សូមអរគុណ!

ភាវនាសទ្ធិយា


ទស្សនាវដ្តី ផ្សាយដំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៤ លេខ ១០ ខែតុលា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -



កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញវាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា — ទំព័រ

- ធម្មវិចារណាកថា ព្រះសាសនមុនី កឹម-ន្ហូរ រៀបរៀង (ត) ១០៨៣
- ដោលប្បាប់ព្រះពុទ្ធសាសនា លោក ហេង-សមអាន តែងទំនៀងរៀបរៀង (ត) . . . ១០៩៤
- ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) លោកប៉ូ-ប៉ូ ប្រែរៀបរៀង (ត) ១១០៣
- មធុរសវាហិណី សម្តេចព្រះធម្មលិខិត ស្រ-ឯម នគរបម្រើក្សត្រ ប្រែរៀបរៀង (ត) . . . ១១១៥
- មហោសថជាតក (ត) ១១២៣

ផ្នែកអក្សរសាស្ត្រ

- ពាក្យខ្មែរប្រែតបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ «ក» (ត) . ១១៤៣
- វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត) ១១៤៦
- រឿងស្បែកហ្វុងនៃន (La Fontaine) លោកផេង-ត្រ្បើរ ប្រែពីភាសាបារាំង . . ១១៤៩
- រឿងសាមកុក អ្នកឧកញ៉ា ន្ហូ-ពន ប្រែរៀបរៀង (ត) ១១៦០
- រឿងត្រែងចិន លោក ភ័យ-ប៊ុក ភូឈួយខែត្រតាកែវ ប្រែរៀបរៀង (ត) . . . ១១៨៤
- ទំនៀមទម្លាប់កុលសម្ពន្ធ លោក ឆឹក-ឆាម រៀបរៀង ១១៩០

កំណត់ទំនឹងប្រវត្តិការណ៍

- ពិធីប្រគេនសញ្ញាប័ត្រហ៊ានៈដាមេគណ ក្រុងភ្នំពេញ ចំពោះព្រះគេងធម្មណ ភង់-កឹង . . ១១៩៣

34è Année — N° 10 — Octobre 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse

—Dhammavicharanakatha par le Vénérable KEM-TO (suite) . . 1083
—Principes bouddhiques par M. HENG-SAM-AN (suite) 1094
—Préah Abhidhammapitaka «Kampir Préah Yamaka»
par M. BOU-PO (suite) 1107
—Madhurasavahini par S.Em Préah Dhammalikhita LOUIS-EM
Haut Conseiller (suite) 1115
—Mahosotha Jataka (suite) 1123

Partie littéraire

—Activité de la Commission Culturelle chapitre «Ka» (suite) . . . 1143
—Dictionnaire Sanscrit-Khmer par Vén. PANG-KHAT (suite) . . . 1146
—Fables de la Fontaine traduites par M. PHÉNG-CHRIV. . . . 1149
—Histoire de Sam-Kok traduite par Oknha NOU-KAN (suite) . . . 1160
—Légende Chinoise traduite par M. RAY-BOUC Phouchhouykhèt
de TAKEO (suite) 1184
—Les mœurs et coutumes des Tribus au Cambodge
par M. DIK-KEAM 1190

Notes et chroniques

—Cérémonie de cession de brevet portant nommination de Vénérable
RÉACH-KING comme Mékun de Phnom-Penh 1197

Prix d'Abonnement annuel (comprenant 12 numéros) : 230 ; 00

ធម្មវិចារណាកថា

ព្រះសាសនមុនី កឹម-ស្នរ រៀបរៀង

(តមក)

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ ។
ឲ្យដុំសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

សេចក្តីខ្វះ ជាមូលហេតុនាំឲ្យកើតសាសនា ដូចម្តេច ? ធម្មតាមនុស្ស រមែងមានចិត្តមិនតាំងនៅទីឯណាខ្លាំងជាប្រក្រតីទេ តែមានការខ្វះខាត មិនចេះគ្រប់គ្រាន់ កាលបើខ្លួនជាមនុស្សខ្សត់ខ្សោយ ហើយបានឧបត្ថម្ភសេចក្តីសុខ-ចំរើន អំពីបុគ្គលណាដែលគេនិយមកប់គាន កំណើនចាប់យកបុគ្គលនោះមកជាទីពឹងពាក់ ឬបើស្រឡាញ់គាប់ចិត្តចំពោះវត្ថុណា ដែលខ្លួនសំគាល់ថាឲ្យសុខឲ្យចំរើន ក៏ឧបត្ថម្ភកប់គានលើកតំកើងវត្ថុនោះ ថាជាបុគ្គលខ្ពង់ខ្ពស់មានគុណវិសេសស័ក្តិសិទ្ធិ ក៏នាំគ្នាទៅសម្តែងសេចក្តីកប់គានបន់ស្រន់ជូនសួង នោះតបូជាដោយគ្រឿងសក្ការៈ

ដើម្បីនឹងឲ្យបានដូចជាដូច្នេះ ដូច្នោះ សមតាមបំណងរបស់ខ្លួន សេចក្តីខ្វះខាតនេះឯង ជាមូលហេតុនាំឲ្យកើតសាសនាដែរ ។

មូលហេតុទាំង ៣ យ៉ាង ដែលបានអធិប្បាយមកនេះ ជាផ្លូវនាំឲ្យកើតសាសនា តំណែងមែន ប៉ុន្តែបើបំព្រួញឲ្យខ្លីតិចចុះមកមានតែមួយ គឺនៅត្រង់សេចក្តីភ័យខ្លាចនឹងជាសម្ភដ្ឋាន នាំឲ្យកើតសាសនា ។

ពាក្យថា សាសនៈឬ សាសនា នេះ មានន័យដំណែលជ្រៅណាស់ បើតាមសេចក្តីដែលយើងធ្លាប់ប្រែមកគឺប្រែថា « ពាក្យប្រៀនប្រដៅ ពាក្យមណ្តាំ » រហូតដល់មកប្រែថា « សំបុត្រ ដំណឹង លិខិត » ។ល។ ផងខ្លះទៀត ។ ត្រង់ពាក្យប្រែថា « ប្រៀនប្រដៅ » ពាក្យនេះមិនខុសទេ តែជាត្រូវសមល្អណាស់ ប៉ុន្តែត្រូវសមនៅតែនឹងថ្នាក់ខាងអាយ គឺកន្លែងត្រាដែលគេរៀបចំចងក្រងឡើងជាក្បួនតម្រាជាប្បាប់ឡើង សម្រាប់ឲ្យមនុស្សសិក្សា ដឿ ស្តាប់ គោរព ប្តូជា រាប់អាន តាមលំអាន ប្បាប់ជាគម្រោងស្រាប់ៗ ដែលមានមកហើយ ទើបប្រែថា ពាក្យប្រៀនប្រដៅ តែបើតាមមតិរបស់ខ្ញុំ ពាក្យថា សាសនា នេះ គួរប្រែថា ធម្មជាតិជាទីពឹងឬជាបង្អែកនៃចិត្តឬនៃជីវិតកំពុង ព្រោះជាមនុស្សក្នុងសម័យដែលទើបនឹងកើតឡើងជាដំបូង រមែងមានសេចក្តីស្រឡាញ់ហួងហែងជីវិតរបស់ខ្លួន ខ្លាំងហើយក៏តាំងឆាកវែស្វែងរកវត្តដ៏ស័ក្តិសិទ្ធិជាបង្អែកឲ្យជាទីពុកចិត្តកក់ក្តៅនៃជីវិត ដូចសេចក្តីដែលបានតាណិនាត័ខាងដើមមកហើយ ថា

មូលហេតុ ៣ យ៉ាង គឺ សេចក្តីខ្ជាប សេចក្តីត្រេកអរ សេចក្តីខ្នះខ្នែង
ខាំងនេះណាមួយ បណ្តាលទឹកចិត្តរបស់មនុស្សឲ្យស្វែងរកតែជាបង្អែក
នៃជីវិត ។

ដល់មកត្រង់នេះ ខ្ញុំត្រូវត្រឡប់ងាកទៅនិយាយពីកុសលបញ្ហាក់ជា
ថ្មីម្តងទៀតថា ក្នុងខាងដើមនេះ បានន័យយថា ព្រហ្មញ្ញាសាសនា ឬ
សាសនាព្រាហ្មណ៍ បើតាមប្រវត្តិសាស្ត្រគឺមានតាំងពីបរមបុរាណមុនពុទ្ធ
កាលមកម៉្លេះ ។ សាសនានេះ ក៏មានន័យយពីកាមាវចរកុសល រូបាវ
ចរកុសល នឹងអរូបាវចរកុសល ហើយមានយោគី តាបស ប្តូគ្គល អ្នក
ជឿស្តាប់គោរពប្រតិបត្តិតាម អាចឈោងចាប់យកគុណវិសេស ហើយ
បានទៅកើតកំពង់ខេវលោក ព្រហ្មលោក ដូចអ្នកដែលប្រតិបត្តិតាមខាង
ផ្លូវពុទ្ធសាសនាដែរ បើសាសនានេះ មានសេចក្តីប្រតិបត្តិល្អបានកុសល
ដូចជាពុទ្ធសាសនាដែរ តើខាងពុទ្ធសាសនាមានប្រយោជន៍អ្វី ? បើមាន
តែព្រហ្មញ្ញាសាសនាមួយប៉ុណ្ណោះ ហាក់ដូចជាគ្រប់គ្រាន់ដែរហើយ ចុះ
ហេតុអ្វីចាំបាច់មានពុទ្ធសាសនា តើតទៀងជាគួរប្រដែងខ្លាំង តើពុទ្ធ-
សាសនាមានទុត្តមតតិ ទំនឹងគុណវិសេសខ្ពស់ជាងយ៉ាងណាខ្លះ ? សាសនា
ដទៃក្រៅពីពុទ្ធសាសនា ច្រើនតែសាសនាបដិរូប ប្រែថា សាសនាបួម
ឫថាសាសនាមិនបរិសុទ្ធមានលាយដោយកាតិតខ្លះ មិនតិតខ្លះ ប្រៀប
ដូចទាសដែលលាយដោយជាតិលោហៈផ្សេងៗមានខាន់ដែងជាដើម ទាស

នោះក៏គ្មាយទៅជារបស់មិនសុទ្ធ ឬហៅថាមាសមិនគ្រប់ទឹក ១០ ក៏ដូច្នោះដែរ ព្រោះហេតុអ្វី? ព្រោះហេតុថា សាស្តាចារ្យអ្នកមេប្រឌិតបង្កើតសាសនានោះៗឡើង ជាមនុស្សនៅប្រកបដោយកតាទំក្កិលេសមិនបរិសុទ្ធ ឯសាសនាទោះក៏មិនបរិសុទ្ធដែរ ព្រោះគេប្រឌិតបង្កើតឡើង ដោយការរិះរេគ្នាន់ឬដោយការស្មានប្រមាណយកតែតាមយោបល់របស់ខ្លួន ។ សាសនានេះមានកម្មវិធីប្រៀនប្រដៅសត្វ ឲ្យសត្វប្រតិបត្តិបំពេញត្រឹមតែកុសល ៣ យ៉ាង មានតាមាវចរកុសលជាដើមប៉ុណ្ណោះ ទោះបីកុសលថ្នាក់ណាក៏សុទ្ធតែនៅកន្លងផុតពីវដ្តគាមិកុសលទាំងអស់ ហើយចង្អុលបង្ហាញលទ្ធផលដល់អ្នកដែលប្រតិបត្តិតាម ឲ្យបានត្រឹមតែសម្បត្តិមនុស្ស សម្បត្តិទេវតា សម្បត្តិព្រហ្ម ដែលហៅថា សម្បត្តិកន្លងកាមភព រូបភព អរូបភពប៉ុណ្ណោះ នេះឯងជាការបញ្ជាក់ឲ្យឃើញច្បាស់ថា សាសនានេះប្រៀនប្រដៅដឹកនាំសត្វអ្នកប្រតិបត្តិតាម ឲ្យវិលវល់ជាប់នៅកន្លងផុតពីភព ឬលោកទាំង ៣ នេះ មិនអាចរកផ្លូវ រកច្រកចេញឲ្យផុតចាកលោកទាំង ៣ នេះទៅបានឡើយ ។

ក្នុងចំណោមអ្នកកាន់សាសនានេះ មានត្រូវជាសាស្តាធំៗខ្លះដែលជាអ្នកប្រដៅខ្លួនឯងបរិសុទ្ធ គេមានយោបល់យល់ក្នុងអរិយសច្ចស្រេចឥតខ្ចីនឹងអរិយសច្ចរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គទ្រង់សម្តែងដែរ ដូចជាសាស្តាឈ្មោះ ឯកច្ចសាតបុត្ត គាត់យល់ថា សេចក្តីទុក្ខគ្រប់យ៉ាង

ដែលបៀតបៀនសត្វ បណ្តាលមកតែអំពើតំលេស គឺតណ្ហា ធម៌ដែលនាំឱ្យអស់តណ្ហាគឺខៀង ធម៌ដែលធ្វើទៅហើយ នាំឱ្យបានទៅកើតនោះ គាត់មិនយល់ថា ត្រូវធ្វើតាម អដ្ឋង្គិកមគ្គ (មគ្គប្រកបដោយអង្គ៨ មានសម្មាទិដ្ឋិជាដើម) ទេ គាត់ត្រឡប់ជាយល់ថា ត្រូវធ្វើតាមអត្តកិលមថានុយោគវត្ត គឺប្រព្រឹត្តតបវត្តយ៉ាងតឹងរ៉ឹង មានការប្រព្រឹត្តអង្គុយហាលកំដៅថ្ងៃ ឬ ចុះត្រាំទឹកក្នុងរដូវរងាជាដើមឯណោះទៅវិញ នេះឯងជាការបញ្ជាក់ឱ្យឃើញថា សាសនា នេះ មិនបរិសុទ្ធ មិនស្គាល់ហេតុផលដោយច្បាស់លាស់ ។

ចំណែកខាងពុទ្ធសាសនា ទើបជាសាសនាដ៏បរិសុទ្ធ ជាសាសនាមានតួមគគប្រកបដោយហេតុផល ច្បាស់លាស់ជាងសាសនាដទៃឯទៀត ដែលយើងនិយាយនេះ មិនមែនដោយសារថា ខ្លួនជាអ្នកកាន់ពុទ្ធសាសនាហើយ ក៏ចេះតែនិយាយអួតកាន់ដើងខាងពុទ្ធសាសនាទៅមិនមែនដូច្នោះទេ ។ ពុទ្ធសាសនា ពិតជាសាសនាបរិសុទ្ធប្រកបដោយហេតុផល គួរឱ្យជឿស្តាប់កាន់តោតប្រតិបត្តិតាមមែន។ ពីព្រោះព្រះពុទ្ធព្រះអង្គជាម្ចាស់នៃពុទ្ធសាសនានេះ ជាអច្ឆរិយមនុស្សតែជាមនុស្សអស្ចារ្យមួយរូប ដែលមានព្រះហឫទ័យដ៏បរិសុទ្ធស្អាតចាកគ្រឿងសៅហ្មង ដែលយើងបានដឹងប្រវត្តិរបស់ព្រះអង្គមកហើយ សឹងមានសេចក្តីពាក់ព័ន្ធក្នុងគម្ពីរជាច្រើនអនេក្ខាថា ព្រះពុទ្ធកាលដែលទៅកន្លងហួនៈជាតោធិសត្វ ទំាង

យោមបំពេញបារមីធម៌ អស់រយៈកាល ៤ អសង្ខេយ្យ ទំនឹង ១ សែនកប្ប
ត្រាច់ដើរតាំលាស់កន្លងកាលវដ្តសង្សារ ដើម្បីតែពោធិញ្ញាណ ។ ក្នុង
ខ្សុំ ៤ អសង្ខេយ្យ ទំនឹង ១ សែនកប្បនោះ ពោះបរមព្រះអង្គអន្ទោលទៅកើត
ក្នុងកំណើតនៃមនុស្ស ឬ អមនុស្ស ឬ ក៏សត្វអ្វីក៏ដោយ ក៏សុទ្ធតែជាការពៀ
សោធន៍ពារកពោធិញ្ញាណ ដើម្បីសេចក្តីសុខ សេចក្តីចំរើនខ្ញុំផុតពាកទុក្ខ
តែម្យ៉ាងប៉ុណ្ណោះ ដរាបដល់មកកើតក្នុងជាតិជាតិចុងបំផុតដែលមានបរមនាម
ជា សិទ្ធត្ថៈ ។ ដោយអំណាចស្នាមគំនូសដែលឆ្នាក់ជាតជាប់ក្នុងព្រះ
ហឫទ័យប្រព្រឹត្តទៅក្នុងពោធិញ្ញាណដែលហៅថា ឧបនិស្សយោនោះ មិន
រលត់ចាត់ ក៏បង្ខំឲ្យព្រះអង្គចេញសាងព្រះផ្នួស ស្វែងរកពោធិញ្ញាណ
ជារំលើកក្រោយចុងក្រោយ ដរាបដល់បានជួបទំនឹងពោធិញ្ញាណ ដែលយើង
ទាំងគ្នាហៅថា ព្រះពុទ្ធ ឬហៅថា ព្រះអង្គត្រាស់ដឹង ។ ពាក្យថាត្រាស់
ដឹងនេះ ជាពាក្យខ្ពស់ពិចារណាស្តាប់ បើប្រែឲ្យងាយស្តាប់មកវិញថា
ស្រាវជ្រាវរកឃើញ គឺព្រះអង្គទ្រង់រកឃើញនូវធម៌ពិត ជាធម៌ល្អត្រឹមត្រូវ
ជ្រះ ជាធម៌ប៉ិនប៉ាង តុំដែលមាននរណាដឹង ឬ រកឃើញដល់ខ្លួនឯង
សោះ ទើបតែមានព្រះពុទ្ធត្រាស់ព្រះអង្គរកឃើញមុនគេ បានជាលោក
ទាំងមូលទាំងគ្នាសន្មតហៅព្រះអង្គថា ព្រះពុទ្ធអ្នកត្រាស់ដឹង ។

ក្នុងសម័យដែលព្រះអង្គឯងត្រាស់ដឹងជាព្រះពុទ្ធហើយ ទ្រង់ប្រ-
កាសធម្មៈរបស់ព្រះអង្គដែលហៅថា ពុទ្ធសាសនា ក្នុងលទ្ធិសាសនា

ព្រាហ្មណ៍ដែលមានមកជាយូរអង្វែងហើយៗ សាសនាព្រាហ្មណ៍នេះ បែកចេញទៅជាលំដូ ជាសាខាធំៗ ជាច្រើនតទៅទៀត ដែលមានឈ្មោះថា សាសនាជេន សាសនាមិត្រន្ទ សាសនាបរិពាជក ទើងសាសនាបស់ត្រូវាំង ៦ មានគ្រូឈ្មោះបូរណកស្សបជាដើម សាសនាទាំងអស់នេះ សុទ្ធតែមានទំយោគីនាក្សប្រឿនប្រដៅបរិស័ទ ឲ្យប្រតិបត្តិខេរទៅកាន់កាមសុខល្វីកាន្ទយោគ ទើងអត្តកិលមថានុយោគទាំងអស់ ។ ឯពុទ្ធសាសនា ព្រះអង្គទ្រង់សម្តែងវែកញែកបង្អុរប្រាប់ពន្យល់ឲ្យស្គាល់ផ្លូវរៀបផ្លូវត្រង់ជាមុនគឺឲ្យស្គាល់ថា ផ្លូវនេះទៅកាន់អបាយភូមិ ផ្លូវនេះទៅកាន់ខេរលោក ផ្លូវនេះទៅកាន់ព្រហ្មលោក ផ្លូវនេះទៅកាន់និព្វាន ទើបព្រះអង្គទ្រង់ណែនាំសត្វឲ្យប្រតិបត្តិធម្មៈ ដើរទៅកន្លងផ្លូវកណ្តាលជាបន្ទោះនៃកាមសុខល្វីកាន្ទយោគ ទើងអត្តកិលមថានុយោគ ឬហៅថា មជ្ឈិមាបដិបទា ជាសេចក្តីប្រតិបត្តិប្រព្រឹត្តទៅកន្លងប្រទេរភាកណ្តាល មិនធ្លាពេក មិនតឹងពេក គឺមិនបួលទៅខាងកាមសុខល្វីកាន្ទយោគ ទើងអត្តកិលមថាយោគ ។

ពុទ្ធសាសនានេះ ជាសាសនាមានទុត្តមគតិដ៏ល្អបរិសុទ្ធប្រកបដោយហេតុផល ទោះបីព្រះអង្គសម្តែងអំពីកុសលថ្នាក់ណាក៏ដោយ កុសលថ្នាក់នោះ សុទ្ធតែឈរមូលទៅរកខាងវិវដ្តគាមិកុសលទាំងអស់ ជាកុសលអាចញុំាងអ្នកប្រតិបត្តិតាមឲ្យរួចផុតចាកទុក្ខទាំងពួង ដែលមានប្រចាំ

នៅក្នុងលោកនាំឲ្យ ៣ ឆ្ពោះទៅកាន់និព្វាន បើអ្នកប្រតិបត្តិតាមពុទ្ធសាសនា មិនទាន់ដើរទៅដល់ទីដៅពោលគឺនិព្វានទេ មិនហៅថាជាអ្នកបានទទួលលទ្ធផលនៃសេចក្តីប្រតិបត្តិតាមពុទ្ធសាសនានៅឡើយ ។

ពុទ្ធសាសនា ជាសាសនាមានវគ្គ មានសង្កាត់ មានរបៀបរៀបរយតាមលំដាប់លំដោយល្អណាស់ មានអង្គការធ្វើអ្នកប្រតិបត្តិតាមឲ្យមានដំណើរត្រង់ផ្លូវ មិនឲ្យកាន់ច្រឡំ មិនឲ្យរៀបវេរទៅរកផ្លូវខុស ដូចបរិយត្តិ (ការសិក្សា) ការសិក្សានេះជាដំហានឆ្ពោះទៅរកបដិបត្តិ (សេចក្តីប្រតិបត្តិ) គឺការប្រព្រឹត្តកាន់តាម សេចក្តីប្រតិបត្តិនេះជាដំហានឆ្ពោះទៅរក បដិវេធៈ (ការត្រាស់ដឹង) ការត្រាស់ដឹងនេះជាប្រភពនៃមគ្គផលនិព្វាន មគ្គផលនិព្វាននេះជាប្រភពនៃនិព្វាន និព្វានទើបជាទីបំផុតនៃលោក និព្វានជាលទ្ធផលនៃការសិក្សាទឹងសេចក្តីប្រតិបត្តិ ត្រង់នេះឯងជាការបញ្ជាក់ឲ្យ ឃើញច្បាស់ថា ពុទ្ធសាសនា ជាសាសនាមានទត្តមគតិល្អវិសេសខ្ពស់ផុតជាងសាសនាឯទៀតទាំងអស់ ។

ពុទ្ធសាសនា ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងទុកជាឧត្តមទាំងប៉ុន្មាន ដែលក្រុមព្រះសង្ឃិតិការចារ្យ បានប្រមូលរៀបចំទុកជាក់តាមពួកតាមក្រុម កំណត់ហៅថា ទីឃៈ ព្រះសូត្រ ព្រះអភិធម្ម ប្រជាប់ដោយធម្មក្ខន្ធ ៨.៤០០ ធម្មក្ខន្ធ មានចំនួនច្រើនយ៉ាងណាក៏ដោយ ក៏សុទ្ធតែជាឧត្តមានគោលបំណងធ្វើអ្នកប្រតិបត្តិតាម ឲ្យបែរមុខឆ្ពោះទៅ

រកនិភ្លានតែម្យ៉ាងប៉ុណ្ណោះ ។ ប៉ុន្តែឯយើងជាតុន្ទបរិស័ទចាំងបព្វជិតចាំងគ្រហស្ថ ដែលបានប្រកាសខ្លួនថាជាតុន្ទសាសនិក (អ្នកកាន់តុន្ទសាសនា) ត ។ មកនៅនាសម័យបច្ចុប្បន្ននេះ កាលបើប្រាប្តេចំពោះការណ៍យកចិត្តណាមួយក្នុងតុន្ទសាសនាដោយកាយ វាចា ចិត្ត ច្រើនធ្វើដោយសេចក្តីយ្បៀងឃ្លាត ឬដោយការកាន់ច្រឡំ ព្រោះហេតុនោះខ្ញុំសូមនាយកទុកជាហេរណ៍ចេស់អ្នកដែលមានគំនិតគតិតទុកសឬកាន់ច្រឡំក្នុងអំពើដែលខ្លួនធ្វើដែលខ្លួនគិតនោះមកលាតត្រដាងឲ្យឃើញជាតួយ៉ាងខ្លះ តទៅនេះ ៖

បព្វជិតខ្លះ ដែលបួសហើយភ្លេចនាទី ឬមុខការរបស់ខ្លួន ដែលខ្លួនត្រូវតែធ្វើ ត្រូវតែចំពេញនឹងមានពុំបាន ។ គ្រែសិក្ខាគឺ សីល សមាធិ បញ្ញា ជានាទី ឬមុខការរបស់បព្វជិត ។ ត្រូវតែយកចិត្តទុកជាក់ចំពេញតឹត្រូវប្រតិបត្តិតាម ប៉ុន្តែបព្វជិតខ្លះ បណ្តែតបណ្តោយខ្លួនឲ្យនៅចំនេះ មិនសូវអើពើ ធ្វើហាក់ដូចជាថាគ្រែសិក្ខាមិនមែនជានាទីរបស់ខ្លួនទៅវិញ បែរជាទៅខ្វល់ខ្វាយយកចិត្តទុកជាក់ចំពោះកិច្ចការណាផ្សេងដែលព្រះពុទ្ធជាម្ចាស់មិនបានតម្រូវជាក់ឲ្យនោះទៅវិញ ឬបើទុកជាមានពុទ្ធានុញ្ញាតឲ្យធ្វើបានខ្លះដែរ ប៉ុន្តែការធ្វើនោះ ទៅជាជ្រុលជ្រួសហួសប្រមាណ មិនសមរម្យជាកិច្ចការដែលបព្វជិតគួរធ្វើ នេះឈ្មោះថាជាការកាន់ច្រឡំទី ១ របស់បព្វជិត ។

បព្វជិតខ្លះក្នុងសម័យបច្ចុប្បន្ន កាលបើបានឡើងកាន់ឋានៈជាអ្វីមួយ

មានកិត្តិយសប្រហែលនឹងបព្វជិតក្នុងសម័យពុទ្ធកាល ដែលបានសម្រេចគុណវិសេសព្រោះហេតុអ្វី ? ព្រោះហេតុថា បព្វជិតក្នុងសម័យពុទ្ធកាលបើអង្គណាមួយបានសម្រេចគុណវិសេសគឺមគ្គផលហើយ តែងមានបរិស័ទនាំគ្នាចោមរោមគោលសរសើរ សម្តែងសេចក្តីគោរពរាប់អានបូជាដោយគ្រឿងសក្ការៈ យ៉ាងណា ឯបព្វជិតដែលបានហាន:ណាមួយ ក៏មានបរិស័ទចោមរោមសរសើរគោរព រាប់អានបូជាដោយគ្រឿងសក្ការៈដូច្នោះដែរ ម្ល៉ោះហើយបព្វជិតនោះ ក៏ស្រាវឆ្ងល់ឆ្ងល់ហាន:របស់ខ្លួនដោយសារគ្រហស្ថរាប់អានលើកតំកើងនោះ ក៏ទើរតំនិតកើលនៅត្រឹមនោះទៅ ជាហេតុឲ្យក្លេចបំភេញវត្តសិក្ខាដែលជាការណ៍យកចិត្តរបស់ខ្លួន ដែលខ្លួនត្រូវប្រតិបត្តិតទៅ នេះឈ្មោះថាជាការកាន់ច្រឡំទី ២ របស់បព្វជិត ។

កុលបុត្តគេខ្លះជាគ្រហស្ថ ឈ្មោះថាជាអ្នកនៅក្នុងចំណោមកាម ស្វែងរកកាម បរិភោគកាម ខ្លួលសេចក្តីសុខក្នុងកាម កាលបើកាមមានការវិបត្តិប្រែប្រួលបណ្តាលឲ្យទុក្ខទោសកើតឡើង ក៏មានសេចក្តីមឿយណាយធុញទ្រាន់ស្អប់ខ្ពើមកាម មិនចង់ឲ្យជួបប្រទះនឹងកាមនោះតទៅទៀតដោយបានដឹងច្បាស់ថា សេចក្តីទុក្ខទោសទាំងអស់ដែលធ្លើមនុស្សសត្វឲ្យបានខ្លួលខ្លះទុក្ខវេទនាត្រង់យ៉ាង គឺបណ្តាលមកតែអំពីកាមហ្នឹងឯងជាហេតុ ។ កុលបុត្តនោះ លុះបានដឹងច្បាស់ដូច្នេះហើយ ក៏រកឧបាយដោះដៃគេចចេញអំពីកាមនោះ គឺប្តូរចិត្តលះបង់កាម ទាំងលះបង់គេ

ខ្លួនជាគ្រហស្ថផង ចូលមកកាន់កេវដាបព្វជិត លុះបានកេវដាបព្វជិត
ហើយ ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ថ្នាក់ខ្ពស់ ដើម្បីធ្វើនូវធម៌ជាទីបំផុតនៃទុក្ខ
ដែលកើតអំពីកាមនោះបេញ្ញា នេះមិនដូច្នោះ បែរត្រឡប់ជាប្រព្រឹត្តព្រហ្ម-
ចរិយធម៌ថាកថាបថយក្រោយ ដើម្បីទៅរកកាមកង់លោកនេះ ឬកង់
លោកខាងមុខដដែលទៅវិញ ។ ត្រង់ពាក្យថា ដើម្បីទៅរកកាមកង់
លោកនេះ គឺដើម្បីឲ្យបានហាន:ជានេះ ជានោះ កង់បច្ចុប្បន្ននេះ ត្រង់
ពាក្យថា ដើម្បីទៅរកកាមកង់លោកខាងមុខ គឺដើម្បីឲ្យបានសម្បត្តិកង់
កពជាទៅតានេះ ជាទៅតានោះ ឬជាទៅតាណាមួយកង់លោកខាងមុខ
ដោយអំណាចព្រហ្មចរិយធម៌របស់អាត្មាអញនេះ ។ បើបព្វជិតបណ្តោយ
ចិត្ត ឬបណ្តោយចាំងកាយចាំងចិត្តឲ្យស្ទុះបអង្អែល ប្រឡែងប្រឡូកជាមួយ
ទឹងត្រឿងកាមដូចជាគ្រហស្ថដដែល តើការគ្រាំសម៉ូនៅធ្វើជាកេវបព្វ-
ជិតបែបនេះ ទឹងមានប្រយោជន៍អ្វីខ្លះដែរឬទេ ? នេះឈ្មោះថាជាការកាន់
ប្រឡំទី ៣ របស់បព្វជិត ។

(នៅមានត)

ធម្មបទ - ខុទ្ទកនិកាយ

លោក ហោង-សមអាង រៀបរៀង

(តមក)

រីឯនន្ទិវិសាលឃើញម្ចាស់សោកស្តាយដូច្នោះ ក៏ពួលទៅនិយាយថា " បពិត្រព្រាហ្មណ៍ ! សូមអ្នកទៅគ្រាលម្ហូងទៀតចុះ ដាក់ថ្លៃ ២០០០ តហាបណៈ ប៉ុន្តែត្រូវអ្នកនិយាយពាក្យល្អ កុំថាគេដូចមុនទៀតឡើយ " ។ ព្រាហ្មណ៍ឮហើយក៏ទៅនិយាយគ្រាលម្ហូងទៀត ក្នុងពេលបញ្ជោរនេះនោះ ព្រាហ្មណ៍ពោលទំនន្ទិវិសាលថា " ម៉ែគាត់ចំរើន ចូរអ្នកអូសរនេះនេះទៅ " ។ នន្ទិវិសាលបានឮសំដីម្ចាស់ដាច់គាប់ចិត្ត ក៏ទាញអូសរនេះ ១០០ ដែលមានទម្ងន់ហួសប្រមាណបានផុតពីភ្នាល់គ្នា ។ ព្រាហ្មណ៍ជាម្ចាស់ត្រូវឈ្នះបានថ្លៃ ២០០០ តហាបណៈ។

ព្រោះហេតុនោះ ព្រះមុនីន្ទលោកនាថទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផ្លូវសុភដែលបុគ្គលបានពោលហើយ ជាអំពើប្រព្រឹត្តទៅដើម្បីអបាយ គឺនាំឲ្យអន្តរាយបាតភ្នាត់-មិត្ត ទីដនក្រាមបង្គាប់ ។ សំដីទ្រគោះតែងនាំឲ្យទុក្ខកាយ ដែលបំរុងធ្វើដំណើរលំបាកទៅ ។ ជនពោលទ្រគោះថ្នាក់ថ្នមនោះ លុះទម្លាយកាន់កាយទៅទៀតតែងទៅកើតក្នុងនរក

រួចពីនរកមកកើតជាប្រេត រួចពីប្រេតមកកើតជាអសុរកាយ រួចពីអសុរកាយមកកើតជាតិរច្ឆាន រួចពីតិរច្ឆាន មកកើតជាមនុស្ស តែជាមនុស្សជួបប្រទះតែពាក្យទ្រគោះចោះចោកគំរាមពីអ្នកដទៃ ។

ផរុសវាចា ជាពាក្យអាក្រក់ លោកឲ្យឈ្មោះថា ទាប ជាពាក្យមិនត្រូវគោលឡើយ

៧- សម្ផប្បលាប កិរិយាគោលទូវពាក្យពេយកយ ឥតប្រយោជន៍

សម្ផប្បលាបវាចា ជាសំដីពេយកយធ្វើឲ្យអ្នកស្តាប់កយមាយចិត្ត អ្នកនិយាយលេះលោះ អាចញ៉ាំងគាការៈឲ្យអ្នកដទៃឃើញថា ជាមនុស្សលេះលោះ គ្មានទរណាយកជាមុខជាមាត់អ្វីទេ ។

បុគ្គលណាគោលទូវពាក្យឥតប្រយោជន៍ បុគ្គលនោះឈ្មោះថា អនត្ថកាមិ តែអធម្មកថីតែអាចញ៉ាំងព្រះសទ្ធម្មឲ្យអន្តរធានទៅ ។ ដូចមានព្រះពុទ្ធដីកាថា យេបិ តេ កិត្តយេ កិត្តិ អធម្មិ ឧម្មាតិ ។ល។ សទ្ធម្មិ អន្តរធាបេន្តិ (១) ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា គោលពាក្យមិនមែនធម៌ថាជាធម៌ ភិក្ខុទាំងឡាយនោះប្រតិបត្តដើម្បីមិនមែនជាគុណដល់ជនមានប្រមាណច្រើន ដើម្បីមិនទាំមកទូវសេចក្តីសុខដល់ជនមានប្រមាណច្រើន

១- ចាក អង្គុត្តរនិកាយ ឯកនិបាត ។

ដើម្បីមិនជាប្រយោជន៍ ដើម្បីមិនមែនជាគុណ ដើម្បីសេចក្តីទុក្ខ ដល់ជនមានប្រមាណច្រើន តើដល់ខេញ្ចនីឥន្ទមនុស្សចាំងឡាយ ម្នាលភិក្ខុចាំងឡាយ ! ភិក្ខុចាំងឡាយនោះតែងរងកម្មដ៏សាហក់ជាច្រើន ភិក្ខុចាំងឡាយនោះតែងញ៉ាំងព្រះសទ្ធម្មឲ្យអន្តរធានទៅ ។

សម្ផប្បលាបវាទ នេះមានទោសធ្ងន់ណាស់ ។ ភាវណ៌ដូចជា :

រឿងកបិលភិក្ខុ

កន្លងសាសនកាលនៃព្រះសម្មាសម្ពុទ្ធ ព្រះនាមកស្សប មានភិក្ខុ ១ រូប ឈ្មោះ កបិល ជាពហុស្សូត ចាំនរឿងព្រះវិន័យបិតកចេះដឹងច្រើនហើយ ជាធម្មកថិកយ៉ាងដំនាញ ១ រូបផង មានបរិវារនឹងលាភសក្ការៈច្រើន ។ កបិលភិក្ខុ ស្រឡាំងដោយពហុស្សូត សំគាល់ខ្លួនថាជាអ្នកជ្រាជ្រួ ពោលផ្ចុយនឹងអត្ថដែលអ្នកជ្រាជ្រួចាំងឡាយពោលថា ក្លែរ ត្រឡប់ពោលថា មិនគួរវិញ តែងពោលនូវសម្ផប្បលាបស្រែងធម៌វិន័យជាច្រើន កាលបើភិក្ខុចាំងឡាយអ្នកមានសីល ពោលទូន្មានម្តងៗក៏តែងតែដេរប្រទេចនូវភិក្ខុចាំងឡាយនោះវិញ ។ កបិលភិក្ខុនោះ ស្លាប់ទៅ។ កើតក្នុងអវីចិមហានរក មានអណ្តាតភ្លើងឆេះឡើងសន្ធោសន្ធៅអស់ ១ ពុទ្ធន្តរ លុះសេសសល់ផលកម្មណាមក ចានមកកើតជាត្រីមានសម្បុរដូចមាស នៅក្នុងស្ទឹងអចិរវតី ប៉ុន្តែមានស្នូយ ។ លុះស្លាប់ពីត្រីទៅកើតក្នុងអវីចិមហានរកវិញជាដែល ។

សម្ផប្បលាបកម្ម ជាពាក្យអាក្រក់ លោកឲ្យឈ្មោះថា ចាប ជាពាក្យមិនត្រូវពោលឡើយ ។

មនោកម្ម

មនោកម្ម គឺអំពើដែលធ្វើអាក្រក់ដោយចិត្ត មាន ៣ យ៉ាង គឺ អភិជ្ឈា ១ ព្យាបាទ ១ មិច្ឆាទិដ្ឋិ ១ ។

៨- អភិជ្ឈា ចិត្តសម្ងំនឹកពៃចំពោះទ្រព្យអ្នកដទៃដោយគិតបម្រុងឲ្យបានមកជារបស់ខ្លួន ។

អភិជ្ឈានេះ បើកើតមានក្នុងសន្តានចិត្តនៃបុរសស្ត្រីណាហើយ ក៏ធ្វើឲ្យសន្តានចិត្តនៃបុរសស្ត្រីនោះឲ្យសៅហ្មង កាលបើចិត្តមិនបរិសុទ្ធជាចិត្តសៅហ្មងហើយ ច្រាកជាទៅកាន់ទុគតិ គឺទៅកើតកន្លែងតក្កហ្វាយក្នុងបច្ចុប្បន្នជាតិនេះក៏ក្តៅក្រហាយមិនសប្បាយក្នុងចិត្ត ដ្បិតជាប់ដំណាក់ទៅកន្លែងតែដែលខ្លួនច្រាថ្នា កើតរបៀបដូសារក្តៅក្រហាយកើតលក្ខណៈក្នុងចិត្ត ។ ភាវណ៌ដូចជា ៖

រឿងព្រះបៀលល្មោភរាជសម្បត្តិ(១)

ក្នុងអតីតកាល ព្រះបៀលក្រុងពារាណសី ទ្រង់លង់ចូលក្នុងអំណាចនៃអភិជ្ឈា មួយថ្ងៃ ។ ព្រះរាជហប្ចទ័យរំពៃថែរឈមទៅរកព្រះរាជអាណាចក្រឯទៀត ។ ដោយមិនកំណត់ ។

១- ជាតកដ្ឋកថាឯកាទសនិបាត ត្រង់ភាគទី៥ សូត្រជាតក ។

ក្នុងខណៈនោះ សក្កោជេវភាជ ស្តេចទ្រង់ជ្រាបដោយចិត្តនៃត្រូវចេតនាព្រះចៅពាកណាសីហើយ ទើបទ្រង់ត្រិះរិះថា "ចើអាត្មាអញព្រងើយកន្តើយ តាមតាលោកនឹងស្តៅក្រហាយ ដោយព្រះពាអង្គនេះមិនខាន គួរតែទៅផ្ញើផ្ញាល់ឲ្យអៀនខ្មាស ហើយពន្យល់ឲ្យមកកាន់សេចក្តីស្ងប់វិញ ; " ទ្រង់ព្រះតម្រិះគិតយ៉ាងនេះហើយ ក៏ទ្រង់យាងចុះមកដោយកែងកេខ៉ាព្រាហ្មណ៍កន្លះ ចូលទៅគាល់ព្រះចៅពាកណាសីក្រាបបង្គំទូលថា "សូមព្រះតេជៈដ៏កល់លើស្ងួន ខ្ញុំព្រះបង្គំបានដើរទៅឃើញក្រុងឧត្តរបញ្ចាល ឥន្ទបត្ត នឹងក្រុងសាកេត រាជធានីទាំង ៣ នេះ សឹងតេញដោយសេចក្តីសុខសប្បាយ ស្រូវអង្ករ តោត សណ្តែក ។ល។ ទាំងឡាយចរិបូណ៌តោរតេញឥតខ្វះខាត ទាំងសម្បុរណ៌ដោយមាស.ប្រាក់.កែវ.កង ពិខួរស្រស់ល្អកាន្ទាន់ជាដើម បើព្រះអង្គមានព្រះចំណង់កងរាជធានីទាំង ៣ នោះ ខ្ញុំព្រះបង្គំសូមព្រះរាជទានពលតែ ១០០ នាក់ពីព្រះអង្គ ខ្ញុំលួចយកអសារទៅរឹបជាន់ដណ្តើមយកនគរទាំងនោះ ឲ្យបានដោយឫទ្ធានុភាពព្រះអង្គ " ។ ព្រះចៅពាកណាសី ទ្រង់ជ្រាបថានឹងបានឧត្តរនគរទាំងនោះ ក៏ទ្រង់សោមនស្សរីករាយសប្បាយក្រៃលែង ទ្រង់ពាលាព្រាហ្មណ៍កន្លះលើកទ័ពទៅច្បាំង ក្នុងពេលស្អែក តែទ្រង់ភ្លេច មិនបានព្រះរាជទានទ័ពដំណើរនឹងបានឧត្តរដល់មាណពនោះសោះ ។

លុះត្រឹមខែ្ណ ទ្រង់ចាត់ឲ្យរៀបចំតបូរស្រេចហើយ ទ្រង់គ្រាស់ឲ្យហៅ
ព្រាហ្មណ៍កម្ងោះនោះចូលគាល់ អាមាត្យតាំងឲ្យក្រាបបង្គំទូលថា
"បពិត្រព្រះមហាអំណាច បើព្រះអង្គមិនប្រទានទីដំណែកនឹងថ្វាយទឹក
ដល់មាណពនោះ តើឲ្យទូលព្រះបង្គំទៅហៅនៅកន្លែងណា ? ។ ព្រះកថា
ទ្រង់បញ្ជាឲ្យតាហានតាមរកគ្រប់ប្រកល្អកក្នុងទីក្រុង តែមិនប្រទះសោះ ។

ព្រះចៅក្រុងពារាណសី ទ្រង់ជ្រាបថារកព្រាហ្មណ៍មាណពនោះ
មិនឃើញ ក៏ទ្រង់ទោមនស្សខ្លួនម្នាញអន្ទះអន្ទែងក្តៅក្រហល់ក្រហាយ
ព្រោះតណ្ហារួបរឹតព្រះហឫទ័យ សំឡឹងរំពៃចង់តែបានពាជានី ៣ នោះ
បណ្តាលឲ្យធ្លាក់លោហិតយ៉ាងច្រើនចេញពីព្រះនាសា ហៅថាបក្ខន្ទិកា
ពាធ ពួកគេឲ្យមិនអាចនឹងថ្វាយការថែរក្សាបាន ព្រោះផាកេតចិត្តឥត
ឃើញស្វាកស្នាមអ្វីបន្តិចឡើយ ។

ព្រះឥន្ទ្រាធិរាជ ទ្រង់យាងចុះមកដោយភ្លែងកេងជាព្រាហ្មណ៍ ចូល
ទៅសួរមគ្យាចារ ព្រះកថាទ្រង់គ្រាស់ថា "ចូរឲ្យរង្វាន់ហើយបង្គាប់ឲ្យ
ទៅវិញទៅ" ព្រាហ្មណ៍ទូលតបថា "មិនត្រូវការរង្វាន់ខាន់ទៅ ឬទ្រង់ច
ត្រូវទេ តែតាំងចិត្តនឹងថ្វាយការព្យាបាលរក្សាប៉ុណ្ណោះ" ។

កាលបានរកជាខ្លួនភ្លាតហើយ ឥន្ទ្រព្រាហ្មណ៍ក៏ចូលទៅក្រាបបង្គំទូលសួរ
អំពីសមុដ្ឋាននៃរោគ ព្រះកថាទ្រង់គ្រាស់ឲ្យស្តាប់តាំងពីដើមដល់ចប់ហើយ
អញ្ជើញព្រាហ្មណ៍ឲ្យដាក់ទុសថ ។ ព្រាហ្មណ៍ដឹងអាការៈនៃរោគហើយ

កំក្រាបទ្ទឹងខ្លួលថា "បពិត្រព្រះមហាក្សត្រ! បើតាស់ចឹក មានតេឡាតាស់អាចជាក់ថ្នាំរម្ងាប់ពិសតាស់បាន បើខ្មោចឆ្លើ មានគ្រូខ្មោចចេះមន្តអាគមគាថា សូត្រចេញខ្មោចបាន រឯជម្ងឺឈឺចិត្ត ព្រោះតែសម្ងំរំលោកបង់បានទ្រព្យអ្នកដទៃ ជាជម្ងឺគ្មានស្លាកស្នាម តើនរណាហ្ន៎! អាចជាក់ថ្នាំរក្សាដល់ជនល្មោកបាន?" ។ កាលឥន្ទ្រាហ្ន៎ពោលដូច្នោះហើយ ទើបសំដែងឲ្យទ្រង់ជ្រាបដោយព្រះអង្គឯងថា "បពិត្រមហាក្សត្រ! មិនគួរឡើយគ្រាន់តែឮសំដីប្រាប់ប៉ុណ្ណោះ កំប៉ុះព្រះទ័យប្រាថ្នាការកន្ទំលោក លោកដោកយ៉ាងនេះទេ នេះព្រោះតែល្មោកហើយ បានជាក្លាយទៅជាប្រឈួនដ៏សាហ៊ាសស្ទើរតែអស់ព្រះជន្ម សូមព្រះអង្គទ្រង់ព្រះតម្រិះត្រិះរិះគិតមើល តើព្រះអង្គប្រាថ្នាពរដ៏សម្បត្តិនោះមកធ្វើអ្វី? ប្រសិនជាបានពរដ៏ធំធាំនោះមក តើព្រះអង្គសោយព្រះក្រយាហួសពី ១ ចំណែកឬ? មិនគួរព្រះអង្គលុះដោយអំណាចនៃសេចក្តីល្មោកដូច្នោះសោះ ។ ព្រោះថា បុគ្គលណាលោភ សំឡឹងតយតន់ប្រទ្ឋងយកទ្រព្យគេ បុគ្គលនោះរមែងខូចយសក្នុងក្នុងលោកនេះ ដូចទ្រង់ជួបប្រទះនេះឯង ទើបថាលោក សោយទុក្ខវេទនាក្នុងអបាយមានឧរគជាដើម ។

ព្រះចៅពាកណសិទ្រង់សណ្តាប់ការពោលរៀបរាប់ដោយឧទាហរណ៍ត្រមាំងនុះហើយក៏កើតព្រះប្រាជ្ញាញាណឡើងភ្លាម ប្រាជ្ញា

ញាណនោះបានដូចជាឧស្ម័នចិញ្ចឹកចាត់ខ្លួនសោក ចាត់ប្រឈួនក្នុងកាលនោះឯង ។

អកិដ្ឋា ជាគំនិតគិតអាក្រក់ លោកឱ្យឈ្មោះថា ចាប ជាអំពើមិនត្រូវគិតឡើយ ។

៩- ព្យាបាទៈ ចិត្តបង្កគំនុំគុំគួនគិតបង់ឱ្យអ្នកដទៃដល់នូវសេចក្តីវិនាស ។

ព្យាបាទនេះ បើខុកជាសេចក្តីក្រោធដែលមានសត្វដទៃជាទីតាំងហើយ ប៉ុន្តែមិនបានគិតថា "ឱ្យសត្វនោះស្លាប់ទៅចុះ" ដូច្នេះនៅឡើយទេ ខឹងចាត់ថា ព្យាបាទក៏មិនបានដែរ ។ ឯសេចក្តីក្រោធនេះជាអកុសលចិត្តពិតហើយ ប៉ុន្តែមិនមែនជាអកុសលកម្មបថទេ គឺមិនមែនជាព្យាបាទ គ្រាន់តែក្រោធខឹងប៉ុណ្ណោះ លុះតែសេចក្តីក្រោធកើតឡើងហើយ ថែមទាំងមានគំនិតគិតថា "ឱ្យសត្វនោះស្លាប់ទៅចុះ" ដូច្នេះទើបចាត់ជាព្យាបាទ ។

ព្យាបាទនេះ បើមានក្នុងសន្តានចិត្តបុរសស្ត្រីណាហើយ រមែងធ្វើសន្តានចិត្តនៃបុរសស្ត្រីនោះឱ្យកំរើកញាប់ញ័រឡើង ឱ្យប្រឹងខំប្រែលឱ្យទៅពុំបាន មានអាការៈតុះតោរឡើងជាមិច្ឆាទិដ្ឋិបង់នូវកុសលធម៌ទាំងពួង មិនឱ្យកើតឡើងបាន ហើយអាចនាំសត្វឱ្យទៅកើតក្នុងអបាយផង ។

ទោសនៃព្យាបាទនេះ ។ ភាវណាដូចជា ៖

រឿងអង្គគរប្រេត (១)

ក្នុងសម័យថ្ងៃមួយ ព្រះមហាមោគ្គលានត្ថេរ ចុះពីភ្នំគិជ្ឈកូដជាមួយនឹងព្រះលក្ខណត្ថេរ លោកបានឃើញប្រេត ១ ឈ្មោះ អង្គករៈ មានកំពស់ ៦៩ យោជន៍ មានភ្លើងឆេះស្រោចពីក្បាលរហៀសពួនខ្លួន ព្រះមោគ្គលានបានឃើញប្រេតនោះហើយក៏ញញឹម ព្រះលក្ខណត្ថេរក៏សួរពីហេតុដែលញញឹមភ្លាម ព្រះមោគ្គលានប្រាប់ថា ពេលនេះជាពេលមិនគួរទេ ចាំទៅដល់សំណាក់ព្រះសាស្តាចាំខ្ញុំប្រាប់ ។ លុះទៅដល់សំណាក់ព្រះសាស្តាហើយ ព្រះលក្ខណត្ថេរក៏ផ្តើមសួរទៀត ព្រះមោគ្គលាន ក៏ប្រាប់ថា "ខ្ញុំឃើញប្រេត ១ មានអត្តភាពយ៉ាងនេះ ។ ខ្ញុំគិតថាអត្តភាពដូច្នេះខ្ញុំមិនដែលឃើញសោះ ចានជាខ្ញុំញញឹម" ។

ព្រះសាស្តាចារ្យ ទ្រង់មានព្រះដីកាថា "ប្រេតនោះតថាគតចានឃើញតាំងពីតថាគតនៅក្នុងពោធិមណ្ឌលម៉្លេះ? ប៉ុន្តែគ្មានសាក្សីចានជាមិននិយាយ ឥឡូវនេះចានមោគ្គលានជាសាក្សីហើយតថាគតត្រូវតែនិយាយ ។ តិក្ខុទាំងឡាយក៏ក្រាបបង្គំទូលសួរអំពីបុព្វកម្មប្រេតនោះ ។ ព្រះអង្គទ្រង់សំដែងថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានៃព្រះពុទ្ធព្រះនាម កស្សប មានសេដ្ឋីម្នាក់ឈ្មោះ សុមង្គល ចានផែនាសធ្វើជាឥដ្ឋក្រាលលើផែនដីពេញ ចម្ងាយ ២០ ឧសភៈ ហើយចាត់ឲ្យ

១- ជាតកធម្មបទដ្ឋកថា ទណ្ឌវគ្គ ។

សាន់វត្តកំណាត់ត្រីមស្នើនឹងទ្រព្យដែលជាតម្លៃមាសប៉ុណ្ណោះទៀត ។

ថ្ងៃ ១ សេដ្ឋីទៅវត្តព្រឹកឃ្លានឃើញចោរម្នាក់ មានដើនប្រឡាក់កក់ដេកនៅក្បែរសៅលើសាលា ក៏លាន់មាត់ថា "មនុស្សមានដើនប្រឡាក់កក់នេះ ប្រហែលជាមនុស្សដើរកេស៊ីយប់" ។ ចោរឮហើយក៏ចង់តបទុំថា "គង់តែនឹងដឹងគ្នាទេសេដ្ឋី" ហើយក៏តាំងឮាយាមបំផ្លាញសុមង្គល. សេដ្ឋី ឯដុតស្រែកង់ស្រែ ៧ ដង កាត់ដើនគោចាំង១ាយ ៧ ដង ដុតផ្ទះ ៧ ដង សេដ្ឋីទៅតែមិនឮទឹង ចោរទៅអែបអបអ្នកបំរើសេដ្ឋីម្នាក់យកជាមិត្រយ៉ាងជិតស្និទ្ធហើយសួរថា "បេស់អ្វីជាទីពេញចិត្តសេដ្ឋី ?" អ្នកបំរើសេដ្ឋីឆ្លើយថា "មានគន្ធកុដិទើបជាទីស្រឡាញ់បេស់លោក ។ កាលព្រះសាស្តាចារ្យ នឹងភិក្ខុ-សាមណេរ ទិមន្តទៅបិណ្ឌបាតថ្ងៃ ចោរនោះចូលទៅដុតគន្ធកុដិនេះរួច ។ សេដ្ឋីបានឮថានេះគន្ធកុដិ ក៏ម្ចាស់មកមើលឃើញនេះដូច្នោះ ក៏មិនទោមនស្សសោះ ថែជាខះដៃសើចទៅវិញ ដោយត្រេកអរនឹងបានកសាងម្តងទៀត ទើបចំណាយទ្រព្យធ្វើគន្ធកុដិជាថ្មីទៀតលុះធ្វើរួចហើយ បានប្រគេនចង្ហាន់ដោយសេចក្តីរីករាយដល់ព្រះសាស្តាចារ្យ មានភិក្ខុ២ហ្មឺនជាបរិវារ ។ ចោរឃើញសេដ្ឋីធ្វើដូច្នោះហើយក៏គិតថា « បើអញមិនសម្លាប់សេដ្ឋីនេះ មុខជាមិនអាចនឹងបង្ខំនាត់បានឡើយ " ហើយក៏សៀតគាំចតបង្អឺប់ដើរទៅដើរមកក្នុងវត្តស្ទាត់ចាំសម្លាប់សេដ្ឋី អស់គំរប់ ៧ ថ្ងៃ ប៉ុន្តែកន្លងកាលមិនបានសោះ ។ សេដ្ឋីធ្វើ

បុណ្យត្រង់ ៧ ថ្ងៃហើយ ថ្វាយចង្ហុំព្រះសាស្តាក្រាបទូលថា « បពិត្រព្រះអង្គដ៏ចំរើន មានបុរសម្នាក់ដុតស្រែកន្លះស្រែ ៧ ដង កាត់ដើងគោ ៧ ដង ដុតផ្ទះ ៧ ដង ឥឡូវនេះគន្ធកុដិប្រហែលជាបុរសនោះដុតដែរ ខ្ញុំព្រះករុណាសូមចែកចំណែកបុណ្យជាបឋមដល់បុរសនោះ ។ ចោរបានឮពាក្យនោះហើយក៏គិតថា « អើហ្ន៎ ! អំពើដែលអញធ្វើនេះជាទម្ងន់ណាស់ សេដ្ឋីមិនទាន់ធ្លាប់អញបន្តិចបន្តួចសោះ បើអញមិនសូមទោសនឹងគាត់ទេ មុខជាការពិន័យរបស់ទេវតានឹងធ្លាក់លើអំបែងក្បាលអញមិនខាន ឡើយ” គិតហើយក៏ទៅក្រាបទៀបជើងសេដ្ឋីសូមទោសជាបឋមតាំងពីដំបូងដែលខ្លួនបានធ្វើទាំងអស់ សេដ្ឋីក៏និយាយថា « ពាក្យដែលខ្ញុំបានថាហួសទៅហើយនោះ ត្រូវអ្នកឯងអត់ទោសឲ្យខ្ញុំផង ខ្ញុំអត់ទោសឲ្យអ្នកឯងហើយ អ្នកឯងទៅចុះ ។ ចោរមិនព្រមទៅ សុំរួចគ្នាទៅបំរើសេដ្ឋី និយាយអង្វរសេដ្ឋីថា « បើលោកអត់ទោសឲ្យខ្ញុំបានហើយ សូមលោកមេត្តាឲ្យខ្ញុំបានព្រមទាំងកូនប្រពន្ធទាំងអស់នៅបំរើក្នុងផ្ទះលោក ” សេដ្ឋីប្រកែកថា « ណ្ហើយកុំ ! ប្រហែលពាក្យខ្ញុំពោលបន្តិចបន្តួចប៉ុណ្ណោះ អ្នកឯងបំផ្លាញខ្ញុំម្ល៉ឹងទៅហើយ ចំណង់បើអ្នកឯងនៅផ្ទះជាមួយខ្ញុំ ធ្វើម្តេចខ្ញុំហ៊ានិយាយផង ” ។

ចោរនោះ លុះស្ងាប់ទៅ ។ កើតកន្លងវិចនៈកអស់កាលជាអង្វែងដោយសេសសល់ផលកម្ម ជាមកកើតជាអជគរប្រៃនេះ ដែលមានក្លិនឆេះនៅទៀបកំពូតិដ្ឋកូដហ្នឹងឯង ។

ព្យាបាទ គឺបង្អាក់អ្នកដទៃឱ្យរំខាស លោកឱ្យឈ្មោះថា ចាប
ជាអំពើមិនត្រូវធ្វើឡើយ ។

១០ មិច្ឆាទិដ្ឋិ គំនិតយល់ខុសចាកគន្លងធម៌ពិតមែន
ពាក្យថា ទិដ្ឋិនេះ ប្រែថា "សេចក្តីយល់" បើយល់ត្រូវលោកហៅ
ថា សម្មាទិដ្ឋិ បើយល់ខុសលោកហៅថា មិច្ឆាទិដ្ឋិ ។

ក្នុងដីកាសង្គីតិសូត្រថា កិរិយាយល់ខុសហើយប្រកាន់យកថាពិត
នោះគឺតែដែលមិនទៀង យល់ឃើញថាទៀង អំពើនាំមកនូវសេចក្តីទុក្ខ
យល់ឃើញថា នាំមកនូវសេចក្តីសុខ ឱ្យទានមានផល យល់ឃើញថា
គ្មានផលវិញ លទ្ធិដូច្នេះលោកហៅថា មិច្ឆាទិដ្ឋិ ។

មិច្ឆាទិដ្ឋិមាន ២ យ៉ាងគឺ:

១- សស្សតទិដ្ឋិ យល់ថាទៀងភាត់បិតរេរ៉ា គឺជាតិនេះស្លាប់
កើតជាសត្វ ទៅលោកខាងមុខក៏កើតជាសត្វទៀតមិនប្រែប្រួល ។

២- ឧច្ឆេទទិដ្ឋិ យល់ថាគ្មាន ថាសូន្យ គឺស្លាប់ហើយមិន
កើតទៀត ។

បើបុគ្គលណាជាមិច្ឆាទិដ្ឋិហើយ បុគ្គលនោះ ទោះនិយាយក្តី ធ្វើក្តី គិត
ក្តី ក៏សុទ្ធតែខុសទាំងអស់ ។ ព្រោះមិច្ឆាទិដ្ឋិនេះ ជាឫសគល់នៃអកុសល
ត្រង់ចំពូក ។ ហេតុនេះហើយជាព្រះបរមសាស្តាទ្រង់ត្រាស់ថា ជាហំ
កិក្ខវេ អញ្ញំ ឯកធម្មំ សមនុបស្សាមិ ម្នាលភិក្ខុទាំងឡាយ!

តថាគតមិនឃើញមានធម៌ដទៃណាមួយជាហេតុ ជាឫសគល់នាំអកុសលដែលមិនទាន់កើតឡើង ឲ្យកើតឡើង នាំអកុសលដែលកើតឡើងហើយឲ្យរឹងរឹតតែកើតចំរើនឡើងដូចមិច្ឆាទិដ្ឋិនេះឡើយ ។

មិច្ឆាទិដ្ឋិនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទុកកន្លងតម្រាអង្គុត្តរនិកាយថា តថាគតស្រាវជ្រាវរកអំពើដែលមានទោសច្រើនដូចមិច្ឆាទិដ្ឋិមិនឃើញមាន មានតែមិច្ឆាទិដ្ឋិនេះឯងហើយ ដែលមានទោសច្រើនជាងគេបំផុត ។ អនន្តរិយកម្មទាំង ៥ ក៏មានទោសច្រើនដែរ តែមិច្ឆាទិដ្ឋិមានទោសច្រើនជាងនោះទៅទៀត ព្រោះអនន្តរិយកម្មមានកំណត់តែថា "ញុំាងអ្នកដែលធ្វើឲ្យកើតកន្លងនរក" ប៉ុណ្ណោះ ។ ឯទោសមិច្ឆាទិដ្ឋិ រកកំណត់មិនបានតែថា "ចាត់ជាឫសគល់នៃវដ្តៈនឹងចេញចាកភពមិនជាយរួចឡើយ" ។

កន្លងគ្រាដែលកប្បវិនាស មហាជនតែងទៅកើតកន្លងឋានត្រហ្មលោកទាំងអស់គ្នា ប្លែកតែជនមិច្ឆាទិដ្ឋិមិនបានកើតកន្លងទីនោះនឹងគេទេ ហើយជាទៅនេះកន្លងលោកន្តរនរក ដែលក្នុងប្រលយកប្បនេះមិនដល់ឯណោះទៅវិញដោយកម្មាឯកម្មវេបក់ខ្លួន ។

(នៅមានត)

ឥន្ទ្រិយយមក

ពាវីសតិន្ទ្រិយានំ ឧសេ្សន្តោ យមកំ យមកំ ឧសេ្សត្វា ចក្ខុ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយំ ចក្ខុតំ អាទិកំ អាបុច្ឆនំ កត្វា អាមន្តាតិ វិសជ្ជេត្វា ឥន្ទ្រិយំ យមកំ ឧសេ្សសិ ។

លំដាប់នេះ សូមវិសជ្ជនាកង់ឥន្ទ្រិយយមកតទៅ ដំណើរសេចក្តីថា លោកនាថោ សម្តេចព្រះបរមលោកនាថ កាលទ្រង់ត្រាស់ទេសនាធម្មយមកចប់ហើយ ក៏លំដាប់នោះទើបទ្រង់ត្រាស់ទេសនាឥន្ទ្រិយយមក សំដែងដោយឥន្ទ្រិយ ២២ ប្រការតទៅទៀត ។

ឯឥន្ទ្រិយ ២២ ប្រការនោះ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ១ បុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិ-

ន្ត្រើយ ១ សមាធិន្ត្រើយ ១ បញ្ញាន្ត្រើយ ១ អនញ្ញតញ្ញស្សាមីតន្ត្រើយ ១ អញ្ញាន្ត្រើយ ១ អញ្ញាតាវិន្ត្រើយ ១ គ្រប់ជាតន្ត្រើយ ៦៦ ប្រការ ។

កាលព្រះអង្គត្រាស់ទេសនាតន្ត្រើយ ៦៦ ប្រការនោះ យមកំ យមកំ ឯសេ្ឋត្វា ទ្រង់ត្រាស់ទេសនាជាគូ ។ គ្នា គឺត្រាស់បុច្ឆាក៏ជាគូ វិសជ្ជនាក៏ជាគូ ត្រាស់បុច្ឆាជាអាទិ៍ថា ចក្ខុ ចក្ខុន្ទ្រើយំ ចក្ខុ នោះឬឈ្មោះចក្ខុន្ត្រើយ? ចក្ខុន្ត្រើយនោះឬឈ្មោះថា ចក្ខុ? ជាលំដាប់ដកចេញដល់ អញ្ញាតាវិន្ទ្រើយ ។

ត្រាស់បុច្ឆាជាគូ ។ ដូច្នេះហើយ ទើបត្រាស់វិសជ្ជនាជាគូ ។ រៀងគ្នាទៅថា អាមន្តា អើ! ចក្ខុនោះឯងឈ្មោះថាចក្ខុន្ត្រើយ ចក្ខុន្ត្រើយនោះឯងឈ្មោះថាចក្ខុ ជាលំដាប់ដកចេញដល់ អញ្ញាតាវិន្ទ្រើយ ។

មានពាក្យអធិប្បាយថា សភាវៈណាធ្វើឲ្យជាធំក្នុងការយើញរូប សភាវៈនោះហៅថា ចក្ខុន្ត្រើយ ក្នុងការស្តាប់នូវសំឡេងហៅថា សោតន្ត្រើយ ក្នុងការហិតក្លិនហៅថា ឃានន្ត្រើយ ក្នុងការលិទ្ធភក្សរសហៅថា ជិវ្ហាន្ត្រើយ ក្នុងការពាល់ត្រូវហៅថា កាយន្ត្រើយ ក្នុងការដឹងនូវអារម្មណ៍ផ្សេង ។ ហៅថា មនិន្ត្រើយ ។

សភាវៈណាធ្វើរូបកាយអាកប្បកិរិយា ទំង៏ ឥត្ថិលិង្គ ឲ្យកើតច្រើនដង សភាវៈនោះឈ្មោះថា ឥត្ថិន្ត្រើយ ។

សភាវៈណាធ្វើរូបកាយអាកប្បកិរិយា ទំង៏ បុរិសលិង្គ ឲ្យកើត

ប្រាកដ សភាវៈនោះឈ្មោះថា បុរិសិន្ទ្រិយ ។

អត្ថន្ទ្រិយនោះ ជានធិដ្ឋេយ្យនៃស្ត្រី ។ បុរិសិន្ទ្រិយនោះ ជានធិដ្ឋេយ្យនៃបុរស ។ កេរស្ត្រីនិងកេរបុរសទាំងពីរនេះ កើតមានដល់សត្វទាំងឡាយក្នុងបឋមកប្ប តែតាំងពីចាប់កកើតកប្បឡើងជាដំបូងហើយមានតគ្នាជាលំដាប់ដរាបមកដល់សត្វថ្ងៃនេះ ។ លុះចំណេរយូរមក កេរបុរសនិងកេរស្ត្រីនេះផ្ទាស់ប្តូរគ្នាទៅវិញទៅមក សមតាមភាសាព្រះអដ្ឋកថាចារ្យសំដែងក្នុងវិនយបិដកថា សម្តេចព្រះមានព្រះភាគទ្រង់បញ្ញត្តឲ្យនាងភិក្ខុនីដែលមានកេរស្ត្រីត្រឡប់ជាបុរសនោះ ឲ្យនៅជាមួយពួកភិក្ខុបាន ព្រោះកេរនៃនាងភិក្ខុនីនោះបាត់ហើ ។

ឥត្ថីលិង្គំ ហីនំ កេរស្ត្រីជាកេរថោកទាប ព្រោះហេតុថា ស្ត្រីបើប្រាថ្នាជាពុទ្ធភូមិ ត្រូវប្រាថ្នាឲ្យកើតជាបុរសមុនសិន ទើបសេចក្តីប្រាថ្នានោះបានសម្រេច បើមិនកើតជាបុរសទេ ប្រាថ្នាជាពុទ្ធភូមិមិនបានសម្រេចឡើយ ។

ឥលវអកុសលេន ចំណែកកេរប្រុសនិងត្រឡប់ទៅជាកេរស្ត្រីវិញនោះដោយកម្លាំងអកុសលកម្ម ។ ឯកេរស្ត្រីនិងត្រឡប់ទៅជាកេរបុរសវិញនោះដោយកម្លាំងនៃកុសលកម្ម ។ ដូចព្រះសោរេយ្យត្ថេរកាលដើមឡើយលោកជាបុរសមានប្រពន្ធហើយមានកូនពីរនាក់ ។ ថ្ងៃមួយលោកបានទៅជួបនឹងព្រះកស្សបសម្មាសម្ពុទ្ធ ក៏កើតចិត្តប្រតិព័ទ្ធស្នេ-

ហាតិតថា ឆ្នើម្តេចនឹងបានព្រះថេរអង្គនេះមកជាប្រពន្ធអញ ឬមួយឆ្នើម្តេចនឹងឲ្យបានប្រពន្ធអញមានរូបកាយល្អល្អះដូចជាលោកម្ចាស់នេះ ក្នុងលំដាប់នៃចិត្តគិតដូច្នេះ កេរស្ត្រីក៏កើតមានច្រើនដងឡើង តើថាកាយខ្លួនឯងជារូបពងតាយស្ត្រីក្តាម លែងជារូបពងបុរស ។

សោរេយ្យសេដ្ឋីបុត្រ ដឹងថាខ្លួនក្លាយទៅជាស្ត្រីហើយ ក៏ទឹកអៀនខ្មាសគេណាស់ មិនហ៊ានលៃទៅនៅផ្ទះជាមួយប្រពន្ធកូនវិញ ទើបរត់ចេញពីស្រុកទៅនៅកន្លែងតវតេក្កសិលា មានប្តីហើយបានកូនតាំងពោះដែលកើតចេញពីទ្រូងរបស់ខ្លួន ។

ខាងក្រោយមក នាងក្លាយកេរនេះ បានទៅសួរទៅមាគោសនឹងព្រះកច្ចាយនត្ថេរ ដោយដឹងគោសរបស់ខ្លួនថា ស្រឡាញ់លោកតាំងពីមុនមកនោះកេរស្ត្រីក៏អន្តរធានបាត់ទៅ កើតកេរបុរសដូចដើមឡើងវិញ មានចិត្តខឿយណាយក្នុងឃរាវាស ទើបចូលបួសក្នុងព្រះបវរពុទ្ធសាសនាបានសម្រេចព្រះអរហត្ត ។ សូម្បីលោកជាបច្ចេមកវៃកសត្វ តើបានអរហត្តក្នុងជាតិនោះ ក៏នៅតែក្លាយកេរបុរសទៅជាកេរស្ត្រីក្នុងបច្ចុប្បន្នភាន់ក្អែកដោយអំណាចកម្មាំងអកុសលចិត្ត ដែលប្រមាទព្រះកច្ចាយនត្ថេរនោះ ។ ប៉ុន្តែគោសនេះស្រាលអាចសួរមាគោសរួច ។

មានពាក្យព្រះអដ្ឋកថាចារ្យពោលក្នុងអនុមតគ្គសំយុត្តថា ការដែលស្ត្រីទៅកើតជាបុរស ឬបុរសទៅកើតជាស្ត្រីក្តី ស្ត្រីទៅកើតជាបុរសក្តី

ឯកមេត្តំ ហោតុចាំដ៏ពីរប្រការនេះ ទំដ៏ពាប់ទំដ៏ប្រមាណមិនបានទេ ដ្ឋនកាលកើតជាបុរសក្នុងចក្រវាឡនេះ ទៅកើតជាស្ត្រីក្នុងចក្រវាឡដទៃ ក៏មាន ដ្ឋនកាលកើតជាស្ត្រីក្នុងចក្រវាឡដទៃ មកកើតជាបុរសក្នុងចក្រវាឡនេះក៏មាន ចេះតែប្រែប្រួលផ្លាស់ប្តូរគេទៅមកយ៉ាងនេះ ទំដ៏ពាប់ក៏ណាត់ជាតិពុំបានឡើយ ។

ឯជាតិត្រៃយ៍នោះ បានទំដ៏ការធ្វើឲ្យជាធំក្នុងកិច្ចចំពោះមុខឲ្យសត្វរស់នៅបាន ។

សុខិត្រៃយ៍នោះ បានទំដ៏សការៈជាធំក្នុងកិច្ចនាំឲ្យបានសុខ ។

ទុក្ខិត្រៃយ៍នោះ បានទំដ៏សការៈជាធំក្នុងកិច្ចនាំឲ្យបានទុក្ខ ។

សោមនស្សិត្រៃយ៍នោះបានទំដ៏សការៈជាធំក្នុងការធ្វើនូវសោមនស្សគឺធ្វើឲ្យសត្វចាំដ៏ឡាយមានចិត្តល្អ ។

ទោមនស្សិត្រៃយ៍នោះ បានទំដ៏សការៈជាធំក្នុងការធ្វើនូវទោមនស្សគឺធ្វើឲ្យសត្វសត្វមានចិត្តគាក់មន់ឬតូចចិត្ត ។

ឧបេក្ខិត្រៃយ៍នោះ បានទំដ៏សការៈជាធំក្នុងលក្ខណៈឧបេក្ខា ។

សទ្ធិត្រៃយ៍នោះ បានទំដ៏សការៈជាធំក្នុងការចាំឲ្យកើតសទ្ធា គឺជឿក្នុងព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណ ទំដ៏ជឿក្នុងផលសីលផលទានជាការកុសលចាំដ៏ពួន ។

វីរិយិត្រៃយ៍នោះ បានទំដ៏សការៈជាធំក្នុងលក្ខណៈនៃការលើកឡើង

ន្ទរចិត្តកាន់ការម្មណ៍ មិនឲ្យរួញរាក្នុងការកុសល ។

សតិន្ទ្រៀយ៍នោះ ឋានន័យសភាវៈជាធំក្នុងលក្ខណៈនៃការនឹករឭក មានសតិបដ្ឋាន ៤ នឹងអនុស្សតិ ១០ ជាដើម ។

សមាធិន្ទ្រៀយ៍នោះ ឋានន័យសភាវៈជាធំក្នុងសមាធិ គឺការតាំងចិត្តមាំមិនឋានញាប់ញ័រដោយយកិលេស នឹងមិនឋានញាំងចិត្តឲ្យអណ្តែតអណ្តូង ។

បញ្ញិន្ទ្រៀយ៍នោះ ឋានន័យសភាវៈជាធំក្នុងលក្ខណៈនៃការពិចារណាឃើញដោយបញ្ញា ដោយកំណត់មានកង្វល់ចំផុត ការដែលឃើញដោយកម្មស្សកតាញ្ញាណ ។

អនញ្ញាតញស្សាមិតិន្ទ្រៀយ៍នោះ ឋានន័យសភាវៈជាធំក្នុងលក្ខណៈនៃការដឹងដោយអកិញ្ចាច្រាំមួយប្រការ ។

អញ្ញិន្ទ្រៀនោះ ឋានន័យសភាវៈជាធំក្នុងការដឹងនូវត្រៃវិជ្ជ ។

អញ្ញាតាវិន្ទ្រៀយ៍នោះ ឋានន័យសភាវៈជាធំក្នុងការត្រាស់ដឹងនូវបញ្ញាក្នុងអរិយមគ្គ អរិយផល ។

ក្នុងសុត្តន្តភាជនីយ សម្តែចព្រះបរមគុរុសពលមិនឋានត្រាស់ទេសនានូវឥន្ទ្រៀយ៍ទាំង ២២ ប្រការនោះទេ ក្នុងសូត្រខ្លះ ច្រើនត្រាស់សំដែងតែឥន្ទ្រៀយ៍ពីរប្រការ បីប្រការ ច្រាំប្រការ ។ ឯឥន្ទ្រៀយ៍បីប្រការខាងចុងចំផុត គឺអនញ្ញាតញស្សាមិតិន្ទ្រៀយ៍ ១ អញ្ញិន្ទ្រៀយ៍ ១ អញ្ញាតាវិន្ទ្រៀយ៍ ១ ច្រើនសំដែងចំពោះតែកង្វល់បរមត្ថ ។ ឥន្ទ្រៀយ៍ ៦ ប្រការមានចក្ខុន្ទ្រៀយ៍ជាដើម

មានមតិទ្វេយ៍ជាបរិយោសាន ទ្រង់សំដែងទាំងក្នុងព្រះសូត្រ ទាំងក្នុងព្រះបរមត្ថ ទាំងក្នុងព្រះវិន័យ ។ ឥន្ទ្រិយ ៥ ប្រការ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ទ្រង់សំដែងកប់បញ្ចាលកងពោធិបក្ខិយធម៌ គឺធម៌ជាចំណែកនៃពោធិ ជាហេតុនឹងឲ្យត្រាស់ដឹងនូវព្រះអរិយមគ្គ អរិយផល ។

សម្តេចព្រះបរមគុរុទ្រង់សំដែងនូវឥន្ទ្រិយ ២២ ប្រការដោយទ្រង់ប្បញ្ញត្តិនីវិសជ្ជនាជាគូៗគ្នា ទើបឈ្មោះថាឥន្ទ្រិយយមក ។

កាលព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនានូវគម្ពីរយមកនេះ ចាត់ជាព្រះធម្មក្ខន្ធច្រាំពាន់មួយរយព្រះធម្មក្ខន្ធ ទ្រង់ត្រាស់ទេសនា ១៨ ថ្ងៃទើបចប់ ខ្ញុំតាបានសម្រេចព្រះអរិយមគ្គអរិយផល មានប្រមាណ ៧ កោដិកន្លះ យមកបករណាវសានកាល គឺកាលចប់គម្ពីរយមក ។

ធម្មិរយមកៈ ចប់ប៉ុណ្ណេះ ។

គម្ពីរព្រះមហាបដ្ឋាន

យមកំ នាម បករណំ ឧស្សន្នា សម្មាសម្ពុទ្ធោ មហាបដ្ឋានំ ឧស្សន្នោ អនន្តនយមណ្ឌិតំ ចតុវីសតិបច្ចយំ ហេតុបច្ចយោតិ អាទិ អារទ្ធោ កថយីតិ ។

លំដាប់នេះ សូមវិសជ្ជនាកន្លះគម្ពីរព្រះមហាបដ្ឋានតទៅ ដំណើរសេចក្តីថា សម្មាសម្ពុទ្ធោ សម្តេចព្រះមានព្រះភាគព្រះអង្គត្រាស់ដឹង

ខ្លួនបានត្រាស់ដឹងដោយព្រះអង្គឯង ពុំមានបុគ្គលណាជាគ្រូអាចារ្យប្រៀនប្រដៅ ដោយអាការដ៏ល្អគឺមិនបានវិបរិតឧស្សាហ្វា ព្រះអង្គត្រាស់ទេសនាខ្លួនតម្ពីរព្រះយមកចប់ហើយ ក្នុងលំដាប់នោះ ទើបត្រាស់ទេសនាខ្លួនតម្ពីរព្រះមហាបដ្ឋានតទៅ ដ៏ប្រដាប់ដោយន័យពុំមានទីបំផុត មានបច្ចុយ ២៤ ប្រការ មានន័យជ្រាលជ្រៅឆ្ងាយខ្លួលាយជាងតម្ពីរពាំង ៦ ខាងដើម ។

ឯតម្ពីរព្រះមហាបដ្ឋានអនន្តន័យជាគំរប់ ៧ នេះ មានអត្ថដ៏ល្អិតសុខុមតម្ពីរកាពជ្រាលជ្រៅជាងព្រះសព្វញ្ញុតញាណ ដែលមានក្នុងព្រះត្រៃបិដក សិនេះទុ វិយ បើដូចសិនេះបពិត ពុំនោះសោតដូចជាមហាសមុទ្រពាំងបួនជ្រៅជាងមហាទឹ ទឹងជាទីអាស្រ័យនៅនៃសត្វរាវជាតិតូចធំ ។ ព្រះមហាបដ្ឋាននោះជាវិស័យនៃព្រះសព្វញ្ញុសម្ពុទ្ធប្រចាំព្រះអង្គ មិនមែនជាវិស័យនៃព្រះសាវកពាំងបួនទេ ។

(នៅមានត)

សម្តែងព្រះធម្មទេសនា ល្ងី-ឯម ប្រៃរៀបរៀង

(តមក)

ព្រះសារីបុត្តថេរៈ លោកបានទទួលថាយាស ហើយក៏ញុំាងមនុស្ស
សួរសុខទុក្ខរវែងដល់បុរសនោះ ហើយនិមន្តត្រឡប់ទៅកាន់ព្រះវិហារវិញ។
ក្រោយពីនោះមក ចោរឃាដកាមាត្យ មានសេចក្តីរំលឹករឿយៗ នូវគុណ
ដែលបានបួសជាដល់ព្រះថេរៈ ហើយធ្វើមរណកាលក្នុងក្រយៅដីវិតទៅកន្លង
ទៅណោះ ក៏បានទៅកើតក្នុងស្ថានសួគ៌ទេវលោកសោយទិព្វសម្បត្តិ
ប្រកបដោយស្រីទេពអប្សរមានប្រមាណច្រើន ចោមរោមជាបរិវារយ៉ាងរីករាយ
ប្រក្រតី ដោយផលនិសង្សនោះឯង។ ឧហ្ម៎ មុខគួរអស្ចារ្យពេកណាស់
កំណាំងអានុភាពនៃបុគ្គលដែលមានពាក្យកិលេសប្រាសចេញហើយ អាច
ញុំាងសត្វលាមកអ្នកមានជាបស្ងាប់ហើយគួរនឹងទៅកើតក្នុងនរក នេះ
ត្រឡប់ឲ្យទៅកើតក្នុងស្ថានសួគ៌វិញបាន ដោយអំណាចសេចក្តីព្យាយាម
របស់ព្រះមហាថេរៈនោះឯង។ ហេតុដូច្នេះ បានជាមានសុភាសិត
ជាបទគាថាថា:

ធានំ តាណំ មនុស្សានំ ធានំ ទុក្ខតិតារណំ
ធានំ សគ្គសុខ សោចាណំ ធានំសន្តិករំបរំ ។

អធិប្បាយថា ទានជាទីពឹងផ្នែកនៃមនុស្សទាំងឡាយ ទានអាចឃាត់

ឃាំងកំឆ័កមិនព្រមឲ្យទៅកាន់ខុត្តតំបន ពានក្រាកដស្មើដូចជរណ្តើរកែវ ឡើងទៅកាន់ស្ថានសួគ៌ ពានដ៏ទុត្តម អាចធ្វើម្ចាស់ពានឲ្យរលត់ទុក្ខពាំង ពួងបានដោយពិត ។

ឥច្ចិតិច្ចិតធានេន ឆាំ ចិន្តាមណី វិយ
កប្បរុក្ខោ សន្តានំ ឆានំ កត្តុយដោវិយ

ពានបីដូចជាកែវចិន្តាមណី អាចឲ្យសម្រេចសេចក្តីប្រាថ្នាពាំងពួង តាមចិត្តនឹក ពុំខោះសោតបីដូចជាដើមកប្បព្រឹក្ស អាចឲ្យសម្រេចសម្បត្តិ ពាំងពួងដល់សត្វនិករទូទៅ ពានបីដូចជាឆ្នាំងដ៏ពេញដោយថ្នាយជាទិព្វ អាចផ្តល់ឲ្យដល់សត្វពាំងឡាយបានដោយពិត ។

លីលាវន្តសរ្ឋ ឆានេន ចក្កាវត្តិសិរិមរ្ឋិច
លភន្តិ សក្កសម្បត្តិ តថា លោកុត្តរសុខំ ។

មួយវិញទៀត ជនពាំងឡាយ តែងបានសោយសម្បត្តិជាស្តេចចក្រ-ពត្តិដ៏មានសិរីសួស្តីក្តី បានសោយទិព្វសម្បត្តិជាព្រះឥន្ទ្រាធិរាជក្តី ក៏បាន ដោយពានដែលខ្ជួនបានឲ្យដល់បុគ្គលអ្នកមានសីលដោយពិត ឬថាជន ពាំងឡាយតែងបានខ្ជួរលោកុត្តរសុខ គឺសេចក្តីសុខជាលោកុត្តរសម្បត្តិក៏ ក៏បានដោយផលពានជាដើមនោះដែរ ។

ចាបកាម្មេសុ ឆិរត្តោ បិតោយំ នរកាយរេ
សាវីបុត្តស្ស ថេរស្ស បិណ្ឌចាតស្ស កំសាសា

អថាយំ បវិវេច្ចិត្វា នេតំ ទុក្ខសមាកុលំ
នេវសំយមបរិភុញ្ជា តតោ នេវបុនំ វរំ ។

ចោរយោដកាមាត្យនេះ ស្ថិតនៅជាទិច្ចតែក្នុងចិត្តបាបកម្មចាំងឡាយ ទំនត្រូវទៅស្ថិតនៅក្នុងឋានទុគ្គតិ ដោយពិត តែបែរអាចរៀបចាកអបាយទុក្ខបាន ព្រោះហេតុបានថ្វាយបិណ្ឌបាតព្រះថេរៈព្រះនាមសារីបុត្ត ។ ទានដែលចោរយោដកាមាត្យបានធ្វើ ជាអំពើមិនប្រឡែលាយដោយសេចក្តីទុក្ខឡើយ ។ ដោយផលានិសង្សបិណ្ឌបាតទាននេះ ចោរយោដកាមាត្យបានឡើងទៅកាន់ទេវបុរីដ៏ប្រសើរ សឹងមានពួកទេវតាចោមរោមជាបរិវារជាសុខសប្បាយពិត ។

តស្មា សុខេត្តេ សទ្ធាយ ទេយ្យ ធាជានិ តាមិនំ
វត្តិតព្វា សីលម្បិ ផលនញ្ចាតិសុន្ទរំ ។

ព្រោះហេតុនោះ សប្បុរសចាំងឡាយត្រូវតែឲ្យទាន ដែលជាគុណគាចឲ្យសម្រេចប្រយោជន៍ដល់បុគ្គលជាស្រែបុណ្យល្អ តាមចិត្តសទ្ធាដោយពិត ត្រូវតែរក្សាសីល (តាមកាលគួរ) ទាននឹងសីលនេះជាធម្មជាតមានផលល្អក្រៃលែង ។

កាលនោះ តិក្ខចាំងឡាយបានចូលមកប្រជុំគ្នាក្នុងកោងធម្មសភា បានលើកឧញ្ចាលើងថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ទើបក្រាបបង្គំទូលថា: បពិត្រព្រះមានព្រះភាគដ៏ចំរើន! បុរសដ៏លាមក

ដូចពោរយោជកាមាត្យនោះ តើនឹងទៅកើតក្នុងអបាយណាព្រះអង្គ ព្រះបរមសាស្តាជាម្ចាស់ ទ្រង់ត្រាស់ព្យាករណ៍ថា ម្នាលភិក្ខុទាំងឡាយ បុរសនោះបានទៅកើតក្នុងស្ថានទេវលោកហើយ ដោយអានុភាពនៃទានដែលបុរសនោះបានថ្វាយដល់ព្រះសារីបុត្តក្នុងថ្ងៃនេះឯង មួយទៀតសោតលុះអម្មុងយូរទៅនាអនាគតកាល បុរសនោះនឹងបានត្រាស់ដឹងជាព្រះបច្ចេកពុទ្ធមួយព្រះអង្គ ដោយអំណាចផលនិសង្សដែលហូរជូនមកពុំដាច់នោះដោយពិត ។ លុះព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងយ៉ាងនេះហើយ ក៏ទ្រង់ប្រកាសជាបន្តាថាដូចនេះថា :

កោ សារិបុត្តនិហិតសទ្ធោ
ខណេន ទាបេតិ ច សក្កមគ្គំ
តស្មា សុខេត្តេសុ ទទាថ ទានំ
កាមត្តកំ សក្កបទម្បត្តេ ។

អធិប្បាយថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ការថ្វាយអាហារបិណ្ឌបាត្រ មានប្រមាណតិចដែលបុរសអ្នកសំឡាប់ចោរ បានថ្វាយហើយដល់ព្រះមហាសារីបុត្ត ក៏តងឹអាចញុំាង ឲ្យបានដល់នូវស្ថានសួគ៌ទេវលោកមួយរំពេច ព្រោះហេតុដូចនោះ អ្នកទាំងឡាយត្រូវតែឲ្យទានដែលជាគុណញុំាងសេចក្តីប្រថុថ្នាឲ្យសំរេច ជាទីបាយទៅកាន់ស្ថានសួគ៌ឯទេវលោក ចំពោះបុគ្គលអ្នកមានសីល ពុកដូចស្រែដ៏មានជីជាតិល្អដោយពិត។

សម្តែងរឿងនិទានបុរសអ្នកសំឡាប់ចោរ ជាគំរប់ប្រាំមួយក្នុងវគ្គទី ប ក៏ចប់សេចក្តីជាសង្ខេប តែប៉ុណ្ណោះឯង ។

៣- សង្ខេបាសការវត្តកថា

សម្តែងរឿងនិទានឧបាសកម្នាក់ អ្នកមានសទ្ធាតទៅខ្លៅ ដោយ ពាក្យថា: អតីតេ ពារាណសិយំ ឧបាសកោ ដូចនេះ ជាដើម អធិប្បាយថា បានឮរឿង ។ មកថា កាលអតីតកាលកន្លងទៅយូរ ហើយ ក្នុងដំណាក់សាសនានៃព្រះសព្វញ្ញុពុទ្ធ ទ្រង់ព្រះនាមកស្សប: នោះ មានបុរសម្នាក់ អ្នកមានសទ្ធាជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ តែងចំណីមជាតិ ដោយការស៊ីឈ្នួលគាបអំពៅ គាត់នៅអាស្រ័យក្នុងក្រុងពារាណសីនោះឯង ។

មានកាលមួយថ្ងៃ បុរសនោះបានឃើញកំពុមួយរូបមានជម្ងឺ គាត់បានប្រគេនសប្បិប្រមាណមួយវែកដល់កំពុនោះ ដល់ថ្ងៃមួយទៀត បានប្រគេនស្ករអំពៅមួយដុំ ដល់កំពុមួយរូបដទៃ អ្នកមានជម្ងឺដូចមុននោះដែរ ថ្ងៃជាខាងក្រោយទៀត បានឃើញសុខ១ (ឆ្កែ) មួយកាអត់ចាយ កំសោយ ចាយពន់ពេក គាត់មានចិត្តមេត្តា បានឱ្យចាយមួយដុំលុមស៊ីឆ្អែតដោយអនុគ្រោះដល់ឆ្កែនោះ ។ មិនតែប៉ុណ្ណោះ បានឱ្យហិរញ្ញវត្ថុមួយកហាបណៈ ដល់បុរសម្នាក់ អ្នកជំនាក់បំណុលគេដោយសេចក្តីអាសូរ ។ អង្គ.

និវសំ លុះដល់ថ្ងៃមួយជាខាងក្រោយទៀត បុរសនោះបានចូលស្តាប់ព្រះធម៌ទេសនា កំពុងសេចក្តីជ្រះថ្លាហើយបានបូជាសំពត់សាដកមួយដល់ធម្មចិកវដែលសម្តែងព្រះធម៌ទេសនានោះឯង ។

ឯបុរសនោះ បានធ្វើបុណ្យដូចបានពណ៌នាប៉ុណ្ណេះហើយ បានតាំងប្រណិធាន សេចក្តីថ្នាថ្នូដូចនេះថា កាលបើខ្ញុំអន្ទោលទៅកន្លងភពតួចធំនានា បណ្តាតែតាំងឡាយដែលមានទៅកន្លងសមុទ្រទឹងក្តីជាដើម ប្រសិនបើខ្ញុំថ្នាតែណា ។ ហើយ កំសូមតែនោះ ។ សំរេចតាមថ្នាថ្នារបស់ខ្ញុំដោយពិត ។

លុះចំណេរកាលមកជាខាងក្រោយ បុរសអ្នកមានសទ្ធានោះកំពុងមរណកាលក្បែរណាស្រាប់ដែរហើយ បានទៅកើតក្នុងស្ថានទេវលោកនាយមួយរំពេច ដូចជាភ្ញាក់អំពីដេកលក់ដូច្នោះ បានសោយទិព្វសម្បត្តិយ៉ាងធំប្រសើរក្នុងស្ថានទេវលោកនោះឯង លុះអស់កំណត់អាយុទិព្វហើយក៏ច្យុតអំស្ថានទេវលោកនោះ ចុះមកចាប់បដិសន្ធិកើតក្នុងត្រកូលព្រាហ្មណ៍មហាសាល ដ៏ស្តុកស្តម្ភមាំមួនមានទ្រព្យសម្បត្តិច្រើន ក្នុងទសវត្តិជំនាន់តុ្ងកាលនៃព្រះមានព្រះភាគជាម្ចាស់នៃយើងនេះឯង ។

លុះប្រសូតិចេញអំពីផ្ទៃមាតាហើយ ក៏បានចំរើនវ័យរឹងប៉ឹងក្លាហ៊ានឡើងហើយ តែងចូលទៅកាន់វត្តស្តាប់ធម៌ទេសនាអស់កាលតាំងតួនហើយបានឮទូរទោសក្នុងឃពាសនេះ ទូរអាងសង្ឃក្នុងការចេញបួសនេះ

ចានសុំអនុញ្ញាតអំពីសំណាក់មាតាបិតាហើយ ទើបចេញទៅបួសក្នុងព្រះពុទ្ធសាសនា ។ លុះបានបួសរួចហើយតាំងប្រាំខែ បានចំរើនសមាធិកម្មដ្ឋាន កំបានសម្រេចព្រះអរហត្ត កំចាត់បង់នូវកិលេសទាំងពួងជាស្រេច ព្រមទាំងបដិសម្ភិទាញាណជាអគ្គព្រះអរហន្ត វិសេសកក្នុងលោក ។

លំដាប់តពីនោះមក ព្រះថេរៈអគ្គនោះកំបានថ្វាយបង្គំលាព្រះសាស្តាចារ្យជាម្ចាស់ហើយចេញទៅអំពីវត្តព្រះជេតពន មានព្រះតម្កុសង្ឃប្រមាណប្រាំរយអង្គចោមរោមជាយសបរិវារ ទំមន្តទៅកាន់ទុត្តនគរ ។ កំឯកង៏ទុត្តនគរនោះ មានកំរោសេដ្ឋីម្នាក់ជាស្ត្រីមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានឃើញព្រះថេរៈអគ្គនោះព្រមទាំងព្រះសង្ឃប្រាំរយអង្គជាបរិវារទំមន្តចូលមកដើម្បីបិណ្ឌបាត្រចង្ហាន់ កំមានសេចក្តីជ្រះថ្លារួសរាន់ម៉ឺងម្នាទទួលយកបាត្រអំពីព្រះហស្តព្រះថេរៈ ហើយប្រគេនចង្ហាន់ចំពោះព្រះថេរៈព្រមទាំងព្រះសង្ឃប្រាំរយអង្គ ទំមន្តធានាក្នុងគេហស្ថានរបស់ខ្លួនខោះឯង ។ លុះព្រះសង្ឃធ្វើកត្តកិច្ចធានាស្រេចហើយ នាងកំអាចធនាទំមន្តព្រះថេរៈព្រមទាំងព្រះសង្ឃទាំងនោះដើម្បីទទួលចង្ហាន់ក្នុងគេហដ្ឋានរបស់នាងតទៅដរាប ហើយនាងបានចាត់ចែងចំណាយទ្រព្យឲ្យជាងស្ថាបនាអគារស្ថានប្រមាណប្រាំរយខ្នង ព្រមទាំងតាក់តែងសម្ភារៈគ្រប់ប្រដាប់ប្រគេនព្រះសង្ឃទាំងអស់នោះ ហើយបាវណាឲ្យគង់នៅអាស្រ័យក្នុង

សេនាសនៈនោះឯង នាងបានគោរពប្រតិបត្តិបំរើព្រះសង្ឃចាំងអម្បាលនោះ ដោយបច្ច័យបួនជាប់តុំជាប់ឡើយ ។

លំដាប់នោះ ព្រះថេរៈបានញ៉ាំងសេដ្ឋកិរិយានោះឲ្យប៉ិនប៉ៅក្នុងបញ្ចសីលដ៏ខ្ជាប់ខ្ជួនតទៅដរាប ហើយលោកគង់នៅក្នុងទីនោះសមគួរតាមកាល ។ លុះថ្ងៃជាខាងក្រោយ ព្រះថេរៈមានប្រាថ្នាទីងមន្តនៅក្នុងទីដទៃ លោកបានទាំកភ្នំចាំងប្រុំរយជាបរិវារចេញទៅកាន់បដន្តរាមតាមលំដាប់ទីមិត្តតែបានដល់ហើយក៏គង់នៅអាស្រ័យក្នុងស្រុកនោះ តុំចាន់បានយូរប៉ុន្មាន ក៏ទីមន្តឡើងកាន់សំពៅចេញអំពីបដន្តរាមនោះទៀត ព្រមចាំងភិក្ខុប្រុំរយជាបរិវារបើកធ្លងសមុទ្រសំដៅទៅកាន់ត្រើយខាងនាយ ។ កាលព្រះថេរៈទីមន្តទៅដល់ពាក់កណ្តាលសមុទ្រ ស្រាប់តែមានទុទរវាត (ភេតខ្យល់) ចាប់សឹកសៀតកើតឡើង បៀតបៀនព្រះថេរៈឲ្យបានទុក្ខវេទនាជាខ្លាំងម្ល៉ង់ ។

ឯភិក្ខុចាំងឡាយ បានឃើញដូច្នោះហើយ ក៏ទូលសួរព្រះថេរៈថា: បពិត្រលោកដ៏ចំរើន កាលពីមុន ។ បើភេតនេះកើតឡើងដល់លោកម្ចាស់ហើយតើ រម្ងាប់ទៅវិញដោយថ្នាំអ្វី ?

(នៅមានត)

ព្រះសាស្តាមុន្តិ តាំម-ភ្នុរ ពន្ធនាគារ

(តមក)

អតីតកថំ ឮដំកាលនោះ មានកាលសម័យថ្ងៃមួយក្តី អាចារ្យកេវដ្តព្រាហ្មណ៍ រមិលមើលមុខគ្នុះកញ្ចក់តាំលយល់ស្រមោលស្នាមដំបៅនោះឮដំថាសនោះហើយ គិតក្នុងចិត្តថា ស្នាមនេះ ដែលមហោសថបុត្រគេហាចតិកធ្វើអាត្មាហើយ អាចារ្យកេវដ្តព្រាហ្មណ៍ទើមមាំមាក្រពេក ដូច្នេះខ្លួនចំឡែកខ្លាស់អស់ស្តេចមួយរយទើមមួយ ទើបអាចារ្យកេវដ្តព្រាហ្មណ៍មកត្រិះរិះគិតតែក្នុងចិត្តឯងថា កាលណាហ្ន៎! អញនឹងបានឃើញខ្នងនៃស្តេចនោះ? លុះគិតហើយថា បើដូច្នោះមានតែអញទៅធ្វើទុក្ខយកលយកកូនស្រីនៃស្តេចយើង ឈ្មោះនាងបញ្ចាលចន្ទី នាងនោះជាទីគ្រេគ្រងនូវរូបឆោមទុតមណ្ឌដូចស្ត្រីសួគ៌ អញចង្អាញនាងនោះឲ្យស្តេចវិទេហរាជមើល ហើយអញនឹងប្រលោមស្តេចវិទេហរាជ ដោយនូវគាមគុណថា យើងនឹងឲ្យនាងទៅជាភរិយាស្តេចវិទេហរាជ រីទុក្ខយកលនេះ ដូចគ្រឿលេចផ្តែសន្ធូចនាំមកមួយអន្លើ បើស្តេចវិទេហរាជ នូវហោមហោសថមកដល់កណ្តាប់ដៃអញហើយ អញនឹងសម្លាប់អ្នកតាំងពីដើមស្រាជ័យហោង រីអាចារ្យកេវដ្តព្រាហ្មណ៍គិតនូវអាថិទុក្ខយកលអម្បាលនោះហើយ ឡើងទៅគាល់ព្រះបាទបុលទីព្រហ្មទត្តរាជ ដល់ហើយឡើង

លើព្រះរាជមន្ទីរ អង្គុយឃាន់មួយសមគួរនឹងអាត្មា ហើយក្រាបទូលថា នេះ
បពិត្រព្រះសម្មតិទេព ក្សត្រវិជ្ជប្រសើរជាអង្គុស់ខ្ញុំអើយ! អញ្ជើញខ្ញុំមានគំនិត
ទុច្ចរិតមួយ អញ្ជើញពុំទាន់ចានក្រាបទូលព្រះបាទបុលន្ទិព្រហ្មទត្តរាជ
ឡើយ ។ ស្តេចស្តាប់ពាក្យអាចារ្យកេវដ្តព្រាហ្មណ៍ទូលនូវប្រការអម្បាល
នោះហើយ មានបន្ទូលថា អាចរិយ ម្នាលអាចារ្យអើយ! អញសព្វថ្ងៃ
អាស្រ័យនឹងគំនិតអាចារ្យឯងហោង ថាបើដូច្នោះ តើគំនិតព្រះស្តេចនឹង
គិតធ្វើដូចម្តេច? កិច្ចរព្រះស្តេចថ្វែងប្រាប់មកឲ្យចានដឹង នូវគំនិតទុច្ចរិត
ក្សត្រព្រះស្តេចយល់នោះ ឲ្យប្រាកដឥឡូវនេះហោង ។ ទើបអាចារ្យ
កេវដ្តព្រាហ្មណ៍ទូលថាដូច្នេះ មហាភាគ បពិត្រមហាភាគអើយ! រីទុច្ចរិត
កលជាខ្មែ សូម្បីនឹងដូចទុច្ចរិតកលនេះនោះគ្មានឡើយ ។ ស្តេចបន្ទូល
ថា បើដូច្នោះ ចូរអាចារ្យស្រដីប្រាប់មកហោង ។ អាចារ្យកេវដ្ត-
ព្រាហ្មណ៍ទូលថា មហាភាគ បពិត្រមហាភាគអើយ! គួរដើម្បីនឹងមាន
តែយើងតាំងនេះឯងហោង ។ ឮដំណាលនោះ អាចារ្យកេវដ្តព្រាហ្មណ៍
នាំស្តេចនោះឡើងទៅលើប្រាសាទហើយថាដូច្នេះ មហាភាគ បពិត្រ
មហាភាគអើយ! យើងនឹងប្រលោមលោមស្តេចវិទេហរាជនោះ ដោយ
ខ្លួវសមាគិសេស ឲ្យបានស្តេចវិទេហរាជនឹងមហោសថបុត្រគហបតី
ហើយយើងនឹងឲ្យសម្លាប់ហោង ។ ស្តេចមានបន្ទូលថា ម្នៃអាចារ្យ
អើយ! រីទុច្ចរិតកលនោះគាប់តិតហោង ថាបើដូច្នោះ យើងនឹងប្រលោម

លោមស្តេចនោះឲ្យបានទាំមកដោយខ្លួនអំពើទុច្ចរិតយ៉ាងណាមិញ ? ។ អាចារ្យ
កោដ្ឋព្រាហ្មណ៍ទូលថា មហារាជ បពិត្រមហារាជអើយ ! រីព្រះរាជធីតា
នៃព្រះបាទអម្ពាសនោះ ទ្រង់នាមឈ្មោះហៅនាងបញ្ចាលចន្ទី ដ៏ទ្រង់
ទ្រង់ខ្លួនប្រពៃដោមនោះល្អឧត្តមសមខ្លួនលក្ខណាផង យើងនឹងឆងាក្យសរ-
សើរខ្លួនលំអស្រីពិលាសដោយខ្លួនគុណបុណ្យនៃនាងនោះ ដោយចំណង
ចម្រៀង យើងចងជាគាថាដកចដោយខ្លួនប្រាថ្នាឈ្នាសគន្ធងគន្ធេចផង
ពាំងឡាយ យើងនឹងឲ្យទៅច្រៀងខ្លួនចំពុកផងឮដំមិថិលានគរ រីស្រីតែន
ប្រសើរដ៏មានរូបសុភាពបន្តិចលំអដូច្នេះ តើនឹងធ្វើអ្វី ក៏មិនបានខ្លួនវាជ
សម្បត្តិស្តេចវិទេហរាជនោះ ? កាលនោះ បើយើងដឹងហើយខ្លួនសុភាពជា
ស្តេចវិទេហរាជ ប្រតិព័ទ្ធកាត់សំឡាញ់ដោយលេស៊ីកនៃនាងនោះមកដល់
យើងហើយ អញចុំនឹងទៅឮដំហាវនោះ ហើយនឹងកំណត់ថ្ងៃ ណៃ
ឲ្យមកយកទាំងកូនតហាបតិ ។បមាបីដូចត្រីលេបសន្ទូច បានមកហើយ
កាលបើដូច្នោះហើយ យើងនឹងសម្លាប់ហាន ។ រីព្រះបាទបុលនីព្រហ្ម-
ទត្តរាជ ស្តេចស្តាប់ខ្លួវាក្យនៃអាចារ្យកោដ្ឋព្រាហ្មណ៍នោះហើយ មាន
ព្រះទ័យត្រេកអរខ្លួលយក ហើយមានព្រះបន្ទូលថា ម្នៃអាចារ្យអើយ !
រីឯបាយកលនៃអ្នកនោះជាឯបាយកលល្អក្លាត់ អញនឹងធ្វើដូច្នោះហាន ។

តំបន មន្តិ បុលនីព្រហ្មទត្តសួ សយនថាលិតា
សាលិកា សកុណិកា សុត្វា បច្ចក្ខំ អគាសិ ។

រីសាវិកា ដែលតែងរក្សាទូវក្រឡាបទ្ធំនៃព្រះបាទបុលីព្រហ្មទត្តនោះ ក៏ឮទូវគំនិតនោះ ក៏ធ្វើឲ្យប្រែកដូច្នោះហើយសឿមនៅហោង ។

(ឯកនិវសំ) ទោភណាតាឲ្យការតេ បន្លោសាបេត្វា ពហុធនំ ទត្វា ឪតរំតេសំ ឧស្សុត្វា តាតា ឯតិស្សា រូបសម្បត្តិំ និស្សាយ តាឲ្យំ កកេថាតិ អាហ ។ មានកាលមួយថ្ងៃ ស្តេចមានចន្ទលហៅទូវអ្នកចាស់ចេះចង់តន្ទង់តាឲ្យដកចំនុកអំពីបុរាណមក ស្តេចឲ្យឈ្នះទូវទ្រព្យនោះច្រើន ឲ្យទៅអ្នកចាស់នោះ ហើយបង្ហាញទូវព្រះរាជធីតាកញ្ញានៃអ្នកចាស់ចេះចង់តន្ទង់ចំនុកផង់ដូច្នោះនោះថា ម៉ែហក្នេង អ្នកចាំង់ឲ្យាយ ចូរធ្វើចំនុកផង់តន្ទង់និយាយអកិច្ចាយ ហេតុអាស្រ័យទូវលំអរូបសម្បត្តិនៃនាង់បញ្ញាលចន្ទីនោះហោង ។ រីអស់អ្នកផង់ចង់ទូវចម្រៀងសរសើរដំណើរនាង់មុខគួរឲ្យស្រណុកចិត្តអាណិតក្រៃពេកណាស់ ឲ្យព្រះរាជាទ្រង់ព្រះសណ្តាប់ ។ ស្តេចមានព្រះហឫទ័យត្រេកអរ ទ្រង់ព្រះរាជទានទ្រព្យដ៏ច្រើនដល់អ្នកចេះចង់តន្ទង់តាឲ្យចាំង់ឲ្យាយនោះ ។ រីអស់ស្រីរបាំផង រឿងតាឲ្យអំពីសំណាក់នៃអ្នកច្រាជ្ញចាំង់ឲ្យាយ ចេះចង់តន្ទង់តាឲ្យនោះហើយ ក៏ច្រៀងលេង៧ដ៏ស្បែងមណ្ឌលមហាស្រុតានោះហោង ។ រីចម្រៀងផង់នោះក៏ទូលាយសុះសាយទៅដល់ស្រុកស្រែលំនៅជនបទច្រាកដស្រេច ដូច្នោះហោង តែសុ ស្បែងលេងអ្នកផង់នោះ ធ្វើ៧ដ៏ចម្រៀងទូលាយសាយ

សត្វគ្រប់ទៅឮដំណែងនៃមនុស្សម្នាមហាជនផងទាំងឡាយ ស្តេចមានព្រះបន្ទូលឲ្យហៅនូវអ្នកច្រៀងចំរៀងផងនោះមកថា តា តា ចៃហក្មេងទាំងឡាយ ស្តុម្ល៉ោ អ្នកទាំងឡាយ ចូរចាប់យកនូវបក្សីចង្រឹងនូវចង្រ្កង់ឮដីកនៃបក្សីនោះផង ហើយលែងបក្សីផង ឲ្យហើរទៅ ចូរក្មេងចុះមកហោង ។ អ្នកផងនោះ គេឮនូវសំឡេងចង្រ្កង់នោះឮដីកណ្តាលអាកាសហើយ ក៏សឹងដឹងនូវពាក្យមេត្រីស្រដីសរសើរដំណើរថាដូច្នេះ កិរ ដោយយើងឮមកនេះ កលជាខ្មៅតា ឬ មនុស្សឯណា ក៏មកច្រៀងសរសើរដំណើរអំពីគុណបុណ្យលំអរូបសម្បត្តិនៃនាងកូនស្រីស្តេចឈ្មោះនាងបញ្ចាលចន្ទី រីអំពើលោកធ្វើច្រកាដូច្នេះ ប្រយោជន៍ឲ្យច្រកាជ រីអ្នកផងនោះសឹងធ្វើដូច្នោះហោង ។ រីស្តេចមានបន្ទូលឲ្យហៅនូវអ្នកច្រៀងមក អាចចេះចងនូវខ្ទំនុកនោះផង មកថាដូច្នេះថា តា តា ម្នាលក្មេងទាំងឡាយ រីឥឡូវនេះ ចូរអ្នកទាំងឡាយ ចងនូវចម្រៀងសរសើរដំណើរលំអរូបសម្បត្តិនៃនាងនេះហើយចងនូវគាថាដកចេញទាំងពួងវិញថា រីនាងកុមារីគាចញ្ចាលចន្ទីនេះឯង ដ៏ប្រសើរជាង មានសុភាពរូបល្អដូច្នេះនេះ មិនគួរបើអញនឹងឲ្យស្តេចដទៃឮដំប្រលុងសកលជម្ពូទ្វីបនេះឡើយ គួរតែអញឲ្យដល់ស្តេចវិទេហរាជឮដីមិថិលានគរ រឯឥស្សរៈយយសនៃស្តេចវិទេហរាជមិញ ក៏សមគួរដល់ព្រះរាជធីតានេះពេកហោង ។ រីអ្នកផងចេះចងគន្ថឯខ្ទំនុកគាថានោះ ធ្វើដូចព្រះបន្ទូល ហើយទៅក្រាបទូលស្តេច ។ ព្រះរាជាទ្រង់ឲ្យនូវទ្រព្យដល់

អ្នកប្រាជ្ញផងនោះ ហើយបង្គាប់ប្រើវិញ្ញាខៀតថាដូច្នេះ តាតា ម្ចាស
ក្មេងតាំងឡាយ តុន្ថោ រីអ្នកតាំងឡាយ ចូរទៅហើយប្រឹងដោយ
កលទុបាយនេះ ឮដំណឹងលាននគរនោះវិញ្ញាខៀតហោង ។ តែ តាឯ
តាយន្តា អន្តុប្បុព្វេន មិថិលំ បត្វា សមជ្ជមណ្ឌាសេ
តាយីសុ ។ រីអ្នកចម្រៀងផងនោះក៏ប្រឹងនូវចម្រៀងនោះ ដើររៀង
ទៅកាន់មិថិលាននគរនោះដោយនូវលំដាប់ ហើយប្រឹងឮដំណឹងម.
ហោស្រព ។ រីមហាជនផងតាំងឡាយ ស្តាប់នូវចម្រៀងនោះ ក៏តត្រើត
តើតមានសំរួលសំណើចជារយៈពាន់ ស្តេចកាន់ទ្បាន់នូវទ្រព្យនោះច្រើន
ឮដំអ្នកផងប្រឹងនោះ ។ ឮដំកណ្តាលរាត្រីយប់នោះហោង រីអ្នកផង
នោះក៏ប្រឹងលើចុងឈើ ឮដំកាលបៃតបច្ចូសនោះហើយ ក៏ចង់ចង្រ្កង់
ឮដំតនៃសត្វបក្សីផង ហើយក៏ចុះមកហោង ។ រីមហាជនផងតាំងឡាយ
ឯណា ។ សុត្វា ក៏ឮនូវសត្វចង្រ្កង់នោះឮដំអាកាសថាដូច្នេះ រីខេវតាវិ-
សេសឯណា តាយន្តិ ក៏ប្រឹងសរសើរនូវលំអសម្បុរបូនៃកូនស្រីស្តេច
ឈ្មោះនាងបញ្ចាលចន្ទីស្រីដ៏ប្រសើរហើយកូវ រីកោលាហលវល់ជាមួយ
អរោសិ ស្រែចមានឮដំកងនគរហោង ។ ម្ចាំះហើយ រីស្តេចវិទេហ-
រាជឮនូវសំឡេងនោះហើយ អ្នកឲ្យហៅនូវអ្នកចម្រៀងផងនោះមកសួរនូវ
ល្បែងមហោស្រពលើព្រះរាជមន្ទីរអោត្តា ហើយស្តេចត្រែកអានឹងឲ្យទ្រព្យ

ផងនោះច្រើនទៅអ្នកចម្រៀងផងនោះហើយ ដោយទ្វារគំនិតថាដូច្នេះ
ចុលឯកជា រំស្តេចចុលនីព្រហ្មទត្តរាជ សមគាតភ្ញាចនឹងចង់ឲ្យនូវព្រះ
រាជបុត្រីកូនស្រីតែន់ប្រសើរ មានព្រះដំណើរនោះល្អ មានសុភាពដូច្នេះ
នេះ មកអញមិនខេឡើយ ។ រំអ្នកចម្រៀងផងនោះ រៀលទៅទូលព្រះបាទ
ចុលនីព្រហ្មទត្តរាជហោង ។ កាលនោះ បើដូច្នោះហើយ អាចារ្យកែវដ្ឋ-
ព្រាហ្មណ៍ថានឹងស្តេចនោះដូច្នេះ មហាភាគ បពិត្រមហារាជអើយ !
ឥឡូវនេះ អញខ្ញុំនឹងទៅប្រយោជន៍នឹងកត់ថ្ងៃ ទៀ ឲ្យដឹងច្បាស់ជាហោង ។
ស្តេចនោះថា អាចារ្យ អើយ ! សាធុគាប់ហោង ថាបើ
ដូច្នោះ តួរគេប្បីនឹងបានអ្វីកំនឹងយកទៅ ? ។ អាចារ្យកែវដ្ឋព្រាហ្មណ៍ថា
តួរគេប្បីតែមានបណ្ណាការអ្វីបន្តិចទៅផងនោះ ទើបគាប់ហោង ។ ទើប
ស្តេចប្រើឲ្យអាចារ្យកែវដ្ឋព្រាហ្មណ៍នោះ យកទ្វារគ្រឿងបណ្ណាការផងទៅ
ដល់ស្រុករំខេហារដ្ឋមិថិលាមហានគរព្រះបាទរំខេហារាជ ដោយទ្វារហែ
ពលសកលយោធាសេនាផងច្រើនហោង ។ រំមហាជនផងទាំងឡាយ
គេឮថាអាចារ្យកែវដ្ឋព្រាហ្មណ៍មកដូច្នោះហើយ អ្នកអើយ ! តើតជាកោ-
លាហលវល់ជាមួយក្នុងព្រះនគរ សឹងថាដូច្នេះ ថាឧត្តមថាព្រះបាទចុលនី
ព្រហ្មទត្តរាជក្តី ព្រះបាទរំខេហារាជក្តី សឹងនឹងចងភ្ជាប់មិត្តភាពមេត្រីផង
គ្នា មែនពិតឬម្តេចអេះ ? នោះហោង មហាជនផងទាំងឡាយ សឹង
និយាយនឹងគ្នាថា ព្រះបាទចុលនីព្រហ្មទត្តរាជ គាត់អាចថានឹងចង់ឲ្យព្រះ

ភាជបុត្រនៃអាត្មា មកជាព្រះអគ្គមហេសីនៃស្តេចយើងមែនពិត ឬជាមួយ
សោតលោកធ្វើទុច្ចរិតលួងទេ ? តែថាបានឮមក រីអាចារ្យកៅដ្ឋ-
ព្រាហ្មណ៍ឯង គាត់តែងប្រយោជន៍ដល់រកគាត់ថ្ងៃឬក្សត្រាពេលណាជាល្អ
ហើយនឹងនាំពតិមានទៅថ្វាយព្រះចុតបុលនិវិញហោង ។ រីព្រះចុតវិទេ-
ហរាជ ក៏ស្តេចឮនូវពតិមាននោះហើយ សូម្បីរីព្រះមហាសត្តក៏ ក៏អ្នក
ឮនូវសំតូពតិមាននេះដែរ រីដំរិះនេះ អ្នកគិតស្រេចមានទៅព្រះមហាសត្ត
អ្នកគិតថា នាដំណើរអាចារ្យកៅដ្ឋព្រាហ្មណ៍នោះ នាយល់ជាមិនសុ-
ភាពតាប់ចិត្តនៃអញទេរីយ អ្មាំះហើយពោធិសត្តអ្នកតែងនឹងដឹងអាចារ្យ
កៅដ្ឋព្រាហ្មណ៍មកនោះជាក់ច្បាស់ហើយ ។ រីពោធិសត្តអ្នកប្រើពតិមាន
ទៅចំពោះថ្លានគាន់បុរសជាទុបនិក្ខិត្ត ដែលទៅចំរើសំណាក់នៃព្រះចុត
បុលនីនោះថាដូច្នេះ ភវន្តា រីអ្នកចាំងឡាយ ជាឯត្តា ដឹងហើយនូវ
អាថនេះឲ្យជាក់ច្បាស់ ហើយព្រះស្តេចចូរប្រើមកគាន់ព្រមានអញវិញ
ហោង ។ ឮដំកាលនោះ រីទុបនិក្ខិត្តបុរសផងដែលទៅមុខនោះមិញ
ប្រើពតិមានមកគាន់ពោធិសត្តវិញនោះថាដូច្នេះ រីយើងមិនដឹងនូវពតិមាន
ដោយនូវច្បាស់នោះសោត រីស្តេចឯងក្តី អាចារ្យកៅដ្ឋព្រាហ្មណ៍ក្តី សឹង
អង្គុយនៅឮដំណែងក្រឡាព្រះបន្ទំ មកគិតមានតែសត្តសារិកា ជាសត្ត
បក្សីតែងរក្សាក្រឡាព្រះបន្ទំនៃស្តេចឯង តែងនឹងគិតគំនិតនោះហោង ។
រីពោធិសត្តស្តាប់នូវពាក្យនោះហើយ ក៏គិតថា រីអត្ថកាសនៃសត្រូវនោះ

អង្គីមានទ្វេប្រការម្តេចមិញ រីនគរនោះ គេធ្វើចំណែកប្រពៃ តាក់តែង
លេងឲ្យសប្បាយដូច្នេះ រីអញនេះ មិនឲ្យអាចារ្យកែវដ្ឋព្រាហ្មណ៍ដើម្បី
ទីនឹងយល់ឡើយ រីព្រះមហាក្សត្រនោះ អ្នកឲ្យសារទ្វេផ្លូវនានាទីនឹងមកនោះទ្វេ
តភាវៀងសង្ខាងអំពីក្នុងនគរ ដកបដល់ព្រះកដបន្ទុំ អំពីព្រះកដកំនង
ឲ្យដតមានតិដកបទៅដល់ផ្ទះនៃអាគ្នាហោង សូម្បីឯលើក្តី អ្នកឲ្យចាំង
ទ្វេតភារសោត អ្នកធ្វើប្រាយកយនូវលាដក្តីជាដើមឮដ៏ផ្ទៃក្រោម អ្នកឲ្យ
ដំកល់ទ្វេក្អមទឹកតេញ អ្នកឲ្យដាំទ្វេដើមចេក ឲ្យដឡើងទ្វេចន៌ផង ។

តេវាន្តោ ឧភរំ បរិសិត្វា សុវិកត្តំ ឧភរំ អ-
បស្សន្តោ វញ្ញា មេ មន្តោ អលង្ការមិតោតិ ចិន្តេត្វា
ឧភរស្ស អនុស្សនត្តំ កតភាវំ ឯ ជានាតិ ។ រីអាចារ្យ
កែវដ្ឋព្រាហ្មណ៍ចូលទៅនគរនោះ មិនយល់ទ្វេចំណែកនគរដែលគេ
រណ្តាប់ប្រពៃនោះឡើយ តិតថា រីផ្ទះលោករណ្តាប់ប្រពៃដើម្បីអញ មិន
ជឹងទ្វេសុភាពគេធ្វើ ដើម្បីមិនឲ្យយល់នគរនោះឡើយ ហើយអាចារ្យ
កែវដ្ឋព្រាហ្មណ៍ទៅថ្វាយបង្គំស្តេច បង្ហែរទ្វេគ្រឿងបណ្ណាការទាំងពួងនោះ
ទៅស្តេច ហើយអង្គុយឮដ៏ហានមួយ ដ៏មានសក្ការៈនោះគឺស្តេចបានធ្វើ
ហើយ កំនឹងប្រាប់ទ្វេហេតុដំណើរនៃអាគ្នាមកនោះ អភាសិ ក៏ស្រដី
ជាបទគាថាដូច្នេះ :

ភជា សន្តវគ្គោ តេ វតជាតិ បវេច្ឆតិ
អាកច្ឆន្តុ ឥតោ ទូតា មញ្ចុគ្គា បិយភាណិនោ ។
ភាសន្តុ មុទុកា ភថា យា ភថា បដិនន្ទិតា
បញ្ហាណោ ច វិនេហោ ច ឧភោ ឯត្ថ ភវន្តុ តេតិ ។

មហាភជ បតិត្រមហាភជអើយ ! រីស្តេចនៃយើងនេះមានចំណង់ជាមិត្តផ្តិតស្នេហាជាមួយអាខ្ញុំនឹងអម្ចាស់ឮស្តាប់ សមបង្វែរឲ្យខ្ញុំព្រះភជ-ធីតាបុត្រីស្រីរតនប្រសើរ មកដល់មហាភជហោង ហើយចាប់ដើមអំពីនេះទៅកុំ រីភជខ្ញុតនាមានសំឡេងពីពេះនោះ ស្រដីគួរស្រឡាញ់តេញចិត្ត តើយកខ្ញុំវត្រឿងបណ្ណាការនាំសារចូលមកអំពីស្រុកបញ្ចាលនោះហើយ បតិត្រមហាភជអើយ ! រីពាក្យឯណាខន់កូនពីពេះគួរត្រេកអរ រីពាក្យនោះនឹងស្រដីខ្ញុំពាក្យនោះហោង រីព្រះថ្លៃបញ្ចាលបន្ទូលក្តី ព្រះថ្លៃវិទេហភជក្តី ក៏មហាក្សត្រទាំងពីរព្រះអង្គនោះ ចូលមូលមនុកូលខ្ញុំគ្នាជាមួយហោង ។

រីអាចារ្យកវដ្តព្រាហ្មណ៍ថាអម្បាលនោះហើយ ក៏ទូលវិញ្ញាវិតថា មហាភជ បតិត្រមហាភជអើយ ! រីស្តេចជាអម្ចាស់នៃយើងខ្ញុំឯនាយ ស្តេចមានបំណងដើម្បីនឹងចង់ប្រើអាមាត្យដទៃជាក្រៃនឹងខ្ញុំនោះ ក៏ខ្លាចអាមាត្យនោះ ក៏មិនអាចដើម្បីនឹងខ្ជួលប្រាប់តតិមានធ្វើឲ្យគាប់ចិត្ត តិតដូច្នោះហើយ ដើបស្តេចមានព្រះបន្ទូលត្រាស់ប្រើអញខ្ញុំកុណាថា ម៉ៃ

អាចារ្យអើយ ! ឆុន្ទោ អែកអាចារ្យ ពោធេត្វា ចូរស្រដីឲ្យដឹងនឹងស្តេចនោះឲ្យច្រើនហើយនៃ ព្រះស្តេចប្រសោមយកនូវស្តេចនោះឲ្យបាន ព្រះស្តេចថាដូច្នេះ មហាភាគ បពិត្រមហាភដអើយ ! ឆុន្ទោ អែមហាភដ ចូរស្តេចលីលាទៅកូវ អម្ចាស់នឹងបានទាន់កុមារីស្រីវ័ន្តប្រសើរនាងមានដំណើរបួលស្តែក្រពេកហោង ព្រោះតាជាស្តេចមេត្រី មួយអន្លើនឹងអម្ចាស់យើងខ្ញុំ នឹងបំតេជោក្តើរទៅហោង ។ ព្រះបាទវិទេហភដស្តេចស្តាប់នូវពាក្យនៃអាចារ្យកេវដ្តព្រាហ្មណ៍នោះហើយ ស្តេចមានព្រះហឫទ័យនោះត្រេកអរផ្សូវផ្សាយពេកក្រៃ ហាក់ទៅដឹតដោយនូវឮថាដូច្នេះ តែវ ដោយយើងឮមកនោះ អហំ រមែញនឹងបាននាងកុមារី ជំទ្រង់នូវរូបទោមនោះល្អទត្តមពេកណា ស្តេចបន្ទូលថា អាចារ្យអើយ ! កំដោយនូវឮមក ពាក្យអាចារ្យឯងក្តី ពាក្យនៃបាមហោសថក្តី ទៅឮដំណមួយខ្នះនោះហើយ អាចារ្យឯង ចូរទៅកូវ នឹងបានយល់មហោសថកូនអញ សូម្បីអែកទាំងពីរ សឹងជាអ្នកប្រាជ្ញអាចឲ្យអត់គ្នាទៅវិញទៅមក យកចិត្តគំនិតនឹងគ្នាហើយចូរបាមកហោង ។ អាចារ្យកេវដ្តព្រាហ្មណ៍ស្តាប់នូវពាក្យនោះហើយ ក៏ក្រាបលាចុះសំដៅទៅ ដើម្បីនឹងចង់យល់ថៅមហោសថអ្នកប្រាជ្ញនោះ ដោយនូវគិតដូច្នេះថា អំពីនេះទៅកូវ យើងនឹងបានយល់នូវថៅអ្នកប្រាជ្ញនោះ ។ ឥឡូវនេះឯង រឺពោធិសត្វអ្នកដឹងនូវសុភាពនៃអាចារ្យកេវដ្តព្រាហ្មណ៍ នឹងមកកាន់សំណាក់នៃអាត្មាអញ ។

គិតថាដូច្នេះ រីការសំណេះសំណាលចរចាទៅវិញទៅមក យកចិត្តគំនិត
គ្នាមួយអន្ទឹងនឹងអ្នកជាបជាមិនខ្លាំអញ្ជោះ ចូរកុំឲ្យមានឡើយ អ្នកគិតដូច្នេះ
ហើយ កំអ្នកផឹកខ្លាំប្រថ្នង សូម្បីបន្តិចស្រេចរត់ពីព្រឹកព្រហាមហោង ។
រីពោធិសត្វអ្នកលាបស្រលាបដោយលាមកតក់ គឺអាចម៍គោអាចម៍ក្របី
អាចម៍មាន់-ទា-ក្អែ-ខ្ចី ខ្លាំអាចម៍មនុស្សផងដោយខ្លាំបង់បត់បែន (ទាហ
លេន) ដ៏ច្រើនក្រាស់ក្រែ ហើយអ្នកឲ្យលាបខ្លាំប្រថ្នងឲ្យដ៏សសាវផ្ទះ
ហើយអ្នកឲ្យដាក់ខ្លាំគ្រែមាសមួយអោនោះ ពោធិសត្វថា រីក្រែតែងនឹងដឹត
ហើយសឹងអ្នកឲ្យនាំចេញទៅខ្លាំគ្រែតាំង រីគ្រែសំណល់លៃងនោះមាន
ច្រើនហោង ។ រីពោធិសត្វអ្នកឲ្យកត់សំគាល់មនុស្សចាំងឲ្យថាដូច្នេះ
ភ្ញូម្ចា រីអ្នកចាំងឲ្យ ចូរស្រដីនឹងព្រាហ្មណ៍នោះ ជាអ្នកឆ្លោះដើម្បីនឹង
ស្រដីដូច្នេះថា ម្នាលព្រាហ្មណ៍អើយ! ព្រះវិស្ណុងកុំស្រដី សន្ទុំ មួយ
អន្ទឹងនឹងទៅអ្នកប្រាជ្ញនោះ ឲ្យដំថ្ងៃនោះ គឺទៅអ្នកប្រាជ្ញនោះ ផឹកខ្លាំប្រថ្នង
សូម្បីថាបើអញធ្វើខ្លាំស្រដីមួយអន្ទឹងខ្លាំព្រាហ្មណ៍នោះ ភ្ញូម្ចា រីអ្នកចាំង-
ឲ្យ ចូរឃាត់អញថា ឧទ្ធវបណ្ឌិតអើយ! រីប្រថ្នងសូម្បី គឺអម្ចាស់ផឹក
ចូរអម្ចាស់កុំស្រដីឡើយ ។ ឯវំ វិចារេត្វា មហាសត្តោ រត្តបដំ
ឯកាសេត្វា សត្តមេ ទ្វារកោដ្ឋកេ បុរិសេ ឋបេត្វា
រត្តមញ្ជុកេ ឯបដ្ឋិ ។ រីព្រះបរមពោធិសត្វ អ្នកពិចារណាខ្លាំ

ប្រកាអម្បាលនោះ ហើយក៏ស្រែកនូវសំពត់ប្រាល អ្នកដេកនៅត្រែស្ទឹក
ឈើឮដំណឹងបង្អស់កន្លងក្នាងគ្នាជាតំរប់៧ជាន់នោះហាង ។ រីអាចារ្យកវដ្ត-
ព្រាហ្មណ៍ឈរនៅឮដំគ្នាជាប្រថមទាំងឡាយ ក៏ដណ្តើងកព្រះមហា-
សច់នោះថា ហៃចៅអ្នកប្រាជ្ញអើយ! អ្នកនៅឯណា? ។ លំដាប់នោះ
រីមនុស្សម្នាមហាជនផងទាំងឡាយ សឹងប្រាប់ប្រាប់ព្រាហ្មណ៍នោះថា
ម្នាលព្រាហ្មណ៍អើយ! ព្រះស្តេងឯងកុំធ្វើបន្ទូនូវសំឌូទ្ធាំងពេក ស្អែកទឹង
មិនបានចូលទៅឡើយ ម្ល៉ោះហើយសូមកុំស្រដីមកដល់ថ្ងៃនេះ រីប្រែង
សូម្បីតែចៅអ្នកប្រាជ្ញតែងធឹកព្រះស្តេងដើម្បីទឹងធ្វើនូវសំឌូនោះទ្ធាំងដូច្នោះ
នោះមិនបានចូលទៅឡើយ ។ រីគ្រាសំណល់លែងនោះក្តី កំមហាជនផង
សឹងស្រដីទឹងព្រាហ្មណ៍នោះដូច្នោះហាង ។ អាចារ្យកវដ្តព្រាហ្មណ៍កន្ទូង
នូវគ្នាជាតំរប់៧ជាន់នោះ ទៅកាន់សំណាក់នៃចៅអ្នកប្រាជ្ញនោះហើយ ។
រីចៅមហាសច់អ្នកប្រាជ្ញសំដែងនូវអាការជាទឹងស្រដីអង្គាល ។ បើដូច្នោះ
កូវអស់មនុស្សម្នាមហាជនផងទាំងឡាយ កំសឹងឃាត់ពោធិសត្វនោះថា
ឧេ! បពិត្រអម្ចាស់អើយ! តុម្ភេ អម្ចាស់ មា កេ៩យិត្ត កុំស្រដី
ទ្ធាំងពេក រីប្រែងសូម្បីអម្ចាស់ឌឹក អម្ចាស់ស្រដីធ្វើអ្វី? ឯមិនា ទុជ្ជ-
ព្រាហ្មណេន សទ្ធិ មយ្ហអន្ទេទឹងព្រាហ្មណ៍កំណាចនេះឡើយ ។ រី-
អាចារ្យកវដ្តព្រាហ្មណ៍នោះ ទៅកាន់សំណាក់នៃចៅមហាសច់អ្នកប្រាជ្ញ
មិនទាន់អង្គុយឡើយ មិនបាននូវកំណលដើម្បីទឹងអាស្រ័យនូវហានឈរ

ឡើយ ហើយគេបង្ហាញនូវការដឿគេដាដើម ដែលជាន់លើអាចម៍គោ
ខ្ចីកខោះ ឈរនៅឥង្គាល់ បើដូច្នោះកូវ រឺអ្នកមួយរមិលមើលនូវព្រាហ្មណ៍
នោះ រឺអ្នកមួយហែកភ្នែកឲ្យ ឯគោ រឺអ្នកមួយ កមុកកំ ឧក្កិបិ
កំញាក់មុខនូវចិញ្ចើម ឯគោ រឺអ្នកមួយ អាកង្ខាយិ កំពញ
កបុរំ នូវម្រោមដៃឲ្យបង្ហាញព្រាហ្មណ៍នោះហើយ រីឯបាវ្យគេវដ្ដ-
ព្រាហ្មណ៍ យល់នូវអំពើនៃអ្នកផងគេធ្វើដូច្នោះហើយ កំសៀមនៅមិន
ស្រដីអ្វីដល់មួយម៉ាត់ឡើយ ហើយថា ម៉ៃហាថាមហោសថអ្នកប្រាជ្ញអើយ!
យើងនឹងលាអ្នកទៅ កាលណាបើដូច្នោះកូវ អ្នកផងថា ម្នាលព្រាហ្មណ៍
កំណាច ព្រះស្ដេចឯងកុំធ្វើនូវសំពួងាំងពេកឡើយ ស្អែកនេះហើយយើង
កាប់នូវឆ្នឹងនៃអ្នកហោង រីឯបាវ្យគេវដ្ដព្រាហ្មណ៍ ឮនូវពាក្យនៃអ្នកផង
នោះហើយ សឹងកិតភ័យញ័រដើងញ័រដៃក្រពេក ប្រែចេញមកមើលមើល
ទៅអស់អ្នកទាំងនោះ ។ ឮដំណាលនោះ អស់អ្នកផងទាំងឡាយដោះឡើង
ខ្ចីខែ ។ មានដៃកាន់បន្ទះឫស្សីវាយត្រូវខ្នង ខ្លះចាប់តបង្អើខផង ខ្លះតប
ខ្លះដាល់ ។ អាចារ្យគេវដ្ដព្រាហ្មណ៍កិតភ័យតក្កមា ម្ដីម្ចាត់ចេញទៅ
ឧបមាបីដូចម្រឹគរួចចេញពីមាត់ពស់សីហ៍នោះឯង ហើយទៅកាន់ព្រះពស
ដំណាក់ហោង ។ រីឯព្រះចាទរិះគិតឃើញសោត ទ្រង់ព្រះចិន្ដាតំណា
ថា ថ្ងៃនេះ អញទៅមានសំពួងនឹងចាន់ដើងចាន់ឮតតិមានអំពីមហោសថ
បុត្រនៃអញហើយត្រេកអរ គោះយោបាយកម្ម្អី ។ តប្បីមានដំណើងហោង

តម្លៃនេះ អ្នកប្រាជ្ញទាំងពីរ ទើបអត់យកចិត្តគ្នាទៅរៀនទៅមកឬ ម្តេចហ៎:?
រីឯអាចារ្យកែវវត្តព្រាហ្មណ៍តែឡើងទៅដល់ព្រះពន្លាមន្ទីរស្តេច ហើយក្រាបថ្វាយបង្គំអង្គុយឰដ៏ហានមួយសមគួរទើបអត្តា ។ ស្តេចឃើញអាចារ្យកែវវត្តព្រាហ្មណ៍មកដល់ហើយ ក៏ស្តេចដណ្តើងនូវអាការសន្ធនាសមគួរពៅងជណ្តើតអ្នកប្រាជ្ញ ហើយពោលនូវគាថានេះ ដូច្នេះថា:

កថន្នុ កេវដ្ដ មហោសធេន
សមាកមោ អាសិ តទិច្ឆ ព្រូហិ
កច្ចិ តេ បដិនិជ្ឈតោ
កច្ចិ តុដ្ឋោ មហោសធោតិ ។

ម្នៃអាចារ្យកែវវត្តព្រាហ្មណ៍ អ្នកបានកប់ប្រសប់សន្ធនានូវធម៌មួយអន្ទើនូវអ្នកប្រាជ្ញនោះ ជាម្តេចព្រះស្តេច បួរព្រះស្តេចប្រាប់នូវហេតុនោះមក រីឯមហោសធ នូវអាចារ្យឯង បានយកចិត្តគ្នាទៅរៀនទៅមកឬទេ?។

ឰដ៏កាលនោះ រីឯអាចារ្យកែវវត្តព្រាហ្មណ៍ ក្រាបថ្វាយបង្គំប្រណម្យខ្លួលថា បពិត្រមហាពជក្សត្រថ្លៃប្រសើរអើយ អញខ្ញុំបានទៅដល់មហោសធហើយព្រះអង្គ រីឯមហោសធនោះ មិនមែនជាអ្នកប្រាជ្ញឡើយ ជាអ្នកឥតធម៌សប្បុរសក្រៃពេក អាចារ្យកែវវត្តព្រាហ្មណ៍ក្រាបទូលនូវគាថាដូច្នេះ:

អនរិយរូបោ បុរិសោ ជនិន្ទ
អសម្ភោជនកោ ឋន្ទោ អសញ្ញិរូបោ
យថា ម្ញកោ ច ពលិវោ ច
ន តេ តាទិសកា សថាតិ ។

បពិត្រមហាពជគ្សត្រប្រសើរអើយ រីមហោសថនោះ ជាពជគាមាគ្សនៃព្រះអង្គ មានសុភាពនោះអង្គឺជាអ្នកមានសប្បុរសឡើយ ឯលោអញខ្ញុំទៅហើយឥតត្រេកអរ ជាអ្នកបរិនិព្វានរូស មានកំណើតនោះ មិនមែនជាអ្នកច្រោជឡើយ អញខ្ញុំចូលទៅកាន់ឥតឋានស្រដីសួរនូវអាថ៌អ្វីមួយនឹងអញខ្ញុំឡើយ ធ្លើហាក់ដូចគេថ្ងន់លួងនឹងហោង ។

រឯព្រះឋាវរិទេហរាជ ស្តេចស្តាប់ពាក្យអាចារ្យកេវដ្តព្រាហ្មណ៍ក្រាបទូលដូច្នោះហើយ មានព្រះតក្រ្តសួតសួចសញ្ចប់នៅពុំសប្បាយហើយ មានព្រះឱន្ទូលឋង្គាប់ប្រើអាមាគ្យ ឲ្យច្រដាប់ច្រដាំគ្រឿងបណ្ណាការនូវស្បៀងនាំទៅជាគ់ឲ្យអាចារ្យកេវដ្តព្រាហ្មណ៍នៅឰដ៏ចំណាត ហើយឲ្យដំណើរអាចារ្យកេវដ្តព្រាហ្មណ៍ទៅហោង ក្រោយពីអាចារ្យកេវដ្តព្រាហ្មណ៍ទៅនោះ ស្តេចទ្រង់ព្រះចំឡោតិចារណាថា ហេតុអ្វីមហោសថបុត្រនៃអញ ម៉ិនមកសួរទូលសំណេះសំណាល ឋណ្ណាលមេត្រីស្រដីមួយអន្ទឹងនឹងអាចារ្យកេវដ្តព្រាហ្មណ៍នោះ តើជាហេតុម្តេច នេះសមមហោសថយល់អាចារ្យកេវដ្តព្រាហ្មណ៍ចូលមកវិនិតិតការនេះ អនាគត ភ័យសមនឹងមាន

ទៅឯមុខមិនខេឡើយ រឹតែនិតឯណាមួយ ចើមហោសថគឺតរហើយកម្រមួកឯណាមួយនឹងជាន់ជាន់ជាន់យល់នោះក្រៃពេក រីសេចក្តីលោភយលោភតើមហោសថសឹងដឹងអស់តតំជាំនឹងឡើយ នោះយោបល់ខ្ញុំនឹងមានភ័យញ៉ាំរន្ធត់ក្តី ស្តេចឯណាមួយក៏នៅបន្ទំស្រុក លុះកណ្តាប់ដៃសត្រូវក្តីក៏សឹងតែមហោសថបុត្រនៃអញដឹងហោង ។ នោះយោបល់អាចារ្យកវដ្ត-ព្រាហ្មណ៍មកដល់នេះក្តី សមមហោសថដឹងខ្លួនតំនិតព្រាហ្មណ៍នោះ ដូចតមកដល់នេះ មិនជាប្រយោជន៍ ជាមិត្តឡើយ សមមកប្រលោមខ្លួនបញ្ចកាមគុណ នឹងនាំយកអញទៅកាន់នគរឯនាយ រីអនាគតទៅ សមភ័យនឹងព្រាហ្មណ៍នេះមិនខេឡើយ ស្តេចទ្រង់ព្រះចិន្តាខ្លួនអាចិប្រស្នាប្រកាសអម្បាលនោះហើយ ស្តេចកតភ័យញ៉ាំរដើងញ៉ាំរដៃក្រៃពេក ស្តេចឲ្យហៅអាចារ្យទាំង ៤ មកដល់ហើយ ស្តេចដណ្តឹងអាចារ្យសេនកថា ម្នាលអាចារ្យសេនកអើយ រីយើងនឹងទៅកាន់នគរទត្តបញ្ចាល នឹងនាំយកព្រះរាជបុត្រីនៃព្រះបាទបុលនីព្រហ្មទត្តមកនោះ ព្រះស្តេចនឹងចូលចិត្តឬទេ ? ។ អាចារ្យសេនកស្តាប់ហើយទូលថា ម.ហារាជ បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ មហាក្សត្រមានព្រះបន្ទូលម្តេចដូច្នេះ រីស្រីស្អួស្តីនឹងមកដល់ព្រះអង្គហើយ មិនគួរគេប្បីទៅបង្អង់ឡើយ ។បមាបីដូចបង្កែមចូលកងមាត់ហើយ មេចឡើយនឹងខ្លាក់ចេញវិញ ។ រីព្រះបាទបុលនីព្រហ្មទត្តរាជអាចមានចំណង់នឹងចង់ថ្វាយព្រះរាជបុត្រី ដ៏ទ្រង់ខ្លួរបូនោះទត្តម ផ្សំជា

ព្រះអគ្គមហេសីនៃព្រះអង្គនោះ ដ្បិតអស់ស្តេចទាំងឯកលដមុខ្ញុំចនេះ
សឹងជាចំណុះនៃព្រះចាខុលន៍ ទៅខាងតែព្រះអង្គឯង សេសសល់តុំជា
ចំណុះ ដំជាស្តេចឯកពជធំស្មើនឹងស្តេចចុលន៍ ហេតុនោះឈឹង ទើប
យកព្រះពជបុត្រី តែងតាំងបញ្ចាលចន្ទីនឹងថ្វាយជាព្រះអគ្គមហេសីទេតីនៃ
ព្រះអង្គ ដ្បិតមានតែព្រះអង្គឯង ឥតអ្នកឯណាទឹងស្មើឡើយ រីឯយើងខ្ញុំ
សោត ទឹងថានឧវត្រឿងប្រជាប់ទំនើប តឹសំពត់ទ្វាអាវ ដោយសូវបុណ្យ
សម្ភារព្រះចារមីអង្គាស់ហោង ។ ទើបព្រះចាខរីវេហពជ មានព្រះ
បន្ទូលដល់ឆ្មឹងអាចារ្យទាំង ៣ រីអាចារ្យទាំង ៣ សឹងទូលស្រេចដូចពាក្យ
អាចារ្យសេនកនោះហោង ។ ស្តេចស្តាប់ពាក្យអ្នកប្រាជ្ញ ៤ ទូលនូវប្រការ
អម្បាលនោះហើយ មានព្រះហឫទ័យត្រេកអរនឹងអាចារ្យទាំង ៤ ស្រេច
ហើយ ស្តេចឲ្យយកវាំន់ទៅជូនអាចារ្យកេវដ្តព្រាហ្មណ៍នោះមួយសារក្រ
វែងមុននោះហោង ។ លំដាប់នោះ រីពោធិសត្វអ្នកដឹងនូវអាចារ្យវិល
ទៅដូច្នោះហើយ អ្នកដោះឡើងស្រេចទំកអប់ត្រឡប់ទៅទូវគន្ធពិដោរ តឹ
ងាងអមកប្រដាប់ប្រដាប្រពៃស្រេចហើយនៃ ព្រះអង្គសោយនូវកោជនា.
ហារត្រកាលផ្សេង ។ ស្រេច ប្រដាប់អាក្នាលីលាឡើងទៅដល់ព្រះពជ
មន្ទីរស្តេច ក្រាបថ្វាយបង្គំអង្គុយក្បែរដីហ៊ានមួយសមគួរខ្លឹងអាក្នា ។ ព្រះ
ចាខរីវេហពជ ឃើលពោធិសត្វមកដល់ហើយ ស្តេចប្រទីព្រះចិត្តថា
រីមហាសថបុត្រនៃអញនេះ មានប្រាជ្ញាខ្លឹងក្រអ្នកប្រាជ្ញឯណាខ្លឹងផ្ទឹមឥត

ស្តើរឡើយ អាថិសេចក្តី អតីត-អនាគត បច្ចុប្បន្ននេះក្តី សឹងមហោសថ
អ្នកប្រាជ្ញអាចដឹងអស់ឥតកំចាំងឡើយ រីឯណើរអញទៅគួរក្តីពុំគួរក្តី
គឺមហោសថបានតិតៀរហើយ ។ ព្រះមហាសត្វ ស្តេចទ្រង់ព្រះចិន្តាឲ្យ
ប្រកាអេម្បាលខោះហើយ ពុំមានព្រះបន្ទូលដូចព្រះតំរិះខោះឡើយ ហេតុ
តែលោកឲ្យចំណងតណ្ហាច្រើន ហើយកើតជាវង្វើងក្នុងក្លាំងស្មារតីមក
បន្ទូលនឹងពោធិសត្វឲ្យគាថា ដូចេ្នះ :

ឆន្ទម្បិ វិតាវ មតិ សមេតិ
យេ បណ្ឌិតា ឧត្តមភូរិបញ្ញា
យានំ អយានំ អថភាបិ ឋានំ
មហោសថ តុំបិ មតិ តកវេហីតិ ។

ម្នាលបុមហោសថអើយ ! រីឯបុាយចំណងនៃយើងទាំង ៦ នាក់នេះ
សឹងខ្លួនឲ្យតំនិតគ្នាស្រេចហើយ ខោះយោបល់អាចារ្យកៅដ្ឋព្រាហ្មណ៍ក្តី
អញក្តី អ្នកប្រាជ្ញទាំង ៤ ក្តី ឯបមាបីដូចស្តឹង សឹងហូរទៅកាន់យមុនា
នទីនាយហោង ខោះយោបល់មានអ្នកប្រាជ្ញឯណា ភូរិបញ្ញា មានប្រាជ្ញា
ទុត្តម រីអ្នកប្រាជ្ញខោះខ្លួលមកស្រដីខ្លួរដំណើរគួរទៅ មិនគួរទៅក្តី ទៅ
មានហេតុដូចម្តេច ។ ក្តី រីឯបុាយនេះ មិនគួរទៅចង់ឡើយ ។

ព្រះពោធិសត្វ ស្តាប់ព្រះបន្ទូលហើយគិតថា ស្តេចនេះលោភខ្លាំ
កាមគុណពេក ហេតុតែកាន់ឿយកតាក្សនៃអាចារ្យទាំង ៤ ជាអ្នក
កំឡៅអន្ធពាលវង្វើង យកខុសជាគាប់ៗជាខុសវិញ បើដូច្នោះ អញនឹង

សំដែងនូវសេចក្តីដែលមានមកក្នុងកាលមុនៗ ឲ្យស្តេចក្រឡាប់ចិត្តហោង
ពោធិសត្វគិតដូច្នោះហើយ ក្នុកទូលនូវគាថាបួនបទ ដូច្នេះថា:

ជាជាសិ ខោ ភទ្ទ មហាឧក្កាវ
មហព្ពលោ ចុលនីព្រហ្មទត្តោ
ភជា ច តំ ឥច្ចតិ មារណាតុំ
មិតំ យថា ភិក្ខចរេន លុទ្ធោ ។
យថាបិ មច្ឆោ ពលិសំ
វង្កំ មំសេន ជាទិតំ
អាមគិទ្ធោ ន ជានាតិ
មច្ឆោ មរណាមត្តនោ ។
ឯវមេវ ភុវំ ភទ្ទ
ចុលនេយ្យសុ នីកវំ
កាមគិទ្ធោ ន ជានាសិ
មច្ឆោ មរណាមត្តនោ ។
សចេ កច្ចសិ បញ្ចាលំ
ខិប្បមត្តំ ជហេសុសិ
មិតំ បច្ចានុប្បន្នំវ
មហន្តំ ភយមេសុតីតិ ។

(នៅមានត)

អក្សរសាស្ត្រខ្មែរ ខ្មែរគួរចែចូន
ឲ្យជានខ្ជាប់ខ្ជួន ជង់រឹងជាតមត់ ។
ព្រោះអក្សរជាតិ ជោលជាតិប្រាកដ
អក្សរលេត ជាតិកំរោយ ។

ប.ព.

ភាសាខ្មែរប្រៀបធៀបនឹងភាសាបរទេស

ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ « ក »

(តមក)

— I —

Impuberté	(n.f.)	អវយបត្តិ (ព.ប្ប.) ។
Inceste	(n.m.)	ការស្មន់ (ព.ប្ប.) ។
Incestueux	(adj.)	នៃលស្មន់ (ព.ប្ប.) ។
Incestueux	(n.m.)	អ្នកស្មន់ (ព.ប្ប.) ។
Incapacité de la femme mariée		អសមត្ថភាពនៃស្ត្រីមានប្តី (ព.ប្ប.) ។
Inexécution des devoirs imposés par la loi		ការល្មើសចំពោះការណីយកិច្ច នៃលច្បាប់បង្ខំ (ព.ប្ប) ។
Infidèle	(adj.)	អស្មាមីកត្តិ (ព ប្ប.) ។
Infidélité de lafemme		អស្មាមីកត្តិនៃស្ត្រី(១) (ព.ប្ប.) ។
Interdire		ឃាត់ (ព.ប្ប.) ឯឯកហ្វូតពីជនម្នាក់ នូវសិទ្ធិត្រប់ត្រង ឬឯងសិទ្ធិជាតិចែងសម្បត្តិខ្លួនដោយសេរី ។

១— បើតាមយោបល់ខ្ញុំ គួរប្រែជាៈ អស្មាមីកត្តិនៃស្ត្រីជាការិយា ឬ នៃការិយា ។

Interdit civil	ឯនត្រូវឃាត់ខាងបរិវេណី (ព.ច្ប.) ។
Interdiction civile	ឯហាត់ខាងបរិវេណី (ព.ច្ប.) ។
Interdit pénal	ឯនត្រូវឃាត់ខាងអាជ្ញា (ព.ច្ប.) ។
Interdiction pénale	ឯហាត់ខាងអាជ្ញា (ព.ច្ប.) ។
Interdiction légale	ឯហាត់ខាងនីត្យានុកូល (ព.ច្ប.) ។

— M —

Le mariage civil est prouvé par l'acte de mariage	អាពាហ៍ពិពាហ៍បរិវេណី មានភស្តុតាងដោយលិខិតអាពាហ៍ពិពាហ៍ (ពច្ប) ។
Mariage du 1er degré	អាពាហ៍ពិពាហ៍ថ្នាក់ទី ១ (ពច្ប) ។
Membre de la Famille Royale	ព្រះរាជវង្សានុវង្ស ។
Motif légitime	ហេតុសមរម្យ (ពច្ប) ។
Modifier un texte	កែប្រែអត្ថបទ (ពច្ប) : កែប្រែអត្ថបទ ឯ លុបអត្ថបទចាស់ ហើយយកអត្ថបទថ្មីមកជំនួសវិញ ។
Modification d'un texte	ការកែប្រែអត្ថបទ (ពច្ប) ។
Muet (n.m.)	មនុស្សគ ។
Muet (adj.)	គ ។
Mutisme (n.m.)	ភាពគ (ពច្ប) ។
Mariage du 2ème degré	អាពាហ៍ពិពាហ៍ថ្នាក់ទី ២ (ពច្ប) ។
Mariage dissous	អាពាហ៍ពិពាហ៍ដែលរលាយ (ពច្ប) ។
Ministre de la minorité ethnique	រដ្ឋមន្ត្រីនៃអប្បភាពជាតិពន្ធុ ។

— N —

Nullités absolues des mariages civils	អោយភាពជាចំនាត់នៃអាពាហ៍ពិពាហ៍បរិវេណី (ពច្ប) ។

Nullités relatives des mariages civils — មោឃភាពមិនដាច់ខាត នៃអាពាហ៍ពិពាហ៍បវេណី (ពប្ប) ។

Nul (adj.) — មោឃៈ ។

— O —

Obstacles au mariage — ឧបស័គ្គចំពោះអាពាហ៍ពិពាហ៍ ។

— P —

Paraphrase (n.f.) — បរប្រយោគ ។ (ត្រូវអានថា : ប៉ៈ-រ៉ៈ-)

Paralytique (n.m.) — មនុស្សឰឝ ។

Paralytique (adj.) — ឰឝ ។

Paralysie (n.f.) — ភាពឰឝ ។

Personnes du sang royal — ព្រះរាជវង្សានុវង្ស ។

Prouve du mariage civil — ភ័ស្តុតាងនៃអាពាហ៍ពិពាហ៍បវេណី (ពប្ប) ។

Prodigue (n.m.) — មនុស្សរាកញ្ជះរាកញ្ជាយ ។

Prodigue (adj.) — រាកញ្ជះរាកញ្ជាយ ។

Prodigalité excessive — ភាពរាកញ្ជះរាកញ្ជាយហួសប្រមាណ (ពប្ប) ។

Prohiber le mariage — អាយ័តមិនឲ្យរៀបអាពាហ៍ពិពាហ៍ (ពប្ប) ។

Prohibition (n.f.) — ការអាយ័តមិនឲ្យរៀបអាពាហ៍ពិពាហ៍ (ពប្ប) ។

Priorité de diriger la famille — អាទិភាពខាងដឹកនាំគ្រួសារ (ពប្ប) ។

Prouver (v.t.) — (ជួន) ភ័ស្តុតាង (ពប្ប) ។

Puissance paternelle — អំណាចអេបា (ពប្ប) ។

Puissance maritale — អំណាចស្វាមី (ពប្ប) ។

(នៅមានត)

វិបដានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ទាំង . ខាត់ រៀបរៀង

(តមក)

អតិឆ្ន គុ. ដែលប្រសើរកន្ធង ដែលខ្ពស់កន្ធង ។

អតិសំវត្ត ប៉ុ. ទោសៈក្រៃលែង ។

អតិសំវុទ្ធ គុ. ដែលសិទ្ធលង់ ដែលលង់ក្រៃពេក ។

អតិសំគ្ឃ ប៉ុ សំឡេងតក្រៃលែង ។

អតិសក្ត គុ. ដែលជាប់ក្រៃលែង ។

អតិសក្តិ ស្ត្រី. សេចក្តីស្និទ្ធស្នាំក្រៃលែង ។

អតិសក្តិមន្ត គុ. ដែលមានសេចក្តីស្និទ្ធស្នាំក្រៃលែង ។

អតិសិ ប៉ុ. សំឡាញ់ក្រៃលែង សំឡាញ់ប្រសើរ ។

អតិសំកដ នប៉ុ សេចក្តីអន្តរាយក្រៃលែង ។

អតិសំកល្ប ប៉ុ. សេចក្តីតម្រិះក្រៃលែង តម្រិះ យល់ត្រូវក្រៃលែង ។

អតិសំក្រុទ្ធ គុ. ដែលក្រោធខ្លាំងក្រៃលែង ។

អតិសំបយ ប៉ុ. កិរិយាសន្សំទុកក្រៃលែង ។

អតិសត្តិ គុ. ដែលគោរពក្រៃលែង ។

អតិត្តរ៉ែម ក្រ.វិ. ដោយឆាប់ហ័ស ។

អតិសទ្ធ ឆគុ. អង្គុយក្រែពក ស្ងាប់ ។

អតិសទយ គុ. ដែលមានសេចក្តីអាណិតកន្ទុង ។

អតិសទ្ធគ្គ គុ. ដែលខ្ជិចឆ្ងាក្រៃលែង ។

អតិសំតត គុ. ដែលដាប់ឆ្ងាក្រៃលែង ដែលដាប់ឆ្ងារធឹក ។

អតិសំជា ឆគុ. ច្រេះច្រែងព្រមក្រៃលែង ច្រេះភ្លែន បញ្ឆោត ឆោត ។

អតិសំជិត គុ ដែលឆោតច្រេសហើយ ។

អតិសំជាឆ ឧបុ. ច្រេះភ្លែន កិរិយាបញ្ឆោត ។

អតិសឌ្ឍេយ្យ គុ. ដែលឆយ្យឹឆ្ងាប់ឆ្ងាក្រៃលែង ដែលឆយ្យឹព្រមត្រៀងឆ្ងាក្រៃលែង ។

អតិសំឆិជាឆ ឧបុ. ទឹងឆ្ងាក្រៃលែង ។

អតិសមបិ គុ. ដែលអាចក្រៃលែង ។

អតិសមិបតា ស្រី. ភាវៈទឹងឆ្ងាក្រៃលែង ។

អតិសមុត្តុម្ភ គុ. ដែលខ្ចាំងក្រៃលែង (សំឡេង) ។

អតិសំខាធ គុ. ដែលចង្អៀតក្រៃលែង ។

អតិសំក្រម ប៉ុ. ការយាវភើមចិត្តក្រៃពេក ការយោញាប់ញ័រចិត្តក្រៃពេក ។

អតិសរស គុ. ដែលប្រកបដោយរសក្រៃលែង ។

អតិសគ៌ី គុ. ប្រទាន ការយោឡ ។ *អតិសជិន* ឧប៉ុ ប្រទាន ការយោឡ ។

អតិសបិណ ឧប៉ុ. ការយោកម្រើកក្រៃលែង (ការកនៅក្នុងគភ៌)។

អតិសវិ គុ. ដែលសព្វគ្រប់ក្រៃលែង ដែលប្រសើរ ។

អតិសវិគ្គុដ្ឋមិ ក្រ.វិ. ប្រកបដោយសេចក្តីចង្អៀតក្រៃលែង ។

អតិសហសា ក្រ.វិ ដោយរហ័សកន្ទុង ។

អតិសំវត្សរ គុ. ដែលអស់ឆ្នាំក្រៃលែង ។

អតិសាង្ឃស ឧប៉ុ. ការយោខ្ចាចក្រៃលែង ។

អតិសាយមិ ក្រ.វិ. ល្ងាចក្រៃពេក ។

អតិសារ ប៉ុ. ភេគភាគអាចមិ ។

អតិសាសហ ឧប៉ុ. សាហ៍សក្រៃលែង ការយោបៀតបៀនក្រៃលែង ។

អតិសាហសិក គុ ដែលប្រកបដោយសាហ៍សក្រៃលែង ។

(នៅមានត)

រឿងល្បែកទ្រាហ្វុងតែន (La Fontaine)

លោក ដេន-ទ្រីវ ប្រែរៀបរៀង

១- ក្អែកនឹងកញ្ជ្រោង

នាយក្អែកពាំសាច់ប្រហុកមួយដុំ ទំលើមែកឫក្សា ។

នាយកញ្ជ្រោងធុំក្លិនប្រហុក ក៏មានវាចាទៅកាន់នាយក្អែកដូច្នេះថា:

" ដំណាងសួរ លោកនាយក្អែក ! រូបលោកនាយស្អាតអ្វីម្ល៉េះទេ បើតាមខ្ញុំថាទយល់ លោកនាយល្អហើយសមផង ខ្ញុំថាទមិនកុហកទេ ប្រសិនបើសូរសៀងលោកនាយតីកេះថែមទៀតផង នោះលោកនាយប្រាកដជាបក្សីវិសេសជាងសកុណាទាំងអស់ក្នុងព្រៃនេះ " ។

សំដីសរសើរប៉ុណ្ណេះ មិនបានធ្វើឲ្យក្អែកសប្បាយអស់ពីពោះទៅទេ ដើម្បីបង្ហាញនូវសូរសៀងដ៏ពីរោះនោះ ក្អែកក៏ហាមាត់យ៉ាងធំធឹងស្រែក ឯប្រហុកជ្រុះក្តុកមកដី ។

កញ្ជ្រោងពាំវាប់ ហើយពោលថា: " លោកនាយ ! សូមលោកជ្រាបពីថ្ងៃនេះទៅថា: អ្នកបញ្ឆោតែងចិញ្ចឹមជីវិតដោយសារតែអ្នកស្តាប់ដំបូន្មានប៉ុណ្ណេះ សូមដូនធឹងប្រហុកមួយដុំនេះចុះ " ។

ក្អែកខ្មាសហើយ តប់ប្រមល់តែក ទើបស្បថថា ពីថ្ងៃនេះទៅ អញឈប់ស្តាប់អាណាឲ្យសោះ ប៉ុន្តែស្បថឥតអំពើ ព្រោះហួសហើយ ។

២- កណ្តុរក្រុងនឹងកណ្តុរស្រែ

កន្លងកាលកន្លងទៅហើយ កណ្តុរក្រុងទៅអញ្ជើញមិត្រកណ្តុរស្រែមកស៊ីលៀងគោជនាហារយ៉ាងឆ្ងាញ់ឯគេហដ្ឋានអាត្មា ។ ម្ហូបអាហារវៀបជាក់លើតុមានតម្រាលយ៉ាងវិចិត្រ ។ គោជនាហារសឹងបរិបូណ៌ឥតខ្វះអ្វី ទាស់តែមានមនុស្សមកធ្វើឲ្យរំខាន ក្នុងគេលដែលមិត្រចាំងពីរកំពុងបរិភោគ ។ គេឮតែសូរមនុស្សដើរនៅក្បែរទ្វារបន្ទប់ កណ្តុរក្រុងស្ទុះភៀតទៅលបមើល កណ្តុរស្រែក៏ស្ទុះក្រោកតាម ។ លុះបាត់ឮសូរមិត្រចាំងពីរត្រឡប់មកកន្លែងវិញ ហើយកណ្តុរក្រុងមានវាចាថា: ត្រូវយើងបន្តើយកតគកិច្ចយើង ។

កណ្តុរស្រែឆ្លើយដូច្នេះថា: ណ្ហើយចុំណ្ងឹងចុះ គួរសមហើយ ស្អែកសូមអញ្ជើញមិត្រទៅផ្ទះខ្ញុំម្ចាស់វិញ ចំណែកគោជនាហារមិនបានដាក់ថ្លៃថ្នូរដូចរបស់មិត្រទេ តែគ្មានអ្វីមកធ្វើឲ្យខ្ញុំដាច់ចិត្តយកទឹក ខ្ញុំខ្លួនឯងតាមអំ.តើចិត្ត ដូច្នេះ សូមលាហើយ ការសប្បាយលាយដោយភ័យ ។

៣- ហ៊ឹងបង់ធំស្មើនឹងគោ

ហ៊ឹងមួយឃើញគោ មើលទៅដូចជាមានរូបកាយធំល្អ ចំណែកខ្លួនមិនធំប៉ុន្មានហួសពីស៊ុតមាន់ ក៏មានចិត្តលោភចង់ចំគោ ប៉ះប៉ាំង ទំធ្វើឲ្យក្រែងធំ មានទំហំប៉ុនគោ ហើយនិយាយទៅប្អូនស្រីវាថា: ប្អូនហង្ឍឯង

មើលអញឲ្យច្បាស់ បើប៉ុនល្មមហើយ ត្រាប់អញ បើមិនទាន់ល្មម អញ
នឹងបំបោរឯងតទៅទៀត ។ - ឫទ្ធស្រីត្រាប់ថា "មិនទាន់ប៉ុនទេ" ។
- ហាងមើលអញមើល ចុះប៉ុនេះ ? ។ - ហ្នឹងក៏មិនទាន់ប៉ុនស្មើ។
- មើលទៀតមើល ចុះប៉ុណ្ណោះ ? ។ - បងឯងគ្មានប្រហែលចន្តិចសោះ ។
សត្វតូចតម្រក់ ទំបំបោរឯងតាល់តែផ្ទុះខ្លួនផង ។

ក្នុងលោកសន្និវាសនេះ មានមនុស្សប្រើនដែលមិនមានសេចក្តីសន្តោស
ជាតិអ្នកធ្វើការកេសុីធម្មតា ចង់ធ្វើឫកដូចអ្នកអង្គម្ចាស់ ជាតិស្តេចតូច។
ចង់មានពាជឲ្យស្មើនតមេហាអំណាច ជាតិអ្នកអង្គម្ចាស់តូចតាច ចង់
ឲ្យមានអ្នកបំរើជាន់ខ្ពស់ដូចស្តេចផែនដីនឹងព្រះអង្គម្ចាស់ ។

៤- កញ្ជ្រោងនឹងក្រសារ

ថ្ងៃមួយ កញ្ជ្រោងរៀបចំកោជនាហារ ហើយអញ្ជើញសំឡាញ់
ក្រសារមកចរិកោត ម្ហូបក៏តិចហើយមិនគ្រប់គ្រាន់ សម្លុះសុទ្ធតែរាវ។
ព្រោះកញ្ជ្រោងតាត់ស៊ីតិច ។ សម្លនេះសោតទៀតជាក់តែកន្លះចានទៀប ។
ក្រសារចំពុះវែងស៊ីពុំបានមួយម៉ាត់ប្តមួយដុំតូចសោះ ។ ចំណែកកញ្ជ្រោង
សត្វឈ្លើយ លិទ្ធតែម្ចាក់ឯងអស់មួយរំពេចកន្លះគោះ ។

ដើម្បីសងសឹក អំពីរឿងបញ្ហោតនេះ មិនកន្លងៅបានប៉ុន្មានថ្ងៃ
ក្រសារក៏អញ្ជើញកញ្ជ្រោងមកស៊ីលៀងដំណែលនៅរបស់ខ្លួនម្តងវិញ ។

ក្រញ្ជោងមានវាចាថា « ពេញចិត្តណាស់ ព្រោះមិត្រកត្តិមានការខ្វល់មិនតឹងតែងទេ » ។

ដល់ពេលកំណត់ : ក្រញ្ជោងត្រាច់ទៅឯផ្ទះក្រសារជាសំឡាញ់ ហើយសំដែងការគួរសមកត់ចាត់យ៉ាងក្រៃលែង ចំណែកមួយបក់ឆ្ពិនស្រែចៈកំពុងតែស្រួលខ្លួនស៊ីអាហារបានផង ក្រញ្ជោងរកពីណាមានមិនមក ជុំកូនសាច់ចិញ្ចាំយ៉ាងឈ្មួយ គាត់រីករាយសប្បាយគិតស្មានថា ម្ពដ៏នេះអស់ក្រឡាហើយ ។

ដើម្បីធ្វើឲ្យក្រញ្ជោងពីចុក ស៊ីមិនកើតវិញ ក្រសារដាក់សម្ភក្នង់ថ្លមួយកវែង ហើយតួចល្មមតែកគាត់អាចលូកចុះ អាឱលក្រញ្ជោងមាត់ធំហួស លូកស៊ីពុំកើត ក្រសារលូកចិកស៊ីតែម្នាក់ឯងធ្វើព្រងើយ ។

ក្រញ្ជោងអត់អាហារត្រឡប់មកផ្ទះវិញ ខ្មាសក្រសារខម្នាក់កន្ទុយជាក់ស្លឹកត្រចៀកចុះ មុខសូត ។

អ្នកបញ្ឆោតគេចាំងឲ្យយ ! ចូរប្រយ័ត្នខ្លួន មានថ្ងៃណា អ្នកមុខជាខឹងបានសេចក្តីអាម៉ាសមុខ ដូចរឿងនេះមិនខានឡើយ ។

៥- សត្វលាពីរ

លាចាំងតែរធ្វើដំណើរជាមួយគ្នា លាមួយ គេផ្ទុកសុទ្ធតែបម្រុង ។ លាមួយទៀត គេផ្ទុកសុទ្ធតែក្រូចឆ្មាប់ លានេះបែកក្រអឺត ដឹងថាខ្លាំងបង់ប្រសើរលើខ្លួន មិនចង់ឲ្យអ្នកណាជួយសម្រាលខ្លួនសោះ ក៏ដើរ

លើកដើងខ្ពស់ ។ ចោរដំហានណែន ។ ហើយអង្រួនប្រាក់ឮធឹង ។ បៃបសង្ឃ
លុះចោរមកដល់ ដ្បិតគេត្រៀមការប្រុងតំ គេស្ទុះទៅកាលដឹកប្រាក់ ចាប់
ចង្កេះហើយបញ្ឈប់ ។ លាខេនចំប្រឹងការពារប្រាក់ ស្រាប់តែដឹងថា
ខ្លួនត្រូវតែចៅព្រៃធំ ហើយឈឺក្រែល ក៏ថ្ងូរដកដង្ហើមធំ ហើយពោលថា:
«កាលគេលះដើម តើគេសន្យាថា ឲ្យចោរកេងអញដូច្នេះឬ? ចំណែក
លាខាងណោះដែលដើរតើរក្រោយ គេរួចពីគ្រោះថ្នាក់ ចុះបង្រៃអ្វីតែអញ
តំបះទៅលើចោរកេងស្ទើរចង់ងាប់» ។

លាខីតរធ្វើយតបថា: «ម្នាលសំឡាញ់! មិនមែនស្រួលប៉ុន្មានទេ
ដែលមានការងារខ្ពង់ខ្ពស់នោះ បើបងឯងបញ្ជិះតែម្ចាស់ដូចខ្ញុំ នោះបង
ឯងធ្វើម្តេចនឹងបានឈើខ្លួន» ។

៦- មេមាន់ស៊ុតមាស

អ្នកកំណាញ់ត្រឡប់ជាខាតដើម មកពីចង់ចំណេញច្រើនពេក ។

មេមាន់មួយ ក្នុងមួយថ្ងៃតែងចេញមាសមួយដុំ ។ អ្នកម្ចាស់មាន់ស្មាន
ថាក្នុងគោះមាន់មានសុទ្ធតែមាសក៏សម្លាប់មាន់ ពុះរកមើលហើយឃើញ
ដូចជាមាន់ធម្មតា: នេះគឺបំផ្លាញតែខ្លួនឯង នាំខាតឧស់បៃស់ដ៏ច្រើនសែរ ។

រឿងនេះ ជាដំបូន្មានដល់អ្នកកំណាញ់ ដែលត្រឡប់ទៅជាអ្នកកំ
សត់វិញ ឥលប់ព្រឹក ឥលប់ល្ងាច គោះបីដល់ពេលខ្លួនដិតស្លាប់ក៏ដោយ
ព្រោះតែចង់បានជ្រុលពេក ។

សុភាសិតខ្មែរ: ''លោកហួសខ្នាត នាំទាតដើម'' ។

៧- បបរកន្ធឹងក្រសារ

សត្វបបរស៊ីចំណីអាក្រក់ណាស់ ។

មានបបរមួយ រកបានរំពាមួយយ៉ាងហ៊ាំ អរពេក ស៊ីរឡៃបរឡប់មិនប្រយ័ត្ន ស្លាក់ឆ្អឹងមួយដុំធំខ្លាំងចំពងក ឈឺស្ទើរចង់ផាប់ ។ ខេសកាលអ្វី ហេតុតែបុណ្យបបរ ដែលហាមាត់ស្រែកមិនរួចសោះនោះ លោតែមានក្រសារមួយដើរមកតែម្នាក់ឯង បបរឆ្លើសញ្ជា ក្រសារតម្រង់មកភ្លាម ចាប់ធ្វើការមួយរំពេច មិនឲ្យឃើតយូរ ចឹកពាក្បឆ្អឹងមកក្រៅបាន រួចតវាថ្លៃឈ្នួល ។ បបរឆ្លើយថា: ''អ្វី? ថ្លៃឈ្នួល? ឃើសើចផងអាសំឡាញ់! អ្វី! ឲ្យអាឯងដឹកកចេញផុតពីមាត់អញមកក្រៅប៉ុណ្ណឹង ខៅមិនចាន់ល្មមចិត្តខៀតឬ? ចៀសចេញទៅ អាមិនស្គាល់គុណគេ កុំឲ្យអញខាំចំថែកក្បាលថែមខៀត ខុកជាគ្រាន់បើហើយ! ។

៨- សត្វលាយកស្បែកសិង្ហមកគ្របលើខ្លួន

លាមួយយកស្បែកសិង្ហមកពុំដិតខ្លួន ធ្វើឲ្យគេខ្លាចកន្ធឹងដំបន់នោះ ។ គួរដែរឬ សត្វចោលមៀតគ្មានអំណាចអ្វីសោះ ចេះធ្វើឲ្យគេញាប់ញ័រកិតក័យអស់ពាំងស្រុក ។

ចៃដន្យអ្វីហេតុតែកម្ម ស្រាប់តែពុងស្វឹកគ្រេកលេចចេញមកបន្តិច
នាំឲ្យអ្នកទាំងអស់គ្នាស្គាល់ថាជាសត្វលា ។ បាត់ភ្ញាក់ផ្អើលខ្លាចវិញ
ស្រាប់តែដំបងលេចឡើងព្រោងព្រាត សំពងសត្វលាតរុណយ៉ាងខ្លាំង ។
អ្នកខ្លះដែលមិនយល់ នឹកឆ្ងល់ថា ហេតុម្តេចក៏គេហ៊ានដេញសង្ឃឲ្យរត់
ជ្រកក្នុងកេងស្ទាល់កិនបានដោយងាយ ។

៩- សិង្ហនឹងកណ្តុរប្រែង

កណ្តុរប្រែងមួយចេញពីរូងមក ចៃបល្ងំលើខ្លាំង ស្រាប់តែដើរទៅ
ខៅក្បែរដើងសត្វសិង្ហមួយ ។ ក្នុងពេលនោះ ស្តេចសត្វចតុប្បទសំដែង
ចិត្តមេត្តា កំទុកជីវិតឲ្យដល់កណ្តុរនោះ ។

ការល្អមិនដែលសាបសូន្យឥតផលឡើយ ។

ក្រោយមក មិនយូរប៉ុន្មាន សិង្ហដើរទៅជាប់ក្នុងសំណាញ់អន្ទាក់ព្រាន
ខោះបីខំប្រឹងស្រែកឮរំពងព្រៃយ៉ាងណា ក៏សិង្ហមិនអាចដោះខ្លួនឲ្យរួចពី
អន្ទាក់បាន កណ្តុរមិនភ្លេចគុណក៏តំរង់មកភ្លាម ហើយកកេរសំណាញ់ដាច់
ខ្លួចខ្លីអស់ ។

ខន្តីនឹងពេលជំយូរ ប្រសើរជាងកម្លាំងនឹងការក្តុងក្តាំង ។

រឿងខាងលើនេះ បានតតិពីរយ៉ាង:

សុភាសិតខ្មែរ ①- អំតើល្អមិនដែលសាបសូន្យឥតផល;
②- ការតូងតាងមិនស្មើការអំណត់ ។

១០- ព្រាបនឹងស្រមោច

មានព្រាបមួយចុះមកផឹកទឹកនៅមាត់ត្រពាំង ទឹកយ៉ាងថ្លា កុំតុងតែខ្មេនផឹក លោក្រឡេកទៅឃើញស្រមោចមួយអណ្តែតរវើក ។ នាកណ្តាលត្រពាំងនោះ ហើយកំពុងតែខំប្រឹងហែលទៅ ។ ដើម្បីមករកខាង ប៉ុន្តែឥតអំពើ ។

ខណៈនោះ ព្រាបលោមានចិត្តល្អ ក៏ចឹកកូនមែកឈើមួយទង់ចុះទៅ មែកឈើតូចនេះ ដូចជាគោះថ្នាយ៉ាងធំដល់ស្រមោច ។ ហើរឡើងទៅលើមែកឈើបានរួចរស់ជីវិត ។

ក្រោយនោះបន្តិចមក មានព្រានដើងទេម្នាក់ មករកចាប់សត្វស្លាយស្មាមួយទៅស្មា ដើរលេង ។ ចំរុងចាប់ព្រាបខាងលើនេះ គេមានចិត្តសប្បាយខ្លុកជាមុនថា មុខជាសើមមាត់ហើយជាន់នេះ ។

តែដល់កំពុងតែយឺតស្មាយ៉ាងតឹង ហើយដំរង់ជាស្រេច រៀបនឹងដំរោះកៃ ស្រមោចទាំតែងចាប់ ព្រានភ្ញាក់ដើងឆាកក្បាលមើល ព្រាបឮសូរហើរគឹលទៅឆ្ងាត់ សម្លឹងដែលព្រានបានតែតខ្លុកកំហើរទៅជាមួយផង អស់រលីង ។

១១- ឆ្មាំងជីនឹងឆ្មាំងដែក

ឆ្មាំងដែកនិយាយបបួលឆ្មាំងជី ឲ្យធ្វើដំណើរទៅស្រុកឆ្ងាយលេងជាំ

មួយគ្នា ។ ឆ្នាំងដទៃយោយអង្វរសូមទោសថា: ខ្ញុំនៅតែផ្ទះ ស្បែរដើង ក្រានបានហើយ ព្រោះខ្ញុំគ្រាន់តែប៉ះនឹងតែអ្វីបន្តិចមុខជាអន្តរាយមិនមាន ចំណែកអ្នក ស្បែកនឹងជាន់ខ្ញុំ ។ យល់ថា អ្នកឯងគ្មានអ្វីជាគ្រឿងឧបស័គ្គ ឡើយ ។ ឆ្នាំងដែកតបថា: យើងជាអ្នកការពារ អ្នកមិនត្រូវព្រួយ ឡើយ ប្រសិនបើ តាមផ្លូវ លោជាមានវាតអ្វីឯង ។ បំរុងមកខ្ចីចអ្នកឯង យើងជាទាស្ទុះទៅឈរកណ្តាល ហើយយើងខ្ចីចតែ ១ ប៉ុន្ម អ្នកឯងនឹង រួចខ្លួនប្រាកដ ។

ពាក្យប៉ុណ្ណោះនេះ ធ្វើឲ្យឆ្នាំងដីខុកចិត្តអស់តីរោះ ហើយយល់ព្រម តាម ។ ឆ្នាំងដែកឈរទទឹមឆ្នាំងដី រួចអ្នកទាំងពីរចេញដំណើរល្អិចល្អន់ ។ រមៀលខ្ចីចគ្នាទៅវិញទៅមក គ្រាន់តែប៉ះនឹងអ្វីតូចមួយ ឆ្នាំងដី ស្រែកថ្ងូរ មិនបានទាំង ១ រយដំហានផង ឆ្នាំងដីបែក ២ ចោយប៉ះ ខ្ចីចតែនឹងគ្នាឯង មិនបាច់ចាំព្រួយខ្លាចក្រែងអ្នកដទៃមកខ្ចីចឬធ្វើឲ្យ បែកឡើយ ។

ត្រូវយើងកល់គ្នាដើរចូលតែនឹងមនុស្សមានភាពស្មើគ្នា បើតុំដូច្នោះ ទេ ខ្លាចក្រែងយើងនឹងដូចជាឯកសាឆ្នាំងដីខាងលើនេះ ។

១២- បបែកនឹងកូនចៀម

កូនចៀមមួយចុះរកផឹកទឹក នៅមាត់ស្ទឹងមួយទឹកយ៉ាងថ្លា ។ ចចក

ដែលអត់អាហារយូរថ្ងៃហើយ ដើរស្វែងរកចំណី មកប្រទះកូនចៀមនៅ
ទីនោះដែរ ។ បចកកំញើញកូនចៀមថា « អាណាបើកអំណាចឲ្យអាឯង
មកកកូរទឹកអញល្អក់ដូច្នេះ អាឯងត្រូវហើនឥតតិចារណា អាត្រូវពោស
ឥឡូវមិនខានឡើយ » ។

កូនចៀមឆ្លើយថា: សូមទ្រង់ព្រះមេត្តាប្រោស សូមកុំមានព្រះហឫ-
ទ័យខ្ញាល់អ្វីឡើយ សូមទ្រង់ពិនិត្យសំគាល់មើលសិន ដែលខ្ញុលព្រះបង្គំ
ចូលមកផឹកនេះ គឺនៅឆ្ងាយពីទ្រង់ប្រមាណ ២០ ដំហាន ហើយក្រោម
ទឹកផង ហេតុដូច្នេះ ខ្ញុលព្រះបង្គំធ្វើដូចម្តេច នឹងអាចធ្វើឲ្យល្អក់ទឹក
ទ្រង់បាន ។

បចកស្រែកគំហកវិញមកទៀតថា: អាឯងហ្នឹងធ្វើឲ្យល្អក់! ហើយម្យ៉ាង
ទៀត ពីឆ្នាំទៅ អាឯងនិយាយដើមអញ ។ ដឹងឬស្សាស់ ។

កូនចៀមឆ្លើយទៀតថា: ខ្ញុលព្រះបង្គំនិយាយដើមដូចម្តេចកើត បើ
ខ្ញុលព្រះបង្គំមិនទាន់ចាំងកើតផង សត្វថ្ងៃខ្ញុលព្រះបង្គំនៅចុងដោះម្តាយ
នៅឡើយ ។

– បើមិនមែនអាឯង ក៏បងអាឯងដែរ! ។

– ខ្ញុលព្រះបង្គំគ្មានបងទេ ។

- បងប្អូនសាច់ញាតិអាឯង គ្មានប្រយ៉ូ អាឯងពាល់គ្នាខេះគ្នាខេះ សន្តោសអញម្តងសោះទេ អ្នកតង្វាលអាឯងក្តី ឆ្កែអាឯងក្តី ពេលនេះត្រូវតែអញសងសឹកវិញ ។

គ្រាន់តែពោលប៉ុណ្ណោះហ៊ាយ ចចកមិនចាំដែកវែកតទៅទៀត ឲ្យយូរការ ព្រោះឃ្លានតេក ក៏ស្ទុះទាំពាំកូនចៀមយកបួលត្រៃបរិភោគ ។

(នៅមានត)

គតិលោកយោគគតិធម៌ ពួកមនុស្សគ្រប់ពណ៌ ត្រូវគោរព ត្រូវរៀនឲ្យយល់ បេះឲ្យសព្វ កាយ កប់មួយមួយ ពុំប្រសើរ ។ ទាំងពីរនេះប្រៀបដូច កង់បក្រ ត្រូវរឹលប្រទាក់ កុំឲ្យស្ទើរ កុំឲ្យមួយរត់ មួយត្រឹមដើរ ឈ្មោះថាដំណើរមិនប្រពៃ ។

ផេង - ផ្ទឹ

កំណាព្យទី ៤៩

ទេសន៍វិបុលកវដ្តសេនា ន្ធ-កាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាឃុទ្ធសាស្ត្រ
អ្នកវាងវៃធ្វាសបើបានអាន
ទំាងបេះទយយកលច់ណាន
ទាំងមានសន្តានស្នេហាជាតិ

ឃ្លេ - អ៊ុន

ចូឆ្នូក៏ត្រឡប់ចូលបន្ទាយ ហើយនិយាយនឹងភៅធូថា មាំឈៀវនេះដឹងថាអ្នកឯងជាគាហានខ្លា ឃានជាខ្លាចថ្លៃដៃអ្នក ភៅធូឆ្លើយថា ព្រឹកស្អែកនេះខ្ញុំឃានទំាងសុំយកអាសាចេញភៅតយុទ្ធគ្នានឹងមាំឈៀវ ហើយនឹងចាប់យកខ្លួនមាំឈៀវឲ្យឃាន ចូឆ្នូឆ្លើយថា ឯមាំឈៀវនោះគេក៏ខ្លាំងពូកែណាស់ដែរ អ្នកកុំអាលមើលងាយប្រមាទឡើយ ភៅធូថា បើខ្ញុំឃានចាប់ខ្លួនមាំឈៀវមិនឃានទេ ស៊ូតែស្លាប់កណ្តាលសមរភូមិ ហើយភៅធូក៏ឲ្យចំរើកាន់សំបុត្រភៅដល់មាំឈៀវទំាងកណ្តាលយប់នោះថា ព្រឹកនេះឲ្យមាំឈៀវចេញមកច្បាំងនឹងយើងកុំឃាន មាំឈៀវឃើញសំបុត្រទំាងខ្លាំងណាស់ និយាយថា ភៅធូនេះចរចាត្រហើនមើលងាយយើង

តេកណាស់ ថ្ងៃដែកយ៉ាងណាទៅវេលាព្រឹកនេះ យើងនឹងលើកទាហាន
ចេញទៅចាប់ខ្លួនក៏ឲ្យត្រាតែបាន ។

លុះដល់តេលព្រឹក ទៅធ្លូនឹងមាំឈៀកំលើកទាហានចេញពីបន្ទាយ
រៀងខ្លួន កាលចេញទៅប្រទះមុខគ្នាហើយ មាំឈៀគិបរេសទៅបញ្ជា
ពីមុខទាហានត្រលែងភែងហើយស្រែកថា នរណាជាទាហានខ្លាំនោះ ឲ្យ
ចេញខ្លួនមកល្បែងថ្ងៃដែគ្នា បួធួបញ្ជារេសទៅមុខទាហាន និយាយថា
មាំឈៀនេះមានកម្លាំងច្រើនណាស់ ប្រហែលគ្នានឹងលីចាំ បួធួនិយាយ
មិនទាន់ផុតមាត់ ទៅធ្លូក៏បរេសបួលទៅតយុទ្ធគ្នានឹងមាំឈៀ ។ នឹងទៅ
ធ្លូតយុទ្ធគ្នាបាន ១០០ ភ្លែង មិនបានខន់ថយជាងគ្នាទាំងសងខាង តែរេស
អស់កម្លាំង នាំគ្នាថយសំពកក្រោយទាហានហើយផ្លាស់យករេសថ្មី នាំ
គ្នាចេញតយុទ្ធម្ដងទៀតបាន ១០ ភ្លែង ។

កាលទៅធ្លូចេញទៅចាំងឹងមាំឈៀជាលើកទី ២ នោះ មានទា
សោយណ្ដាលឡើងពេញខ្លួន ដោះគ្រោះចេញអស់ពីខ្លួនប្រយុទ្ធគ្នា ពួក
ទាហានទាំងសងខាងឃើញនាយមានកម្លាំងស្មើគ្នា មិនមានខន់ខ្លាយ
ជាងគ្នាដូច្នោះ ក៏នាំគ្នាស្រែកហោកគ្រៀវគឺងកងទាំងសងខាង ឯមាំឈៀ
នឹងទៅធ្លូតស៊ូគ្នាទៀតបាន ៣០ ភ្លែង ទៅធ្លូមានកំហឹងពេញកម្លាំង លើក
ជាវឡើងកាប់សំដៅខ្លួនមាំឈៀ ។ តេចខុសគាស់ទាត់ដោយចុងលំពែង
ហើយចាក់តម្រង់ដើមទ្រូងទៅធ្លូ ។ ចោលជាវចេញពីដៃចាប់កន្ត្រាក់យក

លំពែងពីមាំឈៀវ ។ ទីដែលទៅធ្លក់ដណ្តើមលំពែងគ្នាពាល់ពែងបាក់ជាពីរកំ-
ណាត់ ម្នាក់បាន ១ កំណាត់ ក៏វាយគ្នាជាប់ទៅវិញទៅមកលើខ្លួនសែះ
ចូនូវឃើញដូច្នោះខ្លាចក្រែងទៅជូនដំណឹង ទីដែលមាំឈៀវគឺប្រើហៅហ៊ូអឿន
ចោហង្ស ២ នាយដំរីសែះចូលទៅជួយទៅនូ ។

ចុំដែរតែកទីដែលមាំតាយឃើញដូច្នោះ ក៏ចរសែះចូលទៅជួយមាំឈៀវ
ពាហនតាំងសងខាងនេះក៏ប្រឡូកជាប្រឡំចលំទៅវិញទៅមក ពួកពា-
ហនមាំឈៀវបាញ់ធ្នូត្រូវខ្លួនទៅនូជាប់ព្រួញពីរផ្លែ ពាហនចូនូឃើញ
ដូច្នោះក៏បាក់ទ័ពត្រឡប់ចូលបន្ទាយ មាំឈៀវបានការកំចរពេលចូលប្រ-
កាប់ប្រហារទៅដល់ក្បែរបន្ទាយ ចូនូឲ្យបិទទ្វារបន្ទាយជិតមិនឲ្យចេញ
ច្បាំងតាំងតែចាត់ការយោមល្បាតជាមាំមួន មាំឈៀវកំលើកពាហនចូល
បន្ទាយវិញ ហើយនិយាយទីហ៊ានស៊ុយថា តាំងពីបានធ្វើការច្បាំងគ្នា
មកដល់ថ្ងៃនេះ មិនដែលឃើញនរណាចូលចម្បាំងចេញកម្ចាំងគេសោ
ទ្រទន់អង់អាចដូចជាទៅនូនេះគ្មាន កំរិយាក៏ដូចខ្លា សមដូចពាក្យដែលឮ
នោះមែន ។

ខណៈនោះ ចូនូឃើញថា មាំឈៀវខ្លាំងពូកែណាស់ ធើបប្រើស៊ុ-
ឡុងទីដូឡងឃុំពាហនលើកទៅតាំងបន្ទាយនៅត្រើយទិសខាងលិចជា
ទ័ពសន្ធប់មាំឈៀវទុក ហើយឡើងឈរនៅលើទីដ៏ខ្ពស់ ក្រឡេកទៅ
ឃើញមាំឈៀវទីពាហនសែះនៅមុខបន្ទាយប្រមាណ ៣០០ ធើបដោះ

មួកតឹកស្បែលចុះចោលទៅហើយថា មាំឈ្មែវនេះប៉ែកមិនស្មាប់នឹងដៃយើងទេ អំណើះតទៅខាងមុខគង់ក៏ធ្វើអន្តរាយដល់យើងវិញជាមិនខាន សតយើងនេះមិនដឹងជាកំណាត់ថានឹងធ្លាក់ទៅត្រង់ទីណា ហៃហ៊ូអៀនបានឮចូធ្លូថាដូច្នោះ ក៏នឹកខឹងណាស់ឆ្លើយថា ខ្ញុំបាននឹងគាសាចេញកំចាត់មាំឈ្មែវចេញឲ្យផុនចូធ្លូយ៉ាត់ដូចម្តេចក៏មិនស្តាប់ ស្រាប់ដែលឡើងដំរះសេះយ៉ុំនាំគាហានចេញតាមក្រោយទៅ ចូធ្លូឃើញហៃហ៊ូអៀនកំពុងខឹងណាស់ ក្រែងថ្លស់ការនឹងមាំឈ្មែវ ក៏លើកគាហានតាមទៅពីក្រោយ មាំឈ្មែវឃើញហៃហ៊ូអៀនលើកគាហានចេញមកដូច្នោះ ក៏បះសេះចូលទៅនឹងតស៊ូគ្នានឹងហៃហ៊ូអៀន ខ្លួលក្រឡែកទៅឃើញខង់ឥតហ្លួងជោតមកជាសំគាល់ ក៏ដឹងថាចូធ្លូជាកងដូនលើកតាមមកខៀត មាំឈ្មែវក៏មិនបានចូលតច្បាំងនឹងហៃហ៊ូអៀន ក៏លើកគាហានបះសេះគេចដម្រង់ទៅចំងឹងចាប់ខ្លួនចូធ្លូវិញ ។

ចូធ្លូក្រឡែកឃើញដូច្នោះ ក៏ភ័យស្ទុះស្មារតី គាញបង្ហៀរសេះតត្រឡប់ទៅក្រោយ គាហានទាំងពួងក៏បែកបាក់ត្រាត់ក្រាយគ្នា មាំឈ្មែវឃើញបានការក៏ដេញគាហានចូលប្រកាប់ពីក្រោយ ស្រាប់តែមានគាហានម្នាក់មកប្រាប់ថា ឥឡូវចូធ្លូឲ្យគាហានលើកទៅតាំងបន្ទាយចាំខ្លួប់ពីក្រោយទៅត្រើយខាងលិច មាំឈ្មែវឮដូច្នោះនឹងដេញឲ្យជ្រុលហួសទៅមិនបានរាំងក្រោយក៏ឲ្យនឹកក្រែងខ្លាច ទើបប្រមូលគាហានត្រឡប់

ចូលបន្ទាយវិញ ហើយប្រឹក្សាទឹងហ៊ានស៊ុយថា ឥឡូវចូរឲ្យគាហានលើកទ្ធនៅត្រើយម្ខាង តាំងបន្ទាយសម្រាប់ចាំខ្លប់ខ្លាតយើង។ ទឹងហ្លាំងតាំងសង្ឃខាងកំឃើញថាលើសកម្លាំងណាស់ទឹងហ្លាំងម្តេចបាន ទឹងគិតកែទៀប ប្រការម្តេចឲ្យស្រួល លីទាំងហានហ៊ានស៊ុយឆ្លើយថា ដែលចូរឆ្លើងគាគ្រានេះយើញសមើមខ្លាំងណាស់ សូមឲ្យលោកតិតកេតុថាយជាមេត្រីទឹងគ្នាវិញ កុំធ្វើសង្គ្រាមតទៅទៀយ តាំគ្នាលើកទ័ពត្រឡប់ទៅសិនបើហួសខែស:កាល:រដូវណា សឹមគិតធ្វើការតទៅទៀត ។

ហ៊ានស៊ុយឮដូច្នោះ កំនិយាយទឹងម៉ាឈៀវថា ពាក្យដែលលីទាំនិយាយនេះកំឃើញថាជាការគួរស្តាប់ណាស់ លួមអ្នកទឹងអនុក្កួលតាមចុះម៉ាឈៀវកំទៅសឿម អៀវឈើវហៅឈួន គាហានហ៊ានស៊ុយឆ្លើយថា ដែលលីទាំនិយាយនេះគួរណាស់ សូមឲ្យលោកធ្វើតាមចុះ ហ៊ានស៊ុយកំតែងជាសំបុត្រហើយឲ្យអៀវឈើវកាន់ចូលទៅក្នុងបន្ទាយចូរ្ន សេចក្តីថាយើងតាំងសង្ឃខាងទឹងហ្លាំងគ្នាដូច្នេះមិនគួរទេ ព្រោះពេលនេះជាខែស:កាល:រដូវណាស់ យើងតាំងសង្ឃខាងចូលជាមេត្រីទឹងគ្នា លើកទ័ពត្រឡប់ទៅវិញចុះ ។

ចូរ្នឃើញសេចក្តីសំបុត្រដូច្នោះ កំនិយាយទឹងគៀវឈើវថា អ្នកចូលត្រឡប់ទៅបន្ទាយប្រាប់នាយរបស់អ្នកចុះថា ព្រឹកស្អែកយើងនឹងតបសំបុត្រ ទាវិញ អៀវឈើវកំលាចូរ្នទៅ ទីប្រឹក្សាតាំងពួងក៏សួរចូរ្នថា ដែល

ទបពាជនីឆ័តបសំបុត្រទៅវិញនោះទើបនិយាយដូចម្តេច ចូចូរធ្វើយថា ដែលយើងនិយាយនេះ ជាទុក្ខយកែឆ្ងល់ខ្លួលតាក្សតែមាត់ក្រៅទេ លុះព្រឹកឡើងទើបប្រើប៉ើកាន់សំបុត្រចូលទៅក្នុងបន្ទាយហ៊ានស៊ុយ សេចក្តីថាដែលអ្នកទើងយើងមិនបានធ្វើសង្គ្រាមទើឆ្ងាតទៅនោះ យើងកំត្រូវចិត្តណាស់ រំលានេះយើងនឹងរៀបលើកទ័ពត្រឡប់ទៅវិញជាពាប់ពុំមាន់ត្រូវបង្ហឹមបន្ទិចទៅសិន រួចចូចូរកំប្រើមនុស្សឲ្យធ្វើស្ពានចែបដូចជានឹងនាំពលទ្ធឆ្ងាទៅ ប្រាថ្នាទើងឲ្យម៉ាឈៀនើងហ៊ានស៊ុយដឿចិត្ត ។

ឯម៉ាឈៀលុះយើញសំបុត្រសេចក្តីដូច្នោះ កំយាយទើងហ៊ានស៊ុយថា ដែលចូចូរឲ្យមានសំបុត្រទុក្ខលតាក្សដូច្នោះកំមែនហើយ តែថាយើងទើងដឿចុកចិត្តជាប្រាកដមិនបានត្រែងវាបញ្ឆោតយើង សូមលោកចាត់ការឲ្យត្រៀមពលយោធាទុកសម្រាប់តទល់នឹងទ័ពមុខចូចូ ខ្ញុំបាទនឹងចាត់ចែងទាហានទុកខ្លួលទ័តបញ្ឆោតរួចប់ពីក្រោយ ហ៊ានស៊ុយយល់យើញត្រូវ កំត្រួតត្រៀមពលទាហានចាំនឹងតួងតាមភាក្សម៉ាឈៀ ។

ចូចូរដឹងថា ហ៊ានស៊ុយក្បាខ្ទាទ័ទាងតយមុខ ចូចូរអណាស់និយាយថា ត្រូវទើងទុបាយយើង ការរបស់យើងនឹងសម្រេចជាប្រាកដ លុះព្រឹកឡើងចូចូរកំឃ្លាំទាហានចេញទៅក្រៅបន្ទាយ ទាងទាហានហ៊ានស៊ុយយើញចូចូរលើកចេញមកកំគិតថា ចូចូរនឹងលើកទ័ពទៅ មិនឆ្ងាយើញរួបចូចូរ ពួកទាហានចាំងអស់នោះកំប្រជ្រៀតគ្នាចេញទៅមើលក្រៅបន្ទាយ

ស្រែកប្រាប់គ្នាថា មកមើលបូឆួរើយគ្នាយើង បូឆួបរសេះទៅមុខពាហន
ហើយស្រែកថា អញមានភ្នែកពីរ មាត់១ ប្រមុះ១ ដូចខ្លួនពាល់គ្នាដូច្នេះ
ដែរ មិនមែនមាត់ពីរ ភ្នែក៤ទេ តែថាប្លែកបន្តិចដោយមានអំណាចច្រើន
គឺជាមនុស្សដែលមានប្រាជ្ញាទន់សេចក្តីគិត ទរណាចង់មកមើលក៏មកចុះ
ពាហនហ៊ានស៊ុយឮដូច្នោះក៏កំតកំយ៉ាឈរមើលក្បែរខ្លួន ទើបបូឆួប្រើ-
ហានឲ្យទៅប្រាប់ហ៊ានស៊ុយថា មហាទុបរាជឲ្យគេញើញអ្នកចេញទៅ
សន្ធនាគ្នា ។

ហ៊ានស៊ុយឮដូច្នោះ ក៏បរសេះចេញមកក្រៅបន្តិច បូឆួឃើញហ៊ាន-
ស៊ុយចេញមកក៏ដោះក្រោះចេញ ពាក់តែអាវតាមជម្ងាបរសេះចូលទៅ
ទីមគ្គានឹងសេះហ៊ានស៊ុយតែមួយនឹងមួយក៏គន់ប់គ្នាទៅវិញទៅមក បូឆួ
និយាយថា ខ្លួនអ្នកនឹងខ្ញុំក៏មិនមែនដទៃ ចិតារបស់អ្នកខ្ញុំក៏ជានគំនាប់រាប់
អានគ្នាថាជាមា ខ្លួនយើងទាំងពីរគាលនៅតែតម្លោះតំជានាម៉ឺនធ្លើរជាការ
នៅជាមួយគ្នា ជាមនុស្សត្រូវអធ្យាស្រ័យគ្នា ឥឡូវយើងបែកចាកគ្នាមកយូរ
ហើយ ទើបនឹងមកប្រទះគ្នាគ្រានេះ អាយុអ្នកជាន់ប៉ុន្មានហើយ ហ៊ាន-
ស៊ុយឆ្លើយថា អាយុខ្ញុំជាន ៤០ ឆ្នាំហើយ ។

បូឆួក៏ធ្វើជាយកដៃអង្អែលទ្រូងហើយថា យើងធ្លើរជាការនៅជាមួយ
គ្នាកន្លងស្រុកក្រុងភ្លាម ។ សោះ លោតែងឃ្លាតចាកគ្នាមកដូច្នេះ ដូចជាមិន
ជាន់ប្រាប់ខ្លួនអាយុកន្លងទៅដល់ប៉ុណ្ណោះហើយ កាលណាស្រុកយើង

ទើបកបាបជាប្រក្រតី ។ ដើមឡើងពីវេលាថ្ងៃនោះ ទើបបានប្រាស្រ័យគ្នាជាមួយគ្នាទៀត ហ៊ានស៊ុយទើបចូលទូលនិយាយគ្នាក្នុងវិថីនោះ ទើបបានប្រាស្រ័យពីកិច្ចការសង្គ្រាមកំពេលនោះ អ្នកទាំងពីរក៏នាំគ្នាសើចពោរពេញជាមួយគ្នា លុះដល់វេលាមៅងឲ្យ ហើយក៏ត្រលប់គ្នា ។ តាហានម្នាក់ក៏ចូលទៅប្រាប់ម៉ាឈៀវថា ឥឡូវហ៊ានស៊ុយចេញទៅនិយាយទើបចូលយូរណាស់ ទើបនិយាយពីកិច្ចការអ្វីក៏មិនយល់ឡាស់ ។

ម៉ាឈៀវក្តដូច្នោះក៏ទៅសួរហ៊ានស៊ុយថា លោកចេញទៅនិយាយអ្វីទើបចូលក្នុងវិថីសង្គ្រាមក្នុងថ្ងៃនេះ ? ។ ហ៊ានស៊ុយឆ្លើយថា និយាយរំលឹកដល់រឿងពីដើម ដែលធ្លាប់ជួបធ្វើពាសការជាមួយគ្នា ។ ម៉ាឈៀវសួរថា លោកមិនបានចរចាដោយកិច្ចការសង្គ្រាមទេឬ ? ។ ហ៊ានស៊ុយថា ចូលមិនបានចរចាទេ ខ្ញុំឯងក៏មិនបាននិយាយដែរ ។ ម៉ាឈៀវមានសេចក្តីសង្ស័យនៅតែស្មៀម មិនបាននិយាយថាប្រការម្តេច ក៏ត្រឡប់ទៅវិញ ។

កាលចូលត្រឡប់ទៅដល់ចន្លោះ ក៏សួរការសៀនថា ពីព្រឹកមិញយើងចេញទៅនិយាយការនឹងហ៊ានស៊ុយនោះ អ្នកដឹងយល់ខ្លៃបខាយរបស់យើងប្រការម្តេចខ្លះឬទេ ? ។ ការសៀនថា ខ្លៃបខាយលោកដែលចេញទៅនិយាយនឹងហ៊ានស៊ុយនោះ ជាសេចក្តីសំខាន់ល្អណាស់ តែថា

ម៉ាំឈៀវនឹងហ៊ានសុីយនៅមិនទាន់មានសេចក្តីសង្ស័យអ្វីនឹងគ្នាទេ ខ្ញុំបាទ
គិតថា បើជាធ្វើកលមួយយ៉ាងទៀត ប្រហែលជាកើតសង្ស័យនឹងគ្នា
មិនខាន ។

ចូឆួសួរថា តំនិតរបស់អ្នកឯងនឹងគិតធ្វើប្រការម្តេច ។ កាសៀង
ថា ខ្ញុំបាទគិតនឹងឲ្យយកក្រជាសទៅប្រកកន្ត្រឹស្រោម ហើយសរសេរ
ការខ្នងជាអក្សរថៃបរលុបកុំឲ្យមើលឃើញតួរអក្សរច្បាស់ ឲ្យចំរើម្ចាក់ទាន់
យកទៅឲ្យហ៊ានសុីយ ហើយឲ្យធ្វើជាថា នេះសំបុត្រជាការសម្ងាត់ បើ
ម៉ាំឈៀវដឹងគន់នឹងទៅមើល កាលណាហែកស្រោមយកមក ឃើញតែ
ក្រជាសទេក៏គន់នឹងសង្ស័យថា ហ៊ានសុីយលាក់សំបុត្រនោះ ហើយយក
តែស្រោមនឹងក្រជាសទេមកភ្លក់ឲ្យមើល មុខជាម៉ាំឈៀវនឹងហ៊ានសុីយ
គន់នឹងមន្ទិលចិត្តគិតសង្ស័យនឹងគ្នាមិនខាន រួចអំពីនោះ សឹមយើងគិត
ប្រើមនុស្សឲ្យទៅចរចាបញ្ចុះបញ្ចូលយកខ្លួនហ៊ានសុីយ មកខុកជាពួកយើង
វិញ មុខជានឹងកំចាត់ម៉ាំឈៀវបានដោយងាយ ។

ចូឆួស្តាប់យល់ត្រូវណាស់ ក៏ឲ្យយកក្រជាសមកប្រកស្រោម ហើយ
ការខ្នងស្រោមតាមសំដីកាសៀង ឲ្យចំរើម្ចាក់ទាន់យកទៅឲ្យហ៊ានសុីយក្នុង
បន្ទាយ ។ លុះម៉ាំឈៀវដឹង ទើបទៅសួរហ៊ានសុីយថា ចូឆួឲ្យសំ-
បុត្រមកនិយាយការអ្វីខ្លះ ? ហ៊ានសុីយក៏ហុចសំបុត្រនោះទៅឲ្យម៉ាំឈៀវ
មើល ។ ម៉ាំឈៀវហែកស្រោមឃើញតែក្រជាសទេគ្មានអក្សរ ក៏សួរ

ថា ហេតុម្តេចបានជាគ្មានអក្សរលោកយកសំបុត្រទៅលាក់ទុកឯណា ។ ហ៊ានស៊ុយឆ្លើយប្រាប់ថា សំបុត្រចូរឲ្យមកយ៉ាំងនោះឯង យើងមិនទាន់ហែកស្រាមមើល ខ្លួលអ្នកមកដល់ ដែលមិនមានអក្សរយ៉ាំងនេះប្រហែលចូរឲ្យទៅលសំបុត្រនោះទុកឯណា ហើយយកក្រដាសខេមាក់ជាដំនួសមកវិញ ។

ម៉ាឈៀវថា លោកនិយាយយ៉ាំងនោះ ខ្ញុំមិនយើញសមសេចក្តីសោះ ព្រោះចូរឲ្យជាមនុស្សមានតម្រិះប្រាជ្ញាម៉ាមួនណាស់ ដែលទីងក្តោចសំបុត្រនោះមិនមែនទេ ប្រហែលលោកចូលគំនិតទៅខាងចូរឲ្យគិតទីងប្រឲ្យសកំយខ្ញុំវិញទេដឹង ឲ្យជាឲ្យសំបុត្រសម្ងាត់ទៅមកកេតុ្មាមិនឲ្យខ្ញុំយើញផង ហើយក្តែងយកក្រដាសខេមកឲ្យខ្ញុំមើល ។ ហ៊ានស៊ុយថា យើងមានសេចក្តីត្រង់សុចរិតណាស់ បើអ្នកទៅឲ្យលសង្ស័យទីងយើងដូច្នេះ តេលត្រឹកស្អែកយើងទីងចេញទៅនិយាយទីងចូរឲ្យអ្នកចាំមើលចុះ ទីងយើញតិរុយ៉ាំងម្តេច ឲ្យអ្នកយកលំពែងចាក់យើងឲ្យធ្លាក់ពីលើសេះស្លាប់ចុះ ។ ម៉ាឈៀវថា បើលោកសត្យត្រង់ធ្វើបានដូចថាមែន ខ្ញុំគឺអស់សង្ស័យ ។

លុះដល់តេលត្រឹក ហ៊ានស៊ុយក៏នាំហៅឈួន លីវ៉ាំ លៀងហេង ម៉ាអ៊ួន អៀវឈើវ នាយតហាន ៥ នាក់នេះ ចេញពីបន្ទាយ ហ៊ានស៊ុយ

ប្រើគាហានចូលទៅហៅចូនដល់មុខបន្ទាយថា ហ៊ានស៊ុយឲ្យអញ្ជើញលោកទៅចរចាគ្នានៅខ័ណ្ឌលប្រជុំជន ។ ចូនពួកដូច្នោះក៏ឲ្យចូហាន់នាំគាហាន សេះ ៣០ ចេញទៅគំនាប់ហើយប្រាប់ថា មហាឧបរាជឲ្យកំផាប់លោកថា សំបុត្រដែលឲ្យមកនោះ កុំឲ្យលោកបង្ហាញនរណាឲ្យដឹងខ្លួនឡើយ ទៅឡើយក្រែងខូចការដែលគិត ។ ចូហាន់ប្រាប់ដូច្នោះហើយ ក៏ត្រឡប់ចូលទៅក្នុងបន្ទាយវិញ ។ ម៉ាឈៀវឮដូច្នោះក៏ប្រឡោតទឹង ទើបបរសេះកំលាំពែងចេញទៅនឹងចាក់ហ៊ានស៊ុយ ។ គាហានហ៊ានស៊ុយជួយការពារបាន ហើយនាំហ៊ានហ៊ុយរត់ចូលបន្ទាយ ។ ហ៊ានស៊ុយក៏ស្រែកឲ្យម៉ាឈៀវថា ក្មួយអើយអ្នកកុំប៉ិនឆ្លៀសឡើយ ដែលយើងនឹងគិតប្រឆូសក៉ាយនឹងអ្នកនោះមិនមែនទេ ។ ម៉ាឈៀវទឹងខ្លាំងណាស់មិនបានជឿសោះ កំបរសេះតម្រង់ចូលទៅក្នុងបន្ទាយ ។

ឯហ៊ានស៊ុយ ក៏ប្រឹក្សានឹងបណ្តាពួកនាយគាហានចាំង ៥ នាក់ថា ឥឡូវនេះ ម៉ាឈៀវមានសេចក្តីសន្ទិះសង្ស័យថា យើងត្រឡប់ទៅចូលខាងចូនវិញ តើយើងនឹងគិតប្រការម្តេចទើបបានឲ្យគេអស់សង្ស័យ ។ អៀវឈីវនៃឆ្លើយថា ធម្មតាជាមនុស្សមិនបានកើតខ្លាចអ្នកធំ ព្រោះហ៊ានកាន់ខ្លួនព្រោះមានថ្លៃដៃប្រមាថមើលងាយលោកណាស់ បើនឹងធ្វើការតទៅតាលណាឲ្យឈឺនឹងឈ្នះចូនវិញ ត្រូវតែអ្វីដែលលោកនឹងទៅចំណុះចូនក្រែង យើងនឹងត្រឡប់ចូលទៅខាងចូនវិញល្អជាង ទោះបីយ៉ាងណាក៏គង់នឹងខំទុក

បំរុងលោកឲ្យឡើងយសស័ក្តិជាបណ្តាសំណព្វ ។ ហ៊ានសុីយថា ខ្ញុំនេះធំធំមាំថែមអាពុកមាំឈៀវដាមិត្តសំឡាញ់ធំធ្ងាមកពីដើម ដែលធំធាលសេចក្តីសត្យសុចរិត ត្រឡប់ទៅចូលខាងចូលមកធ្វើប្រឌួសកំយមាំឈៀវដាកូនវេសមិត្រសំឡាញ់ពៃនោះមិនគួរសោះ ។ អៀវឈីវថា លោកភ្ញាក់ក្រែងខ្លួចសេចក្តីសត្យដូច្នោះកំគួរហើយ តែថាគ្រានេះមុខជាធំធាំកើតចលាចលដល់ខ្លួនហើយ ធំធំមិនធ្វើក៏ត្រូវតែធ្វើ ។

ហ៊ានសុីយយល់ឃើញត្រូវផង ទើបនិយាយថា បើដូច្នោះនេះណាធំធាំអាចនាំយកសេចក្តីនេះទៅពន្យល់ឲ្យចូរដួងធំបាន ។ អៀវឈីវថា ខ្ញុំបាទធំធំសុំអាសាទៅផង ហ៊ានសុីយក៏តែងសំបុត្រមួយច្បាប់ថា "ខ្ញុំបាទ ហ៊ានសុីយ សុំគំនាប់មកដល់មហាឧបរាជ ព្រោះខ្ញុំបាទបានប្រមាទលើកមហានង្គាក្សខ័ពមកតច្បាំងធំធំលោក នោះព្រោះគិតស្រាលសេចក្តី មិនបានពិនិត្យពិចារណាឲ្យឃើញទុសត្រូវឡើយ ខ្ញុំបាទឃើញទោសខ្លួនហើយ កំលះបង់មិនគិតធំធ្វើសេចក្តីប្រឌួសកំយដល់លោកតទៅទៀត ទើបចូលមកសូមលន់តួទោសសូមគំនាប់លោកតាមប្រពៃណី សូមឲ្យលោកអត់ឧនន្ទូវទោសឲ្យខ្ញុំបាទចុះ" លុះតែងសំបុត្ររួចហើយ ក៏ឲ្យអៀវឈីវកាន់យកទៅជូនចូដួ ។ ដំណឹងសំបុត្រដួច្នោះ កំសោមនស្សត្រេកអរណាស់ថា ហ៊ានសុីយមានសេចក្តីកក្តីដល់យើងហើយ បើសម្រេចការហើយយើងធំធំតាំងឲ្យធ្វើជាចៅហ្វាយស្រុកសៃលៀង ខ្ញុំនឹកឯងធំធំឲ្យធ្វើជាចុល័ដ្ឋ

ពួកឥហានជាកំជាប់មកយើងនឹងតាំងជប់លៀងតាមគួច-ជំ អ្នកឯងត្រូវ
វិលត្រឡប់ទៅប្រាប់ហ៊ានស៊ុយចុះថា តេលយប់នេះ ឲ្យដុតភ្លើងឲ្យឆេះ
ឡើងក្នុងបន្ទាយមាំឈៀវ យើងនឹងចូលទៅចាប់យកខ្លួនមាំឈៀវឲ្យ
បាន ។ អៀវឈើតែនាប់ចូឆ្លើយកំលាយមកវិញ ប្រាប់តតិមាន
នោះឲ្យហ៊ានស៊ុយស្គាប់គ្រប់ប្រការ ។

ហ៊ានស៊ុយឮដូច្នោះ ក៏មានអំណរណាស់ ឲ្យឥហានដញ្ជួនទៅសម
តនទុកក្រោយបន្ទាយជាច្រើន ហើយទើបប្រឹក្សានឹងនាយឥហានចាំង ៥
នាក់ថា តេលយប់នេះយើងឲ្យរៀបតុលៀងអាហារ ឲ្យអញ្ជើញមាំ-
ឈៀវមកបរិភោគ បើបានទុកាសស្រួលហើយនឹងចាប់ខ្លួនសំឡាប់ចេញ។
ខណៈកាលកំពុងប្រឹក្សាគ្នានោះ មានឥហានម៉ាំឈៀវដឹងដំរួយថា ហ៊ាន-
ស៊ុយគិតនឹងប្រទូសកំយមាំឈៀវ ឥហាននោះក៏នាំយកវឿងទៅប្រាប់
មាំឈៀវ។ ដឹងដូច្នោះ ក៏ស្រែកមកប្រញាប់ ឲ្យចាំងតេក មាំតាយឃុំ
ឥហាន ៣០ នាក់ តាមការពារអន្តរយៈពីក្រោយ ហើយក៏ដើរចូលទៅ
កន្លែងបន្ទាយ ឃើញហ៊ានស៊ុយកំពុងនិយាយប្រឹក្សាគ្នាជាមួយនឹងនាយឥ-
ហាន ៥ នាក់ ឮនឮចុងសំដីថា ត្រូវប្រញាប់ធ្វើការនោះកុំបង្អង់ទុកឲ្យ
យូរឡើយ មាំឈៀវក៏ដើរស្រែកដេងចូលទៅស្រែកដេរថា មែនអាសត្រូវ
ក៏គិតធ្វើអញហើយតើ ។ នាយឥហានហ៊ានស៊ុយទាំង ៥ នាក់ឮនឮ
ដូច្នោះ ក៏ស្ងុតស្ងាំងកាំងនឹងនៅមិនោះ ។ មាំឈៀវក៏ហួតត្រប៉ែកាប់

ហ៊ានស៊ុយ ។ លើកដើងវង្វែរពីដងដាច់ភ្លាក់ចុះ ។ ឥហាទហ៊ានស៊ុយ
ទាំង ៥ នាក់ក៏ហួតក្រប៉ាលស្លា រត់ចូលមកតស៊ូនឹងម៉ាឈៀ ។ ក៏ថយ
ចេញទៅក្រៅបន្តិយ នាយឥហាទ ៥ នាក់ក៏ដេញតាមទៅ ។ ម៉ាឈៀ
ខ្លួលតនឹងក្រប៉ា ឥាប់ត្រូវម៉ាដួនដួលចុះ ហើយចាក់ត្រូវលឿងហេងនឹង
ក្រប៉ាស្លាប់មួយរំពេច ហៅឈួន លីទាំ អៀរឈើទៅងឹតនាក់ឃើញដូច្នោះ
នឹងតស៊ូថ្មមួយម៉ាឈៀតុំចុងក៏ទាំគ្នាតែ ។ ម៉ាឈៀកើត្រឡប់ដេញ
ចូលទៅនឹងសម្លាប់ហ៊ានស៊ុយចេញ ខ្លួលពួកឥហានទាំយកខ្លួនហ៊ាន-
ស៊ុយតែរួចទៅបាន ហើយលបជុតក្តៅងនេះឡើងខាងក្រោយបន្តិយ ។
ឥហានម៉ាឈៀនឹងឥហានហ៊ានស៊ុយ ក៏ចូលច្រកាប់ច្រចាក់គ្នាជាច្រូល
ច្របល់ តេញទាំងបន្តិយនឹងក្រៅបន្តិយ ។

ចាំងតេកនឹងម៉ាតាយ ក៏លើកឥហានតាមទៅទាន់ម៉ាឈៀ ចូល
ជួយគ្នាតស៊ូទំលាយចេញពីក្នុងបន្តិយមកវិញ ប្រទះនឹងពួកឥហានចូលួ
លើកមកតែខ្លួថែមទៀត ក៏ចូលប្រឡូកគ្នាជា ៤ ផ្នែកសន្ធឹកសន្ធាប់ណាស់
មិនចាំងដឹងថា ពួកឯងឯពួកគេ ចាំងតេកនឹងម៉ាតាយក៏បែកគ្រាត់គ្នាពីម៉ា-
ឈៀវ៉ា ឃើញលើសកម្លាំងក៏ឡើងសេះនាំឥហាន ១០០ ជាយទំលាយតែ
ត្រូងទៅដល់កណ្តាលស្ពាន ខ្លួលក្លីស្លាងឡើងឃើញលីទាំលើកឥហាន
ដេញតាមពីក្រោយ ម៉ាឈៀក៏ជរសេះកមកតនឹងលីទាំ ។ ឃើញកម្លាំង

ខ្លួនឯងតែម្តង ម៉ាឈៀវពុំបាន ក៏ញាក់សេះវេះរត់ថយទៅក្រោយ ម៉ា-
ឈៀវក៏ដេញដិតពីក្រោយតាមទៅ ។

អីតុមក៏លើកទាហានដេញតាមម៉ាឈៀវទៅទៀត ហើយបាញ់
ទ័ងធ្លាក់ក្រោយ ម៉ាឈៀវឮសូរព្រួញរត់ពីក្រោយខ្លួនក៏ក្រាបចុះព្រួញនោះ
ហួសទៅត្រូវលំទាំធ្លាក់ពីលើសេះស្លាប់ ម៉ាឈៀវឃើញដូច្នោះ ក៏ញាក់
សេះវិលត្រឡប់ទៅតទឹងអ៊ុតុម ។ ក៏ញាក់សេះវេះរត់ទៅ ម៉ាឈៀវ
លើកពលត្រឡប់ទៅឈរកណ្តាលស្ពានវិញ ទាហានបួនក៏លើកទៅ
ស្ពាត់ទាងដើមស្ពាន ទឹងបុងស្ពានខាំងសងខាង ចេះតែបាញ់ធ្លាក់ចុះបួលទៅ
ខាំងសងខាង ម៉ាឈៀវយកលំតែងត្រីចាត់ព្រួញទ្លាតធ្លាក់ទៅក្នុងទឹក
ខាំងអស់គ្មានពាល់ត្រូវដល់ខ្លួនសោះ ហើយដេញទាហានឲ្យចូលប្រចាប់
កងខ័ពបួនទឹងឲ្យធ្លាយទាងដើមស្ពាន ទាហានមានតិចណាស់ក៏យក់-
លាយចេញមិនបាន លើសកម្លាំងក៏ត្រឡប់ថយក្រោយ ម៉ាឈៀវទឹង
ញ៉ាអស់ខាំងខ្លួនក៏ស្រែកដោយសំឡេងខ្លាំង ហើយបំផ្លាយសេះខំលាយ
ចេញទៅតែម្នាក់ឯង ទាហានបួនក៏ចេកផ្លូវឲ្យ ម៉ាឈៀវក៏ត្រឡប់វិល
បួលទៅកណ្តាលហ្វូងទាហាន ។ ក៏បាញ់ទឹងធ្លាក់ម៉ាឈៀវធ្លាក់ចុះ
ទាហានបួនក៏សុះស្រែបួលទៅទឹងចាប់ខ្លួន ខ្លួលចាំងតែកទឹងម៉ាតាយ
លើកតលវាយខំលាយបួលមកទាន់ ក៏ដួយតស៊ូគ្នាជាច្រើនលើល ហើយ
ចាប់យកខ្លួនម៉ាឈៀវបាន ទាហានម្នាក់លោតចុះពីលើខ្នងសេះ

ឲ្យមាំឈៀវតែឡើងជិះលើខ្នង ហើយរកយុទ្ធលាយចេញពីក្នុងចំណោមទៅបាន ។

ឯកូនធ្នូដ៏ធំថា មាំឈៀវតត់ទៅបានដូច្នោះ ក៏ឲ្យប្រកាសដល់ពួកទាហានទាំងពួងឲ្យស្រួតលើកគ្នាតាមទាំងយប់ថ្ងៃ បើនរណាយកក្បាលមាំឈៀវបានមកឲ្យយើង ។ នឹងឲ្យបំណាច់ភ្នំនាំមាសមួយភាន់ប្រាក់មួយភាន់ បើចាប់ទាំងរស់បាននឹងតាំងឲ្យធ្វើជាទាហ៊ានធំ បណ្តាពួកទាហានដែលចង់បានគុណបំណាច់ ក៏នាំគ្នាស្រួតតាមទៅ ។ មាំឈៀវតត់ទៅគ្រានោះ មានពួកទាហានតិចណាស់ គឺមានតែជាំងតេក ១ មាតាយ ១ នឹងកូនទាហានប្រមាណ ៣០ នាក់ នឹងរោងទៅតស៊ូនឹងទ័ពកូនធ្នូពុំបាន ក៏ទំនែស្រួតតែតត់ទៅខាងទិសឦសាន្តស្រុកសៃលៀង ។

ចូរធ្នូលើកទ័ពជួនតាមទៅជាក្រោយ ដឹងថាមាំឈៀវតត់ហួតហួចទៅតាមមិនទាន់ហើយ ក៏លើកទ័ពវិលមកស្រុកខៀងអ៊ីនវិញ ឈប់សម្រាកទាហាននៅក្បែរបួសជើងហ៊ានស៊ុយឲ្យជា ហើយចូរឃើញថាជាមនុស្សពិការនឹងធ្វើសង្គ្រាមតទៅទៀតពុំបាន ក៏តាំងឲ្យធ្វើជាចៅហ្វាយស្រុកសៃលៀង ឲ្យហៅឈ្មួន នឹងអៀវឈើវាជាចុងភ្នាក់សំពាប់ឃុំនាំទាហានទៅលា្លតតាមមាត់ស្ទឹងអ៊ុយហោ ដើម្បីការពារកងទ័ពមាំឈៀវ ឯបណ្តាទាហានក្រៅពីនោះ ក៏តាំងជាទាហ៊ានធំៗគួរ តាមគុណបំណាច់តិចច្រើន ។

ខ្ញុំ:នោះ អៀវហ៊ីដាពាហានឆ័អៀវឈើវាកំនិយាយថា មហាឧបាជ្ឈាយ៍លើកទ័ពទៅឥឡូវនេះ ក្នុងស្រុកខៀងអ៊ីនទោះនឹងរកនរណាជាជំនឹងរក្សាត្រួតត្រាគ្មាន ខ្ញុំបាទយើញថា ម៉ាឈៀវបែកទ័ពទៅគ្រានេះគង់នឹងមានសេចក្តីព្យាបាទជាប់ក្នុងចិត្ត មុខជានឹងតតាសងសឹកវិញ ហើយក្រែងម៉ាឈៀវនឹងបញ្ជុំបញ្ចូលពលពាហានបានច្រើន នឹងលើកមកធ្វើអន្តរាយជាក្រោយក៏នឹងប្រសប់ការ សូមឲ្យលោកចាត់ការរើសមនុស្សឲ្យធ្វើវត្តមានតំនិតមារយាទ ឲ្យល្មមទុកចិត្តបានទៅរក្សាស្រុកខៀងអ៊ីនដើម្បីការពារកុនឹងម៉ាឈៀវ បើម៉ាឈៀវលើកទ័ពមក នឹងបានជួយគ្នាតយុទ្ធឲ្យបាន ។ ចូឆ្លូវឆ្លើយថា ការនេះកុំបីអ្នកព្រួយបារម្ភ យើងបានគិតចំរុងទុកជាស្រេចហើយ អៀវហ៊ីឮដូច្នោះ ក៏តំមាប់លាចូឆ្លូទៅស្រុកសៃ-លៀងជាមួយនឹងហ៊ានស៊ីយ ។

កាលហ៊ានស៊ីយលើកទ័ពទៅហើយ ពាហានចាំឆ្លងក៏និយាយនឹងចូឆ្លូថា យើងខ្ញុំមានសេចក្តីសង្ស័យណាស់ ព្រោះកាលដើមម៉ាឈៀវលើកទ័ពមកវាយបន្ទាយតុងគួននោះ ហេតុម្តេចមហាឧបាជ្ឈាយ៍មិនឲ្យលើកទ័ពទៅតាំងព័ទ្ធពីក្រោយហ៊ានស៊ីយទុក បើលោកលើកទៅព័ទ្ធពីក្រោយមិនមានដំយៃដំនះឆាប់ឬ ? មហាឧបាជ្ឈាយ៍មកតាំងឧទ្ទួលម៉ាឈៀវនៅបន្ទាយតុងគួននេះ ពាល់តែជាប់ដៃគ្នាជាយូរណាស់ ហើយខើបឲ្យលើកទៅចាំព័ទ្ធខ្នងវាយ៉ាងត្រើយទំលងកើតដាក្រោយវិញ តើដោយហេតុប្រការអ្វី ?

ចូរឆ្លើយថា កាលខេះឈ្មោះខ្លួនថាញ៉ា មិនទាន់យកដៃបិទត្រចៀក ឮក្នុងគ្នាមិនទាន់ឮល់ទេ ខណៈកាលមាំឈ្វៀរលើកទ័ពមកនោះ យើងមិនបានឲ្យលើកទៅទ័ពីក្រោយទុក ព្រោះយើងយើញថាហានមាំឈ្វៀរលើកមកមិនទាន់អស់រលើង លុះទើងបង្ខំឲ្យស្រួតរួតទៅទ័ពីក្រោយក្តាម ។ បើហានមាំឈ្វៀរលើកមកជាក្រោយ ក៏ទើងសល់ទៅទើងត្រូវតតាំងចំប្បាងគ្នាជាពីរផ្នែក យើញទើងកម្លាំងក្រោយយកជ័យដំនះមិនបាន ហេតុនេះបានយើងក្លែងទៅខ្លួលតគ្នាឲ្យយូរ ច្រាច្បាទើងឲ្យហានមាំឈ្វៀរលើកមកឲ្យអស់ លុះក្រោយសឹមយើងឲ្យស៊ុមប្លងទើងដូច្នេង នាំហានលើកទ្លងទៅត្រើយម្ខាង តាំងព័ទ្ធខ្ចប់ទុកឲ្យត្រូវតាមកលៗបាយ ត្រូវធ្វើការសង្គ្រាមតែមុខមួយមិនត្រួយធ្លុះរលៃរកើងទៅទ័តឯណាដែរ ក៏បានជ័យជំនះដោយកម្លាំងទើងថ្លីដៃហានតាំងតួនយ៉ាងស្រួល ។

បណ្តាសេនាហានតាំងអស់ បានស្តាប់ដូច្នោះក៏យល់យើញថាត ទើបសួរថា កាលលោកតាំងនៅទីនោះ មានមនុស្សយកសេចក្តីមកច្រាប់ថា ហានមាំឈ្វៀរលើកមកខ្មែត ២ ទាន់ ៣ ទាន់ មហាឧបកជមានសេចក្តីត្រេកអរត្រឡប់ជាអស់សំណើចនោះ ដោយយើញហេតុយ៉ាងម្តេច ? ។ ចូរឆ្លើយច្រាប់ថា ស្រុកសៃលៀងនោះមានខ្មែត្រកយជាច្រើន កាលហានលើកដើរមក យើងក៏ដឹងថា កងទ័ពបណ្តាខ្មែត្រតាំងនោះលើកមកអស់រលើងហើយទើបមានចិត្តត្រេកអរ ព្រោះយើញថា

ទាហានចាំឆ្លងនោះ សុទ្ធតែនៅស្រុកទៃតែគ្នា មិនរៀបរយគ្នានឹងធ្វើ
ការជាចិត្តមួយ ទោះនឹងមកច្រើនយ៉ាងណាក៏ដូចជាតិច ឃើញថាគង់
នឹងចាញ់ថ្វៃដៃទាហានយើងជាប្រាកដ ឯានជាយើងសើច បើអ្នកមាន
សតិបញ្ញាតិច នឹងធ្វើសង្គ្រាមតនឹងម៉ាំឈៀវត្រឹមខ្លួបតែមួយយ៉ាងហ៊ាស
ដៃលនឹងឲ្យឯានជ័យជំនះ ដល់បណ្តាទាហានគ្រប់ទៃត្រូចយ៉ាងធ្វើនេះ
កម្រក្រៃណាស់ ។

បណ្តាសេនាទាហានឯានស្តាប់ហើយ កំនាំគ្នាខនគំនាប់ហើយ
សរសើរថា មហាឧបាជនេះពេញជាមានតម្រិះប្រាជ្ញាជ្រៅសុខុម ប្រកប
ដោយអានុភាពប៉ិដូចទេព្តា ។ ឯគួរធ្វើយាឡើងថា យើងមានជ័យជំនះ
គ្រានេះ កំអាស្រ័យដោយកម្លាំងនឹងថ្វៃដៃអ្នកកាល់គ្នា ហើយក៏ឲ្យបំណាច់
រង្វាន់ទាហានធំ-តូចតាមសមគួរ ហើយប្រគល់ទាហានរបស់ម៉ាំឈៀវ
ដៃលចាប់ឯានមកជាឈ្លើយនោះ ឲ្យហៅហ៊ូគៀនឃុំយកទុករក្សាស្រុក
ខៀងអ័ន ឲ្យខៀវគីចៅហ្វាយស្រុកកេងខៀវនៅជួយរាជការផង ឯគួរចាត់
ចែងទាហានទឹងរៀបស្រុកគូម៉ាស្រេចហើយ កំឲ្យលើកកងកំពត្រឡប់ចូល
ទៅស្រុកក្រុង ។

សាមគ្គីកថាខ្សែ ៥០

តាំងពីចូរឈ្នះម៉ែគម៉ាឈៀវ រត់រួចទៅ ចូរឆ្លើកម៉ែគចូលទៅក្រុងវិញ ព្រះបៅហៀនគេ យាងចេញទៅទទួលដល់ក្រៅក្រុង រហូតដល់ខ្មៅពីលើកម៉ែគទៅឰបឱនថ្វាយស្រុកសែឈួន ។

ឯព្រះបៅហៀនគេជ្រាបថា ចូរូមានដំយ៉ាងដំនេះសង្គ្រាមម៉ាឈៀវ ហើយលើកម៉ែគត្រឡប់មកវិញ ក៏ទ្រង់មានព្រះរាជហឫទ័យសោមនស្ស ស្តេចទ្រង់គង់រាជវរៈចេញទៅទទួលម៉ែគចូរូដល់ក្រៅម៉ែក្រុង ហើយមានតម្រាស់ទីឯចូរូថា អំណើះតានេះទៅ បើមិនមានតម្រាស់ឲ្យហៅ ក៏កុំឲ្យចូលគាល់ដូចជានាហ្នឹងជម្មតានោះឡើយ បើយើងមានការឲ្យហៅចូលគាល់ ក៏ត្រូវឲ្យសៀតក្រចឹចូលគាល់ជាវរភ ហើយកុំបាច់ឲ្យក្រាបថ្វាយបង្គំជាដាច់ខាត ។

ចូរូបានឮព្រះតម្រាស់ផ្តាំដូច្នោះ ក៏មានចិត្តកំរើបជាខំហាំក្រលែងលើសពីដើម ក៏ត្តិសត្តក៏ឮខ្នើខ្នាយទៅដល់ខៀវឡែ ចៅហ្វាយស្រុកហ៊ានគុង ។ ឯខៀវឡែនោះ ជាកូយខៀវឡែង ។ នោះពីដើមជាពួកស្រុកសែឈួន ទៅស្នែងរៀនវិជ្ជានេះតំបន់ក្តុំបេងស៊ីន លុះរៀនវិជ្ជាការបានចំណានហើយ ក៏មកនៅកន្លែងស្រុកហ៊ានគុង អាណាប្រជានុកស្តុចំណុះស្រុកនោះ បើនរណាឈឺថ្កាត់ដោយជម្ងឺអ្វី ។ ក៏យកជាជុះជួយខំនុកបំ-រុងឲ្យសម្រេចសេចក្តីប្រាថ្នាគ្រប់ប្រការ អាណាប្រជានុកស្តុតាំងពួងក៏

ពាប់អានស្រឡាញ់ទៅមកដាច់គ្នារវៈ បើនឹងរក្សាកេតអ្នកឯណាជា ក៏មិនបានយកវត្ថុអ្វី ឲ្យយកតែស្រូវ ៥ ថាំង ទៅតំខាប់ប្អូជាគ្រូ លុះខៀវឡើងស្ទាប់ ខៀវឡើជាកូយក៏បានវិជ្ជាការខោះធ្វើតាមប្រពៃព្រណីតមក អាណាប្រជានុកស្ត្រីតាំងពួនក៏ពាប់អានស្រឡាញ់ តាំងនៅក្នុងខ្ពង់ខពស់ឆ្ងាយគ្រប់ប្រការ សន្មតិឲ្យជាអ្នកធំ ខៀវឡើក៏ប្រជៅមនុស្សតាំងពួនឲ្យធ្វើតាមខ្លួន តាំងនៅដោយប្រក្រតីមិនបានបៀតបៀនគ្នា បើអ្នកឯណាធ្វើខុសដល់ ៣ ដង ក៏មិនបានយកទោសអាណាប្រជានុកស្ត្រីតាំងពួនក៏នៅជាសុខក្សេមក្សាន្តត្រប់ភូមិលំនៅ បណ្តាស្រុកគ្រាមនិគមដែលត្រូវឡើងស្រុកហ៊ានតុង នោះក៏កោតខ្លាចអំណាចខៀវឡើតាំងអស់ ឯចៅហ្វាយស្រុកហ៊ានតុងនោះសោត ក៏កោតខ្លាចគំនាប់គោរពខៀវឡើ ។

ខណៈនោះខៀវឡើដឹងដំណឹងថា ប្អូធ្លូមានដំយដំនះមាំឈៀវហើយមានចិត្តកំរើបធំលើសឡើង ក៏និតចារម្ភខ្លាចក្រែងប្អូធ្លូនឹងលើកទ័ពមកធ្វើអន្តរាយដល់ស្រុកហ៊ានតុង ទើបខៀវឡើឲ្យប្រមូលមនុស្សចាស់ទុំមកប្រឹក្សាថា ឥឡូវនេះប្អូធ្លូ ដើរច្រាប់ច្រាមគ្រប់អាណាខេត្តតាំងពួង ក៏ចុះចូលជាច្រើនណាស់ហើយ ដូចម៉ាថេងចៅហ្វាយស្រុកសែលៀងនោះសោត ប្អូធ្លូក៏សម្លាប់ចេញបាន មាំឈៀវជាកូនខៀតក៏ចែកចាញ់ទ័ពប្អូធ្លូ តែតការជាធំខ្លាយលើសអំពីដើម បើនឹងលើកទាហានមកវាយស្រុកហ៊ានតុង ការណាមុខជាអាណាប្រជានុ-

ក្រសួងទាំងពួងនឹងបានសេចក្តីក្តៅក្រហាយជាខ្លាំង គួរតែយើងនឹងតាំងខ្លួនឡើងជាម្ចាស់ ឈ្មោះក្រុងចៅហ៊ានឡើងអង នឹងបញ្ជុះបញ្ចូលទាហានឲ្យបានច្រើន ហើយនឹងធ្វើការតែនឹងបួនគ្នា ការពារស្រុកខុកមិនឲ្យជាអន្តរាយ រក្សាអាណាប្រជានុកស្រួលឲ្យនៅជាសុខតទៅ អ្នកទាំងពួងពាល់គ្នានឹងយល់ឃើញប្រការម្តង ។

ឃើមផៅធ្វើយថា លោកគិតនេះគួរណាស់ ព្រោះស្រុកហ៊ានតុងមានមនុស្សច្រើនទៅក្នុងរាល់លោកកងចំនួន ១០ ម៉ឺន ចំណីអាហារកំបិរបូណិទាំងអស់ តែថានៅមិនទាន់ស្មើនឹងបួនទៅឡើយ ឯម៉ាឈៀវដែលបែកខ្ចាត់ខ្ចាយមកវិញនេះ កំគង់នឹងមកប្រាស្រ័យនៅនឹងយើងខោះយ៉ាងណាក៏គង់តែបួនខោះ នឹងលើកទ័ពតាមមកដល់ស្រុកយើងជាប្រាកដ ដែលយើងនឹងគិតធ្វើការតយុទ្ធនឹងបួនខោះ គួរតែនឹងទៅកាយយកស្រុកសែឈួនទាំងសែសិបវែត្រឲ្យបានសិន ទើបកម្ចាត់យើងនឹងបានច្រើន ព្រោះឡៃដៀងចៅហ្វាយស្រុកអេកដាវ ដែលជាធំកងស្រុកសែឈួននោះក៏ជាមនុស្សលោកណាស់ មុខជានឹងកាយបានដោយងាយបើបាទសម្រេចហើយ លោកនឹងតាំងខ្លួនជាអម្ចាស់ទើបស្រួល ខ្ញុំវិញបានស្តាប់ដូច្នោះក៏យល់ត្រូវផង ទើបឲ្យកេខ្លួនខ្ញុំវិញអូយមកប្រឹក្សា ដើម្បីនឹងលើកទ័ពទៅកាយស្រុកសែឈួន ។

ខ្លៅដៀវចៅហ្វាយស្រុកអេកដ៏ខ្លាំងខ្លៀវនោះ ជាមនុស្សហ៊ានគ្នាមកតាំដើម ព្រោះខ្លៅអៀវជាអាពុកខ្លៅដៀងអនិច្ចកម្មទៅ ខ្លៅដៀងកំពុងខ្លើងជាចៅហ្វាយស្រុកជំនួសអាពុក ចាប់យកម្ចាយខ្លៀវខ្លៅទៅសម្លាប់ ខ្លាចខ្លៀវខ្លែងលើកទ័ពមកធ្វើអន្តរាយ ទើបគាំងឲ្យចាំងយីជាចៅហ្វាយស្រុកចាំសេ ប្រាថ្នាខ្លែងឲ្យចាក់ពាំងទ័ពខ្លៀវខ្លៅ លុះចាំងយីដឹងដំណឹងថាខ្លៀវខ្លៅ រិះគិតប្រមូលជាកងទ័ពខ្លែងលើកមកវាយយកសែឈួនដូច្នោះ ក៏ឲ្យប៉ាវសេះស្រួតនាំដំណឹងនោះទៅប្រាប់ខ្លៅដៀង។ ដឹងរឿងដូច្នោះក៏ភ័យណាស់ ទើបឲ្យហៅបណ្តាខាម៉ឺនធំ តូចពាំងតួងមកប្រឹក្សា៖

ខ្លៀវសុងទីប្រឹក្សាឆ្លើយថា ដែលខ្លៀវខ្លែងលើកទ័ពមកធ្វើអន្តរាយដល់ស្រុកសែឈួននោះលោកកុំព្រួយឡើយ ខ្ញុំបាទសុំយកតែអណ្តាត៣ផ្លាប់នេះអាសាខ្លៅតនឹងខ្លៀវខ្លៅ មិនឲ្យលើកមកធ្វើអន្តរាយបាន ខ្លៅដៀងបានស្តាប់ក៏ត្រេកអរមើលខ្លៀវសុងឃើញរូបកាន់តាបកន្តិល ក្បាលត្រមោងដូចផ្លែល្ពៅ ប្រមុះក្រពើត រូបមិនសមជាអ្នកចេះនិយាយ ក៏មិនបានទឹងដឿ ទើបសួរថាអ្នកនឹងតិតៅនិយាយយ៉ាងម្តេច ប្រាប់ឲ្យយើងស្តាប់សិន ។

ខ្លៀវសុងឆ្លើយថា ខ្ញុំបាទជឹងថាចូរនេះជាអ្នកមានអំណាចដើរប្រាប់ប្រាមខ្ញុំណាសេមាឲ្យទៅកងអំណាចខ្លួនចាំងអស់ សូមឲ្យអ្នកសុំតសោត កិច្ចធ្លុកចាត់ចេញអស់ហើយ ឥឡូវមាំណៀវជាកូនមាចថង

សោតកំចាញ់ប្រៀបបួនរួបែកទ័ពរត់មកខៀត បួនមានទាហានប្រែនណាស់ សុំឲ្យគាត់តែងគ្រឿងបណ្ណាការទៅសុំបុះបួលគំនាប់បួន ខ្ញុំបាទនឹងសុំយកអាសាកាន់សំបុត្រទៅនិយាយឲ្យបួនលើកទ័ពមកវាយស្រុកហ៊ានតុង បើស្រុកហ៊ានតុងកើតសឹកជាប់ដៃគ្នាហើយ កំមុខជាមិនលើកទ័ពមកធ្វើអន្តរាយស្រុកយើងទេ ខ្លៅដៀងស្គាប់យើញត្រូវតំមានសេចក្តីត្រេកអរ ទើបចាត់ចែងតែងគ្រឿងបណ្ណាការនឹងសំបុត្រមួយច្បាប់ឲ្យខៀវសុង ។ កំលបគួរផែនទីស្រុកសែឈួនត្រប់រយៈពាំងអស់ហើយ កំនាំចូលទៅក្រុងហ៊ូតោធ្វើគាត់ស្រុកកេងជាវៀត ។

ឯណៈនោះ ទុងបងនឹងថា ខ្លៅដៀងប្រើឲ្យខៀវសុងនាំគ្រឿងបណ្ណាការចូលទៅគំនាប់បួន កំចាត់ប្រើមនុស្សឲ្យតាមស៊ើបស្តាប់ការពាក់ការមើលក្នុងស្រុកហ៊ូតោ លុះខៀវសុងទៅដល់ស្រុកហ៊ូតោហើយ នឹងចូលទៅគំនាប់បួនមិនបាន ព្រោះបួនមិនបានចេញទំយ៉ាយការពាក់ការទៅរង់ចាំដល់ ៣ ថ្ងៃ ទើបឲ្យមនុស្សចំរើចូលទៅតាមដំណើរសេចក្តីដល់បួន ។ កំឲ្យហៅខ្លួនខៀវសុងចូលទៅខាងក្នុង ខៀវសុងគំនាប់ហើយកំជូនសំបុត្រនឹងគ្រឿងបណ្ណាការឲ្យបួន ។

(នៅមានត)

លោក ង៉ាយ-ប៊ុកវ ប្រែរៀបរៀង

(តមក)

៣- រឿងជីវិតទិព្វ

មានកាលមួយថ្ងៃ ម៉ាំលៀងបានគូរសត្វក្រៀលមួយសម្បុរសស្អុតគ្មានក្អែក ។ តែដោយការធ្វេសប្រហែស ម៉ាំលៀងភ្លេចគូរឲ្យមានភ្នែកមួយដំណក់ជាប់ចំភ្នែកក្រៀលនោះ ។ ក្រៀលភ្លើកភ្លែកធំ ត្រដាងស្លាបហើរទៅលើនភាល័យ ។ ព្រឹត្តិការណ៍ថ្ងៃកន្លះ ធ្វើឲ្យប្រជាពលរដ្ឋដែលស្ថិតនៅទីនោះផ្អើលនោះឡោតគ្រឹកគគ្រេងពាសពេញទីនោះ ។ មានជនពួកខ្លះធ្វើបុតហ្មាយថ្វាយដល់ព្រះមហាក្សត្រ ។ ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឲ្យរដ្ឋមន្ត្រីមកអញ្ជើញម៉ាំលៀងទៅកាន់ពន្ធនាគារ ។ ម៉ាំលៀងមិនចង់ទៅសោះឡើយ តែរដ្ឋមន្ត្រីបង្ខំម៉ាំលៀងដោយអួសពាញពាលតែដល់ព្រះបរមរាជវាំង ។

ម៉ាំលៀងមានជំពប់ស្អប់ព្រះមហាក្សត្រ ដោយបានឮដំណឹងថាព្រះមហាក្សត្រធ្វើទុក្ខបុកម្នេញបណ្តាពួកស្ត្រីគ្រួចតាច ។ ដោយហេតុនេះហើយបានជាម៉ាំលៀងតំណក់ចិត្តថា ខ្លួនមិនគួរគំនូរទៅតាមព្រះរាជបញ្ជាព្រះមហាក្សត្រទេ ។ ព្រះមហាក្សត្រ ទ្រង់ត្រាស់បង្គាប់ឲ្យម៉ាំលៀងគូរនាគ

ម៉ាំលៀងគួរគឺងគក់គគ្រាត ។ បើព្រះមហាក្សត្រទ្រង់គ្រាស់បង្គាប់ឲ្យ
ម៉ាំលៀងគួរសត្វកជហង្ស? (blénix) ម៉ាំលៀងគួរមានញីគ្មានស្វាប ។
សត្វទាំងពីរមានសភាពគួរឲ្យខ្ពើមឆ្អើមតន់តេក ។ សត្វនេះលោតចុះឡើង
ជុំវិញព្រះមហាក្សត្រ បន្ទោបង់ខ្លួវលាមកស្អុយតេញតាស មានក្លិន
អសោចាលំតែព្រះមហាក្សត្រទ្រង់ព្រះក្រោធភ្លាំង ។ ទ្រង់មានព្រះរាជ
ឱង្ការឲ្យមហាមាត្យចាប់ម៉ាំលៀងតន្ត្រាក់យកជក់ទិត្យ ហើយយកម៉ាំលៀង
ទៅឃុំទាំងនៅក្នុងសើនមួយ ។

ព្រះមហាក្សត្រទ្រង់យកជក់ទិត្យនោះ មកគួរក់សជាតំនរមាសមួយ ។
តែមាសមួយតំនរនេះ ទ្រង់យល់ថាតិចតេកមិនអាចបំពេញខ្លួវសេចក្តី
លោភរបស់ព្រះអង្គបាន ទ្រង់ក៏គួរមួយតំនរទៀត រួចតំនរទី ៣ ទី ៤...
រហូតដល់តំនរជាអនេកប្រការ ។ ដល់គួរហួចហើយ ទ្រង់ទតទៅឃើញ
មិនមែនឃើញថាតំនរមាស ទៅជាតំនរដុំថ្មទៅវិញ ។ ដោយថ្មទាំង
លើធ្ងន់តេកតំនរថ្មនោះក៏រលំក្លាក់មកក្រោមអស់ ។

សេចក្តីលោភ នៃព្រះមហាក្សត្រមិនទាន់ផុតរលត់ត្រឹមនេះទេ ។
ដោយទ្រង់មិនសព្វព្រះហឫទ័យនឹងតំនរមាស ទ្រង់ក៏គួរអិដ្ឋមាសថែម
ទៀត ។ ទ្រង់គួរមួយ ពីរ បី . . . តែអិដ្ឋមាសនោះតូចតេក . . . ទ្រង់
ក៏គួរអិដ្ឋមាសមួយធំ វែងជាច្រើនម៉ែត្រ ។ ដល់ទ្រង់គួរហួចហើយ ទ្រង់
ក៏ទតទៅឃើញមិនមែនជាអិដ្ឋមាស ត្រឡប់ទៅជាពស់វែកមួយវែងស្ទុះ

មកចឹកព្រះអង្គ ។ បើកុំតែពួករដ្ឋមន្ត្រីព្រះអង្គរត់ទៅជួយ កុំអីពស់នោះវាលេបមហាក្សត្រតាំងរស់ទៅហើយ ។

មហាក្សត្រទ្រង់យល់ជាក់ច្បាស់ថា ទ្រង់ដែនអាចប្រព្រឹត្តសកម្មភាពអ្វីបានក្រៅតែម៉ាំលៀងសោះឡើយ ។ ទ្រង់ក៏ត្រាស់បង្គាប់ឲ្យយកម៉ាំលៀងចេញពីគុកហើយ ទ្រង់បានព្រះពរជាទានខ្លួមាសប្រាក់ជាច្រើនព្រមតាំងទ្រង់មានព្រះទស្សាវាផ្អែមល្ហែម បង់ឲ្យម៉ាំលៀងធ្វើសមរសនឹងព្រះអង្គម្ចាស់ក្សត្រី ។

ម៉ាំលៀងមានផែនការរបស់ខ្លួន បានប្រកាសចំពោះព្រះភក្ត្រព្រះអង្គថា លោកយល់ព្រមធ្វើព្រះសមរសនឹងព្រះអង្គម្ចាស់ក្សត្រី ។ ព្រះមហាក្សត្រ ដោយទ្រង់ខតទៅឃើលម៉ាំលៀងស្លូតត្រមធ្វើតាមព្រះពរជបញ្ជាគ្រប់យ៉ាង ទ្រង់ក៏ព្រះពរជាទានខ្លួដែកទំពួដល់ម៉ាំលៀងវិញ ។

ព្រះមហាក្សត្រទ្រង់ព្រះតម្រិះក្នុងព្រះអង្គឯងថា: "ប្រសិនបើថាអញប្រាប់ម៉ាំលៀងឲ្យវាគួរកុំ ប្រហែលជាមានសត្វសាហាវ ។ បើដូច្នេះត្រូវឲ្យវាគួរសមទ្រវិញប្រសើរជាង" ។ ទ្រង់ក៏ត្រាស់បង្គាប់ឲ្យម៉ាំលៀងគួរសមទ្រ ។

ម៉ាំលៀងគ្រាន់តែយកដកទំពួ គ្រវាសតិរដេង ស្រាប់តែលេចសមុទ្រទឹកល្អាង ។ ទៅចំព្រះភក្ត្រព្រះអង្គមានទឹកសមុទ្រត្រជាក់ទាំល្អហ្លែវមានតិណាខៀវផ្ទៃមេឃ ភ្ញីចាំងដូចជាកញ្ចក់ ។

ព្រះមហាក្សត្រទ្រង់ខឹងមោយល់សមុទ្រហើយ ទ្រង់ត្រាស់បង្គាប់ឲ្យម៉ាំលៀងគូរត្រីខៀត ។ ម៉ាំលៀងក៏គូរត្រីតាមព្រះពាជបញ្ជា ។ សមុទ្រក៏មានត្រីភាសតេញគ្រប់តណាហិចហែលបក់កខ្ទុយរវើច ។ ត្រីនោះក៏ហែលឆ្ងាយតាំរាំងរហូតទៅដល់កណ្តាលសមុទ្រ ។ ព្រះមហាក្សត្រទ្រង់ក្រសាលសប្បាយ ឧទ្ធត្រីនោះតាន់តេក ទ្រង់ក៏មានព្រះពាជឫទ្ធាវ៉ាថា: "ត្រូវឯងគូរនាក់មួយ ! អញចង់ទៅមើលត្រីកណ្តាលសមុទ្រ" ។

ម៉ាំលៀងក៏គូរនោកធំមានស្តេងមួយ ។ ព្រះមហាក្សត្រ ព្រះមហាពាជទេវី ព្រះអង្គម្ចាស់ក្សត្រី ក្សត្រា ស្តេចឡើងគង់លើនាក់ស្តេងនោះជាមួយនឹងពួកដេមទ្រីជាព្រះពាជបរិវារ ។

ម៉ាំលៀងយកដក់ទឹកមកគូរក់សទៅ ស្រាប់តែព្រះនាយបក់មកនាក់នោះក៏ធ្វើដំណើរទៅកាន់កណ្តាលសមុទ្រ ។ ម៉ាំលៀងគូរក់សម្តងខៀត ស្រាប់តែ មុទ្រមានរលកធំ ។ បក់បោកមកកាន់នាក់ធ្វើឲ្យព្រះអង្គទ្រង់ទឹកអស់ ។

ព្រះមហាក្សត្រទ្រង់មានព្រះពាជបន្ទូលសួរសើហានាថា: "ម៉ាំលៀងឈប់ កុំគូរខៀត" ។ តែម៉ាំលៀពុំព្រមតាមព្រះពាជបញ្ជាធ្វើដូចជាមនុស្សថ្នង់ កំរេះតែគូរក់សតទៅខៀត ទាល់តែព្យុះសង្ឃរាធំបក់មកបុះនាក់នោះលិចលង់កន្លងផុតសាបូណ្ណាលឲ្យព្រះមហាក្សត្រ ព្រះមហាពាជទេវី

ព្រះកជវង្សានុវង្សលិចលង់អស់ព្រះជន្មាយុ ។ ឯពួកវង្សមន្ត្រីកំពូលមរណភាពកន្លងមហាសាគរនោះដែរ ។

ក្រោយដែលព្រះមហាក្សត្រខ្លួលចំរើតទៅ កិច្ចការនៃមាំលៀងកំពុងតែសូរុរទ្ធីទៅគ្រប់ប្រទេស ។ តែមាំលៀង គ្មានអ្នកណាបានដឹងថាគាត់ទៅឯណាឡើយ ។ មានខ្លះពោលថាគាត់បានត្រឡប់ទៅកាន់ភូមិគាត់វិញ មានខ្លះថាគាត់ ដើរតែភូមិមួយទៅភូមិមួយ តួរបស្ទាយ៉ាងដើម្បីជារបរចិញ្ចឹមជីវិតទៅតាមយថាកម្មរបស់ខ្លួន ។

បប់រឿងជាក់ទិព្វ

នៅមានរឿង វីរបុរសសីគាល់តទៅទៀត ជារឿងព្រេងតែសន្តិតែវង្ស ល្អអានណាស់ ។

៤- រឿងវីរបុរស « សីគាល់ »

4— L'histoire du héros Chegal

(Conte de la Nationalité)

តាំងតែបុរាណកាលមក ផែនដីយើងសត្វថ្លៃក្លៀដោយព្រះអាទិត្យ ៧ ព្រះថ្ងៃ ៦ ។ អាកាសក្តៅស្ងាន់រុងរឿង ចរិយាកាសកំណៀ សត្វតិរច្ឆានក៏មានច្រើនលើសលុប ។ ក្នុងសម័យនោះ លោកវីរបុរស សីគាល់ បានចុះតម្រកក្នុងលោក ចម្រើនវ័យវ័ឌ្ឍមាការធំឡើង ហើយមានកិរិយាពីរៗ នៅសេរខ្លួ លោកបានលាកិរិយាចាំងពីរបស់លោក ដែលស្ថិតនៅ

ក្នុងកោះនៃសមុទ្រខាងកើត ឃាតព្រះទ័ននៅតែឆ្ពោះ រួចដំរេះមួយ
ហោះធ្វើដំណើរដុំវិញពិភពលោក ។ ដំណើរលោកសីតាល់នោះមានវត្ត
បំណង គឺលោកចង់ពិនិត្យមើលមនុស្សជាតិ ទឹងសត្វតិរច្ឆានចាំងអស់រស់
នៅទៅតាមព្រះពជបំណងនៃអាទិទេព តើរស់នៅដោយសមភាពទឹង
សន្តិភាពឬ? ។

លោកបានធ្វើដំណើរនេះយ៉ាងវែង ។ មានមួយថ្ងៃ លោកបាន
អញ្ជើញទៅដល់ភពមួយស្ងាត់នៅដាច់ឆ្ងាយ ។ លោកបានក្រឡេក
ទៅឃើញមានបក្សាបក្សីជាច្រើនណែនណាន់តាន់តាប់ ជជែកគ្នាទៅវិញ
ទៅមកដោយសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ។ លោកសីតាល់ក៏ទឹកក្នុងចិត្ត
ថា: អញបានឧស្សាហ៍ជាងពាក់កណ្តាលពិភពលោកហើយ អញបាន
ឃើញជាក់ច្បាស់ទឹងមិនសេចក្តីថាមនុស្សជាតិទឹងតិរច្ឆានជាតិបានឧទ្ទិសសម
ភាពទឹងសន្តិភាពគ្រប់ៗគ្នា ។ តើឥឡូវនេះ ម្តេចក៏បក្សាបក្សីនេះឈរ
ជិតគ្នាទឹកមុខព្រួយបារម្ភដូច្នេះ? ។

លោក សីតាល់ ក៏ពោលទៅកាន់បក្សាបក្សីទាំងនោះថា: „ មនុស្ស
ជាតិ តិរច្ឆានជាតិនៃពិភពលោក គេរស់នៅសុខសប្បាយគ្រប់គ្នា ។
ម្តេចក៏អ្នកឯងឆ្ងល់គ្នាមានទឹកមុខព្រួយម្ល៉ះ" ។

ក្នុងពេលនោះ មានគាអូតមួយជាអ្នកមានវោហារគ្រាន់បើ បានចូល
មកជិតលោកសីតាល់ហើយបានពោលថា:

(នៅមានត)

ទំនៀមកុលសម្ពន្ធ

ខ្មែរលើ

ពាក្យថា "កុលសម្ពន្ធ" ដូចជាមានន័យជាក់ជាំដែរបន្តិច តែខ្ញុំយកឈ្មោះនេះមកនិយាយ ព្រោះសព្វថ្ងៃក្រុមនេះ នៅមានស្ថេរគ្រប់ប្រទេសក្នុងអាស៊ីទូទៅ ។ នៅប្រទេសខ្មែរ ក្រុមនេះហៅថា "ខ្មែរលើ" ។ ខ្មែរលើគឺជាជនមួយពួកដែលមានឈាមជ័រជាខ្មែរដែរ តែពួកយើងដាច់ខ្មែរធម្មតាភាគច្រើន មិនសូវជាយល់ ឬដឹងនូវទំនៀមនៃជននេះសោះ ។ ឥឡូវរាជរដ្ឋាភិបាលសង្គមកម្ពុជាយើង កំពុងអប់រំពួកខ្មែរលើឲ្យមានជីវភាពខ្ពង់ខ្ពស់ឈរមុខនៅវេទិកាអាស៊ីអាគ្នេយ៍ ។ ដូចេះ ពួកខ្មែរលើមុខតែអាចបំភ្លេចនូវទំនៀមទំលាប់បាន ។ ខ្ញុំសូមឆ្លៀតឱកាសនេះ និងានទំនៀមទម្លាប់ខ្មែរលើខ្លះជូនលោកអ្នកជ្រាប តាមឯកសារបស់លោក ថូ ធន សាស្ត្រាចារ្យនៅអនុវិទ្យាល័យព្រះមហាក្សត្រិយានី កុសុមៈ (ក្រចេះ) ដែលកត់ទុកនៅក្នុងក្រុមដំទុំទំនៀមទម្លាប់ ដូចតទៅ ៖

ឃ្លាពីធីរបស់ខ្មែរលើ

ខែត្រក្រចេះ ដែលជែនចែកទៅជាតន្តីខ្លះ ទៅជាមណ្ឌលតន្តីខ្លះ ជាកន្លែងដែលចរិបូណ៌ទៅដោយពួកកុលសម្ពន្ធ ដែលយើងស្គាល់ឈ្មោះពិតថា "ខ្មែរលើ" ។

ខ្មែរលើមានប្បពេទិ ប្តូរទៀមទាប់ពីតែប្លែកពីខ្មែរយើងធម្មតា ។ ទំនៀមដែលប្លែកពីខ្មែរធម្មតានេះ មិនស្មើរាល់ផ្ទើទ្បើយើងព្រឺព្រួចស្បើយទេ តែចំពោះពិធីមួយ ដែលយើងធ្លាប់តែឮនៅក្នុងគម្ពីរខ្មែរនោះ ឥឡូវភ្លេកខ្មែរលើនៅប្រព្រឹត្តសព្វថ្ងៃ គឺ « ពិធីបូជាយញ្ញ » ឬ « យញ្ញពិធី » ។ ពិធីបូជាយញ្ញ ដែលគួរទ្បើស្បើបព្រឺព្រួច គឺការសែនព្រេនដើម្បីគោរពនូវព្រលឹងស្រួវ ដែលយើងហៅថា ព្រះនៃស្រែតណ៌ ។

រដូវប្រែតប្រាឡះយកគ្រាប់ស្រួវចេញពីគួរបួចហើយកាលណា ពួកខ្មែរលើយកធារស្រួវទៅគរ ឬទុកក្នុងដោកតែម្តង ។ អ្នកមានមុខមាត់ដែលគេស៊ីឈ្នួលបានស្រួវច្រើននៅក្នុងភូមិ គេសន្មតថា ជាអ្នកមាននៅក្នុងភូមិ ហើយអ្នកនេះត្រូវរៀបចំពិធីសែនព្រេនព្រលឹងស្រួវ មិនដែលខានទេ ។

គេលពិធីសែនព្រលឹងស្រួវមកដល់តាមឫក្សការហើយ ។ ក្បៀវដែលគេបានអញ្ជើញនោះ កំមកអង្គុយដាំកន្ទំតែនក្នែនតាមលំដាប់ហានៈទៅដុំវិញពីនូងស្រោ ឬក៏ទៅហែតាមលំដាប់ពីនូងស្រោ ប្រសិនបើជាមានទុំច្រើនស្រោច្រើន ។ ពីនូងស្រោ គេរៀបដាក់ជាគំនរតើធំទៅតូចទ្បើងទៅ មានកំពស់ប្រហែលជា ១ ម៉ែត្រកន្លះ ។ ក្បៀវអង្គុយបំរុងបឺតស្រោតាមបំពង់កន្ទុំ ក្បែកក្រឡាប់ចាក់សំឡីងដោតទៅក្រុមជន្ត្រីមួយវេន ។ ពួកអ្នកភ្លេងដួតក្បាលសំពត់ជាតី ឈរកាន់គងនៅត្រង់ដៃ នៅក្បែរកន្ទុំនូង

ដែលគេសំពះបូជាយញ្ញ ។ នៅតំឃាតដ្ឋាន មានក្របីយ៉ាងធាត់មួយ ឬក៏មួយទឹមត្រូវគេចងក្រៀកនៅទីនោះស្រេច ។ សត្វអត់ឮឈរសម្រក់ទឹកភ្នែកតក់ ។ ចំរុងលាខ្លួនថាកម្មនុស្សលោកនៅតាមមុខពួកជ ។ គេចងអម្បោះពីស្នែងក្របីដែលត្រូវសម្លាប់ បន្តពីដល់តំនរស្រូវដើម្បីឲ្យព្រលឹងស្រូវនៅទទួលសេតសោយឈាមក្របីស្រស់ ។

ពេលហោមពិធីមកដល់តាមកំណត់ខុសហើយ ខ្មែរលើម្នាក់ពាធាត់ក្រអាញដើរអើអាក កាន់ក្រឹសមុខសស្វាចដម្រង់ទៅសត្វអត់ឮ ។ ខណៈនោះ ភ្លេងក៏ប្រគំ «បទអំប្រី(១)» ឡើង ។ ខ្មែរលើកាន់ក្រឹសស្ទុះចូលទៅចាក់ខ្វេះឆ្អែះសរសៃកែងក្របីផ្តាច់ឲ្យហូរឈាម ។ អ្នកចាស់ពុំមានមុខមាត់និយាយសំបួងសំរួង អញ្ជើញខ្មោចព្រាយអារក្សអ្នកតាបង់បត់ត្រង់ទិសទស ពិសេសគឺគេសូត្រអញ្ជើញព្រលឹងស្រូវឲ្យចូលមកសេពសោយឈាមក្របី ។

លុះនិយាយបួងសួងចប់ហើយ ភ្លេងប្រគំរហូតដល់តំរង់ ៣ ដង ។ ឯអ្នកអារកាត់សរសៃដើងក្របី ចេះតែកាត់ទាល់តែក្របីស្រែកខ្ទន់ខ្លួនដួលត្រង់ទៅលើព្រះធរណី ។ ក្នុងពេលដែលក្របីដួលមិនទាន់ស្លាប់ ក្បៀវកំស្រែកហ៊ោក្រៃ ។ ខ្មៅងគួរឲ្យត្រឹកក្បាល ហើយស្ទុះចូលទៅចាប់អារសាច់ក្របីទាំងរស់ រួចចោះទៅក្នុងរណើកភ្លើងដេះគុលនៅក្បែរនោះស្រាប់

១- បទភ្លេងមួយចម្រៀងមួយបែបរបស់ខ្មែរលើ ។

រួចនាំគ្នាស៊ីផឹក បីតស្រាជាបដល់អស់ពីកន្ត្រកនិងនាំផ្ទះនោះ ទើបនាំគ្នាថយចេញទៅកន្លែងរៀង ។ ខ្លួន ។

ពួកស្លូប

សម្លៀកបំពាក់: ស្លូបប្រុស ។ ច្រើនស្លៀកសំពត់ណែដូចខ្មែរលើដែរ តែលែងដងខ្លួនទេ ។ ចំណែកស្រី ។ វិញ ស្លៀកសំពត់តាំងខ្លៅ ។ សំពត់ស្លៀក គេកាត់តែបុំនឹងធ្មេញឈើ យកមករុំព័ទ្ធតែមួយជុំចន្លោះ សំខ្លួយទៅក្រោមហៀរកែង ។ ជនខ្លះគេយកសំពត់មួយទៀតមកបាមពុង ។ សម័យឥឡូវ ពួកស្លូបបានឈប់មុខមកកាន់ការងារមិនសំលៀកបំពាក់កាន់តែដូចខ្មែរធម្មតាហើយ ។

គ្រឿងស្លាន: តិលំនៅរបស់ស្លូបមិនបានជាមាំទាំទេ ។ គេសង់ជាខ្នមតូច ។ ដូចជាជម្រកបណ្តោះអាសន្ន ។ រៀបសង់ផ្ទះ គេមានទំនៀមទាន់សង់ផ្ទះខែធ្នូនៃថ្ងៃ ។

របររកស៊ី: អាជីវកម្មរបស់ពួកស្លូប មិនបានជាសព្វគ្រប់ទេ គេធ្វើឲ្យតែគ្រប់គ្រាន់ប៉ុណ្ណោះ ។ គេច្រើនតែដាំស្រូវ ពោត ត្រាវ ដំឡូង ដែលជាការចាំបាច់កន្ត្រកចិញ្ចឹមជីវិត ។

ភាសា: រឿងភាសានេះ ពួកកុលសម្ភន្ធនិយាយមិនដូចគ្នាទេ ។ បើតាមខ្ញុំសង្កេតទៅដូចជាត្រូវតាមមតិលោក ជន. ប. ការុល (Jonh B. Carroll)

ដែលនិយាយថា "ភាសារបស់សង្គមនីមួយៗ មិនដាច់ឲ្យមានឯកភាពត្រឹមត្រូវបានទេ ប្រសិនជាសង្គមមនុស្សកើតឆ្ងាំឡើង ភាសាកាន់តែរវៃរកសេចក្តីឃ្លឹងឃ្លាតបន្តិចដែរ ។ ដូច្នេះ សង្គមនីមួយៗ រមែងមានលំនាំសំដីផ្សេងៗគ្នា" ។ ភាសារបស់តុលសម្ព័ន្ធនៅស្រុកខ្មែរ មានពួកគួយ ជង ស្អួច ជាដើម មានភាសាដូច្នេះខ្លះ ខ្ញុំសូមលើកយកពាក្យខាងក្រោមនេះជាឧទាហរណ៍:

ខ្មែរធម្មតា	ស្អួច	ព្នង
ទៅណា	ចេវ៉ូនី	អាត្រក់ម៉ែ

ឧទាហរណ៍ខាងនេះ អាចបញ្ជាក់ថា សង្គមមនុស្សប្លែកគ្នាអាចឲ្យប្រើភាសាប្លែកគ្នាបន្តិចទៅដែរ ។ ដូចយ៉ាងជនស្បែកក្រហមនៅសហរដ្ឋអាមេរិក ពួកណាវ៉ហូ « Navajo » ពួកផឺប្លូ « Pueblo » ពួកអាប៉ាចេ « Apache » ទើងពួកឯទៀត ។ មិយោយមិនត្រូវគ្នាទេ ។

សាសនា: ពួកស្អួចមិនមែនប្លែកពីខ្មែរយើងសម័យដើមប៉ុន្មានទេ ។ ការកាន់សាសនាវិញនោះ គឺគោរពប្រតិបត្តិទំពាំងមាំតែលើខ្មោចអារក្ស អ្នកតា ដូចតែខ្មែរយើងពីដើមដែរ ។ ពួកស្អួចតែដល់ខែចែត្រ តែងនាំគ្នាធ្វើបុណ្យបូជាអារក្សអ្នកតា ដើម្បីឲ្យបានអាយុវែង ។ ពិធីបុណ្យនេះ គេយកម្ហូបចំណីទៅរៀបសែនត្រង់ទៅតែខ្នងណាដែលមានអារក្សអ្នកតាឬកន្ទុងណាដែលមានដើមឈើធំ ។ គួរដាច់ស្បថស្បែង ។

ពិធីអាពាហ៍ពិពាហ៍: ខំនៀមស្តីដណ្តឹងកូនក្រមុំគេ មុនរៀបការ ពួកស្អួបនៅមានប្រព្រឹត្តដូចខ្មែរយើងជម្មតា ។ មុនដំបូង គេរកអ្នកផ្លូវទៅមហាទៅស្តីដណ្តឹងកូនគេដល់ផ្ទះឪពុកម្តាយខាងស្រី ។ អ្នកផ្លូវទៅមហាចៃ ប្តូរគ្នាស្រុះស្រួលថាព្រមឲ្យកូនហើយ គេនឹងចាត់រៀបការកូនប្រុសស្រី ។ ពេលថ្ងៃរៀបមង្គលការ ឪពុកម្តាយខាងកូនប្រុស ត្រូវរៀបណ្តាប់ចណ្តាការ (ដែលយើងនិយមថាលើកដំនូន) លើកយកទៅជូនដល់ម៉ែឪខាងស្រី ។ ណ្តាប់លើកដំនូនមាន ស្រាអេក ១ ក្អម[1] ចន្ទុះ ១ ដើមមាន់ ១ ទឹងខំភ្ងោច[2]ដើម្បីចុកចែកជូនដល់ក្មៀវខាងស្រី ។

មេបាខាងស្រីទទួលយកណ្តាប់ចណ្តាការនេះហើយ ទើបសម្លាប់មាន់ចុចកេមឲ្យស្អាត ហើយកាត់ដើងចាំងពីរ យកគោះរៀនត្រមាំងគោះ ថ្នើមប្រមាត់ចេះដូងចុក ឯសាច់តួមាន់ គេយកទៅស្ងោរសំពាប់ចុករៀបចាយស្តុកយកទៅសែនភ្ងោច ។ លុះចំអិនរួចស្រេច មេបាហៅកូនប្រុសកូនស្រីមកអង្គុយផ្ទឹមគ្នា ដោយមិនចាប់ចាំតែងខ្លួនច្រើនទេ ទើបគេយកស្តុកម្ហូបមាន់ស្ងោរមកដាក់ខាងមុខគូស្វាមីភរិយា ។ មេបាខាងប្រុសស្រីព្រមខាងញាតិដឹតញាយមកអង្គុយព័ទ្ធជុំវិញ ហើយទើបមេបាបង្គាប់ឲ្យកូនប្រុសយកដៃឆុបទាក់កូនស្រី ឯកូនស្រីវិញ ក៏យកដៃទៅ

១- ស្រាអេក ស្រាព្នងមួយបែបនៃលក្ខេត្រាំដោយគ្រឿងផ្សំក្នុងកោង ។

២- រៀបធ្វើទំនៀង ដេរយកអង្កាំទៅបុកធ្វើជាមេរ្យាព្ងាតដុំតូច ។ វែងខ្លួនចំនឹងស្នាមនុះរួច ស្ងោរឲ្យឆ្អិន ។

ពាក់កកូនប្រុសដែរ ។ នៅខែនេះ គេឃើញមានស្រីឆ្មបម្នាក់ ដៃម្ខាងកាន់ពោះវៀនមាន់ ដៃម្ខាងកាន់ជើងមាន់ ឥតឮយខាងក្រោយកូនប្រុសកូនស្រី និយាយសែនព្រួនប្រាប់ខ្មោចថា ឥឡូវបានរៀបការកូនប្រុសកូនស្រីពាំងពីនោកនេះឲ្យធ្វើជាប្តីប្រពន្ធ សូមកុំឲ្យខ្មោចជីដូនជីតាឆ្អែឆ្អន់អ្វី មេឆ្មបនិយាយចប់ក៏ចូលទៅក្នុងផ្ទះ ដៃកាន់ជើងមាន់ទៅកកាយខ្នងកូនប្រុសស្រីបណ្តើរអស់ពីរ: ៣ ដង ទើបគេត្រាក់សបញ្ជោរចោលទៅក្រៅទៅ ។ ពិធីរៀបមង្គលការខុកជាហើយស្រេច មិនចាប់កាត់ចំណងដៃផ្សំដៃណែកអ្វីទេ ។

ពេលធ្លាងទូផ្លែ : នៅពេលធ្វើនំខនំ្ន គេរកឆ្មបដែរ ។ ឆ្មបនៅរក្សាកូនចំនួន ៣ ថ្ងៃ ទើបទុកឲ្យស្រីសម្រាលកូននៅតែឯង ។ គេមិនឃើញមានពិធីបង្គក់ឆ្មបទេ ។ ពេលសំកាលកូនមកមានដុតភ្លើងដើងក្រានខៅបុងដើង គេអាងភ្លើងដូចយើងអាងមិនឲ្យរងា គេដេកអាងភ្លើងជួចខ្នែរធម្មតាមិនបានទេ ព្រោះភ្លើងខៅតែក្តងដើងក្រាន បើដេកអាង មុខត្រូវភ្លើងតែបាត់ដើង ។

ពិធីឈាបឆកប្ញ: មនុស្សបុគ្គលខោះប្រុសក្តីស្រីក្តី តែដល់ស្លាប់គេយកឈើពីរធ្វើជាមេសណ្តក ចងរែងជាខោប ហើយលើកសពដាក់ពីលើ រួចមនុស្សពីខោកំសែងមុខក្រោយយកខៅកប់ ។ ក្រៅពីនេះមិនមានពិធីអ្វីប្លែកទេ ។

ពិធីប្រគេនសង្ឃាប័ត្រ
ចំពោះព្រះតេជព្រះគុណ រាជ-កឹង វិត្តសារវ័ន
ជាមេគណក្រុងភ្នំពេញ

កាលពីថ្ងៃសុក្រ ទី ៣១ ខែ ឧសភា ១៨៦២ វេលាព្រឹក នៅក្នុង
ឧបដ្ឋានសាលាវត្តសាកវ័នតេជោ ក្រុងភ្នំពេញ មានធ្វើពិធីប្រគេនសង្ឃា-
ប័ត្រចំពោះព្រះសិរីសម្ថតិវង្ស ភ ជ - កឹង ជាមេគណ ក្រុងភ្នំពេញ
ក្រោមអធិបតីភាព នៃសម្តេចព្រះមហាសុមេធាធិបតី ជួង - ណាត
(ជោតញ្ញាណោ) សង្ឃនាយកគណៈមហានិកាយ ។

នៅមុនពេលប្រារព្ធពិធីនេះ មានព្រះសង្ឃ គ្រហស្ថ ឧបាសក
ឧបាសិកាជាច្រើន ចូលនិមន្ត-អញ្ជើញទៅរួបរួមក្នុងពិធីនេះ ដែលយើង
សង្កេតឃើញថាអាទិ៍ ផ្នែកព្រះសង្ឃមានព្រះពោធិវង្ស ហួត-តាត
អគ្គាធិការនៃពុទ្ធិកសិក្សា ព្រះធម្មលិខិត ម៉ឹង សែស ចៅអធិការវត្ត
មហាមន្ត្រី ព្រះមហាថេរាំង ឡាយ ជាចៅអធិការគ្រប់វត្តកន្លះក្រុង ព្រម
ទាំងព្រះសង្ឃជាច្រើនរូបអង្គទៀត ។ ផ្នែកគ្រហស្ថ មាន ឯ.ឧ.

ខេត្ត ៥ឯ ព្រះពជប្រតិភូប្រចាំ ក្រុងភ្នំពេញ ឬគ្គលិកសាលាក្រុង ចៅសង្កាត់នានាក្នុងក្រុង លោកនាយស្នងការប៉ូលិសក្រុង ព្រមទាំង ឧបាសក ឧបាសិកាជាច្រើន ។

នៅវេលាម៉ោង ៤ ទឹង ៤៥ នាទី សម្តេចព្រះសង្ឃនាយកទឹមទ្ធដល់ ដោយមានព្រះថេរានុត្ថេរ ថ្វាយបង្គំខួលសម្តេចសង្ឃគាមចំនៀម ។ លុះក្រៀវទាំងបញ្ចូដិតទាំងត្រហស្តទឹមទ្ធទឹងមកដួចដុំហើយ ឯ.ខ. ខេត្ត-ឯ ឯ បានថ្លែងអំណរដំស្មោះស្ម័ត្រ ព្រមទាំងថ្លែងនូវសេចក្តីសង្ឃឹមថា ដោយមានការរៀបចំឲ្យមានមេគណប្រចាំក្រុងភ្នំពេញនេះ ជាការប្រសើរណាស់ ជាហេតុនាំឲ្យព្រះពជនានីយើងមានរបៀបរៀបរយទឹងស្អាតល្អ ត្រប់ថែបយ៉ាងគេ ។

បន្ទាប់មក សម្តេចព្រះសង្ឃនាយកបានថ្លែងអំពីដំណើរដែលនាំឲ្យ កើតមានមេគណក្រុងភ្នំពេញ ។ សម្តេចព្រះសង្ឃនាយកបានបញ្ជាក់ថា មានព្រះពជក្រមមួយលេខ ១៦ ចុះខែកុម្ភៈ ១៩៤៣ ត្រង់ប្រការ ១៣ មានចែងថា "ត្រូវមានមេគណសម្រាប់ក្រុងភ្នំពេញ" តែតាំងពីពេលនោះមក ពុំទាន់បានរៀបចំនៅឡើយ ហើយចំនួនវត្តនៅក្នុងក្រុងទាំងផ្នែកមហានិកាយមានតែ ១៧ វត្ត ឥឡូវដោយត្រូវពង្រីកទីក្រុង ត្រូវមានវត្ត ៤ ទៀត បានចូលមកក្នុងព្រះពជនាមី គឺចំនួនវត្តក្នុងក្រុងក៏កើនឡើងពី ១៧ ទៅ ២១ វត្ត ហើយកាលៈទេសៈក៏បានតម្រូវផង ទើប

សម្រេចរៀបចំឲ្យមានមេគណក្រុងឡើង ដោយក្រសួងជម្ចការ សាលាក្រុងភ្នំពេញបានយល់ស្រប ហើយសម្តេចព្រះប្រមុខរដ្ឋ ព្រះអង្គកំទ្រង់សព្វាជញ្ញាឲ្យមានមេគណក្រុងនេះដែរ ហើយបានតម្រូវឲ្យព្រះសិរីសម្មតិវង្ស ភ.ភ.កឹង ខ្ពស់ឋានន្តរនេះ ។

លុះថ្ងៃឆ្លងបំហើយ សម្តេចព្រះសង្ឃនាយក បានប្រគល់ត្រាជាសញ្ញាតែងតាំងចំពោះព្រះសិរីសម្មតិវង្ស ភ.ភ.កឹង ជាមេគណក្រុងភ្នំពេញ ពេញសមត្ថកាតតាំងពីពេលនេះតទៅ ។

យើងសូមដកស្រង់ខ្លះជីវប្រវត្តិ នៃព្រះសិរីសម្មតិវង្ស ភ.ភ.កឹង មេគណក្រុងភ្នំពេញ ដោយសង្ខេបដូចតទៅនេះ ៖

"ព្រះសិរីសម្មតិវង្ស ភ.ភ.កឹង មានព្រះជន្មាយុ ៥២ ឆ្នាំ ញោម ប្រុសនាម អ៊ួង ភ.ភ ញោមស្រីនាម ក្រែស-ឈួក ។ លោកកើតពីថ្ងៃទី ២៣ វិច្ឆិកា ១៩១០ នៅឃុំត្រាកោង ស្រុកកំពង់ស្ពាន ខេត្តព្រៃកប្បស្សី (កម្ពុជាក្រោម) ។ កាលនៅពីកុមារ បានទៅសិក្សាអក្សរសាស្ត្រនៅវត្តតេនបទុម ។ អាយុ ១១ ឆ្នាំ បានបួសជាសាមណេរ លុះដល់គ្រប់អាយុក៏បានបំពេញឧបសម្បទាជាភិក្ខុ បានទាមទាយាជា សុវណ្ណកេសរ លោកបានសិក្សារៀនសូត្រគន្ថធុរៈ ទឹង វិបស្សនាធុរៈ បានខ្ពស់ជាឋានានុក្រម បានខ្ពស់ជាពាជាគណៈទី ៤ ជាពាជាគណៈទី ៣ បានធ្វើជាសាស្ត្រាចារ្យ កាន់ការជាអគ្គាធិការរងនៃពុទ្ធិកសិក្សា ជាទីប្រឹក្សានៃ

ពុទ្ធិកសមាគមកម្ពុជរដ្ឋ សមាគមមិត្តពុទ្ធិកវិទ្យាល័យ សមាគមមិត្រខ្មែរ
កម្ពុជាក្រោម ជាជនកសមាជិក ជាឧបការសមាជិក ទទឹងជាលេខាធិការ
នៃសមាគមគំលាទុបដ្ឋានព្រះមហាក្សត្រិយានី ។ ល ។

លោកបានទទួលមេដែយ៍អស្សារិទ្ធិមុនីសារគរណ៍ពីឆ្នាំ ១៩៥៣
ហើយនៅឆ្នាំ ១៩៦២ នេះ លោកបានទទួលនាទីជាមេគណក្រុងភ្នំពេញ។

យើងសូមបញ្ជាក់ថា ក្នុងកាសពិធីនេះ ចៅគែកេសដ្ឋៈសេរីនអាច់
មានសេចក្តីជ្រះថ្លា បានប្រគេនទូរកេសដ្ឋៈសេរីនអាច់ចំនួន ២០០ ដប
សម្រាប់ចាត់ចែងក្នុងពិធីនេះផង ។ ពិធីនេះបានចប់សព្វគ្រប់នៅវេលា
ម៉ោង ៦ ល្ងាច ។

ភ្នំពេជ្រ


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣៤ លេខ ១១ ខែវិច្ឆិកា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -



ភ្នំពេញសន្ទេសារ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញ្ញារាល់ខែពីព្រះសាសនបណ្ឌិត្យ

បញ្ជីរឿង

	ទំព័រ
ផ្នែកសាសនា	
– ធម្មវិចរណកថា ព្រះសាសនមុនី កឹម-គួរ រៀបរៀង (ត)	១២០៤
– គោលដ្ឋាប់ព្រះពុទ្ធសាសនា លោក ហេង-សមអាន តែងនឹងរៀបរៀង (ត)	១២១២
– ព្រះអភិធម្មបិដក (គម្ពីរព្រះយមក:) លោកប៊ូ-ប៉ូ ប្រែរៀបរៀង (ត)	១២២០
– មធុរសវិហិណី សម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សា ប្រែរៀបរៀង (ត)	១២២៨
– មហោសថជាតក (ត)	១២៣៦
ផ្នែកអក្សរសាស្ត្រ	
– ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ "ក" (ត)	១២៥៤
– វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត)	១២៥៨
– រឿងល្បីកន្ទាហ្វុងតែន (La Fontaine) លោកផេង-ន្រ្តីវ ប្រែពីភាសាបារាំង(ត)	១២៦០
– រឿងសាមកុក អ្នកនាពញ៉ា នូ-កន ប្រែរៀបរៀង (ត)	១២៦៨
– រឿងត្រែងចិន លោក ភ័យ-ប៊ុក ភ្ញូយទៃត្រែងកែវ ប្រែរៀបរៀង (ត)	១២៩៨
– រឿងត្រាំងណាក់ទង្គ័ល របស់ក្រុមទំនៀមទម្លាប់	១៣០៣
កំណត់ទីន្រ្តប្រវត្តិការណ៍	
– ពិធីសម្ពោធវិមានឯកកម្ម	១៣០៩
– ពិធីតាំងបៅអភារ និងគ្រួសគ្រែ	១៣១៤

34è Année—N° 11—Novembre 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse

—Dhammavicharanakatha par le Vénérable KEM-TO (suite) . . 1204
—Principes bouddhiques par M. HENG-SAM-AN (suite) 1212
—Préah Abhidhammapitaka «Kampir Préah Yamaka» par M. BOU-PO (suite) 1220
—Madhurasavahini par S.Em LOUIS-EM Haut Conseiller (suite) 1228
—Mahosotha Jataka (suite) 1236

Partie littéraire

—Activités de la Commission Culturelle chapitre «Ka» (suite). . . 1254
—Dictionnaire Sanscrit-Khmer par Vénérable PANG-KHAT (suite). 1258
—Fables de la Fontaine traduites par M. PHÈNG-CHRIV (suite) 1260
—Histoire de Sam-Kok traduite par Oknha NOU-KAN (suite) . . . 1268
—Légende Chinoise traduite par M. RAY-BOUC Phouchhouykhèt de TAKEO (suite) 1298
—Histoire de Trapéang Léak Néangkéal (mœurs et coutumes) . . 1303

Notes et chroniques

—Cérémonie d'inauguration de monument de l'Indépendence. . . 1308
—Cérémonie de Nomminations des Chau-Athika et leurs adjoints...1314

Prix d'Abonnement annuel (comprenant 12 numéros) : 230 ; 00

ធម្មវិចារណាកថា

ព្រះសាសនមុនី គឹម-ស្រ៊ុន រៀបរៀង

(តមក)

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ ។
ឲ្យជ្រិះសាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

ព្រះសម្មាសម្ពុទ្ធ ទ្រង់លើកយកអកុសលមូលគឺ លោភៈ ទោសៈ មោហៈ សម្តែងចំពោះពុទ្ធបរិស័ទផ្នែកខាងគ្រហស្ថ ទ្រង់លើកយកភពៈ ទោសៈ មោហៈ សម្តែងចំពោះពុទ្ធបរិស័ទផ្នែកខាងបព្វជិត ប្លែកគ្នាតែ ២ ខាងដើមគឺៈ លោភៈ ចំពោះគ្រហស្ថ ភពៈ ចំពោះបព្វជិត ក្រៅពីនេះនៅដូចគ្នា ។ គួរឲ្យចង់ដឹងថា ព្រោះហេតុអ្វីបានជាព្រះអង្គទ្រង់សម្តែងផ្សេងគ្នាដូច្នេះ ? ព្រោះហេតុថា គ្រហស្ថជាអ្នកមានសម្បត្តិផ្ទាល់ខ្លួន ឬថាសម្បត្តិជាអាយុជីវិតរបស់គ្រហស្ថ ។ តែងមានចិត្តផ្តេកផ្តិតជាប់ដំណាក់ធំធំសម្បត្តិដែលកំពុងមាននៅក្នុងកណ្តាប់ដៃខ្លួន ទាំងមានចិត្តជាប់ចំពាក់ធំធំសម្បត្តិដែលកំពុងតែស្វែងរកផង ព្រោះហេតុនោះបានជាព្រះអង្គទ្រង់សម្តែង លោភៈ ចំពោះជនកេរគ្រហស្ថ ដើម្បីឲ្យ

ដ៏ឆ្ងាយ ។ លោក: ជាកិលេសធ្វើចិត្តរបស់បុគ្គលឲ្យជាប់ចំពាក់ក្នុងសម្បត្តិ
ទាំងជាឫសគល់នៃអកុសល ដែលជាហេតុបណ្តាលឲ្យកើតទុក្ខទោស
ផ្សេងៗ ក្នុងលោកនេះឬក្នុងលោកខាងមុខ ។ ចំណែងខាង ភក: ព្រះ
អង្គទ្រង់សំដែងចំពោះបព្វជិត ដោយហេតុថា បព្វជិតជាមនុស្សមិនមាន
សម្បត្តិផ្ទាល់ខ្លួនដូចជាគ្រហស្ថទេ គ្រាន់តែមាន ភក: តិរេចក្តីត្រេកត្រ-
អាលទៅក្នុងអារម្មណ៍ផ្សេងៗ មានរូបារម្មណ៍ជាដើមតាមផ្លូវចិត្តខ្លះប៉ុណ្ណោះ
ពីព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ថា ធម្មតាបព្វជិត ក្នុងពេលមុនខឹងចូល
មកបួសក្នុងពុទ្ធសាសនា ចាខលះបង់ទ្រព្យសម្បត្តិអស់រលីងពីខ្លួនហើយ
សូម្បីបើមានចំពាក់ចំណុលគេ ក៏ចាខលៃលុកដោះស្រាយជ្រះស្រឡះ
ហើយសិនដែរទើបបួស លុះបួសហើយមានត្រឹមតែបរិក្ខារ ៨ សម្រាប់ប្រើ
ប្រាស់ជារបស់បព្វជិតប៉ុណ្ណោះ តែនេះមិនដូច្នោះ មានបព្វជិតខ្លះវង្វើងក្នុង
តំនិតដើមរបស់ខ្លួន ត្រឡប់ជាស្វែងរកគ្រឿងប្រើប្រាស់ដែលជារបស់មិន
សមគួរដល់បព្វជិត ឬប្រមូលសន្សំទុកជាក់ខ្លួវលោភសក្ការ: គឺសម្បត្តិឲ្យ
មានកាន់តែច្រើនឡើង ។ កាលបើមានសម្បត្តិច្រើនជារបស់ផ្ទាល់ខ្លួន
ហើយ បព្វជិតនោះ ក៏រមែងកើតលោភចិត្ត លះបង់ស្ងួបអង្អែលទ្រព្យ
សម្បត្តិ ហួងហែងទ្រព្យសម្បត្តិ ចិត្តជាប់ចំពាក់ក្នុងទ្រព្យសម្បត្តិដែល
មាននោះ។ ដូចជាគ្រហស្ថដែរ ។ រឿងនេះបើមានគេយល់ឆាស់ថា ទេ
សម្បត្តិទាំងអស់នោះ ដែលកើតឡើងដល់បព្វជិត អាស្រ័យដោយឆាយក

ទាយិកា ប្រគេនខ្លះតើ មានលោកទៅស្វែងរកបានមកដោយយកសិក្ខាបទណាដ៏ក្នុងអង្គាលណា ? ពុកផាគេប្រគេនកំដោយ ឬមានមកដោយវិធីណា កំដោយ ធម្មតាមនុស្សដែលទៅជាបុថុជ្ជន តែងនឹងតែគេតែលោភៈ គឺធ្វើចិត្តឲ្យជាប់ចំពាក់ ឲ្យមានការរវល់ ហួងហែងថែទាំពុកជាតំពុំមានគ្រោះតែរឿងនេះឯង ឬជាព្រះពុទ្ធបរមគ្រូ ទ្រង់អនុញ្ញាតថា អាវាសជាទីនៅរបស់បព្វជិតនីមួយ ។ ត្រូវឲ្យមានកប្បិយកុដិ សម្រាប់ពុកជាក់សម្បត្តិសង្ឃ (សម្បត្តិរមឬសម្បត្តិកណ្តាល) ដើម្បីកុំឲ្យបព្វជិត មានកង្វល់រវល់លំបាកចំពោះលាភគឺសម្បត្តិ ដែលតើតឡើងដល់ខ្លួន ។ បើយើងជាបព្វជិត មិនប្រតិបត្តិតាមពុទ្ធឧដ្ឋដនេះទេ បណ្តោយចិត្តឲ្យវង្វេងជាប់ទៅកង់ទ្រព្យសម្បត្តិដូចជាគ្រហស្ថដែរ ដែលបានឱយាយមកហើយនោះ ក៏មិនវិសេសប្លែកអំពីគ្រហស្ថប៉ុន្មាន នេះឯងឈ្មោះថាជាការកាន់ប្រឡំទី ៩ របស់បព្វជិត ។

បព្វជិតខ្លះ តើតពុកគួញគ្នែរថា ខ្ញុំ! អាគ្នាអញតាំងពីបួសមក មិនមានដែលបានធ្វើបុណ្យទានអ្វីទាំងគេសោះ ។ ការគួញគ្នែរបស់បព្វជិតនោះ ហាក់ដូចជាពុំសូវសមមៀ ព្រោះហេតុអ្វី ? ព្រោះហេតុថា បព្វជិតបានលះបង់ទ្រព្យសម្បត្តិរបស់ខ្លួនជ្រះស្រឡះអស់រលីង តាំងតាំងពីមុនបួសមក បួសម្ល៉ះ ទៅជាអប្បិច្ចបុគ្គលគ្មានទ្រព្យសម្បត្តិទៅហើយ ទើងបានទ្រព្យសម្បត្តិពីណាយកមកលះធ្វើទាន មានតែការយោសនាសូមគេ យកមក

លះធ្លើ ការសូមទ្រព្យគេយកមកធ្វើទានខោះ មិនមែនជាការចាំបាច់
របស់ចម្បងដ៏តប៉ុន្មានទេ ដូចអន្ទុបុព្វកថា ៥ យ៉ាងមានទានកថាជាដើម ព្រះ
សម្មុខ្ទច្រើនតែសម្តែងក្រោពុទ្ធចរិស័ទជាគ្រហស្ថទេតើ ព្រោះគ្រហស្ថ
មានកោតសម្បីទ គេអាចលះធ្លើទានបាន ជាការជួយសង្គ្រោះឲ្យអ្នកដទៃ
បានសុខដើម្បីគេបានបុណ្យផង ជាហេតុបន្ថយកម្ចាំងកំលេសតិលោភៈ
ទំងមច្ឆរិយៈផង ។ ខ្ញុំបានទំកំរំពីងកវែកក្នុងតម្ពីរផ្សេង ។ មិនឃើញមាន
ភុទ្ធដីកាត្រង់ណាដែលសម្តែងសរសើរថា បព្វជិតគួរធ្លើបុណ្យទានដោយ
ទ្រព្យសម្បត្តិសោះ ឃើញមានតែកបិទទានក្នុងវិន័យបិដក ដែលព្រះអង្គ
ទ្រង់អនុញ្ញាតឲ្យសហធម្មិកបព្វជិតចាំង ៥ មានភិក្ខុជាដើមអាចធ្លើបាន ប៉ុន្តែ
ការធ្លើកបិទទានបានខោះ សូមកុំច្រឡំអំពីពុទ្ធគន្ធាស្រ័យរបស់ព្រះអង្គថា
បើលាភសក្ការៈកើតឡើងសម្បូរដល់បព្វជិតអង្គណាមួយ បព្វជិតអង្គខោះ
គួរចែករំលែកលាភសក្ការៈខោះ ដល់ភិក្ខុសាមណេរចាំងឡាយ ខោះជា
សទ្ធិវិហារិក ឬអន្តេវាសិកដែលអាស្រ័យនៅក្នុងវត្តជាមួយឲ្យគ្នាបានប្រើ-
ប្រាស់ផង ឬក៏ទំកឃើញវត្តណាមួយ ដែលមានភិក្ខុសាមណេរខ្វត់
ខ្វាយមិនសូវសម្បូរលាភ ហើយចង់អនុគ្រោះវត្តខោះ ឲ្យសង្ឃបានលាភ
ខ្លះគ្រាន់ទំងប្រើប្រាស់ បើសម័យខោះដូនជាសម័យកាលចំរ៉ា ក៏គួរចាត់
ចែងលាភរបស់ខ្លួនមានស្បង់ចីពរជាដើមតាមមានតាមបាន ជាកបិទទាន
ទាំយកទៅវែរប្រគេនសង្ឃវត្តខោះ ដើម្បីឲ្យលោកបានខ្លួលក្រាលត្រង

កបិនទាន តាមពុទ្ធានុញ្ញាតផង ដើម្បីវិស្សាសិកបានអានិសង្សខ្ពស់ជាង ប៉ុណ្ណោះដាការគួរដែរ ប៉ុន្តែមិនដូច្នោះ មានបព្វជិតខ្លះ គ្មានលាភអ្វីជារបស់ខ្លួនសោះទេ ហើយបង់ធ្វើកបិនទាន កំតាំងផ្តើមធ្វើដោយប្រើធនៈយោសនាដោយផ្ទាល់មាត់ ឬដោយលិខិត (ប្រក្រាម) ដាក់ឈ្មោះខ្លួនឯងជាការអំពាវនាវហៅភេតាយក-ភាយិកា ។ ការយោសនានេះ ឈ្មោះថាជាការប៉ះពាល់ឬបៀតបៀនខ្លួនភេតៈ ទើសត្តាបរស់តាយក-តាយិកាផង ។ កន្លងពេលដែលធ្វើនោះសោតទៀត កំមានលែ្បងជាំ ឬក្ងេងក្ងាត់គគ្រឹកគគ្រេងផ្តើលយកឬ ផ្តើលមារ ត្រង់នេះហាក់ដូចជាបង់ហួសត្រាំដែនទេដឹង? បើជាគ្រហស្ថវិញ ពោះបីគេផ្តើមធ្វើដោយវិធីណាមួយ ពោះយោសនាដោយផ្ទាល់មាត់ក្តី ដោយលិតលិខិតក្តី កន្លងពេលដែលធ្វើមានក្ងេងក្ងរឬតគ្រឹកគគ្រេងយ៉ាងណាក្តី កំចេះតែអាចធ្វើទៅបានទាំងអស់ ។ បើបព្វជិត មិនស្ទាត់អើពើនឹងព្រហ្មចរិយធម៌ជាទាយបរស់ខ្លួនប៉ុន្មានទេ ចៃដាច្នាន់ចិត្តទៅភេការធ្វើទានច្រាច្បាស់យកបុណ្យដូចគ្រហស្ថដែរ មិនចាំបាច់មកបួសធ្វើអ្វីទេ ទៅធ្វើជាភេទគ្រហស្ថវិញ ជាដំណើរងាយស្រួលកន្លងការធ្វើទានផង ។ បើបព្វជិតណាមួយ មិនយល់ស្របតាមន័យដែលបុនពោលមកនេះទេ ឈ្មោះថាជាការកាន់ច្រឡំនូវបរមត្ថរបស់បព្វជិត ។

ឆុរៈ តួន៍ពុទ្ធសាសនាមាន ៤ យ៉ាងគឺ កន្តឆុរៈ ១ វិមុសន្តឆុរៈ ១ ។ កន្តឆុរៈ បានខាងការសិក្សាបរិយត្តិ (ព្រះត្រៃបិដក)

វិបស្សនាធុរៈ ជានខាងការសិក្សាសមថកម្មដ្ឋាន ទើងវិបស្សនាកម្មដ្ឋាន។ ធុរៈទាំងពីរនេះ ជាការណ៍យកចិត្តរបស់បព្វជិត។ ត្រូវតែបំពេញធុរៈទាំងពីរនោះ ធុរៈណាមួយ ទៅតាមសមត្ថភាពដែលខ្លួនអាចធ្វើទៅកើត ទើងខានតុំបានជាជាប់ខាត។ បើកុលបុត្រដែលបួសជាបព្វជិតហើយ មិនដើរតើចំពោះធុរៈទាំងពីរនោះ ធុរៈណាមួយទេ បណ្តោយខ្លួនឲ្យនៅតំនេរគ្រាន់តែរឿនឲ្យចេះធម៌ចាលិខុកសម្រាប់សូត្រមន្ត ជារ បង្សុកូល ហើយនៅរងាំចាំខួលនិមន្តន៍របស់ពួកក-ពួកកា ឬនៅចាំខួលលាភសក្ការៈអំពីពួកក-ពួកកា ប៉ុណ្ណោះ ហើយស្មានថាការណ៍យកចិត្តរបស់បព្វជិតមានតែត្រឹមប៉ុណ្ណេះឯង គ្មានអ្វីក្រៅអំពីនេះទៅទៀតទេ បើបព្វជិត មានគំនិតយល់ដូច្នោះមែន ឈ្មោះថាជាការកាន់ច្រឡំនូវ ខ្លឹមរបស់បព្វជិត។

បព្វជិតខ្លះ បានចេញរួចផុតអំពីអន្ទាក់គឺកាមគុណហើយ ត្រឡប់ជាចូលទៅជាប់ក្នុងអន្ទាក់គឺកាមគុណជាដែលវិញ; ន័យនេះបានសេចក្តីថា កុលបុត្រខ្លះ បានលះបង់នូវគំនរកោគទ្រព្យដែលមានវិញ្ញាណ ទើងឥតវិញ្ញាណទេះបីតិចច្រើនរបស់ខ្លួនផង បានលះបង់នូវក្រុមញាតិមិត្តជាទីស្រឡាញ់ពេញចិត្តចង ហើយចូលមកបួសក្នុងពុទ្ធសាសនា ឈ្មោះថាបានចេញរួចផុតអំពីអន្ទាក់គឺកាមគុណហើយ លុះបួសបានហៅជាបព្វជិតហើយ ត្រូវបំពេញត្រៃសិក្ខាគឺ សីល សមាធិ បញ្ញា ដែលជានាវិរបស់ខ្លួនឲ្យបានហ្មត់ចត់ ដើម្បីលះបង់កិលេសតាមលំដាប់ ហើយធ្វើចិត្ត

ឲ្យមានដំណើរឆ្ពោះទៅកាន់បរមសុខ គឺព្រះនិព្វាន ប៉ុន្តែបព្វជិតខ្លះ មិនដូច្នោះទេ ត្រឡប់ជាផ្ចុយទៅវិញ បណ្តោយឲ្យលាភសក្ការៈគ្របសង្កត់ប្តូរចិត្តឲ្យធ្ងន់លង់លុះក្នុងអំណាចនៃលាភសក្ការៈ រហូតដល់ទៅប្រើវិធីស្វែងរកលាភសក្ការៈក្នុងផ្លូវដ៏ថោកទាបប្រកបដោយអនេសនៈនឹងបាបធម៌ដោយឥតមានសេចក្តីអៀនខ្មាស ។ ដីវិភាគរបស់បព្វជិតណា ដែលរស់នៅអាស្រ័យលាភសក្ការៈ កើតឡើងដោយខុសច្បាប់នេះ ព្រះពុទ្ធជាម្ចាស់ ទ្រង់តិះដៀលថា ដីវិភាគរបស់បព្វជិតនោះ ឈ្មោះថាជាដីវិភាគដ៏លាមក ព្រោះហេតុអ្វី? ព្រោះហេតុថា បព្វជិតនោះធ្វើឲ្យទាយក-ទាយិកាមានសេចក្តីជ្រះថ្លាខ្លឹងដ៏ប្រព្រឹត្តទៅក្នុងផ្លូវខុសច្បាប់ គឺមិនមែនជាសេចក្តីជ្រះថ្លាដាំឲ្យបានបុណ្យកុសលជាហេតុឲ្យរួចចាកទុក្ខបានឡើយ ។ បើបព្វជិតណាមួយ ធ្ងន់ចិត្តតឹត្រែកអរតេញចិត្តស្មោកក្នុងលាភសក្ការៈនឹងការជាប់ចិត្តចំពោះទាយក ទាយិកា ដែលគេមានសេចក្តីស្រឡាញ់កាន់ខ្លួន បព្វជិតនោះឈ្មោះថា ជាប់នៅក្នុងអន្ទាក់គឺកាមគុណដែល ដូចកាលខ្លួនដែលនៅជាគ្រហស្ថដែរ នេះឯងឈ្មោះថាជាការកាន់ប្រឡំ ៧ របស់បព្វជិត ។

កុលបុត្តម្នាក់ៗដែលចូលមកបួសក្នុងព្រះពុទ្ធសាសនា អាស្រ័យដោយមានគំនិតគិតឃើញពីខាងដើមផ្សេងៗគ្នា មានច្រើនបែប ច្រើនយ៉ាង គឺអ្នកខ្លះ គិតឃើញទោសរបស់ឃរាវាស (ការនៅគ្រប់គ្រងផ្ទះ) ថាសុទ្ធ

តែប្រកបដោយទុក្ខទោសច្រើនស្ថានណាស់ មិនអាចធ្វើខ្លួនឲ្យបរិសុទ្ធផុតចាកទុក្ខបានឡើយ លុះគិតឃើញហើយ ក៏កើតសេចក្តីខ្លឹចណាយធុញទ្រាន់ទីដែលកេរឃាត់ស ហើយចេញទៅបួសដោយហេតុនេះកំមាន ។ អ្នកខ្លះគិតឃើញទោសនៃខន្ធ ៥ របស់ខ្លួន ដែលត្រូវស្អប់កើតកង់វង្គសង្សារវឿយ ។ លុះគិតឃើញហើយ ក៏ចេញទៅបួសដោយហេតុនេះកំមាន ។ អ្នកខ្លះជាមនុស្សខ្សោយខ្លិលប្រអូស គិតឃើញថា ការនៅធ្វើជាគ្រហស្ថនេះ ពិបាកប្រកបការងារកេរឲ្យសម្បត្តិសម្រាប់ចិញ្ចឹមជីវិតណាស់ បើធ្វើជាអ្នកបួសវិញ ទើបស្រួលងាយនឹងចិញ្ចឹមជីវិត ក៏ចេញទៅបួសដោយហេតុនេះកំមាន ។ អ្នកខ្លះ គិតឃើញថាអាត្មាអញ មានវ័យល្មមបួសជាសាមណេរឬជាភិក្ខុហើយ ព្រោះអ្នកដទៃគេបួសរាល់គ្នា ម៉េចឯងមិនបួសទេ ក្រែងអ្នកផងគេនឹងនិន្ទាយ៉ាងនេះ ឬយ៉ាងនោះពុំមាន ហើយក៏ចេញទៅបួសដោយហេតុនេះកំមាន ។ អ្នកខ្លះ ពុំបានជាគិតឃើញដល់ទុក្ខទោស ឬ ហេតុណាមួយទេ តែត្រូវតួកញាតិមាន មាតាបិតាជាដើមនិយាយណែនាំបង្ខំឲ្យបួស ក៏សុខចិត្តព្រមបួសដោយហេតុនេះកំមាន ។ អ្នកខ្លះ គិតឃើញថា ក្នុងពុទ្ធសាសនាសម្បូរការសិក្សាណាស់ អាត្មាអញគួរតែរៀនឲ្យចេះដឹងវិជ្ជាខាងផ្លូវពុទ្ធសាសនា លុះគិតឃើញហើយ ក៏ចេញទៅបួសដោយហេតុនេះ កំមាន ។ ល ។

(នៅមានត)

ចាកធម្មបទ - ខុទ្ទកនិកាយ

លោក ខោន-សមអាន រៀបរៀង

(ត្រមក)

ឯមិបាទិដ្ឋនេះ ឧទាហរណ៍ដូចជា :

រឿងសុនក្ខត្តលិច្ឆវី

សុនក្ខត្តលិច្ឆវី ជាព្រះរាជបុត្ររបស់ព្រះបាទលិច្ឆវី ព្រះចៅក្រុងវេ-សាលី នៃដែនវជ្ជី បានចូលមកបួសក្នុងព្រះពុទ្ធសាសនា បានចំពូកក្នុមើលឃើញរូបទៅតាំងឡាយ តែស្តាប់សំឡេងមិនឮ ក៏ចូលទៅគាល់ព្រះសាស្តាក្រាបថ្វាយបង្គំ សូមរៀនបរិកម្មកសិណចំពូកសោតវិញ្ញាតទៅទៀត តែព្រះពុទ្ធជាម្ចាស់មិនបានគ្រាស់តឿលដូចមុនឡើយ ដោយទ្រង់ជ្រាបថា កុងអតីតកាល សុនក្ខត្តកំកុំ បានប្រហារត្រចៀកកំកុំមានមើល ១ រូប ឱ្យថ្នង់ ។ សូម្បីសុនក្ខត្តកំកុំព្យាយាមបរិកម្មការមាជាយូរខួបឯងអស់ ៣ ឆ្នាំ ក៏មិនបានចំពូកសោតឡើយ ។ កាលបើមិនបានចំពូកសោតដូច្នោះ សុនក្ខត្តកំកុំយល់ឆ្នេងថា "ព្រះសមណគោតមជាតិក្សត្រ អញក៏ជាតិក្សត្រដូចគ្នា ប្រសិនបើជាអញបានចំពូកសោតវិញ្ញាតទៅ ក្រែងលោអញបានគ្រាស់ជាព្រះពុទ្ធស្មើនឹងព្រះអង្គ បានជាមិនតឿលប្រាប់វិធីចំរើនឱ្យកើតចំពូ

សោតដល់អញ គឺព្រះអង្គប្រាថ្នាកាំងញ្ញាណវិស័យនៃអញប្រាកដ ។
កាលសុនក្ខត្តកិក្ខុយល់ខុសដូច្នោះ កំចង់តំទុំគំញ្ជាជាទន្ទឹងព្រះបរមគ្រូតទៅ
ហើយក៏លាចាកសិក្ខាបទទៅជាឃរាវាសវិនាសចាកព្រះពុទ្ធសាសនា ទៅ
ចូលសិក្សាលទ្ធិអន្យតិរ្ថិយនៃពួកនិគ្រន្ថនាដបុត្រ ។

ឯគំនិតរបស់សុនក្ខត្តកិក្ខុក្តៅលទោសព្រះសម្មុខដូច្នោះ ជាគំនិត
យល់ខុសទេ ។ ព្រះពុទ្ធទាំងឡាយមិនមានហឫទ័យញាប់ញ័រដោយ
លោកធម៌ទេ សមនឹងពុទ្ធភាសិតថា

អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ
សង្ខារា សស្សតា នត្ថិ នត្ថិពុទ្ធានមិញ្ជិតំ

" ខាងក្រៅពីពុទ្ធសាសនា មិនមានសមណៈទេ ព្រះពុទ្ធទាំងឡាយ
មិនមានសេចក្តីញាប់ញ័រទេ ដូចជាស្នាមជើងដែលមិនមាននៅលើអា-
កាសដូច្នោះឯង " ។

គំនិតយល់ខុសនៃសុនក្ខត្តកិក្ខុ កប់ថាជាមិច្ឆាទិដ្ឋិពេញទី ព្រោះ
គំនិតក្តៅលព្រះហឫទ័យព្រះសាស្តាចារ្យមិនត្រូវតាមទំនងដែលពិតមែន។
សុនក្ខត្តកិក្ខុ លុះអស់ជំនឹត ទៅកើតក្នុងនរកអស់កាលជាយូរអង្វែង។
មិច្ឆាទិដ្ឋិ គំនិតយល់ខុសមានទោសយ៉ាងក្រៃលែង ព្រះនិព្វាន
លោកឲ្យឈ្មោះថា ទាប ជាអំពើមិនត្រូវធ្វើឡើយ ។

គោលច្បាប់នៃព្រះពុទ្ធសាសនាទី ១ នេះ គឺឲ្យវៀរចាកជាប ដូច
ន័យដែលសំដែងមកនេះ ពាប់ជាជា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ
ជាំងឡាយ ។

បុរសស្ត្រី អ្នកវៀរចាកអំពើជាបដោយការប្រតិបត្តិតាមវិន័យឈ្មោះ
ថា ជាអ្នកដំរះខ្លួនជ្រះណា ជាអ្នកមានកាយកាចរសុទ្ធស្អាត គួរដល់
ការងារកម្ម ។ ដំណើរនេះបុរសស្ត្រី អ្នកមានបំណងល្អ គប្បីបំពេញ
កុសលធម៌ តាមគោលច្បាប់នៃព្រះពុទ្ធសាសនាទី ២ តទៅទៀត ។

២- កុសលសម្បជ្ញា ការប៉ំពេញកុសលឲ្យបរិបូណ៌
(គោលទី ២ នេះ សង្គ្រោះបូលកង់សុត្តន្តបិតក)

ពាក្យថា កុសល នេះ បានដល់សេចក្តីល្អជាំងអស់ ដែលលោក
សំដៅយក គឺសុចរិតធំងបុញ្ញកម្មផ្សេង។ ដែលមាចនាំឲ្យបាននូសេចក្តីសុខ
កាយសប្បាយចិត្ត ជាហេតុញ៉ាំងសត្វលោកឲ្យទៅកើតកង់សុគតិភព ។

ពាក្យថា កុសល នេះប្រែថា អំពើឈ្លាសវៃ អំពើឥតទោស
អំពើជាគ្រឿងលះកិលេស ។

ពាក្យថា ការប៉ំពេញកុសលឲ្យបរិបូណ៌ បានដល់ការ
ដែលតប្បាយមធ្វើកុសលឲ្យកើតឡើងកង់កាយកាចចិត្ត គឺប៉ំពេញកុសល-
កម្មបថ ១០ ប្រការ ។

កុសលកម្មបថ គឺអំពើល្អជាផ្លូវសម្រាប់អ្នកប្រព្រឹត្តបានទៅកាន់សុគតិភព ឬអំពើល្អដូចជាប្រឡាយសម្រាប់បង្ហូរសេចក្តីសុខមកឲ្យអ្នកប្រព្រឹត្ត ។ កុសលកម្មបថ ១០ ប្រការនេះ គឺ កាយកម្ម អំពើល្អសម្រេចដោយកាយមាន ៣ យ៉ាង ១ វចីកម្ម អំពើល្អសម្រេចដោយសំដីមាន ៤ យ៉ាង ១ មនោកម្ម អំពើល្អសម្រេចដោយផ្លូវចិត្តមាន ៣ យ៉ាង ១ ។

កាយកម្ម

១- ចាណាតិចាតា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង់ គឺសម្លាប់សត្វ ។

២- អទិន្នាទានា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬវាចា គឺលួចដណ្តើមទ្រព្យរបស់គេ ។

៣- កាមេសុមិច្ឆាចារា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

វចីកម្ម

៤- មុសាវាទា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

៥- ចិសុណាយ ភាចាយ វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់បំបាក់បំបែកអ្នកដទៃ ។

៦- ផរុសាយ ភាចាយ វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកដេរប្រទេចអ្នកដទៃជាដើម ។

៧- សម្ផប្បលាបា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យពេយពាយឥតប្រយោជន៍ ។

មនោកម្ម

៨- អនភិជ្ឈា មិនមានចិត្តសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃដោយគិតប្រុងនឹងឱ្យបានមកជាទ្រព្យរបស់ខ្លួន ។

៩- អព្យាបាទោ មិនមានចិត្តបង្កំគំនុំគុំគួនគិតបំផ្លាញឱ្យអ្នកដទៃដល់នូវសេចក្តីវិនាស ។

១០- សម្មាទិដ្ឋិ គំនិតយល់ឃើញត្រូវពិត ហើយប្រកាន់ខ្ជាប់ថាជាត្រូវមែន ។

កុសលកម្មបថទាំង ១០ ប្រការនេះ បើបុរសស្ត្រីណាបានប្រព្រឹត្តកាន់តាមឱ្យត្រឹមត្រូវដល់កម្រិតហើយ បុរសស្ត្រីនោះនឹងត្រូវបានអានិសង្សច្រើនជាអនេក ដូចមានពុទ្ធដីកាដែលព្រះបរមសាស្តាចារ្យ ទ្រង់ត្រាស់សំដែងចំពោះព្រាហ្មណ៍នឹងគហបតីទាំងឡាយ នៅក្នុងសាល-

ត្រាមថា អាកង្ខេយ្យ ចេ ភិក្ខវេ តថាគតោ ធម្មចារី សម្ម-
ចារី ម្នាលព្រាហ្មណ៍ខ្ញុំនឹងតបតទាំងឡាយ បើអ្នកប្រព្រឹត្តធម៌ អ្នក
ប្រព្រឹត្តស្មើ គប្រព្រឹត្តតាមកុសលកម្មបថ ១០ ប្រការមានប្រាថ្នាថា លុះខ្ញុំ
ធ្លើមរណកាល ខ្ញុំបាយខ្ញុំទៅកាន់បរលោក ខ្ញុំសូមឲ្យបានកើតជាខត្តិយ
មហាសាល ជាព្រាហ្មណ៍មហាសាល ជាហបតីមហាសាល ជាទេវតា-
ក្នុងកាមាវចរសួគ៌ ជាព្រហ្មមានរូប ក្នុងរូបាវចរភូមិ ជាព្រហ្មគ្មានរូប ។

ក្នុងអរូបាវចរភូមិ ឬប្រាថ្នាចង់ឲ្យបានសម្រេចអរហត្តផល ក៏គង់
សម្រេចដូចសេចក្តីប្រាថ្នារបស់ខ្លួនមិនខាន ។

សួរថា " កុសលកម្មបថ ១០ ប្រការជាកាមាវចរកុសលរមែងឲ្យ
ផលត្រឹមតែទៅកើតក្នុងកាមាវចរភូមិប៉ុណ្ណោះ ចុះហេតុអ្វី បានជាព្រះសាស្តា
ទ្រង់សំដែងថា ឲ្យផលទៅកើតក្នុងកាមាវចរភូមិ នឹងអរូបាវចរភូមិ
ដែរ ? មិនតែប៉ុណ្ណោះថា នឹងបានសម្រេចអរហត្តផលក៏មាន ? " ។

ឆ្លើយថា " ពិតដូច្នោះមែនហើយ កុសលកម្មបថនេះ បើបុគ្គល
បានប្រព្រឹត្តតាមល្អហើយ អាចនាំឲ្យទៅកើតក្នុងកាមាវចរភូមិមែន តែជា
បច្ច័យអាចដុំរុលចិត្តឲ្យទៅកាន់ទេវលោកជាន់លើ ដែលហៅថារូបាវច-
ភូមិ នឹងអរូបាវចរភូមិ ដែលសម្រេចដោយការចំរើនឈានខ្លះ ។

កុសលប្រព្រឹត្តទៅក្នុងកាមាវចរភូមិ

កុសលពួកណាដែលជាវិស័យរបស់អ្នកនៅត្រកអរដោយកាមគុណ

ទីដ៏ឲ្យផលដល់អ្នកនោះឲ្យកើតជាមនុស្សប្រសើរសិន ឬជាទេវតា អាស្រ័យតាមគុណកុដ្ឋកាមាវចរសួគ៌ កុសលនោះហៅថាកាមាវចរភូមិ ។ កាមាវចរភូមិ គឺ:

មនុស្សប្រសើរ

ទេវតាក្នុងចាតុម្មហារាជិកា

- តាវត្តឹង្ស
- យាមា
- តុសិត
- និម្មានរតី
- បរនិម្មិតវសវត្តី

កុសលប្រព្រឹត្តទៅក្នុងរូបាវចរភូមិ

កុសលពួកណាដែលជាវិស័យត្រេកអរដោយរូបជ្ឈាន ទីដ៏ឲ្យផលដល់អ្នកនោះឲ្យកើតជាព្រហ្មមានរូប កុសលនោះហៅថា រូបាវចរភូមិ ។ រូបាវចរភូមិ គឺ:

ព្រហ្មបារិសជ្ជា
ព្រហ្មបរោហិតា } ជាន់ ៣ នេះជាបឋមជ្ឈានភូមិ
មហាព្រហ្មា

បរិត្តាភា
អប្បមាណាភា } ចាំង ៣ នេះជាទុតិយជ្ឈានភូមិ
អាភស្សរា

បរិត្តសុភា
អប្បមាណសុភា } ចាំង ៣ នេះជាតតិយជ្ឈានភូមិ ។
សុភកិណ្ហកា

វេហប្ផលា
អសញ្ញី } ចាំង ៣ នេះជាចតុត្ថជ្ឈានភូមិ
បញ្ចសុទ្ធាវាស

កុសលប្រព្រឹត្តទៅក្នុងអរូបាវចរភូមិ

កុសលពួកណា ដែលជាវិស័យរបស់អ្នកត្រេកអរដោយអរូបជ្ឈាន ទីឆន្ទៈផលដល់អ្នកនោះ ឬកើតជាព្រហ្មគ្មានរូប កុសលនោះហៅថា អរូបាវចរភូមិ ។ អរូបាវចរភូមិគឺ :

អាកាសានញ្ចាយតនៈ

វិញ្ញាណាញ្ចាយនៈ

អាកិញ្ចញ្ញាយតនៈ

នេវសញ្ញានាសញ្ញាយតនៈ

(នៅមានត)

ព្រះអភិធម្មបិដក

គម្ពីរព្រះយើមក:

លោក ប៊ូ - ប៉ូ ប្រែរៀបរៀង

(តមក)

កាលព្រះពុទ្ធអង្គបានគ្រាស់ដឹងនូវមហាបដ្ឋាន ក្រោមដើមមហាពោធិព្រឹក្សនោះ ទឹកព្រះហឫទ័យរីកធំទូលំទូលាយឥតចង្អៀតចង្អល់សោះ ដូចជាតិមិគ្គលមហាមច្ឆជាតិ (ត្រីធំ) ដែលចេញទៅកាន់ផ្ទៃមហាសមុទ្រ មានជម្រៅទឹក ៨ ហ្មឺន ៤ ពាន់យោជន៍ នឹងឋត់បៃរះទ្រូនទៅខាងណា ក៏បានឥតខើសពាល់ឡើយ ។ ព្រះពុទ្ធអង្គទ្រង់តិចាណោនូវព្រះមហាបដ្ឋាននេះ សមគួរដល់ព្រះបញ្ញាបារមីរបស់ព្រះអង្គតាមព្រះពុទ្ធបំណង ។ ទឹកព្រះហឫទ័យរបស់ព្រះអង្គក៏ថ្វាស្អាតរហូតដល់ព្រះឆវីវណ្ណមង្ស ។ ព្រះរស្មីមានពណ៌ ៦ ប្រការគឺ ១ ពណ៌ខៀវ ២ លឿង ៣ ក្រហម ៤ ស ៥ ហង្សធាតុ (ជម្ពូនទីដូចដើងហង្ស) ៦ ផ្កែក (ពន្លឺពេជ្រ) ផ្សាយចេញពេញពាំងសរីរកាយរហូតទៅក្នុងទិសពាំងដប់ ។ ព្រះរស្មីរបស់ព្រះអង្គផ្សាយទៅក្នុងគ្រាគ្រាស់ដឹងថ្មីៗ គង់ក្រោមដើមព្រះមហាពោធិព្រឹក្សនោះដូចម្តេចកាលព្រះអង្គគង់លើបល្ល័ង្កមគ្គលសិលាអាសន៍ ក្រោមដើមជាទិដ្ឋតព្រឹក្សពិត្យកំមានព្រះរស្មី ៦ ពណ៌ផ្សាយចេញពីព្រះឋវីរកាយដូច្នោះដែរ ។

សម្តេចព្រះបរមសាស្តាទ្រង់ត្រាស់ទេសនា ខ្ញុំវត្តម្ចាស់មហាចង្ហាន អនុន្តន័យនេះ ទ្រង់ចែកចេញខ្ញុំបច្ច័យចាំង ២៤ ប្រការ មានហេតុប្បច្ច័យ ជាដើម មានអវិគតប្បច្ច័យជាបរិយោសាន ។

ឯបច្ច័យចាំង ២៤ ប្រការនោះគឺ ១- ហេតុប្បច្ច័យ ២- អារម្ម-ណប្បច្ច័យ ៣- អធិបតិប្បច្ច័យ ៤- អនន្តរប្បច្ច័យ ៥- សមនន្តរប្បច្ច័យ ៦- សហជាតប្បច្ច័យ ៧- អញ្ញមញ្ញប្បច្ច័យ ៨- និស្សយប្បច្ច័យ ៩- ឧបនិស្សយប្បច្ច័យ ១០- បុរេជាតប្បច្ច័យ ១១- បច្ឆាជាតប្បច្ច័យ ១២- អាសេវនប្បច្ច័យ ១៣- កម្មប្បច្ច័យ ១៤- វិបាកប្បច្ច័យ ១៥- អា-ហារប្បច្ច័យ ១៦- ឥន្ទ្រិយប្បច្ច័យ ១៧- ឈានប្បច្ច័យ ១៨- មគ្គប្បច្ច័យ ១៩- សម្បយុត្តប្បច្ច័យ ២០- វិប្បយុត្តប្បច្ច័យ ២១- អត្ថិប្បច្ច័យ ២២- នត្ថិប្បច្ច័យ ២៣- វិគតប្បច្ច័យ ២៤- អវិគតប្បច្ច័យ ។

១- ហេតុប្បច្ច័យ

ក្នុងបទហេតុប្បច្ច័យនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាដោយ ហេតុជាបច្ច័យមាន ៦ ប្រការ គឺហេតុជាបច្ច័យខាងអកុសល ៣ ប្រការ ហេតុជាបច្ច័យខាងកុសល ៣ ប្រការ ។

ហេតុជាបច្ច័យខាងអកុសល៣ប្រការនោះគឺ លោភៈ ១ ទោសៈ ១ ទោហៈ ១ រួមគ្នាជា ៣ ប្រការ ។

ហេតុជាបច្ចយ័ខាងកុសល ៣ ប្រការនោះគឺ អលោភោ ១ អទោសោ ១ អមោហោ ១ រួមគ្នាជា ៣ ប្រការ ។

ឯហេតុជាបច្ចយ័ខាងអកុសលនិងកុសលចាំង ៦ ប្រការនោះ គឺដូចជាមូលខាងអកុសលនិងកុសល ដែលសម្តេចព្រះបរមគុរុឥសពលទ្រង់ត្រាស់ទេសនារួចហើយក្នុងមូលយមក: ដូចសំដែងខាងដើមហើយ ប៉ុន្តែគាត់តែកងគម្ពីរយមកនោះថា មូលនៃកុសលនិងមូលនៃអកុសល ក្នុងគម្ពីរព្រះមហាបដ្ឋាននេះថា ហេតុជាបច្ចយ័ខាងកុសលនិងហេតុជាបច្ចយ័ខាងអកុសលប៉ុណ្ណោះ ឯធម៌ដូចគ្នាឥតខុសគ្នាទេ ។ អ្នកមានប្រាជ្ញាគប្បីប្រាប់ថា លោភោ ទោសោ មោហោ នីង អលោភោ អទោសោ អមោហោ នោះ មានន័យដូចសំដែងហើយក្នុងគម្ពីរព្រះយមក: ។

២- អារម្មណប្បច្ចយ

ក្នុងអារម្មណប្បច្ចយ័នោះ សម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ទេសនាដោយអារម្មណ៍ ៦ ប្រការគឺ រូបារម្មណ៍ ១ សទ្ទារម្មណ៍ ១ គន្ធារម្មណ៍ ១ រសារម្មណ៍ ១ ផោដ្ឋព្វារម្មណ៍ ១ ធម្មារម្មណ៍ ១ ។

រូបារម្មណ៍នោះ បាននីងរូបចាំងពួងដែលជាទីយឺតគោង នីងជាទីត្រេកអរនៃចក្ខុ ។

សទ្ទារម្មណ៍នោះ បាននីងសម្លេងចាំងពួង ដែលជាទីយឺតគោងនៃសោត ។

គន្ធារម្មណ៍នោះ ឋានទំនងកុំនៃតាំងពួងដែលជាទីយឺតគោងនៃនាសិក
គឺឃាន: ។

រសារម្មណ៍នោះ ឋានទំនងរសតាំងពួងដែលជាទីយឺតគោងនៃជិវ្ហា ។

ផោដ្ឋព្វារម្មណ៍នោះ ឋានទំនងគ្រឿងសម្ផស្សតាំងពួងដែលជាទីយឺត
គោងនៃកាយ ។

ធម្មារម្មណ៍នោះ ឋានទំនងធម៌តាំងពួងដែលជាទីយឺតគោងនៃចិត្ត ។

មានពាក្យបុច្ឆាថា កេ អារម្មណាបរិច្ចយោ តំវិយោដែលហៅថា
"អារម្មណាបរិច្ចយ" នោះតើ អាស្រ័យហេតុផលដូចម្តេច ?

មានពាក្យវិសជ្ជនាថា រូបជាឥដ្ឋារម្មណ៍ គឺរូបល្អដ៏ជាទីស្រឡាញ់
ពេញចិត្តមានមកប្រាកដដល់ចក្ខុវិញ្ញាណក្នុងកាលណា ក៏ជាបច្ច័យនឹង
ឲ្យកើតសេចក្តីសោមនស្សត្រេកអរក្នុងកាលនោះ ។ រូបជាអនិដ្ឋារម្មណ៍
គឺរូបអាក្រក់មិនជាទីស្រឡាញ់ពេញចិត្ត មានមកប្រាកដដល់ចក្ខុវិញ្ញាណ
ក្នុងកាលណា ក៏ជាបច្ច័យឲ្យកើតសេចក្តីទោមនស្សអាក់អន់ចិត្តក្នុងកាល
នោះ ។ អ្នកប្រាជ្ញគប្បីចូលចិត្តថា រូបជាឥដ្ឋារម្មណ៍មកប៉ះនឹងចក្ខុទ្វារ
ក៏ជាបច្ច័យឲ្យកើតសុខសោមនស្ស ។ រូបជាអនិដ្ឋារម្មណ៍មកប៉ះនឹងចក្ខុ-
ទ្វារ ក៏ជាបច្ច័យឲ្យកើតទុក្ខទោមនស្ស សូមនាំរឿងមួយដែលមានក្នុងព្រះ
សូត្រមកបញ្ជាក់ឲ្យឃើញជាឧទាហរណ៍ ដោយសង្ខេបថា ៖

រឿងស្រីអា

ឯកោ កុលបុត្តោ មានកុលបុត្រម្នាក់នៅលីវពុំទាន់មានប្រពន្ធ ទំធ្វើការបម្រើតាមាក្នុងផ្ទះផងក្រៅផ្ទះផង តែម្នាក់ឯងជាទិច្ចកាលរាល់ថ្ងៃ ។ តាមាឃើញកូនខ្លួនយូរហាត់លំបាកពេកដូច្នោះ ក៏ប្រាប់កូនថាឱ្យរកដណ្តឹងប្រពន្ធឱ្យគ្រាន់បានជួយធ្វើការ ។ ប៉ុន្តែកូននោះបដិសេធមិនព្រមតាមប្រាមម្តាយកុំឱ្យដណ្តឹងប្រពន្ធ ។ ម្តាយមិនព្រមស្តាប់ពាក្យកូនហាមប្រាម ក៏នៅរកត្រកូលមួយប្រុងនឹងដណ្តឹងកូនគ្រប់គ្រង ។ កូននោះដឹងរឿងហើយប្រាប់ម្តាយឱ្យទៅដណ្តឹងកូនគ្រប់គ្រង ក្នុងត្រកូលដែលខ្លួនស្រឡាញ់ពេញចិត្ត ។ ម្តាយក៏ទៅដណ្តឹងនាងនោះតាមពាក្យកូនប្រាប់ហើយរៀបមង្គលការយកនាងនោះមកនៅផ្ទះជាមួយ ។ រីឯនាងជានាងកុមារីការនោះជាស្រីគាវគកូន ។ ម្តាយប្រាប់កូនប្រុសឱ្យទៅរកស្រីម្នាក់ទៀតមកធ្វើជាប្រពន្ធបុង្គដើម្បីឱ្យមានកូនគ្រាន់នឹងតបាជ ។ លុះកុលបុត្រនោះបានប្រពន្ធបុង្គមកនៅជាមួយហើយ នាងប្រពន្ធដើមខឹងស្អប់មិនចង់ឱ្យឃើញមុខនាងប្រពន្ធបុង្គសោះ កំចង់ចិត្តពាបាបប្រុងនឹងបំផ្លាញឱ្យវិនាស ។ ដល់គ្រានាងប្រពន្ធបុង្គមានផ្ទៃពោះ នាងប្រពន្ធដើមធ្វើថ្នាំលួចដាក់ក្នុងចាយឱ្យនាងប្រពន្ធបុង្គនោះបរិភោគ ក៏រលូតកូនពីពោះបាត់ទៅ។ ដល់នាងប្រពន្ធបុង្គមានផ្ទៃក្នុងលើកទីពីរ នាងប្រពន្ធដើមលួចដាក់ថ្នាំឱ្យរលូតទៅទៀត ។ ក្នុងគ្រាទីបី នាងប្រពន្ធបុង្គដឹងខ្លួនចំបំផុតបាំងការពារមិនឱ្យ

នាងប្រពន្ធដើមដឹងថាខ្លួនខុសមុន ។ ប៉ុន្តែលុះខុសមុនជាតគ្រប់ខែ នាងប្រ-
ពន្ធដើមដឹងក៏ដាក់ថ្នាំរំលូតកូនខ្មៅ ដោយបន្ទំដាក់ជាមួយថ្នាយ ។
ឯកូនកន្លែងផ្ទៃធំពេកដោយចាស់ខែភ្លាក់មិនរួច កំស្លាប់នៅស្រុះខ្លឹងក្នុង
ម្តាយ ។ នោះក៏ស្លាប់ទៅដែរ ។

ប៉ុដ្ឋដឹងរឿងនេះ ក្រោធខឹងខ្លាំងណាស់អត់ទ្រាំពុំបាន ក៏ជេរដំណាត់
ជាក់ប្រពន្ធដើមជាស្រីគានោះតាល់តែស្លាប់ទៅខ្មៅ ទៅសោយទុក្ខវេ-
ទនាកន្លងរកអស់កាលជាយូរអង្វែង ។ អ្នកមានប្រាជ្ញាតប៉ាំសន្និដ្ឋានថា
រូបដែលជាអនិដ្ឋារម្មណ៍ គឺជាទីស្អប់ខ្ពើមជាបច្ច័យឲ្យកើតទុក្ខវេទនា ដូច
ស្រីគានោះឯង ។

រឿងសត្វមៀម

រូបដែលជាឥដ្ឋារម្មណ៍ គឺជាទីស្រឡាញ់ពេញចិត្ត កាលបើមកប៉ះ
នឹងចក្ខុហើយ ក៏ជាបច្ច័យឲ្យកើតសុខសោមនស្សសប្បាយរីករាយ
កន្លងបច្ចុប្បន្នជាទីសរសើរនៃខេត្តា លុះរំលាងបញ្ចក្ខន្ធហើយជាន់ទៅកើត
ក្នុងស្ថានសួគ៌ ដល់ជាតិជាអរិយសាវ័កជាន់សម្រេចព្រះនិព្វាន ។ សូមនាំ
និទានសត្វមៀមមកបញ្ជាក់ជានិទស្សនៈយ៉ាង ដំណាលសេចក្តីថា ៖

ឧទិយកោ វិហរន្តេ កាលព្រះមានព្រះភាគស្តេចគង់នៅក្នុង
គុហាទេវិយកន្តារ ឯកោ ឧលុកោ ត្រានោះ មានសត្វមៀមមួយ
នៅក្នុងដើមព្រីក្បែរជិតព្រះពុទ្ធអង្គ ។ ខាងកំពុងស្តេចទៅទ្រង់តិក្ខាចារក្នុង

វេលាព្រឹក ។ សត្វមៀមនោះហើរតាមប្រកិតទៅរហូតដល់ភ្នំស្រុក ។ លុះព្រះភុទ្ធគង្គព្រមទាំងភិក្ខុសង្ឃត្រឡប់មកអំពីភិក្ខាចរវិញ ស្តេចគង់ទៅស្ងៀមក្នុងភ្នំគុហា សត្វមៀមនោះក៏ទៅចាំមើលរហូតដល់ស្តេចចូលទៅខាងក្នុងគុហា ។ លុះព្រះភុទ្ធគង្គ ព្រមទាំងភិក្ខុសង្ឃចូលទៅខាងក្នុងគុហាហើយ ទើបសត្វមៀមនោះត្រឡប់ទៅឯសំបុកវិញ ។ សត្វមៀមតែងតាមគន់មើលព្រះបរមសាស្តាកល់ថ្ងៃមិនចេះឆ្អែតឆ្អន់សោះ ។

ថ្ងៃមួយ សម្តេចព្រះបរមសាស្តាទាំងភិក្ខុសង្ឃស្តេចទៅភិក្ខាចារ ។ បសន្នចិត្តោ សត្វមៀមបានឃើញក៏មានចិត្តជ្រះថ្លាហើរតាមស្តេចទៅដល់ភ្នំស្រុកកំឈប់សំកាំងនៅឯនោះ ទើបហើរចុះពីអាកាសកាងស្លាបឡើងឆើបក្បាលថ្វាយអភិវាទសម្តេចព្រះភុទ្ធគង្គ ។ ទ្រង់ត្រាស់ទៅនឹងព្រះអានន្ទត្ថេរថា បសន្នោ ន្វាយំ ម្នាលអានន្ទ ! អ្នកចូរមើលសត្វមៀមនោះ ហេតុតែសម្ងឹងមើលពួកភិក្ខុសង្ឃដោយចិត្តសោមនស្សត្រេកអរ ក្នុងអនាគតកាលសត្វមៀមនេះនឹងបានត្រាស់ជាព្រះបច្ចេកពុទ្ធ ទ្រង់នាមថា សោមនស្ស ។ តស្មឹ អដ្ឋវត្តា ចំណែកខ្លះដែលអាស្រ័យនៅក្នុងព្រឹក្សពិមានស្បែរភ្នំគុហានោះ បានឮព្រះពុទ្ធដីកាត្រាស់ដូច្នោះ ក៏តោលនាថា សរសើរសត្វមៀមដោយអនេកបរិយាយ ។

ហេតុនោះ អ្នកប្រាជ្ញទាំងឡាយ គប្បីធ្វើមនសិការកំណត់ខុកក្នុងចិត្តថា រូបជាតដ្ឋារម្មណ៍កើតមានប្រាកដដល់ចក្ខុទ្វារ ជាបច្ច័យឱ្យកើត

សោមនស្ស ក្នុងបច្ចុប្បន្នបានខ្ជះខ្ជែសេចក្តីសរសើរតំណាក់នៃខេត្តា លុះ
រលត់បញ្ចក្ខន្ធហើយ មានសុគតិជាទីប្រព្រឹត្តទៅក្នុងខាងមុខ ដូចនិទាន
សត្វមៀមនេះ ។

៣- អធិបតិប្បច្ច័យ

អធិបតិប្បច្ចយោតិ ឯត្ថ ចត្តារោ អធិបតិ ឆន្ទា-
ធិបតិ វីរិយាធិបតិ ចិត្តាធិបតិ វិមំសាធិបតិ អធិបតិ
ភូតត្តតិ ឆន្ទោ ច វីរិយំ ច ចិត្តំ វិមំសា ចត្តារោ ធម្មា
បច្ចយា ភុសលេសុ ធម្មេសុតិ តស្មា ឥមេ អធិប-
តិនោ បច្ចយាតិ វេទិតព្វាតិ ។

លំដាប់នេះ សូមវិសជ្ជនាក្នុងអធិបតិប្បច្ច័យតទៅ ដំណើរសេចក្តី
ថា កាលសម្តេចព្រះមានព្រះភាគត្រាស់ទេសនាអារម្មណប្បច្ច័យចប់ហើយ
ទើបទ្រង់ត្រាស់ទេសនាអធិបតិប្បច្ច័យតទៅទៀត មានព្រះពុទ្ធដីកាត្រាស់
ថា ចត្តារោ អធិបតិ អធិបតី មាន ៤ ប្រការ គឺ៖ ឆន្ទាធិបតិ ១
វីរិយាធិបតិ ១ ចិត្តាធិបតិ ១ វិមំសាធិបតិ ១ ។

ឆន្ទៈ បានន័យសេចក្តីប្រាថ្នា, សេចក្តីពេញចិត្ត ។

វីរិយៈ បានន័យសេចក្តីព្យាយាម ។

(នៅមានត)

សម្តេចព្រះធម្មលិខិត ល្វី . ជម ប្រែរៀបរៀង

(តមក)

ព្រះថេរៈបានពោលតបថា ម្នាលអាវុសោចាំងឡាយ កាលពីមុន បើខ្ញុំបានសប្បិចំនួនមួយវែកនាន់ហើយ ពេលនេះក៏អម្លាប់ទៅមួយរំពេចពុំយឺតយូរឡើយ ។ កិក្ខុចាំងឡាយទូលតបថេរដើការញាថា បពិត្រលោកដ៏ចំរើន យើងខ្ញុំចាំងឡាយនឹងបានខ្លួសប្បិទឹកដោះពរមកពីណានោះ លើទឹកសមុទ្រនេះ សូមលោកម្ចាស់អត់ទ្រាំបន្តិចទៅសិនចុះ ។

ព្រះថេរៈបានពោលតបថា ម្នាលអ្នកមានអាយុចាំងឡាយ ឯសប្បិនេះគឺយើងមិនមែនបានដោយក្រខេ ត្រូវអ្នកចាំងឡាយកាន់យកបាត្ររបស់ខ្ញុំទៅដងទឹកសមុទ្រនាំយកមកឲ្យដល់ខ្ញុំឥឡូវនេះចុះ ។

ទើបកិក្ខុចាំងឡាយបានធ្វើតាមបង្គាប់ព្រះថេរៈនោះឯង ។ ឯទឹកសមុទ្រនោះសោត កំតួរជាទឹកស្ងោរឲ្យពន់ពេក គ្រាន់តែពួកកិក្ខុដងជាក់ក្នុងបាត្រលើកឡើងហើយ ក៏ប្រែក្លាយត្រឡប់កើតជាសប្បិពាវប្រាកដមួយរំពេចនោះឯង ។

កាលនោះ កិក្ខុចាំងឡាយបានឃើញហើយក៏មានចិត្តស្ញើចរីករែលែងទើបបង្អោនទាំចូលទៅប្រគេនចំពោះព្រះថេរៈនោះ ។

កាលបើព្រះថេរៈបានឆាន់សង្ឃរួចហើយ អាពាធក៏រម្ងាប់ទៅមួយរំពេច ប៉ាដូចជាអណ្តាតប្រទីបដែលត្រូវខ្យល់បក់មកខ្លាំងក៏រលត់សូន្យទៅដូច្នោះឯង ។ ទើបតគ្គំតាំងឡាយសួរចំពោះព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចំរើន សេចក្តីអស្ចារ្យនេះ តើមានប្រការដូចម្តេច ? តាំងតែពីមុនរៀងមកដល់កាលឥឡូវនេះ យើងខ្ញុំពុំដែលបានឃើញដល់ម្តងសោះឡើយ ។ ព្រះថេរៈបានឆ្លើយតបថា បើដូច្នោះ អ្នកតាំងឡាយចាំមើលនូវពិធីអស្ចារ្យរបស់បុគ្គលអ្នកមានបុណ្យដែលបានធ្វើមកពីមុន ឲ្យជាក់ច្បាស់ឥឡូវនេះចុះ ។ លុះព្រះថេរៈពោលយ៉ាងនេះហើយ ក៏ក្រឡេកមើលទឹកសមុទ្រហើយអធិដ្ឋានថា "ឥទំ សប្បិភោគុ" ទឹកសមុទ្រទាំងអស់នេះសូមកើតជាសប្បិចុះ ។ ស្រាប់តែសមុទ្រប្រមាណមួយជួរភ្នែកនៃព្រះថេរៈនោះ ក៏ប្រែក្លាយទៅជាសប្បិដ៏ផ្អែមឆ្ងាញ់ជាមួយរំពេចនោះឯង ។

គ្រានោះតគ្គំតាំងឡាយ សឹងមានចិត្តបង្កើតជាអស្ចារ្យក្រៃលែងហើយសួរតទៅទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន បុណ្យរបស់លោកម្ចាស់ដទៃទៀតប្រាកដដូចនេះមានដែរឬ ។

ព្រះថេរៈពោលថា ម្នាលអ្នកដ៏មានអាយុតាំងឡាយ បើដូច្នោះ ត្រូវអ្នកតាំងឡាយចាំមើលបុណ្យរបស់យើងឥឡូវនេះចុះ លុះពោលដូចនេះ

ហើយក៏ក្រឡេកមើលខ្លួនក្តុំដោយដុំវិញហើយអធិដ្ឋានថា "ឥមេ ភុ-
ឆ្ឍបិណ្ឌា ហោន្តុ" ភ្នំទាំងនេះសូមកើតជាដុំស្ករអំពៅចុះ ។

ឯភ្នំទាំងនោះក៏កើតជាដុំស្ករអំពៅទាំងអស់ក្នុងកាលនោះឯង ។

ឯកិក្ខទាំងឡាយ សឹងមានចិត្តបង្កើតជាអស្ចារ្យហើយ សួរព្រះថេរៈ
តទៅទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន បុណ្យរបស់លោកម្ចាស់ដទៃ
ទៀតប្រាកដដូច្នេះមានដែរឬ ។ លំដាប់នោះព្រះថេរៈតបថា ម្នាលអ្នក
ដ៏មានអាយុទាំងឡាយ បើដូចនោះ ត្រូវអ្នកទាំងឡាយចាំមើលបុណ្យរបស់
យើងចុះ លុះព្រះថេរៈលោកពោលដូចនោះហើយ ក៏ក្រឡេកមើលទឹក
សមុទ្រម្ខាងទៀត ហើយអធិដ្ឋាន "កត្តកាឆជាតិ សព្យញ្ជនជាតិ
ឧបដ្ឋហន្តុ" ការជនសំរាប់ដាក់ចាយទាំងឡាយ ព្រមទាំងម្ហូបចំណី
ទាំងពួងចូរឱ្យកើតមានប្រាកដដល់ក្នុងកាលឥឡូវនេះឯង ។

ទឹកសមុទ្រមានប្រមាណមួយដួរត្នែកដោយដុំវិញ ក៏ក្លាយជាការជន
តេញដោយចាយ ព្រមទាំងម្ហូបចំណីទាំងពួងមានប្រការផ្សេង ។ កើត
ឡើងប្រាកដក្នុងកាលនោះហោង ។

លំដាប់តពីនោះ ព្រះថេរៈក្រឡេកមើលខ្លួនជុំវិញហើយពោល ឯភ្នំហិម-
ពាន្តកិសឹងប្រែត្រឡប់កើតជាមាសសុទ្ធប្រាកដក្នុងកាលនោះ គួរជាទី
អស្ចារ្យពន់ពេក ។ មួយវិញទៀត ព្រះថេរៈក្រឡេកមើលខ្លួនជង្រៃដែល
មានទៅក្នុងទីចំពោះមុខ ស្រាប់តែជង្រៃទាំងនោះ ប្រែត្រឡប់ទៅជា

ជនវៃត្រពេញដេរដាស ដោយសំពត់ចិញ្ចឹមស្អាតមុខទ្លុសមានពណ៌ផ្សេង ១
កើតឡើងប្រាកដក្នុងកាលនោះឯង ។

ឯកិក្ខុទាំងឡាយ លុះបានឃើញនូវបាដិហារិយជាអស្ចារ្យកើតឡើង
ប្រាកដដោយបុញ្ញវិទ្ធិដូចនោះហើយ ក៏មានសេចក្តីស្ញប់ស្ញែងកង់ចិត្តតែ
ពាល់គ្នា ទើបសួរទៀតថា: បពិត្រលោកម្ចាស់ដ៏ចំរើន បាដិហារ្យទាំងនេះ
កើតឡើងប្រាកដដោយបុញ្ញកម្ម តើបុញ្ញកម្មនោះលោកម្ចាស់បានធ្វើអំ-
ពើអ្វីខ្លះ ?

ព្រះថេរៈបានសម្តែងប្រាប់នូវកុសលកម្ម ដែលខ្លួនបានធ្វើមកហើយ
ក្នុងសាសនាព្រះខេមពលទ្រង់ព្រះនាមកស្សបៈ ដោយសេចក្តីពិស្តារដូច
បានសម្តែងមកខាងក្រោយ ហើយលោកសម្តែងនូវព្រះគាថាទាំងឡាយ
ដោយសេចក្តីសោមនស្សដូចនេះថា:

ឥមស្មឹ កប្បេ កកេប្ប កស្សបោ ជាម ជាយតេ
សត្ថា លោកហិតត្ថាយ លោកេ ឧប្បជ្ជតិ ជាយតេ

អធិប្បាយថា: ក្នុងកប្បនេះ មានអគ្គព្រះសម្មាសម្ពុទ្ធជាទាយក
ទ្រង់ព្រះនាមកស្សបៈ ទ្រង់បានត្រាស់ដឹងជាអគ្គព្រះពុទ្ធក្នុងលោក ដើម្បី
ប្រយោជន៍ដល់សត្វលោកទាំងអស់ ព្រះអង្គតែងសម្តែងធម៌ទេសនាដឹក
នាំសត្វឲ្យតួងផុតចាកសំសារវដ្តឲ្យបានសម្រេចដល់ព្រះនិព្វាន ។

តជ្ជាហំ ខុដ្ដយន្តម្ហិ ឯយ្យេ ភុទ្ធ្យការកោ

តេន កម្មេន ជីវាមិ ចោសេមិ បុត្តទារកេ
កិលន្តិន្ទ្រិយមនក្លេ កិក្កុំ ភេតាតុរំ តថា
កិក្ខាចារិកវត្តេន សម្បត្តាយ ឧទាកតំ ។

កាលនោះ ខ្ញុំបានកើតជាអ្នកកំសត់ម្នាក់ បានប្រកបការស៊ីឈ្នួលក្នុងភេងយន្តគាបអំពៅ តែងចិញ្ចឹមគ្រួសារ រស់នៅដោយអំពើស៊ីឈ្នួលនោះឯង វេលាមួងនោះ ខ្ញុំបានឃើញកិក្ខុមួយអង្គមានឥន្ទ្រីយ៍លំបាកថមថយខ្ចាំងដោយភេតបៀតបៀន បានចូលទៅជិតភូមិអ្នកស្រុកតាមគន្លងកិក្ខាចារវត្ត ដើម្បីចំណាបត្រូវបង្ហាយភៅផ្សំធ្វើជាកេសជ្ជភក្សាភេតនោះឯង ។

ឧឡ្ហកមត្តំ សម្បិច អទំ តស្ស កិក្ខុនោ
សន្ធមាន្តោ ទានផលំ ទយាយុទត្តមានសោ ។

ខ្ញុំបានជ្រើសក់ច្បាស់នូវផលនៃទាន ពាំងមានជួងហូរទ័យទោរទន់ដោយសេចក្តីអាណិត បានយកសម្បីប្រមាណមួយវែកប្រគេនផល់កិក្ខុដែលមានផម្ងឹនោះ ។

តេន កម្មេន សង្ខារេ សំសរន្តោ ភវាភវេ
យត្ថិច្ឆាមិ យំ យត្ថុត្ត ឧប្បជ្ជតិ អនប្បកំ

ដោយផលនៃសង្ឃបុញ្ញកម្មនោះឯង ខ្ញុំបានអន្ទោលទៅកើតក្នុងភពតូច

ភតធំនានា បើខ្ញុំប្រាថ្នាខ្លួរបេះណា ។ ត្រង់នោះមានប្រមាណច្រើន
កើតឡើងក្រោកជក្នុងកាលនោះឯង ។

ឥច្ឆាមហំ សមុទ្ទស្មឹ ផលម្បិ ឃដមត្តោ
តំ សព្វម្បិ ឃដំ ហោតិ ឃដទានស្សិទំ ផលំ ។

បើខ្ញុំប្រាថ្នាចង់ឲ្យទឹកក្នុងសមុទ្រ ត្រឡប់កើតជាភាជន៍ពេញដោយ
សប្បៃដើម្បីខ្លួន ទឹកចាំងនោះក៏អាចត្រឡប់កើតទៅដោយភាជន៍ពេញសប្បៃ
ក្រោកជជល់ខ្ញុំបាន នេះជាផលដែលខ្ញុំបានឲ្យទានសប្បៃដោយពិត ។

សុណាថ មយ្ហំ អញម្បិ បុញ្ញកម្មំ មនោរមំ
តថា និស្សាហំ កិត្តិំ កោកេន បរិបិច្ឆិតំ ។
តុច្ឆបិណ្ឌំ កហោត្វា កហោត្វាន បត្តេ តស្ស
សមោកិរឹ តេន សោ សុខីតោ អាសិ ភេកព្យ-
បកតំ តថា ។

សូមអ្នកចាំងឮដោយស្តាប់ខ្លួរបុញ្ញកម្ម ដែលជាទីមនោរម្យរបេះខ្ញុំដទៃ
ទៀត ដូចមានតទៅនេះ ត្រាមួងនោះ ខ្ញុំបានឃើញកិត្តិមួយអង្គមានភេត
បៀតបៀន ត្រេចទៅស្វែងរកភេសជ្ជដើម្បីព្យាបាលភេត ខ្ញុំបានយកស្តារ
អម្ពៅទៅជាក់ចុះក្នុងបាត្រនៃកិត្តិនោះ ដោយអំណាចស្តារអម្ពៅជាភេសជ្ជ
ដែលខ្ញុំបានប្រគេននោះ ទើបកិត្តិអង្គនោះបានខ្លួរសេចក្តីសុខសប្បាយ ភេត
កង់កាយក៏ដល់ខ្លួរសេចក្តីរម្ងាប់សះស្បើយទៅកង់ខណៈនោះឯង ។

នេន មេ កុឝ្ឆលានេន សំសរំ នេវមាឝុសេ
យត្តត្ថោស្មិ ឝុទ្ធោឝ្ឆាមាំ តត្ថតំ សុលភំ មម
សេលាបំ វ័ប្បុលោ មយ្ហំ ហោន្តំ ចត្តាឝុវត្តកោ
មហគ្ឃាបំ ភុឝ្ឆបិណ្ឌោ ភុឝ្ឆលានេ ឥទំ ផលំ

ដោយផលទានដែលខ្ញុំបានឲ្យស្លាអម្លៅនោះ ខ្ញុំបានអន្លោលទៅកើតក្នុងស្ថានសួគ៌ទីឆ៌ស្ថានមនុស្ស បើខ្ញុំត្រូវការដោយស្លាអម្លៅក្នុងទីណា ខ្ញុំក៏បានស្លាអម្លៅនោះដោយងាយក្នុងទីនោះឯង ។ ម្យ៉ាងទៀត បើខ្ញុំប្រាថ្នាឲ្យដុំថ្មកើតជាស្លាអម្លៅ សូម្បីដុំថ្មយ៉ាងធំ ។ ពាំងឲ្យយ កំតង់អាចប្រព្រឹត្តទៅតាមចិត្តរបស់ខ្ញុំ អាចប្រែត្រឡប់ទៅជាដុំស្លាអម្លៅកើតប្រាកដដល់ខ្ញុំ នេះជាផលទានដែលខ្ញុំបានឲ្យស្លាអម្លៅដល់កិកូមានជម្ចឹក្នុងកាលនោះដោយពិត ។

អថាបំ មេ ភគវំ បុញ្ញំ សុណាថ សាឝុ កិត្តិនោ[1]
ជាតឝ្ឆត្តំ ឥទ្ធមាំ ទិស្វាន សុនខំ តទា
ភត្តបិណ្ឌេន សន្តប្បិ តម្ប៊ិ ឆានំ ផលាវហំ
តតោបដ្ឋាយ ជាហោសិ អន្នបាណេន ឌិនតា
សុលភន្នបាណោ សុខីតា អហោសិ ជាតិជាតិយំ
អជ្ឈាបិ យនិ ឥដ្ឋាមិ ភោឝនេន បយោឝនំ ។

១- ឥធ «សាធុវិតិ» ជាថោ យុត្តតរោ យេវ ។

នៃលោកជាសប្បុរសចាំងឲ្យឃើញ សូមអ្នកចាំងឲ្យឃើញស្តាប់នូវបុញ្ញកម្មដែលខ្ញុំបានធ្វើហើយជាដរាបតទៅ ដូចមានតទៅថា កាលនោះខ្ញុំឃើញសត្វតែមួយ មានខ្លួនដ៏ញាប់ញ័រដោយសេចក្តីស្រេកឃ្លានចៀតចៀនក្រៃពេក ខ្ញុំបានសង្រ្គោះតែនោះ ដោយបានឲ្យចាយមួយដុំដល់ភាពដែលខ្ញុំបានឲ្យហើយនោះ ជាភាពមានផលច្រើនអាចនាំមកនូវសេចក្តីសុខគ្រប់ប្រការ សេចក្តីដែលខ្វះខាតដោយចាយនឹងកំពុងដែលមានសោះឡើយ តាំងពីកាលនោះដរាបមក ខ្ញុំតែងជួបនូវសេចក្តីសុខមានចាយនឹងកំរកបានដោយងាយសត្វជាតិ ។ សូម្បីក្នុងថ្ងៃនេះ បើខ្ញុំមានប្រាថ្នានូវភោជន តង្វាយភោជននោះអាចកើតឡើងប្រាកដមួយរំពេចពុំខានឡើយ ។

ចក្ខុបថេ សមត្តា មេ ជាយន្តុក្ខលិយោ ឥហ្វ
អថាបិ បរិក្ខុសលំ អភាសិ តំ សុណាថ មេ
ឥណាយិកស្ស ចោសស្ស អនាសេកកហាបណំ
តេន មេ បុញ្ញកម្មេន អនន្តំ ភវសម្បទំ
បត្តុំ ជាតព្ភបញ្ញ លភាមិ ជាតិជាតិយំ ។

(នៅមានត)

ព្រះសាសនមុនី ឆាឝ-ស្ងួរ ពិនិត្យ

(តមក)

បពិត្រមហាពជឥស្សរ ក្នុងប្រសើរ ព្រះបាទបុលនីព្រហ្មទត្តពជមាន
អំណាចអានុភាព ប្រកបទ្វេកំឡាំងរហ័តលសកលយោធាសេនាគាហាន
នោះច្រើន ហើយគាត់ធ្វើទុក្ខកលប្រើអាចារ្យកេរដ្ឋព្រាហ្មណ៍ឲ្យនាំពជ
សារបណ្តាលមេត្រីស្រដីថា ខ្ញុំធ្វើឲ្យនាងបញ្ចាលចន្ទីមកជាព្រះអគ្គម-
ហេសីនៃព្រះអង្គ អំពើទុក្ខកលនេះ អម្ចាស់ពុំខានជ្រាប ខ្ញុំធ្វើឲ្យមា
ថ្វាយ រីស្តេចបុលនីនោះ ដូចជាជង្ឃសន្ធប រីអាចារ្យកេរដ្ឋព្រាហ្មណ៍ជាពជ
ទូតមកនោះ ដូចវៀរ រីឯនាងបញ្ចាលចន្ទីនោះមិញ ដូចនុយចិនៅផ្ទៃ
សន្ធប រីអម្ចាស់សោត ដូចមច្ច កាលណាបើលេបទ្វៃនុយសន្ធបនោះ
ហើយ ខ្ញុំងមានសេចក្តីភ័យដល់ស្លាប់ឯងពុំលែងឡើយ ។ បពិត្រមហា-
ពជអើយ កាលណាបើព្រះអង្គស្តេចលីលាទៅដល់ខនងឯនាយហើយ គេ
ខ្ញុំងចោមចាប់សម្លាប់ព្រះអង្គ រីស្តេចបុលនីនោះ ទុបមាដូចព្រានព្រៃក
ក់យទ្វៃបង្អាត់ ប្រយោជន៍នៅចោមចាប់សម្លាប់ម្រឹគ រីអស់ម្រឹគផង កាល
ណាបើចូលទៅកងបង្អាត់នោះហើយ មានភ័យស្លាប់ដល់អាត្មា មានប្រ-
ការនោះម្តេចមិញ បើស្តេចអម្ចាស់ទៅហើយ សមខ្ញុំងមានភ័យដូចម្រឹគ
ចូលកងបង្អាត់ ដូចត្រីលេបនុយសន្ធបនោះហោង ។

ស្តេចស្តាប់ពាក្យពោធិសត្វដូច្នោះហើយ ស្តេចឮល់ទ្ធិពោធិ-
សត្វនោះមហិមាក្រៃ ហើយទំអត់សង្កត់ព្រះហឫទ័យ មានព្រះបន្ទូលថា
រីកូនគហបតីនេះ វាមិនកោតអញថាជាស្តេចឡើយ វាមើលងាយអញ
ដូចខ្ញុំអាត្មាវាហោង រីព្រះបាទបុលន្ទព្រហ្មទត្តក៏ដូ ដំណាស្តេចធំប្រសើរ
ប្រើអាចារ្យតែវដ្តព្រាហ្មណ៍ឲ្យទាំពតិមានមកកាន់អញ ថានឹងឲ្យកូនស្រី
នៃស្តេចនោះមកអញ វាជំនះហើយ វាមិនស្រដីនូវពាក្យប្រកបជាមង្គល
ដល់តិចឡើយ វាធ្មឹមអញដូចត្រីលេបសន្ទូច ដូចម្រឹគចូលកន្ទបក្តាត់
ហើយថានឹងលុះនូវស្លាប់ វាពុកអញជាអ្នកកំឡៅអន្ធពាលស្រាលសេចក្តី
វាស្រដីអព្វមង្គលនូវពាក្យឲ្យបង់លាភ គឺស្រីតែនប្រសើរ វាមិនស្រដីនូវ
ពាក្យជាទត្តម ពុំដឹងនូវការជាប្រយោជន៍ ជាមង្គលដូចអ្នកប្រាជ្ញទាំង ៤
ហេតុខ្លួនជាអ្នកស្រែជួងជាតិ ជាកូនគហបតី កាលណាបើនឹងស្រដី មាន
ទឹកមាត់នោះហូរហៀរសៅរអាំពាជាយថ្លាល់ទាំងសងខាង មិនដឹង
គាប់គួរ ចេះតែក្លែវស្រែ រស់ខ្លួនតែនង្គ័លរនាស់ វាធ្វើឲ្យអន្តរាយនូវក្តីជា
ប្រយោជន៍នៃអញនេះ ។

ស្តេចតិះដៀលពោធិសត្វដូច្នោះហើយ មានព្រះបន្ទូលទៅនឹងអា-
មាត្យទាំងឡាយ សូត្រនូវបទគាថា ដូច្នេះ :

ឥមិ កលេ កហោត្តាន ឯសេ ទិដ្ឋា មម
យោ មេ រតនលាភស្ស អន្តរាយាយ កាសតិ ។

ម្នាលអ្នកចាំងឡាយអើយ ! រឿងហោសថបុត្រគហបតី ក៏ស្រដៀងឲ្យ
អន្ទាយណាគអញនឹងបានស្រីតែនប្រសើរមកអញ ចូរអ្នកចាំងឡាយចង់
ឥតហោសថនេះ ចំបាបង់ចេញចាកអំពីស្រុកអញនេះហោង ។

ពោធិសត្វដឹងសុភាពជាស្តេចឮលំដួច្នោះហើយគិតថា បើអញទៅ
នេះហើយ ម្ល៉េះសមអាមាត្យចាំងឡាយ ឥតគ្រាន់ដើងដៃអញតាមព្រះ
បន្ទូលព្រះមហាក្សត្រនោះហើយ ឃល់តុំគួរណាស់ ហើយអញឮស
តេអស់កាលដ៏លង់ទៅហោង ពោធិសត្វគិតដូច្នោះហើយ ក្រាបថ្វាយបង្គំ
លាព្រះមហាក្សត្រចុះអំពីលើប្រាសាទទៅកាន់ផ្ទះអាត្មាហោង ។ ឯចំណែក
ព្រះមហាក្សត្រសោត ទ្រង់ទំអត់សង្កត់ព្រះហឫទ័យ តាំបង្គាប់ឲ្យធ្វើពោធិ-
សត្វដោយកំហឹងនោះឡើយ ។ លំដាប់នោះ ពោធិសត្វគិតថា រឿងស្តេច
នេះជាអ្នកកំឡៅអន្ទាល មិនឃល់ខ្លាការជាប្រយោជន៍នៃអាត្មា ដ៏លុះ
ខ្លាំចំណាំកំលេសតណ្ហា មិនដឹងខ្លាអនាគតភ័យ សង្ឃឹយស្មានជានឹងបាន
ព្រះរាជបុត្រីព្រះបាទបុលនីនោះ គេះយោបាស្តេចទៅ ក៏នឹងលុះខ្លាមហា-
វិនាសធំ គួរអញនឹងធ្វើតបតាមពាក្យកំហឹងព្រះហឫទ័យស្តេចហើយ ដ្បិត
ស្តេចនេះជាអម្ចាស់មានបច្ច័យខ្លួនច្រើន គួរអញប្រើកូនសេកសោម
បណ្តើតទៅសួរសេចក្តីឲ្យបានដឹងជាក់ច្បាស់ជាមុន ហើយសឹមអញ
ទៅជាក្រោយដោយអាត្មាឯង រឿងពោធិសត្វគិតដូច្នោះហើយ ឲ្យហៅកូន
សេកនោះមកផ្តាំប្រដៅ ដ្បិតនឹងប្រើទៅឮដ៏ឆន្ទតរុត្តរបញ្ញាលនោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អហ រ័ាគចិតមិឯណា ឣ.
កាលព្រះមហាសត្វប្រើសេកសោមបណ្ឌិត ទៅដណ្តឹងសេចក្តីកំពុងអំពី
សារិកាពុំទាន់ច្រុកដ បទព្រះនាថាពុំទាន់ប្លាស់ លុះព្រះបានត្រាស់
ហើយ បន្ទូលទំនឹងកិកូផងតាំងឯ្លាយជាគាថាដូច្នេះ:

តតោ ច សោ អបក្កម្ម វេឧហាសុ ឧបន្តិកា
អថ អាមន្តយិ ទ្វតំ មាថ្ងរំ សុវបណ្ឌិតំ ។

ម្នៃកិកូផងតាំងឯ្លាយអើយ! ឮដំកាលនោះ ព្រះមហាសត្វអ្នក
ច្រាជ្ញ កាលណាបើអ្នកចុះមកអំពីគាល់ព្រះចន្ទវិទេហកជហើយ ព្រះអង្គ
លីលាយាត្រាទៅគាន់លំនៅព្រះអង្គឯង ហើយទ្រង់ត្រឿងតន្ទពិដោរ
សោយគោជនាហារត្រកាលផ្សេង។ គឺនាងអមកប្រជាប់ប្រជាថ្វាយព្រះ
អង្គស្រេចស្តេចតង់សប្បាយបន្ទិចហើយ លំដាប់នោះ ទើបព្រះអង្គបន្ទូល
មានព្រះសូរសៀងពីពេះស្មោះហៅទៅគាន់កូនសេកសោមបណ្ឌិត គឺត
ន័ាប្រើដោយអំពើព្រះច្រុកជាឈ្មោសទុយកល ហេតុព្រះអង្គអធ្យាស្រ័យ
យល់ បន្ទូលនូវបទព្រះគាថាដូច្នេះ

ឯហិ សម្ម ហារិតបក្ខ វេយ្យាវច្ចំ តវេហិ មេ
អត្ថំ បញ្ហាលកជ្ជស្ស សាលិកា សយនេ ចាលិកា ។

ថា ឯហិ សម្ម ហារិតបក្ខ ម្នៃកូនសេកសោមបណ្ឌិត គឺតដ៏
មានរបៀបស្អាបខៀវល្អសំឡាញ់អើយ! ទៅចុំកូនត្រាំមាស្លាយ មិន

អង្គុរគេហៈ? ចូរបាមកឯអាយ អញនឹងប្រើឲ្យទៅធ្វើដោយខ្លួនបំរើអញ
បន្តិច រីសេកសោមបណ្ឌិត ឮព្រះបន្ទូលព្រះទុស្សព្រះមហាសថហៅ
ហើយ ហើរគ្រលេចញ្ជាមកចំលើចង្កេះ ទើបព្រះមហាសថបន្ទូលថា ម្នៃ
សេកសោមបណ្ឌិតសំឡាញ់អើយ! អញនឹងប្រើឲ្យទៅនគរទន្តបញ្ចាលនាយ
នឹងប្រើមនុស្សទៅ រីអាចំសេចក្តីខ្លះក្រៃក្រៃ រីស័យចូរឲ្យទៅឯងនៃ
ទើបដឹងអាចំសេចក្តីសាច់គ្រោចនោះ បើបានដឹងស្រេចហើយចូរក្រឡាប់
លៃមកប្រាប់អញឆាប់កុំបីយូរឡើយ សេកសោមបណ្ឌិតគិតហើយ ទូល
ដល់ឆ្លើងតោធសត្វវិញថា ឆឹ ឆកេតិ ឆេវ បពិត្រអម្ចាស់អើយ!
ព្រះអង្គនឹងប្រើទៅឲ្យដឹងអាចំសារតើសេចក្តី អំពីនគរទន្តបញ្ចាលនោះ
ម្តេចហឹង? ព្រះមហាសថបន្ទូលប្រាប់ថា ម្នៃសេកសោមបណ្ឌិត អញ
គិតនឹងប្រើឲ្យទៅនោះ ដ្បិតព្រះបាទបុលន្ទព្រហ្មទត្តរាជ ឲ្យអាចារ្យកេ-
វដ្តព្រាហ្មណ៍ជារាជទូត បង្ខើងដំកើងព្រះរាជសារ បណ្តាលមេត្រីស្រេចថា
នឹងយកនាងបញ្ចាលចន្ទីព្រះរាជបុត្រីពិសិទ្ធគុមនឹងពិធកល្យាណីស្រីវេ-
លិក្ខណ៍ប្រសើរ ថ្វាយជាព្រះអគ្គមហេសីព្រះបាទវិទេហរាជអម្ចាស់យើង
ជាមែនពិត ឬមួយលោកធ្វើជាប្រស្នាលួងនឹងគេហៈ? បទនោះហោង អញ
នឹងប្រើឲ្យទៅ ។ សេកសោមបណ្ឌិត ស្តាប់ហើយទូលតោធសត្វថា
បពិត្រព្រះមហាសថអើយ! ចាប់អ្វីត្រួយព្រះទ័យប្រើខ្ញុំទៅហឹង! ព្រះអង្គ
មិនប្រើមនុស្សម្នាទៅដល់ឆ្លើងទបនិក្ខិតបុរសយើងនឹងនៅនោះមិញ តោធ-

សត្វស្លាប់ហើយ ប្រាប់សេកសោមបណ្ដើតវិញថា ហៃសេកសោម-
បណ្ដើតសំឡាញ់អើយ! រឿងអ្នោះពីរោះគាប់ហោង តើមោះអញឲ្យ
ដណ្ដើង១បន្ទុកទុត ហើយផ្តាំមកវិញថា សេចក្តីខេះ យើងខ្ញុំមិនដឹងបន
លោកមិនតិតនាហានក្រៅឲ្យអ្នកដទៃដឹងឡើយ មានតែព្រះបាទបុលនីព្រហ្ម-
ទត្តរាជឯង នឹងអាចារ្យកេវដ្តព្រាហ្មណ៍ ឬនឹងទៅនាក្រឡាព្រះបន្ទូលរម-
សុខសួស្តីស្ងាត់ តិតតែនឹងអាចារ្យកេវដ្តព្រាហ្មណ៍ នឹងមហាសត្រឯង
តតមុខមន្ត្រីសេនាបតីប្រជាពស្ត្រឯណាមួយដឹងបានឡើយ មានតែបក្សី
ស្រីសត្វសារិកាញី ១ តែងនឹងរក្សាក្រឡាព្រះបន្ទូលព្រះបាទបុលនីសត្វថ្លៃ
នោះ ទើបនឹងបានដឹងថា បើព្រះមហាសេដ្ឋអ្នកនឹងចង់ដឹងអាថិសារតើ
សេចក្តី សត្វព្រះហឫទ័យពិត សូមបានសេកសោមបណ្ដើតមកស្នេហ៍
ស្និទ្ធតិតនឹងបក្សីស្រីសត្វសារិកាញីនោះបានឬ? មនុស្សម្នានោះរាកម្រក
ក្រែពន់ប្រមាណហេតុនោះហោង ខ្សេកសោមបណ្ដើតអើយ! អញនឹង
ប្រើបាឯងឲ្យទៅដល់ឃល់សត្វសារិកានោះ ថាបើបាទៅដល់ឃល់សត្វ
សារិកាញីនោះហើយ កុំបាដណ្ដើនអាថិសារតើសេចក្តីកំប៉ាំង បើបាចូល
ទៅនៅនឹងស្រីសត្វសារិកាញី កុងក្រង់ធ្វើឲ្យស្ងាត់ហើយសន្សឹមដណ្ដើង
សារិកាឯង ។ សេកទូលវិញថា បពិត្រមហាសេដ្ឋអើយ! នាក្នុងរ
អង្សាស្រីយថ្លៃគាប់ហោង បពិត្រមហាសេដ្ឋអើយ! ខ្ញុំទៅដល់ឃល់សត្វ
សារិកានោះបានហោង កុំខមូន់សេចក្តីកំប៉ាំង ម្ល៉ះតើសារិកាកប្រាប់ខ្ញុំ

ទើបព្រះមហាសត្វបន្ទូលថា ម៉ៃសេកសោមបណ្ឌិត នៅលើតំនិតប្រាជ្ញ
ជាឯងស្រាប់ ចាប់អ្វីអញនឹងប្រាប់ណែនាំបានឡើយ សេកសោមបណ្ឌិត
អើយ! ស្រីសត្វសារិកាញីនោះ មានប្រាជ្ញាឈ្លាសវៃ អធ្យាស្រ័យ
យល់តាមវោហារប្រស្នាល្មមលើប្រាជ្ញជាងឯង ម៉ៃសេកសោមបណ្ឌិត
ចាត់តែនឹងដណ្តឹងស្រែចអសារនោះ កំសារិកានោះសង្ឃឹមនឹងប្រាប់បានឡើយ
សេកសោមបណ្ឌិតអើយ! បើបក្សីស្រីសត្វសារិកាញីនោះ មានប្រាជ្ញ
ឈ្លាសវៃ អធ្យាស្រ័យ ចាកៅស្ងួនស្នេហាជាសង្សារ ទើបបក្សីស្រីសត្វ
សារិកានឹងប្រាប់ចាចាទ ។

អមោតិ សោ បដិសុត្វា មាថូភេ សុវបណ្ឌិតោ
អតមាសិ មារិតបតោ សាលិកាយ ឧបន្តិកំ ។

សេកសោមបណ្ឌិត ស្តាប់ព្រះបន្ទូលពោធិសត្វហើយ អរមហិមា
ជាក់សិរីសោភនៈចំពុះបុះ ហើយលើកចុងចំអេងសង្ឃឹងកាងខ្នះស្ងប
សើចក្អែក ។ ទើបទូលពោធិសត្វថា បពិត្រមហាសត្វអើយ! ខ្ញុំអ
ណាស់ ស្មានជាអម្ចាស់ប្រើឲ្យកៅយល់គប់សេចក្តីអំពីស្រីសត្វសារិកា
ញីម្ល៉ោះទេហ៎: ឥឡូវនេះ ព្រះករុណាប្រើថា ឲ្យបានសារិកាញីជាមិត្ត
ហើយស្ងួនជាសង្សារផង្គា ម្ល៉ោះហើយខ្ញុំកៅឥឡូវនេះហោង ។ ព្រះម-
ហោសត្វឃាត់ថា អះសេកសោមបណ្ឌិតឈប់ស្នេះ ធ្វើកិច្ចឃ្លាំទឹងឯ

លាដ ឆ្អែតហើយសម្បើមជាមៅហោង ។ សត្ថាកោន សហាសប្ប
ចាកោន តេសេ មក្កេត្វា ព្រះមហាសត្ថឃាត់ហើយ ព្រះអង្គ
យកប្រែនត្ថពិដោរអច់ត្រឡប់មួយរយមួយពាន់ដង ថ្វាជ្រះប្រពៃហើយ
នៃ ទើបលាចអំពីចំពុះចុះមៅដល់ស្វាប ដរាបដល់ក្រចកជើង ហើយ
ទើបសេកសោមបណ្ដិតកាន់ខ្នងក្បាលចុះ លើកចុងចំអេងកាន់ដំកើងថ្វាយ
បង្គំ ហើយហើរឡើងប្រទក្សិណ ទើបពោធិសត្វបើកសីហបញ្ជរបវរ
បង្អួចវត័ន៍ ព្រះអង្គលែងសេកហើរមៅកណ្ដាលអាកាស សេកសោម
បណ្ដិតគិតដោយប្រាជ្ញាទុជាយឈ្មោះយល់កលមិចលាខនរ ទំនងគ្គរ
បញ្ចាលជាសត្រូវពុំប្រពៃឡើយ ហើយសេកសោមបណ្ដិតគិតយល់មៅ
ដល់អវិដ្ឋបុរីស្រីមហាខនរ ឰដ៏សិរីវាស្ត្រីនោះ ជាមិត្តមេត្រីនឹងព្រះខនរ
ទុគ្គរបញ្ចាលតាប់ប្រពៃ សេកសោមបណ្ដិតយល់ដូច្នោះហើយនៃ ទើប
ហើរផ្លោះសោះសា ដោយទូវក់ឡាំងតាប់រៃគៀបតាប់ស្មៅឡាប់ បន្ទិចមៅ
ដល់អវិដ្ឋបុរីសិរីវាស្ត្រ សេកសោមបណ្ដិតគិតកត់សំគាល់អាថិហារតើ
សេចក្ដីអំពីខនរនោះស្រេចហើយ សេកសោមបណ្ដិតហើរផ្លុកផ្លោះស្មោះ
មៅសំដៅខនរទុគ្គរបញ្ចាល ដោយទូវក់ឡាំងសោះសាស្មៅឡាប់បន្ទិចមៅ
ដល់ ហើយសេកវាំពីងទីងចូលមៅកាន់សរីកា ។ កាលនាសេកនឹង
ចូលមៅកាន់សរីកានោះ តើធ្លុះម្ដេចទីងឡាបានយល់សរីកា? កាលនោះ
សេកលបចូលមៅកន្លែងព្រះរាជមន្ទីរ ហើយហើរមៅទំនាក់ពួលតាងឃ្លាយ

ច្រាសាទមាសប្រសើរ ដើរយកមើលទៅលំនៅនៃសាវ៉ែកាពុំឃើញឡើយ ទើបសេកស្រែកនូវសំឡួសម្រែកពីកេះ ផ្ទែមល្អែមស្រទន់មុខគួរឱ្យស្រឡាញ់ ។ តើ តាវណា ថានាសេកនឹងចង់ឱ្យស្វាត់កំពាំង បទក្អូមកស្រែកនោះ ? ថាបទលំទៅសាវ៉ែកានៅកន្លែងក្រឡាបនូបមេសុខសួស្តីស្វាត់ កម្រសត្វបក្សីណាមិនចូលទៅជល់ ហេតុនោះហោង ទើបសេកស្រែកបន្ទឺនូវសំឡួឱ្យសាវ៉ែកាឮហើយនៃ ទើបនឹងឱ្យសាវ៉ែកាហើរចេញមកឯក្រៅ ទើបសេកនឹងហើរទៅកាន់សាវ៉ែកាបាន ។ កាលនោះរីសត្វបក្សីស្រីសាវ៉ែកា កាលបើបានឮសំឡួសំឡេងសេកផ្ទែមពីកេះដូច្នោះកូវ សាវ៉ែកាត្រេកអរ ព្រឺព្រួចក្នុងព្រះហឫទ័យ ហើយឆ្លាក់ឆ្មៀងផ្លៀងផ្លងរមិលមើលមកសេកពុំឃើញឡើយ ហើយនឹងនំទៅពុំស្រណុក នឹងចប់ពុំបានឡើយ ហើយសាវ៉ែកានោះ មកស្រែកនូវសំឡួសម្រែកកាសាបន្ទឺទៅកាន់សេកវិញ រីសេកសោមបណ្តិត ឮមាត់សាវ៉ែកាស្រែកបន្ទឺសំឡួទៅជាក់ហើយ សេកហើរចុះមកអំពីកំពូលច្រាសាទ យល់សាវ៉ែកានំទៅបង្ហួចមាសជាក់ ជាក់ចំពុះចុះផ្ទែកផ្លៀងឆ្មៀងឱ្យមកសាវ៉ែកា ដោយនូវកិច្ចការគ្នានឹងឱ្យសាវ៉ែកាច្រឡំថាចង់ មិនហើរទៅត្រង់សាវ៉ែកាតែម្តងឡើយ ហើរឆ្ងាត់ឆ្វៀលទៅមកនឹងលឱ្យសាវ៉ែកាហៅ រីសាវ៉ែកាយល់សេកហើរពុំចុះកាន់ខ្លួនធាប់ លំដាប់នោះ រីសាវ៉ែកានឹងចប់អាត្មាពុំបានឡើយ ហើយហៅទៅកាន់សេកថា ម៎ហ៎ សម្ន សុវណ្ណាបញ្ជរេ ឯសីធាហ៎ ម៎ៃ

សេកសោមបណ្ដើតសំឡាញ់ប្អូនអើយ ! ហៅតែងទឹងហើរ តើទឹងហៅកាន់ហានឯណាឲ្យព្រួយកេយ៉ាងំចំអេងស្ងាបអសារជា ទឹងហើរលេងតតការអញ្ជើញមកចំលើងទឹងប្អូនឯបង្ហិចមាសនេះ សេកសោមបណ្ដើតតិតថាមេអាយ ! ហៅហើយហ៎: អញហើរហៅបាន ក្បាលខោះសេកសោមបណ្ដើតហើរហៅចំខទ្ទឹមទឹងនាងសារិកានាបង្ហិចមាស ទើបសួរខួលសំណេះសំណាលត្រេកអរត្រេកអាលទឹងគ្នា សេកជណ្ដើងសារិកាឮបែតាថាដូច្នេះ :

ក្ងក្ងិ តេ សុឃរេ ខមនិយំ ក្ងក្ងិ វៃសេ អជាមយំ
ក្ងក្ងិ តេ មឆុជា លាជំ លភ្លតិ សុឃរេ ន្ទុំ ។

សុឃរេ មោ: សុវណ្ណាបញ្ជរេ ឯសីជាហ៎ ថាហៃនាងស្រីសត្វសារិកា មានលំនៅក្នុងក្រង់ប្រជាប់ទង្គំប្រពៃប្រសើរអើយ ! នាងនៅក្នុងក្រឡាបទុំបរមសុខសួស្ដីស្ងាត់ រីក្ដីសុភាពអំណត់អត់ក្រញ៉ាំងមានប្លែហ៎: ? រីបក្សីសត្វសារិកាញ៉ែឆ្លើយវិញថាដូច្នេះ :

ក្ងុសលញ្ជេវ មេ សម្ន អថោ សម្ន អជាមយំ
អថោ មេ មឆុជា លាជំ លភ្លតិ សុវបណ្ដើត ។

ហៃសេកសោមបណ្ដើតសំឡាញ់ប្អូនអើយ ! នាប្អូននៅជាខ្ញុំក្រមព្រះបាទអ្នកជាអម្ចាស់ ក្នុងក្រឡាបទុំបរមសុខសួស្ដីសត្វថ្ងៃនេះ ស្រណុកសប្បាយឥតពុំគ្នាឡើយ មានតែសុខស្រណុកសប្បាយជាប្លែហ៎: ? រីតើឃ្លាំ

ច្រឡំទឹងលាដង្កែមតីសា ព្រះអង្គច្រង់ព្រះករុណាព្រះកដភានសត្វថ្លៃ
ហោង ។

តុតោ ច សម្ម អាគម្ម តាសុ្ស ភ បហាតោ តុវំ
ច ច មេសិ តតោ បុព្វេ ឯដ្ឋោ ភ យទិ ភ សុតោតិ។

ហៃសេកសោមបណ្ឌិតមិត្តសំឡាញ់ប្អូនអើយ ! អញគិតច្រកាមួយ
សោត ប្អូនចង់ដឹងចៅ។ មកអំពីឋានប្រទេសឯណា នៅត្រែវែត្រែវម
ព្រះហិមពាន្តឆ្ងាយនាយ ឬដំជាសេកមានអម្ចាស់ច្រង់ព្រះករុណាដូចប្អូន
នេះ ថាបើចៅមានអម្ចាស់។ ចៅនោះឈ្មោះអ្វី ? ព្រះបាទអ្នកជាអម្ចាស់
ប្រើចៅមក ឬមួយចៅមកឯង ? តស្តុអ្វីត្រកាល កំចៅត្រកាល ព្រួយតែ
ចំអេងហើរមក ចៅប្រាប់ប្អូនឲ្យឆាប់ ប្អូនទឹងប្រដាប់ដោយខ្លួរចំណង់ចៅ
ចង់ បំណាច់ចៅមកបង់ស្រុកវុកព្រៃ មកដល់យល់ប្អូនអំពីប្អូនទៅជាត្រមុំ
រក្សាក្រឡាចខ្នុំ ប្អូនតុំដែលយល់ចក្ខីសេកសោមបណ្ឌិតឲ្យប្រាកដពីមុន
មកដូចចៅឥឡូវ កុំថាតែយល់ឡើយ តែឈ្មោះមិត្តក៏មិនដែលឮផង ។

សោ តស្ស វចនំ សុត្វា . . . សេកសោមបណ្ឌិត ស្តាប់
ពាក្យនាងសារិកានោះហើយ គិតពិចារណាដោយខ្លួវប្រាជ្ញាឈ្លាសឧបាយ
កលថា នាងសារិកានេះហើយ រាជណ្តឹងអញច្រើនប្រការអ្វីមាល្បាយអេះ
ចើអញប្រាប់សារិកានេះដោយពិតថា ព្រះមហាសត្វអ្នកប្រើអញមកពី
មិថិលានគរោយ អញមិនវិលវិញឡើយ សមនឹងស្តាប់ហោង រីអញនឹង

សារិកានេះ កំនត់ងមិនបានស្ដាប់ស្នេហាជាសង្ឃរៈសំណេះសំណាលសាកសួរនាថសារពើ សេចក្ដីអំពីសារិកា ហើយកំនត់ងទៅថ្វាយព្រះមហាសថអម្ចាស់អញមិនបានឡើយ បើដូច្នោះ អញនឹងរំរេកប្រស្នាមុសាវាទកូតថ្វាយថា មកអំពីអវិជ្ជប្បរស្រីព្រះមហាឧត្តរនោះវិញ រីសេកសោមបណ្ឌិតកាលណាបើគិតពិចារណាខ្លួនប្រការអម្បាលនោះហើយ ក៏ឆ្លើយទៅកាន់សារិកាវិញថា :

ម្នាលនាងសារិកាប្អូនពុំដាស់ឮញ៉ាប់បងអើយ ! រីអម្ចាស់បងនោះសោតទ្រង់ព្រះនាមហៅព្រះបាទសិរិជ ព្រះអង្គទ្រង់ព្រះករុណាឲ្យក្សត្រឡាបន្ទំបរមសុខសួស្ដីក្នុងថ្ងៃសាខ ព្រះអង្គទ្រង់ព្រះករុណាតំរេសសឹងដោះស្រាយសត្វពាំងឲ្យអំពីចំណង រីអញបងនាងសោត ព្រះអង្គបើកសីហបញ្ជរបង្ខួចមាសជានិច្ចជាកាលច្រសើរ ទើបលែងបងចេញទៅអស់ចិត្តហើយ អញបងមកដំទៅបង្ខួចមាសវិញ នាងប្អូនទៅដំទៅបង្ខួចមាសជានិច្ចជាកាលម្ដេចមិញ អញបងក៏ដូច្នោះហោង ។

កាលនោះ ឯបក្សីស្រីសត្វសារិកា ស្ដាប់តាក្យសេកសោមបណ្ឌិតស្រេចហើយ ទើងឲ្យសេកសោមបណ្ឌិតស្ដាប់ស្នេហាជាសង្ឃរៈផង្គាហើយយកទឹកឃ្មុំ ប្រឡំនឹងលាជក្រៃ ដាក់ក្នងដំរាមាស ឲ្យអកាសបរិភោគ ហើយថា ម្នាលសេកសោមបណ្ឌិតម៉ត្តសំឡាញ់ប្អូនអើយ ! ចៅមកនេះ តាំហានបម្ងាយ ក្រែងចៅឃ្លានអាហារ ចៅទំងការញ៉ើតប្អូន

នោះ បួរចៅបរិភោគទឹកឃ្មុំប្រឡុំនឹងលាជទ្បើសប្បាយ ទៃហេសកសោម បណ្ឌិត ប្អូនគិតឆ្ងល់អំពីដំណើរចៅមកហានអាយនេះ ប្អូនរិនគិតមិនយល់ ឡើយ ចៅមកដោយខ្លួរហេតុម្តេច ? បួរចៅប្រាប់ប្អូនឲ្យដឹងតិចពាំ ក៏ស្តុ អ្វីត្រកាល ក៏ចៅត្រអាលមករកប្អូន ។ នឹងកេដោយចំណង់ចៅចង់ ។ សេកសោមបណ្ឌិតនោះ ស្តាប់ពាក្យនាងសារិកានោះហើយ ក៏រិនអក ខ្ចុយកលប្រស្នាមុសាវាទ ក្តួតប្រាប់ទៅនាងសារិកា ខ្លួរបទព្រះគាថា ដូចខ្មែរ :

តស្សុ មេកា ឧតិយា សិ សាលិកា មញ្ញុកាលិកា
តំ តត្ថ អវិ សេដ្ឋោ បេក្ខតោ សុឃរេ មមន្តិ។

សាលិកេ ទៃហនាងសារិកាអើយ ! នាងស្តាប់បងនឹងថ្លែងដោយ ដំណើរបងមកនោះប្រាប់នាង បងវិតបើប្រាប់ក៏ស្តុការអ្វីដទៃក្រៃនឹង ប្រពន្ធនោះឡើយ ទៃហសារិកានាងអើយ ! នាងយល់ជាសេក នាងស្មាន បងប្រាប់ប្រពន្ធសេកដូចគ្នាហ៎ៈ ទេនាង ! បងប្រាប់ប្រពន្ធសារិកាវិញ ប្រពន្ធបងមួយហើយ ជាសារិកាដូចនាងឯង បងតន់មើលមើលនាងអំពី ចំពុះបុះទៅដល់ចំអេងស្មាប ដកបដល់ក្រចក បងរកត្រង់ណាជាប្លែកនឹង សារិកាប្រពន្ធបងនោះគ្មានឡើយ បងតន់មើលមើលនាងទំនៅទ្រនំហើយ បងយល់នាងកាន់ចំអេងស្មាបខន់តបខ្លះខ្លើរហើរចេញទៅនោះ យល់ ល្ងាក់ល្ងមផ្សាស្រើជាបក្សីក្រែងក្រនំនោះ បងស្តាប់ពាសាសំដីស្រដីមូល-

មធុរៈក្រអៅស្រទន់ផ្អែមស្រីនោះ ពុំថ្លែកនឹងសាវ៉ាកប្រពន្ធបងឡើយ ។

អដ ដំ សា ឬទ្ធិ លំដាប់នោះ រីសាវ៉ាកស្តាប់ពាក្យសេក-សោមបណ្ដិតហើយ ទើបសាវ៉ាកដណ្តឹងវិញថា សម្ន សុវបណ្ដិត ហៃសេកសោមបណ្ដិតសំឡាញ់ប្អូនអើយ! ប្អូនស្តាប់ពាក្យនោះហើយ ប្អូនឆ្លើយអ្វីម្ល៉ះទេ ? អ្នកប្រាប់ប្អូនថា អ្នកមានកិរិយាដូចប្អូនហើយហ៎ៈ អ្នកថាប្រពន្ធនោះកលម្តេចហ៊ឺន ? ប្រពន្ធថៅនៅឯណា ចៅប្រាប់ប្អូនមើល ? ។ សេកសោមបណ្ដិត ស្តាប់ហើយឆ្លើយវិញថា ខ្ញុំស្រីសាវ៉ាកប្អូនពុំដាំបងអើយ ! បងនឹងថ្លែងអំពីដើមប្រពន្ធបងនោះមិនបានឡើយ នាងវ៉ាដូចគេយកឈើមកប្រហកអំពីចំពុះ ចុះទាំងលំចំតងឹក បងនឹងរិះរកស្រដីពុំបានឡើយ វ៉ាចង្អៀតអស់ដាំមួងណានាង សាវ៉ាកដណ្តឹងថា ហៃសេកសោមបណ្ដិតសំឡាញ់ប្អូនអើយ! ម្តេចដល់ម្ល៉ះ អម្បាលអម្ងាស់ប្អូនប្រាប់ប្អូនបន្តិចក សេកសោមបណ្ដិតថា ហៃសាវ៉ាកប្អូនពុំដាំបងអើយ! ព្រួងបងវ៉ាចង្អៀត បងទំនៀតប្រាប់នាង សាវ៉ាកអើយ ! ប្រពន្ធបងនោះខ្វែងវ៉ាតាបយកបាត់ទៅហើយ នាងអើយ ! បើគិតដោយដំណើរនោះហើយ បងវែងស្រណោះអាលោះអាល័យក្រៃពន់ប្រមាណ ចូរនាងស្តាប់បងនឹងទំប្រាប់ សាវ៉ាកអើយ មានកាលសម័យថ្ងៃមួយ ព្រះចុងអ្នកជាអម្ងាស់ ស្តេចទៅប្រពាតលេងដោយខ្លួរល្បែងចិត មួយអន្លើនឹងអស់ស្រីព្រះស្នំក្រមការបរិវារច្រើន ព្រះអង្គិបន្ទូលហៅបងថា សេក-

សោមបណ្ដិតអើយ ! មកឯណាយ ទៅលេងនឹងអញ សារិកានាងអើយ ! រីក្រែត្សបងទៅលេងឯណា ។ មួយក្ដី នឹងទៅហែព្រះចុងអ្នកឆាអម្ចាស់ក្ដី បងតែងនឹងយកប្រពន្ធបងនោះទៅផង មិនដែលឃ្លាតឡើយ កាលទៅដួតទឹកហែព្រះអង្គនោះ បងយកសារិកាប្រពន្ធបងនោះទៅផង នេះហោង ព្រះអង្គស្រង់ទ្រង់ក្រសាលនឹងព្រះពជទេពីស្រីព្រះស្ងំ អញនឹងគាត់នេះយើងបុះទៅដួតទឹកហែព្រះអង្គនោះទៅលេងលុះល្ងាចទន់ ។ ទើបព្រះអង្គឡើង ស្ដេចមកគង់លើប្រាសាទហើយ យើងលាព្រះអង្គចេញអំពីបង្គំចទៅដំហាលស្វាច នាផ្ទៃជង្គារប្រាសាទតែពីនោះឯង កាលនោះ សារិកាញ៉ាគាត់មានគភ៌ធំណាស់ហើយ ហៀបនឹងប្រសូតហើយ យើងចាំង ២ ហាលស្វាចនឹងនាងសារិកា ។ សារិកានាងអើយ ! នោះខ្វែងចោរត្រែសយ្នងវាហើរមកពីទិសឯណាមិនដឹងឡើយ ឮតែស័ព្ទសន្ធឹកធូរត្រដូរមកដល់ហើយ សារិកានាងអើយ ! រីអញជាប្រុសមានកំឡាំងហើយហើរបួច ឯគាត់ឯណាជាស្រីកំឡាំងតិច ហើយក៏ជួនឧន្ទឹងនឹងគភ៌សោត នឹងហើរចេញពុំរួចឡើយ វាឆាបគាត់ចុងទៅហោង សារិកានាងអើយ ! នាអញមើលទៅឃើញវាហើយ ដូចនឹងជាចំឡែកអញស្វាប់ផងបំផ្លើសលេងឯស្រី ទៅតែនឹងទុក្ខសម្រក់ទឹកភ្នែក ដូចនឹងបែកទ្រូងជាពីរវីរាហារោះបើលាជមួយដុំ ឬទឹកឃ្មុំមួយដំណក់ សូម្បីនឹងជីតនាចំពុះនោះគ្មានឡើយណា នាងអើយ ! វាឥតចំខែវល្លែលើយ ឥតស្បើយនឹង

រក្សាក្រឡាបន្ទំក្រមព្រះចាន់បុលនីសត្វថ្លៃឯង ឥតបក្សីដទៃក្រៃជាគំរប់ពីរ
ពុក្នុនោះដល់តិចឡើយ ត្រង់ណាហៅសុខប៉ុន្តែឯងបង់តុំដែលមាន លុះ
លង់ទៅតិច ព្រះចាន់អ្នកជាអម្ចាស់ត្រាស់រកថា សេកទៅឯណាមិនមក
គាល់អញហ៎ : ? នេះហោង ទើបបង់ទៅគាល់ កំឆ្កាប់រវើតែអញនឹង
សារីកាន់ខន្ធីមផងគ្នាគាល់ស្តេច នេះម្តេចឡើយ សារីកាញីចាត់ស្វាត់ទៅ
តែអញម្នាក់ឯង គិតរឿងពីដើមមកនោះវាស្រណោះពេកណាទាន់អើយ !
ទឹងខប់សំណាកពុំបាន មានទឹកភ្នែកហូរសស្រាកអំក្នាង ព្រះអង្គដល្អឹង
ថា សេកសោមបណ្ឌិតអើយ ! មកគាល់អញម្តេចចាំងទឹកភ្នែកដូច្នេះហ៊ឺន?
នេះហោងបង់ទូលព្រះអង្គថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃម្រេសើរអើយ!
ខ្ញុំសោកស្តាយសារីកាប្រពន្ធខ្ញុំស្ងាប់ ព្រះអង្គទ្រង់ព្រះករុណាជាដូច្នោះហ៎:
អាស្រូវសេកសោមបណ្ឌិត កំយ៉ែកណ្តាលដំខ្ទុះកេងសាលា ខ្ញាសតេមិនគួរ
សមសន្សឹមដើរហើរទៅរកប្រពន្ធខៀតអេះ ទើបអញទូលថា បពិត្រព្រះ
សម្មតិទេពក្សត្រថ្លៃប្រសើរអើយ ! ព្រះអង្គទ្រង់ព្រះករុណាពិសេសហោង
ខ្ញុំនឹងទៅរកប្រពន្ធខៀត ធ្លើម្តេចនឹងបានដូចសារីកាប្រពន្ធខ្ញុំនោះ ត្រូវនឹង
ចាន់ចិត្តទូលាយ ចរចាពុំគង់ស័ល្យមារយោងដោយច្បាប់ស្រី ពុំប្រណិប័តន៍
ប្តីស្វាមីពុក្នុស្តើអម្ចាស់នោះឡើយ មិនយូរឡើយ ព្រះអង្គបន្ទូលប្រាប់
មួយរំពេចនោះឯងថា ហៃសេកសោមបណ្ឌិត អញគិតទើបយល់ហ៎: គេ
ប្រាប់អញថា មានសត្វបក្សីស្រីសារិកាញីមួយ ប្រកបដោយមារយោង

ចន្ទភ្លាតច្បាប់បក្សីស្រីសត្វសារិកាញីនោះឯងថា សារិកានោះឯង តែងបាត់មើលថា បើសារិកានោះឯង ក្រែងគេអកិតាសមូលចូលចិត្តទើងបាជាសង្សារហើយ បាក្រច្បាប់មកប្រាប់អញ។ ទើងប្រដាប់ខ្លួវគ្រឿងបណ្ណាការ ទើងបរិពារទៀអធិតមហិមា ប្រកបខ្លួវឫក្សាពេជ្ឈសួស្តីអំពីអវដ្ឋបូរីស្រីមហានគរយើងនេះ ទៅកាន់ខនគរទុត្តរបញ្ចាល ជាមិត្តមេត្រីទើងព្រះបាទបុលនីព្រហ្មទត្ត តិតមូលផងគ្នា ហើយកំធ្វើអាពាហ៍ពិពាហ៍បាទើងសារិកាជាប្តីប្រពន្ធហោង ម្នៀស្រីសារិកាអាសម្ថៃបងអើយ! នាបងសង្ឃឹតទុហាតមក បទនេះហោង សេកប្រាប់ហើយ សូត្រជាបទគាថាដូច្នេះ:

តស្ស តាមា ហំ សម្មតោ អាកតោ តវន្តិកេ
សចេ កវេយ្យាសិ ទុតាសំ ខុកយោវាវសេម្ហាសេតំ។

សាលិកេ ម្នៀស្រីសត្វសារិកាពុំធ្លាបងអើយ! នាបងទុហាតសង្ឃឹតមកនេះ ទ្បែបានដល់យល់ខាង បទតែទ្បែបានខាងជាសាច់សង្សារកំឯចិត្តខាង តើញ៉ាំងតិតស្មើរៀមមកបង ជាសាច់សង្សារប្តេ? ម្នៀស្រីសត្វសារិកាឆ្លួនកុំថា បើបានអកិតាសបងនៅ កំយើងចាំងពីរទើងបានស្នេហ៍ស្និទ្ធជាមិត្តសង្សារនៅនេះទើងគ្នាហោង។

រីសារិកាស្តាប់ពាក្យសេកសោមបណ្តៀតហើយ មានចិត្តត្រេកអរស្មោះសរទើងសេកក្រែពេក តីមោះកាយមាយោខអាត្មាជាស្រីស្រដីតែមាត់

ទេ ថាជាពុំច្រាបថ្នាមិនឲ្យសេកជើង រីសារិកាចិត្តកន្ធើតតែសេកមហិ-
មា ឯមាត់តែស្រែដ៏ថាពុំច្រាបថ្នា ឆ្លើយទៅកាន់សេកជាបទគាថា ដូច្នេះ :

សុភៀវ សុរី គោមេយ្យ សាលិគោ បន សាលិកំ
សុវស្ស សាលិគោ យេវ សិង្គសោ ហោតិ តិក្ខិសោតិ។

សង្ឃ សុវបណ្ឌិត ម្ចៃចៅសេកសោមបណ្ឌិតមិត្តសំឡាញ់
ប្អូនអើយ ! នាដោយពាក្យចៅចរចស្រែដ៏ថា ចៅនឹងមកនៅនឹងអញ នេះ
ជាការគាប់ហោង តែយល់សើរើថា សត្វពួជតង្ស៍ពុំស្មើដូចគ្នា តិរេក
នឹងសេកនោះជាគូនឹងគ្នា សារិកានឹងសារិកានោះជាគូនឹងគ្នា ក៏ឥឡូវនេះ
ចៅជាសេកប្អូនជាសារិកា មកជាគូនឹងគ្នានោះ នឹងមានដំនៀលលោក
ដៀលថា ខ្ម ! សារិកាអើយ ខ្ញុំនជាសារិកាគួរជាគូនឹងសារិកាដូចគ្នាអេះ
ម្ដេចឡើយកំស្រើបស្រាលសើរើពែកភ្លើលលើ មកដោយឯសេកវិញហ៎ះ
ប្អូនថប់ណាស់ហោង ។ មួយនោះលែងគេះយោចីលោកនឹងដៀលថា ស្រែ
សើរើស្រើបស្រាលគ្នាយដោយចៅៗហោង សេកសោមបណ្ឌិតចៅ
អើយ ប្អូនថប់មួយចៅឥឡូវនេះ ចៅជាសេក អញជាសារិកា បើនឹង
បង្កើតពុត្រជនឹងគ្នា តើវានឹងជាម្ដេចចៅអើយ វានឹងជាសេកប្អូវនឹងជាសា-
រិកាហើយប្អូនថប់នោះក្រែ ។

(នៅមានត)

អក្សរសាស្ត្រខ្មែរ ខ្មែរធ្លាប់ថ្លៃថ្នូរ
ឲ្យបានខ្ជាប់ខ្ជួន គង់វង់គង់មាំ ។
ព្រោះអក្សរជាតិ ដោលជាតិជ្រាលជ្រៅ
អក្សរលេខ ជាតិកំរោយ ។

ប.ព.

ពាក្យខ្មែរប្រែតាមរនេសរ

ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ « ក »

(តមក)

— R —

Rapporter (v. t)	លើកចោល : លើកចោលអត្ថបទមួយ គឺចង់សេច អត្ថបទនេះ ដែលឲ្យមានដល ចាប់តាំងពីថ្ងៃចុះ ហត្ថលេខាដំបូងមក ជានសេចក្តីថា អត្ថបទនេះ ពុំកង្វះជាមិនដែលមាន ។	
Biens actifs	ទ្រព្យសកម្ម ។	
Biens passifs	ទ្រព្យអកម្ម ។	
Biens (n m)	ទ្រព្យ ។	
Biens mobiliers	ចលនទ្រព្យ	(ពហ្ម) ។
Biens immobiliers	អចលនទ្រព្យ	(ពហ្ម) ។
Biens meubles	សង្ហារិមទ្រព្យ	(ពហ្ម) ។
Biens immeubles	អសង្ហារិមទ្រព្យ	(ពហ្ម) ។
Fortune (n.f.)	សម្បត្តិ	(ពហ្ម) ។
Héritage (n.m.)	មតិក ។	

Interdire (v.s.pr.)	ហាមឃាត់ : ហាមជនណាម្នាក់មិនឲ្យធ្វើអ្វីមួយ ។ ទ. គ្រូពេទ្យហាមឃាត់អ្នកជម្ងឺ មិនឲ្យសេពសុរា ។
Ivre	ស្រវឹង ។
Ivresse (n.f.)	ភាពស្រវឹង ។
Ivrogne (n.m.)	មនុស្សស្រវឹង ។
Ivrognerie (n f.)	ភាពប្រមឹក ។
Ivrogne invétéré	មនុស្សស្រវឹងដោក ។
Opiomane (n.m.)	មនុស្សជក់អាភៀន ។
Opiomane invétéré	មនុស្សជក់អាភៀនដោក ។
Opiomanie (n.f.)	ការជក់អាភៀន ។
Opiomanie invétéré	ការជក់អាភៀនដោក ។
Patrimoine (n. m.)	បេតិកភណ្ឌ (ត្រូវអានថា : បេតិក:ភណ្ឌ) ។
Sénilité (n.f.)	ភាពចាស់ជរា ។
Sénile (adj.)	ចាស់ជរា ។
Vieux (n.m.)	មនុស្សចាស់ ។
Vieillesse	ភាពចាស់ ។
Rectifier un texte	កែសម្រួលអត្ថបទ (ពប្ប) : កែសម្រួលអត្ថបទ ឲ្យត្រឹមត្រូវនូវន័យនៃពាក្យនៃអត្ថបទនោះ ឬប្តូរតម្លៃនៃអត្ថបទនោះនៅនឹងដែល ។
Rectification d'un texte	ការកែសម្រួលអត្ថបទ (ពប្ប) ។
Règles communes	វិធានសាមីទស (ពប្ប) ។
Relations incestueuses	ការទាក់ទងខាងស្មន់ (ពប្ប) ។

Réintégrer le domicile conjugal ត្រឡប់មកលំនៅសង្វាសវិញ (ពប្ប)។

Réintégration du domicile conjugal ការត្រឡប់មកលំនៅសង្វាសវិញ (ពប្ប)។

Respect du foyer conjugal គារវៈចំពោះក្រានសង្វាស (ពប្ប)។

— S —

Siège (n.m.) ទីសំណាក់ការ (ពប្ប)។

Situation de la femme mariée ស្ថានភាពនៃស្ត្រីមានប្តី (ពប្ប)។

Sommer de faire ដាក់កំហិតឲ្យធ្វើ ។

Sommation de faire ការដាក់កំហិតឲ្យធ្វើ ។

Sommer de réintégrer le domicile conjugal ដាក់កំហិតឲ្យត្រឡប់មក លំនៅសង្វាសវិញ (ពប្ប)។

Sommation de réintégrer le domicile conjugal ការដាក់កំហិតឲ្យត្រឡប់មកលំនៅសង្វាសវិញ (ពប្ប)។

Sourd (n.m.) មនុស្សថ្លង់ ។

Sourd (adj) ថ្លង់ ។

Surdité (n.f.) ភាពថ្លង់ ។

Subdiviser l'étude du droit ចែកបន្តការសិក្សា នៃនីតិសាស្ត្រ (ពប្ប)។

Subdivision de l'étude du droit ការចែកបន្តការសិក្សា នៃនីតិសាស្ត្រ (ពប្ប)។

— A —

Actes judiciaires . . . . លិខិតតុលាការ ។

Actes extrajudiciaires . . លិខិតក្រៅតុលាការ ។

Avances (n.f.pl.) . . . . ប្រាក់ផ្តល់មុន ។

— B —

Blessures (n.f.pl) . . . របួស ។

— C —

Caisse d'avances . . . បេឡាផ្តល់មុន ។

Connaissance relative . . . ការបេះដឹងជាសាបេក្ខ ។

Convoler en secondes noces . រៀបអាពាហ៍ពិពាហ៍លើកទី ២ ។

Coups (n.m.pl.) . . . ការវាយដំ ។

Curatelle (n.f.) . . . ហ៊ានូបត្ថម្ភ : មុខងារនៃហ៊ានូបត្ថម្ភក៍ ។

Curateur (n.m.) . . . ហ៊ានូបត្ថម្ភក៍ : បុគ្គលដែលឲ្យប៉ាន់តាំងឲ្យធ្វើ. ការអនីតិជនអត្តាធីន ឬមនុស្សពាលខ្លះពញ្ញាយ អ្នកសតិទន់ខ្សោយ អ្នកពិការ មនុស្សច្រមឹកដោក មនុស្សដាក់អាភៀនដោក ក្នុងការគ្រប់គ្រងទ្រព្យនៃជនទាំងនេះ ។

— D —

Dément (n.m.) . . . មនុស្សវិកលចរិត ។

Démence (n.f.) . . . ភាពវិកលចរិត ។

Dispensaire municipal . . . . ទសថាល័យក្រុមមឿង ។

Divorcer d'avec . . . . . លែងលះ (ពជ្ឈ) ។

Docteur en médecine . . . . វេជ្ជបណ្ឌិត ។

Donation entre vifs . . . . . អំណោយកាលនៅរស់ ។

(នៅមានត)

វិបុលានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ថាំង . ខាត់ រៀបរៀង

(តមក)

អតិសិតាង្គវិហង្គ ប៉ុ. ហង្ស ។

អតិសិទ្ធិ ស្ត្រី. សិទ្ធិក្រៃលែង សេចក្តីសម្រេចក្រៃលែង ។

អតិសុកុមារ គុ. ផែលទ្វីក្រៃពេក ផែលក្មេងក្រៃពេក ផែលទន់ភ្លន់ក្រៃពេក ។

អតិសុខ គុ. ផែលសុខកន្ទុង ផែលស្រួលក្រៃលែង ។

អតិសុគម គុ. ផែលចូលទៅដិតជាន់ក្រៃលែង ។

អតិសុភគ គុ ផែលល្អកន្ទុង ផែលប្រពៃក្រៃលែង ។

អតិសុរភិ គុ. ផែលក្រអូបក្រៃលែង ។

អតិសុលភ គុ. ផែលរកងាយក្រៃពេក ។

អតិសុវិត្ត គុ. ផែលប្រព្រឹត្តល្អក្រៃលែង ផែលមូលកន្ទុង ។

អតិសុក្ស្ម គុ. ផែលល្អិតក្រៃលែង ផែលឆ្នាះកន្ទុង ។

អតិសុជ្ជ ឆាគុ. លះបង់ បន្សំតបង់ ឲ្យ ឃល់ព្រម ។

អតិសុជ្ជ្ជ ស្ត្រី. ការកសាងក្រៃលែង ការកសាងប្រសើរ ។

អតិសៅកុមាយ៉ី ន.ប៉ុ. ភាវនៃ . . ក្មេងក្រពេក ។

អតិសៅជឌ្ឍ ន.ប៉ុ. ភាវនៃ . . ជាជនក្រៃលែង ភាវនៃ . . . ជាជនប្រសើរ។
អភិជនក្រៃលែង អភិជនប្រសើរ ។

អតិសៅបណ្ឌិ គុ ដែលជាក្រុនក្រៃលែង ដែលជាក្រុនប្រសើរ ។

អតិសៅភៀត្យ ន.ប៉ុ ភាវនៃជនបរិភោគក្រៃលែង ។

អតិស្ដួល ១ គុ ដែលថ្ងោះក្រៃលែង ដែលក្រាស់ក្រៃលែង ។

អតិស្ដុធ គុ. ដែលទន់ភ្លន់ក្រៃលែង ដែលទងវងកន្ធង ។

អតិស្នេហ គុ. សេចក្ដីស្នេហាក្រៃលែង ន័ះក្រៃលែង ។

អតិស្បធិន៍ គុ ដែលប្រណាំងប្រជែងក្រៃលែង ។

អតិស្ដុដ គុ. ដែលគ្រោកនក្រៃលែង ដែលជាក់ច្បាស់ក្រៃលែង ។

អតិស្វរ៍ ឆគុ. ស្ងួះក្រៃលែង ស្រែកក្រៃលែង ។

អតិស្វល្ប គុ. ដែលតូចក្រៃលែង ។

អតិហាប៉ំ ប៉ុ សេចក្ដីរីករាយក្រៃលែង ។ អតិហប៉ុ៍ល គុ. ដែល
សប្បាយក្រៃលែង ។

(នៅមានត)

តាមអំពើចិត្ត ។

រឿងនេះបានជាគតិថា: ការយល់ឃើញរបស់អ្នកមានអាន្តរាគ តែងត្រូវនិយមពុកជាប្រសើរជាងអស់ ។

១៣- ក្តាន់ធឹងទំពាំងបាយជូរ

ក្តាន់មួយត្រូវពួកអ្នកដាក់បង្កាត់ដេញតែ់ទៅជ្រកតួន ធឹងដើមទំពាំង-បាយជូរ ។ ដោយអំណាចទំពាំងបាយជូរមានស្លឹកលូតលាស់រៃធឹងចិទ ជុំធឹ ក្តាន់បានរួចរស់ជីវិតដោយសារ ។ ពួកព្រានស្មានថា ឆ្កែកេជាន មិនឃើញ ក៏ហៅឆ្កែឲ្យត្រឡប់មកវិញ ។ លុះបានរួចពីគ្រោះថ្នាក់ ក្តាន់ស៊ីទំពាំងបាយជូរ ដែលជាអ្នកធ្វើសេចក្តីល្អដល់ខ្លួនពីលើកមុន តាល់តែអស់រលីង នេះគឺជាសេចក្តីអកតញ្ញូតេញាទី មិនយូរប៉ុន្មាន គេមើលឃើញគេត្រឡប់មកវិញ ហើយដេញម្តងទៀត សត្វនោះគ្មានទីជម្រក ក៏ដល់នូវសេចក្តីវិនាស ។

រឿងនេះ ជាតតិដល់អ្នកដែលបំផ្ទិចបំផ្លាញទីកន្លែងដែលខ្លួនបានជ្រកហើយ ។

១៤- បបកតែងខ្លួនជាអ្នកគង្វាលបៀម

បបកមួយអាស្រ័យនៅជិតពួកបៀម តែវាមិនដឹងធ្វើយ៉ាំងណាទើន
អាចចាប់បៀមបាន ព្រោះតែគ្រប់សប់តេក ។ វាយកគំនិតកន្ត្រាងមក
ជាដំនួយ ហើយតែងខ្លួនជាកេរច្មី គឺស្បែកបែបអ្នកគង្វាល ពាក់អាវដៃធំ
មានចាំងដំបងព្រមចាំងខ្ចុយផង ។ ដើម្បីបញ្ឆោតការបន្ទុំឲ្យអស់ដើង
វាថែមចាំងសរសេរដាក់នៅមួកថា « ខ្ញុំហ្នឹងហើយឈ្មោះហ្គីយោជាអ្នក
គង្វាលនៅហ្នឹងនេះ" ។ រៀបចំស្រេចហើយ ដើងមុខចាំងពីរកាន់ដំបង
ហ្គីយោថ្មើរចូលទៅសឹម ។ ។ ចំណែកហ្គីយោអ្នកគង្វាលមែនខែន
ដេកស្លុកស្តឹងលើស្មៅខ្ចី ស្រមុកខ្លរ ។ ដើម្បីកៀងបៀមឲ្យបានទៅដល់
ទីកន្លែងខ្លួន បបកចំងចន្ទែមសំដីទៅជួយនោអាវខៀត ដោយគិតស្មានថា
សំដីជាការចាំបាច់ ។ តែវាគ្មានចាំងឲ្យខ្លួចការសោះ ។ បបកមិនអាច
ធ្វើសំឡេងឲ្យដូចជាសំឡេងអ្នកគង្វាលបាន វាស្រែកឡើងឮអស់ចាំងព្រៃ
ដូចជាបើកកកាយការសម្លាត់អាក្នុងឲ្យគេឮអស់ ។ គេក្បាក់ពល់គ្នាៈ អ្នក
គង្វាល ឆ្កែ បៀម ។ អាខ្លះស្រែក អាខ្លះខេះដៃ បបកស្ទន់រកវត់ទៅណាឬ
ខ្លឹងការតោកគ៌ពុំកើត ព្រោះតែសខ្លឹងនោអាប្រដែងប្រដាង ។

អ្នកណាជាបបក តម្រូវប្រព្រឹត្តតាមភាពជាបបក នោះជាការគាប់
ប្រសើរច្រើន ។

(សុភាសិតខ្មែរៈ ការមិនសង្រ្គមកថា រមែងចាំឲ្យខាតបង់) ។

១៥- សិង្ហាសាល

សិង្ហាសាលមួយ តាំដើមខ្លាប់ជាទីកោតខ្លាចនៃសត្វទាំងអស់ក្នុងព្រៃ។ កាលខ្លួនដកខ្លាំង ទឹកស្តាយកម្លាំងពីដើម ព្រោះត្រូវពួកសត្វឯទៀតធ្វើបាបវិញ ដោយហេតុខ្លួនមានកម្លាំងទន់ខ្សោយ ។

សេះមួយចូលទៅច្រាយមួយដើង ចចកទាំមួយចង្កឹម គោព័ធមួយស្មែង ។ សិង្ហាវង្កវែងា មុខស្លូត មានចិត្តស្រទន់ស្រទាត់ ស្រែកស៊ើរមិនរួច ព្រោះចាស់ពេក ។ សិង្ហខួលខ្លួនតាមកម្ម គ្មានស្រែកថ្ងូរបន្តិច តែដល់ឃើញសត្វលាវត់មកចំវុងទឹងតាត់មួយដើងដូចគេដែរ សិង្ហលោចេញសំដីថា: ណ្លើយ ! កុំអី ! ដូចជាជ្រុលពេកណាស់ ខ្ញុំស៊ូស្ងប់ជាជាង មិនឲ្យដើងអ្នកឯងមកប៉ះសាច់ខ្ញុំឡើយ ។

១៦- ទន្សាយនឹងកង្កែប

មានទន្សាយមួយនៅកន្លែង ចេះតែដេកជញ្ជឹង (នៅកន្លែងមិនដឹងធ្វើអ្វីប្រសិនមិនគិត) ទន្សាយនេះអផ្សុកពេកតាំងតែទឹក: ព្រោះសត្វនេះព្រួយ ហើយការភ័យខ្លាចចេះតែកកូរក្នុងខ្លួនផង ។ ក៏ទឹកថា: ជាតិអ្នកខ្លាចច្រើន សុទ្ធតែអ្នករង្កវែងា មិនដែលស៊ូអ្វីឲ្យឆ្ងាញ់ដូចគេ គ្មានសេចក្តីរីករាយសប្បាយឡើយ មានតែសេចក្តីជូរម្ត៉ងាទិច្ច អញយល់ដូច្នេះថា ការភ័យខ្លាចចង្រៃនេះ ធ្វើមិនឲ្យអញដេកលក់បាន ឲ្យនៅតែ

បើកភ្នែកមហួត អ្នកមានជ្រុងជ្រាលស្ពន់យោយថា: ត្រូវឲ្យរៀនលះបង់ចេញ
ដោយខ្លួនឯង តើគេអាចលះការខ្វាចចោលបាន ? បើតាមអញ ។ យល់
ថា: មនុស្សទាំងអស់សុទ្ធតែមានការភ័យខ្លាចដូចអញអីចឹងដែរ ។

សត្វខន្ធាយនឹកជញ្ជឹងដូចអធិប្បាយខាងលើ ហើយខណៈនោះ ក
ប្រុងចាំនៅមាត់ទ្វេ ចេះតែសង្ស័យរសាប់រសល់ ខ្យល់ចក់ស្រមោលអ្វី
បន្តិចក៏ដោយ តែងធ្វើឲ្យវាភ្ញាក់ភ័យ ។ សត្វក្រៀមក្រំនេះ កំពុងតែគិត។
ស្រាប់តែឮសូរអ្វីស្រឹប ក៏នឹកថា ដល់ហើយ បើដូច្នេះ ត្រូវស៊ុះចេញពីរូង
ទៅក្រៅខាងនោះសិន ។ ខន្ធាយស៊ុះតេវលើមាត់ត្រង់ ស្រាប់
តែភ្លែបភ្ញាក់ភ័យ លោតចុះកូនចិកកូន ។ ពួនអស់ ។ ខន្ធាយនឹងថា
ខ្ញុ! អញក៏ធ្វើឲ្យគេខ្លាចដូចជាគេធ្វើឲ្យអញខ្លាចដែរ ! អញមកក៏គង់មាន
គេខ្លាចដែរ ! បើដូច្នេះ មិនគឺអញយកការភ្ញាក់ផ្អើលមកក្នុងចិនេះ តើអញ
បានអំណាចហ៊ានពីណាមក ? ខ្ញុ! មានសត្វខ្លះ ឃើញអញមកគិតភ័យ
ញាប់ញ័រដែរ ! បើអីចឹងអញជាមេចម្លាំងមួយទេតើ ! អញយល់ច្បាស់ថា
គ្មាននរណាផ្អើលចោលមឿតជាងអ្នកណាទេ ។ ទៅលើផែនដីនេះ អ្នក
ណាអាចរកបាននរណាដែលមិនភ្ញាក់ផ្អើលជាងខ្លួន ។

១៧- សត្វលាធឹងឆ្កែតឿ

ចូរយើងកុំបង្ខំចំណេះរបស់យើងឲ្យហួសព្រំដែន យើងមុខជាខឹងធ្វើ
មិនបានប្រសើរ ប្តូមិនបានសម្រេចដូចបំណង ។

ទាន់សត្វលាមួយ ចង់ឲ្យម្ចាស់ពាក់អានក៏នឹកក្នុងចិត្តថា "ហេតុអ្វីថ្ងៃនេះ កំម្ចាស់ប្រុស-ស្រីស្រឡាញ់ដូចជាមិត្រវេរបស់គាត់ ចំណែកអញៈចេះតែត្រូវដំបង តាំព្រោះថ្ងៃនេះតួច ហើយគួរឲ្យស្រឡាញ់ តើពាក់ធ្វើអ្វីដល់ម្ចាស់ ! មើលទៅឃើញតែពាក់លើកដើងតំនាប់ ហើយស្រាប់តែម្ចាស់បង្ហោសអង្កែលស្រឡាញ់ពាក់ ប្រសិនបើជាធ្វើឲ្យគេស្រឡាញ់ដូចជាការណ៍នេះ មិនមែនជាក្រ តើងាយសោះ ។

កំពុងតែគិតដូច្នោះ ស្រាប់តែឃើញម្ចាស់ដើរមកចំកមុខញញឹម លាដើរសំដៅទៅរក លើកដើងមួយ ក្រចកគគ្រាត ថ្នមអស់ពីចិត្ត ហើយជូតចង្កាម្ចាស់ មិនតែប៉ុណ្ណោះ ដើម្បីសំដែងសេចក្តីសប្បាយនឹងការពាក់អាន ក៏ស្រែកសម្រែងយ៉ាងពីរោះបន្តូរថែមទៀត ។

ម្ចាស់ស្រែកថា "យើ ! យើ ! ការបង្ហោសអង្កែលឬ ? ច្រៀងបន្តូរឬ? ចុះដំបងនៅឯណា ! លុះដំបងមកដល់ លាទើបដឹងខ្លួនថា ការធ្វើដូច្នេះមិនគាប់ប្រសើរឡើយ ។

១៨- សិង្ហនឹងលាបរបាញ់រកចាប់សត្វ

ថ្ងៃមួយ សិង្ហជាស្តេចសត្វទៅបរបាញ់ ពីព្រោះជាថ្ងៃបុណ្យរបស់គេ ។ ពួកសត្វដែលសិង្ហបំរុងរកចាប់មិនតឹសត្វចាបទេ សុទ្ធតែជ្រូករមាំ ក្តាន់ រមាំង ប្រើស យ៉ាងធាត់ ។ ហើយស្អាតៗផង ។ ដើម្បីញ៉ាំងកិច្ចនេះ

ឲ្យសម្រេច សង្ឃប្រើទុកញាំលាដែលសម្រែកឮខ្លួនខ្លាំរពេញព្រៃ ទុកញាំលាធ្វើជាស្នែង សង្ឃយកទៅឲ្យនៅមួយកន្លែង យកស្មឹកឈើគ្រប់ជាតិហើយច្រាប់ឲ្យស្រែក ពាល់តែសត្វដែលមិនសូវក្លាក់ផ្តើលដួលម្តេច ក៏អត់ត្រាំមិនរត់ចេញពីលំនៅមិនកើត ដ្បិតពួកសត្វទាំងនោះ មិនធ្លាប់ស្តាប់ឮសម្រែកលាសោះ ។

សម្រែកលាលាន់ឮ គួរជាទីស្ញប់ស្ញែងពេកណាស់ សេចក្តីគិតភ័យទៅគ្របសង្កត់សត្វកងព្រៃគ្មានសល់ ម្រឹគទាំងឡាយផ្តើលក្លាក់ស៊ុះរត់ទៅជាប់អន្ទាក់ធ្លាក់លើដៃសង្ឃជាច់ជាន់ទាំងអស់ ត្រង់កន្លែងដែលវាឃ្លាំចាំ ។

លាសប្បាយហើយពេញចិត្តនឹងចាប់សត្វជាន់ច្រើន ទើបពេញសំដីថា: ម៉ែចព្រះតេជព្រះគុណ ពេលនេះ ខ្ញុំធ្វើការល្អឬទេ ?

សង្ឃឆ្លើយថា មែន ! ប្រសប់ស្រែកលេខ ១ ប្រសិនជាខ្ញុំមិនបានស្គាល់លោកឯង ឱនពួជលោកផង ខ្ញុំក៏គង់តែភ័យរត់ដែរ ។

១៩- កង្រែងនឹងរូបបដិមា

ពួកអ្នកឆ្លៀវ ច្រើនដូចជារូបបដិមា ឬជាមុខសម្រាប់ពាក់ ការឃើញមុខពួកនេះ តែងញ៉ាំងអ្នកធម្មតាឲ្យគោរពកោតក្រែង ដូចជាខេត្តា ។ សត្វលាចេះគោរពកោតតែរបស់អ្វីដែលឃើញមិនគ្រែត ចំណែកកង្រែងមិនដូច្នោះឡើយ គិតជ្រៅណាស់ ហើយតិចារណាឲ្យគ្រប់ជ្រុងជ្រោយថា បើ

ការណ៍អស់ហ្នឹងគ្រាន់តែជារបស់ក្រៅខ្លួន ដូចជារូបបដិមាអ្នកខ្លាំងតូចតែម្នាក់ ។ មានរូបបដិមាមួយប្រហោងក្នុង តែធំជារូបធម្មតា ។ សត្វកន្ធោងមានសេចក្តីសរសើរដល់កម្លាំងក្រួចថា ខ្លឹងការបម្លាក់ថា ៖ រូបក្បាលនេះល្អមែន ប៉ុន្តែ គាស់គ្មានខួរ ។

២០- កូនត្រីធំឯព្រាធសំណាញ់

នាយនេសាខម្នាក់ បង់បានកូនត្រីប្រកែងមួយក្នងស្ទឹង ។ អ្នកនេសាខគោលថា " បានមួយនេះ ខុកជាម្ហូបដើមដំបូង បើដូច្នេះជាក់ក្នុងត្រកៅ" ។

កូនត្រីព្រួយចិត្ត ទើបនិយាយអង្វរថា "លោកយកខ្ញុំទៅធ្វើអ្វី ប្រសិនបើស៊ីក៏មិនបានកន្ទុះមាត់ផង សូមលោកមេត្តាលែងខ្ញុំ ខុកខ្ញុំធំសិនហើយលោកត្រឡប់មកចង់យកខ្ញុំវិញ មិនលែងមានគេទិញបានថ្លៃច្រើនជាងនេះ បើលោកចំច្រឹងកត្រីប៉ុនខ្ញុំប្រហែលមួយរយយកមកធ្វើសម្លមិនដឹងជាសម្លនោះដូចម្តេចផង សូមលោកផ្សឹខ្ញុំចុះ សម្លថែបហ្នឹងគ្មានដំណៀឡើយ" ។

នាយនេសាខធ្វើយថា: "អើ! គ្មានដំណៀក៏ប្លីចុះ នែអាសំឡាញ់ ឯងទៅនិយាយអធិប្បាយប្រាប់គេ ក្នុងឆ្នាំងខ្លះដែលគេកំពុងចៀនឯនោះចុះ ឯងទេសន៍ជាមួយអញឥតផលទេ ។

(មានសុភាសិតមួយសំដែងថា : "ចាបមួយនៅដៃ គ្រាន់បើជាងម្ភៃនៅដើមឈើ") ។

២១- ធ្នាប់ធំឯកូនកណ្តុរ

កូនកណ្តុរនៅក្មេងពេក មិនទាន់យល់ដើងការណ៍សព្វគ្រប់ ស្មានថាខ្លួនអាចបន្ទន់ចិត្តឆ្មាបាន ទើបសុំឲ្យឆ្មាមេត្តា ហើយទំប្រឹងពន្យល់ឆ្មាដូច្នេះថា : "សូមលោកអាណិតខ្មុកឲ្យខ្ញុំរស់នៅផង កណ្តុរតូចមួយប៉ុនរូបខ្ញុំនឹងចំណាញអ្វីអស់ប៉ុន្មានក្នុងផ្ទះនេះ ។ តើលោកយល់ថាខ្ញុំមើលងាយចៅហ្វាយប្រុស-ស្រីនឹងមនុស្សក្នុងផ្ទះហ្នឹងឬ ? ស្រូវតែមួយគ្រាប់ក៏ខ្ញុំអាចចិញ្ចឹមជីវិតបាន ស្វាមួយគ្រាប់ ខ្ញុំកកេរដល់កោងខ្នងមិនទាំងបានសម្រេចផង ។ ពេលនេះ ខ្ញុំស្គមណាស់ សូមលោកចាំពេលក្រោយ សូមខ្មុកខ្ញុំឲ្យជាចំណីកូនលោកជាន់ក្រោយទៅ ។ ឆ្មាឆ្លើយថា: អាឯងកាន់ច្រឡំទេ យ៉ាងមុខអញ ឯងស្មានថាជាអ្នកខ្វះលុយអង្វរឬ ? អាឯងទៅនិយាយឲ្យមនុស្សថ្លង់ស្តាប់ល្អជាជាង ។ ជាតិជាឆ្មាហើយចាស់ផង ឯងស្មានថាអញអត់ទោសឲ្យឬ ? មិនដែលមាន ! មិនដែលឮ ! ។

(នៅមានត)

ភាគ្លាទី ៥០

ទុកញ៉ាវិបុលភជសេនា ជួ-កាន ប្រែរៀបរៀង

(ពមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
ទំនងបេះទុយយកលចំណាន
ចាំងមានសន្ដានស្នេហាជាតិ

ឃ្លេ - ឆ្នុន

ចូរឆ្លងដំណឹងក្នុងសំបុត្រនោះហើយក៏សួរខៀវសុងថា ខ្លៅជៀងជានាយអ្នកឯងនោះ ច្រើនឆ្នាំហើយមិនដែលជួនគ្រឿងបណ្ណាការមកគាប់តាមចំនៀមទម្លាប់ប្រពៃណីសោះ ព្រោះហេតុអ្វីបានជាធ្វើដូច្នេះ ខៀវសុងដាក់បថា ស្រុកសែឃ្លួននោះ ជាស្រុកជាប់ស្រយាលឆ្ងាយអាល័យកម្រដែលទំនងទៅមកគេកណាស់ មួយយ៉ាងទៀត អាណាខ្ញុំត្រាំងក្នុងកំសុខ្លួនតែកើតចំរូងចំរៃមិនចាន់កបថាបជាប្រក្រតី មានសេចក្ដីខ្វាចបាម្ដក្រែងចោរកំណាច ទឹងលើកគ្នាប្លន់ដណ្ដើមយកគ្រឿងបណ្ណាការកណ្ដាលផ្លូវបានជាមិនអាចទឹងនាំមកបាន ចូរឆ្លងក៏ស្រែកគំហកថា អញ្ជើដើរច្រកប

ច្រាមអា ណាវែត្រង់ឯងពួនកបាបជាសុខក្សេមក្សាន្តអស់ហើយ ចោរ
ឯណាដែលនៅមានខ្មែតសោត ។

ខ្មៅសុឆ្នើយថា ទំសងឯត្បូងនោះស៊ុនគួនជាសត្រូវបស់លោកតំ
នៅមាន ទំសខាងលិចកំតីខ្មៅតី ទំសខាងជើងកំតីខ្មៅឡ បើសត្រូ
វបស់លោកនៅមានដុំខ្លួនដូច្នេះ ខ្ញុំឯណាដែលលោកថាច្រាបច្រាមកប
តាបហើយនោះ ចូរគួបាននូដូច្នោះកំខឹងណាស់ តាំងិត្យមើលរូបកងខ្មៅ
សុងឃើញលក្ខណៈតាបថាកមិនតាប់អធ្យាស្រ័យសោះ កំក្រោកចូលទៅ
ក្នុងបាត់ ទីប្រឹក្សាទាំងពួងក៏នាំគ្នានិយាយនឹងខ្មៅសុងថា អ្នកនេះគ្មាន
អធ្យាស្រ័យសោះ ហ៊ានមកនិយាយផ្ទុញផ្ទាល់មហាឧបពាជដូច្នេះគួរហើយ
ឬ នេះហាក់តែអ្នកឯងបានន៎ាបណ្ដាការមកថ្វាយតាំបម្បាយ បានជាមហា
ឧបពាជមិនយកទោស ត្រូវអ្នកឯងចេញទៅឲ្យឆាប់ ។ ចុះកុំបីនៅឲ្យយូរ
ឡើយ ។

ខ្មៅសុឆ្នើយថា ខ្លួនខ្ញុំនេះជាអ្នកស្រុកសែឈួនទំងិនិយាយអ្វី ។
កំទៅតាមត្រង់ មិនគ្មានយកសេចក្តីវៀចមកចរចាប្រចុបប្រចៀចដូចមនុស្ស
ឯខ្មែតទេ អៀវស៊ុ៊ាឮដូច្នោះកំស្រែកតំហាកថា ខ្លួនជាអ្នកស្រុកសែឈួន
ចរចាសុទ្ធតែត្រឹមត្រង់ យើងពួកស្រុកក្រុងនេះ អ្នកឯងឃើញនរណាជា
អ្នកនិយាយប្រចុបប្រចៀចសោត ខ្មៅសុងងាកមុខមកមើលអៀវស៊ុ
ឃើញរូបកងស្អាតជាត បែបជាអ្នកមានកេរ៉ាហារចេះចរចា កំភ្ញាសួរទៅ

ថា អ្នកនេះឈ្មោះអ្វី មហាឧបាសិកាតាំងឲ្យធ្វើនាម៉ឺនន៍យោយការខាងអ្វី អៀវស៊ុវធ្វើយតបថា យើងឈ្មោះអៀវស៊ុវជាពួកក្សត្រឡាំងមហាឧបាសិកា ។

ខៀវសុងជំនឹងថា អៀវស៊ុវជាមនុស្សមានសតិបញ្ញាកំសន្ធនាក្រុងស្រុយដោយសុភាព អៀវស៊ុវយើញខៀវសុងប្រកបដោយអធ្យាស្រ័យស្រួលបួលហើយ ក៏នាំគ្នាឯផ្ទះហើយចាត់ចែងឲ្យអង្គុយទីសមគួរបួចហើយសួរថា ស្រុកសែឈួនោះផ្លូវឆ្ងាយជាច់អាល័យណាស់ អ្នកឯងឡូហ៍មកដល់ស្រុកក្រុងនេះបាន ខៀវសុងថាខ្ញុំជាឧបាសិកាត្រាវគេ ហើយបើនាយចៅហ្វាយប្រើក៏ត្រូវតែទៅ ទោះបីផ្លូវដែលទៅនោះ លុយទឹកតក់ល្បាប់ឬលុយភ្លើងក៏ត្រូវតែទៅឲ្យបាន អៀវស៊ុវថា ស្រុកសែឈួនោះ កូមិហានជាចៃដន្យយ៉ាងម្តេច ។

ខៀវសុងថា ឯស្រុកសែឈួនោះ មានកូមិហានធំខ្លាំងស្រុណុកសឡាយណាស់ ពីដើមគេហៅថាស្រុកអេកដាវ ទីសឯត្បូងនោះមានស្ទឹងតូចតាមកាំងកាំងម្ខាង ទីសឯជើងមានតួយកៀមកុក ផ្លូវដែលនឹងទៅមកតិចឆ្ងើតជាណាស់ ហើយស្រុកនោះមានបរិមណ្ឌលចំនួន ៣០០០ សិន (១.២០០ គ.ម) មានរយៈភូមិល្មមមានផ្ទះជាប់ជាប់គ្នា តាំងត្រីអង្គុចំណើត្រីសាច់តិចរបូណាជាទីស្រួលសឡាយជាជាងស្រុកដទៃ អៀវស៊ុវសួរថា បណ្តាក្នាក់ជាឧកញ៉ាកងក្នុងស្រុកសែឈួនោះ មានអ្នកណាមានសតិបញ្ញាដែលនឹងគិតការពារខ្មែរកុបាលអស់អាណាប្រជាទុក្ខស្តួ ដោយ

ការផ្ទាស់ប្តូរឲ្យកើតសុខសំរាន់មានខ្លះដែរឬទេ ខៀវសុនិថា មនុស្សដែលមានសតិបញ្ញានឹងសេនាភាហាន ដែលមានថ្វីដៃខ្លាំងពូកែខោះមានច្រើនមិនដឹងដែលនឹងពណិនាជូនអ្នកស្គាប់ឃុនទេ ។

ខៀវស៊ីវិសួរថា នាហ្នឹនដែលមានសតិបញ្ញាដូចពាក្យអ្នកថាខេះមានប្រហែលប៉ុន្មាននាក់ ខៀវសុនិឆ្លើយថា នាម៉ឺនដែលមានសតិបញ្ញាពិស្តារជ្រៅខ្លាយ នឹងប្រកបទៅដោយសេចក្តីស័ក្សសុចរិតប្រាកដខោះប្រហែល ១ ១០០ នាក់ តែដែលមានប្រាជ្ញាជាប្រមាណដូចយ៉ាងខ្លួនខ្ញុំនេះសូម្បីនឹងយកវេះទៅផ្គុកក៏មិនអស់ ។ ខៀវស៊ីវិថា ឥឡូវនេះ ខ្លួនអ្នកជានាហ្នឹនក្នុងក្រសួងអ្វី ? ។ ខៀវសុនិឆ្លើយថា ខ្ញុំឃុនជាភ្នាក់ងារគ្រាន់តែមិប្រឹក្សាយ៉ាងតូចទេ មិនសមគួរដែលនឹងជានាហ្នឹនដូចគេទាំងពួងឡើយ ចុះខ្លួនអ្នកតើជាមិអ្វី ? ។ ខៀវស៊ីវិថា យើងជានាហ្នឹនសម្រាប់កាន់បញ្ជីរបស់ព្រឹត្យមហាទបាជ ត្រូវត្រួតត្រាឲ្យដឹងរបស់ខ្លះខាតចូលចេញទាំងពួង ។ ខៀវសុនិថា ខ្ញុំឃុនបានឮគេនិយាយថា ខ្លួនអ្នកនេះជាមនុស្សមានសតិបញ្ញាណាស់ ហេតុម្តេចមកធ្វើត្រឹមភ្នាក់ងារក្រៅដំណែងដូច្នេះបើនឹងទុស្សាហ៍ធ្វើពជាក្នុងព្រះចៅហៀនតេជាល់ឲ្យថាមន្ត្រីធំ នឹងបានជួយចំនុកបំរុងផែនដី ដើម្បីឲ្យព្រះចៅហៀនតេសប្បាយព្រះទ័យផងដែរ មិនបានឬ ? ។

អៀវស៊ីវាក្តដូច្នោះ ក៏ទំអត់សង្កត់ទុកក្នុងចិត្តហើយថា ដែលខ្លួនខ្ញុំមកនៅធ្វើការកន្លងមកក្នុងផ្ទាំងប៉មហាទុកជ គ្រាន់តែជាគ្នាក់ងាយក្រៅដំណែងនោះក៏មែន តែថាបណ្តាជនាទុជន ក៏បានគោតក្រែងរមែងខ្លាចនឹងរាប់អានស្រឡាញ់ច្រើន ព្រោះមហាទុបាជបានដឿទុកចិត្តជាច្រើនតស់របស់ទ្រព្យទាំងពួងឲ្យខ្ញុំទុកដាក់ថែរក្សា ហើយក៏មានសេចក្តីអាស្សរការុណាជាច្រើន បានរំលឹកប្រដៅឲ្យដឹងកិច្ចការទាំងពួងជានិច្ច គុណទុបការៈរបស់មហាទុបាជនោះនឹងរកទ្រមាណជាមិនបានឡើយ បានជាខ្ញុំជាប់ចិត្តនឹងកក្តីគ្រាន់តែប៉ុណ្ណោះ ។ អៀវស៊ុងអស់សំណើចហើយថា ខ្ញុំបានកើដឹងអស់ហើយ តើមហាទុបាជនេះនឹងបានដឹងស្គាល់របស់អ្វីឲ្យជាច្រើនដូនគ្នាន ពោះបើនឹងចេះសំបុត្រប្លាំងការសិល្បសាស្ត្រក្នុងលែបតាហានក៏គ្រាន់តែជាប្រមាណ នឹងយកវាំងអ្វីមកលើកប្រដៅអ្នក ។ តើបមកពប់បុល្យលើកយកគុណទុបការៈនៃមហាទុបាជនោះ ព្រោះសព្វថ្ងៃនេះហាក់តែមានកសនាពីអតីតជាតិជួយទុបត្ថម្ភគាំទ្រ តើបបានតាំងខ្លួនជាធំប៉ុណ្ណោះបាន ។

អៀវស៊ីវាថា ខ្លួនអ្នកនៅស្រុកក្រៅឆ្ងាយណាស់ មិនបានដឹងច្បាស់ថា មហាទុបាជនេះមានវាំងការនឹងកលទុបាយក្រាយក្រាជ្រៅខ្លាយសោះ ហេតុអ្វីក៏គាបហ៊ានថាដូច្នោះ ឯមហាទុបាជនេះ គឺជាមនុស្សចេះដឹងណាស់ បើអ្នកចង់ដឹងច្បាស់ជាមែនឬមិនមែនយើងនឹងយកសំបុត្រ

ដែលមហាឧបាសិកានេះ ឈ្មោះថាជាំនេតមកឲ្យមើល ហើយ
ចាប់យកសំបុត្រនោះហុចមកឲ្យខៀវសុង ។ ក៏យកមកមើលឃើញមាន
សេចក្តី ១៣ ។ ពណ៌នាពីការរណរង្គសង្គ្រាម ឲ្យតាំងបន្ទាយនឹងចាត់
ចែងរៀបពលខាហានខ័ពខ្ពស់ ខ័ពនោកតាមរបៀបក្បួន លុះមើលចប់ក៏
សួរថា សំបុត្រនេះមហាឧបាសិកាយកយ៉ាងដំនៀមពីណាមកសរសេរឲ្យគេ
ឬ? ។ អៀវស៊ីវ៉ាថា មហាឧបាសិកាតែងបញ្ចេញពាក្យប្លែកណាដំនៀម
ចុក ច្រើនតែនឹងឲ្យជាប់ជាប្លាប់តៅខាងមុខ។ ហេតុម្តេចបានជាអ្នកមកថា
ជាពាក្យមើលងាយប្រមាថ ថាមហាឧបាសិកាមានសតិបញ្ញាតិច បើច្រើន
មិនមានន័យតែងសេចក្តីសំបុត្រនេះឲ្យគេបានឬ? ។

ខៀវសុងអស់សំណើចហើយថា សំបុត្រប្លែបយ៉ាងនេះកូនក្មេងតូច។
នៅក្នុងស្រុកសែឈួនវាសូត្រលេងខ្លួនតែងតេញក្នុងស្រុក គឺជាពាក្យប្លែកណា
មានអ្នកច្រើនដូចគេបង្ខូចពីដើមទេ ហេតុម្តេចអ្នកមកថា មហាឧបាសិកា
តែងខ្លួនឯងលេងសោត គឺវែសយកពាក្យថាសំមកថាកុហកកវែ ដែលនឹងដឿ
ខោះ កំយ៉ាងបែបអ្នកឯងវាងួនស្តាប់ក៏ថាល្អ ។ អៀវស៊ីវ៉ាថា សំបុត្រនេះ
មហាឧបាសិកាតែងខុសដើម្បីនឹងឲ្យឃើញច្រើកដរហូតទៅគ្រាតែអស់ផែនដី
មនុស្សទាំងប្រុសទាំងស្រីក៏ចាន់ដឹងត្រប់គ្នា ហេតុម្តេចអ្នកមកថាពាក្យនេះ
ជាពាក្យសម្រាប់សូត្រលេងទៅវិញ មិនសមគួរនឹងយកពាក្យនេះមកក្បែង
ប្រមាថមើលងាយមហាឧបាសិកាដូច្នេះសោះ ។ ខៀវសុងថា បើអ្នកមិន

គឿតាក្សខ្ញុំថា អ្នកចំទស់បុត្រនេះខុកហៅចុះ ខ្ញុំនឹងសូត្រឲ្យស្តាប់តែមាត់ខេ ហើយខៀវសុង៑ក៏ស្វាធ្យាដោយបញ្ញាក់ដែរដែលចាំបាន ត្រូវឃ្លាត្រប់អក្សរដែលតែង៑កង៑សំបុត្រនោះ គ្មានរបៀលសុកង៑ឯណាទីមួយឡើយ ។

អៀវស៊ីវឡូវឮដូច្នោះក៏ដឹងថា ខៀវសុង៑ធ្លាតចាំមែន ទើបថាអ្នកនេះមានប្រាជ្ញាធ្លៀវធ្លាតមែន បានមើលសំបុត្រឲទស់យើង៑តែ ១ ចប់ក៏ចាំបានគ្មានក្លេចសោះ ទឹង៑កអ្នកឯណាឲ្យស្មើនឹង៑អ្នកកម្រណាស់ ខៀវសុង៑តំនាប់អៀវស៊ីវហើយថា អ្នកចូលនៅឲ្យសុខសម្រាន្តចុះ យើង៑សុំលាវិលទៅស្រុកសិនហើយ អៀវស៊ីវថា អ្នកកុំអាលរួសរាន់ប្រញាប់វិលទៅស្រុកចូរបង្អង់នៅសិន យើង៑នឹង៑ចូលទៅដំរាបមហាឧបរាជឲ្យនាំអ្នកចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេឲ្យបានជ្រាប ខៀវសុង៑មានសេចក្តីត្រេកអរឧទ្ទូលតាក្សហើយ ក៏តំនាប់លាទៅទីសំណាក់ ។

អៀវស៊ីវក៏ចូលទៅដំរាបចូធ្លូជាមហាឧបរាជថា ហេតុអ្វីអ៊ុតញ៉ាំមិញនេះ បានជាមហាឧបរាជទឹង៑នឹង៑ខៀវសុង៑ជាខ្លាំង ។ ចូធ្លូថា វាចរចាត្រហើនមើលងាយមិនមានកោតក្រែង៑យើង៑ បានជាយើង៑ទឹង៑ ។ អៀវស៊ីវថា កាលត្រាយីអេង៑ហេតុម្តេចលោកចេះអត់ឯង តែត្រឹមខៀវសុង៑ប៉ុណ្ណេះតួឬលោកអត់មិនបាន ? ។ ចូធ្លូថា ឯយីអេង៑នោះជាមនុស្សមានសតិបញ្ញាប្រាកដណាស់ បានជាយើង៑ត្រាំអត់ស្ងួតចិត្តព្រោះខ្លាចសេចក្តីគរហានិន្ទ ឯខៀវសុង៑នេះ វាជាមនុស្សប្លែអាក្រក់គ្មានសតិបញ្ញាសោះ ទឹង៑

អត់ឲ្យវាបានប្រយោជន៍អ្វី ។ គៀវស៊ុវថា មហាឧបាសកកុំគាលប្រមាថ
ខៀវសុងនេះ ខ្ញុំបាទឃើញថាជាមនុស្សមានសតិបញ្ញាខ្លាតណាស់ អំ-
បាញ់មិញនេះ ខ្ញុំបាទបានយកសំបុត្រដែលលោកតែងទុកនោះ ឲ្យខៀវ-
សុងមើលតែ ១ បន្តិចទាំងបានទាំងអស់ ជាមនុស្សឆ្លៀវឆ្លាតណាស់ ហើយ
ថា សំបុត្រនោះជាពាក្យបុកណា កូនក្មេងក្នុងស្រុកសែឈួនសូត្រលេង
គ្រប់ផ្ទះ ។ ចូរឆ្ងល់ដូច្នោះក៏ខឹងណាស់ថា ពាក្យនេះអង្គីមនុស្សតែដើមនឹង
មកប្រាប់យើងគឺទេ បើយើងតែងសំបុត្រនេះ ក៏ត្រូវគ្នានឹងពាក្យបុកណា
ហើយក៏នឹងយកទុកប្រយោជន៍អ្វី ទើបឲ្យយកសំបុត្រនោះមកហែកចោល
ជាក់ក្នុងភ្លើងឆេះអស់ទៅ ។

គៀវស៊ុវថា ឯខៀវសុងនោះជាមនុស្សស្រុកក្រៅ សូមឲ្យមហាឧប-
កជនាំចូលទៅគាល់ព្រះចៅហៀនតេ ឲ្យបានឃើញក្នុងកជឋានដ៏ប្រកប
ទៅដោយរបៀបដ៏រុងរឿង ដើម្បីកុំឲ្យសត្រូវមើលងាយ មានតែសេចក្តី
កោតក្រែងអានុភាពរបស់លោក ។ ចូរឆ្លើយថា ខៀវសុងជាពួកស្រុកក្រៅ
ទើងត្រូវការអ្វីនាំចូលទៅគាល់នោះ បើដូច្នោះគេលត្រឹកស្អែក យើងនឹង
នាំគាហានចូលទៅហាត់នៅទីស្នាក់កណ្តាលវាល ឲ្យអ្នកនាំខៀវសុងទៅ
មើលឲ្យឃើញរបៀបច្បាំងរបស់យើងចុះ ដើម្បីកងនឹងបាននាំយកទៅផ្សាយ
ក្នុងស្រុកសែឈួនឲ្យបានប្រាកដល្អឥតទៅ ហើយយើងនឹងលើកគាហាន
ទៅវាយយកស្រុកគាំងតាំង បើបានសមប្រកបតាមគំនិតដែលគិតទុក

ហើយ កំពៅក៏យកយកស្រុកសែឈួនទៀត ។

អៀវស៊ុវ ខ្លួលតាក្សបួនូហើយ កំតំនាប់លាចេញពៅលំនៅវិញ លុះត្រឹកឡើង អៀវស៊ុវកំនាំទៀវសុងចេញពៅមើល ពួកគាហានហាត់ក្លេងអាវុធ ។ ខណៈនោះ បួនូក៏ជ្រើសរើសកគាហានដែលមានថ្វីដៃហៅថាគាហានខ្លា ឲ្យចេញពៅចំនួន ៥ ម៉ឺនគាត់ សុទ្ធតែតែងកួរគាត់អាវពាក់គ្រោះដែះសេះកាន់ដាវលំតែងមានឆ្នូន. ស្តាំតាមក្បួន បួលប្រយុទ្ធហាត់ដៃគ្នាជាពន្ធឹកសន្ធឹកសន្ធាប់ ។

បួនូឃើញទៀវសុងដាកមុខមើលគាហានតាំងពួន ក៏ឲ្យហៅបួលពោជត ហើយសួរថា គាហានក្នុងស្រុកសែឈួនដូចគាហានរបស់យើងនេះដែរឬទេ ? ។ ទៀវសុងដាកបតថា ឯស្រុកសែឈួននោះ ទឹងបានបង្ហាត់មនុស្សឲ្យចុះរបៀបជាគាហាន ដើម្បីទឹងលើកពៅសង្កត់សង្កិនយកស្រុកណាកំទេ ខ្ញុំបាទមិនធ្លាប់ឃើញ ឯប្រពៃណីស្រុកសែឈួននោះ បើទឹងប្រាបប្រាមសឹកសត្រូវដែលបង្កើតឡើង ជាចំរូងចំពាសនោះ ត្រូវរម្ងាប់ដោយយកតាក្សស័ត្សសុចរិត ជាគោលបាំកពៅរម្ងាប់ ។

បួនូឮដូច្នោះក៏ទឹងណាស់ថា ក្នុងទេត្រទ័ណ្ឌសីមានេះ យើងសំឡឹងមើលមិនឃើញមាននរណាមានគាហានច្រើនដូចយើង បណ្តាអាណាខែត្រតំងពួន ដែលទឹងរឹងទំងមិនចំណុះចុះបួលមកគំនាប់ដល់យើងទេក៏ចុបមាដូចដុំស្មៅ បើយើងទឹងលើកគាហានពៅអន្ទឹងណាក៏ទឹងជាន់សង្កត់

ឲ្យល្អិតខ្លួចខ្លីជាងដំឆូលី ខ្ញុំណាក៏មិនអាចតស៊ូជាមួយយើងបាន បើ
ឯងវាយយកស្រុកណាក៏បានស្រុកនោះ អ្នកឯងដឹងឬទេ ? ។ ខៀវសុង
ឆ្លើយថា ដែលមហាឧបរាជឯងលើកកងទ័ពទៅច្បាបក្រាមស្រុកណាទៅ
ទិសឯណា ក៏មានល្បីគេនិយាយរន្ធឺឮទាំងផែនដីថា លោកមានវិជ្ជាចំ-
ណានកងការសង្គ្រាមណាស់ ដូចកាលគ្រាស្រុកចាក់អៀនចម្បាំងលីវចាំ
ស្រុកអ៊ូនសៀ ចម្បាំងខៀវស៊ីវ ស្រុកកាំងតាំងចម្បាំងដីវយី ដំបន់ភ្លុងឆ
ប្រទះគ្នាទឹងគួនអ៊ូ តយកតុងគួន កាត់ពុកមាត់ពុកចង្កា ដោះក្រឹសចោល
គ្រាមួយជា ៤ គ្រាមកហើយ ខ្ញុំចាំកំដឹងថា ទឹងរកអ្នកឯណាស្មើទឹង
លោកគ្មាន ។

ចូរឮដូច្នោះកំខឹងប្រឡាតខ្លាំងណាស់ ស្រែកផេះថា អាចោរឥត
ភ្លូជឥតត្រកូល ក៏ហ៊ានមកវាយលើកចរចាមើលងាយអញដូច្នេះ ឥឡូវកោត
ក្រែងអញតិចសោះ ហើយបង្គាប់ឲ្យចាហានយកខ្លួនខៀវសុង ទៅ
សម្លាប់ ។ អៀវស៊ីវតំនាប់ហើយឃាត់ថា ដែលខៀវសុងចរចាជាការ
មាត់ងាយប្រមាថជលំមហាឧបរាជ ហើយទឹងឲ្យយកខ្លួនទៅសម្លាប់នោះ
ក៏គួរហើយ តែថាខៀវសុងនោះជាកេរ្តិ៍មកពីក្រោ បើលោកមិនអត់
ទោសទឹងសម្លាប់ចេញហើយ កិត្តិស័ព្ទនោះក៏ទឹងល្បីឮទៅគ្រប់ស្រុក បើ
ហានអ្នកឯណាទឹងចង់មករកលោក ក៏ឲ្យទឹករន្ធឺសខ្លាចពុំអាចមកបាន ។

ប្អូនឮដូច្នោះក៏យល់ឃើញផង តែខោសនោះនៅមិនសោយ ទើប
បង្គាប់ឲ្យខាហានយកដំបងដេញយាខៀវសុងតែចេញទៅ ខៀវសុងក៏
តែចេញទៅផុត ហើយចាត់ចែងរៀបដំណើរនឹងវិលទៅវិញ ក៏ស្រួត
ចេញទៅជាប្រញាប់ពាំងយប់ថ្ងៃ ហើយគិតថា ខ្លួនអញបើនឹងយក
ស្រុកសៃឈួនទៅឲ្យប្អូន គួរឬទាមកធ្វើអាក្រក់នឹងអញវិញដូច្នេះ កាល
អញនឹងមកនោះបានឧយាយុកនឹងខ្លៅជៀងជាខន់ គ្រានេះក៏មិនសម
ដូចពាក្យថា នឹងត្រឡប់ទៅវិញទេមិនបានការ មនុស្សពាំងតួងតែនឹង
តហោនិន្ទាសើចចំអកលេងឲ្យឈឺចិត្ត បើគិតទុំសក្តី ត្រូវក្តី ត្រូវតែអញ
ចូលទៅរកខ្លៅពីឯស្រុកកេងជីវុះ ដើម្បីនឹងស្តាប់មើលឡែបាយខ្លៅ.
ពីតើនឹងជាមនុស្សល្អឬអាក្រក់ប្រការម្តេច នឹងបានគិតប្រែប្រួលតទៅខៀវ
ខៀវសុងពិចារណារិះគិតដូច្នេះ ហើយក៏បរសេះនាំខាហានស្រួតតម្រង់
ទៅស្រុកកេងជីវ ទទួលខ្លួនបេងជីនដំណឹងក៏ប្រើជូឡុង នាំខាហាន ៩០០
ចេញទៅទទួល លុះជូឡុងចេញទៅប្រទះក៏បង្អើនខ្លួនគំនាប់ហើយសួរ
ថា អ្នកនេះឬឈ្មោះខៀវសុងនៅស្រុកសៃឈួន ? ។ ខៀវសុងក៏គំនាប់
គួរសមមកវិញហើយសួរថា អ្នកនេះឈ្មោះជូឡុងទោះឬ ? ។ ជូឡុងក៏
ឆ្លើយទទួលថា ខ្ញុំនេះហើយឈ្មោះជូឡុង ពាំងសងខាងក៏នាំគ្នាចុះពី
លើសេះ ។

ជូឡុងនិយាយថា ខ្លៅពីជានាយខ្ញុំដឹងដំណឹងថា អ្នកទស្សាហ៍មក

ពីស្រុកឆ្វាយ មុខជាអ្នកចាំដ៏អស់គ្នាបានសេចក្តីខឿយហត់លំបាកណាស់ ទើបប្រើខ្ញុំឲ្យនាំរបស់សម្រាប់បរិភោគយកមកចំរុងទុលអ្នក ហើយសុំឲ្យឈប់ស្នាក់សំរាកកម្លាំងបរិភោគអាហារនេះ ឲ្យរួចដោយស្រួលសប្បាយហើយសឹមចូលទៅ ។ ខៀវសុងឮដូច្នោះ ក៏ត្រេកអរណាស់ឈប់សំរាកនៅទីនោះ ។ ជូឡុងក៏ឲ្យគាហានរៀបតុលៀងអាហារតាមប្រពៃណី ។ ខៀវសុងមកតំរិះក្នុងចិត្តថា ខ្លៅពីនេះជាមនុស្សមានអជ្ឈាស្រ័យយកក់ពាក់កាប់អានអ្នកមានសតិបញ្ញាពិតដូចពាក្យគេថាមែន ។ លុះបរិភោគរួចហើយ ជូឡុងក៏នាំខៀវសុងចូលទៅដល់ទីសំណាក់សំរាប់ភ្ញៀវ ។ គួនអ៊ូនាំគាហាន ១០០ នាក់មកចាំចរុងទុល លុះឃើញខៀវសុងចូលទៅដល់ក៏ឲ្យកាងគន់ស្តារនឹងឃ្មោះចរុងទុល ហើយចូលទៅតំនាប់ថា ខ្លៅពីចង់ឮដឹងថាអ្នកមកពីស្រុកឆ្វាយ ទើបប្រើខ្ញុំចេញមកចាត់ចែងទីសំណាក់ឲ្យទៅតាមសប្បាយ ខៀវសុងក៏ឈប់នៅទីនោះមួយយប់ ។

លុះព្រឹកឡើង គួនអ៊ូនឹងជូឡុងក៏នាំខៀវសុងទៅតាមផ្លូវបម្លាយផ្លូវប្រវែងប្រហែល ៩០ សិន (២ គ.ម) ទៀត ក៏ប្រទះនឹងខ្លៅពីហើយនឹងខ្ញុងចេងចាំងចង់ លើកគាហានចេញមកចរុងទុលតំនាប់ខៀវសុងហើយថា ពីដើមក៏ធ្លាប់ឮគេសរសើរដល់អ្នកជារឿយថាមានតម្រិះប្រាជ្ញាច្រើន លុះនឹងទៅសន្ទនាដោយមេត្រីដើម្បីឲ្យស្គាល់កាប់អានក៏ពុំបាន ព្រោះផ្លូវទៅមកឆ្ងាយជាប់អាល័យ អ្នកបានមកដល់ទីនេះ ក៏ជាបុញ្ញាភិនិវេសរបស់យើងច្រើន

ណាស់ សូមអញ្ជើញអ្នកចូលទៅក្នុងស្រុកកេងដ៏វែងនេះ ដើម្បីនឹងជាន
សន្ទនាជាបដិសណ្ឋារៈគ្រោះត្រូវនឹងប្រថ្នា ។បមាដូចអ្នកយកទឹកមកឲ្យ
ផឹកនៅវេលាដែលកំពុងស្រេកឲ្យជាត់ក្រវល់ក្រវាយ ខ្មៅតិនិយាយហើយ
ក៏នាំខ្មៀវសុងចូលទៅក្នុងស្រុកកេងដ៏វែង ហើយចាត់ចែងទីដ៏សមគួរឲ្យ
ខ្មៀវសុងអង្គុយ រួចរៀបតុលៀងអាហារបរិភោគជាមួយ និយាយលេង
តាមប្រក្រតី ។

ខ្មៀវសុងឮខ្មៅតិប្រាប់តែអំពីសេចក្តីដូចនេះ មិនបាននិយាយដល់
កិច្ចការស្រុកទេស ដូច្នោះក៏ក្លែងសួរថា លោកមកនៅជាធំក្នុងស្រុកកេង-
ដ៏វែងនេះ មានអាណាខែត្រឡើងជាចំណុះប៉ុន្មានខែត្រ ។ ខុងបេងក៏ដែង
ឆ្លើយឡើងថា ស្រុកកេងដ៏វែងនេះ នាយយើងខ្ញុំស៊ុនគួនហៅហ្នាយស្រុក
កាំងតាំងនៅជាបណ្តោះអាសន្នទេ មិនមែនជាកម្មសិទ្ធិចំពោះខ្លួនកាល
ណា ព្រោះនាយយើងជាប្អូនថ្លៃស៊ុនគួន គេចាល់ហើយក៏ឲ្យនៅទៅ
សព្វថ្ងៃនេះក៏ចេះតែមកតឿនការយកវិញ នាំឲ្យរំខានក្នុងចិត្តមិនដឹងដែល
នឹងថ្លែប្រួលយ៉ាំងណាឡើយ ។ ខ្មៀវសុងថា ស្រុកកាំងតាំងនោះមានអា-
ណាខែត្រឡើង ខែត្រឯកដល់ ៦ មណ្ឌល ខែត្រត្រីកំមានដល់ ៨១ ដំបន់
សារតើចំណីអាហារកើបបិណ្ឌបាតប្រកាន់ ទាំងមនុស្សចំណុះស្រុកក៏ច្រើន
ទៅមិនខាន់តេញចិត្តខ្មៀតឬ តែស្រុកកេងដ៏វែងប៉ុណ្ណោះនៅតាមមកតឿនការ
ខ្មៀត ។ ជាំងឆងថា នាយយើងនេះជាតួជព្រះរាជវង្សព្រះចៅហៀនតេ

ក្រុកដ តែត្រឹមស្រុកមួយកំរេតៅមិនបានទំនិតតាំងខ្លួនក៏មិនបាន ត្រូវប់
ទៅខ្លីស្រុកនេតៅ ឲ្យសត្រូវចង្អាប់ប្រើដូច្នេះមិនគួរសោះឡើយ ។

ខ្មៅពីថា អ្នកតាំងពីរកុំនិយាយឡើយ ពាសនារបស់ខ្ញុំហើយ តាម
តែបុណ្យចុះ តែចុំណ្លេះកំលួមសុខហើយ ខ្ញុំមិនគិតនឹងប្រុងធ្វើទេ
លើសពាសនាទេ ។ ខ្មៅសុងថា ខ្លួនលោកក៏ជាពួជព្រះវង្សព្រះចៅ-
ហៀនតេ មនុស្សតាំងពួងក៏សរសើរ តាំងមានសេចក្តីស្រឡាញ់កំច្រើន
កុំចាប់តែទំនងដណ្តើមយកស្រុកគេដ៏វាចុំណ្លេះឡើយ សូម្បីពាសនាលោក
ទំនងខ្លួលតាំងខ្លួនជាជំនួសព្រះចៅហៀនតេផង ក៏គ្មាននរណាទំនងតហា
និខ្លាថាម្តេចបាន ។ ខ្មៅពីរលើកដៃឡើងគំនាប់ហើយហាមឃាត់ថា ចូរ
ឲ្យអ្នកមានសេចក្តីអាណិតខ្ញុំចុះ កុំថាដូច្នេះទៀតឡើយ លើសពាសនា
ណាស់មិនសមគួរទេ ខ្មៅពីក្តែងតាំនិយាយតែពីសេចក្តីដរៃដល់ ៣ ថ្ងៃ
ហើយទៀសុងគំនាប់លាទំនងទៅស្រុកសែឈួនវិញ ខ្មៅពីក៏នាំភាហាន
ចេញដួនដំណើរទៅដល់ត្រើស្រុក ហើយក៏ឲ្យរៀបតុលៀងអាហារ ។

ខ្មៅពីនិយាយថា អ្នកមកដល់ស្រុកគេនដ៏វានេះ ខ្ញុំបានឃាត់អ្នកឲ្យ
នៅលេងដល់ ៣ ថ្ងៃ ចាន្តែនាគ្នាក៏បានសេចក្តីសប្បាយ តែឡូវអ្នក
ចរចាលាកលាយើងទៅហើយ កាលណាឡើយទំនងបានជួបយើញមុខគ្នា
ទៀត ថាហើយខ្មៅពីក៏យំខ្សឹកខ្សួល ខ្មៅសុងឃើញដូច្នោះក៏ឲ្យទឹក
អាណិតអនាថខ្មៅពីពន់ប្រមាណ ទើបនិយាយថា ខ្លួនខ្ញុំសព្វថ្ងៃនេះក៏

គិតថាទីឆង់មកនៅជាមួយទីឆ៍លោកឲ្យលោកប្រើប្រាស់ តែថានៅមិនមានមានតុកាសត្រូវកលការ មួយយ៉ាងទៀត បើលោកទីឆ៍តាំងនៅក្នុងស្រុកកេងដ៏វែងនេះ កំយើញថាមិនជាទីមាំមួនបានឡើយ ព្រោះមានតែឯកើតនោះស៊ុមគ្នាទើកំជាសត្រូវម្ខាង មានតែឯដើងសោត បូធ្លាកំបាំងតែទីឆ៍មកញ៉ាញ៉ី កាលណាឡើយលោកទីឆ៍បាននសេចក្តីសុខក្សេមក្សាន្ត ទុបមាដូចលោកបានមកនៅកណ្តាលក្នុងក្តីឆ៍ ខ្លៅតាថា យើងកំដឹងខ្លួនថាដែលនៅក្នុងស្រុកកេងដ៏វែងនេះអស់មានសេចក្តីសប្បាយហើយ តែថា តាល់តំនិតហើយមិនដឹងធ្វើម្តេច សព្វថ្ងៃទំសម្តីងមើលកំមិនយើញមានតែកន្ទែងឯណា គួនឹងយកជាទីអាស្រ័យបាន ។ ខ្មៅសុងថា ឯស្រុកសែឈួននោះ ភូមិហានកំធំទូលាយមនុស្សច្នាកំច្រើន ស្រូវអង្គរចំណីត្រីសាច់កំបរិបូណ៌ អ្នកដែលមានសតិបញ្ញាតាំងពួង កំកាប់អានស្រឡាញ់លោកដោយឮថាជាអ្នកមានអញ្ញាស្រ័យមេត្រីកាប់អានដោយស្មោះត្រង់ ថើទីឆ៍លើកទ័ពទៅកាយយកស្រុកសែឈួននោះ តែចង្អុលដៃមួយទៅកំគងីបានដោយងាយ មិនត្រូយលំបាកដល់សេនាពាហនតាំងពួង មុខជាទីឆ៍តាំងនៅជាសុខក្នុងស្រុកនោះបាន ។

ខ្លៅតាថា ខ្លៅជឿនចៅហ្វាយស្រុកសែឈួននោះ កំជាពូជត្រះពាជវង្សត្រះចៅហៀនតេដូចខ្លួនឯ៎ ហើយកំបានចំនុកបំរុងអាណាប្រជាពុកស្តេមកតាំដើម អ្នកដទៃប្តីទីឆ៍អាចទៅធ្វើអន្តរាយបាន ។ ខ្មៅសុងថា

លោកមានប្រសាសន៍នោះក៏គួរមែន ខ្ញុំបាទក៏មិនមែនជាមនុស្សលក់ម្ចាស់
ទេ តែថាបានមកជួបប្រទះនឹងលោក ហើយក៏មានសេចក្តីអាណិត
ស្រឡាញ់លោកណាស់ ទើបនាំពត៌មាននេះដោយការពាក់ព្រៀងឲ្យលោក
ជ្រាប ព្រោះខ្លៅជៀងនោះជាមនុស្សលោភឥតខ្នាស សូម្បីជាពួជព្រះពជ
វង្សក៏មែន តែមិនមានសតិបញ្ញាសោះ ទាំងមិនចេះបំភ្លឺមនុស្សអ្នកមាន
តម្រិះច្រើនថា មួយទៀតទៀរឡៅខាងដើងក៏ចង់តែនឹងមកធ្វើអន្តរាយ
មនុស្សទាំងឡាយក៏ច្រើនច្រើមច្រើនតែនឹងប្រែចិត្តប្រែគំនិតទៅជាយ៉ាងខ្លះ ។
បើយ៉ាងដូចលោកដូច្នេះ លើកតែទៅមុខជាអ្នកស្រុកនោះនឹងមានសេចក្តី
គ្រែកអរ ខ្លួចជា គន់នឹងចូលមកខាងលោកជាច្រើន ដែលខ្ញុំបាទមកគ្រា
នេះ គឺច្រើនឹងយកស្រុកសែឈ្នួនទៅឲ្យចួនដូ តែយើញចួនដូអាសត្រូវពាជ
សម្បត្តិនោះ ព្រោះហើនក្តេងក្តាងកាន់ខ្លួនថា ល្អលើសគេ លុបលាងមនុស្ស
ដែលមានសតិបញ្ញាចេញអស់ នោះខ្ញុំបាទនឹងលើកស្រុឲ្យទៅក៏មិនជាការ
មានប្រយោជន៍ ឲ្យជាខ្ញុំបាទគេចមកអោកលោក ច្រើនឹងជំពប់សេចក្តី
ទាំងនេះ សុំឲ្យលោកវិះគិតកែវែរម៉ែលតាមយោបល់ចុះ បើបានស្រុក
សែឈ្នួនហើយ ក៏នឹងបានគិតរកទីយកគ្រាទៀត មុខជានឹងបានជាជំ
ជួបរសេចក្តីច្រើនថា បើលោកគេញចិត្តត្រូវការនឹងយកស្រុកសែឈ្នួនជា
ច្រើកដកាលណា ខ្ញុំបាទនឹងខ្លួលជាធ្លុះចាត់ការខាងក្នុងមិនឲ្យមានទាក់
ទាម តែឥឡូវនេះនៅមិនទាន់ដឹងជាចិត្តលោកនឹងចង់គិតការប្រការម្តេច ។

ខ្លៅពីថា អ្នកនិយាយមកនេះកំជាទីពេញចិត្តខ្ញុំណាស់ តែថា ខ្ញុំចាស់តំនិតគ្រោះជ្រួតខ្លៅដៀងជាសែជាមួយគ្នា បើនឹងលើកតលយោងគាថាយកតែម្ខាង មនុស្សផងទាំងពួងនឹងមិនទាំគ្នានហានិភ្លាទេឬ ? ។ ខ្លៀសុងថា ធម្មតាកើតមកជាប្រុស កាលនឹងចង់ប្រថ្នាធ្វើដំនោះ លុះក្រឡេកទៅឃើញទីចង្ការនុកាសល្អហើយ កំត្រូវតែធ្វើតាមការ ដែលរកចិត្តគំតមិនជាចំស្រេចគ្រោះដូច្នេះដូច្នោះ ចេះតែខ្លាចគេនិន្ទា យូរទៅចេញបានប្រយោជន៍នោះទៅគេឯណា យើងកំត្រូវអសារសោះទេ លុះនឹងគំតតែធ្វើជាក្រោយកំមានតែសេចក្តីលំបាក ។ ខ្លៅពីថា អ្នកមានចិត្តមេត្តាតឆ្យលំយើងសព្វគ្រប់ដូច្នេះជាគុណអនេកណាស់ តែថាស្រុកសែឈ្នួននេះយើងកំដឹងហើយ ជាផ្លូវជាចំស្រយាលឆ្ងាយគ្រោះថ្នាលជាងស្មើនឹងនឹងកុំខ្ចល់ពាបជាច្រើនអន្ទឹ នឹងដើរទៅមកកំលំបាកណាស់ សេះឬណាជាពាហនៈនឹងទៅមកកំកម្រ បើនឹងគំតធ្វើការនោះ តើនឹងត្រូវកែប្រែប្រការដូចម្តេចទើបស្រួល ។

ខ្លៀសុងកំលូកតាមចង្ការទ្រូងក្តងអាវ ចាញយកផែនទីស្រុកសែឈ្នួនដូនៅខ្លៅពីហើយថា លោកមិនចូលចិត្តផ្លូវដែលនឹងទៅមកក្នុងដំចង់ស្រុកសែឈ្នួននោះ កំចូរពិគ្រោះមើលតាមផែនទីនេះចុះ ពោះនឹងមានកំតងំតិចឬច្រកក្តុ ហើយនឹងកន្ទែងដែលមានត្រីសាច់សម្រាងំជាអាហារបរិភោគនៅត្រង់អន្ទឹឯណា នឹងជាចំស្បៀងអាហារឬមានចរំចូលិ

ប្រការម្តេច កំមានស្រែចសព្វគ្រប់ទៅក្នុងដែនខ័ណ្ឌនេះទាំងអស់ ហើយ
ក្នុងស្រុកសែឈួននោះ គឿនស៊ីឡាញ់របស់ខ្ញុំចុងមាន ២ នាក់ ម្នាក់
ឈ្មោះហួត-ចេង ម្នាក់ឈ្មោះចេងតឹត ទាំងពីរនាក់នេះកំណាចខ្លុកចិត្តបាន
ខ្ញុំចុងនឹងទៅនិយាយកិតដំមិនចប់ចាស់ចែង ប៉ែហួត-ចេង ចេងតឹតមក
ដល់លោកហើយ កំចូលប្រឹក្សាគ្រោះគ្នាចុះ កុំតែតសង្ឃឹយអ្នកឡើយ ។
ឡៅតាលើកដៃឡើងតំនាចហើយថា ដែលអ្នកបានប្រាប់តឡាស់ក្នុងកល
កិច្ចការណែនាំឲ្យខ្ញុំបានជឹងដូច្នេះ គុណអ្នកមិនមានខ្ចីចុង ប៉ែសម្រេច
រាជការកាលណា ខ្ញុំនឹងសងគុណអ្នកឲ្យដល់ខ្លួន ។ ទៀសុងថា ខ្លួន
ខ្ញុំចុងនេះ មានសេចក្តីប្រុងប្រាំនឹងរកចៅហ្វាយនាយមានសេចក្តីល្អ មាន
ចិត្តសុចរិតជឹងអធ្យាស្រ័យកំបានដូចចិត្តហើយ ទោះប៉ែខ្ញុំចុងនឹងជឹងយល់
ការអ្វីជាការកំជ្រុងកំមិនគួរនឹងលាក់ពុត ត្រូវតែជំរាបឲ្យអស់ ដែលនឹង
តាំងចិត្តឲ្យលោកតបស្នងសងគុណវិញនោះគ្មានសោះឡើយ លុះនិ-
យាយហើយក៏តំនាច់លាចេញទៅ ទុងបេងកំប្រគួនអ្នកនាំគាហានជូនដំ-
ណើរទៅ ចម្ងាយផ្លូវ ១០០ សិន (៤ គ.ម.) ។ ហើយក៏ត្រឡប់
វិលមកវិញ ។

លុះទៀសុងទៅដល់ស្រុកសែឈួនហើយ កំគេចចូលទៅរកហួត-
ចេងជាគឿនស៊ីឡាញ់ស្និទ្ធនឹងគ្នាមកតាំដើម ហើកកំណាំនារឿងកំវឲ្យ
ស្តាប់តាមសេចក្តីដែលចូរធ្លូវអក្រក់មាក់ងាយគ្រប់ប្រការ ហើយថា ៦

ចិត្តបួងបួងនោះ បើយើងឯកល់គ្នាទីឆង់ទៅធ្វើខ្លួនឱ្យបានសេចក្តីសុខសម្រាន្ត
នោះគង់តែទីឆង់មានសេចក្តីទុក្ខទៅវិញ មិនគួរទីឆង់គិតយកស្រុកសែឈួន
ទៅឱ្យសោះឡើយ ឥឡូវខ្ញុំលើកស្រុកនេះឱ្យឡៅពីទៅហើយ ទើប
ត្រឡប់មកឱ្យដំណឹងអ្នក តើទីឆង់យល់យើញប្រការម្តេច ? ។

ហួតបេងឮដូច្នោះ កំមានចិត្តត្រេកអរណាស់ថា ពីដើមខ្ញុំកំគិតថា
ទីឆង់យកខ្លួនទៅបួលជ្រកកោនពីឆបុណ្យឡៅពីដែរ ព្រោះយើញថាឡៅ
ដៀងនេះជាមនុស្សមិនកើតជាការអ្វីសោះ ឥឡូវអ្នកស្ម័គ្រទៅទៅទីឆង់ឡៅ.
ពី លើកយកស្រុកសែឈួនទៅឱ្យហើយ កំដូចជាគំនិតរបស់ខ្ញុំដែលគិត
ខុកដែរ យើងទីឆង់ឆ្កៀសគ្នាថ្មី ខ្លួលបេងត៍តបួលមកដល់ក៏សួរថា អ្នក
ពាំងពីរនិយាយគ្នានេះ ខ្ញុំស្តាប់យល់ចិត្តអស់ហើយ ប្រហែលជាលើក
យកស្រុកសែឈួនទៅឱ្យអ្នកដទៃហើយ ។ ខៀវសុងថា អ្នកថានេះត្រូវ
ណាស់ តើត្រូវទីឆង់ចិត្តយើងពាំងពីរនាក់ តែថាអ្នកមានប្រាជ្ញាបួរពេយទៅ
មើលថាយើងទីឆង់លើកឱ្យអ្នកឯណា ។ បេងត៍តថា ស្រុកសែឈួននេះ
ដែលទីឆង់លើកឱ្យអ្នកដទៃនោះ យើងសំឡឹងមើលហើយ មិនមានយើញ
សមគួរដល់អ្នកឯណាសោះ យើញសមគួរតែទីឆង់លើកឱ្យឡៅពីមួយទើប
ត្រូវ ខៀវសុង ហួតបេង បេងត៍ត ៣ នាក់នេះ កំទះដៃសើចឡើងត្រម
គ្នា ហើយនិយាយគ្នាតទៅទៀត ខៀវសុងថា យើងពាំង ៣ យល់យើញ

ដូចគ្នា ហើយកុំបន្ថែមឡើយ ព្រឹកនេះខ្ញុំនឹងចូលទៅកេឡៅជៀង ខ្លាចខ្ញុំ-
យាយឲ្យខ្លៅជៀងច្រើអ្នកចាំងពីឲ្យទៅកេឡៅពីឯស្រុកកេនជាវ ហួតចេង
ចេងតែតកំពុងលួលពាក្យខៀវសុង ខៀវសុងក៏ចូលទៅកេឡៅជៀង ។ សួរថា
អ្នកទៅស្រុកក្រុងបានឃើញការមកប្រការម្តេចខ្លះ ? ។

ខៀវសុងដំណាលថា ខ្ញុំបានទៅដល់ស្រុកក្រុងនោះ ប្រាថ្នាខ្លាំង
ការពារមិនឲ្យមានភ័យអន្តរាយមកដល់ស្រុកយើង ក៏មិនសមតាមសេចក្តី
ពិត ព្រោះបក្ខជាសត្រូវពេជសម្បត្តិ មានចិត្តនោះគ្រក់ណាស់ ឯសេចក្តី
អាក្រក់របស់បក្ខនោះខ្លាំងពេកមិនអស់ឡើយ ឥឡូវមានចិត្តក់រើបគិត
ខ្លាំងប៉ងធ្វើអន្តរាយដល់ស្រុកយើងទៀត ខ្លៅជៀងថា ចើដូច្នោះយើងខ្លាំង
គិតប្រការម្តេចឲ្យបានស្រួល ។ ខៀវសុងថា ខ្ញុំបានគិតឃើញថា ខ្លៅព័
ខ្លាំងលោកជាសែងាមួយគ្នា ខណៈកាលជាយើងដុតខ្ទមបក្ខអស់ពល ៨៣
ម៉ឺននៅមាត់តាមស្រុកគាំងតាំងនោះ ខ្លៅព័ក៏ជួយធ្វើការពាល់តែសម្រេច
បក្ខខ្លាចប្រាថ្នាខ្លាំងគំនិតខ្លៅព័ជាដាច តែកាលណាចេញឈ្មោះខ្លៅព័
ក៏ជូនដេញត្រលឹងអស់ពីខ្លួន ខ្លាំងញញើតអ្វីយ៉ាំងខៀវឡប់ណ្តោះ ឯកំគង់
គោតខ្លាចខ្លៅពីណាស់ សុំឲ្យលោកវិះគិតចងមេត្រីខ្លាំងខ្លៅពីតាមប្រពៃ-
ណីទៅចុះ ដើម្បីខ្លាំងបានជួយការពារស្រុកយើង ខៀវឡខ្លាំងមិនអាចមក
ចៀតចៀងបាន ។ ខ្លៅជៀងថា ដែលអ្នកនិយាយនេះគេញជាត្រូវចិត្ត
យើងណាស់ ព្រោះយើងបានគិតចំណងទៅចងមេត្រីខ្លាំងខ្លៅពីជាយូរមក

ហើយ ឥឡូវអ្នកថាមកត្រូវនឹងចិត្តយើង តែលំបាកគិតនឹងប្រើឲ្យអ្នកឯ
ណាទៅជាប់រវើបាន ។

ខៀវសុងថា ដែលនឹងឲ្យកាន់សំបុត្រទៅដល់ឡៅពីនោះយើញមាន
តែមនុស្ស ២ នាក់ គឺហួតចេងនឹងបេងគឹត ទើបគួរនឹងប្រើឲ្យបានការពេជ
ការជាប្រាកដ ឡៅជឿងស្តាប់យល់ត្រូវនឹងចិត្ត ទើបប្រើឲ្យទៅហៅហួត
ចេង បេងគឹត ។ ចូលមកដល់ហើយក៏ប្រាប់សេចក្តីឲ្យជឿងត្រង់ប្រការ
ទើបឲ្យតែងសំបុត្រជាសេចក្តីថា ខ្ញុំបាទឡៅជឿងជាប្អូន សូមគិតមកដល់ឡៅពីជាបងដ៏
ក្រោះសព្វថ្ងៃនេះ ខ្ញុំបាទមានចិត្តនឹករលឹកដល់បងណាស់ តែថាជាផ្លូវដាច់ស្រយាលឆ្ងាយអាល័យ
កម្រដែលនឹងទៅមកបានតាមស្រួល លុះនឹងចាត់ចែងរបស់ទាំងមកគិតតាមប្រពៃណីក៏មិនមាន
ការ ដែលមិនសមគួរដោយប្រការឯណា ក៏សូមឱ្យបងអត់ទោសប្អូនទៅចុះ
ក្រោះឥឡូវនេះខៀវឡុងគិតការធំក្រៃលែង ប៉ងនឹងមកឆ្លើយតបយល់ឱនត្រដែនរបស់ខ្ញុំបាទ ។ ក៏សម្ងំរកទីតឹងពុំបាន តាមចិត្តគិត
ក្រែងថានឹងពឹងពាក់ក្រែស្រ័យតែបងមួយ ដោយបុកណាទិយាយទុកមកថា
ជង្រុកដូចខែមិនស្មើនឹងសែជាមួយគ្នាតែម្នាក់ ហេតុនេះ សូមឱ្យបងអនុ-
ក្រោះជួយដោះទុក្ខធុរៈខ្ញុំបាទ កុំឱ្យមានសេចក្តីអាប់យសដោយខៀវឡុងនោះឡើយ ។ លុះតែងសំបុត្រស្រេចហើយ ក៏ប្រគល់ឱ្យហួតចេងកាន់

ទៅដល់ឡៅតី ឲ្យបេងតំតង់ទាហាន ៥ នាក់លើកចេញទៅទៅពាក់កណ្តាលផ្លូវចាំទទួលឡៅតី ចើឡៅតីមកដល់កាលណា ក៏ឲ្យអញ្ជើញចូលមកកន្លែងស្រុកសែឈួន ។

ខណៈនោះ អ៊ុយគួនទីប្រឹក្សាទៅស្រុកសែឡង ដឹងថាឡៅជៀនទីនប្រើហួតចេងកាន់សំបុត្រទៅតំនាក់អញ្ជើញឡៅតីដូច្នោះ ទើបតត់រលះរលាំងចូលមកហើយស្រែកថា ហេតុម្តេចលោកមកជឿពាក្យសំដីឡៅសុន ទីនប្រុងលើកយកស្រុកសែឈួនចាំង ១១ មណ្ឌលទៅឲ្យអ្នកដទៃវិញដូច្នោះ ។ ឡៅសុនបានឮក៏តិយណាស់ អង្គុយទៅស្ងាំងតាំង ។ ឡៅជៀនឆ្លើយថា ហេតុម្តេចអ្នកមកថាដូច្នេះ អ្នកឯងមិនជឿឬ ? ឡៅតីនោះជាសែជាមួយទីនយើង ដែលទីនឲ្យទៅអញ្ជើញមកតាំងនេះ ក៏ប្រាថ្នាទីនឲ្យជួយការពារស្រុក ដើម្បីឲ្យទៅជាសុខតទៅបុ៉ណ្ណោះ អ្នកឯងឯណាថា ខុសឬត្រូវប្រការម្តេចបានយ៉ាថាដូច្នេះ ។

អ៊ុយគួនថា លោកមានប្រសាសន៍នោះត្រូវហើយ ព្រោះឡៅតី ទីនលោកជាសែជាមួយគ្នា តែថាឡៅតីមានប្រាថ្នាមានតំនិតខ្សែបន្ទាយច្រើនណាស់ ប្រៀបដូចភ្នាក់ញាស់ថាស័លតែតែរង្វើចិត្តនោះពោរពេញសុភាពកបាចប្រកបអស្ចារ្យ ឲ្យមនុស្សដទៃស្រឡាញ់កប់មានខ្លួនទៅយើញកិរិយាក្រៅកំសាំដៅថាល្អ ឯចិត្តឡៅតីនោះមិនមែនបរិសុទ្ធទេ ប្រការមួយទៀត ឡៅតីនោះកំមានខុនបេងទីនជាន់ជាន់ជាតិប្រឹក្សាម៉ាណាស់

ទាំងគួនអ៊ូ ខៀវហ៊ុយ ជួឡង អ៊ុយអៀន ហាងគុង សឹងជាសេនាវៃឯក ចំខ្លែកខ្លាំងតូកែខ្លែត ដែលលោកទំនងឲ្យទៅអញ្ជើញខ្លៅតាយកមកខុកក្នុងស្រុកសែឈួននេះ តាលណាខ្លៅតាទឹងជាក់ខ្លួនឲ្យតូច ដូចគេយកកាដ.សាហ៍មកកន្ទុះទំនងបានឬ? មួយទៀតស្រុកសែឈួននេះ បើទំនងមានទៅហ្វាយស្រុក២នាក់ កំដូចជាវាញាក់ចុះប្រែងក្នុងកេងជាមួយគ្នាទំនងទៅម្តេចបាន ខ្ញុំស្មានថាប្រហែលខៀវសុងនេះបានវះចូលទៅស្រុកគេងជាខែយាយឲ្យកតិកាសញ្ញាទំនងខ្លៅតា ទើបប្រឡៀសមកលួងបញ្ជោតលោកឲ្យយល់តាម ដើម្បីទំនងបង្ខូចស្រុកលើកខុកឲ្យអ្នកដទៃ សូមឲ្យលោកវៀសវៃរាប់ខ្លួនខៀវសុងសម្លាប់ចោលទើបគួរសម ឯស្រុកសែឈួននេះប្រៀបដូចកន្លះដីធំទៅទំនងមាំណាស់ លោកកុំគាលប្រឡាសប្រឡោតធោតតាមសំដីគេញុះញង់នោះឡើយ គ្មានណាឯងហើយ ទំនងមកធ្វើអន្តរាយបានទេ ត្រូវយើងនិតនិតគ្នេរប្រមូលពលរេហ៍ឲ្យបានច្រើន ហើយលើកទៅកំចាត់ខ្លៅតាចេញទើបបាន ។

ខ្លៅតៀងធ្វើយថា អ្នកនិយាយនេះគួរហើយ តែបើបួនទំនងខៀវឡៃលើកទ័ពមកធ្វើអន្តរាយយើងវិញ តើអ្នកទំនងត្រូវនិតនិតប្រការម្តេចទៅវិញ?។ អ៊ុយគួនថា ដែលទំនងការពារបួនទំនងខៀវឡៃនោះមិនជាការក្រលុំខ្លាចទេ បើបួនទំនងខៀវឡៃលើកមក យើងទំនងរៀបចំតាហានលើកទៅក្បាតយ

ដើមផ្លូវគាត់ខុសឲ្យមាំកុំឲ្យចូលមកបាន តង់ទន់ត្រាន់ចិត្តលើកត្រឡប់ទៅឯង ស្រុកសែលឈ្នះកំទង់ទៅជាសុខតទៅ ។

ខ្លៅដៀនឮដូច្នោះធ្វើយថា ធម្មតាសឹកលើកមកដល់ប្រទល់ព្រំស្រុកជិតទន់ឯលុកយកបានហើយ ទន់ថយត្រឡប់ទៅវិញនោះកំមិនដែលឮមាន ដូចក្ងើនឆេះភោលជាលដល់ភេមចិត្តើមហើយ ទន់មិនក្តៅដល់ភ្នែកខ្លួនឬ ? បើទន់លត់ចេញទន់ស្រឿមទៅ ឲ្យក្ងើនខោះរលត់ឯងទៅវិញបានឬ ? ពាក្យនេះយើងមិនយកជាត្រូវទេ អ្នកថយចេញទៅចុះ ។ អង់លុយឃើញដូច្នោះកំឃាត់ថា លោកមកជឿស្តាប់ពាក្យខ្មៅសុងនោះ បីដូចជាយកកំយមកជាក់ខ្លួន ។

ខ្លៅដៀនថា ដែលយើងទន់ឲ្យទៅអញ្ជើញខ្លៅតីមកក្នុងគ្រានេះ កំច្បាស់ទន់ឲ្យជួយក្សាស្រុកខេស ហេតុអ្វីអ្នកមកថាមានកំយដល់ខ្លួន ។ អង់លុយថា ខ្មៅឡេនេះខោះចំជាសត្រូវទន់ឯលោក កំបីដូចជាកមរាស់ដែលកើតទៅកាយខានត្រៅ បើទន់ឃកក្រចកកែះចេញទៅកំតង់ជាជាត់ទៅវិញ ឯខ្លៅតីទន់ចូលមកតាំងខ្លួនទៅក្នុងស្រុកនោះ បីដូចកើតជួសជាប់ទៅកង់ថ្មើមកណ្តាលដើមទ្រូង កម្រដែលទន់ឯយោងផ្ទុំឲ្យជាបាន ព្រោះខ្លៅតីជាមនុស្សអកតញ្ញូមិនបានដឹងគុណអ្នកឯណា ចូរឲ្យកទៅចិញ្ចឹមរក្សាកំត្រឡប់ធ្វើការងអាចប្រទូសក៏យតទៅវិញ កាលទៅខោទន់ស៊ុនគួនសោត កំបណ្តោតយកស្រុកកេងជាវទៅខាល់តែឥឡូវ តីមិនជាមនុស្ស

ខ្ញុំគ្រាន់ទទឹងអ្នកឯណា ដែលលោកនឹងទុកចិត្តឡើងតំណែងយកមកទុកក្បាក្នុងស្រុកនេះ មុខជានឹងកើតអន្តរាយជាប្រាកដ ។

ឡើងឮដូច្នោះកំគាំហកស្រែកឲ្យអង្គុយថា ឡើងតាជាសែជាមួយនឹងយើង កាលណានឹងគិតធ្វើការដល់យើងជាបងប្អូន អ្នកឯងនិយាយខេះមិនគួរសោះ កំបង្គាប់ឲ្យការហានចាប់ខ្លួនអង្គុយនឹងអ៊ុយគួនខាំចេញទៅ ហើយប្រញាប់ឲ្យហួតចេងស្រួតកាន់សំបុត្រនោះ លុះហួតចេងទៅដល់ស្រុកកេងជីវហើយ កំចូលទៅគាំទាប់ឡើងពីរួចជូនសំបុត្រឲ្យមើលឡើងតាជីងក្នុងសេចក្តីសំបុត្រហើយ កំមានអំណរសាទរណាស់ បង្គាប់ឲ្យរៀបតុលៀងអាហារតាមប្រពៃណី ។

ខណៈកាលកំពុងសេពសុកនោះ ឡើងតាកំនិយាយថា ខ្ញុំវាសុងប្រាប់ខ្ញុំថា ឈ្មោះអ្នកជាមនុស្សមានសតិបញ្ញាចាំងចិត្តកំណត់សុចរិត ខ្ញុំកំមានសេចក្តីត្រេកអរណាស់ ឥឡូវនេះអ្នកមកដល់ បានឃើញមុខសន្ទនាគាកំជាបុញ្ញលាភប្រពៃណាស់ ។ ហួតចេងថា ខ្ញុំបាទនេះជាអាហ្នឹងតួចតាច ខ្លួនណាកំគេមិនសូវស្គាល់ក៏មានប៉ុន្មាន តែថាខ្ញុំវាសុងទៅប្រាប់ចេញនាមដល់លោក ខ្ញុំបាទកំមានអំណរ ដែលបានមកក្នុងគ្រានេះប្រាថ្នានឹងចង់ដឹងថា ខ្ញុំវាសុងមកបានថានឹងលោកនោះ លោកទៅមានសេចក្តីវិតក្កទៅឡើយឬម្តេច? ។

ខ្ញុំពិចារណាថា ខ្ញុំសព្វថ្ងៃនេះកំដាមនុស្សអកតញ្ញូណាស់ ផែនដីទាំងមូលធំណាស់ តែខ្ញុំរកទីលំនៅឲ្យដាក់ច្បាស់ជារបស់ខ្លួនមិនបាន ត្រូវខ្ចីស្រុកគេនៅជាប្រចាន់ចំពីគេអានបានមិនដឹងជាថ្ងៃណា គិតទៅគួរឲ្យឈឺផ្សាក្នុងចិត្តពន់ប្រមាណ សូម្បីតែបក្សីបក្សាវាកំគង់មានឈើជាច្រើនខ្ពស់ កើតមកជាមនុស្សមិនមានទីលំនៅហើយ កំគួរឲ្យសង្វែគវេទា ដែលខ្ញុំវិលត្រឡប់មកនិយាយថាឲ្យដឹងនោះ ខ្ញុំក៏អរណាស់ដែរ តែថាខាលំគំនិត ព្រោះជ្បាតខ្ញុំដៀងជាសែជាមួយ មិនដឹងឲ្យទៅធ្លើម្តេច ។ ហួតចេងថា ស្រុកសែឈួននោះកូមិហានកំមាំមួន បរិបូណ៌ដោយស្បៀងអាហារ ជាទីតូមជាងស្រុកដទៃ បើអ្នកឯណាមិនមានច្រកជ្រាស្មាតៅហើយ ទៅតាំងខ្លួនទៅជាធំក្នុងស្រុកនោះ កំគង់ថ្លៃត្រឡប់ទៅជារបស់អ្នកដទៃ ឥឡូវខ្ញុំដៀងឲ្យមានសំបុត្រមកដល់លោក ក៏ដូចលើកស្រុកនោះមកជូនហើយ តើជាវាសនារបស់លោកច្រកជ លោកត្រូវតំណត់គិតយកចុះ កុំបីបោះបង់ចោលស្រុកសែឈួននោះឡើយ ដែលលោកខ្វល់គិតធ្វើការតទៅខាងមុខ ខ្ញុំចាខ្វល់ជួយចំទុកបំរុងឲ្យបានសម្រេចតាមសេចក្តីប្រាថ្នា ទោះបីជាវិតខ្ញុំចាខ្វល់ស្លាប់អស់រកំមិនសោកស្តាយ ខ្ញុំតិកំលើកដៃឡើងគំនាប់ហើយថា ខ្ញុំមានអំណរគុណខ្វល់អ្នកច្រើនណាស់ ។

លុះសេតសុភហើយ ខ្ញុំរចេងក៏ចាត់ចែងខ្វល់សំណាក់ឲ្យហួតចេងនៅអាស្រ័យតាមសមគួរ ចាំងថងយើញខ្ញុំតិអង្គុយជ្រប់សញ្ជប់នៅ

ដូច្នោះ កំពូលមកនិយាយថា ឯធម្មតាអ្នកមានសតិបញ្ញាខ្លះ បើនឹងគិតធ្វើការអ្វី ខ្លះនឹងតេរភ្ញាចិត្តក្តី មិនទៅញាចិត្តក្តី កំត្រូវតែនិយាយឲ្យលេចឮច្បាស់ឡើង ដែលនឹងមកសញ្ជប់សញ្ជឹងកវែកចិត្ត តំហាក់ដូចមនុស្សគ្មានតម្រិះប្រាជ្ញា ដូចយ៉ាងពេកដូចមនុស្សមានសតិបញ្ញា នឹងមកអង្គុយកើតទុក្ខថយមុខថយក្រោយនៅដូច្នេះមិនគួរសោះ ។ ខ្លៅតាថា អ្នកនិយាយមកនោះកំត្រូវហើយ តែថា ខ្ញុំមកពីគ្រោះមើលឃើញមិនដឹងបើនឹងគិតយ៉ាងណា សតិបញ្ញាបេស់អ្នកនឹងយល់ឃើញប្រការម្តេច?។

ជាំងថងថា ឯស្រុកកេងដីវនេះ ខាងទិសឯកើត មានស៊ុនគួន ជាខេសសត្រូវនៅខាងនោះ ខាងទិសឯជើង មានបួធួជាបច្ចាមិត្រ គិតតែនឹងបៀតបៀនកល់ថ្ងៃ សព្វថ្ងៃនេះ ដូចជាគេនៅកងកណ្តាលគំនរភ្លើង ដែលឆេះកាលចូលមក ព្រោះសត្រូវនៅសៀតសិកជុំវិញខ្លួន ឯស្រុកសែ-ឈួននោះមានមនុស្សក្រីនៅច្រើនកុះករ ទ្រព្យសម្បត្តិកិបវិបូលិ ព្រមទាំងចំណីត្រីសាច់មិនចេះខ្វះខាត បើសង្ឃឹតទៅយកស្រុកនោះបាន កំនឹងមានតែសេចក្តីសុខសប្បាយ ឥឡូវខ្ញុំសុំនឹងហួតចេងទាំងពីរនាក់ចូលមកតិកាក្បាដល់លោកថានឹងខំទុកបំរុង ដូចខ្ញុំឮមកចង្អុលកំណប់ទ្រព្យមាសឲ្យហើយ ម្តេចខ្សឹយលោកមកមានវិតក្ក អង្គុយសញ្ជប់សញ្ជឹងដូច្នេះ ។

ខ្លៅតាថា ដែលខ្ញុំមានសេចក្តីវិតក្កនេះ ព្រោះឃើញថា ចួធួនឹង

ខ្ញុំធ្វើការសព្វថ្ងៃនេះដូចទឹកនឹងភ្លើង គឺបូជាភ្លើងរមែងធ្វើឲ្យអាណាប្រជា
ន្ទុកស្តែចានសេចក្តីក្តៅក្រហាយ ព្រោះចិត្តរាជមនុស្សតែងប្រទូស្តនៅឲ្យ
វិនាស ហើយខ្លឹងលើកដំកើងខ្លួន ឲ្យជាធំពេញពាសក្នុងអាណាចក្រ
មណ្ឌល ឯខ្លួនខ្ញុំដូចទឹកត្រជាក់ជាអ្នកយោគយល់អាណិតគេ បើខ្លឹងធ្វើ
ការអ្វីតែរមែងតាំងចិត្តគិតគ្នាឲ្យបានចំរើនប្រយោជន៍ស្រុក ខ្លឹងគិតឲ្យបាន
សុខអាណាប្រជាន្ទុកស្តែចាំងឡាយចាំងពួង តេជៈផល ដែលចិត្តជា
សត្យសុចរិតដូច្នេះ ទើបមកបណ្តាលឲ្យមានតម្រិះចេះតាំងខ្លួនបានដល់
ត្រឹមណេះហើយ បើខ្លឹងលះបង់សេចក្តីសត្យដែលប្រព្រឹត្តមកជាំលាប់
ដោយយើញទ្រព្យហើយខ្លឹងលះបង់សេចក្តីសត្យកាត់យកតាមចិត្តលោភ
ទុសតែផ្លូវយុត្តិធម៌ខ្លឹងធ្វើមិនបាន ។

ចាំងឥឆាថា ដែលលោកបានតាំងនៅក្នុងសេចក្តីសត្យនោះ កំជា
ទីខ្លៅតា មនុស្សស្រុះស្រួលពោលសរសើរលោកណាស់ហើយ តែថា
ផែនដីសព្វថ្ងៃនេះមិនបានជាប្រក្រតីសោះ បេះតែកើតកលិយុគផ្សេង ។
មនុស្សចាំងចាស់ចាំងក្មេងកាន់អាវុធរក្សាខ្លួនមិនមានផុតពីដៃ បើលោក
ខ្លឹងយកចិត្តល្អទៅតែខ្មែកំយើញថាមិនបាន ធម្មតាភ័យមកដល់ខ្លួនច្រើណា
ហើយ ត្រូវតែគិតការពារឲ្យរួចខ្លួនសិន ទើបពុកថាជាអ្នកមានច្រើជា ដូច
ជាស្រុកសែលួនខ្មោះ គួរតែត្រូវការខ្លាំគេជាខ្លាំអាស្រ័យចំពាំអស់ភ័យអន្ត.
រាយ បើផែនដីបានសុខសប្បាយពុំចាបាច់ណា សឹមគិតស្តង់គុណ

គេវៀរនោះតាមសមគួរឲ្យអស់សេចក្តីតវាមិន្ទានឹងមិនល្អឬ? បើលោកមិនគិតយកស្រុកសែឈួនវៀរនេះទេ អំណោះតទៅ មុខជាស្រុកនោះកំនឹងត្រឡប់ទៅជារបស់អ្នកដទៃទៀត បើនឹងទុកធ្វើការជាក្រោយ ក៏មិនឲ្យមានសម្រេចសេចក្តីច្រើនថ្នាំ នាំតែព្រួយ ការខាតតម្រិះច្រើនជាអ្នកដែលប្រុងនឹងដួយទុបត្តម្ភកំនេះទៅ ។

ឡៅតីឮដូច្នោះក៏យល់ត្រូវផង ទើបឆ្លើយថា ពាក្យដែលអ្នកលើកស្មាតែខ្ញុំនោះ គួរតែនឹងមានចាំកែទុកក្នុងផែនមាស ដើម្បីប្រដៅចិត្តព្រឹកល្ងាច ហើយក៏ឲ្យអញ្ជើញខុងបេងចូលមកប្រឹក្សាដែលនឹងចាត់ការកេណ្ឌទាហានលើកកងទ័ពចេញទៅស្រុកសែឈួន ។ ខុងបេងថា ស្រុកគេងជាសំខាន់ណាស់ នឹងលើកទាហានទៅឥឡូវនេះ ហើយនឹងទុកចិត្តការដែលនៅឯក្រោយតាំបាន ត្រូវតែកេណ្ឌមនុស្សទុកឲ្យនៅរក្សាផង ។ ឡៅតីថា លោកថានេះគួរណាស់ បើដូច្នោះ ខ្លួនខ្ញុំនឹងចាំងថង អ៊ុយ.អៀន ហង់តុង នឹងលើកទាហានទៅស្រុកសែឈួនចុះ ខ្លួនលោកនឹងគួនអ៊ូ ខៀវហ៊ុយ ជួយរក្សានៅក្បាស្រុកគេងជាវឯណោះ ខុងបេងក៏ទទួលពាក្យ ហើយឲ្យគួនអ៊ូទៅនៅស្រុកសុងយ៉ុង ខៀវហ៊ុយជាកងក្រវែលរក្សាស្រុកចាំង ៤ អន្ទៅដែលវាយបានថ្មី ឲ្យជួយរក្សាទៅនៅក្បាស្រុកតាំឡែង ។

ឡៅតីតាំងឲ្យហង់តុងជានាយទ័ពមុខ តាំងឲ្យអ៊ុយអៀនជានាយកងក្រោយ នាំទាហាន ៥ ម៉ឺនត្រៀមទុកស្រេច ចំពាំបានដោតបុស្បស្លួនឹង

លើកចេញទៅស្រុកសែឈួន ។ ខណៈនោះ លៀវហួដែលជានាយ
ចោរព្រៃនៅកំម្ទុនឃស្រុកហ៊ូតោ ក៏លើកពួកកៀនចូលមកនៅទីធំខ្លៅ-
ពី ។ ក៏ចាត់ឲ្យទៅរក្សាស្រុកសុងឃុំធំជាមួយនឹងគួនអ៊ូ លុះបានដោតបូក្ស
ល្អហើយ ខ្លៅពីក៏ឲ្យលើកកងទ័ពចេញទៅតាមផ្លូវចម្ងាយប្រហែល
២០០០ សិន (៩០គ.ម.) ទទួលជួបទីធំចេងតឹត នាំគាហានចេញមកគំ
ទាប់ហើយដំរកបថា ឥឡូវខ្លៅជឿនាយខ្ញុំប្រជាទឲ្យលើកគាហានចេញ
មកទទួលលោក ខ្លៅពីក៏មានចិត្តត្រេកអរណាស់ ប្រើចំរើកាន់សំបុត្រ
ស្រួតចូលទៅប្តឹងដល់ខ្លៅជឿនឲ្យដឹងការជាមុន ។

ខ្លៅជឿនដឹងដំណឹងហើយ ក៏ឲ្យមានសំបុត្រទៅដល់អាណាខេត្រ
តំងពួនដែលត្រូវឡើង បង្គាប់តាមរយៈផ្លូវថា បើខ្លៅពីមកដល់ដំបន់ណា
ត្រូវទទួលចាត់ការតាមគួរសម កុំឲ្យធ្វេសប្រហែលឲ្យអត់ស្បៀងអាហារ
តំរាំតែការណាបានទៅដល់ស្រុកសែឈួន ហើយក៏ឲ្យចាត់គាហាន ៣
ម៉ឺន ទីធំវេសម្រាវដំរមានសប្បាធជាំងទីធំគ្រឿងវែហើយទីធំបណ្តា-
ការគ្រឿងមាសប្រាក់តំងពួនជាច្រើន ទីធំចេញទៅទទួលខ្លៅពីនៅដំ-
បន់ជ្រាំយសៀ ។ ឥឡូវគួនឃើញខ្លៅជឿនចាត់ចេងគាហាន ទីធំចេញ
ទៅទទួលខ្លៅពីដូច្នោះ ក៏ចូលទៅទិយាយថា ខ្ញុំនខ្ញុំបានមកធ្វើការជាការ

(នៅមានត)

លោក ប៉ាយ-ឌុក ប្រែរៀបរៀង

(តមក)

៣- រឿងព្រះបាសឺហ្គាល់

កន្លងពេលនោះ មានអាអូតមួយជាអ្នកមានវ៉ៅហាត្រាន់បើ បានចូលមកជិតលោកសឺហ្គាល់ ហើយពោលថា ៖

"តើកន្លងពេលឥឡូវនេះ ពួកសត្វនៃពិភពលោកស៊ប់នៅដោយសន្តិភាពឬ? ពីមុនមកប្លែកដមែនលោក! តែឥឡូវនេះ គ្មានទេ តាំងពីពស់វែកបែបភាពដូចអារក្សមកស្ថិតនៅកន្លែងនេះ វាធ្វើឱ្យខូចរបៀបរៀបរយពិភពលោក ។

លោកសឺហ្គាល់ កិតបពៅវិញថា: "ម្តេចកើដូច្នោះ" ។

អាអូតបក្សាធ្វើយដំណបពៅវិញថា: មានពស់វែកមួយយ៉ាងធំស្ថិតនៅកន្លែងនោះ ។ រស្មីនៃព្រះចន្ទ្រពាំងប្រាំមួយធ្វើឱ្យរូបកាយពស់នោះមានពណ៌ភាពដ៏អស្ចារ្យ ចំហាយកំដៅព្រះអាទិត្យពាំងប្រាំពីរបានរចនាធ្វើឱ្យពស់នោះមានកំឡាំងពលំមានរូបធំធាត់ពន់ពេកណាស់ ពស់មិនចាំបាច់ធ្វើការអ្វីដើម្បីចិញ្ចឹមជីវិតខ្លួនក៏សោះឡើយ ។ វាបានកំហែងគំរាមយើង

ពាំងអស់គ្នាថា ត្រូវតែយើងកូនមួយថ្ងៃយកបក្សីមួយមកឲ្យធ្វើជាចំណីអាហារបស់ពួកវៀងតរៀងទៅ ដើម្បីបានសុខ ។ បើយើងមិនព្រមឲ្យបក្សានោះទេ ក៏នឹងសម្លាប់បក្សាបក្សីពាំងអស់នៅទីនេះ កុំឲ្យមានសល់ឡើយ ។ ថ្ងៃនេះយើងត្រូវយកសត្វខាងទៅឲ្យវាស៊ី យើងត្រូវមកសំដែងនៅទីនេះខ្លួវសេចក្តីសោកស្តាយអាឡោះអាល័យគ្នានឹងគ្នា ។ ព្រោះហេតុដូច្នេះបានជាយើងមានទឹកមុខស្រងូតស្រងាត់ ។

កាលនោះលោកសីហ្គាល់ មានចិត្តអាណិតអាសូរបក្សាបក្សីពាំងឡាយនោះណាស់ ហើយក៏ស្រែកថា :

" ម្តេចពួកអ្នកឯងបណ្តោយឲ្យបងប្អូនអ្នកឯងគេយកទៅសម្លាប់តាមអំពើចិត្តដូច្នេះ ម្តេចក៏មិនក្រោកឡើងតស៊ូនឹងគេសល់នោះ? " ។ មានសំឡេងបក្សីជាន់តេជាតំណាងបក្សីបក្សាពាំងឡាយស្រែកថា :

" ចាំងនឹងគេសល់វែក ! គ្មានអ្នកណាចាំងបានទេ បើចង់ចាំងនឹងគេសល់នោះ ត្រូវតែបំផ្លាញព្រះអាទិត្យ ឧន៏ព្រះចន្ទឲ្យខ្វេចខ្ចីគ្មានសល់សិន ទើបរូបគេសល់នោះមារកំណាំងថយមកនៅតាមដើមវិញ ហើយកូនឯងស្លាប់ឯងដោយឯងយូរមិនខាន " ។

លោកសីហ្គាល់ ពោលយ៉ាងខ្លាំងថា : " កុំព្រួយចិត្ត ខ្ញុំនឹងតស៊ូនឹងគេសល់វែកនេះ " ។

លោកសីហ្គាល់ គោលក្នាម ក៏ប៉ះដាយសេះតម្រង់ទៅចំតិរបក្ខ
តានោះ ។ លុះទៅដល់កំពូលភ្នំ លោកយកដួចាញ់តម្រង់ព្រះអាទិត្យ
មួយ ។ ព្រះទិត្យនោះ ដោយត្រូវដួចក៏ប្រែទៅជាដុំផ្សែងមួយមានតណាំខ្មៅ
ហើយធ្លាក់មកប្រថពី ។ លោកសីហ្គាល់ ចាញ់ព្រះអាទិត្យទីតិរួចទីបី
ទីបួន . . . . . ។

លុះព្រះអាទិត្យទីប្រាំមួយធ្លាក់ដល់ព្រះធរណី ព្រះអាទិត្យទីប្រាំពីរ
ដែលស្ថិតនៅ ក៏ស្រែកពីលើមហាមេឃមកថា:

" លោកសីហ្គាល់ ! សូមលោកឈប់ចាញ់ទៅ បើលោកចាញ់ខ្ញុំ
ចំហាយក្តៅរលត់រលាយតាំផែនដី សត្វលោកទាំងអស់នឹងស្លាប់ដោយរោ
សូម្បីតែលោកឯងក៏ស្លាប់ដែរ " ។

លោកសីហ្គាល់ ក្រោយដែលចាន់តិតត្រឹមត្រូវក៏តបទៅវិញថា:
" ល្អហើយ ខ្ញុំមិនឲ្យលោកធ្លាក់ទេ តែឲ្យលោកកុំធ្វើឲ្យសត្វអាក្រក់
ពាលខ្ជិលតែមានកំឡាំងកំហែងធំធាត់ម៉ាំមួនសោះឡើយ ។

ពួកកប្បាបក្សីទាំងឡាយ កាលបើបានក្រឡេកមើលទៅឃើញព្រះ
អាទិត្យទាំងប្រាំមួយធ្លាក់ពីលើមហាមេឃ ក៏មានចិត្តសោមនស្សពន់ពេក
ក៏ស្រែកថា:

" យើងបានរស់កនមានជីវិតហើយ យើងត្រូវទៅមើលអាសត្វ
កាឡកិណ្ណៈ ខ្ជិលតែឈ្មោនតាមដែលកាប់ផ្ទាញជីវិតគេជាអនេកប្បការ " ។

ពួកបក្សាបក្សីក៏ប្រជុំគ្នាមួយក្រុម។ ហើយហ៊ានហើរទៅលើនភាល័យ ជាដួរហែ រហូតដល់គោហាដែលជាទីលំនៅសត្វចង្រៃនោះ ។ ពួកនេះ បានឃើញពស់វែកចង់បែនខ្លួនវាជារង្វង់មូលញ៉ាំចំប្រប់ តែនៅរស់នៅ ឡើយ ។ ពួកបក្សាបក្សីទាំងឡាយ ក្រោយដែលបានប្តូរយោបល់គ្នា កំចាត់ឲ្យសត្វចាតមួយយកសារលិខិតមួយទៅជូនលោកសីហ្គាល់ :

" បើលោកមានចិត្តសប្បុរស ធ្វើឲ្យព្រះចន្ទធ្លាក់មកលើប្រថពីវេត ពស់វែកនោះលែងធ្វើបាបយើងបានហើយ " ។

លោកសីហ្គាល់ ក្រោយដែលបានអានសារលិខិតនោះ ក៏យកធ្នូ ចាញ់ឆ្ពោះទៅចំព្រះចន្ទម្តងមួយរហូតដល់ច្រាំ ។ ដល់ព្រះចន្ទទាំងច្រាំ ធ្លាក់មកលើប្រថពីហើយ ព្រះចន្ទក៏ច្រាំមួយក៏មានវាចាតិលើមហាមេឃថា:

" ឈប់ លោកសីហ្គាល់ បើលោកចាញ់ខ្ញុំទៀត ផែនប្រថពីនឹងគ្មានរស្មីសោះឡើយ ។ សត្វលោកនឹងទៅជាមានភ្នែកខ្វាក់ ហើយខ្លួនលោកក៏ដូចេះដែរ " ។

លោកសីហ្គាល់ ក៏តបទៅព្រះចន្ទវិញថា: " ល្អហើយ ខ្ញុំលែងចាញ់លោកហើយ តែត្រូវលោកលែងបំភ្លឺសត្វតំណាចអាក្រក់តាំងតាំងពីថ្ងៃនេះតទៅ " ។

លោកសីហ្គាល់ នឹងបក្សាចាតបានចុះពីលើភ្នំមកដល់ក៏ស្រាប់តែឃើញបក្សាបក្សីទាំងឡាយច្រឿងហាក្រវ ។ គ្រប់ៗគ្នាសប្បាយរីក

ភយតន់ភេតណាស់ ។ មានសត្វស្វាបត្រប់បែប-យ៉ាងហើយមានស្វាប
ត្រប់តណាមានសត្វខគទ្ធឆសត្វអាអូតជាដើម ក្រឡេកឃើញតិចម្ចាយខ្លួ
ជាវង្វេកៗ នៃលោកសីហ្គាល់ ។ ពួកសកុណាទាំងនោះកំទាំគ្នាដម្រៀប
ជាជួរហែ មានខគទ្ធឆអាអូតជាមេដឹកនាំ ហើយក៏នាំក្បាលសំដែងគារ-
វកាតទ្ធឆកតញ្ញូធម៌ជាយ៉ាងថ្លាលថ្លៅចំពោះលោកសីហ្គាល់ ។

ខគទ្ធឆអាអូតក៏ពោលពាក្យទៅកាន់លោកសីហ្គាល់ថា: យើងសុំ
សំដែងខ្លួកតញ្ញូតាជាយ៉ាងថ្លាលថ្លៅចំពោះលោក ជាបុព្វការីយ៉ាងឆ្នើម
រវស់យើង ។ ពស់វែកដ៏កាចសាហាវនោះដែលធ្វើឲ្យខ្លួចសន្តិភាព ឥឡូវ
ស្លាប់ដោយរបៀបទៅហើយ ។ យើងបានសុខក្សេក្សាន្តគ្រប់ៗ គ្នា ។
ពួកយើងមានចិត្តត្រេកអរសោទវេតទ្ធបមា ។

លោកសីហ្គាល់ក៏ដែលលើសេះ ហើយធ្វើយតបទៅវិញថា:

(ទៅមានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមទម្លាប់	នៃទេមរជាតិ
ខ្មែរធ្លាឮឃ្នាត	សក្សាពេញទី ។
ព្រោះទេមរជាតិ	ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី	ជាំងពីព្រេងនាយ ។

ប.ព

រឿងព្រេងត្រពាំងលាក់ឆ្កែល

នៅខេត្តកំពង់ឆ្នាំង

នៅឃុំស្វាយជ្រំ ស្រុកសាលាប្អៀរ ខេត្តកំពង់ឆ្នាំ មានត្រពាំងមួយ ហៅថា ត្រពាំងលាក់ឆ្កែល ។ បានជាមានឈ្មោះដូច្នេះ ព្រោះមានរឿងដំណាលតៗគ្នាមកថា ៖

មានកុមារម្នាក់ជាក្មេងកំព្រាគ្មានមាតាបិតា សាត់ព្រាត់អនាថាឥតញាតិសន្ដានគ្រប់គ្រង ។ ចៅកំព្រានោះបានទៅនៅក្តី ពឹងពាក់សំណាក់អាស្រ័យ ទឹងលោកគ្រូមេវត្ត ជាំយមាក(១) ។

លោកគ្រូតឹងតឹត្បិយើញចៅកំសត់នោះ ជាក្មេងស្លូតត្រង់ ក៏មានព្រះទ័យអាណិតអាសូរកុណា ឧទ្ទិសឲ្យកុមារនោះនៅរៀនអក្សរ ។ កុមារនោះរៀនជាយូរឆ្នាំ បានចេះចាំតែអក្សរ ១១ តួ ព្រោះក្រែងជាអាប់ឧន

១– ប្រហែលជាពាក្យដើមថាប្រឡាយមាធិ ? ព្រោះពាក្យថាប្រឡាយបានខាងទឹកមានទឹក ហ្ន៎, មាធិ គឺបានខាងផ្នូរ រួមសេចក្តីថា ប្រឡាយមាធិ ប្រែថា ប្រឡាយផ្នូរទឹក ។

កាលលោកគ្រូដាក់ឲ្យចាប់ "ន មោ" ចាំហើយ ដល់ដាក់ "ពុ ទ្ធ" ឲ្យទន្ទេញតទៅទៀត ក្លែង ឯ ន មោ ឈឺធ្ងន់ ខោះប៉ាលោកគ្រូបង្ខំយ៉ាងណា ក៏ចេះចាំបានតែ ន មោ ដល់ ៥ ឈ្នាំ (១) ប៉ុណ្ណោះ សូម្បីលេខ ខ្ជួន គុណហារ អ្វីក៏គ្មានចេះបន្តិចបន្តួចសោះឡើយ ហើយកុមារនោះចេះតែញ៉ាយាមទន្ទេញអស់រយៈ ៥ ឈ្នាំ។ ទាំងយប់ទាំងថ្ងៃឥតឈប់ឈរឮសូរតែឆ្ងឹង។ ហេតុដូច្នេះ ទើបអ្នកស្រុកអ្នកភូមិគេហៅថា ចៅ ៥ ឈ្នាំ។ គ្រប់គ្នា ។

មានកាលមួយថ្ងៃ លោកគ្រូទឹកក្អកកង្គក់ព្រះទ័យថាចៅ ៥ ឈ្នាំ នេះមកនៅក្តីយូរឡាំហើយ គ្មានចេះចំណេះអ្វីសោះ តែចេះតែរាប់ប្រណិប័តន៍អាត្មាអញមិនឲ្យមានហ្មត់ ក៏រំយោលមារយាទក៏សុចរិតស្មូតត្រង់ល្អណាស់ ទើបលោកគ្រូហៅចៅ ៥ ឈ្នាំ មកឲ្យដំបូន្មានប្រៀនប្រដៅ អំពីឲ្យចាប់ចូលទៅនៅអាស្រ័យនឹងមន្ត្រី ផ្គាប់បុណ្យសក្តិសព្វគ្រប់ហើយ ក៏មានព្រះពុទ្ធដីកាទៅកាន់ចៅ ៥ ឈ្នាំ ថា នែកុមារ! ចៅមកនៅវត្តរៀនអក្សរតាំងពីក្មេងតូចរហូតដល់ធំពេញកម្លោះហើយ មិនចេះសោះ ចើដូច្នេះអាចក្តីនឹងទាំងចៅឯងឲ្យទៅនៅចំរើនអ្វីនឹងបាន ចូរចៅត្រឡប់តាមច្បាប់ដែលអាត្មាជាគ្រូប្រដៅហើយនោះទៅ ក្រែងលោមានកិត្តិសព្ទនាមឈ្មោះបានជាធំ។ កាលចៅ ៥ ឈ្នាំ ត្រមង់ទួលតាមពុទ្ធដីកាឥតមានប្រកែកហើយ

๑- អានថា អំក-ឆ ។

លោកគ្រូនោះគំនាំចៅ ៨ ឦ ទៅជូនឪពុកខ្ញុំឯង សុំផ្ទៀងទៅធ្វើជាកូនក្មួយបំរើ ហើយលោកគ្រូមានតុក្កដាគាំទ្រលោកមន្ត្រីនោះថា " សុំលោកមេត្តាចៅ ៨ ឦ នោះផង បើមានទោសខុសឆ្គាំឆ្គងយ៉ាងណា សូមលោកអភ័យទោស អនុគ្រោះប្រដៃប្រដៅឲ្យមានខុះ ព្រោះចៅនេះជាមនុស្សកំព្រាឥតមេបាទេ នៅតែនឹងអាចក្តី តាំងពីតូចមក " ។

មន្ត្រីនោះ គំនួលចៅ ៨ ឦ ឲ្យនៅក្នុងផ្ទះបំរើបំពាស់ តាមធម្មតាមន្ត្រីនោះឃើញគំនិតមារយាទសុចរិតត្រង់ល្អមែន ប៉ុន្តែមិនចេះលេងមិនចេះអក្សរសោះ ទើងឲ្យធ្វើជាឪពុកមានជាវាសក្តិយ៉ាងណាក៏មិនកើត ។ លុះចំណេរចំរើកាលទៅ ប្រហែលជាចំនួន ១០ ឆ្នាំជាយ ស្រុកមានកើតចម្បាំង ចៅ ៨ ឦ ក៏លាមន្ត្រីវិលទៅសុំលោកគ្រូមេត្តាជ្រាយមាគ៌ាបន្ថែម ។ លោកគ្រូអង្គនោះ ក៏ចំបួសជាសាមណេរក្បាស់ល ១០ ព្រោះសាមណេរ ៨ ឦ នេះលង់ខ្លៅណាស់ ទើងឲ្យបួសជាកិក្ខុមិនកើត ។

លុះបួសបានជាសាមណេរហើយ អ្នកផងហៅថាលោកនេន ៨ ឦ ។ កាលនៅយូរទៅ លោកនេន ៨ ឦ ជាអ្នកបួសខ្ជាត់លាភសក្ការៈ ជាំងកូនសិស្សក៏គ្មាន ក៏ទៅបញ្ចុះបញ្ចូលបបួលក្មេងអ្នកស្រុកម្នាក់ឈ្មោះចៅយ៉ាកមកនៅបំរើ ដើម្បីឲ្យស្រួលកងការចិញ្ចឹមជីវិត ។ នៅរដូវបុណ្យភ្ជុំបិណ្ឌដែលលោកកុដិដាវ ។ គេបាននំចំណីច្រើន រៀបយប់ស្ងាត់ចៅយ៉ាកដើរលើសសំបកអន្សម នំគម ក្រោមកុដិគេមកជាក់ក្រោមកុដិលោកនេន ៨ ឦ

ឲ្យយើញច្រើនជាងកុដដែរ ដើម្បីបង្ហូតគេ ថាលោកគ្រូខ្លួនមានទំនំចំណីច្រើនជាងគេ ។

ថ្ងៃមួយ ចៅយ៉ាកជាកូនសិស្ស បានទៅយើញអ្នកស្រែម្នាក់ កំពុងភ្ជួរស្រែនៅក្បែរត្រពាំងមួយ ដែលពេលស្លាចគេដោះគោចេញ ទុកនង្គ័លក្បែរត្រពាំងនោះហើយគេដឹកគោទៅផ្ទះ ។ កាលគេចេញផុតទៅ ចៅយ៉ាកយកនង្គ័លគេទៅលាក់ក្នុងទឹកត្រពាំង ហើយទៅរៀបរាប់ប្រាប់លោកគ្រូ ឥ ឮ ថា "ខ្ញុំកុណាយកនង្គ័លអ្នកស្រែម្នាក់ ដែលភ្ជួរនៅក្បែរត្រពាំងទឹកមួយមានតាពយាំងនេះ មានដើមឈើយាំងនោះ ខ្ញុំកុណាដាក់នង្គ័លនោះបែរយោមទៅខាងនេះ ចុងទៅខាងនោះ . . . សូមលោកគ្រូចាំយកតាមដំណើរនោះចុះ " ។

ព្រឹកឡើង ម្ចាស់នង្គ័លដឹកគោមកភ្ជួរ មិនយើញនង្គ័ល ក៏ទំដើរកែគ្រប់ប្រកល្អក ជួបជុបប្រទះនឹងចៅយ៉ាក ។ សួរថា " លោកតូចទៅណាមកណា កំលះរលាំងភ្ញាំងម្ល៉ះ ? " ។ ម្ចាស់នង្គ័លប្រាប់ថា « អាកំអើយ ! ចោរកំលួចនង្គ័លតូចបាត់ពីយប់មិញទៅ រកមិនយើញសោះ " ។

ចៅយ៉ាកប្រាប់ថា "បើដូច្នេះ លោកតួយកខៀនធួបម្ខូស្វាទៅសំពះលោកគ្រូខ្ញុំឈ្មោះលោកតា ឥ ឮ នៅវត្តចាំយាំក សុំឲ្យលោកទាយឲ្យចុះ លោកគ្រូខ្ញុំទាយធុតណាស់" ។ ម្ចាស់នង្គ័លក៏លែងទៅផ្ទះ យក

ខៀនឆ្លងទន្លេស្ទឹង តម្រង់ទៅលោកតា ឥន្ទ្រ សុំឲ្យលោកជួយ ។ ឯលោកតាយើង កាលបានឮសូត្រយ៉ាហ៊ីយ ក៏រំពឹងគន់គូរមើលហើយសាសត្វថា « ខន្ធីលនោះមានចោរនាំទៅលាក់ក្នុងត្រពាំងទឹក ដងភ្លែតទៅខាងត្បូង ឃាមទៅខាងជើង ផ្លឿនឆ្ពោះទៅខាងលិច » ។ ចប់ទំនាយស្រេច ម្ចាស់ខន្ធីលក៏ត្រាច់ទៅរកតាមទំនាយនោះ បានឃើញតិតជួបលោកគ្រូ ឥន្ទ្រ ជាយនោះមែន ។ តាំងពីកាលនោះមក កំសត្វខ្ញុំឮទៅសត្វទិសទីថា លោកតា ឥន្ទ្រ ជាយពូកែណាស់ មនុស្សម្នាតាំងក្មេងតាំងចាស់ តែមានអាសន្នអន់ក្រក៏រត់ទៅរកឲ្យលោកគ្រូ ឥន្ទ្រ ជាយជួយគ្រប់គ្នា ។

ព្រោះមានទំនាន់ដូច្នេះ ទើបជាត្រពាំងនោះមានឈ្មោះថា "ត្រពាំងលាក់ខន្ធីល" រៀងកបដកចមកហូតដល់សព្វថ្ងៃ ។

ពិធីសម្ពោធវិមានឯករាជ្យ (៩-១១-៦២)

អស់លោកបានជ្រាបស្រាប់ហើយ ថាឯកជ្យប្រទេសយើងបានកើតមានឡើងនៅថ្ងៃទី ៩ ខែវិច្ឆិកា ១៩៥៣ ជាតិតម្រាកជ មិនមែនដូចពាក្យចចាមអាមថា កើតមានឡើងដោយសារសន្ធិសីទហ្សឺណែវ (ប្រទេសស្វីស) នៅឆ្នាំ ១៩៥៤ នោះទេ ។ ចាប់តាំងពីនោះមក យើងបានឯកជ្យមានចំនួន ១០ ឆ្នាំទំនងឆ្នាំនេះ ដោយស្នាព្រះហស្តដ៏ឆ្នើមនៃព្រះមហាក្សត្រ ជាទីគោរពនឹងជាទីស្នេហាស្មើដោយជីវិតនៃយើងព្រះនាមព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ដោយព្រះអង្គទ្រង់ស៊ូប្តូរព្រះជន្មដ៏ថ្លៃថ្លានៃព្រះអង្គ ដើម្បីប្រជាជាតិខ្មែរ ហើយទ្រង់យាងទៅចាប់អង្រួនពិភពលោកឲ្យភ្ញាក់រលឹក ទំនងឲ្យមានយល់ច្បាស់នូវការស្រេកឃ្លានសេរីភាពនៃប្រជាជាតិខ្មែរ ដែលប្រទេសចាក់ឆ្ងែចេះតែក្តាប់ខុក ពុំព្រមត្រឡប់ថ្វាយចំពោះព្រះអង្គ ។ ជាអាសាន ដោយគ្រាំទំនឹងព្រះសកម្មភាពប្រកបដោយព្រះបញ្ញាញាណដ៏ឆ្នាតឆ្លាវ រកវេជ្ជណាកន្ធឹងពុំបាន ប្រទេសចាក់ឆ្ងែក៏ត្រមស់ចិត្តត្រឡប់ផ្លូវការត្រួតត្រាប្រទេសកម្ពុជាជំពេញសមត្ថភាព ថ្វាយជាកម្មសិទ្ធិដ៏ជិតបំបូលិគ្មានខ្វះវិស័យណា ចំពោះព្រះអង្គនៅថ្ងៃទី ៩ ខែវិច្ឆិកា ១៩៥៣ ។

តាំងពីពេលនោះមក ប្រទេសកម្ពុជាយើងមានទាមទារឲ្យស្គាល់ក្នុងឆាកអន្តរជាតិថា ជាប្រទេសឯករាជ្យប្រកបដោយអធិបតេយ្យ ខ្ពង់សម្បុណ្ណិកាព រួចព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហានុវរ្ម័ន ព្រះអគ្គក្សត្រនៃប្រទេសជាតិ ដោយយកព្រះទ័យទុកដាក់គ្រប់វិស័យ រហូតដល់ទ្រង់ដាក់រាជ្យថ្វាយចំពោះព្រះវរាជបិតា ព្រះនរោត្តមព្រះបាទសម្តេច ព្រះសុភាមិត្ត ព្រោះតែព្រះអង្គ កាលបើទ្រង់គង់ជាព្រះមហាក្សត្រទៅទ្រង់ពុំអាចកសាងប្រទេសជាតិឲ្យបានពេញទំហឹង ពេញសមត្ថភាព មានការប្រែស្រួយភាក់ខ្ពង់ជាមួយប្រជាពលរដ្ឋ ជាទីស្នេហារបស់ព្រះអង្គជាដើមបាន ។ ក្នុងចំណោមវត្តចំណង់ដើម្បីកសាងប្រទេសជាតិ មានវត្តចំណង់មួយដែលព្រះអង្គទ្រង់បានចាត់ចែងការឲ្យមានរូបភាពឡើងខាងក្រោយពេលបានឯករាជ្យ ។ ឯវត្តចំណង់នោះគឺ វិមានឯករាជ្យនេះឯង ឲ្យសមទៅតាមប្រទេសឯករាជ្យនានា ក្នុងសាកលលោកដើម្បីទុកជាអនុស្សាវរីយ៍ជាតិ ។ តែដោយប្រទេសយើងខ្វះទឹនធនធានឯករាជ្យថ្មី ហើយថវិកាជាតិក៏អន់ខ្សោយ ការកសាងវិមានឯករាជ្យក៏រសាត់យារមកដល់ឆ្នាំ ១៩៦២ នេះ ទើបបានហើយ ។

ឥឡូវថ្ងៃមហានក្ខត្តឫក្សប្រកបដោយជោគជ័យមកដល់ហើយ ។ វិមានឯករាជ្យដែលកសាងឡើងដោយបេតុង៨ការ៉េ មានជណ្តើរបួលត្រប់ទិសទាំងបួន តាក់តែងដោយថ្មតែរដ៏វិចិត្រ កំពូលប្រដាប់ដោយក្បាច់រចនាដ៏

យ៉ាងស្រស់ឆើតឆាយ និយមយកតាមបែបអង្គរវត្ត តាំងទៅចំកណ្តាលមហាវិថីមុខ ដែលគេអាចក្រឡេកឃើញតាំងគ្រប់ទិស ដូចជាកំភូលប្រាសាទអង្គរវត្តដែរ ។ ទៅដុំវិញ ទឹងទៅតាមសួនច្បារដ៏ប្រណីត ពីខាងកើតទឹងខាងលិច មានវិចត្រគាត់តែងលំអដោយទង់ជាតិ ទឹងបន្ទឹងអគ្គិសនីគ្រប់គណៈ ។ ទៅមុខវិថីស្ថានតរុកោសល្យ (សាលាតរុវិថី) តាមចិញ្ចើមថ្នល់ខាងលិច មានព្រះតម្នាក់ដ៏ធំវិចត្រលំអដោយស្នឹកក្តួជាតិពណ៌បៃតងស្រស់ទឹងទង់ជាតិបក់វិចគួរជាទីចាប់ចិត្តទស្សនា សម្រាប់សម្តេចព្រះទេបយុវរាជ ព្រះប្រមុខរដ្ឋគង់ប្រថាប់ ទឹងសម្រាប់នាហ្មឺនសព្វមុខមន្ត្រីជាព្រះរាជបរិពារព្រះអង្គ ព្រមទាំងក្រុមអង្គខូតនានាដែលជាភ្ញៀវកិត្តិយស ។

គេលទៅទាំង ៨ សម្តេចព្រះប្រមុខរដ្ឋទ្រង់ថ្លែងព្រះសុន្ទរកថាដ៏យ៉ាងពិរោះក្បោះក្បាយ ប្រកបដោយសារប្រយោជន៍ជាអនេក ស្តីពីឯករាជ្យនៃប្រទេសកម្ពុជា ដើម្បីជាទីសណ្តាប់ដល់ប្រជាពលរដ្ឋជាទីស្នេហារបស់ព្រះអង្គ ព្រះរាជសុន្ទរកថានេះ យើងទឹងចុះផ្សាយជូនកុងទស្សនាវដ្តីកម្ពុជសុរិយាលេខ ១២ ។ លុះចប់ព្រះរាជសុន្ទរកថាដ៏សែនពិរោះនេះហើយ សម្តេចព្រះបិតាឯករាជ្យជាតិ ទ្រង់ស្តេចយាងមួយអន្ទោងដោយនាហ្មឺនសព្វមុខមន្ត្រី ព្រមទាំងអង្គខូត ទៅកាន់ខ្សែបូរដែលចងសន្ធឹងតូរបូលបែកខាងដើង ជានិមិត្តរូបនៃពិធីសម្ពោធវិមានឯករាជ្យ ។ បន្ទាប់ពីនោះមក

មានពិធីដង្ហែក្បួនយោធា ក្រុមយុវនែ យុវតី ក្នុងព្រះរាជអាណាចក្រទាំង
មូលដ៏ឃាំងអធិកអធម្មមហិមា ដែលមានក្បាលទីចាប់ពីកំដូនតេញ្ញៅ
អស់រយៈពេលយ៉ាងយូរ ។ ខាងលើអាកាសវេហាស៍ អាកាសយាន
បានហោះហើរព័ទ្ធផ្នែលទីពីធីជារច្រើនដុំ ប្រកបដោយសូរយ៉ាងខ្លាំងស្ទើរ
ចៃគមួយ ដើម្បីបញ្ជាក់ខ្លួលខ្នុលជប្រសើរនៃឯករាជ្យ នឹងសេចក្តី
ត្រេកអរសាទរ ព្រមទាំងមានចុងភ្ជាប់ការភ្លើង ២១ លាន់ បញ្ជាក់ខ្លួកំឡាំង
ឯករាជ្យផង ។

ចំណែកអ្នកទស្សនាវិញ យើងមិនអាចពិពណ៌នាបានឡើយ គឺ
មានសភាពច្រើនអនេកជាង៏សព្វថ្ងៃ នឹងគណនាត្រាកប់ពុំបាន ទាំងគ្នា
ឈរកកស្រឡាប់ ហាក់អ្នកយកស្ថិតចេកមកជាក់តម្រឿប តាមជនរិចព្រះ
នរោត្តម នឹងជុំវិញវិមានឯករាជ្យ ។

សូមជំរាបបញ្ជាក់ថា ពិធីសម្ពោធវិមានឯករាជ្យបានចប់នៅថ្ងៃទី
១១-១១-៦៧ ពេលម៉ោង ១០ ។ ឧកាសនោះ សម្តេចព្រះប្រមុខរដ្ឋ
មួយអន្ទឹ ដោយព្រះរាជបរិពារដូចជម្ងាតាមជង្ហែផង បានស្តេចយាងទៅ
រលត់ទៀនជ័យ ដែលទ្រង់បានអុជដំកល់ទុកនៅចំកណ្តាលវិមានឯករាជ្យតាំ
ថ្ងៃទី៩-១១-៦៧ មក ។ ក្នុងពេលជាមួយគ្នានេះ មានធ្វើពិធីផ្លាស់ទង់ជ័យ
គឺ សម្តេចទ្រង់ប្រគានទង់ជ័យថ្មីដល់ក្រុមយោធា ហើយទ្រង់សព្វព្រះហ-
ឫទ័យឡើងង្ហែយកទង់ជ័យចាស់ទៅដំកល់ទុកក្នុងមន្ទីរពិពិធកណ្ឌតហាន ។

មានការណ៍ចម្លែកមួយដែលគួរលើកយកមកដំណាលជូនជាដំណឹង គឺ
ការកំរើងំសាន្តនៃអ្នកទស្សទាក្នុងពេលរាត្រី ។ នៅយប់ថ្ងៃទី ១១ ខែធ្នូ កា
ប្រហែលចាប់ពីម៉ោង ២០ ទៅ នៅជុំវិញវិមានឯករាជ្យ តាមដងមហាវិថី
ព្រះនរោត្តម នឹងនៅវត្តភ្នំ មានការកំរើងំសាន្ត ។ ខ្មែរនឹងបរទេស ប្រុស
ស្រី ក្មេង ចាស់ ឥតមានប្រកាន់ពណ៌ ទាំងអាំងកំសាន្តយ៉ាងរីករាយ ពាក់
ពាក់ខ្លះលើចលេងសប្បាយជាសញ្ញាថា កម្ពុជាជាតោះសន្តិភាព ក្នុងដែនដី
អាស៊ីគាគអគ្នេយ៍ ។ ការកំរើងំជាសាធារណៈនេះបានតាំងនៅរហូតដល់
ម៉ោង ៣ ភ្លឺទើបចប់ ។ ពិធីនេះ ពីបូរាណកាលមក មិនដែលកើតមានដល់
ម្ដងសោះ ទើបតែនឹងកើតមានក្នុងសម័យនេះ ហើយយើងសន្និដ្ឋានថា
ប្រហែលជានឹងមានជាទម្លាប់មិនខាននៅក្នុងអនាគត នៅឧកាសពិធី
បុណ្យឯករាជ្យម្ដង ។ ។

នៅទីអាសាន យើងឆ្លៀតឧកាសនេះ សូមជូនយោបល់ដ៏ស្ដួច
ស្ដើងមួយ បន្ថែមចំពោះវិមានឯករាជ្យ ដែលជាតេជានុភាពយ៉ាងខ្ពង់ខ្ពស់នៃ
ប្រទេសកម្ពុជា ។

ឯកូនយោបល់នោះមានដូចតទៅ : ឯករាជ្យជាស្នាព្រះហស្តដ៏ឆ្នើម
នៃសម្ដេចសហជីវិនៃព្រះប្រមុខរដ្ឋ ដោយមានកងដ៏រឹងមាំ នាំក្បាលបាន

ភ្ជួតដៃជាមួយកងរយោធា តាមដង្ហែអង្គព្រះមហាក្សត្រ ។ ដូច្នេះ នៅតាម
ជញ្ជាំងខឿនក្រោមនៃវិមាន គួរបញ្ចាក់ព្រះរូបសម្តេចព្រះបិតាឯកពាជ្យជាតិ
ទ្រង់ស្តេចយាងពីមុខ ហើយរូបកងដំរីពលនាវីក្បាហាន នឹងកងរយោធ-
តាលខេមរភូមិន្ទហែពីខាងក្រោយ ដោយលីកាំភ្លើងឈើច្រូងច្រាង ។ ឯ
ការធ្វើយ៉ាងនេះគ្រាន់ជាទីទស្សនា ហើយបានយល់ភ្លាម ។ នៃក្រុមទេស-
ចរក៍ អំពីឯកពាជ្យយើង ដែលបានមកដោយសន្តិវិធី ។

បានជាយើងជូនយោបល់ដូច្នេះ ដោយអនុលោមទៅតាមប្រវត្តិ-
សាស្ត្រខ្មែរ ដែលធ្លាប់មានមកនៅប្រាសាទអង្គរ ព្រោះនៅប្រាសាទ
ខ្លះ មានរចនាជារឿងផ្សេង ។ មានរឿងចម្បាំងរវាងខ្មែរនឹងចាមជាដើម ។
ទម្លាប់ប្រវត្តិសាស្ត្រនេះនាំឲ្យអ្នកទស្សនាអាចយល់នឹងចំបានភ្លាម ។ ជាង
ការសិក្សាតាមក្បួនតម្រា ។

ផេង-ត្រីវ

ពិធីតាំងចៅអធិការ នឹង គ្រូសូត្រប្ចឹកក្នុងឆ្នាំ ១៩៦២
ចាប់ពីខែមករា មកដល់ខែមេសា

ចាប់ពីខែមករា មកដល់ខែមេសា ១៩៦២ មានការតាំងចៅអធិការ នឹងគ្រូសូត្រតាំងអស់ ២៣ អង្គក្នុងព្រះរាជាណាចក្រកម្ពុជា ។

១- នៅថ្ងៃទី ១៧ ខែមករា ១៩៦២ បានចាត់តាំងព្រះតេជៈគុណ តេញ-សន នាមឆាយា សីលសំវរៈ កើតឆ្នាំវក ព្រះជន្ម ៥៤ ឆ្នាំ បួសបាន ៣៣ ព្រះវស្សា ជាចៅអធិការវត្តពេងដំរី ឃុំកំពង់លាវ ស្រុកព្រៃវែង ខេត្តព្រៃវែង លេខសញ្ញាប័ត្រ ៣៦៧៤ ។

២- នៅថ្ងៃទី ១៦ ខែកុម្ភៈ ១៩៦២ បានចាត់តាំងព្រះតេជៈគុណ ទូច-ឃ្មាំង នាមឆាយា ព្រហ្មៈជាត កើតឆ្នាំជូត ព្រះជន្ម ៤៩ ឆ្នាំ បួសបាន ២៩ ព្រះវស្សា ជាចៅអធិការវត្តព្រែកពោធិមង្គល ឃុំព្រែកពោធិសួស្តី ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣៦៧៨ ។

៣- នៅថ្ងៃទីខែឆ្នាំជវៈ បានចាត់តាំងព្រះតេជៈគុណ អ៊ឹម-ជា នាមឆាយាជោតត្ថេរ កើតឆ្នាំខាល ព្រះជន្ម ៤៧ ឆ្នាំ បួសបាន ២៣ ព្រះវស្សាជាគ្រូសូត្រស្តាំ នៅវត្តពោធិមង្គល ឃុំព្រែកពោធិសួស្តី ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣៦៧៩ ។

៤- នៅថ្ងៃទី ១៩ ខែកុម្ភៈ ១៩៦២ បានចាត់តាំងព្រះគេជ:គុណ ម៉ី-ឈួន នាមឆាយា សុវណ្ណបញ្ញា កើតឆ្នាំ ១៩០៧ ព្រះជន្ម ៥៥ ឆ្នាំ បួសបាន ៣៥ ព្រះវស្សា ជាចៅអធិការវត្តដំនឹក ឃុំដំនឹក ស្រុកក្រូចឆ្មារ ខែត្រកំពង់ចាម លេខសញ្ញាប័ត្រ ៣២៨០ ។

៥- នៅថ្ងៃខែឆ្នាំដដែល បានចាត់តាំងព្រះគេជ:គុណ ណាប-ម្ហួង នាមឆាយា ឥន្ទវង្សតិបេរ កើតឆ្នាំ ១៩១៩ ព្រះជន្ម ៤៣ ឆ្នាំ បួសបាន ២៣ ព្រះវស្សា ជាគ្រូសូត្រស្តាំវត្តដំនឹក ឃុំ ស្រុក ទីឆ្ងាខែត្រដដែល លេខសញ្ញាប័ត្រ ៣២៨១ ។

៦- នៅថ្ងៃខែឆ្នាំ វត្ត ឃុំ ស្រុក ខែត្រដដែល បានចាត់តាំងព្រះគេជ:គុណ ង្ហ-សន កើតឆ្នាំ ១៩៣០ ព្រះជន្ម ៣២ ឆ្នាំ បួសបាន ១១ ព្រះវស្សា ជាគ្រូសូត្រឆ្វេង លេខសញ្ញាប័ត្រ ៣២៨២ ។

៧- នៅថ្ងៃទី ៣១-១-៦២ បានចាត់តាំងព្រះគេជ:គុណ សោម-ក្រែង នាមឆាយា វិនយធម្មត្ថេរ កើតឆ្នាំខាល ព្រះជន្ម ៧១ ឆ្នាំ បួសបាន ៥១ ព្រះវស្សា ជាគ្រូសូត្រស្តាំវត្តចាកយណ៍ព្រះដីវ ឃុំចាកយណ៍ ស្រុកស្រីសន្ធរ ខែត្រកំពង់ចាម លេខសញ្ញាប័ត្រ ៣២៨១ ។

៨- នៅថ្ងៃខែឆ្នាំ វត្ត ឃុំ ស្រុក ខែត្រដដែល បានតាំងព្រះគេជ-គុណ ប៉ុល-អ៊ឹម ភេមឆាយោធម្មវិនយត្ថេរ កើតឆ្នាំមមែ ព្រះជន្ម ៦៧ ឆ្នាំ បួសបាន ៤៦ ព្រះវស្សា ជាគ្រូសូត្រឆ្វេង លេខសញ្ញាប័ត្រ ៣២៨២ ។

៩- នៅថ្ងៃទី ៣១-១-៥២ បានចាត់តាំងព្រះតេជៈគុណ ឈុន-ណោ នាមនាយ សុវណ្ណត្ថេរ កើតឆ្នាំជូត ព្រះជន្ម ៧៤ ឆ្នាំ បួសបាន ៥២ ព្រះវស្សា ជាចៅអធិការវត្តកោះច័ន្ទ ឃុំកោះមិត្រ ស្រុកកំពង់សៀម ខែត្រកំពង់ចាម លេខសញ្ញាប័ត្រ ៣៤៨៣ ។

១០-១១- នៅថ្ងៃខែឆ្នាំ វត្ត ឃុំ ស្រុក ខែត្រដដែល បានចាត់តាំង ព្រះតេជៈគុណ ព្រំ-អ៊ុច នាមនាយបញ្ញាសុវណ្ណ កើតឆ្នាំ ១៨៩១ ព្រះជន្ម ៧១ ឆ្នាំ បួសបាន ៥១ ព្រះវស្សា ជាគ្រូសូត្រស្តាំ លេខសញ្ញាប័ត្រ ៣៤៨ ទីឯចាត់តាំងព្រះតេជៈគុណ ក្រែ ច-ជួង នាមនាយ ធម្មបញ្ញា កើតឆ្នាំ ១៨៩៨ ព្រះជន្ម ៦៦ ឆ្នាំ បួសបាន ៤៣ ព្រះវស្សា ជាគ្រូសូត្រ ឆ្វេង លេខសញ្ញាប័ត្រ ៣៤៩ ។

១២-១៣-១៤-១៥-១៦-១៧-១៨- នៅថ្ងៃខែឆ្នាំដូចខាងលើ បានចាត់តាំងព្រះតេជៈគុណ ហាន់-ហួច នាមនាយពុទ្ធប្បញ្ញោ កើត ឆ្នាំរកា ព្រះជន្ម ៤១ ឆ្នាំ បួសបាន ១៤ ព្រះវស្សា ជាចៅអធិការវត្តគ្នាគ-ពង ឃុំសំពៅលើ ស្រុកកំពង់ត្រាញ ខែត្រកណ្តាល លេខសញ្ញាប័ត្រ ៣៤៨៦ បានចាត់តាំងព្រះតេជៈគុណ អ៊ុក-សាន់ នាមនាយធម្មកេ-សរ កើតឆ្នាំ ១៨០៦ ព្រះជន្ម ៦០ ឆ្នាំ បួសបាន ៣៥ ព្រះវស្សា ជាចៅ-អធិការវត្តអរុណរតី ឃុំត្រពាំងក្រសាំង ស្រុកកំពង់ត្រាញ (កណ្តាល) លេខ

សញ្ញាប័ត្រ ៣៤៧ ជានចាត់តាំងព្រះតេជៈគុណ កែវ-ភង់ នាម-ធាយោគម្តីរញ្ជាណោ កើតឆ្នាំរកា ព្រះជន្ម ៣៤ ឆ្នាំ បួសជាន ១៤ ព្រះ-វស្សា ជាចៅអធិការវត្តយសមេត្រីខាងត្បូង ឃុំលំហាច ស្រុកភ្នំពេញ (កណ្តាល) លេខសញ្ញាប័ត្រ ៣១៤៨ ជានចាត់តាំងព្រះតេជៈគុណ ម៉ា-វឿម នាមធាយាវិសាលវង្ស កើតឆ្នាំ ១៨៦២ ព្រះជន្ម ៤០ ឆ្នាំ បួស ជាន ១៤ ព្រះវស្សា ជាចៅអធិការវត្តមង្គលសត្ថារ៉ាម ឃុំព្រែកតាសេក ស្រុក មុខកំពូល (កណ្តាល) លេខសញ្ញាប័ត្រ ៣២៤៤ ជានចាត់តាំងព្រះ-តេជៈគុណ ជួង-វិបុល នាមធាយា មុនីថេរោ កើតឆ្នាំ ១៨៣៦ ព្រះជន្ម ៦៦ ឆ្នាំ បួសជាន ៦ ព្រះវស្សា ជាចៅអធិការវត្តពិជយទជ្ឈ ឃុំកំពត ស្រុកកំពត (កំពត) លេខសញ្ញាប័ត្រ ៣៣០០ ជានចាត់តាំងព្រះតេជ-គុណ ឆុត.ធឹម នាមធាយាបញ្ញាសុវណ្ណ កើតឆ្នាំ ១៨៣៣ ព្រះជន្ម ៦៩ ឆ្នាំ បួសជាន ៨ ព្រះវស្សា ជាចៅអធិការវត្តសំរោងពពែខ្ញែ ឃុំតាខ្ញែ ស្រុក ព្រៃកប្បាស (តាកែវ) លេខសញ្ញាប័ត្រ ៣៣០១ ជានចាត់តាំងព្រះ-តេជៈគុណ ប៊ែន.ម៉ាន នាមធាយាសង្ឃរក្ខិត កើតឆ្នាំរោះ ព្រះជន្ម ៤៥ ឆ្នាំ បួសជាន ២៤ ព្រះវស្សា ជាគ្រូសូត្រស្តាំវត្តស្រែយ៉ូវ ឃុំស្រែយ៉ូវ ស្រុក កំពង់ស្វាយ (កំពង់ធំ) លេខសញ្ញាប័ត្រ ៣៣០២ ។

១៨- នៅថ្ងៃទី ១០ ខែមិថា ១៨៦២ ជានចាត់តាំងព្រះតេជៈគុណ ម៉ៅ-ស្វាយ នាមធាយាសច្ចនោបតោ កើតឆ្នាំ ១៨៤៣ ព្រះជន្ម ៦៤ ឆ្នាំ

បួសបាន ៥ ព្រះវស្សា ជាចៅអធិការវត្តខ្ណាសារ ឃុំកំពង់ចិន ស្រុកស្អាង (កំពង់ធំ) លេខសញ្ញាប័ត្រ ៣៣០៣ ។

២០-២១- នៅថ្ងៃទី១ខែ ឃុំ ស្រុក ខែត្រ ដូចខាងលើ បានចាត់តាំងព្រះតេជៈគុណ ចាន់-សុ១ នាមឆាយាសីរវន្តោ កើតឆ្នាំ ១៨២០ ព្រះជន្ម ២២ ឆ្នាំ បួសបាន ២ ព្រះវស្សា ជាគ្រូសូត្រស្តាំ លេខសញ្ញាប័ត្រ ៣៣០៤ បានចាត់តាំងព្រះតេជៈគុណ ហួន-ឃន នាមឆាយា កល្យាណចម្មោ កើតឆ្នាំ ១៨៣៨ ព្រះជន្ម ២៣ ឆ្នាំ បួសបាន ១ ព្រះវស្សា ជាគ្រូសូត្រឆ្វេង លេខសញ្ញាប័ត្រ ៣៣០៥ ។

២២- នៅថ្ងៃទី ១០-៣-៦២ បានចាត់តាំងព្រះតេជៈគុណ កិ-តាំ នាមឆាយា សិរីវណ្ណោ កើតឆ្នាំមមែ ព្រះជន្ម ៤៣ ឆ្នាំ បួសបាន ២០ ព្រះវស្សា ជាគ្រូសូត្រស្តាំ វត្តកំពង់ក្អុក ឃុំកំពង់ក្អុក ស្រុកសូត្រនិគម (សៀមរាប) លេខសញ្ញាប័ត្រ ៣៣០៦ ។

២៣- នៅថ្ងៃទី ១៦-៣-៦២ បានចាត់តាំងព្រះតេជៈគុណ ឌេត-ឆឹម នាមឆាយា ចន្ទវ័ន្តោ កើតឆ្នាំ ១៨៣២ ព្រះជន្ម ៣០ ឆ្នាំ បួសបាន ៨ ព្រះវស្សា ជាចៅអធិការវត្តវៃវែត ឃុំពប ស្រុកពាក់ង (ត្រៃវែង) លេខសញ្ញាប័ត្រ ៣៣០៧ ។

២៤- នៅថ្ងៃទី១ខែ ឃុំ ស្រុក ខែត្រ ដូចខាងលើ បានចាត់តាំងព្រះតេជៈគុណ ជុក-ចាក នាមឆាយា ពុទ្ធសារ កើតឆ្នាំវក ព្រះជន្ម ៤២ ឆ្នាំ បួសបាន ២១

ព្រះវស្សា ជាចៅអធិការវត្តគរុណរង្សី ឃុំសណ្តែក ស្រុកសៀមរាប (សៀមរាប) លេខសញ្ញាប័ត្រ ៣៣១០ ។

២៩- នៅថ្ងៃទី ១៨-៤-៦២ ឯកឧត្តមព្រះតេជៈគុណ ស្រ៊ី. ជាម នាមឆាយា សន្តមុនីវង្ស កើតឆ្នាំ កុរ ព្រះជន្ម ៤០ ឆ្នាំ បួសបាន ១៨ ព្រះវស្សា ជាចៅអធិការវត្តធម្មត្រ័យ ឃុំផ្សារដែក ស្រុកពញាឮ (កណ្តាល) លេខសញ្ញាប័ត្រ ៣៣១១ ។

៣០- នៅថ្ងៃទី ២២-៤-៦២ ឯកឧត្តមព្រះតេជៈគុណ ឧប្ប៊ៈ-ប៊ិន នាមឆាយា សុជន្មវង្សបញ្ញា កើតឆ្នាំ ១៩២១ ព្រះជន្ម ៤១ ឆ្នាំ បួសបាន ២១ ព្រះវស្សា ជាចៅអធិការ វត្តឆ្នាក់ ឃុំត្នោត ស្រុកជុំគីរី (តាកែវ) លេខសញ្ញាប័ត្រ ៣៣១២ ។

៣៧-៣៨-៣៩-៣០-៣១-៣២- នៅថ្ងៃខែឆ្នាំ ដូចខាងលើ ឯកឧត្តមព្រះតេជៈគុណ ប៊ុល-ស៊ឹម នាមឆាយាបញ្ញាថេរ កើតឆ្នាំ មមី ព្រះជន្ម ៤៧ ឆ្នាំ បួសបាន ២៤ ព្រះវស្សា ជាចៅអធិការវត្តកំលស្សវ ឃុំមេសប្រចាន់ ស្រុកតាកំង (វៃក្រវែង) លេខសញ្ញាប័ត្រ ៣៣១៣ ឯកឧត្តមព្រះតេជៈគុណ ស្សួ-សៀង នាមឆាយា អគ្គមុនី កើតឆ្នាំ ១៩៣៤ ព្រះជន្ម ២៧ ឆ្នាំ បួសបាន ៦ ព្រះវស្សា ជាចៅអធិការវត្តជាយតនារាម ឃុំព្រៃត្រី ស្រុកកំពង់លែង (កំពង់ឆ្នាំង) លេខសញ្ញាប័ត្រ ៣៣១៤ ឯកឧត្តមព្រះតេជៈគុណ រស់-ម៉ែន នាមឆាយា សុវណ្ណប្បញ្ញា

កើតឆ្នាំកុរ ព្រះជន្ម ៦៤ ឆ្នាំ បួសបាន ៤ ព្រះវស្សា ជាចៅអធិការ
វត្តជោតវ័ន ឃុំត្រពាំងសាប ស្រុកចុងគី (តាកែវ) លេខសញ្ញាប័ត្រ
៣៣១៥ ចានចាត់តាំងព្រះគេជៈគុណ ឈួន-ច្រាង នាមធាយាមង្គល-
ត្ថេរៈ កើតឆ្នាំរកា ព្រះជន្ម ៣០ ឆ្នាំ បួសបាន ៩ ព្រះវស្សា ជាគ្រូសូត្រ
ស្តាំ វត្ត ឃុំ ស្រុក ខែត្រខាងលើ លេខសញ្ញាប័ត្រ ៣៣១៦ ចានចាត់
តាំងព្រះគេជៈគុណ កែប-ភ័ នាមធាយាធម្មប្បញ្ញា កើតឆ្នាំរកេង ព្រះ
ជន្ម ៥៩ ឆ្នាំ បួសបាន ៣៣ ព្រះវស្សា ជាចៅអធិការវត្តមុនីសាគរ ឃុំ-
ពង្រ ស្រុកឆ្លូ (ក្រចេះ) លេខសញ្ញាប័ត្រ ៣៣១៧ ចានចាត់តាំងព្រះ
គេជៈគុណ ភ្លូប-សៀង នាមធាយាឥន្ទសរៈ កើតឆ្នាំខាល ព្រះជន្ម
៣២ ឆ្នាំ បួសបាន ១៣ ព្រះវស្សា ជាគ្រូសូត្រស្តាំនៃវត្ត ឃុំ ស្រុក ខែត្រ
ខាងលើ លេខសញ្ញាប័ត្រ ៣៣១៨ ។

ភក្តិសទ្ធិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ៣៤ លេខ ១២ ខែធ្នូ

ព.ស. ២៥០៤ គ.ស. ១៩៦២

- ក្នុង ៣ -





ភ្នំពេញសន្ទេសារ

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

	ទំព័រ
ផ្នែកសាសនា	
– ធម្មវិចារណាកថា ព្រះសាសនមុនី កឹម-ឆួរ រៀបរៀង (តបប់)	១៣២៣
– គោលដ្ឋាប់ព្រះពុទ្ធសាសនា លោក ហេង-សមអាន នៃតនឹងរៀបរៀង (តបប់)	១៣៣៧
– ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) លោកប៉ូ-ប៉ុំ ប្រែរៀបរៀង (ត)	១៣៤៦
– មធុរសោភណី សម្តេចព្រះធម្មលិខិត ស្ង៊ី-ឯម នគរមប្រឹក្សា ប្រែរៀបរៀង (ត)	១៣៦៥
– មហោសធ (ត)	១៣៦៩
ផ្នែកអក្សរសាស្ត្រ	
– ពាក្យខ្មែរប្រែតំបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរសាស្ត្រ (ត)	១៣៧៤
– វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត)	១៣៧៨
– រឿងស្បែកខ្លាឃ្មុំនៃតែន (La Fontaine) លោកជើង-ជ្រីវ ប្រែពីភាសាបារាំង(ត)	១៣៩០
– រឿងសាមកុក អ្នកនាកញ៉ា នូ-ហន ប្រែរៀបរៀង (ត)	១៣៩៦
– រឿងព្រេងចិន លោក ភ័យ-ប៊ុក ប្រែរៀបរៀង (ត)	១៤០៩
– រឿងភ្នំប្រុសភ្នំស្រីនៅខែត្រកំពង់ចាម របស់ក្រុមទំនៀមទម្លាប់	១៤១៧
– ចៅងជាទេសោទុប្បការណ៍ប្លែក លោក ឆឹក-ខាម នៃតរៀបរៀង	១៤២០
កំណត់ទឹងប្រវត្តិការណ៍	
– ព្រះរាជសុន្ទរកថានៃសម្តេចព្រះប្រមុខរដ្ឋថ្លែង នៅទីការសភាធិសម្ពោធវិមានឯកភក្តី នៅថ្ងៃទី ៩-១១-៦២	១៤២៣
– អំពីការកាំងមន្ត្រីសង្ឃ	១៤៣៦

មួយឆ្នាំមាន ១២ លៀវក្រៅ តម្លៃជាវ ២៣០រៀល

34è Année — N° 12 — Décembre 1962

KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire publiée par l'Institut-Bouddhique de Phnom-Penh

SOMMAIRE

Partie religieuse

—Dhammavicharanakatha par le Vénérable KEM-TO (suite et fin) 1323
—Principes bouddhiques par M. HENG-SAM-AN (suite et fin) . 1337
—Préah Abhidhammapitaka «Kampir Préah Yamaka» par M. BOU-PO (suite) 1356
—Madhurasavahini par S.Em. Préah Thammalikhit LOUIS-ÈM Haut Conseiller (suite). 1365
—Mahosotha Jataka (suite) 1369

Partie littéraire

—Activités de la Commission Culturelle chapitre «Ka» (suite) . . . 1384
—Dictionnaire Sanscrit-Khmer par Vénérable PANG-KHAT (suite). 1388
—Fables de la Fontaine traduites par M. PHÈNG-CHRIV (suite) 1390
—Histoire de Sam-Kok traduite par l'Oknha NOU-KAN (suite) . . . 1396
—Légende Chinoise traduite par M. RAY-BUC Pheuchhouykhèt de TAKEO (suite) 1409
—Légende de Phnom-Pros et Phnom-Srey à la Province de Kg Cham de la Commission des Mœurs et coutumes. 1417
—« PAUNG » instument de pêche par M. DIC-CÉAM 1420

Notes et chroniques

—Discours de Monseigneur Chef de l'Etat prononcé à l'occasion de l'Inauguration de Monument de l'IndéPendance le 9-11-62. . . 1423
—Nomination des Chau Athikar et leurs adjoints dans diverses pagodes du Royaume 1436

Prix d'Abonnement annuel (comprenant 12 numéros) : 230 ; 00

ធម្មវិចារណាកថា

ព្រះសាសនមុនី កឹម-ស្រួរ រៀបរៀង

(តចប់)

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលោមពា ឲ្យធ្វើល្អទៅ ។
ឲ្យដុំសាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

បណ្តាអ្នកបួសតាំងអស់ដូចបានរៀបរាប់មកខាងដើមប៉ុន្មាននោះ ចំណែកខាងអ្នកដែលគិតរើសយកខ្លួនក្នុងវិជ្ជសង្ឃរហើយចេញមកបួស ហ្នឹងប្រសើរជាងគេ បន្ទាប់មកគឺអ្នកដែលចង់សិក្សាវិជ្ជាខាងពុទ្ធសាសនាហើយចេញមកបួស ក៏ទុកថាជាអ្នកប្រសើរដែរ ។ ចំពោះអ្នកដែលបួសហើយរៀនវិជ្ជាខាងពុទ្ធសាសនា ។ នោះ បានខាងបរិយត្តិ គឺការសិក្សាចំដែកតាំង ៣ គឺ វិនយបិដក សុត្តន្តបិដក អភិធម្មបិដក ចំពោះកិច្ចដែលត្រូវកន្លងពុទ្ធសាសនាក៏មាន ៣ ថ្នាក់ដែរ បរិយត្តិ ការសិក្សាជាថ្នាក់ទី ១ បដិបត្តិ សេចក្តីប្រតិបត្តិជាថ្នាក់ទី ២ បដិវេធៈ ការត្រាស់ដឹងខ្លួមគ្គនិងផល ឬការចាក់ធ្លុះយល់ខ្លួសការៈពិតក្នុងលោកជាថ្នាក់ទី ៣ ប៉ុន្តែ

អ្នកវៀនខ្លះ ច្រើនតែខ្ជិលកើលនៅត្រឹមចរិយត្តិ មិនសូវហួសទៅរកបដិបត្តិ
ទេ ព្រោះហេតុអ្វី ? ព្រោះហេតុថា លោកអ្នកបរិយត្តិច្រើនមានការរវល់
ធំធាការសម្តែងធម៌ រវល់ធំធាការបង្រៀន រវល់ធំធាការដោះស្រាយបញ្ហាធម៌
អាថ៌ផ្សេង ។ រវល់ធំធាការទទួលលាភសក្ការៈ ដែលកើតឡើងដោយគុណ
ធម៌របស់ខ្លួន ។ កាលបើមានលាភសក្ការៈកើតឡើងដល់ខ្លួនក្តី មាន
បរិស័ទជ្រះថ្លាចោមរោមកុះករចំពោះខ្លួនក្តី បព្វជិតគួរឲ្យមានសតិសម្ប-
ជញ្ញៈគឺមានស្មារតីដឹងខ្លួនប្រុងប្រយ័ត្នជានិច្ចកុំឲ្យធ្លាក់ចុះកន្លងបមាទធម៌ដែល
ជាហេតុនាំឲ្យក្រេចខ្លួន បណ្តាយឲ្យអស្មិមានៈកើតឡើងពីព្រោះតែលាភៈ
សក្ការៈ ធំធំ បរិស័ទនោះឡើយ ។ អស្មិមានៈនេះ ជាកិលេសធម៌ដ៏
លាមក កាលបើកើតឡើងក្នុងសន្តានចិត្តនៃបព្វជិតណា រមែងបំបាំង
ចិត្តនៃបព្វជិតនោះ ឲ្យប្រាំងឡើងងោរ ឡើងពង ដើលជាយអ្នក
ដទៃថាមិនត្រឹម មិនស្មើនឹងខ្លួន អ្មាំរហើយក៏ក្លាយទៅជាបព្វជិតពាលជា
បព្វជិតអសប្បុរសទៅវិញ ក៏មាន ។ ភាហារណ៍ដូច កថិលមច្ចកិកន្លងអដ្ឋ-
កថាធម្មបទ កិក្នុងនេះគ្រាន់តែបង្ហះបរិយត្តិ តែគ្មានសេចក្តីប្រតិបត្តិតាម ឬ
ដូចកិក្នុងពីរប្រយ៉ាងសំឡាញ់នឹងគ្នា : មួយរូបរៀនខាងបរិយត្តិ មួយរូបទៀត
ខាងខាងបដិបត្តិ នៅអាស្រ័យក្នុងវិត្រជាវត្ត ។ រឿងនេះក៏មានក្នុងអដ្ឋ-
កថាធម្មបទដាក់ស្តួតងស្រាប់ដែរ ព្រោះហេតុនោះ ត្រង់ការវៀនបរិយត្តិ
ការបង្ហះដឹងបរិយត្តិជ្រៅជ្រះយ៉ាងណាក៏ដោយ បើមិនមានសេចក្តីប្រតិបត្តិ

តាមផងទេ ក៏មិនទាន់ពាប់ថាជាការសំខាន់ក្នុងពុទ្ធសាសនាទៅឡើយទេ លុះតែមានបដិបត្តិ ការកាន់ ការប្រព្រឹត្តតាមឱ្យបានត្រឹមត្រូវតាមចំណេះដែលខ្លួនចេះដឹងនោះឯង ទើបពាប់ថាជាការសំខាន់ក្នុងពុទ្ធសាសនា ។

សេចក្តីដែលបានខាណិនាមកហើយនេះ មិនទាន់សព្វគ្រប់ប្លុកល្អន់ណាស់ណាទៅឡើយទេ ប៉ុន្តែ សូមពុទ្ធបរិស័ទចាំងឱ្យយល់ថា សេចក្តីប្រតិបត្តិណា ដែលប្រព្រឹត្តទៅដើម្បីពន: (តម្រែកកន់វគ្គកាមនឹងតិលេសកាម) ដើម្បីប្រកបដោយសេចក្តីទុក្ខ ដើម្បីការសន្សំតិលេសមានលោភៈជាដើម ដើម្បីសេចក្តីប្រាថ្នាធំ ដើម្បីសេចក្តីមិនសន្តោស ដើម្បីការច្រឡូកច្រឡំដោយបក្ខពួក ដើម្បីសេចក្តីវិលច្រអូស ដើម្បីការពាបាកគេចាញ់ ស្មើ សេចក្តីប្រតិបត្តិនោះ មិនមែនជាធម៌ មិនមែនជាវិន័យ ដែលហៅថា ពុទ្ធសាសនា របស់ព្រះសម្មាសម្ពុទ្ធទេ ។ ពុទ្ធសាសនាជាឧត្តមដ៏ខ្ពង់ខ្ពស់ ដែលព្រះអង្គទ្រង់សំដែងខ្ចាន់ដឹកនាំសត្វឱ្យលះបង់តិលេសមានពន:ជាដើម ហើយឱ្យសត្វធ្វើដំណើរឆ្ពោះទៅកាន់បរមសុខ គឺនិព្វានតែម្យ៉ាងប៉ុណ្ណោះ ។ បើពុទ្ធសាសនាប្រឿនប្រដៅសត្វឱ្យប្រតិបត្តិឆ្ពោះទៅកេបរមសុខ គឺនិព្វានតែម្យ៉ាងទេ ចុះហេតុអ្វី ក្នុងអនុបុព្វិកថា ៥ យ៉ាង ត្រង់សន្តកថា ព្រះអង្គទ្រង់សំដែងសរសើរសេម្បត្តិហ៊ានសួគ៌ នាំឱ្យសត្វស្រឡាញ់ជាប់ចិត្តក្រាថ្នាចង់បានទៅវិញ ? ត្រង់នេះ គួរជ្រាបថា ព្រះសម្ពុទ្ធបរមគ្រូជាទេសនាកោសល ព្រះអង្គប៉ុនប្រសប់កងវិធីសំដែង

ធម៌ខ្លួនឯងសត្វវិសេសក្រៃលែងជាងគ្រូដទៃ ពាំងអស់ក្នុងលោក ពីព្រោះ
ព្រះអង្គទ្រង់ត្រាស់ថា អធ្យាស្រ័យសត្វសត្វមិនដូចគ្នា មិនស្មើគ្នា
ទេ ដោយហេតុថា អធ្យាស្រ័យរបស់សត្វខ្លះនៅខន់ខ្លីគ្រោតគ្រោត
តាចថោក អធ្យាស្រ័យរបស់សត្វខ្លះ ជាស់ក្បាខ្ពង់ខ្ពស់មានទុក្ខម-
គតិស្ន ។ បើសត្វណាដែលមិនតាន់មានសទ្ធាសេចក្តីជ្រះថ្លា គឺមាន
អធ្យាស្រ័យខន់ខ្លីនៅឡើយទេ ព្រះអង្គទ្រង់សំដែងសរសើរសម្បត្តិហាន
សួគ៌ជាការប្រលោមលួងលោម ដើម្បីឲ្យសត្វនោះ កើតសទ្ធាសេចក្តី
ជ្រះថ្លាស្រឡាញ់ជាប់ចិត្តចង់បាន ការចង់បានសម្បត្តិហានសួគ៌នោះ
លុះតែសត្វតាំងឲ្យាយគប្បីធ្វើកុសលផ្សេង ។ មានការឲ្យទានរក្សាសីល
ជាដើម ទើបអាចបានទៅសម្បត្តិសួគ៌ក្នុងទេវលោក ។ កាលបើ
ព្រះអង្គបានត្រាស់ថា សត្វណាមានសទ្ធាជ្រះថ្លាដ៏ក្លៀវក្លាចំពោះការ
កុសលមានទានឯងសីលជាដើម ហើយប្រាថ្នាចង់បានសម្បត្តិមនុស្ស
និងសម្បត្តិទេវតាក្នុងហានសួគ៌ ព្រះអង្គត្រឡប់ជាទ្រង់សំដែងគម្រាមឲ្យ
សត្វនោះមានសេចក្តីភ័យខ្លាច ឲ្យមានសេចក្តីខ្សឿយណាយចុញ្រាន់
ចំពោះសម្បត្តិមនុស្សនិងសម្បត្តិទេវតាក្នុងហានសួគ៌នោះទៅវិញ គឺព្រះអង្គ
ទ្រង់សំដែងពន្យល់ឲ្យសត្វយើញច្បាស់ថា សម្បត្តិមនុស្សក្នុងលោកនេះ
ក្តី សម្បត្តិទេវតាក្នុងហានសួគ៌ក្តី សុទ្ធតែជាគោលជាគ្រឿងកាមពាំងអស់
ឯគោលរបស់កាមមានច្រើនប្រការណាស់ ដូចសត្វដែលធ្លាក់ទៅរនាំងទុក្ខ

កន្លងអង្គុយកូមិតនេក ប្រែត អសុរកាយ តំរេចាន ព័ត្រោះតែទោសនៃ
កាម អ្នកដែលខ្លួនឯងខ្ពស់ខ្ពែនាផ្សេង ។ ក្នុងលោកនេះ មានការជាប់
គុកច្រវាក់ជាដើម ព័ត្រោះតែទោសនៃកាម សត្វដែលអន្ទោលយោនយក
កំណើតកើតស្លាប់ក្នុងកលវដ្តសង្សារមិនមានទីចំផុត ព័ត្រោះតែទោសនៃ
កាមហ្នឹងឯងជាមូលហេតុ ។ ពាក្យថា កាមក្នុងទីនេះ សំដៅយកកាម
ទាំងពីរគឺ ១. វត្ថុកាម ចានខាងក្រៅមានវិញ្ញាណ មានគោក្របី ខ្ញុំប្រុស
ស្រី ជាដើម ទីឯក្រៅឥតវិញ្ញាណ មានមាសប្រាក់ ដីស្រែ ចំការ ហ្វារ
ដំណាំជាដើម ឬសំដៅយក រូប សំឡេង ក្លិន រស សម្ផស្សក៏ចាន ២. កិ-
លេសកាម ចានខាងធម៌ដែលធ្វើចិត្តឲ្យសៅហ្មង មានរាគៈ លោភៈជា
ដើម ។ កាមទាំងពីរនេះ ឈ្មោះថាជាអន្ទាក់បេស់មារ សម្រាប់ពាក់ចង
សត្វឲ្យជាប់នៅក្នុងភពទាំងបី បើសត្វណា មានតំនិតទៀយណាយធុញ
ព្រាត់គេចចេញអំពីភព ឬអំពីអន្ទាក់បេស់មារ។ នោះឯង តែងមាន
សេចក្តីក្តៅក្រហាយមិនសប្បាយចិត្តដោយពោះប្រការទាំងពា សត្វនោះ
កន្លងខ្លួរ៉ាស់យបេស់ខ្លួន ម្ល៉ោះហើយមារនោះ ក៏តែងស្វែងរកទោសគ្រប់
បៀតបៀនបន្ទុបន្ទាប់ដំណើរ មិនឲ្យគេចេញរួចអំពីអន្ទាក់បេស់ខ្លួនទៅ
ចាន ។ កាលបើសត្វណា ឃើញទោសបេស់កាម ហើយមានសេចក្តី
តក់ស័យតក់ស្លុតខ្លាច បន្ទាកេចាយដោះដៃគេចចេញអំពីកាម ព្រះអង្គ

ទ្រង់សំដែងចង្អុលបង្ហាញ ឧក្កុម: ថាជាផ្លូវសម្រាប់រត់គេចចេញអំពីកាម ។ ឧក្កុម: ប្រែថា ចេញចាកកាម ការចេញចាកកាមនោះដោយវិធីពីរយ៉ាងគឺ ១- ការលះពួកក្រុមគ្គីគ្នា ហើយចេញទៅសម្ងំនៅកន្លែងស្ងប់ស្ងាត់ហៅថា កាយឧក្កុម: ការលះបង់សំដីទុច្ចរិតចេញហៅថា វចីឧក្កុម: ការលះបង់គំនិតទុច្ចរិតចេញ ហៅថា ចិត្តឧក្កុម: ២- ការលះបង់ទ្រព្យនិងញាតិត្រមាំងគេចត្រូហស្តចេញ ហើយចូលទៅបួសក្នុងពុទ្ធសាសនា ក៏ហៅថា ឧក្កុម: ។

ឧក្កុម: ជាគោលចំណង ឬ ជាទីដៅនៃពុទ្ធសាសនាដោយតិត្រោះថា មានតែឧក្កុមនេះទេ ដែលជាទុច្ចាយដើម្បីគេចចេញចាកកាម ឬចេញចាកកងទុក្ខទាំងពួង ដែលមាននៅប្រចាំក្នុងភពទាំងបី ព្រោះហេតុនោះ បើបុគ្គលណាចំពេញកុសលណាមួយមានទានជាដើម ហើយប្រាថ្នាចង់បានសម្បត្តិក្នុងកាមភព មានសម្បត្តិទេវតាកងឋានសួគ៌ជាដើម ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា បុគ្គលនេះមានសេចក្តីយល់ខុសឬយល់ដោយភ័ន្តច្រឡំ សល្ហកោ វិយ ប្រៀបដូចពួកសត្វល្អិតមានមមាចជាដើម ធម្មតាសត្វមមាចកាលបើឃើញពន្លឺភ្លើងក្នុងរាត្រី គំស្មានថាភ្លើងនោះជារបស់ត្រជាក់គួរកើតយសឬប្រាយ ទាំងនាំគ្នាទៅចោមរោម មិនយូរប៉ុន្មានក៏ដល់នូវសេចក្តីវិនាសក្សីណក្សយដ៏តែ ពីព្រោះតែមានសេចក្តីយល់ខុស

ខោះឯងជាហេតុ ។ មួយយ៉ាងទៀត បើបុគ្គលណាមួយចំតេញរូបាវចរ-
កុសលតឺធ្វើសមាធិកម្មដ្ឋាន បានដល់ខ្ទរឈាន ហើយមានសេចក្តីសប្បាយ
កន្ធឈានដោយសេចក្តីយល់ថា ឈានដែលអាត្មាអញបានខោះឯង ជា
ដំណើរនាំឲ្យអាត្មាអញបានទៅកើតក្នុងព្រហ្មលោក ព្រហ្មលោកខោះជា
ទីបំផុតនៃទុក្ខ ព្រះសព្វញ្ញុពុទ្ធ ព្រះអង្គមានវិចារណញ្ញាណដ៏ជ្រាលជ្រៅ
ទ្រង់ត្រាស់ថា បុគ្គលខោះមានសេចក្តីយល់ខុស ឬយល់ដោយកន្តប្រឡឹ
ឯិសាម្ងន្លេ ដែរ ប្រៀបដូចមនុស្សវង្វេងទិស ធម្មតាមនុស្សវង្វេង
ទិស រមែងមិនស្គាល់ទិសទី ឬផ្លូវដែលធ្វើដំណើរទៅ ហើយបានសេចក្តី
សុខស្រួលទេ តែងតែបានសេចក្តីទុក្ខគ្រោះថ្នាក់ជាធម្មតា ពីព្រោះតែ
មានសេចក្តីវង្វេងយល់ខុសខោះឯងជាហេតុ ព្រោះហេតុអ្វី ? ព្រោះហេតុ
ថា សម្បត្តិកន្ធតាមកតមានសម្បត្តិទៅតាជាដើម ជាបេស់មិនទៀងទាត់
ទាំងអាយុបេស់ទៅតាកន្ធឈានទីមួយ ។ សោតទៀត ក៏មិនទៀងទាត់ដែរ
ព្រោះហេតុនោះ ទៅតាដែលបិតនៅកន្ធឈានទៅលោកនោះ កាលបើ
ដល់កំណត់អាយុហើយ ក៏ត្រូវច្យុតមកកាន់ឋានមនុស្សលោកនេះដដែលវិញ ចំណែកខាងបុគ្គលជាយោគាវចរ ដែលបានទៅកើតក្នុងព្រហ្មលោក
ដោយអំណាចឈាននោះ ក៏មិនទៀងទាត់ កាលបើដល់កំណត់អាយុ
ហើយ ក៏ត្រូវច្យុតមកកើតក្នុងមនុស្សលោកនេះដដែលវិញ ជាហេតុទាំ

ឲ្យធ្វើបុណ្យខ្លះ ធ្វើច្រើនខ្លះជាច្រើនទៀត ។ បុណ្យណាដែលនាំសត្វឲ្យ
អន្តោលយោនយកកំណើតវិលចុះវិលឡើង ពីមនុស្សលោកទៅកាន់ទេវ-
លោកនិងព្រហ្មលោក ឬ ទេវលោកនិងព្រហ្មលោកមកកាន់មនុស្សលោក
វិញ បុណ្យនោះហៅថាបុញ្ញាភិសង្ខារ ។ នេះចាត់ជាវដ្តគាមិកុសល ព្រោះ
ជាកុសលញុំាងសត្វឲ្យធ្វើដំណើរត្រាច់ទ្លាក់នៅតែក្នុងវដ្តសង្សារមិនមានទី
បំផុត ។ បុណ្យណា ទោះជាកាមាវចរកុសលក្តី រូបាវចរកុសលក្តី អរូ-
បាវចរកុសលក្តី ដែលគេធ្វើទៅហើយ មិនជាប់ជំពាក់ដោយកិលេស-
តណ្ហាកង់តតួចតតួចតំាទេ គឺមានច្រើនជាច្រើនបដោយវិបស្សនាឃើញច្បាស់
នូវទោសវចស់សង្ខារទាំងឡាយ កង់តតួចតតំានោះ ។ ហើយរិះរក
ធ្វើយដើម្បីរលាស់ចោលនូវសង្ខារទាំងនោះចេញ បុណ្យនោះហៅថា
វិវដ្តគាមិកុសល ព្រោះជាកុសលញុំាងសត្វឲ្យមានដំណើរឆ្ពោះទៅកាន់
ទីបរមសុខ គឺនិព្វាន ដែលជាដំណើរច្រាសចាកវដ្តសង្សារ ។

នៅទីអាសនៃធម្មវិចារណកថានេះ ខ្ញុំសូមលើកយកពាក្យមួយ
ម៉ាត់គឺសីលតូ្ត ឬសីលតូ្តបកមាសៈ មកអធិប្បាយបែកញែកដោះស្រាយ
ដូនជាសណ្តាប់ ដោយហេតុថា សីលតូ្តបកមាសៈនេះ ជាបញ្ហាមួយដ៏
ស្មុគ្រស្មាញ គេមិនអាចនឹងវិនិច្ឆ័យសេចក្តីឲ្យបានច្បាស់លាស់ដាយរួ
មកហើយ តាព្រោះមតិរបស់បុគ្គលខ្លះយល់ដូច្នេះ បុគ្គលខ្លះយល់ដូច្នោះ

ឧទាហរណ៍ ដូចអ្នកខ្វះយល់ថា ពួកវិជ្ជា មន្ត អាគម គាថា អ្នមអាម
ពាំងប៉ុន្មានហៅថាសីលព្វតបរាមាស: អ្នកខ្វះយល់ថា ការកាន់សាសនា
ដទៃក្រៅពីពុទ្ធសាសនាពាំងប៉ុន្មានហៅថា សីលព្វតបរាមាស: អ្នកខ្វះយល់
ថា សីលទីធ៌វត្តរបស់សមណព្រាហ្មណ៍ពាំងឡាយ ខាងក្រៅពុទ្ធសាសនា
នេះពាំងប៉ុន្មាន ហៅថា សីលព្វតបរាមាស: សេចក្តីយល់អស់ពាំងនេះជា
ការគួរដែរ ខ្ញុំក៏តុំអាចបដិសេធបានឡើយ ។ មួយយ៉ាងទៀត តាមន័យ
ក្នុងអដ្ឋកថា សុត្តន្តបិដកថា ការប្រព្រឹត្តិកាន់តាមវត្តគោ ឬវត្តសុនខ ហៅ
ថា សីលព្វតបរាមាស: ដូចជា សេដ្ឋបុត្រតីរោគក់ជាមិត្រទីធ៌គ្នាតាំងពីក្មេង
មក ។ សេដ្ឋបុត្រពាំងតីរោគក់នោះ លុះមានវ័យចំរើនធំឡើងរៀងខ្លួន មាន
សេចក្តីខឿយណាយទីធ៌ការនៅគ្រប់គ្រងផ្ទះសម្បែង ហើយក៏គិតគ្នាថា
យើងគួរកេចបាយប្រព្រឹត្តប្រតិបត្តិបែបយ៉ាងណា ដើម្បីញ៉ាំងខ្លួនយើងឲ្យ
បានសេចក្តីបរិសុទ្ធិទីធ៌សេចក្តីសុខសម្រាប់អនាគតរបស់យើង ។ បណ្តា
សេដ្ឋបុត្រពាំងតីរោគក់នោះ សេដ្ឋបុត្រម្នាក់ គិតឃើញថា គោជាសត្វ
ស្រួលជាងគេពាំងអស់ ពីព្រោះគោគ្មានឃ្មាំង ឬជង្រុកសម្រាប់សន្សំ
បៃស់ទ្រព្យខុកជាក់ខេ កាលបើសេចក្តីស្រេកឃ្លានកើតឡើង ក៏ដើរស្មៅ
រកស្មៅឬស្មឹកឈើ ទីធ៌ទឹកដែលមានស្រាប់ ៗ ជាអាហារ ឥតមានត្រួយ
អំពីការខ្វះខាតអ្វីឡើយ បើធ្វើយ៉ាងនេះ ទើបឈ្មោះថាអាត្មាអញធ្វើខ្លួន

ឲ្យចរិសុទ្ធិបាន ។ ចំណែកខាងសេដ្ឋីបុត្រម្នាក់ទៀត គិតឃើញថា ឆ្កែជាសត្វស្រួលជាងគេចាំងអស់ ពីព្រោះឆ្កែគ្មានឃ្លាំង ឬជង្រុកសម្រាប់សន្សំទ្រព្យរបស់ខុកជាក់ខេ កាលបើមានសេចក្តីស្រេកឃ្លានកើតឡើង ក៏ដើរស្វែងរកអាហារដែលមានស្រាប់ ។ ចរិកោគៅ មិនចាប់ព្រួយអំពីការខ្វះខាតអ្វីឡើយ បើធ្វើយ៉ាងនេះ ទើបឈ្មោះថាអាត្មាអញធ្វើខ្លួនឲ្យមានសេចក្តីចរិសុទ្ធិបាន ។

សេដ្ឋីបុត្រដែលយល់ឃើញគោស្រួល ហើយក៏តាំងផ្តើមប្រព្រឹត្តវត្តគោ យកស្មៅគោមកចំបន្ថុបពីលើក្បាលធ្វើជាស្មៅ យកកន្ទុយគោមកចងភ្ជាប់ពីក្រោយធ្វើជាកន្ទុយរបស់ខ្លួន ដៃជាំងពីរធ្វើជាជើង ។ គោវត្តៈ ការប្រព្រឹត្តិរបស់គោ គោសីល ប្រក្រតីរបស់គោ កង-កប្បៈ អាកប្បកិរិយា (សណ្តាប់ធ្នាប់) របស់គោ កងចារៈ អាចារៈ (មារយាទ) របស់គោ យ៉ាងណា ឯសេដ្ឋីបុត្រនោះ ក៏ប្រព្រឹត្តដូចជាគោយ៉ាងនោះដែរ ។ សេដ្ឋីបុត្រដែលយល់ឃើញថាឆ្កែស្រួល ក៏តាំងប្រព្រឹត្តវត្តឆ្កែ គឺយកកន្ទុយឆ្កែមកចងជាប់ខាងក្រោយធ្វើជាកន្ទុយរបស់ខ្លួន ដៃជាំងពីរធ្វើជាជើង ។ កុក្កុរវត្តៈ ការប្រព្រឹត្តរបស់ឆ្កែ កុក្កុរ-សីលៈ ប្រក្រតីរបស់ឆ្កែ កុក្កុរកប្បៈ អាកប្បកិរិយារបស់ឆ្កែ កុក្កុរចារៈ អាចារៈរបស់ឆ្កែ យ៉ាងណា សេដ្ឋីបុត្រនោះ ក៏ប្រព្រឹត្តដូចជាឆ្កែយ៉ាងនោះដែរ ។ ការប្រព្រឹត្តិវត្តគោ ទំនងវត្តឆ្កែរបស់សេដ្ឋីបុត្រ

តាំងពីខែក់ខែះអស់ ១២ ឆ្នាំ ។ ថ្ងៃមួយ អ្នកតាំងពីរខែះបានជួបគ្នា ក៏
តាំងពោលអួតគុណវិសេសរបស់ខ្លួន ។ ថាគ្រាន់បើប្រសើរជាងគ្នាទៅវិញ
ទៅមក ប៉ុន្តែអ្នកតាំងពីរខែះ មិនអាចញុំាងគ្នាទឹងគ្នាឲ្យសុខចិត្តបាន
ឡើយ ។ ថ្ងៃក្រោយមក សេដ្ឋីបុត្រតាំងពីខែក់ខែះ ឮដំណឹងថា ព្រះ
សម្មាសម្ពុទ្ធបានត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គមានប្រាជ្ញាញាណ
ដំខែះមុតប្រសើរជាងមនុស្ស ខែតា មារ និងព្រហ្មតាំងអស់ ខែះបើមាន
អ្នកណាមួយសួរបញ្ហាដ៏ល្អិតជ្រាលជ្រៅដាំងណា ព្រះអង្គកំអាចដោះ
ស្រាយបានតាំងអស់ ដោយឥតមានទើសទាក់ទឹងអ្វីឡើយ កំពាំគ្នាទៅ
កាន់សំណាក់ព្រះអង្គ លុះដល់ហើយក៏ថ្វាយបង្គំ ហើយក្រាបទូលអំពី
គុណវិសេសរបស់ខ្លួន ដើម្បីឲ្យព្រះអង្គទ្រង់ជ្រាបថា តើខាងណាប្រសើរ
ជាងខាងណា ? ខណៈខែះ ព្រះសម្ពុទ្ធបរមគ្រូទ្រង់មិនព្យាករថាអ្នកណា
វិសេសជាងអ្នកណាខែ ព្រោះព្រះអង្គជ្រាបថា ការប្រព្រឹត្តវត្តគោនិងវត្តឆ្កែ
របស់សេដ្ឋីបុត្រតាំងពីខែះជាអត្តកិលមថានុយោគដូចគ្នា ។ លំដាប់ខែះ
ព្រះអង្គទ្រង់សំដែងអំពីវត្តតាំងពីយ៉ាយរបស់បុគ្គលអ្នកមានសេចក្តីយល់ខុស
ហើយប្រព្រឹត្តវត្តញុំាងខ្លួនឲ្យបានសេចក្តីទុក្ខលំបាកឥតផលប្រយោជន៍ ដូច
ជាការប្រព្រឹត្តវត្ត គឺព្យាយាមអង្គុយហាលកំដៅថ្ងៃក្តៅ បង្អត់អាហារខ្លួន
ឯងអស់ជាច្រើនថ្ងៃក្តៅ ដុតកៅងឆ្អែរខ្លួនឯងក្តៅ យ៉ាងនេះជាដើម កិពាប់

បញ្ចូលក្នុងអត្តកិលមថានុយោគវត្តចាំងអស់ ។ សេដ្ឋបុត្រចាំងពីរនាក់
នោះ លុះស្តាប់ធម្មទេសនារបស់ព្រះអង្គចប់ហើយ គិយល់ថា វត្តដែល
ខ្លួនបានគ្រាយាមប្រព្រឹត្តអស់រយៈកាល ១៦ ឆ្នាំ ត្រឡប់ជាគ្មានផលប្រ-
យោជន៍អ្វីសោះ គឺព្រោយដោយនឹកស្តាយបង់គំនិតដែលគិតខុស
នោះ ។ ក្នុងខណៈនោះ អ្នកចាំងពីរគឺនាំគ្នាលះបង់វត្តគោធិរត្តឆែនោះ
ចេញ ហើយប្រកាសខ្លួនជាសាវ័កចូលក្នុងពុទ្ធសាសនាវិញ ។ ការប្រ-
ព្រឹត្តិវត្តគោធិរត្តឆែរបស់សេដ្ឋបុត្រចាំងពីរនាក់ ដូចបានតំណាលមកនេះ
គឺហៅថា សីលព្វតបរាមាសៈដែរ ។ ប៉ុន្តែចំណែកធម៌នេះ ខ្ញុំបានពិនិត្យ
មើលសេចក្តីជាច្រើនអន្លើក្នុងអដ្ឋកថានៃសុត្តន្តបិដក ព្រមទាំងមតិរបស់ខ្ញុំ
ផងយល់ថា សីលព្វតបរាមាសៈនេះប្រែថា ការស្មោចអង្អែលឬការប្រ-
កាន់ខ្ជាប់នូវសីល និងវត្ត បានន័យថា ការប្រកាន់ខ្ជាប់នូវសីលនិងវត្តរបស់
សមណព្រាហ្មណ៍ (អ្នកបួសខាងក្រៅពុទ្ធសាសនា) ដោយគំនិតយល់
ថា សេចក្តីបរិសុទ្ធិរបស់អាត្មាអញមិនមែនដោយហេតុដទៃទេ គឺដោយ
សារសីល និង វត្តដែលអាត្មាអញបានកាន់ប្រព្រឹត្តនេះឯង ។ សមណ-
ព្រាហ្មណ៍ជាអ្នកបួសខាងក្រៅពុទ្ធសាសនានោះ តើសំដៅយកអ្នកបួស
បែបណា? សំដៅយកបុគ្គលដែលមានសេចក្តីឰឡែយណាយក្នុងកាម ចាំង
ឃើញទោសផ្សេងៗរបស់កាម ហើយចេញទៅបួសជាតាបសប្តូរស ។

តាបស ឬឥសី ពួកនេះជាកម្មាភិបុគ្គល (អ្នកធ្វើកម្មនិងផលរបស់កម្ម) ជាន់ប្រព្រឹត្តតបធម៌ គឺ សីលនិងវត្តយ៉ាងតឹងរ៉ឹង ទាំងមានគំនិតយល់ថា សេចក្តីចរិសុទ្ធិផុតចាកទុក្ខរបស់អាត្មាអញក្នុងសង្សារនេះ អាស្រ័យដោយសារសីលនិងវត្តដែលអាត្មាអញប្រព្រឹត្តនេះ ។ ការប្រព្រឹត្តិកាន់សីលនិងវត្តរបស់តាបស ឬឥសីពួកនេះដោយមានបំណងខ្ពោះទៅរកសុខក្នុងភពតែម្យ៉ាងប៉ុណ្ណោះ ឈ្មោះថា សីលព្វតបរាមាសៈ ព្រោះហេតុអ្វី ? ព្រោះហេតុថា តាបស ឬឥសី ពួកនេះ ប្រព្រឹត្តតបធម៌នៅជាប់ជំពាក់ដោយកិលេសតណ្ហានៅឡើយ ឬថាមិនទាន់ឃើញទោសក្នុងភពនៅឡើយ ។ ត្រង់តាបស ឬឥសីខាងក្រៅពុទ្ធសាសនា ប្រព្រឹត្តកាន់សីលនិងវត្តដោយមានគំនិតយល់ដូចជាន់ពោលមកហើយនោះ លោកចាត់ថាជាសីលព្វតបរាមាសៈ ចុះចំណែកខាងពុទ្ធបរិស័ទទាំងឧបាសិកាទាំងគ្រហស្ថ ក្នុងពុទ្ធសាសនា បើប្រព្រឹត្តព្រហ្មចរិយធម៌គឺ សីលនិងវត្ត ហើយមានគំនិតយល់ដូចជាពួកតាបស ឬឥសីខាងក្រៅពុទ្ធសាសនានោះដែរ តើអាចចាត់ថាជាសីលព្វតបរាមាសៈបានដែរឬទេ ? អាចចាត់ថាជាសីលព្វតបរាមាសៈបានដោយពិត ព្រោះនៅមានគំនិតជាប់ជំពាក់ដោយកិលេសតណ្ហា ក្នុងភពដូចគ្នា ។ បើយើងយល់ថា សីលព្វតបរាមាសៈ មានតែលើបុគ្គលខាងក្រៅពុទ្ធសាសនាតែម្យ៉ាង ឯបុគ្គលអ្នកកាន់ពុទ្ធសាសនាមិនមាន

សីលព្រតបរាមាសៈទេ ចុះហេតុអ្វីក៏គេតម្កើងជាច្រើនអនេកនេះថា ប្គលអ្នកបានដល់នូវសោតាបត្តិមគ្គ ឬសោតាបត្តិផល ទើបអាចលះផ្តាច់នូវសីលព្រតបរាមាសៈចេញបាន ។ សេចក្តីនេះ យើងអាចសន្និដ្ឋានថា ប្គលណាមួយដែលមានសន្តានចិត្តនៅជាប្ថុជ្ជនៅឡើយ ប្គលនោះឈ្មោះថានៅជាប់ជាប់ជាយសីលព្រតបរាមាសៈដូចគ្នាទាំងអស់ ដោយហេតុថា សីលព្រតបរាមាសៈនេះជាពួកនៃសំយោជនធម៌ លុះតែអរិយមគ្គអរិយផលកើតឡើងកាលណា ទើបអាចលះបង់បានន្ទូវសីលព្រតបរាមាសៈកាលនោះ ។

ចប់ ធម្មវិចារណាកថា ដោយសង្ខេប

ប្រកាធម្មបទ - ទុកនិកាយ

លោក ហេង-សមអាង រៀបរៀង

(តចប់)

កំឯកុសលកម្មបថ ១០ ប្រការនេះ ព្រះមានព្រះភាគទ្រង់សំដែងថា គ្រាន់តែដាក់បទនិស្សយនៃទេវលោកជាន់លើ ៗ ខោះប៉ុណ្ណោះ ដ្បិតកុសលកម្មបថ ១០ ប្រការ ឈ្មោះថា សីល បុគ្គលលុះស្ថិតនៅក្នុងសីលធ្វើទូវកសិណបរិកម្ម ញ៉ាំងឈានមួយឲ្យកើតឡើង ទើបទៅកើតក្នុងឋានមួយក្នុងភូមិបាន ញ៉ាំងទុតិយជ្ឈានឲ្យកើតឡើង ទើបទៅកើតក្នុងទុតិយជ្ឈានភូមិបាន ញ៉ាំងតតិយជ្ឈានឲ្យកើតឡើង ទើបទៅកើតក្នុងតតិយជ្ឈានភូមិបាន ញ៉ាំងចតុត្ថជ្ឈានឲ្យកើតឡើង ទើបទៅកើតក្នុងចតុត្ថជ្ឈានភូមិបាន ធ្វើទូវកូបាចារជ្ឈានឲ្យជាដើងទ្រ ចំរើនវិបស្សនាបានដល់អនាគាមិផលហើយ ទើបទៅកើតក្នុងសុទ្ធាវាសទាំង ៥ ឋាយបាន ធ្វើទូវកូបាចារជ្ឈានឲ្យជាដើងទ្រ ញ៉ាំងអរូបាចារសមាបត្តិឲ្យកើតឡើងហើយ ទើបទៅកើតក្នុងអរូបាចារភូមិបាន ធ្វើទូវកូបាចារជ្ឈាន ទំនងអរូបាចារជ្ឈានឲ្យជាដើងទ្រ ចំរើនវិបស្សនាទើបបានសម្រេចព្រះអរហត្ត កំចាត់ទូវកិលេសាសវៈទាំងពួងបាន ។ ព្រះសម្ពុទ្ធមានភុទ្ធដីកាថា កុសលកម្មបថអាចឲ្យផលច្រើនជាអនេកដូចន័យដែលធ្វើយមកដូច្នេះ" ។

គោលប្បាប់ព្រះពុទ្ធសាសនាខ្លី ២ នេះ គឺឲ្យចំពេញកុសលឲ្យបរិបូណ៌ ធ្វើសេចក្តីល្អឲ្យកើតមានឡើងក្នុងខ្លួនសន្តាន ដូចន័យដែលសំដែងមកនេះ ពាក់ជាជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

ការលះបាបអកុសល និងការបំពេញកុសលឲ្យបរិបូណ៌ នេះជាកិច្ចវត្តដ៏ធ្ងន់ធ្ងរមិនខាន តែមិនខាន់អស់ការប្រតិបត្តិតទៅទៀតទេ ព្រោះថាមនុស្សក្នុងពិភពលោក បពិត្រក្នុងឋានៈជាបុថុជ្ជន តែងតែមានចិត្តពាក់ព្រន្ធាក់ដោយកិលេស នាំឲ្យធ្លាក់ក្រាញរើរុះដោយការប៉ះប្រទះ នឹងអារម្មណ៍ទាំងឡាយ ដែលអាចចូលមកញាំញីត្រូវសង្កត់សន្តានចិត្ត ព្រោះចិត្តដែលនៅប្រកបដោយកិលេសនៅឡើយ ចិត្តរបស់បុថុជ្ជន នៅញាប់ញ័រដោយលោកធម៌ ។ កាលបើមានចិត្តត្រេកអរ ក្នុងការលះអកុសលបំពេញកុសលនោះ ច្រើនតែបិតនៅក្នុងពេលកំពុងធ្វើ កំពុងប្រតិបត្តិ លុះផុតពីពេលនោះហើយ ចិត្តរបស់បុថុជ្ជន ច្រើនផ្លាស់ប្តូរងាកបែរទៅរកអំពើបាបអកុសលវិញ ។

ហេតុនេះ បុគ្គលអ្នកមានការណ៍យកចិត្តទុកក្នុងការបំពេញសេចក្តីល្អ គប្បីធ្វើចិត្តឲ្យស្អាតផូរផង់ តាមគោលប្បាប់នៃព្រះពុទ្ធសាសនាខ្លី ៣ តទៅទៀត ។

៣- សចិត្តបរិយោទបនំ ការជុះខាត់សំអាតចិត្តរបស់ខ្លួន (គោលខ្លី ៣ នេះសង្គ្រោះចូលក្នុងអភិធម្មបិដក) ។

ពាក្យថា ការដុសខាត់សំអាតចិត្តរបស់ខ្លួន ចាន់ដល់ការញុំាង
ចិត្តរបស់ខ្លួនឲ្យបរិសុទ្ធដោយសព្វគ្រប់ ដរាបចាន់ដល់សម្រេចមគ្គផល
មានព្រះអរហត្តជាទីបំផុត ។

ចិត្តៈ សព្ទនេះប្រែថា "ធម្មជាតិសម្រាប់សន្សំអារម្មណ៍ សម្រាប់
គិត សម្រាប់ផ្ទើសើរើសនូវអារម្មណ៍" ។

ចិត្តៈ គឺធម្មជាតិល្អិតប្រកបដោយបរមានុភាពល្អិតយ៉ាងក្រៃលែង
ឥតមានរូបកាយសណ្ឋានទ្រង់ទ្រាយយ៉ាងនេះយ៉ាងនោះឡើយ គ្រាន់តែជា
នាមធម៌ម្យ៉ាង បើទំាយោយទាយបញ្ចក្ខន្ធ គឺវិញ្ញាណនោះឯង ជារបស់
ប្រែប្រួលរេរួយរោយរាច់ឥតឈប់ ក្រឡប់ត្រឡិនទៅមកដោយឆាប់រហ័ស
ជួនកាលយ៉ាងនេះ ជួនកាលយ៉ាងនោះ ចាន់ជាលោកសំដែងអំពីប្រភេទ
របស់ចិត្ត ក្នុងគម្ពីរព្រះអភិធម្មដោយពិស្តារថាមាន១២១ដួង ដោយសង្ខេប
៨៩ ដួង ។ ប៉ុន្តែចិត្តនេះជាធម្មជាតិតែមួយទេ ដែលចាន់ជាច្រើនដូច្នេះ
ព្រោះចែកតាមប្រភេទនៃការប្រព្រឹត្តទៅ កាលបើប្រព្រឹត្តទៅយ៉ាងណា
ក៏ឲ្យឈ្មោះតាមអាការៈដែលប្រព្រឹត្តទៅយ៉ាងនោះ ។

ចិត្តនេះជាធម្មជាតិមិនរើសអារម្មណ៍ ក៏កុងអារម្មណ៍ទាំង ៦ នោះ
តាមតែអារម្មណ៍ណាក៏ដោយ ចិត្តតែងតែត្រូវការគិត ត្រូវការដឹង ត្រូវ
ការសន្សំទាំងអស់ ។ បើអារម្មណ៍មកកាន់ឆ្វេងនឹកក្អែកហើយ ចិត្តក៏កើត
ឡើងភ្លាមឲ្យលួសឃើញ ឲ្យលួសដឹងថារូបនេះរូបនោះ ។ បើសព្វអារម្មណ៍

គន្ធារម្មណ៍ ដោជញ្ជារម្មេ ធម្មារម្មណ៍ ប្លូលមកកាន់ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ហើយវិចិត្តកំកើតឡើងភ្លាម ខ្លួលភ្ញ ខ្លួលហិត ជញ្ជក់ ជញ្ជាប់ តិតថា នេះសំឡេង នេះក្លិន នេះរស នេះសម្ផស្ស នេះធម៌ ដោយពិតឥតអាក់ខានឡើយ ។

ចិត្តនេះជាធម្មជាតិសំខាន់ប៉ំផុត បុគ្គលបានសុខ ក៏ព្រោះចិត្ត បានទុក្ខក៏ព្រោះចិត្ត សម្រេចព្រះនិព្វានក៏ព្រោះចិត្ត ។

បានទុក្ខក៏ព្រោះបិត្ត បានសុខក៏ព្រោះបិត្ត

ត្រង់ពាក្យថា " បានទុក្ខក៏ព្រោះបិត្ត បានសុខក៏ព្រោះបិត្ត " នោះអធិប្បាយថា បុគ្គលនឹងធ្វើកិច្ចការអ្វី ។ ដោយពាក្យ ក៏ព្រោះតែចិត្ត ផ្តើមជាមុនទើបធ្វើបាន កាលបើចិត្តគិតខុសហើយ កិច្ចការនោះ ។ ក៏មិនបានល្អ ថែមទាំងមានសេចក្តីទុក្ខកើតឡើងផង បើចិត្តរិះគិតត្រូវ ទើបបានផលល្អ ជាគុណឲ្យបានសេចក្តីសុខចំរើនដល់ខ្លួន ។ ព្រោះកម្មគឺអំពើដែលសត្វធ្វើត្រង់យ៉ាង ដែលនឹងមានផលក្រៀវក្រា ក៏អាស្រ័យនឹងចេតនា ឯចេតនាគឺតួកម្ម បានជាព្រះមុនិន្ទលោកាចារ្យទ្រង់ត្រាស់ថា ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ម្នាលភិក្ខុទាំងឡាយ តថាគតតែងថា ចេតនាជាតួកម្ម ។

កាលបើសត្វទាំងឡាយធ្វើអំពើណាមួយ ប្រកបដោយសេចក្តីលោភ សេចក្តីក្រោធ សេចក្តីវង្វែង អំពើនោះចាត់ជាអកុសលកម្ម បើប្រកប

ដោយសេចក្តីមិនលោភ សេចក្តីមិនក្រោធ សេចក្តីមិនវង្វែង អំពើទោះ
លោភជាដើមជាកុសលកម្ម ។ កម្មទាំងពីរនេះឲ្យឈ្មោះស្មើគ្នា គឺកុសលកម្ម
ឲ្យផលជាសុខ អកុសលកម្មឲ្យផលជាទុក្ខ ។ ដូចមានពុទ្ធភាសិត
បញ្ជាក់ថា ៖

យាទិសំ វបតេ ពីជំ តាទិសំ លភតេ ផលំ
កល្យាណការី កល្យាណំ បាបការី ច បាបកំ ។

មនុស្សក្នុងលោក គេសាបព្រោះពូជបែបណា តែងដុះកើតជាន
ដើមបញ្ចេញផ្លែមកដាបែបនោះវិញ មានឧបមាដូចម្តេចមិញ
កល្យាណជន អ្នកធ្វើអំពើល្អ តែងជួបផលល្អ ជាបជនអ្នកធ្វើអំពើ
អាក្រក់ តែងជួបផលអាក្រក់ ។

សុភាសិតនេះ សំដែងចុចចំផ្ទុសសេចក្តីឲ្យឃើញថា បើសត្វណា
បានធ្វើអំពើល្អឬអាក្រក់ ដំពើទោះឯង គឺបែងចែករំលែកឲ្យសត្វនោះ ។
បានល្អឬអាក្រក់តាមបែបដែលធ្វើ ។ អំពើអាក្រក់នាំសត្វទៅកាន់ទុគ្គតិ
អំពើល្អនាំសត្វទៅកាន់សុគតិ ។ អំពើទាំងនេះ គឺសម្រេចតាមតែអំពីចិត្ត
ជាប្រកពនាំមាគ៌ាជាមុនទាំងអស់ ។

អំពើអាក្រក់ឲ្យផលជាទុក្ខកើតឡើងអំពីចិត្តជានាយហើហ្វាយ បញ្ជា
ការយទំនឹកចាឲ្យធ្វើអាក្រក់ ឧទាហរណ៍ដូចជា ៖

រឿងប្រែត ១០ នាក់[1]

កាលព្រះមានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ កាលនោះព្រះមោគ្គល្លានត្ថេរ និងព្រះលក្ខណត្ថេរ គង់នៅលើភ្នំគិជ្ឈកូដ ក្នុងបុព្វណ្ហសម័យ ។ ព្រះថេរៈទាំងពីរអង្គ នាំគ្នាចុះពីភ្នំគិជ្ឈកូដ ដើម្បីទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ។ កាលដែលកំពុងចុះពីភ្នំនោះ ព្រះមោគ្គល្លានបានឃើញប្រេតទាំង ១០ នាក់កំពុងរងទុក្ខវេទនា លោកក៏បានធ្វើខ្លួនការញញឹម ។ ព្រះលក្ខណត្ថេរ ឃើញព្រះមោគ្គល្លានញញឹម ក៏សួរថា « ដូចម្តេច បានជាលោកញញឹម ? » ព្រះមោគ្គល្លានតបថា « ពេលនេះខ្ញុំពុំគួរប្រាប់ទេ លោកចាំសួរខ្ញុំក្នុងទីចំពោះព្រះភ័ក្ត្រព្រះសាស្តាចុះ » ។

លុះត្រឡប់មកពីបិណ្ឌបាតក្នុងពេលក្រោយភត្ត ព្រះថេរៈទាំងពីរអង្គ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយគង់ក្នុងទីដ៏សមគួរ ។ ព្រះលក្ខណត្ថេរ សួរព្រះមោគ្គល្លានថា ហេតុដូចម្តេចបានជាលោកញញឹមពេលនោះ ? ព្រះមោគ្គល្លានប្រាប់ថា ក្នុងពេលនោះខ្ញុំបានឃើញប្រេត ១០ នាក់ មានអាការៈប្លែក ។ គឺថា :

ទី១– ខ្ញុំឃើញ អដ្ឋិសង្ខលិកៈ គឺកងឆ្អឹងកំពុងអណ្តែតនៅលើអាកាស ពួកគ្នាតែប្លែក ដេញតាមធាប ចឹកចោះ កេចដណ្តើងខួរកងឆ្អឹងនោះ កងឆ្អឹងនោះចេះតែស្រែកថ្ងូរ ។ ម្ចាលអាវុសោ ! ខ្ញុំគិតថា អើ !

១– ជាតស័យុត្តនិកាយ ត្រង់លក្ខណសំយុត្ត អដ្ឋិសង្ខលិកវគ្គ ។

ហ្ន៎ ! អស្ចារ្យណាស់ យើងអើ ! មិនដែលឃើញសោះ យើងអើ ! ការបាន អត្តភាពបែបនេះមានដែរតើ ដោយហេតុនេះបានជាខ្ញុំញញឹម ។

គ្រានោះឯង ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ សត្វនោះតថាគតបានឃើញអំពីមុនមកដែរ ។ ប៉ុន្តែតថាគតមិនទាន់សំដែង ព្រោះថាបើតថាគតសំដែងរឿងសត្វនោះទៅ ជនទាំងឡាយណា ដែលមិនជឿពាក្យតថាគត ជនទាំងឡាយនោះនឹងមានប្រយោជន៍ទាំងឡាយតែសេចក្តីទុក្ខអស់កាលជាអង្វែង ប៉ុន្តែវេលានេះ សាវ័កបស់តថាគត មានចក្ខុបានឃើញដែរហើយ ។ ដូច្នេះត្រូវតែតថាគតសំដែងប្រាប់ផលកម្មបស់សត្វនោះ ។ ម្នាលភិក្ខុទាំងឡាយ សត្វនោះ កាលពីដើមជាគោឃាតកៈ នៅក្រុងពជគ្រឹះនេះឯង ដោយវិបាកបស់កម្មនោះ ក៏នៅនេះក្នុងនរកជាអង្វែង សេសសល់តិចតួចនៃកម្មនោះ ក៏ត្រឡប់មកកើតបានអត្តភាពបែបនេះឯង " ។

ម៉ែ- ខ្ញុំបានឃើញ មិនសេសសល់ តិចរៀកសាច់ អណ្តែតលើអាកាស ពួកត្មាត ក្អែក វេញតាមធាប ចឹកចោះ តោចដណ្តើងទូរចំរៀកសាច់នោះ ចំរៀកសាច់នោះក៏ចេះតែស្រែកថ្ងូរ ។

ព្រះសាស្តា ទ្រង់ត្រាស់សំដែងប្រាប់បុព្វកម្មបស់សត្វនោះ " ម្នាលភិក្ខុទាំងឡាយ សត្វនោះកាលពីដើមជាគោឃាតកៈនៅក្រុងពជគ្រឹះនេះឯង " ។

ទី ៣- ខ្ញុំបានឃើញ មឹសបិណ្ឌាៈ តឹដុំសាច់កំពុងអណ្តែតលើអាកាស ពួកភ្នាត ក្អែក ដេញតាមឆាប ចឹកចោះ កើចជញ្ជែងនូវសាច់ដុំនោះ សាច់ដុំនោះក៏ចេះតែស្រែកថ្ងូរ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សំដែងប្រាប់នូវបុព្វកម្មរបស់សត្វនោះថា "ម្នាលភិក្ខុទាំងឡាយ សត្វនោះ កាលពីដើមជាព្រានបក្សីនៅក្នុងក្រុងរាជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះក៏ទៅនេះក្នុងនរកជាអង្វែង សេសសល់វិបាករបស់កម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង" ។

ទី ៤- ខ្ញុំបានឃើញ ឯឆ្ងាវីបុរស តឹបុរសមិនមានស្បែកខាងក្រៅ កំពុងអណ្តែតលើអាកាស ពួកភ្នាត ក្អែក ដេញតាមឆាប ចឹកចោះ កើចជញ្ជែងនូវបុរសគ្មានស្បែកនោះ។ ក៏ចេះតែស្រែកថ្ងូរ ។

ព្រះបរមលោកនាថ ទ្រង់ត្រាស់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះថា "ម្នាលភិក្ខុទាំងឡាយ សត្វនោះកាលពីដើមជាអ្នកសម្លាប់ចៀមនៅក្នុងក្រុងរាជគ្រឹះនេះឯង ។ ដោយវិបាករបស់កម្មនោះ ក៏ទៅនេះក្នុងនរកអស់កាលជាអង្វែង សេសសល់វិបាករបស់កម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង" ។

ទី ៥- ខ្ញុំបានឃើញ អសិលោមបុរស តឹបុរសមានរោមដូចជាវ៉ៃ កំពុងអណ្តែតលើអាកាស ជាវ៉ៃទាំងនោះក៏អណ្តែតភ្លាត់ ។ មកត្រូវ

កាយបុរសនោះ ។ បេះតែស្រែកថ្ងូរ ” ។

ព្រះចរមសាស្តាចារ្យ ទ្រង់ត្រាស់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះ ថា “ ម្នាលភិក្ខុទាំងឡាយ សត្វនោះ កាលពីដើមជាអ្នកសម្លាប់ជ្រូកនៅក្នុងក្រុងកជង្គឹនេះឯង ។ ដោយវិបាករបស់កម្មនោះ ក៏ទៅនេះក្នុងនរកអស់កាលជាអង្វែង សេសសល់វិបាកនៃកម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ” ។

ទី ๖- ខ្ញុំបានឃើញ សត្តិលោមបុរស គឺបុរសមានទេមដូចជាលំពែងកំពុងអណ្តែតលើអាកាស លំពែងទាំងនោះក៏អណ្តែតធ្លាក់មកត្រូវកាយបុរសនោះ ។ ក៏បេះតែស្រែកថ្ងូរ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះថា “ ម្នាលភិក្ខុទាំងឡាយ សត្វនោះតាំងើមជាព្រានម្រឹគនៅក្នុងក្រុងកជង្គឹនេះឯង ដោយវិបាករបស់កម្មនោះ ក៏ទៅនេះក្នុងនរកអស់កាលជាយូរ ។ សេសសល់វិបាកនៃកម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង ” ។

ទី ๗- ខ្ញុំបានឃើញ ឧសុលោមបុរស គឺបុរសមានទេមដូចព្រួញកំពុងអណ្តែតលើអាកាស ព្រួញទាំងនោះក៏អណ្តែតធ្លាក់មកត្រូវកាយបុរសនោះ។ ក៏បេះតែស្រែកថ្ងូរ ។

ព្រះមុនីន្ទលោកវិត្រ ទ្រង់ត្រាស់សំដែងប្រាប់បុព្វកម្មរបស់ជ្រូតនោះ

ថា "ម្នាលភិក្ខុទាំងឡាយ សត្វនោះ កាលពីដើមជាតេជ្ឈយោតនៅក្នុងក្រុងរាជគ្រឹះនោះឯង" ។

ខ៨- ខ្ញុំបានឃើញ សុចិលោមបុរស គឺបុរសមានរោមដូចដែកស្រួច កំពុងអណ្តែតលើអាកាស ដែកស្រួចទាំងនោះក៏អណ្តែតធ្លាក់មកត្រូវកាយបុរសនោះ។ ក៏ចេះតែស្រែកថ្ងូរ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះថា "ម្នាលភិក្ខុទាំងឡាយ សត្វនោះ ពីដើមជាអ្នកចរបំបោលគោ នៅក្នុងក្រុងរាជគ្រឹះនេះឯង" ។

ខ៨- ខ្ញុំបានឃើញ សុចិលោមបុរស គឺបុរសមានរោមដូចដែកស្រួច កំពុងអណ្តែតលើអាកាស ដែកស្រួចនោះ ក៏ជោតចូលទៅក្នុងក្បាល ធ្លាយចេញមកតាមមាត់ ជោតចូលទៅក្នុងមាត់ ធ្លាយចេញមកតាមច្រមុះ ជោតចូលទៅក្នុងច្រមុះ ធ្លាយតាមភ្នែក ជោតចូលក្នុងភ្នែក ធ្លាយចេញមកតាមត្រចៀក ជោតចូលទៅក្នុងត្រចៀក ធ្លាយចេញមកតាមស្មៅង ជោតចូលក្នុងស្មៅង ធ្លាយចេញតាមជាតជើង បុរសនោះក៏ចេះតែស្រែកថ្ងូរ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សំដែងប្រាប់បុព្វកម្មរបស់សត្វនោះថា "ម្នាលភិក្ខុទាំងឡាយ សត្វនោះកាលពីដើមជាអ្នកញុះញង់គេនៅក្នុងក្រុងរាជគ្រឹះនេះឯង" ។

ទី ១០- ខ្ញុំបាននឃើញ ក្បាលស្មាបុរស តឹបុរសមានអណ្តែប៉ុន
ភ្នំ កំពុងអណ្តែតលើអាកាស កាលបុរសនោះដើរទៅ លុះតែលើក
អណ្តែលើទើបដើរទៅបាន កាលអង្គុយក៏អង្គុយសង្កត់លើអណ្តែនោះឯង
ពួកត្មាត ក្អែក ដេញតាមឆាប ចឹកចោះ តើចដណ្តែនខ្លួនបុរសនោះ ។
ក៏ចេះតែស្រែកថ្ងូរ ។

ព្រះសាស្តាចារ្យនៃយើង ទ្រង់ត្រាស់សំដែងប្រាប់នូវវិបាកកម្មរបស់
សត្វនោះថា « ម្នាលភិក្ខុទាំងឡាយ សត្វនោះកាលតឹដើមជាអ្នកកាន់
អំពើរឿង ជាអ្នកនិច្ចយកាត់ក្តីដោយទុច្ចរិតនៅក្នុងក្រុងពជគ្រឹះនេះឯង »
ព្រះសាស្តាទ្រង់ត្រាស់បញ្ជាក់ថា « ម្នាលភិក្ខុទាំងឡាយ សត្វទាំង
១០ នោះ សុទ្ធតែទៅនេះក្នុងនរកអស់កាលដ៏យូរអង្វែង សេសសល់
វិបាកនៃកម្មនោះ ក៏ត្រឡប់មកបានអត្តភាពបែបនេះឯង » ។

អំពើល្អឲ្យផលជាសុខ ។ តាហារណ៍ដូចជា ៖

រឿងធម្មិកឧបាសក

ធម្មិកឧបាសកនោះ ជាអ្នកបរិបូណ៌ដោយកល្យាណធម៌ច្រើនយ៉ាង
តែលោមានជម្ងឺខ្លះនឹងស្លាប់ ឲ្យកូនទៅនិមន្តព្រះភិក្ខុទាំងឡាយមកស្តា-
ប្បាយ សតិបដ្ឋានសូត្រ កំពុងតែស្តាប់ធម៌ បាននឃើញទេវតាក្នុងនភាអា-
វៀរសួគ៌ទាំង ៦ ជាន់ នាំយកទូវែង ៦ មកអញ្ជើញ ឲ្យទៅកើតក្នុងភព

របស់ខ្លួន ។ ធម្មិកឧបាសក លុះច្យុតពីមនុស្សលោកនេះទៅ បានទៅកើតក្នុងស្ថានតុសិតសួគ៌ ។

សម្រេចព្រះនិព្វានក៏ព្រោះបិត្ត

គ្រន់តាស្យថា សម្រេចព្រះនិព្វាន ក៏ព្រោះបិត្តនោះ អធិប្បាយថា បុគ្គលដែលចម្រើនចិត្តដោយ សមថវិធី និង វិបស្សនាវិធី ដរាប បានសម្រេចព្រះអរហត្តកំចាត់បង់នូវកិលេសាវៈទាំងពួងបាន លោកឲ្យឈ្មោះថា បានដល់ព្រះនិព្វាន ទាំងនេះក៏សម្រេចមកអំពីការប្រតិបត្តិផ្លូវចិត្តទាំងអស់ ។ ដូចមានពុទ្ធភាសិតថា :

ឧន្នឡំ ឯកចរំ អសរីរំ គុហាសយំ
យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។

ពួកជនណាសង្រ្កមចិត្ត ដែលមិនមានសរីរៈ ដែលត្រាច់តែម្នាក់ឯង តែងខ្ជួលអារម្មណ៍ក្នុងទីឆ្ងាយ មានគុហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅបាន ពួកជននោះឯងតែងផុតចាកចំណងនៃមារ ។

សេចក្តីប្រតិបត្តិក្នុងផ្លូវព្រះនិព្វាន សុទ្ធតែសំដែងជាប់ដោយការប្រតិបត្តិផ្លូវចិត្តទាំងអស់ ។ ហេតុដូច្នោះ បានជាលោកតោលថា « សម្រេចព្រះនិព្វានក៏ព្រោះបិត្ត » ។

ចិត្តនេះ ជាធម្មជាតិសំខាន់ជំនុតក្នុងកាយទឹងក៏ថា ដូចមានពុទ្ធ-
ភាសិតជាតឹកតាងថា :

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរជាយរឹសេស
សម្រេចហើយដោយចិត្ត បើបុគ្គលណាមានចិត្តដែលគេសប្រទូស្តហើយ
គេនោលក្តី ធ្វើក្តី (គិតក្តី) នូវទុច្ចរិតទាំងបីប្រការ ផលជាទុក្ខតែង
ជាប់តាមបុគ្គលនោះ ព្រោះអំពើទុច្ចរិតបីប្រការនោះឯង ដូចជាកង់រទេះ
ដែលវិលទៅតាមដើងគោ កាលកំពុងនាំទៅនូវទឹម ។

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។

ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរជាយរឹសេស
សម្រេចហើយដោយចិត្ត បើបុគ្គលណាមានចិត្តជ្រះថ្លាហើយ គេនោលក្តី
ធ្វើក្តី (គិតក្តី) នូវអំពើសុចរិតទាំងបីប្រការ ផលជាសុខតែងជាប់តាម
បុគ្គលនោះ ព្រោះអំពើសុចរិតបីប្រការនោះឯង ដូចស្រមោលតែង
អន្ទោលតាមអត្តភាព ។

អស់លោក-អ្នក ជាពុទ្ធបរិស័ទចាំដណ្តើយ ! កាលបើចិត្តជាធម្មជាតសំខាន់ដូច្នេះហើយ គួរតែរក្សាចិត្តតាមពុទ្ធកាសិត ដែលទ្រង់ជាស់តឿនរំលឹកថា :

សុទ្ធិន្តសំ សុនិបុណាំ យន្តកាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។

បុគ្គលជាបណ្ឌិតមានប្រាជ្ញា គួរខំប្រឹងរក្សាចិត្ត ដែលឃើញបានដោយកម្រ ដែលស្អិតពន់ពេក ដែលលង់ទៅក្នុងអារម្មណ៍ណាហើយមិនងាយនឹងគាញ់ឲ្យងាកចេញមកវិញបាន ចិត្តដែលអ្នកមានប្រាជ្ញារក្សាហើយ តែងនាំសុខមកឲ្យជាអនេក ។

ឯរក្សាចិត្តនោះ គឺប្រយ័ត្នចិត្តមិនឲ្យប្រឡាក់ដោយគ្រឿងសៅហ្មងឲ្យផូរផង់ទៅជាប្រក្រតីនោះឯង ។

ចិត្តនេះជាធម្មជាតស្អាតផូរផង់ ប៉ុន្តែរមែងសៅហ្មងដោយឧបក្កិលេសចាំដណ្តើយ ដែលចូលមកថ្មី ។ ដូចជាសំគត់ទៅថ្មី សុទ្ធតែជារបស់ស្អាតចាំដណ្តើអស់ ប៉ុន្តែរមែងសៅហ្មងដោយដីឬធូលី ដែលចូលមកប៉ះពាល់ខាងក្រោយ ។

ឯឧបក្កិលេសនោះសោត ក៏ជាអកុសលជាតដែលកើតមកតាមចិត្ត ហើយត្រឡប់ប្រទុស្តចិត្តឲ្យសៅហ្មងវិញ ដូចជាព្រៃដែលកើតអំពីដែក ហើយត្រឡប់ស៊ីដែកឲ្យខូចដូច្នោះឯង ។

ចបក្កំលេសជាគ្រឿងសៅហ្មងចិត្តទោះមាន ១៦ គឺ :

១- អកិដ្ឋាវិសមលោភៈ ល្មោភជាអកិដ្ឋាជាវិសមៈ

២- ឥស្សាចារៈ គំនុំ គឺចងគំនុំបម្រុងនឹងធ្វើឲ្យគេវិនាស

៣- ក្រោធៈ សេចក្តីក្រេវក្រោធ

៤- ឧបនាហៈ ការចងកំហឹងពុក

៥- មក្ខៈ ការលុបគុណអ្នកដ៏មានគុណ

៦- បឡាសៈ ការវៀចកប្រៀបផ្ទឹម ឬប្រណាំងឥសា

៧- ឥស្សៈ សេចក្តីច្រណែនឈ្នានីស

៨- មច្ឆរិយៈ សេចក្តីកំណាញ់

៩- មាយោ ការប្រព្រឹត្តិបិទបាំងទោស

១០- សាឋេយ្យៈការអួតអាង ឬ ការសែបអប

១១- ថម្ភៈ សេចក្តីរឹងត្អឹង

១២- សារម្ភ ការប្រណាំងប្រដែង

១៣- មានៈ សេចក្តីប្រកាន់ខ្លួន

១៤- អតិមានៈ សេចក្តីប្រកាន់ខ្លួនហួសពេក គឺមើលងាយគេ

១៥- មទៈ សេចក្តីស្រវឹង

១៦- បមាទៈ ការធ្វេសប្រហែស ឬ បណ្តែតបណ្តោយ ។

អកុសលតាំង ๑๖ នេះ សូម្បីណាមួយ កាលបើបណ្តាយឱ្យក្រុកកនចូលមកកាន់ចិត្តហើយ សុទ្ធតែធ្វើចិត្តឱ្យសៅហ្មងតុំថ្លាស្អាតតាំងអស់ ព្រោះហេតុដូច្នោះ ចានជាលោកហៅថា « ឧបក្កិលេស » ។ ឧបក្កិលេសនេះ ទោះបីមានច្រើនដល់ទៅ ๑๖ ក៏ពិតហើយ ប៉ុន្តែតុំកើតកន្លែងវេលាជាមួយគ្នាទេ រមែងផ្ទាស់ប្តូរគ្នាកើត ។

ម្យ៉ាងទៀត ចិត្តតែមួយទេ តែកាលបើមានកុសលធម៌ណាមួយមកសណ្ឋិតនៅដូចជាម្ចាស់ផ្ទះហើយ ឧបក្កិលេសដែលជាអកុសលធម៌ ក៏តុំអាចលុកលុយចូលមកបាន កាលបើអកុសលធម៌ណាមួយចូលមកនៅសណ្ឋិតដូចជាម្ចាស់ផ្ទះហើយ កុសលធម៌ ក៏រកឧកាសចូលមកតុំបាន ។

ឯកុសលនោះ កាលបើលើកយកតែកុសលដែលគួរឱ្យកើតមានក្នុងចិត្តមានតុំបាន ហើយមានឧបការៈច្រើនផងមកសំដែង ក៏គឺសតិសម្បជញ្ញៈ ព្រោះលោកសរសើរថា « សតិសម្បជញ្ញៈ ជាធម៌មានឧបការៈច្រើន ។

សតិ គឺសេចក្តីរឭក សម្បជញ្ញៈ គឺសេចក្តីដឹងខ្លួន គុណធម៌តាំងពីរនេះ ប្រព្រឹត្តទៅក្នុងកិច្ចជាមួយគ្នា ផ្សេងតែអាការៈ គឺសតិ គឺភ្ជាប់ជារមាងការនឹកឃើញក្នុងវេលាដែលធ្វើហើយ និយាយហើយ គិតហើយ សូម្បីកន្លងទៅយូរហើយ ក៏នឹកឃើញបាន សម្បជញ្ញៈ ជា

ក្លាត់ដាវខាងការដើនខ្លួន ក្នុងវេលាដែលកំពុងធ្វើ កំពុងនិយាយ កំពុងគិត ។ ឯចិត្ត បើសម្បជញ្ញៈគ្រប់គ្រងហើយ តែងស្ទុះបម្រុះខនៀលទៅកៀសកាគារម្មណ៍ផ្សេង។ តាមតែប្រទះ ស្រេចតែនឹងប្រាថ្នាមិនរើសថាដូចម្តេចគួរ ឬ មិនគួរឡើយ ។

ចំណែកចិត្តដែលមានសតិសម្បជញ្ញៈគ្រប់គ្រង រមែងរើសតែចំណែកដែលល្អ។ ។ ធម្មតាថេរីមនុស្សដែលគ្មានសាវ៉ាបរ សេះតែងនាំភ្លៅទៅតាមចំនើងចិត្តរបស់ភ្នក ធ្វើឲ្យកើតសេចក្តីអន្តរាយតាមតែប៉ះទង្គិចអ្វីក៏ដោយ តុំបានស្រួលឡើយ ។

ចំណែកថេរដែលមានខាយសាវ៉ាជាអ្នកឈ្លាសវៃ នៅគ្រប់គ្រងរក្សារមែងលឿនទៅត្រង់តាមផ្លូវ តុំធ្វើឲ្យកើតសេចក្តីអន្តរាយដល់នរណា ឬអ្វីមួយឡើយ ញ៉ាំងប្រយោជន៍នៃការប្រើថេរឲ្យសម្រេចដោយល្អ សេចក្តីនេះ ឧបមាយ៉ាងណាមិញ ឯការប្រព្រឹត្តិរបស់មនុស្សកំយ៉ាងនោះដែរ គឺបុគ្គលអ្នកមិនមានសតិសម្បជញ្ញៈ រមែងមានកាយ វាចា ប្រព្រឹត្តទុស។ ភ្លាត់ ធ្វើឲ្យកើតសេចក្តីអន្តរាយដល់ខ្លួនទីឯអ្នកជាដៃ ។ ចំណែកបុគ្គលដែលមានសតិសម្បជញ្ញៈ រមែងមានកាយ វាចា ប្រព្រឹត្តទៅត្រង់តាមផ្លូវដែលល្អ។ ជាហេតុឲ្យបានសេចក្តីសុខដល់ខ្លួនទីឯអ្នកជាដៃ ។ ហេតុនេះ

ត្រូវឲ្យមានសតិសម្បជញ្ញៈតាំងនៅគ្រប់ ១ កាល ញុំាងចិត្តឲ្យស្អាតថ្លាផូរ
ផង់ៅបាន ។

គោលច្បាប់នៃព្រះពុទ្ធសាសនាមី ៣ គឺ ការខ្ជាន់ជុំសងាត់សំ-
អាតចិត្តឲ្យផូរផង់ ជាលំដាប់ដកបដិសន្ធិបានសម្រេចព្រះអរហត្តជាទីបំផុត
ដូចន័យដែលសំដែងមកនេះ ពាប់ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ
តាំងឡាយ ។

និគមវាចៈ

ការលះ ការវៀរចាកបាបតាំងអស់ ដោយអំណាចនៃការកាន់សីល
ឲ្យបរិសុទ្ធ ការញុំាងកុសលធម៌ឲ្យកើតឡើងក្នុងសន្តានចិត្តឲ្យបរិបូណ៌
ដោយអំណាចនៃការកាន់សីលផង ការឲ្យទានផង ព្រមតាំងប្រតិបត្តិតាម
ពុទ្ធឧរាទផ្សេង ។ ទៀតផង ។ ការអប់រំចិត្តឲ្យល្អ ដោយអំណាចនៃ
សមថកម្មដ្ឋានទីងរបស់វិបស្សនាកម្មដ្ឋាន ឈ្មោះថា ជាវិធីប្រតិបត្តិដ៏ខ្ពស់បំផុត
ដើម្បីជុំសងាត់ចិត្តឲ្យស្អាតចាកទីវណ្ឋបក្កិលេស ទីងអនុសយក្កិលេស
ដើម្បីឲ្យចិត្តបរិសុទ្ធឲ្យកើតប្រាជ្ញាខឿយណាយចាកសង្ខារ ឲ្យចិត្តមៃ
ឈមទៅរកមគ្គផលនិព្វាន ដែលជាលទ្ធផលខ្ពស់បំផុត នៃការប្រតិបត្តិ
តាមផ្លូវព្រះពុទ្ធសាសនា ។ ក្នុងពុទ្ធទាននៃគម្ពីរខុទ្ទកនិកាយ មាន
សេចក្តីថា អរិយសាវកសាវិកា ប្រែនតែបន្ទឹមទានក៏ចាដោយ

សេចក្តីត្រេកអរ ក្នុងវេលាដែលចំពុះស៊ុកក្នុងអរហត្តផលថា ‹‹ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ ណាបរំ ឥត្ថត្តាយ» ប្រែថា ‹‹ជាតិ (របស់អញ) អស់ហើយ ព្រហ្មចរិយធម៌ បំពេញស្រេចហើយ ការណីយកិច្ច អ្នកអញបានធ្វើហើយ កិច្ចដទៃប្រព្រឹត្តទៅ ដើម្បីមគ្គភាវនានោះទៀត ពុំមានឡើយ» ។

គោលប្បាប់នៃព្រះពុទ្ធសាសនា ៣ នេះ ជាខ្លឹមនៃព្រះពុទ្ធដំណើរឡាយគ្រប់ព្រះអង្គ ដោយមានពុទ្ធចំណង ក្នុងការខ្ជាន ប្រៀនប្រដៅសត្វ ត្រូវគ្នាគ្រប់ព្រះអង្គដំណើរអស់ ។ បុគ្គលអ្នកត្រូវការប្រតិបត្តិ តាមធម៌ព្រះពុទ្ធសាសនា ត្រូវប្រតិបត្តិតាមលំអាននៃគោលប្បាប់ដំណើរ ៣ នេះទើបឈ្មោះថា ប្រតិបត្តិត្រឹមត្រូវបបំពេញកិច្ចនៃព្រះពុទ្ធសាសនា ។

ចិត្តៈ ជានធំឯការយកចិត្តទុកជាក់ ។

វិមំសា ជានធំឯបញ្ញាតំចារណា ។

ឆន្ទៈ វីរិយៈ ចិត្តៈ វិមំសា ជានជាឈ្មោះថា អធិបតី ព្រោះហេតុថាជាធំ ។ បើមានអធិបតីតាំង ៤ យ៉ាងនេះហើយ ជាបច្ច័យ ធំឲ្យសម្រេចកិច្ចការតាមសេចក្តីប្រាថ្នា ។ ព្រះយោគាវចរដែលចំរើនសមថៈធំឯវិបស្សនាធំឯជានសម្រេចដូចសេចក្តីប្រាថ្នា កំអាស្រ័យអធិបតីតាំង ៤ ប្រការនេះឯង ហេតុនោះទើបគោលថាជាបច្ច័យ ។

មក្តដលេសុ ក៏ ម្យ៉ាងទៀត អធិបតីតាំង ៤ នោះជាបច្ច័យឲ្យជានមគ្គផលធំឯឈាន បើគ្មានអធិបតីតាំង ៤ នោះជាបច្ច័យទេ ក៏មិនជានសម្រេចមគ្គផលធំឯឈានដែរ ដូចព្រះយោគាវចរកុសលបុត្រអ្នកចំរើនមេត្តាឈាន កំអាស្រ័យអធិបតី ៤ ប្រការ គឺសេចក្តីប្រាថ្នាធំឯចំរើនឈាន ១ សេចក្តីតាំងចិត្តមក្នុងការចំរើនឈាន ១ យកចិត្តទុកជាក់ក្នុងការចំរើនឈាន ១ ប្រកបដោយបញ្ញាតំចារណាឈាន ១ ទើបធំឯជាន

ទ្វារមេត្តាព្រហ្មវិហារឈាន បើគ្មានអធិបតីធាំធំ ៤ នេះទេ ក៏មិនបានទ្វារ
មេត្តាឈានដែរ សមដូចព្រះពុទ្ធដីកាថា មេត្តាព្រហ្មវិហារំ ភាវេ-
ត្វាតោមេ ព្រោះយោគាវចរកើតក្នុងប្រថ្នាទំនឹងចំរើនទ្វារមេត្តាព្រហ្មវិហារ
តម្រូវប្រកបដោយ ឆន្ទៈ គឺសេចក្តីតេញចិត្តទំនឹងឲ្យបាន ហើយមានព្យា-
យោមលះបង់នូវបដិឃៈចិត្ត ទំនឹងចិត្តអាឃាតញ្ញាបានខាងតៀរវែរចេញ
កាលបើគ្មានចិត្តអាឃាតញ្ញាបានហើយ ក៏កើតចិត្តស្រឡាញ់អាណិត
មេត្តាសត្វទាំងពួង ហើយមានបញ្ញាពិចារណាឃើញថា សត្វទាំងពួង
មានកម្មជាវេរស់ខ្លួន ឯអាត្មាមិញសោតក៏មានកម្មជាវេរស់ខ្លួនដូចគេដែរ
មិនខុសគ្នាទេ ។ កាលបើប្រកបត្រមដោយអធិបតីទាំង ៤ នេះហើយ
មេត្តាឈានក៏កើតមានឡើងក្នុងសន្ដាន ។ លុះមេត្តាកើតមានហើយ
តតុណ្ណា មុទិតា ឧបេក្ខា ក៏កើតមានឡើងតាមលំដាប់គ្នា ។
កាលបើព្រហ្មវិហារទាំង ៤ កើតមានក្នុងសន្ដានហើយ ក៏ជាទីស្រឡាញ់
តេញចិត្តនៃមនុស្ស និងអមនុស្សទូទៅ ដូចព្រះវិសាខត្ថេរដែលប្រកប
ដោយមេត្តាជាទីស្រឡាញ់នៃមនុស្ស និងអមនុស្សទាំងឡាយ ។

រឿងព្រះវិសាខត្ថេរ

សោ កិរ ទារកលិបុត្តេ ជាតេ ភូមកថា ព្រះវិសាខត្ថេរនោះ
កាលលោកជាគ្រហស្ថនៅក្នុងនគរជាជលិបុត្រ ជាអ្នកមានទ្រព្យសម្បត្តិ
ស្តុកស្តម្ភ នៅដាយភក់សត្រង់ត្រង់ផ្ទះគេស់កាលជាយូរអង្វែង ។ លោ

ខាងក្រោយ លោកបានឮដំណឹងថា ខ្ញុំបាទសង្ឃសម្បូរព្រះវិហារ ខ្ញុំព្រះ
ចេតិយ មានភិក្ខុសង្ឃគង់នៅជាច្រើន រុងរឿងដោយសំពត់ជ្រលក់ទឹក
អម្ចត់ដ៏ជាខន្ធដ៏ជ័យនៃព្រះអរហន្ត លាភខ្ញុំបាទោះអាចនឹងអង្គុយដេកជាសុខ
មានការសប្បាយជាច្រើនយ៉ាង ឧតុសប្បាយំ ច តិរជ្ជវីសប្បាយ
សេនាសនៈទីដេកទីគង្គុយ ភោជន ខ្ញុំបាទម្នាស្សវៃនៈក៏ជាទីសប្បាយ ព្រោះ
ហេតុមានភិក្ខុជាធម្មកថិកអ្នកចេះចាំព្រះត្រៃបិដកច្រើន សុទ្ធតែលោក
ជាអ្នកប្រាជ្ញក្នុងព្រះត្រៃបិដក ។ កាលវិសាខទេវបុត្រឮដំណឹងដូច្នេះ
ហើយ ក៏គិតថា អាត្មាអញនៅក្នុងស្រុកនេះពុំមានប្រយោជន៍អ្វីទេ បើ
អាត្មាអញទៅនៅក្នុងលាភខ្ញុំបាទវិញ ខ្ញុំបាទមានប្រយោជន៍ជាច្រើន គឺខ្ញុំ
បាននមស្សការព្រះចេតិយ ខ្ញុំបានបញ្ជូនចំរើនសមណធម៌ធ្វើឲ្យមានទី
តឹងដល់ខ្លួន ។ បរលោកកិ កច្ចគ្គា ដាម ឈ្មោះជាមនុស្ស
កាលទៅកាន់បរលោក មិនដែលកាន់យកទ្រព្យសម្បត្តិអ្វី។ ទៅជាមួយ
ផងបានទេ សូម្បីមានបុត្រកវិយាខ្ញុំនឹញាតិមិត្រច្រើនដល់ប៉ុន្មាន កំលះ
បន់ចោលចាំនឹងស់ ហើយទៅតែម្នាក់ឯង ដោយហោចទៅ គ្រាន់តែសរីរៈ
ក្នុងកាយរបស់ខ្លួនក៏យកទៅមិនបានផង ។ វិសាខទេវបុត្រគិតដូច្នេះហើយ
ទើបហៅបុត្រខ្ញុំនឹងកវិយាមកជិត មហាកោកក្កទុំ ឯយ្យាទេត្វា
ប្រគល់ទ្រព្យគំនរកោគសម្បត្តិដ៏ច្រើនឲ្យបុត្រខ្ញុំនឹងកវិយាថែរក្សា រួចយក
តែក្រាក់មួយរៀលវេចទៅជាយសំពត់ចង្កេះរបស់ខ្លួន ហើយលាបុត្រកវិយា

ចុះចេញពីផ្ទះទៅដោយកំណត់កង់ចិត្តថា ខ្ញុំនឹងទៅកាន់លង្កាទ្វីប លុះមកដល់មហាសមុទ្រកេរូកដីឆ្ងៃទៅពុំបាន កំសំណាក់អាស្រ័យនៅក្បែរឆ្នេរសមុទ្របានប្រមាណមួយខែ ។ កាលទុជាសកនៅក្បែរឆ្នេរមហាសមុទ្រនោះ កំឡើងណាំដួកម្នាដោយប្រាក់មួយរៀលលក់ដូរតាមធម៌ មិនហ៊ានលក់ដូរឲ្យខុសពីធម៌ ដោយលក់ដូរប្រហែលមួយខែបានប្រាក់មួយពាន់កហាបណៈគឺមួយពាន់រៀល ភៀមាតុសលតាយ ព្រោះវិសាខទុជាសកនោះជាអ្នកបុំនប្រសប់ខាងការលក់ដូរតាមធ្លាប់មកពីមុន ។

វិសាខទុជាសកនៅទីនោះប្រហែលមួយខែ កំបានឮនាវាធ្វើមហាសមុទ្រទៅត្រើយខាងនាយ លុះដល់ត្រើយហើយក៏ឡើងពីនាវាដើរទៅតាមលំដាប់ បានដល់ព្រះវិហារធំទើបចូលទៅកេតុកំពង់ឡាយកុងមហាវិហារ ថ្វាយបង្គំដោយគោរពហើយសូមបព្វជ្ជា ។ សីមំ ធំ តោ កេតុកំពង់ឡាយកឺនាវិសាខទុជាសកនោះមកកាន់សីមាទុជាសថ ដើម្បីឲ្យបព្វជ្ជាទុជាសម្បទ ។ វិសាខទុជាសកកំហូតយកប្រាក់មួយពាន់រៀលពីហោបៅឲ្យបូតធ្លាក់ទៅលើផែនដី ។ កេតុកំពង់ឡាយមានព្រះមហាថេរជាដើមសួរថា បេសម្អីធ្លាក់ចុះទៅដីនោះ ។ វិសាខទុជាសកប្រាប់ថាប្រាក់មួយពាន់រៀល ។ ព្រះមហាថេរមានថេរៈដីកាថា ម្នាលទុជាសក ចាប់ដើមតាំងពីនាក់បួសរួចហើយ មិនសមគួរទើបចាត់ចែងចាយយកយន្តប្រាក់កាសនោះទេ បើអ្នកចង់ចាត់ចែងយ៉ាងណា ចូរចាត់ចែងឲ្យស្រេចពីខាង

ក្រៅសីមាទៅចុះ តែកាលណាអ្នកបួសជាតិកុរូរហើយ អ្នកនឹងចាត់ចែងប្រាក់នោះមិនគួរទេ ។ រីសាវទុជាសកក៏បរិភោគប្រាក់នោះឲ្យជាទានប្រកាសថា យេ អត្ថិកា ចេម្នាក់ណាចង់បានប្រាក់នេះ ចូរយកទៅតាមប្រាថ្នាចុះ ។ តិកុតាំងឆ្ងាយនាំរីសាវទុជាសកចូលទៅកាន់កេងទេបាបឥតក្នុងសីមាឲ្យបញ្ជូនទុបសម្បទេ ញ៉ាំងរីសាវទុជាសកឲ្យតាំងនៅក្នុងតិកុភាពក្នុងព្រះបវរពុទ្ធសាសនា ។ ឯព្រះរីសាវតិកុនៅក្នុងសំណាក់ព្រះមហាថេរជាទុបជ្ឈាយ៍អាចរៀបចំបានប្រមាណប្រាំរសៀវ មាតិកាបកុណាំកត្តា រៀនចប់មាតិកាបានតិរចនេះចាំស្ទាត់ហើយ បងរៃត្បាល់ចារណាចេញរសៀវហើយ ទើបរៀនកម្មដ្ឋានជាទីសប្បាយ តំរេតុកម្មដ្ឋានហើយលាព្រះមហាថេរទៅកាន់វិហារដទៃ ។ តាមលំដាប់ ចន្លាភេមាសេ ទៅនៅក្នុងវិហារតាំងឆ្ងាយនោះ នៅវិហារមួយៗបួនៗខែ តែងចំរើនទូវមេត្តាសាយទៅដល់សត្វតាំងឆ្ងាយក្នុងទិសានុទិសគ្រប់ទិស ។

ថ្ងៃមួយ ព្រះរីសាវមហាថេរតិចារណាមើលទូវសីលរបស់ខ្លួនថាតាំងពីអាត្មាអញបួសរួចមកមិនដែលមានភ្លាំងភ្លាត់ឆ្លើយសៅហ្មងក្នុងសិក្ខាបទណាមួយទេ ។ កាលលោកគិតឃើញដូច្នេះក៏បន្ទូលទូវទានភាកក្នុងទីនោះដោយគាថាថា យាវ ឧបសម្បន្នោ ជាអាទិ ឃើងបានឧបសម្បទមកអស់កាលប៉ុន្មាន រហូតដល់ឥឡូវមកនៅក្នុងព្រះវិហារនេះ ក្នុង

រៀនខ្លះយើងតុំមានសៅហ្មងចិត្តចំបង្គួចទេ លោកនេះឈ្មោះថាជាលោកជាគ្រូលែនរបស់យើង ។

កាលព្រះវិសាខមហាឧបាសោលគាថានេះចប់ហើយ ក៏និមន្តទៅឯចិត្តឧត្តរវិហារ ទៅឈរត្រង់ផ្លូវបែកជាពីរហើយគិតថា អយ្យខ្ញុំទោផ្លូវនេះទៅឯចិត្តបព្វតវិហារមែនឬតុំមែន ចិន្តេន្តោ អដ្ឋាសិ កាលព្រះមហាថេរកំពុងតែឈរគិតដូច្នេះ ខេត្តាដែលអាស្រ័យនៅក្នុងកុំក្បែរផ្លូវ មានុំ បសារេត្វា កំលាដៃចង្អុលប្រាប់ផ្លូវថា សូមលោកម្ចាស់និមន្តទៅតាមផ្លូវខាងនេះចុះ ទើបឃាមដល់ទៅចិត្តបព្វតវិហារ ដូចសេចក្តីប្រាថ្នាតុំខាន ។ ព្រះមហាថេរឮដូច្នោះ ក៏និមន្តទៅតាមផ្លូវដែលខេត្តាចង្អុលប្រាប់នោះ ។ លោកទៅទៅក្នុងចិត្តបព្វតវិហារប្រមាណបានបួនខែ ។ កន្លងវេលាជិតក្តី ថ្ងៃនោះជាថ្ងៃគំរប់បួនខែ ព្រះថេរៈគិតថាក្តីឡើងទើបនឹងនិមន្តចេញពីវិហារនោះ ទៅកើវិហារមួយទៀត លុះចូលទៅសឹង ខេត្តាដែលស្ថិតនៅដើមឥន្ធនវិលក្នុងទីបំផុតនៃទីចង្រ្កមមកអង្គុយលើដែនថ្មចំរៅនោះការខ្ពើយយំរៀបចប់ ។ ព្រះមហាថេរៈសួរថា តោ ឯសោ អ្នកណាមកយំនៅទីនេះ ហេតុអ្វីបានជាមកយំដូច្នេះ ។ ខេត្តានោះទូលថា ខ្ញុំព្រះករុណាជាខេត្តានៅទីនេះឯង បានជាខ្ញុំព្រះករុណាយំ ព្រោះដើងថាលោកម្ចាស់ទើនិមន្តចេញពីទីនេះ ។ ព្រះមហាថេរសួរថា ចុះគាត្មានៅក្នុងទីនេះមានប្រយោជន៍

ដូចម្តេចដល់អ្នកឯង ។ ខេត្តាខោះទូលថា លោកម្ចាស់តង៌នៅកង៌ីនេះ អមនុស្សពាន់ឆ្នាំយឺតែង៌មានមេត្តាចិត្តរកគ្នាទៅវិញទៅមក ។ ព្រះមហាថេរប្រាប់ថា បើអាត្មានៅកង៌ីនេះនាំឲ្យអ្នកភក់គ្នាបានសេចក្តីសុខស្បាយ នៅជាការប្រពៃណាស់ ហើយព្រះថេរៈកង៌នៅឯខោះអស់រៀលបួនខែតទៅមុខទៀត ។ លុះលោកតង៌នៅគ្រប់បួនខែហើយតង៌តឥង៌ឥមន្តចេញពីវិហារនោះទៅ ខេត្តាមកទួញយំដូចជាមុនទៀត ។ ព្រះថេរៈកង៌នៅបួនខែតទៅទៀត ។ ព្រះវិសាខមហាថេរចេះតែតង៌នៅកង៌ចិត្តបព្វតវិហារនោះបួន ។ ខែរៀងទៅរហូតដល់រំលត់ខន្ធបរិនិព្វានទៅកង៌ចិត្តបព្វតវិហារនោះឯង ។

ព្រះវិសាខមហាថេរ ដែលបានជាមិស្រឡាញ់ពេញចិត្តនៃអមនុស្សពាន់ឆ្នាំយឺដោយអំណាចមេត្តាព្រហ្មវិហារ ។ ឯការដែលព្រះវិសាខមហាថេរបានន្លូវមេត្តាព្រហ្មវិហារនោះ ព្រោះអាស្រ័យហេតុលោកប្រកបដោយអធិបតិធម៌ពាន់បួន គឺ ឆន្ទាធិបតិ ១ វីរិយាធិបតិ ១ ចិត្តាធិបតិ ១ វិមំសាធិបតិ ១ ដូចពណ៌នាមកហើយនោះ ។

យំ យំ ឝកេតិ បុគ្គលឧត្តង៌ធ្វើកិច្ចការឯណា ។ ក៏តែង៌បានសម្រេចដោយអំណាចឆន្ទៈ វីរិយៈ ចិត្តៈ និង៌វិមំសា ព្រោះថាធម៌ពាន់បួននេះជាអធិបតី ។ ធម៌ពាន់បួននេះ បានជាឈ្មោះថាបច្ច័យនោះ ព្រោះហេតុជាបច្ច័យឲ្យបានលោកិយសម្បត្តិ និង៌លោកុត្តរសម្បត្តិ ។ ព្រះអរិយ-

ប៉ុន្តែលដែលបានសម្រេចមគ្គផលដែរ កាលគ្រោះតែមានអធិបតីតាំងបួននេះ ជាបច្ច័យ បើគ្មានអធិបតីតាំងបួនជាបច្ច័យទេ ក៏ពុំបានសម្រេចមគ្គផលផងឡើយ ឧបមា លោកិយសុខិ ទើបចាប់ស្រដីទៅថ្វី ត្រឹមលោកិយសុខ អធិបតីតាំងបួននេះ តែងឲ្យសម្រេចសម្បត្តិលោកិយជាមុនជាបួន លុះដល់ជាតិជាអរហាទើបឲ្យបានសម្រេចសម្បត្តិលោកុត្តរ សូមនាំនិទានមកសំដែងជានិទស្សនន័យ ដូចតទៅនេះ :

រឿងមេកណ្តុរ

អតីតោ ភិក្ខវេ កិស្មិញ្ចិទេវ ភាគសិ អតីតកាល មានសេដ្ឋីឈ្មោះមិនប្រាកដ នៅក្នុងក្រុងវេដ្ឋ មានទ្រព្យសម្បត្តិ ៤០ កោដិគប់ពុកក្នុងផែនដី ព្រោះតែយកក្រែងមានអន្តរាយ ។ កាលបើសេដ្ឋីនោះស្លាប់ទៅ ខាងក្រោយមក ភរិយារបស់សេដ្ឋីនោះក៏ស្លាប់ដែរ ទៅកើតជាមេកណ្តុរ នៅចាំផែនក្បែរកំណប់ទ្រព្យនោះ ព្រោះហេតុក្នុងវេលាដែលស្លាប់ ភាគចិត្តលោភតែទ្រព្យសម្បត្តិមិនបាន ។ ចំណែកឯប្អូរមក សេដ្ឋីជាស្វាមីក៏ស្លាប់ដែរតែទៅខឿត ។ ឯមនុស្សជាបេះដារ ខ្ញុំកំដរនៅគ្នាដើរចេញចោលផ្ទះអស់ទៅ នៅសល់តែផ្ទះខ្ទេ គ្មានកូនប្រុសឬស្រីម្នាក់នៅថែរក្សាផ្ទះកូមិនោះតវែរត្រកូលឡើយ ខ្មោះហើយកូមិនោះក៏ស្ងាត់ឈឹងសូន្យគ្មានមនុស្សម្នាក់សោះ មានតែដើមឈើនឹងស្មៅដុះគ្របគ្រលាស់តេញទៅជាព្រៃស្មសាន ពុំមានអ្នកណាដឹងថា ជាកូមិស្រុកបេសសេដ្ឋីឡើយ ។

គ្រានោះ មានឧបាយជាងកែវម្នាក់គ្រាចំស្លុះស្មូនរកកែវមណី ដើរ
ទៅតាមភូមិចាស់ដែលគេចោះចង់ចោលនឹងតាមដងព្រៃ ថា សាណោ
កោដេត្វា ដើរទៅដល់ភូមិចាស់រចស់សេដ្ឋីនោះហើយក៏ដាំចែកផ្ទាំង
ឋដ្ឋកដីចុះផ្ទៀងទៅខាងក្រោមទៀត ។ សា មុសិកោ មេកណ្តុរនោះ
វិលមកពីរកស៊ុវិញ ឃើញឧបាយជាងកែវក៏មានចិត្តស្រឡាញ់គិតថា
គួរតែអញតាំយកទ្រព្យមកឲ្យជាងកែវ ទើបអញនឹងបានអាហារស៊ុដោយ
ងាយ ។ មេកណ្តុរគិតហើយក៏តាំយកប្រាក់មួយកហាបណៈ (មួយរៀល)
ទាំរមកដិតឧបាយជាងកែវមណី។សួរថា តកិំ អម្ម នៃមេកណ្តុរ ហេតុអ្វីបាន
ជាឯងតាំយកប្រាក់មកកាន់ទីនេះ ។ មេកណ្តុរឆ្លើយថា អ្នកចូរខ្ចួល
យកប្រាក់នេះទៅចំណាយចិញ្ចឹមខ្លួនអ្នកខ្លះ ចូរទិញសាច់យកមកឲ្យខ្ញុំខ្លះ។
ឃរំ គេត្វា ឧបាយជាងកែវក៏ខ្ចួលយកប្រាក់នោះទៅឯផ្ទះហើយទិញ
សាច់ជាអាហារយកមកឲ្យមេកណ្តុរ ។ ខ្ចួលយកសាច់ទៅឯលំនៅខ្លួន
ហើយយកប្រាក់មកឲ្យឧបាយជាងទៀតរាល់ថ្ងៃ ក្នុង ១ ថ្ងៃ ១ រៀល រៀង
ទៅទាល់តែអស់ប្រាក់នោះ ។ ឯឧបាយជាងកែវក៏មានប្រាក់បរិបូណ៌ ។
ចំណែកមេកណ្តុរបានអាហារបរិភោគឆ្អែតឆ្អន់ ដោយអាស្រ័យអធិដ្ឋានបារមី
បួនប្រការជាបច្ច័យ ហេតុនោះសម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ទេសនា
ន្ទូវនន្ទុ: រីឃេ: ចិត្តៈនិងរំមសា ថាជាអធិបតី ជាបច្ច័យដោយប្រការដូច្នេះ ។

សម្តេចព្រះធម្មលិខិត ស្រឹ - ឯម វិប្រវៀបរៀង

(ពុម្ព)

ក្នុងមួយដួរកែកដោយដុំវិញ សឹងមានផ្នាំឯងបាយផ្នាំឯងសម្លជាច្រើន គេញាដោយម្ហូបចំណីផ្សេង ។ តើតឡើងដល់ខ្ញុំ មិនតែប៉ុណ្ណោះឡើយ អ្នកតាំងឡាយ ចូរស្តាប់ខ្ញុំកុសលកម្មដទៃទៀតដែលខ្ញុំបានធ្វើហើយ ដូចមានតទៅថា តាលនោះ ខ្ញុំបានឲ្យប្រុកម្មួយកហាបណៈដល់បុរសកំសត់អ្នកជំពាក់បំណុលគេ ដើម្បីយកទៅសងគេ ដោយបុញ្ញកម្មនោះឯង ខ្ញុំមានកោតសម្បត្តិកប៉មិនបាន គឺមានមាសនឹងប្រុកប្រើនប្រើប្រាស់ពុំចេះអស់កល់ ។ ជាតិពុំដែលជាប់ឡើយ ។

សចជ្ជនកាមោមិ យនសេលោបិ បព្វតោ
ហោតិ ឧបមយំ សព្ពំ កុណាតោ មោឧបេ ឥលំ ។

ថាបើខ្ញុំមានប្រុថ្នាចង់បានទ្រព្យសម្បត្តិក្នុងជាតិថ្ងៃនេះ សូម្បីតែដុំថ្មភ្នំគំនរដ៏ប្រែត្រឡប់ទៅជាទ្រព្យទាំងអស់តាមប្រុថ្នាបាន នេះជាផលនៃចេតនាដែលខ្ញុំមានចិត្តរីករាយក្នុងគុណធម៌ទាំងពួងដោយពិត ។

អញ្ញាម្បិ មម បុញ្ញាម្ពោ សុណាថ សុតិសោកណំ
កាសុបសុរ កកវតោ សាសនេកំពហូសុតំ

ឥទំសេដ្ឋំ មុនីនោធម្មំ សុត្វាបីណាតមានសោ
ឫជេសិ សាជកំមយ្ហិ ធម្មស្ស ធម្មសាមិនោ
តេនាហំ បុញ្ញកម្មេនសង្ឃរំ ជេវមានុសេលភាមិ
បណិតំវត្តំ យំ លោកស្មឹ រវំ រវំ ឥច្ចមានោ
អហំ អជ្ជហិមវន្តម្ហិ បព្ភតំ ជានាវិកវត្តេហិ
ជានយិស្សំ សមន្តតោ
សចេ ឥច្ចាមិ អជ្ជេវ វត្តេន ជាន បិយ តេ
ជន្តុនោ ជម្ពុតលស្មឹ វត្តជានស្សំនិដលំ ។

ម្នាលអ្នកចាំឆ្លាយដ៏ចំរើន សូមអ្នកចាំឆ្លាយស្តាប់នូវបុញ្ញកម្ម ដែលជាទីលំអនៃកិរិយាស្តាប់ដោយល្អរបស់ខ្ញុំ ដូចមានតទៅថា: កាលអាសនាព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបៈ ខ្ញុំបានស្តាប់នូវព្រះធម្មទេសនារបស់ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់សម្តែងនូវពុទ្ធសុត្តសូត្រមួយ ហើយខ្ញុំមានចិត្តជ្រះថ្លាក្រៃលែង ក៏បានបូជាសំពត់ឆាដកចំពោះព្រះធម្មទេសនារបស់ព្រះធម្មិស្សរៈជាម្ចាស់នោះឯង ដោយអានុភាពនៃបុញ្ញកម្មនោះ ខ្ញុំបានអន្ទោលទៅកើតក្នុងស្ថានទេវលោក និងមនុស្សលោក បើខ្ញុំប្រាថ្នាចង់បានសំពត់ល្អប្រសើរប្រភេទណាក្នុងលោក ខ្ញុំអាចនឹងបាននូវសំពត់ល្អប្រសើរប្រភេទនោះដោយងាយ តែបើខ្ញុំប្រាថ្នានូវក្តីហឹមភាពឲ្យកើតជាសំពត់ ក្នុងថ្ងៃនេះ ក៏គង់អាចនឹងបានស្មើគ្នានូវសំពត់

ចិត្តឥតមានមន្ទិលជាសំពត់ស្អាតរៀសមានពណ៌ផ្សេងៗកើតឡើងដោយ
ដុំវិញ ឥតមានខ្វះឡើយ បើខ្ញុំប្រថ្នាចង់ឲ្យជនចាំងឆ្លុះក្នុងជម្ពូទ្វីបបាន
ស្មើកដណ្តប់សំពត់គ្រប់ៗគ្នាក្នុងវេលានេះ ក៏គង់នឹងអាចបានចាំងអស់ពុំខាន
ឡើយ នេះជាផលដែលខ្ញុំបានថ្វាយសំពត់ជាទានដោយពិត ។

ឯតេសំ បុញ្ញកម្មានំ ភវាសា កាមភូមិយំ
សម្បត្តិមនុភោគ្គាន សារត្តិបុរបុត្តមេ
ជាតោ កុលេ មហាភោគេ វុឌ្ឍិម្ប្រាត្តោ សុខេដ្ឋិតោ
សត្ថុ ធម្មំ សុណិត្វាន បត្វជិត្វាន សាសនេ
លោកុត្តរំ អត្តសំ ភុញ្ជន្តោ មុនិភវាសា
កាលេសេ បហាយិត្វាន អរហាត្តមភ្ភាបុណិ
ភុសលំ ជាវមន្តញ្ច ខុទ្ទកន្តិកធាចិមិ
អនន្តផលទំ មោតំ ឯញ្ជន្តិ ធធាតំ តំ ។

ខ្ញុំបានបរិភោគទូវសម្បត្តិជាសុខក្នុងកាមភព គឺស្ថានសួគ៌ផង បានកើត
ក្នុងត្រកូលអ្នកមានភោគសម្បត្តិច្រើនក្នុងសាវត្ថីបុរីជាទីគួរ បានដល់នូវ
សេចក្តីចំរើនហើយស្ថិតនៅជាសុខក្សេមក្សាន្តផង ព្រោះតែបុញ្ញកម្មចាំង
នោះ បានស្តាប់ព្រះធម៌ទេសនានៃព្រះសាស្តាចារ្យជាម្ចាស់រួចហើយ ។ មាន
សេចក្តីជ្រះថ្លា បានបួសក្នុងព្រះពុទ្ធសាសនាហើយ បានដឹកនូវទឹកអត្តរសដ៏
ប្រសើរជាលោកុត្តរធម៌ ព្រោះបានអាស្រ័យនូវព្រះសម្មាសម្ពុទ្ធជាអ្នកប្រាជ្ញ

ឆ្នើមក្នុងលោក ហើយបានលះបង់នូវកងកិលេសទាំងឡាយ បានសំរេចអរហត្តផល ព្រមទាំងបដិសម្ភិទាញាណ ឃើញព្រះនិព្វានជាក់ច្បាស់ ឆ្ងងផុតចាកសំសារទុក្ខ ដូច្នេះអ្នកជាសប្បុរសទាំងឡាយមិនត្រូវមើលងាយកុសលដែលខ្លួនបានធ្វើថាជាកុសលមានប្រមាណតិចសោះឡើយ ឯកុសលដែលខ្លួនបានធ្វើនោះ ពោះបីមានប្រមាណតូចតិចដូចម្តេចក្តី ក៏គង់ឲ្យផលជាអនន្តគុណពាប់ពុំបានឡើយ អាចឲ្យនូវសម្បត្តិព្រះនិព្វានដូចន័យដែលខ្ញុំបានសម្តែងមកហើយដោយពិត ។

កាលនោះ កិកុសង្ឃទាំងឡាយក្តី លុះបានស្តាប់ព្រះធម៌ទេសនានៃព្រះមហាថេរនោះហើយក៏មានចិត្តសោមនស្សជ្រះថ្លា បានបំពេញនូវកុសលកម្មមានទានជាដើម មហាជនទាំងឡាយក្តី សឹងបានទៅកើតក្នុងស្ថានសួគ៌ក្នុងអាងមុខដោយច្រើនជាអនេកប្បការ ព្រោះតែបានស្តាប់ព្រះធម្មទេសនានោះហាង ។

សម្តែងរឿងនិទានទេវបុត្តមានសព្ទជាគំរប់ ៧ ក្នុងវគ្គទី៥ ក៏បរិបូរសេចក្តីតែប៉ុណ្ណេះឯង ។

ព្រះសោសនមុនី ឆេម-ឡូវ ពិនិត្យ

(តមក)

សេកសោមបណ្ឌិត ផ្តៀងដំតស្តាប់ពាក្យសារិកាហើយ គិតតែក្តីឆ្ងល់ចិត្តថា ឧសារិកានេះ ពាចនំបានអញ្ជាសង្ឃរតែង តែចិត្តវាទៅតែដៀលហៈ ហើយវាពុតជាក់ខំលាក់អញ្ជាបង់សៀតថា មិនច្រាំថ្នាំជាសង្ឃរ បពិត្រមិនដឹងអញ្ជានឹងបិតបៅទៅផង បើដូច្នោះអញ្ជានឹងធ្វើបរិហារទេវាហារណ៍មកជាសណ្តាប់ ហើយសារិកានេះកាន់ដឹងដឿពាក្យអញ ទើបសេកប្រុលមសារិកាជាបទគាថាដូច្នេះ

យំ យោ តាមេ តាមយតិ

អបិ ចណ្ឌាលិតាមបិ

សព្ពោ ហិ សនិសោ ហោតិ

ឧត្តិ តាមេ អសានិសោតិ ។

សាលិកេ ហៃនាងសារិកាពុំដាបង់អើយ កុំនាងសង្ឃាបទថាកំណើតផ្សេង ។ មួយជាសេក មួយជាសារិកា ច្នោះតិះដៀលទេហៈនាងឧបមាអ្នកឯណាមួយដ៏បរិសុទ្ធ ហើយមកច្រាំថ្នាំបង់ស្រែចណ្ឌាលកាឡកណ្ណីចង្រៃមានស្នាមដូចផ្សេង ។ កាលបើនឹងនៅលំនៅជាមួយនឹងគ្នាជា

សង្ឃារ ត្រង់ណាហៅចំណង ៩ ប្រការ ឆកគ្នាជាសុទ្ធសួស្តី វិស័យ ជាសង្ឃារតូ ឬត្រង់ចំណងនឹងផ្សេងនោះគ្មានឡើយ ។

កាមេតិ កាមស្មឹ ហិ ចិត្តមេវ បមាណំ ជាតិ ។ សារីកានង៍អើយ ខ្លួចតែបង់ចិត្តឯងនីមែន ។ មកជាប្រមាណនោះក៏នឹងជាមិនបានឡើយ ។ សារីកាឆ្លើយវិញថា ម្នាលសេករសោមបណ្ឌិតអើយ លុះចំណេរចីរកាលទៅ បង៍នឹងបិតនៅនឹងប្អូន គង់ជាលំនៅមួយ ហេតុអ្វីប្អូនថាដូច្នោះ ហេតុប្អូនថប់សោត ៣ ប្រការ ថប់នោះ បើសេកញ៉ីនឹងសេកឈ្មោលសឹងសន្ធានសេកនឹងសេកដូចគ្នាទៅវ៉ា ឆ្អាប់ស្រឡាញ់គ្នាដោយសន្ធានសេកនឹងសេក ឥឡូវនេះចៅត្រឡប់មកស្រឡាញ់ជាសារិកាវិញ ឯសេកវែងស្រឡាញ់សេកជាសន្ធានគ្នានឹងគ្នា ក៏ចៅនឹងស្រឡាញ់អ្វីប្អូនជាសារិកា នៅស្នេហាទៅឥង្គាល់ឡើយ ម្តេចហើយចៅច្រាសលះអញជាសារិកា នោះបង់សៀតច្រាសនិកសទៅទីណៃ រៀចៅសោមបណ្ឌិតធម្មតាសេចក្តីស្រឡាញ់ពេញចិត្ត ហើយមកច្រាសនិកសស់ឡាញ់ចេញនោះ មហាន្តោ ឧត្តោ ចៅអើយវាជាពុក្តធំរៃ ប្អូនថប់មួយរៃត្រង់ដំនៀលលោកផងតាំងតួង នោះមនុស្សយើងក្តី បក្សីក្តីនឹងដំនៀលប្អូន ថានៃសារិកាអើយសើរើអ្វីមាល្អាយ ខ្លួនជាសារិកា ម្តេចឡើយទៅដោយឯសេកវិញ រីសេកសោមបណ្ឌិត រឹងតាំងបមាទាហរណ៍មកសំដែងថ្លែងជាសណ្តាប់នៃសារិកានូវបទគាថាដូច្នេះ :

អត្តំ ជម្ពាវតី ជាម មាតា សិរិវឌ្ឍ កដិណោ
សា បិយា ភិសុនេវឌ្ឍ តកល្លាសឌ្ឍ ច មហោសិយាតិ ។

ភៃសាវិកាទាន់អើយ នាងស្តាប់ទេបមាមួយទៀយយថា កាលនោះ
មានស្រីកាឡកណ្ណីមួយឈ្មោះជម្ពាវតី ជាស្រីសន្តានកើតពីកណ្ហគោត្រ
មានបងប្អូននោះសោត ១០ នាក់ នាងជម្ពាវតីនេះជាបួន នាងនោះ
ហោងជាព្រះកនិដ្ឋាងនៃមហាសុត្រ ទ្រង់ព្រះនាមហៅ ព្រះបាទសិរិវឌ្ឍ
ជាព្រះអគ្គមហេសីព្រះបាទាសុទេពរាជ ដ៏ជាព្រះវរមាតាបិតាព្រះបាទ
សិរិវឌ្ឍ មានអំណាចមហិមា ហេតុតែនាងនោះដឹងទេមកជាព្រះអគ្គ.
មហេសី សារិកានាងអើយ ដោយបងឮគេស្រដីទៀយរៀងមក មាន
កាលមួយថ្ងៃ ព្រះបាទាសុទេពរាជ ស្តេចលីលាយាត្រាចេញអំពីទ្វារ
វត្តស្រីមហាទេតរ ទឹងបរោងផងច្រើន ស្តេចទៅប្រភាតនាទេព្យាន មានព្រះ
ហឫទ័យនោះសប្បាយ ព្រះអង្គស្តេចត្រឡប់មកអំពីទេព្យានដល់ទ្វារព្រះ
ទេតរវិញ កាលនោះនាងជម្ពាវតី ជាស្រីគេញក្រមុំត្រហ្មចរីល្អក្រៃ ជា
ស្រីចណ្ឌាលមានមានៈច្រើន នាងស្ងៀកសំពត់ដណ្តប់សៃរ្យស្តើងជាយ
ទៅបិតលើងឮដំហាទទ្វារវត្តីស្រីមហាទេតរនោះ កាលនោះព្រះបាទាសុ-
ទេពរាជយល់នាងជម្ពាវតី ល្អៅល្អញគេញក្រមុំត្រហ្មចរី បិតឮដំហាទ
ព្រះទេតរ ស្តេចមានព្រះហឫទ័យសោមនស្សប្រតិពទ្ធ តាត់ស្រឡាញ់ទឹង
នាងមហិមា ស្តេចត្រាស់ឲ្យទៅដណ្តឹង ថានាងមានប្តីឬអតប្តី ស្តេចឮ

ថាឥតប្តី ដូច្នោះហើយ ស្តេចនាំនាងទៅកាន់ព្រះភជមន្ទីរស្តេច ដម្កល់នាងទុកជាព្រះអគ្គមហេសីមហាក្សត្រ ។ សត្វព្រះភជហប្ញទ្ធិយានឹងនាងក្រៃពេក ជាអម្ចង្គតិចទៅ នាងទ្រង់គភ៌លុះខែ ១០ គ្រប់បរិបូណ៌ ពុំយូរឡើយ នាងប្រសូតព្រះភជបុត្រប្រុសមួយ លុះព្រះភជបុត្រចម្រើនធំឡើង ព្រះចុទភាសុទេភភជ ជាព្រះវរបិតាសុគត លោកមកដម្កល់ព្រះភជបុត្រនោះឲ្យសោយភជសម្បត្តិ ស្នងព្រះវរបិតា ឡើងព្រះនាមហៅព្រះចុទសិរីភជ នៅឰដ៏ទ្វារវត៌ស្រីមហាខគរនោះហាន ហៃស្រីសារិកាពុំងាមាសបងអើយ នោះលោកជាមហាក្សត្រថ្លៃមហិមា ម្តេចយកស្រីខណ្ឌាលកាឡកណ្ណីមកជាប្តីប្រពន្ធ កំនេះយើងជាបក្សី ឥឡូវនេះជាប្តីប្រពន្ធផងគ្នានោះវាសមទេហ: ។ កើ វត្តព្ញ ។ ឥឡូវស្រីដ៏អ្នកប្អូនអើយ វាមហាសមគួរពេកហាន ។ សេកសោមបណ្ឌិតនាំទំពាទមក ជាឧទាហរណ៌មួយវិញទៀតថាដូច្នេះ ហៃសារិកានាងអើយ ស្តាប់បងឲ្យជាក់បងនឹងនិយាយអំពីរឿងព្រេងមកសម្តែងឲ្យនាងដឹង ហើយក៏និយាយនូវបទគាថាដូច្នេះ :

រតនវតី កតិបុរិសី សាមិ វិជ្ជំ អកាមយិ

មនុស្សា មិតិយោ សន្តិ ឧត្តិ តាមេ អសាធិសោតិ ។

ហៃស្រីសារិកាស្នេហាបងអើយ មានតំនួរមួយឈ្មោះ រត្នវតីពេញក្រមុំ សមនូវរូបឧត្តមល្អមហិមា ក៏ប្រាថ្នាបងធ៌មហប្ញសី មួយឈ្មោះវច្ច:

មហាឫសីនោះមានចិត្តប្រតិព័ទ្ធសន្ធត ជាខន្ធដ្ឋប្រពន្ធនឹងគ្នានោះតើសឹងអ្វី
តិបន្តស្រដីនេះជាសង្ខេបខេណានាង ឲ្យតែខ្ញុំតែប្អូនដឹង និយាយនេះវែ
ច្រើនផ្សេង។ បងនឹងសម្តែងឲ្យអានស្តាប់ សារីកានាងអើយ នាកាល
តវាងតិតខ្លួនទៅហើយ មានព្រាហ្មណ៍មួយលះបងសម្បត្តិ ចេញទៅ
ប្តូសជាតាបសប្រជាប់អាស្រមបរមសាលានៅព្រៃព្រះហេមពាន្ត មាន
ឈ្មោះមហាឫសី កាលនោះមានកំនុំតែភ្លើរឈ្មោលផង នៅឰដ៏ព្រៃព្រះ
ហេមពាន្តមាននៅឰដ៏តោហាមួយទៀប អាស្រមនិចន្ត្រមមហាឫសី កាល
នោះ មានតិរច្ឆានមួយប្រមាណប៉ុនតង់ះទេះ ពាក់តែងនឹងចាប់អស់កំនុំផង
តាំយាដផ្ទាក់ផឹកឈាមស្លាប់សោះ អស់កំនុំផងគ្នាតកតិតឰាបដោយខ្លួ
អំណាចតិរច្ឆាន កំនុំផងពុំអាចដើម្បីនឹងរម្ងាប់ភ័យនោះបានឡើយ កំនុំ
ផងទៅពុំស្រណុកជាខុក្ខមហិមា ចប្តូលគ្នាទៅសំណាក់តាបសឫសី ហើយ
សូមអង្វរដោយហេតុដំណើរអាគ្នាខ្លះ។ ថាបពិត្រតាបសឫសីអើយ សូម
មានព្រះអង្គទ្រង់ព្រះករុណា ជួយយកជីវិតយើងខ្ញុំផង យើងខ្ញុំឥតប៉ើង
នាក់ក្រៃទឹងព្រះអង្គឡើយ ដ្បិតតិរច្ឆានោះវាតែងកាត់ក្បាលយើងខ្ញុំ តា
នោះមក យើងខ្ញុំប្រុសត្រាត់ជាត់ញាតិកា បងប្អូនវិនាសអស់ សូមមាន
ព្រះអង្គសម្ងាប់តិរច្ឆាននេះឲ្យយើងខ្ញុំ បើតិរច្ឆាននេះស្លាប់ហើយ ហៅ
ព្រះអង្គទ្រង់ព្រះករុណាមេត្តាយើងខ្ញុំឲ្យបានសួស្តីប្រុសលែងខុក្ខហោង។
តាបសឫសីឮហើយខ្លាល់ មានព្រះហឫទ័យខន្ធត់នឹងអត់ពុំបានមានពុទ្ធដ៏-

ភាថា មេកំនួរអប្រិយ ម្តេចមិនមកស្រដីប្រើអញធ្វើជាណាតិបាតសង្ឃាត
អ្វីអញនឹងសម្លាប់សត្វនោះហើយ អញជាតាបសឫស្សីមិនមែនឮជាអញ
កាន់សីលឬទេ មិនថយចេញទៅ កំនួរផងក៏ត្រសែតអស់ទៅឥតបើរិះរៃ
រកអ្នកឯណានោះជាពំនាក់ឡើយ អស់កំនួរកំនែកបបួលគ្នាមកជុំវិញគំនិត
ទឹងគ្នាថា យើងទៅសំបួងសង្រួងតាបសតែពាក្យទេនោះឯណាបាន
ឥទ្ធិរយើងនឹងគិតជ្រើសរើសរកបានកំនួរ ស្រីកំនែកក្រមុំៗគ្គមល្អមួយទៅ
ថ្វាយនោះនៃ ទើបលោភនឹងករុណាសម្លាប់តិរច្ឆានោះទៀយើង កំនួរ
ផងគិតហើយ ទើបមកជ្រើសរើសបានកំនួរមួយដំពេញក្រមុំត្រហ្មចារីស័ង
ល្អដ៏មានខ្លួនសម្បូលត្រសូលល្អាយល្អងញ៉ែងញ៉ង ឈ្មោះរត្នវតីស្រីកំនួរ
ហើយមកស្ថានម្ខាងភាំមអន្ធាមសូរឮកងចំកៀនត្រសាល់ថ្ពាល់ខាត់ផ្សូរផង់
បីដូចស្រីទេពកញ្ញាទ្រទេសទ្រទន់ល្អាសល្អន់ប្រពៃស្រេចហើយនៃ ទើប
នាំទៅកាន់សំណាក់តាបសឫសីហើយ អស់កំនួរផងលើកតំបងឹអញ្ជលី
ពិតព្រះពុទ្ធដីកាថា បពិត្រអើយ ! រត្នវតីស្រីកំនួរខេះ អស់យើងខ្ញុំថ្វាយ
ជាបាទបរិចារិកព្រះអង្គហោង រីតាបសឫស័យលុះត្រវតី ស្រីកំនួរនោះ
ហើយមានព្រះហឫទ័យ ប្រតិព័ទ្ធនឹងរត្នវតីស្រីកំនួរនោះ អ្នកទទួលយក
ហើយជាក់សិក្ខាបទ ពីព្យាយាមបង់ តន់ជាត្រហស្ថវិសេហើយ បានដំបង
ប្រខន់ទៅរើចាំនៅទ្វារគោហា កាលណាបើតិរច្ឆានចេញមកអំពីកុង
គោហា កំនួរទៅរកកំនួរដូច្នោះកុរ តាបសឫសីលើកដំបងសំពងក្បា

ស្នាលតិដ៏ងាដ៏ស្ងាប់ស្រែងាដ៏ ហើយត្រូវប្រមកនៅទីដ៏រត្នវតីស្រីកិន្នរបង្កើត
បុត្រស្រីបុត្រប្រុសទីដ៏គ្នាលុះអស់ជន្មាខ័ណៃ ។ នៅឰដ៏ហានោះហោដ៏ ។
ហៃស្រីសាវិកាពុំដាមាសបដ៏អើយ រឿងនោះមហាឫសីជាមនុស្សលោក
យកស្រីកិន្នរសត្វតិរច្ឆាន ម្តេចលោកស្ងួនស្នេហា ជាសដ៏ព្រះបាន ក៏នេះ
ម្ដដ៏បដ៏ទីដ៏ងាដ៏យើដ៏តាំដ៏តិរសើដ៏ជាសត្វតិរច្ឆានទីដ៏រគេ នាដ៏ជាបក្សី ថាបើ
សមគួរទីដ៏គ្នាជាសដ៏ព្រះហើយ ទីដ៏ស្រដីអ្វីបានរឿយជាមហាសមគួរ
ណាស់ហោដ៏ ក៏ងាដ៏គិតបទថាសន្ដានខ័ណៃសើដ៏ដូចគ្នាទេ រីបក្សីស្រីសត្វ
សាវិកាស្ដាប់ពាក្យសោមបណ្ឌិតហើយ ឆ្លើយថាហៃហៅ ។ ឪាមិយាយ
ត្រដ៏ព្រឹទ្ធមកផ្ដិតជាសន្ដានមិត្រទីដ៏ប្អូន ជាមហាសមគួរហើយ តើប្អូនទីដ៏
ថាម្ដេចទីដ៏ខៅឡើយ ហៃសោមបណ្ឌិត តែធម្មតាចិត្តជាមិត្រសដ៏ព្រះមិន
ដែលទីដ៏ស្នេហ៍ស្ងួនសត្វការ ប្អូនគប់ប្រសប់ហើយណៃ ច្រាសនិពាសខ័ណៃ
ឧភវីដ៏អាល័យក្រៃណាខៅអម្ងាស់បដ៏អើយ សោមបណ្ឌិតស្ដាប់ពាក្យសា-
វិកាយល់មាយា ថាជាពុំគិតឡើយ សោមបណ្ឌិតគិតដោយនៅប្រាជ្ញ
ខោះឈ្វាសមាយាស្រីកំស្រដីល្បដ៏លដ៏ចិត្តសាវិកានូវបទគាថាដូច្នេះ :

ហាន្ត ខោហំ កមិសញ្ញមិ សាលិកេ មញ្ញកាណិកេ
បច្ចក្ខាឧបធិ ហោតំ អតិមញ្ញសិ ឆ្លួន មន្តិ ។

សាលិកេ ហៃនាដ៏សាវិកាអាសពុំដាបដ៏អើយ មញ្ញកាណិ-
កេ នាដ៏ស្រដីពីកេះសោះសារ ទីមាលអម្បាយកេះ សាវិកាអើយ

នាពាក្យនាងថា ខ្ញុំឯងនាពាក្យនោះហោង ជាគន្ធងគួរបង់នាងឯង ម្យ៉ាសារិកាមាសបង តាមដោយបងគិត នេះហៅនាងមើលងាយបងណាស់ នែសារិកានាងនៅក្នុងតុំពាន់ដងបងជាគន្ធង ខ្ញុំមសង្ឃានាងហៈ បងនឹងក្រអូប្រពន្ធ អម្ចាស់មានបុណ្យមិនរកទ្យេងទ្យាង ខ្ញុំរកប្រពន្ធទៀតមើលហៈ សារិកាអើយ ប្រពន្ធបងវាស្លាប់នាសបង់តែទ្រូងបងបាត់ទៅហៅមហាមានកំពូលមកប្រសព្វលើនាង ឥឡូវបងប្រែខ្វែងជាអកំពូវិញ ។ ហាន្ធ ខោហំ កមិស្សាមិ ។ សារិកាអើយ ម្ល៉ះហើយបងលានាងទៅហោង ។ សេកតុំស្រដីទេឡើយ ធ្វើជាសំគុកខ្ញុំកខ្ញុំខ្ញុះស្ងាប ខ្ញុះខ្ញុំខ្ញុំ-ពាប្រែប្រួលជាខ្ញុំងហើរទៅ រំពេកស្រីសគួសារិកាស្តាប់ពាក្យកាសាសេកថាខ្ញុំងណាទៅ រំពេកស្រីសគួសារិកាក៏មានចិត្តខ្ញោះក្តៅដូចខ្ញុំងបែកថ្មែចេញ ហេតុបានយល់សេកគេញចិត្តមិនចង់ឃ្លាតឃ្លា ដោយមានយាងស្រីក៏តុំស្រដីថា មិនត្រូវថ្នាទៅខ្ញុំងសេកឡើយ ហើយធ្វើយទៅខ្ញុំងបទគាថាខ្ញុំងសេកដូច្នេះ :

ឯ សិរី តវមានសទ្ធ មាថ្ងូរ សុវបណ្ឌិត
ឥទេវ តាវ អច្ចសទ្ធ យាវ កដាដំ ឧត្តុសិ
សោសិ សង្គំ មុធិន្ធាំ អាទុកាវិញ្ញូ កដិនោតិ ។

សទ្ធ សុវបណ្ឌិត ម្យ៉ាសេកសោមបណ្ឌិតដ៏មានវាចៀបស្ងាបខ្ញុំវសទ្ធាញ់បង់អើយ ចៀសស្តាប់ប្តូនត្រាប់ស្តាប់សោកថា ធម្មតាធ្វើការ

ស្មោះជាចង់ឆាប់លេះរលៀងចង់តែបាន រីការនោះក៏មិនល្អឡើយ ហៃ
ចៅសោមបណ្ឌិត ចៅថ្នឹងជញ្ជឹងគិតនឿយក្រៅ នាបីហៅលំនៅមួយ
ទីឯគ្នាជាផ្ទះសម្បែងក៏ទីឯជាខុតខួនអ្វី ហៃចៅសោមបណ្ឌិត ប្អូនគិត
ស្មានចៅមានសម្រាន្តឯណាឃើយ ស្មែរបរអម្ចាស់អញមានបុណ្យមហិមាជា
ឥស្សរកំពូលអស់ស្តេចចាំងកំឡុងសកលជម្ពូទ្វីប បំណាច់ចៅមកដល់ណាយ
ក៏ចៅមើលស្រីសម្បត្តិបុទ្គលអម្ចាស់អញសិន រង៌ាល្ងាចខន់ៗ អម្ចាស់
មានបុណ្យតើនឡើងអំពីក្រឡាបខ្ញុំ បរមសុខសួស្តីទំនើងចៅទីឯស្តាប់ស័ព្ទ
តន្ទេសព្ទភាទ្យ គង់តន្ទោងតង់ស្រវៃស្មោហ្វូងកុកលេងទៅជួរជន្ទ្រីរង់
សំនៅស័ព្ទចម្រៀងច្រៀងជ្រួតត្រដួចតិកោះ ស្រណោះស្រងាំតីនាស្រី
ផង សឹងពាក់ម្ជុលអាក៏មអន្ទាមសូរឆែកឆគ្រហាល់ប្រជាប់ចង្កេះ សឹងជាង
ស្អាងស្អាត ប៉ាក់ខ្លូរចេសមាសល្អប្រណែតស្រេចរំលេចនៅកញ្ចក់ដាំត្បូង
មរកតត្រូបពុំក្រតិខ្លូរពិភពទឹមដាំស្ងាបកំកេមរំលេចរលង់ត្រចង់ត្រចាស់ល្អ
ពណ្ណាយ មានមុខទាត់ម៉ត់ហ្មត់ឈ្មង់ជង់ខ្លួនស្រួតមូលខន់ល្ងន់ល្ងាស
ហើយតែរវៃលំនាំល្អាក់ល្អមព្រម ៗ ទីឯគ្នាដូចកិន្នកកិន្នរី ពុំនោះសោត
ដូចស្រីសួគ៌មុខគួរតែពិតពិលរមិលមើល ហើយសន្សឹមៅហោង លំដាប់
អំពីនោះ លុះល្ងាចខន់ៗ សុវិយោ សោមបណ្ឌិតបានស្នេហ៍ស្និទ្ធ
តសង្ឃរទើងសារិកាជាលំនៅមួយហោង ឬឯសេកសោមបណ្ឌិត គិតថានា
អញសង្ឃឹតប្រាថ្នាសារិកាជាសង្ឃរនេះ ចរទើងចង់ជើងអាចអំពើសេចក្តី

កំពុងឆ្ងន់សាវិកាឲ្យបានហើយ ក៏ឥឡូវនេះ អញបានសាវិកាជាសង្ឃរួចហើយ តប្បីអញជម្ពើឆ្ងល់អាចសេចក្តីកំពុងអំពីសាវិកាឲ្យដឹងជាក់ ហើយអញនឹងទៅ ក្រែងព្រះមហាសត្វម្ចាស់អញអ្នកឧទ្ទិង ទើបសោមបណ្ឌិតហៅសាវិកាថា ម្នាលសាវិកាអើយ ។ សាវិកាឆ្លើយថា ឥតី សាមិអម្ចាស់ខ្ញុំហៅខ្ញុំអ្វីហ: ។ សេកថា កិញ្ចិ នេ វត្តុកាមោម្ហីតិ ។ សាវិកាអើយ បងនឹងស្រដីលេងនឹងនាងបន្តិចហ: សាវិកាថា វទ សាមីតិ ។ អម្ចាស់ប្អូន បងស្រដីមកប្អូននឹងស្តាប់ ។ សេកថាសាវិកានាងអើយ ថ្ងៃយើងចម្រើនសុខសួស្តី ពិធីការមង្គលនេះហោង ។ បងចង់ស្រដីលេងនឹងនាង បងចងជំង សាលិកេ ម្នាលនាងសាវិកាអើយ សាវិកាថា ម្នាលចៅសោមបណ្ឌិតអើយ នាមង្គលការយើងជាសុរេចនាថ្ងៃនេះឯង ពាក្យណាចើប្រកបទូវមង្គលអំពាលជាសួស្តី កំចៅស្រដីហោង ប្អូននឹងស្តាប់ ពាក្យណាចើអត្ថមង្គលអំពាលពុំជាសួស្តី កុំចើចៅស្រដីខ្ជាចវាអប្រិយខ្លួនយើងតាំងតែពុំបានថេរនឹងគ្នា សោមបណ្ឌិតឆ្លើយថា ភទ្រេ មង្គលកថា ។ សាវិកាអើយ ពាក្យនេះហៅមង្គលអំពាលនៅសួស្តីក្តាត់ហោង ។ សាវិកាថាម្នាលសោមបណ្ឌិត ចើបួនចៅថ្ងៃដ៏មកប្អូននឹងស្តាប់ អណ្តាប់នោះសេកថា សាវិកានាងបង ។ ថ្ងៃដ៏ច្រាប់នាង ។ រីសោមណ្ឌិតរិះគិតសួងជម្ពើឆ្ងល់សេចក្តីកំពុងអំពីសាវិកា ទូវបទគាថាដូច្នេះ :

យោ ឧ ខ្វាយឹ តិក្ខោ សន្ធោ តិភេជនបនេ សុតោ
ជ័តា បញ្ចាលកជ្ឈ ជិសជ័ វិយ វណ្ណាជ័
តំ ឧស្សតិ វិនេបាតំ សោ វិភាមោ ភវិស្សតិ ។

ចៃសាវិតានាង៉ដើយកាលបង៉ទៅដ្ឋប្តីស្រីមហានគរនោយក្តី តាំង
តាបង៉មកយល់នាង៉ក្តីកំពុងខ្សឹមខ្សួលអ្នកស្រដីកប្រឿង៉រឿង ។ ជំណាសព្វផ្លូវព្រ
ឮដីស្រុកតូចស្រុកធំទឹតមស្រុកគ្រៅបំនៅដនបទ ឮក្រុងដខ្លួនគោមហាមា
ថាព្រះកដធីតាអម្ចាស់យើង៉មួយព្រះនាមឈ្មោះហៅនាង៉ចន្ទី ក៏ស្រដី
កប្រឿង៉សរសើដំណើរអំពីក្សត្រីនោះ ថារូបល្អនោមនាយដូចផ្កាយ
កណ្តាលអាកាស មានព្រះភ័ក្ត្រនោះដូចផង់ស្រៀរស្រស់ញញឹមប្រឹមប្រិយ
ព្រះកេសីធ្មារខ្មៅតន់ទៅដូចស្មាបកូមក៏ មានចុង់ត្រួយខ្លួយខ្លីង៉ដូចបុង
ក្រើសមានកូមោនោះ កោង៉ខ្លេសខ្លួយដូចបង្ខួយកៅណ្ហ ពុំនោះ
សោតដូចជាង៉កាន់ទៅកសមានព្រះនេត្រយង៉ខ្មៅ ថាបើនិង៉តន់ទៅដូច
ក្អែកកូមម្រិតតើតមួយថ្លៃ មានព្រះខន្ធនោះជិតដិចកិត ប្រជាប់ប្រស្រី
ស្រេចស្រស់ស្រាប់ប្រជាប់ពាក់ខ្លួរអង្គុលី មានព្រះបិដ្ឋីនោះល្អប្រសៃ
មានព្រះសូរង៉នោះមូលម៉ត់ម៉ង៉ មួលត្រសូលផ្លូលផ្លត់កកង្គាញ៉ា មានព្រះ
ឋនានោះក្សោះក្សាំសំនៅព្រះឧកដូចបទុមា មាសទុត្តមក្រពុំពីរក្បោះ ពុំនោះ
សោតដូចផ្លែទម្ងាប់មាសដ្ឋាប់ឮដីទក៏ មានព្រះអង្គិនាង៉នោះមូល ច្រគាក

ស្រឡះស្រឡួតមានព្រះហស្តនោះ មូលត្រសូលខន់ល្ងន់ល្ងាសដូចខន
ចេកមាស ត្រវៀលចក់លំទោន មានម្រាមព្រះហស្តនោះវែងសួន ដូច
ខនលំតង់ចុងវល្ងិ៍លួតលាស់ខ្ចី មានព្រះដំណើរនោះទ្រទន់ញ៉ែងញ៉ាងក្សត្រី
នោះហោង បងឮថាទឹងថ្ងាយជាព្រះអគ្គមហេសីស្តេចមួយទ្រង់នាមឈ្មោះ
ហៅអ្វី ថាឈ្មោះវិទេហកសនោះហោង ។ ដោយឮគេស្រដីថាព្រះចុល
ចុលណីទឹងព្រះចុលវិទេហកសជាសត្រូវនឹងគ្នាមិញអេះ កល់អ្វីក៏ព្រះចុល
ចុលណីមកយកព្រះរាជបុត្រីឲ្យជាព្រះអគ្គមហេសី នៃព្រះចុលវិទេហកស
វិញហ: មហាក្សត្រីនៃឮដំណឹងដូចនេះតើគ្មានឡើយ បពអ្ងែមនឲ្យហ:
កំមកឲ្យព្រះចុលវិទេហកសជាសត្រូវវិញហ: សារិកាតុំជាបងឮល់ត្រង់
នេះ ចូរនាងរិះគ្រាប់បង ។ សារិកាស្តាប់ពាក្យសេកហើយ ឆ្លើយថា
ម៉ៃសោមបណ្ឌិត ប្អូនរិះគិតនឹងចៅមិញហើយអេះ ប្អូនថាពាក្យណាជា
មង្គលតប្បីស្រដីពាក្យនោះ ពាក្យអត្ថមង្គលចៅកុំស្រដីឡើយ បពយើង
នឹងសម្រេចនៅការមង្គលនឹងគ្នាថ្ងៃនេះ ប្អូនថានឹងចៅដូច្នោះហើយមិញតើ
ម្តេចចៅមិនអើតើនឹងពាក្យប្អូន ឃកពាក្យអត្ថមង្គលនោះមកស្រដីវិញហ:។
សោមបណ្ឌិតស្តាប់ពាក្យសារិកាហើយ រិះរូតដណ្តឹងពាក្យសារិកាថាម៉ៃ
សារិកា តំណាមាសបងអើយ បងមិនបេះស្រដីនឹងពាក្យប្អូនស្អួនស្រដីអ្វី
មាល្អាយ សារិកាដោយកំឡៅបងគិត ព្រះចុលឥសូមហាក្សត្រលោក
គិត អាពាហ៍ពិពាហ៍នោះជាមង្គលអំពល់សួស្តី ប្រសើរដំណើរឫក្សពារ

តិលាធាយប្រពៃ កំប្អូនប្រែខ្វែងថាខាស់មិនប្រពៃវិញ សារិកាអើយនាង
ថាដោយដំណើរនេះមកមើលចង ។ ទីនឹងស្តាប់ ។ សារិកាតែវត្វើយថា
ម្នាលម្ចាស់សោមបណ្ឌិតសំឡាញ់តេញចិត្តប្អូនអើយ ប្អូនទីនខ្វែងសំដែងច្រើបប់
អាចិសារតើសេចក្តីកំប៉ាំងពាំនឹងក្នុងក្រៅក៏ល្មើស្តាប់តុំបានឯ បពលោកមិនឱ្យ
មានអ្នកឯណែដ៏ង ។ សោមបណ្ឌិតស្តាប់ហើយទីនរួតក្នុងចិត្តទីនសារិកា ថា
នុសារិកាតំណាមាសបងអើយ អ្នកឯណែនានា ក៏ល្មើតំណាលាក់ប៉ាំង ឯល្មើ
ទីនឥឡូវស្រឡាញ់ស្មើខ្លួនឯង តើប្អូនសើរើធ្វើជាលាកវិញ សារិកាល្មើ
ស្តាប់សេចក្តីម្ល៉ើរម្តេចមិនច្រើបប៉ុណ្ណោះហោង ។ សារិកាស្តាប់ពាក្យ
សោមបណ្ឌិត ហើយតែរួតបពោរដោយអត់ធ្មត់ជាក់ខ្លួនឱ្យជាអ្នកឯណែវិញ
ធ្វើហាក់ពុំស្មើហាជាសង្ឃរបោះកូរ ប៉ុន្តែសារិកាអាឡោះអាល័យមែនល្មើ
សេកខ្ចាចពុំត្រែកស្មើហាទីនអាត្មាល្មើនោះ កំក្តៅហឫទ័យមិនអាចលាក់
សេចក្តីកំប៉ាំងកំនុកនោះពុំបានឡើយ ម្តីម្នាលរលាំងច្រើបប់ល្មើសេកជា
បពគាថាពីដូច្នេះ

ឆ្លៀងសោ តេ អមិត្តានំ វិកាលោ លោកសុ មាថ្ងូរ
យថា មញ្ញោ លភតិ សប្ប វេរេនលោន កវិសប្បតីតិ។

ម្នាលសោមបណ្ឌិត សំឡាញ់ប្អូនអើយ ថាបើព្នោះកុំបល្មើផ្សេះ
ផ្សាយគោះតើយទីនប្អូនឡើយ ល្មើស្តាប់ប្អូនទីនច្រើបអស់សេចក្តី ម្នាល
ល្មើសោមបណ្ឌិត នាព្រះបាទបុលណាព្រហ្មទត្តពង តិតទីនយកព្រះពង

បុត្រពិតធ្វើអាពាហ៍ពិពាហ៍ ទើបព្រះជាម្ចាស់ទេវហកសយល់មកដូច្នោះ
ទៅតិតស្នេនជាមិត្រហ: ជាសត្រូវទេ ហៃសោមបណ្ឌិតទៅទើបដឹង
ដើម្បីអ្វី អាអាពាហ៍ពិពាហ៍ជាសត្រូវនឹងគ្នានោះហ: សោមបណ្ឌិត
ពុំអស់ចិត្តឡើយ តែទំណើតទៅទៀបជាន់ដីសារិកាជាបទគាថាដូច្នេះ
បុន តេន ត្វំ កទ្ធ តស្មា ឯវម្បិ កថំ កថេសិ តំ
ភុំត្តេ ។ ហៃសារិកាស្នេហាបងអើយ បងស្តាប់សំដីនាងស្រដី
ហើយ ហៅនាងស្រដីកេកល់បងរឹងធ្ងល់ សារិកានាងថាអាពាហ៍ពិ-
ពាហ៍នឹងគ្នាជាប្តីប្រពន្ធហើយ សិនឧនាងថាជាសត្រូវវិញ ថាបើជា
សត្រូវនឹងគ្នាហើយតើនឹងធ្វើអាពាហ៍ពិពាហ៍ នឹងគ្នាជាប្តីប្រពន្ធបានឡើយ
សារិកាបងចង់ឮបន្ថែមច្រាប់បងឲ្យសព្វគ្រប់ សោះបងសួរចង់ដឹងដដែលៗ។
សារិកាថាហៃសោមបណ្ឌិត ទៅនឹងគិតចង់អ្វីទៅស្តាប់សំដីប្អូននឹងច្រាប់
ទៅទៀបទគាថាដូច្នេះ ។

អានយិត្វាន វេទេហិ បញ្ចាលានំ រថេសភោ
តតោ នំ ឃាតយិ សត្ថតិ ជាសញ្ច សទិ ភរិសត្តតិ ។

ហៃសោមបណ្ឌិត ព្រះជាទេវបូលណើ គិតថានឹងយកព្រះកនបុត្រ
ឈ្មោះនាងបញ្ចាលចន្ទ្រនេះ ថ្វាយជាព្រះអគ្គមហេសីព្រះជាទេវហកស
ព្នោះគឺមានលោកនឹងលួង តែឲ្យបានចេញមកអំពីមិថិលានគរនោះ
លុះដល់ទត្តរបញ្ចាលនេះលោកមិនធ្វើឲ្យអ្នកតាមជាមិត្រឡើយ មិន

តែប៉ុណ្ណោះ ដោយប្អូនឮលោកស្រដីថាមានអ្នកប្រាជ្ញ ម្ចងឈ្មោះព្រះមហាសង្ឃ តែនឹងចិត្តប្រដៅអាចារ្យធម៌សារតើសេចក្តី លោកយល់លោកភ្ជាក់ផ្អើរគំនិតមហាសង្ឃ ក្សត្រសព្វថ្ងៃ លោកនឹងប្តូនឲ្យបានតាំងមហាសង្ឃនោះផង លុះឲ្យបានអ្នកតាំងពីរនោះមកហើយ ទើបលោកនឹងការគ្រក លុយកក្បាលអ្នកតាំងពីដើមលំដាប់ស្រាជ័យ មានតាំងស្រាត្រាមពីរ ហើយលោកនឹងបបួលសម្ងាប់ស្តេចតាំងម្ខុយរយមួយរោះផង ដោយគតគំនិតអ្នកដទៃក្រៃនឹងប្រាជ្ញ អាចារ្យតែវេដ្ឋព្រាហ្មណ៍ឡើយ គិតហើយទូលមហាក្សត្រស្តាត់តែអាចារ្យនឹងស្តេចក្នុងគម្រាលក្រឡាចខ្ញុំជាសុំទុកនឹងតែពីរនេះតាំងឯង ។ រីសោមបណ្ឌិត ផ្តិតដើងស្តាប់ពាក្យសារិការប្រាប់ អស់អាថិសារតើសេចក្តីកំចាំងកំងតាំងពួង ឥតសំណាល់ដំណល់ទុកក្នុងចិត្ត ស្រេចហរិប្បូរណ៍ហើយ ម្នាះហើយកំផ្ងើជាសរសើរប្រាជ្ញអាចារ្យតែវេដ្ឋព្រាហ្មណ៍វិញថា នែអាចារ្យតែវេដ្ឋព្រាហ្មណ៍អើយ អាចរិះគិតអាថិសេចក្តីកំចាំងអ្វីមាល្បាយអេះ រិះគេចាលតលនឹងសម្ងាប់ស្តេចនោះតិតហោង ។ សេកផ្ងើជាសរសើរអំពីប្រាជ្ញអាចារ្យតែវេដ្ឋព្រាហ្មណ៍ ស្រេចសោមបណ្ឌិតរិះគិតនឹងសារិកា ផ្ងើជាថាបង្ហើយក្រោយថានែសារិកាស្នេហ៍បងអើយ បងឆ្ងោយអ្វីមាល្បាយ ហើយនឹងលោកអំពើលោកផ្ងើជាអត្ថមង្គល ចលាចល់មានសភាពដូច្នេះកំមកស្រដីវិញ ។

(នៅមានត)

អក្សរសាស្ត្រខ្មែរ ខ្មែរគួរចែចូន
ឲ្យជាទន្លាប់ខ្លួន តង់រង់ជាតិមាតុ ។
ព្រោះអក្សរជាតិ ដោលជាតិប្រាកដ
អក្សរលត់ ជាតិក៏រលាយ ។

ប.ព.

ភាសាខ្មែរប្រៀបតាមរទេស

ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ « ក »

(តមក)

— E —

Emanciper un mineur . . .	ឲ្យអត្តាធីនភាពដល់អនីតិជនម្នាក់ ។
Emancipation d'un mineur	អត្តាធីនកម្មដល់អនីតិជនម្នាក់ : ធ៌កិច្ចដែលបើកឲ្យអនីតិជនម្នាក់ រក្សាអត្តភាពខ្លួនព្រមទាំងគ្រប់គ្រងទ្រព្យខ្លួន ។
Enfant commun	កូនរួម : កូនរបស់ប្តីប្រពន្ធរួមគ្នា ។
Ester en justice	ប្តឹងតុលាការ ។
Excès (n.m.)	អតិរេកភាព ។

— F —

Folie (n.f.)	ភាពឆ្កួត ។
Fou (n.m.)	មនុស្សឆ្កួត ។

— H —

Héritier réservataire	ទាយាទបម្រុងទុក (ពប្ប) ។
Héritier non réservataire	ទាយាទអបម្រុងទុក (ពប្ប) ។
Hériter (v.tr.)	ទទួលមត៌ក (ភប្ប) ។

Hériter d'un oncle ទទួលមត៌កពីមាឡាក់ ។

Heriter (v.tr.) ទទួលជាមត៌ក (ពប្ប)។

Héritier (ère) (n.m. et f.) ទាយាទ ។ (ពប្ប) អ្នកទទួលមត៌ក ។

Hopital psychiatrique មន្ទីរពេទ្យវិកលចរិត ។

(bis)— Hériter une maison de sa mère ទទួលផ្ទះ មួយជាមត៌កពីម្តាយខ្លួន ។

— I —

Imbécile (n.m.) មនុស្សល្ងង់ ។

Imbécile (adj.) ល្ងង់ ។

Imbécilité (n.f.) ភាពល្ងង់ ។

Injures graves ប្រមាថជាទម្ងន់ ។

— L. —

Legs (n.m.) អព្វ័យទាន : អំណោយដោយលិខិតបញ្ជាក់របស់ជនម្នាក់អុទ្ទិសដល់ស្លាប់ ។

Léguer (v.tr.) ធ្វើអព្វ័យទាន ។

Légataire (n.m.) អព្វ័យលាភី ។

Légataire particulier អព្វ័យលាភីពិសេស ។

Légataire universel អព្វ័យលាភ៌សាកល ។

Libéralités (n.f.pl.) សទ្ធាទាន : អំណោយរបស់ជនមានសទ្ធាជ្រះថ្លា ។

— M —

Marque de fabrique សញ្ញាការណដ្ឋាន ។

Médecin (n.m.) គ្រូពេទ្យ ។

Mineur émancipé អនីតិជនអព្ភាធីន : ជនមានអាយុពី ១៨ ទៅ ២១ ឆ្នាំ ដែលគេដាក់ ឲ្យនៅក្រៅក្បាលមេភាព ។

— P —

Personne déchue de ia puissance paternelle — បុគ្គលជ្រាសចាកអំណាចមេបា ។

Pharmacie (n.f.) — ទសព័ស្ថាន ។

Pharmacien (cienne) — ទសព័ការី ប្រើស្ត្រីថា : ទសព័ការិនី ។ មើលថា ការិណី ។

Prince hériter — ព្រះអង្គម្ចាស់រដ្ឋទាយាទ ។

Psychiatre (n.m.) — គ្រូពេទ្យវិកលចរិត : គ្រូពេទ្យអ្នកព្យាបាលរោគវិកលចរិត ។

Psychiatrie (n.f.) — វិជ្ជាវិកលចរិត : វិជ្ជាសម្រាប់ព្យាបាលរោគវិកលចរិត ។

Psychiatrique (adj.) — វិកលចរិត ។

Puissance paternelle — អំណាចមេបា ។

— Q —

Quotité disponible — បមាណភាពទំនេរ ។

— R —

Reconnaître un enfant naturel — ទទួលស្គាល់កូនក្រៅឡើប ។

Reconnaissance d'un enfant naturel — ការទទួលស្គាល់កូនក្រៅឡើប ។

(se) Remarier (v.pr.) — រៀបអាពាហ៍ពិពាហ៍ដ៏ថ្មី ។

Règle absolue — វិធានដាច់ខាត ។

Règle relative — វិធានសាបេក្ខ : វិធានទៅប្រែបដោយសេចក្តីប្រថ្នា ក្នុងការកែប្រែយ៉ាងណាៗ ទៅទៀតតាមកាលៈទេសៈ ។

Relativité de la connaissance — សាបេក្ខភាពនៃការចេះដឹង ។

Révoquer un testament — លុបមតិកសាសន៍ ។

Révocation d'un testament — ការលុបមតិកសាសន៍ ។

Réserve (n.f.) — បំរុងទុក ។

— S —

Sévices (n.m.pl.) — សម្បីឃ្នងកម្ម ។ មើលថា សាំ-ប៊ី-ឡៃ-ណៃ: ក់ ។

Succéder (vintr.ind.) — តពី..... ការទំនាក់ការតពី..... ទទួលមរតក-ធិការ (ពក្យ) ។

Succéder (vintr.ind.) — តពី.... ។ ឧ. ឃុបតពីថ្ងៃ ។

Succéder (v.int.ind.) — ការទំនាក់ការតពី...។ ឧ. លោក «ក» ការទំនាក់ការតពីលោក «ខ» ។

Succéder (v.int.ind.) — ទទួលមរតកធិការ (ពក្យ): ទទួលការគ្រប់គ្រងមតិកពី... ។ ខ្ញុំបានទទួលមរតក-ធិការពីម្ដាយខ្ញុំ ។

Succession (n.f.) — មរតកធិការ (ពក្យ): ទ្រព្យមតិក ។

Succession (n.f.) — មរតកធិការ (ពក្យ) ការប្រគល់តាមច្បាប់នូវទ្រព្យ ទឹងភាគព្វកិច្ចនៃមនុស្សស្លាប់ដល់មនុស្សរស់ ។

Succession (n.f.) — មរតកធិការ: ចំណុចបុគ្គល ឬរបស់ទាំងអស់នៃសកាន់ការគ ឬតពីគ្នាមិនឲ្យមានខាងឆ្នោះ។ ឧ. មរតកធិការនៃបុគ្គល ឬសន្តតិវង្សនៃព្រះមហាក្សត្រ ។

(នៅមានតទៀត)

អតិហា (២) ឆាតុ. ហើរក្រៃលែង រំលងក្រៃលែង ឆ្ងង ។

អតិហារិន៍ គុ. ដែលឆាំទៅក្រៃលែង ដែលលេចក្រៃលែង ដែលត្រចះត្រចង់ កន្ធង ។

អតិហាស ប៉ុ. ការិយាសើចក្រៃលែង ។

អតិហ្ឫម្ភ គុ. ដែលរីករាយក្រៃលែង ។

អតិហេលន ឧប៉ុ. ការិយាចំអកឡកឡឺយក្រៃលែង ។

អតិហ្រ្គេបណា គុ. ដែលឆាំឡួកឡុសក្រៃលែង ។

អតី (អតិ+តី) ឆាគុ. ទៅក្រៃលែង កន្ធង (ពេល) ឆ្ងង (ផ្លូវ) ងើរជាន់ (ទីហាន នេហាម) បង្អង ចៀសវៀង ឆ្ងេរប្រហែស ត្រួសត្អូត បំបាយបង់។ *អតីត* ដែលកន្ធងទៅហើយ ដែលស្ងាប់ដែលឆ្ងង ។

អតីក្ឫស្ន គុ. ដែលសំពោងក្រៃលែង ដែលទន់ ដែលទន់ភ្លន់ ។

អតីន្ទ្រិយ គុ. ដែលមានឥន្ទ្រិយក្រៃលែង ដែលចងអារម្មណ៍ក្រៃលែង ។ ឧប៉ុ. ឥន្ទ្រិយក្រៃលែង ឥន្ទ្រិយប្រសើរ ចិត្ត ព្រលឹង ។

អតិថិ ន.ប. ពាលមិនឆ្លាវ ។ បុគ្គលមិនមែនជាទីគាប ។

អតិរិ អវ្យ. ណាន់ ពេកណាស់ ជាដាច ។

អតុន្ទិល គុ. ដែលមិនងុះពោះ ដែលមិនកំពោង ។

អតុល គុ. ដែលថ្វឹងមិនបាន ដែលប្រៀបមិនបាន ។

អតុល្យការ ប. ស្មើមិនត្រង់ ព្រះអាទិត្យ ។

អតុម្ភិការ គុ. ដែលធ្វើឲ្យត្រេកអរមិនមាន ។

អតុលបុណ្យ គុ ដែលមិនពេញដោយសម្បត្តិប្បាសេ ។

អតុល្យ ន.ប. វត្ថុមិនមែនជាស្មើ ។ *អតុល្យភាព* ប. ស្មើវត្ថុមិនមែនស្មើ ក្នុងពោ ។

អតុប្ប គុ. ដែលមិនឆ្អែត ។ - ភ ស្រី ភាវនៃកិរិយាមិនឆ្អែត ។

អតុប្តិ ស្ត្រី កិរិយាឆ្អែតមិនមាន កិរិយាមិនពេញចិត្ត ។

អតុប្ប គុ. ដែលមានក្រៃថ្លាមិនមាន ។

អតៃជស គុ ដែលមានពន្លឺមិនមាន ដែលមិនមែនជាលោហ ។

(នៅមានត)

រឿងល្បែកឡាហ្វុងតែន (La Fontaine)

លោក ដេង-ទ្រីវ ប្រែរៀបរៀង

(ពន្យក)

២៦-ម្រឹត្យរវីងអ្នកកាប់ឫស

មានបុរសកំសត់ទុគ៌តម្នាក់ រកស៊ីកាប់ឫសលក់ ។ ថ្ងៃមួយកំពុងតែលីឫសមួយចាប់ ចាំងមែកចាំងស្ទឹកយ៉ាងធ្ងន់ ខ្លួនក៏ចាស់ ថ្លុងផង ដើរផង ខ្ចីរកោង។ ក្បាលងក់។ លើកដើងចោះជំហានស្ទើរមិនរួច គាត់ទំប្រឹងទៅទ្បាដល់ខ្ទមកន្ទុចវុំសុទ្ធតែផ្សែងក្តៅធ្ង ។ ដោយខឿយត្រួយពេកអស់កម្លាំងស្ទើរដកដង្ហើមមិនដល់គ្នា គាត់ក៏ទម្លាក់ចាប់ឫស អង្គុយគិតនឹកដល់សេចក្តីទុក្ខលំបាករបស់គាត់ហើយពោលថា: "អ្នកឯងមានសេចក្តីសប្បាយយ៉ាងណាហើយ ចាប់តាំងពីអ្នកឯងកើតមកក្នុងលោកនេះ! បើគិតឲ្យសព្វៗទៅ មិនគឺអ្នកឯងហ្នឹងហើយ ដែលជាមនុស្សកំសត់ជាងគេនៅលើដីមួលនេះ! ដួងតារាងងាប់ពេល ហើយមិនដែលមានវេលាខំនេះសោះ ។ ប្រែជាខ្លួនអ្នកឯង កូនប្រុសស្រី ភាហាន តន្ទាងសត្វគ្រប់ មេបំណុលនឹងកំណែនចាំងអស់នេះ បន្តែមថែរឯ ឮរំសេចក្តីក្រមកលើអ្នក ហើយឆ្លើយឲ្យអ្នក

ឯងទៅជាមនុស្សលំបាកវេទនាមកដល់សព្វថ្ងៃនេះ" ។ គិតឃើញយ៉ាងដូច្នេះហើយ ទើបបុរសកំសត់ហៅម្រីត្សមកគាច់យកឲ្យស្រឡះទៅ ។

ម្រីត្សមកភ្លាម ហើយសួរថា ត្រូវឲ្យកន្ធើដូចម្តេច ។

បុរសកំសត់ឆ្លើយថា : "យើងហៅកន្ធកឲ្យមកជួយលើកទុសជាក់លើស្មាបន្តិច រួចកុំបង្អង់ ថយចេញឲ្យឆាប់ៗទៅ" ។

ទោះបីយើងចង់ស្លាប់ក៏ដោយ តែសេចក្តីស្លាប់មកដល់ហើយ រមែងធ្វើឲ្យមនុស្សពាំងអស់ ស៊ូរងទុក្ខវេទនាជាជាងស្លាប់ : ព្រោះហើយជាបំណងរបស់មនុស្សលោក ។

២៧- លាធីដំឆ្កែ

ត្រូវជួយគ្នាទៅវិញទៅមក នេះហើយជាច្បាប់លោកទៅលើផែនដី ។ ថ្ងៃមួយ បុរសម្នាក់ចេញលាធីដឆ្កែទៅក្នុងព្រៃ ។ ដល់ពីដំណាក់ ម្ចាស់ក៏ឈប់ក្រោមឈើមួយដើម ហើយដេកលក់ទៅ ។ លាគិតតែស៊ីស្មៅខ្ចីលាស់ល្អទៅពីកលមួយ ។ កន្ធដែលនោះ ឆ្កែឃ្លានចាយពេកខំបអង្វរលាថា : អាណិតគ្នាទៅ អាស៊ីឡាញ់ ចូរឯងបន្ធាបខ្លួនមក អញនឹងយកចាយកន្ធកឆ្លើយបន្តិចស៊ី ដ្បិតអញឃ្លានណាស់ ។ លានៅស្ងៀមគ្មានឆ្លើយមួយម៉ាត់សោះ ខ្លាចខាតពេលស៊ីស្មៅ ឆ្កែអង្វរយូរណាស់

ទើបលោធ្វើយថា: អាសំឡាញ់! អញគ្រាប់អាឯងឲ្យដឹង ចាំម្ចាស់ក្រោកឡើងពីសម្រន្តសិន លុះលោកក្រោកឡើង ចំណែកអាឯងតង់តែមានទេ កុំភ័យឡើយ ។ ទុកាសនោះ ទទួលមានចិតចេញពីព្រៃមក ដេញចាំលាភ្លាម លាស្រែកហៅផ្តែឲ្យជួយ ផ្តែមិនកំរើកសោះ ឈរតែមើលធ្វើព្រងើយ ហើយស្រែកគ្រាប់ទៅលាថា: អាសំឡាញ់! អញគ្រាប់ឲ្យអាឯងទំរត់ឲ្យលឿនសិន ចាំម្ចាស់យើងក្រោកឡើង លោកមិនចេះបង្អែបង្អងដំទេ ទំផាយរត់ឲ្យលឿន បើចិតតាមមាន់ ធាក់បំបែកមាត់ក្អមយ ដើងទៅ ព្រោះគេទើបនឹងជាក់ដែកឲ្យថ្មីៗ បើអាសំឡាញ់ដឿតាមអញ ចូរឯងធាក់ក្អមឲ្យដួលលមើល ។

ផ្តែកំពុងតែនិយាយ ចិតហែកលាស៊ីអស់រលីង ។

(សុភាសិតខ្មែរ: សង្ឃឹត ជាការកំឡៅ) ។

២៨- ត្រីធំងំក្អែកទឹក

មិនមានត្រីតាំងណាមួយទៅជិតខាង ដែលក្អែកទឹកនេះមិនបានចាប់ត្រីយកមកបរិភោគសោះ បើងប្អូរទាំងប៉ុន្មានត្រូវបង់ឥន្ធឲ្យក្អែកទឹកគ្មានសល់ ។ ម្តេចចំណីមានបរិបូណ៌ លុះឆាមកសង្កិត់សង្កិនសត្វនេះវេលាណា ម្តេចចំណីមានមិនគ្រប់គ្រាន់ ចាប់ត្រីមិនបាន ព្រោះខ្លួនចាស់ ក្អែកទឹកដទៃទាំងអស់ត្រូវទំប្រឹងស្វែងរកដោយខ្លួនឯង ។ ក្អែកយើងនេះចាស់

ពេក មុជទឹកចាប់ត្រីមិនបាន តើតទុក្ខខ្វាំងអំពីការអត់អាហារ ។ បើដូច្នេះ តើធ្វើដូចម្តេច? សេចក្តីត្រូវការនាំសត្វឲ្យបែកច្រកជា ។ កំពុងតែចំលើមែកឈើ ក្អែកទឹកស្រាប់តែក្រឡេកទៅឃើញកំពឹសមួយពាររតើម ។ ទៅមាត់ត្រពាំង ។ ក្អែកទឹកមានការចាំទៅការទ័តឹសថា ខែសំឡាញ់! ចូរឯងនាំដំណឹងដ៏ស្រាន់នេះ ទៅប្រាប់ដល់ញាតិសន្តានឯងឲ្យបានដឹងគ្រប់គ្នាថា: ពេលនេះមុខជាត្រូវស្លាប់អស់ហើយ ទៅតែប្រុំចិញ្ចៀតម្ចាស់ត្រពាំងនឹងមកចាប់យកទៅស៊ីអស់ជាមិនខាន ។ កំពឹសប្រញាប់ត្រឡប់ទៅប្រាប់ហេតុអកុសលដល់អ្នកទៅកន្លែងតាំងអស់ ។ ការជ្រួលច្របល់យ៉ាងធំកើតមានឡើងមួយរំពេច ។ ពួកសត្វទឹកតាំងពុំខ្ចាននៅលមកប្រជុំគ្នា ដើម្បីរកមធ្យោបាយដោះខ្លួន ក៏សួរការណ៍នេះនឹងបក្សីថា: "ឧត្រុះតេជគ្រះគុណក្អែកទឹក លោកបានពត៌មានហ្នឹងពីណាមក? តើលោកយល់ថា ជាដំណឹងពិតឬមិនពិត ចំពោះរឿងហ្នឹង តើលោកបានដឹងពិតប្រាកដមែនឬ? តើលោកយល់ឃើញផ្លូវដូចម្តេចខ្លៅ ដើម្បីដោះស្រាយឬទេ? តើត្រូវធ្វើដូចម្តេចទើបស្រួល? ។

- ក្អែកទឹកឆ្លើយថាត្រូវតែផ្ញាស់កន្លែង ។
- បើដូច្នេះ យើងខ្ញុំនឹងត្រូវប្រតិបត្តិបែបណា? ។
- អ្នកកល់គ្នាកុំព្រួយ អញជានាំយកអ្នកកល់គ្នាមួយម្តង ។ ពាល់

តែអស់ទៅពុកឯកន្លែងអញ ហើយកន្លែងនោះមានតែអញនឹងខេត្តាខើប ស្គាល់ផ្លូវ ជាកន្លែងយ៉ាងស្ងាត់ ជាត្រគាំងមួយកើតឯងក្នុងព្រៃ មនុស្សក្បាលខ្មៅមិនស្គាល់ខេ មានតែកន្លែងហ្នឹងខេ ដែលអាចជួយអ្នកភាល់គ្នាឲ្យរួចផុតពីសេចក្តីទុក្ខបាន ។

ពួកសត្វទឹកដឿជាក់កងចិត្ត ។ ក្អែកទឹកតាំមួយម្តង ។ យកទៅពុកទៅកន្លែងមួយក្រោមថ្មយ៉ាងចង្អៀត មិនមានអ្នកណាទៅត្រង់ ។ ហើយក្អែកទឹកអាខូចស៊ីមួយថ្ងៃមួយ ។ មិនចាប់ខឿយព្រួយទៅមុជចាប់កងចឹង ។

(សុភាសិត : ចូរកុំដឿអ្នកណាដែលស៊ីខ្លួនជាអាហារ) ។

២៩- ជាងលក់ទឹកដោះនឹងក្អមទឹកដោះ

ខាង«តែវែត» ជាក់ក្អមលើរង្វេលស្រួលហើយ ក៏លើកខួលប្រាថ្នាមិនចង់ឈប់ឆ្លងចន្លង់ ដើម្បីឲ្យដល់ផ្សារឆាប់ ស្ទៀកសំពត់ធម្មតា ករឆ្នីញាឡើងយ៉ាងខ្លី ពាក់ស្បែកជើងបាតកប ដើរចុះដំហានវែងៗ កំពុងតែដើរ ខាងនោះមើលគិតតម្លៃទឹកដោះថា: បើអញយកថ្លៃទឹកដោះទៅលិញស៊ីតមាន់ មិនមែនបានច្រើនយ៉ា! ក្បាស់ទៅបានប៊ីសំបុក រឿងនោះនឹងសម្រេចដូចប្រាថ្នា ដោយការប្រឹងប្រែងឲ្យហ្មត់ចត់ ហើយចិញ្ចឹមកូនមាន់នៅជុំវិញផ្ទះ ជាការមិនតិចបាកឡើយ បើកញ្ជ្រោងប្រុសប៉ប់យ៉ាង

ដូចម្តេច កំមិនលែងខ្ញុំកន្ត្រៀមទៅញាំបានកូនជ្រូកមួយ ចិញ្ចឹមជ្រូកតំ
មិនអស់កន្លះប៉ុន្មាន ដល់រាជាត់ជំងឺកាលណា អញលក់ចោនច្រើន
អញយកច្រកំហឹងទៅញាំមេគោមួយដាក់ក្នុងក្រោល យូរទៅកើតបាន
កូនមួយ ដែលអញឃើញវាលោតហក់តញ្ជែងទៅតណ្តាលហ្វូង ។

ដល់ត្រង់នេះ នាងតៃវែត សប្បាយគេក ក្អេចខ្លួន លោតដែរក្តួមទឹក
ដោះភ្នាក់ខ្លាកបែកខ្ចាយ៖ លាហើយ! កូនគោ មេគោ កូនជ្រូក កូន
មាន់ ។ តៃវែតមុខស្លុត ដើរចេញពីទឹកដោះដែលកំពុងហូរហាច
គេញដី ហើយមកសុំអភ័យទោសពីប្តី ព្រោះខ្លាចក្រែងប្តីកយ ។

(នៅមានត)

នារីណាប្តីដេរប្រទេចក្តី ប្តូរប្តីសំឡឹងសំឡក់ដោយក្តីក្រោធក្តី នៅ
តែធ្វើទឹកមុខ ស្រស់ស្រាយញញឹម នារីនោះឈ្មោះថាស្រីគ្រប់
លក្ខណ៍ ។

ស្រីណា ស្រឡាញ់ប្តី ទោះជាប្តីនៅក្រុង ឬនៅស្រុកព្រៃ ឬពុំ-
នោះទេ ដាប្តីគ្មានបុណ្យ ឬមានបុណ្យក្តី ស្រីនោះទើបលោកតាំងមូល
ឲ្យសេចក្តីសុខ ។

សេចក្តីពិត កស្តាជាគ្រឿងអលង្ការនៃនារីតាំងឡាយ នារីឥត
កស្តា ឈ្មោះថាមិនមានគ្រឿងអលង្ការ បើខុកជាមានរូបល្អ ក៏ឈ្មោះ
ថាមិនមានរូបល្អដែរ ។

ទកញ្ចាវិបុលភជសេនា ន្ធ - កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្វើសបើបានអាន
ទំងបេះទយយកលប់ណាន
ចាំងមានសន្តានស្នេហាជាតិ

យូរ - អ៊ុន

នៅទីឆ៍លោក ។ ក៏ចាន់ខំនុកបំរុងឲ្យស៊ុបៀតត្បូងគ្រប់ឆ្នាំមកយូរហើយ នៅមិនបានធ្វើសេចក្តីគាប់ប្រសើរអ្វីស្មងគុណលោកឡើយ ឥឡូវលោកទីឆ៍ចេញទៅខួលឡៅពីនោះ ខ្ញុំចាខយល់ឃើញថាមិនត្រូវ ទីឆ៍សុំឃាត់លោកឲ្យបង្អង់ឈប់សិន ដែលលោកទីឆ៍ចេញទៅឥឡូវនេះ មុខជាទីឆ៍បង់ដោយកលខុចាយឡៅពីជាក្រុកជ សូមឲ្យលោករំពឹងមើលឲ្យមាំមាំសិន ។

ឡៅសុង៍ថា ដែលអ៊ុយគួនមកឃាត់ហាមលោក ជាការខ្លឹងទីឆ៍ដំណើរអ្នកធំដូច្នេះ ខ្ញុំចាខទីឆ៍ចាន់ឃើញជាប្រយោជន៍អ្វីក៏ខ្សោះ តីជាមនុស្សឫស្យា មានតែទីឆ៍ឲ្យលោកកាត់មេត្រីបង៍ប្អូនឲ្យជាប់ពីគ្នា

ក្រោយទើនឲ្យជាចំរូងចម្រាស់ទៅខៀត ។ ឡៅដៀងក៏ស្រែកគំហកបណ្តោញអ៊ុយគួនថា អ្នកឯងកុំមកនិយាយស៊ីជ្រែដែលដូច្នេះឡើយ យើងគិតឃើញជាប្រយោជន៍ស្រួលមួយហើយ យើងមិនត្រូវដឿស្តាប់អ្នកឯងទេ ។ អ៊ុយគួនក៏មានសេចក្តីតូចចិត្តណាស់ ហើយយកមុខទៅកន្លែងទៅលើថ្នាលហៀរហូរឈាមចេញពេញអស់ពាំងខ្លួន ហើយខាំជាយអាវឡៅដៀងពុកមិនឲ្យចេញទៅ ។ ឡៅដៀងទើនខ្លាំងណាស់ក៏កន្ត្រាក់ជាយអាវមកវិញ អ៊ុយគួនក៏មិនព្រមលែងទាល់តែបាក់ធ្មេញរបួតចេញ ២ ដុំ ។ ឡៅដៀងក៏ឲ្យទាហានទាំយកខ្លួនអ៊ុយគួនចេញទៅក្រៅ អ៊ុយគួនក៏ស្រែកយំត្រឡប់ទៅផ្ទះ ។

លីអ៊ីនឃើញដូច្នោះ ក៏ចូលមកស្រែកថា លោកមិនព្រមដឿស្តាប់ពាក្យអ៊ុយគួនឃាត់ហាមដូច្នេះ ទើនតែចេញទៅខ្លួលឡៅពីនោះ ក៏ដូចជាទៅកេតីស្ងាប់ ដែលទើនខ្លួលឡៅពីឲ្យចូលមកកន្លែងស្រុកសែឈួននេះ ក៏ដូចជាទៅខ្លួលខ្លាឲ្យចូលមកនៅកន្លែងកូមិ ។ ឡៅដៀងថា ឯឡៅពីនោះជាសែជាមួយទើនយើង ដែលថាគេទើនមកគិតការនោះក៏ខុសពាក្យបេស់អ្នកឯងយើងមិនចង់ឮសោះ ហើយក៏ឲ្យទាហានបណ្តេញចេញទៅ ។ ខៀវសុនិយាយទើនឡៅដៀងថា ពួកនាហ្នឹងអស់នេះបង់កម្លាំងដែលលោកទើនខំនុកប៉ុងឲ្យស៊ីបៀតែឲ្យតប្រយោជន៍សោះ គ្មាន

សេចក្តីកតញ្ញូនឹងលោកនេះ មានប្រាថ្នាតែនឹងយកសេចក្តីសុខចំពោះខ្លួន ហើយនឹងបំរុងចិញ្ចឹមអរិយាជុគ្រប់ណ្ហើះ គ្មានសេចក្តីសព្វស្រេស្មោះត្រង់នឹងលោក ប្រហែលគិតនឹងធ្វើប្រទូសរាយដល់លោកទេដឹង ចើយ៉ាងដូច្នេះឡៅពីចូលមក ក៏មានតែសេចក្តីខឹងតាស់ខែង មិនឲ្យធ្វើការបានស្រួល ទើបមានចិត្តឫស្យាក្រែងធ្វើដូច្នេះ ដើម្បីមិនឲ្យឡៅពីចូលមកបាន ។ ឡៅជៀងថា ដែលសំដីអ្នកថាដូច្នេះ ជាប្រយោជន៍ដល់ខ្ញុំពិត ។ មិនបង់កម្លាំងដែលខ្ញុំពប់អានស្រាប្រាញ់ ។

លុះដល់ពេលព្រឹក ឡៅជៀងនឹងឲ្យតាហានចេញទៅខួលឡៅពីខួលមានតាហានម្នាក់ចូលមកប្តឹងថា ឥឡូវអង្គុយយកពួរចងខ្ញុំម្នាក់ខ្លួនទៅត្រង់ស៊ុំគ្នាស្រុក ដៃមួយកាន់សំបុត្រ ដៃមួយកាន់ក្រប៉ាស្រែកថា សំបុត្រនេះយើងប្តឹងទៅហ្វាយនាយ បើស្តាប់យើងក៏ហើយទៅ បើមិនស្តាប់យើងនឹងយកក្រប៉ានេះកាត់ពួរឲ្យខ្លាក់ចែកគ្នាស្លាប់នៅទីនេះចុះ ។ ឡៅជៀងឮដូច្នោះក៏ប្រើឲ្យមនុស្សទៅយកសំបុត្រនោះមកមើលឃើញសេចក្តីថា : « ខ្ញុំបាទអង្គុយសុំគំនាប់ទុកឲ្យលោកជ្រាបព្រោះខ្ញុំបាទបានឮបូកណាគោលតគ្នាមកថា ថ្នាំល្អស៊ីទៅដូរចត់ក្តឹងមាត់តែថាប្រយោជន៍ដល់មនុស្សឈឺ មនុស្សត្រង់និយាយមិនពីរោះដល់ត្រចៀក តែជាប្រយោជន៍ដល់កាលខាងមុខ ដែលលោកមិនស្តាប់ពាក្យខ្ញុំបាទ នឹងចេញទៅខួលឡៅពីឯស្រុកប៉ាសៀនោះ ខ្ញុំបាទយល់

យើញថា កាលដៅមានផ្លូវដៅស្រួល តែដល់ត្រឡប់មកវិញមុខ
ជាគ្មានផ្លូវមកស្រួលទេ ឲ្យលោកតិត្រែះមើលឲ្យល្អសិន បើលោក
ស្តាប់ពាក្យខ្ញុំបាទ ចូរលោកឲ្យចាប់ខ្លួនដៀវសុងកាត់ក្បាលចេញ ហើយ
ស្តាត់ដៀវតីកុំឲ្យចូលមកកងស្រុកសៃឈ្នួនបាន ខ្លួនលោកក៏ធំឆ៍បាន
គ្រងសម្បត្តិជាសុខតដៅ បណ្តាអាណាប្រជានុកស្តួចាំងពួងក៏ធំឆ៍មិន
មានសេចក្តីក្តៅក្រហាយឡើយ ។

ដៀវដៀងឃើញសំបុត្រដូច្នោះហើយក៏ខឹងណាស់ថា ដៀវតីជា
មនុស្សមានសតិបញ្ញា យើងទិនគេក៏ស្រឡាញ់គ្នាស្មើធំឆ៍បងប្អូនបង្កើត
តោះមួយធំឆ៍គ្នា គ្មានចិត្តរង្កៀសអ្វីធំឆ៍គ្នាសោះ ហេតុម្តេចមនុស្សពួក
នេះកាកែងមកនិយាយខឹងធំឆ៍ដល់ខ្ញាំងម្ល៉ះ ។ ឥតិតធំឆ៍ឲ្យយើងធំឆ៍ដៀ
តីដៅជាសត្រូវធំឆ៍គ្នាឬ ? អង្គលុយបានឮដូច្នោះក៏តែតតួចចិត្តពេក
ណាស់ ស្រែកឡើងដោយសំឡេងខ្លាំង ហើយយកគ្រប៊ីកាត់ពួរគោះ
ដាច់ធ្លាក់មកបាក់កស្លាប់មួយរំពេច ។ ដៀវដៀងកិចាត់ឥហាន ៣
ហ្មឺនយកព្រៃយាំងល្ហ ផ្តុកតេញ ៣ រះនេះ ធំឆ៍របស់មាសប្រាក់ស្បៀង
អាហារជារបើនលើកចេញចាកស្រុក ស្រុតដៅចាំខួលដៀវតីស្រុក
ចោំងសៀ ។

ឯដៀវតីលើកតលមកដល់ព្រំដែនស្រុកសៃឈ្នួន បញ្ជាឥ-
ហានចាំងពួងមិនឲ្យបៀតបៀន ធ្វើទុក្ខបុកម្នេញអាណាប្រជានុកស្តួ

តាមរយៈទៃត្រកែស្បៃផ្លូវនោះ ឋណ្ណាកស្ត្រកំមានសេចក្តីត្រេកអរ ឡៅ-
ពីទៅដល់ត្រំដែនទៃត្រណា ឥស្ត្រកន្ធទៃត្រនោះក៏ប្រមូលគ្នាចេញមក
គំនាប់ឡៅតី ។ ក៏និយាយសាកសួរសុខទុក្ខតាមសុភាព ។ ហួតចេនក៏
និយាយនឹងថ្នាងថនថា ខៀវសុងឲ្យនាំសំបុត្រស្លាត់មកដល់ខ្ញុំថ្ងៃថា
ឡៅដៀនទឹងលើកតហានមកទួលនាយរបស់អ្នក ឯស្រុកចាំយសៀ
យើញបានការស្រួលហើយ បួរកែតកំចាត់ឡៅដៀនចេញពីដើមដៃ
កុំឲ្យតែតកែខ្លួនបាន ។ ចាំងថនថា សេចក្តីនេះ អ្នកកុំឲ្យលនិយាយ
ឲ្យបែកផ្សាយសេចក្តីឡើយ ក្រែងកិត្តិសព្ទនោះទឹងខ្លាចទៅ ត្រូវ
ធ្វើឲ្យឡៅដៀងទឹងឡៅតីនាយយើងទៅមករកគ្នាជាមេត្រីសិន រួច
សន្យឹមធ្វើការនោះជាក្រោយ ។ ហួតចេនក៏យល់ឃើញត្រូវដែង ឯ
ស្រុកសែឈួនទឹងស្រុកចាំយសៀនោះ រយៈផ្លូវចម្ងាយតីគ្នា ៦០០ សិន
(២៤គ.ម.) លុះឡៅដៀនទៅដល់ស្រុកចាំយសៀហើយ ក៏រៀប
តហានចេញទៅទួលឡៅតី។ ក៏ឲ្យតហានតាំងតួងឈប់តាំងបន្ទាយទៅ
ខាងក្រៅស្រុក ហើយក៏ចូលទៅរកឡៅដៀង អ្នកតាំងតីរកគំនាប់គ្នាតាម
ប្រពៃណីបងប្អូន ហើយនិយាយប្រស្រ័យគ្នាតីសេចក្តីសុខទុក្ខអំតីដើម
រហូតមកឲ្យស្កប់ត្រប់ប្រការហើយក៏យំ ឡៅដៀងក៏ឲ្យរៀបតុលៀងអា-
ហារស្រេច ក៏ឲ្យអញ្ជើញឡៅតីចរិកោតសេតសុកជាមួយគ្នាជាសប្បាយ
លុះដល់គេលត្រលប់ឡៅតីក៏គំនាប់លាឡៅដៀងទៅឯបន្ទាយវិញ ។

ខ្លៅជៀងកំនិយាយទំនងបណ្តាទាហ៊ានខ្វះកងការទាំងពួងថា អង-
លុយទិងអ៊ុយគួរ ២ នាក់នេះ មិនមានប្រាជ្ញាអ្វីសោះ ខ្ញុំគិតទៅក៏
គួរអស់សំណើចណាស់ គួរឬមកសង្ស័យថា ខ្លៅតើមិនជាមនុស្សសុច-
តែត្រង់ទឹងចង្អុលនោះមិនគួរសោះឡើយ យើងឃើញខ្លៅពីហើយថ្ងៃ
នេះ តាត្រោះមើលឫកឫគាកិរិយាស្គាល់ថាជាមនុស្សត្រង់ ដឹងអធ្យាស្រ័យ
ស្រឡាញ់ចង្អុលតិតណាស់ បើយើងបានខ្លៅតែបងយើងមកទុកជួយ
ខំទុកបំរុងផែនដីជាមិនគោកយន្តពុយតែខាងក្រៅហើយ កាលណា
ឡើយទឹងកោតញាញើតដល់ចួនទិងខៀវឡែនោះ ខ្ញុំនឹងខ្ញុំនេះកំពុសណាស់
ដែលទឹងមិនបានលើកទឹកដល់បងចង្អុលរបស់ខ្ញុំនៅពីថ្ងៃមុន ។ លុះតែខៀវ
សុងមកប្រាប់ទើបតិតយើញ សេចក្តីតាប់ប្រសើររបស់ខៀវសុងមាន
លើយើងច្រើនណាស់ ទិយាយហើយក៏ដោះអាវចេញពីខ្លួន ឲ្យបំរើ
យកទៅឲ្យខៀវសុងឯស្រុកសែឈួន ឲ្យទាំងមាស៨០០ដុំឡឹងខៀត ។

ខណៈនោះ ខ្លៅកុយ ខ្លេងចុង ខៀវយិន តេងហៀន
ទឹងទីប្រឹក្សាទាំងពួងខាងមាហាន ទាំងគ្នាទិយាយទឹងខ្លៅជៀងថា លោក
កុំអាលត្រេកអរបួលទៅជិតខ្លៅពីពេក ព្រោះខ្លៅពីនោះធ្លាប់កិរិយាកេះ
ភយទិយាយសំដីពីកេះទន់សុភាពក៏មែន តែថាជាមនុស្សប្រាជ្ញាមានមា-
យាយ៉ាងល្អិត ចិត្តនោះក៏ងឿរូសដូចដែកប្តូរពេជ្រមើលមិនលេចដូចសំដី
ទេ សុំកុំឲ្យលោកប្រមាទបួរិះគិតរកងឹខ្លួនឲ្យមួនទាំ ។ ខ្លៅជៀងអស់

សំណើចហើយថា អ្នកចាំងអស់នេះ បបួលគ្នាមកសង្ស័យខ្លះ ។ មិនគួរការសោះ ព្រោះឡៅតីចង់ឃើងនោះ មិនមែនជាមនុស្សចិត្ត ២ ។ ចំប្រឹក្សាចាំងនោះ ក្តុហើយក៏នាំគ្នាជកដង្រើមធំ ហើយចេញទៅ ។

កាលឡៅតីវិលត្រឡប់ទៅបន្ទាយវិញ ចាំងថងក៏ចូលទៅសួរថា ថ្ងៃនេះលោកទៅពិសាលៀងនឹងឡៅជៀងនោះ ឃើញឡៃចខាយជាប្រការម្តេចខ្លះ ? ។ ឡៅតីក៏ប្រាប់ថា ឡៅជៀងនោះជាមនុស្សសុចរិតត្រង់ប្រាកដណាស់ ។ ចាំងថងថា ឯឡៅជៀងនោះ ជាមនុស្សត្រឹមត្រូវក៏មែន តែថាបណ្តាខាហ្មឹនចំប្រឹក្សាចាំងពួងសុទ្ធតែជាមនុស្សបើងរឹងរូសមិងមែនចុះចិត្តប្រាកដទេ បើលោកនឹងដំអក់ពុកឡៃយូរទៅនឹងខូចការអស់រវត្តប្រយោជន៍ ខ្ញុំឃាតគិតថា សូមឡៃលោកហៅរក ឡៅជៀងមកលៀងអាហារឯបន្ទាយយើង ។ ត្រូវប្រើខាហានឡៃចាប់សម្លាប់ចោលចេញ ហើយសឹមលើកចូលទៅស្រុកសែឈ្នះស្រួលជាជាង មិនចាំបាច់ហូតក្រចើឡៃចេញពីស្រោម មិនចាំបាច់ឃើតដួងដាក់ព្រួញឡៃខូចដាច់ប្រឡោះមិនស្រួលឬ ? ។

ឡៅតីថា អ្នកគិតដូច្នេះ ខ្ញុំមិនពេញចិត្តសោះ ព្រោះឡៅជៀងនោះជាសែជាមួយនឹងខ្ញុំ ហើយគេក៏មានចិត្តសុចរិតល្អត្រង់នឹងខ្ញុំមែន ។ យើងមកឥឡូវនេះសោត ក៏ប្រាថ្នានឹងតាំងខ្លួនដោយសុចរិតប្រពៃដើម្បីឡៃគេសរសើរ កាលមានដំណើរលើកមកដល់កិតួឡៃមនុស្សចាំងពួង

ឃើញចិត្តយើងជាល្អ ខឹងសេចក្តីមេត្រី ឆ្លៀតមិនទាន់ប៉ុន្មាន ក៏ទៅ
ធ្វើអន្តរាយដល់ខ្លៅដៀងនែ្តម្តងដូច្នេះ មិនជាខឹងហាន៎ខ្លាដល់មនុស្ស
ខឹងទេតា លោកតេះដៀលទេឬ? ដែលខឹងធ្វើឲ្យខូចសេចក្តីសត្យ ទុសអំពី
ប្រពៃណី នោះខឹងធ្វើមិនបាន ។

ចាំឆបងថា ដែលខ្ញុំបាទថាខាំងនេះ ខឹងជាសេចក្តីគិតរបស់
ខ្ញុំបាទក៏ទេតើ ខ្លៅដៀងទេញ ហួតចេងឲ្យគិតធ្វើការកំចាត់
ខ្លៅដៀងចេញ ហួតចេងក៏យកសំបុត្រនោះមកបង្ហាញខ្ញុំបាទ ។ ក៏ដំណរ
លោកតាមការ ។ ខ្លួលនិយាយគ្នាមិនបានផុតមាត់ ហួតចេងចូលមក
ដល់ហើយថា ដែលខ្ញុំបាទឲ្យធ្វើការនោះ មិនមែនជាផ្លូវប្រយោជន៍ដល់
ខ្លួនខ្ញុំបាទទេ ប្រាថ្នាខឹងឲ្យជាគុណដល់លោកទេតើ ការនេះមិនមែនជា
ទុសអំពីប្រពៃណីនោះឡើយ គឺត្រូវហើយខឹងប្រពៃណីពីដើម ។

ខ្លៅតិចថា ខ្លៅដៀងនេះជាសែជាមួយគ្នាខឹងយើង ដែលខឹងធ្វើ
អន្តរាយនោះមិនគួរសោះឡើយ ។ ហួតចេងថា បើលោកមិនធ្វើតាម
ពាក្យខ្ញុំបាទទេ មុខជាខឹងខូចការជាប្រាកដ ព្រោះខ្លៅដៀងនឹងខ្ញៀវឡ
ជាគូសត្រូវគ្នា បើខ្ញៀវឡើងមកវាយស្រុកសែឈ្នះបានក្នុងគ្រានេះ
លោកមកតាំងផ្លូវឆ្ងាយនឹងមិនបង់កម្លាំង ដែលពួកខាហានមកលំបាកឥឡូវ
ហាត់ទេឬ? ប្រការមួយទៀត ខឹងចាំគិតតែអង់ឲ្យទៅយួរថ្ងៃយប់ទៅទៀត
ប្រយោជន៍អ្វី បើមានមនុស្សទាំងដើរទៅញុះញង់ខ្លៅដៀងឲ្យប្រឡូសក៏យ

ន៏ឯលោកវិញក៏សឹងតែបាន លោកក៏ន៏ឯងមានតែសេចក្តីវល់ខាតការខេ
ខៅ ឥឡូវមេឌុសូរ្យតាំងពួនក៏មានសេចក្តីត្រេកអរស្រឡាញ់លោកច្រើន
ណាស់ លោកចូរហ៊ាសគិតការនេះឲ្យបានខាន់ឡៅដៀងមិនខាន់ដឹងជាន
ត្រូវតែសម្លាប់ចេញៅ ហើយយកស្រុកសែឈួនជាតំាងឲ្យបានមុន
សិន ដែលន៏ឯគិតធ្វើការធំៅខាងមុខនោះក៏ន៏ឯបានស្រួល ឡៅតាក៏មិន
ត្រម តាំងតែនិយាយគ្នាមិនដាច់ស្រេចដូច្នេះជាច្រើនគ្រា ។

លុះពេលព្រឹកឡើង ឡៅតាក៏ចូលៅថវាយគាហាឯបន្ទាយឡៅ.
ដៀងខៀត អ្នកទាំងពីរសេពសុកនិយាយគ្នាជាប្រក្រតីភាមប្រពៃណីបង
ប្អូន ទើបចាំងឋង់ឡឹបប្រាប់ហួតចេង់ថា ការកំប្រលំតួដល់ប៉ុណ្ណេះហើយ
នាយយើងនៅកាន់តែសេចក្តីសំគ្បត្រង់ មិនត្រមធ្វើតាមពាក្យយើងសោះ
ដូច្នេះ ការនេះមុខជាន៏ឯខូចអសារឥតការ ពោះនាយន៏ឯកាន់សេចក្តី
សំគ្បក៏តាមអធ្យាស្រ័យៅចុះ យើងត្រូវតែរិះគិតធ្វើឯង៏ៅ ទើបបង្គាប់
អ៊ុយអៀនថា ឥឡូវឡៅដៀងសេពសុកស្រឹទ្ធមិនដឹងខ្លួន បានការហើយ
អ្នកចូលៅសម្លាប់ចេញចុះ ។ អ៊ុយអៀនក៏ហួតគ្រប៉ដើរចូលៅចំពោះ
មុខតុលៀងអាហារហើយថា ខ្ញុំបាទន៏ឯសុំកំគ្រប៉ដូនលោកតាំងពីរមើល
លេង៏ឲ្យសប្បាយក្តែក ។ ចាំង៏ឋង់ក៏ស្រែកឡើង៏ថា ចៃដូច្នោះស្អុះហើយ
គាហានតាំងពួងចូរថយចុះមកខាង៏ជាន់ក្រោម ឲ្យអ៊ុយអៀនកំគ្រប៉មើល
លេង៏ នោះអ៊ុយអៀនក៏កំគ្រប៉ៅមុខតុ ។ គាហានឡៅដៀងឃើញអ៊ុយ.

អៀនកំក្រៃ ទឹងតួកខាហានក្រៅពីនោះ កំភាន់ត្រឿងសស្ត្រាវុធ ទាំ
គ្នាក្រេឡកមើលឡៅដៀងយើញសំកុកនៅ កំភ្លឺកក្នុងចិត្ត ខៀយើមកប្តូត
ក្រប៉ាចេញមកហើយថា ដែលកំក្រប៉ាគ្នាខគូនោះមិនល្អទេ ខ្ញុំបាទនឹងសុំកំ
ក្រប៉ាតតួនអស់លោកមើល ថាហើយកំក្រោកឡើងកំតខល់គ្នាទឹងនុយ-
អៀន ។ កំហើយសំឡឹងចោលកន្ទុយភ្នែតមើលឡៅហាង ។ កំចេញកំក្រប៉ា
ជាមួយខៀត ។ ឡៅកុយ ឡេងហ្មៅ តេងហៀន ជាខាហានឡៅដៀង
យើញដូច្នោះកំដកក្រប៉ាចេញហើយស្រែកថា ខ្ញុំទឹងសុំកំឲ្យអស់លោកទាំង
៤ សើចលេងតាមសប្បាយខ្លះ ទាំងពីរនាក់កំកំក្រប៉ាចូលជាតួកនឹងគ្នា ។

ឡៅពីយើញខាហានទាំងតួងកំក្រប៉ាដូច្នោះកំភ័យណាស់ ទើបខាញ
ក្រប៉ាអំពីដៃខាហានដែលនៅឈរដើតខាងនោះ ក្រោកចេញទៅឈរនៅ
មុខតុហើយថា ខ្ញុំយើងបងប្អូនមកជួបគ្នាមានសេចក្តីសប្បាយស៊ីជាយ
ផឹកស្រាជាមួយគ្នាតាមប្រពៃណី តួរឬអ្នកទាំងតួងមកមានសេចក្តីសង្ស័យ
ដូច្នេះមិនគួរសោះ មិនមែនទឹងដូចពីគ្រាព្រះចៅហ៊ានកោចោ ទឹងព្រះចៅ-
ឈប៉ាអង សោយសុកជាមួយគ្នាកងបន្ទុយដំកប៉ុនតួនោះទេ ចូរឲ្យ
ចោលក្រប៉ាចេញឲ្យអស់ពីដៃទាំងអស់គ្នា បើខណាមិនចំលាក់ក្រប៉ាចេញ
ទឹងត្រូវកាក់ក្បាលឥឡូវនេះ ។

ឡៅដៀងស្រែកគំហកឲ្យខាហានទាំងតួងថា យើងបងប្អូនស្រ-
ឡាញ់គ្នាដោយសុចរិត ហេតុម្តេចអ្នកទាំងតួងមកធ្វើឲ្យច្រួលច្របល់

ដូច្នេះ ត្រូវការអ្នកកាន់ក្រប៉ាចូលមកក្នុងទីប្រជុំ ចូលថយចេញទៅឲ្យ
ឆាប់ ។ ទាហានទាំងនោះខ្លាចឡៅដៀងកំថយចេញទៅអស់ ទើប
ឡៅពីហៅទាហានឡៅដៀងដែលជាទាយធំនោះ ឲ្យឡើងមកថ្នាក់លើ
ដែលបរិភោគអាហារ ហើយឲ្យស្រោងកត្រប់គ្នា ហើយនិយាយថា ខ្លួន
យើងទាំង ២ ជាបងប្អូនធំនឹងគ្នា ដែលយើងមកគ្រានេះក្រុងថ្នាំធំជួយការ
ពារក្សាស្រុកខេសឲ្យបាននៅជាសុខសប្បាយតទៅ ដែលយើងខឹងគ្នត
ដាំចិត្ត ២ នោះគ្មានទេ អ្នកកាល់គ្នាកុំបីឆ្លៀសងឹរឃ្លែអ្វីឡើយ ។ ទាហាន
ពួកនោះ លុះឮឡៅពីថាដូច្នោះក៏ត្រេកអរសាទរ លើកដៃឡើងគំនាប់
ហើយថយចុះមកវិ ។

ឡៅដៀងឮឡៅពីនិយាយដូច្នោះកំចាប់ដៃហើយថា បងនេះស្រ-
ឡាញ់ខ្ញុំណាស់ ឃើញសុចរិតពិតមែន ។ ខ្ញុំគ្មានមន្ទិលសងឹរឃ្លែអ្វីទេ
ខឹងសុំស្នងគុណបងតទៅរហូតដល់ស្លាប់ ។ ឡៅពីនឹងឡៅដៀងក៏មាន
សេចក្តីស្មោះសរនឹងគ្នាទៅវិញទៅមក លុះសេពសុករហើយ ក៏ទៅ
អង្គុយនិយាយគ្នាគាល់តែដល់តេលត្រលប់ កាលឡៅពីត្រឡប់ទៅ
បន្ទាយវិញក៏និយាយទឹងប៉ាងបងថា អ្នកនេះមិនមានសេចក្តីពិតត្បិតប៉ិយ
អ្វីសោះ ដែលអ្នកធ្វើចាំងនេះនឹងឲ្យមនុស្សគេហានិទ្ធដល់យើងបាន ត
ថ្ងៃនេះតទៅមុខ ចូរកុំគិតធ្វើដូច្នេះទៀតឡើយ ។ ចាំងបងក៏គំនាប់លា
ចេញទៅកាន់ទីតែម្នឹង ។

ឯខ្លៅកុយ ខ្សែនខ្ចៅ តេនហៀន ក៏និយាយទំនងខ្លៅជៀងថា ថ្ងៃនេះលោកតាសាសុកជាម្ចាស់ទំនងខ្លៅតាយើញខ្សែបទាយម្តេចខ្លះ សូមឲ្យលោកនាប់លៃទៅស្រុកវិញកុនៅឲ្យយឺតយូរតទៅឡើយ បើលោកមិនត្រឡប់ទៅផ្ទាប្រញាប់ទេ ទំនងមានសេចក្តីភ័យអន្តរាយជាក្រោកដ ។ ខ្លៅជៀងថា ខ្លៅតាបងយើងនោះមានចិត្តសុចរិតត្រង់ណាស់ ជាន ប្រទះឃើញទឹងក្បែកជាក្រោកដហើយ ដែលទំនងតតាមត្រូវស្តីទំនងយើងដូចអ្នកភាំងតួងសំតាល់នោះកំពុសទៅ អ្នកកុំបីសង្ស័យអ្វីឡើយ ។ ខ្លៅកុយ ខ្សែនខ្ចៅ តេនហៀនថា ឯចិត្តខ្លៅតានោះជាមនុស្សត្រង់សុចរិតតាមែនហើយ ប៉ុន្តែ បណ្តាជាន សុទ្ធតែមានចិត្តគិតបំណងបំផ្លាញទំនងធ្វើអាក្រក់ជាពុល នោះបើយ៉ាងណាក៏គង់ចាក់រុកឲ្យដណ្តើមយកស្រុកសែលួនឲ្យបាន ទៅខ្លៅតាពុំខាន ព្រះគតមានប្រទានតែទំនងយកប្រយោជន៍ដាក់ខ្លួនប៉ុណ្ណោះ ។ ខ្លៅជៀងក៏មិនបានឿស្តាប់ ទើបអញ្ជើញខ្លៅតាឲ្យចូលមកបរិភោគអាហារជាមួយគ្នា ក្នុងស្រុកចាំយសៀកលៃថ្ងៃ ។

ខណៈនោះ មានបំរើសេះមកប្រាប់ថា ឥឡូវខ្សែទំនងលើកទ័ពមកវាយយកបន្ទាយហែចាំងគួន ខ្លៅជៀងក៏ចូលទៅរកខ្លៅតាឲ្យជួយប្រឹក្សា ហើយក៏និយាយអង្វរលន់តួឲ្យខ្លៅតាលើកទាហានទៅការពារទំនងខ្សែ ខ្លៅតាខ្ជិលតាស្យហើយ ក៏លើកទាហានចេញទៅតាំងបន្ទាយនៅហែចាំង ទាហានតាំងតួងក៏និយាយទំនងខ្លៅជៀងថា

ឥឡូវឡៀតីលើកទៅខ្លួលតទ័ពទៀឡេហើយ សុំកុំឲ្យលោកខុកចិត្តឡៀ.
តីក្រែងត្រឡប់តតប្រជួស្តុកយថយក្រោយមកធ្វើអន្តរាយលោកវិញ ត្រូវ
លោកចាត់ចែងឲ្យជាក់តយល្បាតតាមផ្លូវដែលត្រូវទៅមកឲ្យមាំមួន ដើម្បី
ទប់ទល់ការពារខ្លួនលោក ឡៀដៀងក៏មិនស្តាប់ លុះទីប្រឹក្សាចាំង
នោះចូលមកព្រួតនិយាយជាច្រើនជង្គេត ទើបឡៀដៀងយល់ឃើញ
ដង ហើយតាំងរៀបចាត់ចែងទាហានឲ្យទៅវិញ គោរាយ ២ នាក់
ឃុំទាំងទាហានចេញទៅរក្សាបន្ទាយចាំយស៊ីគួនច្រាំថ្នាំទប់ការពារឡៀតី
ហើយក៏លើកទ័ពត្រឡប់ទៅស្រុកសែឈួនវិញ ។ ឯឡៀតីនោះ លុះ
លើកទ័ពទៅដល់បន្ទាយហៃចាំងគួនហើយ កំបង្គាប់ទាហានចាំងពួងមិន
ឲ្យធ្វើអន្តរាយដល់ពួកជនានុជនក្នុងស្រុក ច្រាំថ្នាំទប់ឲ្យឮកិត្តិសព្ទរន្ធឺតទៅ
ដើម្បីទប់ចិត្តអាណាប្រជានុរាស្ត្រ ឲ្យមានមេត្រីភក្តីស្រឡាញ់ ។

សាមក្កីខ្សែ ៥១

តាំងតីស៊ុនគួនឆឺងដំណាំងថា ឡៀតីលើកទ័ពទៅស្រុកសែឈួន ស៊ុនគួនប្រើនយាយឲ្យសំ-
បុត្រទៅហៅតាងស៊ុនហ៊ូយិនឯស្រុកកេងដីវ រហូតទៅដល់ឡៀតីភាប់កោងាយ តំងអៀវហួត
សម្លាប់ ហើយវាយយកបន្ទាយចាំយស៊ីគួនបាន ។

ឯស៊ុនគួនដឹងថា ឡៀតីលើកទ័ពទៅស្រុកសែឈួន កំឲ្យហៅ
នាម៉ឺនតាំងពួងចូលទៅប្រឹក្សា គោះយ៉ាងនិយាយថា ដែលឡៀតីលើកទ័ព
ទៅស្រុកសែឈួនគ្រានេះ កំដាច់ផ្លូវឆ្ងាយដាច់អាល័យ បានសេចក្តីស្រួល

(នៅមានត)

លោក ប៉ិ៍យ-ម៉ិុតរ ប្រែរៀបរៀង

(តចប់)

រឿងលោកវរៈជនម្នាក់នាម "សឺហ្គាល់"

"លោកអ្នកមិនត្រូវអគុណខ្ញុំទេ ។ ឯបំណងរបស់ខ្ញុំ គឺប្រាថ្នាឲ្យតែលោកអ្នកបានសុខសប្បាយ រស់នៅដោយសន្តិភាពប៉ុណ្ណោះ" ។

លោកសឺហ្គាល់ ក៏លាបក្បាបក្បៀតាំងខ្លាយ ហើយក៏បន្តដំណើរទៅទៀត ។

មួយរំពេចនោះ លោកបានទៅដល់ភូមិមួយ ។ លុះលោកអញ្ជើញចូលទៅក្នុងភូមិនោះ លោកបានក្រឡេកទៅឃើញទឹកមុខពួកអ្នកភូមិដូចជាថប់ព្រួយបារម្ភអំពីរឿងអ្វីម្យ៉ាង ។ លោកក៏បានបញ្ឈប់សេះតិចនិត្យមើលសព្វគ្រប់ខ្លួនតាំងខ្លាយនោះ ស្រាប់តែឃើញយាយចាស់ម្នាក់ដែលកើតទុក្ខភ័យឥតឧបមា ។ លោកក៏បានសួរទៅយាយចាស់នោះថា :

"នែលោកយាយ ! ខ្ញុំសូមសួរលោកយាយ តើនៅភូមិនេះ ប្រជាពស្ត្រតាំងខ្លាយ តាំងប្រុសស្រីរស់នៅដោយសេចក្តីសុខសប្បាយឬ ? ម្តេចក៏មានទឹកមុខក្រៀមក្រំយ៉ាងនេះ :

យាយចាស់ក៏តបទៅលោកសឺហ្គាល់វិញថា: "ប្រជាពស្ត្រប្រុសស្រីសុខសប្បាយ ! ចាស់ ! បើតាមអតីតកាលមែន តែឥឡូវនេះ យើងខ្លួនតែ

សេចក្តីខុសត្រូវលំបាកជាងនេះទៅទៀត ។ អ្នកឯងឃើញស្រាប់ សត្វថ្លែនគេញីមួយនៅក្នុងភូមិនេះ សូម្បីតែចៀមមួយក៏គ្មានផង ស្មៅដែលដុះនៅទីនេះសុទ្ធសឹងតែអស់ ។ ទឹកដែលហូរពីប្រភព ហូរទៅលើថ្មឆ្កាត់ទៅក្នុងចំងាយខ្លីឥតប្រយោជន៍ ។ ពេលនេះ ត្រូវវែនគេមកបរិភោគមនុស្សតាំងឡាយនេះហើយ » ។

ក្នុងពេលនោះ មានតាចស់ម្នាក់ចូលទៅជិតលោកសីហ្គាល់ ហើយពោលថា :

« នៅមហាសាគរខាងលិចទិស មានសត្វសាហាវយង់ឃ្នង់មួយ។ សត្វនោះតែងតែមកកាន់ទីនេះ សម្លាប់ហ្វូងសត្វពាហនៈ ហើយវាបរិភោគគោ ចៀម យើងអស់គ្មានសល់ ។ ដល់ក្រោយ វាធ្វើចិត្តរឹងរូសអើង មិនត្រឹមមកបរិភោគសត្វពាហនៈនោះដល់ទីកន្លែងទេ វាមានបង្គាប់បញ្ជាឲ្យយកគោ ចៀម វាល់ថ្ងៃទៅកាន់មាត់សមុទ្រឯទីកន្លែងវាតែម្តង ។ បើយើងមិនត្រឹមយកសត្វតាំងនោះឲ្យវាស៊ីទេ វានឹងបំផ្លាញភូមិយើងគឺយកភូមិចោលទៅ « ក្នុងសមុទ្រខ្ចិចខ្លីអស់គ្មានសល់.. » ។ តាចស់និយាយហត់ មានក្មួនក្មេងម្នាក់ពោលតទៅទៀតថា :

« ដូច្នេះនេះ ជិតអស់គោ ចៀមយើងហើយ . . . រួចត្រូវវាស៊ីមនុស្សតទៅទៀត . . . » ។

លោកសីហ្គាល់ តបៈវ៉ាតាថាសវិញថា: តើសត្វសាហាវយង់ឃ្នង
នោះនៅឯណា" ? ។

មានបុរសម្នាក់ឆ្លើយថា: "មានគ្រូមន្តអាគមម្នាក់ឲ្យដំណឹងថា សត្វ
នោះកាចសាហាវពន់ពេក" ។

លោកសីហ្គាល់ ក៏ចំផាយសេះទៅកាន់គេហដ្ឋានលោកគ្រូហើយ
សួរទៅលោកគ្រូនោះថា:

"អ្នកឯងដឹងជាក់ច្បាស់ តើសត្វកាចសាហាវនោះជាអ្វី ? វាបំ
ផ្លាញអស់ប៉ុន្មានទៅ ? " ;

លោកគ្រូក៏តបទៅលោកវិញថា: "សត្វកាចសាហាវនោះ គឺ
នាគ . . . " ។

លោកសីហ្គាល់ ឆោលថា: "តើឯងសូត្រធម៌ប្រយោជន៍អ្វី ? នាគ
នៅតែស៊ីគោ ចៀម អ្នកស្រុកដដែល ! " ។

លោកគ្រូមន្តអាគមក៏ឆ្លើយថា: "នែវ៉ាបុរសអើយ ! ធម៌ខ្ញុំ បើទុកជា
សូត្រយ៉ាំងណា ក៏ពុំស្តាប់ ក៏ចិត្តវង្វេងតែពីធ្លីឆ្ងីឆ្ងាយ មិនមានចេះខន់សោះ
ឡើយ ។ ទៅកន្លែងខ្លះ ក៏គេមិនអាចចាប់វាបាន ទៅតាមមាត់សមុទ្រដាវ
ធ្វើពីដែកថែបលត់ច្រាំបួនជង់ មិនអាចធ្វើនាគនោះឲ្យមានរបួសបាន ក្រៅ
ពីនេះ មានតែក្លើងទៅដែលអាចសម្លាប់នាគនេះបាន" ។

លោកសីហ្គាល់ អង្គុយគិតមួយស្របក់ ហើយក្នុងមួយរំពេចនោះគំ
លោតលើខ្នងសេះបំផ្លាយទៅកាន់ទិសបូព៌ា ។ លោកអញ្ជើញទៅដល់តំរក្ក
ដែលមានដែក ។ លោកសីហ្គាល់ឃានបំផ្លាយសេះចំដុំក្នុង ហើយខ្នងសេះ
ឃានដែកបិដេម មានវិជ្ជមាត្រជាងម្ភៃសន៌ីម៉ែត្រ ហើយគំលែត្រឡប់
យ៉ាងលឿនមកកាន់កូមិនោះវិញ ។ ដំណើរលោកសីហ្គាល់ ដែលមាន
រយៈផ្លូវចម្ងាយជាងមួយសែនគីឡូម៉ែត្រ គឺលោកធ្វើតែមួយរំពេចប្រហែល
ពេលខ្លួលឃានឃ្លាយមិនឃាន់រួចផង . . . ។

លោកសីហ្គាល់ កំប្រាប់ទៅប្រជាកស្ត្រីជាន់ឡាយ ឲ្យប្រមូលទុស
ហើយដុតឲ្យឆេះ ទើបយកដែកជាន់ជើងកំណាត់ទៅពេលក្តៅឲ្យក្រហមផ្លៅ
រួចឲ្យយកដែកនេះទៅកាន់មាត់សមុទ្រ ព្រមជាន់ចៀមមួយដែលត្រូវឲ្យ
ឃាតបរិភោគពេលនោះ ។ លោកបានចាត់ឲ្យយកដែកក្រហមផ្លៅនោះ
ទៅតម្ងើនដូចជាខ្ញាន់ទ្វារ ហើយយកចៀមមួយទៅជាក់ជាតដែកក្តៅ
នោះ ។ សាច់ចៀមខ្លែនោះធុំក្លិនឆ្ងាញ់សាយភាយទៅលើសមុទ្រ ។
ស្រាប់តែក្នុងមួយរំពេច មានភ៉ាយោបក់មកយ៉ាងខ្លាំង ប្រជាត់ទឹកសមុទ្រ
មានទឹកគួចខ្ពស់លើងទៅលើកំពស់ប្លន់ឬក្រាំម៉ែត្រ ។ ក្នុងពេលនោះ
មានឃាតសម្បុរភ្លៅមួយលោតមកកាន់មាត់សមុទ្រហើយ ស៊ុះទៅលើចៀម
ខ្លែ ហើយកិកកេរស៊ីចៀមនោះ ។ តំប៉ុន្តែខ្លួលដែកក្រហមផ្លៅនោះ
រលំសន្ធត់ទៅលើឃាត ។ តំខំរើបម្រាស់ស្រែកថ្ងូរ ព្រោះលោកក្តៅយ៉ាង

ខ្ញុំឯង ។ មិនយូរប៉ុន្មានគាត់ក៏សួរឲ្យដឹងតួនាទីនោះទៅ ។

ពួកប្រជាពស្ត្រីទៅកូមិនោះទាំងអស់គ្នាត្រង់ខ្លោងទ្វារចូលទៅក្នុង ។ មានខ្លះមានចិត្តក្តាហានទៅដើរទៅដល់មាត់សមុទ្រដើម្បីនឹងមើលនាគស្វាប់ ។ ដល់អ្នកទាំងអស់បានដឹងដឹងដោយជាក់ច្បាស់ថា នាគស្វាប់ពិតប្រាកដហើយ អ្នកទាំងឡាយទាំងបុរសស្ត្រី ក៏មានចិត្តរីករាយសប្បាយឥតឧបមា នាំគ្នាពោលសរសើរតែអំពីលោកសីហ្គាល់ ហើយក៏ស្រែកត្រេកអរសាទរតន់ពេកត្រមទាំងសំដែងនូវគុណញ្ញូតាធម៌ជាយ៉ាងជ្រាលជ្រៅចំពោះលោក ។ អ្នកទាំងអស់ទាំងបុរស-ស្ត្រី.ក្មេងចាស់ ក៏រៀបក្បួនដង្ហែលោកសីហ្គាល់ស្រែកច្រៀងសរសើរអរនេកប្រការ ។ លោកសីហ្គាល់កាន់បង្ហៀរសេះហើយពោលពាក្យទៅកាន់ប្រជាពស្ត្រីថា :

« ឆន្ទៈនៃព្រះអាទិទេពគឺមានបំណងចង់ឲ្យសត្វលោកស់បានសុខក្សេមក្សាន្តនៅលើប្រថពី ។ សេចក្តីសុខនេះមិនត្រូវឲ្យអ្នកណាចូលមកធ្វើឲ្យប្រែប្រួលអ្វីសោះឡើយ ។ នាគកំណាចវាស្លាប់ហើយ តាំងពីថ្ងៃនេះ មិនត្រូវឲ្យអ្នកណាមកជិះជាន់គ្នាទៀតឡើយ ។ ខ្ញុំសូមឲ្យលោកអ្នកទាំងឡាយប្រកបដោយសន្តិភាព សុភមង្គលគ្រប់យ៉ាងកុំបីឃ្លៀងឃ្លាតឡើយ ។ ខ្ញុំសូមជូនពរអស់លោកអ្នក សូមឲ្យកូមិនេះសម្បូណិដោយគោគ្រឿងមានគោនឹងចៀមជាដើម » ។

ពេលនោះ គឺជាវេទមិថុនា ។ មានមហាជនជាច្រើនស្ថិតនៅមាត់សមុទ្រ ហើយដង្ហែលោក សឺហ្គាល់ ដោយការព្រៀងយ៉ាងសប្បាយមហិមា ។ លោក សឺហ្គាល់ បំផាយសេះទៅជាន់ ។ លោកចំណងទៅសួរប្រតន្ទទីច ដែលមានទីលំនៅជាកោះមួយនៃមហាសាគរខាងបូព៌ាទិស ។ នាងប្រតន្ទទី ១ នៃលោក សឺហ្គាល់ ដល់ឃើញស្វាមីត្រឡប់មកវិញ ក៏យំទួញសោកជាខ្លាំង ។ លោក សឺហ្គាល់ បានពណ៌នាប្រាប់អតីតរណ៍យ-កិច្ចរបស់លោកដែលបានទៅសម្លាប់ពស់វែកធំ ឪនាងដែលកតែងតែធ្វើឲ្យប្រជាពលរដ្ឋកើតទុក្ខលំបាកវេទនាជាខ្លាំង ។ កាលបើបានសវនាការឿងនោះចប់សព្វគ្រប់ នាងក៏មានចិត្តសោមនស្សពន់ពេក ។

តែនាងបានប្រព្រឹត្តទុរ្ភកំហុសដ៏មិនសមគួរមួយ គឺធ្វើមិនឲ្យស្វាមីអាចធ្វើដំណើរចេញទៅណាទៀតបាន ។ ក្នុងពេលកត្រី នាងបានមកលួចកាត់ស្លាបសេះម្ចាស់កុំឲ្យហោះរួច ។

ព្រឹកឡើងពេលព្រះអាទិត្យរះ លោក សឺហ្គាល់ចំណងនឹងធ្វើដំណើរទៅកាន់ភូមិដែលកន្លងទៅមុខ ។ លុះចេញពីគេហដ្ឋានប្រតន្ទទីច ទៅបម្រុងនឹងឡើងជិះសេះ តែសេះខោះមានតែស្លាបម្ខាង មិនអាចហោះបានដោយស្រួល លោក សឺហ្គាល់ បានត្បាយមយ៉ាងលំបាកដើម្បីទៅឲ្យបានដល់ភូមិដែលប្រតន្ទទីពីស្ថិតនៅ ។

ការយោធិតារនៃលោក សឺហ្គាល់ កំពុងញុះញង់ឆ្កាំងតែលោកក៏បាន
ដោះស្រាយដោយឆាតណាគារឿងកំដូចខាងលើឲ្យខានស្លាប់ ខាងកំហុត
ខឹងទឹងស្វាមី ទៅជាភ្ញាក់ឡើងភ្លាមៗទៅវិញ ។

តែខាងជាការយោ ដើម្បីកុំឲ្យលោក សឺហ្គាល់ អាចត្រឡប់ទៅកាន់
ការយោធីមួយវិញបាន ខាងបានធ្វើតេលកត្រីស្វាត់ទៅលបលួចកាត់
ស្លាបសេះ ដែលទៅសល់ចោលកុំឲ្យសល់នៅ ឲ្យទៅតែរូបសេះធម្មតា
គ្មានស្លាប (១) ។

លុះដល់តេលមួបួសសម័យ ជាតក្តី លោក សឺហ្គាល់ បានក្រោកប្រ-
ញាប់ប្រញាល់ចន្តដំណើរទៅខៀត ។ តែដល់លោកលោតលើខ្នងសេះ
សេះនោះគ្មានស្លាប មិនអាចហោះទៅលើនភាល័យបាន ក៏វិលវល់យំ
ស្រែកមួយស្រែចក់ ហើយភ្លាក់ទៅលើសមុទ្រ ។ ដំណឹងនៃលោកសឺ-
ហ្គាល់ភ្លាក់ទៅលើសមុទ្រនោះ កំលាន់ឮខ្ទើតសពេញប្រថពី ។ មនុស្ស
តាំងប្រុសស្រី ក្មេងចាស់ សោកស្តាយអាឡោះអាឡែលោក សឺហ្គាល់ ពន់
ពេក ។ សូម្បីតែសត្វតិរច្ឆាន បក្សាបក្សីក៏ហោះហើរយំស្រែកលើសាគរ
ដើម្បីសុំឲ្យសាគរប្រគល់រូបកាយលោក សឺហ្គាល់ ជាបុត្តការីបុគ្គលរបស់
ខ្លួនគ្រប់ៗគ្នា ។ គេបានឮសូវតែលេកបោកច្រាំង . . ពួកបក្សា បក្សី

(១) "សេះយើងសព្វថ្ងៃបានជាមិនហោះ ប្រហែលមកពីប្រពន្ធាំងពីរនៃលោក សឺហ្គាល់
នេះឯងទេដឹង ? " ។

អស់តម្រិះនឹងរកលោក សឺហ្គាល់មិនឃើញ ក៏វិលត្រឡប់ទៅកាន់ព្រៃនៃវិញ ។ តាំងពីនោះមក បក្សា បក្សី សត្វតិរច្ឆានចាំងឡាយ ពាល់តែឆ្នាំតែងនាំគ្នាទៅកាន់សាគរ ដើម្បីនឹងតាមការលោក សឺហ្គាល់មកវិញ តែ... ចើទុកជាប្រឹងប្រែងយ៉ាងណា ក៏មិនឃើញលោក សឺហ្គាល់ នោះសោះឡើយ ។

ចប់រឿងលោក សឺហ្គាល់ នៅមានរឿង «ខ្សៅ សាន នឹងចៅក្រម» តទៅខ្មែត ។

រឿងត្រូវដាក់ការកម្សាន្ត កាលបើជនបាន អានហើយនាឲ្យរីកចិត្ត ។ រីកថ្លើមរីកចាំងតំនិត ចម្រាត់ការគិត ស្លឹតពីជីវិតកាលថ្ងៃ ។ ការរស់នៅលំបាកវៃក្រ គួរយើងគិតដែ ធ្វើយ៉ាងណាឲ្យបានធូ ។ ឲ្យស្រួលកុំឲ្យមួម្ហូ កុំឲ្យចិត្តខ្វ រស់នៅមិនយូរទេឡើយ ។ បើចិត្តយើងបានធូរស្បើយ នេះគឺជាគ្រើយ អាយុយើនយូរកន្លង ។

រឿងភ្នំប្រុស ភ្នំស្រី

នៅខែត្រកំពង់ចាម

ចំនៀមទម្លាប់ នៃទេមរជាតិ
ខ្មែរគួរខ្មីឃ្នាត សិក្សាពេញទី ។
ព្រោះទេមរជាតិ ជាជាតិសោភ័
ក្នុងទ្វីបអាស៊ី ឆាំងតែព្រៃងងាយ ។

បើយើងធ្វើដំណើរចេញពីក្រុងភ្នំពេញ ទៅកំពង់ចាម តាមផ្លូវថ្នល់ ជិតដល់ទៅចំរួមខែត្រកំពង់ចាម យើងនឹងឃើញភ្នំ ២ នៅចន្លឹមគ្នា ១ ខ្ពស់ ១ ទាប ។ ភ្នំខ្ពស់ឈ្មោះភ្នំស្រី ភ្នំទាបឈ្មោះភ្នំប្រុស (១) ។

ប្រវត្តិនៃភ្នំនោះ មានរឿងដំណាលដូចតទៅនេះ:

កាលពីព្រេងនាយ មានស្តេចស្រីមួយព្រះអង្គព្រះនាម " ស្រីអយុធ្យា " សោយរាជ្យនៅនគរខ្មែរ ។ ដោយព្រះនាងជាស្តេចសោយរាជ្យ គ្មានបុរសណាមួយហ៊ានដណ្តឹងយកជាកន្សោរឡើយ ម្ល៉ោះហើយព្រះនាងក៏ដណ្តឹងបុរសដ៏មានរូបជាទីគាប់ព្រះទ័យ មកធ្វើជាព្រះស្វាមី

១- ធ្លងពីផ្សារកំពង់ចាម ទៅផ្សារទន្ទេបិទ ហើយហួសទៅតាមថ្នល់ជាប់ ថ្នល់ស្ទឹងស្រែកត្បូងឃ្មុំ ខាងស្តាំដៃ មានភ្នំមួយ ឈ្មោះភ្នំពានដាំង ដែលមានទេសភាពខ្ពស់ម្ខាង ទាបម្ខាង ខាងទាបគេហៅថា ភ្នំប្រុស ខាងខ្ពស់ថា ភ្នំស្រី ដែរ ។

ហើយដោយហេតុព្រះរាជទិន្ន ស្រីអយុធ្យា ដណ្តឹងប្រុសជាព្រះស្វាមី ដូច្នោះ ស្រី។ ដែលនៅក្រោមព្រះរាជាវាទព្រះខាន កំដណ្តឹងប្រុស។ ធ្វើជាស្វាមីតាមដែរ ។

ក្នុងរជ្ជកាលនោះ មុខតួឱ្យវេទានឹងស្រីខ្លះដែលមានរូបឆន់។ ទៅរកដណ្តឹងប្រុស។ គេនាំគ្នាប្រកែកមិនយក គេរើសតែស្រី។ មានរូបល្អ។ ទើបយកធ្វើជាភរិយា. គេធ្វើដូច្នេះ អស់មួយរាត្រីស្តេចស្រីនេះ ។ លុះដល់មករាត្រីស្តេចក្រោយ។ ទៀត ពួកស្រីៗដំទុំគ្នាថា «« យើងឥឡូវនេះ ដូចជាមិនសមសោះ ខ្លួនជាស្រីហើយដើរដណ្តឹងប្រុស។ ធ្វើជាថ្ម បើដូច្នេះ យើងនឹងនាំគ្នាលើកដីចាក់ភ្ជួនជាភ្នំ ភ្ជាប់ជាមួយនឹងពួកប្រុស។ គឺប្រុស។ លើកដីធ្វើជាភ្នំមួយ យើងស្រី។ ធ្វើជាភ្នំមួយ បើប្រុស។ ចាញ់យើងត្រូវឱ្យប្រុស។ ដណ្តឹងយើងជាស្រីតទៅ »» ។ លុះគិតដូច្នេះហើយ ក៏នាំគ្នាទៅបបួលពួកប្រុសធ្វើភ្នំ ចុះខសខ្សាភ្ជាប់គ្នា ដូចគោលមក ហើយខាងស្រីមានមេកំណែនកេណ្តាមនុស្សស្រីបានច្រើន, ខាងប្រុសក៏មានមេកំណែនកេណ្តាមនុស្សប្រុសបានច្រើនស្មើគ្នា, លុះកេណ្តាបានគ្នាច្រើនគ្រប់ចំនួនតាំងខាងប្រុស ខាងស្រីរួចហើយ ក៏និយាយប្តេជ្ញាខឹងគ្នាថា «« យប់នេះយើងតាំងអស់គ្នា ត្រូវជញ្ជាំងដីកណាត់យកឈ្នះចាញ់ត្រឹមតែល្ងាយព្រឹកនេះ បើភ្លាយព្រឹកនេះទៀង យើងត្រូវឈប់ »» តែត

ត្រមត្រាដូច្នេះហើយ កំនាំគ្នាជញ្ជីងដ៏ វែកខ្លួលតាមកម្លាំងខ្លះ ។

គេលនោះ ពួកស្រី ។ មានក្រោធ្យ ជញ្ជីងដ៏ចាន ៣.៤ ម៉ាំង កំនាំគ្នាចង្អិតគោមតូចមួយយ៉ាំងខ្លាំង ទៅជ្រុងឆ្ងាំសាន់ក្តុំ ពួកប្រុស ។ ក្រឡេកមើលភៅលើយើញគោម ដែលគេចង្អិតនឹងប្រុសម្រីមួយដើមនោះ ស្ទាន់ថាផ្កាយព្រឹកនេះ កំចប្លួលគ្នាឈប់ធ្វើការ នាំគ្នាទុំគ្រួលត់អស់ទៅគ្នានសល់ ឯពួកស្រី។ គេនាំគ្នាជញ្ជីងដ៏ជាចជល់ផ្កាយព្រឹកនេះទើបឈប់ ។

ដល់មានំងោវកឹត ប្រុស ។ ក្មាក់ឡើងយើញផ្កាយព្រឹកនេះ កំលាន់មាត់ថា "យើងដេកយូរហើយ ផ្កាយព្រឹកទើបនឹងរះអម្បាញ់មិញនេះសោះ" ហើយនាំគ្នាក្រឡេកមើលភៅក្តុំខាងស្រី យើញមានទំហំធំខ្លាំងជាងក្តុំបេះខ្លួន កំអៀនអន់ក្នុងចិត្ត ដោយចាញ់ប្រៀបស្រី ។

តាំងពីកាលនោះមក ប្រុស។ កំដណ្តើងស្រី។ ធ្វើជាកំយោជាចជល់សត្វថ្ងៃនេះ ។

ប៉ោងជាឧទ្ទេសាទុប្បករណ៍ប្លែក

លោក ឌឹក . តាម រៀបរៀង

អ្វីទៅដែលគេហៅថា ប៉ោង ? សំនួរនេះដូចជាខ្ញុំសួរលោកអ្នកថា អ្វីទៅដែលគេហៅថា ចាយ ? ចំពោះអ្នកដែលស្គាល់ប៉ោងរួចហើយ ។ ការណ៍ដែលនាំឲ្យខ្ញុំយកពាក្យនេះ មកអធិប្បាយចុះផ្សាយដូនដល់លោកអ្នកអាន ព្រោះប៉ោងនេះ ជាប្រដាប់ឧទ្ទេសាទុប្បករណ៍មួយដែលមានដំណើរប្លែកពីប្រដាប់ឧទ្ទេសាទុប្បករណ៍ដទៃ ហើយថែមទាំងមានទំនៀមទំលាប់ដែលពាក់ព័ន្ធដល់ប៉ោងនេះផង ជាទំនៀមប្លែក ដែលគួរឲ្យចង់ដឹងចង់ស្គាល់ ។ ម្យ៉ាងទៀតប៉ោងនេះ គេច្រើនដាក់កន្លែងជូរសម្រកយកត្រីស៊ីសំតាមមាត់បឹង អូរ ឬស្រែក ។

បើលោកអ្នកធ្វើដំណើរពីភ្នំពេញទៅខេត្តកំពង់ឆ្នាំង លុះទៅដល់ស្រែខ្នុរ សូមលោកបែរទៅឆ្វេង មានផ្លូវមួយទៅស្ពុកអាចម៍មាស ។ ពីស្រែខ្នុរទៅចម្ងាយប្រហែល ៤គ.ម. មានភូមិមួយហៅថាភូមិអណ្តូងប្រុះ ក្នុងឃុំស្រែខ្នុរស្រុកសំលាញ់ ខេត្តកំពង់ឆ្នាំង ។ ដើរតែបន្តិចទៀតអស់លោកទើបឃើញមានអ្នកប្រើប្រាស់ប៉ោង ។

ប៉ោង គឺជាឧទ្ទេសាទុប្បករណ៍ខ្មែរមួយបែប ពន់ពេក្រាម ក្លិបលើ

ហើយស្តួចត្រង់ក ។ កំតស់ប្រែប្រួលនិយមតាមបំណងអ្នកធ្វើ ។ គេយកបន្ទះឫស្សីស្តើង ។ ស្មាញសន្លឹកគ្នា លើកមួយសន្លឹកមួយ ។ ចាំងមានប្រឹសតិចជាង តែមិនដូចប្រឹសលជខេ ។ ប្រឹសខាងក្រៅ គេហៅថា ប្រឹស « ចក់ » ធ្វើតិចូស្សីមួលតួច ។ ឲ្យជិត តែខាងចុងអាចរួមចេញចូលបាន ។ បើកាលណាត្រីចូលទៅជុំវិញ ប្រឹសនេះបិទជិតមកវិញ ។ ប្រឹសនេះគេធ្វើត្រាន់តែរប់សត្វកះណ្តៀរ ដែលគេដាក់ជាទុយកងខ្ចីខ្លោះកុំឲ្យចេញរួចប៉ុណ្ណោះ ។ ឯប្រឹសខាងក្នុងមាំ ហើយពង្រីកខាងចុងសំរាប់ឃាំងត្រីកុំឲ្យចេញទៅវិញរួច ។ ប្រឹសខាងក្នុងគេហៅថា "ប្រឹសកូប" ។ ត្រីដែលចូលទៅក្នុងប្រឹសកូបហើយ ចេញមិនរួចទេ ។

វិធីបង្កាក់ចាំង :

មុនឡើងយកចាំងទៅដាក់ក្នុងទឹក អ្នកនេសាទ យកអាចម៍គោឬក្របីលាបចាំង ហើយហាលថ្ងៃឲ្យស្ងួត ។ បានដាគេលាបអាចម៍សត្វនេះ ព្រោះកុំឲ្យសត្វកណ្តៀរដែលគេដាក់ធ្វើជាទុយហូរចេញទៅក្រៅ ។ អ្នកនេសាទដាក់ចាំង មុនដំបូងត្រូវដើរដង្កិចក្នុងទឹកជម្រៅប្រហែលមួយចំអាម ឬឲ្យស្មើនឹងប្រឹសបក់ ហើយទើបគេភ្ជួនទៅដាក់ឯស្នែងក្រប៉ ។

ដីដែលគេភ្ជួននេះ ដូចជាប្រួលស្មាក់ត្រឲ្យចូលចាំង ។ ដល់ដីកដីបាន ល្មមដាក់ហើយ ទើបអ្នកនេសាទយកចាំងដាក់បញ្ឈរទៅក្នុងដីដែលជីកហួច ទើបគេបិទគ្របយកដុំដីសង្កត់ឲ្យនឹងហើយយកមែកឈើមកហ៊ុំពទ្ធ

ចោង់ឲ្យដឹត ដើម្បីកុំឲ្យត្រូចង្វា ឬត្រូខាងក្រៅបចិចស៊ុសគួណ្តៀរដែល គេដាក់ជាខ្នុយនៅខាងក្នុងចោង់ចាន ។

ត្រីដែលចូលចោង់មានតែត្រីអណ្តែង ឡាំងនឹងត្រីខ្ចឹង ។ ត្រីទាំងនេះ ចូលចិត្តតប់កក់ដូច្នេះហើយ ចានជាគេដឹកដឹសិន ទើបគេដាក់ចោង់ឲ្យទៅ ក្នុងរណ្តៅ ។

ប្រៀបជាកាន់ឧណ្ហាកម្មចោង:

ចោង់គេដាក់ឲ្យតែត្រូចាំងចូល គឺត្រីអណ្តែង ត្រូឡាំងនឹងត្រីខ្ចឹង តែត្រីក្រៅពីនេះ ដូចជាត្រីរស់ឬត្រូផ្តក់ បើចូលទៅក្នុងចោង់ គេថាចោង់ "លៀក" ចានន័យថា "ឆ្អែន ឬស៊ាយ" ។ ដូច្នេះ គេត្រូយកចោង់ ដែលត្រូផ្តក់ឬត្រីរស់ចូល ទៅគាចចន៍ហាលថ្ងៃ រាយឆ្អើចាចជាក់ខ្ណាកម្ម គាចនឹងឃ្លាច ហើយអ្នកនេសាទថា "អាឯនក្រោយៗកុំឲ្យត្រូវទៀត" ។ ពេលក្រោយ គេយកទៅជាក់ទៀត ត្រីអស់នោះលែងចូលហើយ ចូលតែ ត្រីអណ្តែង ។

គេលដែលខ្ញុំឃើញនៅភូមិអណ្តូងប្រុះ ត្រីដែលចូលចោង់សុទ្ធតែ ត្រីអណ្តែងប្រហែលមួយកន្ត្រែងក្នុងមួយចោង់ ។ នៅកន្លែរនោះ មានចោង់ មួយគេគ្រចចន៍ហាលថ្ងៃជាក់ខ្ណាកម្ម ព្រោះតែចណ្តាយឲ្យត្រីដទៃរួល ចូល ហេតុនេះហើយដែលបណ្តាលឲ្យខ្ញុំចម្ងន់ចំទៀមទម្លាប់ចោង់នេះ ពុក ជាការណ៍ថ្លែកមួយដល់អស់លោក.អ្នកអាន ។

ខ្លឹមសារសំណេរនិងប្រវត្តិការណ៍

ព្រះពាលសុន្ទរកថានៃសម្តេចព្រះប្រមុខរដ្ឋ
ថ្លែងក្នុងទុកាសវគ្គធម៌បុណ្យឆ្លងឯករាជ្យជាតិ នឹងសម្ពោធប្លងធ-
យដ្ឋានឯករាជ្យ ថ្ងៃទី ៩ វិច្ឆិកា ១៩៦២

ជនរួមជាតិជាទីស្នេហា !

ថ្ងៃនេះ យើងធ្វើបុណ្យឆ្លងនៃឯកភាពជាតិយើង ដែលប្រទេស
ជាតិនិងសែស អតីតអាណាព្យាបាលនៃប្រទេសយើង បានទទួលស្គាល់
តាមផ្លូវច្បាប់អន្តរជាតិនៅក្នុងឆ្នាំ ១៩៤៩ ដោយសន្ធិសញ្ញាដែលខ្មែរនឹង
ជាតិ បានចុះហត្ថលេខានៅក្រុងហ្គាវ៉ស់ក្នុងថ្ងៃ ៨ វិច្ឆិកា ហើយដែលភាគ
ច្រើនទីយកតិច្ចបានចំពេញ ដោយកិច្ចព្រមព្រៀងផ្លូវសេមត្តកិច្ចទំនិងកេតនភ័ណ្ឌ
ពីជាតិនិងមកខ្មែរនៅក្នុងចុងឆ្នាំ ១៩៥៣ រដ្ឋការជាតិនិងសែស (ស៊ីវិល-
ធានាគារ-ប៊ូលីស-តុលាការ បានរំលែតអំណាចរបស់ខ្លួនជាស្ថា-
តរនៅក្នុងថ្ងៃ ៩ វិច្ឆិកា ១៩៥៣) ។

ក្នុងទុកាសនេះ យើងមានកិត្តិយសសម្ពោធជាទឡ្ហីករឿងនូវរឿងនិទាន
ឯកភាពយើង ហើយដែលយើងសូមទុទ្ធិសដោយគោរពចំពោះវិញ្ញាណក្ខន្ធ
នៃវីរបុរសខ្មែរទាំងឡាយ ដែលបានធ្វើតលីកម្មនៃជីវិតរបស់ខ្លួន ដើម្បី
ឯកភាព សេរីភាព-អធិបតេយ្យនិងសន្តិភាពនៃកម្មវត្ថុ ។

តាមចំនៀមចំណាប់នៃបុណ្យទួចឯកភជ្ជ យើងត្រូវ (ក្នុងពេលបុណ្យនោះ) រំលឹកនូវសាវតារប្រវត្តិសាស្ត្រនៃការកសាងឯកភជ្ជ ។

ក្នុងសន្ទរកថានៃខ្ញុំនាបច្ចុប្បន្ននេះ ខ្ញុំយល់ឃើញថាពុំចាំបាច់យកចំណាប់ដោយពិស្តារវែងអន្លាយទេ នូវប្រវត្តិសាស្ត្រនៃការកសាងឯកភជ្ជយើង ព្រោះអស់លោកដែលស្តាប់ខ្ញុំ សុទ្ធសឹងតែជ្រាបនូវប្រវត្តិសាស្ត្រនោះដ៏ជ្រៅជ្រះណាស់ទៅហើយ ។

ខ្ញុំគ្រាន់តែសូមជូនសេចក្តីបញ្ជាក់ដូចតទៅនេះ ៖

មជ្ឈដ្ឋានបរទេសខ្លះ គេចូលចិត្តផ្តល់ឱ្យខ្លួនគេនូវអំណាចមួយ ដែលខុសស្រឡះអំពីប្រពៃណីអន្តរជាតិ ដែលជាប់តែមិនអនុញ្ញាតឱ្យចូលជ្រៀតជ្រែកក្នុងកិច្ចការ របស់ប្រទេសដែលពុំមែនជាប្រទេសរបស់ខ្លួន ។

មជ្ឈដ្ឋានបរទេសនោះ គេផ្តល់ដល់ខ្លួនគេនូវអំណាចតែប្រែប្រវត្តិសាស្ត្រ ទំនៀមប្បាប់របស់យើងដែលចែងអំពីឯកភជ្ជយើង ហើយគេសម្រេចថា ឯកភជ្ជខ្មែរមានកំណើតនៅក្នុងឆ្នាំ ១៩៥៨ ដោយសន្និសីទ្ធហ្សឺណែវ ។

ចំពោះការសម្រេចដោយបំពានយ៉ាងនេះ ខ្ញុំបានទាំមកតទល់ នូវឯកសារទំនៀមតាងប្រកបនូវលក្ខណៈច្បាប់គេញឹក ដែលបង្ហាញឱ្យឃើញថា ត្រូវជ្រើសរើសវែងតែ ២ ឆ្នាំ ដូចតទៅនេះទេ បើនិយាយអំពីឆ្នាំកំណើតនៃឯកភជ្ជខ្មែរគឺ :

១- ថ្ងៃ ១៨៤៨ ព្រោះខែកុម្ភៈឆ្នាំខោះឯង ដែលរដ្ឋបាក់ឯសែស បានខកខ្លួលត្រមលប់លាងជាដាច់ខាតតាមផ្លូវច្បាប់ ខ្លួវសន្ធិសញ្ញាឆ្នាំ ១៨៦៣ ទឹងអនុសញ្ញាឆ្នាំ ១៨៤៦ ដែលតែងតាំងអាណាព្យាបាលបាក់ឯ លើកម្ពុជរដ្ឋ ។

រដ្ឋបាក់ឯសែស កំបានខកខ្លួលស្គាល់ខ្លួវឯករាជ្យខ្មែរ តាមផ្លូវច្បាប់ ដោយសន្ធិសញ្ញាថ្ងៃ ៨ វិច្ឆិកា ១៨៤៩ ។

ចំពោះឯករាជ្យ ១៨៤៩ នេះ មានអ្នកខ្លះតេដំបាស់ ដោយតេមានសំអាងថា តាមបទបញ្ញត្តិនៃសន្ធិសញ្ញា ១៨៤៩ នោះ ប្រទេសខ្មែរបានបញ្ជាក់ថា ខ្លួនខែកុងសហភាពបាក់ឯសែសជាសមាគមរដ្ឋ ។

ការដំបាស់បែបនេះជាការខុសតេញ៉ូ ចំពោះមុខច្បាប់អន្តរជាតិ ព្រោះប្រទេសឯករាជ្យនិមួយ ។ រមែងតែមានសិទ្ធិចូលជាសមាគម កុងសហភាព សហរដ្ឋ ឬអង្គការអន្តរជាតិណា ដែលខ្លួនចូលចិត្តឬត្រូវការ ។

ឧទាហរណ៍ ប្រទេសស៊ីលង្កា ខែកុងសហភាពអង់គ្លេស ប្រទេសកាណាដា អូស្ត្រាលី ដែលសំគាល់ថា ហ្លួងអង់គ្លេសជាប្រមុខរដ្ឋ ឬមហាក្សត្រីយានីរបស់ខ្លួន ហើយខែកុងប្រទេសនោះមាន Gouverneur général ជាតំណាងស្តេចអង់គ្លេស ។ ឧទាហរណ៍ គឺប្រទេសថៃឡង់ ទឹងប្រទេសជាច្រើនទៀត ដែលចូលជាសមាគមរដ្ឋ កុងអង្គការ (សេតាតូ) ។

តាមផ្លូវស្បៃប់ យើងសំគាល់ថា ប្រទេសចាំងអស់នោះពុំមែនឯកកដ្ឋពុំកើតឡើយ ទោះជាប្រទេសខ្លះ ពុំមានអធិបតេយ្យ ឬសេរីភាពគេញ៉ាំ ក្នុងនយោបាយក្រៅប្រទេសរបស់ខ្លួនក្តី ។

ដោយហេតុនេះហើយ បានជាមហាប្រទេសជាច្រើន បានទទួលស្គាល់ប្រទេសកម្ពុជាយើង ជារដ្ឋឯកកដ្ឋតេញលក្ខណៈច្បាប់អន្តរជាតិក្រោយពេលដែលបានចុះហត្ថលេខាលើសន្ធិសញ្ញា ១៩៤៩ ។ ប្រទេសដែលគេទទួលស្គាល់យើងនោះមានចំនួន ៣៩ ក្នុងចំណោមប្រទេសនោះមានសហរដ្ឋអាមេរិក អង់គ្លេស ឥតាលី អូស្ត្រាលី ព្រមទាំងប្រទេសថៃ-ឡង់ ក៏គេបានទទួលស្គាល់យើងដោយមេត្រីភាពដែរ ព្រោះពេលនោះគេកំពុងតែផ្តាច់ចិត្តមហាប្រទេសប្រជាធិបតេយ្យដែលឈ្នះចំប៉ាង ដោយចង់ឲ្យគេលើកលែងទោសពៃរ៍អំពីខ្លួន ដែលបានចូលដៃចូលជើងនឹងពួកជប៉ុន ។ ម្យ៉ាងទៀតពេលនោះ ពួកលោកសេរីនឹងយើងពុំទាន់ចាស់ចិត្តខ្លួនគំនិតគ្នា ដោយរឿងអតីតកាលនៅឡើយទេ ។

២- តែបើនិយាយថា ឯកកដ្ឋ ១៩៤៩ គ្រាន់តែជាឯកកដ្ឋ « De Surface » មានតែសំបកលើខ្លួនក្រៅពុំមានខ្លឹមសារផ្ទៃក្នុងទេនោះ គួរណាស់តែសំគាល់ថា ១៩៥៣ ជាឆ្នាំកំណើតឯកកដ្ឋតិតប្រាកដរបស់ជាតិខ្មែរ ព្រោះតើនៅក្នុងឆ្នាំនោះហើយ ដែលយើងបានធ្វើឲ្យចក្ខុវិស័យមកឲ្យយើងជាជាប់ខាតដោយខុសឆ្គាត្រឹមត្រូវ ទូរអំណាចទឹក អំណាច

ប៉ូលីស អំណាចតុលាការ អំណាចបរទេស ។ ហើយនៅក្នុងឆ្នាំ ១៩៥៣ ទៀត រាជរដ្ឋាភិបាលយើងបានសម្រេចតែងតាំងខ្លួនខ្មែរ ឬខ្លួនបរទេស ដែលលែងសុំការយល់ព្រមអំពីប្រធានសហការជាក់ ។ ចាប់តាំងអំពីឆ្នាំ ១៩៥៣ មក ប្រទេសយើងក៏ឈប់ចូលទៅដំណើរការក្រុមទីប្រឹក្សានៃសហការជាក់ដែរ ។

និយាយថា សន្ធិសីទហ្សឺណែវនាឆ្នាំ ១៩៥៤ បានផ្តល់ឯករាជ្យដល់ប្រទេសកម្ពុជា ដូចជាបានផ្តល់ឲ្យប្រទេសវៀតណាមនឹងលាវ ជាការខុសប្លែកពន់ពេកណាស់ ព្រោះជាក់ណ ទាំងការពារទាំងស៊ីវិល ទាំងយោធ ប៉ូលីស បានដកអំណាចនីតិបុគ្គលិក នីតិវេបញ្ជាការ អ្នកចាត់ការរបស់ខ្លួន ពីប្រទេសខ្មែរយើងនោះទៅជាជាច់ខាត ៩ ខែមុនការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនាហ្សឺណែវ ។

ម្យ៉ាងទៀត បើសន្ធិសីទហ្សឺណែវ ១៩៥៤ បានផ្តល់ឯករាជ្យឲ្យរដ្ឋឥណ្ឌូចិនមែនពិត ហេតុអ្វីក៏នៅក្នុងសន្ធិសីទហ្សឺណែវ ១៩៦២ បង្អួនលាវនៅខ្លួចសុំឯករាជ្យរបស់ខ្លួនពីអន្តរជាតិ ? ។

មជ្ឈដ្ឋានបរទេសដែលគេមិនចង់ឲ្យរាជរដ្ឋាភិបាលខ្មែរមានឈ្មោះថា បានឯករាជ្យជាតិ គេខ្លួចរំលឹកគុណហ្សឺណែវ ១៩៥៤ ថា បើគ្មានហ្សឺណែវនេះ ប្រទេសយើងកំពុងតែមូលដ្ឋានការបរទេសពីដែនដីខ្លួនពុំកើតទេ ។

បើហ្សឺណែវ ៥៤ មានមហិច្ឆិដ្ឋយ៉ាងណាក៏ដោយ ក៏ពុំអាចបដិសេធ
ការពិតដែលថា ប្រទេសយើងបានចូលរួមក្នុងសន្និសីទនេះ ជាមួយនឹងប្រទេស
ដែលមានសារៈសំខាន់ជាងយើងច្រើនដែរ ។

ដូច្នេះ ការដែលយើងមិនបានចូលរួមក្នុងសន្និសីទនេះ ដោយសារតែ
ការមិនយល់ព្រមរបស់ប្រទេសមួយចំនួនតូចនោះ ពុំមែនជាការបរាជ័យរបស់
យើងទេ ។ ផ្ទុយទៅវិញ ការមិនចូលរួមនេះ ប្រហែលជាមានប្រយោជន៍ដល់
យើងច្រើនជាងការចូលរួមទៅទៀត ព្រោះយើងមិនបានចុះហត្ថលេខាលើ
សេចក្តីសម្រេចដែលមិនសមរម្យ ដែលប្រទេសមួយចំនួនតូចបានដាក់ចេញ
ដើម្បីបង្ខិតបង្ខំយើងនោះឡើយ ។

ការមិនចូលរួមនេះ ក៏ជាការបង្ហាញឱ្យឃើញច្បាស់ដល់ពិភពលោក
ទាំងមូលថា យើងមិនមែនជាអ្នកដែលគ្មានសេរីភាពក្នុងការសម្រេចចិត្តនោះ
ទេ ។ ការមិនចូលរួមនេះ ក៏ជាការបង្ហាញឱ្យឃើញច្បាស់ដល់ពិភពលោក
ទាំងមូលថា យើងមិនមែនជាអ្នកដែលគ្មានសេរីភាពក្នុងការសម្រេចចិត្តនោះ
ទេ ។ ការមិនចូលរួមនេះ ក៏ជាការបង្ហាញឱ្យឃើញច្បាស់ដល់ពិភពលោក
ទាំងមូលថា យើងមិនមែនជាអ្នកដែលគ្មានសេរីភាពក្នុងការសម្រេចចិត្តនោះ
ទេ ។

ទីធ្លាប្រៀបធៀបគ្នាជាផ្លូវការលើកទី (ថ្ងៃទី) នៃសេចក្តីតវ៉ាតាមទាំងឯកសារជាសំបុត្រលើកទីមួយ ចំពោះដីធ្លាកំពង់ ទីធ្លាការលើកទីពីរនៃការប្រកាសរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ យូ-ណាវ-ឡែ តាមការស្នើសុំឯកសារជាលក្ខណៈមិនទាន់ច្បាស់លាស់អំពីបាកំពង់ ។

ការលោតត្រង់ទីធ្លាប្រៀបធៀបនោះ អាចឱ្យលទ្ធផលដូចតទៅនេះ៖

- ឯកសារលេខ ១ នៃមហាក្សត្រប្រទេសកម្ពុជា ទៅកាន់លោកប្រធានាធិបតីកុំងសង់អូរយ៉ូល ចែងអំពីបញ្ហាពង្រីកឯកសារខ្នាត ៥ ម៉ែត្រ ១៨៥៣,

- ឯកសារលេខ ២ នៃមហាក្សត្រខ្មែរទៅកាន់លោកប្រធានាធិបតីបារាំង ទទួចសុំឱ្យមានការសម្រេចជាបន្ទាន់ ១៨ ម៉ែត្រ ១៨៥៣,

- សេចក្តីឆ្លើយរបស់លោកប្រធានាធិបតីអូរយ៉ូល ១៨ ម៉ែត្រ ១៨៥៣,

- សេចក្តីស្នើរបស់ព្រះរាជា ចំពោះបញ្ហាតុលាការ ២៥ ម៉ែត្រ ១៨៥៣,

- សេចក្តីស្នើរបស់ព្រះរាជា ចំពោះបញ្ហាពាណិជ្ជ ២៥ ម៉ែត្រ ១៨៥៣,

- សេចក្តីស្នើរបស់ព្រះរាជាចំពោះបញ្ហាហិរញ្ញវត្ថុ សេដ្ឋកិច្ចទីធ្លសង្គមកិច្ច ២៥ ម៉ែត្រ ១៨៥៣,

- ភជសារលិខិតលេខ ៣ នៃមហាក្សត្រខ្មែរទៅកាន់លោកប្រធានាធិបតីចុងកាំង ផ្តល់ជូនវិហារតុ-ផលចន្ទមរៀត ដើម្បីដោះស្រាយបញ្ហាគុណភាព ព្រមទាំងជូនការធានាអះអាងរបស់ឆ្លាតិចុងលខ្មែរ ក្នុងការទិបត្តិជនចុងកាំង ដែលជ្រកក្រោមម្លប់រដ្ឋកម្ពុជា : ៣ មេសា ១៩៥៣

- ភជសកម្មភាពយោសនានៃមហាក្សត្រប្រទេសកម្ពុជានៅសហរដ្ឋអាមេរិក ដើម្បីញ៉ាំងឯកភាពនៃប្រទេសកម្ពុជា ឲ្យមានរូបភាពកាន់តែច្បាស់លាស់ឡើង ៖ ខែមេសា ១៩៥៣ ។

- ភជសកម្មភាពបែបគ្នានេះទៅក្រុងចាងកក: ខែមិថុនា ១៩៥៣,

- លិខិតកំណត់នៃរដ្ឋាភិបាលចុងកាំង ទៅកាន់រដ្ឋាំង ៣ នៅឥណ្ឌូចិន សុំឲ្យរដ្ឋាំងនោះ តាមការសិទ្ធិាំងឲ្យដើម្បីបំពេញឯកភាពរបស់ខ្លួន ៣ កក្កដា ១៩៥៣ ។

ការប្រឹបធៀបនេះធ្វើរួចហើយ ខ្ញុំយល់ឃើញថា ពុំចាំធ្វើអត្ថាធិប្បាយឲ្យវែងឆ្ងាយទៅទៀតទេ មនុស្សមហាជនអន្តរជាតិ អាចវិនិច្ឆ័យបានហើយថា តើចុងកាំងចេតនាឲ្យយួន.លាវ.ខ្មែរ តាមការឯកភាពរបៀបណា ដោយចិត្តសទ្ធារបស់ខ្លួន ពុំមានខ្លាចញ័រ ឬមួយដោយសកម្មភាពរបស់ខ្មែរតែម្នាក់ឯង ដោយប្រទេសជិតខាងយើង គេពុំបានជួយអើពើយើងផងទេ ។

ពេលនោះការសែតយួនព្រៃនគរ ដែលសព្វថ្ងៃផ្សេរប្រមាថ ការគាំទ

ខ្ញុំយ៉ាងសម្បើម កំចាត់សរសៃសរសៃរអាត្មាខ្ញុំយ៉ាងសម្បើមដែរ ។

មជ្ឈដ្ឋានបរទេសអស្ចារ្យ គេចាត់ទុកយ៉ាងធំសរសើរទៀតថា បើឯករាជ្យខ្មែរ កើតនៅក្នុងឆ្នាំ ១៩៥៣ មែន ហេតុម្ល៉ឹងក៏ប្រទេសខ្មែរទើបធំឯងចាត់ចូលទៅក្នុងអង្គការសហប្រជាជាតិនាឆ្នាំ ១៩៥៥ ។

ខ្ញុំសូមសួរទៅគេវិញថា តើប្រទេសចិនប្រជាមានិត ដែលជាមហាអំណាចធំសម្បើម ទៅក្នុងពិភពលោកយើងនេះ ហើយដែលពុំទាន់ចូលទៅក្នុងអង្គការសហប្រជាជាតិសោះនោះ ត្រូវសំគាល់ថា សាធារណៈរដ្ឋចិនប្រជាមានិតជាប្រទេសនៅខ្វះឯករាជ្យដែរឬទេ ? ។

តាមការណ៍ពិត ការចូលទៅក្នុងឬនៅក្រៅអង្គការសហប្រជាជាតិពុំមែនមានន័យថាប្រទេសនោះមានឬខ្វះឯករាជ្យទេ ។

សព្វថ្ងៃនេះ នៅក្នុងអង្គការសហប្រជាជាតិ មានប្រទេសខ្លះជាសមាជិកនៃមហាយក្ស ខាងលិចឬខាងកើត ដែលចោះធ្នោតឬលើកដៃតែតាមមេក្លោងរបស់គេ ។

ប្រទេសខ្លះទៀត ដូចជាចិនប្រជាមានិត ដែលមហាយក្សឯទៀតខ្លាចជាច្រើន បែរទៅជាត្រូវនៅក្រៅអង្គការសហប្រជាជាតិវិញ ។

ក្នុងឆ្នាំ ១៩៥៣-៥៦ ប្រទេសខ្មែរយើងចូលទៅក្នុងអង្គការសហប្រជាជាតិពុំច្បាស់ ព្រោះតែមានការជំទាស់ខ្លាំងពីក្រុមធំៗមួយចំនួនក្នុងសង្គមទេយ្យខ្លះ ដែលគេសង្ស័យថា យើងចូលដៃនឹងលោកសិរី ព្រោះ

ក្នុងគ្រានោះ យើងមានការតវ៉ាកំចួនធ្វើប្រតិបត្តិការ ទាហានប្រាន់ពីរឿត-
ម៉ាញចេញពីប្រទេសយើង ដែលយើងធ្វើប្រតិបត្តិការនេះទៀត ក៏ពុំមែន
ដោយចូលដៃនឹងបរទេសណាទេ គឺគ្រាន់តែបំពេញកិច្ចចំពោះឯករាជ្យ
ជាតិយើងប៉ុណ្ណឹង ដែលមិនត្រូវបណ្តោយឲ្យបរទេសណា មកជិះជាន់
ប្រទេសយើង ទោះបីបរទេសនោះជាជាតិសាសន៍អាស៊ីដូចគ្នាក្តី អឺរុបឬ
អាមេរិកក្តី លោកសេរីឬលោកកុម្មុយនិស្តក្តី ។

រឿងខ្មែរដែលពុំបានចូលអង្គការសហប្រជាជាតិ ក្នុងឆ្នាំ ១៩៥៣-
៥៤ នឹងរឿងចិនប្រជាមានិតនាបច្ចុប្បន្ននេះ ពុំមានទាក់ទងអ្វីនឹងឯករាជ្យ
សោះឡើយ មានបុព្វហេតុតែមួយគឺការដែលតំណាងលោកយើងបាក់បែក
គ្នាជាពីរពួក ពីរក្រុមមនោគមវិជ្ជា ហើយពួកក្រុមទាំង ២ នេះ ខ្លួច
តែប្រទាំងគ្នាដោយសាហាវ-ដោយចំបាំងត្រដាក់ ឬចំបាំងក្តៅ ឬចំបាំង
ត្រជាក់ឬការគំរាមផ្សេង។ ។

ដោយហេតុនោះហើយ បានជាប្រទេសយើងស្គាល់តែសេចក្តីព្រួយ
បារម្ភពុំចេះស្រាកស្រាន្តសោះ ចាប់តាំងអំពីពេលចប់ចំចម្បាំងសាកល
លោកលើកទី ២ មកទល់នឹងសព្វថ្ងៃនេះ ។

តែជាកុសលរបស់យើង ការដែលយើងមានជ័យជំនះនៅសន្និសីទ
ហ្សឺណែវ ១៩៥៤ ដែលបានឃាំងមិនឲ្យមហាអំណាចចម្បែកឯកភាពទឹកដី
នឹងប្រជាជាតិយើងបាន ដូចគេធ្វើចំពោះវៀតណាមនឹងកូរ៉េណាចក្រ

លាវ ការដែលយើងតុំផ្តុំដួចិត្តគំនិត តុំក្លាត់ស្លៀត ចេះចៀសវាងជាន់ខ្លួ
ការចូលទៅប្រកួមជាមួយនឹងក្រមមនោគមវិជ្ជាណាមួយ ហើយចេះជ្រើស
រើសខ្លួនផ្លូវអត្ថក្រិតភាពបំផុត ទឹងតឹងរឹងមិនឲ្យគេកាច់បាន ព្រមទាំង
សុភវិនិច្ឆ័យដ៏ធំទូលាយអស្ចារ្យរបស់ព្រះសង្ឃ ពលវត្ត យុវជនយើងទាំង
អស់តុំត្រូមដើរតាម « អ្នកភក្ងាលអាក្រែកាត់ » ផ្តាច់ចិត្តឯកច្ឆន្ទនឹង
ស្តាពរថាត្រូវចង់ចាប់គ្នានៅដុំវិញកដបល្អក់ ការចាប់បដិសន្ធិនៅលើផែនដី
កម្មដ៏ធំឯកម្មវិធីនៃសង្គមភស្តុនិយម កុសលកម្មអស់ទាំងនេះហើយ បាន
ធ្វើឲ្យមាក់កម្ពុជាយើងចៀសវាងខ្លួរការលំបាកលំបិន ការមហន្តរាយបាន តោះ
បើមានសត្រូវមានប្រទេសយៀកណាមខាងត្បូង ទឹងថែឡង់ជាដើម គេ
បង្កើនចំនួនទុបសន្តតិការគំរាម ការឈ្លានពាន ការបង្ខូចសេដ្ឋកិច្ចនឹង
បង្អាប់កិត្តិយស លើមាតិរបស់យើងយ៉ាងណាក្តី ។

ជនរួមជាតិជាទីស្នេហា !

កងដីវភាពប្រទេសជាតិមួយ ។ គ្មានអ្វីឲ្យមានដម្លៃជាងឯកភាពឡើយ
ព្រោះឯកភាពជាមូលដ្ឋាន នៃសេចក្តីថ្លៃថ្នូរនឹងសុភមង្គលទាំងឡាយដទៃ
ទៀត ។

ដោយហេតុនោះហើយ បានជាជាតិយើងទាំងមូលសុទ្ធចិត្តបូជាដ៏តែ
ត្រង់តែលវេលា ដើម្បីរក្សាការពារឯកភាពទឹងនឹងបូរណភាពដែលជាដើងដៃ

របស់ឯកភាព្យ ហើយដែលគេពុំអាចកាត់ឱ្យខ្លាត់ចេញព័ទ្ធខ្លួន ភាយនៃឯក-
ភាព្យទៅបានឡើយ ។

ក្នុងករណីនេះ ខ្ញុំសូមធ្វើការកត់ចំ គោរពចំពោះវិញ្ញាណក្ខន្ធនៃជនរួម
ជាតិយើងខាងឡាយ ដែលបានចូលទៅកាន់មរណភាពដោយការតោរនៅ
បំរើមាតុប្រទេស ព្រមទាំងសូមថ្លែងនូវគតញ្ញូតាធម៌ជាថ្នីម្តងទៀតចំពោះស-
ហការីដ៏ឆ្នើមរបស់ខ្ញុំ មានសម្តេច ប៉ែន-នុត ជាដើម ដែលជួយធ្វើការ
ខ្ញុំពុំមានសំរៃកម្ងាំងសោះ ក្នុងការទាមទារយកឯកភាព្យសំចូលមកបូជា
មាតុប្រទេសយើង ព្រមទាំងចំពោះព្រះសង្ឃនិងតាលវដ្តទាំងឡាយ មាន
ក្តួនចៅពាហានខេមរភូមិន្ទ-ជីវពល.នារីក្លាហានជាដើម ដែលបានស្មគ្រ-
ចិត្តហែខ្ញុំចាប់តាំងពីដើមទី រហូតបានសម្រេចវត្តចំណាំងជូនជាតិ ពុំស្តាយ
ជីវិត ពុំស្តាយកោតសម្បត្តិ ហើយពុំព្រមដឿពាក្យមួលបង្កាច់ឃោសនា
អកុសលរបស់ពួកនយោបាយខ្លះ ទីងជនក្បត់ជាតិ ។

ព្រោះបើជនរួមជាតិ ទីងក្តួនចៅអស់តាំងនោះបែរជាទៅជាដឿ
តាមពាក្យទីងសេចក្តីអំពាវនាវរបស់ពួកវិញ ប្រទេសយើងពុំបានឆាម
ឆោះសន្តិភាព ហើយពុំបានស្គាល់សេរីភាព-ឯកភាព-បូរ-
ណភាព វឌ្ឍនភាពដូចក្នុងកំឡុង ៩ ឆ្នាំនៃអាយុឯកភាព្យយើងនេះទេ គឺ
ច្បាស់ជាបានស្គាល់ទុក្ខវេទនា ទីងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរបង់ប្លន់ដល់ការរំជាទី
ស្នេហានៃយើង ក្នុងពេលមុននេះ ឬមួយដូចវៀតណាមខាងត្បូង ឬ

ក្នុងហ្គេកនឹងតេលនេះ ។

ជនរួមជាតិជាទីស្នេហា !

អាវុធសំខាន់ជាងគេសម្រាប់កសាងនិងការពារឯករាជ្យ និងអនាគតយើង គឺមែនគ្រឿងយោធាចាំក្បាដិស្តុចស្តើង គួរឲ្យវេទនាបេស់កងទ័ពយើងនោះទេ (ចន្លិចទៀតកងទ័ពយើងនេះ និងចាត់ក្រុមរបស់ខ្លួនខ្លះឲ្យមកជង្រែជាស្នូនជូនអស់លោក-អ្នកខេត្តនោះហើយ) ។ អាវុធនោះគឺការរួបរួមចិត្តចាប់ខ្នាជាធ្នូងមួយនៃយើងនេះឯង ។

ល្អីណា ដែលយើងតុំបែកបាក់គ្នាទៅតាមឲ្យលំមនោគមវិជ្ជាបរទេសទេ ប្រទេសយើងនឹងនៅតែមានជំហរធំបុំន មានសុភកាពនឹងជាមកាពកងចំណោមប្រទេសសេរី ប្រទេសឯករាជ្យនៃពិភពលោកជាដរាប ។

ដូច្នេះ សូមចងចូនក្លួនចៅមេត្តាអាណិតប្រទេសយើង សូមរំតែចំណាងសាមគ្គីនឹងសហការនៃខ្មែរយើងឲ្យបានតឹងរឹងមែនទែនឡើង ក្នុងគ្រានេះ ដែលមានសត្រូវគេកាន់តែបញ្ជាក់ឲ្យឃើញច្បាស់ហើយនូវគោលចំណងអសប្បុរសរបេស់គេចំពោះយើង ។

ខ្ញុំជឿជាក់ថា ការរួបរួមរបេស់យើងជាធ្នូងមួយនេះនឹងជួយស្រោចស្រង់ប្រទេសយើង និងឯករាជ្យយើងឲ្យឆ្លងសមុទ្រ គ្រោះថ្នាក់ដែលមាននៅមុខយើងនេះ បានផុតស្រឡះដោយជ័យមង្គល ។

ជយោ កម្ពុជាឯករាជ្យ!

អំពីការតាំងមន្ត្រីសង្ឃ

កាលពីថ្ងៃទី ២ ខែឧសភា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ភ័ន. ហួន នាមឆាយា ឥន្ទជោត អាយុ ៣១ ឆ្នាំ វស្សា ១១ ជាចៅអធិការវត្តសង់ប្រាសាទពង ឃុំអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបាត់ដំបង ។

កាលពីថ្ងៃទី ២ ខែឧសភា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ខែក. រឿន នាមឆាយា រក្ខិតធម្មោ អាយុ ២៩ ឆ្នាំ វស្សា ៩ ជាគ្រូសូត្រ ស្ថាំ វត្តសង់ប្រាសាទពង ឃុំអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបាត់ដំបង ។

កាលពីថ្ងៃទី ២ ខែឧសភា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ សឺង. សារឿន នាមឆាយា សន្តមប្បញ្ញោ អាយុ ២៩ឆ្នាំ វស្សា ៩ ជាគ្រូសូត្រ ឆ្នូង វត្តសង់ប្រាសាទពង ឃុំអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបាត់ដំបង ។

កាលពីថ្ងៃទី ៤ ខែឧសភា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ អឹម. អ៊ុម នាមឆាយា ឥន្ទកេសរ អាយុ ៥១ ឆ្នាំ វស្សា ២៦ ជាចៅអធិការវត្តប្រាសាទ ឃុំប្រាសាទ ស្រុកស្អាង ខេត្តកណ្តាល ។

កាលពីថ្ងៃទី ៤ ខែឧសភា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ជិន. សៀង នាមឆាយា ឥន្ទជោត អាយុ ៣៩ ឆ្នាំ វស្សា ១៤ ជាគ្រូប្រត្តស្ថាំ វត្តប្រាសាទ ឃុំប្រាសាទ ស្រុកស្អាង ខេត្តកណ្តាល ។

កាលពីថ្ងៃទី ៨ ខែ ១សីហា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ អ៊ិ-ជ្រេង នាមនាយ សុក្កធម្មោ អាយុ ៣២ ឆ្នាំ វស្សា ៩ ជាគ្រូសូត្រធ្វើវត្តប្រាសាទ ឃុំប្រាសាទ ស្រុកស្អាង ខេត្តកណ្តាល ។

កាលពីថ្ងៃទី ៨ ខែ១សីហា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ញែម-សុជន នាមនាយ សុវណ្ណសរ អាយុ ៣៨ ឆ្នាំ វស្សា ១៤ ជាគ្រូសូត្រស្តាំ វត្តកំពង់សម្ប ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ។

កាលពីថ្ងៃទី ៨ ខែ១សីហា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ឃុន-ឈឺន នាមនាយ សុវណ្ណសរ អាយុ ២៤ ឆ្នាំ វស្សា ១១ ជាគ្រូសូត្រធ្វើ វត្តកំពង់សម្ប ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ។

កាលពីថ្ងៃទី ៨ ខែ១សីហា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ម៉ៅ-ជៅ នាមនាយ សុវណ្ណជោតោ អាយុ ៣៣ ឆ្នាំ វស្សា ១៣ ជាចៅអធិការវត្តឫស្សីស្រស់ ឃុំឫស្សីស្រស់ ស្រុកតៀនស្វាយ ខេត្តកណ្តាល ។

កាលពីថ្ងៃទី ៨ ខែ១សីហា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ អ៊ុំ-ជិ នាមនាយ ឥន្ទជោតត្ថេរ អាយុ ៦០ ឆ្នាំ វស្សា ៩ ជាចៅអធិការវត្តអន្ទង់រមៀត ឃុំអន្ទង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

កាលពីថ្ងៃទី ២១ ខែ១សីហា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ សៅ-អែល នាមនាយ ឥន្ទសរោ អាយុ ២៨ ឆ្នាំ វស្សា ៨ ជាចៅអធិការ

វត្តចំបក់ចំខមាស ឃុំពុកសរ ស្រុកបាទី ខេត្តតាកែវ ។

កាលពីថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ហួ-ហួន នាមឆាយា បវរោ អាយុ ២៨ ឆ្នាំ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តចំបក់ចំខមាស ឃុំពុកសរ ស្រុកបាទី ខេត្តតាកែវ ។

កាលពីថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ស្រី ឆែម នាមឆាយា ធម្មចារោ អាយុ ២៩ ឆ្នាំ វស្សា ៩ ជាគ្រូសូត្រឆ្វេង វត្តចំបក់ចំខមាស ឃុំពុកសរ ស្រុកបាទី ខេត្តតាកែវ ។

កាលពីថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ស្ងួ-ច្រាក់ ឥន្ទវង្សោ អាយុ ៣៩ ឆ្នាំ វស្សា ២០ ជាចៅអធិការវត្តជម្ពូវង្សី ឃុំបឹងត្រាញ់ ស្រុកសំរោង ខេត្តតាកែវ ។

កាលពីថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ចាន់-ខាង នាមឆាយា ញាណប្បញ្ញោ អាយុ ៤៧ ឆ្នាំ វស្សា ២៦ ជាគ្រូសូត្រស្តាំ វត្តឈូងលៀប ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ។

កាលពីថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ជា វរ:-ឧុល នាមឆាយា វីរិយបណ្ឌិតោ អាយុ ៥៥ ឆ្នាំ វស្សា ៣៤ ជាចៅអធិការវត្តខ្នាប់រង្សី ឃុំប្រាសាទ ស្រុកត្រពាំងត្រែះ ខេត្តបាត់ដំបង ។

កាលពីថ្ងៃទី១១ខែកក្កដា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ខែម ឧ. ជិន នាមឆាយោ អគ្គបិត្តោ អាយុ ៤៣ ឆ្នាំ វស្សា ៣ ជាចៅអធិការវត្តត្រពាំងធំ ឃុំអង្គប្រស្រែ ស្រុកមោសហែក ខេត្តស្វាយរៀង ។

កាលពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ម៉ា-សាមុត នាមឆាយា ហនធម្មោ អាយុ ៦៤ ឆ្នាំ វស្សា ២ ជាគ្រូសូត្រស្តាំ វត្តត្រពាំងធំ ឃុំអង្គប្រស្រែ ស្រុកមោសហែក ខេត្តស្វាយរៀង ។

កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ញ៉ឹក-ជឹម នាមឆាយា កល្យាណធម្មោ អាយុ ៦១ ឆ្នាំ វស្សា ១ ជាគ្រូសូត្រឆ្វេង វត្តត្រពាំងធំ ឃុំអង្គប្រស្រែ ស្រុកមោសហែក ខេត្តស្វាយរៀង ។

កាលពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ១៩៦២ បានតាំងលោកគ្រូ ជាង-សន នាមឆាយា សុវណ្ណញ្ញាណោ អាយុ ៤០ ឆ្នាំ វស្សា ២០ ជាចៅអធិការវត្តក្រាំងតង្រ ឃុំកុមារកជា ស្រុកបាទី ខេត្តតាកែវ ។

កាលពីថ្ងៃទី១១ខែកក្កដាឆ្នាំ ១៩៦២ បានតាំងលោកគ្រូ អ៊ុង-ង៉ន នាមឆាយា ឥន្ទ្រវណ្ណោ អាយុ ៦២ ឆ្នាំ វស្សា ១ ជាគ្រូសូត្រស្តាំ វត្តក្រាំងតង្រ ឃុំកុមារកជា ស្រុកបាទី ខេត្តតាកែវ ។

កាលពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ១៩៦២ ជាន់តាំងលោកគ្រូ ហួយ ភ័ន់ឡៀ នាមឆាយា សុវណ្ណប្បញ្ញោ អាយុ ២២ ឆ្នាំ វស្សា ១ ជាគ្រូសូត្រធ្នើ វត្តក្រាំងពង្រ ឃុំកុមារភាព ស្រុកចាំទី ខេត្តតាកែវ ។

កាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៦២ ជាន់តាំងលោកគ្រូ លាស់-ឡេង នាមឆាយា ជោតំគ្រោ អាយុ ៤៩ ឆ្នាំ វស្សា ២៤ ជាចៅអធិការវត្តឫស្សីសាញ់ ឃុំឫស្សីសាញ់ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។

កាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៦២ ជាន តាំងលោកគ្រូ ង្វាត់-លៀម នាមឆាយា សង្ឃរ៉ាកេ អាយុ ២៩ ឆ្នាំ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តបវេល ឃុំបវេល ស្រុកមង្គលបុរី ខេត្តបាត់ដំបង ។

កាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៦២ ជាន់តាំងលោកគ្រូ ម៉ៅ-សោភ ឧ នាមឆាយា ថិប្បញ្ញោ អាយុ ២៦ ឆ្នាំ វស្សា ៥ ជាគ្រូសូត្រ-ធ្នើ វត្តបវេល ឃុំបវេល ស្រុកមង្គលបុរី ខេត្តបាត់ដំបង ។